

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រមព្រហ្មទណ្ឌ

ឆ្នាំ ២០២៣

រៀបរៀង និងចងក្រងដោយនាយកដ្ឋានរាជកិច្ច នៃ

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ



ព្រះរាជក្រម ឆ្នាំ២០២៣

ក

មាតិកា

១០-០៣-២០២៣	- ព្រះរាជក្រម នស/រកម/០៣២៣/០០១ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ	១
១១-០៣-២០២៣	- ព្រះរាជក្រម នស/រកម/០៣២៣/០០២ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត	៤៥
២២-០៤-២០២៣	- ព្រះរាជក្រម នស/រកម/០៤២៣/០០៣ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ	៦៨
១៦-០៥-២០២៣	- ព្រះរាជក្រម នស/រកម/០៥២៣/០០៤ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ	១៥០
១៦-០៥-២០២៣	- ព្រះរាជក្រម នស/រកម/០៥២៣/០០៥ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ	២៣៤
១៦-០៥-២០២៣	- ព្រះរាជក្រម នស/រកម/០៥២៣/០០៦ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មតាមព្រំដែន រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម	២៥៨
២៩-០៦-២០២៣	- ព្រះរាជក្រម នស/រកម/០៦២៣/០០៧ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីក្រមបរិស្ថាននិងធនធានធម្មជាតិ	២៨៣
២៩-០៦-២០២៣	- ព្រះរាជក្រម នស/រកម/០៦២៣/០០៨ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មអាស៊ាន	៥១៥
០១-០៧-២០២៣	- ព្រះរាជក្រម នស/រកម/០៧២៣/០០៩ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្តិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម	៥៧៩
០៤-០៧-២០២៣	- ព្រះរាជក្រម នស/រកម/០៧២៣/០១០ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះ-ឆ្នោត	៦៥១
០៥-០៧-២០២៣	-ព្រះរាជក្រម នស/រកម/០៧២៣/០១១ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានដើមកំណើតទំនិញ	៦៦០
០៨-០៧-២០២៣	-ព្រះរាជក្រម នស/រកម/០៧២៣/០១២ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ខ្មែរ អេឡិកទ្រី-ខល ផៅវ៉ែរ សម្រាប់គម្រោងអភិវឌ្ឍន៍វារីអគ្គិសនីស្ទឹងឫស្សីជ្រុំកណ្តាលអានុភាព ៧០ មេហ្គាវ៉ាត់ ផ្គួបជាមួយគម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងវាលថ្មកំបុត អានុភាព ១០០ មេហ្គាវ៉ាត់ ខេត្តកោះកុង	៦៧៤

០៨-០៧-២០២៣	- ព្រះរាជក្រម នស/រកម/០៧២៣/០១៣ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ឡាក់ឃី សូឡា ផៅវ៉ែរ ឯ.ក សម្រាប់គម្រោងអភិវឌ្ឍស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺ ព្រះអាទិត្យ អានុភាព ៨០ មេហ្គាវ៉ាត់ ខេត្តព្រៃវែង	៦៩១
០៨-០៧-២០២៣	- ព្រះរាជក្រម នស/រកម/០៧២៣/០១៤ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ស្នេថេក ខូ អិលធីឌី សម្រាប់គម្រោងអភិវឌ្ឍស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព ១៥០ មេហ្គាវ៉ាត់ ខេត្តពោធិ៍សាត់	៧០៨
០៨-០៧-២០២៣	- ព្រះរាជក្រម នស/រកម/០៧២៣/០១៥ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ស្នេថេក ខូ អិលធីឌី សម្រាប់គម្រោងអភិវឌ្ឍស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព ៦០ មេហ្គាវ៉ាត់ ខេត្តស្វាយរៀង	៧២៥
០៨-០៧-២០២៣	- ព្រះរាជក្រម នស/រកម/០៧២៣/០១៦ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ស្នេថេក ខូ អិលធីឌី សម្រាប់គម្រោងអភិវឌ្ឍស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព ៦០ មេហ្គាវ៉ាត់ ខេត្តកំពង់ឆ្នាំង	៧៤២
០៨-០៧-២០២៣	- ព្រះរាជក្រម នស/រកម/០៧២៣/០១៧ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ស្វឹង មេទឹក ហាយដ្រូផៅវ៉ែរ សម្រាប់គម្រោងអភិវឌ្ឍវារីអគ្គិសនីស្វឹងមេទឹក អានុភាព ១៥០ មេកាវ៉ាត់ ខេត្តកោះកុង	៧៥៩
០៥-១០-២០២៣	- ព្រះរាជក្រម នស/រកម/១០២៣/០១៨ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន	៧៧៦
០៥-១០-២០២៣	- ព្រះរាជក្រម នស/រកម/១០២៣/០១៩ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអធិការកិច្ច	៧៧៩
០២-១១-២០២៣	- ព្រះរាជក្រម នស/រកម/១១២៣/០២០ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល	៧៨២

ព្រះរាជក្រម

យើង

នស/រកម/០៣២៣/ ០០១

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាវជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជ្ជករាជរដ្ឋបូរណសន្តិ សុភមង្គល សិរីវិបុល
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ច្បាប់

ស្តីពី

ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ



ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

ច្បាប់នេះ កំណត់អំពីគោលការណ៍ជាមូលដ្ឋាន សម្រាប់ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងការរៀបចំច្បាប់ហិរញ្ញវត្ថុ ជាពិសេសជំហាននីមួយៗនៃដំណើរការរៀបចំ អនុម័ត និងអនុវត្តថវិកា និងការត្រួតពិនិត្យលទ្ធផលថវិកា ព្រមទាំងការកំណត់មុខងារនិងការទទួលខុសត្រូវរបស់តួអង្គពាក់ព័ន្ធ ឱ្យសម្រេចបាននូវភាពជឿទុកចិត្តថវិកា គណនេយ្យភាពហិរញ្ញវត្ថុ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងគណនេយ្យភាពសមិទ្ធកម្ម ក្នុងគោលបំណងដើម្បីធានាប្រសិទ្ធភាព ឥម្ភាភាព គណនេយ្យភាព និងចីរភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងការទ្រទ្រង់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច កំណើនសេដ្ឋកិច្ច និងសមធម៌សង្គម។

មាត្រា២ .-

ច្បាប់នេះ គឺជាច្បាប់គោលដែលកំណត់អំពីការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងមានវិសាលភាពអនុវត្តចំពោះក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិបុគ្គលដទៃទៀតដែលទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ ព្រមទាំងចំពោះទំនាក់ទំនងនិងអន្តរសកម្មរវាងហិរញ្ញវត្ថុសាធារណៈជាតិ ហិរញ្ញវត្ថុសាធារណៈអន្តរជាតិ ហិរញ្ញវត្ថុឯកជនជាតិ និងហិរញ្ញវត្ថុឯកជនអន្តរជាតិ។

មាត្រា៣ .-

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

ជំពូកទី២

គោលការណ៍គ្រឹះ ថវិកា និងរចនាសម្ព័ន្ធរបស់រដ្ឋ

ផ្នែកទី១

គោលការណ៍គ្រឹះ

មាត្រា៤ .-

ថវិកាត្រូវមានគោលការណ៍គ្រឹះ១០(ដប់)យ៉ាង ដែលត្រូវអនុវត្តដាច់ខាតគឺ៖

១- ភាពជាអាជ្ញា។

២- ភាពជឿទុកចិត្តបាន។

៣- ឯកត្តភាព។

៤- សកលភាព។

៥- វិសេសភាព។

៦- ចីរភាព។

៧- គណនេយ្យភាព។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៣

៨- ប្រសិទ្ធភាព។

៩- តម្លាភាព។

១០- សមិទ្ធកម្ម។

មាត្រា៥ .-

ច្បាប់ហិរញ្ញវត្ថុ រួមមាន៖

១- ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

២- ច្បាប់ហិរញ្ញវត្ថុកែតម្រូវ។

៣- ច្បាប់ទូទាត់ថវិកា។

មាត្រា៦ .-

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ គ្រោងនិងអនុញ្ញាតសម្រាប់ការិយបរិច្ឆេទមួយឆ្នាំ នូវប្រភពធនធាននិងបន្ទុករបស់រដ្ឋ អតិរេក ឬខ្វះខាត និងហិរញ្ញប្បទានផ្សេងៗ ដោយធានាតុល្យភាពថវិកា និងរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងអាចកំណត់នូវបទប្បញ្ញត្តិចាំបាច់ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីបម្រើឱ្យរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច។

មាត្រា៧ .-

ច្បាប់ហិរញ្ញវត្ថុកែតម្រូវ អនុញ្ញាតឱ្យធ្វើការកែប្រែបទប្បញ្ញត្តិនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ប្រសិនបើមានតម្រូវការចាំបាច់ ក្នុងការឆ្លើយតបទៅនឹងការផ្លាស់ប្តូរកាលៈទេសៈ មានជាអាទិ៍ គ្រោះមហន្តរាយ ការផ្លាស់ប្តូរជាគំហុកនៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ឬភាពចាំបាច់ជាបន្ទាន់ផ្សេងទៀតពាក់ព័ន្ធជាសារវន្តដល់ផលប្រយោជន៍ជាតិ ដែលមិនបានរំពឹងទុកនៅក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកា។

មាត្រា៨ .-

ច្បាប់ទូទាត់ថវិកា អនុម័តជារៀងរាល់ឆ្នាំ លើលទ្ធផលស្ថាពរនៃការអនុវត្តថវិកានិងហិរញ្ញវត្ថុដទៃទៀតរបស់រដ្ឋ ព្រមទាំងព័ត៌មានមិនមែនហិរញ្ញវត្ថុពាក់ព័ន្ធនៃការអនុវត្តច្បាប់ហិរញ្ញវត្ថុនៅក្នុងការិយបរិច្ឆេទនៃឆ្នាំមុន។

មាត្រា៩ .-

នាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាដល់ការអនុវត្តច្បាប់នេះនិងច្បាប់ដូចមានចែងក្នុងមាត្រា៥ខាងលើ ប្រកបដោយប្រសិទ្ធភាព។

មាត្រា១០ .-

ក្រៅពីបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់នេះ ការគ្រប់គ្រងហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាកម្មវត្ថុនៃច្បាប់ដោយឡែក។

មាត្រា១១ .-

ការិយបរិច្ឆេទនៃឆ្នាំថវិកាចាប់ផ្តើមនៅថ្ងៃទី១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា១២ .-

ទំនាក់ទំនងនិងអន្តរសកម្មរវាងហិរញ្ញវត្ថុសាធារណៈជាតិ ហិរញ្ញវត្ថុសាធារណៈអន្តរជាតិ ហិរញ្ញវត្ថុឯកជនជាតិ និងហិរញ្ញវត្ថុឯកជនអន្តរជាតិ សំដៅដល់ទំនាក់ទំនងដោយផ្ទាល់ឬដោយប្រយោល រវាងហិរញ្ញវត្ថុសាធារណៈជាតិ ហិរញ្ញវត្ថុសាធារណៈអន្តរជាតិ ហិរញ្ញវត្ថុឯកជនជាតិ និងហិរញ្ញវត្ថុឯកជនអន្តរជាតិ ដែលកើតឡើងតាមរយៈ ការគ្រប់គ្រងឬការអន្តរាគមន៍របស់រដ្ឋដោយផ្ទាល់ឬដោយប្រយោល ដើម្បីធានាចីរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ និងអភិវឌ្ឍសង្គម សេដ្ឋកិច្ច។

ទំនាក់ទំនងនិងអន្តរសកម្មទាំងនោះ មានជាអាទិ៍ ឧបករណ៍គោលនយោបាយពាក់ព័ន្ធហិរញ្ញវត្ថុ ប្រតិបត្តិការនៃការខ្ចីប្រាក់ពីគេឬការឱ្យប្រាក់គេខ្ចី ការធានារបស់រដ្ឋ ការវិនិយោគលើទ្រព្យសកម្មហិរញ្ញវត្ថុ ការវិនិយោគទុនរួមគ្នាទាំងក្នុងប្រទេសនិងក្រៅប្រទេស ការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទាំងទ្វេភាគីនិងពហុភាគី គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ការបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុ ការបង្កើតសហគ្រាសចម្រុះរដ្ឋនិងឯកជន វិភាគទានសមាជិកភាពចំពោះស្ថាប័នអន្តរជាតិឬអន្តររដ្ឋាភិបាល ការធ្វើសម្បទានផ្នែកសារពើពន្ធនិងមិនមែនសារពើពន្ធ ការប្រើប្រាស់មូលនិធិបម្រុងហិរញ្ញវត្ថុរបស់រដ្ឋ និងការអនុវត្តកម្មវិធីពិសេសរបស់រាជរដ្ឋាភិបាល ដើម្បីធ្វើអន្តរាគមន៍ដោះស្រាយបញ្ហាវិបត្តិសេដ្ឋកិច្ចនិងសង្គម។

ទំនាក់ទំនងនិងអន្តរសកម្មដែលមានចែងខាងលើ ត្រូវគ្រប់គ្រងដោយបទប្បញ្ញត្តិនៃច្បាប់នេះ ព្រមទាំងបទប្បញ្ញត្តិច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាធរមាន។

មាត្រា១៣ .-

ការគ្រប់គ្រង ការរៀបចំ ការអនុវត្ត ការតាមដាន ការត្រួតពិនិត្យលើការអនុវត្តចំណូលនិងចំណាយថវិការដ្ឋ និងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យនៃថវិការដ្ឋ ព្រមទាំងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវប្រើប្រាស់និងឆ្លុះបញ្ចាំងក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតែមួយគត់។ វិធាននិងនីតិវិធីរួមក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចធ្វើឯកសារផ្ទៃវការឬមិនទាន់ផ្ទៃវការ មានជាអាទិ៍ សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនិងសំណុំឯកសារភ្ជាប់ ព្រមទាំងសេចក្តីព្រាងច្បាប់ទូទាត់ថវិកានិងសំណុំឯកសារភ្ជាប់ ជាទម្រង់លាយលក្ខណ៍អក្សរយ៉ាងច្រើនចំនួន៥(ប្រាំ)ច្បាប់ ក្រៅពីនេះ ជាទម្រង់ឱជីថលជូនទីស្តីការគណៈរដ្ឋមន្ត្រីសម្រាប់កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រសួង ស្ថាប័នពាក់ព័ន្ធ និងស្ថាប័ននីតិប្បញ្ញត្តិ។

មាត្រា១៤ .-

មន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈនៃក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានភារកិច្ចអនុវត្តការងារហិរញ្ញវត្ថុសាធារណៈ ត្រូវមានគុណវុឌ្ឍិវិជ្ជាជីវៈតាមប្រភេទមុខតំណែងការងារនីមួយៗ។ គុណវុឌ្ឍិវិជ្ជាជីវៈតាមប្រភេទមុខតំណែងការងារនីមួយៗនេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ផ្នែកទី២

ថវិកា

មាត្រា១៥ .-

ថវិកា សំដៅដល់ផែនការហិរញ្ញវត្ថុរបស់រដ្ឋ ដែលត្រូវបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ រួមមាន ការគ្រោងចំណូលនិងចំណាយ ការខ្ចី និងការធ្វើហិរញ្ញប្បទានបំពេញតុល្យភាពថវិកា ដើម្បីសម្រេចសមិទ្ធកម្មដែលបានគ្រោងទុក។

ចំណូលទាំងអស់ ត្រូវវិភាជសម្រាប់រាល់មុខសញ្ញាចំណាយទាំងអស់។

ថវិកាដែលត្រូវបានអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ជាមូលដ្ឋានក្នុងការបញ្ជាចំណាយ។

ចំណូលនិងចំណាយទាំងអស់ ត្រូវកត់ត្រាក្នុងគណនីទោលរតនាគារ។

មាត្រា១៦ .-

ថវិកាជាតិឬថវិការដ្ឋ រួមមាន ថវិកាថ្នាក់ជាតិ ថវិកាថ្នាក់ក្រោមជាតិ ឬថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ថវិកាឧបសម្ព័ន្ធ និងគណនីពិសេសរតនាគារ។

មាត្រា១៧ .-

ថវិកាថ្នាក់ជាតិ សំដៅដល់ថវិការបស់ក្រសួង ស្ថាប័ន ដែលរួមមាន ថវិការដ្ឋបាលកណ្តាល ថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល និងថវិកាមន្ទីរជំនាញក្រោមឱវាទ ព្រមទាំងថវិកាអង្គភាពសាធារណៈប្រហាក់ប្រហែល។

ថវិកាថ្នាក់ជាតិ ត្រូវគ្រោង អនុញ្ញាត និងអនុវត្ត តាមវិធាននិងនីតិវិធីដូចមានកំណត់ក្នុងច្បាប់នេះ។

មាត្រា១៨ .-

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅដល់ថវិការដ្ឋបាលរាជធានី ខេត្ត ថវិការដ្ឋបាលក្រុង ស្រុក និងថវិការដ្ឋបាលឃុំ ព្រមទាំងថវិការដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធផ្សេងទៀត ស្របតាមបទប្បញ្ញត្តិជាធរមាន។

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវគ្រោង អនុញ្ញាត និងអនុវត្ត តាមវិធាននិងនីតិវិធីដូចមានកំណត់ក្នុងច្បាប់នេះ និងច្បាប់ពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា១៩ .-

ថវិកាឧបសម្ព័ន្ធនៅថ្នាក់ជាតិ អនុវត្តចំពោះអង្គភាពរដ្ឋមិនមានបុគ្គលភាពគតិយុត្ត ដែលធ្វើប្រតិបត្តិការមានលក្ខណៈឧស្សាហកម្មនិងពាណិជ្ជកម្មជាចម្បង ដោយអនុញ្ញាតឱ្យមានចំណូលដោយឡែកសម្រាប់ចំណាយជាក់លាក់។ ថវិកាឧបសម្ព័ន្ធត្រូវបង្កើតនិងលុបដោយច្បាប់ហិរញ្ញវត្ថុ។ កិច្ចប្រតិបត្តិការនៃថវិកាឧបសម្ព័ន្ធត្រូវគ្រោង អនុញ្ញាត និងអនុវត្ត ក្នុងលក្ខខណ្ឌដូចគ្នាទៅនឹងកិច្ចប្រតិបត្តិការនៃថវិកាថ្នាក់ជាតិដែរ។ ការបង្វែរឥណទានថវិការវាងថវិកាឧបសម្ព័ន្ធនិងប្រភេទថវិកាដទៃទៀត មិនត្រូវអនុញ្ញាតឡើយ។ វិធាននិងនីតិវិធីនៃការគ្រប់គ្រងថវិកាឧបសម្ព័ន្ធត្រូវកំណត់ដោយអនុក្រឹត្យ។

ថវិកាឧបសម្ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិ អនុវត្តចំពោះអង្គភាពរដ្ឋមិនមានបុគ្គលភាពគតិយុត្ត ដែលធ្វើប្រតិបត្តិការសេវាសាធារណៈមានលក្ខណៈឧស្សាហកម្ម ពាណិជ្ជកម្ម និងរដ្ឋបាល ដោយអនុញ្ញាតឱ្យមានចំណូលដោយឡែកសម្រាប់ចំណាយជាក់លាក់។ ថវិកាឧបសម្ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបង្កើតនិងលុបដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ កិច្ចប្រតិបត្តិការនៃថវិកាឧបសម្ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវគ្រោង អនុញ្ញាត និងអនុវត្ត ក្នុងលក្ខខណ្ឌដូចគ្នាទៅនឹងកិច្ចប្រតិបត្តិការនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិដែរ។ ការបង្វែរ

ឥណទានថវិការវាងថវិកាឧបសម្ព័ន្ធ និងប្រភេទថវិកាផ្សេងទៀតនៅរដ្ឋបាលថ្នាក់ក្រោមជាតិ មិនត្រូវអនុញ្ញាតឡើយ។ វិធាននិងនីតិវិធីនៃការគ្រប់គ្រងថវិកាឧបសម្ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា២០ .-

គណនីពិសេសរតនាគារ អនុវត្តចំពោះអង្គភាពរដ្ឋមិនមានបុគ្គលភាពគតិយុត្តដែលធ្វើប្រតិបត្តិការមានលក្ខណៈរដ្ឋបាលជាចម្បង សម្រាប់បម្រើដល់ការអនុវត្តគោលនយោបាយឬការបំពេញបេសកកម្មជាក់លាក់ណាមួយរបស់រាជរដ្ឋាភិបាល ដោយអនុញ្ញាតឱ្យមានចំណូលដោយឡែកសម្រាប់ចំណាយជាក់លាក់។ គណនីពិសេសរតនាគារត្រូវបង្កើតនិងលុបដោយច្បាប់ហិរញ្ញវត្ថុ។

កិច្ចប្រតិបត្តិការនៃគណនីពិសេសរតនាគារ ត្រូវគ្រោង អនុញ្ញាត និងអនុវត្ត ក្នុងលក្ខខណ្ឌដូចគ្នាទៅនឹងកិច្ចប្រតិបត្តិការនៃថវិកាថ្នាក់ជាតិដែរ។ ការបង្វែរឥណទានថវិការវាងគណនីពិសេសរតនាគារនិងប្រភេទថវិកាផ្សេងទៀតមិនត្រូវអនុញ្ញាតឡើយ។

វិធាននិងនីតិវិធីនៃការគ្រប់គ្រងគណនីពិសេសរតនាគារត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា២១ .-

គ្រឹះស្ថានសាធារណៈរដ្ឋបាល ជានីតិបុគ្គលនៃនីតិសាធារណៈដែលមានថវិកាស្វយ័ត។

ថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំស្របតាមគោលចំណងគោលនយោបាយ និងកម្មវិធីដែលកំណត់ដោយក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវឆ្លុះបញ្ចាំងជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវជាអាណាព្យាបាលបច្ចេកទេស។

ប្រភពធនធានជាប្រចាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល រួមមាន ចំណូលផ្ទាល់ និងជាយថាហេតុមានការឧបត្ថម្ភគុណូបការដោយថវិការដ្ឋ និងចំណូលផ្សេងៗ។

គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវមានគណនេយ្យភាពចំពោះក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិសាមីដែលជាអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជាអាណាព្យាបាលហិរញ្ញវត្ថុ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

កិច្ចប្រតិបត្តិការថវិកានៃគ្រឹះស្ថានសាធារណៈរដ្ឋបាលនៅថ្នាក់ជាតិ ត្រូវគ្រោង អនុញ្ញាត និងអនុវត្តជាទូទៅក្នុងលំនាំដូចគ្នាទៅនឹងកិច្ចប្រតិបត្តិការនៃថវិកាថ្នាក់ជាតិដែរ។ កិច្ចប្រតិបត្តិការថវិកានៃគ្រឹះស្ថានសាធារណៈរដ្ឋបាលនៅថ្នាក់ក្រោមជាតិ ត្រូវគ្រោង អនុញ្ញាត និងអនុវត្តជាទូទៅក្នុងលំនាំដូចគ្នាទៅនឹងកិច្ចប្រតិបត្តិការនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិដែរ។

វិធាននិងនីតិវិធីនៃការគ្រោងចំណូល ចំណាយ ការអនុញ្ញាត និងការអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា២២ .-

ចំណាត់ថ្នាក់នៃមាតិកាថវិការដ្ឋ រួមមាន ចំណាត់ថ្នាក់សេដ្ឋកិច្ច ចំណាត់ថ្នាក់កម្មវិធី ចំណាត់ថ្នាក់រដ្ឋបាល ចំណាត់ថ្នាក់ភូមិសាស្ត្រ ចំណាត់ថ្នាក់មុខងារ ចំណាត់ថ្នាក់គម្រោង និងចំណាត់ថ្នាក់មូលនិធិ។

វិធានលម្អិតនិងការអនុវត្តចំណាត់ថ្នាក់នៃមាតិកាថវិកាខាងលើ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ផ្នែកទី៣

ធនធានឥណទានរបស់រដ្ឋ

មាត្រា២៣ .-

ធនធាននិងបន្ទុករបស់រដ្ឋ រួមមាន ធនធាននិងបន្ទុកថវិកា និងធនធាននិងបន្ទុកហិរញ្ញប្បទាន។

ធនធាននិងបន្ទុកថវិកា ត្រូវបង្ហាញនៅក្នុងថវិការដ្ឋជាទម្រង់ចំណូលនិងចំណាយ។

ធនធាននិងបន្ទុកហិរញ្ញប្បទាន ត្រូវបង្ហាញក្នុងទម្រង់ជាតម្រូវការហិរញ្ញប្បទាននិងប្រភពហិរញ្ញប្បទាន។

មាត្រា២៤ .-

ធនធានថវិកា រួមមាន ដូចខាងក្រោម៖

១-ចំណូលសារពើពន្ធ រួមមាន ចំណូលសារពើពន្ធក្នុងស្រុក ចំណូលសារពើពន្ធលើពាណិជ្ជកម្មអន្តរជាតិ និងចំណូលសារពើពន្ធផ្សេងទៀត។

២-ចំណូលមិនមែនសារពើពន្ធ រួមមាន ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ចំណូលពីសហគ្រាសសាធារណៈ ភាគកម្មសាធារណៈនិងអង្គភាពស្វ័យភាពហិរញ្ញវត្ថុផ្សេងទៀត ចំណូលពីសេវាសាធារណៈ ចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្ម និងចំណូលមិនមែនសារពើពន្ធផ្សេងទៀត ដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៣-ចំណូលផ្សេងៗ រួមបញ្ចូលទាំងចំណូលបានមកពីទ្រព្យសកម្មហិរញ្ញវត្ថុរយៈពេលវែង ហិរញ្ញប្បទានឥតសំណង ការសងវិញនូវប្រាក់ឱ្យគេខ្ចី និងចំណូលផ្សេងៗផ្សេងទៀត។

ធនធាននីមួយៗ ត្រូវធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនី និងជាយថាហេតុ អាចលម្អិតជាងនេះទៀតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា២៥ .-

ការបង្កើត ការកែប្រែ ការលុបចោល ការយក ការកំណត់អត្រា ការកំណត់មូលដ្ឋានគិត ការលើកលែង និងការធ្វើសម្បទានពន្ធនិងអាករ ព្រមទាំងវិធាននៃការដោះស្រាយវិវាទសារពើពន្ធត្រូវកំណត់ក្នុងច្បាប់។

គ្មានបទប្បញ្ញត្តិច្បាប់ឬក្រមច្បាប់ណាមួយ ទោះជាប្រភេទណាក៏ដោយ និងគ្មានកិច្ចព្រមព្រៀងអន្តរជាតិណាមួយ ដែលអាចធ្វើឱ្យមានការប្រែប្រួលនាំមកនូវការបាត់ចំណូលសារពើពន្ធនោះឡើយ។ ករណីខាងលើអាចប្រព្រឹត្តទៅបាន លុះត្រាតែអនុវត្តតាមទម្រង់ច្បាប់ជាធរមាន ក្រោយពីមានយោបល់ឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការប្រមូលនិងការត្រួតពិនិត្យចំណូលសារពើពន្ធ ត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា២៦ .-

ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រូវកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។ ការប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវបង់ចំណូលមិនមែនសារពើពន្ធទាំងអស់ចូលក្នុងគណនីទោលរតនាគារ ដោយមិនត្រូវប្រើប្រាស់ចំណែកណាមួយនៃប្រាក់ចំណូលយកទៅកាត់កងដោយត្រង់ជាមួយនឹងចំណាយឬរក្សាទុកសម្រាប់ចំណាយពិសេសណាមួយឡើយ លើកលែងតែមានគោលការណ៍អនុញ្ញាតដោយរាជរដ្ឋាភិបាល តាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា២៧ .-

ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ សំដៅដល់ចំណូលទទួលបានពីការចាត់ចែង ការធ្វើអាជីវកម្ម ផលបានពីសម្បទានលើទ្រព្យសម្បត្តិរដ្ឋ និងចំណូលពីទ្រព្យសម្បត្តិរដ្ឋផ្សេងទៀត ដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ត្រូវអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ។ ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិបុគ្គលសាធារណៈដទៃទៀត ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ។

មាត្រា២៨ .-

ចំណូលពីសហគ្រាសសាធារណៈ ភាគកម្មសាធារណៈ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត រួមមានចំណូលដែលទទួលបានពីការបង់ភាគលាភឬអតិរេកថវិកា ភាគលើសនៃទុនទំនេរ ព្រមទាំងការបង់សាច់ប្រាក់និងសមមូលសាច់ប្រាក់ ក្រោយពីសហគ្រាសឬអង្គភាពត្រូវបានរំសាយ។ ការបង់ចំណូលចូលថវិកាជាតិរបស់សហគ្រាសសាធារណៈ ភាគកម្មសាធារណៈ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ត្រូវកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិសម្រេចក្នុងការកំណត់ឱ្យសហគ្រាសសាធារណៈនិងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ធ្វើការបង់មួយចំណែកឬទាំងអស់នូវភាគលើសនៃទុនទំនេរ ចូលថវិកាជាតិ ក្នុងករណីពិនិត្យឃើញថាសហគ្រាសសាធារណៈឬអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ពុំមានតម្រូវការចាំបាច់ក្នុងការវិនិយោគឬធ្វើការអភិវឌ្ឍសហគ្រាសសាធារណៈ ឬអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀតនោះទេ។

មាត្រា២៩ .-

ចំណូលពីសេវាសាធារណៈ សំដៅដល់ចំណូលដែលប្រមូលបានពីការបង់កម្រៃនៃការប្រើប្រាស់សេវាសាធារណៈ ដោយចំនួបុគ្គលឬនីតិបុគ្គល សម្រាប់សេវាបង់ថ្លៃរបស់រដ្ឋ។ ការផ្តល់សេវាសាធារណៈនិងការប្រមូលចំណូលពី

សេវាសាធារណៈ ត្រូវអនុវត្តដោយក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្នុងគោលដៅបម្រើផលប្រយោជន៍ទូទៅ។ ក្រោមការអនុញ្ញាតរបស់រាជរដ្ឋាភិបាល សេវាសាធារណៈអាចត្រូវបានផ្តល់ដោយភាគីឯកជន តាមរយៈកិច្ចសន្យាដែលធ្វើឡើងរវាងភាគីឯកជននិងក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល ឬរវាងភាគីឯកជន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ឬរវាងភាគីឯកជន និងគ្រឹះស្ថានសាធារណៈរដ្ឋបាល។ កិច្ចសន្យានេះ ត្រូវមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬអង្គភាពដែលទទួលប្រតិភូកម្មពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមបទប្បញ្ញត្តិជាធរមាន។

កម្រៃសេវាសាធារណៈ ជាកម្មវត្ថុដែលត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមី។

មាត្រា៣០ .-

លិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ មានជាអាទិ៍ កិច្ចសន្យា កិច្ចព្រមព្រៀងនិង/ឬលិខិតគតិយុត្តពាក់ព័ន្ធផ្សេងទៀត ត្រូវស្ថិតក្រោមការត្រួតពិនិត្យនិងទទួលបានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមបទប្បញ្ញត្តិជាធរមាន បើពុំនោះសោត ត្រូវចាត់ទុកជាមោឃៈ។

មាត្រា៣១ .-

ចំណូលផ្សេងៗ ដូចមានរៀបរាប់ក្នុងចំណុច៣នៃមាត្រា២៤ ដោយពុំរួមបញ្ចូលចំណូលទាំងឡាយដែលស្ថិតក្នុងប្រភេទចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធខាងលើ ត្រូវគ្រប់គ្រងនិងអនុវត្តក្រោមការកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

មាត្រា៣២ .-

បន្ទុកថវិការបស់រដ្ឋ រួមមាន ចំណាយចរន្តនិងចំណាយមូលធន ដែលត្រូវបានបែងចែកជា៦ប្រភេទ ដូចខាងក្រោម៖

១-បន្ទុកបុគ្គលិក រួមមាន ចំណាយលើបៀវត្ស ប្រាក់បំណាច់និងប្រាក់ឧបត្ថម្ភផ្សេងៗ ប្រាក់វិភាជន៍សង្គម វិភាគទានសង្គម និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ។

២-ចំណាយប្រតិបត្តិការ រួមមាន ចំណាយលើការទិញទំនិញ ការជួសជុលថែទាំ និងការជួលសេវា ដើម្បីទទួលបាននូវមធ្យោបាយនិងសេវាផ្សេងៗ បម្រើឱ្យសកម្មភាពរបស់រដ្ឋ។

៣-បន្ទុកហិរញ្ញវត្ថុ រួមមាន ចំណាយលើការប្រាក់ និងបន្ទុកពាក់ព័ន្ធផ្សេងៗនៃបំណុលសាធារណៈក្នុងប្រទេសនិងក្រៅប្រទេស។

៤-ចំណាយវិនិយោគ រួមមាន ចំណាយលើការទទួលបាននូវទ្រព្យសកម្មរយៈពេលវែងទាំងរូបី និងអរូបី ព្រមទាំងទ្រព្យសកម្មហិរញ្ញវត្ថុរយៈពេលវែង។

៥-ការផ្ទេរ៖

ចំណាយអន្តរភាគមន៍ រួមមាន ចំណាយលើការផ្តល់អត្ថប្រយោជន៍សង្គម ចំណាយអន្តរភាគមន៍ផ្នែកសង្គមកិច្ច និងវប្បធម៌

- ចំណាយឧបត្ថម្ភធន ដោយមានភ្ជាប់លក្ខខណ្ឌនិងគ្មានភ្ជាប់លក្ខខណ្ឌទៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- ចំណាយឧបត្ថម្ភធនទៅគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ចំណាយឧបត្ថម្ភធនទៅសហគ្រាសសាធារណៈ
- ការផ្តល់អំណោយ
- ចំណាយឧបត្ថម្ភធនផ្សេងៗ។

៦-ចំណាយផ្សេងៗ រួមមាន ចំណាយលើពន្ធនិងអាករដែលបង់ដោយរដ្ឋ ចំណាយមិនទាន់បែងចែកមានមុខសញ្ញា ចំណាយមិនបានគ្រោងទុក និងចំណាយដទៃទៀត។

ប្រភេទចំណាយនីមួយៗ ត្រូវធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនី ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៣៣ .-

ធនធាននិងបន្ទុកហិរញ្ញប្បទានរបស់រដ្ឋ ដែលជួយធានាបាននូវតុល្យភាពហិរញ្ញវត្ថុរបស់រដ្ឋ គឺជាលទ្ធផលនៃកិច្ចប្រតិបត្តិការ ដូចខាងក្រោម៖

១-ចលនាប្រាក់ទំនេររបស់រដ្ឋ។

២-ការគ្រប់គ្រងប្រាក់បញ្ញើរបស់និក្ខិត្តករ។

៣-ការខ្ចីប្រាក់ បំណុលប្រហាក់ប្រហែល និងហិរញ្ញប្បទានសហប្រតិបត្តិការ។

៤-ប្រតិបត្តិការសាច់ប្រាក់ផ្សេងទៀត។

មាត្រា៣៤ .-

កិច្ចប្រតិបត្តិការ ដែលមានចែងក្នុងមាត្រា៣៣នៃច្បាប់នេះ ត្រូវតោរពទៅតាមគោលការណ៍គ្រឹះមួយចំនួនដូចខាងក្រោម៖

១-ការវិនិយោគប្រាក់ទំនេររបស់រដ្ឋ ត្រូវអនុវត្តទៅតាមការអនុញ្ញាតជាប្រចាំឆ្នាំជាទូទៅឬការអនុញ្ញាតពិសេសណាមួយ ដែលកំណត់ដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

២-គណនីប្រាក់បញ្ញើរបស់និក្ខិត្តករមិនត្រូវមានវិបារូបន៍។

៣-ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែលត្រូវដាក់ចូលក្នុងគណនីនៅរតនាគារជាតិជាចាំបាច់ លើកលែងតែមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៤-ការខ្ចីប្រាក់ បំណុលប្រហាក់ប្រហែល និងហិរញ្ញប្បទានសហប្រតិបត្តិការ ត្រូវអនុវត្តស្របតាមការអនុញ្ញាតប្រចាំឆ្នាំជាទូទៅ ឬការអនុញ្ញាតពិសេសណាមួយ ដែលកំណត់ដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

ក្រៅពីប្រភពធនធាននិងបន្ទុកហិរញ្ញប្បទានដែលត្រូវគ្រប់គ្រងតាមបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធជាធរមាន វិធាននិងនីតិវិធីនៃការគ្រប់គ្រងធនធាននិងបន្ទុកហិរញ្ញប្បទានឯទៀតដែលមានចែងខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៣៥ .-

ប្រភពនៃមូលនិធិប្រមូលហិរញ្ញវត្ថុ គឺជាមូលនិធិប្រាក់សន្សំរបស់រដ្ឋ។ ប្រភពនៃមូលនិធិបម្រុងហិរញ្ញវត្ថុនេះ រួមមាន៖

- ចំណេញប្រចាំឆ្នាំនៃថវិកាថ្នាក់ជាតិ ក្នុងទំហំពី២(ពីរ)ភាគរយ ទៅ៤(បួន)ភាគរយនៃលទ្ធផលអនុវត្ត
- ចំណេញចរន្តថវិកាថ្នាក់ជាតិមួយឆ្នាំមុនឆ្នាំកំពុងអនុវត្តថវិកា ដែលត្រូវកំណត់នៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ១១

- អតិរេកដែលអាចកើតមានពីការអនុវត្តថវិកាថ្នាក់ជាតិប្រចាំឆ្នាំ ដែលត្រូវកំណត់ដោយច្បាប់ទូទាត់ថវិកា
- ប្រភពផ្សេងៗទៀត ដែលត្រូវកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុ។

មូលនិធិបម្រុងហិរញ្ញវត្ថុ ត្រូវបានសន្សំទុកសម្រាប់គោលដៅនៃការធ្វើអន្តរាគមន៍ដោះស្រាយបញ្ហាដែលមានសារៈសំខាន់ជាសារវន្ត នៅពេលដែលប្រទេសជាតិប្រឈមមុខនឹងវិបត្តិសេដ្ឋកិច្ច ហិរញ្ញវត្ថុ ឬគ្រោះអាសន្នបន្ទាន់នានា ជាអាទិ៍ ការឆ្លងរាលដាលនៃជំងឺកាចសាហាវនិងគ្រោះមហន្តរាយធម្មជាតិ។

មូលនិធិបម្រុងហិរញ្ញវត្ថុ អាចយកទៅវិនិយោគរយៈពេលខ្លី មធ្យម និងវែង។

មូលនិធិបម្រុងហិរញ្ញវត្ថុ ត្រូវកត់ត្រាក្នុងគណនីទោលរតនាគារ។ សមតុល្យនៃមូលនិធិបម្រុងហិរញ្ញវត្ថុ ត្រូវបានយោងបន្តពីមួយឆ្នាំទៅមួយឆ្នាំ។

ការប្រើប្រាស់មូលនិធិបម្រុងហិរញ្ញវត្ថុ ជាកម្មវត្ថុនៃការអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ។ មូលនិធិបម្រុងហិរញ្ញវត្ថុ ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងនិងការចាត់ចែងមូលនិធិបម្រុងហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរាយការណ៍ជូនរដ្ឋសភានិងព្រឹទ្ធសភាជារៀងរាល់ឆ្នាំអំពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងមូលនិធិបម្រុងហិរញ្ញវត្ថុ។

វិធាននិងនីតិវិធីនៃការគ្រប់គ្រងមូលនិធិបម្រុងហិរញ្ញវត្ថុ ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៣៦ .-

ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ធ្វើការប៉ាន់ស្មានពីធនធាននិងបន្ទុកថវិការបស់រដ្ឋ កំណត់ជិហរគោលនយោបាយថវិកា កំណត់ពិតានចំណាយថវិកាថ្នាក់ជាតិនិងពិតានចំណាយថវិកាថ្នាក់ក្រោមជាតិ ព្រមទាំងកំណត់ពិតានតម្រូវការហិរញ្ញប្បទាន និងវាយតម្លៃហានិភ័យហិរញ្ញវត្ថុសាធារណៈ សម្រាប់រយៈពេលមធ្យម ដោយផ្អែកលើមូលដ្ឋាននៃទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច និងអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីធានាបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈ។

ក្របខ័ណ្ឌថវិការយៈពេលមធ្យម កំណត់ពិតានចំណាយថវិការបស់ក្រសួង ស្ថាប័ន ដោយផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់ក្រសួង ស្ថាប័ន និងមានសង្គតិភាពទៅនឹងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម។

ក្របខ័ណ្ឌថវិការយៈពេលមធ្យមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ កំណត់ពិតានចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ដោយផ្អែកតាមក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម។

ក្របខ័ណ្ឌថវិការយៈពេលមធ្យមទាំងពីរខាងលើ ត្រូវប្រើជាមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដើម្បីសម្រេចសមិទ្ធកម្មដែលបានគ្រោងទុក។

មាត្រា៣៧ .-

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវវិភាជឥណទានថវិកាទៅតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែលតាមប្រភេទចំណាយ ព្រមទាំងឆ្លុះបញ្ចាំងឱ្យឃើញនូវថវិកាឧបសម្ព័ន្ធនៅថ្នាក់ជាតិ គណនីពិសេសរតនាគារ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនៅថ្នាក់ជាតិ។

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវវិភាជឥណទានថវិកាដល់រដ្ឋបាលរាជធានី ខេត្ត តាមកម្មវិធី និងប្រភេទចំណាយ និងឥណទានថវិកាជាកញ្ចប់ដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ព្រមទាំងឆ្លុះបញ្ចាំងឱ្យឃើញពីថវិកាឧបសម្ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា៣៨ .-

ឥណទានថវិកាដែលបានអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុ ត្រូវបែងចែកជូនក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល តាមកម្មវិធី និងប្រភេទចំណាយ ដើម្បីរួមចំណែកសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល និងគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាល។

ការបែងចែកឥណទានថវិកាជូនក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល កម្រិតកម្មវិធី និងកម្រិតជំពូកនៃចំណាត់ថ្នាក់មាតិកាថវិកា ត្រូវកំណត់ដោយអនុក្រឹត្យ។

ការបែងចែកឥណទានថវិកាលម្អិតតាមអនុកម្មវិធីនិងចង្កោមសកម្មភាព និងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញប្រកាសដាក់ឱ្យប្រើប្រាស់សៀវភៅថវិកាស្តីពីការបែងចែកឥណទានថវិកាក្រោមកម្រិតកម្មវិធី និងក្រោមកម្រិតជំពូកនៃចំណាត់ថ្នាក់មាតិកាថវិកា ឱ្យបានមុនថ្ងៃទី១ ខែមករានៃឆ្នាំអនុវត្តថវិកា។

ចំណាយមិនទាន់បែងចែកមានមុខសញ្ញា ដែលមានចែងក្នុងចំណុចទី៦នៃមាត្រា៣២នៃច្បាប់នេះ គឺជាមុខចំណាយដែលមានការកំណត់ច្បាស់លាស់ដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយជាកម្មវត្ថុនៃការផ្ទេរដោយអនុក្រឹត្យទៅតាមគោលដៅនៃមុខចំណាយ នៅពេលដែលឥណទានថវិកានោះត្រូវបានអនុម័ត។

ចំណាយមិនបានគ្រោងទុក ដែលមានចែងក្នុងចំណុចទី៦នៃមាត្រា៣២នៃច្បាប់នេះ មិនត្រូវបែងចែកឱ្យទៅក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិឡើយ។ ឥណទានថវិកានៃចំណាយមិនបានគ្រោងទុក ត្រូវបានអនុញ្ញាតសម្រាប់ចំណាយទាំងឡាយណាដែលមិនទាន់អាចកំណត់ជាក់លាក់ជាមុនបាន មានជាអាទិ៍ ភាពបន្ទាន់ឬចំណាយដែលពាក់ព័ន្ធនឹងគ្រោះអាសន្ននិងព្រឹត្តិការណ៍ផ្សេងៗដែលកើតឡើងជាយថាហេតុ សម្រាប់វិភាជឡើងវិញទៅក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ នៅពេលដែលឥណទានថវិកានោះត្រូវបានអនុម័ត។

មាត្រា៣៩ .-

ឥណទានថវិកាមានពីរប្រភេទ គឺឥណទានកំហិតកំណត់ និងឥណទានប៉ាន់ប្រមាណ។

ឥណទានកំហិតកំណត់ គឺត្រូវបានផ្តល់ជាការសន្យានិងការអនុញ្ញាតត្រឹមកម្រិតខ្ពស់បំផុតមួយ ដែលចំណាយប្រភេទនេះត្រូវបានកំណត់ជាមុន។ ចំណាយបែបនេះអាចបង្កើនបានតែតាមរយៈច្បាប់ហិរញ្ញវត្ថុកែតម្រូវតែមួយប៉ុណ្ណោះ។

ឥណទានប៉ាន់ប្រហាណ គឺត្រូវបានអនុញ្ញាតសម្រាប់ចំណាយចាំបាច់ និងក្នុងករណីដែលការគ្រោងមិនគ្រប់គ្រាន់នៅពេលដែលកាលបន្ទាប់ពីការអនុម័តថវិកា។ ចំណាយនៃឥណទានប្រភេទនេះ អាចត្រូវបានប្រើប្រាស់លើសពីកម្រិតដែលបានគ្រោងនៅក្នុងកម្មវិធីនិងជំពូកថវិកាពាក់ព័ន្ធ។ ឥណទានប្រភេទនេះ កើតមានលើបំណុល

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ១៣

សាធារណៈ វិភាគទានសមាជិកភាពចំពោះស្ថាប័នអន្តរជាតិឬអន្តររដ្ឋាភិបាល អន្តរាគមន៍គាំពារសង្គម និងចំណាយផ្សេងទៀតដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ឥណទានបៀវត្សនិងប្រាក់បំណាច់របស់បុគ្គលិក អាចអនុញ្ញាតឱ្យមានកម្រិតលម្អៀងលើការគ្រោងក្នុងរង្វង់នៃចំនួនបុគ្គលិកតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានកំណត់នៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។ ការបង្កើនឥណទានបៀវត្សនិងប្រាក់បំណាច់របស់បុគ្គលិក ដោយសារការកើនឡើងនៃចំនួនបុគ្គលិកនៅក្នុងឆ្នាំអនុវត្តថវិកា មិនត្រូវបានអនុញ្ញាតទេ។ ពិតានចំនួនបុគ្គលិកតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។ ក្នុងករណីមានតម្រូវការពិសេស ចាំបាច់ និងបន្ទាន់ រាជរដ្ឋាភិបាលអាចបង្កើនពិតានចំនួនបុគ្គលិក ព្រមទាំងបង្កើនឥណទានបៀវត្សនិងប្រាក់បំណាច់របស់បុគ្គលិក ស្របទៅនឹងការបង្កើនចំនួនបុគ្គលិក ដែលការបង្កើននេះ ជាកម្មវត្ថុនៃការអនុម័តដោយច្បាប់ទូទាត់ថវិកានៃឆ្នាំអនុវត្តថវិកា។

មាត្រា៤០ .-

ឥណទានចំណាយចរន្ត ត្រូវបែងចែកជាឥណទានសម្រាប់ការអនុវត្តកម្មវិធីដែលបានអនុម័ត និងឥណទានសម្រាប់អនុវត្តវិធានការថ្មីនៃកម្មវិធីនោះ។

ឥណទានសម្រាប់ការអនុវត្តកម្មវិធីដែលបានអនុម័ត រួមមាន ឥណទានដែលបានកំណត់នៅក្នុងចំណាយប្រតិបត្តិការឆ្នាំមុន ដកទាយជ្ជទាន និងដកឥណទានសម្រាប់សកម្មភាពការងារដែលនឹងមិនកើតឡើងវិញនៅក្នុងឆ្នាំគ្រោងថវិកា បូកបន្ថែមឥណទានសម្រាប់ការកែប្រែតាមស្ថានភាពជាក់ស្តែង។

ឥណទានសម្រាប់ការអនុវត្តកម្មវិធីដែលបានអនុម័ត ត្រូវស្ថិតក្នុងកម្រិតអប្បបរមាចាំបាច់ដែលត្រូវការសម្រាប់ដំណើរការសកម្មភាពការងារចាំបាច់នៅក្នុងលក្ខខណ្ឌនៃឆ្នាំមុន។

ការកែប្រែតាមស្ថានភាពជាក់ស្តែង ត្រូវគិតអំពីផលប៉ះពាល់ដែលបានកើតឡើងនៅក្នុងឆ្នាំមុន និងដែលអាចកើតឡើងនៅក្នុងឆ្នាំបន្តបន្ទាប់ ក្នុងក្របខ័ណ្ឌថវិការយៈពេលមធ្យម។

វិធានការថ្មីនៃកម្មវិធី គឺជាវិធានការដែលទាក់ទងទៅនឹងការសម្រេចទាំងឡាយណាដែលនាំឱ្យមានផលប៉ះពាល់ហិរញ្ញវត្ថុបន្ថែមទៀតទៅលើថវិកា។

ឥណទានថវិកាសម្រាប់អនុវត្តកម្មវិធី ត្រូវមានការពន្យល់ពីភាពចាំបាច់ ភាពសមស្រប និងមូលដ្ឋានគណនាក្នុងទិសដៅសម្រេចបាននូវសមិទ្ធកម្មដែលបានគ្រោងទុក។

វិធាននិងនីតិវិធីនៃការបែងចែកឥណទានចំណាយចរន្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៤១ .-

ឥណទានចំណាយមូលធន គឺជាឥណទានវិនិយោគដែលចែកចេញជាឥណទានភ្ជាប់សន្យា និងឥណទានទូទាត់។ ឥណទានវិនិយោគ កំណត់លើគម្រោងឬកម្មវិធីវិនិយោគ ទាំងឡាយដែលរដ្ឋបានផ្តួចផ្តើមនៅក្នុងឆ្នាំ និងគណនាតម្រូវការចំណាយសរុប ដោយមានសង្គតិភាពទៅនឹងផែនការគម្រោងវិនិយោគរយៈពេលមធ្យម។

ឥណទានភ្ជាប់សន្យា ជាឥណទានកំហិតកំណត់ដែលត្រូវបានអនុញ្ញាតនៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ សម្រាប់ឱ្យរាជរដ្ឋាភិបាលធ្វើការធានាចំណាយសម្រាប់ប្រតិបត្តិការទាំងស្រុងនៃគម្រោងឬកម្មវិធីវិនិយោគដែលបានគ្រោងដោយមិនអនុញ្ញាតឱ្យមានការគ្រោងឥណទានបន្ថែមសម្រាប់បញ្ចប់នោះទេ។ ឥណទានភ្ជាប់សន្យានេះត្រូវមានសង្គតិភាពទៅនឹងក្របខ័ណ្ឌថវិការយៈពេលមធ្យម និងធានាបាននូវចីរភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។

ឥណទានទូទាត់ ត្រូវប្រើសម្រាប់ចេញបញ្ជាចំណាយដែលជាបន្ទុករបស់រដ្ឋទៅតាមលក្ខខណ្ឌទូទាត់នៃកិច្ចសន្យាគម្រោងវិនិយោគ និងនៅក្នុងកម្រិតនៃឥណទានភ្ជាប់សន្យា។

ឥណទានភ្ជាប់សន្យានិងឥណទានទូទាត់ ត្រូវដាក់នៅក្រោមអាណាប័ក សម្រាប់ចំណាយចាំបាច់ក្នុងការអនុវត្តគម្រោងវិនិយោគ ដែលបានកំណត់នៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

មាត្រា៤២ .-

ឥណទានភ្ជាប់សន្យាអាចមានតម្លៃគ្មានកំណត់ពេល។ ឥណទាននេះ ត្រូវបានយោងពីមួយឆ្នាំទៅមួយឆ្នាំ រហូតដល់ការលុបជាយថាហេតុ។ ឥណទានទូទាត់ដែលមិនបានប្រើនៅពេលបិទការគ្រប់គ្រង(បញ្ចប់ឆ្នាំ) ត្រូវបានលុបនិងអាចអនុញ្ញាតឥណទានថ្មីសម្រាប់ឆ្នាំបន្ទាប់។

មាត្រា៤៣ .-

គម្រោងឬកម្មវិធីវិនិយោគរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលរាជធានី ខេត្ត ដែលមិនទាន់បញ្ចប់នៅឆ្នាំអនុវត្ត ឥណទានទូទាត់នៃចំណាយមូលធនដែលមិនទាន់បានប្រើប្រាស់នៅពេលបិទការគ្រប់គ្រង(បញ្ចប់ឆ្នាំ) អាចអនុញ្ញាតឱ្យយោងជាឥណទានទូទាត់ទៅឆ្នាំបន្ទាប់បាន សម្រាប់បញ្ចប់គម្រោងឬកម្មវិធីវិនិយោគចាំបាច់។ ឥណទានយោងទៅឆ្នាំបន្ទាប់នេះ ត្រូវសម្រេចដោយអនុក្រឹត្យតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យ៉ាងយូរនៅត្រឹមថ្ងៃទី៣១ ខែមករា នៅឆ្នាំបន្ទាប់។

ឥណទានទូទាត់ដែលអនុញ្ញាតឱ្យយោងទៅឆ្នាំបន្ទាប់ ត្រូវកម្រិតមិនឱ្យលើសពី១០(ដប់)ភាគរយ រៀងៗគ្នានៃឥណទានចំណាយវិនិយោគថ្នាក់ជាតិប្រចាំឆ្នាំ និងឥណទានចំណាយវិនិយោគនៃរដ្ឋបាលរាជធានី ខេត្តប្រចាំឆ្នាំ។ ឥណទានទូទាត់ដែលអនុញ្ញាតឱ្យយោងពីឆ្នាំមុនដែលមិនបានប្រើប្រាស់ក្នុងឆ្នាំបន្ទាប់ ត្រូវទុកជាមោឃៈនៅក្នុងច្បាប់ទូទាត់ថវិកានៃឆ្នាំបន្ទាប់។

ដោយឡែក ការយោងឥណទានទូទាត់ទៅឆ្នាំបន្ទាប់សម្រាប់គម្រោងឬកម្មវិធីវិនិយោគរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ឥណទានដែលអនុញ្ញាតឱ្យយោងខាងលើនេះ ជាកម្មវត្ថុនៃការកត់ត្រាក្នុងច្បាប់ទូទាត់ថវិកានៅឆ្នាំបន្ទាប់។

វិធាន លក្ខណវិនិច្ឆ័យ និងនីតិវិធីនៃការអនុញ្ញាតឱ្យយោងឥណទានទូទាត់ទៅឆ្នាំបន្ទាប់ ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៤៤ .-

ឥណទានវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស គឺជាឥណទានប៉ាន់ប្រមាណ ហើយពុំអាចធ្វើជាកម្មវត្ថុនៃទិដ្ឋភាពទៅប្រតេទចំណាយណាមួយផ្សេងទៀតបានឡើយ។

មាត្រា៤៥ .-

គ្មានវិធានការជាបទប្បញ្ញត្តិច្បាប់ បទបញ្ជា ឬរដ្ឋបាលណាមួយ អាចត្រូវបានអនុម័តទទួលស្គាល់ឬសម្រេចបានទេ ប្រសិនបើតម្រូវការចំណាយនៃបន្ទុកថ្មីដែលនឹងកើតឡើងនោះ មិនត្រូវបានវាយតម្លៃ ព្យាករ និងអនុញ្ញាតមុននិងក្នុងពេលគ្រោង និងកំណត់ដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

មាត្រា៤៦ .-

ចំណូល ត្រូវប្រមូល កត់ត្រា និងបង់ទាំងស្រុងចូលគណនីទោលរតនាគារ ហើយមិនត្រូវយកទៅកាត់កងដោយត្រង់ជាមួយចំណាយណាមួយឡើយ។

ចំណូលទាំងមូល ត្រូវវិភាជសម្រាប់រាល់មុខសញ្ញាចំណាយទាំងអស់។ ប៉ុន្តែ ចំណូលខ្លះអាចត្រូវវិភាជសម្រាប់តែមុខសញ្ញាចំណាយជាក់ស្តែងណាមួយក្នុងទម្រង់និងក្រោមលក្ខខណ្ឌ ដែលត្រូវកំណត់ដោយច្បាប់។ ការវិភាជទាំងនេះ ត្រូវរៀបចំតាមទម្រង់ថវិកាឧបសម្ព័ន្ធ ឬគណនីពិសេសរតនាគារ។

ការបង្កើនដោយអាណាប័កនូវទឹកប្រាក់នៃឥណទានដែលបានអនុម័ត ដោយសំអាងលើប្រាក់ចំណូលពិសេសណាមួយ ត្រូវបានហាមឃាត់ដាច់ខាត។

ផ្នែកទី៤
សិទ្ធិអំណាចនិងការទទួលខុសត្រូវ

មាត្រា៤៧ .-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងចំណូលនិងចំណាយថវិកា ការខ្ចីប្រាក់ពីគេ ការឱ្យប្រាក់គេខ្ចី និងការធានារបស់រដ្ឋ ដែលត្រូវបានអនុញ្ញាតដោយច្បាប់។

គោលបំណង ពិតាន និងលក្ខណៈផ្នែកហិរញ្ញវត្ថុនៃការខ្ចីប្រាក់ពីគេ ការឱ្យប្រាក់គេខ្ចី និងការធានារបស់រដ្ឋត្រូវកំណត់នៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

មាត្រា៤៨ .-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំ ការអនុវត្ត ការតាមដាននិងការគ្រប់គ្រងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចផ្តល់របាយការណ៍អំពីស្ថានភាពក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ជូនរដ្ឋសភានិងព្រឹទ្ធសភាពីរដងក្នុងមួយឆ្នាំ គឺនៅពាក់កណ្តាលឆ្នាំ និងនៅពេលពិភាក្សាអនុម័តសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

មាត្រា៤៩ .-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចដឹកនាំការគោរពនិងការរក្សាវិន័យហិរញ្ញវត្ថុសាធារណៈ ព្រមទាំងពង្រឹងប្រសិទ្ធភាពថវិកាទាំងកម្រិតវិភាជន៍ និងកម្រិតអនុវត្តន៍ តាមរយៈការរៀបចំនិងអនុវត្តក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ការរៀបចំក្របខ័ណ្ឌថវិការយៈពេលមធ្យម ការគោរពច្បាប់ហិរញ្ញវត្ថុ និងលទ្ធកិច្ចការអនុវត្តថវិកា ដោយមានយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំលើការគ្រប់គ្រងថវិកា។

មាត្រា៥០ .-

រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ មានភារកិច្ចទទួលខុសត្រូវក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ការគ្រប់គ្រងថវិកា និងការត្រួតពិនិត្យការអនុវត្តថវិការបស់ខ្លួន ជាពិសេសត្រូវមានគណនេយ្យភាពចំពោះការកំណត់និងលទ្ធផលនៃការអនុវត្តគោលនយោបាយ នៅក្នុងវិស័យនិងដែនសមត្ថកិច្ចរបស់ខ្លួន ដែលស្របទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ជំពូកទី៣

ការរៀបចំនិងការអនុម័តថវិកា

ផ្នែកទី១

ក្របខ័ណ្ឌនៃការរៀបចំថវិកា

មាត្រា៥១ .-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញសារាចរស្តីពីប្រតិទិនលម្អិតនៃការរៀបចំថវិកាប្រចាំឆ្នាំនៅអំឡុងពាក់កណ្តាលខែមករា។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងសារាចររបស់រាជរដ្ឋាភិបាលស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងគម្រោងថវិកាប្រចាំឆ្នាំ ដោយផ្អែកលើក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមនិងក្របខ័ណ្ឌថវិការយៈពេលមធ្យម ដែលបានកំណត់ដោយរាជរដ្ឋាភិបាល ដើម្បីដាក់ជូននាយករដ្ឋមន្ត្រីពិនិត្យនិងសម្រេច នៅដើមខែឧសភា ដោយមានបញ្ជាក់នូវទម្រង់ បែបបទ និងនីតិវិធីនៃការរៀបចំគម្រោងថវិកា ព្រមទាំងឯកសារពាក់ព័ន្ធដែលត្រូវភ្ជាប់ជាមួយ។

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានគ្រប់អង្គភាពសាធារណៈប្រហាក់ប្រហែល និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងគម្រោងថវិកាប្រចាំឆ្នាំ ដោយអនុលោមតាមសារាចររបស់រាជរដ្ឋាភិបាលដូចមានចែងខាងលើ និងត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅអំឡុងពាក់កណ្តាលខែមិថុនា។

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវដាក់ឆ្លងគណៈរដ្ឋមន្ត្រី ពិនិត្យ និងសម្រេចនៅក្នុងអំឡុងពាក់កណ្តាលខែតុលា។ បន្ទាប់ពីបានពិនិត្យនិងសម្រេចរួចហើយ រាជរដ្ឋាភិបាលត្រូវបញ្ជូនសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនិងសំណុំឯកសារពាក់ព័ន្ធផ្សេងទៀត ជូនទៅរដ្ឋសភា យ៉ាងយូរនៅសប្តាហ៍ទី៤ នៃខែតុលា ដើម្បីពិនិត្យនិងអនុម័តមុននឹងបញ្ជូនសេចក្តីព្រាងច្បាប់នេះជូនទៅព្រឹទ្ធសភា យ៉ាងយូរនៅសប្តាហ៍ទី១នៃខែធ្នូ ដើម្បីពិនិត្យ ហើយឱ្យយោបល់មុនថ្ងៃទី២០ ខែធ្នូ និងប្រកាសឱ្យប្រើដោយព្រះរាជក្រម ព្រមទាំងរៀបចំបែបបទអនុវត្តឱ្យបានចប់សព្វគ្រប់ យ៉ាងយូរត្រឹមថ្ងៃទី៣១ ខែធ្នូ។

ក្នុងករណីមានការស្នើសុំពីគណៈកម្មការជំនាញពាក់ព័ន្ធរបស់រដ្ឋសភា ក្រោមការសម្របសម្រួលរបស់គណៈកម្មការទទួលបន្ទុកហិរញ្ញវត្ថុនៃរដ្ឋសភា សមាជិករាជរដ្ឋាភិបាលដែលទទួលបន្ទុកដឹកនាំគ្រប់គ្រងក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល មានភារកិច្ចដឹកនាំមន្ត្រីជំនាញពាក់ព័ន្ធដើម្បីឆ្លើយបំភ្លឺអំពីគោលបំណងគោលនយោបាយ និងកម្មវិធី ព្រមទាំងរបាយការណ៍សមិទ្ធកម្មនៃកម្មវិធីក្រោមសមត្ថកិច្ចក្រសួង ស្ថាប័ន និងអង្គភាព

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ១៧

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវផ្សព្វផ្សាយជាសាធារណៈក្នុងរយៈពេល១សប្តាហ៍ បន្ទាប់ពីបញ្ជូនទៅរដ្ឋសភា និងផ្សព្វផ្សាយជាសាធារណៈក្នុងរយៈពេល២សប្តាហ៍បន្ទាប់ពីច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនេះចូលជាធរមាន។

ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខ័ណ្ឌថវិការយៈពេលមធ្យម ត្រូវបញ្ជូនទៅរដ្ឋសភា និងផ្សព្វផ្សាយនៅក្នុងខែមេសា បន្ទាប់ពីទទួលបានការសម្រេចដោយគណៈរដ្ឋមន្ត្រី។

ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខ័ណ្ឌថវិការយៈពេលមធ្យម អាចត្រូវបានធ្វើបច្ចុប្បន្នកម្ម មុននឹងបញ្ជូនភ្ជាប់ទៅនឹងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំទៅរដ្ឋសភា។

ផ្នែកទី២

ដំណើរការនៃការរៀបចំ និងការអនុម័តថវិកា

មាត្រា៥២ .-

ការរៀបចំថវិកា ត្រូវគោរពបទប្បញ្ញត្តិដែលមានចែងនៅក្នុងមាត្រា៤ មាត្រា៦ និងមាត្រា១៥នៃច្បាប់នេះ។

មាត្រា៥៣ .-

ការគ្រោងចំណូល ត្រូវឈរលើមូលដ្ឋាននៃប្រភពធនធានថវិការបស់រដ្ឋដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងចំណូលផ្សេងៗ ដោយ៖

១-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវគ្រោងដោយផ្តាល់នូវចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងចំណូលផ្សេងៗ ដែលជាកម្មវត្ថុនៃការប្រមូលនៅក្រោមសមត្ថកិច្ចរបស់ខ្លួន។

២-រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានគ្រប់អង្គភាពសាធារណៈប្រហាក់ប្រហែល និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ដែលមានចំណែកក្នុងការគ្រប់គ្រងចំណូលក្រោមសមត្ថកិច្ចរបស់ខ្លួនត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនូវបញ្ជីរាយគ្រប់មុខចំណូល និងបញ្ជីប៉ាន់ស្មានចំណូលទាំងអស់ ដើម្បីកត់ត្រាក្នុងគម្រោងចំណូលនៃថវិកាឱ្យបានពេញលេញនិងត្រឹមត្រូវ។ ចំណូលទាំងនេះជាចំណែកមិនអាចបំបែកបាននៃចំណូលសរុបនៃថវិការដ្ឋ។

មាត្រា៥៤ .-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវគ្រោងធនធានហិរញ្ញប្បទាន ដោយឈរលើមូលដ្ឋាននៃប្រភពបានមកពី៖

១-ការបោះផ្សាយលក់មូលបត្ររដ្ឋ។

២-ការខ្ចីប្រាក់ពីស្ថាប័នហិរញ្ញវត្ថុនិងដៃគូអភិវឌ្ឍ។

៣-ប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាល។

៤-ហិរញ្ញប្បទានពីប្រភពផ្សេងៗទៀត ស្របតាមបទប្បញ្ញត្តិជាធរមាន។

មាត្រា៥៥ .-

ការគ្រោងចំណាយចរន្តនិងចំណាយវិនិយោគ ត្រូវរៀបចំឡើងដោយរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមការអនុវត្តកម្មវិធីនិងសកម្មភាពការងារទាំងមូល។

មាត្រា៥៦ .-

ការគ្រោងតម្រូវការថវិកា ត្រូវរៀបចំឡើងដោយហ្មត់ចត់និងច្បាស់លាស់ដោយផ្អែកលើគោលការណ៍ច្បាប់ គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយនិងយុទ្ធសាស្ត្រតាមវិស័យ ព្រមទាំងគោលបំណងគោលនយោបាយ កម្មវិធី និងលទ្ធផលរំពឹងទុក របស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែលពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបង្កើតនិយាមនិងឯកតារង្វាស់សម្រាប់រាល់សកម្មភាពការងារ ដែលមានលក្ខណៈផ្សេងៗគ្នា ព្រមទាំងសម្រាប់ទ្រព្យនិងសេវា ដោយសហការជាមួយនឹងក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែលពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា៥៧ .-

ការគ្រោងចំណាយវិនិយោគត្រូវរៀបចំផ្អែកលើគម្រោងឬកម្មវិធីវិនិយោគដោយឡែកៗ ដែលមានការយល់ព្រមជាមុន ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងវិនិយោគសាធារណៈ និងដែលត្រូវបានរៀបចំឡើងសំដៅសម្រេចឱ្យបានន្ធវគោលបំណង ដែលបានកំណត់ក្នុងរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល។ គម្រោងឬកម្មវិធីវិនិយោគទាំងអស់ គឺជាមូលដ្ឋានសម្រាប់វាយតម្លៃចំណាយវិនិយោគសរុបរបស់គម្រោងឬកម្មវិធី និងសម្រាប់កំណត់រយៈពេលនៃឥណទានភ្ជាប់សន្យានិងឥណទានទូទាត់ សម្រាប់ដំណាក់កាលនីមួយៗក្នុងឆ្នាំ។

មាត្រា៥៨ .-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិគ្រោងចំណូលនិងចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមិនបានលើកគម្រោងចំណូល និងចំណាយរបស់ខ្លួនតាមកាលកំណត់ ដោយផ្អែកលើលទ្ធផលនៃឆ្នាំកំពុងអនុវត្តដើម្បីធានាការគោរពតាមប្រតិទិននៃការរៀបចំ និងការអនុម័តសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដូចមានចែងក្នុងមាត្រា៥១នៃច្បាប់នេះ។

មាត្រា៥៩ .-

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ចែកចេញជាពីរផ្នែក។

ផ្នែកទី១ : បទប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ រួមមានៈ

១-អនុញ្ញាតឱ្យប្រមូលគ្រប់ធនធានថវិការដ្ឋ និងកំណត់ធនធានទាំងនោះ ជាទឹកប្រាក់សរុប។

២-ចែងអំពីបទប្បញ្ញត្តិដែលពាក់ព័ន្ធដល់ធនធានថវិការដ្ឋ ដែលរួមមាន ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងចំណូលផ្សេងៗ។

៣-កំណត់នូវបន្ទុកថវិកា ជាឥណទានខ្ពស់បំផុតដែលត្រូវបានអនុញ្ញាតជាគុណប្រយោជន៍ដល់ថវិការដ្ឋ។

៤-ចែងអំពីបទប្បញ្ញត្តិដទៃទៀតពាក់ព័ន្ធនឹងបន្ទុកថវិការដ្ឋ រួមបញ្ចូលនូវពិតាននៃការឱ្យប្រាក់គេខ្ចី។

៥-កំណត់គុណភាពថវិកា/សមតុល្យធនធាននិងបន្ទុកថវិកា។

៦-កំណត់ពិតានធនធានហិរញ្ញប្បទាន។

៧-ចែងអំពីបទប្បញ្ញត្តិពាក់ព័ន្ធនឹងធនធាននិងបន្ទុកហិរញ្ញប្បទាន រួមបញ្ចូលនូវពិតាននៃការខ្ចីប្រាក់ពីគេនិងការផ្តល់ជំនួយ។

៨-ចែងអំពីបទប្បញ្ញត្តិពាក់ព័ន្ធនឹងមូលនិធិបម្រុងហិរញ្ញវត្ថុរបស់រដ្ឋ។

៩-ចែងអំពីបទប្បញ្ញត្តិហិរញ្ញវត្ថុផ្សេងៗទៀត។

ផ្នែកទី២ : តារាងឧបសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ រួមមាន៖

១-តារាងចំណូលថវិកាថ្នាក់ជាតិ ចែកជាប្រភេទ ជំពូក គណនី អនុគណនី និងតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល។

២-តារាងចំណូលថវិការដ្ឋបាលរាជធានី ខេត្ត ចែកជាប្រភេទ ជំពូក គណនី អនុគណនី និងតាមរាជធានី ខេត្ត។

៣-តារាងចំណាយ បែងចែកទៅតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល តាមប្រភេទចំណាយ។

៤-តារាងចំណាយតាមកម្មវិធី។

៥-តារាងចំណាយវិនិយោគ បែងចែកទៅតាមប្រភេទចំណាយដល់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ដែលចែកចេញជាឥណទានភ្ជាប់សន្យានិងឥណទានទូទាត់។

៦-តារាងពិតានចំនួនបុគ្គលិកតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

៧-តារាងចំណាយឧបត្ថម្ភធនទៅគ្រឹះស្ថានសាធារណៈរដ្ឋបាល។

៨-តារាងចំណូល ចំណាយថវិកាឧបសម្ព័ន្ធ និងគណនីពិសេសរតនាគារ(ថ្នាក់ជាតិ)។

៩-តារាងចំណាយថវិការដ្ឋបាលរាជធានី ខេត្ត(តាមប្រភេទចំណាយ តាមកម្មវិធី និងតាមរាជធានី ខេត្ត)។

១០-តារាងតុល្យភាពហិរញ្ញវត្ថុឆ្នុះបញ្ចាំងពីកិច្ចប្រតិបត្តិការថវិកាដែលជាសមតុល្យធនធាននិងបន្ទុកថវិកា ព្រមទាំងឆ្នុះបញ្ចាំងពីតម្រូវការហិរញ្ញប្បទាននិងប្រភពហិរញ្ញប្បទាន។

មាត្រា៦០ .-

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវដាក់ជូនរដ្ឋសភានិងព្រឹទ្ធសភា ត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

១-សេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់នេះ។

២-ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខ័ណ្ឌថវិការយៈពេលមធ្យម ឬបច្ចុប្បន្នកម្មនៃឯកសារនេះ។

៣-ឧបសម្ព័ន្ធស្តីពីគម្រោងសមិទ្ធកម្មប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលរាជធានី ខេត្ត។

ក្រៅពីឯកសារខាងលើនេះ រាជរដ្ឋាភិបាល អាចផ្តល់ឯកសារពាក់ព័ន្ធផ្សេងទៀត ដើម្បីភ្ជាប់ទៅនឹងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ សម្រាប់ជាព័ត៌មានបន្ថែម ជូនរដ្ឋសភានិងព្រឹទ្ធសភា។

មាត្រា៦១ .-

ក្នុងករណីសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ មិនត្រូវបានអនុម័តមុនថ្ងៃទី១ ខែមករា នៃឆ្នាំការិយបរិច្ឆេទនោះ វិធានការដូចខាងក្រោម ត្រូវបានបន្តដោយស្របច្បាប់៖

១-ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងចំណូលផ្សេងៗ ត្រូវបានអនុញ្ញាតនិងបន្តឱ្យប្រមូល ក្នុងលក្ខខណ្ឌនិងតាមបទប្បញ្ញត្តិដែលបានកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុពីមុន និងក្នុងក្របខ័ណ្ឌច្បាប់ ព្រមទាំងលិខិតបទដ្ឋានដែលមានជាធរមាន។

២-ចំណាយចរន្តថវិការដ្ឋ តាមក្របខ័ណ្ឌនៃឥណទានថវិកាឆ្នាំមុន ដោយគិតតាមវិធីមួយភាគដប់ពីរជាបណ្តោះអាសន្នក្នុងខែនីមួយៗរហូតដល់ថវិកាថ្មីត្រូវបានអនុម័ត។

៣-ចំណាយវិនិយោគ ក្នុងកម្រិតឥណទានទូទាត់ដែលនៅទំនេរនៃក្របខ័ណ្ឌឥណទានថវិកាឆ្នាំមុន ហើយអាចលើសពីនេះក្នុងករណីចាំបាច់ ដោយមិនឱ្យការទូទាត់នោះលើសពីកម្រិតឥណទានភ្ជាប់សន្យា ដែលបានអនុម័តក្នុងថវិកាឆ្នាំមុន។

៤-ចំណាយបដិភាគសម្រាប់អនុវត្តគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស និងបន្ទុកបំណុលសាធារណៈ រួមមានការរំលស់ប្រាក់ដើម ការប្រាក់ និងបន្ទុកពាក់ព័ន្ធផ្សេងៗស្របតាមកិច្ចព្រមព្រៀងជាធរមាន។

៥-ចំណាយទាំងឡាយដែលជាកាតព្វកិច្ចពាក់ព័ន្ធនឹងសមាជិកភាពរបស់កម្ពុជាក្នុងស្ថាប័នអន្តរជាតិនិងអន្តររដ្ឋាភិបាល។

ផ្នែកទី៣
សិទ្ធិអំណាចនិងការទទួលខុសត្រូវ

មាត្រា៦២ .-

ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវអនុម័តក្នុងលក្ខខណ្ឌដូចគ្នានឹងច្បាប់ដទៃទៀតដែរ លើកលែងតែករណីដូចខាងក្រោម៖

១-ធនធាន បន្ទុក និងតុល្យភាពថវិការដ្ឋ ដែលត្រូវអនុម័តសរុបជាកញ្ចប់ រួមបញ្ចូលនូវ៖

- ធនធាននិងបន្ទុកថវិកាថ្នាក់ជាតិ
- ធនធាននិងបន្ទុកថវិការដ្ឋបាលថ្នាក់ក្រោមជាតិ
- ធនធាន បន្ទុក និងតុល្យភាព/សមតុល្យថវិការដ្ឋ
- បទប្បញ្ញត្តិស្តីពីធនធាននិងបន្ទុកហិរញ្ញប្បទាន។

២-បញ្ជីសរុបនៃថវិកាឧបសម្ព័ន្ធ និងគណនីពិសេសរតនាគារ ដែលត្រូវអនុម័តជាកញ្ចប់។

៣-បទប្បញ្ញត្តិផ្សេងទៀត ដែលត្រូវអនុម័តជាជំពូក។

៤-សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំទាំងមូលដែលជាកម្មវត្ថុនៃការអនុម័តចុងក្រោយ។

មាត្រា៦៣ .-

ការកែប្រែបទប្បញ្ញត្តិណាមួយនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ មិនអាចប្រព្រឹត្តទៅបានទេ ប្រសិនបើការកែប្រែនោះសំដៅបន្ថយធនធាន ឬបង្កើត ឬបន្ថែមបន្ទុកថវិការដ្ឋដែលធ្វើឱ្យប៉ះពាល់ជាសំខាន់ដល់តុល្យភាពនៃថវិកាដែលបានស្នើឡើង លើកលែងតែក្នុងករណីដូចខាងក្រោម៖

ការស្នើចំណាយថ្មីដែលត្រូវបានធ្វើឡើងដោយលុបឬបន្ថយចំណាយណាមួយផ្សេងទៀត ដើម្បីរក្សាតុល្យភាព

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២១

- ការស្នើចំណាយថ្មីដែលត្រូវបានធ្វើឡើងដោយមានភ្ជាប់ជាមួយនូវការស្នើសន្សំសំចៃលើប្រភេទចំណាយណាមួយដែលបានស្នើឡើងរួចហើយដើម្បីរក្សាតុល្យភាពថវិកា
- ការស្នើចំណាយថ្មីដែលត្រូវបានធ្វើឡើងដោយមានភ្ជាប់ជាមួយនូវការស្នើបង្កើតមុខចំណូលថ្មី ឬបង្កើនចំណូលដើម្បីរក្សាតុល្យភាពថវិកា។

ការកែប្រែបទប្បញ្ញត្តិណាមួយនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ ត្រូវមានការវាយតម្លៃលើទំហំនៃផលប៉ះពាល់ក្នុងឆ្នាំអនុវត្ត និងក្នុងករណីចាំបាច់ក្នុងឆ្នាំបន្តបន្ទាប់។

ការកែប្រែបទប្បញ្ញត្តិណាមួយនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ ត្រូវមានមូលហេតុនិងយុត្តិកម្មត្រឹមត្រូវ។

ការស្នើកែប្រែបទប្បញ្ញត្តិណាមួយនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ ដែលផ្ទុយនឹងខ្លឹមសារនៃមាត្រានេះ មិនត្រូវយកមកពិនិត្យនិងអនុម័តនោះទេ។

មាត្រា៦៤ .-

ការបែងចែកឥណទានថវិកាជូនក្រសួង ស្ថាប័ន កម្រិតជំពូក និងកម្រិតកម្មវិធីនៃចំណាត់ថ្នាក់មាតិកាថវិកា ត្រូវអនុវត្តតាមមាត្រា៣៨នៃច្បាប់នេះ។ ការបែងចែកនេះមិនអាចនាំឱ្យមានការកែប្រែឥណទានថវិកាដែលត្រូវបានកំណត់ដោយច្បាប់ឡើយ។

ជំពូកទី៤
ការអនុវត្តថវិកា
ផ្នែកទី១
ក្របខ័ណ្ឌនៃការអនុវត្តថវិកា

មាត្រា៦៥ .-

ការផ្ទេរឥណទានថវិកាពីមួយទៅមួយរវាងក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលរាជធានី ខេត្ត ត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុ។

ក្នុងករណីមានភាពចាំបាច់នៃការពង្រឹងរចនាសម្ព័ន្ធស្ថាប័នរបស់រាជរដ្ឋាភិបាល ការផ្ទេរឥណទានថវិកា ពីមួយទៅមួយរវាងក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល អាចប្រព្រឹត្តទៅបានដោយអនុក្រឹត្យ ក្នុងលក្ខខណ្ឌដែលការផ្ទេរឥណទានថវិកានេះ មិនមានការកែប្រែមុខចំណាយនិងការបែងចែកឥណទានថវិកាតាមជំពូកនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា និងមានគោលបំណងនៃសកម្មភាពដូចគ្នា។

ក្នុងករណីមានភាពចាំបាច់នៃការផ្ទេរមុខងារពីរដ្ឋបាលថ្នាក់ជាតិ ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្ទេរឥណទានថវិកា ពីសាមីក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល ទៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានការពាក់ព័ន្ធ អាចប្រព្រឹត្តទៅបានដោយអនុក្រឹត្យ ក្នុងលក្ខខណ្ឌដែលការផ្ទេរឥណទានថវិកានេះមិនមានការកែប្រែមុខចំណាយនិងការបែងចែកឥណទានថវិកាតាមជំពូកនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា និងមានគោលបំណងនៃសកម្មភាពដូចគ្នា។

ក្នុងករណីមានភាពចាំបាច់នៃការពង្រឹងរចនាសម្ព័ន្ធស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្ទេរឥណទានថវិកាពីមួយទៅមួយរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ អាចប្រព្រឹត្តទៅបានដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្នុងលក្ខខណ្ឌដែលការផ្ទេរឥណទានថវិកានេះ មិនមានការកែប្រែមុខចំណាយនិងការបែងចែកឥណទានថវិកាតាមជំពូកនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា និងមានគោលបំណងនៃសកម្មភាពដូចគ្នា។

មាត្រា៦៦ .-

ការបង្វែរឥណទានថវិកាពីជំពូកមួយទៅជំពូកមួយនៅផ្នែកក្នុងថវិការបស់ក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល ត្រូវកំណត់ដោយអនុក្រឹត្យ។

ការបង្វែរឥណទានថវិកាពីកម្មវិធីមួយទៅកម្មវិធីមួយនៅផ្នែកក្នុងថវិការបស់ក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល ត្រូវបានអនុញ្ញាតក្នុងកម្រិតយ៉ាងច្រើនបំផុត៥(ប្រាំ)ភាគរយនៃឥណទានកម្មវិធីនីមួយៗ។ ការបង្វែរឥណទានថវិកានេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

នាយករដ្ឋមន្ត្រី អាចផ្ទេរសិទ្ធិសម្រេចក្នុងកម្រិតណាមួយជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំពោះការបង្វែរឥណទានថវិកាដែលមានចែងក្នុងកថាខណ្ឌទាំងពីរខាងលើ។ ក្នុងករណីដែលមានការផ្ទេរសិទ្ធិសម្រេចនេះ ការបង្វែរឥណទានថវិកា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការបង្វែរឥណទានថវិកាពីជំពូកមួយទៅជំពូកមួយនៅផ្នែកក្នុងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចធ្វើប្រតិភូកម្មជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ នូវសិទ្ធិសម្រេចក្នុងការធ្វើនិយតកម្មឥណទានថវិការបស់ខ្លួន ដើម្បីដោះស្រាយតម្រូវការក្នុងករណីចាំបាច់។

ការបង្វែរឥណទានថវិកាពីកម្មវិធីមួយទៅកម្មវិធីមួយនៅផ្នែកក្នុងថវិការដ្ឋបាលរាជធានី ខេត្ត ត្រូវបានអនុញ្ញាតក្នុងកម្រិតយ៉ាងច្រើនបំផុត៥(ប្រាំ)ភាគរយនៃឥណទានកម្មវិធីនីមួយៗ។ ការបង្វែរឥណទានថវិកានេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

វិធាននិងនីតិវិធីនៃការបង្វែរឥណទានថវិកាផ្នែកក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៦៧ .-

ការបង្វែរឥណទានថវិកាពីគណនីមួយទៅគណនីមួយក្នុងជំពូកតែមួយ និងពីអនុកម្មវិធីមួយទៅអនុកម្មវិធីមួយក្នុងកម្មវិធីតែមួយ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចេញប្រកាសផ្ទេរសិទ្ធិអំណាចនៃការបង្វែរឥណទានថវិកានេះទៅក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលរាជធានី ខេត្ត។

ការបង្វែរឥណទានថវិកាពីអនុគណនីមួយទៅអនុគណនីមួយក្នុងគណនីតែមួយ និងពីចង្កោមសកម្មភាពមួយទៅចង្កោមសកម្មភាពមួយក្នុងអនុកម្មវិធីតែមួយ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង ឬដោយសេចក្តីសម្រេចរបស់ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត លើកលែងតែមុខចំណាយមួយចំនួនដែលមានហានិភ័យក្នុងការគ្រប់គ្រងថវិកា។ មុខចំណាយដែលត្រូវបានលើកលែងនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលត្រូវធ្វើបច្ចុប្បន្នកម្មជាប្រចាំនៅពេលស្រាវជ្រាវតម្រូវការជាក់ស្តែង។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២៣

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវសិក្សា ពិនិត្យ និងកែសម្រួលបន្ថែមជាបន្តបន្ទាប់នូវសិទ្ធិក្នុងការបង្វែរឥណទានថវិកានៅផ្នែក្នុងជំពូក និងផ្នែក្នុងកម្មវិធី ជូនដល់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលរាជធានី ខេត្ត ស្របតាមគោលការណ៍នៃការអនុវត្តថវិកាសមិទ្ធកម្ម។

វិធាននិងនីតិវិធីនៃការបង្វែរឥណទានថវិកានៅផ្នែក្នុងជំពូកនិងផ្នែក្នុងកម្មវិធី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៦៨ .-

ការបែងចែកឥណទានថវិកាដែលកត់ត្រានៅក្នុងចំណាយមិនទាន់បែងចែកមានមុខសញ្ញា និងចំណាយមិនបានគ្រោងទុក ក្រោមរូបភាពនៃឥណទានថវិកាបន្ថែមជាគុណប្រយោជន៍ដល់កម្មវិធី និងជំពូកផ្សេងៗរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៦៩ .-

នៅក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកា ឥណទានថវិកាសម្រាប់មុខសញ្ញាដែលលែងមានតម្រូវការប្រើប្រាស់អាចត្រូវបានលុបដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៧០ .-

នៅពេលដែលការវិវត្តនៃចំណូល និងចំណាយ ស្តែងចេញឱ្យឃើញនូវការបាត់តុល្យភាពថវិកា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចេញជាប្រកាសដើម្បីបង្កកមួយចំណែកឬទាំងស្រុងនៃប្រភេទឥណទានថវិកាមួយចំនួនដែលបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ។ ក្នុងករណីដែលការបាត់តុល្យភាពនេះមានលក្ខណៈធ្ងន់ធ្ងរ រាជរដ្ឋាភិបាលអាចចេញអនុក្រឹត្យតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយលុបមួយចំណែកឬទាំងស្រុងនៃប្រភេទឥណទានថវិកាមួយចំនួនដែលបានអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។ ការលុបឥណទាននេះ ជាកម្មវត្ថុនៃការអនុម័តដោយច្បាប់ទូទាត់ថវិកា។

មាត្រា៧១ .-

ក្នុងករណីមានតម្រូវការចាំបាច់ដើម្បីអន្តរាគមន៍ ឬដោះស្រាយបញ្ហាប្រឈមដែលបង្កដោយគ្រោះអាសន្ននិងគ្រោះមហន្តរាយ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ផលប្រយោជន៍ជាតិ ផ្អែកលើរបាយការណ៍របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នាយករដ្ឋមន្ត្រីអាចចេញអនុក្រឹត្យ៖

- ផ្ទេរឥណទានថវិកាពីមួយទៅមួយរវាងក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្ទេរឥណទាននៅផ្នែក្នុងថវិការបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយអនុញ្ញាតឱ្យកែប្រែមុខចំណាយ និងបែងចែកឥណទានថវិកាដែលផ្ទេរនេះឡើងវិញ
- បន្ថែមឥណទានថវិកាដើម្បីប្រើប្រាស់ តាមករណីចាំបាច់នីមួយៗ។



ការផ្ទេរនិងការបន្ថែមឥណទានថវិកានេះ ជាកម្មវត្ថុនៃការអនុម័តដោយច្បាប់ហិរញ្ញវត្ថុកែតម្រូវ នៅពេលដែលចាំបាច់ណាស់ឯសទាំងនេះត្រូវបានចប់សព្វគ្រប់។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ដោយបដិប្បញ្ញត្តិទៅនឹងកថាខណ្ឌខាងលើនេះ ប្រសិនបើច្បាប់ហិរញ្ញវត្ថុកែតម្រូវនេះមិនអាចធ្វើទៅកើតក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកាដែលកើតមានព្រឹត្តិការណ៍ ការផ្ទេរនិងការបន្ថែមឥណទានថវិកាទាំងនេះជាកម្មវត្ថុនៃនិយ័តភាវូបនីយកម្មក្នុងច្បាប់ទូទាត់ថវិកានៃឆ្នាំអនុវត្ត។

មាត្រា៧២ .-

ការកែប្រែផ្សេងៗលើច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ អាចធ្វើទៅបាននៅក្នុងអំឡុងពេលនៃឆ្នាំថវិកាតាមរយៈច្បាប់ហិរញ្ញវត្ថុកែតម្រូវដែលត្រូវដាក់សុំការអនុម័តយល់ព្រមពីរដ្ឋសភានិងព្រឹទ្ធសភា ដូចការអនុម័តច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដែរ។

មាត្រា៧៣ .-

ច្បាប់ហិរញ្ញវត្ថុកែតម្រូវ ត្រូវរៀបចំដោយផ្នែកឬទាំងស្រុងដែលមានទម្រង់ដូចគ្នានឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។ ច្បាប់ហិរញ្ញវត្ថុកែតម្រូវ មានឧបសម្ព័ន្ធដូចខាងក្រោម៖

១-របាយការណ៍បង្ហាញពីមូលហេតុនិងគោលដៅនៃការកែប្រែឥណទានថវិកា ដោយឆ្លុះបញ្ចាំងពីស្ថានភាពនៃការអនុវត្តនិងតុល្យភាពនៃថវិកា។

២-ឧបសម្ព័ន្ធពន្យល់លម្អិតអំពីតម្រូវការឥណទានថវិកាដែលបានស្នើសុំការកែប្រែ។

៣-តារាងសង្ខេបអំពីចលនាឥណទានថវិកាដែលនាំឱ្យមានការកែប្រែក្នុងឆ្នាំអនុវត្ត។

ផ្នែកទី២
ដំណើរការនៃការអនុវត្តថវិកា

មាត្រា៧៤ .-

ការអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យរបស់រដ្ឋ ជាភារកិច្ចរបស់អាណាប័កនិងគណនេយ្យករសាធារណៈ។

មុខងារជាអាណាប័កនិងមុខងារជាគណនេយ្យករសាធារណៈ មានវិសមិតភាពនឹងគ្នា។

រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក និងមេឃុំ គឺជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន។ មុខងារជាអាណាប័ករបស់អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត ត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិជាធរមាន។

អាណាប័កដើមខ្សែ ជាអ្នកបញ្ជាចំណូលនិងចំណាយថវិការដ្ឋ ចំពោះឥណទានថវិកា ដែលត្រូវបានវិភាជជូនសាមីក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

អាណាប័កដើមខ្សែ ត្រូវប្រគល់សិទ្ធិជូនប្រធានអង្គភាពថវិកាក្រោមឱវាទ ជាអាណាប័កផ្ទេរសិទ្ធិ សម្រាប់អនុវត្តកិច្ចប្រតិបត្តិការថវិកាក្នុងរង្វង់ឥណទានថវិកាដែលត្រូវបានវិភាជជូន ដើម្បីសម្រេចសមិទ្ធកម្មតាមការគ្រោងទុក។ សិទ្ធិអំណាចនិងការទទួលខុសត្រូវរបស់អង្គភាពថវិកា ត្រូវកំណត់ដោយអនុក្រឹត្យ តាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អាណាប័កដើមខ្សែឬអាណាប័កផ្ទេរសិទ្ធិ អាចចាត់តាំងថ្នាក់ដឹកនាំក្រោមឱវាទ ជាអាណាប័កជំនួសដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២៥

តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់អាណាប័ក ព្រមទាំងការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិនិង អាណាប័កជំនួស ត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៧៥ .-

ការអនុវត្តថវិការដ្ឋ ជាកម្មវត្ថុនៃការត្រួតពិនិត្យថវិកាដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបង្កើតអង្គភាពត្រួតពិនិត្យថវិកា ឱ្យនៅអមក្រសួង ស្ថាប័ន អង្គភាពសាធារណៈ ប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងធ្វើប្រតិភូកម្មមុខងារជូនអង្គភាពត្រួតពិនិត្យថវិកានេះ ដើម្បីអនុវត្ត ការត្រួតពិនិត្យថវិកា។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចផ្ទេរសិទ្ធិជូនអង្គភាពណាមួយដែលនៅក្បែរ ឬស្ថិតនៅកម្រិត អនុវត្តថវិកា ឱ្យអនុវត្តការត្រួតពិនិត្យថវិកាខាងលើនេះ។ ការធ្វើប្រតិភូកម្មមុខងារនិងការផ្ទេរសិទ្ធិត្រួតពិនិត្យថវិកា ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការត្រួតពិនិត្យថវិកា អាចធ្វើឡើងតាមនីតិវិធីខ្លី សាមញ្ញ និងបត់បែនបាន អាស្រ័យលើមុខចំណាយ ឬអង្គភាព អនុវត្តថវិកា ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

វិធាន និងនីតិវិធីអនុវត្តនិងត្រួតពិនិត្យថវិកា ព្រមទាំងមុខងារនិងភារកិច្ចរបស់អង្គភាពត្រួតពិនិត្យថវិកា ត្រូវ កំណត់ដោយអនុក្រឹត្យតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៧៦ .-

រាល់ចំណាយថវិការដ្ឋ សម្រាប់ការទិញ ការសាងសង់ ការជួសជុល ការជួលសេវា ត្រូវអនុលោមតាមវិធាននិង នីតិវិធី ដែលកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈជាធរមាន។

ផ្នែកទី៣

ការតាមដានវាយតម្លៃការអនុវត្តថវិកា

មាត្រា៧៧ .-

ក្នុងក្របខ័ណ្ឌនៃថវិកាសមិទ្ធកម្ម ការតាមដាននិងវាយតម្លៃការអនុវត្តថវិកា ត្រូវធ្វើឡើងដោយផ្អែកលើឧបករណ៍ និងវិធីសាស្ត្រសម្រាប់វាស់វែងនិងវាយតម្លៃ។

ការតាមដាន ត្រូវពិនិត្យលើគុណភាពនៃការរៀបចំកម្មវិធី ការអនុវត្តកម្មវិធីនិងសមិទ្ធកម្ម និងការប្រើប្រាស់ ធនធាន។ ដោយឡែក ការវាយតម្លៃ ត្រូវពិនិត្យលើសក្តិសិទ្ធភាពនិងសមិទ្ធកម្មដែលសម្រេចបានប្រចាំឆ្នាំ និងពហុឆ្នាំ នៃកម្មវិធីរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ស្ថិតក្រោមក្របខ័ណ្ឌគណនេយ្យភាព រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈ ប្រហាក់ប្រហែល និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំរបាយការណ៍សមិទ្ធកម្ម ប្រចាំឆ្នាំ តាមគោលការណ៍និងវិធីសាស្ត្រដែលកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យដោយបញ្ជាក់អនុលោមភាព និងផ្តល់អនុសាសន៍លើរបាយការណ៍ សមិទ្ធកម្មរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រើប្រាស់ជាធាតុចូលសម្រាប់កែលម្អដែនការសមិទ្ធកម្មនាឆ្នាំបន្ទាប់។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចផ្តួចផ្តើម និងដឹកនាំការវាយតម្លៃ តាមការចាំបាច់ និងតាមការជ្រើសរើស ដើម្បីវាស់វែងប្រសិទ្ធភាពនិងសក្តិសិទ្ធភាពនៃកម្មវិធី។

ក្របខ័ណ្ឌ វិធីសាស្ត្រ យន្តការ និងនីតិវិធីក្នុងការតាមដាននិងវាយតម្លៃ ក្នុងក្របខ័ណ្ឌថវិកាសមិទ្ធកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ។

ផ្នែកទី៤

សិទ្ធិអំណាចនិងការទទួលខុសត្រូវ

មាត្រា៧៨ .-

ស្ថិតក្រោមលក្ខខណ្ឌ និងកម្រិតកំណត់នៃសិទ្ធិអំណាចដែលបានផ្តល់ក្នុងច្បាប់ហិរញ្ញវត្ថុ និងក្រោមអំណាចរបស់នាយករដ្ឋមន្ត្រី មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុម្នាក់គត់ ដែលមានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេរួមបញ្ចូលនូវការបោះផ្សាយមូលបត្ររដ្ឋ ការទទួលហិរញ្ញប្បទានឥតសំណង ការវិនិយោគលើទ្រព្យសកម្មហិរញ្ញវត្ថុ ការធានានិងការសន្យាផ្នែកហិរញ្ញវត្ថុនានា និងមានសិទ្ធិក្នុងការឱ្យប្រាក់គេខ្ចី ទាំងក្នុងនិងក្រៅប្រទេស។ ក្រៅពីនេះ គ្មានអ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតណាមួយ មានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេឬឱ្យប្រាក់គេខ្ចី ឬចេញជាលិខិតធានា ឬក៏ធ្វើទង្វើណាផ្សេងៗទៀត ដោយផ្ទាល់ឬដោយប្រយោល ដែលអាចនាំឱ្យកើតមាននូវបំណុលឬបន្ទុកហិរញ្ញវត្ថុផ្សេងទៀត ដោយផ្ទាល់ឬដោយប្រយោលដល់ព្រះរាជាណាចក្រកម្ពុជាបានទេ។

ចំពោះការខ្ចីប្រាក់ពីគេ និងការបង្កើតកាតព្វកិច្ចហិរញ្ញវត្ថុនានារបស់សហគ្រាសសាធារណៈ ត្រូវគោរពតាមលក្ខខណ្ឌ ដែលកំណត់ក្នុងបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសហគ្រាសសាធារណៈ និងតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុនិងក្រោមអំណាចរបស់នាយករដ្ឋមន្ត្រី មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុម្នាក់គត់ ដែលមានសិទ្ធិរៀបចំកម្មវិធីដោះស្រាយបំណុលដែលរដ្ឋជំពាក់គេឬបំណុលដែលគេជំពាក់រដ្ឋ។

មាត្រា៧៩ .-

រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ព្រមទាំងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ មានកាតព្វកិច្ចទទួលខុសត្រូវចំពោះការអនុវត្តថវិកា និងលើការសម្រេចបាននូវសមិទ្ធកម្ម ដែលបានគ្រោងក្នុងវែនសមត្ថកិច្ចរៀងៗខ្លួន ក្នុងក្របខ័ណ្ឌដែលច្បាប់បានកំណត់។

មាត្រា៨០ .-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចគ្រប់គ្រងលទ្ធកម្មសាធារណៈនិងចេញលិខិតបទដ្ឋានគតិយុត្តដើម្បីណែនាំការអនុវត្តកិច្ចលទ្ធកម្មសាធារណៈដល់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈជាធរមាន។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២៧

មាត្រា៨១ .-

រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ប្រធានសហគ្រាសសាធារណៈ និងនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវធានាអនុលោមភាពពេញលេញ ការទទួលខុសត្រូវ តម្លាភាព និងគណនេយ្យភាព ក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈជាធរមាន។

មាត្រា៨២ .-

ប្រធានកម្មវិធី មានភារកិច្ចទទួលខុសត្រូវចំពោះមុខរដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លើការរៀបចំថវិកា ការសម្របសម្រួលការគាមដាន និងការជំរុញកិច្ចប្រតិបត្តិការនានាក្នុងកម្រិតកម្មវិធី រួមទាំងការអនុវត្តថវិកានិងសម្រេចបាននូវសមិទ្ធកម្មតាមការគ្រោងទុក។

ប្រធានអង្គភាពថវិកា មានភារកិច្ចទទួលខុសត្រូវលើកិច្ចប្រតិបត្តិការនានាក្នុងក្របខ័ណ្ឌសិទ្ធិអំណាចនិងការទទួលខុសត្រូវរបស់ខ្លួន រួមទាំង ការរៀបចំ ការអនុវត្តថវិកា និងសមិទ្ធកម្មដែលបានគ្រោងចំពោះមុខប្រធានកម្មវិធីនិងអាណាប័កដើមខ្សែ។

សិទ្ធិអំណាច ភារកិច្ច និងការទទួលខុសត្រូវរបស់ប្រធានកម្មវិធីនិងអង្គភាពថវិកាត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៨៣ .-

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុជាសេនាធិការ ទទួលបន្ទុកការងារបច្ចេកទេសហិរញ្ញវត្ថុ និងទទួលបន្ទុកសម្របសម្រួលនិងគាំទ្រដល់កិច្ចប្រតិបត្តិការនានានៃកម្មវិធីទាំងឡាយ រួមមានជាអាទិ៍ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ការរៀបចំថវិកាប្រចាំឆ្នាំ ការអនុវត្តថវិកា ការត្រួតពិនិត្យ និងការតាមដាននិងវាយតម្លៃ ព្រមទាំងលទ្ធផលនៃការអនុវត្តថវិការបស់ខ្លួន រួមបញ្ចូលនូវរបាយការណ៍អនុវត្តថវិកានិងរបាយការណ៍សមិទ្ធកម្ម។

តួនាទី ភារកិច្ច សិទ្ធិអំណាច និងការទទួលខុសត្រូវ ព្រមទាំងគុណវុឌ្ឍិរបស់ប្រធានអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ត្រូវកំណត់ដោយអនុក្រឹត្យ។

ជំពូកទី៥
គណនេយ្យនិងការធ្វើនាត់ថវិកា
ផ្នែកទី១
ក្របខ័ណ្ឌគណនេយ្យ

មាត្រា៨៤ .-

គោរពតាមគោលការណ៍គណនេយ្យភាព រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ប្រធានសហគ្រាសសាធារណៈ និងនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំ និងផ្តល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវរបាយការណ៍ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន រួមមាន របាយការណ៍ចំណូលនិងចំណាយថវិការដ្ឋ

របាយការណ៍សមិទ្ធកម្ម របាយការណ៍ស្តីពីការអនុវត្តគម្រោងដែលពាក់ព័ន្ធនឹងការខ្ចីប្រាក់ពីគេ ការខ្ចីប្រាក់គេខ្ចីការធានារបស់រដ្ឋ និងហិរញ្ញប្បទានឥតសំណង និងរបាយការណ៍ដែលពាក់ព័ន្ធនឹងចំណូលមានប្រភពមកពីការវិនិយោគលើទ្រព្យសកម្មហិរញ្ញវត្ថុ ព្រមទាំងព័ត៌មានផ្សេងៗទៀត តាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ប្រភេទ លក្ខខណ្ឌ កាលបរិច្ឆេទនៃការផ្តល់ និងគំរូនៃរបាយការណ៍ ដូចមានចែងក្នុងកថាខណ្ឌខាងលើ។

មាត្រា៨៥ .-

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យនៃថវិការដ្ឋ ត្រូវអនុវត្តដោយគណនេយ្យករសាធារណៈ។ ការធ្វើមជ្ឈការតួលេខ ត្រូវធ្វើឡើងដោយគណនេយ្យការរតនាគារ ដែលជាគណនេយ្យករសាធារណៈនៅរតនាគារជាតិ។

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យនៃថវិការដ្ឋត្រូវផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ ស្របតាមវិធានគណនេយ្យសាធារណៈ និងការគ្រប់គ្រងសាច់ប្រាក់ដោយគណនេយ្យករសាធារណៈ។

គ្រប់ប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យនៃថវិការដ្ឋ ត្រូវមានលិខិតយុត្តិការជាសំអាងនិងអនុវត្តជាទម្រង់អេឡិចត្រូនិក ឬឌីជីថលក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ វិធាននិងនីតិវិធីនៃការកំណត់លិខិតយុត្តិការ និងទម្រង់អេឡិចត្រូនិក និងឌីជីថលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៨៦ .-

គណនេយ្យសាធារណៈ គឺជាប្រព័ន្ធនៃការកត់ត្រា ការចាត់ថ្នាក់ ការវាស់វែង ការផ្ទុំបញ្ចូលគ្នា និងការបង្ហាញព័ត៌មានថវិកានិងហិរញ្ញវត្ថុ ដែលអនុញ្ញាតឱ្យមានការត្រួតពិនិត្យលើទិន្នន័យនៃប្រតិបត្តិការថវិកា និងគណនេយ្យ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍អនុវត្តថវិកា ព្រមទាំងការគណនានិងវិភាគលើចំណូលនិងថ្លៃដើមជាក់ស្តែងនៃសកម្មភាពឬសេវាកម្ម និងជាមូលដ្ឋានសម្រាប់ការវាយតម្លៃលើសមិទ្ធកម្ម។

ប្រភេទគណនេយ្យសាធារណៈ មានគណនេយ្យថវិកា គណនេយ្យទូទៅ និងគណនេយ្យវិភាគ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចកំណត់ប្រភេទគណនេយ្យសាធារណៈដទៃទៀត តាមតម្រូវការចាំបាច់ ក្នុងគោលបំណងធានាដល់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យមានប្រសិទ្ធភាពនិងសក្តិសិទ្ធភាព។

គណនេយ្យសាធារណៈត្រូវយកទៅអនុវត្តចំពោះថវិការដ្ឋ លើកលែងតែថវិការបស់សហគ្រាសសាធារណៈ។

ការកាន់បញ្ជីគណនេយ្យ និងការរៀបចំរបាយការណ៍នៃគណនេយ្យសាធារណៈត្រូវធ្វើជាភាសាខ្មែរ និងជាប្រាក់រៀល។

ការិយបរិច្ឆេទគណនេយ្យនីមួយៗត្រូវកំណត់រយៈពេលចំនួន១២(ដប់ពីរ)ខែ ដោយគិតចាប់ពីថ្ងៃទី១ ខែមករារហូតដល់កាលបរិច្ឆេទបិទបញ្ជីគណនេយ្យនៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល។

មាត្រា៨៧ .-

គណនេយ្យថវិកា កត់ត្រា តាមដាន និងរាយការណ៍អំពីការប្រើប្រាស់ឥណទានថវិកា ទាំងចំណូលនិងចំណាយថ្ងវការដ្ឋ ដែលមានកំណត់ដោយច្បាប់ហិរញ្ញវត្ថុ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

គណនេយ្យថវិកាត្រូវរៀបចំឡើងដោយឈរលើមូលដ្ឋានសាច់ប្រាក់។ ការកត់ត្រាចំណូល និងចំណាយថវិកា រដ្ឋត្រូវគោរពតាមគោលការណ៍ ដូចខាងក្រោម:

- ត្រូវទទួលស្គាល់ជាចំណូលថវិកា នៅក្នុងឆ្នាំអនុវត្តថវិកា នៅពេលដែលចំណូលទាំងនោះត្រូវបានទទួលជាសាច់ប្រាក់រួចរាល់ ដោយគណនេយ្យករសាធារណៈ
- ត្រូវទទួលស្គាល់ជាចំណាយថវិកា នៅក្នុងឆ្នាំអនុវត្តថវិកា នៅពេលដែលចំណាយទាំងនោះត្រូវបានទូទាត់ជាសាច់ប្រាក់រួចរាល់ ដោយគណនេយ្យករសាធារណៈ។

សលាកបត្របង្វែរចំណូល និងអាណត្តិបើកប្រាក់ ក្នុងការិយបរិច្ឆេទនៃឆ្នាំអនុវត្តថវិកា អាចត្រូវបានបន្តទទួលយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែមករា នៃឆ្នាំបន្ទាប់ ដោយត្រូវកត់ត្រាលេខនាបន្ថែមនៅត្រឹមថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំអនុវត្ត។

ក្នុងករណីដែលមានច្បាប់ហិរញ្ញវត្ថុកែតម្រូវ ត្រូវបានអនុម័តនៅក្នុងឆ្នាំអនុវត្តថវិកាឬមានអនុក្រឹត្យបន្ថែមឥណទានថវិកា ស្របតាមមាត្រា៧១នៃច្បាប់នេះ ចំណូលនិងចំណាយថវិកាដែលបានគ្រោងក្នុងច្បាប់ហិរញ្ញវត្ថុកែតម្រូវ ឬអនុក្រឹត្យនេះ អាចអនុវត្តបានក្នុងអំឡុងនៃរយៈពេលបំពេញបន្ថែម និងត្រូវចុះកិច្ចបញ្ជិកាគណនេយ្យនៅក្នុងការិយបរិច្ឆេទអនុវត្តថវិកាប្រចាំឆ្នាំ។ រយៈពេលបំពេញបន្ថែមនៃការអនុវត្តថវិកាសម្រាប់ករណីនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៨៨ .-

ធនធាននិងបន្ទុកហិរញ្ញប្បទានរបស់រដ្ឋត្រូវធ្វើការកត់ត្រាទៅតាមប្លង់គណនេយ្យសាធារណៈ និងទៅតាមមុខសញ្ញាឬប្រភេទនៃប្រតិបត្តិការសាច់ប្រាក់នីមួយៗ។ ប្រតិបត្តិការចំណូលនិងចំណាយថវិកាដែលកើតចេញពីប្រតិបត្តិការសាច់ប្រាក់ ត្រូវកត់ត្រាទៅតាមមុខសញ្ញាចំណូលនិងចំណាយ ស្របតាមលក្ខខណ្ឌដែលមានកំណត់ក្នុងមាត្រា៨៧នៃច្បាប់នេះ។

មាត្រា៨៩ .-

គណនេយ្យទូទៅ កត់ត្រាគ្រប់ប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដនិងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុនិងលទ្ធផលហិរញ្ញវត្ថុ។

គណនេយ្យទូទៅ ត្រូវរៀបចំឡើងដោយឈរលើមូលដ្ឋានបង្គរ និងត្រូវអនុវត្តតាមស្តង់ដាគណនេយ្យសាធារណៈរបស់កម្ពុជា។

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យនៃថវិការដ្ឋត្រូវបានទទួលស្គាល់ក្នុងបញ្ជីគណនេយ្យនៅក្នុងការិយបរិច្ឆេទដែលប្រតិបត្តិការទាំងនោះបានកើតឡើង ដោយមិនអាស្រ័យលើការទទួលបានសាច់ប្រាក់ឬការទូទាត់សាច់ប្រាក់។

គណនេយ្យទូទៅត្រូវធានាគុណភាពនៃគណនី ទិន្នន័យហិរញ្ញវត្ថុនិងគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ។

វិធាននិងនីតិវិធីនៃការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។

មាត្រា៩០ .-

គណនេយ្យវិភាគ វាស់វែងនូវថ្លៃដើមក្នុងការផលិតផលិតផល ផ្តល់សេវាសាធារណៈ ឬកិច្ចអន្តរាគមន៍ផ្សេងទៀត របស់រដ្ឋ ទៅតាមអង្គភាព មុខងារ វិស័យ កម្មវិធី ឬគម្រោង ដើម្បីជាមូលដ្ឋានបន្ថែមដល់ការសម្រេចចិត្តលើ ការគ្រប់គ្រងរបស់រដ្ឋបាលសាធារណៈ។

គណនេយ្យវិភាគ ត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋានទិន្នន័យនៃគណនេយ្យថវិកានិងគណនេយ្យ ទូទៅ។

មាត្រា៩១ .-

បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ត្រូវកំណត់គ្រប់លក្ខខណ្ឌ ដែលធ្វើឱ្យកិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិង គណនេយ្យ អាចកត់ត្រា វិភាគ និងគ្រប់គ្រងការអនុវត្តច្បាប់ហិរញ្ញវត្ថុ ប្រកបដោយគណនេយ្យភាព ប្រសិទ្ធភាព និង សក្តិសិទ្ធភាព។

បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យ។

ផ្នែកទី២
ការទូទាត់ថវិកា

មាត្រា៩២ .-

ការទូទាត់ថវិកា គឺជាកម្មវត្ថុនៃច្បាប់ទូទាត់ថវិកា។

មាត្រា៩៣ .-

សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ត្រូវរៀបចំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយផ្អែកលើទិន្នន័យ ចំណូល ចំណាយ និងព័ត៌មានហិរញ្ញវត្ថុដទៃទៀតដែលរាយការណ៍ដោយគណនេយ្យករសាធារណៈ និងទៅតាម សមិទ្ធកម្មនៃការអនុវត្តថវិកាដែលរាយការណ៍ដោយអាណាប័កដើមខ្សែ។

សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ចែកចេញជាពីរផ្នែក។

ផ្នែកទី១ : បទប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់ទូទាត់ថវិកា រួមមាន៖

១-ការបញ្ចប់នូវចំនួនទឹកប្រាក់ជាស្ថាពរនៃចំណូល ចំណាយ និងលទ្ធផលថវិកា ដែលបានអនុវត្តនៅក្នុង ការិយបរិច្ឆេទនៃឆ្នាំថវិកា។

២-ការបញ្ចប់នូវចំនួនទឹកប្រាក់ជាស្ថាពរនៃធនធាននិងបន្ទុកហិរញ្ញប្បទាន ដែលធានាដល់តុល្យភាពហិរញ្ញវត្ថុ នៃឆ្នាំអនុវត្តថវិកា និងបានបង្ហាញនៅក្នុងតារាងតុល្យភាពហិរញ្ញវត្ថុ។

៣-ការអនុម័តលើស្ថានភាពហិរញ្ញវត្ថុនិងលទ្ធផលនៃការិយបរិច្ឆេទ ដែលមានកំណត់ក្នុងមាត្រា៨៩នៃច្បាប់នេះ ស្តីពីគណនេយ្យទូទៅ ។

៤-ការទទួលស្គាល់នូវនិយ័តភាពឥណទានថវិកា រួមមាន ការផ្ទេរ ការបន្ថែមឥណទានថវិកា និងការលុបឥណទាន ថវិកា ក្នុងករណីដែលកើតមានឡើងក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកា។



៥-ការសម្គាល់មោឃៈនូវឥណទានថវិកាដែលមិនបានប្រើប្រាស់ លើកលែងតែមានបដិប្បញ្ញត្តិដែលអនុញ្ញាត

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៣១

៦-បទប្បញ្ញត្តិពាក់ព័ន្ធនឹងព័ត៌មានហិរញ្ញវត្ថុចាំបាច់ផ្សេងៗទៀត។

ផ្នែកទី២ : តារាងឧបសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់ទូទាត់ថវិកា រួមមានៈ

១-តារាងតុល្យភាពហិរញ្ញវត្ថុ និងតារាងកិច្ចប្រតិបត្តិការថវិកា។

២-តារាងចំណូលថវិកា រួមបញ្ចូលនូវៈ

-តារាងចំណូលថវិកាថ្នាក់ជាតិ ចែកជាប្រភេទ ជំពូក គណនី អនុគណនី និងតាមក្រសួង ស្ថាប័ន

-តារាងចំណូលថវិការដ្ឋបាលរាជធានី ខេត្ត ចែកជាប្រភេទ ជំពូក គណនី អនុគណនី និងតាមរាជធានី ខេត្ត។

៣-តារាងចំណាយថវិកាដែលឆ្លុះបញ្ចាំងនូវលទ្ធផលស្ថាពរនៃចំណាយថវិកា ដូចមានចែងក្នុងចំណុចទី៤ផ្នែកទី១ ខាងលើ រួមបញ្ចូលនូវៈ

-តារាងចំណាយ បែងចែកទៅតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល តាមប្រភេទចំណាយ

-តារាងចំណាយតាមកម្មវិធី

-តារាងចំណាយវិនិយោគ ដោយហិរញ្ញប្បទានក្នុងប្រទេស និងហិរញ្ញប្បទានក្រៅប្រទេស បែងចែកទៅតាមប្រភេទចំណាយដល់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល

-តារាងចំណាយឧបត្ថម្ភធនទៅគ្រឹះស្ថានសាធារណៈរដ្ឋបាល

-តារាងចំណាយថវិការដ្ឋបាលរាជធានី ខេត្ត(តាមប្រភេទចំណាយ តាមកម្មវិធី និងតាមរាជធានី ខេត្ត)។

៤-តារាងស្ថានភាពនិងលទ្ធផលហិរញ្ញវត្ថុ។

៥-តារាងចំណូល ចំណាយ ថវិកាឧបសម្ព័ន្ធ និងគណនីពិសេសរតនាគារ(ថ្នាក់ជាតិ)។

មាត្រា៩៤ .-

សេចក្តីព្រាងច្បាប់ទូទាត់ថវិកាដែលត្រូវដាក់ជូនរដ្ឋសភានិងព្រឹទ្ធសភា ត្រូវភ្ជាប់ជាមួយនូវឯកសារដូចខាងក្រោមៈ

១-សេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់នេះ។

២-ឧបសម្ព័ន្ធស្តីពីរបាយការណ៍ហិរញ្ញវត្ថុ។

៣-ឧបសម្ព័ន្ធស្តីពីរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំតាមក្រសួង ស្ថាប័ននីមួយៗ អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលរាជធានី ខេត្ត។

៤-ឧបសម្ព័ន្ធស្តីពីឥណទានដែលបានមោឃភាពនិងឥណទានដែលអនុញ្ញាតឱ្យយោងទៅឆ្នាំបន្ទាប់ ក្នុងករណីដែលមានដូចមានចែងក្នុងមាត្រា៤៣នៃច្បាប់នេះ។

៥-ឧបសម្ព័ន្ធស្តីពីចំនួនបុគ្គលិកតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

៦-ឧបសម្ព័ន្ធស្តីពីចំណូល ចំណាយថវិការដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

ក្រៅពីឯកសារខាងលើនេះ រាជរដ្ឋាភិបាល អាចផ្តល់ឯកសារពាក់ព័ន្ធផ្សេងទៀត ដើម្បីភ្ជាប់ទៅនឹងសេចក្តីព្រាងច្បាប់ទូទាត់ថវិកា សម្រាប់ជាព័ត៌មានបន្ថែម ជូនរដ្ឋសភានិងព្រឹទ្ធសភា។

មាត្រា៩៥ .-

សេចក្តីព្រាងច្បាប់ទូទាត់ថវិកាត្រូវដាក់ឆ្លងគណៈរដ្ឋមន្ត្រី ពិនិត្យ និងសម្រេចនៅក្នុងអំឡុងពាក់កណ្តាលខែតុលា។ បន្ទាប់ពីបានពិនិត្យនិងសម្រេចរួចហើយ រាជរដ្ឋាភិបាលត្រូវបញ្ជូនសេចក្តីព្រាងច្បាប់ទូទាត់ថវិកានិងសំណុំឯកសារពាក់ព័ន្ធផ្សេងទៀត ដំណាលគ្នានឹងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំជូនទៅរដ្ឋសភា ដើម្បីពិនិត្យនិងអនុម័ត មុននឹងបញ្ជូនសេចក្តីព្រាងច្បាប់នេះជូនទៅព្រឹទ្ធសភា យ៉ាងយូរនៅសប្តាហ៍ទី១នៃខែធ្នូ ដើម្បីពិនិត្យ ហើយឱ្យយោបល់មុនថ្ងៃទី២០ ខែធ្នូ និងប្រកាសឱ្យប្រើដោយព្រះរាជក្រម យ៉ាងយូរត្រឹមថ្ងៃទី៣១ ខែធ្នូ។

សេចក្តីព្រាងច្បាប់ទូទាត់ថវិកា ត្រូវផ្សព្វផ្សាយជាសាធារណៈក្នុងរយៈពេល១សប្តាហ៍ បន្ទាប់ពីបញ្ជូនទៅរដ្ឋសភា និងផ្សព្វផ្សាយជាសាធារណៈក្នុងរយៈពេល២សប្តាហ៍បន្ទាប់ពីច្បាប់ទូទាត់ថវិកានេះចូលជាធរមាន។

មាត្រា៩៦ .-

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុទៅអាជ្ញាធរសវនកម្មជាតិ ក្នុងអំឡុងខែសីហា ដើម្បីឱ្យអាជ្ញាធរសវនកម្មជាតិពិនិត្យនិងផ្តល់មតិសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនេះឱ្យបានរួចរាល់ ក្នុងអំឡុងពាក់កណ្តាលខែតុលា ស្របពេលដែលរាជរដ្ឋាភិបាលបញ្ជូនសេចក្តីព្រាងច្បាប់ទូទាត់ថវិកាទៅរដ្ឋសភា។

ផ្នែកទី៣
សិទ្ធិអំណាចនិងការទទួលខុសត្រូវ

មាត្រា៩៧ .-

គណនេយ្យករសាធារណៈទទួលបន្ទុកលើការទទួលនិងគ្រប់គ្រងចំណូល ទូទាត់ចំណាយ និងរក្សាទុកដាក់មូលនិធិ។ គណនេយ្យករសាធារណៈមានភារកិច្ចផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការអនុវត្តថវិកាស្របតាមបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈនិងការគ្រប់គ្រងសាច់ប្រាក់។ មានតែគណនេយ្យករសាធារណៈទេ ដែលមានសិទ្ធិអំណាចក្នុងការអនុវត្តប្រតិបត្តិការនិងដោះស្រាយបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសាច់ប្រាក់។ គណនេយ្យករសាធារណៈទទួលបន្ទុកកាន់បញ្ជីគណនេយ្យនិងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយធានាឱ្យបាននូវការគោរពគោលការណ៍និងបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ព្រមទាំងធានាឱ្យបាននូវភាពស្មោះត្រង់នៃកិច្ចបញ្ជីគណនេយ្យ និងការគោរពតាមនីតិវិធីហិរញ្ញវត្ថុជាធរមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ក្នុងដែនសមត្ថកិច្ចនេះ គណនេយ្យករសាធារណៈត្រូវមានការទទួលខុសត្រូវជាលក្ខណៈបុគ្គល និងជាប្រាក់កាស។

មាត្រា៩៨ .-

គណនេយ្យករសាធារណៈ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ អាណាប័ក និងគណនេយ្យករសាធារណៈដទៃទៀត ត្រូវទទួលស្គាល់គណនេយ្យករសាធារណៈដែលបានទទួលការតែងតាំងរួច។

មាត្រា៩៩ .-

រាល់ការអនុវត្តចំណូលនិងចំណាយថវិការដ្ឋ ត្រូវធ្វើឡើងទៅតាមសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងបទប្បញ្ញត្តិជាធរមាន។

រាល់ការកត់ត្រាចំណូលនិងចំណាយថវិការដ្ឋ ត្រូវគោរពទៅតាមមាតិកាថវិកានិងប្លង់គណនេយ្យសាធារណៈ ហើយរាល់របាយការណ៍ចំណូលនិងចំណាយថវិការដ្ឋ និងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវមានតម្លាភាពនិងផ្សព្វផ្សាយជាសាធារណៈ ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

· រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិចាត់មន្ត្រីក្រោមឱវាទចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមទាំងរាល់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យ តាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈ ប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិបុគ្គលសាធារណៈដទៃទៀត ដែលបានអនុវត្តប្រតិបត្តិការថវិការដ្ឋ ដើម្បីធានាការប្រមូលបាននូវព័ត៌មាននិងទិន្នន័យច្បាស់លាស់សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ទូទាត់ថវិកា។

ជំពូកទី៦

ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង សវនកម្មផ្ទៃក្នុង និងអធិការកិច្ចហិរញ្ញវត្ថុ

ផ្នែកទី១

ក្របខ័ណ្ឌនិងដំណើរការ

មាត្រា១០០ .-

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំនិងដំណើរការប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងសវនកម្មផ្ទៃក្នុង ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

វិធាននិងនីតិវិធីនៃការរៀបចំ និងដំណើរការប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងសវនកម្មផ្ទៃក្នុង ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា១០១ .-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការបច្ចេកទេសតែមួយរបស់រាជរដ្ឋាភិបាលនៅក្នុងកិច្ចការអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងមានភារកិច្ចធ្វើអធិការកិច្ចហិរញ្ញវត្ថុ នៅតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាល និងនីតិបុគ្គលដទៃទៀតដែលទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ ដោយផ្អែកលើហានិភ័យ ករណីសង្ស័យ និងបណ្តឹង។

វិធាននិងនីតិវិធីនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុត្រូវកំណត់ដោយអនុក្រឹត្យ។

ផ្នែកទី២

សិទ្ធិអំណាចនិងការទទួលខុសត្រូវ

មាត្រា១០២ .-

រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ប្រធានសហគ្រាសសាធារណៈ និងនាយកគ្រឹះស្ថានសាធារណៈ

រដ្ឋបាល ត្រូវចាត់សវនកររដ្ឋផ្ទៃក្នុងឱ្យធ្វើសវនកម្មលើអនុលោមភាពនិងប្រសិទ្ធភាពប្រតិបត្តិការនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អង្គភាពក្រោមឱវាទស្របតាមបទប្បញ្ញត្តិជាធរមាន។

អង្គភាពរងសវនកម្មផ្ទៃក្នុង និងបុគ្គល ឬអង្គភាពពាក់ព័ន្ធ មានកាតព្វកិច្ចសហការ ផ្តល់ និងអនុញ្ញាតឱ្យចូលដល់ឯកសារ ព័ត៌មាន គណនីធនាគារ មន្ត្រី បុគ្គលិក ទ្រព្យសម្បត្តិ ប្រតិបត្តិការ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងសហការអនុវត្តនីតិវិធីសវនកម្មនិងការងារផ្សេងទៀត ដើម្បីអភិវឌ្ឍមុខងារសវនកម្មផ្ទៃក្នុង ដោយគ្មានការរារាំង ប្រកបដោយការទទួលខុសត្រូវនិងប្រសិទ្ធភាពខ្ពស់ ស្របតាមបទប្បញ្ញត្តិគតិយុត្តជាធរមាន និងតាមការអនុញ្ញាតរបស់រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ប្រធានសហគ្រាសសាធារណៈ និងនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាលសាមី។

អង្គភាពរងសវនកម្មផ្ទៃក្នុងនៃក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវកែលម្អតាមអនុសាសន៍របស់សវនកម្មផ្ទៃក្នុងឱ្យបានទាន់ពេលកំណត់ ឱ្យមានប្រសិទ្ធភាពខ្ពស់ស្របតាមបទប្បញ្ញត្តិជាធរមាន។

មាត្រា១០៣ .-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិចាត់មន្ត្រីក្រោមឱវាទចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមាន ការអនុវត្តចំណូលនិងចំណាយថវិការដ្ឋ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ស្របតាមវិធាននិងនីតិវិធីនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុជាធរមាន។

ស្ថាប័នរងអធិការកិច្ចហិរញ្ញវត្ថុមានកាតព្វកិច្ចសហការ ឆ្លើយបំភ្លឺ ផ្តល់លិខិតយុត្តិការ ទិន្នន័យ បញ្ជីកគណនេយ្យ គណនីធនាគារ ទ្រព្យសម្បត្តិរដ្ឋ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន គ្រប់គ្រាន់និងត្រឹមត្រូវ សម្រាប់ជាកម្មវត្ថុនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុ ដោយគ្មានការរារាំង ប្រកបដោយការទទួលខុសត្រូវនិងប្រសិទ្ធភាពខ្ពស់។

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិបុគ្គលដទៃទៀតដែលទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ ដែលរងអធិការកិច្ចហិរញ្ញវត្ថុ ត្រូវអនុវត្តតាមវិធានការអធិការកិច្ចហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពខ្ពស់ស្របតាមបទប្បញ្ញត្តិជាធរមាន។

ជំពូកទី៧
ទោសប្បញ្ញត្តិ

មាត្រា១០៤ .-

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិបុគ្គលដទៃទៀតដែលទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ ដែលអនុវត្តមិនបានត្រឹមត្រូវនូវបញ្ញត្តិនៃច្បាប់នេះនិងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតជាធរមាន ត្រូវទទួលរងនូវវិធានការហិរញ្ញវត្ថុដែលកំណត់ដោយអនុក្រឹត្យតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៣៥

វិធានការហិរញ្ញវត្ថុ ចំពោះនីតិបុគ្គលដទៃទៀតដែលទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ ដូចមានចែងខាងលើនេះ មិនមែនជាឧបសគ្គសម្រាប់ការចោទប្រកាន់និងការផ្តន្ទាទោសព្រហ្មទណ្ឌ ព្រមទាំងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមានឡើយ។

មាត្រា១០៥ .-

អ្នករាជការសាធារណៈនិងពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតទាំងឡាយណា ដែលអនុវត្តបំពានលើបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតជាធរមានក្នុងការអនុវត្តមុខងារនិងភារកិច្ចរបស់ខ្លួន ត្រូវទទួលទណ្ឌកម្មខាងរដ្ឋបាលស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។ ទណ្ឌកម្មខាងរដ្ឋបាលនេះ មិនមែនជាឧបសគ្គសម្រាប់ការចោទប្រកាន់និងការផ្តន្ទាទោសព្រហ្មទណ្ឌ ព្រមទាំងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមានឡើយ។

មាត្រា១០៦ .-

អ្នករាជការសាធារណៈនិងពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដែលត្រូវបានរកឃើញថាបានធ្វើឱ្យបាត់បង់ប្រាក់កាសសាធារណៈឬខូចខាតទ្រព្យសម្បត្តិរដ្ឋ នោះតម្លៃនៃការបាត់បង់ឬការខូចខាត រួមទាំងការប្រាក់លើតម្លៃបាត់បង់ឬខូចខាតនោះនិងសំណងផ្សេងៗទៀត នឹងក្លាយជាបំណុលផ្ទាល់ចំពោះសាមីខ្លួននោះ ដែលត្រូវបំពេញកាតព្វកិច្ចសងនិងបង់ចូលថវិការដ្ឋវិញ។ ការទទួលខុសត្រូវជាប្រាក់កាសនេះ មិនមែនជាឧបសគ្គសម្រាប់ការចោទប្រកាន់និងការផ្តន្ទាទោសព្រហ្មទណ្ឌ ព្រមទាំងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមានឡើយ។

វិធាននិងនីតិវិធីពាក់ព័ន្ធនឹងការទទួលខុសត្រូវជាប្រាក់កាសនេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី៨

អន្តរប្បញ្ញត្តិ

មាត្រា១០៧ .-

រាជរដ្ឋាភិបាល ត្រូវរៀបចំនិងដាក់ឱ្យអនុវត្តន្ទវលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានាការអនុវត្តជាមូលដ្ឋានន្ទវថវិកាសមិទ្ធកម្ម យ៉ាងយូរត្រឹមឆ្នាំ២០២៦។

មាត្រា១០៨ .-

ច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយណា ដែលពាក់ព័ន្ធការអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ និងច្បាប់វិសោធនកម្មពាក់ព័ន្ធទាំងឡាយ ដែលកំពុងអនុវត្ត ត្រូវបន្តអានុភាពអនុវត្ត រហូតដល់មានច្បាប់និងលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ជំពូកទី៩

អវសានប្បញ្ញត្តិ

មាត្រា១០៩ .-

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

ថ្ងៃសុក្រ ៤កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០២៣

ក្នុងព្រះបរមនាមនិងតាមព្រះរាជក្រាសង់បង្គាប់

ប្រមុខរដ្ឋស្តីទី

សម្តេចវិបុលសេនាតក្តី សាយ ឈុំ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមទ្រង់ព្រះមេត្តាប្រោសព្រះរាជទានព្រះបរមរាជានុញ្ញាតប្រកាសឱ្យប្រើ

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

អភិសន្តិបណ្ឌិត ស ខេង

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ឧបសម្ព័ន្ធនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

សទ្ទានុក្រម

ក

កម្មវិធី សំដៅដល់ការប្រមូលផ្ដុំនូវឥណទាននៃក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរួមចំណែកដល់ការអនុវត្តគោលនយោបាយសាធារណៈដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន។ កម្មវិធីនីមួយៗមានគោលបំណងច្បាស់លាស់ដែលអាចវាស់វែងបាន ដោយមានការកំណត់សូចនាករជាក់លាក់។ កម្មវិធី ជាមូលដ្ឋានសម្រាប់កំណត់អនុកម្មវិធីនិងចង្កោមសកម្មភាព។

ការខ្ចីប្រាក់ពីគេ សំដៅដល់ការកៀរគរធនធានហិរញ្ញប្បទាន តាមរយៈការបោះផ្សាយលក់មូលបត្ររដ្ឋ និងការខ្ចីប្រាក់ពីស្ថាប័នហិរញ្ញវត្ថុ ពីដៃគូអភិវឌ្ឍ និងពីនីតិបុគ្គលផ្សេងទៀតស្របតាមបទប្បញ្ញត្តិជាធរមាន។

ការធានារបស់រដ្ឋ សំដៅដល់ការទទួលបំពេញកាតព្វកិច្ចហិរញ្ញវត្ថុជំនួស ក្នុងករណីភាគីដែលទទួលបានការធានាពីរដ្ឋ ពុំមានលទ្ធភាពទូទាត់សងទៅភាគីម្ខាងទៀតនៃកិច្ចព្រមព្រៀង។

ការធ្វើមជ្ឈការគូលេខ សំដៅដល់ការប្រមូលផ្ដុំគូលេខនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យ របាយការណ៍ថវិកា និងរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពពាក់ព័ន្ធ ដោយគណនេយ្យការរតនាគារ ដើម្បីរៀបចំរបាយការណ៍ថវិកា និងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់រដ្ឋ។

ការឱ្យប្រាក់គេខ្ចី សំដៅដល់ការផ្តល់ប្រាក់ឱ្យគេខ្ចីដោយប្រើថវិការដ្ឋ និង/ឬដោយប្រើហិរញ្ញប្បទានដែលរដ្ឋខ្ចីប្រាក់ពីគេ ស្របតាមបទប្បញ្ញត្តិជាធរមាន។

ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម សំដៅដល់ឯកសារយុទ្ធសាស្ត្រ ដែលផ្តល់នូវការប៉ាន់ស្មានពីធនធាននិងបន្ទុកថវិការដ្ឋ កំណត់ជំហរគោលនយោបាយថវិកា កំណត់ពិតានចំណាយថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងកំណត់ពិតានតម្រូវការហិរញ្ញប្បទាន និងវាយតម្លៃហានិភ័យហិរញ្ញវត្ថុសាធារណៈ សម្រាប់រយៈពេលមធ្យម ដោយផ្ដែកលើមូលដ្ឋាននៃទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច និងអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីធានាបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈ។

ក្របខ័ណ្ឌថវិការយៈពេលមធ្យម សំដៅដល់ការរៀបចំឱ្យមានជាយន្តការស្ថាប័នសម្រាប់ការធ្វើអាទិភាវូបនីយកម្ម ដើម្បីបង្ហាញអំពីអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាលដោយដាក់ចេញនូវពិតានចំណាយ និងសនិទានកម្មសម្រាប់រយៈពេលមធ្យម ជូនក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្របខ័ណ្ឌថវិការយៈពេលមធ្យម ផ្សារភ្ជាប់ទៅនឹងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងផែនការយុទ្ធសាស្ត្រថវិកា តាមរយៈការធ្វើសមាហរណកម្មផ្ដែកគោលនយោបាយ ការរៀបចំផែនការ និងការប៉ាន់ស្មានថវិកាសម្រាប់រយៈពេលមធ្យម៣(បី)ឆ្នាំ។

ក្រសួង សំដៅដល់ក្រសួង ដែលត្រូវបង្កើតឡើងដោយអនុលោមតាមច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី និងដឹកនាំដោយសមាជិករាជរដ្ឋាភិបាលដែលជាអាណាប័កដើមខ្សែនៃថវិការបស់ក្រសួងសាមី។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ត

គណនីទោលរតនាគារ សំដៅដល់ប្រព័ន្ធនៃការគ្រប់គ្រង និងប្រមូលផ្តុំគណនីធនាគារ ឬសាច់ប្រាក់របស់រាជរដ្ឋាភិបាល ដែលស្ថិតក្រោមរចនាសម្ព័ន្ធនិងការគ្រប់គ្រងតែមួយគត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈគណនេយ្យករសាធារណៈ។ គណនីទោលរតនាគារ ត្រូវបានប្រើប្រាស់ក្នុងការប្រមូលផ្តុំធនធានរបស់រដ្ឋ សម្រាប់ធានាដល់ប្រសិទ្ធភាពនៃការទូទាត់ចំណាយរបស់រដ្ឋ។

គណនេយ្យកររតនាគារ សំដៅដល់គណនេយ្យករសាធារណៈដែលបំពេញមុខងារនៅអគ្គនាយកដ្ឋានរតនាគារជាតិ។ គណនេយ្យកររតនាគារ រួមមាន គណនេយ្យកររតនាគារកណ្តាល និងគណនេយ្យកររតនាគាររាជធានីខេត្ត។ គណនេយ្យកររតនាគារទទួលបន្ទុកលើការងារហិរញ្ញវត្ថុនិងគណនេយ្យរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងមានមុខងារធ្វើមជ្ឈការតួលេខនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យ និងរបាយការណ៍ថវិកានិងហិរញ្ញវត្ថុរបស់អង្គភាពដទៃទៀត ដើម្បីរៀបចំរបាយការណ៍ថវិកានិងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់រដ្ឋ។

គណនេយ្យករសាធារណៈ សំដៅដល់ភ្នាក់ងាររបស់រដ្ឋដែលទទួលបន្ទុកលើកិច្ចការទទួលនិងគ្រប់គ្រងចំណូលទូទាត់ចំណាយ រក្សាទុកដាក់និងគ្រប់គ្រងសាច់ប្រាក់ កាន់បញ្ជីគណនេយ្យ និងរៀបចំរបាយការណ៍ថវិកានិងរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋ។ គណនេយ្យករសាធារណៈ រួមមាន គណនេយ្យកររតនាគារ គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល គណនេយ្យករថវិកាឧបសម្ព័ន្ធ គណនេយ្យករគណនីពិសេសរតនាគារ និងគណនេយ្យករដែលអនុវត្តគណនេយ្យនៃថវិការដ្ឋដទៃទៀត។

គណនេយ្យតាព សំដៅដល់ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែលរដ្ឋបាលថ្នាក់ក្រោមជាតិ និងនីតិបុគ្គលដទៃទៀត ចំពោះមុខងារ និងភារកិច្ចពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ តាមរយៈប្រព័ន្ធរបាយការណ៍។ ភ្នាក់ងារអនុវត្តថវិកាជាតិ ដែលមានអាណាប័កនិងគណនេយ្យករសាធារណៈ ត្រូវទទួលខុសត្រូវចំពោះសេចក្តីសម្រេចចិត្តរបស់ខ្លួន ក្រោមសិទ្ធិអំណាចដែលផ្តល់ដោយច្បាប់។

ច

ចីរភាព សំដៅដល់គុណ្យភាពរវាងចំណូលនិងចំណាយ ដែលត្រូវស្ថិតនៅក្នុងទំហំដែលថវិកាអាចទ្រទ្រង់បាន។ ក្នុងករណីដែលមានឱនភាពថវិកា ការធ្វើហិរញ្ញប្បទាន ឬការខ្ចីបំណុល ត្រូវគិតគូរនៅក្នុងកម្រិតមួយ ដែលអាចទូទាត់សងវិញបានក្នុងរយៈពេលវែង។

ចំណូលសារពើពន្ធក្នុងស្រុក សំដៅដល់ចំណូលទទួលបានពីការបង់ពន្ធអាករនិងទោសទណ្ឌពីការអនុវត្តច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ។

ចំណូលសារពើពន្ធលើពាណិជ្ជកម្មអន្តរជាតិ សំដៅដល់ចំណូលទទួលបានពីការបង់ពន្ធ អាករ និងកម្រៃផ្សេងៗលើការនាំចូលនិងការនាំចេញ។

ដ

ដែនអភិវឌ្ឍ សំដៅដល់ប្រទេសឬស្ថាប័នដែលផ្តល់ហិរញ្ញប្បទានក្នុងទម្រង់ជាឥណទាន ហិរញ្ញប្បទាន [illegible] ឬជិនុយបច្ចេកទេសដល់ព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងការកសាង [illegible]

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ត

តម្លាភាព សំដៅដល់រាល់ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងព័ត៌មាន គោលការណ៍ និងនីតិវិធីទាំងឡាយពាក់ព័ន្ធនឹងថវិកា ទាំងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ដែលត្រូវផ្សព្វផ្សាយទាន់ពេល ជូនដល់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងសាធារណជន ស្របតាមការកំណត់នៃបទប្បញ្ញត្តិជាធរមាន។

តុល្យភាពថវិកា សំដៅដល់តុល្យភាពរវាងធនធាននិងបន្ទុកថវិកាក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនិងច្បាប់ហិរញ្ញវត្ថុកែតម្រូវ។

តុល្យភាពហិរញ្ញវត្ថុ សំដៅដល់តុល្យភាពរវាងធនធាននិងបន្ទុករបស់រដ្ឋក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនិងច្បាប់ហិរញ្ញវត្ថុកែតម្រូវ។ តុល្យភាពហិរញ្ញវត្ថុត្រូវបានធានាតាមរយៈទំនាក់ទំនងរវាងតុល្យភាពថវិកានិងការធ្វើហិរញ្ញប្បទានរបស់រដ្ឋ។ ក្នុងករណីមានអតិរេកថវិកា រដ្ឋអាចប្រើប្រាស់អតិរេកថវិកាសម្រាប់ដោះស្រាយតម្រូវការហិរញ្ញប្បទានឬក្នុងករណីមានឱនភាពថវិកា រដ្ឋត្រូវប្រើប្រាស់ប្រភពហិរញ្ញប្បទានសម្រាប់បំពេញឱនភាពថវិកា។

ទ

ទ្រព្យសកម្ម សំដៅដល់ធនធាននានាដែលអង្គភាពគ្រប់គ្រង ជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ហើយអង្គភាពរំពឹងទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចឬសក្តានុពលសេវានាពេលអនាគតពីធនធានទាំងនោះ។

ទ្រព្យសកម្មហិរញ្ញវត្ថុ សំដៅដល់ទ្រព្យសកម្មទាំងឡាយណាដែលជា (ក) សាច់ប្រាក់ (ខ) ឧបករណ៍មូលធនរបស់អង្គភាពផ្សេងទៀត និង(គ) សិទ្ធិតាមកិច្ចសន្យាមួយដើម្បីទទួលបានសាច់ប្រាក់ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត ឬដោះដូរឧបករណ៍ហិរញ្ញវត្ថុជាមួយអង្គភាពដទៃដើម្បីទទួលបានផលចំណេញ។

ប

ប្រធានកម្មវិធី សំដៅដល់ថ្នាក់ដឹកនាំ ដែលត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលជាអាណាប៉ក់ដើមខ្សែ ដើម្បីទទួលខុសត្រូវលើការរៀបចំថវិកា ការសម្របសម្រួល ការតាមដាន និងការដុំរុញកិច្ចប្រតិបត្តិការនានាក្នុងកម្រិតកម្មវិធី រួមទាំងការអនុវត្តថវិកា ដើម្បីសម្រេចបាននូវសមិទ្ធកម្មតាមការគ្រោងទុក។

ប្រធានអង្គភាពថវិកា សំដៅដល់ប្រតិបត្តិករទទួលខុសត្រូវលើកិច្ចប្រតិបត្តិការនានាក្នុងក្របខ័ណ្ឌសិទ្ធិអំណាចនិងការទទួលខុសត្រូវរបស់ខ្លួន រួមទាំងការរៀបចំថវិកា ការអនុវត្តថវិកា និងសមិទ្ធកម្មដែលបានគ្រោងចំពោះមុខប្រធានកម្មវិធី និងអាណាប៉ក់ដើមខ្សែ។

ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង សំដៅដល់វិធានការឬដំណើរការត្រួតពិនិត្យដែលបានរៀបចំនិងអនុវត្តដោយអង្គភាពផ្ទាល់ ដើម្បីផ្តល់ការធានាសមស្របក្នុងគោលបំណងសម្រេចបាននូវប្រសិទ្ធភាពនិងសក្តិសិទ្ធភាពនៃប្រតិបត្តិការ ភាពជឿទុកចិត្តបាននិងសុចរិតភាពនៃព័ត៌មាន ព្រមទាំងអនុលោមភាពទៅនឹងគោលការណ៍ ផែនការនីតិវិធី និងបទប្បញ្ញត្តិជាធរមាន។

ប្រសិទ្ធភាព សំដៅដល់ថវិកាដែលត្រូវបែងចែកត្រឹមត្រូវនិងចំអាទិភាពគោលនយោបាយនៅក្នុងទំហំសមស្រប ហើយចំណាយត្រូវអនុវត្តដោយធានាបានតម្លៃនៃលុយ។

ព

ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត សំដៅដល់សមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដើម្បីបំពេញមុខងារសាធារណៈដទៃទៀត។

ត

តាពជាអាជ្ញា សំដៅដល់ច្បាប់ស្តីពីហិរញ្ញវត្ថុ ដែលតម្រូវឱ្យគោរពដាច់ខាតនិងពុំអាចបំពានដោយស្ថាប័នសាធារណៈណាមួយបានឡើយ ហើយច្បាប់នេះក៏មានឧត្តមភាពទៅលើច្បាប់នានាផងដែរ ខាងផ្នែកទិដ្ឋភាពហិរញ្ញវត្ថុសាធារណៈ។

តាពជ្រឹទុកមិត្តបាន សំដៅដល់ព័ត៌មានឬទិន្នន័យអំពីថវិកា ដែលត្រូវមានភាពពេញលេញគ្រប់ជ្រុងជ្រោយត្រឹមត្រូវនិងមានសង្គតិភាព។ ទន្ទឹមនេះ ការពណ៌នាអំពីព័ត៌មានហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុ ក៏តម្រូវឱ្យមានភាពស្មោះត្រង់ និងសុចរិត មិនបំផ្លើស ឬលាក់លៀមនូវចំណូលឬចំណាយណាមួយឡើយ។

រ

រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដែលជានីតិបុគ្គលសាធារណៈហើយមានស្វ័យភាពក្នុងការគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនស្ថិតក្រោមដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ ដែលមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្ត លើកលែងតែករណីមានបញ្ញត្តិដោយឡែកដែលចែងផ្សេងពីនេះ។

រដ្ឋបាលថ្នាក់ជាតិ សំដៅដល់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងមន្ទីរជំនាញក្រោមឱវាទ លើកលែងតែករណីមានបញ្ញត្តិដោយឡែកដែលចែងផ្សេងពីនេះ។

របៀបវារៈគោលនយោបាយ សំដៅដល់យុទ្ធសាស្ត្រសម្រាប់សម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ដែលឆ្ពុះបញ្ចាំងក្នុងផែនការរដ្ឋ ដែលរួមមានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលនយោបាយតាមវិស័យ និងអនុវិស័យរបស់ក្រសួង ស្ថាប័ន។

រយៈពេលមធ្យម សំដៅដល់រយៈពេលដែលមិនតិចជាង៣(បី)ឆ្នាំ និងមិនលើសពី៥(ប្រាំ)ឆ្នាំ។

ទ

ទិន័យហិរញ្ញវត្ថុសាធារណៈ សំដៅដល់ការគោរពនិងអនុវត្តតាមគោលការណ៍ បទប្បញ្ញត្តិ និងនីតិវិធីជាធរមានក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងការគោរពតាមលក្ខខណ្ឌនៃសូចនាករសំខាន់ៗកំណត់ក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំក្របខ័ណ្ឌថវិកា និងពង្រឹងប្រសិទ្ធភាពនិងវិន័យក្នុងការអនុវត្ត ដើម្បីធានានូវចីរភាពហិរញ្ញវត្ថុសាធារណៈ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។

ទិសសន្តាព សំដៅដល់ចំណូលនិងចំណាយ ដែលជាកម្មវត្ថុត្រូវបង្ហាញអំពីមូលដ្ឋានគិតគូរលម្អិតច្បាស់លាស់ [illegible]ប់ហិរញ្ញវត្ថុ។ ចំណូលត្រូវបង្ហាញប្រភេទធំៗ រីឯចំណាយត្រូវបង្ហាញអំពីគោលបំណងនិង

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៤១

គោលដៅនៃការប្រើប្រាស់ឥណទានថវិកានិងមានមុខសញ្ញាប្រើប្រាស់ច្បាស់លាស់ ព្រមទាំងស្ថិតនៅក្នុងកម្រិតអតិបរមាកំណត់។ ក្នុងន័យនេះ ថវិកាចាំបាច់ត្រូវបង្ហាញច្បាស់លាស់អំពីគោលបំណងនិងគោលដៅនៃសកម្មភាពការងារសាធារណៈទាំងឡាយ ដែលតម្រូវឱ្យប្រមូលចំណូលទាំងអស់ និងទូទាត់ចំណាយទាំងអស់របស់ថវិការដ្ឋ។

ស

សកលភាព សំដៅដល់គ្រប់ប្រភេទចំណូលទាំងអស់ ដែលត្រូវប្រើប្រាស់សម្រាប់រាល់មុខចំណាយដោយគ្មានលក្ខខណ្ឌ។ គ្រប់ប្រភេទចំណូលទាំងអស់ ត្រូវប្រមូល កត់ត្រា និងបង់ទាំងស្រុងចូលគណនីទោលរតនាគារ និងមិនត្រូវយកទៅកាត់កងដោយត្រង់ជាមួយចំណាយណាមួយឡើយ។

សមិទ្ធកម្ម សំដៅដល់លទ្ធផលនៃការអនុវត្តថវិកាទាំងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ដែលអាចវាស់វែងបានក្នុងទម្រង់ជាសូចនាករគន្លឹះ។ សម្រាប់ជាមូលដ្ឋាននៃការវាយតម្លៃភាពសន្សំសំចៃ ប្រសិទ្ធភាព និងសក្តិសិទ្ធិភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

សវនកម្មផ្ទៃក្នុង សំដៅដល់សកម្មភាពពិគ្រោះយោបល់និងការធានាអះអាងដោយឯករាជ្យ មិនលំអៀងដោយប្រើអភិក្រមជាប្រព័ន្ធ មានជំនាញត្រឹមត្រូវក្នុងការវាយតម្លៃ និងបង្កើនប្រសិទ្ធភាពលើដំណើរការគ្រប់គ្រងហានិភ័យ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ច ដើម្បីបន្ថែមតម្លៃនិងធ្វើឱ្យប្រតិបត្តិការប្រសើរឡើងដែលអនុញ្ញាតឱ្យអង្គភាពសម្រេចគោលបំណងតាមការកំណត់។

សហគ្រាសសាធារណៈ សំដៅដល់នីតិបុគ្គលដែលមានស្ថិយភាពហិរញ្ញវត្ថុដែលមានដើមទុនទាំងអស់ឬភាគច្រើនជារបស់រដ្ឋ។ ក្រៅពីបទប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់នេះ ការគ្រប់គ្រងសហគ្រាសសាធារណៈ ជាកម្មវត្ថុនៃការកំណត់ដោយច្បាប់ដែលមានការពាក់ព័ន្ធផ្សេងទៀត។

ស្ថាប័ន សំដៅដល់ស្ថាប័នក្រៅពីក្រសួង ដែលបង្កើតឡើងដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឬបង្កើតឡើងដោយច្បាប់ដែលដឹកនាំដោយប្រធានជាអាណាប័កដើមខ្សែនៃថវិការបស់ស្ថាប័នសាមី។

ហ

ហិរញ្ញវត្ថុសាធារណៈ សំដៅដល់ធនធាននិងបន្ទុករបស់រដ្ឋ ដែលរួមមាន ចំណូល ចំណាយ ទ្រព្យសកម្ម និងទ្រព្យអកម្ម ដែលរដ្ឋត្រូវគ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងឱ្យមានចីរភាព ស្ថិរភាព និងប្រសិទ្ធភាពក្នុងរយៈពេលមធ្យមនិងវែងក្នុងគោលដៅអភិវឌ្ឍសង្គម សេដ្ឋកិច្ចរបស់ប្រទេស។

អ

អ្នករាជការសាធារណៈ សំដៅដល់ (ក) បុគ្គលដែលបម្រើការងារនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬស្ថាប័នតុលាការដែលត្រូវបានតែងតាំងដោយលិខិតបទដ្ឋានគតិយុត្ត ទោះជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្នក្តី ទោះជាបានទទួល ឬមិនបានទទួលប្រាក់ឈ្នួលក្តី ដោយមិនគិតពី ឋានៈ អាយុរបស់បុគ្គលនោះឡើយ (ខ)បុគ្គលផ្សេងទៀត ដែលធ្វើការក្នុងមុខងារសាធារណៈ រួមទាំងទីភ្នាក់ងារសាធារណៈ ឬសហគ្រាសសាធារណៈ ព្រមទាំងស្ថាប័នសាធារណៈដទៃទៀត ដែលមានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

អង្គភាពត្រួតពិនិត្យថវិកា សំដៅដល់អង្គភាពដែលត្រូវបានបង្កើតឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ដាក់ឱ្យនៅអមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ឬអាចជាអង្គភាពដែលនៅកៀក ឬស្ថិតនៅកម្រិតអនុវត្តថវិកា ដែលត្រូវបានផ្តល់ប្រតិភូកម្មដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបំពេញមុខងារត្រួតពិនិត្យហិរញ្ញវត្ថុ ត្រួតពិនិត្យការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ និងត្រួតពិនិត្យនិងជំរុញការប្រមូលចំណូលមិនមែនសារពើពន្ធ។

អង្គភាពថវិកា សំដៅដល់អង្គភាពដែលក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិសាមី បានផ្តល់អាណត្តិកិច្ចច្បាស់លាស់ក្នុងការអនុវត្តសកម្មភាពការងារដើម្បីបង្កើតបានជាលទ្ធផលជាក់លាក់ អាចវាស់វែងបាន និងរួមចំណែកក្នុងការសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងរង្វង់តណាទានថវិកាដែលបានវិភាជជូន។ អង្គភាពថវិកាអាចជាអគ្គនាយកដ្ឋាន ឬអង្គភាពដែលមានថ្នាក់ស្មើ ឬកម្រិតប្រហាក់ប្រហែលអគ្គនាយកដ្ឋាន ឬនាយកដ្ឋាន ហើយមានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ ព្រមទាំងមានទំហំការងារ ចំនួនបុគ្គលិក និងទំហំថវិកាសមស្រប។

អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ សំដៅដល់អង្គភាពតែមួយគត់ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាណាប័ក ដើមខ្សែរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលមានតួនាទី និងភារកិច្ចដឹកនាំ ណែនាំ គាំទ្រ និងសម្របសម្រួលជាមួយគ្រប់អង្គភាពថវិកា ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ការរៀបចំថវិកាប្រចាំឆ្នាំ ការអនុវត្តថវិកា ការពិនិត្យ និងការតាមដានការអនុវត្តថវិកា និងបូកសរុបរបាយការណ៍។ អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុអាចជាអគ្គលេខាធិការដ្ឋាន ជាអគ្គនាយកដ្ឋានឬជានាយកដ្ឋានឬទីចាត់ការឬការិយាល័យទទួលបន្ទុកការងារហិរញ្ញវត្ថុ ដែលទទួលបន្ទុកការងារថវិកានិងហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

អង្គភាពរដ្ឋមិនមានបុគ្គលភាពគតិយុត្ត សំដៅដល់អង្គភាពចំណុះក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវប្រគល់មុខងារ ឬបង្កើតឱ្យអនុវត្តថវិកាឧបសម្ព័ន្ធ តាមលក្ខណៈវិនិច្ឆ័យដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

អង្គភាពសាធារណៈប្រហាក់ប្រហែល សំដៅដល់អង្គភាពសាធារណៈ ក្រៅពីក្រសួង និងស្ថាប័ន ហើយពុំមែនជាអង្គភាពក្រោមឱវាទរបស់ក្រសួងឬស្ថាប័នណាមួយឡើយ។ អង្គភាពសាធារណៈប្រហាក់ប្រហែល ត្រូវបង្កើតដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន និងទទួលហិរញ្ញប្បទានទាំងស្រុងឬមួយផ្នែកនៃថវិកាជាតិ ដែលដឹកនាំដោយប្រធានជាអាណាប័កដើមខ្សែនៃថវិការបស់សាមីអង្គភាពសាធារណៈ។

អង្គភាពអនុវត្តថវិកា សំដៅដល់អង្គភាពថវិកា និងអង្គភាពផ្សេងៗទៀតចំណុះក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលអនុវត្តថវិកា។

អធិការកិច្ចហិរញ្ញវត្ថុ សំដៅដល់ការត្រួតពិនិត្យ ស្រាវជ្រាវ អង្កេត និងផ្សឿងផ្ដាត់លើកិច្ចប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ រួមទាំងការអនុវត្តលិខិតគតិយុត្តពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ ដើម្បីចូលរួមធានាគណនេយ្យភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

អាណាប័ក សំដៅដល់អ្នកមានសិទ្ធិអំណាចគ្រប់គ្រាន់តាមច្បាប់ក្នុងការបញ្ជាកិច្ចប្រតិបត្តិការចំណូល និងចំណាយថវិការបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងរង្វង់ឥណទានថវិការបស់ខ្លួន។ អាណាប័ក រួមមាន អាណាប័កដើមខ្សែ អាណាប័កផ្ទេរសិទ្ធិ និងអាណាប័កជំនួស។

អាណាប័កដើមខ្សែ សំដៅដល់រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក និងមេឃុំ ដែលមានសិទ្ធិពេញលេញក្នុងការបញ្ជាចំណូល និងចំណាយថវិកាដោយខ្លួនឯងផ្ទាល់ ដោយត្រូវគោរពទៅតាមព្រំដែននៃសិទ្ធិអំណាច និងមុខងាររបស់ខ្លួន។

អាណាប័កជំនួស សំដៅដល់ថ្នាក់ដឹកនាំក្រោមឱវាទ ដែលទទួលបានការចាត់តាំងពីអាណាប័កដើមខ្សែឬអាណាប័កផ្ទេរសិទ្ធិ ដើម្បីប្រគល់សិទ្ធិជំនួសខ្លួនឬដើម្បីផ្ទេរសិទ្ធិ ដោយផ្អែកលើបទបញ្ជាគណនេយ្យសាធារណៈ ក្នុងពេលដែលអាណាប័កដើមខ្សែឬអាណាប័កផ្ទេរសិទ្ធិ អវត្តមាន ឬមានធុរៈ។

អាណាប័កផ្ទេរសិទ្ធិ សំដៅដល់ប្រធានអង្គភាពថវិកាក្រោមឱវាទ ដែលបានទទួលសិទ្ធិពីអាណាប័កដើមខ្សែសម្រាប់អនុវត្តកិច្ចប្រតិបត្តិការថវិកាក្នុងរង្វង់ឥណទានថវិកាដែលវិភាជជូន ដើម្បីសម្រេចសមិទ្ធកម្មតាមការគ្រោងទុក។

ឯ

ឯកត្តភាព សំដៅដល់គ្រប់ចំណូលនិងចំណាយទាំងអស់ ដែលត្រូវគ្រោងព្រមគ្នា នៅក្នុងឯកសារតែមួយ គឺច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។ នៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឯកត្តភាពក៏សំដៅផងដែរដល់ប្រព័ន្ធថវិកាតែមួយដែលមានការឯកភាពនិងមានសង្គតិភាព ហើយត្រូវអនុវត្តតាមយន្តការ ដែលមានក្របខ័ណ្ឌតែមួយច្បាស់លាស់។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ព្រះរាជក្រម

នស/រកម/០៣២៣/០០៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរាវជ្ជរាស្ត្ត ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោតាស កម្ពុជ៦ករាជវជ្ជបូរណសន្តិ សុតមន្តណ សិរីវិបុណ ខេមរាស្រីពិរាស្ត្ត ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ច្បាប់
ស្តីពី
ការគ្រប់គ្រងទឹកស្អាត



ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១ .- គោលបំណង

ច្បាប់នេះ កំណត់អំពីក្របខ័ណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រងនិងអភិវឌ្ឍន៍ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត នៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងដើម្បីធានាគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ ព្រមទាំងចូលរួមលើកកម្ពស់សុខុមាលភាពសាធារណៈនិងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋប្រកបដោយបរិយាបន្ន។

មាត្រា២ .- វិសាលភាព

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតដែលមានលក្ខណៈអាជីវកម្ម នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

មាត្រា៣ .- និយមន័យ

វាក្យសព្ទសំខាន់ៗ ដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធ នៃច្បាប់នេះ។

ជំពូកទី២
សមត្ថកិច្ចគ្រប់គ្រង

មាត្រា៤ .- សមត្ថកិច្ចគ្រប់គ្រង

ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ជាសមត្ថកិច្ចគ្រប់គ្រងនិងការទទួលខុសត្រូវដោយផ្ទាល់របស់រដ្ឋ។ រដ្ឋអាចផ្តល់សិទ្ធិជូនវិស័យឯកជន ដើម្បីផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋនិងផ្នែកផលិតកម្ម សេវាកម្ម ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការគ្រប់គ្រងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត អាចធ្វើប្រតិភូកម្មការគ្រប់គ្រងសេវាផ្គត់ផ្គង់ទឹកស្អាតជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមបទប្បញ្ញត្តិនិងនីតិវិធីជាធរមាន។

បុគ្គលគ្រប់រូបដែលធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតត្រូវមានការអនុញ្ញាតដែលផ្តល់ដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ហើយត្រូវអនុវត្តតាមបទប្បញ្ញត្តិនិងនីតិវិធីជាធរមាន។

មាត្រា៥ .- គោលនយោបាយនិងផែនការ

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ត្រូវរៀបចំគោលនយោបាយនិងផែនការអភិវឌ្ឍន៍វិស័យទឹកស្អាត ដោយផ្អែកលើការសិក្សានិងស្រាវជ្រាវដែលប្រើប្រាស់ព័ត៌មានបច្ចេកទេស សេដ្ឋកិច្ច សង្គម និងបរិស្ថានដើម្បីកំណត់ផែនការយុទ្ធសាស្ត្រ ផែនការរមៃ និងផែនការវិនិយោគ សម្រាប់ដឹកនាំគ្រប់គ្រងវិស័យទឹកស្អាត និងគ្រប់គ្រងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតដែលមានលក្ខណៈអាជីវកម្ម ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ត្រូវកៀរគរឱ្យអស់លទ្ធភាពនូវធនធាន ដូចជាធនធានមនុស្ស ធនធានហិរញ្ញវត្ថុនិងធនធានបច្ចេកទេស ដើម្បីអភិវឌ្ឍវិស័យទឹកស្អាតក្នុងព្រះរាជាណាចក្រកម្ពុជា។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ជំពូកទី៣
គោលការណ៍

មាត្រា៦ .. គោលការណ៍

ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ត្រូវឈរលើគោលការណ៍ៈ

- ធ្វើឱ្យមានតម្លាភាពនិងសមធម៌ក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត
- ធ្វើឱ្យមានសមភាពនិងមិនមានការរើសអើងរវាងអ្នកផ្តល់សេវានិងអ្នកទទួលសេវាផ្គត់ផ្គង់ទឹកស្អាត
- លើកទឹកចិត្តដល់វិនិយោគិនជាតិនិងអន្តរជាតិឱ្យចូលរួមវិនិយោគក្នុងវិស័យទឹកស្អាត
- ផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតដោយឈរលើលក្ខខណ្ឌ៤យ៉ាងគឺ ទឹកស្អាតត្រូវមានគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ។

ជំពូកទី៤
មូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត

មាត្រា៧ .. មូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត

មូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត ត្រូវបានបង្កើតឡើងដើម្បីធានាឱ្យមានការថែទាំ ការធ្វើឱ្យប្រសើរឡើង និងការអភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ជាពិសេសនៅក្នុងតំបន់កំពុងអភិវឌ្ឍនិងតំបន់ដាច់ស្រយាល។

មូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត បានមកពីថវិការដ្ឋ ជំនួយ បរិច្ចាគ វិភាគទានរបស់បុគ្គល ដៃគូអភិវឌ្ឍ និងប្រភពស្របច្បាប់ផ្សេងទៀត។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់មូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត ត្រូវកំណត់ដោយអនុក្រឹត្យ។

ជំពូកទី៥
ការគ្រប់គ្រងអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត
ផ្នែកទី១
ការផ្តល់អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត

មាត្រា៨ .. លក្ខខណ្ឌទូទៅនៃអាជ្ញាបណ្ណ

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលមានបំណងផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់កំណត់ជាក់លាក់ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតពីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះនិងបទប្បញ្ញត្តិជាធរមាន។

មាត្រា៩ .. ប្រភេទនៃអាជ្ញាបណ្ណ

អាជ្ញាបណ្ណដូចមានចែងក្នុងមាត្រា៨ខាងលើមានពីរប្រភេទគឺ អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត និងអាជ្ញាបណ្ណផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំ។ លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា១០ .. ការសិក្សាសមិទ្ធិលទ្ធភាព

អ្នកគ្រប់គ្រងរូប ដែលមានបំណងសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវស្នើសុំលិខិតអនុញ្ញាតសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់ជាក់លាក់ណាមួយ ដែលកំណត់ដោយប្រកាសរបស់អ្នកទទួលបន្ទុកវិស័យទឹកស្អាត។

ក្នុងករណីដែលតំបន់ណាមួយមានតម្រូវការចាំបាច់និងបន្ទាន់ក្នុងការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត មានសិទ្ធិសម្រេចលើកលែងការសិក្សាសមិទ្ធិលទ្ធភាព។

បែបបទនិងនីតិវិធីនៃការស្នើសុំលិខិតអនុញ្ញាតផ្តល់សិទ្ធិសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្ម ផ្គត់ផ្គង់ទឹកស្អាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

មាត្រា១១ .- ការឆ្លើយតបនិងការផ្តល់អាជ្ញាបណ្ណ

បន្ទាប់ពីបានទទួលពាក្យស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដែលបានបំពេញត្រឹមត្រូវនិងគ្រប់គ្រាន់តាមបែបបទរួចហើយ ក្រសួងទទួលបន្ទុកវិស័យទឹកស្អាតត្រូវចេញបង្កាន់ដៃទទួលពាក្យស្នើសុំ ក្នុងរយៈពេល៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ។

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាតត្រូវអនុវត្តនីតិវិធីពិនិត្យនិងផ្តល់អាជ្ញាបណ្ណ ក្នុងរយៈពេលយ៉ាងយូរ ៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

ក្នុងករណីដែលការស្នើសុំត្រូវបានបដិសេធ ក្រសួងទទួលបន្ទុកវិស័យទឹកស្អាតត្រូវបញ្ជាក់មូលហេតុនៃការបដិសេធនេះ។

មាត្រា១២ .- វិធីនៃការផ្តល់អាជ្ញាបណ្ណ

ការផ្តល់អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតទៅលើតំបន់ដែលត្រូវធ្វើការផ្គត់ផ្គង់ទឹកស្អាតនោះ ត្រូវបានអនុវត្តទៅតាមវិធីប្រកួតប្រជែងឬវិធីប្រគល់ផ្ទាល់។

លក្ខណៈនិច្ឆ័យសម្រាប់កំណត់តំបន់ដែលជាកម្មវត្ថុនៃការផ្តល់អាជ្ញាបណ្ណតាមវិធីប្រកួតប្រជែងឬវិធីប្រគល់ផ្ទាល់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

មាត្រា១៣ .- សុពលភាពអាជ្ញាបណ្ណ

អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដែលផ្តល់ជូនរូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវមានសុពលភាពជាក់លាក់ដែលកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

អាជ្ញាបណ្ណនេះ អាចត្រូវដកហូតមុនពេលផុតកំណត់បាន ក្នុងករណីអ្នកកាន់អាជ្ញាបណ្ណអនុវត្តផ្ទុយនឹងលក្ខខណ្ឌដែលមានចែងក្នុងអាជ្ញាបណ្ណ។ ក្នុងករណីនេះ អ្នកកាន់អាជ្ញាបណ្ណត្រូវទទួលខុសត្រូវដោយខ្លួនឯងចំពោះហានិភ័យដែលអាចកើតមានឡើងពាក់ព័ន្ធនឹងការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួន។

មាត្រា១៤ .- ការផ្ទេរ ការលក់ ការជួល និងការដាក់ប្រាតិភោគនូវអាជ្ញាបណ្ណ

ការផ្ទេរ ការលក់ ការជួល និងការដាក់ប្រាតិភោគនូវអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតត្រូវមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។ ការផ្ទេរ ការលក់ ការជួល និងការដាក់ប្រាតិភោគនូវអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតត្រូវអនុវត្តតាមនីតិវិធីដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ដើម្បីផលប្រយោជន៍សាធារណៈ ក្រសួងទទួលបន្ទុកវិស័យទឹកស្អាតអាចអនុញ្ញាត បដិសេធ ឬដាក់លក្ខខណ្ឌដូចខាងក្រោម៖

- ដាក់លក្ខខណ្ឌតាមគោលការណ៍ដែលមានចែងក្នុងអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត
- ត្រូវពង្រឹងសកម្មភាពអាជីវកម្មដើម្បីបង្កើនសមត្ថភាព លទ្ធភាព និងប្រសិទ្ធផលនៃការផ្គត់ផ្គង់ទឹកស្អាត
- ចំពោះតម្លៃផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ត្រូវគោរពតាមបទប្បញ្ញត្តិស្តីពីសារពើពន្ធជាធរមាន។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៤៩

មាត្រា១៥ .. ការបំពេញមុខងារដោយតតិយជន

ប្រតិបត្តិករ អាចប្រគល់ឱ្យតតិយជនណាម្នាក់បំពេញមុខងារជំនួសខ្លួនបាននូវផ្នែកទាំងអស់ឬផ្នែកខ្លះ នៃការងារបច្ចេកទេសដែលពាក់ព័ន្ធនឹងសេវាផ្គត់ផ្គង់ទឹកស្អាត លុះត្រាតែមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ។

បទប្បញ្ញត្តិនិងលក្ខខណ្ឌទាំងឡាយដែលពាក់ព័ន្ធនឹងប្រតិបត្តិករ ត្រូវយកមកអនុវត្តផងដែរចំពោះតតិយជនដែលទទួលមុខងារនេះ ក្នុងវិសាលភាពការងារដែលបានប្រគល់។

ផ្នែកទី២
ខិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត

មាត្រា១៦ .. ខិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត

ប្រតិបត្តិករ ដែលទទួលអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត មុននឹងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ពីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ទម្រង់បែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

មាត្រា១៧ .. សុពលភាពខិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត

វិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត ត្រូវមានសុពលភាពជាក់លាក់ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ មុនកាលបរិច្ឆេទអស់សុពលភាពនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត ប្រតិបត្តិករត្រូវស្នើសុំមកក្រសួងទទួលបន្ទុកវិស័យទឹកស្អាតដើម្បីបន្តសុពលភាព។

នីតិវិធីសម្រាប់ការស្នើសុំបន្តវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ផ្នែកទី៣
កម្រៃសេវាសាធារណៈ

មាត្រា១៨ .. ការបង់កម្រៃសេវាសាធារណៈ

ការស្នើសុំលិខិតអនុញ្ញាតផ្តល់សិទ្ធិសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត និងវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត ត្រូវបង់កម្រៃសេវាសាធារណៈ។

កម្រៃសេវាសាធារណៈនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ផ្នែកទី៤
ការស្នើសុំពង្រីកតំបន់សេវាកម្ម

មាត្រា១៩ .. ការពង្រីកតំបន់សេវាកម្ម

ការពង្រីកតំបន់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវមានការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីទទួលបន្ទុកវិស័យទឹកស្អាត។

ប្រតិបត្តិករ អាចស្នើសុំការអនុញ្ញាតពង្រីកតំបន់សេវាកម្មទៅតំបន់ដែលមានព្រំប្រទល់រួមជាមួយនឹងតំបន់សេវាកម្មរបស់ខ្លួនបាន ហើយដែលតំបន់នោះមិនទាន់មានអ្នកធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។

ការស្នើសុំពង្រីកតំបន់សេវាកម្មផ្គត់ផ្គង់ទឹកស្អាតរបស់ប្រតិបត្តិកអាចធ្វើទៅបាន លុះត្រាតែប្រតិបត្តិករនោះបានបំពេញផ្នែសេវាផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់របស់ខ្លួនយ៉ាងតិច៨០(ប៉ែតសិប)ភាគរយ និងអនុវត្តនូវកម្មវិធីសាងសង់ប្រព័ន្ធប្រព្រឹត្តកម្មបាន១០០(មួយរយ)ភាគរយ តាមផែនការកំណត់។

បែបបទនិងបរិបថនៃការអនុញ្ញាតឱ្យពង្រីកតំបន់ផ្គត់ផ្គង់ទឹកស្អាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ផ្នែកទី៥
លក្ខខណ្ឌស្តីពីការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត

មាត្រា២០ .- លក្ខខណ្ឌអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត

លក្ខខណ្ឌស្តីពីការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត គឺជាឧបសម្ព័ន្ធនៃអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដែលត្រូវកំណត់ដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ដើម្បីតម្រូវឱ្យប្រតិបត្តិកអនុវត្ត ក្នុងការធ្វើអាជីវកម្មរបស់ខ្លួន។

លក្ខខណ្ឌស្តីពីការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវកំណត់អំពីកាតព្វកិច្ច លក្ខខណ្ឌបច្ចេកទេស និងផែនការអាជីវកម្ម រួមទាំងរបាយការណ៍ហិរញ្ញវត្ថុ ដែលប្រតិបត្តិកត្រូវគោរពនិងអនុវត្តនៅពេលដែលខ្លួនទទួលបានអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់សេវាកម្មជាក់លាក់។

លក្ខខណ្ឌស្តីពីការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ដែលជាឧបសម្ព័ន្ធនៃអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។ ការបន្ត ការព្យួរ ការដកហូត ការលុបអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវពិនិត្យការអនុវត្តរបស់ប្រតិបត្តិករលើលក្ខខណ្ឌស្តីពីការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ដែលជាឧបសម្ព័ន្ធនៃអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។

បែបបទនិងបរិបថនៃការបន្ត ការព្យួរ ការដកហូត ការលុបអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ដោយអនុលោមតាមលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌទី៣(បី)ខាងលើ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ជំពូកទី៦
ស្តង់ដាគុណភាពទឹក

មាត្រា២១ .- ស្តង់ដាគុណភាពទឹកស្អាត

ប្រតិបត្តិករ ត្រូវផ្គត់ផ្គង់ទឹកស្អាតដែលធានាបាននូវគុណភាពនិងសុវត្ថិភាពសម្រាប់សុខភាពសាធារណៈ ដោយត្រូវគោរពតាមស្តង់ដាកម្ពុជាសម្រាប់ការតម្រូវគុណភាពនិងសុវត្ថិភាពទឹកស្អាត ស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ត្រូវធ្វើការណែនាំផ្សព្វផ្សាយអំពីស្តង់ដាកម្ពុជាសម្រាប់ការតម្រូវគុណភាពនិងសុវត្ថិភាពគុណភាពទឹកស្អាតឱ្យដល់ប្រតិបត្តិករ ដើម្បីឱ្យមានការឯកភាពនៃការប្រើប្រាស់ទឹកស្អាតតាមស្តង់ដាគុណភាពទឹកស្អាតតែមួយនិងបង្កើនប្រសិទ្ធភាពផលិតទឹកស្អាតដើម្បីធានាសុខភាពសាធារណៈ។

មាត្រា២២ .- ការត្រួតពិនិត្យគុណភាពទឹក

ប្រតិបត្តិករ ដែលទទួលបានអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវមានមន្ទីរពិសោធន៍ ឬឧបករណ៍ត្រួតពិនិត្យគុណភាពទឹក សម្រាប់ត្រួតពិនិត្យគុណភាពទឹក តាមការកំណត់របស់ក្រសួងទទួលបន្ទុក

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៥១

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត អាចចាត់តាំងមន្ត្រីជំនាញចុះយកសំណាកសម្រាប់វិភាគនិងធ្វើតេស្ត គុណភាពទឹក នៅគ្រប់ទីតាំងធ្វើអាជីវកម្មទឹកស្អាតរបស់ប្រតិបត្តិករ ក្នុងករណីចាំបាច់។

ជំពូកទី៧
ការប្រើប្រាស់ដី ប្រភពទឹក និងរចនាសម្ព័ន្ធរួម

មាត្រា២៣ .- ការប្រើប្រាស់ដី

ការកំណត់និងការប្រើប្រាស់ដីដើម្បីដំឡើងឬសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ត្រូវគោរពតាមបទប្បញ្ញត្តិច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ដើម្បីជាប្រយោជន៍សាធារណៈ ប្រតិបត្តិករអាចទទួលបានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិស្របច្បាប់លើទីតាំងដែលត្រូវធ្វើការរៀបចំដំឡើង សាងសង់ ឬជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។

ប្រតិបត្តិករត្រូវខិតខំដោះស្រាយតាមរយៈការចរចា សម្របសម្រួលជាមួយម្ចាស់កម្មសិទ្ធិ ដោយទូទាត់សំណងសមរម្យ និងយុត្តិធម៌ ដើម្បីមានសិទ្ធិចូល សិទ្ធិឆ្លងកាត់ និង/ឬប្រើប្រាស់ដី សម្រាប់ដំឡើង សាងសង់ ឬជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។

ក្នុងករណីដែលមិនអាចទទួលបានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ ប្រតិបត្តិករ ត្រូវស្នើសុំទៅអាជ្ញាធរមានសមត្ថកិច្ចដើម្បីដោះស្រាយបញ្ហានេះ ដើម្បីជាប្រយោជន៍សាធារណៈ។

មាត្រា២៤ .- ការប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត

ចំពោះរាល់ការសាងសង់ឬជួសជុលហេដ្ឋារចនាសម្ព័ន្ធបម្រើផលប្រយោជន៍សាធារណៈឬឯកជន ដែលអាចប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត កម្មសិទ្ធិករដើឬម្ចាស់ការឬអ្នកអនុវត្តគម្រោងនេះត្រូវធ្វើការសិក្សាវាយតម្លៃអំពីផលប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតបញ្ចូលក្នុងគម្រោងរបស់ខ្លួន ដើម្បីមានលទ្ធភាពធ្វើការដោះស្រាយផលប៉ះពាល់នោះឱ្យបានសមស្រប។

កម្មសិទ្ធិករដើឬម្ចាស់ការឬអ្នកអនុវត្តគម្រោងសាងសង់ឬជួសជុលហេដ្ឋារចនាសម្ព័ន្ធដែលអាចប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ត្រូវជូនដំណឹងមកក្រសួងទទួលបន្ទុកវិស័យទឹកស្អាត និងប្រតិបត្តិករដែលស្ថិតនៅក្នុងតំបន់ជួសជុលឬសាងសង់នោះជាលាយលក្ខណ៍អក្សរ ដោយបង្ហាញអំពីគម្រោងផែនការនៃការសាងសង់ឬជួសជុលយ៉ាងតិច៣០(សាមសិប)ថ្ងៃ មុនពេលចាប់ផ្តើមអនុវត្តគម្រោង។ បន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងនេះ ក្រសួងទទួលបន្ទុកវិស័យទឹកស្អាតឬប្រតិបត្តិករដែលមានការពាក់ព័ន្ធ ត្រូវផ្តល់ប្លង់មេនៃប្រព័ន្ធបណ្តាញផ្គត់ផ្គង់ទឹកស្អាត ឬប្រព័ន្ធប្រព្រឹត្តកម្ម ឬលក្ខខណ្ឌដទៃទៀត ដើម្បីសហការសម្របសម្រួលដោះស្រាយនិងការពារផលប៉ះពាល់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់ដែលត្រូវអនុវត្តគម្រោងទាំងនោះ ជាមួយនឹងកម្មសិទ្ធិករដើឬម្ចាស់ការឬភាគីអ្នកអនុវត្តគម្រោង និងក្រសួង ស្ថាប័នមានសមត្ថកិច្ច អាជ្ញាធរដែនដីពាក់ព័ន្ធ។

ក្នុងករណីការជួសជុលឬសាងសង់អ្វីមួយ ដែលធ្វើឱ្យខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ភាគីជួសជុលឬសាងសង់ត្រូវផ្តល់សំណងជាក់ស្តែងសមរម្យលើការខូចខាត ដើម្បីធានាដល់សេវាផ្គត់ផ្គង់ទឹកស្អាតនៅតែមាននិរន្តរភាព ស្ថិរភាព បម្រើឱ្យជីវភាពសង្គម និងសុខុមាលភាពប្រជាជន ដែលជាតម្រូវការចាំបាច់ពុំអាចខ្វះបាន។

មាត្រា២៥ .- ការគ្រប់គ្រង ការថែរក្សា និងការការពារប្រភពទឹក

ប្រតិបត្តិករ អាចប្រើប្រាស់ប្រភពទឹកទៅតាមលក្ខណៈភូមិសាស្ត្រដែលអំណោយផលនិងតាមមធ្យោបាយដែលមានស្រាប់ សម្រាប់ធ្វើប្រព្រឹត្តកម្ម។ ការប្រើប្រាស់ប្រភពទឹកនេះ ត្រូវគោរពនិងធ្វើកិច្ចសហការ ជាមួយរដ្ឋបាល

ROYAUME DU CAMBODGE LE MINISTRE DU PALAIS

ថ្នាក់ក្រោមជាតិ និង/ឬក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការគ្រប់គ្រង ថែរក្សា និងការពារប្រភពទឹក ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ក្រសួងទទួលបន្ទុកវិស័យធនធានទឹក ក្រសួង ស្ថាប័នពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវសហការគ្នាក្នុងការចាត់វិធានការថែរក្សា ការពារប្រភពទឹកសម្រាប់បម្រើឱ្យការផ្គត់ផ្គង់ទឹកស្អាត។

ជំពូកទី៨
ថ្លៃលក់ទឹកស្អាត

ផ្នែកទី១
ការកំណត់ថ្លៃលក់ទឹកស្អាត

មាត្រា២៦ .. ការកំណត់ថ្លៃលក់ទឹកស្អាត

ការកំណត់ថ្លៃលក់ទឹកស្អាត ត្រូវផ្អែកលើមូលដ្ឋានគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្ថានភាពភូមិសាស្ត្រនីមួយៗ ប្រភពទឹក ប្រព័ន្ធប្រព្រឹត្តកម្ម បច្ចេកវិទ្យា ប្រជាសាស្ត្រ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តដទៃទៀត និងត្រូវផ្អែកលើការគិតគូរច្បាស់លាស់អំពីកត្តាថ្លៃដើមផលិត សំដៅធានាបានទាំងផលប្រយោជន៍អ្នកប្រើប្រាស់ ទាំងផលប្រយោជន៍អ្នកផ្តល់សេវា ជាពិសេសសម្រួលដល់ប្រជាជនដែលមានជីវភាពខ្សត់ខ្សោយ។

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត មានសមត្ថកិច្ចកំណត់ថ្លៃលក់ទឹកស្អាត និងកែប្រែថ្លៃលក់ទឹកស្អាត តាមការចាំបាច់ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

បែបបទនិងនីតិវិធីកំណត់ថ្លៃលក់ទឹកស្អាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ផ្នែកទី២
ការកែប្រែថ្លៃលក់ទឹកស្អាត

មាត្រា២៧ .. ការពិនិត្យឡើងវិញនូវថ្លៃលក់ទឹកស្អាត

ថ្លៃលក់ទឹកស្អាតត្រូវពិនិត្យឡើងវិញរៀងរាល់៥(ប្រាំ)ឆ្នាំម្តង តាមដំណើរការដូចគ្នាទៅនឹងការកំណត់ថ្លៃលក់ទឹកស្អាតនាពេលមុនដែរ។ យោងតាមតម្រូវការចាំបាច់ណាមួយ ការកែប្រែថ្លៃលក់ទឹកស្អាតអាចធ្វើទៅបានមុនរយៈពេលកំណត់៥(ប្រាំ)ឆ្នាំ ដោយមានការពិគ្រោះយោបល់ជាមួយឬពីប្រតិបត្តិករ។

មាត្រា២៨ .. ការពិនិត្យសើរើថ្លៃលក់ទឹកស្អាតក្នុងករណីពិសេស

ក្នុងករណីពិសេស ប្រតិបត្តិករអាចស្នើសុំពិនិត្យឡើងវិញលើការកំណត់ថ្លៃលក់ទឹកស្អាត ដូចខាងក្រោម៖

- ករណីប្រធានសក្តិ
- ស្ថានភាពវិបត្តិនយោបាយ សេដ្ឋកិច្ច ហិរញ្ញវត្ថុនៅក្នុងប្រទេស
- ចលាចលជាសាធារណៈ វិវាទការងារ ឬចលាចលក្នុងវិស័យឧស្សាហកម្ម
- ក្នុងខាតឬនត្ថិភាពនៃសម្ភារៈ បរិក្ខារ កម្លាំងពលកម្ម ឬការដាក់កំហិត ឬរឹតត្បិត លើការប្រើប្រាស់សម្ភារៈ បរិក្ខារ កម្លាំងពលកម្ម
- ទាត់ទារណ៍ណាមួយ ដែលក្រុមហ៊ុនធានារ៉ាប់រងមានកេរ្តឹ៍ឈ្មោះមិនអាចផ្តល់ការធានារ៉ាប់រងបាន
- ហត្ថការណ៍ផ្សេងទៀត ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ប្រតិបត្តិការអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត អាចធ្វើការពិនិត្យឡើងវិញនូវថ្លៃលក់ទឹកស្អាតក្នុងករណីពិសេស ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ។

ជំពូកទី៩
ភាគព្វកិច្ចនិងសិទ្ធិរបស់ប្រតិបត្តិករ

ផ្នែកទី១
ភាគព្វកិច្ចរបស់ប្រតិបត្តិករ

មាត្រា២៩ .- ភាគព្វកិច្ចទូទៅ

ប្រតិបត្តិករ ត្រូវអនុវត្តតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដោយធានាឱ្យបាននូវលក្ខខណ្ឌ៤(បួន)គឺទឹកដែលមានគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ។

ប្រតិបត្តិករ មានភាតព្វកិច្ច៖

- រៀបចំផែនការផលិតកម្ម អាជីវកម្មនិងផែនការវិនិយោគរយៈពេលខ្លី មធ្យម និងវែង ដែលតម្រូវដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត
- ផ្គត់ផ្គង់ទឹកស្អាតឱ្យអស់លទ្ធភាពនិងសមត្ថភាពដែលមាន ដើម្បីបំពេញតម្រូវការប្រើប្រាស់របស់អតិថិជនដោយពុំមានការរើសអើង
- ធ្វើការដំឡើងមធ្យោបាយតភ្ជាប់សេវាផ្គត់ផ្គង់ទឹកស្អាតតាមការស្នើសុំរបស់អតិថិជនឱ្យបានទាន់ពេលវេលានិងស្របតាមផែនការដែលបានកំណត់
- គ្រប់គ្រងនិងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត
- ទទួលខុសត្រូវក្នុងការធានាគុណភាពទឹកស្អាតអនុលោមតាមបទប្បញ្ញត្តិជាធរមាន
- គោរពឱ្យបានត្រឹមត្រូវនូវគោលការណ៍កំណត់ថ្លៃលក់ទឹកស្អាតនិងអនុវត្តថ្លៃសេវាផ្សេងៗ តាមការសម្រេចរបស់ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត
- គ្រប់គ្រងកាកសំណល់ពីការផលិតទឹកស្អាតអនុលោមតាមបទប្បញ្ញត្តិច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន
- យកចិត្តទុកដាក់ចូលរួមអភិរក្ស អភិវឌ្ឍប្រភពទឹកសម្រាប់ប្រព្រឹត្តកម្មដើម្បីផលិតទឹកស្អាតដែលមានទីតាំងក្នុងមូលដ្ឋានអាជីវកម្មរបស់ខ្លួន ដើម្បីធានាបាននូវនិរន្តរភាពក្នុងការផ្គត់ផ្គង់ទឹកស្អាត
- ផ្តល់របាយការណ៍ព័ត៌មាននិងរបាយការណ៍ហិរញ្ញវត្ថុ តាមការតម្រូវរបស់ក្រសួងទទួលបន្ទុកវិស័យទឹកស្អាតនិង/ឬស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ច
- គោរពឱ្យបានម៉ឺងម៉ាត់រាល់លក្ខខណ្ឌដែលមានចែងនៅក្នុងអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតនិងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលពាក់ព័ន្ធនឹងការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត

ត្រូវផ្តល់កិច្ចសហការដល់ការធ្វើអធិការកិច្ចរបស់មន្ត្រីអធិការកិច្ចក្នុងវិស័យទឹកស្អាត។

មាត្រា៣០ .- ការគោរពតាមអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេស

ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ត្រូវមានអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា៣១ .. ការផ្តល់ទិន្នន័យនិងព័ត៌មានអំពីការផ្គត់ផ្គង់ទឹកស្អាត

ប្រតិបត្តិករ ត្រូវកត់ត្រារាល់ទិន្នន័យនិងព័ត៌មានស្តីពីស្ថានភាពផលិតកម្មនិងអាជីវកម្ម បញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ទិន្នន័យនិងព័ត៌មាន ដែលបានផ្តល់ជូនក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ពាក់ព័ន្ធនឹងហិរញ្ញវត្ថុរបស់ប្រតិបត្តិករមិនត្រូវបានបញ្ចេញផ្សព្វផ្សាយជាសាធារណៈនោះទេ លើកលែងតែមានការស្នើសុំពីសាមីប្រតិបត្តិករ ឬមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធ។

មាត្រា៣២ .. វិធានការបន្ទាន់

ប្រតិបត្តិករ ត្រូវតាមដានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនិងគុណភាពទឹកជាប្រចាំ ដើម្បីធានាថាមិនបង្កហានិភ័យដល់សុខភាពសាធារណៈ។

ក្នុងករណីប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតឬគុណភាពទឹកមានហានិភ័យដោយប្រការណាមួយ ប្រតិបត្តិករត្រូវចាត់វិធានការចាំបាច់ជាបន្ទាន់ មានជាអាទិ៍ជូនដំណឹងដល់អ្នកប្រើប្រាស់ទឹកស្អាតនៅពេលវេលាជាក់លាក់ណាមួយនៅក្នុងតំបន់ដែលមានហានិភ័យ ឱ្យត្រៀមលក្ខណៈដោះស្រាយចំពោះមុខដាបណ្តោះអាសន្ននូវកង្វះខាតទឹកស្អាត ចាត់វិធានការបង្ហូរទឹកចោល លាងសម្អាត និងកែសម្រួលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតឱ្យមានស្ថានភាពដូចប្រក្រតីឡើងវិញ។

មាត្រា៣៣ .. ការធ្វើតេស្តគុណភាពទឹក

ប្រតិបត្តិករ ត្រូវធ្វើតេស្តគុណភាពប្រភពទឹក ទឹកក្នុងប្រព័ន្ធប្រព្រឹត្តកម្ម ទឹកក្នុងប្រព័ន្ធបណ្តាញផ្គត់ផ្គង់ទឹកស្អាត និងទឹកក្នុងមជ្ឈោបាយតភ្ជាប់សេវាផ្គត់ផ្គង់ទឹកស្អាតនូវប៉ារ៉ាម៉ែត្រចាំបាច់សម្រាប់តាមដានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួន ដើម្បីធានានូវស្តង់ដាគុណភាពទឹកស្អាតស្របតាមកថាខណ្ឌទី១ នៃមាត្រា២១នៃច្បាប់នេះ។

មាត្រា៣៤ .. វិធានការរក្សាអនាម័យប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត

ប្រតិបត្តិករ ត្រូវចាត់វិធានការសម្លាប់មេរោគឬវិធានការដទៃទៀតដើម្បីរក្សាអនាម័យសម្រាប់ប្រព័ន្ធប្រព្រឹត្តកម្ម ប្រព័ន្ធបណ្តាញផ្គត់ផ្គង់ទឹកស្អាត និងមជ្ឈោបាយតភ្ជាប់សេវាផ្គត់ផ្គង់ទឹកស្អាត ស្របតាមបទប្បញ្ញត្តិបច្ចេកទេសដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ផ្នែកទី២
សិទ្ធិរបស់ប្រតិបត្តិករ

មាត្រា៣៥ .. សិទ្ធិមូលដ្ឋានរបស់ប្រតិបត្តិករ

ប្រតិបត្តិករដែលបានអនុវត្តត្រឹមត្រូវតាមច្បាប់នេះ ត្រូវបានធានានូវសិទ្ធិជាមូលដ្ឋានដូចខាងក្រោម៖

- ធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតផ្តាច់មុខក្នុងតំបន់សេវាកម្មរបស់ខ្លួន
- ទទួលបានការលើកទឹកចិត្តស្របតាមគោលនយោបាយវិនិយោគរបស់រាជរដ្ឋាភិបាល និងគោលនយោបាយដែលពាក់ព័ន្ធនឹងការគាំទ្រផ្នែកហិរញ្ញប្បទាន
- ទទួលបានសិទ្ធិគ្រប់គ្រងនិងការពារប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់សេវាកម្មរបស់ខ្លួន
- ចាត់វិធានការចាំបាច់និងសមស្របនានាក្នុងសមត្ថកិច្ចរបស់ខ្លួនដើម្បីធានាដល់ការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដូចជា ផ្អាកបណ្តោះអាសន្ន ឬកាត់ផ្តាច់ការផ្គត់ផ្គង់ទឹកស្អាតជាស្ថាពរ ចំពោះអតិថិជនដែលមិនបានទូទាត់វិក័យបត្រប្រើប្រាស់ទឹកស្អាត ឬកែច្នៃនាឡិកាទឹក ឬតបណ្តាញខាងមុខ ដែលជាការតភ្ជាប់ទឹកមុនចូលនាឡិកា ដោយពុំមានការអនុញ្ញាត រហូតដល់ពេលអតិថិជនបានទូទាត់វិក័យបត្រប្រើប្រាស់ទឹកស្អាត ឬបានកែតម្រូវនាឡិកាទឹកមកស្ថានភាពដើមវិញ ឬបានផ្លាស់ប្តូរថ្មី។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS

ផ្នែកទី៣
សមាគមអ្នកផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត

មាត្រា៣៦ .- សមាគមអ្នកផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត

ប្រតិបត្តិការ មានសិទ្ធិបង្កើតសមាគមអ្នកផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ បន្ទាប់ពីបានចុះបញ្ជីរួចហើយ សមាគមនេះត្រូវតម្កល់ច្បាប់ថតចម្លងនៃប្រកាសស្តីពីការចុះបញ្ជីសមាគមនិងលក្ខន្តិកៈមួយច្បាប់នៅក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

សមាជិកភាពនៅក្នុងសមាគមអ្នកផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ត្រូវធ្វើឡើងដោយការស្ម័គ្រចិត្តនិងត្រូវបើកចំហសម្រាប់នីតិបុគ្គលសាធារណៈ សហគ្រាសសាធារណៈ ឬឯកជន និងបុគ្គលទាំងឡាយណាដែលមានចំណេះដឹងឬបទពិសោធពាក់ព័ន្ធនឹងវិស័យផ្គត់ផ្គង់ទឹកស្អាត ដោយអនុលោមតាមលក្ខន្តិកៈរបស់សមាគម។

សមាគមអ្នកផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត គឺជាដៃគូសហប្រតិបត្តិការជាមួយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ក្នុងការជំរុញនិងអភិវឌ្ឍន៍វិស័យផ្គត់ផ្គង់ទឹកស្អាត។

ជំពូកទី១០
ការគ្រប់គ្រង ការត្រួតពិនិត្យប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងសមត្ថកិច្ចមន្ត្រីអធិការកិច្ច

មាត្រា៣៧ .- ការគ្រប់គ្រងនិងការត្រួតពិនិត្យ

ប្រតិបត្តិការ ត្រូវរៀបចំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតឱ្យមានអនុលោមភាពតាមការតម្រូវចំពោះគុណភាព បរិមាណនិងសម្ពាធទឹកតាមស្ថានភាពភូមិសាស្ត្រ ចាប់ពីប្រភពទឹក ប្រព័ន្ធប្រព្រឹត្តកម្ម រហូតដល់មធ្យោបាយតភ្ជាប់សេវាផ្គត់ផ្គង់ទឹកស្អាត ស្របតាមបទប្បញ្ញត្តិបច្ចេកទេសដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ត្រូវចេញបញ្ជាជាលាយលក្ខណ៍អក្សរឱ្យប្រតិបត្តិការ ត្រូវធ្វើការកែតម្រូវប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ឬផ្លាស់ប្តូរអ្នកគ្រប់គ្រងបច្ចេកទេស ដើម្បីការពារសុខភាពសាធារណៈ ក្នុងករណីរកឃើញថាប្រព័ន្ធនេះមិនមានអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសដូចមានចែងក្នុងច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬអ្នកគ្រប់គ្រងបច្ចេកទេសផ្គត់ផ្គង់ទឹកស្អាតមានកំហុសក្នុងការអនុវត្តការងារ និងបញ្ញត្តិ ឬសេចក្តីណែនាំទាំងឡាយដែលបានដាក់ចេញដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

មាត្រា៣៨ .- ការតែងតាំងមន្ត្រីអធិការកិច្ច

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត តែងតាំងមន្ត្រីអធិការកិច្ច ដើម្បីចុះតាមដាន អង្កេត ស្រាវជ្រាវត្រួតពិនិត្យ ប្រមូលភស្តុតាង និងជំរុញការអនុវត្តច្បាប់នេះ។

មន្ត្រីអធិការកិច្ច ត្រូវទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើស ដូចមានចែងក្នុងច្បាប់នេះស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

មន្ត្រីអធិការកិច្ច អាចចុះពិនិត្យប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតគ្រប់ពេលវេលា។

ក្នុងប្រតិបត្តិការពិនិត្យបទល្មើស មន្ត្រីអធិការកិច្ចត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងអាចស្នើសុំ[illegible]ដែនដីគ្រប់លំដាប់ថ្នាក់និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត[illegible]បទល្មើសដូចមានចែងក្នុងច្បាប់នេះ។

[illegible]ប្រតិបត្តិការអនុវត្តច្បាប់នេះ មន្ត្រីអធិការកិច្ចត្រូវស្លៀកពាក់ឯកសណ្ឋាននិងត្រូវមានលិខិត[illegible]

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ច ត្រូវកំណត់ដោយអនុក្រឹត្យ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ច ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

មាត្រា៣៩ .- សិទ្ធិអំណាចរបស់មន្ត្រីអធិការកិច្ច

មន្ត្រីអធិការកិច្ចមានសិទ្ធិដូចតទៅ៖

(ក) ចូលទៅក្នុងបរិវេណទីតាំងធ្វើអាជីវកម្មទឹកស្អាតរបស់ប្រតិបត្តិករ ដោយបង្ហាញលិខិតបញ្ជាបេសកកម្ម ដែលចេញដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាតដើម្បី៖

- ពិនិត្យនិងយកសំណាកទឹកនិងវត្ថុធាតុដើម ឬសារធាតុផ្សេងៗ ដែលយកមកប្រើប្រាស់ក្នុងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត
- ត្រួតពិនិត្យការអនុវត្តលក្ខខណ្ឌបច្ចេកទេសនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត
- ត្រួតពិនិត្យថ្លៃលក់ទឹកស្អាតនិងគុណភាពសេវាផ្គត់ផ្គង់ទឹកស្អាត មានជាអាទិ៍សម្ពាធទឹក បរិមាណទឹក រយៈពេលនៃការផ្គត់ផ្គង់
- ត្រួតពិនិត្យលើប្រព័ន្ធប្រព្រឹត្តកម្ម ប្រព័ន្ធបណ្តាញផ្គត់ផ្គង់ទឹកស្អាត និងការបញ្ចេញកាកសំណល់។

(ខ) តាមដាន ស្រាវជ្រាវលើឧបករណ៍ឬសារធាតុគីមី ដោយបិទស្លាក បោះត្រា លើវត្ថុតាងបទល្មើស ឬចាត់វិធានការចាំបាច់នានា ក្នុងករណីដែលសង្ស័យថាមានអំពើល្មើសនឹងច្បាប់នេះ។

(គ) តម្រូវឱ្យប្រតិបត្តិករផ្តល់ព័ត៌មានឬបង្ហាញអាជ្ញាបណ្ណអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតនិងវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត ព្រមទាំងឯកសារពាក់ព័ន្ធនឹងអាជីវកម្មរបស់ខ្លួន។

(ឃ) អញ្ជើញបុគ្គលពាក់ព័ន្ធ មកផ្តល់ព័ត៌មាន ការបំភ្លឺ ឯកសារ ឬវត្ថុផ្សេងៗ ដើម្បីធ្វើការស្រាវជ្រាវ។

(ង) ចាត់វិធានការផ្អាកជាបណ្តោះអាសន្នការផ្គត់ផ្គង់ទឹកស្អាត ដែលបានស្រាវជ្រាវឃើញថាមានកស្តុតាងបង្ហាញថាមិនមានអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេស និងបង្កហានិភ័យក្នុងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ឬបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ រុក្ខជាតិ បរិស្ថាន និងសន្តិសុខសង្គម រួចហើយរាយការណ៍យ៉ាងឆាប់តាមដែលអាចធ្វើបាន ជូនក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចាត់វិធានការបន្តតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។

(ច) លើកសំណើជូនរដ្ឋមន្ត្រីទទួលបន្ទុកវិស័យទឹកស្អាតដើម្បីស្នើសុំគោលការណ៍ ព្យួរ ដកហូត ឬលុបវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត អាជ្ញាបណ្ណអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ឬឯកសារពាក់ព័ន្ធក្នុងករណីដែលប្រតិបត្តិករប្រព្រឹត្តល្មើសនឹងច្បាប់នេះ។

(ឆ) អនុវត្តការពិន័យអន្តរការណ៍ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

(ជ) បំពេញភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

បែបបទ និងនីតិវិធីសម្រាប់ធ្វើអធិការកិច្ចក្នុងវិស័យទឹកស្អាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ជំពូកទី១១
វិធានការក្នុងគ្រាអាសន្ន

មាត្រា៤០.- ស្ថានភាពដែលជាគ្រាអាសន្ន

ស្ថានភាពដែលចាត់ទុកជាគ្រាអាសន្នអនុលោមតាមច្បាប់នេះមានដូចជា៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS *

- ការផ្គត់ផ្គង់ទឹកស្អាតមិនបានគ្រប់គ្រាន់ដោយសារបញ្ហាប្រធានសក្តិ ដូចជាគ្រោះរាំងស្ងួត ឬទឹកជំនន់ធ្ងន់ធ្ងរ
- ការផ្គត់ផ្គង់ទឹកស្អាតមិនបានគ្រប់គ្រាន់ដោយសារចលាចលក្នុងវិស័យឧស្សាហកម្មឬក្នុងសង្គម បាតុកម្ម កូដកម្ម ឬការផ្អាកសហគ្រាសជាបណ្តោះអាសន្ន
- ការផ្គត់ផ្គង់ទឹកស្អាតឬប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតធ្វើឱ្យប៉ះពាល់ឬគំរាមកំហែងដល់សុវត្ថិភាពរបស់សាធារណជន ឬសុខភាពសាធារណៈ
- ការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន។

មាត្រា៤១ .- ទិដ្ឋានការក្នុងគ្រាអាសន្ន

ក្នុងករណីមានគ្រាអាសន្ន ក្រសួងទទួលបន្ទុកវិស័យទឹកស្អាតនិងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចាត់វិធានការនិងដាក់ចេញនូវគោលការណ៍ណែនាំដើម្បីគ្រប់គ្រងគ្រាអាសន្នទាំងនោះ។

ប្រតិបត្តិករ ត្រូវគោរពតាមការកំណត់និងការណែនាំទាំងឡាយរបស់ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ដើម្បីគ្រប់គ្រងស្ថានការណ៍នៃការផ្គត់ផ្គង់ទឹកស្អាត។

ជំពូកទី១២
ការដោះស្រាយវិវាទ

មាត្រា៤២ .- ការប្តឹងតវ៉ាចំពោះសេចក្តីសម្រេចបដិសេធរបស់ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត

បុគ្គលដែលមិនសុខចិត្តចំពោះការបដិសេធមិនផ្តល់លិខិតអនុញ្ញាតសិក្សាសមិទ្ធិលទ្ធភាព អាជ្ញាបណ្ណ វិញ្ញាបនបត្រអនុញ្ញាតដំណើរការ ឬការស្នើសុំពង្រីកតំបន់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត មានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីការបដិសេធនោះទៅក្រសួងទទួលបន្ទុកវិស័យទឹកស្អាត មុននឹងប្តឹងទៅតុលាការ។

រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានបណ្តឹងតវ៉ា។

ក្នុងករណីដែលមានបុគ្គលណាមួយមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត បុគ្គលនោះមានសិទ្ធិប្តឹងតវ៉ាទៅតុលាការតាមនីតិវិធីក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃគិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាតមិនសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្តឹងអាចប្តឹងទៅតុលាការក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់នោះ។

មាត្រា៤៣ .- ការប្តឹងតវ៉ាចំពោះសេចក្តីសម្រេចជាទណ្ឌកម្មរដ្ឋបាល

បុគ្គលដែលមិនសុខចិត្តចំពោះការព្យួរ ដកហូត ឬលុបលិខិតអនុញ្ញាតផ្តល់សិទ្ធិសិក្សាសមិទ្ធិលទ្ធភាព អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត វិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត ឬអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីការព្យួរ ដកហូត ឬលុបនោះ ទៅក្រសួងទទួលបន្ទុកវិស័យទឹកស្អាត មុននឹងប្តឹងទៅតុលាការ

រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានបណ្តឹងតវ៉ា។

ក្នុងករណីដែលមានបុគ្គលណាមួយមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត បុគ្គលនោះមានសិទ្ធិប្តឹងតវ៉ាទៅតុលាការគាមនីតិវិធីជាធរមានក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាតមិនសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្តឹងអាចប្តឹងទៅតុលាការក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់នោះ។

មាត្រា៤៤ .- ការប្តឹងតវ៉ាចំពោះវិធានការរដ្ឋបាលរបស់មន្ត្រីអធិការកិច្ច

បុគ្គលដែលមិនសុខចិត្តចំពោះវិធានការរដ្ឋបាលណាមួយរបស់មន្ត្រីអធិការកិច្ច អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរ ទៅក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួល លិខិតជូនដំណឹងអំពីវិធានការនោះ។

រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ត្រូវចេញសេចក្តីសម្រេចលើបណ្តឹងតវ៉ាដោយបញ្ជាក់អំពីមូលហេតុ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានបណ្តឹងតវ៉ា។

ក្នុងករណីដែលមានបុគ្គលណាមួយមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត បុគ្គលនោះមានសិទ្ធិប្តឹងតវ៉ាទៅតុលាការគាមនីតិវិធីជាធរមានក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ យ៉ាងយូរគិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាតមិនសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្តឹងអាចប្តឹងទៅតុលាការក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់នោះ។

មាត្រា៤៥ .- ការសម្រុះសម្រួលវិវាទរវាងប្រតិបត្តិករនិងប្រតិបត្តិករ

រាល់វិវាទរវាងប្រតិបត្តិកនិងប្រតិបត្តិកពាក់ព័ន្ធនឹងអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ភាគីវិវាទអាចប្តឹងមកក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ដើម្បីធ្វើការសម្រុះសម្រួលមុននឹងប្តឹងទៅមជ្ឈមណ្ឌលមជ្ឈត្តការ ឬតុលាការមានសមត្ថកិច្ច លើកលែងតែករណីវិវាទពាក់ព័ន្ធនឹងដែននៃតំបន់សេវាផ្គត់ផ្គង់ទឹកស្អាត ដែលភាគីវិវាទត្រូវប្តឹងមកក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ក្នុងករណីមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ក្រសួងទទួលបន្ទុកវិស័យទឹកស្អាតពាក់ព័ន្ធនឹងដែននៃតំបន់សេវាផ្គត់ផ្គង់ទឹកស្អាត ភាគីវិវាទអាចប្តឹងទៅតុលាការមានសមត្ថកិច្ចតាមនីតិវិធីជាធរមាន ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរបន្ទាប់ពីបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនេះ។

មាត្រា៤៦ .- វិវាទរវាងប្រតិបត្តិកនិងអ្នកប្រើប្រាស់ទឹកស្អាត

ក្នុងករណីប្រតិបត្តិកឬអ្នកប្រើប្រាស់ទឹកស្អាតមានវិវាទនឹងគ្នា ចំពោះការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ឬការប្រើប្រាស់ទឹកស្អាត ភាគីវិវាទអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រសួងទទួលបន្ទុកវិស័យទឹកស្អាតឬមន្ទីរទទួលបន្ទុកវិស័យទឹកស្អាតរាជធានី ខេត្ត។

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាតឬមន្ទីរទទួលបន្ទុកវិស័យទឹកស្អាតរាជធានី ខេត្ត ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលបណ្តឹងតវ៉ា។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៥៩

ក្នុងករណីដែលមានបុគ្គលណាមួយមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់មន្ទីរទទួលបន្ទុកវិស័យទឹកស្អាតរាជធានី ខេត្ត មានសិទ្ធិប្តឹងទៅក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ។ ក្នុងករណីនេះ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាតត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលបណ្តឹងតវ៉ា។

បុគ្គលដែលមិនសុខចិត្តចំពោះសេចក្តីសម្រេចលើបណ្តឹងតវ៉ា មានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីជាធរមានក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃគិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាតមិនសម្រេចលើបណ្តឹងតវ៉ានោះក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌទី២ខាងលើ ម្ចាស់បណ្តឹងអាចប្តឹងទៅតុលាការតាមនីតិវិធីជាធរមានក្នុង៦០(ហុកសិប)ថ្ងៃគិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

ជំពូកទី១៣
ទោសប្បញ្ញត្តិ

មាត្រា៤៧ .- ប្រភេទទណ្ឌកម្ម

ទណ្ឌកម្មនៅក្នុងច្បាប់នេះ រួមមានទណ្ឌកម្មរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌ។

ទណ្ឌកម្មរដ្ឋបាលរួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការព្យួរ ការដកហូត ការលុបលិខិតអនុញ្ញាតផ្តល់សិទ្ធិសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ឬវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត។ ក្នុងករណីមានការព្យួរ ការដកហូត ការលុបអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ត្រូវចាត់វិធានការនានាដើម្បីធានានិរន្តរភាពនៃការផ្គត់ផ្គង់ទឹកស្អាត។

អំពើដែលត្រូវទទួលរងទណ្ឌកម្មរដ្ឋបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល ជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ទណ្ឌកម្មព្រហ្មទណ្ឌរួមមាន៖

- ពិន័យអន្តរការណ៍
- ពិន័យជាប្រាក់
- ទោសដាក់ពន្ធនាគារ។

បទល្មើសផ្សេងទៀតដែលត្រូវពិន័យអន្តរការណ៍ស្របតាមច្បាប់នេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

ការសម្រេចដាក់ពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចក្នុងវិស័យទឹកស្អាតដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌។

ការបង់ប្រាក់ពិន័យអន្តរការណ៍ នាំឱ្យរំលត់បណ្តឹងអាជ្ញា។

ការសម្រេចដាក់ពិន័យអន្តរការណ៍មិននាំឱ្យរួចផុតពីកាតព្វកិច្ចអនុវត្តវិធានការរដ្ឋបាល និងទណ្ឌកម្មរដ្ឋបាលដែលបានដាក់ចេញស្របតាមច្បាប់នេះឡើយ។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីអធិការកិច្ចក្នុងវិស័យទឹកស្អាតដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការមានសមត្ថកិច្ច។

បែបបទនិងនីតិវិធីនៃការពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាតនិងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ការបង់ប្រាក់ពិន័យអន្តរការណ៍ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យអន្តរការណ៍ និងការចាត់ចែងប្រាក់ចំណូលដែលបានពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសដូចមានចែង ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាតនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

រាជរដ្ឋាភិបាល អាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលបានចូលរួមក្នុងការបង្ក្រាបបទល្មើសក្នុងវិស័យទឹកស្អាត។

មាត្រា៤៨ .- ការសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដោយគ្មានការអនុញ្ញាត

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ៥ ០០០ ០០០(ប្រាំលាន)រៀល ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាដែលធ្វើការសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដោយគ្មានលិខិតអនុញ្ញាតផ្តល់សិទ្ធិសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតពីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

មាត្រា៤៩ .- ការពិន័យអន្តរការណ៍ចំពោះរូបវន្តបុគ្គល

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ៥ ០០០ ០០០(ប្រាំលាន)រៀល ចំពោះប្រតិបត្តិករធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតជារូបវន្តបុគ្គល ដែលប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

១- ដំណើរការអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដោយប្រើប្រាស់អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតហួសសុពលភាព ដូចមានចែងក្នុងកថាខណ្ឌទី១ មាត្រា១៣ នៃច្បាប់នេះ។

២- ធ្វើអាជីវកម្មដោយប្រើប្រាស់វិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាតហួសសុពលភាព ដូចមានចែងក្នុងកថាខណ្ឌទី១ មាត្រា១៧ នៃច្បាប់នេះ។

៣- ការផ្គត់ផ្គង់ទឹកស្អាតដោយមិនអនុលោមតាមស្តង់ដាកម្ពុជាសម្រាប់ការតម្រូវគុណភាព និងសុវត្ថិភាពទឹកស្អាត ដូចមានចែងក្នុងកថាខណ្ឌទី១ មាត្រា២១ នៃច្បាប់នេះ។

៤- ការមិនបានកត់ត្រារាល់ទិន្នន័យនិងព័ត៌មានស្តីពីស្ថានភាពផលិតកម្មនិងអាជីវកម្មឱ្យបានត្រឹមត្រូវបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ដូចមានចែងក្នុងកថាខណ្ឌទី១ មាត្រា៣១ នៃច្បាប់នេះ។

៥- ការមិនបានធ្វើតេស្តគុណភាពប្រភពទឹក ទឹកក្នុងប្រព័ន្ធប្រព្រឹត្តកម្ម ទឹកក្នុងប្រព័ន្ធបណ្តាញផ្គត់ផ្គង់ទឹកស្អាត និងទឹកក្នុងមធ្យោបាយតភ្ជាប់សេវាផ្គត់ផ្គង់ទឹកស្អាតនូវប៉ារ៉ាម៉ែត្រចាំបាច់សម្រាប់តាមដានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួន តាមពេលវេលាដែលតម្រូវតាមស្តង់ដា និងតាមការកំណត់របស់ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ដូចមានចែងក្នុងមាត្រា៣៣ នៃច្បាប់នេះ។



៦- ការខកខានក្នុងការចាត់វិធានការសម្លាប់មេរោគ ឬវិធានការអនាម័យក្នុងប្រព័ន្ធប្រព្រឹត្តកម្ម ប្រព័ន្ធបណ្តាញផ្គត់ផ្គង់ទឹកស្អាត និងមធ្យោបាយតភ្ជាប់សេវាផ្គត់ផ្គង់ទឹកស្អាត ដូចមានចែងក្នុងមាត្រា៣៤ នៃច្បាប់នេះ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៦១

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី៥ ០០០ ០០០(ប្រាំលាន)រៀល ទៅ១០ ០០០ ០០០(ដប់លាន)រៀល ចំពោះប្រតិបត្តិការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតជារូបវន្តបុគ្គល ដែលប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

១_ ការផ្ទេរ ការលក់ ការជួល និងការដាក់ប្រាតិភោគនូវអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដោយគ្មានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ដូចមានចែងក្នុងកថាខណ្ឌទី១ មាត្រា១៤ នៃច្បាប់នេះ។

២_ ការឱ្យតតិយជនណាម្នាក់បំពេញមុខងារជំនួសខ្លួននូវផ្នែកទាំងអស់ ឬផ្នែកខ្លះនៃការងារបច្ចេកទេស ដែលពាក់ព័ន្ធនឹងសេវាផ្គត់ផ្គង់ទឹកស្អាត ដោយគ្មានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ដូចមានចែងក្នុងកថាខណ្ឌទី១ មាត្រា១៥ នៃច្បាប់នេះ។

៣_ ការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដោយគ្មានវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត ដូចមានចែងក្នុងកថាខណ្ឌទី១ មាត្រា១៦ នៃច្បាប់នេះ។

៤_ ការពង្រីកតំបន់សេវាកម្មដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា១៩ នៃច្បាប់នេះ។

៥_ ការមិនមានមន្ទីរពិសោធន៍ឬឧបករណ៍ធ្វើតេស្តត្រួតពិនិត្យគុណភាពទឹកតាមការកំណត់របស់ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ដូចមានចែងក្នុងកថាខណ្ឌទី១ មាត្រា២២ នៃច្បាប់នេះ។

៦_ ការលក់ទឹកស្អាតខុសពីថ្លៃដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

៧_ ការរៀបចំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស ដូចមានចែងក្នុងមាត្រា៣០ នៃច្បាប់នេះ។

៨_ ផ្តល់ទិន្នន័យនិងព័ត៌មានមកក្រសួងទទួលបន្ទុកវិស័យទឹកស្អាតឬមន្ត្រីមានសមត្ថកិច្ច ដោយខ្លួនដឹងថាព័ត៌មាននេះមិនត្រឹមត្រូវឬក្នុងហេតុផលក្លែងបន្លំទិន្នន័យនិងព័ត៌មាន។

៩_ ការខកខានក្នុងការចាត់វិធានការបន្ទាន់ ដូចមានចែងក្នុងមាត្រា៣២ នៃច្បាប់នេះ។

១០_ ការមិនអនុវត្តតាមការបញ្ជាជាលាយលក្ខណ៍អក្សរឱ្យធ្វើការកែតម្រូវប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ឬផ្លាស់ប្តូរអ្នកគ្រប់គ្រងបច្ចេកទេស ដូចមានចែងក្នុងកថាខណ្ឌទី២ នៃមាត្រា៣៧ នៃច្បាប់នេះ។

១១_ ការមិនគោរពតាមវិធានការក្នុងគ្រាអាសន្នដូចមានចែងក្នុងកថាខណ្ឌទី២ មាត្រា៤១ នៃច្បាប់នេះ។

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត អាចសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលបន្ថែមដូចមានចែងក្នុងច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តស្របតាមច្បាប់នេះ ចំពោះរូបវន្តបុគ្គលដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃមាត្រានេះ។

មាត្រា៥០ _ ការពិន័យអន្តរការណ៍ចំពោះនីតិបុគ្គល

ចំពោះប្រតិបត្តិការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតជានីតិបុគ្គលដែលប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ មាត្រា៤៩ នៃច្បាប់នេះ ប្រាក់ពិន័យអន្តរការណ៍ត្រូវកើនឡើងទ្វេដង។

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត អាចសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលបន្ថែមដូចមានចែងក្នុងច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តស្របតាមច្បាប់នេះ ចំពោះនីតិបុគ្គលដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ មាត្រា៤៩ នៃច្បាប់នេះ។

មាត្រា៥១ _ ការមិនបានជូនដំណឹងអំពីផលប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល ចំពោះបុរន្ទបុគ្គលឬនីតិបុគ្គលឯកជន ជាកម្មសិទ្ធិការនៃដីឬម្ចាស់ការឬអ្នកអនុវត្តគម្រោង សាងសង់ឬជួសជុលបៃតង ឬហេដ្ឋារចនាសម្ព័ន្ធនានា ដោយមិនបានជូនដំណឹងជាមុនមកក្រសួងទទួលបន្ទុកវិស័យទឹកស្អាត និង

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ប្រតិបត្តិការដែលស្ថិតក្នុងតំបន់សាងសង់ឬជួសជុល អំពីគម្រោងសាងសង់ឬជួសជុលនេះ ស្របតាមកថាខណ្ឌទី២ មាត្រា២៤ នៃច្បាប់នេះ ក្នុងករណីដែលបានដឹងថាការអនុវត្តគម្រោងនេះនាំឱ្យមានផលប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។

មាត្រា៥២ .- ករណីដែលអំពើល្មើសត្រូវបានប្រព្រឹត្តម្តងទៀត

បុគ្គលដែលត្រូវបានសម្រេចឱ្យបង់ប្រាក់ពិន័យអន្តរការណ៍ដូចមានចែងពីមាត្រា៤៨ ដល់មាត្រា៥១ នៃច្បាប់នេះរួចហើយ ហើយបុគ្គលនោះបានប្រព្រឹត្តអំពើល្មើសដដែលម្តងទៀត ប្រាក់ពិន័យអន្តរការណ៍ត្រូវកើនឡើងទ្វេដង។

មាត្រា៥៣ .- ការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដោយគ្មានអាជ្ញាបណ្ណ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៣(បី)ខែ ទៅ១(មួយ)ឆ្នាំនិងពិន័យជាប្រាក់ពី៥ ០០០ ០០០(ប្រាំលាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល ចំពោះបុគ្គលដែលធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដោយគ្មានអាជ្ញាបណ្ណពីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

មាត្រា៥៤ .- ការមិនគោរពតាមស្តង់ដាគុណភាពទឹកស្អាត

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំនិងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះប្រតិបត្តិការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដោយមិនអនុលោមតាមស្តង់ដាកម្ពុជា សម្រាប់ការតម្រូវគុណភាពនិងសុវត្ថិភាពទឹកស្អាត ហើយបង្កឱ្យមានផលប៉ះពាល់ដល់សុខភាពអ្នកប្រើប្រាស់។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៤០ ០០០ ០០០(សែសិបលាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល កាលបើអំពើដែលមានចែងក្នុងកថាខណ្ឌទី១ខាងលើ បង្កឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពអ្នកប្រើប្រាស់។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ)ឆ្នាំ ទៅ១៥(ដប់ប្រាំ)ឆ្នាំ កាលបើអំពើដែលមានចែងក្នុងកថាខណ្ឌទី១ខាងលើ បង្កឱ្យបាត់បង់អាយុជីវិតអ្នកប្រើប្រាស់។

មាត្រា៥៥ .- ការធ្វើឱ្យខូចខាតដោយចេតនានូវប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំនិងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះបុគ្គលដែលធ្វើឱ្យខូចខាតដោយចេតនានូវផ្នែកណាមួយនៃហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។

មាត្រា៥៦ .- ការយកទឹកដើម្បីប្រើប្រាស់ឬចែកចាយបន្តដោយគ្មានការអនុញ្ញាត

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ៣(បី)ឆ្នាំនិងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ៦០ ០០០ ០០០(ហុកសិបលាន)រៀល ចំពោះបុគ្គលដែលយកទឹកពីប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតតាមគ្រប់មធ្យោបាយ ដើម្បីប្រើប្រាស់ឬចែកចាយបន្ត ដោយគ្មានការអនុញ្ញាតជាមុនពីប្រតិបត្តិការ។

មាត្រា៥៧ .- ការកែច្នៃឬផ្លាស់ប្តូរនាឡិកាទឹកដោយគ្មានការអនុញ្ញាត

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ៦(ប្រាំមួយ)ខែនិងពិន័យជាប្រាក់ពី២ ០០០ ០០០(ប្រាំលាន)រៀល ទៅ១០ ០០០ ០០០(ដប់លាន)រៀល ចំពោះបុគ្គលដែលធ្វើការកែច្នៃ ឬផ្លាស់ប្តូរនាឡិកាទឹកបេស្សរ្យតិបត្តិការ ដោយគ្មានការអនុញ្ញាតជាមុនពីប្រតិបត្តិការ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

មាត្រា៥៨ .. ការបំពុលទឹក

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំនិងពិន័យជាប្រាក់ពី១០ ០០០ ០០០ (ដប់លាន)រៀល ទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះបុគ្គលដែលមានចេតនាប្រើប្រាស់សារធាតុណាមួយដើម្បីបំពុលទឹកក្នុងប្រភពទឹក ឬក្នុងផ្នែកណាមួយនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំនិងពិន័យជាប្រាក់ពី៤០ ០០០ ០០០ (សែសិបលាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល កាលបើអំពើដែលមានចែងក្នុងកថាខណ្ឌទី១ខាងលើ បង្កឱ្យប៉ះពាល់សុខភាពអ្នកប្រើប្រាស់។ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំ ទៅ១០(ដប់)ឆ្នាំ ក្នុងករណីដែលការប្រព្រឹត្តអំពើនេះធ្វើឡើងដោយក្រុមមានការចាត់តាំង។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ)ឆ្នាំ ទៅ១៥(ដប់ប្រាំ)ឆ្នាំ កាលបើអំពើដែលមានចែងក្នុងកថាខណ្ឌទី១ខាងលើ បង្កឱ្យបាត់បង់អាយុជីវិតអ្នកប្រើប្រាស់។ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥(ដប់ប្រាំ)ឆ្នាំ ទៅ៣០(សាមសិប)ឆ្នាំ ក្នុងករណីដែលការប្រព្រឹត្តអំពើនេះធ្វើឡើងដោយក្រុមមានការចាត់តាំង។

មាត្រា៥៩ .. ទណ្ឌកម្មចំពោះនីតិបុគ្គល

នីតិបុគ្គលអាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងចាប់ពីមាត្រា៥៣ ដល់មាត្រា៥៨ នៃច្បាប់នេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ទ្វេដង ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

មាត្រា៦០ .. បទល្មើសប្រព្រឹត្តដោយមន្ត្រីអធិការកិច្ច

មន្ត្រីអធិការកិច្ច ដែលប្រើប្រាស់សិទ្ធិអំណាចដោយរំលោភបំពានខុសពីគោលបំណងនៃច្បាប់នេះ បណ្តាលឱ្យប៉ះពាល់ដល់សិទ្ធិ បូរណភាពរូបរាងកាយ ឬធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃ ត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។

មន្ត្រីអធិការកិច្ចដែលប្រព្រឹត្តកំហុស ក្នុងការអនុវត្តមុខងាររបស់ខ្លួន ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយពុំគិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

មាត្រា៦១ .. ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត

ការអនុវត្តបទប្បញ្ញត្តិនៃជំពូកទី១៣ នៃច្បាប់នេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀតក្នុងករណីដែលអំពើដែលកំណត់ថាជាបទល្មើសដែលមានចែងក្នុងច្បាប់នេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

ជំពូកទី១៤
អន្តរប្បញ្ញត្តិ

មាត្រា៦២ .. ដំណាក់កាលអន្តរកាលសម្រាប់បុគ្គលដែលគ្មានអាជ្ញាបណ្ណ

ការអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ បុគ្គលដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដែលគ្មានអាជ្ញាបណ្ណ ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណក្នុងរយៈពេល៣(បី)ខែបន្ទាប់ពីទទួលបានលិខិតបញ្ជាក់ពីក្រសួងទទួលបន្ទុកវិស័យទឹកស្អាតឬអង្គភាពដែលទទួលបានប្រតិភូកម្មពីក្រសួងទទួលបន្ទុកវិស័យ

មាត្រា៦៣ .- ការបន្តសុពលភាពអាជ្ញាបណ្ណដែលមានស្រាប់

សុពលភាពនៃអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដែលទទួលបានមុនច្បាប់នេះចូលជាធរមាន ត្រូវបន្តរហូតដល់ពេលផុតកំណត់សុពលភាពអាជ្ញាបណ្ណ។ ក្នុងរយៈពេល៣(បី)ខែមុនពេលផុតកំណត់សុពលភាពអាជ្ញាបណ្ណ អ្នកកាន់អាជ្ញាបណ្ណត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណថ្មីជំនួសឱ្យអាជ្ញាបណ្ណចាស់ដែលត្រូវអស់សុពលភាពដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

មាត្រា៦៤ .- ការបន្តអនុភាពអនុវត្តនៃលិខិតបទដ្ឋានគតិយុត្តជាធរមាន

លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការគ្រប់គ្រងទឹកស្អាតនិងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ជំពូកទី១៥
អវសានប្បញ្ញត្តិ

មាត្រា៦៥ .- និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

ថ្ងៃ សៅរ៍ ៥កើត ខែ ដំរីស្រី ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០២៣

ក្នុងព្រះបរមនាមនិងតាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

សម្តេចវិបុលសេនាភក្តី សាយ ឈុំ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមទ្រង់ព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីអភិសិរីវុទ្ធា ហ៊ុន សែន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីតំណាងព្រះអង្គម្ចាស់អមរាជគណៈរដ្ឋមន្ត្រី

អភិឆ្ពនីតិកោសលបណ្ឌិត ប៊ិន ឈិន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

កិត្តិសង្គហបណ្ឌិត ចម ប្រសិទ្ធ

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៦៥

ឧបសម្ព័ន្ធនៃច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត

សទ្ទានុក្រម

១- **ការពង្រីកតំបន់សេវាកម្ម** សំដៅដល់ការបង្កើនប្រព័ន្ធបណ្តាញផ្គត់ផ្គង់ទឹកស្អាតទៅខាងក្រៅតំបន់សេវាកម្ម ដែលខ្លួនកំពុងធ្វើការផ្គត់ផ្គង់ទឹកស្អាត។

២- **ការសិក្សាសមិទ្ធិលទ្ធភាព** សំដៅដល់ការសិក្សាពីកត្តាភូមិសាស្ត្រ ប្រជាសាស្ត្រ ប្រភពទឹក បច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីបង្ហាញពីលទ្ធភាពនៃការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់ណាមួយជាក់លាក់។

៣- **តំបន់សេវាកម្ម** សំដៅដល់តំបន់មួយដែលត្រូវបានកំណត់តាមបែបភូមិសាស្ត្រ ដែលនៅក្នុងតំបន់នោះ ប្រតិបត្តិករមានសិទ្ធិផ្តាច់មុខក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតជូនអតិថិជន ដោយអនុលោមតាមលក្ខខណ្ឌរបស់អាជ្ញាបណ្ណដែលត្រូវបានផ្តល់ដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

៤- **ថ្លៃលក់ទឹកស្អាត** សំដៅដល់ចំនួនជាប្រាក់រៀល ដែលបានអនុញ្ញាតឱ្យប្រតិបត្តិការប្រមូលយកពីអតិថិជនរបស់ខ្លួន សម្រាប់ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតក្នុងឯកតាមួយម៉ែត្រគូបណា ស្មើនឹង១០០០(មួយពាន់)លីត្រ។

៥- **ថ្លៃសេវាផ្សេងៗ** សំដៅដល់ថ្លៃដែលប្រតិបត្តិការប្រមូលពីអតិថិជន បន្ថែមពីលើថ្លៃលក់ទឹកស្អាត ដោយអនុលោមតាមកិច្ចព្រមព្រៀងដាវទឹក ដែលអាចរួមបញ្ចូលថ្លៃភ្ជាប់បណ្តាញ ថ្លៃផ្តាច់និងភ្ជាប់បណ្តាញឡើងវិញ ថ្លៃជួសជុល ថ្លៃពិន័យលើការទូទាត់យឺត ឬថ្លៃផ្សេងទៀតដែលត្រូវបានអនុញ្ញាតតាមច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៦- **ទឹកឆៅ** សំដៅដល់ទឹកដែលបានមកពីប្រភពទឹកនានាដែលពុំទាន់បានឆ្លងកាត់ការធ្វើប្រព្រឹត្តកម្ម។

៧- **ទឹកស្អាត** សំដៅដល់ទឹកដែលបានឆ្លងកាត់ការធ្វើប្រព្រឹត្តកម្ម ហើយមានគុណភាព សុវត្ថិភាព និងអាចផ្គត់ផ្គង់បានដល់អតិថិជន។

៨- **ប្រភពទឹក** សំដៅដល់ទឹកលើដី ដែលរួមមានសមុទ្រ ទន្លេ ស្ទឹង ព្រែក ជ្រោះ ជ្រលងដងអូរ ប្រឡាយ បឹងបួ គ្រពាំង ស្រះ ថ្លុក អាងទឹក ទឹកក្រោមដីដែលហូរនៅក្រោមដីក្នុងចន្លោះថ្មគួច ធំ និងភាគល្អិតនៃដីដែលផ្លាស់ទី ពីកន្លែងមួយទៅទីកន្លែងមួយទៀត ទឹកភ្លៀង និងបណ្តុំនៃទឹកក្នុងទ្រង់ទ្រាយផ្សេងៗទៀត។

៩- **ប្រព្រឹត្តកម្ម** សំដៅដល់ដំណើរការកែប្រែគុណភាពទឹកពីទឹកឆៅឱ្យទៅជាទឹកស្អាត តាមរយៈបច្ចេកវិទ្យាសម្អាតទឹកផ្សេងៗ ។

១០- **ប្រព័ន្ធប្រព្រឹត្តកម្ម** សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ដំណើរការកែប្រែគុណភាពទឹក ដោយរាប់ចាប់ពីស្ថានីយបូមទឹកឆៅ រហូតដល់អាងស្តុកទឹកស្អាត។



១១- **ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត** សំដៅដល់ប្រព័ន្ធប្រព្រឹត្តកម្ម ប្រព័ន្ធបណ្តាញផ្គត់ផ្គង់ទឹកស្អាត និងមធ្យោបាយតក្កវិជ្ជាសេវាផ្គត់ផ្គង់ទឹកស្អាតនានា។

១២- **បុគ្គល** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គល។

១៣_ **មធ្យោបាយតភ្ជាប់សេវាផ្គត់ផ្គង់ទឹកស្អាត** សំដៅដល់បំពង់ទឹកស្អាតតភ្ជាប់ទៅនឹងប្រព័ន្ធបណ្តាញផ្គត់ផ្គង់ទឹកស្អាត និងឧបករណ៍បរិក្ខារតភ្ជាប់សេវាផ្គត់ផ្គង់ទឹកផ្សេងៗទៀត រហូតទៅដល់នាឡិកាវាស់ស្ទង់ទឹកស្អាតតាមទីតាំងរបស់អតិថិជន។

១៤_ **ប្រព័ន្ធបណ្តាញផ្គត់ផ្គង់ទឹកស្អាត** សំដៅដល់ស្ថានីយបូមចែកចាយ អនុស្ថានីយបូមចែកចាយ បំពង់មេ បំពង់មេរង និងអាងអាកាស។

១៥_ **វិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត** សំដៅដល់លិខិតចេញដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត អនុញ្ញាតឱ្យប្រតិបត្តិការប្រើប្រាស់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួន ដើម្បីផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតនៅក្នុងតំបន់សេវាកម្មរបស់ខ្លួន។

១៦_ **វិធានការសម្លាប់មេរោគ** សំដៅដល់ការសម្អាតប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតដោយការប្រើប្រាស់សារធាតុគីមី ឬបច្ចេកវិទ្យានានា ដើម្បីសម្លាប់មេរោគក្នុងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។

១៧_ **ប្រតិបត្តិករ** សំដៅដល់បុគ្គលដែលទទួលបានអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។

១៨_ **សេវាផ្គត់ផ្គង់ទឹកស្អាត** សំដៅដល់ការផ្គត់ផ្គង់ទឹកស្អាតដែលផ្តល់ដោយប្រតិបត្តិករជូនដល់អតិថិជននិងមានលក្ខណៈអាជីវកម្ម។

១៩_ **អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត** សំដៅដល់លិខិតចេញដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ដែលផ្តល់ជូនប្រតិបត្តិករ ដោយមានកំណត់លក្ខខណ្ឌ សិទ្ធិ និងការទទួលខុសត្រូវក្នុងការវិនិយោគដំណើរការអាជីវកម្ម និងសេវាផ្គត់ផ្គង់ទឹកស្អាត នៅក្នុងតំបន់សេវាកម្មជាក់លាក់ណាមួយ ដែលបានកំណត់ព្រំប្រទល់ច្បាស់លាស់។

២០_ **អាជ្ញាបណ្ណផ្គត់ផ្គង់ទឹកស្អាតប្រកេទលក់ដុំ** សំដៅដល់លិខិតចេញដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ដែលផ្តល់ជូនប្រតិបត្តិករ ដោយមានកំណត់លក្ខខណ្ឌ សិទ្ធិ និងការទទួលខុសត្រូវក្នុងការវិនិយោគ ដំណើរការផលិតកម្ម និងចែកចាយទឹកស្អាតក្រោមទម្រង់ជាអ្នកលក់ដុំដល់អ្នកទទួលសិទ្ធិចែកចាយបន្ត។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ព្រះរាជក្រម

នស/រកម/០៤២៣/ ០០៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស អម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ
រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាធិបតេយ្យ
ប្រជាមានិតឡាវ

មាត្រា១.-

អនុម័តយល់ព្រមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលបានចុះហត្ថលេខានៅរដ្ឋធានីវៀងច័ន្ទនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នាថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

មាត្រា២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តសន្ធិសញ្ញានេះ។

មាត្រា៣.-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ *ពុធ៍ ពាពីត* ខែ *ពិសាម* ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី *២២* ខែ *ផេលា* ឆ្នាំ២០២៣

ពរលរ.២ពា០៤.៣៤១

ឧ សីហមុនី

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

សន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ
រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (ដែលតទៅនេះហៅថា "ភាគីទាំងពីរ")

ដោយភ្ជាប់នឹងសាមគ្គីភាពជាប្រពៃណី មិត្តភាពជាភាតរៈ និងសម្ព័ន្ធភាពរវាងប្រជាជនទាំងពីរ កម្ពុជា ឡាវ ដែលមានជិតជាមនៅក្នុងប្រវត្តិសាស្ត្ររួមរបស់ប្រទេសទាំងពីរ តាំងពីយូរយោរណាស់មកហើយ ហើយដែលត្រូវបានពង្រឹង ពង្រីក និងមានវត្តមានជាអមតៈ

ក្នុងគោលបំណងកសាងខ្សែព្រំដែនសន្តិភាព ស្ថិរភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍយូរអង្វែង ឈរលើមូលដ្ឋានគោរពឯករាជ្យ អធិបតេយ្យភាព និងបូរណភាពដែនដីគ្នា គោរពផលប្រយោជន៍គ្នា ស្មើភាពលើប្រយោជន៍រៀងខ្លួន និងដើម្បីបង្កើនឥតឈប់ទំនាក់ទំនងជិតខាងល្អ សាមគ្គីភាពជាប្រពៃណីរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

ក្នុងការខិតខំជម្នះធ្វើការបោះបង្គោលព្រំដែន និងដើម្បីជានាបានស្ថិរភាពសម្រាប់ប្រជាជននៅតំបន់ព្រំដែននៃប្រទេសទាំងពីរ និងរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គម ប្រែក្លាយតំបន់ព្រំដែនឲ្យទៅជាតំបន់សន្តិភាព មិត្តភាព និងសហប្រតិបត្តិការលើគ្រប់វិស័យ ដើម្បីភាពសុខសាន្តរបស់ប្រជាពលរដ្ឋដែលរស់នៅតាមបណ្តោយព្រំដែននៃប្រទេសទាំងពីរ កម្ពុជា-ឡាវ ឡាវ-កម្ពុជា

ផ្អែកលើសុឆន្ទៈរួមរវាងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ឯកភាពធ្វើឲ្យបានឆាប់សន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋទទួលយកលទ្ធផលនៃការត្រួតពិនិត្យខ្សែព្រំដែនរួមប្រមាណជា ៨៦% ដែលប្រទេសទាំងពីរសម្រេចបានលើការងារព្រំដែន

ដើម្បីកំណត់ជាផ្លូវការខ្សែព្រំដែនរដ្ឋរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សំដៅកសាងខ្សែព្រំដែនសន្តិភាព មិត្តភាពយូរអង្វែង និងជាអចិន្ត្រៃយ៍រវាងប្រទេសទាំងពីរតរៀងទៅ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង

ឯកឧត្តម សនសាយ ស៊ីផាន់ដន នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

បានសម្រេចចុះហត្ថលេខាលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (ក្រោយមកហៅថា"សន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ") តាមខ្លឹមសារឯកភាពគ្នាដូចប្រការខាងក្រោម៖

ប្រការ ១

១.១-ដោយឈរលើមូលដ្ឋាននៃការគោរពគោលការណ៍ច្បាប់អន្តរជាតិ ក្នុងនោះគោលការណ៍ខ្សែព្រំដែនមិនកែប្រែដែលបន្សល់ទុកពីជំនាន់អាណានិគម ភាគីទាំងពីរឯកភាពចាត់ទុកខ្សែព្រំដែនដែលមាននៅពេលដែលប្រទេសទាំងពីរបានឯករាជ្យទុកជាមូលដ្ឋានសំខាន់ ដើម្បីកំណត់ព្រំដែនរដ្ឋរវាងប្រទេសទាំងពីរ។ ភាគីទាំងពីរឯកភាពអនុម័តយកគោលការណ៍ ដើម្បីដោះស្រាយបញ្ហាព្រំដែនរវាងប្រទេសទាំងពីរដូចខាងក្រោម៖

ក-ទទួលស្គាល់ខ្សែព្រំដែនរួម ដែលបន្សល់ទុកឲ្យដោយអាណានិគម តាមផែនទីខ្នាត ១/១០០ ០០០ និងផែនទីសមស្របផ្សេងៗទៀត ដែលធ្វើឡើងនៅចន្លោះឆ្នាំ១៩៣៣ ដល់ ឆ្នាំ១៩៥៣ ដោយក្រុមភូមិសាស្ត្រឥណ្ឌូចិន

ខ-ទទួលស្គាល់គោលការណ៍ដែលទទួលស្គាល់ជាអន្តរជាតិក្នុងវិស័យកំណត់ព្រំដែន

គ-គិតគូរដល់ការកាន់កាប់ជាក់ស្តែងរបស់ប្រជាជនជាច្រើនជំនាន់មកហើយ

ឃ-ឈរលើស្មារតីសមភាព យុត្តិធម៌ សមធម៌ សម្រុះសម្រួល ការគោរពសិទ្ធិ និងផលប្រយោជន៍គ្នាទៅវិញទៅមក និងការឯកភាពលើទស្សនៈ។

១.២-ផ្អែកលើគោលការណ៍កំណត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដូចបានលើកឡើងនៅក្នុងប្រការ ១ កថាខណ្ឌ ១.១ នៃសន្ធិសញ្ញានេះ និងផ្អែកលើកំណត់ហេតុនៃកិច្ចប្រជុំ កិច្ចព្រមព្រៀង និងកំណត់ហេតុបោះបង្គោលព្រំដែនរវាងប្រទេសទាំងពីរ កម្ពុជា-ឡាវ មានចំនួន៩កម្រិតនៃកិច្ចប្រជុំ ស្មើនឹងចំនួន ១៨៨ លើក ដែលក្នុងនោះ ភាគីទាំងពីរឯកភាពលើកយកកិច្ចព្រមព្រៀងចំនួន១ និងកំណត់ហេតុនៃកិច្ចប្រជុំចំនួន២០ សំខាន់ៗមកបញ្ចូលក្នុងសន្ធិសញ្ញានេះ រួមមាន៖(១)-កំណត់ហេតុស្តីពីកិច្ចប្រជុំលើកដំបូង រវាងគណៈកម្មការព្រំដែន កម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៩៥ នៅរដ្ឋធានីវៀងច័ន្ទ (២)-កំណត់ហេតុស្តីពីកិច្ចប្រជុំលើកទីពីរ រវាងគណៈកម្មការព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ១៩៩៧ នៅរាជធានីភ្នំពេញ (៣)-កំណត់ហេតុកិច្ចប្រជុំលើកទី៣ រវាងគណៈកម្មការព្រំដែនកម្ពុជា-ឡាវ និង

ឡាវ-កម្ពុជា ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៨ នៅវៀងច័ន្ទ (៤)-កំណត់ហេតុកិច្ចប្រជុំលើកទី៤ រវាងគណៈកម្មការចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៩ នៅរាជធានីភ្នំពេញ (៥)-កំណត់ហេតុកិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មការចម្រុះព្រំដែន កម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០០ នៅរាជធានីភ្នំពេញ (៦)-កំណត់ហេតុកិច្ចប្រជុំលើកទី១ នៃអនុគណៈកម្មការបច្ចេកទេសចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០០ នៅរាជធានីភ្នំពេញ (៧)-កំណត់ហេតុសម័យប្រជុំលើកទី២ របស់អនុគណៈកម្មការបច្ចេកទេសចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០០ នៅទីក្រុងប៉ាក់សេ (៨)-បែបបទបច្ចេកទេសសម្រាប់ការចុះត្រួតពិនិត្យព្រំដែនរួម រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០០ នៅប៉ាក់សេ (៩)-កំណត់ហេតុស្តីពីការប្រជុំពិគ្រោះយោបល់រវាងក្រុមប្រតិបត្តិការកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ នៅរាជធានីភ្នំពេញ (១០)-កំណត់ហេតុកិច្ចប្រជុំលើកទី៣ នៃអនុគណៈកម្មការបច្ចេកទេសចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០២ នៅទីក្រុងសៀមរាប (១១)-កំណត់ហេតុកិច្ចប្រជុំលើកទី៤ នៃអនុគណៈកម្មការបច្ចេកទេសចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ នៅទីក្រុងប៉ាក់សេ (១២)-កំណត់ហេតុកិច្ចប្រជុំលើកទី៥ នៃគណៈកម្មការចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៣ នៅទីក្រុងហ្លួងប្រាបាង (១៣)-កំណត់ហេតុកិច្ចប្រជុំលើកទី៥ នៃអនុគណៈកម្មការបច្ចេកទេសចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៣ នៅទីក្រុងហ្លួងប្រាបាង (១៤)-កំណត់ហេតុកិច្ចប្រជុំវិសាមញ្ញ នៃគណកម្មការចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៥ នៅរាជធានីភ្នំពេញ (១៥)-កំណត់ហេតុកិច្ចប្រជុំលើកទី៦ នៃអនុគណៈកម្មការបច្ចេកទេសចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៥ នៅរាជធានីភ្នំពេញ (១៦)-កំណត់ហេតុកិច្ចប្រជុំរវាងប្រធានគណៈកម្មការបច្ចេកទេសចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៥ នៅទីក្រុងប៉ាក់សេ (១៧)-កំណត់ហេតុកិច្ចប្រជុំពិភាក្សារវាងក្រុមប្រតិបត្តិការចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៥ នៅខូង-ចំប៉ាសាក់ (១៨)-កំណត់ហេតុកិច្ចប្រជុំវិសាមញ្ញនៃគណៈកម្មការចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី៧ ខែមករា ឆ្នាំ២០០៦ នៅរាជធានីភ្នំពេញ (១៩)-កំណត់ហេតុកិច្ចប្រជុំលើកទី៧ នៃអនុគណៈកម្មការបច្ចេកទេសចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី៧ ខែមករា ឆ្នាំ២០០៦ នៅរាជធានីភ្នំពេញ (២០)-កំណត់ហេតុកិច្ចប្រជុំរវាងឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៩ នៅខេត្តសៀមរាប និងកិច្ចព្រមព្រៀងចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ នៅរាជធានីភ្នំពេញ ដោយឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស រដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

បញ្ជីកំណត់ហេតុ និងកិច្ចព្រមព្រៀង ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ១ អមសន្ធិសញ្ញានេះ។

ផ្អែកលើឯកសារខាងលើ ភាគីទាំងពីរសម្រេចបានការត្រួតពិនិត្យខ្សែព្រំដែនរួម ប្រមាណជា ៨៦ភាគរយ(%) ស្មើនឹង ៨៦៥ គីឡូម៉ែត្រ នៃខ្សែព្រំដែនរួម។ ភាគីទាំងពីរឯកភាពគ្នាកំណត់ព្រំដែនរដ្ឋរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្នុងទិសដើរទូទៅនៃខ្សែព្រំដែនពីខាងលិចទៅខាងកើត ដោយចាប់ផ្តើមចេញពីច្រកភ្នំព្រៈចំបុក នៅចំណុចប្រសព្វនៃព្រំដែនទាំងបីប្រទេស រវាងព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងព្រះរាជាណាចក្រថៃឡង់ដ៍ និងបញ្ចប់ទៅវិញនៅទិសខាងកើត នៅចំណុចប្រសព្វនៃព្រំដែនបីប្រទេសរវាងព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដោយបានបោះបង្គោលព្រំដែនរួចរាល់នៅលើដីជាក់ស្តែងបានចំនួន ១២១ បង្គោល ដូចមាននិយាមកាសស់វែងចេញពីផែនទីអ៊ុយតេអ៊ឹម (UTM) ខ្នាត ១/៥០ ០០០ ដែលត្រូវបានគណនាឯកតាជាម៉ែត្រ ដូចខាងក្រោម ៖

១-វៀរលែងតែគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលស្ថិតក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល ប្រសិនបើសហគ្រាសណាមួយបែងចែកភាគលាភចេញពីប្រាក់ចំណូលមុនបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំទៅឱ្យអ្នកចូលហ៊ុនក្នុងស្រុកឬអ្នកចូលហ៊ុនបរទេស សហគ្រាសនោះត្រូវបង់ប្រាក់ពន្ធដែលមានចំនួនស្មើនឹងផលគុណនៃទឹកប្រាក់ភាគលាភបំប៉ោងទៅតាមអត្រាពន្ធលើប្រាក់ចំណូលគុណនឹងអត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំដូចមានចែងក្នុងមាត្រា២០នៃច្បាប់នេះ។

២- ប្រាក់ពន្ធដែលបានបង់តាមកថាខណ្ឌទី១នៃមាត្រានេះ ត្រូវបានអនុញ្ញាតជាឥណទានពន្ធសម្រាប់កាត់កងនឹងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំជាប់ពន្ធដែលមានការបែងចែក។ ប្រសិនបើឥណទានពន្ធមានចំនួនលើសពីប្រាក់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ចំនួនលើសនោះត្រូវបានអនុញ្ញាតឱ្យយោងទៅមុខសម្រាប់កាត់កងនឹងពន្ធលើប្រាក់ចំណូលនៃឆ្នាំជាប់ពន្ធបន្តបន្ទាប់។

៣-ភាគលាភដែលបានបង់ពន្ធតាមកថាខណ្ឌទី១នៃមាត្រានេះ នៅពេលបែងចែកបន្ត មិនត្រូវជាប់ពន្ធបង់មុនលើការបែងចែកភាគលាភដូចមានចែងក្នុងមាត្រានេះទៀតទេ។

៤- ពន្ធបង់មុនលើការបែងចែកភាគលាភដូចមានចែងក្នុងមាត្រានេះ មិនអនុវត្តទេចំពោះប្រាក់ចំណូលពីបុព្វលាភធានារ៉ាប់រងឬធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិឬហានិភ័យផ្សេងៗនៅព្រះរាជាណាចក្រកម្ពុជាដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រា២១នៃច្បាប់នេះ។

៥-វិធាននិងនីតិវិធីនៃការប្រមូលប្រាក់ពន្ធបង់មុនលើការបែងចែកភាគលាភត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ផ្នែកទី៥
ពន្ធអប្បបរមា

មាត្រា២៤ .- ពន្ធអប្បបរមា

១-ពន្ធអប្បបរមាត្រូវបានកំណត់តាមអត្រា១(មួយ)ភាគរយលើផលរបរប្រចាំឆ្នាំ រួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម ហើយត្រូវបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។ ពន្ធអប្បបរមាអាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំដែលបានបង់ដាក់ស្តែងតាមវិធានដូចមានចែងក្នុងមាត្រា៣៧ មាត្រា៣៨ និងមាត្រា៣៩នៃច្បាប់នេះ។ ពន្ធអប្បបរមាត្រូវបានកំណត់លើសមាសភាគទាំងឡាយណាដែលមិនកាន់បញ្ជីគណនេយ្យបានត្រឹមត្រូវ។ គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ទទួលបានការលើកលែងពន្ធអប្បបរមា ដោយត្រូវមានរបាយការណ៍សវនកម្មឯករាជ្យ។

២- វិធាននិងនីតិវិធីនៃលក្ខណៈនិច្ចយនៃការកាន់បញ្ជីគណនេយ្យមិនត្រឹមត្រូវ និងការបង់ពន្ធអប្បបរមាត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ១៦៣

ផ្នែកទី៦
ពន្ធកាត់ទុកនិងប្រាក់អំណោះពន្ធលើប្រាក់ចំណូល

មាត្រា២៥.- ពន្ធកាត់ទុកទូទៅ

ពន្ធកាត់ទុកទូទៅត្រូវបានកំណត់ដូចខាងក្រោម៖

១- អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្មដែលបានធ្វើការទូទាត់ជាសាច់ប្រាក់ឬជាវត្តុឱ្យអ្នកជាប់ពន្ធនិវាសនជន ត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធទៅតាមអត្រាកំណត់ដូចខាងក្រោម លើចំនួនទូទាត់មុនការកាត់ទុកប្រាក់ពន្ធ៖

ក- អត្រា១៥(ដប់ប្រាំ)ភាគរយ ចំពោះ៖

- ប្រាក់ចំណូលដែលបុគ្គលមិនស្ថិតក្រោមរបបស្វ័យប្រកាសបានទទួលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែល
- សួយសារចំពោះទ្រព្យអចលនៈ និងភាគកម្មក្នុងធនធានរ៉ែ និងការប្រាក់ដែលអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្មក្រៅពីធនាគារក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន។

ខ- អត្រា១០(ដប់)ភាគរយ ចំពោះប្រាក់ចំណូលពីការឱ្យជួលចលនទ្រព្យឬអចលនទ្រព្យ។

គ- អត្រា៦(ប្រាំមួយ)ភាគរយ ចំពោះការប្រាក់ដែលធនាគារក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមានគណនីបញ្ញើមានកាលកំណត់។

ឃ- អត្រា៤(បួន)ភាគរយ ចំពោះការប្រាក់ដែលធនាគារក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមានគណនីបញ្ញើគ្មានកាលកំណត់។

២- ការកាត់ទុកក្នុងមាត្រានេះមិនត្រូវអនុវត្តទេ ចំពោះការប្រាក់ដែលបង់ទៅឱ្យធនាគារក្នុងស្រុកនិងការទូទាត់ចំពោះប្រាក់ចំណូលលើកលែងពន្ធដូចមានចែងក្នុងមាត្រា៩នៃច្បាប់នេះ។

មាត្រា២៦.- ពន្ធកាត់ទុកលើការទូទាត់ប្រាក់ឱ្យដល់អ្នកជាប់ពន្ធអនិវាសនជន

អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម រួមទាំងគ្រឹះស្ថានអចិន្ត្រៃយ៍របស់បុគ្គលអនិវាសនជនដែលធ្វើការទូទាត់ប្រាក់ចំណូលប្រភពកម្ពុជា ដូចមានចែងក្នុងមាត្រា៣៣នៃច្បាប់នេះ ឱ្យទៅអ្នកជាប់ពន្ធអនិវាសនជន ត្រូវកាត់ទុកនិងបង់នូវប្រាក់ពន្ធតាមអត្រា១៤(ដប់បួន)ភាគរយនៃទឹកប្រាក់ត្រូវបើក។ ពន្ធកាត់ទុកនេះ មិនត្រូវអនុវត្តចំពោះបុព្វលាភធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិឬហានិភ័យផ្សេងៗនៅព្រះរាជាណាចក្រកម្ពុជានោះទេ។

មាត្រា២៧.- ពន្ធកាត់ទុកជាពន្ធចុងក្រោយ

ពន្ធកាត់ទុកលើការទូទាត់ឱ្យដល់បុគ្គលនិវាសនជនមិនស្ថិតក្រោមរបបស្វ័យប្រកាសតាមមាត្រា២៥ នៃច្បាប់នេះ និងពន្ធកាត់ទុកលើការទូទាត់ឱ្យដល់អ្នកជាប់ពន្ធអនិវាសនជនតាមមាត្រា២៦នៃច្បាប់នេះ ជាពន្ធកាត់ទុកជាពន្ធចុងក្រោយសម្រាប់អ្នកទទួលការទូទាត់ឬការបែងចែកដែលមានបញ្ជាក់ក្នុងមាត្រាទាំងឡាយនៃច្បាប់នេះ។

មាត្រា២៨ .- ប្រាក់រំដោះពន្ធលើប្រាក់ចំណូល

សហគ្រាសដែលជាប់ពន្ធលើប្រាក់ចំណូលតាមរបបស្វ័យប្រកាស រួមទាំងគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលផុតរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល មានកាតព្វកិច្ចបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែតាមអត្រា១(មួយ)ភាគរយនៃផលបរិ រួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែមដែលសម្រេចបានក្នុងខែមុន។ ប្រាក់រំដោះពន្ធលើប្រាក់ចំណូលនឹងត្រូវបានយកមកកាត់កងពីពន្ធលើប្រាក់ចំណូលនៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ។

ផ្នែកទី៧
កាតព្វកិច្ចរបស់អ្នកជាប់ពន្ធ

មាត្រា២៩ .- កាតព្វកិច្ចរបស់អ្នកជាប់ពន្ធមធ្យមនិងអ្នកជាប់ពន្ធធំ

អ្នកជាប់ពន្ធមធ្យមនិងអ្នកជាប់ពន្ធធំត្រូវមានកាតព្វកិច្ចដូចខាងក្រោម៖

១_ អនុវត្តកាតព្វកិច្ចបញ្ជីកាគណនេយ្យដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រា៦នៃច្បាប់នេះ និងត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំជូនរដ្ឋបាលសារពើពន្ធតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់ក្នុងរយៈពេល៣(បី)ខែ ក្រោយពីដំណាច់ឆ្នាំជាប់ពន្ធនីមួយៗ ដោយភ្ជាប់ជាមួយនូវតារាងតុល្យការ គណនីលទ្ធផល និងព័ត៌មានបន្ថែម។

២_ ចំពោះសហគ្រាសដែលមានការខាតបង់ ក៏ត្រូវដាក់លិខិតប្រកាសសារពើពន្ធតាមបែបបទនិងក្នុងរយៈពេលដូចគ្នាដែរ។

មាត្រា៣០ .- កាតព្វកិច្ចរបស់អ្នកជាប់ពន្ធតូច

អ្នកជាប់ពន្ធតូចមានកាតព្វកិច្ចដូចខាងក្រោម៖

១_ ត្រូវដាក់លិខិតប្រកាសនិងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ជូនរដ្ឋបាលសារពើពន្ធជារៀងរាល់ឆ្នាំក្នុងរយៈពេល៣(បី)ខែ ក្រោយដំណាច់ឆ្នាំប្រតិទិននីមួយៗតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់។

២_ ក្នុងករណីមិនបានកាន់កត់ត្រាបញ្ជីចំណូលចំណាយតាមការកំណត់របស់រដ្ឋបាលសារពើពន្ធ ចំនួនប្រាក់ចំណូលជាប់ពន្ធត្រូវកំណត់ដោយរដ្ឋបាលសារពើពន្ធ បន្ទាប់ពីបានត្រួតពិនិត្យនិងគណនាតាមអត្រាចំណូលទៅតាមមុខរបរអាជីវកម្ម ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៣១ .- កាតព្វកិច្ចរបស់ភ្នាក់ងារកាត់ទុក

១_ បុគ្គលឬអ្នកទទួលភារៈបើកប្រាក់ដែលកាត់ទុកប្រាក់ពន្ធតាមមាត្រា២៥និងមាត្រា២៦នៃច្បាប់នេះ ត្រូវដាក់លិខិតប្រកាសសារពើពន្ធនិងបង់ប្រាក់ពន្ធដែលបានកាត់ទុកជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលបានធ្វើការទូទាត់។

២_ សហគ្រាសត្រូវដាក់លិខិតប្រកាសពន្ធបង់មុនលើការបែងចែកភាគលាភ ដូចមានចែងក្នុងមាត្រា [illegible] នៃច្បាប់នេះ និងបង់ពន្ធជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលការបែងចែកត្រូវបានទូទាត់។

មាត្រា៣២ .– កាតព្វកិច្ចបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល

អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធនិងបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលជូនរដ្ឋបាលសារពើពន្ធជារៀងរាល់ខែ តាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលប្រតិបត្តិការអាជីវកម្មបានកើតឡើង។

ផ្នែកទី៨
ប្រភពប្រាក់ចំណូល

មាត្រា៣៣ .– ប្រាក់ចំណូលប្រភពកម្ពុជា

ដោយមិនមានការកម្រិតត្រឹមតែប្រាក់ចំណូលដូចខាងក្រោមនេះ ប្រាក់ចំណូលប្រភពកម្ពុជារួមមាន៖

១– ការប្រាក់ដែលបង់ដោយសហគ្រាសនិវាសនជន ក្រុមហ៊ុនសហកម្មសិទ្ធិនិវាសនជន ឬស្ថាប័នរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

២– ភាគលាភដែលបានបែងចែកដោយសហគ្រាសនិវាសនជន។

៣– ប្រាក់ចំណូលពីសេវាកម្មដែលបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៤– ប្រាក់ចំណូលពីការគ្រប់គ្រងនិងសេវាបច្ចេកទេស ដែលបានទូទាត់ដោយបុគ្គលនិវាសនជន។

៥– ប្រាក់ចំណូលដែលបានមកពីចលនទ្រព្យឬអចលនទ្រព្យក្នុងករណីដែលទ្រព្យនោះស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៦– ប្រាក់សួយសារដែលបានមកពីការប្រើប្រាស់ឬសិទ្ធិប្រើប្រាស់ទ្រព្យអរូបីដែលបានទូទាត់ដោយអ្នកជាប់ពន្ធនិវាសនជនឬអ្នកជាប់ពន្ធអនិវាសនជនតាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ដែលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៧– ផលចំណេញពីការលក់ចលនទ្រព្យ ឬអចលនទ្រព្យ រួមទាំងទ្រព្យអរូបី ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬផលចំណេញពីការផ្ទេរផលប្រយោជន៍ណាមួយនៃចលនទ្រព្យឬអចលនទ្រព្យ រួមទាំង ទ្រព្យអរូបី ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៨– បុព្វលាភធានារ៉ាប់រងឬធានារ៉ាប់រងបន្តចំពោះហានិភ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៩– ផលចំណេញពីការលក់ចលនទ្រព្យដែលជាចំណែកនៃទ្រព្យអាជីវកម្មរបស់គ្រឹះស្ថានអចិន្ត្រៃយ៍របស់អ្នកជាប់ពន្ធអនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

១០– ប្រាក់ចំណូលពីសកម្មភាពអាជីវកម្មរបស់អ្នកជាប់ពន្ធអនិវាសនជន តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា៣៤ .– ប្រាក់ចំណូលប្រភពបរទេស

រាល់ប្រាក់ចំណូលដែលមិនមែនជាប្រាក់ចំណូលប្រភពកម្ពុជាដូចមានចែងក្នុងមាត្រា៣៣នៃច្បាប់នេះត្រូវចាត់ទុកជាប្រាក់ចំណូលប្រភពបរទេស។

មាត្រា៣៥ .– ការកំណត់ប្រភពចំណូល

ក្នុងករណីដែលគ្មានព័ត៌មានគ្រប់គ្រាន់ដើម្បីកំណត់ប្រភពចំណូល ឬប្រសិនបើវិធាននានាដែលមានចេមកហ្រើយពុំអាចឆ្លុះបញ្ចាំងឱ្យបានច្បាស់លាស់នូវប្រាក់ចំណូលពីប្រភពណាមួយបានទេនោះ រដ្ឋបាលសារពើពន្ធជាអ្នកកំណត់ប្រភពនៃប្រាក់ចំណូលនោះ។

ផ្នែកទី៥
គណនាប្រាក់ពន្ធប្រចាំឆ្នាំត្រូវបង់

មាត្រា៣៦ .- តណទានពន្ធបរទេស

១- អ្នកជាប់ពន្ធនិវាសនជនដែលបានទទួលប្រាក់ចំណូលប្រភពបរទេសនិងបានបង់ពន្ធតាមច្បាប់ពន្ធជារបរទេស ត្រូវបានទទួលនូវតណទានពន្ធសម្រាប់កាត់កងពីប្រាក់ពន្ធលើប្រាក់ចំណូលដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែត្រូវមានឯកសារបញ្ជាក់អំពីការបង់ពន្ធនៅបរទេសនោះ។

២- ដើម្បីគណនាប្រាក់ពន្ធដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជាមុនពេលកាត់កងតណទានពន្ធនេះ ត្រូវយកចំនួនសរុបនៃប្រាក់ចំណូលដែលបានទទួលពីប្រភពកម្ពុជានិងប្រភពបរទេសមកគិត។

៣- តណទានពន្ធត្រូវបានកំណត់ជាច់ដោយឡែកពីគ្នាសម្រាប់ប្រាក់ពន្ធដែលបានបង់ដោយនិវាសនជនកម្ពុជានៅប្រទេសក្រៅនីមួយៗ។ ប៉ុន្តែតណទានពន្ធដែលអនុញ្ញាតឱ្យកាត់កងសម្រាប់ឆ្នាំជាប់ពន្ធគឺចំនួនដែលទាបជាងគេក្នុងចំណោម៖

ក- ប្រាក់ពន្ធដែលបានបង់ជាក់ស្តែងនៅប្រទេសក្រៅណាមួយ។

ខ- ចំនួនដែលបានមកពីការយកប្រាក់ពន្ធលើប្រាក់ចំណូលសរុបពីគ្រប់ប្រភព សម្រាប់រយៈពេលជាមួយគ្នាដែលគណនាតាមអត្រាពន្ធក្នុងមាត្រា២០នៃច្បាប់នេះ ទៅគុណនឹងផលចែករវាងប្រាក់ចំណូលដែលបានទទួលនៅប្រទេសក្រៅនោះ និងប្រាក់ចំណូលសរុបពីគ្រប់ប្រភព។

៤- តណទានពន្ធបរទេសអាចផ្តល់ឱ្យបាន លុះណាតែអ្នកជាប់ពន្ធនិវាសនជនបានបំពេញបែបបទព្រមទាំងផ្តល់ឯកសារនានាដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ ជាពិសេសសេចក្តីបញ្ជាក់របស់អ្នកទូទាត់ប្រាក់ពន្ធនៅបរទេសដោយរដ្ឋបាលសារពើពន្ធបរទេសនោះ។

៥- ក្នុងករណីតណទានពន្ធមានចំនួនលើសពីបំណុលពន្ធ ចំនួនលើសនោះអាចយោងទៅប្រើនៅឆ្នាំបន្តបន្ទាប់រហូតដល់ឆ្នាំទី៥(ប្រាំ)គិតពីឆ្នាំបន្ទាប់នៃឆ្នាំដែលតណទានពន្ធនោះបានកើតឡើង។ ប្រសិនបើមានតណទានពន្ធច្រើនឆ្នាំ ត្រូវយកតណទានពន្ធទាំងនោះមកប្រើតាមលំដាប់ឆ្នាំដែលបានកើតឡើង។

មាត្រា៣៧ .- ការគណនាបំណុលពន្ធលើប្រាក់ចំណូល

ការគណនាបំណុលពន្ធលើប្រាក់ចំណូលត្រូវបានកំណត់ដូចខាងក្រោម៖

១- គណនាបំណុលពន្ធសរុបតាមមាត្រា២០នៃច្បាប់នេះ។

២- ដកតណទានពន្ធដែលបានបង់តាមមាត្រា២៣ និងតណទានពន្ធបរទេសតាមមាត្រា៣៦នៃច្បាប់នេះ ប៉ុន្តែមិនឱ្យលើសបំណុលពន្ធក្នុងកថាខណ្ឌទី១នៃមាត្រានេះទេ។

មាត្រា៣៨ .- ការគណនាប្រាក់ពន្ធត្រូវបង់ឬតណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធ

ការគណនាប្រាក់ពន្ធត្រូវបង់ឬតណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធត្រូវបានកំណត់ដូចខាងក្រោម៖

១- ក្នុងករណីដែលលទ្ធផលគណនាតាមមាត្រា៣៧នៃច្បាប់នេះ មានចំនួនច្រើនជាងផលបូកនៃប្រាក់ពន្ធដែលបានកាត់ទុកក្នុងនាមអ្នកជាប់ពន្ធដោយភ្នាក់ងារកាត់ទុកនានាតាមមាត្រា២៥នៃច្បាប់នេះ [illegible]ប្រាក់ដោះពន្ធលើប្រាក់ចំណូលដែលអ្នកជាប់ពន្ធបានបង់ប្រចាំឆ្នាំតាមមាត្រា២៨នៃច្បាប់នេះ អ្នកជាប់ពន្ធត្រូវបង់បន្ថែមចំនួនដែលលម្ពៀងនោះជូនរដ្ឋបាលសារពើពន្ធ។

២- ប្រសិនបើលទ្ធផលគណនាតាមមាត្រា៣៧នៃច្បាប់នេះ មានចំនួនតិចជាងផលបូកនៃចំនួនប្រាក់ពន្ធដែលបានកាត់ទុកក្នុងនាមអ្នកជាប់ពន្ធដោយគ្នាក់ងារកាត់ទុកនានាតាមមាត្រា២៥នៃច្បាប់នេះ និងចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលអ្នកជាប់ពន្ធបានបង់សម្រាប់ឆ្នាំជាប់ពន្ធតាមមាត្រា២៨នៃច្បាប់នេះ ក្រោយពីបានគណនាបំណុលពន្ធអប្បបរមារួចហើយ អ្នកជាប់ពន្ធអាចសុំបង្វិលសងវិញនូវចំនួនដែលលម្អៀង ឬយោងទៅប្រើជាប្រាក់រំដោះសម្រាប់ឆ្នាំបន្ទាប់។

៣- មុននឹងធ្វើការទូទាត់ប្រាក់ពន្ធតាមកថាខណ្ឌទី១នៃមាត្រានេះ ឬក៏សុំបង្វិលសង ឬយោងទៅប្រើជាប្រាក់រំដោះសម្រាប់ឆ្នាំបន្ទាប់តាមកថាខណ្ឌទី២នៃមាត្រានេះ អ្នកជាប់ពន្ធត្រូវតែកំណត់ជាមុននូវបំណុលពន្ធអប្បបរមា តាមនីតិវិធីដូចមានបែងក្នុងមាត្រា៣៩នៃច្បាប់នេះ។

មាត្រា៣៩ .- ការគណនាប្រាក់ពន្ធអប្បបរមា ប្រាក់ពន្ធត្រូវបង់ ឬឥណទានសម្រាប់ឆ្នាំជាប់ពន្ធ

ការគណនាប្រាក់ពន្ធអប្បបរមា ប្រាក់ពន្ធត្រូវបង់ ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធ ត្រូវបានកំណត់ដូចខាងក្រោម៖

១- អ្នកជាប់ពន្ធត្រូវបង់ពន្ធអប្បបរមានៅពេលធ្វើការទូទាត់ប្រាក់ពន្ធលើប្រាក់ចំណូល។ ពន្ធអប្បបរមាត្រូវបង់អាចត្រូវបានកាត់បន្ថយដោយបំណុលពន្ធលើប្រាក់ចំណូលក្នុងឆ្នាំជាប់ពន្ធជាមួយគ្នាតាមមាត្រា២០នៃច្បាប់នេះ។

២- ក្នុងករណីបំណុលពន្ធលើប្រាក់ចំណូលលើសពីបំណុលពន្ធអប្បបរមា៖

ក- អ្នកជាប់ពន្ធត្រូវទូទាត់ប្រាក់ពន្ធត្រូវបង់តាមមាត្រា៣៧នៃច្បាប់នេះ នៅពេលដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។

ខ- ប្រសិនបើចំនួនទឹកប្រាក់ដែលបានកាត់ទុកតាមមាត្រា២៥និងមាត្រា២៨នៃច្បាប់នេះ មានចំនួនលើសពីបំណុលពន្ធអប្បបរមា អ្នកជាប់ពន្ធអាចស្នើសុំជាឥណទានពន្ធបាន។

គ- ក្នុងករណីដូចក្នុងកថាខណ្ឌទី២នៃមាត្រានេះ អ្នកជាប់ពន្ធមិនជាប់ពន្ធអប្បបរមាទេ។

៣- ប្រសិនបើបំណុលពន្ធលើប្រាក់ចំណូលតិចជាងបំណុលពន្ធអប្បបរមា៖

ក- ឥណទានពន្ធរបស់អ្នកជាប់ពន្ធតាមកថាខណ្ឌទី២នៃមាត្រា៣៨នៃច្បាប់នេះ ត្រូវបានកាត់បន្ថយដោយទឹកប្រាក់លម្អៀងខាងលើ។

ខ- ឥណទានពន្ធដែលបានកាត់បន្ថយក្នុងការអនុវត្តតាមវាក្យខណ្ឌ ក នៃកថាខណ្ឌនេះ ត្រូវចាត់ជាការទូទាត់ប្រាក់ពន្ធអប្បបរមាសម្រាប់ឆ្នាំជាប់ពន្ធ។

ជំពូកទី៣
ពន្ធលើប្រាក់បៀវត្ស
ផ្នែកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា៤០ - កម្មវត្ថុនៃពន្ធ

[illegible] ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រចាំខែកំណត់លើប្រាក់បៀវត្សដែលបានទទួលក្នុងក្របខ័ណ្ឌនៃការវាយតម្លៃកម្មភាពបម្រើការងារ។

មាត្រា៤១ ._ វិសាលភាពនៃពន្ធ

១_ រូបវន្តបុគ្គលនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជានិងប្រាក់បៀវត្សប្រភពបរទេស។

២_ រូបវន្តបុគ្គលអនិវាសនជន ត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា។

មាត្រា៤២ ._ និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងជំពូកនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១_ និវាសនជន ក្នុងករណីដែលប្រើចំពោះនិយោជិត អ្នកជាប់ពន្ធ ឬរូបវន្តបុគ្គល មានន័យថា ដែលមានទីលំនៅដ្ឋានឬមានកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី១៨២(មួយរយប៉ែតសិបពីរ)ថ្ងៃ នៅក្នុងរយៈពេល១២(ដប់ពីរ)ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធចរន្ត។

២_ អនិវាសនជន មានន័យថា រូបវន្តបុគ្គលណាមួយដែលមិនមែនជានិវាសនជនតាមកថាខណ្ឌទី១នៃមាត្រានេះ និងទទួលប្រាក់បៀវត្សប្រភពកម្ពុជា។

៣_ វៀរលែងតែមានបទប្បញ្ញត្តិផ្ទុយ ការប្រើពាក្យ និយោជិត អ្នកជាប់ពន្ធ និងរូបវន្តបុគ្គល សំដៅដល់ទាំងនិវាសនជននិងអនិវាសនជន ដូចមានចែងក្នុងមាត្រានេះ។

៤_ និយោជក រួមមានស្ថាប័នរដ្ឋ នីតិបុគ្គលនិវាសនជន ក្រុមហ៊ុនសហកម្មសិទ្ធិនិវាសនជន គ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា អង្គការ សមាគម គណបក្សនយោបាយ ឬរូបវន្តបុគ្គលនិវាសនជនដែលប្រកបអាជីវកម្ម។

៥_ និយោជិត សំដៅដល់ រូបវន្តបុគ្គលដែលបានទទួលប្រាក់បៀវត្សពីសកម្មភាពបម្រើការងាររបស់ខ្លួន រួមបញ្ចូលទាំងអ្នកទទួលឧបត្ថម្ភឬអភិបាលរបស់សហគ្រាស អ្នករាជការសាធារណៈនិងពលដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត លើកលែងតែសមាជិករដ្ឋសភានិងព្រឹទ្ធសភា។

៦_ ប្រាក់បៀវត្សប្រភពកម្ពុជា សំដៅដល់ ប្រាក់បៀវត្សដែលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបម្រើការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដោយឡែកចំពោះប្រាក់បៀវត្សដែលអនិវាសនជនបានទទួលក្នុងការផ្តល់ជំនួយបច្ចេកទេស ត្រូវចាត់ទុកថាមានប្រភពនៅក្នុងប្រទេសដែលអ្នកទូទាត់ប្រាក់បៀវត្សនោះស្នាក់នៅ។

៧_ បរទេស៖

ក_ ពេលណាប្រើជាមួយរូបវន្តបុគ្គល មានន័យថា អនិវាសនជន។

ខ_ ពេលណាប្រើក្នុងការកំណត់ប្រភពប្រាក់ចំណូល មានន័យថា ក្រៅព្រះរាជាណាចក្រកម្ពុជា។

គ_ ប្រាក់បៀវត្ស សំដៅដល់ បៀវត្ស ប្រាក់ឈ្នួល លាភការ ប្រាក់បំណាច់ បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់ឧបត្ថម្ភ និងអត្ថប្រយោជន៍បន្ថែម ដែលបានទូទាត់ឱ្យដល់និយោជិតឬដែលបានទូទាត់ដើម្បីជាប្រយោជន៍ដល់ឬប្រយោលដល់និយោជិត ចំពោះការបំពេញសកម្មភាពបម្រើការងារ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ១៦៩

ផ្នែកទី២
ប្រាក់បៀវត្សលើកលែងពន្ធ

មាត្រា៤៣ .- ប្រាក់បៀវត្សរបស់មន្ត្រីការទូតនិងមន្ត្រីបរទេសដទៃទៀត

ការលើកលែងពន្ធលើប្រាក់បៀវត្សរបស់មន្ត្រីការទូតនិងមន្ត្រីបរទេសដទៃទៀតត្រូវបានកំណត់ដូចខាងក្រោម៖

១- ត្រូវបានលើកលែងពន្ធលើប្រាក់បៀវត្សចំពោះ៖

ក- ប្រាក់បៀវត្សដែលមន្ត្រីនិងនិយោជិតនៃបេសកកម្មទូតឬកុងស៊ុលរបស់រដ្ឋាភិបាលបរទេសណាមួយដែលកាន់លិខិតឆ្លងដែនការទូតឬផ្លូវការរបស់ប្រទេសនោះ បានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារជាផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ- ប្រាក់បៀវត្សដែលតំណាង មន្ត្រី និងនិយោជិតបរទេសរបស់អង្គការអន្តរជាតិនិងរបស់ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសនៃរដ្ឋាភិបាលដទៃទៀត បានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារជាផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២- ការលើកលែងពន្ធក្នុងមាត្រានេះ ត្រូវឈរលើគោលការណ៍បដិការវាងរដ្ឋាភិបាលដែលពាក់ព័ន្ធ។

មាត្រា៤៤ .- ប្រាក់ចំណូលលើកលែងពន្ធរបស់និយោជិត

ប្រាក់ចំណូលលើកលែងពន្ធរបស់និយោជិតត្រូវបានកំណត់ដូចខាងក្រោម៖

១- ប្រាក់សំណងដោយពិតប្រាកដនូវចំណាយខាងវិជ្ជាជីវៈ ដែលបានចាយដោយនិយោជិតតាមសេចក្តីបង្គាប់ និងសម្រាប់ជាប្រយោជន៍នៃនិយោជក ហើយដែលបានបំពេញលក្ខខណ្ឌ៣(បី)ដូចខាងក្រោម៖

- បានចាយក្នុងផលប្រយោជន៍ផ្ទាល់និងដាច់ខាតរបស់សហគ្រាស
- មិនបង្ហាញលក្ខណៈហួសប្រមាណឬស្តុកស្តម្ភហួសហេតុ
- បានបង្ហាញជាភស្តុតាងដោយវិក្កយបត្ររាយលម្អិតនិងបានទូទាត់ស្រេចបាច់ ហើយដែលបានធ្វើក្នុងនាមអ្នកបានទទួលប្រាក់សំណងនូវចំណាយពិតប្រាកដ។

២- ប្រាក់បំណាច់នានាក្នុងករណីរំលាយកិច្ចសន្យាក្នុងកម្រិតដែលមានបញ្ញត្តក្នុងច្បាប់ស្តីពីការងារនិងប្រភេទនៃប្រាក់បំណាច់ដែលទទួលបាននូវការលើកលែងពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៣- លាភការបន្ថែមសម្រាប់បង្កើតបេឡាសោធននិងធានាសុខុមាលភាពសង្គម ឬមានចរិតលក្ខណៈខាងសង្គមកិច្ច ក្នុងករណីដែលបានបញ្ញត្តក្នុងច្បាប់ស្តីពីការងារនិងច្បាប់ស្តីពីរបបសន្តិសុខសង្គម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ROYAUME DU CAMBODGE
LE MINISTRE DE FAUNS ET FINANCES

៤- ការផ្តត់ផ្តង់ឱ្យដោយឥតយកថ្លៃឬយកថ្លៃទាបជាងថ្លៃដើមនូវឯកសណ្ឋានឬបរិក្ខារសម្រាប់វិជ្ជាជីវៈ ពិសេស

៥- ប្រាក់បំណាច់ម៉ៅការសម្រាប់ចំណាយបេសកកម្មនិងការធ្វើដំណើរ។ ប្រាក់បំណាច់នេះមិនត្រូវត្រូតគ្នាជាមួយប្រាក់សំណងពិតប្រាកដនូវចំណាយដូចមានចែងក្នុងមាត្រានេះទ្បើយ។

ផ្នែកទី៣
មូលដ្ឋានគិតពន្ធនិងអត្រាពន្ធ

មាត្រា៤៥ .- មូលដ្ឋានគិតពន្ធប្រចាំខែ

វៀរលែងតែអត្ថប្រយោជន៍បន្ថែមដែលត្រូវកំណត់ពន្ធតាមមាត្រា៤៨នៃច្បាប់នេះ មូលដ្ឋានគិតពន្ធប្រចាំខែរបស់និវាសនជន គឺជាប្រាក់បៀវត្សជាប់ពន្ធដោយអនុញ្ញាតឱ្យកាត់កងនូវ៖

១- ប្រាក់កាត់ទុកដែលជាកាតព្វកិច្ចក្នុងការប្រតិបត្តិតាមច្បាប់ស្តីពីការងារនិងច្បាប់ស្តីពីរបបសន្តិសុខសង្គម។

២- ការទូទាត់នានាដែលត្រូវបានលើកលែងពន្ធដូចមានចែងក្នុងមាត្រា៤៤នៃច្បាប់នេះ។

មាត្រា៤៦ .- ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ

ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែត្រូវបានកំណត់ដូចខាងក្រោម៖

១- ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែរបស់និយោជិតនិវាសនជនរួមមាន៖

ក- ប្រាក់បៀវត្សដែលបានទទួលពីប្រភពកម្ពុជា។

ខ- ប្រាក់បៀវត្សដែលបានទទួលពីប្រភពបរទេស។

គ- ប្រាក់បុរេប្រទាន ប្រាក់ឱ្យខ្ចី ឬប្រាក់រំដោះដែលនិយោជកបានបើកឱ្យនិយោជិត។ ប្រាក់បុរេប្រទាន ប្រាក់ឱ្យខ្ចី ឬប្រាក់រំដោះត្រូវបូកបន្ថែមលើបៀវត្សជាប់ពន្ធនៃខែដែលប្រាក់ទាំងនោះបានបើកហើយត្រូវកាត់បន្តយពីប្រាក់បៀវត្សក្នុងខែដែលនិយោជិតបានបង់សងវិញ។

២- ផ្អែកលើការបង្ហាញកស្មុតាងនៃស្ថានភាពគ្រួសារ និយោជិតនិវាសនជនណាមួយដែលមានកូនស្ថិតក្នុងបន្ទុកនិង/ឬសហព័ទ្ធដែលធ្វើតែជាមេផ្ទះនាពេលដែលត្រូវបង់ពន្ធ ត្រូវបានទទួលនូវការបន្តយមូលដ្ឋានកំណត់ពន្ធតាមចំនួនដែលត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៣- ចំពោះអ្នកជាប់ពន្ធអនិវាសនជន ប្រាក់បៀវត្សជាប់ពន្ធ គឺជាប្រាក់បៀវត្សប្រភពកម្ពុជាដែលត្រូវជាប់ពន្ធតាមបទប្បញ្ញត្តិទាំងឡាយនៃជំពូកនេះ។

មាត្រា៤៧ .- អត្រាពន្ធលើប្រាក់បៀវត្សប្រចាំខែ

សម្រាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ត្រូវកំណត់តាមអត្រាកំណើនតាមថ្នាក់០(សូន្យ)ភាគរយ ៥(ប្រាំ)ភាគរយ ១០(ដប់)ភាគរយ ១៥(ដប់ប្រាំ)ភាគរយ និង ២០(ម្ភៃ)ភាគរយ លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែនិងត្រូវកាត់ទុកដោយនិយោជក។ ការកំណត់កម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៤៨ .- ការកំណត់ប្រាក់ពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែម

ចំពោះអត្ថប្រយោជន៍បន្ថែមជារៀងរាល់ខែ និយោជកត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធតាមអត្រា ២០(ម្ភៃ)ភាគរយនៃតម្លៃសរុបរបស់អត្ថប្រយោជន៍បន្ថែមដែលបានផ្តល់ឱ្យនិយោជិតទាំងអស់។ តម្លៃនៃអត្ថប្រយោជន៍បន្ថែម គឺជាតម្លៃទីផ្សារ រួមទាំងពន្ធអាករទាំងអស់។

វិធាននិងនីតិវិធីនៃការលើកលែងពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែមត្រូវកំណត់តាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ១៧១

មាត្រា៤៩ .- ការកំណត់ប្រាក់ពន្ធលើប្រាក់បៀវត្សរបស់អ្នកជាប់ពន្ធអនិវាសនជន

រៀរលែងតែអត្ថប្រយោជន៍បន្ថែមដែលត្រូវកំណត់ពន្ធតាមមាត្រា៤៨នៃច្បាប់នេះ សម្រាប់អ្នកជាប់ពន្ធអនិវាសនជន ប្រាក់ពន្ធត្រូវកាត់ទុកដោយអ្នកបើកប្រាក់ឱ្យតាមអត្រា២០(ម្ភៃ)ភាគរយ លើរាល់ការទូទាត់ប្រាក់បៀវត្សជាប់ពន្ធដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា៤៦នៃច្បាប់នេះ។ ពន្ធកាត់ទុកនេះ គឺជាពន្ធចុងក្រោយនៃពន្ធលើប្រាក់បៀវត្សសម្រាប់អនិវាសនជនជាអ្នកទទួលប្រាក់បៀវត្ស។

មាត្រា៥០ .- ឥណទានពន្ធបរទេស

អ្នកជាប់ពន្ធនិវាសនជនដែលបានទទួលប្រាក់បៀវត្សប្រភពបរទេសនិងបានបង់ពន្ធតាមច្បាប់ពន្ធជារបរទេស ត្រូវបានទទួលនូវឥណទានពន្ធសម្រាប់កាត់កងពីប្រាក់ពន្ធលើប្រាក់បៀវត្សដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែត្រូវមានឯកសារបញ្ជាក់អំពីការបង់ពន្ធនៅបរទេសនោះ។ ការគណនាប្រាក់ពន្ធដែលត្រូវបង់និងឥណទានពន្ធត្រូវកំណត់ដូចខាងក្រោម៖

១- ដើម្បីគណនាប្រាក់ពន្ធដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា មុនពេលកាត់ឥណទានពន្ធនេះ ត្រូវយកចំនួនសរុបប្រាក់បៀវត្សដែលបានទទួលពីប្រភពកម្ពុជានិងប្រភពបរទេសមកគិត។

២- ឥណទានពន្ធត្រូវបានកំណត់ជាច់ដោយឡែកពីគ្នាសម្រាប់ប្រាក់ពន្ធដែលបានបង់ដោយនិវាសនជនកម្ពុជានៅប្រទេសក្រៅនីមួយៗ។ ប៉ុន្តែឥណទានពន្ធផ្តល់ឱ្យសម្រាប់ពន្ធលើប្រាក់បៀវត្សដែលបានបង់នៅប្រទេសក្រៅ គឺជាចំនួនដែលទាបជាងគេក្នុងចំណោម៖

ក- ប្រាក់ពន្ធដែលបានបង់ជាក់ស្តែងនៅប្រទេសក្រៅណាមួយ។

ខ- ចំនួនដែលបានមកពីការយកប្រាក់ពន្ធលើប្រាក់បៀវត្សសរុបពីគ្រប់ប្រភព ក្នុងរយៈពេលជាមួយគ្នាដែលគណនាតាមអត្រាកំណើនតាមថ្នាក់ក្នុងមាត្រា៤៧នៃច្បាប់នេះ ទៅគុណនឹងផលចែករវាងប្រាក់បៀវត្សដែលបានទទួលនៅប្រទេសក្រៅនោះ និងប្រាក់បៀវត្សសរុបពីគ្រប់ប្រភព។

៣- ការបង្វិលសងឥណទានពន្ធបរទេសអាចធ្វើទៅបាន លុះណាតែអ្នកជាប់ពន្ធនិវាសនជនបានបំពេញបែបបទ ព្រមទាំងផ្តល់ឯកសារនានាកំណត់ដោយរដ្ឋបាលសារពើពន្ធ ជាពិសេសសេចក្តីបញ្ជាក់របស់និយោជកនិងរដ្ឋបាលសារពើពន្ធនៃទីកន្លែងបម្រើការងារនៅបរទេសនោះ។

ផ្នែកទី៤
កាតព្វកិច្ចរបស់និយោជកនិងនិយោជិត

មាត្រា៥១ .- កាតព្វកិច្ចកាត់ទុកប្រាក់ពន្ធ

កាតព្វកិច្ចកាត់ទុកប្រាក់ពន្ធត្រូវបានកំណត់ដូចខាងក្រោម៖

១- ពន្ធនេះ គឺជាកាតព្វកិច្ចរបស់រូបវន្តបុគ្គលដែលបានទទួលប្រាក់បៀវត្ស រួមទាំងរូបវន្តបុគ្គលបរទេសជ្យរលែងតែមានបុទប្បញ្ញត្តិផ្ទុយដែលមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិ។

២- ពន្ធលើប្រាក់បៀវត្ស ត្រូវប្រមូលតាមរបៀបកាត់ទុកជាមុនជារៀងរាល់ខែដោយនិយោជកនៅកាលពេលបើកប្រាក់បៀវត្ស។

៣_ ប្រសិនបើនិយោជកស្នាក់នៅបរទេស តំណាងដែលនិយោជកបានចាត់តាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺជាអ្នកទទួលការៈកាត់ទុកពន្ធលើប្រាក់បៀវត្សមុនពេលបើកប្រាក់បៀវត្សឱ្យនិយោជិត និងត្រូវប្រកាសបង់ប្រាក់ពន្ធទាំងនោះជូនរដ្ឋបាលសារពើពន្ធ។

៤_ និយោជកឬតំណាងនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់និយោជកបរទេស និងនិយោជិតត្រូវទទួលខុសត្រូវរួមគ្នាក្នុងការបង់ពន្ធលើប្រាក់បៀវត្សក្នុងព្រះរាជាណាចក្រកម្ពុជា ដោយពុំកំណត់ថា ប្រាក់បៀវត្សបានបើកឱ្យនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬនៅបរទេសឡើយ។ ក្នុងករណីមិនបានកាត់ទុកប្រាក់ពន្ធលើប្រាក់បៀវត្ស និយោជកត្រូវទទួលខុសត្រូវចំពោះច្បាប់នេះ។

មាត្រា៥២_ ការកាត់ទុកប្រាក់ពន្ធ ការកាន់កាប់បញ្ជិកា និងរបាយការណ៍

និយោជកដែលបើកប្រាក់បៀវត្សត្រូវជាប់ពន្ធ ត្រូវបំពេញការកិច្ចដូចខាងក្រោម៖

១_ កាត់ទុកប្រាក់ពន្ធមុនពេលបើកប្រាក់បៀវត្ស។

២_ រាយការណ៍ជូនរដ្ឋបាលសារពើពន្ធនិងនិយោជិតអំពីស្ថានភាពប្រាក់ពន្ធដែលបានកាត់ទុក។

៣_ កាន់កាប់និងថែរក្សាបញ្ជិកា។

មាត្រា៥៣_ កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ

១_ ពន្ធលើប្រាក់បៀវត្សត្រូវដល់កំណត់និងត្រូវបង់នៅពេលបើកប្រាក់បៀវត្ស។

២_ ភ្នាក់ងារកាត់ទុកមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធលើប្រាក់បៀវត្សជារៀងរាល់ខែយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលប្រាក់បៀវត្សបានកើតឡើង។

មាត្រា៥៤_ វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើប្រាក់បៀវត្សត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី៤
អាករលើតម្លៃបន្ថែម
ផ្នែកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា៥៥_ កម្មវត្ថុនៃអាករ

អាករលើតម្លៃបន្ថែមត្រូវអនុវត្តលើការផ្គត់ផ្គង់ជាប់អាកនូវទំនិញឬសេវា។

មាត្រា៥៦ ភាពនៃអាករ

អាករលើតម្លៃបន្ថែមអនុវត្តលើរាល់ការផ្គត់ផ្គង់ជាប់អាកនូវទំនិញឬសេវានៅក្នុងព្រះរាជាណាចក្រ

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ១៧៣

មាត្រា៥៧ .- និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងជំពូកនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- ទំនិញ សំដៅដល់ ទ្រព្យរូបីក្រៅពីដីធ្លីនិងប្រាក់កាស។

២- សេវា សំដៅដល់ ការផ្តល់អ្វីមួយដែលមានតម្លៃក្រៅពីទំនិញ ដីធ្លី និងប្រាក់កាស។

៣- ការផ្តត់ផ្តង់ទំនិញ សំដៅដល់ ការផ្ទេរសិទ្ធិប្រើប្រាស់ ឬសិទ្ធិចាត់ចែងក្នុងឋានៈជាម្ចាស់កម្មសិទ្ធិទំនិញ ទោះបីមានសំណងឬគ្មានសំណងក្តី។ ការផ្តត់ផ្តង់សេវាបន្ទាប់បន្សំដែលទាក់ទិននឹងការផ្តត់ផ្តង់ទំនិញត្រូវចាត់ទុកដូចជាការផ្តត់ផ្តង់ទំនិញ។

៤- ការផ្តត់ផ្តង់សេវា សំដៅដល់ ការផ្តត់ផ្តង់ដែលមិនមែនជាការផ្តត់ផ្តង់ទំនិញ ដីធ្លី ឬប្រាក់កាសដែលធ្វើឡើងដើម្បីបានទទួលសំណងឬគ្មានសំណងក្តី។ ការផ្តត់ផ្តង់ទំនិញបន្ទាប់បន្សំដែលទាក់ទិននឹងការផ្តត់ផ្តង់សេវា ត្រូវចាត់ទុកដូចជាការផ្តត់ផ្តង់សេវា។

៥- បុគ្គល សំដៅដល់ បុគ្គលឬក្រុមបុគ្គលដែលធ្វើអាជីវកម្ម ហើយនិងបុគ្គលណាមួយទៀតដែលទាក់ទិនជាមួយនឹងបុគ្គលនោះ។

៦- ទាក់ទិន ចំពោះបុគ្គលណាមួយ មានន័យថា៖

ក- បុគ្គលណាមួយដែលមានកម្មសិទ្ធិចាប់ពី២០(ម្ភៃ)ភាគរយឡើងទៅលើតម្លៃឬសិទ្ធិបោះឆ្នោតនៃភាគកម្មនៅក្នុងដើមទុនផ្ទាល់នៃបុគ្គលដែលលើកយកមកពិចារណា។

ខ- មានការគ្រប់គ្រងរួមគ្នា ឬមាននាយករួមគ្នាជាមួយបុគ្គល។

គ- ជាសមាជិកគ្រួសារ ឬជាសហព័ទ្ធ ឬជាសមាជិកក្រុមគ្រួសារនៃសហព័ទ្ធរបស់បុគ្គល។

ឃ- បានទិញចាប់ពី៣០(សាមសិប)ភាគរយឡើងទៅនៃធាតុចេញសរុបរបស់បុគ្គលក្នុងរយៈពេល៣(បី)ខែបន្តបន្ទាប់។

៧- អាករ ក្នុងជំពូកនេះ សំដៅដល់ អាកររលើតម្លៃបន្ថែម។

ផ្នែកទី២
គោលការណ៍ទូទៅ

មាត្រា៥៨ .- បុគ្គលជាប់អាករ

បុគ្គលជាប់អាករ សំដៅដល់ បុគ្គលដែលត្រូវជាប់ពន្ធតាមរបបស្វ័យប្រកាសរហើយដែលធ្វើការផ្តត់ផ្តង់ជាប់អាករដូចមានចែងក្នុងមាត្រា៥៩នៃច្បាប់នេះ។ សម្រាប់គោលដៅនៃមាត្រានេះ បុគ្គលអនិវាសនជនដែលផ្តត់ផ្តង់ទំនិញឌីជីថលឬសេវាឌីជីថលមកក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវចាត់ទុកជាបុគ្គលជាប់អាករ។

មាត្រា៥៩ .- ការផ្តត់ផ្តង់ជាប់អាករ

លើកលែងតែមានបទប្បញ្ញត្តិផ្ទុយនៅក្នុងជំពូកនេះ ពាក្យ ការផ្តត់ផ្តង់ជាប់អាករ សំដៅដល់៖

១- ការផ្តត់ផ្តង់ទំនិញឬសេវាដោយបុគ្គលជាប់អាកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២- ការដកយកទំនិញឬសេវាមកប្រើប្រាស់ផ្ទាល់ខ្លួនដោយបុគ្គលជាប់អាករ។

៣- ការផ្តល់ជាអំណោយឬការផ្តត់ផ្តង់ក្រោមតម្លៃពិតនូវទំនិញឬសេវាដោយបុគ្គលជាប់អាករ។

៤- ការផ្តត់ផ្តង់ទំនិញឌីជីថលឬសេវាឌីជីថលមកក្នុងព្រះរាជាណាចក្រកម្ពុជាដូចមានចែងក្នុងមាត្រា៥៨ នៃច្បាប់នេះ។

៥- ការនាំចូលទំនិញមកក្នុងដែនគយនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា៦០ .- តម្លៃជាប់អាករ

តម្លៃជាប់អាករត្រូវបានកំណត់ដូចខាងក្រោម៖

១- តម្លៃជាប់អាករនៃការផ្គត់ផ្គង់ គឺជាថ្លៃទំនិញឬសេវាដែលអ្នកលក់យកពីអ្នកទិញ។ តម្លៃជាប់អាករមានតម្លៃដឹកជញ្ជូន និងតម្លៃលើខ្ចង់ដទៃទៀតដែលត្រូវទូទាត់ឱ្យអ្នកលក់ចំពោះការផ្គត់ផ្គង់នោះ រួមបញ្ចូលអាករគ្រប់ប្រភេទ លើកលែងតែអាករលើតម្លៃបន្ថែម។

២- ក្នុងករណីដែលការទូទាត់ចំពោះការផ្គត់ផ្គង់ជាប់អាកដោសំណងអ្វីមួយក្រៅពីប្រាក់កាសដើម្បីជាផលប្រយោជន៍ផ្ទាល់ឬប្រយោលដល់អ្នកលក់ សំណងនោះត្រូវគិតបញ្ចូលក្នុងតម្លៃជាប់អាករតាមតម្លៃទីផ្សារ។

៣- តម្លៃជាប់អាកររបស់ទំនិញនាំចូល គឺជាតម្លៃគិតពន្ធគយ រួមបញ្ចូលទាំងពន្ធគយនិងអាកនានានៅពេលនាំចូល។

៤- ប្រសិនបើតម្លៃជាប់អាកររបស់ទំនិញឬសេវាដែលបានផ្គត់ផ្គង់មិនតំណាងឱ្យតម្លៃពិតទេនោះរដ្ឋបាលសារពើពន្ធអាចកំណត់ចេញនូវតម្លៃមួយសម្រាប់ទំនិញឬសេវា ហើយតម្លៃនោះត្រូវចាត់ទុកជាតម្លៃត្រឹមត្រូវរហូតដល់ពេលមានកស្តុតាងបញ្ជាក់ផ្សេងដែលរដ្ឋបាលសារពើពន្ធបានយល់ព្រម។

៥- តម្លៃជាប់អាករនៃទំនិញដែលបានប្រើប្រាស់រួច ដែលបុគ្គលជាប់អាករបានទិញពីអ្នកប្រើប្រាស់ដើម្បីលក់ជាប្រចាំឬលក់ជំនួសមុខឱ្យអ្នកប្រើប្រាស់ គឺជាចំនួនលម្អៀងរវាងថ្លៃលក់និងថ្លៃទិញ ឬប្រាក់កម្រៃដែលបានមកពីការលក់ទំនិញនោះ។

មាត្រា៦១ .- ពេលផ្គត់ផ្គង់

ពេលផ្គត់ផ្គង់ត្រូវបានកំណត់ដូចខាងក្រោម៖

១- អាករលើតម្លៃបន្ថែមត្រូវដល់កំណត់និងត្រូវបង់នៅពេលផ្គត់ផ្គង់។

២- ពេលផ្គត់ផ្គង់ទំនិញឬសេវា គឺជាពេលដែលអ្នកលក់ត្រូវចេញវិក្កយបត្រ ឬជាពេលដែលអ្នកលក់បានចេញវិក្កយបត្រ ប្រសិនបើវិក្កយបត្រនោះត្រូវបានចេញមុនពេលដែលអ្នកលក់ត្រូវចេញវិក្កយបត្រ។

៣- វិក្កយបត្រអាករលើតម្លៃបន្ថែម ត្រូវចេញយ៉ាងយឺតបំផុត៧(ប្រាំពីរ)ថ្ងៃ ក្រោយការបញ្ជូនទំនិញឬការបំពេញសេវា ឬក្រោយការទូទាត់ក្នុងករណីដែលការទូទាត់ធ្វើឡើងមុនការបញ្ជូនទំនិញឬការបំពេញសេវា។ ប្រសិនបើការបញ្ជូនទំនិញពុំមានវិក្កយបត្រភ្ជាប់ជាមួយទេ ត្រូវភ្ជាប់ឯកសារបញ្ជូនទំនិញដែលបានកត់ត្រាត្រឹមត្រូវក្នុងទិនានុប្បវត្តិបញ្ជូនទំនិញ។

៤- ចំពោះការផ្គត់ផ្គង់ទំនិញឬសេវាដែលធ្វើឡើងជាបន្ត ឬដែលមានការទូទាត់ច្រើនលើក ពេលផ្គត់ផ្គង់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៥- ចំពោះការនាំចូលទំនិញ ពេលផ្គត់ផ្គង់ គឺជាពេលដែលអ្នកនាំចូលដាក់លិខិតប្រកាសជូនរដ្ឋបាលគយស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា៦២ .- ទីកន្លែងផ្គត់ផ្គង់

ទីកន្លែងផ្គត់ផ្គង់ត្រូវបានកំណត់ដូចខាងក្រោម៖

១- ការផ្គត់ផ្គង់ទំនិញត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើទំនិញនោះត្រូវបានប្រគល់ឱ្យ ទោះបីមានលក្ខណៈជាការផ្ទេរសិទ្ធិប្រើប្រាស់ឬសិទ្ធិចាត់ចែងនៅក្នុងព្រះរាជាណាចក្រកម្ពុជាក៏ដោយ។ ចំពោះករណីដែលការផ្គត់ផ្គង់ត្រូវមានការដឹកជញ្ជូន ការផ្គត់ផ្គង់ត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើទំនិញស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅពេលដែលការដឹកជញ្ជូនត្រូវចាប់ផ្តើម។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ១៧៥

២_ ការផ្តត់ផ្តង់សេវាត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើសេវានោះបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា វៀរលែងតែ៖

ក_ ការផ្តត់ផ្តង់សេវាជាប់ទាក់ទិននឹងអចលនទ្រព្យត្រូវកំណត់ថា សេវានោះបានធ្វើឡើងនៅទីកន្លែងដែលអចលនទ្រព្យនោះស្ថិតនៅ។

ខ_ ការផ្តត់ផ្តង់សេវាជាប់ទាក់ទិននឹងការដឹកជញ្ជូនត្រូវកំណត់ថា សេវានោះបានធ្វើឡើងនៅទីកន្លែងនៃការដឹកជញ្ជូននោះ។

៣_ ទំនិញត្រូវចាត់ទុកថាបាននាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើទំនិញនោះត្រូវបាននាំចូលមកក្នុងដែនគយនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា៦៣ _ ការផ្តត់ផ្តង់មិនជាប់អាករ

ការផ្តត់ផ្តង់មិនជាប់អាករមានដូចខាងក្រោម៖

១_ សេវាសិក្សាអប់រំ។

២_ សេវាប្រៃសណីយ៍សាធារណៈ។

៣_ សេវារបស់មន្ទីរពេទ្យនិងគ្លីនិក សេវាខាងវេជ្ជសាស្ត្រនិងទន្តសាស្ត្រ និងការលក់ទំនិញបន្ទាប់បន្សំខាងវេជ្ជសាស្ត្រនិងទន្តសាស្ត្រដែលទាក់ទិននឹងការបំពេញសេវាទាំងនេះ។

៤_ សេវាដឹកជញ្ជូនអ្នកដំណើរដោយប្រព័ន្ធដឹកជញ្ជូនសាធារណៈ ដែលជាកម្មសិទ្ធិទាំងស្រុងរបស់រដ្ឋ។

៥_ សេវាធានារ៉ាប់រង។

៦_ ការផ្តត់ផ្តង់ថាមពលអគ្គិសនីនិងការផ្តត់ផ្តង់ទឹកស្អាត។

៧_ ផលិតផលកសិកម្មមិនទាន់កែច្នៃផលិតក្នុងស្រុក។

៨_ សេវាប្រមូលសំរាមនិងកាកសំណល់រឹងឬរាវ។

៩_ សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

១០_ ការនាំចូលសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនដែលរួចពន្ធគយក្នុងកម្រិតតម្លៃដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

១១_ សកម្មភាពមិនស្វែងរកចំណេញដើម្បីបម្រើផលប្រយោជន៍សាធារណៈ ដែលបានទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៦៤ _ ការផ្តត់ផ្តង់មិនជាប់អាករចំពោះបេសកកម្មទូតនិងអង្គការអន្តរជាតិ

ការផ្តត់ផ្តង់មិនជាប់អាករចំពោះបេសកកម្មទូតនិងអង្គការអន្តរជាតិត្រូវបានកំណត់ដូចខាងក្រោម៖

១_ ការនាំចូលឬការទិញក្នុងស្រុកនូវទំនិញឬសេវាដោយបេសកកម្មទូតនិងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត សម្រាប់យកមកប្រើនៅក្នុងតំបន់បំពេញមុខងារដោយផ្លូវការរបស់ខ្លួន ត្រូវកំណត់ថាជាការផ្តត់ផ្តង់មិនជាប់អាករ។ ការផ្តត់ផ្តង់មិនជាប់អាករត្រូវបានធ្វើឡើងក្នុងករណីមានការបញ្ជាក់ពីប្រធានបេសកកម្មជូនរដ្ឋបាលសារពើពន្ធថា ទំនិញទាំងនោះបាននឹងត្រូវបានប្រើសម្រាប់គោលដៅនៃការប្រើប្រាស់ខាងលើតែប៉ុណ្ណោះ។

២_ ការនាំចូលឬការទិញក្នុងស្រុកនូវទំនិញឬសេវាសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលិកផ្លូវការនៃបេសកកម្មទូតនិងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត ដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវកំណត់ថាជាការផ្តត់ផ្តង់មិនជាប់អាករចំពោះតែមុខទំនិញទាំងឡាយណាដែលមានចុះនៅក្នុងបញ្ជីរាយមុខទំនិញដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៣_ ការផ្តត់ផ្តង់មិនជាប់អាករនៅក្នុងមាត្រានេះ ត្រូវឈរលើគោលការណ៍បដិការរវាងរដ្ឋាភិបាលពាក់ព័ន្ធ។

ផ្នែកទី៣
អត្រាអាករនិងការកំណត់ប្រាក់អាករ

មាត្រា៦៥ ._ អត្រាអាករ

អត្រាអាករត្រូវបានកំណត់ដូចខាងក្រោម៖

១_ អាករលើតម្លៃបន្ថែមត្រូវកំណត់តាមអត្រា១០(ដប់)ភាគរយ លើតម្លៃជាប់អាករនៃការផ្តត់ផ្តង់ជាប់អាករនីមួយៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២_ អាករលើតម្លៃបន្ថែមត្រូវកំណត់តាមអត្រា០(សូន្យ)ភាគរយ លើតម្លៃជាប់អាករនៃការផ្តត់ផ្តង់ជាប់អាករនីមួយៗចំពោះទំនិញនាំចេញពីព្រះរាជាណាចក្រកម្ពុជា ឬការផ្តត់ផ្តង់សេវាជាប់អាករដែលបានបំពេញនៅក្រៅព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងមាត្រា៦២នៃច្បាប់នេះ។

៣_ រដ្ឋបាលសារពើពន្ធអាចប្រើប្រាស់ឯកសារមួយចំនួន ដើម្បីបញ្ជាក់ថាមានការនាំចេញជាក់ស្តែងក្នុងនោះមានជាអាទិ៍ ប្រតិវេទន៍គយនាំចេញរបស់រដ្ឋបាលគយ ឯកសារនាំចូលរបស់ប្រទេសនាំចូល លិខិតឥណទានបានប្រើប្រាស់ និងការទូទាត់ដែលធនាគារក្នុងស្រុកបានទទួល។

មាត្រា៦៦ ._ ការកំណត់ប្រាក់អាករ

ប្រាក់អាករត្រូវបានកំណត់ដូចខាងក្រោម៖

១_ អាករដែលបានកំណត់ក្នុងមាត្រា៦៥នៃច្បាប់នេះ ត្រូវចាត់ទុកជាបំណុលចំពោះរដ្ឋនៅពេលផ្តត់ផ្តង់។

២_ ប្រាក់អាករត្រូវបង់ជូនរដ្ឋស្មើនឹងប្រាក់អាករលើធាតុចេញសរុបតាមអត្រាក្នុងមាត្រា៦៥នៃច្បាប់នេះ ដកឥណទានអាករលើធាតុចូលដែលបានអនុញ្ញាតសរុបក្នុងខែជាមួយគ្នា។

មាត្រា៦៧ ._ អចលកម្មរូបីដែលឈប់ប្រើប្រាស់ក្នុងអាជីវកម្ម

ក្នុងកាលណីអចលកម្មរូបីនៃអាជីវកម្មណាមួយដែលបានទទួលឥណទានអាករដូចមានចែងក្នុងមាត្រា៦៦នៃច្បាប់នេះ ត្រូវឈប់ប្រើប្រាស់នៅក្នុងអាជីវកម្មរបស់បុគ្គលជាប់អាករ ទ្រព្យនោះត្រូវចាត់ទុកថាបានលក់និងត្រូវជាប់អាករតាមតម្លៃទីផ្សារនៅពេលឈប់ប្រើប្រាស់។

មាត្រា៦៨ .- ឥណទានអាករលើជាតុចូលនិងការផ្គត់ផ្គង់មិនជាប់អាករ

ឥណទានអាករលើជាតុចូលនិងការផ្គត់ផ្គង់មិនជាប់អាករត្រូវបានកំណត់ដូចខាងក្រោម៖

១- ប្រាក់អាករដែលបុគ្គលជាប់អាករបានបង់លើទំនិញឬសេវាសម្រាប់ប្រើប្រាស់ក្នុងអាជីវកម្មដែលបុគ្គលជាប់អាករម្នាក់ទៀតបានផ្គត់ផ្គង់ឱ្យ ឬប្រាក់អាករដែលបានបង់ដោយបុគ្គលជាប់អាករក្នុងឋានៈជាអ្នកនាំចូលលើទំនិញឬសេវានាំចូលសម្រាប់ប្រើប្រាស់នៅក្នុងអាជីវកម្មរបស់ខ្លួន ត្រូវក្លាយជាឥណទានអាករលើជាតុចូលសម្រាប់កាត់កងចេញពីអាករលើជាតុចេញ។ ជាតុចូល មានន័យថា ទំនិញឬសេវាដែលបានទិញចូល ហើយជាតុចេញ មានន័យថា ទំនិញឬសេវាដែលបានលក់ចេញ។

២- ក្នុងករណីទំនិញឬសេវាទិញចូលត្រូវបានប្រើប្រាស់មួយចំណែកជាការផ្គត់ផ្គង់ជាប់អាករ និងមួយចំណែកទៀតជាការផ្គត់ផ្គង់មិនជាប់អាករ ឥណទានអាករត្រូវបានអនុញ្ញាតឱ្យតែចំពោះចំណែកដែលបានប្រើប្រាស់ជាការផ្គត់ផ្គង់ជាប់អាករ។

៣- ចំពោះការផ្គត់ផ្គង់មិនជាប់អាកនូវទំនិញឬសេវាដល់បេសកកម្មទូតនិងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត ដូចមានចែងក្នុងមាត្រា៦៤ នៃច្បាប់នេះ អ្នកផ្គត់ផ្គង់ត្រូវបានអនុញ្ញាតនូវឥណទានអាករលើជាតុចូលដោយពុំគិតពីលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រានេះ។

មាត្រា៦៩ .- ឯកសារចាំបាច់សម្រាប់សុំឥណទានអាករលើជាតុចូល

ការស្នើសុំឥណទានអាករលើជាតុចូលត្រូវភ្ជាប់មកជាមួយនូវ៖

១- វិក្កយបត្រអាករលើតម្លៃបន្ថែម ដែលបានធ្វើឡើងស្របតាមមាត្រា៧៨នៃច្បាប់នេះ។

២- ប្រតិវេទន៍គយនាំចូលដែលបានធ្វើឡើងស្របតាមច្បាប់ស្តីពីគយ និងបង្កាន់ដៃបង់ប្រាក់ពន្ធ ឬបង្កាន់ដៃបង់ប្រាក់ផ្សេងៗរបស់រដ្ឋបាលគយ។

មាត្រា៧០ .- អាករលើជាតុចូលដែលមិនអនុញ្ញាតឱ្យប្រើជាឥណទាន

អាករលើជាតុចូលដែលមិនអនុញ្ញាតឱ្យប្រើជាឥណទាន រួមមានប្រាក់អាករដែលបុគ្គលជាប់អាកបានបង់លើការចំណាយ ជាអាទិ៍មាន ការទទួលភ្ញៀវ ការកម្សាន្តឬសម្រាកលំហែ ការទិញរថយន្ត ឬការទិញផលិតផលតេលសិលាមួយចំនួន។

ផ្នែកទី៤
ការបង់ប្រាក់អាករ

មាត្រា៧១ .- កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់អាករ

បុគ្គលជាប់អាករត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់អាករជារៀងរាល់ខែយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់។

មាត្រា៧២ .- ការចាត់ចែងចំពោះចំនួនឥណទានលើស

ប្រសិនបើអាករលើធាតុចូលដែលបុគ្គលជាប់អាករបានបង់តាមមាត្រា៦៥នៃច្បាប់នេះ មានចំនួនច្រើនជាងអាករលើធាតុចេញដែលបុគ្គលនោះប្រមូលសម្រាប់ខែណាមួយៈ

១- ចំនួនលើសត្រូវប្រើជាឥណទានអាករចំពោះប្រាក់អាករដែលបុគ្គលនៅជំពាក់ខែកន្លងទៅ។

២- ចំនួនលើសដែលនៅសល់ទៀតនោះ ត្រូវចាត់ទុកជាឥណទានអាករលើធាតុចូលនៃមាត្រា៦៨ នៃច្បាប់នេះ សម្រាប់ខែបន្ទាប់។

មាត្រា៧៣ .- ការបង្វិលសងប្រាក់អាករឱ្យអ្នកនាំចេញ

រដ្ឋបាលសារពើពន្ធអាចបង្វិលសងនូវៈ

១- ឥណទានអាករលើធាតុចូលលើសប្រចាំខែ តាមការស្នើសុំរបស់បុគ្គលជាប់អាករដែលមានសកម្មភាពនាំចេញជាចម្បង ប្រសិនបើបុគ្គលនោះបានបង្ហាញឯកសារបញ្ជាក់ច្បាស់លាស់ក្នុងការនាំចេញ និងបានប្រតិបត្តិត្រឹមត្រូវនូវកាតព្វកិច្ចកាន់បញ្ជីកានិងឯកសារផ្សេងៗទៀត។

២- ប្រាក់អាករដែលទេសចរបរទេសបានបង់លើការទិញទំនិញពីបុគ្គលជាប់អាករ សម្រាប់យកទៅប្រើប្រាស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា។

មាត្រា៧៤ .- ការបង្វិលសងប្រាក់អាករក្នុងករណីមានឥណទានអាករលើសចាប់ពី៣(បី)ខែឡើងទៅ

ប្រសិនបើបុគ្គលជាប់អាករមានឥណទានអាករលើធាតុចូលលើសចាប់ពី៣(បី)ខែឡើងទៅ បុគ្គលនោះអាចដាក់ពាក្យសុំបង្វិលសងប្រាក់អាកនៅដំណាច់ខែទី៣(បី) ឬនៅក្នុងខែណាមួយជាបន្តមកទៀត។ ដើម្បីទទួលបានការបង្វិលសងប្រាក់អាករសម្រាប់ខែណាមួយ ពាក្យសុំត្រូវដាក់ស្នើក្នុងរយៈពេល២០(ម្ភៃ)ថ្ងៃក្រោយដំណាច់ខែទាំងនោះ។

មាត្រា៧៥ .- ការអនុវត្តអាករលើតម្លៃបន្ថែមចំពោះគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់

ការផ្គត់ផ្គង់ធាតុចូលផលិតកម្មក្នុងស្រុកសម្រាប់បម្រើដល់ការអនុវត្តគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដូចមានចែងក្នុងបទប្បញ្ញត្តិពាក់ព័ន្ធនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រា០(សូន្យ)ភាគរយ។

មាត្រា៧៦ .- ការទទួលខុសត្រូវចំពោះការប្រមូលនិងការបង់អាករ

ការទទួលខុសត្រូវចំពោះការប្រមូលនិងការបង់អាករត្រូវបានកំណត់ដូចខាងក្រោមៈ

១- បុគ្គលជាប់អាករឬអ្នកនាំចូល មានកាតព្វកិច្ចត្រូវបង់អាករតាមមាត្រា៦៥នៃច្បាប់នេះ លើកលែងតែផ្តល់ជាប់អាករដែលបុគ្គលជាប់អាករឬអ្នកនាំចូលបានអនុវត្ត។

២- លុះត្រាតែមានខណ្ឌពិសេសបញ្ជាក់អំពីការទទួលខុសត្រូវរបស់អ្នកទិញចំពោះប្រាក់អាករ ក្នុងករណីដែលអ្នកផ្គត់ផ្គង់មិនមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងករណីដែលមានឧបសគ្គផ្សេងទៀតដែលរារាំងការប្រមូលប្រាក់អាករពីអ្នកផ្គត់ផ្គង់ ត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ១៧៩

៣_ បុគ្គលណាមួយដែលបានធ្វើការផ្តត់ផ្តង់ទំនិញឬសេវា ក្នុងនាមម្ចាស់កម្មសិទ្ធិនិងមិនមែនក្នុងឋានៈជានិយោជិតរបស់បុគ្គលណាមួយហើយដែលមានការគ្រប់គ្រងលើការផ្តត់ផ្តង់ ត្រូវចាត់ទុកថាជាបុគ្គលជាប់អាករសម្រាប់ការផ្តត់ផ្តង់នោះ។

ផ្នែកទី៥
បទប្បញ្ញត្តិខាងរដ្ឋបាល

មាត្រា៧៧ _ ការចុះបញ្ជី

ការចុះបញ្ជីត្រូវបានកំណត់ដូចខាងក្រោម៖

១_ បុគ្គលជាប់អាករដូចមានចែងក្នុងមាត្រា៥៨នៃច្បាប់នេះ ត្រូវធ្វើការចុះបញ្ជីសម្រាប់អាករលើតម្លៃបន្ថែមក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ក្រោយថ្ងៃដែលបុគ្គលនោះក្លាយជាបុគ្គលជាប់អាករ។

២_ ចំពោះបុគ្គលដែលមានការតម្រូវឱ្យធ្វើការចុះបញ្ជី ហើយមិនបានធ្វើការចុះបញ្ជី រដ្ឋបាលសារពើពន្ធអាចធ្វើការចុះបញ្ជីបុគ្គលនោះ ចាប់តាំងពីពេលដែលបុគ្គលនោះត្រូវមកធ្វើការចុះបញ្ជី។ បុគ្គលដែលត្រូវបានចុះបញ្ជីតាមបែបនេះ ត្រូវទទួលខុសត្រូវចំពោះប្រាក់អាករទាំងអស់ក្នុងមាត្រា៦៥នៃច្បាប់នេះ ចាប់តាំងពីកាលបរិច្ឆេទដែលបុគ្គលនោះត្រូវមកធ្វើការចុះបញ្ជី។

៣_ សម្រាប់ក្រុមបុគ្គលទាក់ទិនពីរនាក់ឬច្រើននាក់ ដែលក្នុងនោះបុគ្គលម្នាក់ឬច្រើននាក់មិនមែនជាបុគ្គលជាប់អាករទេនោះ រដ្ឋបាលសារពើពន្ធអាចចាត់ទុកបុគ្គលជាប់អាករណាមួយថាបានចុះបញ្ជីសម្រាប់សកម្មភាពសេដ្ឋកិច្ចទាក់ទិនទាំងមូលឬភាគណាមួយ។ ប្រសិនបើគ្មានបុគ្គលទាក់ទិនណាម្នាក់ជាបុគ្គលជាប់អាករទេនោះ រដ្ឋបាលសារពើពន្ធអាចចុះបញ្ជីនូវបុគ្គលក្នុងក្រុមម្នាក់ឬច្រើននាក់សម្រាប់សកម្មភាពសេដ្ឋកិច្ចទាក់ទិនទាំងមូលឬភាគណាមួយ។

៤_ សម្រាប់គោលដៅនៃការចុះបញ្ជីនិងដោយមានការយល់ព្រមពីរដ្ឋបាលសារពើពន្ធ ចំពោះបុគ្គលជាប់អាករមួយក្រុមដែលជាប់ទាក់ទិនគ្នាដូចមានចែងក្នុងមាត្រា៥៧នៃច្បាប់នេះ សកម្មភាពរបស់សមាជិកនានានៅក្នុងក្រុម អាចចាត់ទុកជាសកម្មភាពរបស់សមាជិកជ្រើសតាំងតែម្នាក់ប៉ុណ្ណោះ។ ក្នុងករណីនេះសមាជិកម្នាក់ៗនៅក្នុងក្រុមត្រូវមានការទទួលខុសត្រូវរួមគ្នានិងយ៉ាងពេញលេញចំពោះការប្រតិបត្តិតាមបទប្បញ្ញត្តិនៃជំពូកនេះ។

មាត្រា៧៨ _ វិក្កយបត្រអាករលើតម្លៃបន្ថែម

វិក្កយបត្រអាករលើតម្លៃបន្ថែមត្រូវបានកំណត់ដូចខាងក្រោម៖

១_ បុគ្គលជាប់អាករដែលធ្វើការផ្តត់ផ្តង់ ត្រូវចេញវិក្កយបត្រអាករដោយមានដាក់ចំណងជើងថាវិក្កយបត្រអាករ ហើយមានចុះលេខរៀងត្រឹមត្រូវឱ្យទៅអ្នកទិញដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស និងត្រូវចេញវិក្កយបត្រធម្មតាទៅឱ្យអ្នកទិញដែលមិនស្ថិតនៅក្រោមរបបស្វ័យប្រកាស។



២_ បុគ្គលទាំងឡាយមិនអាចចេញវិក្កយបត្រឬឯកសារផ្សេងទៀតបញ្ជាក់នូវទឹកប្រាក់ណាមួយថាជាការទូទាត់សងលើការផ្តត់ផ្តង់ទំនិញឬសេវាបានទេ លើកលែងតែបុគ្គលនោះជាបុគ្គលជាប់អាករបានចុះបញ្ជីស្របតាមមាត្រា៧៧នៃច្បាប់នេះ ហើយទំនិញឬសេវាផ្តត់ផ្តង់គឺជាទំនិញឬសេវាជាប់អាករ។

៣_ ក្រៅពីទណ្ឌកម្មដទៃទៀត ប្រសិនបើវិក្កយបត្រណាមួយត្រូវបានរកឃើញថាក្លែងបន្លំជាវិក្កយបត្រអាករលើតម្លៃបន្ថែម ហើយវិក្កយបត្រនោះបានបង្ហាញថា មានទឹកប្រាក់អាករមួយចំនួនត្រូវបង់ បុគ្គលអ្នកចេញវិក្កយបត្រត្រូវបង់ជូនរដ្ឋបាលសារពើពន្ធក្នុងរយៈពេល៧(ប្រាំពីរ)ថ្ងៃ ក្រោយកាលបរិច្ឆេទចេញវិក្កយបត្រនូវទឹកប្រាក់ដែលបានចុះលើវិក្កយបត្រនោះ ទោះបីជាទឹកប្រាក់អាករត្រូវបង់មែនឬមិនមែនក្តី។

៤_ ក្នុងករណីមានការលក់រាយ ដែលក្នុងនោះ ការលក់ភាគច្រើនមិនបានធ្វើជាមួយបុគ្គលជាប់អាករវិក្កយបត្រដែលតម្រូវដោយកថាខណ្ឌទី១នៃមាត្រានេះ ត្រូវចាត់ទុកថាបានបំពេញគ្រប់គ្រាន់ ប្រសិនបើអ្នកលក់បានផ្តល់បង្កាន់ដៃទទួលប្រាក់លម្អិតដែលបានកត់ត្រាក្នុងបញ្ជីបេឡា ឬក៏ឯកសារផ្សេងទៀត។

៥_ ចំពោះការនាំចូល ប្រតិវេទន៍គយដែលបានបំពេញត្រឹមត្រូវនិងដែលមានសេចក្តីបញ្ជាក់អំពីការបង់ប្រាក់អាករ ត្រូវប្រើប្រាស់ជាឯកសារត្រួតពិនិត្យដើម្បីកំណត់លក្ខណៈអាចទទួលបាននូវឥណទានអាករ។

មាត្រា៧៩ ._ ការមិនបានចេញវិក្កយបត្រអាករលើតម្លៃបន្ថែម

ការមិនបានចេញវិក្កយបត្រអាករត្រូវទទួលរងទណ្ឌកម្មដូចខាងក្រោម៖

១_ ក្រៅពីទណ្ឌកម្មដទៃទៀត ប្រសិនបើរដ្ឋបាលសារពើពន្ធរកឃើញជាលើកទី២(ពីរ)ថា គ្រឹះស្ថានអាជីវកម្មណាមួយរបស់បុគ្គលជាប់អាករមិនបានចេញវិក្កយបត្រតាមការតម្រូវនោះ រដ្ឋបាលសារពើពន្ធអាចបិទគ្រឹះស្ថានអាជីវកម្មនោះក្នុងរយៈពេលមានកំណត់មួយដែលមិនលើសពី៧(ប្រាំពីរ)ថ្ងៃ។

២_ ប្រសិនបើគ្រឹះស្ថានអាជីវកម្មណាមួយដែលធ្លាប់ត្រូវបានបិទដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ នៅតែប្រព្រឹត្តអំពើល្មើសបែបនោះជាថ្មីទៀត គ្រឹះស្ថានអាជីវកម្មនោះអាចត្រូវបានបិទជាថ្មីទៀតក្នុងរយៈពេលមានកំណត់មួយដែលមិនលើសពី៧(ប្រាំពីរ)ថ្ងៃ។

មាត្រា៨០ ._ បញ្ជី កំណត់ត្រា និងព័ត៌មាន

បញ្ជី កំណត់ត្រា និងព័ត៌មានសម្រាប់អាករលើតម្លៃបន្ថែម ត្រូវបានកំណត់ដូចខាងក្រោម៖

១_ បុគ្គលជាប់អាករ ត្រូវប្រើប្រាស់ប្រព័ន្ធកត់ត្រាសាច់ប្រាក់ដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ និងត្រូវរក្សាទុកនូវច្បាប់ចម្លងវិក្កយបត្រទាំងអស់ដែលបានចេញនិងវិក្កយបត្រទាំងអស់ដែលបានទទួល។

២_ បុគ្គលជាប់អាករ ត្រូវកត់ត្រានិងរក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជីកំណត់ត្រានៃរាល់កិច្ចការជំនួញដែលបានធ្វើ ហើយត្រូវមានគណនីតាមដានទឹកប្រាក់អាករដែលបានប្រមូលលើការលក់និងទឹកប្រាក់អាករដែលបានបង់លើការទិញនានារបស់ខ្លួន ព្រមទាំងសេចក្តីកែតម្រូវផ្សេងៗលើតម្លៃលក់ឬទឹកប្រាក់អាករទៅតាមបែបបទដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ។

៣_ កិច្ចការដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រានេះ ត្រូវធ្វើប្រចាំថ្ងៃ ហើយត្រូវធ្វើការបូកសរុបនិងគណនាសមតុល្យនៅដំណាច់ខែនីមួយៗ។ បុគ្គលជាប់អាករត្រូវធ្វើជារៀងរាល់ខែនូវសម្រង់អាករលើតម្លៃបន្ថែមទៅតាមបែបបទកំណត់ដោយរដ្ឋបាលសារពើពន្ធ។

៤_ វិក្កយបត្រ កំណត់ត្រា និងឯកសារផ្សេងទៀត ដែលជាប់ទាក់ទិននឹងអាករនេះ ត្រូវរក្សាទុកតាមលំដាប់ថ្ងៃខែ តាមបែបបទ និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់ក្នុងរយៈពេល១០(ដប់)ឆ្នាំក្រោយការបិទាប់កិច្ចការជំនួញចុងក្រោយបំផុតដែលជាប់ទាក់ទិននឹងឯកសារទាំងនេះ។





៥_ ប្រព្រឹត្តកត់ត្រាសាច់ប្រាក់ ឯកសារ និងកំណត់ត្រាទាំងអស់ដែលត្រូវរក្សាទុកតាមមាត្រានេះ ព្រមទាំងឯកសារនិងកំណត់ត្រាឯទៀតដែលទាក់ទិននឹងអាជីវកម្មរបស់បុគ្គល ត្រូវផ្តល់ឱ្យរដ្ឋបាលសារពើពន្ធត្រួតពិនិត្យនៅពេលមានការស្នើសុំ។

មាត្រា៨១ .- វិធានពិសេសសម្រាប់ការនាំចូល

បទប្បញ្ញត្តិនានានៃជំពូកនេះដែលទាក់ទិននឹងការនាំចូល ត្រូវគ្រប់គ្រងដោយរដ្ឋបាលគយទៅតាមច្បាប់ស្តីពីគយ។

មាត្រា៨២ .- ការបញ្ឈប់អាជីវកម្មនិងការផ្ទេរអាជីវកម្ម

វិធាននៃការបញ្ឈប់អាជីវកម្មនិងការផ្ទេរអាជីវកម្មត្រូវបានកំណត់ដូចខាងក្រោម៖

១- ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ក្រោយការបញ្ឈប់អាជីវកម្ម បុគ្គលជាប់អាករត្រូវដាក់លិខិតប្រកាសជូនរដ្ឋបាលសារពើពន្ធតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់ ដោយភ្ជាប់មកជាមួយនូវព័ត៌មានលម្អិតអំពីការលក់និងការទិញនានា ក្រោយពីការប្រកាសសារពើពន្ធចុងក្រោយបំផុត និងព័ត៌មានលម្អិតអំពីទំនិញទាំងអស់នៅក្នុងស្តុកដែលមិនទាន់បង់អាករឬដែលបានទទួលឥណទានអាករួចហើយ ព្រមទាំងបង់ប្រាក់អាករដល់កំណត់ទាំងនោះ។

២- ការផ្ទេរអាជីវកម្មពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត មិនត្រូវជាប់អាកររលើតម្លៃបន្ថែមទេ។

៣- វិធាននិងនីតិវិធីសម្រាប់ការបញ្ឈប់និងការផ្ទេរអាជីវកម្មត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៨៣ .- ឥណទានអាករសម្រាប់ទំនិញស្តុកចំពោះបុគ្គលចុះបញ្ជីថ្មី

ឥណទានអាកចំពោះទំនិញស្តុកត្រូវបានកំណត់ដូចខាងក្រោម៖

១- ចំពោះបុគ្គលទើបបានចុះបញ្ជី ហើយនៅថ្ងៃចុះបញ្ជីនោះមានស្តុកទំនិញដែលបានបង់អាកររលើតម្លៃបន្ថែមរួចហើយ បុគ្គលនោះអាចដាក់ពាក្យសុំឱ្យរដ្ឋបាលសារពើពន្ធអនុញ្ញាតនូវឥណទានអាករ ចំពោះប្រាក់អាករដែលបានបង់លើស្តុកទាំងនោះ បន្ទាប់ពីរដ្ឋបាលសារពើពន្ធបានត្រួតពិនិត្យឃើញថា វិក្កយបត្រឬច្បាប់ចម្លងនៃប្រតិវេទន៍គយរបស់ទំនិញទាំងនោះមានលក្ខណៈត្រឹមត្រូវ។

២- បើមានការឯកភាពចំពោះលក្ខណៈត្រឹមត្រូវនៃឯកសារទាំងនោះហើយ រដ្ឋបាលសារពើពន្ធអាចអនុញ្ញាតនូវឥណទានអាករចំពោះការផ្គត់ផ្គង់ដែលបានធ្វើក្នុងអំឡុងពេល៦០(ហុកសិប)ថ្ងៃ មុនថ្ងៃចុះបញ្ជី។ ឥណទានអាកនេះអាចយកទៅប្រើក្នុងការប្រកាសសារពើពន្ធទាំងឡាយសម្រាប់អាកនេះ ទៅតាមលក្ខខណ្ឌដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ។

មាត្រា៨៤ .- វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលអាករ



វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលអាករលើតម្លៃបន្ថែមត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី៥
អាករពិសេស

មាត្រា៨៥ .- កម្មវត្ថុនៃអាករ

អាករពិសេសត្រូវអនុវត្តលើទំនិញឬសេវាមួយចំនួនដែលមានលក្ខណៈប្រណីត ឬមិនមែនជាតម្រូវការចាំបាច់ក្នុងជីវភាពប្រចាំថ្ងៃ ឬប៉ះពាល់ដល់សុខភាព សង្គម ឬបរិស្ថាន។

មាត្រា៨៦ .- វិសាលភាពនៃអាករ

អាករពិសេសអនុវត្តលើការនាំចូល ការផលិត ឬការចែកចាយទំនិញ ឬការផ្តត់ផ្តង់សេវាដែលជាប់អាករពិសេសសម្រាប់ប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា៨៧ .- និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងជំពូកនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- បុគ្គលជាប់អាករពិសេស សំដៅដល់ អ្នកនាំចូល ឬអ្នកផលិតទំនិញ ឬអ្នកផ្តត់ផ្តង់សេវាជាប់អាករពិសេស។

២- ការនាំចូល សំដៅដល់ សកម្មភាពនាំចូលទំនិញមកក្នុងដែនគយនៃព្រះរាជាណាចក្រកម្ពុជាដោយបុគ្គលណាមួយ។

៣- អ្នកនាំចូល សំដៅដល់ បុគ្គលណាមួយដែលធ្វើការនាំចូលដោយខ្លួនឯងឬដោយបុគ្គលដទៃ។ សម្រាប់គោលដៅនៃកថាខណ្ឌនេះ អ្នកទទួលទំនិញ បុគ្គលជាម្ចាស់កម្មសិទ្ធិ បុគ្គលដែលនឹងទៅជាម្ចាស់កម្មសិទ្ធិ ឬអ្នកមានសិទ្ធិចាត់ចែងលើកម្មសិទ្ធិទំនិញមុនពេលដែលទំនិញនោះឈប់ជាកម្មវត្ថុនៃការត្រួតពិនិត្យគយ ត្រូវបានចាត់ទុកថាជាអ្នកនាំចូលដែរ។

៤- ការផលិត សំដៅដល់ សកម្មភាពបំប្លែងវត្ថុធាតុដើម ផ្តុំ ដំឡើង វេចខ្ចប់ ច្រកបំពេញ ឱ្យទៅជាផលិតផលពាក់កណ្តាលសម្រេចឬផលិតផលសម្រេច។

៥- អ្នកផលិត សំដៅដល់ បុគ្គលណាមួយដែលធ្វើការផលិតទំនិញ ឬបុគ្គលណាមួយដែលជួលបុគ្គលដទៃទៀតផលិតទំនិញឱ្យខ្លួន។

៦- អ្នកចែកចាយ សំដៅដល់ បុគ្គលដែលធ្វើការផ្តត់ផ្តង់ទំនិញដែលនាំចូល ឬផលិតដោយខ្លួនឯង ឬទិញបន្តពីអ្នកនាំចូលឬពីអ្នកផលិត។

៧- ការផ្តត់ផ្តង់ សំដៅដល់ ការលក់ ឬការដកយកមកប្រើប្រាស់ផ្ទាល់ខ្លួន ឬការផ្តល់ជាអំណោយ ឬការលក់អាករតម្លៃពិតនូវទំនិញឬសេវាដោយបុគ្គលជាប់អាករពិសេស។



៨- តែមប្រ៊ីអាករ សំដៅដល់ សន្លឹកតែមប្រ៊ីសម្រាប់បិទលើទំនិញជាប់អាករពិសេសដើម្បីបញ្ជាក់ថាជាប់អាករពិសេស។

៩- អាករ ក្នុងជំពូកនេះ សំដៅដល់ អាករពិសេស។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ១៨៣

មាត្រា៨៨ .- ទំនិញឬសេវាជាប់អាករពិសេស

ដោយមិនកំណត់ត្រឹមតែដូចខាងក្រោមនេះ ទំនិញឬសេវាដែលជាប់អាករពិសេស៖

១- ទំនិញមួយចំនួនមានជាអាទិ៍៖

ក- ផលិតផលគេលសិល៖

- ប្រេងសាំង
- ប្រេងម៉ាស៊ូត
- ប្រេងសាំងយន្តហោះ
- ប្រេងរំអិល។

ខ- គេសដ្ឋ:៖

- គេសដ្ឋ:គ្មានជាតិសុភ មានជាអាទិ៍ គេសដ្ឋ:ដែលមានជាតិឧស្ម័ន មានជាក់ស្តែ ឬសារជាតិផ្អែម ឬក្លិនផ្សេងៗ និងគេសដ្ឋ:គ្មានជាតិសុភដទៃទៀត លើកលែងតែទឹកនិងទឹកវ៉ែ ទឹកដោះគោ និងទឹកដមផ្លែឈើឬបន្លែ
- ស្រា
- ស្រាបៀរ
- គេសដ្ឋ:មេរ័យផ្សេងទៀត។

គ- បារី បារីស៊ីហ្គា និងបារីគ្រប់ប្រភេទ។

ឃ- គ្រឿងអេឡិចត្រូនិក។

ង- ទោចក្រយានយន្ត។

ច- រថយន្ត។

ឆ- គ្រឿងបន្លាស់យានយន្ត។

ជ- ផលិតផលប្លាស្ទិក។

ឈ- ផលិតផលគ្រឿងសម្អាង។

ញ- ផលិតផលកញ្ចក់ជាគ្រឿងសំណង់។

ដ- ស៊ីម៉ងត៍។

២- សេវាមួយចំនួនមានជាអាទិ៍៖

ក- សេវាទូរគមនាគមន៍។

ខ- សេវាជឹកជញ្ជូនអ្នកដំណើរផ្លូវអាកាស។

គ- សេវាលំហែកម្សាន្ត។

៣- រាជរដ្ឋាភិបាលអាចចេញអនុក្រឹត្យកំណត់បន្ថែមឬព្យួរនូវមុខទំនិញឬសេវាជាប់អាករពិសេសតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៨៩ .- អត្រាអាករពិសេស



១- អត្រាអាករពិសេសត្រូវកំណត់ជាអត្រាភាគរយលើតម្លៃទំនិញឬសេវាដែលជាមូលដ្ឋានគិតអាករពិសេស ឬជាតម្លៃកំណត់ទៅលើទម្ងន់ ចំណុះ ទំហំ ឬបរិមាណ។

២- អត្រាអាករពិសេសត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិង

មាត្រា៥០ .- មូលដ្ឋានគិតអាករពិសេស

មូលដ្ឋានគិតអាករពិសេសត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៥១ .- វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលអាករ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលអាកពិសេសត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី៦
អាករសម្រាប់បំភ្លឺសាធារណៈ

មាត្រា៥២ .- កម្មវត្ថុនៃអាករ

អាករសម្រាប់បំភ្លឺសាធារណៈត្រូវអនុវត្តលើការផ្គត់ផ្គង់ផលិតផលសុរា មេរ៉ាយ ឬថ្នាំជក់។

មាត្រា៥៣ .- វិសាលភាពនៃអាករ

អាករសម្រាប់បំភ្លឺសាធារណៈអនុវត្តលើការផ្គត់ផ្គង់នូវផលិតផលសុរា មេរ៉ាយ ឬថ្នាំជក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា៥៤ .- និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងជំពូកនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- សុរា សំដៅដល់ ផលិតផលគ្រប់ប្រភេទដែលមានជាតិអាល់កុល។

២-មេរ៉ាយ សំដៅដល់ ទឹកស្រវឹងដែលធ្វើឡើងដោយការត្រាំគ្រឿងផ្សំផ្សេងៗ ដែលមានជាអាទិ៍ស្រាបៀរ ឬភេសជ្ជៈមានជាតិស្រវឹង។

៣- ថ្នាំជក់ សំដៅដល់ ផលិតផលទាំងមូលឬមួយផ្នែកដែលធ្វើដោយស្លឹកថ្នាំជក់ជាវត្ថុធាតុដើមហើយដែលផលិតសម្រាប់យកទៅជក់។

៤- អាករ ក្នុងជំពូកនេះ សំដៅដល់ អាករសម្រាប់បំភ្លឺសាធារណៈ។

មាត្រា៥៥ .- អត្រាអាករ

អត្រាអាករសម្រាប់បំភ្លឺសាធារណៈត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៥៦ .- មូលដ្ឋានគិតអាករ

មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៥៧ .- ពេលផ្គត់ផ្គង់

១- អាករសម្រាប់បំភ្លឺសាធារណៈត្រូវកំណត់និងត្រូវបង់នៅពេលផ្គត់ផ្គង់ដំបូង។

២- វិធាននៃការផ្គត់ផ្គង់ត្រូវអនុវត្តស្របតាមវិធាននៃការផ្គត់ផ្គង់សម្រាប់អាករលើតម្លៃបន្ថែមដូចមានចែងក្នុងកថាខណ្ឌទី១ ដល់កថាខណ្ឌទី៤នៃមាត្រា៦១នៃច្បាប់នេះ។

មាត្រា៩៨ .- កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់អាករ

បុគ្គលជាប់អាករត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់អាករសម្រាប់បំភ្លឺសាធារណៈជារៀងរាល់ខែយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលផលិតផលត្រូវបានផ្គត់ផ្គង់។

មាត្រា៩៩ .- វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលអាករ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី៧
អាករលើការស្នាក់នៅ

មាត្រា១០០ .- កម្មវត្ថុនៃអាករ

អាករលើការស្នាក់នៅត្រូវអនុវត្តលើការផ្គត់ផ្គង់សេវាស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា១០១ .- វិសាលភាពនៃអាករ

អាករលើការស្នាក់នៅអនុវត្តលើការផ្គត់ផ្គង់សេវាស្នាក់នៅក្នុងសណ្ឋាគារក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា១០២ .- និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងជំពូកនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- សណ្ឋាគារ សំដៅដល់ ទីកន្លែងផ្គត់ផ្គង់សេវាស្នាក់នៅមានលក្ខណៈជាបន្ទប់ គ្រែ និងមានផ្តល់នូវសម្បទានិងសេវាផ្សេងៗទៀតទៅតាមប្រភេទទីកន្លែងផ្តល់សេវាស្នាក់នៅនីមួយៗ ដូចជា សណ្ឋាគារ សណ្ឋាគារអាជ្ញាតមុិន សណ្ឋាគារស្វីត សណ្ឋាគារវីសត ម៉ូតែល ឡដ្ជ បឹងកាឡ្ប ផ្ទះសំណាក់ឬផ្ទះភ្ញៀវ កន្លែងបោះជំរំទេសចរណ៍ និងទីកន្លែងផ្តល់សេវាស្នាក់នៅដទៃទៀតដែលមានលក្ខណៈប្រហាក់ប្រហែល ទោះបីជាដាក់ឈ្មោះថាជាអ្វីក៏ដោយ។ ពាក្យ **សណ្ឋាគារ** មិនរួមបញ្ចូលផ្ទះជួល ឬផ្ទះល្វែងជួលរយៈពេលខ្លីនិងរយៈពេលវែងទេ។

២- អាករ ក្នុងជំពូកនេះ សំដៅដល់ អាករលើការស្នាក់នៅ។

មាត្រា១០៣ .- អត្រាអាករ

អាករលើការស្នាក់នៅត្រូវកំណត់តាមអត្រា២(ពីរ)ភាគរយ។

មាត្រា១០៤ .- មូលដ្ឋានគិតអាករ

មូលដ្ឋានគិតអាករលើការស្នាក់នៅ គឺជាថ្លៃស្នាក់នៅ រួមបញ្ចូលទាំងបន្ទុកផ្សេងៗ ព្រមទាំងពន្ធអាករផ្សេងៗ លើលែងតែអាករលើតម្លៃបន្ថែមនិងអាករលើការស្នាក់នៅខ្លួនឯង។

មាត្រា១០៥ .- ពេលផ្គត់ផ្គង់

ពេលនៃការផ្គត់ផ្គង់សេវាស្នាក់នៅត្រូវអនុវត្តស្របតាមវិធាននៃការផ្គត់ផ្គង់សេវាសម្រាប់អាករលើតម្លៃបន្ថែម ដូចមានចែងក្នុងមាត្រា៦១នៃច្បាប់នេះ។

មាត្រា១០៦ .- កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់អាករ

បុគ្គលជាប់អាករត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់អាករលើការស្នាក់នៅជារៀងរាល់ខែយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលសេវាស្នាក់នៅត្រូវបានផ្តត់ផ្តង់។

មាត្រា១០៧ .- វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលអាករ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលអាករលើការស្នាក់នៅត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី៨
ពន្ធប៉ាតង់

មាត្រា១០៨ .- កម្មវត្ថុនៃពន្ធ

ពន្ធប៉ាតង់ គឺជាពន្ធប្រចាំឆ្នាំដែលត្រូវបានកំណត់លើសកម្មភាពអាជីវកម្មនីមួយៗរបស់អ្នកជាប់ពន្ធដោយផ្អែកលើប្រភេទអ្នកជាប់ពន្ធនិងកម្រិតផលរបរ។

មាត្រា១០៩ .- វិសាលភាពនៃពន្ធ

ពន្ធប៉ាតង់អនុវត្តលើអ្នកជាប់ពន្ធដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា១១០ .- ការលើកលែងពន្ធ

ពន្ធប៉ាតង់ត្រូវបានលើកលែងដូចខាងក្រោម៖

១- ស្ថាប័នរដ្ឋ បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត។

២- សកម្មភាពរបស់អង្គការណាមួយដែលត្រូវបានរៀបចំឡើង និងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬអប់រំ និងគ្មានចំណែកណាមួយនៃទ្រព្យឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន។

៣- គ្រប់សកម្មភាពអាជីវកម្មដែលមានផលរបរប្រចាំឆ្នាំក្រោមកម្រិតផលរបរអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដូចមានកំណត់ក្នុងមាត្រា៦នៃច្បាប់នេះ។

មាត្រា១១១ .- អត្រាពន្ធ

អត្រាពន្ធប៉ាតង់ត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា១១២ .- កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ



១- ពន្ធប៉ាតង់ត្រូវបង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ។

២- អ្នកជាប់ពន្ធដែលចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល៦(ប្រាំមួយ)ខែដើមឆ្នាំ ត្រូវបង់ប្រាក់ពន្ធប៉ាតង់រយៈពេលមួយឆ្នាំ ប៉ុន្តែប្រសិនបើចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល៦(ប្រាំមួយ)ខែចុងឆ្នាំ អ្នកជាប់ពន្ធត្រូវបង់ប្រាក់ពន្ធប៉ាតង់ពាក់កណ្តាល។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ១៨៧

មាត្រា១១៣ .- សកម្មភាពនិងទីកន្លែងប្រកបអាជីវកម្មជាប់ពន្ធ

សកម្មភាពនិងទីកន្លែងប្រកបអាជីវកម្មជាប់ពន្ធត្រូវកំណត់ដូចខាងក្រោម៖

១- អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មច្រើន ត្រូវបង់ពន្ធប៉ាតង់ផ្សេងគ្នាទៅតាមសកម្មភាពអាជីវកម្មនីមួយៗ។

២- សកម្មភាពជាឧបសម្ព័ន្ធនានានៃសកម្មភាពអាជីវកម្ម ត្រូវបានចាត់ទុកថាជាសកម្មភាពអាជីវកម្មតែមួយ។

៣- អ្នកជាប់ពន្ធដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់មុខរបរអាជីវកម្មតែមួយនៅក្នុងរាជធានី ខេត្តតែមួយ ត្រូវបង់ពន្ធប៉ាតង់តែមួយ។

៤- អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មនៅក្នុងរាជធានី ខេត្តផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់ទៅតាមរាជធានី ខេត្តដែលអាជីវកម្មនោះស្ថិតនៅ។

៥- អ្នកជាប់ពន្ធដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់សកម្មភាពអាជីវកម្មតែមួយដែលស្ថិតនៅតាមរាជធានី ខេត្តផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់អប្បបរមាសម្រាប់ប្រភេទអ្នកជាប់ពន្ធនីមួយៗ ទៅតាមរាជធានី ខេត្តដែលអាជីវកម្មនោះស្ថិតនៅ។

៦- ករណីមានការផ្លាស់ប្តូរទីកន្លែងទៅរាជធានី ខេត្តផ្សេង ឬផ្លាស់ប្តូរសកម្មភាពអាជីវកម្មថ្មី ត្រូវបង់ប្រាក់ពន្ធប៉ាតង់ថ្មីម្តងទៀត។

មាត្រា១១៤ .- បណ្ណពន្ធប៉ាតង់

១- រដ្ឋបាលសាររតើពន្ធត្រូវចេញបណ្ណពន្ធប៉ាតង់ជូនអ្នកជាប់ពន្ធបន្ទាប់ពីប្រាក់ពន្ធប៉ាតង់ត្រូវបានបង់រួចរាល់។

២- អ្នកជាប់ពន្ធមានកាតព្វកិច្ចដាក់តាំងបង្ហាញបណ្ណពន្ធប៉ាតង់ដែលមានសុពលភាពនៅតាមទីតាំងប្រកបអាជីវកម្មរបស់ខ្លួន។

មាត្រា១១៥ .- វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ

វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី៩
ពន្ធលើផ្ទាំងផ្សព្វផ្សាយ

មាត្រា១១៦ .- កម្មវត្ថុនៃពន្ធ

ពន្ធលើផ្ទាំងផ្សព្វផ្សាយត្រូវអនុវត្តលើផ្ទាំងផ្សព្វផ្សាយគ្រប់ប្រភេទ។

មាត្រា១១៧ .- វិសាលភាពនៃពន្ធ

ពន្ធលើផ្ទាំងផ្សព្វផ្សាយអនុវត្តលើការផ្សព្វផ្សាយតាមគ្រប់រូបភាពទាំងចល័តនិងអចល័តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា១១៨ .- និយមន័យ

សម្រាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីពន្ធលើផ្ទាំងផ្សព្វផ្សាយ ពាក្យ ផ្ទាំងផ្សព្វផ្សាយ សំដៅដល់៖

១- បណ្តាប្រកាសផ្សាយពាណិជ្ជកម្មធ្វើឡើងដោយកៅស៊ូ ក្រដាសធម្មតា កំណាត់ ឬវត្ថុផ្សេងៗ។

២- ស្លាកអាជីវកម្មដ្ឋានសម្រាប់ដាក់សម្គាល់ឈ្មោះ ទីតាំង ទីស្នាក់ការ ការិយាល័យ ឬទីកន្លែងប្រកបអាជីវកម្មនានា។

៣- ផ្ទាំងអក្សរ ឬផ្ទាំងរូបភាពសម្រាប់គោលបំណងពាណិជ្ជកម្ម។

មាត្រា១១៩ .- ការលើកលែងពន្ធ

ពន្ធលើផ្ទាំងផ្សព្វផ្សាយត្រូវបានលើកលែងចំពោះផ្ទាំងផ្សព្វផ្សាយក្នុងគោលបំណងមិនស្វែងរកប្រាក់ចំណេញដូចខាងក្រោម៖

១- ស្លាករបស់ស្ថាប័នរដ្ឋ។

២- ស្លាករបស់ស្ថានទូតឬស្ថានកុងស៊ុលបរទេស អង្គការដៅតិនិងអង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់ដ្ឋាភិបាលដទៃទៀត អង្គការមិនមែនរដ្ឋាភិបាលនិងសមាគមនានា។

៣- ផ្ទាំងផ្សព្វផ្សាយដែលមានគោលដៅអប់រំសង្គមជាប្រយោជន៍សាធារណៈ មានដូចជាអាទិ៍ការថែរក្សានិងការពារបរិស្ថាន ការបញ្ឈប់អំពើហិង្សាក្នុងគ្រួសារ ការការពារធនធានធម្មជាតិ ការអប់រំចរាចរណ៍ និងការអប់រំសុខភាព។

មាត្រា១២០ .- អត្រាពន្ធនិងមូលដ្ឋានគិតពន្ធ

អត្រាពន្ធនិងមូលដ្ឋានគិតពន្ធលើផ្ទាំងផ្សព្វផ្សាយត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា១២១ .- កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ

ពន្ធលើផ្ទាំងផ្សព្វផ្សាយត្រូវបង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ។

មាត្រា១២២ .- ការខកខានមិនបានដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ

ប្រសិនបើអ្នកជាប់ពន្ធមិនបានបង់ពន្ធលើផ្ទាំងផ្សព្វផ្សាយដូចមានចែងក្នុងជំពូកនេះ អាជ្ញាធរមានសមត្ថកិច្ចមិនត្រូវចេញលិខិតអនុញ្ញាតទាក់ទិននឹងស្លាកឬផ្ទាំងផ្សព្វផ្សាយដែលមិនទាន់បានបង់ពន្ធលើផ្ទាំងផ្សព្វផ្សាយឡើយ។

មាត្រា១២៣ .- វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើផ្ទាំងផ្សព្វផ្សាយត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី១០
ពន្ធលើប្រតិបត្តិការប្រេងកាតនិងឧស្ម័នធម្មជាតិ
ផ្នែកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១២៤ .- កម្មវត្ថុនៃពន្ធ

ពន្ធលើប្រតិបត្តិការប្រេងកាតនិងឧស្ម័នធម្មជាតិអនុវត្តលើការធ្វើប្រតិបត្តិការប្រេងកាតនិងឧស្ម័នធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា១២៥ .- វិសាលភាពនៃពន្ធ

បទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាតនិងឧស្ម័នធម្មជាតិអនុវត្តលើប្រតិបត្តិការប្រេងកាតនិងឧស្ម័នធម្មជាតិនៅក្នុងបូរណភាពទឹកដីនិងអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងបាតសមុទ្រនិងស្រទាប់ដីក្រោមបាតសមុទ្រនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខនិងតំបន់ខ្ពង់រាបបាតសមុទ្រ ព្រមទាំងតំបន់ផ្សេងៗទៀតដែលព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិអធិបតេយ្យ។

មាត្រា១២៦ .- និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងជំពូកនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- សម្រាប់គោលដៅនៃប្រតិបត្តិការប្រេងកាត៖

ក- ប្រេងកាត សំដៅដល់ ប្រេងឆៅ ឧស្ម័នធម្មជាតិ និងអ៊ីដ្រូកាបូនផ្សេងទៀត ទោះបីជាស្ថិតក្នុងសភាពរឹង រាវ ឧស្ម័ន ស្ថានភាពធម្មជាតិ និងរាល់សារធាតុផ្សេងទៀតដែលជាសមាសធាតុផ្សំជាមួយអ៊ីដ្រូកាបូននោះ។

ខ- កិច្ចព្រមព្រៀងប្រេងកាត សំដៅដល់ កិច្ចសន្យាបែងចែកផលប្រេងកាត ឬទម្រង់កិច្ចសន្យាណាមួយដែលត្រូវបានផ្តល់ឱ្យក្រោមច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត និងបទប្បញ្ញត្តិពាក់ព័ន្ធរវាងរាជរដ្ឋាភិបាលកម្ពុជានិងអ្នកជាប់ពន្ធពាក់ព័ន្ធ ដើម្បីធ្វើប្រតិបត្តិការប្រេងកាត។

គ- ប្រតិបត្តិការប្រេងកាត សំដៅដល់ រាល់សកម្មភាពស្វែងរករក អភិវឌ្ឍ និងផលិតប្រេងកាតដែលបានធ្វើឡើងនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀងប្រេងកាត ស្របតាមកិច្ចព្រមព្រៀងប្រេងកាត។

ឃ- តំបន់ចុះកិច្ចព្រមព្រៀង សំដៅដល់ តំបន់ដែលជាកម្មវត្ថុនៃកិច្ចព្រមព្រៀងប្រេងកាត ដែលបានអនុញ្ញាតផ្តល់ឱ្យពីដំបូង រួមបញ្ចូលទាំងផ្នែកណាមួយនៃតំបន់នោះដែលត្រូវបានប្រគល់សងវិញ ដោយអនុលោមទៅតាមកិច្ចព្រមព្រៀងប្រេងកាត។

គម្រោងអភិវឌ្ឍន៍ សំដៅដល់ ផែនការអភិវឌ្ឍន៍ កម្មវិធីការងារអភិវឌ្ឍន៍ និងសកម្មភាពការងារអភិវឌ្ឍន៍នានា ដើម្បីអភិវឌ្ឍនិងធ្វើផលិតកម្មប្រេងកាតនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀងដែលបានយល់ព្រមដោយស្ថាប័ន។

ច- ផែនការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ សំដៅដល់ ផែនការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញរបស់អ្នកជាប់ពន្ធដែលបានយល់ព្រមដោយស្ថាប័នក្រោមកិច្ចព្រមព្រៀងប្រេងកាត ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត។

ឆ- ចំណាយបុរេសនា សំដៅដល់ ចំណាយក្នុងការស្វែងរុករកដើម្បីកំណត់សក្តានុពលកូគព្ភសាស្ត្រប្រេងកាតដំហានដំបូងដោយមិនមានសិទ្ធិធ្វើការអភិវឌ្ឍនិងផលិតកម្ម។

ជ- ចំណាយស្វែងរុករក សំដៅដល់ ចំណាយក្នុងការអង្កេតផ្នែកកូគព្ភសាស្ត្រ សិលាវិទ្យា រូបកូគព្ភសាស្ត្រ គីមីកូគព្ភសាស្ត្រ ឋានលេខា ចំណាយភ្ញាគទិន្នន័យ ចំណាយទស្សនាទានវិស្វកម្មមុនពេលអភិវឌ្ឍន៍ ចំណាយលើការខួងស្វែងរុករក ខួងវាយតម្លៃ ការសិក្សាលើសមិទ្ធិលទ្ធភាព ផលប៉ះពាល់បរិស្ថាន ចំណាយរដ្ឋបាលទូទៅ និងចំណាយផ្សេងៗទៀតដែលកើតឡើងនៅក្នុងប្រតិបត្តិការប្រេងកាត ដើម្បីកំណត់វត្តមាន ទីតាំង បរិមាណ និងគុណភាពនៃជម្រកធនធានប្រេងកាត។

ឈ- ចំណាយអភិវឌ្ឍន៍ សំដៅដល់ ចំណាយដែលបានកើតឡើងបន្ទាប់ពីស្ថាប័នបានយល់ព្រមចំពោះគម្រោងអភិវឌ្ឍន៍ ដើម្បីសាងសង់មធ្យោបាយផលិតកម្មសម្រាប់ប្រតិបត្តិការប្រេងកាត មានជាអាទិ៍ការរៀបចំទីតាំង ការខួងអណ្តូង ការសាងសង់អណ្តូងសម្រាប់ផលិតកម្ម និងការសាងសង់បំពង់បង្ហូរប្រេងកាតដែលជាមធ្យោបាយផលិតកម្ម ការចំណាយលើការទិញទ្រព្យរូបីនិងទ្រព្យអរូបី ព្រមទាំងសកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងការអភិវឌ្ឍរបស់អ្នកចុះកិច្ចព្រមព្រៀងប្រេងកាត ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងលិខិតអនុញ្ញាតផលិតកម្មចេញដោយស្ថាប័ន។

ញ- ប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ សំដៅដល់ ប្រាក់បម្រុងដែលត្រូវបានអនុញ្ញាតឱ្យកាត់កងជាមុនសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញស្របតាមផែនការនិងលក្ខខណ្ឌកំណត់ដោយស្ថាប័ន។

ដ- ចំណាយសរុបសម្រាប់បិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ សំដៅដល់ ចំណាយសរុបសម្រាប់បិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀងដែលបានយល់ព្រមដោយស្ថាប័នតាមគម្រោងបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញរបស់អ្នកជាប់ពន្ធស្របតាមកិច្ចព្រមព្រៀងប្រេងកាត។

ឋ- ពេលចាប់ផ្តើមផលិតកម្មពាណិជ្ជកម្ម សំដៅដល់ ពេលដែលអ្នកជាប់ពន្ធចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មស្របតាមការកំណត់ក្នុងកិច្ចព្រមព្រៀងប្រេងកាតឬការកំណត់ដោយស្ថាប័ន។

២- សម្រាប់គោលដៅនៃប្រតិបត្តិការធនធានរ៉ែ៖

ក- ធនធានរ៉ែ សំដៅដល់ សារធាតុទាំងឡាយ ទោះបីជាក្នុងទម្រង់រឹង ឧស្ម័ន ដែលកកើតឡើងដោយធម្មជាតិតាមដំណើរវិវត្តកូគព្ភសាស្ត្រ ឬជាលទ្ធផលនៃការជីកយកពីក្នុងដីឬដី ក្នុងសមុទ្រ ក្រោមបាតសមុទ្រ មានជាអាទិ៍ ត្បូងថ្ម ធ្យូងថ្ម រ៉ែអលោហៈ រ៉ែលោហៈ ទឹកខនិដ ថ្ម ក្រួស ខ្សាច់ និងដីឥដ្ឋ។ ពាក្យ ធនធានរ៉ែ មិនរាប់បញ្ចូលប្រេងកាតដូចមានចែងក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌទី១នៃមាត្រានេះទេ។

ខ- អាជ្ញាបណ្ណធនធានរ៉ែ សំដៅដល់ លិខិតអនុញ្ញាតដែលផ្តល់សិទ្ធិឱ្យអ្នកជាប់ពន្ធ ដោយស្ថាប័នដើម្បីធ្វើប្រតិបត្តិការធនធានរ៉ែ។

គ- ប្រតិបត្តិការធនធានរ៉ែ សំដៅដល់ សកម្មភាពទាំងឡាយដែលបានអនុញ្ញាតក្រោមលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណធនធានរ៉ែ។ ប្រតិបត្តិការធនធានរ៉ែត្រូវបានបែងចែកជាដំណាក់កាលបុរេសនា ដំណាក់កាលស្វែងរករក និងដំណាក់កាលអាជីវកម្មធនធានរ៉ែ។

ឃ- ដែនអាជ្ញាបណ្ណ សំដៅដល់ ដែនដែលត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការធនធានរ៉ែនិងដាកម្មវត្ថុនៃអាជ្ញាបណ្ណ រួមបញ្ចូលទាំងផ្នែកណាមួយនៃដែនដែលត្រូវបានបោះបង់ចោលដោយអនុលោមទៅតាមអាជ្ញាបណ្ណធនធានរ៉ែនោះ។

ង- ផែនការបិទការដ្ឋានរ៉ែនិងការស្តារបរិស្ថានឡើងវិញ សំដៅដល់ ផែនការស្តារបរិស្ថានរបស់អ្នកជាប់ពន្ធដែលបានយល់ព្រមដោយស្ថាប័នក្រោមអាជ្ញាបណ្ណធនធានរ៉ែ។ ការស្តារការដ្ឋានរួមបញ្ចូលទាំងការលុបអណ្តូងរ៉ែ ការដាំដើមឈើឡើងវិញ ការសម្អាតនានាក្នុងដែនអាជ្ញាបណ្ណ។

ច- ចំណាយបុរេសនា សំដៅដល់ ចំណាយដែលទាក់ទិននឹងការស្វែងរករកដំហានដំបូងនៅស្រទាប់ដីលើដោយប្រើប្រាស់ឧបករណ៍សាមញ្ញដែលមានការប៉ះពាល់បន្តិចបន្តួចដល់ផ្ទៃដីដើម្បីកំណត់វត្តមានធនធានរ៉ែ។

ឆ- ចំណាយស្វែងរករក សំដៅដល់ ចំណាយក្នុងការសិក្សាស្រាវជ្រាវក្នុងបំណងរកឱ្យឃើញធ្វើតេស្តសន្ទស្សន៍រ៉ែ ដើម្បីកំណត់សក្តានុពល ទំហំ គុណភាព បរិមាណ ព្រមទាំងលទ្ធភាពសេដ្ឋកិច្ចអាជីវកម្មតាមរយៈការធ្វើបុរេសនា ការស្រាវជ្រាវភូគព្ភសាស្ត្រ រូបភូគព្ភសាស្ត្រ និងគីមីភូគព្ភសាស្ត្រ ការជីកកកាយ ការខួង ការដឹកជញ្ជូន និងការធ្វើវិភាគដី ដីល្បាប់ ទឹក ថ្ម និងគំរូរ៉ែផ្សេងៗទៀត ព្រមទាំងចំណាយរដ្ឋបាលទូទៅ និងចំណាយផ្សេងៗទៀតដែលកើតឡើងនៅក្នុងប្រតិបត្តិការធនធានរ៉ែ ដើម្បីកំណត់វត្តមាន ទីតាំង បរិមាណ និងគុណភាពនៃជម្រកធនធានរ៉ែ។

ជ- ចំណាយអភិវឌ្ឍន៍ សំដៅដល់ ចំណាយដែលបានកើតឡើងដើម្បីអភិវឌ្ឍជម្រកធនធានរ៉ែឱ្យចាប់ផ្តើមដំណើរការផលិតកម្មពាណិជ្ជកម្មបាន មានដូចជាអាទិ៍ការគូសប្លង់ ការសាងសង់ការដំឡើងបំបនកណ្តាសម្រាប់ផលិតកម្ម ការធ្វើអណ្តូងផលិតកម្ម ការខួងអណ្តូងផលិតកម្ម និងព្រមទាំងសកម្មភាពទាំងឡាយណាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍរបស់អ្នកជាប់ពន្ធស្របតាមលក្ខខណ្ឌដែលមានចែងក្នុងលិខិតអនុញ្ញាតផលិតកម្មចេញដោយស្ថាប័ន។

ឈ- ប្រាក់បម្រុងសម្រាប់ចំណាយស្តារការដ្ឋាន សំដៅដល់ ប្រាក់បម្រុងដែលអនុញ្ញាតឱ្យកាត់កងជាមុនសម្រាប់ចំណាយស្តារការដ្ឋានឡើងវិញដែលនឹងត្រូវបានធ្វើឡើងស្របតាមផែនការស្តារការដ្ឋាន។

ញ- ចំណាយសរុបដែលបានយល់ព្រមសម្រាប់ស្តារការដ្ឋាន សំដៅដល់ ចំណាយសរុបសម្រាប់ស្តារការដ្ឋានឡើងវិញនៅក្នុងដែនទទួលអាជ្ញាបណ្ណដែលបានយល់ព្រមដោយស្ថាប័នតាមផែនការស្តារការដ្ឋានរបស់អ្នកជាប់ពន្ធ ស្របតាមអាជ្ញាបណ្ណឬកិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីធនធានរ៉ែ។

ដ- រយៈពេលចាប់ផ្តើមផលិតកម្មពាណិជ្ជកម្ម សំដៅដល់ ពេលដែលអ្នកជាប់ពន្ធចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មស្របតាមការកំណត់ក្នុងអាជ្ញាបណ្ណធនធានរ៉ែ។

៣_ សម្រាប់គោលដៅនៃជំពូកនេះ៖

ក_ អ្នកជាប់ពន្ធ សំដៅដល់ រូបវន្តបុគ្គលឬនីតិបុគ្គលដែលបានចុះកិច្ចព្រមព្រៀងប្រេងកាតជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ឬដែលទទួលបានអាជ្ញាបណ្ណធនធានរ៉ែ។

ខ_ ស្ថាប័ន សំដៅដល់ ក្រសួងរ៉ែនិងថាមពល ឬស្ថាប័នរាជរដ្ឋាភិបាលដែលទទួលបន្ទុកគ្រប់គ្រងវិស័យប្រេងកាតឬគ្រប់គ្រងវិស័យរ៉ែ។

ផ្នែកទី២
អត្រាពន្ធលើប្រាក់ចំណូល

មាត្រា១២៧ _ អត្រាពន្ធលើប្រាក់ចំណូល

១_ អ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការប្រេងកាត និងអ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការធនធានរ៉ែ ដូចមានចែងក្នុងមាត្រា១២៦នៃច្បាប់នេះ ត្រូវជាប់ពន្ធលើប្រាក់ចំណូលតាមអត្រា៣០(សាមសិប)ភាគរយនៃប្រាក់ចំណូលជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធ។ សម្រាប់គោលដៅនៃច្បាប់នេះ ពាក្យ ប្រាក់ចំណូលជាប់ពន្ធ សំដៅដល់ប្រាក់ចំណូលសុទ្ធដែលបានមកពីការយកចំណូលដុលសម្រេចបានពីប្រតិបត្តិការប្រេងកាតឬធនធានរ៉ែ ដកចំណាយនានាដែលអនុញ្ញាតដោយច្បាប់នេះ។

២_ បន្ថែមលើអត្រាពន្ធដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ អ្នកជាប់ពន្ធត្រូវជាប់ពន្ធលើប្រាក់ចំណូលលើសកម្រិតតាមអត្រាកំណើនតាមថ្នាក់ដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រានេះ ដោយផ្អែកលើសមាមាត្រនៃប្រាក់ចំណូលលើសកម្រិត។ សមាមាត្រនៃប្រាក់ចំណូលលើសកម្រិតនៃឆ្នាំជាប់ពន្ធចរន្តណាមួយ គឺជាផលចែករវាងទឹកប្រាក់បូកបង្គរនៃចំណូល និងទឹកប្រាក់បូកបង្គរនៃចំណាយពីប្រតិបត្តិការប្រេងកាត ឬធនធានរ៉ែមកទល់នឹងឆ្នាំជាប់ពន្ធចរន្តនោះ។

៣_ អត្រាពន្ធលើប្រាក់ចំណូលលើសកម្រិតមានដូចក្នុងតារាងខាងក្រោម៖

ថ្នាក់	សមាមាត្រនៃប្រាក់ចំណូលលើសកម្រិត				អត្រាពន្ធលើប្រាក់ចំណូលលើសកម្រិត
១			ដល់	១,៣	០(សូន្យ)ភាគរយ
២	លើសពី	១,៣	ដល់	១,៦	១០(ដប់)ភាគរយ
៣	លើសពី	១,៦	ដល់	២	២០(ម្ភៃ)ភាគរយ
៤	លើសពី	២	ឡើងទៅ		៣០(សាមសិប)ភាគរយ

៤_ អ្នកជាប់ពន្ធត្រូវបានលើកលែងពីការបង់ពន្ធអប្បបរមាដូចមានចែងក្នុងមាត្រា២៤នៃច្បាប់នេះ។

ផ្នែកទី៣
ការកាត់កង

មាត្រា១២៨ _ គោលការណ៍និងកំហិតនៃការកាត់កងចំណាយ



១_ អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យគណនាប្រាក់ចំណូលជាប់ពន្ធដោយធ្វើការកាត់កងចំណាយនានាដូចមានចែងក្នុងមាត្រា១២៩ ដល់មាត្រា១៣៣នៃច្បាប់នេះ នៅដំណាច់ឆ្នាំជាប់ពន្ធដែលសកម្មភាពជាប្រតិកម្មការណ៍ដូកម្មបានកើតឡើង រួមទាំងចំណាយចរន្តពាក់ព័ន្ធផ្សេងទៀតនៅក្នុងឆ្នាំជាប់ពន្ធនីមួយៗ។

២_ ចំណាយដែលទាក់ទិននឹងប្រតិបត្តិការប្រែងកាតឬធនធានរ៉ែនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀងណាមួយ ឬដែនអាជ្ញាបណ្ណណាមួយសម្រាប់ឆ្នាំជាប់ពន្ធណាមួយ ត្រូវបានអនុញ្ញាតឱ្យកាត់កងតែពីប្រាក់ចំណូលដុលសរុបពីប្រតិបត្តិការប្រែងកាតឬធនធានរ៉ែក្នុងតំបន់ចុះកិច្ចព្រមព្រៀង ឬដែនអាជ្ញាបណ្ណនៃឆ្នាំជាប់ពន្ធនោះប៉ុណ្ណោះ។

៣_ ប្រសិនបើនៅក្នុងឆ្នាំជាប់ពន្ធណាមួយ ចំណាយសរុបដែលទាក់ទិននឹងប្រតិបត្តិការប្រែងកាតឬធនធានរ៉ែនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀង ឬដែនអាជ្ញាបណ្ណលើសពីចំណូលដុលសរុបដែលនាំឱ្យមានលទ្ធផលខាតបង់ ការខាតបង់ត្រូវបានចាត់ទុកជាបន្ទុកសម្រាប់កាត់កងពីប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានក្នុងឆ្នាំជាប់ពន្ធបន្ទាប់។ ប្រសិនបើប្រាក់ចំណូលជាប់ពន្ធនោះមិនគ្រប់គ្រាន់សម្រាប់កាត់កងជាស្តាពរទេ បំណែកនៃការខាតបង់ដែលនៅសេសសល់ត្រូវយោងទៅឆ្នាំជាប់ពន្ធបន្តបន្ទាប់រហូតដល់ឆ្នាំជាប់ពន្ធទី១០(ដប់)។ ក្នុងករណីដែលមានការខាតបង់លើសពី១(មួយ)ឆ្នាំ ការយោងការខាតបង់ត្រូវអនុវត្តតាមលំដាប់ឆ្នាំដែលការខាតបង់ទាំងឡាយបានកើតឡើង។

៤_ ការខាតបង់ដែលកើតមានឡើងក្នុងតំបន់ចុះកិច្ចព្រមព្រៀងឬដែនអាជ្ញាបណ្ណណាមួយ មិនអាចយោងយកទៅកាត់កងក្នុងតំបន់ចុះកិច្ចព្រមព្រៀងឬដែនអាជ្ញាបណ្ណដទៃទៀតឡើយ។

មាត្រា១២៩_ ចំណាយការប្រាក់

អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យកាត់កងចំណាយការប្រាក់តាមវិធានសមាមាត្របំណុល៣(បី)ធៀបនឹងដើមទុន១(មួយ)។

មាត្រា១៣០_ ប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ ឬចំណាយស្តារការដ្ឋាន

ប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ ឬចំណាយស្តារការដ្ឋាន ត្រូវបានកំណត់ដូចខាងក្រោម៖

១_ សម្រាប់ប្រតិបត្តិការប្រែងកាត៖

ក_ ប្រសិនបើអ្នកជាប់ពន្ធមានផែនការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញដែលបានយល់ព្រមដោយស្ថាប័ន ទឹកប្រាក់ដែលបានតម្រូវឱ្យអ្នកជាប់ពន្ធបង់ចូលមូលនិធិសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ ត្រូវបានចាត់ទុកជាប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ។ ប្រាក់បម្រុងនេះ ត្រូវបានអនុញ្ញាតជាសំវិធានធន និងត្រូវបានអនុញ្ញាតឱ្យកាត់កងក្នុងឆ្នាំជាប់ពន្ធ ដើម្បីគណនាប្រាក់ចំណូលជាប់ពន្ធ។ ក្នុងករណីអ្នកជាប់ពន្ធគ្មានផែនការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញដែលបានយល់ព្រមដោយស្ថាប័នទេ ប្រាក់បម្រុងតាមកថាខណ្ឌនេះមិនត្រូវបានអនុញ្ញាតឡើយ។

ខ_ ប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ ត្រូវបានគណនាដោយផ្អែកទៅតាមចំណាយសរុបដែលបានយល់ព្រមដោយស្ថាប័នសម្រាប់បិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ។ ប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញក្នុងឆ្នាំនីមួយៗ និងឆ្នាំដែលប្រាក់បម្រុងត្រូវបានអនុញ្ញាតឱ្យចាប់ផ្តើមកាត់កង ត្រូវកំណត់តាមផែនការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ។

គ- ប្រសិនបើចំណាយសរុបជាក់ស្តែងនៃការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញមានចំនួនលើសពីចំនួនសរុបនៃទឹកប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ ចំនួនលើសនោះត្រូវបានអនុញ្ញាតឱ្យកាត់កងពីប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ។

ឃ- ប្រសិនបើនៅចុងបញ្ចប់នៃការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញចំណាយសរុបជាក់ស្តែងនៃការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញមានចំនួនតិចជាងចំនួនសរុបនៃទឹកប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ ចំនួនលម្អៀងនោះត្រូវគិតបញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធសម្រាប់ឆ្នាំជាប់ពន្ធដែលបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញនោះបានបញ្ចប់។

២- សម្រាប់ប្រតិបត្តិការធនធានរ៉ែ៖

ក- ប្រសិនបើអ្នកជាប់ពន្ធមានផែនការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញដែលបានយល់ព្រមដោយស្ថាប័ន ទឹកប្រាក់ដែលបានតម្រូវឱ្យអ្នកជាប់ពន្ធបង់ចូលមូលនិធិសម្រាប់ចំណាយស្តារការដ្ឋាន ត្រូវបានចាត់ទុកជាប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញ។ ប្រាក់បម្រុងនេះ ត្រូវបានអនុញ្ញាតជាសំវិធានធន និងត្រូវបានអនុញ្ញាតឱ្យកាត់កងក្នុងឆ្នាំជាប់ពន្ធដើម្បីគណនាប្រាក់ចំណូលជាប់ពន្ធ។ ក្នុងករណីអ្នកជាប់ពន្ធគ្មានផែនការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញដែលបានយល់ព្រមដោយស្ថាប័នទេ ប្រាក់បម្រុងតាមកថាខណ្ឌនេះ មិនត្រូវបានអនុញ្ញាតឡើយ។

ខ- ប្រាក់បម្រុងសម្រាប់ចំណាយស្តារការដ្ឋាន ត្រូវបានគណនាដោយផ្អែកទៅតាមចំណាយសរុបដែលបានយល់ព្រមដោយស្ថាប័នសម្រាប់បិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញ។ ប្រាក់បម្រុងសម្រាប់ចំណាយស្តារការដ្ឋានក្នុងឆ្នាំនីមួយៗ និងឆ្នាំដែលប្រាក់បម្រុងត្រូវបានអនុញ្ញាតឱ្យចាប់ផ្តើមកាត់កង ត្រូវកំណត់តាមផែនការបិទការដ្ឋានរ៉ែនិងការស្តារបរិស្ថានឡើងវិញ។

គ- ប្រសិនបើចំណាយសរុបជាក់ស្តែងនៃការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញមានចំនួនលើសពីចំនួនសរុបនៃទឹកប្រាក់បម្រុងសម្រាប់ចំណាយស្តារការដ្ឋាន ចំនួនលើសនោះត្រូវបានអនុញ្ញាតឱ្យកាត់កងពីប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ។

ឃ- ប្រសិនបើនៅចុងបញ្ចប់នៃការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញ ចំណាយសរុបជាក់ស្តែងនៃការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញមានចំនួនតិចជាងចំនួនសរុបនៃទឹកប្រាក់បម្រុងសម្រាប់ចំណាយស្តារការដ្ឋាន ចំនួនលម្អៀងនោះត្រូវគិតបញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធសម្រាប់ឆ្នាំជាប់ពន្ធដែលការបិទការដ្ឋានរ៉ែនិងការស្តារបរិស្ថានឡើងវិញនោះបានបញ្ចប់។



ង- វិធានការនិងនីតិវិធីនៃការគ្រប់គ្រងប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ ឬចំណាយស្តារការដ្ឋាន ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងស្ថាប័ន។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ១៩៥

មាត្រា១៣១ .- វិធីរំលស់

វិធីរំលស់ត្រូវបានកំណត់ដូចខាងក្រោម៖

១- អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍តាមវិធីរំលស់ស្មើភាគតាមមាត្រា១៣២នៃច្បាប់នេះ។ អ្នកជាប់ពន្ធមិនត្រូវធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍តាមមាត្រា១៥នៃច្បាប់នេះទេ។

២- ចំពោះទ្រព្យរូបីនិងទ្រព្យអរូបីក្រៅពីចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ដែលបានទិញឬបានបង្កើតក្រោយពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មក្នុងតំបន់ចុះកិច្ចព្រមព្រៀងឬដែនអាជ្ញាបណ្ណ អ្នកជាប់ពន្ធត្រូវធ្វើរំលស់ទ្រព្យរូបីតាមវាក្យខណ្ឌ ក ដល់វាក្យខណ្ឌ ឃ នៃកថាខណ្ឌទី១ នៃមាត្រា១៣នៃច្បាប់នេះ និងធ្វើរំលស់ទ្រព្យអរូបីតាមមាត្រា១៤នៃច្បាប់នេះ។

មាត្រា១៣២ .- រំលស់ស្មើភាគ

រំលស់ស្មើភាគសម្រាប់ប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែ ត្រូវបានកំណត់ដូចខាងក្រោម៖

១- សម្រាប់ប្រតិបត្តិការប្រេងកាត៖

ក- អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា និងចំណាយស្វែងរុករកតាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មក្រោមគម្រោងអភិវឌ្ឍន៍ឬ៥(ប្រាំ)ឆ្នាំ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង។

ខ- អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយអភិវឌ្ឍន៍តាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មរបស់មធ្យោបាយផលិតកម្មនីមួយៗក្រោមគម្រោងអភិវឌ្ឍន៍ឬ ១០(ដប់)ឆ្នាំ សម្រាប់ប្រតិបត្តិការប្រេងកាតដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង។

គ- ក្នុងករណីអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មរបស់មធ្យោបាយផលិតកម្មណាមួយក្រោមគម្រោងអភិវឌ្ឍន៍ត្រូវបានកែប្រែ អ្នកជាប់ពន្ធត្រូវធ្វើការកែតម្រូវការធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ដែលនៅសល់តាមអាយុកាលរំពឹងទុកដែលកែប្រែ ដោយមិនត្រូវឱ្យលើសពីអាយុកាលរំលស់តាមវាក្យខណ្ឌ ក និងវាក្យខណ្ឌ ខ នៃកថាខណ្ឌនេះឡើយ។

២- សម្រាប់ប្រតិបត្តិការធនធានរ៉ែ៖

ក- អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា និងចំណាយស្វែងរុករកតាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មក្រោមគម្រោងអភិវឌ្ឍន៍ឬ៥(ប្រាំ)ឆ្នាំ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង។

ខ- អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយអភិវឌ្ឍន៍តាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មក្រោមគម្រោងអភិវឌ្ឍន៍ឬ៧(ប្រាំពីរ)ឆ្នាំ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង។

គ_ ក្នុងករណីអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មក្រោមគម្រោងអភិវឌ្ឍន៍ត្រូវបានកែប្រែ អ្នកជាប់ពន្ធត្រូវធ្វើការកែតម្រូវការធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ដែលនៅសល់តាមអាយុកាលរំពឹងទុកដែលកែប្រែ ដោយមិនត្រូវឱ្យលើសពីអាយុកាលរំលស់តាមវាក្យខណ្ឌ ក និងវាក្យខណ្ឌ ខ នៃកថាខណ្ឌនេះឡើយ។

ឃ_ ក្នុងករណីអ្នកជាប់ពន្ធមានគម្រោងអភិវឌ្ឍន៍ដែលមានរយៈពេលតិចជាង១(មួយ)ឆ្នាំ ចំណាយអភិវឌ្ឍន៍នេះអាចបញ្ចូលទៅធ្វើរំលស់ក្នុងចំណាយបុរេសនានិងចំណាយស្វែងរុករក។

មាត្រា១៣៣ _ ពេលធ្វើរំលស់

ពេលធ្វើរំលស់ត្រូវបានកំណត់ដូចខាងក្រោម៖

១_ អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ដែលបានកើតឡើងមុនពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មដំបូងនៅដំណាច់ឆ្នាំជាប់ពន្ធ ដែលអ្នកជាប់ពន្ធចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មដំបូងក្នុងតំបន់ចុះកិច្ចព្រមព្រៀងឬដែនអាជ្ញាបណ្ណ។

២_ ក្រោយពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មដំបូងក្នុងតំបន់ចុះកិច្ចព្រមព្រៀងឬដែនអាជ្ញាបណ្ណ ប្រសិនបើអ្នកជាប់ពន្ធធ្វើបុរេសនា ឬស្វែងរុករក ឬសាងសង់បន្តនូវមធ្យោបាយផលិតកម្មដទៃទៀតក្រោមគម្រោងអភិវឌ្ឍន៍ក្នុងតំបន់ចុះកិច្ចព្រមព្រៀងឬដែនអាជ្ញាបណ្ណ អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍តាមពេលដូចខាងក្រោម៖

ក_ នៅដំណាច់ឆ្នាំជាប់ពន្ធនីមួយៗចំពោះចំណាយបុរេសនា ឬចំណាយស្វែងរុករកទៅតាមលំដាប់ឆ្នាំដែលចំណាយនោះបានកើតឡើង។

ខ_ នៅដំណាច់ឆ្នាំជាប់ពន្ធដែលមធ្យោបាយផលិតកម្មនីមួយៗត្រូវបានដាក់ឱ្យប្រើប្រាស់ចំពោះចំណាយអភិវឌ្ឍន៍។

រំលស់ត្រូវធ្វើដាច់ដោយឡែកៗពីគ្នាសម្រាប់មធ្យោបាយផលិតកម្មនីមួយៗក្រោមគម្រោងអភិវឌ្ឍន៍ស្របតាមមាត្រា១៣២នៃច្បាប់នេះ ហើយត្រូវបូកសរុបបញ្ចូលគ្នាសម្រាប់កាត់កងក្នុងឆ្នាំជាប់ពន្ធ។

៣_ ចំពោះទ្រព្យរូបីនិងទ្រព្យអរូបីក្រៅពីចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ដែលបានទិញឬបានបង្កើតក្រោយពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មក្នុងតំបន់ចុះកិច្ចព្រមព្រៀងឬដែនអាជ្ញាបណ្ណ អ្នកជាប់ពន្ធត្រូវធ្វើរំលស់នៅដំណាច់ឆ្នាំជាប់ពន្ធ ដែលទ្រព្យទាំងនោះត្រូវបានដាក់ឱ្យប្រើប្រាស់។

ផ្នែកទី៤
ការផ្ទេរអត្ថប្រយោជន៍

មាត្រា១៣៤ _ ការផ្ទេរអត្ថប្រយោជន៍និងការអភិវឌ្ឍនិងផលិតកម្មរួម

១_ ក្នុងករណីមានការផ្ទេរមួយផ្នែកឬទាំងស្រុងនៃអត្ថប្រយោជន៍ដែលជាសិទ្ធិឬចំណែកក្នុងកិច្ចព្រមព្រៀងប្រេងកាត ឬអាជ្ញាបណ្ណធនធានរ៉ែតាមរូបភាពលក់ទិញ ដោះដូរ ឬធ្វើអំណោយ អ្នកជាប់ពន្ធដែលជាអ្នកផ្ទេរ និងបុគ្គលជាអ្នកទទួលបន្តត្រូវអនុវត្តដូចខាងក្រោម៖

ក_ អ្នកជាប់ពន្ធដែលជាអ្នកផ្ទេរត្រូវកត់ត្រាចំណូលទទួលបានពីការផ្ទេរអត្ថប្រយោជន៍ក្នុងកិច្ចព្រមព្រៀងប្រេងកាត ឬអាជ្ញាបណ្ណធនធានរ៉ែជាចំណូលពីប្រតិបត្តិការប្រេងកាត ឬធនធានរ៉ែដែលជាកម្មវត្ថុនៃពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងជំពូកទី២នៃច្បាប់នេះ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ១៩៧

ខ_ បុគ្គលជាអ្នកទទួលបន្តត្រូវ៖

- បន្តអនុវត្តកាតព្វកិច្ចសារពើពន្ធពីអ្នកជាប់ពន្ធដែលជាអ្នកផ្ទេរចំពោះអត្ថប្រយោជន៍ដែលជាសិទ្ធិឬចំណែកដែលបានទទួល
- បន្តធ្វើរំលស់ទ្រព្យរូបី ទ្រព្យអរូបី ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍តាមវិធាននិងនីតិវិធី និងមូលដ្ឋានដែលអ្នកជាប់ពន្ធដែលជាអ្នកផ្ទេរបានធ្វើរំលស់កន្លងមក
- ក្នុងករណីការផ្ទេរអត្ថប្រយោជន៍ក្នុងកិច្ចព្រមព្រៀងប្រេងកាតឬអាជ្ញាបណ្ណធនធានរ៉ែមានតម្លៃលើសពីតម្លៃពិតគណនេយ្យ តម្លៃលម្អៀងនោះត្រូវបានចាត់ទុកជាមូលនិធិពាណិជ្ជកម្ម។ បុគ្គលជាអ្នកទទួលបន្តត្រូវធ្វើរំលស់មូលនិធិពាណិជ្ជកម្មនេះតាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មដែលនៅសល់ឬ ១០(ដប់)ឆ្នាំ សម្រាប់ប្រតិបត្តិការប្រេងកាត និង៧(ប្រាំពីរ)ឆ្នាំសម្រាប់ប្រតិបត្តិការធនធានរ៉ែដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង
- ក្នុងករណីការផ្ទេរអត្ថប្រយោជន៍ក្នុងកិច្ចព្រមព្រៀងប្រេងកាតឬអាជ្ញាបណ្ណធនធានរ៉ែមានតម្លៃតិចជាងតម្លៃពិតគណនេយ្យ តម្លៃលម្អៀងនោះត្រូវបានចាត់ទុកជាចំណូល។ បុគ្គលជាអ្នកទទួលបន្តត្រូវកត់ត្រាជាចំណូលសម្រាប់ឆ្នាំបន្តបន្ទាប់ដោយបែងចែកចំណូលទាំងនេះតាមសមាមាត្រនៃអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មដែលនៅសល់ឬ១០(ដប់)ឆ្នាំ សម្រាប់ប្រតិបត្តិការប្រេងកាត និង៧(ប្រាំពីរ)ឆ្នាំសម្រាប់ប្រតិបត្តិការធនធានរ៉ែដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង។

២_ ចំពោះអ្នកជាប់ពន្ធពីរឬច្រើនដែលត្រូវបានអនុញ្ញាតឱ្យចុះកិច្ចព្រមព្រៀងអភិវឌ្ឍន៍និងផលិតកម្មរួមដើម្បីធ្វើប្រតិបត្តិការរួមគ្នាក្នុងការអភិវឌ្ឍនិងផលិតកម្មលើជម្រកប្រេងកាតមួយឬច្រើន ដែលស្ថិតនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀងប្រេងកាតផ្សេងគ្នា វិធាននិងនីតិវិធីដែលត្រូវអនុវត្តត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ផ្នែកទី៥
កាតព្វកិច្ចអ្នកជាប់ពន្ធ

មាត្រា១៣៥ _ កាតព្វកិច្ចរបស់អ្នកជាប់ពន្ធ

១_ អ្នកជាប់ពន្ធអនិវាសនជនដែលចុះកិច្ចព្រមព្រៀងប្រេងកាត ឬអាជ្ញាបណ្ណធនធានរ៉ែជាមួយរាជរដ្ឋាភិបាលកម្ពុជាដូចមានចែងក្នុងមាត្រា១២៦នៃច្បាប់នេះ ត្រូវបង្កើតជាក្រុមហ៊ុនក្នុងស្រុកមួយសម្រាប់តំបន់ចុះកិច្ចព្រមព្រៀងមួយស្របតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេលយ៉ាងតិច ១៥(ដប់ប្រាំ)ថ្ងៃមុនពេលចាប់ផ្តើមសកម្មភាពសេដ្ឋកិច្ច។

២_ អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាសសារពើពន្ធនិងបង់ប្រាក់ពន្ធអាករប្រចាំខែ ប្រចាំឆ្នាំ ដូនរដ្ឋបាលសារពើពន្ធតាមការកំណត់នៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ។

៣_ ប្រតិបត្តិករដែលជាតំណាងអ្នកជាប់ពន្ធទាំងអស់ក្នុងតំបន់ចុះកិច្ចព្រមព្រៀងឬដែនអាជ្ញាបណ្ណត្រូវរក្សាបញ្ជរគណនេយ្យនិងឯកសារនានានៃប្រតិបត្តិការអាជីវកម្មក្នុងតំបន់ចុះកិច្ចព្រមព្រៀងឬដែនអាជ្ញាបណ្ណតាមការកំណត់ដែលមានចែងក្នុងច្បាប់ស្តីពីរដ្ឋបាលសារពើពន្ធ។

មាត្រា១៣៦ .- ការលើកទឹកចិត្តផ្នែកសារពើពន្ធ

ការផ្តល់ការលើកទឹកចិត្តផ្នែកសារពើពន្ធចំពោះកិច្ចព្រមព្រៀងប្រែងកាតឬអាជ្ញាបណ្ណធនធានរ៉ែណាមួយ ដែលបានធ្វើឡើងមុនពេលចូលជាធរមាននៃបទប្បញ្ញត្តិនៃជំពូកនេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា១៣៧ .- ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ

អ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការប្រែងកាត និងអ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការធនធានរ៉ែដូចមានចែងក្នុងមាត្រា១២៦នៃច្បាប់នេះ ត្រូវអនុវត្តបទប្បញ្ញត្តិក្នុងជំពូកនេះនិងបទប្បញ្ញត្តិដទៃទៀតស្តីពីពន្ធដារ។ ក្នុងករណីដែលមានភាពមិនស្របគ្នា បទប្បញ្ញត្តិនៃជំពូកនេះមានឧត្តមានុភាពលើបទប្បញ្ញត្តិដទៃទៀតស្តីពីពន្ធដារ។

មាត្រា១៣៨ .- វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើប្រតិបត្តិការប្រែងកាតឬប្រតិបត្តិការធនធានរ៉ែត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី១១
ពន្ធលើផ្លែឈួលអចលនទ្រព្យ

មាត្រា១៣៩ .- កម្មវត្ថុនៃពន្ធ

ពន្ធលើផ្លែឈួលអចលនទ្រព្យត្រូវអនុវត្តលើការជួលអចលនទ្រព្យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា១៤០ .- វិសាលភាពនៃពន្ធ

ពន្ធលើផ្លែឈួលអចលនទ្រព្យអនុវត្តលើកម្មសិទ្ធិករ ឬសិទ្ធិវន្តរបស់កម្មសិទ្ធិកវនៃអចលនទ្រព្យដែលមិនមែនជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។

មាត្រា១៤១ .- និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងជំពូកនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- អចលនទ្រព្យ សំដៅដល់៖

ក- អគារនិងសំណង់ផ្សេងៗ ដូចជាផ្ទះ រោងចក្រ សណ្ឋាគារ ការិយាល័យព្រមទាំងឧបសម្ព័ន្ធរបស់វា។

ខ- យន្តូបករណ៍ដែលជាប់ជាមួយគ្រឹះស្ថានឧស្សាហកម្ម។

គ- បបនកណ្តាពាណិជ្ជកម្ម ឧស្សាហកម្មដែលនៅនឹងកន្លែង អគារធំៗ ឬឃ្លាំងស្តុកទំនិញ។

ឃ- លំនៅឋានចល័តសម្រាប់ស្នាក់នៅឬប្រកបអាជីវកម្មផ្សេងៗ។

ង- ដីធ្លីដែលគ្មានសំណង់។



២- សិទ្ធិវន្ត សំដៅដល់ អ្នកមានសិទ្ធិលើទ្រព្យតាមរយៈការផ្តល់ឱ្យដោយម្ចាស់កម្មសិទ្ធិនៃទ្រព្យ។

៣- ផ្លែឈួលអចលនទ្រព្យ សំដៅដល់ ប្រាក់ឈួលដុលដែលបានចុះកិច្ចសន្យាឬបានព្រមព្រៀងជាមួយអ្នកជួលដោយផ្អែកលើតម្លៃទីផ្សារ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ១៩៩

មាត្រា១៤២ .- អត្រាពន្ធ

ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យត្រូវបានកំណត់តាមអត្រា១០(ដប់)ភាគរយនៃថ្លៃឈ្នួលអចលនទ្រព្យ។

មាត្រា១៤៣ .- ការលើកលែងពន្ធ

ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យត្រូវបានលើកលែងដូចខាងក្រោម៖

១- ថ្លៃឈ្នួលពីការជួលអចលនទ្រព្យរបស់រាជរដ្ឋាភិបាលឬក្រសួង ស្ថាប័នរាជរដ្ឋាភិបាល។

២- ថ្លៃឈ្នួលពីការជួលអចលនទ្រព្យរបស់បេសកកម្មការទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត។

៣- ថ្លៃឈ្នួលពីការជួលអចលនទ្រព្យរបស់អង្គការឬសមាគមណាមួយដែល៖

ក- ត្រូវបានរៀបចំឡើងនិងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬអប់រំ។

ខ- គ្មានចំណែកណាមួយនៃថ្លៃឈ្នួលត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន។

៤- ប្រាក់ដែលអ្នកជួលបានតម្កល់ទុកជាប្រាក់ធានា ហើយនៅពេលចប់កិច្ចសន្យា កម្មសិទ្ធិករត្រូវប្រគល់គ្រប់ចំនួនឱ្យអ្នកជួលវិញ។

៥- ថ្លៃឈ្នួលដែលបានកាត់ទុកប្រាក់ពន្ធរួចហើយដោយសហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសតាមមាត្រា២៥និងមាត្រា២៦នៃច្បាប់នេះ។

៦- ថ្លៃឈ្នួលពីការជួលអចលនទ្រព្យរបស់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលបានគិតបញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធរបស់សហគ្រាសរួចហើយ។

មាត្រា១៤៤ .- កាតព្វកិច្ចរបស់កម្មសិទ្ធិកឬសិទ្ធិវិន្ត

កម្មសិទ្ធិកឬសិទ្ធិវិន្តរបស់កម្មសិទ្ធិកមានកាតព្វកិច្ចដូចខាងក្រោម៖

១- ត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធនៅក្នុងភូមិសាស្ត្រដែលអចលនទ្រព្យស្ថិតនៅក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃចុះកិច្ចសន្យាជួល ឬចាប់ពីថ្ងៃមានការប្រែប្រួលអំពីកិច្ចសន្យាតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់។

២- ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមករដ្ឋបាលសារពើពន្ធក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ក្រោយពេលឈប់ជួល ដោយត្រូវចុះកាលបរិច្ឆេទនិងមានហត្ថលេខាត្រឹមត្រូវរបស់កម្មសិទ្ធិកឬអ្នកតំណាងដែលមានសិទ្ធិ។

៣- ត្រូវចេញបង្កាន់ដៃទទួលប្រាក់ជូនអ្នកជួលក្នុងពេលទទួលប្រាក់ឈ្នួលម្តងៗ។

៤- ត្រូវដាក់លិខិតប្រកាសបង់ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យជូនរដ្ឋបាលសារពើពន្ធទៅតាមកាលកំណត់ដូចខាងក្រោម៖

ក- ជារៀងរាល់ខែយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ ប្រសិនបើកិច្ចសន្យាតម្រូវឱ្យមានការបង់ប្រាក់ប្រចាំខែ។

ខ- យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលត្រូវធ្វើការទូទាត់ទៅតាមចំនួនទឹកប្រាក់សរុប ប្រសិនបើកិច្ចសន្យាតម្រូវឱ្យមានការបង់ប្រាក់សរុបសម្រាប់រយៈពេលច្រើនខែ។

មាត្រា១៤៥ .- កាតព្វកិច្ចរបស់អ្នកជួល

អ្នកជួលត្រូវមានកាតព្វកិច្ចបង្ហាញបង្កាន់ដៃទទួលប្រាក់ដែលកម្មសិទ្ធិករផ្តល់ជូន និងត្រូវផ្តល់ព័ត៌មានផ្សេងៗទៀតដែលទាក់ទិននឹងការជួលដល់រដ្ឋបាលសារពើពន្ធ។

មាត្រា១៤៦ .- វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើថ្លៃឈ្នួលអចលនទ្រព្យត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី១២
ពន្ធលើអចលនទ្រព្យ

មាត្រា១៤៧ .- កម្មវត្ថុនៃពន្ធ

ពន្ធលើអចលនទ្រព្យត្រូវអនុវត្តលើអចលនទ្រព្យដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា១៤៨ .- វិសាលភាពនៃពន្ធ

ពន្ធលើអចលនទ្រព្យអនុវត្តលើអចលនទ្រព្យដែលស្ថិតនៅក្នុងរដ្ឋបាលរាជធានី ខេត្តនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា១៤៩ .- និយមន័យ

សម្រាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីពន្ធលើអចលនទ្រព្យ ៣ក្យ អចលនទ្រព្យ សំដៅដល់ ដី ផ្ទះ អគារ និងសំណង់ផ្សេងៗ។

មាត្រា១៥០ .- អត្រាពន្ធ

ពន្ធលើអចលនទ្រព្យត្រូវប្រមូលប្រចាំឆ្នាំតាមអត្រា០,១(សូន្យក្បៀសមួយ)ភាគរយ។

មាត្រា១៥១ .- មូលដ្ឋានគិតពន្ធ

មូលដ្ឋានគិតពន្ធលើអចលនទ្រព្យត្រូវផ្អែកលើតម្លៃអចលនទ្រព្យដែលកំណត់ដោយគណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យ។ មូលដ្ឋានគិតពន្ធលើអចលនទ្រព្យ និងគណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យ ត្រូវកំណត់និងបង្កើតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា១៥២ .- ការលើកលែងពន្ធ

ពន្ធលើអចលនទ្រព្យត្រូវបានលើកលែងដូចខាងក្រោម៖

១-អចលនទ្រព្យដែលជាដីធ្លីកសិកម្ម។

២-អចលនទ្រព្យដែលជាកម្មសិទ្ធិរបស់រាជរដ្ឋាភិបាលឬក្រសួង ស្ថាប័នរាជរដ្ឋាភិបាល។

៣-អចលនទ្រព្យដែលជាកម្មសិទ្ធិរបស់សហគមន៍ឬបុគ្គលណាមួយដែល៖

ក- ត្រូវបានរៀបចំឡើងនិងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនានិងសប្បុរសធម៌។

ខ- គ្មានចំណែកណាមួយនៃអចលនទ្រព្យឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាប្រយោជន៍ដល់ឯកជន។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២០១

៤_ អចលនទ្រព្យជាកម្មសិទ្ធិរបស់បេសកកម្មការទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត។

៥_ អចលនទ្រព្យដែលជាហេដ្ឋារចនាសម្ព័ន្ធ មានដូចជាអាទិ៍ផ្លូវ ស្ពាន ប្រព័ន្ធផលិតទឹកស្អាតឬផលិតអគ្គិសនី ព្រលានយន្តហោះ កំពង់ផែ ស្ថានីយអុយស្ម័យយាន រួមបញ្ចូលទាំងអគារនិងការិយាល័យដែលបម្រើផ្គាល់ដល់សកម្មភាពនៃហេដ្ឋារចនាសម្ព័ន្ធទាំងនោះ។

មាត្រា១៥៣ _ កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ

កម្មសិទ្ធិករ ឬអ្នកកាន់កាប់ ឬអ្នកទទួលប្រយោជន៍ចុងក្រោយនៃអចលនទ្រព្យ ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំឆ្នាំ។

មាត្រា១៥៤ _ វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី១៣
ពន្ធប្រថាប់ត្រា

មាត្រា១៥៥ _ កម្មវត្ថុនៃពន្ធ

ពន្ធប្រថាប់ត្រាអនុវត្តលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យនិងចលនទ្រព្យ ការផ្ទេរភាគហ៊ុន កិច្ចសន្យាផ្តត់ផ្តង់ទំនិញឬសេវាដែលប្រើប្រាស់ថវិការដ្ឋ និងលិខិតមានលក្ខណៈគតិយុត្ត។

មាត្រា១៥៦ _ វិសាលភាពនៃពន្ធ

ពន្ធប្រថាប់ត្រាអនុវត្តលើ៖

១_ ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យនិងចលនទ្រព្យ ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យនិងចលនទ្រព្យក្នុងក្រុមហ៊ុន។

២_ ការផ្ទេរចំណែកណាមួយឬទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន។

៣_ កិច្ចសន្យាផ្តត់ផ្តង់ទំនិញឬសេវាដែលប្រើប្រាស់ថវិការដ្ឋ។

៤_ លិខិតមានលក្ខណៈគតិយុត្ត រួមមានលិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងលិខិតស្តីពីការបិទក្រុមហ៊ុន។

មាត្រា១៥៧ _ និយមន័យ

ពាក្យសព្ទសំខាន់ៗដែលប្រើក្នុងជំពូកនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១_ រង្វង់ញាតិ សំដៅដល់៖

- រវាងឪពុកម្តាយបង្កើតនិងកូនបង្កើត
- រវាងប្តីនិងប្រពន្ធ

- រវាងយាយតាបង្កើតនិងចៅបង្កើត
- រវាងបងប្អូនបង្កើតនិងបងប្អូនបង្កើត
- រវាងឪពុកម្តាយក្មេកនិងកូនប្រសា
- រវាងយាយតាក្មេកនិងចៅប្រសា។

២_ ប្រទានកម្ម សំដៅដល់ ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យពីមនុស្សរស់ទៅឱ្យញាតិដោយមិនយកថ្លៃ។

៣_ សន្ដតិកម្ម សំដៅដល់ ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យពីមនុស្សស្លាប់ទៅឱ្យញាតិ។

៤_ តម្លៃចុះកិច្ចសន្យា សំដៅដល់ តម្លៃដែលមានចែងក្នុងកិច្ចសន្យាផ្ដត់ផ្ដង់ទំនិញឬសេវាដែលប្រើប្រាស់ថវិការដ្ឋ។

៥_ តម្លៃភាគហ៊ុន សំដៅដល់ តម្លៃនៃការផ្ទេរភាគហ៊ុនផ្អែកតាមតម្លៃទីផ្សារ។

៦_ ភាគហ៊ុន សំដៅដល់ ចំណែកណាមួយឬទាំងស្រុងនៃភាគហ៊ុន ឬផលប្រយោជន៍ ឬការលក់អាជីវកម្មរបស់ក្រុមហ៊ុននីតិបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ និងសហគ្រាសឯកបុគ្គលដែលបានចុះបញ្ជីឬមិនបានចុះបញ្ជីនៅក្រសួងឬស្ថាប័នមានសមត្ថកិច្ច។

៧_ អចលនទ្រព្យ សំដៅដល់ ដី ផ្ទះ អគារ និងសំណង់ផ្សេងៗ ទោះបីជាបានចុះបញ្ជីឬមិនបានចុះបញ្ជីដោយរដ្ឋបាលសុរិយោដី។

៨_ ក្រុមហ៊ុនអចលនទ្រព្យ សំដៅដល់ ក្រុមហ៊ុនទាំងឡាយណាដែលកាន់កាប់អចលនទ្រព្យដោយផ្ទាល់ឬដោយប្រយោលដែលមានតម្លៃលើសពី៥០(ហាសិប)ភាគរយនៃតម្លៃទ្រព្យសកម្មសរុបរបស់ក្រុមហ៊ុន។

៩_ ចលនទ្រព្យ សំដៅដល់ មធ្យោបាយដឹកជញ្ជូនឬយានជំនិះគ្រប់ប្រភេទ ដូចជា កប៉ាល់ សាឡង់ទូក កាណូត អូប៉ែរ រថយន្ត ក្បាលរថយន្តសណ្ដោង រ៉ឺម៉កសណ្ដោង ស៊ីមីរ៉ឺម៉កសណ្ដោង ទោចក្រយានយន្ត ត្រីចក្រយានយន្ត ត្រាក់ទ័រ និងគ្រឿងយន្តប្រហាក់ប្រហែល។

១០_ លិខិតមានលក្ខណៈគតិយុត្ត សំដៅដល់ លិខិតមានលក្ខណៈគតិយុត្តស្ដីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការបិទក្រុមហ៊ុនដែលបានចុះបញ្ជីនៅក្រសួងឬស្ថាប័នមានសមត្ថកិច្ច។

មាត្រា១៥៨ _ អត្រាពន្ធ

ពន្ធប្រថាប់ត្រាត្រូវកំណត់តាមអត្រាដូចខាងក្រោម៖

១_ ៤(បួន)ភាគរយនៃតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យជាសំណង់និង/ឬដី ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន ឬការផ្ទេរភាគហ៊ុន ឬផលប្រយោជន៍ប្រហាក់ប្រហែលរបស់ក្រុមហ៊ុនអចលនទ្រព្យ។

២_ ៤(បួន)ភាគរយនៃតម្លៃចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ចលនទ្រព្យ ឬការដាក់ភាគហ៊ុនជាចលនទ្រព្យក្នុងក្រុមហ៊ុន។

៣_ ០,១(សូន្យក្បៀសមួយ)ភាគរយនៃតម្លៃភាគហ៊ុនចំពោះការផ្ទេរចំណែកណាមួយឬទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន។

៤_ ០,១(សូន្យក្បៀសមួយ)ភាគរយនៃតម្លៃចុះកិច្ចសន្យាចំពោះកិច្ចសន្យាផ្ដត់ផ្ដង់ទំនិញឬសេវាដែលប្រើប្រាស់ថវិការដ្ឋ។



៥_ ១ ៥០០ ០០០(មួយលាន)រៀល ចំពោះលិខិតមានលក្ខណៈគតិយុត្ត រួមមានលិខិតស្ដីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងលិខិតស្ដីពីការបិទក្រុមហ៊ុន។

មាត្រា១៥៩ .- មូលដ្ឋានគិតពន្ធ

មូលដ្ឋានគិតពន្ធប្រថាប់ត្រាត្រូវបានកំណត់ដូចខាងក្រោម៖

១- តម្លៃអចលនទ្រព្យនិងចលនទ្រព្យត្រូវគិតតាមតម្លៃទីផ្សារនាពេលផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចកំណត់តម្លៃអចលនទ្រព្យនិងចលនទ្រព្យសម្រាប់ធ្វើជាមូលដ្ឋានគិតពន្ធនេះ។

២- តម្លៃភាគហ៊ុនឬផលប្រយោជន៍ប្រហាក់ប្រហែលត្រូវគិតតាមតម្លៃទីផ្សារនាពេលប្រតិបត្តិការផ្ទេរភាគហ៊ុនឬផលប្រយោជន៍ប្រហាក់ហែលនោះកើតឡើង។

៣- តម្លៃចុះកិច្ចសន្យា ត្រូវគិតតាមតម្លៃក្នុងកិច្ចសន្យាផ្តត់ផ្តង់ទំនិញឬសេវាដែលប្រើប្រាស់ថវិការដ្ឋ។

៤- លិខិតមានលក្ខណៈគតិយុត្តត្រូវកំណត់ ១ ០០០ ០០០(មួយលាន)រៀល ចំពោះលិខិតមានលក្ខណៈគតិយុត្តនីមួយៗ។

មាត្រា១៦០ .- អ្នកជាប់ពន្ធ

ពន្ធប្រថាប់ត្រាត្រូវអនុវត្តចំពោះ៖

១- អ្នកទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យនិងចលនទ្រព្យ។

២- អ្នកទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់ភាគហ៊ុន។

៣- អ្នកទទួលបានកិច្ចសន្យាផ្តត់ផ្តង់ទំនិញឬសេវាដែលប្រើប្រាស់ថវិការដ្ឋ។

៤- អ្នកទទួលសិទ្ធិលើលិខិតមានលក្ខណៈគតិយុត្ត។

មាត្រា១៦១ .- ការលើកលែងនិងការអនុគ្រោះពន្ធ

ពន្ធប្រថាប់ត្រាត្រូវបានលើកលែងនិងអនុគ្រោះដូចខាងក្រោម៖

១- ការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់ដីក្នុងលក្ខណៈសម្បទានពីរាជរដ្ឋាភិបាល។

២- ការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យក្នុងរង្វង់ញាតិ។

៣- ការទទួលកម្មសិទ្ធិទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់១៥០(មួយរយហាសិប)សេះ។

៤- ការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យនិងចលនទ្រព្យដែលត្រូវកត់ត្រាក្នុងបញ្ជីសារពើភណ្ឌរបស់ស្ថាប័នរដ្ឋនានានៃព្រះរាជាណាចក្រកម្ពុជា។

៥- ការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យនិងចលនទ្រព្យរបស់បេសកកម្មការទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត។

៦- ការទិញចលនទ្រព្យរបស់សហគ្រាសនានាធ្វើជាទំនិញដើម្បីលក់វិញ។

មាត្រា១៦២ .- កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ

អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធឱ្យបានចប់សព្វគ្រប់ក្នុងរយៈពេល ៣(បី)ខែចំពោះ៖

១- ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យនិងចលនទ្រព្យ ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យនិងចលនទ្រព្យក្នុងក្រុមហ៊ុន។

២- ការផ្ទេរចំណែកណាមួយឬទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន។

៣_ កិច្ចសន្យាផ្តត់ផ្តង់ទំនិញឬសេវាដែលប្រើប្រាស់ដោយការដ្ឋ។

៤_ លិខិតមានលក្ខណៈគតិយុត្ត រួមមានលិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងលិខិតស្តីពីការបិទក្រុមហ៊ុន។

មាត្រា១៦៣ _ ការខកខានមិនបានដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ

ប្រសិនបើម្ចាស់កម្មសិទ្ធិឬអ្នកកាន់កាប់ថ្មីណាមួយមិនបានបង់ប្រាក់ពន្ធប្រថាប់ត្រានៃ

១_ រដ្ឋបាលសុរិយោដីមិនត្រូវចេញឬផ្ទេរវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬបណ្ណសម្គាល់សិទ្ធិអចលនវត្ថុ ឬបណ្ណប្រហាក់ប្រហែលថ្មីនោះទេ។

២_ អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ មិនត្រូវបញ្ជាក់លើការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យ។

៣_ ស្ថាប័នសាធារណការនិងដឹកជញ្ជូន ឬអាជ្ញាធរមានសមត្ថកិច្ចមិនត្រូវចេញបណ្ណសម្គាល់ថ្មីចំពោះការផ្ទេរកម្មសិទ្ធិលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ រៀវលែងតែទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងជលយានយន្តដែលមានកម្លាំងដល់១៥០(មួយរយហាសិប)សេះ។

មាត្រា១៦៤ _ វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធប្រថាប់ត្រាត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី១៤
ពន្ធលើចំណេញមូលធន

មាត្រា១៦៥ _ កម្មវត្ថុនៃពន្ធ

ពន្ធលើចំណេញមូលធនត្រូវអនុវត្តលើចំណេញមូលធនដែលសម្រេចបានពីការលក់ឬផ្ទេរមូលធននៅព្រះរាជាណាចក្រកម្ពុជានិងនៅបរទេសដោយអ្នកជាប់ពន្ធនិវាសនជនជារូបវន្តបុគ្គល និងពីការលក់ឬផ្ទេរមូលធននៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយអ្នកជាប់ពន្ធអនិវាសនជន។

មាត្រា១៦៦ _ វិសាលភាពនៃពន្ធ

ពន្ធលើចំណេញមូលធនអនុវត្តលើអ្នកជាប់ពន្ធដែលទទួលបានចំណេញមូលធន។

មាត្រា១៦៧ _ និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងជំពូកនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១_ អ្នកជាប់ពន្ធ សំដៅដល់ អ្នកជាប់ពន្ធនិវាសនជន ឬអ្នកជាប់ពន្ធអនិវាសនជនដែលបានលក់ឬផ្ទេរមូលធនទៅឱ្យបុគ្គលដទៃ។

២_ អ្នកជាប់ពន្ធនិវាសនជន សំដៅដល់ រូបវន្តបុគ្គលដែលមាននិវាសនដ្ឋាន ឬមានកន្លែងស្នាក់នៅជាប្រចាំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា លើសពី ១៨៣(មួយរយប៉ែតសិបពីរ)ថ្ងៃ នៅក្នុងរយៈពេល១២(ដប់ពីរ)ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធចរន្ត។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២០៥

៣_ អ្នកជាប់ពន្ធអនិវាសនជន សំដៅដល់ រូបវន្តបុគ្គលឬនីតិបុគ្គលដែលមិនមែនជាអ្នកជាប់ពន្ធនិវាសនជន។

៤_ មូលធន សំដៅដល់ អចលនទ្រព្យ ភតិសន្យា ទ្រព្យវិនិយោគ កេរ្តិ៍ឈ្មោះអាជីវកម្ម កម្មសិទ្ធិបញ្ញា និងរូបិយបណ្ណបរទេស។

៥_ ចំណេញមូលធន សំដៅដល់ ប្រាក់ចំណូលជាប់ពន្ធដែលបានពីការយកចំណូលពីការលក់ឬផ្ទេរមូលធនដកការកាត់កងចំណាយដែលអនុញ្ញាត។

មាត្រា១៦៨ _ អត្រាពន្ធ

អត្រាពន្ធលើចំណេញមូលធនត្រូវបានកំណត់តាមអត្រា២០(ម្ភៃ)ភាគរយ។

មាត្រា១៦៩ _ ការលើកលែងពន្ធ

ពន្ធលើចំណេញមូលធនត្រូវបានលើកលែងចំពោះការលក់ឬផ្ទេរ៖

១_ ទ្រព្យដែលជាកម្មសិទ្ធិរបស់ស្ថាប័នរដ្ឋ។

២_ ទ្រព្យដែលជាកម្មសិទ្ធិរបស់បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសនៃរដ្ឋាភិបាលដទៃទៀត។

៣_ និវាសនដ្ឋានជាគោលដើមរបស់អ្នកជាប់ពន្ធ។

៤_ អចលនទ្រព្យក្នុងរង្វង់ញាតិ។

៥_ ទ្រព្យសម្រាប់បម្រើប្រយោជន៍សាធារណៈស្របតាមច្បាប់ស្តីពីអស្សាមិករណ៍។

៦_ ដីកសិកម្មជាកម្មសិទ្ធិឬសិទ្ធិកាន់កាប់របស់ប្រជាពលរដ្ឋដែលជាកសិករកំពុងបង្កបង្កើនផលពិតប្រាកដ និងមានអាសយដ្ឋានរស់នៅស្ថិតនៅក្នុងឃុំ/សង្កាត់ដែលដីកសិកម្មនោះស្ថិតនៅ។

មាត្រា១៧០ _ វិធាននៃការកាត់កងចំណាយ

វិធាននៃការកាត់កងចំណាយចំពោះចំណេញមូលធនមានដូចខាងក្រោម៖

១_ វិធីកាត់កងចំណាយតាមការកំណត់។

២_ វិធីកាត់កងចំណាយតាមជាក់ស្តែង។

មាត្រា១៧១ _ កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ

អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ត្រូវដាក់លិខិតប្រកាសពន្ធ តាមទម្រង់ដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ និងបង់ប្រាក់ពន្ធលើចំណេញមូលធនជូនរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេលមិនលើសពី៣(បី)ខែបន្ទាប់ពីសម្រេចបានចំណេញមូលធន។

មាត្រា១៧២ _ វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើចំណេញមូលធនត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី១៥
ពន្ធលើដីធ្លីមិនបានប្រើប្រាស់

មាត្រា១៧៣ .- កម្មវត្ថុនៃពន្ធ

ពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវអនុវត្តលើដីមានសំណង់និងដីគ្មានសំណង់ដែលមិនបានប្រើប្រាស់។

មាត្រា១៧៤ .- វិសាលភាពនៃពន្ធ

ពន្ធលើដីធ្លីមិនបានប្រើប្រាស់អនុវត្តលើដីធ្លីមិនបានប្រើប្រាស់ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា១៧៥ .- និយមន័យ

សម្រាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីពន្ធលើដីធ្លីមិនបានប្រើប្រាស់ ៣ក្យ ដីធ្លីមិនបានប្រើប្រាស់សំដៅដល់ ដីមានសំណង់ឬគ្មានសំណង់ដែលមិនបានប្រើប្រាស់។

មាត្រា១៧៦ .- អត្រាពន្ធ

ពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវប្រមូលប្រចាំឆ្នាំតាមអត្រា២(ពីរ)ភាគរយ។

មាត្រា១៧៧ .- មូលដ្ឋានគិតពន្ធ

មូលដ្ឋានគិតពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវផ្អែកលើតម្លៃដីដែលកំណត់ដោយគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់។ មូលដ្ឋានគិតពន្ធលើដីធ្លីមិនបានប្រើប្រាស់និងគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ត្រូវកំណត់និងបង្កើតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា១៧៨ .- ការលើកលែងពន្ធ

ការលើកលែងពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា១៧៩ .- កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ

កម្មសិទ្ធិករ ឬអ្នកកាន់កាប់ ឬអ្នកទទួលប្រយោជន៍ចុងក្រោយនៃដីធ្លីមិនបានប្រើប្រាស់ ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំឆ្នាំ។

មាត្រា១៨០ .- វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២០៧

ជំពូកទី១៦
ពន្ធលើមធ្យោបាយដឹកជញ្ជូន

មាត្រា១៨១ .- កម្មវត្ថុនៃពន្ធ

ពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវអនុវត្តលើមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ។

មាត្រា១៨២ .- វិសាលភាពនៃពន្ធ

ពន្ធលើមធ្យោបាយដឹកជញ្ជូនអនុវត្តលើមធ្យោបាយដឹកជញ្ជូននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា១៨៣ .- និយមន័យ

សម្រាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីពន្ធលើមធ្យោបាយដឹកជញ្ជូន ពាក្យ មធ្យោបាយដឹកជញ្ជូនសំដៅដល់ មធ្យោបាយដឹកជញ្ជូនឬយានដំនិះគ្រប់ប្រភេទ ដូចជា កប៉ាល់ សាឡង់ ទូក កាណូត អូប៉ែរ រថយន្ត ក្បាលរថយន្តសណ្តោង រ៉ឺម៉កសណ្តោង ស៊ីមីរ៉ឺម៉កសណ្តោង ទោចក្រយានយន្ត ត្រីចក្រយានយន្ត ត្រាក់ទ័រ និងគ្រឿងយន្តប្រហាក់ប្រហែល។

មាត្រា១៨៤ .- អត្រាពន្ធ

១- ពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវកំណត់ទៅតាមប្រភេទមធ្យោបាយដឹកជញ្ជូនដូចខាងក្រោម៖
- ក- រថយន្តដឹកទំនិញ។
- ខ- ក្បាលរថយន្តសណ្តោង រ៉ឺម៉កសណ្តោង ស៊ីមីរ៉ឺម៉កសណ្តោង។
- គ- រថយន្តដឹកអ្នកដំណើរ។
- ឃ- ជលយានឬជលយានយន្ត។
- ង- រថយន្តទេសចរណ៍។
- ច- យានឬយានយន្តកែច្នៃ។

២- អត្រាពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា១៨៥ .- អ្នកជាប់ពន្ធ

ពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវអនុវត្តលើម្ចាស់កម្មសិទ្ធិនៃមធ្យោបាយដឹកជញ្ជូន។

មាត្រា១៨៦ .- ការលើកលែងពន្ធ

ពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវបានលើកលែងចំពោះ៖

១- រថយន្តគិលានសង្គ្រោះ រថយន្តពន្លត់អគ្គិភ័យដែលជាកម្មសិទ្ធិរបស់រដ្ឋ។

២- យានយន្តដែលជាកម្មសិទ្ធិរបស់អង្គភាពកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងនគរបាលជាតិ។

៣- យានយន្តដែលជាកម្មសិទ្ធិរបស់ស្ថានទូតឬស្ថានកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារស្ថាប័នប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត។

៤- ទោចក្រយានយន្តនិងត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រនិងគ្រឿងយន្តប្រហាក់ប្រហែលនិងរថយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់ ១៥០ (មួយរយហាសិប) សេះ ឬតិចជាង។

ទំព័រ២០៨អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

មាត្រា១៨៧ .- កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ

ម្ចាស់កម្មសិទ្ធិមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំឆ្នាំ។

មាត្រា១៨៨ .- វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី១៧
វិធានទិន្ននីតិវិធីសារពើពន្ធ
ផ្នែកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១៨៩ .- កម្មវត្ថុ

១-បទប្បញ្ញត្តិទាំងឡាយនៃជំពូកនេះ កំណត់នូវសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ អំណាចនិងកាតព្វកិច្ចរបស់រដ្ឋបាលសារពើពន្ធ និងនីតិវិធីនៃការពិនិត្យឡើងវិញនូវប្រាក់ពន្ធបានបង់។

២-បទប្បញ្ញត្តិទាំងឡាយនៃជំពូកនេះ ត្រូវអនុវត្តចំពោះពន្ធគ្រប់ប្រភេទ វៀរលែងតែពន្ធដោយឡែកណាមួយដែលមានវិធានផ្សេង។

មាត្រា១៩០ .- និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងជំពូកទី១៧ និងជំពូកទី១៨ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១-ពន្ធ សំដៅដល់ ពន្ធនិងអាករទាំងឡាយ។

២-បុគ្គល សំដៅដល់ រូបវន្តបុគ្គលឬនីតិបុគ្គល។

៣-អ្នកជាប់ពន្ធ សំដៅដល់ បុគ្គលដែលមានកាតព្វកិច្ចត្រូវបង់ពន្ធ។

៤-រដ្ឋបាលសារពើពន្ធ សំដៅដល់ អង្គការចាត់តាំងនៃអគ្គនាយកដ្ឋានពន្ធដារ។

៥-មន្ត្រីពន្ធដារ សំដៅដល់ មន្ត្រីរាជការពន្ធដារគ្រប់លំដាប់ថ្នាក់ដែលកំពុងបម្រើការងារក្នុងក្របខ័ណ្ឌនៃអគ្គនាយកដ្ឋានពន្ធដារ។

៦-ការស៊ើបអង្កេត សំដៅដល់ ការធ្វើសវនកម្មពន្ធដារគ្រប់ប្រភេទ រួមទាំងការស៊ើបអង្កេតបទល្មើសលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

៧-លិខិតប្រកាសសារពើពន្ធ សំដៅដល់ ឯកសារដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវឱ្យអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកបំពេញទៅតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់នេះ។

៨-ភ្នាក់ងារកាត់ទុក សំដៅដល់ បុគ្គលដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវឱ្យធ្វើការកាត់ទុក និងបង់ប្រាក់ពន្ធជូនរដ្ឋាភិបាលក្នុងនាមតតិយជន។



៩-សកម្មភាពសេដ្ឋកិច្ច សំដៅដល់ សកម្មភាពរបស់បុគ្គលដែលធ្វើជានិច្চកាលជាប់បន្តឬ មួយដងមួយគ្រា ដើម្បីអាចមិនរកចំណេញក្នុងការផ្គត់ផ្គង់ ឬមានបំណងផ្គត់ផ្គង់ទំនិញឬសេវាឱ្យដល់បុគ្គលដទៃក្នុងគោលបំណងដើម្បីបានអត្ថប្រយោជន៍អ្វីមួយ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២០៩

១០_ ពន្ធបន្ថែម សំដៅដល់ ទណ្ឌកម្មជាសាច់ប្រាក់ចំពោះអំពើល្មើសនឹងបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលត្រូវបានគណនាតាមអត្រាដែលបានកំណត់ លើមូលដ្ឋានប្រាក់ពន្ធដែលបានបង់ខ្វះឬបង់យឺត។

១១_ ការប្រាក់ សំដៅដល់ ការប្រាក់ដែលកើតឡើងពីការបង់ពន្ធខ្វះឬការបង់ពន្ធយឺត ដែលត្រូវបានគណនាតាមអត្រាដែលបានកំណត់ លើមូលដ្ឋានប្រាក់ពន្ធដែលបានបង់ខ្វះឬបង់យឺត។

មាត្រា១៩១ _ កិច្ចព្រមព្រៀងអន្តរជាតិ

១_ បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងអន្តរជាតិទាក់ទិននឹងបញ្ហាពន្ធដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី ត្រូវមានវិសាលភាពគ្របដណ្តប់លើបទប្បញ្ញត្តិនៃច្បាប់នេះ។

២_ វិធាននិងនីតិវិធីសម្រាប់អនុវត្តបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងអន្តរជាតិទាក់ទិននឹងបញ្ហាពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា១៩២ _ ភាសាប្រើនៅក្នុងលិខិតប្រកាសនិងឯកសារសារពើពន្ធ

លិខិតប្រកាសសារពើពន្ធទាំងអស់ ក៏ដូចជាឯកសារនិងលិខិតទាក់ទងផ្សេងៗដែលចាំបាច់សម្រាប់ការកំណត់ពន្ធ ការប្រមូលពន្ធ និងការបង្ខំឱ្យប្រតិបត្តិតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ឬដែលទាក់ទិននឹងបែបបទផ្សេងទៀតក្នុងការកំណត់ពន្ធ ត្រូវធ្វើជាភាសាខ្មែរ។

ផ្នែកទី២
សិទ្ធិ អំណាច និងភាគព្វកិច្ច

មាត្រា១៩៣ _ សិទ្ធិនិងភាគព្វកិច្ចរបស់អ្នកជាប់ពន្ធ

សិទ្ធិនិងភាគព្វកិច្ចរបស់អ្នកជាប់ពន្ធត្រូវបានកំណត់ដូចខាងក្រោម៖

១_ អ្នកជាប់ពន្ធមានសិទ្ធិដូចខាងក្រោម៖

ក_ ទទួលបាននូវការរក្សាទុកជាការសម្ងាត់និងត្រូវបានយកមកប្រើប្រាស់តែក្នុងគោលដៅដែលមានបញ្ជាក់នៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារនូវព័ត៌មាននានាទាក់ទិននឹងកិច្ចការអាជីវកម្មរបស់ខ្លួនដែលបានផ្តល់ឱ្យរដ្ឋបាលសារពើពន្ធដូចមានចែងក្នុងមាត្រា១៩៧នៃច្បាប់នេះ។

ខ_ ទទួលព័ត៌មានជាប្រចាំអំពីកិច្ចដំណើរការនៃប្រព័ន្ធពន្ធដារនិងនីតិវិធីនៃការកំណត់ពន្ធដូចមានចែងក្នុងមាត្រា១៩៩និងមាត្រា២១១នៃច្បាប់នេះ។

គ_ ទទួលព័ត៌មានអំពីសិទ្ធិរបស់ខ្លួន រួមទាំងសិទ្ធិក្នុងការប្តឹងតវ៉ាដូចមានចែងក្នុងមាត្រា២១១និងមាត្រា២៣៨នៃច្បាប់នេះ។

ឃ_ ប្តឹងតវ៉ាដូចមានចែងក្នុងច្បាប់នេះ ចំពោះរាល់សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធដូចមានចែងក្នុងមាត្រា២១១និងមាត្រា២៣៨នៃច្បាប់នេះ។

ង_ បង់ពន្ធមិនឱ្យលើសពីបទប្បញ្ញត្តិស្តីពីពន្ធដារកំណត់ដូចមានចែងក្នុងមាត្រា២១៣នៃច្បាប់នេះ។

២- អ្នកជាប់ពន្ធមានកាតព្វកិច្ចដូចខាងក្រោម៖

ក- ចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធដូចមានចែងក្នុងមាត្រា២០៣នៃច្បាប់នេះ។

ខ- ដាក់លិខិតប្រកាសសារពើពន្ធនិងផ្តល់ព័ត៌មានតាមការតម្រូវនៃបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចមានចែងក្នុងមាត្រា២០១និងមាត្រា២០៦នៃច្បាប់នេះ។

គ- បង់ពន្ធតាមកាលបរិច្ឆេទកំណត់ដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ។

ឃ- កាន់ ថែរក្សា និងត្រូវបង្ហាញបញ្ជី លិខិតយុត្តិការ និងឯកសារផ្សេងៗដល់រដ្ឋបាលសារពើពន្ធ ដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ និងមាត្រា២០១នៃច្បាប់នេះ។

ង- បង្ហាញខ្លួនចំពោះរដ្ឋបាលសារពើពន្ធតាមកាលបរិច្ឆេទដែលមានចុះក្នុងលិខិតជូនដំណឹង របស់រដ្ឋបាលសារពើពន្ធដូចមានចែងក្នុងមាត្រា២០២នៃច្បាប់នេះ។

ច- បង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗទៀតដែលរដ្ឋបាលសារពើពន្ធបានកំណត់ ទៅតាមកាលបរិច្ឆេទដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ឬដែលរដ្ឋបាលសារពើពន្ធ បានជូនដំណឹងជាលាយលក្ខណ៍អក្សរដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ និង មាត្រា២១៣ មាត្រា២៣២ និងមាត្រា២៣៣នៃច្បាប់នេះ។

មាត្រា១៩៤ .- អំណាចនិងកាតព្វកិច្ចរបស់រដ្ឋបាលសារពើពន្ធ

អំណាចនិងកាតព្វកិច្ចរបស់រដ្ឋបាលសារពើពន្ធត្រូវបានកំណត់ដូចខាងក្រោម៖

១- រដ្ឋបាលសារពើពន្ធមានអំណាចដូចខាងក្រោម៖

ក- កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកដូចមានចែងក្នុងមាត្រា២០៩ និងមាត្រា២១០នៃច្បាប់នេះ។

ខ- តម្រូវឱ្យអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកបង្ហាញខ្លួនដូចមានចែងក្នុងមាត្រា២០២នៃច្បាប់នេះ។

គ- កំណត់បញ្ជីឯកសារចាំបាច់នានា និងលិខិតយុត្តិការដែលអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ត្រូវកាន់រក្សាទុកនិងផ្តល់ជូនរដ្ឋបាលសារពើពន្ធដូចមានចែងក្នុងមាត្រា២០១និងមាត្រា ២៣០នៃច្បាប់នេះ។

ឃ- ទាមទារឱ្យអ្នកជាប់ពន្ធ ឬតតិយជនផ្តល់ព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ដូចមានចែងក្នុងមាត្រា២០២នៃច្បាប់នេះ។

ង- ចូលលំនៅឋានឬគ្រឹះស្ថានអាជីវកម្មរបស់អ្នកជាប់ពន្ធ ភ្នាក់ងារកាត់ទុក ឬតតិយជន ដើម្បី ទទួលបាននូវព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកដូចមានចែងក្នុងមាត្រា ២៣០នៃច្បាប់នេះ។

ច- ទទួលពីស្ថាប័នរដ្ឋទាំងឡាយនូវព័ត៌មានស្តីពីឬដែលទាក់ទិននឹងអ្នកជាប់ពន្ធឬភ្នាក់ងារ កាត់ទុកដូចមានចែងក្នុងមាត្រា២០៩នៃច្បាប់នេះ។

ឆ- អនុវត្តវិធានការតឹងទារចំពោះអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកនៅពេលដែលបុគ្គលនោះ មិនបានបង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗទៀតតាមការតម្រូវដូចមានចែង ក្នុងមាត្រា២១៧ មាត្រា២១៨ មាត្រា២២០ មាត្រា២២១ និងមាត្រា២២២នៃច្បាប់នេះ។

កំណត់ឡើងវិញនូវប្រតិបត្តិការអាជីវកម្មក្នុងចំណោមបុគ្គលទាក់ទិនដូចមានចែងក្នុង បទប្បញ្ញត្តិស្តីពីពន្ធដារ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២១១

ឈ_ ច្រានចោលនិង/ឬកំណត់សារធាតុពិតនៃប្រតិបត្តិការទាំងឡាយឡើងវិញក្នុងករណីពិនិត្យ ឃើញថាអ្នកជាប់ពន្ធបានរៀបចំឬមានប្រតិបត្តិការទាំងឡាយណាដែលបង្ហាញចន្លៈមិនពិត ឬគ្មានភាពជាក់ស្តែងក្នុងគោលបំណងដើម្បីបន្ថយឬបំបាត់ប្រាក់ពន្ធដែលត្រូវបង់ ដែលផ្ទុយពីស្មារតីនៃបទប្បញ្ញត្តិស្តីពីពន្ធដារ។

២_ រដ្ឋបាលសារពើពន្ធមានកាតព្វកិច្ចដូចខាងក្រោម៖

ក_ ប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗទៀតដូចមានចែងក្នុងមាត្រា១៩៥ នៃច្បាប់នេះ។

ខ_ រក្សាការសម្ងាត់នូវព័ត៌មានដែលអ្នកជាប់ពន្ធឬតតិយជនបានផ្តល់ឱ្យ ហើយផ្តល់ព័ត៌មានទាំងនេះឱ្យដល់តែបុគ្គលណាដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានកំណត់ដូចមានចែងក្នុងមាត្រា១៩៧ និងមាត្រា២៤៤នៃច្បាប់នេះ។

គ_ ផ្តល់ព័ត៌មានដល់អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកសំដៅជានាឱ្យការអនុវត្តបានសមស្របទៅតាមបទប្បញ្ញត្តិស្តីពីពន្ធដារដូចមានចែងក្នុងមាត្រា១៩៩នៃច្បាប់នេះ។

ឃ_ បង្វិលសងវិញ ឬចាត់ជាឥណទានពន្ធនូវប្រាក់ពន្ធដែលបង់លើសដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ។

ង_ ផ្តល់លិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឱ្យអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកដូចមានចែងក្នុងមាត្រា២០៩ ដល់មាត្រា២១១នៃច្បាប់នេះ។

ផ្នែកទី៣
រដ្ឋបាលសារពើពន្ធ

មាត្រា១៩៥_ ស្ថាប័នមានសមត្ថកិច្ច

១_ ស្ថាប័នដែលទទួលខុសត្រូវគ្រប់គ្រងការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារមានដូចខាងក្រោម៖

ក_ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ខ_ ស្ថាប័នដទៃទៀតរបស់រាជរដ្ឋាភិបាលដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានផ្តល់អំណាចឱ្យ។

២_ រដ្ឋបាលសារពើពន្ធមានកាតព្វកិច្ចប្រមូលពន្ធ អនុវត្តទណ្ឌកម្មតាមការកំណត់នៃបទប្បញ្ញត្តិស្តីពីពន្ធដារ និងប្តឹងទៅតុលាការក្នុងករណីមានការរំលោភច្បាប់។

៣_ រដ្ឋបាលសារពើពន្ធ គឺជាស្ថាប័នដែលមានសមត្ថកិច្ចក្នុងការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល។ ការសម្រេចឱ្យរួចមួយផ្នែកឬទាំងស្រុងនូវទណ្ឌកម្មរដ្ឋបាល ជាសិទ្ធិអំណាចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រដ្ឋបាលសារពើពន្ធអាចសម្រេចឱ្យរួចមួយផ្នែកឬទាំងស្រុងនូវទណ្ឌកម្មរដ្ឋបាលនេះបាន ក្នុងករណីទទួលបានការធ្វើប្រតិភូកម្មសិទ្ធិអំណាចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា១៩៦_ សិទ្ធិអំណាចក្នុងគ្រាដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

១_ ក្នុងករណីដែលប្រទេសជាតិប្រឈមមុខនឹងវិបត្តិសេដ្ឋកិច្ច ហិរញ្ញវត្ថុ ឬគ្រោះអាសន្ន ឬតម្រូវការចាំបាច់បន្ទាន់នានា ក្នុងការធានាលំនឹងជីវភាពនិងសុខុមាលភាពរបស់ប្រជាជន និងធានាប្រក្រតីភាពនៃកិច្ចដំណើរការសេដ្ឋកិច្ចនិងសង្គម រាជរដ្ឋាភិបាលអាចសម្រេចផ្តល់ការអនុគ្រោះ ឬលើកលែង ឬព្យួរនូវបទប្បញ្ញត្តិពន្ធណាមួយភ្លាម មួយផ្នែកឬទាំងស្រុង តាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

២_ ការផ្តល់ការអនុគ្រោះ ឬការលើកលែង ឬការព្យួរប្រភេទពន្ធណាមួយ ដូចមានចែងក្នុងកថាខណ្ឌខាងលើ នឹងត្រូវបានកម្មវត្ថុនៃការធ្វើនិយតកម្មវិបនីយកម្មដោយច្បាប់ហិរញ្ញវត្ថុ នាពេលបន្ទាប់។

ទំព័រ២១២អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

មាត្រា១៩៧.- ភាពសម្ងាត់នៃព័ត៌មានពន្ធដារ

១- រដ្ឋបាលសារពើពន្ធនិងបុគ្គលគ្រប់រូបដែលជាឬធ្លាប់ជាមន្ត្រីនិងភ្នាក់ងារនៃរដ្ឋបាលសារពើពន្ធ ត្រូវរក្សាភាពសម្ងាត់នូវព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធដែលបានទទួលនៅក្នុងពេលបំពេញការកិច្ចជាផ្លូវការ ហើយអាចផ្តល់ព័ត៌មានទៅឱ្យតែបុគ្គលដែលមាត្រានេះបានអនុញ្ញាតប៉ុណ្ណោះ។

២- មន្ត្រីនិងភ្នាក់ងារនៃរដ្ឋបាលសារពើពន្ធ អាចផ្តល់ព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធឱ្យចំពោះតែ៖

ក- មន្ត្រីនិងភ្នាក់ងារផ្សេងទៀតរបស់រដ្ឋបាលសារពើពន្ធនៅក្នុងពេលនិងក្នុងគោលដៅបំពេញការកិច្ចតាមបទប្បញ្ញត្តិស្តីពីពន្ធដារ។

ខ- អាជ្ញាធរព្រហ្មទណ្ឌសម្រាប់គោលដៅប្តឹងចោទប្រកាន់អំពីបទល្មើសពន្ធដារ។

គ- តុលាការនៅក្នុងដំណាក់កាលដម្រះក្តីដើម្បីកំណត់ពន្ធត្រូវបង់របស់អ្នកជាប់ពន្ធ ឬក៏ការទទួលខុសត្រូវចំពោះការរំលោភបទប្បញ្ញត្តិស្តីពីពន្ធដារ។

ឃ- អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនឹងពន្ធដាររបស់ប្រទេសណាមួយទៀតស្របតាមកិច្ចព្រមព្រៀងអន្តរជាតិ។

៣- បុគ្គលដែលបានទទួលព័ត៌មានពីបុគ្គលម្នាក់ទៀតដែលបានការអនុញ្ញាតឱ្យផ្តល់ព័ត៌មានដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រានេះ ត្រូវរក្សាភាពសម្ងាត់លើព័ត៌មាននោះទៅតាមការកំណត់នៃមាត្រានេះលើកលែងតែកម្រិតអប្បបរមាណាមួយដែលចាំបាច់ត្រូវអនុញ្ញាតឱ្យផ្តល់ព័ត៌មាននេះ។

៤- ព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធអាចផ្តល់ទៅឱ្យបុគ្គលម្នាក់ទៀតបាន ប្រសិនបើមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នកជាប់ពន្ធ។

មាត្រា១៩៨.- ការផ្តល់ព័ត៌មានដល់អ្នកជាប់ពន្ធ

ការផ្តល់ព័ត៌មានដល់អ្នកជាប់ពន្ធត្រូវអនុវត្តដូចខាងក្រោម៖

១- លិខិតស្នាមឬលិខិតជូនដំណឹងដែលរដ្ឋបាលសារពើពន្ធផ្តល់ទៅឱ្យអ្នកជាប់ពន្ធមានលក្ខណៈជាការដាក់ឱ្យអ្នកជាប់ពន្ធនោះមានកាតព្វកិច្ចចំពោះរដ្ឋបាលសារពើពន្ធ លុះណាតែលិខិតស្នាមឬលិខិតជូនដំណឹងនោះត្រូវបានធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវបានប្រគល់ឱ្យដល់អ្នកជាប់ពន្ធ។ លិខិតស្នាមឬលិខិតជូនដំណឹងដូចមានចែងក្នុងកថាខណ្ឌនេះ រួមបញ្ចូលទាំងការជូនដំណឹងតាមប្រព័ន្ធអេឡិចត្រូនិកដែលក្នុងនោះ មានជាអាទិ៍ទូរសារ សារអេឡិចត្រូនិក។

២- ក្នុងករណីដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវឱ្យរដ្ឋបាលសារពើពន្ធផ្តល់លិខិតស្នាមឬលិខិតជូនដំណឹងទៅឱ្យបុគ្គល លិខិតស្នាមឬលិខិតជូនដំណឹងនោះត្រូវបានចាត់ទុកថាបានប្រគល់យ៉ាងត្រឹមត្រូវលុះណាតែបានប្រគល់ឱ្យបុគ្គលនោះ ឬក៏បានផ្ញើតាមប្រៃសណីយ៍ជាលិខិតអនុសិដ្ឋទៅអាសយដ្ឋានតាមផ្លូវច្បាប់របស់បុគ្គលនោះ។ ចំពោះការជូនដំណឹងតាមប្រព័ន្ធអេឡិចត្រូនិកដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវបានចាត់ទុកថាបានប្រគល់ត្រឹមត្រូវ ប្រសិនបើបានបញ្ជូនទៅអាសយដ្ឋានចុងក្រោយដែលអ្នកជាប់ពន្ធបានផ្តល់ឱ្យរដ្ឋបាលសារពើពន្ធ។

៣- កាលបរិច្ឆេទនៃលិខិតស្នាមឬលិខិតជូនដំណឹងផ្សេងៗ គឺជាកាលបរិច្ឆេទនៃការប្រគល់ឱ្យបុគ្គល។ ក្នុងករណីលិខិតស្នាម ឬលិខិតជូនដំណឹងត្រូវបានផ្ញើតាមលិខិតអនុសិដ្ឋ កាលបរិច្ឆេទនៃការជូនដំណឹង គឺជាកាលបរិច្ឆេទនៃការបោះត្រាលើលិខិតអនុសិដ្ឋរបស់ការិយាល័យប្រៃសណីយ៍។ ក្នុងករណីការជូនដំណឹងតាមប្រព័ន្ធអេឡិចត្រូនិក កាលបរិច្ឆេទនៃការជូនដំណឹង គឺជាកាលបរិច្ឆេទដែលដំណឹងត្រូវបានផ្ញើចេញ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២១៣

๔_ លិខិតស្នាមឬលិខិតជូនដំណឹងត្រូវចាត់ទុកថាបានប្រគល់ទទួលត្រឹមត្រូវ ប្រសិនបើលក្ខខណ្ឌក្នុងកថាខណ្ឌទី២នៃមាត្រានេះ ត្រូវបានបំពេញរួចហើយ ទោះបីជាបុគ្គលដែលត្រូវបានជូនដំណឹងនោះបដិសេធការប្រគល់ឬការទទួលលិខិតអនុសិដ្ឋក្តី។

៥_ ក្នុងករណីដែលអាសយដ្ឋានរបស់បុគ្គលត្រូវបានផ្លាស់ប្តូរ ហើយបុគ្គលមិនបានជូនដំណឹងដល់រដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្តូរនោះទេ លិខិតស្នាមឬលិខិតជូនដំណឹងដែលបានបញ្ជូនទៅអាសយដ្ឋានដែលបានស្គាល់ចុងក្រោយបង្អស់ ត្រូវចាត់ទុកថាបានប្រគល់ទទួលត្រឹមត្រូវ។

៦_ ក្នុងករណីដោយមូលហេតុណាមួយដែលលិខិតស្នាមឬលិខិតជូនដំណឹងមិនអាចផ្តល់ដល់អ្នកជាប់ពន្ធ ដូចមានចែងក្នុងកថាខណ្ឌទី១ ដល់កថាខណ្ឌទី៥នៃមាត្រានេះ លិខិតស្នាមឬលិខិតជូនដំណឹងត្រូវបានចាត់ទុកថាបានប្រគល់យ៉ាងត្រឹមត្រូវ ប្រសិនបើរដ្ឋបាលសារពើពន្ធបាន៖

ក_ បិទលិខិតស្នាម ឬលិខិតជូនដំណឹងភ្ជាប់ទៅនឹងទ្វារនិវាសនដ្ឋាន ឬទីកន្លែងប្រកបអាជីវកម្មរបស់អ្នកជាប់ពន្ធ ឬ

ខ_ ផ្សព្វផ្សាយតាមសារព័ត៌មាន វិទ្យុ ទូរទស្សន៍ ឬគេហទំព័ររបស់រដ្ឋបាលសារពើពន្ធ ដោយតម្រូវឱ្យអ្នកជាប់ពន្ធបង្ហាញខ្លួននៅរដ្ឋបាលសារពើពន្ធមិនឱ្យលើសពី១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទផ្សព្វផ្សាយ។

មាត្រា១៩៩ ._ ការផ្សព្វផ្សាយនិងការពន្យល់ណែនាំបទប្បញ្ញត្តិស្តីពីពន្ធដារ

១_ រដ្ឋបាលសារពើពន្ធ ត្រូវរៀបចំសៀវភៅពន្យល់ខ្លីៗស្តីពីខ្លឹមសារសំខាន់ៗនៃប្រភេទពន្ធនីមួយៗ។

២_ ចំពោះប្រភេទពន្ធណាមួយដែលរដ្ឋបាលសារពើពន្ធកំណត់ថាគួរចុះធ្វើការពន្យល់ណែនាំនោះមន្ត្រីពន្ធដារនៅតាមមូលដ្ឋាន ត្រូវចុះអប់រំដល់អ្នកជាប់ពន្ធឱ្យបានយល់អំពីកាតព្វកិច្ចនិងសិទ្ធិរបស់អ្នកជាប់ពន្ធទាំងនោះ។

មាត្រា២០០ ._ ការលើកទឹកចិត្តចំពោះការប្រមូលពន្ធ

១_ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកសាងប្រព័ន្ធលើកទឹកចិត្តសម្រាប់រដ្ឋបាលសារពើពន្ធ។

២_ វិធាននិងនីតិវិធីសម្រាប់ដំណើរការប្រព័ន្ធលើកទឹកចិត្តត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា២០១ ._ ការកាន់ កត់ត្រា រក្សាទុកបញ្ជី លិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុ

១_ អ្នកជាប់ពន្ធត្រូវកាន់ កត់ត្រា និងរក្សាទុកបញ្ជី លិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុផ្សេងៗដូចដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានកំណត់ និងត្រូវដាក់បញ្ជីនិងឯកសារទាំងនោះតាមការតម្រូវជូនរដ្ឋបាលសារពើពន្ធ។

២_ ចំពោះអ្នកជាប់ពន្ធដែលពុំមានកាតព្វកិច្ចកាន់បញ្ជីគណនេយ្យតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្មជាដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកាន់ទិនានុប្បវត្តិដោយកត់ត្រាចុះតាមលំដាប់ថ្ងៃ ខែ នូវចំណូលនិងចំណាយផ្សេងៗទាំងអស់ដែលទាក់ទិននឹងអាជីវកម្មទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់។

៣- ក្នុងករណីដែលអ្នកជាប់ពន្ធមិនកាន់ កត់ត្រា ឬកត់ត្រាមិនត្រឹមត្រូវនូវបញ្ជីគណនេយ្យ ឬកំណត់ត្រានានាតាមលក្ខខណ្ឌដែលបានកំណត់ រដ្ឋបាលសារពើពន្ធជាអ្នកកំណត់នូវប្រាក់ចំណូលនិងចំណាយផ្សេងៗ។

៤- បុគ្គលដែលត្រូវកាន់ កត់ត្រា ឬរក្សាទុកបញ្ជី ឯកសារនានា ឬទិនានុប្បវត្តិដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារឬបទប្បញ្ញត្តិដទៃ ត្រូវរក្សាទុកបញ្ជីឬឯកសារទាំងនោះ ក្នុងរយៈពេល១០(ដប់)ឆ្នាំសម្រាប់អ្នកជាប់ពន្ធមធ្យមនិងធំ និង៣(បី)ឆ្នាំសម្រាប់អ្នកជាប់ពន្ធតូច គិតពីដំណាច់ឆ្នាំជាប់ពន្ធ។

៥- អ្នកជាប់ពន្ធត្រូវចេញវិក្កយបត្រលើរាល់ប្រតិបត្តិការអាជីវកម្ម។ វិធានវិក្កយបត្រត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៦- អ្នកជាប់ពន្ធត្រូវកែតំត្រាសេចក្តីពាយលម្អិតនៃវិក្កយបត្រឱ្យបានត្រឹមត្រូវចូលក្នុងទិនានុប្បវត្តិ។

មាត្រា២០២ .- សិទ្ធិទទួលព័ត៌មាន

១- ក្នុងគោលដៅកំណត់ប្រាក់ពន្ធត្រូវបង់របស់បុគ្គលណាម្នាក់ ឬដើម្បីប្រមូលពន្ធ ឬដើម្បីបំពេញភាតព្វកិច្ចស្របតាមកិច្ចព្រមព្រៀងអន្តរជាតិ រដ្ឋបាលសារពើពន្ធអាចផ្ញើលិខិតជូនដំណឹងដល់អ្នកជាប់ពន្ធ ឬតតិយជន រួមទាំង ធនាគារ សហគ្រាសធានារ៉ាប់រង និងគ្រឹះស្ថានហិរញ្ញវត្ថុនានាឱ្យ៖

ក- ផ្តល់ព័ត៌មានដែលទាក់ទិននឹងអ្នកជាប់ពន្ធឬបុគ្គលពាក់ព័ន្ធដូចមានចែងក្នុងលិខិតជូនដំណឹង ដូចជាព័ត៌មានស្តីពីអ្នកផ្គត់ផ្គង់ អតិថិជន ឬគណនីនៅធនាគារ។

ខ- បង្ហាញខ្លួនទៅតាមពេលវេលានិងទីកន្លែងដែលមានបញ្ជាក់នៅក្នុងលិខិតជូនដំណឹង ដើម្បីផ្តល់ព័ត៌មាននិងដើម្បីបង្ហាញ ឬផ្តល់ឯកសារ ឬទិន្នន័យដែលបុគ្គលនោះគ្រប់គ្រងដែលមានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងលិខិតជូនដំណឹង។

២- បន្ថែមលើព័ត៌មានដែលបានតម្រូវដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ លិខិតជូនដំណឹងត្រូវមានចុះឈ្មោះនិងលេខអត្តសញ្ញាណកម្មនៃបុគ្គលអ្នកជាប់ពន្ធ (ប្រសិនបើមាន) ហើយនិងហត្ថលេខារបស់រដ្ឋបាលសារពើពន្ធដែលចេញលិខិតជូនដំណឹង។

៣- អ្នកជាប់ពន្ធឬតតិយជន រួមទាំង ធនាគារ សហគ្រាសធានារ៉ាប់រង និងគ្រឹះស្ថានហិរញ្ញវត្ថុនានាត្រូវបញ្ជូនរបាយការណ៍ឬបញ្ជូនលិខិតឆ្លើយតបមករដ្ឋបាលសារពើពន្ធក្នុងរយៈពេល៣០(សាមសិប)ថ្ងៃបន្ទាប់ពីបានទទួលលិខិតជូនដំណឹងស្តីពីការផ្តល់ព័ត៌មានដែលទាក់ទិននឹងអ្នកជាប់ពន្ធ។

៤- បុគ្គលទាំងឡាយអាចរាយការណ៍មករដ្ឋបាលសារពើពន្ធនូវព័ត៌មានដែលពាក់ព័ន្ធនឹងពន្ធដារ។

៥- ការសម្ងាត់វិជ្ជាជីវៈមិនត្រូវបានការពារដល់ការអនុវត្តមាត្រានេះ និងមាត្រាដទៃទៀតនៃច្បាប់នេះ។

មាត្រា២០៣ .- កាតព្វកិច្ចចុះបញ្ជីនិងបច្ចុប្បន្នកម្ម

១- បុគ្គលទាំងឡាយត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល១៥(ដប់ប្រាំ)ថ្ងៃ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ចឬសកម្មភាពផ្សេងទៀត រួមទាំងសកម្មភាពរបស់ស្ថាប័នឬអង្គការនានា ដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា៥នៃច្បាប់នេះ។

២- បុគ្គលទាំងឡាយត្រូវជូនដំណឹងទៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ក្រោយពីការផ្លាស់ប្តូរអាសយដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម ការផ្ទេរ ការបញ្ឈប់អាជីវកម្ម សមាសភាពអ្នកគ្រប់គ្រង ឬអ្នកទទួលបន្ទុកកិច្ចការពន្ធដារបស់សហគ្រាស។

៣- វិធាននិងនីតិវិធីនៃការចុះបញ្ជីនិងការធ្វើបច្ចុប្បន្នកម្មត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២១៥

មាត្រា២០៤ .- លិខិតបញ្ជាក់ការចុះបញ្ជីនិងលេខអត្តសញ្ញាណកម្មសារពើពន្ធ

១- នៅពេលបានអនុវត្តការចុះបញ្ជីរួចរាល់ហើយ រដ្ឋបាលសារពើពន្ធត្រូវចេញលិខិតបញ្ជាក់ការចុះបញ្ជី ដែលមានចុះលេខអត្តសញ្ញាណកម្មសារពើពន្ធរបស់បុគ្គល។ លេខអត្តសញ្ញាណកម្មនេះត្រូវយកទៅប្រើលើគ្រប់ឯកសារទាក់ទិននឹងពន្ធដារ។

២- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវតែប្រើលេខអត្តសញ្ញាណកម្មក្នុងមាត្រានេះ។ រាល់កិច្ចសន្យាជាមួយស្ថាប័នរដ្ឋត្រូវតែមានចុះលេខអត្តសញ្ញាណកម្មសារពើពន្ធទើបចាត់ទុកជាបានការ។

មាត្រា២០៥ .- សិទ្ធិរបស់រដ្ឋបាលសារពើពន្ធក្នុងការចុះបញ្ជីអ្នកជាប់ពន្ធ

រដ្ឋបាលសារពើពន្ធមានសិទ្ធិចុះបញ្ជីចំពោះបុគ្គលទាំងឡាយដែលច្បាប់បានកំណត់ឱ្យចុះបញ្ជី ហើយពុំបានមកចុះបញ្ជី ក្នុងករណីនេះរដ្ឋបាលសារពើពន្ធអាចកំណត់កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី។

ផ្នែកទី៤
លិខិតប្រកាសសារពើពន្ធ

មាត្រា២០៦ .- ការដាក់លិខិតប្រកាសសារពើពន្ធ

ការដាក់លិខិតប្រកាសសារពើពន្ធត្រូវបានកំណត់ដូចខាងក្រោម៖

១- អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធតាមទម្រង់ ពេលវេលា និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់។

២- លិខិតប្រកាសសារពើពន្ធ ត្រូវចុះហត្ថលេខាដោយអ្នកជាប់ពន្ធឬតំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ។

៣- អ្នកវិនិយោគទាំងអស់ ត្រូវដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែសម្រាប់ខែនីមួយៗ និងលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំជាប់ពន្ធនោះ និងបង់ពន្ធអាករទាំងអស់ទៅតាមបទប្បញ្ញត្តិនៃពន្ធនីមួយៗ។

៤- អ្នកវិនិយោគទាំងអស់ ត្រូវភ្ជាប់នូវវិញ្ញាបនបត្ររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបញ្ជាក់ពីការគោរពប្រតិបត្តិជាមួយលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំជាប់ពន្ធនោះ។

៥- អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ឬអ្នកវិនិយោគទាំងអស់ អាចដាក់លិខិតប្រកាសសារពើពន្ធដូចមានចែងក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី៣នៃមាត្រានេះ តាមប្រព័ន្ធទទួលលិខិតប្រកាសអេឡិចត្រូនិករបស់រដ្ឋបាលសារពើពន្ធ ហើយមានតម្លៃស្មើគ្នានឹងលិខិតប្រកាសសារពើពន្ធដាលាយលក្ខណ៍អក្សរដែលជាច្បាប់ដើម។

មាត្រា២០៧ .- ការដាក់លិខិតប្រកាសព័ត៌មាននិងឯកសារផ្សេងទៀត

បុគ្គលណាមួយដែលបានបើកប្រាក់ឱ្យទៅបុគ្គលផ្សេងទៀត ត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធនូវលិខិតប្រកាសព័ត៌មាននិងឯកសារផ្សេងទៀតស្តីពីការបើកប្រាក់នោះទៅតាមបែបបទដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ។

មាត្រា២០៨ .- តំណាងអ្នកជាប់ពន្ធ

១-អ្នកជាប់ពន្ធអាចធ្វើការផ្ទេរសិទ្ធិដាលាយលក្ខណ៍អក្សរទៅឱ្យបុគ្គលដែលជាតំណាងម្នាក់ទៀតឱ្យធ្វើសកម្មភាពជំនួសមុខខ្លួនក្នុងកិច្ចការនានាទាក់ទិននឹងពន្ធដារ។ អ្នកជាប់ពន្ធអាចកំណត់ព្រំដែនសិទ្ធិអំណាចនៃការផ្ទេរសិទ្ធិនេះ។ អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចទទួលខុសត្រូវដោយផ្ទាល់ចំពោះរាល់សកម្មភាពរបស់បុគ្គលដែលជាតំណាងស្របច្បាប់របស់ខ្លួន ឬបុគ្គលដែលបានទទួលការផ្ទេរសិទ្ធិពីខ្លួនរហូតដល់ពេលណាដែលរដ្ឋបាលសារពើពន្ធបានទទួលសេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សរពីអ្នកជាប់ពន្ធស្តីពីការលុបចោលនូវការផ្ទេរសិទ្ធិនោះ។

២-បុគ្គលដែលជាតំណាងអ្នកជាប់ពន្ធ ត្រូវមានសិទ្ធិដំនួសមុខឱ្យអ្នកជាប់ពន្ធដើម្បី៖

- ដាក់លិខិតប្រកាសសារពើពន្ធ
- បង្ហាញរបាយការណ៍ ឬលិខិតស្នាមផ្សេងៗ
- បង់ពន្ធអាករទាំងឡាយដែលកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារ
- ធ្វើបណ្តឹងតវ៉ា
- បំពេញរាល់កាតព្វកិច្ចដែលអ្នកជាប់ពន្ធត្រូវទទួលខុសត្រូវចំពោះមុខច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ។

៣-បុគ្គលដែលជាតំណាងរបស់អ្នកជាប់ពន្ធក្នុងអំឡុងពេល១៥(ដប់ប្រាំ)ថ្ងៃ ត្រូវផ្តល់ព័ត៌មានជូនរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់មកនូវកិស្តុតាងដាលាយលក្ខណ៍អក្សរនៃការផ្ទេរសិទ្ធិដែលមានសុពលភាព។

៤-បុគ្គលដែលទទួលអាជ្ញាបណ្ណជាភ្នាក់ងារសេវាកម្មពន្ធដារអាចជាតំណាងអ្នកជាប់ពន្ធនិងអាចធ្វើការផ្តត់ផ្តង់សេវាទាក់ទិននឹងពន្ធដារដល់អ្នកជាប់ពន្ធ។ វិធាននិងនីតិវិធីនៃការគ្រប់គ្រងភ្នាក់ងារសេវាកម្មពន្ធដារត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ផ្នែកទី៥
ការកំណត់ពន្ធ

មាត្រា២០៩ .- ការកំណត់ពន្ធ

ចំនួនប្រាក់ពន្ធត្រូវបានកំណត់ដូចខាងក្រោម៖

១-ក្នុងករណីដែលប្រាក់ពន្ធរបស់អ្នកជាប់ពន្ធត្រូវបានបង់តាមវិធីកាត់ទុក ហើយអ្នកជាប់ពន្ធគ្មានកាតព្វកិច្ចធ្វើប្រកាសសារពើពន្ធទេនោះ ការកំណត់ពន្ធរបស់អ្នកជាប់ពន្ធ គឺជាការកំណត់ចំនួនប្រាក់ពន្ធដែលបានកាត់ទុកនៅក្នុងឆ្នាំប្រតិទិន។

២-ក្នុងករណីដែលអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកមានកាតព្វកិច្ចត្រូវដាក់លិខិតប្រកាសសារពើពន្ធ ការកំណត់ពន្ធរបស់អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក គឺជាការកំណត់ពន្ធដែលអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកបានគណនានៅលើលិខិតប្រកាសសារពើពន្ធដែលដាក់ជូនរដ្ឋបាលសារពើពន្ធ។

៣-ក្នុងករណីដែលអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក មានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធ ប៉ុន្តែមិនបានដាក់លិខិតប្រកាស មិនបានរក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជិកាគណនេយ្យឬឯកសារផ្សេងទៀតតាមការតម្រូវ ឬមិនបានផ្តល់ព័ត៌មានចាំបាច់ជូនរដ្ឋបាលសារពើពន្ធដើម្បីកំណត់ពន្ធឱ្យបានត្រឹមត្រូវ ការកំណត់ពន្ធចំពោះអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក គឺជាការកំណត់ពន្ធដាឯកតោភាគីដែលរដ្ឋបាលសារពើពន្ធបានធ្វើ និងបានប្រគល់ឱ្យបុគ្គលនោះ។ ការកំណត់ពន្ធដាឯកតោភាគីត្រូវផ្អែកលើ៖

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២១៧

ក- ព័ត៌មានដែលមានចុះនៅក្នុងលិខិតប្រកាសសារពើពន្ធនានាឬឯកសារផ្សេងទៀត ដែលអ្នកជាប់ពន្ធបានដាក់ជូនរដ្ឋបាលសារពើពន្ធ។

ខ- ព័ត៌មានដែលមានចុះក្នុងលិខិតប្រកាសព័ត៌មាន។

គ- ព័ត៌មានផ្សេងទៀតដែលរដ្ឋបាលសារពើពន្ធបានទទួល។

៤- ប្រសិនបើមានមូលដ្ឋានបញ្ជាក់ថា ការប្រមូលពន្ធអាចមានឧបសគ្គ រដ្ឋបាលសារពើពន្ធអាចធ្វើការកំណត់ពន្ធលើអ្នកជាប់ពន្ធនៅពេលណាមួយក៏បាន។

មាត្រា២១០ .- ការកំណត់ពន្ធឡើងវិញនិងរយៈពេលកំណត់ពន្ធឡើងវិញ

ការកំណត់ពន្ធឡើងវិញនិងរយៈពេលកំណត់ពន្ធឡើងវិញត្រូវដំណើរការដូចខាងក្រោម៖

១- ចំពោះការកំណត់ពន្ធដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រា២០៩នៃច្បាប់នេះ រដ្ឋបាលសារពើពន្ធអាចធ្វើការកំណត់ពន្ធឡើងវិញក្នុងរយៈពេល៣(បី)ឆ្នាំ បន្ទាប់ពីឆ្នាំប្រតិទិនដែលការកាត់ទុកបានកើតឡើង។

២- ចំពោះការកំណត់ពន្ធដូចមានចែងក្នុងកថាខណ្ឌទី២និងកថាខណ្ឌទី៣នៃមាត្រា២០៩នៃច្បាប់នេះ រដ្ឋបាលសារពើពន្ធ អាចធ្វើការកំណត់ពន្ធឡើងវិញក្នុងរយៈពេលណាមួយដូចខាងក្រោម៖

ក- ក្នុងរយៈពេល៣(បី)ឆ្នាំ ក្រោយថ្ងៃដាក់លិខិតប្រកាសសារពើពន្ធ។

ខ- ក្នុងរយៈពេល១០(ដប់)ឆ្នាំ ក្រោយកាលបរិច្ឆេទដែលតម្រូវឱ្យដាក់លិខិតប្រកាសសារពើពន្ធ ប្រសិនបើមានកស្តុតាងបញ្ជាក់ថា មានអំពើរំលងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ។

គ- ក្នុងរយៈពេលណាមួយក៏បាន តាមការយល់ព្រមជាលាយលក្ខណ៍អក្សរបស់អ្នកជាប់ពន្ធ។

៣- អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកអាចស្នើសុំធ្វើការកែតម្រូវលិខិតប្រកាសសារពើពន្ធក្នុងរយៈពេល៣(បី)ឆ្នាំ ក្រោយកាលបរិច្ឆេទនៃការដាក់លិខិតប្រកាសសារពើពន្ធតាមកថាខណ្ឌទី២នៃមាត្រា២០៩នៃច្បាប់នេះ ដោយផ្អែកលើមូលដ្ឋាននៃការភាន់ច្រឡំឬការភ្លាំងភ្លាត់ដែលអ្នកជាប់ពន្ធបានធ្វើនៅក្នុងលិខិតប្រកាសពីមុន។ ប្រសិនបើលទ្ធផលប្រកាសសារពើពន្ធកែតម្រូវនោះបណ្តាលឱ្យមានការបង្វិលសងប្រាក់ពន្ធឬឥណទានពន្ធ រដ្ឋបាលសារពើពន្ធអាចធ្វើការពិនិត្យបញ្ជាក់តាមការធ្វើសវនកម្ម។

៤- អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកអាចស្នើសុំឱ្យរដ្ឋបាលសារពើពន្ធធ្វើការកែតម្រូវការកំណត់ពន្ធឡើងវិញក្នុងរយៈពេល៣(បី)ឆ្នាំ ក្រោយកាលបរិច្ឆេទដែលរដ្ឋបាលសារពើពន្ធកំណត់ពន្ធឡើងវិញ ដោយផ្អែកលើព័ត៌មានបន្ថែមដែលអ្នកជាប់ពន្ធឬរដ្ឋបាលសារពើពន្ធមិនបានទទួលក្នុងពេលកំណត់ពន្ធឡើងវិញនោះ។

៥- ក្នុងករណីដែលអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកធ្វើការកែតម្រូវការកំណត់ពន្ធរបស់ខ្លួន ឬស្នើសុំឱ្យរដ្ឋបាលសារពើពន្ធកែតម្រូវការកំណត់ពន្ធឡើងវិញ អាជ្ញាយុកាលនៃការកំណត់ពន្ធឡើងវិញក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២នៃមាត្រានេះ ត្រូវចាប់ផ្តើមគិតពីកាលបរិច្ឆេទនៃការដាក់លិខិតប្រកាសសារពើពន្ធកែតម្រូវឬកាលបរិច្ឆេទដែលរដ្ឋបាលសារពើពន្ធធ្វើការកែតម្រូវការកំណត់ពន្ធឡើងវិញ។



៦- វិធានការនិងនីតិវិធីនៃការកំណត់ពន្ធឡើងវិញនិងរយៈពេលកំណត់ពន្ធឡើងវិញត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា២១១ .- នីតិវិធីនៃការកំណត់ពន្ធឡើងវិញ

ការកំណត់ពន្ធឡើងវិញត្រូវបានដំណើរការតាមនីតិវិធីដូចខាងក្រោម៖

១- រដ្ឋបាលសារពើពន្ធត្រូវជូនលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញដល់អ្នកជាប់ពន្ធ។

២- អ្នកជាប់ពន្ធមានរយៈពេល៣០(សាមសិប)ថ្ងៃ ដើម្បីឆ្លើយតបចំពោះការកំណត់ពន្ធឡើងវិញទៅអង្គភាពដែលទទួលបន្ទុកធ្វើការកំណត់ពន្ធឡើងវិញនោះ។ ក្នុងរយៈពេលនេះ អ្នកជាប់ពន្ធអាចទទួលយក ឬជំទាស់ ចំពោះការកំណត់ពន្ធឡើងវិញ។ អ្នកជាប់ពន្ធត្រូវចាត់ទុកថាយល់ព្រមចំពោះការកំណត់ពន្ធឡើងវិញ ប្រសិនបើពុំបានឆ្លើយតប។

៣- ប្រសិនបើមានការជំទាស់ចំពោះការកំណត់ពន្ធឡើងវិញ អ្នកជាប់ពន្ធត្រូវដាក់ពាក្យតវ៉ាទៅអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ តាមនីតិវិធីដូចមានចែងក្នុងមាត្រា២៣៦នៃច្បាប់នេះ។

៤- អង្គភាពទទួលបន្ទុកការកំណត់ពន្ធឡើងវិញរបស់អគ្គនាយកដ្ឋានពន្ធដារ ត្រូវបញ្ជូនលទ្ធផលនៃការកំណត់ពន្ធឡើងវិញទៅអង្គភាពប្រមូលពន្ធក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ក្រោយការចេញលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញ។

មាត្រា២១២ .- បន្ទុកភស្តុតាង

១- ក្នុងករណីដែលអ្នកជាប់ពន្ធមិនបានរក្សាទុកឯកសារគ្រប់គ្រាន់ ឬក៏មិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់ រដ្ឋបាលសារពើពន្ធមានសិទ្ធិកំណត់ពន្ធលើអ្នកជាប់ពន្ធដោយផ្អែកលើមូលដ្ឋាននៃព័ត៌មានជាក់លាក់ដែលរដ្ឋបាលសារពើពន្ធមាន។

២- ក្នុងករណីដែលប្រាក់ចំណូលជាប់ពន្ធឬប្រាក់ចំណូលដែលបានប្រកាសដោយអ្នកជាប់ពន្ធមានភាពខុសគ្នាច្រើនធៀបទៅនឹងការទិញទ្រព្យសកម្មឬវត្ថុនានាដែលធ្វើឱ្យឃើញចំណាយរបស់អ្នកជាប់ពន្ធលេចធ្លោឡើងនោះ រដ្ឋបាលសារពើពន្ធមានសិទ្ធិកំណត់ពន្ធដោយផ្អែកលើមូលដ្ឋាននៃប្រាក់ចំណូលប៉ាន់ស្មានសមស្របទៅនឹងទំហំនៃចំណាយដើម្បីទិញទ្រព្យសកម្មឬវត្ថុនានាដែលលេចធ្លោនោះ។

៣- ការស្វែងរកភស្តុតាងនានាដើម្បីបញ្ជាក់ថា ប្រាក់ពន្ធដែលរដ្ឋបាលសារពើពន្ធបានកំណត់ដូចក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២នៃមាត្រានេះ មិនត្រឹមត្រូវ គឺជាបន្ទុករបស់អ្នកជាប់ពន្ធ។

ផ្នែកទី៦
ការប្រមូលពន្ធ

មាត្រា២១៣ .- ការបង់ពន្ធ

ការបង់ពន្ធត្រូវបានកំណត់ដូចខាងក្រោម៖

១- ប្រាក់ពន្ធត្រូវដល់កំណត់និងត្រូវបង់នៅក្នុងរយៈពេលដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានតម្រូវឱ្យធ្វើការដាក់លិខិតប្រកាសសារពើពន្ធ។



២- ប្រាក់ពន្ធត្រូវដល់កំណត់ និងត្រូវបង់ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ក្រោយពីការប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធ។

៣- ប្រាក់ពន្ធត្រូវដល់កំណត់និងត្រូវបង់ក្នុងរយៈពេល៣(បី)ថ្ងៃ ក្រោយពីការប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធដូចមានចែងក្នុងកថាខណ្ឌទី៤នៃមាត្រា២០៩នៃច្បាប់នេះ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២១៩

៤- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញប្រកាសនូវវិធាននិងនីតិវិធីដើម្បី៖

- កំណត់កាលបរិច្ឆេទទារបំណុលពន្ធដើម្បីចៀសវាងការខាតបង់ដោយទារបំណុលពន្ធមិនបាន
- ចាត់ទុកបំណុលពន្ធជាប្រាក់ពន្ធដែលមិនអាចប្រមូលបាន។

៥- អាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុលពន្ធមានរយៈពេល១០(ដប់)ឆ្នាំ ចាប់ពីថ្ងៃដែលបំណុលពន្ធត្រូវបានជូនដំណឹងទៅអ្នកជាប់ពន្ធ។ វិធាននិងនីតិវិធីនៃការផ្អាកឬការបង្អង់អាជ្ញាយុកាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា២១៤.- ការទទួលខុសត្រូវរបស់អភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករ

ប្រសិនបើអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិកររបស់សហគ្រាសណាមួយដឹងឮ ឬមានចេតនាធ្វើឱ្យសហគ្រាសមិនរាយការណ៍ ឬរាយការណ៍បន្លំនូវប្រាក់ពន្ធដោយរំលោភទៅលើបទប្បញ្ញត្តិស្តីពីពន្ធដារ ឬមិនឱ្យបង់ពន្ធកាត់ទុកជូនរដ្ឋបាលសារពើពន្ធ អភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករទាំងនោះត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះប្រាក់ពន្ធដែលត្រូវបង់។

មាត្រា២១៥.- ការផ្ទេរអាជីវកម្មឬការផ្ទេរភាគហ៊ុននិងការរួមបញ្ចូលគ្នានៃសហគ្រាស

១- ក្នុងករណីមានការផ្ទេរអាជីវកម្ម ឬការផ្ទេរភាគហ៊ុន ម្ចាស់កម្មសិទ្ធិថ្មីត្រូវទទួលខុសត្រូវចំពោះបំណុលពន្ធទាំងអស់របស់អាជីវកម្ម ឬសហគ្រាស។

២- ក្នុងករណីការរំលាយបញ្ចូលគ្នានៃសហគ្រាស២(ពីរ)ឬច្រើន សហគ្រាសដែលនៅបន្តឬកើតពីការរំលាយបញ្ចូលគ្នានៃសហគ្រាស២(ពីរ)ឬច្រើន ត្រូវទទួលខុសត្រូវចំពោះបំណុលពន្ធទាំងអស់។

ផ្នែកទី៧
សិទ្ធិអំណាចរបស់រដ្ឋបាលសារពើពន្ធក្នុងការប្រមូលប្រាក់ពន្ធ

មាត្រា២១៦.- លិខិតជូនដំណឹងទារបំណុលពន្ធនិងលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ

១- ដូចមានចែងក្នុងកថាខណ្ឌទី៨នៃមាត្រា២១១នៃច្បាប់នេះ រដ្ឋបាលសារពើពន្ធត្រូវផ្ញើលិខិតជូនដំណឹងទារបំណុលពន្ធដែលបញ្ជាក់អំពីចំនួនប្រាក់ពន្ធ ពន្ធបន្ថែម ការប្រាក់ និងការដាក់ពិន័យជាប្រាក់ទៅអ្នកជាប់ពន្ធ។ អ្នកជាប់ពន្ធមានរយៈពេល៣០(សាមសិប)ថ្ងៃ ដើម្បីធ្វើការទូទាត់បំណុលពន្ធដូចមានចែងក្នុងកថាខណ្ឌនេះ។

២- ក្នុងករណីអ្នកជាប់ពន្ធមិនបានទូទាត់បំណុលពន្ធដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ រដ្ឋបាលសារពើពន្ធត្រូវផ្ញើលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធទៅអ្នកជាប់ពន្ធ។

៣- រដ្ឋបាលសារពើពន្ធអាចអនុវត្តវិធានការតឹងទារដូចមានចែងក្នុងមាត្រា២១៧ មាត្រា២១៨ មាត្រា២១៩ មាត្រា២២០ មាត្រា២២១ និងមាត្រា២២២នៃច្បាប់នេះ យ៉ាងតិច១៥(ដប់ប្រាំ)ថ្ងៃ ក្រោយការប្រគល់លិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រានេះ។

មាត្រា២១៧ .- សិទ្ធិឃាត់ទុក ចាប់យក និងឃុំគ្រងលើទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ

សិទ្ធិឃាត់ទុក ចាប់យក និងឃុំគ្រងលើទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធត្រូវបានកំណត់ដូចខាងក្រោម៖

១- ប្រសិនបើបុគ្គលដែលមានកាតព្វកិច្ចបង់ពន្ធតាមការតម្រូវនៃបទប្បញ្ញត្តិស្តីពីពន្ធដារ ធ្វេសប្រហែស ឬបដិសេធមិនព្រមបង់ពន្ធក្រោយពេលដែលលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធត្រូវបានប្រគល់ត្រឹមត្រូវ រដ្ឋបាលសារពើពន្ធមានសិទ្ធិឃាត់ទុក ចាប់យក និងឃុំគ្រងលើទ្រព្យសម្បត្តិបុគ្គលនោះក្នុងកម្រិតតម្លៃសមស្របនឹងបំណុលពន្ធ។ រដ្ឋបាលសារពើពន្ធត្រូវធ្វើលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធទៅអ្នកជាប់ពន្ធយ៉ាងតិច ១៥(ដប់ប្រាំ)ថ្ងៃ មុនអនុវត្តវិធានការតឹងទារដូចមានចែងក្នុងមាត្រា២១៨ មាត្រា២២០ មាត្រា២២១ និងមាត្រា២២២ នៃច្បាប់នេះ។

២- សិទ្ធិឃាត់ទុក ចាប់យក និងឃុំគ្រងលើទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធកើតមានឡើងនៅថ្ងៃដែលលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធត្រូវបានប្រគល់ទៅឱ្យអ្នកជាប់ពន្ធដូចមានចែងក្នុងមាត្រា១៩៨ នៃច្បាប់នេះ។

៣- បើលក្ខខណ្ឌទាំងឡាយនៃមាត្រានេះត្រូវបានបំពេញត្រឹមត្រូវហើយនោះ សិទ្ធិឃាត់ទុក ចាប់យក និងឃុំគ្រងលើទ្រព្យសម្បត្តិដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះមានសុពលភាពនិងអាទិភាពលើសិទ្ធិដទៃទៀតទាំងអស់ដែលមានពីមុនមក ឬដែលកើតឡើងក្រោយសិទ្ធិឃាត់ទុក ចាប់យក និងឃុំគ្រងលើទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ លើកលែងតែមានការកំណត់ផ្ទុយពីនេះក្នុងច្បាប់ស្តីពីក្សយធននិងបទប្បញ្ញត្តិពាក់ព័ន្ធនឹងសិទ្ធិប្រាតិភោគ។ រដ្ឋបាលសារពើពន្ធ ត្រូវធ្វើសេចក្តីប្រកាសផ្សាយជាសាធារណៈអំពីទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធដែលត្រូវបានសម្រេចឃាត់ទុក ចាប់យក និងឃុំគ្រងដោយរដ្ឋបាលសារពើពន្ធ។ វាល់សិទ្ធិប្រាតិភោគដែលត្រូវបានបង្កើតឡើងលើទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ ដែលត្រូវបានសម្រេចឃាត់ទុក ចាប់យក និងឃុំគ្រងដោយរដ្ឋបាលសារពើពន្ធនៅក្រោយកាលបរិច្ឆេទនៃការប្រកាសផ្សាយជាសាធារណៈរបស់រដ្ឋបាលសារពើពន្ធ មិនអាចយកមកតតាំងជាមួយនឹងសិទ្ធិអាទិភាពរបស់រដ្ឋបាលសារពើពន្ធលើទ្រព្យសម្បត្តិនោះបានឡើយ។ បែបបទនិងនីតិវិធីនៃការប្រកាសផ្សាយជាសាធារណៈនូវទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធដែលត្រូវឃាត់ទុក ចាប់យក និងឃុំគ្រងដោយរដ្ឋបាលសារពើពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៤- សោហ៊ុយក្នុងការឃុំគ្រង ត្រួតពិនិត្យ និងថែរក្សាលើទ្រព្យសម្បត្តិនេះ គឺជាបន្ទុករបស់អ្នកជាប់ពន្ធ។

៥- បុគ្គលទាំងឡាយអាចធ្វើការតវ៉ាទៅរដ្ឋបាលសារពើពន្ធដើម្បីសុំឱ្យលើកសិទ្ធិឃាត់ទុក ចាប់យក និងឃុំគ្រងលើទ្រព្យសម្បត្តិរបស់ខ្លួនដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ដោយលើកឡើងនូវកំហុសឆ្គងក្នុងការដាក់សិទ្ធិនោះ។



ប្រសិនបើរដ្ឋបាលសារពើពន្ធបានពិនិត្យឃើញថា ការដាក់សិទ្ធិឃាត់ទុក ចាប់យក និងឃុំគ្រងលើទ្រព្យសម្បត្តិនោះមានការខុសឆ្គង រដ្ឋបាលសារពើពន្ធត្រូវចេញលិខិតបញ្ជាក់អំពីការលើកសិទ្ធិឃាត់ទុក ចាប់យក និងឃុំគ្រងលើទ្រព្យសម្បត្តិក្នុងរយៈពេល១០(ដប់)ថ្ងៃ បន្ទាប់ពីពិនិត្យឃើញ ព្រមទាំងចុះក្នុងលិខិតបញ្ជាក់នោះថា ការដាក់សិទ្ធិឃុំគ្រងនោះមានការខុសឆ្គង។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២២១

មាត្រា២១៨ .- សិទ្ធិប្រើប្រាស់និងអាស្រ័យផល សិទ្ធិចាត់ចែងជាបណ្តោះអាសន្ន និងការបែអូស

សិទ្ធិប្រើប្រាស់និងអាស្រ័យផល សិទ្ធិចាត់ចែងជាបណ្តោះអាសន្ន និងការបែអូសទ្រព្យសម្បត្តិអ្នកជាប់ពន្ធ ត្រូវបានកំណត់ដូចខាងក្រោម៖

១- ក្នុងករណីចាំបាច់ និងដើម្បីធានានូវការទូទាត់បំណុលពន្ធ រដ្ឋបាលសារពើពន្ធមានសិទ្ធិប្រើប្រាស់និងអាស្រ័យផលលើទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធដែលត្រូវបានឃាត់ទុក។

២- ក្រៅពីសិទ្ធិប្រើប្រាស់និងអាស្រ័យផលដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ រដ្ឋបាលសារពើពន្ធអាចប្តឹងទៅតុលាការដើម្បីបែអូសទ្រព្យសម្បត្តិអ្នកជាប់ពន្ធក្នុងគោលដៅធានាការទូទាត់បំណុលពន្ធ។ ក្នុងអំឡុងពេលដែលមិនទាន់មានសេចក្តីសម្រេចបែអូសទ្រព្យសម្បត្តិអ្នកជាប់ពន្ធជាស្ថាពរ និងក្នុងករណីដែលទទួលបានការអនុញ្ញាតតាមដីកាសម្រេចពីតុលាការដែលទទួលពាក្យបណ្តឹង រដ្ឋបាលសារពើពន្ធអាចធ្វើការចាត់ចែងជាបណ្តោះអាសន្ននូវទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធក្នុងទម្រង់ជាការលក់ឡាយឡុង ហើយប្រាក់ដែលបានមកពីការចាត់ចែងជាបណ្តោះអាសន្នត្រូវរក្សាទុកនៅក្នុងគណនីបណ្តោះអាសន្នមួយរបស់រដ្ឋបាលសារពើពន្ធ។

៣- បុគ្គលដែលមានភារៈកាន់កាប់និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធដែលត្រូវរដ្ឋបាលសារពើពន្ធបែអូសដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រានេះ មិនអាចបង្វិលទ្រព្យសម្បត្តិនោះទៅឱ្យអ្នកជាប់ពន្ធវិញ ឬក៏យកទ្រព្យសម្បត្តិនោះទៅធ្វើការទូទាត់ផ្សេងៗបានទេ លើកលែងតែការទូទាត់ដែលរដ្ឋបាលសារពើពន្ធបានអនុញ្ញាត។

៤- ចំពោះទ្រព្យសម្បត្តិជាសាច់ប្រាក់ រដ្ឋបាលសារពើពន្ធអាចបែអូសសាច់ប្រាក់របស់អ្នកជាប់ពន្ធ ឬសាច់ប្រាក់ដែលអ្នកជាប់ពន្ធនឹងត្រូវទទួលបាន ដោយមិនចាំបាច់អនុវត្តតាមនីតិវិធីដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រានេះ។

មាត្រា២១៩ .- ការចាត់ចែងលើទ្រព្យសម្បត្តិដែលបានបែអូស

ក្នុងករណីដែលមានការលក់នូវទ្រព្យសម្បត្តិបន្ទាប់ពីមានការបែអូសទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ ចំនួនទឹកប្រាក់លក់បានដែលលើសអំពីបំណុលពន្ធរបស់អ្នកជាប់ពន្ធនៅក្រោមច្បាប់នេះ ត្រូវបង្វិលទៅឱ្យអ្នកជាប់ពន្ធវិញ លើកលែងតែមានការចាត់ចែងផ្សេងពីនេះដោយតុលាការស្របតាមច្បាប់ជាធរមាន។

មាត្រា២២០ .- ការឃាត់ទុកគណនីធនាគារ

១- រដ្ឋបាលសារពើពន្ធអាចឃាត់ទុកគណនីរបស់អ្នកជាប់ពន្ធនៅធនាគារតាមលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ ហើយដែលមានប្រសិទ្ធភាពអនុវត្តភ្លាមក្រោយពីការប្រគល់លិខិតនោះទៅឱ្យធនាគារ។ ការឃាត់ទុកគណនីធនាគារក្នុងមាត្រានេះ រួមបញ្ចូលទាំងការឃាត់ទុកប្រតិបត្តិការតាមគ្រប់ទម្រង់។

២- តាមរយៈការជូនដំណឹងឱ្យឃាត់ទុកគណនីធនាគារនេះ ធនាគារមិនអាចបើកគណនីថ្មីទៀតឱ្យអ្នកជាប់ពន្ធដដែលបានទេ ហើយក៏មិនអាចធ្វើការទូទាត់ផ្សេងៗចេញពីគណនីនោះបានឡើយ លើកលែងតែការបង់ប្រាក់ដែលរដ្ឋបាលសារពើពន្ធកំណត់ឱ្យដើម្បីទូទាត់ប្រាក់ពន្ធត្រូវបង់ ពន្ធបន្ថែម ការប្រាក់ និងការដាក់ពិន័យផ្សេងទៀត។



៣- គណនីធនាគារដែលបានឃាត់ទុកអាចបើកឱ្យប្រើវិញបាន លុះត្រាតែមានលិខិតជូនដំណឹងពីរដ្ឋបាលសារពើពន្ធ។

៨_ ធនាគារដែលមិនបានអនុវត្តតាមលិខិតជូនដំណឹងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវទទួលខុសត្រូវចំពោះរដ្ឋបាលសារពើពន្ធនូវកម្រិតទឹកប្រាក់ដែលមាននៅក្នុងគណនីរបស់អ្នកជាប់ពន្ធនៅពេលដែលលិខិតជូនដំណឹងត្រូវបានប្រគល់ឱ្យ។

មាត្រា២២១ . _ ការបញ្ឈប់ប្រតិបត្តិការនាំចេញនាំចូល

១_ រដ្ឋបាលសារពើពន្ធអាចបញ្ឈប់ប្រតិបត្តិការនាំចេញនាំចូល។ ការបញ្ឈប់ប្រតិបត្តិការនាំចេញនាំចូល សំដៅដល់ ការឃាត់ទុកដោយរដ្ឋបាលគយនូវទំនិញនាំចូលរបស់អ្នកជាប់ពន្ធ និងទំនិញដែលត្រូវនាំចេញដោយអ្នកជាប់ពន្ធតាមលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ ដែលមានប្រសិទ្ធភាពអនុវត្តភ្លាមក្រោយពេលដែលលិខិតនោះបានប្រគល់ឱ្យរដ្ឋបាលគយ។

២_ រដ្ឋបាលសារពើពន្ធអាចរឹបអូស ប្រើប្រាស់និងអាស្រ័យផល និងចាត់ចែងជាបណ្តោះអាសន្ននូវទំនិញរបស់អ្នកជាប់ពន្ធដែលបានឃាត់ទុកដោយរដ្ឋបាលគយ ទៅតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា២១៨ នៃច្បាប់នេះ។

៣_ ការអនុញ្ញាតឱ្យប្រតិបត្តិការនាំចេញនាំចូលរួចពីការបញ្ឈប់ ត្រូវអនុវត្តតាមលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ។

៤_ ទំនិញឃាត់ទុកដោយរដ្ឋបាលគយដែលមិនមែនជារបស់អ្នកជាប់ពន្ធ ត្រូវបានរួចផុតពីការឃាត់ទុកដោយមានការយល់ព្រមពីរដ្ឋបាលសារពើពន្ធ។

មាត្រា២២២ . _ ការទុកជាមោឃៈនូវលិខិតអនុញ្ញាត និងអាជ្ញាបណ្ណ

រដ្ឋបាលសារពើពន្ធអាចចេញលិខិតជូនដំណឹងទៅកាន់អាជ្ញាធរមានសមត្ថកិច្ចស្នើសុំឱ្យទុកជាមោឃៈនូវលិខិតអនុញ្ញាតនិងអាជ្ញាបណ្ណផ្សេងៗរបស់អ្នកជាប់ពន្ធ ដើម្បីអនុវត្តសកម្មភាពណាមួយ។

ជំពូកទី១៨
ទោសប្បញ្ញត្តិ
ផ្នែកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា២២៣ . _ ការធ្វេសប្រហែស

អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ត្រូវបានចាត់ទុកថាមានការធ្វេសប្រហែស ប្រសិនបើប្រាក់ពន្ធបានបង់មានចំនួនតិចជាងប្រាក់ពន្ធដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារមិនលើសពី១០(ដប់)ភាគរយ អ្នកមិនបានបង់ពន្ធតាមកាលបរិច្ឆេទដែលច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតបានកំណត់។

មាត្រា២២៤ . _ ការធ្វេសប្រហែសធ្ងន់ធ្ងរ

អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ត្រូវបានចាត់ទុកថាមានការធ្វេសប្រហែសធ្ងន់ធ្ងរ ប្រសិនបើប្រាក់ពន្ធបានបង់មានចំនួនតិចជាងប្រាក់ពន្ធដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារលើសពី១០(ដប់)ភាគរយ។

មាត្រា២២៥ .. អំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ

ត្រូវបានចាត់ទុកជាអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ចំពោះអំពើដែលប្រព្រឹត្តផ្ទុយពីការកំណត់របស់ច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតដូចខាងក្រោម៖

១- ការមិនបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ស្របតាមការកំណត់របស់ច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។

២- ការមិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្តូរព័ត៌មាននៃការចុះបញ្ជី។

៣- ការមិនបានដាក់លិខិតប្រកាសសារពើពន្ធ។

៤- ការមិនបានប្រើប្រាស់ប្រព័ន្ធកត់ត្រាដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ។

៥- ការមិនបានចេញវិក្កយបត្រ។

៦- ការមិនផ្តល់ព័ត៌មានឬមិនបញ្ជូនរបាយការណ៍តាមការស្នើសុំ។

៧- ការមិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធធ្វើការពិនិត្យបញ្ជីគណនេយ្យឬឯកសារផ្សេងៗ។

៨- ការមិនបានរក្សាបញ្ជីគណនេយ្យនិងឯកសារផ្សេងទៀត។

៩- ការព្យាយាមរាំងការកំណត់និងការប្រមូលពន្ធ។

១០- ការកសាងឬផ្តល់នូវកំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានក្លែងបន្លំ។

១១- ការលាក់ទុកឬបំផ្លាញចោលដោយចេតនានូវបញ្ជីគណនេយ្យ កំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានផ្សេងៗ។

១២- ការចេញវិក្កយបត្រក្លែងបន្លំ។

១៣- ការមិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធចូលគ្រឹះស្ថានអាជីវកម្មដើម្បីកំណត់និងប្រមូលពន្ធ។

មាត្រា២២៦ .. ការគេចវេះពន្ធ

១-ការគេចវេះពន្ធ គឺជាអំពើណាមួយដែលបានប្រព្រឹត្តឡើងដោយចេតនានិងមានការរៀបចំទុកជាមុនដែលនាំឱ្យបាត់ប្រាក់ពន្ធដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវឱ្យបង់។

២- ត្រូវបានចាត់ទុកថាជាការគេចវេះពន្ធផងដែរចំពោះករណីណាមួយដូចខាងក្រោម៖

ក- ការធ្វេសប្រហែសធ្ងន់ធ្ងរដូចមានចែងក្នុងមាត្រា២២៤នៃច្បាប់នេះ ដែលត្រូវបានប្រព្រឹត្តឡើងពីរលើកដាច់ពីគ្នាក្នុងរយៈពេល៣(បី)ឆ្នាំនៃឆ្នាំប្រតិទិន។

ខ- ការធ្វេសប្រហែសធ្ងន់ធ្ងរដូចមានចែងក្នុងមាត្រា២២៤នៃច្បាប់នេះ ដែលត្រូវបានប្រព្រឹត្តឡើងបីលើកឬច្រើនជាងនេះដាច់ពីគ្នាក្នុងរយៈពេល១០(ដប់)ឆ្នាំនៃឆ្នាំប្រតិទិន។

មាត្រា២២៧ .. មូលហេតុនៃការរំលត់បណ្តឹងអាជ្ញា

១- ការសម្របសម្រួលជាមួយរដ្ឋបាលសារពើពន្ធ តាមរយៈការបង់ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់នាំឱ្យមូលបណ្តឹងអាជ្ញារលត់ចំពោះបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។ ក្នុងករណីដែលរដ្ឋបាលសារពើពន្ធរួចស្រេចព្រមធ្វើការសម្របសម្រួល រដ្ឋបាលសារពើពន្ធត្រូវធ្វើកំណត់ហេតុអំពីការសម្របសម្រួលនេះ រួចបញ្ជូនទៅស្ថាប័នអយ្យការ ឬស្ថាប័នតុលាការដែលមានសមត្ថកិច្ច។

២- បទប្បញ្ញត្តិនៃកថាខណ្ឌទី១នៃមាត្រានេះ មិនត្រូវយកមកអនុវត្តឡើយចំពោះបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

ផ្នែកទី២
សិទ្ធិអំណាចរបស់រដ្ឋបាលសាធារណៈ

មាត្រា២២៨ .- សមត្ថកិច្ចក្នុងការកសាងសំណុំរឿងព្រហ្មទណ្ឌ

១- រដ្ឋបាលសាធារណៈជាស្ថាប័នតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការស៊ើបអង្កេតនិងការកសាងសំណុំរឿងពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដោយអនុវត្តស្របតាមច្បាប់នេះ និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

២- រដ្ឋបាលសាធារណៈ ក៏អាចមានសមត្ថកិច្ចផងដែរក្នុងការស៊ើបអង្កេត និងកសាងសំណុំរឿងទាក់ទិននឹងបទល្មើសព្រហ្មទណ្ឌផ្សេងទៀតដែលមានការពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ប្រសិនបើមានការអនុញ្ញាតពីព្រះរាជអាជ្ញា។

មាត្រា២២៩ .- នីតិសម្បទាជានគរបាលយុត្តិធម៌របស់មន្ត្រីពន្ធដារ

១- មន្ត្រីពន្ធដារទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

២- បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីពន្ធដារ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៣- រាល់ប្រតិបត្តិការរបស់មន្ត្រីពន្ធដារ ដែលពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ រដ្ឋបាលសាធារណៈមានសិទ្ធិស្នើសុំកិច្চសហការពីស្ថាប័នមានសមត្ថកិច្চដើម្បីចូលរួមបង្ក្រាបបទល្មើសលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

មាត្រា២៣០ .- អំណាចក្នុងការស៊ើបអង្កេត

មន្ត្រីពន្ធដារមានអំណាចក្នុងការស៊ើបអង្កេតដូចខាងក្រោម៖

១- មន្ត្រីពន្ធដារមានអំណាចចូលទៅក្នុងគ្រឹះស្ថានអាជីវកម្មឬទីកន្លែងដែលត្រូវបានចាត់ទុកថាជាគ្រឹះស្ថានអាជីវកម្មដើម្បីពិនិត្យបញ្ជីគណនេយ្យ លិខិតប្រកាសសារពើពន្ធគ្រប់ប្រភេទ និងឯកសារពាក់ព័ន្ធផ្សេងៗទៀតដើម្បីកំណត់ពន្ធ។ ការចូលទៅក្នុងគ្រឹះស្ថានអាជីវកម្មដូចមានចែងក្នុងកថាខណ្ឌនេះ ត្រូវធ្វើឡើងនៅក្នុងម៉ោងអាជីវកម្ម ឬនៅគ្រប់ពេលវេលាដោយអនុវត្តតាមដីការបស់ស្ថាប័នអយ្យការឬស្ថាប័នតុលាការដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

២- មន្ត្រីពន្ធដារដែលបានចូលដោយស្របច្បាប់ទៅក្នុងគ្រឹះស្ថានអាជីវកម្មឬទីកន្លែងដែលត្រូវបានចាត់ទុកថាជាគ្រឹះស្ថានអាជីវកម្មដូចដែលមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះមានសិទ្ធិ៖

ក- ធ្វើសម្រង់ ឬចម្លងឯកសារនានា រួមទាំងឯកសារអេឡិចត្រូនិកដែលស្ថិតនៅក្នុងកន្លែងនោះ។

ខ- ចាប់យកឯកសារនានា ឬវត្ថុតាងដទៃទៀតដែលអាចក្លាយជាព័ត៌មានឬកស្តុតាងសម្រាប់កំណត់ប្រាក់ពន្ធត្រូវបង់របស់បុគ្គលណាម្នាក់ ដោយត្រូវធ្វើកំណត់ហេតុស្តីពីការចាប់យក។

គ- ដាក់ឧបករណ៍សម្រាប់ត្រួតពិនិត្យផ្សេងៗ ឬបោះត្រាបិទសម្គាល់ ឃាត់ទុកទំនិញ ប្រសិនបើមានជាប់ទាក់ទិនដល់ការអនុវត្តពន្ធណាមួយ។

ឃ- ធ្វើសារពើភណ្ឌទ្រព្យសកម្ម វត្ថុធាតុដើម ផលិតផលកំពុងផលិត ផលិតផលសម្រេច និងស្តុក/សន្និធិដទៃទៀត។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២២៥

ង_ ចាប់យក ឃាត់ទុក ឬឃុំគ្រងទ្រព្យសម្បត្តិអ្នកជាប់ពន្ធដើម្បីធានាបំណុលពន្ធ។

ច_ ឃាត់ខ្លួនអ្នកជាប់ពន្ធដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដោយអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

៣_ ក្នុងគ្រប់ករណីទាំងអស់ នៅពេលមានបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារត្រូវបានរកឃើញនៅក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតរបស់មន្ត្រីពន្ធដារ ប្រតិបត្តិការរបស់មន្ត្រីពន្ធដារទាក់ទិននឹងការប្រមូលកស្តុតាង ការធ្វើកំណត់ហេតុ និងការអនុវត្តរាល់កិច្ចនីតិវិធីព្រហ្មទណ្ឌចាំបាច់ដទៃទៀត ដោយរួមទាំងការឃាត់ខ្លួនជនសង្ស័យផង ត្រូវធ្វើឡើងដោយមន្ត្រីពន្ធដារដែលមាននីតិសម្បទាជាមន្ត្រីឬក្នាក់ងារនគរបាលយុត្តិធម៌ ហើយត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

៤_ រដ្ឋបាលសារពើពន្ធ អាចតម្រូវឱ្យស្ថាប័នធនាគារដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ផ្តល់ព័ត៌មានអំពីគណនីរបស់អ្នកជាប់ពន្ធឬបុគ្គលពាក់ព័ន្ធនៅធនាគារ ឬឃាត់ទុកគណនីរបស់អ្នកជាប់ពន្ធឬបុគ្គលពាក់ព័ន្ធនោះក្នុងករណីមានកស្តុតាងបញ្ជាក់ថាបានប្រព្រឹត្តអំពើគេចវេះពន្ធ។

៥_ ក្នុងអំឡុងពេលចូលទៅធ្វើការស៊ើបអង្កេត មន្ត្រីពន្ធដារត្រូវមានអាកប្បកិរិយាសមរម្យ ចៀសវាងប្រការដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយសនិងអាជីវកម្មរបស់អ្នកជាប់ពន្ធ។

ផ្នែកទី៣

ទណ្ឌកម្មរដ្ឋបាល

មាត្រា២៣១ _ ប្រភេទទណ្ឌកម្មរដ្ឋបាល

១_ ទណ្ឌកម្មរដ្ឋបាលដែលកំណត់ក្នុងច្បាប់នេះ រួមមានពន្ធបន្ថែម ការប្រាក់ ការផាកពិន័យជាប្រាក់ ការព្យួរឬការដកហូតអាជ្ញាបណ្ណ ការបិទអាជីវកម្មជាបណ្តោះអាសន្ន និងទណ្ឌកម្មរដ្ឋបាលផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

២_ ការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល ជាសមត្ថកិច្ចរបស់រដ្ឋបាលសារពើពន្ធ។ អង្គភាពមានសមត្ថកិច្ចរបស់រដ្ឋបាលសារពើពន្ធ អាចទទួលបានសិទ្ធិក្នុងការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល តាមការកំណត់របស់លិខិតបទដ្ឋានគតិយុត្តជាធរមាន។ ការតវ៉ាចំពោះការសម្រេចរបស់អង្គភាពមានសមត្ថកិច្ចរបស់រដ្ឋបាលសារពើពន្ធ ត្រូវអនុវត្តស្របតាមមាត្រា២៣៦នៃច្បាប់នេះ។

មាត្រា២៣២ _ ការអនុវត្តពន្ធបន្ថែម

១_ ពន្ធបន្ថែមត្រូវអនុវត្តចំពោះអំពើល្មើសបទប្បញ្ញត្តិស្តីពីពន្ធដារ។

២_ ពន្ធបន្ថែមសម្រាប់ការបង់ពន្ធខ្វះឬការបង់យឺត ត្រូវគណនាដាច់ដោយឡែកពីការផាកពិន័យជាប្រាក់ចំពោះការប្រព្រឹត្តអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ។

៣_ ក្នុងករណីមានការបង់ពន្ធខ្វះ ពន្ធបន្ថែមនិងការប្រាក់ ត្រូវដល់កំណត់និងត្រូវបង់តាមបែបបទដូចគ្នាទៅនឹងការអនុវត្តចំពោះប្រាក់ពន្ធដែលបានបង់ខ្វះនោះ។

៤_ ទោះបីក្នុងករណីណាក៏ដោយ ការដាក់ឱ្យអនុវត្តពន្ធបន្ថែមមិនមានផលប៉ះពាល់ដល់ការអនុវត្តទណ្ឌកម្មព្រហ្មទណ្ឌចំពោះអំពើល្មើសនឹងបទប្បញ្ញត្តិស្តីពីពន្ធដារឡើយ។

មាត្រា២៣៣ .- ពន្ធបន្ថែមនិងការប្រាក់

ពន្ធបន្ថែមនិងការប្រាក់ត្រូវបានកំណត់ដូចខាងក្រោម៖

១- ចំពោះបុគ្គលដែលប្រព្រឹត្តអំពើធ្វេសប្រហែសដូចមានចែងក្នុងមាត្រា២២៣នៃច្បាប់នេះ ប្រាក់ពន្ធបន្ថែមត្រូវស្មើនឹង១០(ដប់)ភាគរយនៃចំនួនប្រាក់ពន្ធដែលបង់ខ្វះឬបង់យឺត បូកបន្ថែមការប្រាក់ ១,៥(មួយក្បៀសប្រាំ)ភាគរយ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធខ្វះមិនទាន់បានបង់។

២- ចំពោះបុគ្គលដែលប្រព្រឹត្តអំពើធ្វេសប្រហែសធ្ងន់ធ្ងរដូចមានចែងក្នុងមាត្រា២២៤នៃច្បាប់នេះ ប្រាក់ពន្ធបន្ថែមត្រូវស្មើនឹង២៥(ម្ភៃប្រាំ)ភាគរយនៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ ១,៥(មួយក្បៀសប្រាំ)ភាគរយនៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធខ្វះមិនទាន់បានបង់។

៣- ក្នុងករណីការកំណត់ពន្ធជាឯកតោភាគី ប្រាក់ពន្ធបន្ថែមត្រូវស្មើនឹង៤០(សែសិប)ភាគរយនៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់១,៥(មួយក្បៀសប្រាំ)ភាគរយនៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធខ្វះមិនទាន់បានបង់។

៤- ក្នុងករណីការកំណត់ពន្ធជាឯកតោភាគីចំពោះការមិនដាក់លិខិតប្រកាស ប្រាក់ពន្ធបន្ថែម ត្រូវស្មើនឹង៤០(សែសិប)ភាគរយនៃចំនួនប្រាក់ពន្ធដែលបានកំណត់ បូកបន្ថែមការប្រាក់១,៥(មួយក្បៀសប្រាំ)ភាគរយនៃចំនួនប្រាក់ពន្ធដែលបានកំណត់សម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធមិនទាន់បានបង់។

៥- ប្រសិនបើបុគ្គលមិនបានបង់ពន្ធក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ក្រោយពេលបានទទួលលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ ពន្ធបន្ថែមត្រូវកំណត់តាមអត្រា២៥(ម្ភៃប្រាំ)ភាគរយនៃទឹកប្រាក់ពន្ធបង់យឺត បូកនឹងការប្រាក់១,៥(មួយក្បៀសប្រាំ)ភាគរយនៃទឹកប្រាក់ពន្ធបង់យឺតសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធនោះនៅមិនទាន់បានបង់។

៦- ពន្ធបន្ថែមចំពោះការយឺតយ៉ាវក្នុងការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងពន្ធប្រថាប់ត្រា ត្រូវស្មើនឹង១០០(មួយរយ)ភាគរយនៃប្រាក់ពន្ធត្រូវបង់។

៧- ការប្រាក់ដូចមានចែងក្នុងមាត្រានេះ ត្រូវគិតចាប់ពីថ្ងៃទី១នៃខែបន្ទាប់ពីខែដែលត្រូវបង់ពន្ធ។ ចំពោះពន្ធលើប្រាក់ចំណូល ការប្រាក់ត្រូវគិតចាប់ពីថ្ងៃទី១នៃខែបន្ទាប់ដែលជាខែផុតរយៈពេលកំណត់សម្រាប់ការដាក់លិខិតប្រកាសលទ្ធផលប្រចាំឆ្នាំ។ ការប្រាក់មិនត្រូវអនុវត្តទេ ក្នុងរយៈពេលកំណត់ពន្ធឡើងវិញតាមមាត្រា២១១នៃច្បាប់នេះ ឬក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ក្រោយការប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធតាមមាត្រា២១៣នៃច្បាប់នេះ។

មាត្រា២៣៤ .- ការព្រមានជាលាយលក្ខណ៍អក្សរ

ត្រូវព្រមានជាលាយលក្ខណ៍អក្សរដោយរដ្ឋបាលសារពើពន្ធចំពោះបុគ្គលដែលប្រព្រឹត្តអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃមាត្រា២៤នៃច្បាប់នេះ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២២៧

មាត្រា២៣៥ .- ការផាកពិន័យជាប្រាក់ចំពោះអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ

ការផាកពិន័យជាប្រាក់ចំពោះអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារត្រូវបានកំណត់ដូចខាងក្រោម៖

១- ត្រូវផាកពិន័យជាប្រាក់ចំនួន៥ ០០០ ០០០(ប្រាំលាន)រៀល ដោយរដ្ឋបាលសារពើពន្ធ ដោយពុំទាន់គិតដល់ទណ្ឌកម្មរដ្ឋបាលផ្សេងទៀត ចំពោះបុគ្គលដែលធ្លាប់ត្រូវបានទទួលការព្រមានជាលាយលក្ខណ៍អក្សរពីរដ្ឋបាលសារពើពន្ធលើសពី២(ពីរ)លើកហើយនៅតែប្រព្រឹត្តនូវអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារណាមួយ ដូចមានចែងក្នុងកថាខណ្ឌទី១ កថាខណ្ឌទី២ និងកថាខណ្ឌទី៣នៃមាត្រា២២៥នៃច្បាប់នេះ។

២- ត្រូវផាកពិន័យជាប្រាក់ចំនួន១០ ០០០ ០០០(ដប់លាន)រៀល ដោយរដ្ឋបាលសារពើពន្ធ ដោយពុំទាន់គិតដល់ទណ្ឌកម្មរដ្ឋបាលផ្សេងទៀត ចំពោះបុគ្គលដែលបានប្រព្រឹត្តអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារណាមួយ ដូចមានចែងក្នុងកថាខណ្ឌទី៤ កថាខណ្ឌទី៥ កថាខណ្ឌទី៦ កថាខណ្ឌទី៧ និងកថាខណ្ឌទី៨នៃមាត្រា២២៥នៃច្បាប់នេះ។

៣- ក្នុងករណីដែលបុគ្គលដែលត្រូវបានសម្រេចឱ្យបង់ប្រាក់ផាកពិន័យដូចមានចែងក្នុងកថាខណ្ឌទី១ ឬកថាខណ្ឌទី២នៃមាត្រានេះរួចហើយ ហើយបុគ្គលនោះបានប្រព្រឹត្តនូវអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារណាមួយ ដូចមានចែងក្នុងកថាខណ្ឌទី១ កថាខណ្ឌទី២ កថាខណ្ឌទី៣ កថាខណ្ឌទី៤ កថាខណ្ឌទី៥ កថាខណ្ឌទី៦ កថាខណ្ឌទី៧ និងកថាខណ្ឌទី៨នៃមាត្រា២២៥នៃច្បាប់នេះម្តងទៀត បុគ្គលនោះត្រូវមានទោសព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា២៨៣នៃច្បាប់នេះ។

ផ្នែកទី៤
ដំណោះស្រាយការតវ៉ារបស់អ្នកជាប់ពន្ធ

មាត្រា២៣៦ .- វិធាននៃបណ្តឹងតវ៉ាខាងរដ្ឋបាល

វិធាននៃដំណោះស្រាយបណ្តឹងតវ៉ារបស់អ្នកជាប់ពន្ធអំពីបញ្ហាសារពើពន្ធ ត្រូវបានកំណត់ដូចខាងក្រោម៖

១- អ្នកជាប់ពន្ធដែលមិនយល់ព្រមនឹងការកំណត់ពន្ធឡើងវិញ ការផាកពិន័យជាប្រាក់ ឬសេចក្តីសម្រេចផ្សេងទៀតដែលធ្វើឡើងដោយអង្គភាពមានសមត្ថកិច្ចរបស់រដ្ឋបាលសារពើពន្ធ អាចធ្វើការតវ៉ាទៅអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ។ ការតវ៉ាត្រូវមានកម្រិតត្រង់ដែនតែត្រឹមដើមហេតុឬព័ត៌មានផ្សេងទៀតដែលមាននៅក្នុងការកំណត់ពន្ធឡើងវិញ សេចក្តីសម្រេចឬនីតិវិធីនៃការកំណត់ពន្ធឡើងវិញប៉ុណ្ណោះ។

២- ការតវ៉ាខាងរដ្ឋបាល ត្រូវធ្វើជាលាយលក្ខណ៍អក្សរទៅតាមទម្រង់ដូចមានចែងក្នុងមាត្រា២៣៧ នៃច្បាប់នេះ និងត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធក្នុងរយៈពេលយ៉ាងយឺតបំផុត៣០(សាមសិប)ថ្ងៃ ក្រោយថ្ងៃដែលអ្នកជាប់ពន្ធបានទទួលលិខិតជូនដំណឹងទារបំណុលពន្ធ ការផាកពិន័យជាប្រាក់ ឬសេចក្តីសម្រេចផ្សេងទៀតដែលធ្វើឡើងដោយអង្គភាពមានសមត្ថកិច្ចរបស់រដ្ឋបាលសារពើពន្ធ។

៣- ការតវ៉ាខាងរដ្ឋបាលពុំធ្វើឱ្យអ្នកជាប់ពន្ធរួចផុតពីកាតព្វកិច្ចបង់ប្រាក់ពន្ធ ពន្ធបន្ថែម ការប្រាក់ និងការផាកពិន័យជាប្រាក់ផ្សេងៗដែលបញ្ជាក់នៅក្នុងលិខិតជូនដំណឹងទារបំណុលពន្ធ ការផាកពិន័យជាប្រាក់ ឬសេចក្តីសម្រេចផ្សេងទៀត ដែលធ្វើឡើងដោយអង្គភាពមានសមត្ថកិច្ចរបស់រដ្ឋបាលសារពើពន្ធឡើយ។

ទំព័រ២២៨អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

មាត្រា២៣៧ .- ខ្លឹមសារបណ្តឹងតវ៉ាខាងរដ្ឋបាលរបស់អ្នកជាប់ពន្ធ

១- ការតវ៉ាខាងរដ្ឋបាលអាចនឹងទទួលយកបាន ប្រសិនបើក្នុងពាក្យតវ៉ានោះមានខ្លឹមសារដូចខាងក្រោម៖

ក- លេខអត្តសញ្ញាណកម្មរបស់អ្នកជាប់ពន្ធដែលធ្វើពាក្យតវ៉ា។

ខ- សេចក្តីយោងទៅរកការកំណត់សេចក្តីសម្រេចឬលទ្ធផលដែលជាកម្មវត្ថុនៃពាក្យតវ៉ា។

គ- ដើមហេតុឬអំពើដែលជាកម្មវត្ថុនៃពាក្យតវ៉ា។

ឃ- ហេតុផលនៃការតវ៉ា។

ង- កាលបរិច្ឆេទនិងហត្ថលេខារបស់អ្នកជាប់ពន្ធ និងហត្ថលេខារបស់តំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ។

២- វិធាននិងនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា២៣៨ .- សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធ

១- រដ្ឋបាលសារពើពន្ធត្រូវចេញសេចក្តីសម្រេចជាថ្មីក្នុងរយៈពេលយ៉ាងយឺតបំផុត៦០(ហុកសិប)ថ្ងៃក្រោយពីថ្ងៃបានទទួលពាក្យតវ៉ាដើម្បីបញ្ជាក់ភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវទាំងស្រុង ឬចំណែកណាមួយនៃការកំណត់ពន្ធ ឬសេចក្តីសម្រេចផ្សេងៗដែលអ្នកជាប់ពន្ធតវ៉ា។ រដ្ឋបាលសារពើពន្ធត្រូវបញ្ជាក់ផងដែរនូវមូលដ្ឋាននៃការសម្រេចនេះ។

២- ប្រសិនបើអ្នកជាប់ពន្ធមិនយល់ព្រមលើសេចក្តីសម្រេចថ្មីនេះរបស់រដ្ឋបាលសារពើពន្ធ អ្នកជាប់ពន្ធអាចដាក់ពាក្យតវ៉ាទៅគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធក្នុងរយៈពេលយ៉ាងយឺតបំផុត៣០(សាមសិប)ថ្ងៃ ក្រោយពីថ្ងៃដែលបានទទួលសេចក្តីសម្រេច។

មាត្រា២៣៩ .- គណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ

១- ត្រូវបានបង្កើតគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ មានភារកិច្ចដើម្បីពិនិត្យដោះស្រាយលើបណ្តឹងតវ៉ារបស់អ្នកជាប់ពន្ធដែលមិនពេញចិត្តចំពោះសេចក្តីសម្រេចឬវិធានការចុងក្រោយរបស់អគ្គនាយកដ្ឋានពន្ធដារពាក់ព័ន្ធនឹងវិវាទពន្ធដារ។

២- ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា២៤០ .- បណ្តឹងទៅតុលាការ

១- អ្នកជាប់ពន្ធមានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ចជំទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធក្នុងរយៈពេលយ៉ាងយឺតបំផុត៣០(សាមសិប)ថ្ងៃ ក្រោយពីបានទទួលដំណឹងស្តីពីសេចក្តីសម្រេចនោះ។



២- អ្នកជាប់ពន្ធត្រូវតម្កល់ទុកនៅគេនាគារជាតិនូវប្រាក់ឬទ្រព្យដែលមានតម្លៃសមមូលយ៉ាងតិចស្មើនឹងចំនួនទឹកប្រាក់ពន្ធដែលទាក់ទិននឹងវិវាទ មុននឹងដាក់ពាក្យបណ្តឹងទៅតុលាការ។ វិធាននិងនីតិវិធីនៃការកំណត់និងការប្រាក់ច្រៀតម្កល់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២២៩

មាត្រា២៤១ .- ការអនុវត្តសេចក្តីសម្រេចស្តីពីការផាកពិន័យជាប្រាក់

១- រដ្ឋបាលសាវតើពន្ធ អាចប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនតាមការកំណត់ក្នុងច្បាប់នេះ ដើម្បីជានាដល់ប្រសិទ្ធភាពនៃការអនុវត្តសេចក្តីសម្រេចស្តីពីការផាកពិន័យជាប្រាក់ នៅពេលដែលសេចក្តីសម្រេចនេះចូលជាស្ថាពរ។

២- ក្នុងករណីចាំបាច់ និងដើម្បីជានាដល់ប្រសិទ្ធភាពនៃការអនុវត្តសេចក្តីសម្រេចស្តីពីការផាកពិន័យជាប្រាក់ចូលជាស្ថាពរ បទប្បញ្ញត្តិនៃជំពូកទោល(បទប្បញ្ញត្តិទូទៅ)នៃមាតិកាទី១(បទប្បញ្ញត្តិទូទៅ)ជំពូកទោល(ការបង្ខំដល់រូបកាយ)នៃមាតិកាទី៣(ការបង្ខំដល់រូបកាយ)នៃគន្លឹទី៨នៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវយកមកអនុវត្ត ក្នុងករណីដែលសេចក្តីសម្រេចអំពីការផាកពិន័យជាប្រាក់បានចូលជាស្ថាពរ។

ផ្នែកទី៥

ទណ្ឌកម្មព្រហ្មទណ្ឌ

មាត្រា២៤២ .- បទល្មើសគេចវេះពន្ធ

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត អភិបាល បណ្ណាធិការ កម្មសិទ្ធិកររបស់សហគ្រាសណាមួយ ឬបុគ្គលទទួលខុសត្រូវឱ្យសហគ្រាសណាមួយដែលបានប្រព្រឹត្តអំពើគេចវេះពន្ធដូចមានចែងក្នុងមាត្រា២២៦នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ២០០ ០០០ ០០០(ពីររយលាន)រៀល។

មាត្រា២៤៣ .- បទល្មើសរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី៥០ ០០០ ០០០(ហាសិបលាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល ចំពោះបុគ្គលដែលបានប្រព្រឹត្តអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារណាមួយ ដូចខាងក្រោម៖

១- ព្យាយាមរាំងការកំណត់និងការប្រមូលពន្ធ។

២- កសាងឬផ្តល់នូវកំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានក្លែងបន្លំ។

៣- លាក់ទុកឬបំផ្លាញចោលដោយចេតនានូវបញ្ជិកាគណនេយ្យ កំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានផ្សេងៗ។

៤- ចេញវិក្កយបត្រក្លែងបន្លំ។

៥- មិនអនុញ្ញាតឱ្យរដ្ឋបាលសាវតើពន្ធចូលគ្រឹះស្ថានអាជីវកម្មដើម្បីកំណត់និងប្រមូលពន្ធ។

មាត្រា២៤៤ .- ការធ្វើឱ្យធ្លាយការសម្ងាត់

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត បុគ្គលណាដែលបានធ្វើឱ្យធ្លាយការសម្ងាត់នៃព័ត៌មានពន្ធដារ ដោយបំពានមាត្រា១៩៧នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី៥០ ០០០ ០០០(ហាសិបលាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល។

ទំព័រ២៣០អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

មាត្រា២៤៥.- ការប្រកបវិជ្ជាជីវៈជាភ្នាក់ងារសេវាកម្មពន្ធដារដោយគ្មានអាជ្ញាបណ្ណ

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត បុគ្គលដែលប្រកបវិជ្ជាជីវៈជាភ្នាក់ងារសេវាកម្មពន្ធដារដោយគ្មានអាជ្ញាបណ្ណ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល។

មាត្រា២៤៦.- ការខកខានមិនបានបង់ប្រាក់ពន្ធដែលបានប្រមូលរួច

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត បុគ្គលដែលខកខានមិនបានបង់ប្រាក់ពន្ធដែលបានប្រមូលរួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី ៥០ ០០០ ០០០(ហាសិបលាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល។

មាត្រា២៤៧.- ការប្រមូលប្រាក់ពន្ធដែលមិនមានសិទ្ធិប្រមូល

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត បុគ្គលដែលធ្វើការប្រមូលប្រាក់ពន្ធ ដោយមិនទទួលបានសិទ្ធិពីរដ្ឋបាលការអនុញ្ញាតស្របតាមការកំណត់របស់ច្បាប់នេះឬលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី៥០ ០០០ ០០០ (ហាសិបលាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល។

មាត្រា២៤៨.- ការទទួលខុសត្រូវផ្នែករដ្ឋបាលរបស់មន្ត្រីពន្ធដារ

មន្ត្រីពន្ធដារទាំងឡាយណាដែលអនុវត្តបំពានបទប្បញ្ញត្តិនៃច្បាប់នេះនិងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងទៀត ក្នុងការអនុវត្តមុខងារនិងភារកិច្ចរបស់ខ្លួន ត្រូវទទួលទណ្ឌកម្មរដ្ឋបាលស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។ ទណ្ឌកម្មរដ្ឋបាលនេះ មិនមែនជាឧបសគ្គសម្រាប់ការចោទប្រកាន់និងការផ្តន្ទាទោសព្រហ្មទណ្ឌ ព្រមទាំងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ស្របតាមច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀតឡើយ។

មាត្រា២៤៩.- ការទទួលខុសត្រូវរបស់នីតិបុគ្គល

១- នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា២៤២ មាត្រា២៤៣ មាត្រា២៤៥ មាត្រា២៤៦ មាត្រា២៤៧ និងមាត្រា២៥០នៃច្បាប់នេះ។

២- ចំពោះនីតិបុគ្គលដែលប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងមាត្រា២៤២នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ២០០ ០០០ ០០០(ពីរយលាន)រៀល។

៣- ចំពោះនីតិបុគ្គលដែលប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងមាត្រា២៤៣ មាត្រា២៤៦ និងមាត្រា២៤៧នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥០ ០០០ ០០០(ហាសិបលាន)រៀល ទៅ ១០០ ០០០ ០០០(មួយរយលាន)រៀល។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២៣១

៤_ ចំពោះនីតិបុគ្គលដែលប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងមាត្រា២៤៥នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល។

៥_ ចំពោះនីតិបុគ្គលដែលប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងមាត្រា២៤៦នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥០ ០០០ ០០០(ហាសិបលាន)រៀល ទៅ២០០ ០០០ ០០០(ពីរយលាន)រៀល។

៦_ នីតិបុគ្គលអាចត្រូវប្រកាសទោសបន្ថែមណាមួយ ឬច្រើនដូចមានចែងក្នុងមាត្រា១៦៨(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា២៥០ _ ការទទួលខុសត្រូវរបស់អ្នកផ្តើមគំនិត និងអ្នកសមគំនិត

អ្នកផ្តើមគំនិតឬអ្នកសមគំនិត ដែលមានជាអាទិ៍ដួយជ្រោមជ្រែង អូសទាញ ផ្តល់គំនិត ឬជំរុញបុគ្គលម្នាក់ទៀតឱ្យប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើបទឬញ្ញត្តិស្តីពីពន្ធដារដូចមានចែងក្នុងច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ។

មាត្រា២៥១ _ ការប្រព្រឹត្តបទល្មើសពុករលួយ

១_ ចំពោះបទល្មើសដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា២៤៣ មាត្រា២៤៦ និងមាត្រា២៤៧ នៃច្បាប់នេះ ហើយដែលប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ត្រូវកំណត់ថាជាបទល្មើសពុករលួយ ដែលត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខតែមួយគត់របស់អង្គភាពប្រឆាំងអំពើពុករលួយ ក្នុងការស៊ើបអង្កេត និងកសាងសំណុំរឿងពុករលួយទៅតុលាការ។

២_ ការស៊ើបអង្កេតបទល្មើសពុករលួយក្នុងវិស័យពន្ធដារ និងការកសាងសំណុំរឿងពុករលួយនៅក្នុងវិស័យនេះទៅតុលាការ គឺជាសមត្ថកិច្ចផ្តាច់មុខរបស់អង្គភាពប្រឆាំងអំពើពុករលួយ ស្របតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។

មាត្រា២៥២ _ ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត

ការអនុវត្តបទឬញ្ញត្តិនៃជំពូកទី១៨នៃច្បាប់នេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀតក្នុងករណីអំពើដែលកំណត់ថាជាបទល្មើសដូចមានចែងក្នុងច្បាប់នេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

ជំពូកទី១៩
អន្តរប្បញ្ញត្តិ

មាត្រា២៥៣ _ អន្តរប្បញ្ញត្តិ

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលត្រូវបានដាក់ឱ្យអនុវត្តដោយផ្អែកលើមូលដ្ឋាននៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ និងវិសោធនកម្មជាបន្តបន្ទាប់ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទឬញ្ញត្តិនៃច្បាប់នេះ។

ទំព័រ២៣២ អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

ជំពូកទី២០

អវសានប្បញ្ញត្តិ

មាត្រា២៥៤ .- និរាករណ៍

ច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

មាត្រា២៥៥ .- ការប្រកាសឱ្យប្រើច្បាប់

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ អង្គារ ១៤ កាត់ ខែ ពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០២៣

ពរាស.៤ពា០៥.៤ឥ៤

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**



បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន



ព្រះរាជក្រម

ន.ស/រកម/០៥២៣/ ០០៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហាមុនី
សម្ងានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ងហោតាស កម្ពុជឯករាជរដ្ឋបុរណាសន្តិ សុតមន្តលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និង គតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៣ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖



ច្បាប់

ស្តីពី

លទ្ធកម្មសាធារណៈ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១ .–

ច្បាប់នេះ កំណត់អំពីវិធាន វិធីសាស្ត្រ នីតិវិធី និងរចនាសម្ព័ន្ធសម្រាប់គ្រប់គ្រងនិងអនុវត្តគ្រប់លទ្ធកម្មសាធារណៈ ក្នុងគោលបំណងដើម្បីធានាឱ្យកិច្ចលទ្ធកម្មសម្រាប់ការទិញ ការសាងសង់ ការជួសជុល ការជួលសេវាកម្ម និងការជួលសេវាទីប្រឹក្សា ប្រព្រឹត្តទៅប្រកបដោយតម្លាភាព គណនេយ្យភាព សុចរិតភាព ការប្រកួតប្រជែង ភាពយុត្តិធម៌ ប្រសិទ្ធភាព សក្តិសិទ្ធិភាព ចីរភាព គុណភាព ការសន្សំសំចៃ និងភាពទាន់ពេល ព្រមទាំងធានាឱ្យបាននូវប្រព័ន្ធលទ្ធកម្មសាធារណៈឯកភាពមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា២ .–

ច្បាប់នេះ មានវិសាលភាពអនុវត្តលើគ្រប់លទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនគិតពីប្រភពធនធាន លើកលែងតែ៖

១- លទ្ធកម្មក្រោមគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ ដែលត្រូវអនុវត្តតាមគោលការណ៍ណែនាំ និងនីតិវិធីដូចមានចែងក្នុងកិច្ចព្រមព្រៀងហិរញ្ញប្បទាន។ ប្រសិនបើកិច្ចព្រមព្រៀងមិនបានកំណត់អំពីគោលការណ៍ណែនាំនិងនីតិវិធីលទ្ធកម្មណាមួយផ្សេងទេ ដំណើរការលទ្ធកម្មសាធារណៈត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

២- លទ្ធកម្មដែលត្រូវអនុវត្តតាមច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន។

៣- លទ្ធកម្មដែលប៉ះពាល់ដល់ការសម្ងាត់ក្នុងវិស័យការពារជាតិនិងសន្តិសុខសាធារណៈ ដែលត្រូវមានការសម្រេចពីនាយករដ្ឋមន្ត្រី។

មាត្រា៣ .–

វាក្យសព្ទសំខាន់ៗដែលប្រើប្រាស់ក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

ជំពូកទី២
ស្ថាប័នគ្រប់គ្រងលទ្ធកម្មសាធារណៈ

មាត្រា៤ .–

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាស្ថាប័នគ្រប់គ្រងលទ្ធកម្មសាធារណៈដែលបំពេញមុខងារជានិយ័តករនិងត្រួតពិនិត្យការអនុវត្តលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានតួនាទីភារកិច្ចជាអាទិ៍៖

- រៀបចំនិងផ្សព្វផ្សាយគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈ
- ត្រួតពិនិត្យ វិភាគ តាមដាន និងវាយតម្លៃលើការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈ
- រៀបចំបណ្តុះបណ្តាលជំនាញលទ្ធកម្មដល់មន្ត្រីលទ្ធកម្មនិងបុគ្គលពាក់ព័ន្ធដទៃទៀត
- គ្រប់គ្រងបញ្ជីអ្នកដេញថ្លៃ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

- ត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយ
- ដោះស្រាយបណ្តឹងតវ៉ាពាក់ព័ន្ធនឹងការអនុវត្តលទ្ធកម្មសាធារណៈ
- ចាត់វិធានការសមស្របចំពោះអំពើល្មើសនីតិច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈ
- គ្រប់គ្រងទិន្នន័យ រៀបចំ និងផ្សព្វផ្សាយរបាយការណ៍លទ្ធកម្មសាធារណៈ។

មាត្រា៥ ៖

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចចេញលិខិតបទដ្ឋានគតិយុត្ត ដើម្បីណែនាំការអនុវត្តលទ្ធកម្មសាធារណៈដល់ស្ថាប័នអនុវត្តលទ្ធកម្ម។ ដោយឡែកចំពោះស្ថាប័នអនុវត្តលទ្ធកម្មដែលជាសហគ្រាសសាធារណៈ ដើម្បីធានានូវប្រសិទ្ធភាព សក្តិសិទ្ធិភាព និងការប្រកួតប្រជែង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចចេញលិខិតបទដ្ឋានគតិយុត្តបន្ថែមសម្រាប់ការអនុវត្តលទ្ធកម្មសាធារណៈ។

មាត្រា៦ ៖

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការគ្រប់គ្រងលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

តួនាទីនិងភារកិច្ចរបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យ។

ជំពូកទី៣
ស្ថាប័នអនុវត្តលទ្ធកម្ម

មាត្រា៧ ៖

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវទទួលខុសត្រូវលើការអនុវត្តលទ្ធកម្មសាធារណៈឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។

មាត្រា៨ ៖

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវបង្កើតគណៈកម្មាធិការលទ្ធកម្មមួយ ដើម្បីទទួលខុសត្រូវត្រួតពិនិត្យលើផែនការលទ្ធកម្មនិងឯកសារដេញថ្លៃ ធ្វើការវាយតម្លៃប្រគល់កិច្ចសន្យា គ្រប់គ្រងការអនុវត្តកិច្ចសន្យា និងដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មតាមសមត្ថកិច្ចរបស់ខ្លួន។ គណៈកម្មាធិការលទ្ធកម្ម ត្រូវដឹកនាំដោយថ្នាក់ដឹកនាំបន្ទាប់មួយរូបតាមការប្រគល់សិទ្ធិពីប្រធានស្ថាប័នអនុវត្តលទ្ធកម្ម។ ប្រធានស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវអនុម័តលើការសម្រេចប្រគល់កិច្ចសន្យានិងចុះហត្ថលេខាលើកិច្ចសន្យា។ ប្រធានស្ថាប័នអនុវត្តលទ្ធកម្ម មានឆន្ទានុសិទ្ធិក្នុងការប្រគល់សិទ្ធិជូនថ្នាក់ដឹកនាំក្រោមឱវាទក្នុងការអនុម័តនិងចុះហត្ថលេខាលើកិច្ចសន្យាក្នុងនាមប្រធានស្ថាប័នអនុវត្តលទ្ធកម្ម។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៩ ៖

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវបង្កើតអង្គភាពលទ្ធកម្មមួយដែលមានរចនាសម្ព័ន្ធច្បាស់លាស់និងមានមន្ត្រីមានសមត្ថភាពទទួលបន្ទុកផ្នែកលទ្ធកម្មសាធារណៈគ្រប់គ្រាន់ ព្រមទាំងមានសិទ្ធិសមស្របដើម្បីទទួលខុសត្រូវអនុវត្តរាល់ការងារលទ្ធកម្មសាធារណៈ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២៣៧

អង្គភាពលទ្ធកម្ម មានរចនាសម្ព័ន្ធស្ថិតក្រោមប្រធានស្ថាប័នផ្ទាល់និងជាសេនាធិការឱ្យគណៈកម្មាធិការលទ្ធកម្ម។ អង្គភាពលទ្ធកម្ម ត្រូវដឹកនាំដោយប្រធានមួយរូបដែលមិនត្រូវមានតួនាទីនិងភារកិច្ចពាក់ព័ន្ធនឹងកិច្ចការហិរញ្ញវត្ថុផ្សេងទៀតក្នុងស្ថាប័នរបស់ខ្លួនឡើយ។ ប្រធានអង្គភាពលទ្ធកម្ម ជាលេខាធិការរបស់គណៈកម្មាធិការលទ្ធកម្ម។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពលទ្ធកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា១០ ..

ស្ថាប័នអនុវត្តលទ្ធកម្មដែលជាអង្គភាពថវិកាអាណាប័កផ្តេរសិទ្ធិពេញលេញ អាចត្រូវបានអនុញ្ញាតឱ្យបង្កើតក្រុមលទ្ធកម្មសម្រាប់អនុវត្តលទ្ធកម្មសាធារណៈជំនួសឱ្យការបង្កើតគណៈកម្មាធិការលទ្ធកម្មនិងអង្គភាពលទ្ធកម្ម។

លក្ខណវិនិច្ឆ័យ ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមលទ្ធកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី៤
វិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម

មាត្រា១១ ..

វិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម ត្រូវធ្វើឡើងដោយអនុលោមតាមមាត្រា១២ មាត្រា១៣ និងមាត្រា១៤ នៃច្បាប់នេះ។

លក្ខខណ្ឌ កម្រិតទឹកប្រាក់ នីតិវិធី និងការផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះ សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា១២ ..

វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ ជាវិធីសាស្ត្រលទ្ធកម្មសម្រាប់ជ្រើសរើសអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្ម ដោយបើកចំហចំពោះគ្រប់អ្នកដេញថ្លៃក្នុងស្រុកនិងអន្តរជាតិ។ វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ ជាវិធីសាស្ត្រលទ្ធកម្មដែលមានកម្រិតគម្លាតភាពខ្ពស់និងដែលត្រូវជំរុញឱ្យប្រើក្នុងលទ្ធកម្មសាធារណៈ។ វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈរួមមាន៖

ក. ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ : វិធីសាស្ត្រនេះ ត្រូវប្រើសម្រាប់គម្រោងលទ្ធកម្មដែលមានទឹកប្រាក់កម្រិតធំនិង/ឬមានលក្ខណៈបច្ចេកទេសខ្ពស់។

ខ. ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក : វិធីសាស្ត្រនេះ ត្រូវប្រើក្នុងករណីដែលមានផលិតផលផលិតកម្ម សេវាកម្ម ឬសមត្ថភាពសាងសង់ក្នុងស្រុកគ្រប់គ្រាន់។

មាត្រា១៣ ..

វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងដទៃទៀត ជាវិធីសាស្ត្រលទ្ធកម្មដែលមិនមែនជាការដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈរួមមាន៖

ក. ការដេញថ្លៃមានកម្រិត : វិធីសាស្ត្រនេះ ត្រូវប្រើសម្រាប់គម្រោងលទ្ធកម្មដែលមានលក្ខណៈបច្ចេកទេសស្មុគស្មាញនិងដែលតម្រូវឱ្យមានអ្នកដេញថ្លៃមានសមត្ថភាពជំនាញជាក់លាក់សម្រាប់អនុវត្ត។ វិធីសាស្ត្រនេះ តម្រូវឱ្យមានការធ្វើបុរេលក្ខណសម្បត្តិ។

ទំព័រ២៣៨អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

ខ- ការពិគ្រោះថ្លៃ : វិធីសាស្ត្រនេះ ត្រូវប្រើសម្រាប់មុខសញ្ញាលទ្ធកម្មដែលមានរួចជាស្រេចនៅលើទីផ្សារក្នុងស្រុកនិងមានទឹកប្រាក់កម្រិតមធ្យម។

គ- ការស្នង់តម្លៃ : វិធីសាស្ត្រនេះ ត្រូវប្រើសម្រាប់មុខសញ្ញាលទ្ធកម្មមានរួចជាស្រេចនៅលើទីផ្សារក្នុងស្រុកនិងមានទឹកប្រាក់កម្រិតតូច។

មាត្រា១៥ .-

វិធីសាស្ត្រលទ្ធកម្មដោយឡែក ជាវិធីសាស្ត្រលទ្ធកម្មសម្រាប់ជ្រើសរើសអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្ម ដោយមិនមានការដេញថ្លៃ។ វិធីសាស្ត្រនេះ អាចអនុវត្តបានលុះត្រាតែមានការអនុញ្ញាតជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ វិធីសាស្ត្រលទ្ធកម្មដោយឡែករួមមាន៖

ក- ការចុះកិច្ចសន្យាផ្ទាល់ : វិធីសាស្ត្រនេះ អនុញ្ញាតឱ្យចរចាផ្ទាល់ជាមួយនឹងអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្មក្នុងកាលៈទេសៈណាមួយដូចខាងក្រោម៖

- មុខសញ្ញាលទ្ធកម្មមានប្រភពតែមួយ
- មុខសញ្ញាលទ្ធកម្មដែលត្រូវបានដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈម្តងរួចមកហើយ ហើយជាតម្រូវការចាំបាច់បន្ទាន់និងមិនមានពេលគ្រប់គ្រាន់សម្រាប់ធ្វើការដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈលើកទី២
- ការដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈលើកទី២ មិនទទួលបានជោគជ័យ ទោះបីជាបានកែសម្រួលឯកសារដេញថ្លៃ ក្រោយការដេញថ្លៃលើកទី១ បរាជ័យក៏ដោយ
- តម្រូវការចាំបាច់បន្ទាន់ក្នុងពេលមានគ្រោះមហន្តរាយធម្មជាតិឬគ្រោះអាសន្នផ្សេងទៀត ហើយមានរយៈពេលខ្លីមិនអាចរង់ចាំឱ្យប្រើវិធីសាស្ត្រផ្សេងទៀតបាន
- សម្រាប់គោលបំណងសិក្សាស្រាវជ្រាវ ដកបទពិសោធ ឬអភិវឌ្ឍ។

ខ- ការបន្តកិច្ចសន្យា: វិធីសាស្ត្រនេះ អនុញ្ញាតឱ្យចរចាផ្ទាល់ជាមួយនឹងអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្មក្នុងកាលៈទេសៈដូចខាងក្រោម៖

- មុខសញ្ញាលទ្ធកម្មដូចគ្នានឹងមុខសញ្ញាលទ្ធកម្មក្នុងកិច្ចសន្យាដើម ដែលទទួលបានតាមរយៈការដេញថ្លៃ
- ស្ថិតក្នុងអំឡុងមិនលើសពី៦(ប្រាំមួយ)ខែ បន្ទាប់ពីកិច្ចសន្យាដើមចូលជាធរមាននិងស្ថិតក្នុងឆ្នាំថវិកាតែមួយ
- តម្លៃឯកតាស្មើឬទាបជាងតម្លៃឯកតាក្នុងកិច្ចសន្យាដើម និង
- តម្លៃសរុបមិនលើសពី២៥(ម្ភៃប្រាំ)ភាគរយនៃតម្លៃកិច្ចសន្យាដើម។

គ- ការចុះកិច្ចសន្យាជាមួយនឹងអង្គភាពជំនាញនៃស្ថាប័នរដ្ឋ : វិធីសាស្ត្រនេះ អនុញ្ញាតឱ្យចរចាផ្ទាល់ជាមួយនឹងអង្គភាពជំនាញរបស់ស្ថាប័នរដ្ឋដែលមានធនធាន គ្រឿងចក្រ ឧបករណ៍ សម្ភារៈ និងកម្លាំងពលកម្មគ្រប់គ្រាន់សម្រាប់អនុវត្តកិច្ចសន្យា។

ឃ- ការចុះកិច្ចសន្យាជាមួយនឹងសហគមន៍ : វិធីសាស្ត្រនេះ អនុញ្ញាតឱ្យចរចាផ្ទាល់ជាមួយនឹងសហគមន៍សំដៅលើកទឹកចិត្តសហគមន៍ក្នុងស្រុក ដើម្បីប្រើប្រាស់កម្លាំងពលកម្ម ចំណេះដឹង និងសម្ភារៈក្នុងស្រុកសម្រាប់ចូលរួមក្នុងការអភិវឌ្ឍសហគមន៍។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២៣៩

ជំពូកទី៥

លទ្ធកម្មសេវាទីប្រឹក្សា

មាត្រា១៥ ៖

ទីប្រឹក្សា អាចត្រូវបានជ្រើសរើសដើម្បីផ្តល់សេវាឯកទេសសម្រាប់គ្រប់គ្រងគម្រោង អនុវត្តកិច្ចសន្យាសំខាន់ៗ ឬផ្តល់យោបល់ជំនាញក្នុងការងារពង្រឹងពង្រីកស្ថាប័នឬបង្កើនសមត្ថភាព។ ទីប្រឹក្សាអាចជាក្រុមហ៊ុនទីប្រឹក្សាឬទីប្រឹក្សាឯកត្តជន។

មាត្រា១៦ ៖

ក្រុមហ៊ុនទីប្រឹក្សា ត្រូវបានជ្រើសរើសនៅពេលស្ថាប័នអនុវត្តលទ្ធកម្មមានតម្រូវការសេវាទីប្រឹក្សាច្រើនដែលមានការពាក់ព័ន្ធគ្នាក្នុងពេលតែមួយ។ ការជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាត្រូវផ្អែកលើការស្នើបច្ចេកទេសនិងការស្នើហិរញ្ញវត្ថុរបស់ក្រុមហ៊ុនទីប្រឹក្សានីមួយៗ។

មាត្រា១៧ ៖

ទីប្រឹក្សាឯកត្តជន ត្រូវបានជ្រើសរើសដោយផ្អែកលើលក្ខណសម្បត្តិរបស់ទីប្រឹក្សាសម្រាប់ផ្តល់សេវាជូនស្ថាប័នអនុវត្តលទ្ធកម្ម។

មាត្រា១៨ ៖

វិធីសាស្ត្រជ្រើសរើសទីប្រឹក្សារួមមាន៖

- ការជ្រើសរើសផ្អែកលើគុណភាព
- ការជ្រើសរើសផ្អែកលើគុណភាពនិងថ្លៃ
- ការជ្រើសរើសផ្អែកលើថវិកាកំណត់
- ការជ្រើសរើសផ្អែកលើថ្លៃទាបបំផុត
- ការជ្រើសរើសផ្អែកលើលក្ខណសម្បត្តិរបស់ទីប្រឹក្សា
- ការជ្រើសរើសផ្អែកលើប្រភពតែមួយ
- ការជ្រើសរើសទីប្រឹក្សាឯកត្តជន។

មាត្រា១៩ ៖

វិធីសាស្ត្រជ្រើសរើសផ្អែកលើគុណភាព ត្រូវប្រើសម្រាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា។ វិធីសាស្ត្រនេះ ត្រូវអនុវត្តសម្រាប់ការងារដែលមានការពាក់ព័ន្ធគ្នាក្នុងពេលតែមួយនិងផ្តោតជាសំខាន់លើគម្រិតបច្ចេកទេសនៃសេវា ហើយត្រូវបានប្រើសមស្របសម្រាប់ការងារដូចខាងក្រោម៖

- ការងារជំនាញឯកទេសខ្ពស់ឬស្មុគស្មាញខ្លាំងដែលពិបាកកំណត់លក្ខខណ្ឌយោងការងារនិងលទ្ធផលការងារច្បាស់លាស់ ហើយការងារនោះអាចធ្វើឡើងបានតាមរបៀបផ្សេងគ្នា
- ការងារដែលមានផលប៉ះពាល់ខ្លាំងផ្នែកសង្គម សេដ្ឋកិច្ច និង/ឬបរិស្ថាន ដែលតម្រូវឱ្យមានក្រុមហ៊ុនទីប្រឹក្សាមានជំនាញនិងសមត្ថភាពខ្ពស់សម្រាប់អនុវត្ត។

ROYAUME DU CAMBODGE
MINISTERE DU PALAIS ROYAL

មាត្រា២០ .-

វិធីសាស្ត្រជ្រើសរើសផ្អែកលើគុណភាពនិងថ្លៃ ត្រូវប្រើសម្រាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា។ វិធីសាស្ត្រនេះត្រូវអនុវត្តសម្រាប់ការងារធំៗនិងការងារដែលអាចកំណត់បានច្បាស់លាស់ពីទំហំការងារ លក្ខខណ្ឌយោងការងារ ពេលនិងលទ្ធផលការងារ។ ការប្រើវិធីសាស្ត្រនេះ ត្រូវថ្លឹងថ្លែងលើគុណភាពនិងថ្លៃ ដោយត្រូវផ្តល់ទម្ងន់លើគុណភាពខ្ពស់ជាងថ្លៃស្របតាមកម្រិតបច្ចេកទេសស្មុគស្មាញនៃសេវា។

មាត្រា២១ .-

វិធីសាស្ត្រជ្រើសរើសផ្អែកលើថវិកាកំណត់ ត្រូវប្រើសម្រាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា។ វិធីសាស្ត្រនេះ ត្រូវអនុវត្តសម្រាប់ការងារដែលមានលក្ខណៈសាមញ្ញនិងទំហំការងារអាចកំណត់បានច្បាស់លាស់ ហើយថវិកាមានកំណត់។ ការប្រើវិធីសាស្ត្រនេះ ត្រូវបញ្ជាក់ពីចំនួនថវិកាដែលមាន ដើម្បីឱ្យក្រុមហ៊ុនទីប្រឹក្សាដាក់ការស្នើបច្ចេកទេសតម្រូវតាមចំនួនថវិកានោះ។

មាត្រា២២ .-

វិធីសាស្ត្រជ្រើសរើសផ្អែកលើថ្លៃទាបបំផុត ត្រូវប្រើសម្រាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា។ វិធីសាស្ត្រនេះ ត្រូវអនុវត្តសម្រាប់ការងារដែលមានលក្ខណៈជាបទដ្ឋានឬការងារមានលក្ខណៈជាប្រចាំដែលធ្លាប់អនុវត្តបានល្អនិងមានបទដ្ឋានរួចជាស្រេច។

មាត្រា២៣ .-

វិធីសាស្ត្រជ្រើសរើសផ្អែកលើលក្ខណសម្បត្តិរបស់ទីប្រឹក្សា ត្រូវប្រើសម្រាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា។ វិធីសាស្ត្រនេះ ត្រូវអនុវត្តសម្រាប់ការងារតូចៗឬការងារជំនាញឯកទេស ដែលតម្រូវឱ្យមានទីប្រឹក្សាមានសមត្ថភាពជំនាញជាក់លាក់សម្រាប់អនុវត្តកិច្ចសន្យា។

មាត្រា២៤ .-

វិធីសាស្ត្រជ្រើសរើសផ្អែកលើប្រភពតែមួយ ត្រូវប្រើសម្រាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាឬទីប្រឹក្សាឯកត្តជននៅក្នុងកាលៈទេសៈពិសេស។ វិធីសាស្ត្រនេះ អាចអនុវត្តបានលុះត្រាតែមានការអនុញ្ញាតជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

កាលៈទេសៈពិសេសដែលសមស្របនឹងវិធីសាស្ត្រនេះរួមមាន៖

- ការងារបន្តពីមុនដែលត្រូវបានអនុវត្តដោយក្រុមហ៊ុនទីប្រឹក្សាឬទីប្រឹក្សាឯកត្តជន
- ករណីបន្ទាន់បំផុតដែលតម្រូវឱ្យមានការឆ្លើយតបភ្លាមៗ ឬ
- ករណីមានតែក្រុមហ៊ុនទីប្រឹក្សាមួយឬទីប្រឹក្សាឯកត្តជនម្នាក់ប៉ុណ្ណោះ ដែលមានសមត្ថភាពគ្រប់គ្រាន់និងមានបទពិសោធពិសេសសម្រាប់អនុវត្តគម្រោង។

មាត្រា២៥ .-

វិធីសាស្ត្រជ្រើសរើសទីប្រឹក្សាឯកត្តជន ត្រូវប្រើសម្រាប់ជ្រើសរើសបុគ្គលទីប្រឹក្សាផ្ទាល់។ ការអនុវត្តវិធីសាស្ត្រនេះផ្អែកលើធាតុផ្សំដឹង កម្រិតជំនាញវិជ្ជាជីវៈ បទពិសោធ និងកម្រិតជំនាញពាក់ព័ន្ធផ្សេងទៀតរបស់ទីប្រឹក្សា។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា២៦ ...

សេចក្តីជូនដំណឹងស្តីពីការដាក់ចំណាប់អារម្មណ៍សម្រាប់គ្រប់វិធីសាស្ត្រលទ្ធកម្មសេវាទីប្រឹក្សា លើកលែងតែវិធីសាស្ត្រជ្រើសរើសផ្ទែកលើប្រភពតែមួយ ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈដើម្បីធានាឱ្យមានការប្រកួតប្រជែងដោយស្មើភាពក្នុងចំណោមទីប្រឹក្សាក្នុងស្រុកនិងអន្តរជាតិ។

មាត្រា២៧ ...

លក្ខខណ្ឌនិងនីតិវិធីនៃការជ្រើសរើសទីប្រឹក្សាក្រោមវិធីសាស្ត្រជ្រើសរើសទីប្រឹក្សាក្នុងមាត្រា១៨ នៃច្បាប់នេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី៦
លក្ខណសម្បត្តិអ្នកដេញថ្លៃ

មាត្រា២៨ ...

គ្រប់អ្នកដេញថ្លៃ ត្រូវបានផ្តល់ឱកាសដោយយុត្តិធម៌និងស្មើភាពក្នុងការចូលរួមគ្រប់លទ្ធកម្មសាធារណៈស្របតាមលក្ខខណ្ឌកំណត់នៃវិធីសាស្ត្រនីមួយៗ លើកលែងតែអ្នកដេញថ្លៃទាំងឡាយណាដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់កំពុងស្ថិតនៅក្នុងបញ្ជីខ្មៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬត្រូវបានហាមឃាត់ដោយតុលាការ។

មាត្រា២៩ ...

អ្នកដេញថ្លៃ ត្រូវចុះបញ្ជីចំណាត់ប្រភេទនិងចំណាត់ថ្នាក់អ្នកដេញថ្លៃនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីមានសិទ្ធិចូលរួមក្នុងលទ្ធកម្មសាធារណៈ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើចំណាត់ប្រភេទនិងចំណាត់ថ្នាក់អ្នកដេញថ្លៃតាមកម្រិតសមត្ថភាពរបស់អ្នកដេញថ្លៃដើម្បីធានាការអនុវត្តកិច្ចសន្យា។

នីតិវិធីនៃការធ្វើចំណាត់ប្រភេទនិងចំណាត់ថ្នាក់អ្នកដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៣០ ...

ការកំណត់បុរេលក្ខណសម្បត្តិអ្នកដេញថ្លៃ ត្រូវធ្វើឡើងដោយស្ថាប័នអនុវត្តលទ្ធកម្មសម្រាប់តែគម្រោងលទ្ធកម្មដែលមានលក្ខណៈបច្ចេកទេសស្មុគស្មាញ។

នីតិវិធីសម្រាប់ធ្វើបុរេលក្ខណសម្បត្តិអ្នកដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៣១ ...

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវពិនិត្យនិងវាយតម្លៃលើលក្ខណសម្បត្តិតាមក្រោយរបស់អ្នកដេញថ្លៃនាំមុខ មុនការស្នាមច្រឡាតល់កិច្ចសន្យា។

លក្ខខណ្ឌនិងនីតិវិធីសម្រាប់កំណត់លក្ខណសម្បត្តិតាមក្រោយ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា៣២ .–

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចុះឈ្មោះអ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ ឬអ្នកទទួលការក្នុងបញ្ជីខ្មៅ បន្ទាប់ពីបានរកឃើញថា អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ ឬអ្នកទទួលការ ដែលផ្តល់ភស្តុតាងក្លែងបន្លំឬមិនត្រឹមត្រូវក្នុងពេលដាក់ពាក្យប្តឹងតវ៉ាក្នុងដំណើរការលទ្ធកម្មសាធារណៈ ឬប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះឬបទប្បញ្ញត្តិផ្សេងទៀតដែលពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវជម្រះចេញពីបញ្ជីខ្មៅនូវឈ្មោះអ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ ឬអ្នកទទួលការដែលផុតសុពលភាពក្នុងបញ្ជីខ្មៅ។

ការចុះនិងការជម្រះបញ្ជីខ្មៅ ត្រូវផ្សព្វផ្សាយជាសាធារណៈនិងត្រូវចម្លងជូនគ្រប់ស្ថាប័នអនុវត្តលទ្ធកម្មក្នុងព្រះរាជាណាចក្រកម្ពុជា។

នីតិវិធីនៃការចុះ ការជម្រះ និងការផ្សព្វផ្សាយបញ្ជីខ្មៅ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី៧
ផែនការលទ្ធកម្ម

មាត្រា៣៣ .–

គ្រប់ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ។ ផែនការលទ្ធកម្ម ត្រូវមានសង្គតិភាពនឹងកញ្ចប់ថវិកាប្រចាំឆ្នាំ។

រាល់គម្រោងចំណាយដែលត្រូវអនុវត្តលទ្ធកម្មសាធារណៈ ត្រូវកត់ត្រាបញ្ចូលក្នុងផែនការលទ្ធកម្ម។ ករណីដែលមិនមានការកត់ត្រាក្នុងផែនការលទ្ធកម្ម មិនត្រូវបានអនុញ្ញាតឱ្យផ្តល់ចំណាយឡើយ។

លក្ខខណ្ឌនិងនីតិវិធីនៃការរៀបចំ ការពិនិត្យ និងការអនុម័តផែនការលទ្ធកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៣៤ .–

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវចងជាកញ្ចប់លទ្ធកម្ម ចំពោះមុខសញ្ញាលទ្ធកម្មដែលស្ថិតក្នុងប្រភេទដូចគ្នា មានលក្ខណៈដូចគ្នាឬប្រហាក់ប្រហែលគ្នា ស្របតាមតម្រូវការជាក់ស្តែងសម្រាប់ធ្វើកិច្ចលទ្ធកម្មតែមួយលើក ដើម្បីបង្កើនកម្រិតគុណភាពនៃការប្រកួតប្រជែង ការសន្សំសំចៃសោហ៊ុយចំណាយ និងចំណេញពេល។

មាត្រា៣៥ .–

ហាមបំបែកគម្រោងជាគម្រោងតូចៗក្នុងគោលបំណងបំពានវិធីសាស្ត្រលទ្ធកម្ម។

មាត្រា៣៦ .–

ផែនការលទ្ធកម្ម ត្រូវបានអនុញ្ញាតឱ្យកែតម្រូវក្នុងករណីចាំបាច់។ រាល់ការកែតម្រូវផែនការលទ្ធកម្មដោយសារមិនមានរបាលគ្រប់គ្រាន់សម្រាប់អនុវត្តកិច្ចលទ្ធកម្មឬដើម្បីតម្រូវតាមកិច្ចលទ្ធកម្មដែលបានអនុវត្តរួច ត្រូវហាមឃាត់។ ការកែតម្រូវផែនការលទ្ធកម្មត្រូវស្នើសុំការពិនិត្យនិងសម្រេចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចេញលិខិតបទដ្ឋានគតិយុត្តកំណត់លក្ខខណ្ឌដែលអនុញ្ញាតឱ្យស្ថាប័នអនុវត្តលទ្ធកម្មមានសិទ្ធិកែតម្រូវផែនការលទ្ធកម្មដោយមិនចាំបាច់សុំការពិនិត្យនិងសម្រេចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២៤៣

មាត្រា៣៧ .–

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវធ្វើផែនការលទ្ធកម្មប្រចាំឆ្នាំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងអនុម័ត ឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា។

មាត្រា៣៨ .–

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវអនុវត្តតាមផែនការលទ្ធកម្មប្រចាំឆ្នាំ ដែលបានអនុម័តដោយក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុនិងត្រូវធ្វើរបាយការណ៍អនុវត្តកិច្চលទ្ធកម្មជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានទៀងទាត់។

ជំពូកទី៨
នីតិវិធីនៃការអនុវត្តកិច្চលទ្ធកម្ម

មាត្រា៣៩ .–

ការអនុវត្តកិច្চលទ្ធកម្ម ត្រូវអនុលោមតាមដំណាក់កាលដូចខាងក្រោម៖

- ការរៀបចំឯកសារដេញថ្លៃ
- ការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ
- ការលក់ឯកសារដេញថ្លៃ និងការទទួលនិងការរក្សាទុកសំណុំឯកសារស្នើដេញថ្លៃ
- ការបើកសំណុំឯកសារស្នើដេញថ្លៃ
- ការវាយតម្លៃសំណុំឯកសារស្នើដេញថ្លៃ
- ការប្រគល់កិច្চសន្យា
- ការគ្រប់គ្រងកិច្চសន្យា។

មាត្រា៤០ .–

អង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវរៀបចំឯកសារដេញថ្លៃឱ្យស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ដោយ បញ្ចាក់ពីលក្ខខណ្ឌតម្រូវនិងលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសអ្នកដេញថ្លៃឱ្យបានច្បាស់លាស់ ដែលអាចផ្ទៀងផ្ទាត់បាន ហើយត្រូវពាក់ព័ន្ធនឹងមុខសញ្ញាលទ្ធកម្ម។ ឯកសារដេញថ្លៃ ត្រូវដាក់ជូនប្រធានគណៈកម្មាធិការលទ្ធកម្មពិនិត្យនិងចុះ ហត្ថលេខា។ ចំពោះគម្រោងលទ្ធកម្មដែលមានទឹកប្រាក់ធំ មានចរិតជាយុទ្ធសាស្ត្រ និងមានលក្ខណៈបច្চេកទេសដោយឡែក សម្រាប់គ្រប់គ្រង និងគម្រោងដែលមានវេទយិតភាពខ្ពស់ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវស្នើសុំទិដ្ឋាការយល់ព្រមលើឯកសារ ដេញថ្លៃពីក្រសួងសេដ្ឋកិច្চនិងហិរញ្ញវត្ថុ។

គំរូឯកសារដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្চនិងហិរញ្ញវត្ថុ។

មាត្រា៤១ .–

រាល់សំណុំឯកសារស្នើដេញថ្លៃ ត្រូវភ្ជាប់មកជាមួយនូវឯកសារប្រាក់កក់ធានាការដេញថ្លៃ លើកលែងតែសំណុំ ឯកសារស្នើដេញថ្លៃនៃកិច្চលទ្ធកម្មដែលត្រូវអនុវត្តតាមវិធីសាស្ត្រស្នងតម្លៃនិងវិធីសាស្ត្រជ្រើសរើសទីប្រឹក្សា។

លក្ខខណ្ឌ និងនីតិវិធីនៃការកក់ប្រាក់ធានាការដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្চ

ទំព័រ២៤៤អគ្គនាយកដ្ឋានរាជកិច្চនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

មាត្រា៤២ ...

អង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវរៀបចំសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃសម្រាប់ផ្សព្វផ្សាយ ដើម្បីជ្រើសរើសអ្នកដេញថ្លៃ។ សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ ត្រូវមានព័ត៌មានសំខាន់ៗដូចខាងក្រោម៖

- ការពណ៌នាអំពីប្រភេទនិងបរិមាណនៃទំនិញ ការងារសាងសង់ ការងារជួសជុល ឬសេវាកម្ម
- ឈ្មោះ អាសយដ្ឋាន អ៊ីម៉ែល និងទូរសព្ទរបស់អង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម
- វិធីសាស្ត្រលទ្ធកម្មដែលត្រូវអនុវត្ត
- លក្ខខណ្ឌតម្រូវនានានៃលក្ខណសម្បត្តិអ្នកដេញថ្លៃ
- កាលបរិច្ឆេទនិងពេលលក់ឯកសារដេញថ្លៃ ទទួល និងបើកសំណុំឯកសារស្នើដេញថ្លៃ
- លក្ខខណ្ឌតម្រូវនៃប្រាក់កក់ធានាការដេញថ្លៃនិងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា។

មាត្រា៤៣ ...

សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃនិងសេចក្តីកែសម្រួលនានា ត្រូវប្រកាសផ្សព្វផ្សាយតាមគេហទំព័រលទ្ធកម្ម សាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គេហទំព័ររបស់សាមីស្ថាប័នអនុវត្តលទ្ធកម្ម និងតាមសារព័ត៌មាន ហើយ ត្រូវបិទផ្សាយនៅលើក្តារបិទផ្សាយព័ត៌មានរបស់ស្ថាប័នអនុវត្តលទ្ធកម្ម។

មាត្រា៤៤ ...

អង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវរៀបចំឯកសារដេញថ្លៃឱ្យបានគ្រប់គ្រាន់សម្រាប់លក់ជូនអ្នក ដែលមានបំណងចូលរួមដេញថ្លៃ។ ការលក់ឯកសារដេញថ្លៃ ត្រូវធ្វើឡើងឱ្យបានទូលំទូលាយនៅទីតាំងជាក់លាក់ក្នុង ស្ថាប័នអនុវត្តលទ្ធកម្មនិងតាមប្រព័ន្ធអេឡិចត្រូនិករបស់ស្ថាប័នអនុវត្តលទ្ធកម្ម។

បែបបទនៃការលក់និងការកំណត់ថ្លៃលក់ឯកសារដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៤៥ ...

ប្រសិនបើមានការស្នើសុំបំភ្លឺជាលាយលក្ខណ៍អក្សរពីអ្នកដេញថ្លៃណាមួយអំពីឯកសារដេញថ្លៃ ស្ថាប័នអនុវត្ត លទ្ធកម្មត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅអ្នកដេញថ្លៃដែលស្នើសុំនោះ និងត្រូវចម្លងជូនទៅគ្រប់អ្នកដេញថ្លៃដែល បានទទួលឯកសារដេញថ្លៃ។ ក្នុងករណីចាំបាច់ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវធ្វើការប្រជុំមុនកាលបរិច្ឆេទឈប់ទទួលសំណុំ ឯកសារស្នើដេញថ្លៃ ដើម្បីឆ្លើយបំភ្លឺដោយអញ្ជើញអ្នកដេញថ្លៃដែលបានទទួលឯកសារដេញថ្លៃមកចូលរួម។

មាត្រា៤៦ ...

អង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវទទួល ចុះបញ្ជី និងរៀបចំរក្សាទុកសំណុំឯកសារស្នើដេញថ្លៃ ដែលដាក់ក្នុងស្រោមសំបុត្របិទភ្ជិតនៅកន្លែងមានសុវត្ថិភាព ដោយមិនត្រូវប៉ះពាល់ឱ្យខូចទម្រង់ដើមនៃស្រោមសំបុត្រ ដាក់សំណុំឯកសារស្នើដេញថ្លៃនោះទេ មុនកាលបរិច្ឆេទបើកសំណុំឯកសារស្នើដេញថ្លៃ។

មាត្រា៤៧ ...

សំណុំឯកសារស្នើដេញថ្លៃទាំងអស់ ត្រូវបើកជាសាធារណៈភ្លាមៗបន្ទាប់ពីកាលបរិច្ឆេទឈប់ទទួលសំណុំឯកសារ ស្នើដេញថ្លៃ។ ព័ត៌មានសំខាន់ៗនៃសំណុំឯកសារស្នើដេញថ្លៃនីមួយៗ ត្រូវប្រកាសនៅចំពោះមុខអ្នកចូលរួមបើកសំណុំ ឯកសារស្នើដេញថ្លៃនិងត្រូវកត់ត្រាក្នុងកំណត់ហេតុបើកសំណុំឯកសារស្នើដេញថ្លៃ រួចចម្លងជូនគ្រប់អ្នកដេញថ្លៃនិង អ្នកចូលរួមបើកសំណុំឯកសារស្នើដេញថ្លៃទាំងអស់។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២៤៥

ប្រសិនបើក្នុងដំណើរការដេញថ្លៃលើកដំបូងទទួលបានសំណុំឯកសារស្នើដេញថ្លៃតិចជាងបី គណៈកម្មាធិការលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម មិនត្រូវបើកសំណុំឯកសារស្នើដេញថ្លៃទាំងនោះឡើយ ហើយត្រូវបញ្ជូនត្រឡប់ទៅឱ្យអ្នកដេញថ្លៃវិញ។

ក្នុងករណីដែលដំណើរការដេញថ្លៃលើកដំបូងទទួលបានសំណុំឯកសារស្នើដេញថ្លៃតិចជាងបីដូចបានកំណត់ក្នុងកថាខណ្ឌទី២ខាងលើ ពុំទទួលបានសំណុំឯកសារស្នើដេញថ្លៃ ឬពុំមានសំណុំឯកសារស្នើដេញថ្លៃណាមួយឆ្លើយតបនឹងលក្ខខណ្ឌនៃការដេញថ្លៃនោះ ត្រូវដំណើរការដេញថ្លៃឡើងវិញ។

ក្នុងដំណើរការដេញថ្លៃឡើងវិញ ទោះបីទទួលបានសំណុំឯកសារស្នើដេញថ្លៃចំនួនប៉ុន្មានក៏ដោយ ក៏ត្រូវតែដំណើរការបើកសំណុំឯកសារស្នើដេញថ្លៃទាំងនោះតាមកាលបរិច្ឆេទកំណត់។

មាត្រា៤៨ ..

គណៈកម្មាធិការលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវពិនិត្យវាយតម្លៃលើសំណុំឯកសារស្នើដេញថ្លៃទាំងអស់ជាសម្ងាត់ទៅតាមលក្ខខណ្ឌនិងលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងឯកសារដេញថ្លៃ។ លក្ខខណ្ឌនិងលក្ខណៈវិនិច្ឆ័យបន្ថែមដែលមិនមានចែងក្នុងឯកសារដេញថ្លៃ មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងការវាយតម្លៃឡើយ។

នីតិវិធីវាយតម្លៃលើសំណុំឯកសារស្នើដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៤៩ ..

ការប្រគល់កិច្ចសន្យា ត្រូវបានធ្វើឡើងចំពោះអ្នកដេញថ្លៃណាដែលបានដាក់សំណុំឯកសារស្នើដេញថ្លៃ៖

- មានភាពឆ្លើយតបពេញលេញឬច្រើនទៅនឹងលក្ខខណ្ឌដែលបានកំណត់ក្នុងឯកសារដេញថ្លៃ
- មានតម្លៃដែលត្រូវបានវាយតម្លៃរួចទាបជាងគេ និង
- មានភាពត្រឹមត្រូវបន្ទាប់ពីការត្រួតពិនិត្យលក្ខណសម្បត្តិតាមក្រោយ។

មាត្រា៥០ ..

មុននឹងចាប់ផ្តើមត្រួតពិនិត្យនិងវាយតម្លៃលើសំណុំឯកសារស្នើដេញថ្លៃនៃកិច្ចលទ្ធកម្មនីមួយៗ ប្រធាន អនុប្រធាននិងសមាជិកនៃគណៈកម្មាធិការលទ្ធកម្ម ក្រុមលទ្ធកម្ម ដែលត្រូវចូលរួមវាយតម្លៃប្រគល់កិច្ចសន្យា ត្រូវចុះហត្ថលេខាលើសេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្មដូចមានចែងក្នុងជំពូកទី១១ នៃច្បាប់នេះ។

មាត្រា៥១ ..

បន្ទាប់ពីបញ្ចប់ការវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យាទៅឱ្យអ្នកដេញថ្លៃឈ្នះ ដោយចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់។ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវទុករយៈពេល១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីការចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យា ដើម្បីអ្នកដេញថ្លៃចាញ់អាចស្នើសុំការបំភ្លឺឬប្តឹងតវ៉ាអំពីលទ្ធផលនៃការដេញថ្លៃ។

ប្រសិនបើមានការស្នើសុំបំភ្លឺជាលាយលក្ខណ៍អក្សរពីអ្នកដេញថ្លៃចាញ់អំពីមូលហេតុនៃបរាជ័យក្នុងការដេញថ្លៃ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវធ្វើការឆ្លើយបំភ្លឺជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានការស្នើសុំការបំភ្លឺ។

ចំពោះគម្រោងលទ្ធកម្មដែលមានទឹកប្រាក់ធំ មានចរិតជាយុទ្ធសាស្ត្រ និងមានលក្ខណៈបច្ចេកទេសដោយឡែក សម្រាប់គ្រប់គ្រង និងគម្រោងដែលមានវេទយិតភាពខ្ពស់ សេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យា ត្រូវធ្វើឡើងក្រោយពេលមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៥២ .-

បន្ទាប់ពីរយៈពេល១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ នៃការចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យា ប្រសិនបើមិនមានការប្តឹងតវ៉ាណាមួយឬបន្ទាប់ពីការប្តឹងតវ៉ាទាំងអស់ត្រូវបានដោះស្រាយ អង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្មត្រូវរៀបចំកិច្ចសន្យាលទ្ធកម្មដូចមានចែងក្នុងជំពូកទី៩ នៃច្បាប់នេះ និងត្រូវអញ្ជើញអ្នកដេញថ្លៃឈ្នះមកចុះហត្ថលេខាលើកិច្ចសន្យា ដោយភ្ជាប់មកជាមួយនូវឯកសារប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា។

ក្នុងករណីមានការប្តឹងតវ៉ាក្នុងអំឡុងដូចបានកំណត់ក្នុងកថាខណ្ឌខាងលើ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវចាត់វិធានការដោះស្រាយជាបន្ទាន់។ ប្រសិនបើមិនអាចដោះស្រាយបញ្ចប់ការប្តឹងតវ៉ា ស្ថាប័នអនុវត្តលទ្ធកម្មត្រូវស្នើសុំការសម្រេចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៥៣ .-

ការចុះហត្ថលេខាលើកិច្ចសន្យាលទ្ធកម្ម ត្រូវធ្វើឡើងរវាងប្រធានស្ថាប័នអនុវត្តលទ្ធកម្មឬថ្នាក់ដឹកនាំបន្ទាប់តាមការប្រគល់សិទ្ធិដូចមានចែងក្នុងមាត្រា៨ នៃច្បាប់នេះ និងអ្នកដេញថ្លៃឈ្នះ។

មាត្រា៥៤ .-

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវចាត់ចែងគ្រប់គ្រងកិច្ចសន្យាដើម្បីធានាឱ្យការអនុវត្តកិច្ចសន្យាប្រព្រឹត្តទៅបានត្រឹមត្រូវស្របតាមលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យា។

មាត្រា៥៥ .-

ប្រភេទនៃគម្រោងលទ្ធកម្មដែលមានទឹកប្រាក់ធំ មានចរិតជាយុទ្ធសាស្ត្រ និងមានលក្ខណៈបច្ចេកទេសដោយឡែកសម្រាប់គ្រប់គ្រង និងគម្រោងដែលមានវេទយិតភាពខ្ពស់ ដែលត្រូវស្នើសុំការពិនិត្យនិងសម្រេចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៥៦ .-

ការអនុវត្តលទ្ធកម្មសាធារណៈ ត្រូវអនុលោមតាមបរិបទនៃលទ្ធកម្មប្រកបដោយចីរភាព។ លទ្ធកម្មប្រកបដោយចីរភាព តម្រូវឱ្យមានលក្ខណៈបច្ចេកទេស លក្ខខណ្ឌតម្រូវ និងលក្ខណៈវិនិច្ឆ័យ ដោយផ្តល់អាទិភាពដល់ការការពារបរិស្ថាននិងការគ្រប់គ្រងផលប៉ះពាល់លើសង្គម សេដ្ឋកិច្ច។

លក្ខខណ្ឌ វិធាន និងនីតិវិធីសម្រាប់ការអនុវត្តលទ្ធកម្មប្រកបដោយចីរភាព ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៥៧ .-

ប្រព័ន្ធលទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានបង្កើតឡើងជាឧបករណ៍សម្រាប់កសាងប្រព័ន្ធនិងដើម្បីសម្រួលដល់ការគ្រប់គ្រងលទ្ធកម្មសាធារណៈ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២៤៧

គោលការណ៍សំខាន់ៗនៃប្រព័ន្ធលទ្ធកម្មអេឡិចត្រូនិកមានជាអាទិ៍៖

- ការប្រាស្រ័យទាក់ទងគ្នាតាមអេឡិចត្រូនិកមានតម្លៃស្មើគ្នាទៅនឹងការប្រាស្រ័យទាក់ទងគ្នាតាមក្រដាសស្មាម
- តម្រូវការនានាដើម្បីធានានិរន្តរភាពនិងការផ្សាភ្ជាប់រវាងផ្នែកទន់និងផ្នែករឹងដែលប្រើប្រាស់សម្រាប់គាំទ្រដល់ប្រព័ន្ធលទ្ធកម្មអេឡិចត្រូនិក
- តម្រូវការនានាដើម្បីធានាភាពត្រឹមត្រូវ សុចរិតភាព និងការសម្ងាត់ពាក់ព័ន្ធនឹងការបញ្ជូននិងការរក្សាទុកឯកសារពាក់ព័ន្ធ។

វិធាននិងនីតិវិធីនៃការអនុវត្តលទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី៩
កិច្ចសន្យាលទ្ធកម្ម

មាត្រា៥៨ .-

ការរៀបចំកិច្ចសន្យាលទ្ធកម្ម ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះនិងស្របតាមលក្ខខណ្ឌដែលមានចែងក្នុងឯកសារដេញថ្លៃ ព្រមទាំងស្របតាមគំរូកិច្ចសន្យាដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៥៩ .-

កិច្ចសន្យាលទ្ធកម្ម ត្រូវធ្វើជាភាសាខ្មែរ។ ក្នុងករណីចាំបាច់ កិច្ចសន្យាអាចសរសេរជាភាសាបរទេសដោយត្រូវបកប្រែចេញពីកិច្ចសន្យាជាភាសាខ្មែរ។ ក្នុងករណីមានខ្លឹមសារមិនស្របគ្នារវាងភាសាខ្មែរនិងភាសាបរទេស កិច្ចសន្យាជាភាសាខ្មែរជាឯកសារផ្លូវការ។

មាត្រា៦០ .-

គ្រប់កិច្ចសន្យាលទ្ធកម្ម ត្រូវទូទាត់ជាប្រាក់រៀល លើកលែងតែកិច្ចសន្យាសម្រាប់អនុវត្តគម្រោងលទ្ធកម្មនៅក្រៅប្រទេស ដែលអាចអនុញ្ញាតឱ្យទូទាត់ជារូបិយបណ្ណបរទេស។

មាត្រា៦១ .-

លក្ខណៈបច្ចេកទេសទំនិញ សំណង់ សេវាកម្ម និងលក្ខខណ្ឌយោងការងារនៃសេវាទីប្រឹក្សាដែលចែងក្នុងកិច្ចសន្យាត្រូវតែដូចគ្នានឹងលក្ខណៈបច្ចេកទេសនិងលក្ខខណ្ឌយោងការងារដែលមានចែងក្នុងឯកសារដេញថ្លៃ។

មាត្រា៦២ .-

តម្លៃកិច្ចសន្យា មិនត្រូវលើសពីតម្លៃដេញឈ្នះក្រោយការកែតម្រូវលេខគណិត។ តម្លៃកិច្ចសន្យាជាតម្លៃថេរក្នុងអំឡុងពេលអនុវត្តកិច្ចសន្យា លើកលែងតែក្នុងកាលៈទេសៈពិសេស ជាអាទិ៍វិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលបង្កឱ្យមានផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនិងករណីប្រធានស័ក្តិ។ កាលៈទេសៈពិសេសដែលតម្លៃកិច្ចសន្យាអាចកែប្រែបាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

មាត្រា៦៣ .-

រាល់កិច្ចសន្យា ត្រូវមានប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាលើកលែងតែកិច្ចសន្យាដែលទទួលបានតាមរយៈវិធីសាស្ត្រលទ្ធកម្មស្នង់តម្លៃ កិច្ចសន្យាជាមួយនឹងក្រុមហ៊ុនទីប្រឹក្សាឬទីប្រឹក្សាឯកត្តជន កិច្ចសន្យាជាមួយនឹងអង្គភាពជំនាញនៃស្ថាប័នរដ្ឋ និងកិច្ចសន្យាជាមួយនឹងសហគមន៍។ អ្នកដេញថ្លៃឈ្នះ ត្រូវកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យាមុនពេលកិច្ចសន្យាចូលជាធរមាន។ ចំនួនប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ត្រូវស្មើនឹងចំនួនដែលបានចែងក្នុងឯកសារដេញថ្លៃ។

ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ត្រូវរឹបអូសបង់ចូលថវិការដ្ឋ ប្រសិនបើអ្នកដេញថ្លៃឈ្នះបដិសេធការអនុវត្តកិច្ចសន្យាដែលបានចូលជាធរមានឬបំពានលក្ខខណ្ឌកិច្ចសន្យា ហើយត្រូវស្ថាប័នអនុវត្តលទ្ធកម្មបញ្ឈប់កិច្ចសន្យាមុនកាលកំណត់។

ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ត្រូវមានសុពលភាពរហូតដល់ចប់រយៈពេលធានាគុណភាពទំនិញ សំណង់ឬសេវាកម្ម។

បែបបទនិងនីតិវិធីនៃការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៦៤ .-

ការប្រគល់ទទួល ត្រូវធ្វើឡើងឱ្យបានត្រឹមត្រូវតាមទំហំ បរិមាណ គុណភាព លក្ខណៈបច្ចេកទេស និងស្របតាមពេលដែលបានកំណត់ក្នុងកាលវិភាគប្រគល់ទទួលដូចមានចែងក្នុងកិច្ចសន្យា និងត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់គណៈកម្មការប្រគល់ទទួល។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការប្រគល់ទទួល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៦៥ .-

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវរៀបចំការទូទាត់តម្លៃកិច្ចសន្យាជូនអ្នកផ្គត់ផ្គង់ឬអ្នកទទួលការដោយផ្អែកលើលក្ខខណ្ឌទូទាត់ក្នុងកិច្ចសន្យា។

មាត្រា៦៦ .-

អ្នកដេញថ្លៃឈ្នះ អាចចុះកិច្ចសន្យាបន្តដើម្បីផ្តល់ផ្នែកខ្លះនៃគម្រោងទៅឱ្យភាគីទីបី ប៉ុន្តែត្រូវមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនរបស់ស្ថាប័នអនុវត្តលទ្ធកម្ម។ ក្នុងករណីដែលកិច្ចសន្យាលទ្ធកម្មត្រូវពិនិត្យនិងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវស្នើសុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្នុងករណីដែលអ្នកដេញថ្លៃឈ្នះ ត្រូវបានអនុញ្ញាតឱ្យចុះកិច្ចសន្យាបន្តជាមួយភាគីទីបី អ្នកដេញថ្លៃឈ្នះត្រូវទទួលខុសត្រូវចំពោះមុខស្ថាប័នអនុវត្តលទ្ធកម្មលើការអនុវត្តកិច្ចសន្យាទាំងមូល។

មាត្រា៦៧ .-

ទ្រព្យសម្បត្តិការលទ្ធកម្មសាធារណៈ ត្រូវស្ថិតក្រោមនីតិរួមនៃរបបសារពើពន្ធជាធរមាននិងទទួលបានការលើកលែងការអនុគ្រោះនានាស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២៤៩

ជំពូកទី១០

ការត្រួតពិនិត្យកិច្ចលទ្ធកម្ម សវនកម្ម និងអធិការកិច្ចហិរញ្ញវត្ថុ

មាត្រា៦៨ ...

លទ្ធកម្មសាធារណៈ ជាកម្មវត្ថុនៃការត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមានដទៃទៀត។

វិធាននិងនីតិវិធីនៃការត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៦៩ ...

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិធ្វើការត្រួតពិនិត្យដល់កន្លែងមិនឱ្យដឹងមុនក្នុងអំឡុងនៃការអនុវត្តកិច្ចលទ្ធកម្ម ក្នុងករណីពិនិត្យឃើញថាមានភាពមិនប្រក្រតីកើតឡើង ជាអាទិ៍ការសង្ស័យឬបណ្តឹងតវ៉ាដែលមានមូលដ្ឋានជាក់លាក់នៅក្នុងដំណាក់កាលណាមួយនៃការអនុវត្តលទ្ធកម្មសាធារណៈ សំដៅធានាអនុលោមភាពនិងប្រសិទ្ធភាពក្នុងការអនុវត្តកិច្ចលទ្ធកម្ម។

វិធាននិងនីតិវិធីនៃការត្រួតពិនិត្យដល់កន្លែងមិនឱ្យដឹងមុន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៧០ ...

កិច្ចលទ្ធកម្មសាធារណៈរបស់ស្ថាប័នអនុវត្តលទ្ធកម្ម គឺជាកម្មវត្ថុនៃសវនកម្មនិងអធិការកិច្ចហិរញ្ញវត្ថុស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ជំពូកទី១១

ក្រុមសីលធម៌លទ្ធកម្ម

មាត្រា៧១ ...

ក្នុងការអនុវត្តកិច្ចលទ្ធកម្ម ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការលទ្ធកម្ម ក្រុមលទ្ធកម្ម មន្ត្រីលទ្ធកម្ម អ្នកដេញថ្លៃ ព្រមទាំងមន្ត្រីនិងបុគ្គលដទៃទៀត ដែលមានការពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មត្រូវគោរពតាមក្រមសីលធម៌លទ្ធកម្ម។

ក្រមសីលធម៌លទ្ធកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី១២

ការដោះស្រាយបណ្តឹងតវ៉ានិងទិវាទ

មាត្រា៧២

អ្នកដេញថ្លៃ មានសិទ្ធិប្តឹងតវ៉ាទៅស្ថាប័នអនុវត្តលទ្ធកម្មដោយដាក់ពាក្យប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរពាក់ព័ន្ធនឹងកាមួយកើតឡើងនៅក្នុងដំណាក់កាលនីមួយៗនៃកិច្ចលទ្ធកម្មមុនពេលចុះកិច្ចសន្យា។

សាមីស្ថាប័នអនុវត្តលទ្ធកម្ម មានសមត្ថកិច្ចទទួលពិនិត្យនិងដោះស្រាយបណ្តឹងតវ៉ារបស់អ្នកដេញថ្លៃ។

អ្នកប្តឹងដែលមិនយល់ព្រមនឹងសេចក្តីសម្រេចរបស់សាមីស្ថាប័នអនុវត្តលទ្ធកម្ម អាចប្តឹងទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យនិងដោះស្រាយ។

បែបបទនិងនីតិវិធីនៃការប្តឹងនិងការដោះស្រាយបណ្តឹងនៅស្ថាប័នអនុវត្តលទ្ធកម្មនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៧៣ .–

អ្នកប្តឹងដែលមិនយល់ព្រមនឹងសេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចប្តឹងទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា៧៤ .–

វិវាទទាំងឡាយណាដែលកើតឡើងក្នុងអំឡុងនៃការអនុវត្តកិច្ចសន្យាលទ្ធកម្ម គួរតែនៃកិច្ចសន្យាត្រូវដោះស្រាយតាមបទប្បញ្ញត្តិនិងយន្តការដែលមានចែងក្នុងកិច្ចសន្យា។

ជំពូកទី១៣
ទោសប្បញ្ញត្តិ

មាត្រា៧៥ .–

ទណ្ឌកម្មក្នុងច្បាប់នេះ រួមមានទណ្ឌកម្មរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌ។

ក. ទណ្ឌកម្មរដ្ឋបាលរួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការបញ្ឈប់ជាបន្ទាន់ពីក្នុងលទ្ធកម្មសាធារណៈ
- ការផ្អាកសកម្មភាព ការព្យួរ ការដកហូត ឬការលុបចោលកិច្ចសន្យា
- ការដកឈ្មោះចេញពីបញ្ជីអ្នកដេញថ្លៃ
- ការចុះក្នុងបញ្ជីខ្មៅអ្នកដេញថ្លៃ។

ការព្រមានជាលាយលក្ខណ៍អក្សរ ការដកឈ្មោះចេញពីបញ្ជីអ្នកដេញថ្លៃ ការបញ្ឈប់ជាបន្ទាន់ពីក្នុងលទ្ធកម្មសាធារណៈ និងការផ្អាកសកម្មភាព ការព្យួរ ការដកហូត ឬការលុបចោលកិច្ចសន្យា ជាសមត្ថកិច្ចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម។

ការចុះក្នុងបញ្ជីខ្មៅអ្នកដេញថ្លៃ ជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អំពើល្មើសដែលត្រូវរងទណ្ឌកម្មរដ្ឋបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្នុងករណីដែលបុគ្គលណាដែលមិនសុខចិត្តនឹងសេចក្តីសម្រេចអំពីទណ្ឌកម្មរដ្ឋបាលដូចមានចែងក្នុងច្បាប់នេះ អាចប្តឹងទៅតុលាការក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានលិខិតជូនដំណឹងអំពីការសម្រេចនេះ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២៥១

ខ. ទណ្ឌកម្មព្រហ្មទណ្ឌរួមមាន៖

- ពិន័យជាប្រាក់
- ទោសដាក់ពន្ធនាគារ។

មាត្រា៧៦ .-

អ្នករាជការសាធារណៈត្រប់លំដាប់ថ្នាក់ ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដែលបានប្រព្រឹត្ត ល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះឬត្រូវបានរកឃើញថា មានការពាក់ព័ន្ធនឹងការប្រព្រឹត្តមិនប្រក្រតីនៅក្នុងដំណើរការ លទ្ធកម្មសាធារណៈ ត្រូវទទួលទណ្ឌកម្មខាងរដ្ឋបាលស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។ ទណ្ឌកម្មខាងរដ្ឋបាលនេះ មិនមែនជាឧបសគ្គសម្រាប់ការចោទប្រកាន់និងការផ្តន្ទាទោសព្រហ្មទណ្ឌស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃ ព្រះរាជាណាចក្រកម្ពុជាឡើយ។

មាត្រា៧៧ .-

អ្នកដេញថ្លៃ អ្នកទទួលការ ឬអ្នកផ្គត់ផ្គង់ដែលត្រូវបានរកឃើញថា មានការពាក់ព័ន្ធនឹងអំពើពុករលួយ អំពើបន្ទំ អំពើឃុបឃិត អំពើបង្ខិតបង្ខំ អំពើហិង្សា ឬអំពើសម្ពុតគំរាមនៅក្នុងដំណើរការលទ្ធកម្មសាធារណៈ ឬផ្តល់ភស្តុតាងក្លែងបន្ទំ ឬមិនត្រឹមត្រូវក្នុងពេលដាក់ពាក្យប្តឹងតវ៉ានៅក្នុងដំណើរការលទ្ធកម្មសាធារណៈ ត្រូវបញ្ឈប់ជាបន្ទាន់ពីក្នុងលទ្ធកម្ម សាធារណៈដែលកំពុងដំណើរការឬលុបកិច្ចសន្យាដែលកំពុងអនុវត្តភ្លាមៗដោយស្ថាប័នអនុវត្តលទ្ធកម្ម។ ទណ្ឌកម្មនេះ មិនមែនជាឧបសគ្គសម្រាប់ការដាក់ទណ្ឌកម្មរដ្ឋបាលផ្សេងទៀតដែលជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយក៏មិនមែនជាឧបសគ្គសម្រាប់ការចោទប្រកាន់និងការផ្តន្ទាទោសព្រហ្មទណ្ឌស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន នៃព្រះរាជាណាចក្រកម្ពុជាឡើយ។

មាត្រា៧៨ .-

បុគ្គលដែលប្រព្រឹត្តនៅក្នុងដំណើរការលទ្ធកម្មសាធារណៈតាមការដេញថ្លៃ ដើម្បីកម្ចាត់អ្នកដេញថ្លៃឬធ្វើឱ្យខូច ការដេញថ្លៃដោយអំណោយ ការសន្យា ការព្រមព្រៀង អត្ថប្រយោជន៍អ្វីមួយ ឬតាមគ្រប់មធ្យោបាយទុច្ចរិតដទៃទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀល ទៅ ១០ ០០០ ០០០(ដប់លាន)រៀល។

មាត្រា៧៩ .-

បុគ្គលដែលប្រព្រឹត្តនៅក្នុងដំណើរការលទ្ធកម្មសាធារណៈតាមការដេញថ្លៃ ដើម្បីធ្វើជាឧបសគ្គដល់សេរីភាព នៃការដេញថ្លៃដោយហិង្សា ដោយការបង្ខិតបង្ខំ ឬដោយការសម្ពុតគំរាម ដែលអនុវត្តទៅលើអ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ ឬ អ្នកទទួលការ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៨ ០០០ ០០០(ប្រាំបីលាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល។

មាត្រា៨០ .-

បទល្មើសដែលមានចែងក្នុងមាត្រា៧៨និងមាត្រា៧៩ នៃច្បាប់នេះ ជាបទល្មើសពុករលួយដែលស្ថិតនៅក្រោម [illegible]ចផ្តាច្ចមុខតែមួយគត់របស់អង្គភាពប្រឆាំងអំពើពុករលួយក្នុងការស៊ើបអង្កេតនិងកសាងសំណុំរឿងពុករលួយ [illegible]ការ។

អង្គភាពនិងបុគ្គលដទៃទៀតដែលបានជឿងពីបទល្មើសពុករលួយទាំងឡាយណាដែលមានចែងក្នុងច្បាប់នេះនិង ក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ត្រូវប្តឹងទៅអង្គភាពឬការិយាល័យរាជធានី ខេត្ត ប្រឆាំងអំពើពុករលួយអំពីរឿងហេតុនៃបទល្មើសទាំងនេះ។

មាត្រា៨១ .-

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងមាត្រា៧៨និងមាត្រា៧៩ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដូចគ្នានឹង ការប្រព្រឹត្តបទមជ្ឈិមនោះបានសម្រេចដែរ។

មាត្រា៨២ .-

ចំពោះបទមជ្ឈិមដែលមានចែងក្នុងមាត្រា៧៨និងមាត្រា៧៩ នៃច្បាប់នេះ ទោសបន្ថែមមួយឬច្រើនដូចមានចែង ក្នុងមាត្រា៥៣(ប្រភេទនៃទោសបន្ថែម) នៃក្រមព្រហ្មទណ្ឌអាចត្រូវបានប្រកាស។

មាត្រា៨៣ .-

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះបទមជ្ឈិមដែលមានចែងក្នុងមាត្រា៧៨និង មាត្រា៧៩ នៃច្បាប់នេះ។

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា៧៨និងមាត្រា៧៩ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យ ជាប្រាក់ពី៤០ ០០០ ០០០(សែសិបលាន)រៀល ទៅ២០០ ០០០ ០០០(ពីរយលាន)រៀល ព្រមទាំងទោសបន្ថែមមួយ ឬច្រើនដូចមានចែងក្នុងមាត្រា១៦៥(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

មាត្រា៨៤ .-

ការអនុវត្តបទប្បញ្ញត្តិនៃជំពូកទី១៣ នៃច្បាប់នេះ មិនរារាំងដល់ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត ក្នុងករណី ដែលអំពើដែលកំណត់ថាជាបទល្មើសដែលមានចែងក្នុងច្បាប់នេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌ ផ្សេងទៀត។

ជំពូកទី១៤
អន្តរប្បញ្ញត្តិ

មាត្រា៨៥ .-

លិខិតបទដ្ឋានគតិយុត្តទាំងឡាយណា ដែលពាក់ព័ន្ធការអនុវត្តច្បាប់ស្តីពីលទ្ធកម្មសាធារណៈដែលត្រូវបាន ប្រកាសឱ្យប្រើប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ និងដែលពាក់ព័ន្ធ នឹងលទ្ធកម្មសាធារណៈដែលនៅជាធរមាន ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមក ជំនួសស្រប តាមបទប្បញ្ញត្តិនៃច្បាប់នេះ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២៥៣

ជំពូកទី១៥

អវសានប្បញ្ញត្តិ

មាត្រា៨៦ .-

ច្បាប់ស្តីពីលទ្ធកម្មសាធារណៈដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

មាត្រា៨៧ .-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ អង្គារ ១២ រោច ខែ ពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០២៣

ព្រះ.២រាជ.ជ៥៤

នស៊ីហមុនី

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ខ្ទបសម្ព័ន្ធនៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ

សទ្ទានុក្រម

- **កញ្ចប់លទ្ធកម្ម** សំដៅដល់ការប្រមូលផ្តុំមុខសញ្ញាលទ្ធកម្មដែលមានប្រភេទដូចគ្នា លក្ខណៈដូចគ្នា ឬប្រហាក់ប្រហែលគ្នាបញ្ចូលក្នុងក្រុមតែមួយសម្រាប់ធ្វើលទ្ធកម្មតែមួយលើក។
- **ការដេញថ្លៃ** សំដៅដល់ដំណើរការលទ្ធកម្មសាធារណៈដែលសំណុំឯកសារស្នើដេញថ្លៃត្រូវបានដាក់ ទទួល និងវាយតម្លៃសម្រាប់គោលបំណងប្រគល់កិច្ចសន្យា។
- **ការត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយ** សំដៅដល់ការត្រួតពិនិត្យដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើអនុលោមភាពនៃការអនុវត្តកិច្ចលទ្ធកម្មដែលបានអនុវត្ត្សរចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ដើម្បីតាមដាននិងវាយតម្លៃលើការអនុវត្តកិច្ចលទ្ធកម្ម និងតម្រូវការសម្រាប់កែលម្អនិងបង្កើនប្រសិទ្ធភាពនិងសមត្ថភាពក្នុងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។
- **ការប្រកួតប្រជែង** សំដៅដល់ការប្រើប្រាស់នីតិវិធីលទ្ធកម្មដែលមានការចូលរួមពីអ្នកដេញថ្លៃ ដើម្បីជ្រើសរើសសំណុំឯកសារស្នើដេញថ្លៃដែលឆ្លើយតបពេញលេញឬសមស្របជាងគេនិងមានតម្លៃល្អបំផុត។
- **ការសន្សំសំចៃ** សំដៅដល់ការប្រើប្រាស់ថវិកាសមស្របបំផុតក្នុងចំណាយ ដែលក្នុងនោះត្រូវពិចារណាផងដែរលើកត្តាពាក់ព័ន្ធនានាក្នុងការអនុវត្តនីតិវិធីលទ្ធកម្មដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់ឬអ្នកទទួលការ។
- **កិច្ចលទ្ធកម្ម** សំដៅដល់ដំណើរការលទ្ធកម្មសាធារណៈចាប់ពីពេលរៀបចំឯកសារដេញថ្លៃរហូតដល់ពេលទទួលបានទំនិញសំណង់ សេវាកម្ម ឬសេវាទីប្រឹក្សា។
- **ក្រមសីលធម៌លទ្ធកម្ម** សំដៅដល់ក្រមដែលអ្នកចូលរួមពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈត្រូវយល់ដឹងនិងអនុវត្តដោយស្មោះត្រង់តាមបទប្បញ្ញត្តិគតិយុត្តជាធរមាននិងអនុវត្តឱ្យបានត្រឹមត្រូវតាមតួនាទីនិងមុខងាររបស់ខ្លួន។
- **គណនេយ្យតាព** សំដៅដល់ការទទួលខុសត្រូវរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ក្នុងការធ្វើសេចក្តីសម្រេចនិងចាត់វិធានការក្នុងអំឡុងដំណើរការលទ្ធកម្មសាធារណៈ។
- **ចីរតាព** សំដៅដល់ការកាត់បន្ថយនៃផលប៉ះពាល់ដែលអាចកើតមានទៅលើបរិស្ថាន ប្រព័ន្ធអេកូឡូស៊ី និងការបន្តនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ច។
- **តម្លាតាព** សំដៅដល់ការទទួលបាននូវព័ត៌មានដែលពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈដោយចំហនិងសិទ្ធិចូលរួមក្នុងដំណើរការលទ្ធកម្មសាធារណៈតាមវិធីសាស្ត្រនិងនីតិវិធីលទ្ធកម្មសាធារណៈ។
- **ទីប្រឹក្សា** សំដៅដល់ក្រុមហ៊ុនទីប្រឹក្សាឬទីប្រឹក្សាឯកត្តជនដែលមានមុខរបរផ្តល់សេវាផ្នែកបញ្ញា។ ក្រុមហ៊ុនទីប្រឹក្សាអាចជាក្រុមហ៊ុនពាណិជ្ជកម្មឬនីតិបុគ្គលផ្សេងទៀត។
- **ទ្រព្យ** សំដៅដល់វត្ថុភវ រឹង និងឧស្ម័នដែលមានតម្លៃឬផលប្រយោជន៍សេដ្ឋកិច្ច ដូចជាគ្រឿងចក្រ ឧបករណ៍ សម្ភារៈបរិក្ខារ គ្រឿងឧបភោគបរិភោគ ឱសថ និងផលិតផលផ្សេងៗ រួមទាំងអត្តិសនីផងដែរ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- **បញ្ជីខ្មៅ** សំដៅដល់បញ្ជីហាមឃាត់ការចូលរួមរបស់អ្នកដេញថ្លៃក្នុងដំណើរការលទ្ធកម្មសាធារណៈដែលសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

- **ប្រសិទ្ធភាព** សំដៅដល់ចំណាយចំគោលដៅចំពោះមុខចំណាយដែលត្រូវអនុវត្តនីតិវិធីលទ្ធកម្ម។

- **ផែនការលទ្ធកម្ម** សំដៅដល់ការកំណត់ពីតម្រូវការរបស់ស្ថាប័នអនុវត្តលទ្ធកម្មក្នុងរយៈពេលជាក់លាក់និងកំណត់ពីពេលនិងនីតិវិធីសម្រាប់អនុវត្តកិច្ចលទ្ធកម្ម ក្នុងគោលបំណងបំពេញបានន្ូវតម្រូវការប្រើប្រាស់នៅពេលត្រូវការ។

- **មន្ត្រីលទ្ធកម្ម** សំដៅដល់ប្រធាន អនុប្រធាន និងមន្ត្រីទាំងអស់របស់អង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម។

- **មុខសញ្ញាលទ្ធកម្ម** សំដៅដល់មុខទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សាដែលជាកម្មវត្ថុនៃការដេញថ្លៃ ពិគ្រោះថ្លៃស្នង់តម្លៃ ឬការចរចាថ្លៃ។

- **លទ្ធកម្ម** សំដៅដល់ការទិញឬការរកបានន្ូវទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សាតាមរយៈវិធីសាស្ត្រដែលមានចែងក្នុងច្បាប់នេះ។

- **លទ្ធកម្មប្រកបដោយចីរភាព** សំដៅដល់ដំណើរការនៃកិច្ចលទ្ធកម្មដោយបានគិតគូរអំពីការកាត់បន្ថយផលប៉ះពាល់ដែលអាចកើតមានឡើងដល់បរិស្ថាន ប្រព័ន្ធអេកូឡូស៊ី និងការអភិវឌ្ឍសហគមន៍ប្រកបដោយនិរន្តរភាព។

- **លទ្ធកម្មសាធារណៈ**: សំដៅដល់កិច្ចលទ្ធកម្មដែលធ្វើឡើងដោយស្ថាប័នអនុវត្តលទ្ធកម្ម/អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ។

- **ស្ថាប័នអនុវត្តលទ្ធកម្ម** សំដៅដល់ក្រសួង ស្ថាប័ន អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ដែលអនុវត្តលទ្ធកម្មសាធារណៈ។

- **សុចរិតភាព** សំដៅដល់ការអនុវត្តគោលការណ៍គ្រឹះនិងក្រមសីលធម៌វិជ្ជាជីវៈដែលមិនអាចរំលោភបំពានបាននៃលទ្ធកម្មសាធារណៈ ទាំងក្របខណ្ឌច្បាប់និងស្ថាប័ន។

- **សេវាកម្ម** សំដៅដល់សកម្មភាពដែលពាក់ព័ន្ធនឹងការប្រើប្រាស់កម្លាំងមនុស្ស គ្រឿងបរិក្ខារ ឬបច្ចេកវិទ្យាដែលនាំមកន្ូវផលប្រយោជន៍ដល់ស្ថាប័នសាធារណៈ ប៉ុន្តែមិនរាប់បញ្ចូលការងារសាងសង់និងសេវាទីប្រឹក្សាទេ។

- **សេវាទីប្រឹក្សា** សំដៅដល់សេវាជំនាញការដែលផ្តល់ដោយក្រុមហ៊ុនទីប្រឹក្សាឬទីប្រឹក្សាឯកត្តជនដែលពាក់ព័ន្ធនឹងគម្រោងណាមួយឬសម្រាប់ការពង្រឹងពង្រីកស្ថាប័នឬបង្កើនសមត្ថភាព។

- **សំណង់** សំដៅដល់រាល់សកម្មភាពដែលពាក់ព័ន្ធនឹងការងារសាងសង់ ការងារជួសជុល ការធ្វើឡើងជាថ្មី ការដំឡើង ការជីក ការបូម និងការងារប្រហាក់ប្រហែល ដែលបង្កើតឱ្យមានការប្រើប្រាស់កម្លាំងពលកម្មគ្រឿងម៉ាស៊ីន បរិក្ខារ និងឬបច្ចេកវិទ្យា។

- **សំណុំឯកសារស្នើដេញថ្លៃ** សំដៅដល់សំណុំឯកសាររួមមានឯកសារដេញថ្លៃដែលបានបំពេញដោយអ្នកដេញថ្លៃនិងឯកសារភ្ជាប់មួយចំនួនទៀតដូចមានតម្រូវក្នុងឯកសារដេញថ្លៃ ដែលអ្នកដេញថ្លៃបានដាក់នៅស្ថាប័នអនុវត្តលទ្ធកម្មសម្រាប់គ្រាលំបាំងផ្តត់ផ្តង់ទំនិញ ទទួលការសំណង់ ផ្តល់សេវាកម្ម ឬសេវាទីប្រឹក្សា។

- **សក្តិសិទ្ធិតាព** សំដៅដល់វិសាលភាពឬកម្រិតដែលសម្រេចបាននូវលទ្ធផលចុងក្រោយឆ្លើយតបនឹងគោលបំណងស្នូលនៃការអនុវត្តលទ្ធកម្មសាធារណៈ។

- **អច្ចតាពថវិការអាណាប័កផ្ទេរសិទ្ធិពេញលេញ** សំដៅដល់អង្គភាពថវិកាដែលអាណាប័កដើមខ្សែបានប្រគល់សិទ្ធិអំណាចពេញលេញក្នុងការបញ្ជាចំណូល ចំណាយរបស់អង្គភាព ដោយមិនតម្រូវឱ្យឆ្លងអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនិងការត្រួតពិនិត្យនិងសម្រេចពីអាណាប័កដើមខ្សែ។

- **អំពើឃុបឃិត** សំដៅដល់ផែនការឬការរៀបចំឡើងរវាងអ្នកដេញថ្លៃពីរឬច្រើននាក់ ដើម្បីបង្កើតតម្លៃដេញថ្លៃសិប្បនិម្មិតគ្មានលក្ខណៈប្រកួតប្រជែងពិតប្រាកដ ឬធ្វើឱ្យមានឥទ្ធិពលលើសកម្មភាពរបស់ភាគីណាមួយក្នុងដំណើរការលទ្ធកម្មសាធារណៈឬធ្វើឱ្យមានការជះឥទ្ធិពលលើការអនុវត្តកិច្ចសន្យា។

- **អំពើបន្ធិតបន្ធំ** សំដៅដល់ការហាមឃាត់ឬការគម្រាមកំហែងដោយផ្ទាល់ឬដោយប្រយោលធ្វើឱ្យមានគ្រោះថ្នាក់ដល់បុគ្គលឬទ្រព្យសម្បត្តិរបស់បុគ្គល ដើម្បីធ្វើឱ្យមានឥទ្ធិពលដល់ការចូលរួមក្នុងដំណើរការលទ្ធកម្មសាធារណៈរបស់បុគ្គលនោះឬធ្វើឱ្យមានការជះឥទ្ធិពលលើការអនុវត្តកិច្ចសន្យា។

- **អំពើបន្ទំ** សំដៅដល់ការបកស្រាយបំភ្លៃហេតុការណ៍ដើម្បីធ្វើឱ្យមានឥទ្ធិពលលើដំណើរការលទ្ធកម្មសាធារណៈ។

- **អ្នកដេញថ្លៃ** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានបំណងចូលរួមក្នុងលទ្ធកម្មសាធារណៈនិងបានដាក់សំណុំឯកសារស្នើដេញថ្លៃឬការស្នើបញ្ជាក់ពីចំណាប់អារម្មណ៍។

- **អ្នកដេញថ្លៃនាំមុខ** សំដៅដល់អ្នកដេញថ្លៃដែលបានចូលរួមដេញថ្លៃ ហើយសំណុំឯកសារស្នើដេញថ្លៃរបស់ខ្លួនត្រូវបានគណៈកម្មាធិការលទ្ធកម្មវាយតម្លៃថាជាសំណុំឯកសារស្នើដេញថ្លៃឆ្លើយតបសមស្របជាងគេមុនពេលធ្វើលក្ខណសម្បត្តិតាមក្រោយ។

- **អ្នកឧទ្ធលការ** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលចុះកិច្ចសន្យាលើការងារសាងសង់ ការងារជួសជុល សេវាកម្មឬសេវាទីប្រឹក្សាជាមួយនឹងស្ថាប័នអនុវត្តលទ្ធកម្ម។

- **អ្នកផ្គត់ផ្គង់** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលចុះកិច្ចសន្យាលក់ទំនិញជាមួយនឹងស្ថាប័នអនុវត្តលទ្ធកម្ម។

- **ឯកសារដេញថ្លៃ** សំដៅដល់សំណុំឯកសារដែលអង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្មបានរៀបចំនិងផ្តល់ជាដំបូងទៅឱ្យអ្នកដេញថ្លៃ ដើម្បីប្រើសម្រាប់រៀបចំសំណុំឯកសារស្នើដេញថ្លៃ ដែលរួមមានពាក្យសុំដេញថ្លៃ សេចក្តីអញ្ជើញឱ្យចូលរួមដេញថ្លៃ ការស្នើឱ្យដាក់សំណុំឯកសារស្នើដេញថ្លៃ សេចក្តីអញ្ជើញឱ្យចូលរួមក្នុងការកំណត់បុរេលក្ខណសម្បត្តិ សេចក្តីណែនាំចំពោះអ្នកដេញថ្លៃ លក្ខណៈបច្ចេកទេស ទំហំការងារ លក្ខខណ្ឌយោងការងារ និងលក្ខខណ្ឌនៃកិច្ចសន្យា។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ព្រះរាជក្រម

នស/រកម/០៥២៣/ ០០៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជ៦ករាជរដ្ឋបូរណសន្តិ សុតមន្តណ សិរីវិបុណ
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មតាមព្រំដែន រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៣ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មតាមព្រំដែន រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

មាត្រា១.-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មតាមព្រំដែន រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២២ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

មាត្រា២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។

ថ្ងៃអង្គារ ១៤កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០២៣

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមទ្បាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប៉ាន សូរស័ក្តិ

បានប្រទេងត្រឹមត្រូវតាមច្បាប់ដើម
ប្រធានការិយាល័យរដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២៥៩

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៩ សប្រក

សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រាជរដ្ឋាភិបាល

ប្រគល់សិទ្ធិពេញសមត្ថភាពជូនឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដើម្បីចុះហត្ថលេខាក្នុងនាមរាជរដ្ឋាភិបាលកម្ពុជាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មតាមព្រំដែន រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

ដើម្បីជាសក្ខីភាព នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិពេញលេញតាមអំណាចច្បាប់បានចុះហត្ថលេខាខាងក្រោមលើសិទ្ធិប្រទាននេះ។

ថ្ងៃសៅរ ១៣រោជ ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ ម៉ឺ ឆ្នាំ២០២២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia

រាជរដ្ឋាភិបាល
Royal Government

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

N° 09 JFP

Phnom Penh, 1 March, 2022

DELEGATION OF FULL POWERS

- Having seen the Constitution of the Kingdom of Cambodia;
- Having seen the Royal Decree NS/RKT/0918/925 dated 06 September 2018 on the Nomination of the Government of the Kingdom of Cambodia;
- Having seen the Royal Decree NS/RKT/0320/421 dated 30 March 2020 on the Nomination and Modification of the composition of the Government of the Kingdom of Cambodia;
- Having seen the Royal Kram NS/RKM/0618/012 dated 28 June 2018 promulgating the Law on the Organization and Functioning of Council of Ministers;
- Having seen the Royal Kram NS/RKM/0196/16 dated 24 January 1996 promulgating the Law on the Establishment of the Ministry of Commerce; and
- Referring to the request of the Minister of Commerce.

THE ROYAL GOVERNMENT

Delegates herewith Full Powers to His Excellency **PAN SORASAK**, Minister of Commerce, to sign, on behalf of the Government of the Kingdom of Cambodia, the Agreement on Border Trade between the Government of the Kingdom of Cambodia and the Government of the Socialist Republic of Viet Nam.

In witness whereof, the undersigned, the Prime Minister of the Kingdom of Cambodia, with Full Powers duly entrusted to him, has signed this Delegation of Full Powers.

Prime Minister

Samdech Akka Moha Sena Padei Techo HUN SEN

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ២៦១

កិច្ចព្រមព្រៀង
ស្តីពី
ពាណិជ្ជកម្មតាមព្រំដែន
រវាង
រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
និង
រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម (តទៅនេះហៅជារួមថា "ភាគីទាំងពីរ" និងហៅដាច់ដោយឡែកពីគ្នាថា "ភាគី")

ដោយទទួលស្គាល់នូវផលប្រយោជន៍ដែលទទួលបានពីកិច្ចព្រមព្រៀងស្តីពីការទិញ-លក់ ផ្លាស់ប្តូរ ទំនិញ និងសេវាពាណិជ្ជកម្មនៅតំបន់ព្រំដែនរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០១ នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា

ដោយអនុលោមតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៨ នៅរដ្ឋធានីហាណូយ ប្រទេសវៀតណាម

ដោយទទួលស្គាល់ថា ការអភិវឌ្ឍពាណិជ្ជកម្មតាមព្រំដែនរវាងប្រទេសទាំងពីរ គឺជាយុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រគន្លឹះ ដើម្បីជំរុញទំនាក់ទំនងសេដ្ឋកិច្ចនិងពាណិជ្ជកម្ម បន្តពង្រឹងបន្ថែមទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រទេសទាំងពីរ ជួយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននៅតាមព្រំដែនរបស់ប្រទេសទាំងពីរ និងអភិវឌ្ឍសេដ្ឋកិច្ចរបស់ភាគីនីមួយៗដោយឈរលើមូលដ្ឋានសមភាព និងផ្តល់ផលប្រយោជន៍ ជូគ្នាទៅវិញទៅមក។

បានឯកភាពគ្នាដូចតទៅ៖

មាត្រា ១
គោលបំណង

គោលបំណងនៃកិច្ចព្រមព្រៀងនេះមានដូចខាងក្រោម៖

១. ធ្វើឱ្យប្រសើរឡើង និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនរស់នៅតាមព្រំដែននៃប្រទេសទាំងពីរ។

២. ពង្រឹងមិត្តភាព កិច្ចសហប្រតិបត្តិការនិងទំនាក់ទំនងគ្រប់ជ្រុងជ្រោយ និងការអភិវឌ្ឍប្រកបដោយចីរភាពរវាងប្រទេសទាំងពីរ។

៣. បង្កើតការតភ្ជាប់ការអភិវឌ្ឍយូរអង្វែង មានស្ថិរភាព និងនិរន្តរភាព សម្រាប់ប្រជាជននៃប្រទេសទាំងពីរ។

៤. បង្កើតលក្ខខណ្ឌអនុគ្រោះដល់ពាណិជ្ជករនៃប្រទេសទាំងពីរ។

មាត្រា ២
ខិសាលភាពនិងដែនអនុវត្ត

កិច្ចព្រមព្រៀងនេះគ្របដណ្តប់ពាណិជ្ជកម្មព្រំដែនផ្នែកទំនិញតាមតំបន់ព្រំដែន និង/ឬ ការផ្លាស់ប្តូរ ទំនិញនៅទីផ្សារនានាតាមព្រំដែន ស្របតាមនិយមន័យនៃពាណិជ្ជកម្មតាមព្រំដែន និងផ្សារព្រំដែនដូចបានកំណត់ក្នុងកិច្ចព្រមព្រៀងនេះ រវាងប្រទេសទាំងពីរ។

មាត្រា ៣
និយមន័យ

នៅក្នុងកិច្ចព្រមព្រៀងនេះ៖ វាក្យសព្ទខាងក្រោមត្រូវបកស្រាយ ដូចតទៅ៖

១. ពាណិជ្ជកម្មតាមព្រំដែន សំដៅដល់ពាណិជ្ជកម្មទំនិញដែលធ្វើឡើងនៅតំបន់តាមព្រំដែន និង/ឬនៅផ្សារតាមព្រំដែន ដោយពាណិជ្ជករ ឬប្រជាជនរស់នៅតាមព្រំដែននៃប្រទេសទាំងពីរ។

២. តំបន់ព្រំដែនក្នុងកិច្ចព្រមព្រៀងនេះ រួមមានឃុំនានា ឬតំបន់ដើបាលដែលសមមូលនឹងឃុំ ដែលជាប់នឹងខ្សែបន្ទាត់ព្រំដែនគោករវាងប្រទេសទាំងពីរ។

៣. ពាណិជ្ជករ សំដៅដល់នីតិបុគ្គល ឬរូបវន្តបុគ្គលដែលធ្វើប្រតិបត្តិការដោយឯកជ្ញ និងបានចុះបញ្ជីត្រឹមត្រូវសម្រាប់ធ្វើសកម្មភាពអាជីវកម្ម អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនៃប្រទេសនីមួយៗ។

៤. ប្រជាជនរស់នៅតាមព្រំដែន គឺប្រជាពលរដ្ឋខ្មែរ ឬប្រជាពលរដ្ឋវៀតណាម ដែលបានទទួលការចុះឈ្មោះថាមាននិវេសនដ្ឋានអចិន្ត្រៃយ៍នៅតាមតំបន់ព្រំដែន ដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីនីមួយៗ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនៃប្រទេសនីមួយៗ។

៥. ផ្សារតាមព្រំដែន សំដៅដល់ទីកន្លែងបង្កើតឡើងនៅតាមតំបន់ព្រំដែន ក្រោមច្បាប់ និងបទប្បញ្ញត្តិ នៃប្រទេសនីមួយៗ ដើម្បីបម្រើឱ្យពាណិជ្ជកម្មតាមព្រំដែនរវាងភាគីទាំងពីរ។

៦. ប៉ុស្តិ៍ត្រួតពិនិត្យ/ច្រកទ្វារព្រំដែនគោក សំដៅដល់ប៉ុស្តិ៍ត្រួតពិនិត្យ/ច្រកទ្វារព្រំដែន ដែលត្រូវបានកំណត់ក្រោមច្បាប់ និងបទប្បញ្ញត្តិនៃប្រទេសនីមួយៗ (តទៅនេះហៅថា "ប៉ុស្តិ៍ត្រួតពិនិត្យ/ច្រកទ្វារ ព្រំដែន")។

មាត្រា ៤
ទីតាំងសម្រាប់អនុវត្តសកម្មភាពពាណិជ្ជកម្មនៅតំបន់ព្រំដែន

ពាណិជ្ជកម្ម និងការផ្លាស់ប្តូរទំនិញនៅតំបន់ព្រំដែន ត្រូវបានធ្វើឡើងនៅតាមប៉ុស្តិ៍ត្រួតពិនិត្យ/ច្រកទ្វារព្រំដែនដែលបានបង្កើតឡើងជាផ្លូវការដោយភាគីទាំងពីរ។

មាត្រា ៥
អិច្ចដំរុញផ្សារព្រំដែន

១. ភាគីទាំងពីរឯកភាពគ្នាក្នុងការសម្រួលបដល់ការអភិវឌ្ឍផ្សារព្រំដែន និងប្រព័ន្ធភ័ស្តុភារកម្មនៅ តំបន់ព្រំដែន ដើម្បីជំរុញពាណិជ្ជកម្មតាមព្រំដែន និងសេវាកម្មគាំទ្រនានាពាក់ព័ន្ធនឹងពាណិជ្ជកម្មទំនិញ។

២. អាជីវករ និងប្រជាជនរស់នៅតាមព្រំដែននៃភាគីនីមួយៗ ត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងសកម្មភាពពាណិជ្ជកម្មនៅផ្សារព្រំដែន អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនៃប្រទេសនីមួយៗ។

មាត្រា ៦
ទំនិញពាណិជ្ជកម្មតាមព្រំដែន

១. ភាគីទាំងពីរ យល់ព្រមពង្រឹង និងសម្រួលដល់ការធ្វើពាណិជ្ជកម្មទំនិញតាមប៉ុស្តិ៍ត្រួតពិនិត្យ/ច្រកទ្វារព្រំដែនផ្លូវការដូចមានចែងក្នុងមាត្រា៤។

២. ភាគីទាំងពីរ ឯកភាពគ្នាថា ទំនិញដែលត្រូវបានធ្វើពាណិជ្ជកម្មនៅតំបន់ព្រំដែន មិនត្រូវរួមបញ្ចូលទំនិញដែលត្រូវបានហាមឃាត់ពីការនាំចេញ នាំចូល ឬផ្អាកបណ្តោះអាសន្នពីការនាំចេញឬនាំចូល ដូចមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិនៃប្រទេសនីមួយៗឡើយ។

៣. បញ្ជីទំនិញដែលត្រូវបានហាមឃាត់ ឬផ្អាកបណ្តោះអាសន្នពីការនាំចេញ និងនាំចូល នឹងត្រូវយកមកអនុវត្តអនុលោមតាមច្បាប់និងបទប្បញ្ញត្តិនៃភាគីនីមួយៗ និងកិច្ចព្រមព្រៀងទ្វេភាគីពាក់ព័ន្ធ នានារវាងភាគីទាំងពីរព្រមទាំងកិច្ចព្រមព្រៀងអន្តរជាតិនានាដែលភាគីទាំងពីរជាភាគី។

៤. ចំពោះការនាំចូល និងនាំចេញទំនិញ ដែលបានធ្វើឡើងដោយពាណិជ្ជករតាមព្រំដែន និងបានគ្រប់គ្រងដោយកូតា អាជ្ញាបណ្ណ និងទម្រង់នៃការគ្រប់គ្រងផ្សេងៗទៀត ដូចជាពន្ធគយជាដើម ច្បាប់ និងបទប្បញ្ញត្តិនៃប្រទេសនីមួយៗ ត្រូវយកមកអនុវត្ត។

៥. ភាគីទាំងពីរត្រូវលើកទឹកចិត្ត និងបង្កើតលក្ខខណ្ឌអនុគ្រោះដល់ប្រជាជននៅតាមព្រំដែនក្នុងការទិញ លក់ និងផ្លាស់ប្តូរទំនិញចាំបាច់សម្រាប់ផលិតកម្ម និងការរស់នៅប្រចាំថ្ងៃ។

៦. ទំនិញដែលមានដើមកំណើតនៅក្នុងភាគីម្ខាង ហើយដែលត្រូវបាននាំចេញទៅភាគីម្ខាងទៀត អាចត្រូវបានលើកលែងពន្ធនាំចូល និងពន្ធដារ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនៃប្រទេសនីមួយៗ។

មាត្រា ៧
ការទូទាត់សម្រាប់ពាណិជ្ជកម្មតាមព្រំដែន

១. ការទូទាត់សម្រាប់ពាណិជ្ជកម្មតាមព្រំដែនអាចធ្វើឡើងតាមរយៈរូបិយប័ណ្ណបរទេស ដែលអាចផ្លាស់ប្តូរ បានដោយសេរី ឬប្រាក់រៀលរបស់កម្ពុជា ឬប្រាក់ដុងរបស់វៀតណាម អនុលោមតាមបទប្បញ្ញត្តិដែលបានបញ្ជាក់ក្នុងមាត្រានេះ និងច្បាប់ និងបទប្បញ្ញត្តិនៃប្រទេសនីមួយៗ។

២. មធ្យោបាយទូទាត់សម្រាប់ពាណិជ្ជកម្មតាមព្រំដែន គឺ៖

ក) ការទូទាត់តាមរយៈធនាគារដែលមានការអនុញ្ញាតដោយប្រទេសនីមួយៗ

ខ) ការទូទាត់ជាសាច់ប្រាក់ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនៃប្រទេសនីមួយៗ

គ) ការទូទាត់តាមវិធីនៃការដោះដូរទំនិញ

៣. ការទូទាត់តាមរយៈធនាគារ ត្រូវបានលើកទឹកចិត្តសម្រាប់ពាណិជ្ជកម្មតាមព្រំដែន។

៤. ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិនៃប្រទេសនីមួយៗ ភាគីទាំងពីរបានឯកភាពគ្នាលើកទឹកចិត្តឱ្យបង្កើតសាខាធនាគារពាណិជ្ជ ឬការិយាល័យប្រតិបត្តិការនៅតំបន់ព្រំដែន ដើម្បីជំរុញ និងសម្រួលដល់ការទូទាត់ពាណិជ្ជកម្មតាមព្រំដែន។

៥. ចំនួនសាច់ប្រាក់ដែលអាចយកចូល ឬយកចេញពីប្រទេសនីមួយៗ ដោយមិនមានការធ្វើប្រតិវេទន៍ គយ ត្រូវអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិនៃប្រទេសនីមួយៗ។ ក្នុងគោលបំណងសម្រួលដល់ការធ្វើពាណិជ្ជកម្ម តាមព្រំដែនរវាងប្រទេសទាំងពីរបន្ថែមទៀត ភាគីទាំងពីរបានឯកភាពគ្នាជំរុញឱ្យធនាគារជាតិនៃភាគីទាំងពីរ បន្តធ្វើការឆ្ពោះទៅរកការបង្កើនជាអតិបរមានូវចំនួនសាច់ប្រាក់ដែលអាចយកចូល ឬយកចេញពីប្រទេសនីមួយៗដោយមិនចាំបាច់មានការធ្វើប្រតិវេទន៍គយ។

៦. ចំនួនសាច់ប្រាក់ដែលអាចយកចូល ឬយកចេញពីប្រទេសនីមួយៗ ដោយមិនមានការធ្វើប្រតិវេទន៍គយ ត្រូវបោះពុម្ពផ្សាយក្នុងសារព័ត៌មានរដ្ឋាភិបាល ឬក្នុងផតថលព័ត៌មានរបស់រដ្ឋាភិបាល និងត្រូវបិទផ្សាយនៅតាមការិយាល័យនៃប៉ុស្តិ៍ត្រួតពិនិត្យឬច្រកទ្វារព្រំដែនទាំងអស់។

មាត្រា ៨
សេវាកម្មគាំទ្រដល់ពាណិជ្ជកម្មតាមព្រំដែន

ភាគីទាំងពីរឯកភាពគ្នាជំរុញសេវាកម្មគាំទ្រដល់ពាណិជ្ជកម្មតាមព្រំដែន រួមបញ្ចូលប៉ុន្តែមិនកំណត់ ត្រឹមតែការជួលឃ្លាំង ការបញ្ជូនបន្ត ការដឹកជញ្ជូន ការកែច្នៃ ការរក្សាទុកទំនិញ សេវាធនាគារនិងហិរញ្ញវត្ថុ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនៃប្រទេសនីមួយៗ។

មាត្រា ៩
ការសម្រួលដល់ការឆ្លងកាត់ព្រំដែន

១. ភាគីទាំងពីរឯកភាពគ្នាសម្រួលដល់ការចូល/ការចេញតាមប៉ុស្តិ៍ត្រួតពិនិត្យ/ច្រកទ្វារព្រំដែន របស់ពាណិជ្ជការ និងប្រជាជនរស់នៅតាមព្រំដែន បុគ្គលដែលត្រូវបានអនុញ្ញាតដោយម្ចាស់ទំនិញ យានយន្ត ប្រតិបត្តិករ ដឹកជញ្ជូន អ្នកបើកបរនិងអ្នកបម្រើការលើយានយន្ត ជារបណាឯកសារតម្រូវនានា រួមមានប័ណ្ណបើកបរជាដើម អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនៃប្រទេសនីមួយៗ។

២. ភាគីទាំងពីរឯកភាពគ្នាសម្រួលដល់មធ្យោបាយដឹកជញ្ជូនចូល/ចេញ ឱ្យដល់ទីកន្លែងយកទំនិញចេញ/ផ្ទុកទំនិញនៅតាមតំបន់ព្រំដែន អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនៃប្រទេសនីមួយៗ។

មាត្រា ១០
ការត្រួតពិនិត្យទំនិញតាមប៉ុស្តិ៍ត្រួតពិនិត្យឬច្រកទ្វារព្រំដែន

១. ភាគីទាំងពីរឯកភាពគ្នាអនុវត្តវិធានការបច្ចេកទេសនិងចត្តាឡីស័កចំពោះទំនិញ ដែលកំពុងត្រូវបានដឹកជញ្ជូនតាមប៉ុស្តិ៍ត្រួតពិនិត្យ/ច្រកទ្វារព្រំដែន ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការអនុវត្តវិធានការ អនាម័យ និងសុវត្ថិភាពចំណីអាហារ និងវិធានការអនាម័យឬកូតតាមអនាម័យ ការការពារ សុខភាពនិងសុវត្ថិភាពមនុស្សការការពារសត្វនិងរុក្ខជាតិ បរិស្ថានអេកូឡូស៊ី និងជីវចម្រុះ ការទប់ស្កាត់និងការប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លង។

២. ភាគីទាំងពីរឯកភាពគ្នាលើកទឹកចិត្ត ឱ្យអាជ្ញាធរមានសមត្ថកិច្ចធ្វើការរួមគ្នាឆ្ពោះទៅរកបច្ចេកទេសអនាម័យ និងកូតតាមអនាម័យ និងវិធានការចត្តាឡីស័ក ដែលមានភាពអំណោយផលបន្ថែមទៀតសម្រាប់ការជួញដូរតូចតាចរវាងប្រជាជនរស់នៅតាមព្រំដែននៃភាគីទាំងពីរ។

៣. ទំនិញឆ្លងកាត់ប៉ុស្តិ៍ត្រួតពិនិត្យ/ច្រកទ្វារព្រំដែនរវាងភាគីទាំងពីរ ត្រូវអនុវត្តតាមនីតិវិធីឆ្លងកាត់ព្រំដែនអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនៃប្រទេសនីមួយៗ។

មាត្រា ១១
កិច្ចជំរុញពាណិជ្ជកម្ម

ភាគីទាំងពីរឯកភាពគ្នាសម្រួលដល់សកម្មភាពជំរុញពាណិជ្ជកម្ម ដែលអនុវត្តដោយអាជ្ញាធរពាក់ព័ន្ធ អង្គការ និងសមាគមនៃភាគីនីមួយៗ រួមទាំងសកម្មភាពនៅតំបន់ព្រំដែននៃភាគីម្ខាងទៀត។ ពាណិជ្ជករ ប្រជាជន រស់នៅតាមព្រំដែន និងរូបវ័ន្តបុគ្គលទាំងអស់ ត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងសកម្មភាពទាំងនេះ។

មាត្រា ១២
ការទប់ស្កាត់និងបង្ក្រាបការរត់ពន្ធនិងការក្លែងបន្លំ

ភាគីទាំងពីរប្តេជ្ញាចិត្តសហការគ្នាឱ្យបានជិតស្និទ្ធិក្នុងការទប់ស្កាត់ការប្រយុទ្ធប្រឆាំង និងការបង្ក្រាប ការរត់ពន្ធ និងការក្លែងបន្លំ រួមបញ្ចូលប៉ុន្តែមិនកំណត់ត្រឹម ការក្លែងបន្លំពាណិជ្ជកម្មឆ្លងកាត់ព្រំដែន ការជួញដូរ ខុសច្បាប់នូវថ្នាំជក់ឈើ ឈើកែច្នៃ សត្វព្រៃ គ្រឿងញៀន សមាសធាតុគីមីសម្រាប់ផ្សំអាវុធនិងគ្រឿងផ្ទុះ និងផលិតផលក្លែងក្លាយ។ ដើម្បីសហប្រតិបត្តិការគ្នាឱ្យមានប្រសិទ្ធភាព ភាគីទាំងពីរជំរុញឱ្យភ្នាក់ងារព្រំដែនបង្កើនការផ្លាស់ប្តូរព័ត៌មានបន្ថែមទៀត។

មាត្រា ១៣
ការផ្លាស់ប្តូរព័ត៌មាន

តបតាមការស្នើសុំ ភាគីទាំងពីរឯកភាពផ្តល់ឱ្យគ្នានូវព័ត៌មានដែលត្រូវបានធ្វើបច្ចុប្បន្នកម្ម អំពីច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងពាណិជ្ជកម្ម រួមមានបទប្បញ្ញត្តិស្តីពីនីតិវិធីចូល/ចេញព្រំដែន នីតិវិធីនាំចូល និងនាំចេញ បញ្ជីទំនិញហាមឃាត់នាំចេញ/នាំចូលឬផ្ទាកបណ្តោះអាសន្នពីការនាំចេញ/នាំចូល ពន្ធគយ កម្រៃសេវានិងបន្ទុកត្រូវបង់នានា និងព័ត៌មានផ្សេងៗទៀត។

មាត្រា ១៤
តួនាទីរបស់អាជ្ញាធរខេត្តសម្រាប់ពាណិជ្ជកម្មតាមព្រំដែន

១. ក្នុងវិសាលភាពនៃមុខងារនិងទំនួលខុសត្រូវរបស់ខ្លួនដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិ នៃប្រទេសនីមួយៗ អាជ្ញាធរខេត្តនៅតាមតំបន់ព្រំដែនអាចឯកភាពគ្នាលើវិធានការសមស្របនានាក្នុងការបង្កើន និងសម្រួលដល់ការធ្វើពាណិជ្ជកម្មតាមព្រំដែន។

២. ភាគីទាំងពីរលើកទឹកចិត្តឱ្យអាជ្ញាធរខេត្តនៅតាមតំបន់ព្រំដែនបង្កើតទំនាក់ទំនង "មេត្រីភាព" ក្នុងគោលបំណងលើកកម្ពស់ពាណិជ្ជកម្មតាមព្រំដែននិងទំនាក់ទំនងរវាងប្រជាជននៃប្រទេសទាំងពីរ។

មាត្រា ១៥
កិច្ចរៀបចំសម្រាប់ការអនុវត្ត

ខ- ផ្តល់ការផ្គត់ផ្គង់អគ្គិសនីមួយអាចទុកចិត្តបាន មានគុណភាព និងមានថ្លៃសមរម្យដល់អ្នកប្រើប្រាស់គ្រប់ប្រភេទនៅគ្រប់ទីកន្លែងនៃព្រះរាជាណាចក្រកម្ពុជា។

គ- យកចិត្តទុកដាក់បង្កើនការអភិវឌ្ឍថាមពលស្អាតដែលរួមមានថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពលឱ្យបានជាអតិបរមាតាមដែលអាចធ្វើទៅបាន។

២- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពល ត្រូវធានាថារាល់គម្រោងអភិវឌ្ឍក្នុងវិស័យថាមពលត្រូវអនុវត្តតាមគោលការណ៍នៃថាមពលអគ្គិសនីប្រកបដោយការទទួលខុសត្រូវខាងលើ។

មាត្រា១២៦ .- វិធានដើម្បីសម្រេចបានថាមពលអគ្គិសនីប្រកបដោយការទទួលខុសត្រូវ

ដើម្បីសម្រេចបានថាមពលអគ្គិសនីប្រកបដោយការទទួលខុសត្រូវ ត្រូវអនុវត្តវិធានដូចខាងក្រោម៖

ក- ក្នុងការរៀបចំផែនការអភិវឌ្ឍអគ្គិសនី ត្រូវជ្រើសរើសយកជម្រើសដែលអាចបំពេញទាំងលក្ខខណ្ឌសន្តិសុខថាមពលនិងទាំងលក្ខខណ្ឌចីរភាពថាមពលបានប្រសើរជាងគេ។

ខ- ការផ្តល់អាទិភាពចំពោះការវិនិយោគត្រូវផ្តល់ជូនគម្រោងទាំងឡាយណា ដែលស្ថិតក្នុងជម្រើសផែនការអភិវឌ្ឍដែលផ្តល់ទាំងសន្តិសុខថាមពល និងទាំងចីរភាពថាមពលបានប្រសើរជាងគេ។

គ- លើកកម្ពស់ការអភិវឌ្ឍនិងការប្រើប្រាស់បច្ចេកវិទ្យាដែលបង្កផលប៉ះពាល់តិចដល់បរិស្ថាន។

ឃ- វាយតម្លៃ និងអនុម័តលើផែនការអភិវឌ្ឍគម្រោងក្នុងវិស័យថាមពលប្រកបដោយការទទួលខុសត្រូវទាំងលើសន្តិសុខថាមពលនិងទាំងលើចីរភាពថាមពល។

ជំពូកទី៣
ការរៀបចំផែនការយុទ្ធសាស្ត្រថាមពលអគ្គិសនី
ប្រកបដោយការទទួលខុសត្រូវនិងការអនុវត្ត

មាត្រា១២៧ .- ការលើកកម្ពស់បច្ចេកវិទ្យាថាមពលមេត្រីបរិស្ថាន

១- ក្នុងការរៀបចំផែនការអភិវឌ្ឍថាមពល ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពលត្រូវលើកទឹកចិត្តនិងផ្តល់អាទិភាពដល់គម្រោងដែលប្រើប្រាស់បច្ចេកវិទ្យាថាមពលប្រកបដោយប្រសិទ្ធផល ការបញ្ចេញកាបូនតិច និងសំណល់មិនឱ្យលើសពីស្តង់ដារបរិស្ថានដែលបានកំណត់។

២- ស្តង់ដារបរិស្ថានត្រូវកំណត់ដោយអនុក្រឹត្យ។

៣- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពលត្រូវផ្តល់អាទិភាពអភិវឌ្ឍដល់គម្រោងថាមពលអគ្គិសនីណាដែលស្ថិតក្នុងជម្រើសផែនការអភិវឌ្ឍណាដែលផ្តល់ទាំងសន្តិសុខថាមពល និងទាំងចីរភាពថាមពលបានប្រសើរ

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៣១៥

មាត្រា១២៨ .- បច្ចេកវិទ្យាមានប្រសិទ្ធភាពខ្ពស់ដែលអាចស្វែងកេបាននិងជម្រើសដែលមានផលប៉ះពាល់តិច

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មិនត្រូវផ្តល់ការឯកភាពលើរបាយការណ៍ វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងឬពេញលេញសម្រាប់គម្រោងដែលបង្កឱ្យមានផលប៉ះពាល់បរិស្ថានធ្ងន់ធ្ងរឡើយ។ ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពលមិនត្រូវផ្តល់ការឯកភាពឱ្យអភិវឌ្ឍសម្រាប់គម្រោងណាដែលប្រើប្រាស់បច្ចេកវិទ្យាមិនមានប្រសិទ្ធភាពខ្ពស់ឡើយ។

២- ម្ចាស់គម្រោងត្រូវដាក់ជម្រើសក្នុងការបញ្ចេញសំណល់តិចនិងបញ្ចេញកាបូនតិចក្នុងដំណាក់កាលរចនាគម្រោង ដើម្បីសម្រេចបាននូវគោលបំណងនៃគម្រោង។

មាត្រា១២៩ .- ការលើកកម្ពស់ការផ្គត់ផ្គង់ថាមពលអគ្គិសនីនិងសិទ្ធិអ្នកប្រើប្រាស់

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពល ត្រូវជំរុញនិងលើកកម្ពស់ដល់ការផ្គត់ផ្គង់ថាមពលអគ្គិសនីមួយដែលមានគ្រប់គ្រាន់ មាននិរន្តរភាព ស្ថិរភាព គុណភាព និងថ្លៃសមរម្យ នៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា ទោះជាការផ្គត់ផ្គង់ចេញមកពីបណ្តាញជាតិឬការផ្គត់ផ្គង់តាមបែបប្រព័ន្ធទោលក៏ដោយ។

២- អ្នកប្រើប្រាស់អគ្គិសនីត្រូវបានអនុញ្ញាតឱ្យរៀបចំការផ្គត់ផ្គង់ជាប្រព័ន្ធទោល សម្រាប់បំពេញតម្រូវការអគ្គិសនីរបស់ខ្លួនផ្ទាល់ ត្រូវស្នើសុំការអនុញ្ញាតជាមុននិងត្រូវអនុវត្តតាមបទប្បញ្ញត្តិ នីតិវិធី និងស្តង់ដារបច្ចេកទេស សុវត្ថិភាពដែលកំណត់ដោយក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពល។

៣- អ្នកប្រើប្រាស់អគ្គិសនីមានសិទ្ធិជ្រើសរើសការផ្គត់ផ្គង់ណាដែលអ្នកប្រើប្រាស់អគ្គិសនីយល់ថាសមស្របនិងដែលមានប្រយោជន៍ចំពោះខ្លួនផ្ទាល់។

មាត្រា១៣០ .- ការផលិតនិងប្រើប្រាស់ថាមពលកកើតឡើងវិញតាមផ្ទះ

ការផលិតនិងប្រើប្រាស់ថាមពលកកើតឡើងវិញតាមផ្ទះ ត្រូវអនុលោមតាមគោលការណ៍ណែនាំរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពល ក្នុងករណីការដំឡើងនិងការប្រើប្រាស់ទាំងនេះមិនបានតភ្ជាប់ជាមួយប្រព័ន្ធផ្គត់ផ្គង់រួមដែលធ្វើឱ្យប៉ះពាល់ដល់ប្រតិបត្តិការនិងសុវត្ថិភាពនៃប្រព័ន្ធផ្គត់ផ្គង់រួម។

ជំពូកទី៤
ក្របខ័ណ្ឌទៅតាមប្រភេទថាមពលឬគម្រោងថាមពលអគ្គិសនី
ផ្នែកទី១
ថាមពលកកើតឡើងវិញ

មាត្រា១៣១ .- ករណីអនុគ្រោះពន្ធចំពោះសម្ភារៈបម្រើការដំឡើងបច្ចេកវិទ្យាថាមពលកកើតឡើងវិញ

គ្រប់សម្ភារៈនានាដែលប្រើសម្រាប់តែការដំឡើងបច្ចេកវិទ្យាថាមពលកកើតឡើងវិញ ត្រូវទទួលបានការលើកទឹកចិត្តតាមរយៈការអនុគ្រោះពន្ធស្របតាមបទប្បញ្ញត្តិស្តីពីការវិនិយោគជាធរមាន។

មាត្រា១៣២ .- ការគ្រប់គ្រងនិងការប្រើប្រាស់អគ្គិសនីបន្ថែមពីលើការផ្គត់ផ្គង់បណ្តាញជាតិ

១- ក្រសួងស្ថាប័នទទួលបន្ទុកគ្រប់គ្រងលើការផលិត ការបញ្ជូន ការចែកចាយអគ្គិសនី និងគ្រប់គ្រងលើការប្រើប្រាស់ថាមពលអគ្គិសនី ត្រូវរៀបចំការគ្រប់គ្រង ការបន្ថែម និងការផ្គត់ផ្គង់អគ្គិសនីពីលើការផ្គត់ផ្គង់ពីបណ្តាញជាតិ តាមរយៈការដំឡើងថាមពលពន្លឺព្រះអាទិត្យលើដំបូលភ្ជាប់ជាមួយប្រព័ន្ធផ្គត់ផ្គង់របស់បណ្តាញជាតិ។

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពល ត្រូវរៀបចំគោលនយោបាយនិងលិខិតបទដ្ឋានដើម្បីគ្រប់គ្រងការផ្គត់ផ្គង់

ទំព័រ៣១៦អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

បន្ថែមខាងលើនេះ។ បុគ្គលឯកជនដែលមានបំណងដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនបន្ថែម ហើយមានបំណងតភ្ជាប់ទៅនឹងប្រព័ន្ធផ្គត់ផ្គង់បណ្តាញជាតិ ត្រូវតែអនុវត្តតាមគោលនយោបាយនិងលិខិតបទដ្ឋានសម្រាប់ការគ្រប់គ្រង ការផ្គត់ផ្គង់បន្ថែមដែលក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពលបានរៀបចំខាងលើ។

២- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពល ត្រូវរៀបចំបទប្បញ្ញត្តិបច្ចេកទេស សេដ្ឋកិច្ច និងសុវត្ថិភាពពាក់ព័ន្ធជាមួយការគ្រប់គ្រងការប្រើប្រាស់អគ្គិសនីបន្ថែមពីលើការផ្គត់ផ្គង់ពីប្រព័ន្ធបណ្តាញ។

មាត្រា១៣៣ .- យន្តការទូទាត់ថ្លៃអគ្គិសនីសម្រាប់អ្នកប្រើប្រាស់អគ្គិសនីដែលដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូល

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពល ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីយន្តការទូទាត់ថ្លៃអគ្គិសនីសម្រាប់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូល ដែលបានតភ្ជាប់ជាមួយប្រព័ន្ធផ្គត់ផ្គង់របស់បណ្តាញជាតិ ស្របតាមគោលនយោបាយនិងលិខិតបទដ្ឋានសម្រាប់ការគ្រប់គ្រង ការផ្គត់ផ្គង់បន្ថែមដែលក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពលបានរៀបចំខាងលើ និងស្របតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា១៣៤ .- លក្ខខណ្ឌនៃការភ្ជាប់ប្រព័ន្ធពន្លឺព្រះអាទិត្យណាមួយទៅនឹងបណ្តាញផ្គត់ផ្គង់របស់បណ្តាញជាតិ

ប្រព័ន្ធពន្លឺព្រះអាទិត្យរបស់បុគ្គលដែលមានបំណងតភ្ជាប់ទៅនឹងបណ្តាញផ្គត់ផ្គង់របស់បណ្តាញជាតិ ត្រូវអនុវត្តតាមគោលនយោបាយ លិខិតបទដ្ឋាន បទប្បញ្ញត្តិបច្ចេកទេស សេដ្ឋកិច្ច និងសុវត្ថិភាពជាធរមាន ដែលរៀបចំដោយក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពល។

មាត្រា១៣៥ .- ប្រព័ន្ធអនុគ្រោះពន្ធសាកល្បងលើថាមពលកកើតឡើងវិញ

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពល ដោយសហការជាមួយក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីប្រព័ន្ធអនុគ្រោះពន្ធលើថាមពលកកើតឡើងវិញក្នុងរយៈពេល១(មួយ)ឆ្នាំនៃការសាកល្បង។

២- លិខិតបទដ្ឋានគតិយុត្តនេះត្រូវដាក់បញ្ចូលនូវខ្លឹមសារមួយចំនួនដូចខាងក្រោម៖

ក- ការផ្តល់ថវិការដ្ឋដើម្បីប៉ះប៉ូវដោយរាជរដ្ឋាភិបាលផ្តល់ជាអត្រាថេរមួយសម្រាប់ការជាវអគ្គិសនី ដែលផលិតចេញពីប្រភពពីកន្លែងផ្តល់ថាមពលពន្លឺព្រះអាទិត្យឬប្រព័ន្ធផលិតថាមពលដែលកកើតឡើងវិញ។

ខ- ជានាឱ្យបាននូវកម្រិតថ្លៃថាមពលសម្រាប់រយៈពេលណាមួយ ក្នុងគោលបំណងកាត់បន្ថយថ្លៃដែលត្រូវបង់ដោយអ្នកប្រើប្រាស់ចុងក្រោយ និងសម្រួលដល់ការស្តារឡើងវិញនូវចំណាយនិងលោភរបស់ម្ចាស់គម្រោង និងចំណាយថែទាំ។

គ- ការបង្កើតបញ្ជីថ្លៃលក់អគ្គិសនីមួយ ដែលអ្នកប្រើប្រាស់អគ្គិសនីត្រូវបង់ថ្លៃប្រើប្រាស់អគ្គិសនីពីប្រភពថាមពលកកើតឡើងវិញក្នុងរយៈពេលនៃការសាកល្បង។

ផ្នែកទី២
ថាមពលបរមាណូស៊ីវិល

មាត្រា១៣៦ .- ការគ្រប់គ្រងថាមពលបរមាណូស៊ីវិល



១- ថាមពលបរមាណូស៊ីវិលត្រូវបង្កើតឡើងដោយស្ថិតនៅក្រោមការគ្រប់គ្រងនិងកម្មសិទ្ធិរបស់រាជរដ្ឋាភិបាលដែលមានក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពលជាសេនាធិការ ដោយមានការគ្រប់គ្រងនិងប្រតិបត្តិការតាមស្តង់ដារ និងជាតិនៃកិច្ចគាំពារផ្នែកសុខភាព សុវត្ថិភាព សន្តិសុខ និងបរិស្ថាន។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៣១៧

២- រាជរដ្ឋាភិបាលដោយមានក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពលជាសេនាធិការ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីថាមពលបរមាណូស៊ីវិល។

៣- រាជរដ្ឋាភិបាលមិនត្រូវទទួលយកសំណល់ថាមពលបរមាណូស៊ីវិលពីប្រទេសដទៃជាដាច់ខាតទោះបីតាមលក្ខខណ្ឌឬកាលៈទេសៈណាក៏ដោយ។

៤- រាជរដ្ឋាភិបាលត្រូវបញ្ជូនទៅប្រទេសដើមវិញនូវគ្រាប់ឧបករណ៍ សម្ភារៈ និងបរិក្ខារ ដែលប្រឡាក់និង/ឬ ប៉ះពាល់នឹងសារធាតុវិទ្យុសកម្មដែលត្រូវបានបញ្ឈប់ពីការប្រើប្រាស់ ឬអស់សុពលភាពនៃការប្រើប្រាស់។

មាត្រា១៣៧ .- ការអប់រំ ផ្សព្វផ្សាយ និងអភិវឌ្ឍធនធានមនុស្សស្តីពីថាមពលបរមាណូស៊ីវិល

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពលបរមាណូស៊ីវិល ត្រូវរៀបចំកម្មវិធី ដើម្បីកសាងនិងអភិវឌ្ឍសមត្ថភាពវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាដល់បុគ្គលិកខ្លួននិងស្ថាប័នពាក់ព័ន្ធ ដោយសហការជាមួយស្ថាប័នថាមពលបរមាណូអន្តរជាតិ និងភាគីពាក់ព័ន្ធ។

២- ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការប្រើប្រាស់បច្ចេកវិទ្យាថាមពលបរមាណូស៊ីវិលតាមរយៈការអប់រំ ការផ្សព្វផ្សាយ និងការបង្កើតមជ្ឈមណ្ឌលព័ត៌មានថាមពលនុយក្លេអ៊ែរ និងមជ្ឈមណ្ឌលព័ត៌មានស្រាវជ្រាវវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាបរមាណូស៊ីវិល ដើម្បីកសាងនិងអភិវឌ្ឍធនធានមនុស្ស។

មាត្រា១៣៨ .- កម្មវិធីស្រាវជ្រាវស្តីពីបរមាណូស៊ីវិលសម្រាប់គោលបំណងសន្តិភាព

ក្រសួងស្ថាប័នពាក់ព័ន្ធត្រូវរៀបចំកម្មវិធីស្រាវជ្រាវដើម្បី៖

ក- កំណត់អត្តសញ្ញាណថាមពលបរមាណូស៊ីវិលមេត្រីបរិស្ថានដែលមានលក្ខណៈច្នៃប្រឌិតថ្មី។

ខ- វាយតម្លៃផលប៉ះពាល់ដែលអាចកើតឡើងដោយការអភិវឌ្ឍថាមពលបរមាណូស៊ីវិលចំពោះវិស័យបរិស្ថាននិងវិស័យពាក់ព័ន្ធ។

គ- កំណត់អំពីលក្ខខណ្ឌនៃកិច្ចគាំពារផ្នែកសុខភាព សុវត្ថិភាព សន្តិសុខ និងបរិស្ថាននៃការបោះបង់ចោលនូវសំណល់វិទ្យុសកម្ម។

មាត្រា១៣៩ .- លក្ខខណ្ឌតម្រូវនៃប្រសិទ្ធផលនៃប្រព័ន្ធបណ្តាញចែកចាយ

គម្រោងបណ្តាញផ្គត់ផ្គង់អគ្គិសនីនានា ត្រូវប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយប្រសិទ្ធផល ដើម្បីកាត់បន្ថយការបាត់បង់ថាមពលអគ្គិសនីលើប្រព័ន្ធបណ្តាញ។ ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពលអគ្គិសនីត្រូវទទួលបន្ទុកសិក្សាអំពីកម្រិតនៃបច្ចេកវិទ្យា ដែលត្រូវប្រើប្រាស់ជាមួយនឹងប្រសិទ្ធភាពសេដ្ឋកិច្ចនៃការវិនិយោគ ដើម្បីបន្ថយថ្លៃអគ្គិសនីនិងកាត់បន្ថយផលប៉ះពាល់បរិស្ថាន។ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិទទួលបន្ទុកពិនិត្យនិងសម្រេចលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងការប្រើប្រាស់បច្ចេកវិទ្យាមេត្រីបរិស្ថាននៅពេលដាក់ពាក្យស្នើសុំ។

មាត្រា១៤០ .- ការពង្រីកបណ្តាញជាតិ

១- ការពង្រីកបណ្តាញជាតិទៅកាន់តំបន់នានាទូទាំងប្រទេស ត្រូវមានការពិចារណាផ្នែកបរិស្ថាន សេដ្ឋកិច្ច និងសង្គម ដោយថ្លឹងថ្លែងជាមួយការពិចារណាអំពីភាពមានគ្រប់គ្រាន់ និរន្តរភាព ស្ថិរភាព គុណភាព និងតម្លៃសមរម្យរបស់បណ្តាញជាតិ។

២- រាជរដ្ឋាភិបាលអាចបញ្ឈប់រាល់ការពង្រីកបណ្តាញជាតិទៅកាន់តំបន់ជាក់លាក់ណាមួយក្នុងប្រទេស ប្រសិនបើការពង្រីកនេះ ពិតជាបានប៉ះពាល់ដល់បរិស្ថាន សេដ្ឋកិច្ច និងសង្គមធ្ងន់ធ្ងរ។ ក្នុងករណីនេះរាជរដ្ឋាភិបាលត្រូវស្វែងរកដំណោះស្រាយផ្គត់ផ្គង់អគ្គិសនីតាមបែបវិមជ្ឈការ ដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះ។

មាត្រា១៤១ .- សិទ្ធិទទួលបានព័ត៌មានស្តីពីថាមពលអគ្គិសនី

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពលត្រូវពិនិត្យអំពីលទ្ធភាពក្នុងការវាស់វែងនិងផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានអំពីតង់ស្យុងនិងគុណភាពអគ្គិសនីដែលបានផ្តត់ផ្តង់ ដើម្បីការពារការខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធចែកចាយ ឬការអាក់រអួលក្នុងការផ្តត់ផ្តង់អគ្គិសនី។

មាតិកាទី១១
ឧស្សាហកម្មនិស្សារណកម្មប្រកបដោយការទទួលខុសត្រូវ
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១៤២ .- គោលបំណង

មាតិកានេះ មានគោលបំណងពង្រឹងនិងកែលម្អនូវការគ្រប់គ្រង កិច្ចគាំពារ ការអភិរក្ស និងការស្តារឡើងវិញនូវការដ្ឋានឧស្សាហកម្មនិស្សារណកម្ម ដោយកំណត់នូវការកម្រិតលើគម្រោងនិស្សារណកម្ម និងការបង្ហាញព័ត៌មានពាក់ព័ន្ធ។

មាត្រា១៤៣ .- វិសាលភាព

មាតិកានេះ មានវិសាលភាព អនុវត្តលើធនធានឧស្សាហកម្មនិស្សារណកម្ម មានជាអាទិ៍ ប្រេង ឧស្ម័ន រ៉ែ វត្ថុធាតុកូគព្ភវិទ្យាផ្សេងៗដែលយកចេញពីដីនិងពីប្រភពផ្សេងៗទៀត ដែលបង្កើតឡើងដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ។

ជំពូកទី២
ស្ថាប័នទទួលខុសត្រូវ

មាត្រា១៤៤ .- ក្រសួងស្ថាប័នទទួលខុសត្រូវ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវតាមដានការអនុវត្តគម្រោងឧស្សាហកម្មនិស្សារណកម្មដែលអាចប៉ះពាល់ដល់ធនធានធម្មជាតិ ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ការពារធម្មជាតិ។

មាត្រា១៤៥ .- តួនាទីនិងការកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- ត្រួតពិនិត្យនិងសម្រេចលើការវាយតម្លៃបរិស្ថាន និងយុទ្ធសាស្ត្រពាក់ព័ន្ធនឹងឧស្សាហកម្មនិស្សារណកម្ម។

ខ- ត្រួតពិនិត្យនិងផ្តល់ការឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះបរិស្ថានលើគម្រោងឧស្សាហកម្មនិស្សារណកម្មនៅក្នុងតំបន់ការពារធម្មជាតិ។

គ- តាមដានការអនុវត្តបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថានលើគម្រោងឧស្សាហកម្មនិស្សារណកម្មនៅក្នុងតំបន់ការពារធម្មជាតិ។

មាត្រា១៤៦ .- ការធ្វើប្រតិបត្តិការធនធានរ៉ែជាលក្ខណៈសិប្បកម្មនិងខ្នាតតូច

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យរ៉ែឬរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការធ្វើអាជីវកម្មខ្នាតតូច និងធ្វើជាលក្ខណៈសិប្បកម្មដើម្បី៖

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៣១៩

ក- កំណត់ពីសិទ្ធិនៃការធ្វើប្រតិបត្តិការធនធានរ៉ែជាលក្ខណៈសិប្បកម្មនិងខ្នាតតូចរបស់ប្រជាពលរដ្ឋ។
ខ- ធានាថាសកម្មភាពនៃការធ្វើប្រតិបត្តិការធនធានរ៉ែជាលក្ខណៈសិប្បកម្មនិងខ្នាតតូចធ្វើឡើងដោយនិរន្តរភាពបរិស្ថាន សុវត្ថិភាព និងប្រសិទ្ធផល។
គ- ជំរុញនិងអនុវត្តតាមស្តង់ដារ និងការអនុវត្តដ៏ល្អបំផុតជាអន្តរជាតិក្នុងការគ្រប់គ្រង ការធ្វើប្រតិបត្តិការធនធានរ៉ែជាលក្ខណៈសិប្បកម្មនិងខ្នាតតូច។
ឃ- បង្កើតដំណើរការនៃការកំណត់តំបន់សម្រាប់ការធ្វើប្រតិបត្តិការធនធានរ៉ែជាលក្ខណៈសិប្បកម្មដោយមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសហគមន៍មូលដ្ឋាន។
ង- តម្រូវនិងផ្តល់ជំនួយសម្រាប់អ្នកធ្វើប្រតិបត្តិការធនធានរ៉ែលក្ខណៈសិប្បកម្មក្នុងការបង្កើត និងអនុវត្តផែនការសុវត្ថិភាពនិងសន្តិសុខ។

មាត្រា១៤៧ .- ការបញ្ចៀសការខូចខាតបរិស្ថាន

ម្ចាស់គម្រោងត្រូវបញ្ចៀសការបង្ក ឱ្យមានការបំពុល ឬការខូចខាតដល់បរិស្ថានធ្ងន់ធ្ងរដោយប្រើប្រាស់បច្ចេកវិទ្យាល្អៗដែលអាចស្វែងរកបាននិងការអនុវត្តល្អៗ ដើម្បីបង្កើនប្រសិទ្ធផលជាអតិបរមានៅពេលអនុវត្តសកម្មភាពឧស្សាហកម្ម និស្សារណកម្ម។

មាត្រា១៤៨ .- កាតព្វកិច្ចផ្តល់ឯកសារបញ្ជាក់ពីការប្រើប្រាស់ស្យានីតនិងបារត

ម្ចាស់គម្រោងនៃគម្រោងអាជីវកម្មរ៉ែមាសនិងប្រាក់ត្រូវផ្តល់ឯកសារទៅកាន់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ តាមរយៈក្រសួងស្ថាប័នទទួលបន្ទុករ៉ែ ដើម្បីបញ្ជាក់ថាស្យានីតនិងបារតដែលត្រូវប្រើប្រាស់នៅក្នុងប្រតិបត្តិការនៃការធ្វើអាជីវកម្មរ៉ែមាសនិងប្រាក់ត្រូវបានជារៀនៅក្នុងលក្ខណៈដែលមានសុវត្ថិភាព និងមិនប៉ះពាល់ដល់បរិស្ថាន។

មាត្រា១៤៩ .- លក្ខខណ្ឌតម្រូវសម្រាប់ការប្រើប្រាស់ស្យានីតនិងបារត

ការប្រើប្រាស់ស្យានីតនិងបារតនៅក្នុងគម្រោងអាជីវកម្មរ៉ែមាសនិងប្រាក់ ម្ចាស់គម្រោងត្រូវធានាថាកន្លែងដែលរក្សាទុកសារធាតុទាំងនេះត្រូវមានសុវត្ថិភាពនិងមិនប៉ះពាល់បរិស្ថាន ស្របតាមលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងស្យានីតនិងបារត។

ភាគីទី៣
កិច្ចគាំពារបរិស្ថាន
មាតិកាទី១
គោលការណ៍ទូទៅលើកិច្ចគាំពារបរិស្ថាន
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១៥០ .- គោលបំណង

មាតិកានេះ មានគោលបំណងពង្រឹងប្រសិទ្ធភាពគ្រប់គ្រងសំណល់ ការពារ ទប់ស្កាត់ និងកាត់បន្ថយការបំពុលបរិស្ថាន តាមរយៈការកំណត់គោលការណ៍ទូទៅអំពីភាពកិច្ចនិងការទទួលខុសត្រូវ និងការកំណត់វិធានការគ្រឹះសម្រាប់អនុវត្តលើការគ្រប់គ្រងសំណល់ សារធាតុបំពុល និងការបំពុលបរិស្ថាន សំដៅធានាកិច្ចគាំពារសុខភាពសាធារណៈ និងគុណភាពបរិស្ថាន។

ទំព័រ៣២០អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

មាត្រា១៥១ .- វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តលើសកម្មភាពគ្រប់គ្រងសំណល់ សារធាតុបំពុល និងសកម្មភាពការពារ ទប់ស្កាត់ និងកាត់បន្ថយការបំពុលបរិស្ថាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី២
ស្ថាប័នទទួលខុសត្រូវ

មាត្រា១៥២ .- ក្រសួងស្ថាប័នទទួលខុសត្រូវ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវលើកិច្ចគាំពារបរិស្ថានដើម្បីការពារ ទប់ស្កាត់ និងកាត់បន្ថយការបំពុលបរិស្ថាន និងការប៉ះពាល់ដល់សុខភាពសាធារណៈ។

មាត្រា១៥៣ .- តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត ផែនការសកម្មភាព និងគោលការណ៍ណែនាំនានាពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន។

ខ- សម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងផែនការសកម្មភាពនានាពាក់ព័ន្ធនឹងកិច្ចគាំពារ បរិស្ថាន ការអនុវត្តផែនការត្រៀមបង្ការនិងឆ្លើយតបបន្ទាន់ចំពោះករណីគ្រោះថ្នាក់បំពុលបរិស្ថាន និងការស្តារគុណភាពបរិស្ថាន។

គ- គ្រប់គ្រងទិន្នន័យគុណភាពបរិស្ថានទឹក ដី ខ្យល់ និងទិន្នន័យប្រភពបំពុល សំណល់ សារធាតុបំពុល រួមទាំងទិន្នន័យអេឡិចត្រូម៉ាញ៉េទិក។

ឃ- ចុះត្រួតពិនិត្យនិងធ្វើអធិការកិច្ចលើទីតាំងឬមធ្យោបាយនៃផលិតកម្ម អាជីវកម្មឬសេវាកម្មដែល ពាក់ព័ន្ធនឹងការបង្កើត ការផលិត ការប្រើប្រាស់ ការកែច្នៃ ការទាញយកធនធាន ការធ្វើប្រព្រឹត្តិកម្ម ការបញ្ចេញចោល និងការទុកដាក់ចុងក្រោយនៃសំណល់ សារធាតុបំពុល ការបញ្ចេញសំឡេង រំញ័រ និងអេឡិចត្រូម៉ាញ៉េទិក រួមទាំងការចុះត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងការបំពុលបរិស្ថាននៃ គម្រោងវិនិយោគ។

ង- ពិនិត្យនិងផ្តល់យោបល់បច្ចេកទេសពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថានលើគម្រោងវិនិយោគសាធារណៈ និងឯកជន។

ច- សិក្សា ស្រាវជ្រាវ និងវាយតម្លៃអំពីការសាយភាយសារធាតុគីមីពុលចូលក្នុងបរិស្ថាន វាយតម្លៃកម្រិត នៃការបំពុលបរិស្ថាននិងផលប៉ះពាល់ទៅលើសុខភាពសាធារណៈ។

ឆ- ផ្តល់ការណែនាំនិងការគាំទ្របច្ចេកទេស ធនធាន និងមធ្យោបាយនានាដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ពាក់ព័ន្ធនឹងការងារគ្រប់គ្រងសំរាម សំណល់រឹង ទឹកកខ្វក់ទីប្រជុំជន និងធ្វើការត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ជ- គ្រប់គ្រងការផ្តល់សេវាសាធារណៈពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាននិងសេវាមន្ទីរពិសោធន៍បរិស្ថាន។

ឈ- ជំរុញនិងលើកទឹកចិត្តការវិនិយោគ និងការកៀរគរធនធានសម្រាប់ការងារកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងសំណល់ ការទប់ស្កាត់ការបំពុលបរិស្ថាន និងការស្តារគុណភាពបរិស្ថាន។

ញ- អភិវឌ្ឍសមត្ថភាពជំនាញកិច្ចគាំពារបរិស្ថានដល់មន្ទីរបរិស្ថានរាជធានី ខេត្ត អង្គភាពពាក់ព័ន្ធនឹងរដ្ឋបាល ថ្នាក់ក្រោមជាតិ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៣២១

ជ- បំពេញការកិច្ចជាអង្គភាពបង្គោលជាតិ ជំរុញនិងសម្របសម្រួលការអនុវត្តលិខិតបកណ៍អន្តរជាតិ និងការងារសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងវិស័យកិច្ចការបរិស្ថាន។

ជំពូកទី៣
ភាគព្វកិច្ចគ្រប់គ្រងសំណល់

មាត្រា១៥៤ .- ភាគព្វកិច្ចគ្រប់គ្រងសំណល់

ប្រជាពលរដ្ឋគ្រប់រូបមានភាគព្វកិច្ចទទួលខុសត្រូវលើការគ្រប់គ្រងសំណល់របស់ខ្លួន តាមការកំណត់របស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា១៥៥ .- ភាគព្វកិច្ចបង់ថ្លៃសេវាសំណល់

ប្រជាពលរដ្ឋគ្រប់រូបមានភាគព្វកិច្ចបង់ថ្លៃសេវាប្រមូល ដឹកជញ្ជូន ប្រព្រឹត្តិកម្ម និងទុកដាក់សំណល់តាមការកំណត់របស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា១៥៦ .- អនុលោមភាពស្តង់ដារបញ្ចេញសំណល់

១- ការបញ្ចេញចោលសំណល់ឬសារធាតុបំពុលទៅក្នុងបរិស្ថាន ត្រូវមានអនុលោមភាពតាមស្តង់ដារបញ្ចេញសំណល់។

២- បុគ្គលដែលធ្វើសកម្មភាពផ្ទាល់ បញ្ជា ឬផ្តល់ការសម្របសម្រួលឱ្យមានការប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ ត្រូវទទួលខុសត្រូវចំពោះអំពើល្មើសនេះ។

មាត្រា១៥៧ .- ការដាក់តម្លៃលើអ្នកប្រើប្រាស់

១- ការប្រើប្រាស់ផលិតផលឬសម្ភារៈដែលអាចបង្កឱ្យមានហានិភ័យដល់បរិស្ថាន សុខភាពសាធារណៈ ឬមិនអាចកែច្នៃបានក្រោយពេលក្លាយជាសំណល់តម្រូវឱ្យមានការដាក់តម្លៃលើអ្នកប្រើប្រាស់ផលិតផលឬសម្ភារៈទាំងនោះ។

២- ថវិកាដែលប្រមូលបានពីការដាក់តម្លៃលើអ្នកប្រើប្រាស់ ត្រូវប្រើសម្រាប់គោលដៅធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំណល់និងការទាញយកធនធានពីសំណល់។

៣- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវទទួលខុសត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត និងជំរុញការអនុវត្តការប្រមូល និងការគ្រប់គ្រងថវិកានៃការដាក់តម្លៃលើអ្នកប្រើប្រាស់ ដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ ខាងលើនេះ។

មាត្រា១៥៨ .- ការទទួលខុសត្រូវរបស់អ្នកផលិត នាំចូល ឬផ្គត់ផ្គង់ផ្តាច់មុខ

បុគ្គលដែលផលិត នាំចូល ឬផ្គត់ផ្គង់ផ្តាច់មុខនូវឧបករណ៍ គ្រឿងបរិក្ខារ ឬសម្ភារៈប្រើប្រាស់ ដែលត្រូវបានចាត់ទុកជាសំណល់គ្រោះថ្នាក់ពេលក្លាយទៅជាសំណល់ត្រូវទទួលខុសត្រូវរៀបចំនិងអនុវត្តប្រព័ន្ធប្រមូលយកសំណល់នៃឧបករណ៍ គ្រឿងបរិក្ខារ ឬសម្ភារៈប្រើប្រាស់ត្រឡប់ទៅប្រទេសដើមវិញ ឬធ្វើប្រព្រឹត្តិកម្ម កែច្នៃ កម្ទេចចោលនៅក្នុងស្រុកដោយមិនបង្កគ្រោះថ្នាក់បរិស្ថានឬសុខភាពសាធារណៈ។

មាត្រា១៥៩ .- ការហាមឃាត់ការបោះចោលសំណល់ល្មើសច្បាប់

១- ហាមឃាត់ការបោះចោល បញ្ចេញចោល ឬកម្ទេចចោលសំណល់ល្មើសនឹងបទប្បញ្ញត្តិនៃក្រមនេះ ច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ទំព័រ៣២២អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

២- បុគ្គលដែលធ្វើសកម្មភាពផ្ទាល់ បញ្ជា ឬផ្តល់ការសម្របសម្រួលឱ្យមានការប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ ត្រូវទទួលខុសត្រូវចំពោះអំពើល្មើសនេះ។

ជំពូកទី៤
ការទទួលខុសត្រូវលើការបំពុលបរិស្ថាន

មាត្រា១៦០ .- កាតព្វកិច្ចមិនបង្កការបំពុលបរិស្ថាន

បុគ្គលមិនត្រូវធ្វើសកម្មភាពដែលនាំឱ្យមានការបំពុលបរិស្ថាន ទឹក ដី ខ្យល់ ឬបង្កឱ្យមានផលប៉ះពាល់ដល់សុខភាពឬផលប្រយោជន៍សាធារណៈឬឯកជន។

មាត្រា១៦១ .- កាតព្វកិច្ចមិនបង្កការរំខានដោយសំឡេង រ៉ាំរ៉ៃ ឬក្លិន

បុគ្គលមិនត្រូវធ្វើសកម្មភាពបញ្ចេញសំឡេង រ៉ាំរ៉ៃ ឬក្លិន ដែលបង្កឱ្យមានការរំខានដល់ការរស់នៅបង្កឱ្យមានផលប៉ះពាល់ដល់សុខភាព ផលប្រយោជន៍សាធារណៈឬឯកជន។

មាត្រា១៦២ .- ការទទួលខុសត្រូវលើបញ្ហាការបំពុលបរិស្ថានឬការបង្កគ្រោះថ្នាក់

បុគ្គលដែលបង្កបញ្ហាបំពុលបរិស្ថានត្រូវទទួលខុសត្រូវលើសំណងផលប៉ះពាល់ដល់សុខភាព អាយុជីវិត ឬការខូចខាតទ្រព្យសម្បត្តិ ដែលបណ្តាលមកពីឥទ្ធិពលនៃបញ្ហាបំពុលបរិស្ថាន និងត្រូវទទួលខុសត្រូវលើសំណងការខូចខាតបរិស្ថាន និងការស្តារការបំពុលបរិស្ថាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា១៦៣ .- កាតព្វកិច្ចបង់ថ្លៃបំពុលបរិស្ថាន

បុគ្គលដែលធ្វើសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្មរបស់ខ្លួនបង្កឱ្យមានកំណើនបន្ទុកសារធាតុបំពុលនៅក្នុងបរិស្ថានតាមរយៈការផលិតឬប្រើប្រាស់សារធាតុគ្រោះថ្នាក់ ឬការបញ្ចេញចោលសំណល់ ត្រូវមានកាតព្វកិច្ចបង់ថ្លៃបំពុលបរិស្ថាន។

មាត្រា១៦៤ .- ការបង់ប្រាក់កក់សំណល់

ការប្រើប្រាស់ផលិតផល ឧបករណ៍ គ្រឿងបរិក្ខារឬសម្ភារៈប្រើប្រាស់ ដែលក្រោយពេលប្រើប្រាស់រួចឬលែងប្រើបានក្លាយជាសំណល់គ្រោះថ្នាក់ តម្រូវឱ្យមានការបង់ប្រាក់កក់សំណល់ដោយអ្នកប្រើប្រាស់ និងដែលត្រូវសងត្រឡប់នៅពេលយកសំណល់មកប្តូរ។

មាត្រា១៦៥ .- ការគ្រប់គ្រងនិងប្រើប្រាស់ថវិកាពីការបង់ថ្លៃបំពុលបរិស្ថាន

១- ថវិកាដែលប្រមូលបានពីការបង់ថ្លៃបំពុលបរិស្ថាន ត្រូវប្រើប្រាស់សម្រាប់គោលដៅសិក្សាស្រាវជ្រាវ និងការធ្វើឱ្យប្រសើរឡើងនូវគុណភាពបរិស្ថាន ឬការស្តារបរិស្ថានដែលទទួលរងការបំពុល។

២- ការគ្រប់គ្រងនិងការប្រើប្រាស់ថវិកាពីការបង់ថ្លៃបំពុលបរិស្ថាន ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៣២៣

ជំពូកទី៥
វិធានការត្រួតពិនិត្យការបំពុលបរិស្ថាន
ផ្នែកទី១
ស្តង់ដារគាំពារបរិស្ថាន

មាត្រា១៦៦ .- ស្តង់ដារគាំពារបរិស្ថាន

១- ស្តង់ដារគាំពារបរិស្ថាន មានជាអាទិ៍៖
ក- ស្តង់ដារគុណភាពបរិស្ថាន។
ខ- ស្តង់ដារបញ្ចេញសំណល់។
គ- ស្តង់ដារសំឡេងនិងរំញ័រ។
ឃ- ស្តង់ដារសារធាតុគ្រោះថ្នាក់នៅក្នុងផលិតផល។
ង- ស្តង់ដារពាក់ព័ន្ធកិច្ចគាំពារបរិស្ថានផ្សេងទៀត ស្របតាមការអភិវឌ្ឍបច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍។
២- ស្តង់ដារគាំពារបរិស្ថានដូចបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា១៦៧ .- ស្តង់ដារគុណភាពបរិស្ថាន

ត្រូវចាត់ទុកជាស្តង់ដារគុណភាពបរិស្ថាន ចំពោះស្តង់ដារពាក់ព័ន្ធនឹងគុណភាពទឹកសាធារណៈ គុណភាពដី គុណភាពខ្យល់បរិយាកាសនិងស្តង់ដារគុណភាពខ្យល់ក្នុងអគារ ដែលកំណត់នូវកម្រិតបរិមាណសារធាតុគីមី ឬសារធាតុបំពុលដែលមិនបង្កហានិភ័យដល់សុខភាពសាធារណៈ សម្រាប់ធ្វើការវាយតម្លៃស្ថានភាពគុណភាពទឹក ដី និងខ្យល់។

មាត្រា១៦៨ .- ស្តង់ដារបញ្ចេញសំណល់

ត្រូវចាត់ទុកជាស្តង់ដារបញ្ចេញសំណល់ចំពោះស្តង់ដារពាក់ព័ន្ធការបញ្ចេញសំណល់រាវ ឬទឹកកខ្វក់ ការបញ្ចេញសារធាតុបំពុលខ្យល់ ការបញ្ចេញសំណល់រឹង ការបញ្ចេញសារធាតុឬសំណល់គ្រោះថ្នាក់ ការបញ្ចេញវិទ្យុសកម្ម ដែលកំណត់នូវកម្រិតបរិមាណសារធាតុគីមី ឬសារធាតុបំពុលអាចអនុញ្ញាតឱ្យបញ្ចេញចូលទៅក្នុងបរិស្ថាន ដែលមិនបង្កហានិភ័យដល់បរិស្ថាននិងសុខភាពសាធារណៈ ដោយត្រូវធ្វើការផ្ទៀងផ្ទាត់និងវាយតម្លៃស្របតាមស្តង់ដារដូចមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា១៦៩ .- ស្តង់ដារសំឡេងនិងរំញ័រ

ត្រូវចាត់ទុកជាស្តង់ដារសំឡេងនិងរំញ័រ ចំពោះស្តង់ដារពាក់ព័ន្ធការបញ្ចេញសំឡេងនិងរំញ័រ ដែលកំណត់នូវកម្រិតសំឡេងនិងកម្រិតរំញ័រអាចអនុញ្ញាតឱ្យបញ្ចេញក្នុងអគារឬទីចំហរ ដែលមិនបង្កការរំខានដល់ការរស់នៅ និងមិនបង្កគ្រោះថ្នាក់ដល់សុខភាព ឬការខូចខាតទ្រព្យសម្បត្តិ និងសម្រាប់ការផ្ទៀងផ្ទាត់វាយតម្លៃការអនុវត្តច្បាប់។

មាត្រា១៧០ .- ស្តង់ដារសារធាតុគ្រោះថ្នាក់នៅក្នុងផលិតផល

ត្រូវចាត់ទុកជាស្តង់ដារសារធាតុគ្រោះថ្នាក់នៅក្នុងផលិតផល ចំពោះស្តង់ដារពាក់ព័ន្ធគុណភាពផលិតផលដែលអាចមានផ្ទុកឬប្រឡាក់សារធាតុគ្រោះថ្នាក់ ក្នុងកម្រិតអាចអនុញ្ញាតដែលមិនបង្កហានិភ័យដល់សុខភាពអ្នកប្រើប្រាស់និងបរិស្ថានសម្រាប់ការផ្ទៀងផ្ទាត់វាយតម្លៃការអនុវត្តច្បាប់។

មាត្រា១៧១ .- ការធ្វើបច្ចុប្បន្នកម្មស្តង់ដារគាំពារបរិស្ថាន

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវធ្វើបច្ចុប្បន្នកម្មស្តង់ដារគាំពារបរិស្ថានឱ្យស្របទៅតាមស្ថានភាពកែចម្រើនសេដ្ឋកិច្ចជាតិ ស្ថានភាពបរិស្ថានជាតិឬលក្ខខណ្ឌតម្រូវនានា និងផលប្រយោជន៍សាធារណៈ។

ទំព័រ៣២៤អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

មាត្រា១៧២ .- សិទ្ធិទទួលបានព័ត៌មានអំពីស្តង់ដារគាំពារបរិស្ថាន

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំប្រព័ន្ធទិន្នន័យស្តង់ដារគាំពារបរិស្ថានឱ្យគ្រប់ភាគីពាក់ព័ន្ធ និងសាធារណជនអាចស្វែងរក និងទទួលបានស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

ផ្នែកទី២
លិខិតអនុញ្ញាតសំណាល់

មាត្រា១៧៣ .- ការស្នើសុំនិងប្រភេទនៃលិខិតអនុញ្ញាតសំណាល់

១- បុគ្គលដែលមានបំណងបញ្ចេញសំណល់ឬធ្វើអាជីវកម្ម ត្រូវមានការអនុញ្ញាតពីក្រសួងស្ថាប័នទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

២- ប្រភេទនៃលិខិតអនុញ្ញាតសំណល់មានដូចខាងក្រោម៖

ក- លិខិតអនុញ្ញាតបញ្ចេញសំណល់ មានជាអាទិ៍ លិខិតអនុញ្ញាតបញ្ចេញសំណល់រឹង លិខិតអនុញ្ញាតបញ្ចេញសំណល់គ្រោះថ្នាក់ លិខិតអនុញ្ញាតបញ្ចេញសំណល់រាវ លិខិតអនុញ្ញាតបញ្ចេញសារធាតុបំពុលខ្យល់ លិខិតអនុញ្ញាតបញ្ចេញសំឡេង និងលិខិតអនុញ្ញាតបញ្ចេញកាំរ៉ៃ។

ខ- លិខិតអនុញ្ញាតអាជីវកម្មសំណល់ មានជាអាទិ៍ លិខិតអនុញ្ញាតធ្វើសេវាកម្មសំណល់ ឬលិខិតអនុញ្ញាតធ្វើអាជីវកម្មប្រមូលសំណល់ លិខិតអនុញ្ញាតដឹកជញ្ជូនសំណល់ លិខិតអនុញ្ញាតស្តុកទុកសំណល់ លិខិតអនុញ្ញាតធ្វើអាជីវកម្មកែច្នៃនិងទាញយកធនធានពីសំណល់ លិខិតអនុញ្ញាតធ្វើប្រព្រឹត្តិកម្មឬលិខិតអនុញ្ញាតការទុកដាក់សំណល់ចុងក្រោយ។

៣- នីតិវិធីទាក់ទងនឹងការស្នើសុំលិខិតអនុញ្ញាតសំណល់ ដូចមានចែងនៅក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២ នៃមាត្រានេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

៤- ទោះបីជាមានបញ្ញត្តក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២ នៃមាត្រានេះក៏ដោយ ចំពោះការបញ្ចេញសំណល់ពីទីតាំងរស់នៅប្រចាំថ្ងៃជាលក្ខណៈគ្រួសារដែលមិនមានគោលបំណងធ្វើអាជីវកម្ម មិនតម្រូវឱ្យសុំលិខិតអនុញ្ញាតឡើយ ហើយត្រូវអនុវត្តតាមគោលការណ៍ណែនាំរបស់ក្រសួងទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា១៧៤ .- លក្ខខណ្ឌសម្រាប់ការផ្តល់លិខិតអនុញ្ញាតសំណល់

លិខិតអនុញ្ញាតសំណល់អាចផ្តល់ឱ្យលុះត្រាតែ៖

ក- មានសម្ភារៈ បរិក្ខារ និងមធ្យោបាយត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសសម្រាប់ការបញ្ចេញសំណល់ ឬសម្រាប់ការធ្វើសេវាកម្ម ឬអាជីវកម្មប្រមូល ដឹកជញ្ជូន កែច្នៃ ទាញយកធនធាន ធ្វើប្រព្រឹត្តិកម្ម ឬទីលានទុកដាក់សំណល់ ដែលជានាមិនបង្កឱ្យមានការបំពុលបរិស្ថាន។

ខ- មានអនុលោមភាពតាមស្តង់ដារបញ្ចេញសំណល់ ស្របតាមលិខិតបទដ្ឋានគតិយុត្តដែលកំណត់នៅក្រោមបទប្បញ្ញត្តិនៃក្រមនេះ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

គ- គោរពតាមលក្ខខណ្ឌនៃវិធានការទប់ស្កាត់ការបំពុលបរិស្ថាន ដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ឃ- បានបង់កម្រៃសេវាសាធារណៈសម្រាប់ការផ្តល់លិខិតអនុញ្ញាតសំណល់ ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងស្ថាប័នមានសមត្ថកិច្ច។

មាត្រា១៧៥ .- ការព្យួរឬការដកហូតលិខិតអនុញ្ញាតសំណល់

លិខិតអនុញ្ញាតសំណល់នឹងត្រូវព្យួរបណ្តោះអាសន្នឬដកហូតជាស្ថាពរ ប្រសិនបើ៖

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៣២៥

ក- ប្រើប្រាស់សម្ភារៈ បរិក្ខារ និងមធ្យោបាយសម្រាប់ការបញ្ចេញសំណល់ និងការធ្វើអាជីវកម្មប្រមូលដឹកជញ្ជូនកែច្នៃ ទាញយកធនធានធ្វើប្រព្រឹត្តិកម្ម ឬទីលានទុកដាក់សំណល់មិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។

ខ- មិនបានអនុវត្តត្រឹមត្រូវតាមស្តង់ដារបរិស្ថាននិងវិធានសុវត្ថិភាពបរិស្ថាន។

គ- មានការធ្វេសប្រហែសឬបង្កបទល្មើសក្នុងការគ្រប់គ្រងសំណល់បង្កឱ្យមានការបំពុលបរិស្ថានឬគ្រោះថ្នាក់ដល់សុខភាព។

ឃ- ខកខានមិនបានអនុវត្តលក្ខខណ្ឌតម្រូវ ដែលកំណត់ក្នុងលិខិតអនុញ្ញាតសំណល់។

ផ្នែកទី៣
ការគ្រប់គ្រងការបំពុលបរិស្ថាន

មាត្រា១៧៦ .- ការគ្រប់គ្រងការបំពុលបរិស្ថាន

បុគ្គលឬម្ចាស់ទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ដែលបង្កើតនិងបញ្ចេញសំណល់ សារធាតុបំពុល សំឡេង ឬរំញ័រត្រូវទទួលខុសត្រូវ៖

ក- បំពាក់សម្ភារៈ បរិក្ខារ និងមធ្យោបាយសម្រាប់ការគ្រប់គ្រង និងការបញ្ចេញសំណល់ សារធាតុបំពុល សំឡេង ឬរំញ័រឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងស្របតាមលិខិតបទដ្ឋានគតិយុត្ត ដែលកំណត់ដោយក្រមនេះ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ខ- ដំណើរការសម្ភារៈ បរិក្ខារ និងមធ្យោបាយគ្រប់គ្រងសំណល់ សារធាតុបំពុល សំឡេង ឬរំញ័រឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងការបញ្ចេញឱ្យឆ្លើយតបទៅនឹងស្តង់ដារបញ្ចេញសំណល់។

គ- រៀបចំឱ្យមានអ្នកឯកទេសឬបុគ្គលិកបច្ចេកទេសឱ្យទទួលខុសត្រូវការងារគ្រប់គ្រងការបំពុលបរិស្ថាន និងដំណើរការសម្ភារៈ បរិក្ខារ និងមធ្យោបាយសម្រាប់ការគ្រប់គ្រង និងការបញ្ចេញសំណល់ សារធាតុបំពុលសំឡេង ឬរំញ័ររបស់ទីតាំងផ្ទាល់។

មាត្រា១៧៧ .- ការទទួលស្គាល់អ្នកឯកទេសឬបុគ្គលិកបច្ចេកទេសគ្រប់គ្រងការបំពុលបរិស្ថាន

១- អ្នកឯកទេសឬបុគ្គលិកបច្ចេកទេស ដែលត្រូវចាត់តាំងឱ្យទទួលខុសត្រូវការងារគ្រប់គ្រងការបំពុលបរិស្ថាន និងដំណើរការសម្ភារៈ បរិក្ខារ និងមធ្យោបាយសម្រាប់ការគ្រប់គ្រងនិងការបញ្ចេញសំណល់ សារធាតុបំពុលសំឡេង ឬរំញ័រ ដូចមានចែងក្នុងចំណុច គ មាត្រា១៧៦(ការគ្រប់គ្រងការបំពុលបរិស្ថាន)នៃក្រមនេះ ត្រូវមានការទទួលស្គាល់ជាផ្លូវការពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

២- នីតិវិធីនៃការទទួលស្គាល់ជាផ្លូវការដល់អ្នកឯកទេសឬបុគ្គលិកបច្ចេកទេសដែលត្រូវចាត់តាំងឱ្យទទួលខុសត្រូវការងារគ្រប់គ្រងការបំពុលបរិស្ថាន និងដំណើរការសម្ភារៈ បរិក្ខារ និងមធ្យោបាយសម្រាប់ការគ្រប់គ្រង និងការបញ្ចេញសំណល់ សារធាតុបំពុល សំឡេង ឬរំញ័រ ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ផ្នែកទី៤
ការអនុវត្តស្ម័យត្រួតពិនិត្យនិងស្ម័យរាយការណ៍

មាត្រា១៧៨ .- ការអនុវត្តស្ម័យត្រួតពិនិត្យការបំពុលបរិស្ថាន

បុគ្គលឬម្ចាស់ទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ដែលការបញ្ចេញសំណល់អាចបង្កហានិភ័យបំពុលបរិស្ថានក្នុងកម្រិតខ្ពស់ ត្រូវអនុវត្តស្ម័យត្រួតពិនិត្យការបំពុលបរិស្ថាននៅក្នុងទីតាំងរបស់ខ្លួន ដោយត្រូវអនុលោមតាមលិខិតបទដ្ឋានគតិយុត្តដែលកំណត់ដោយក្រមនេះ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ទំព័រ៣២៦អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

មាត្រា១៧៩ .- ការអនុវត្តស្ថិយរាយការណ៍អំពីការគ្រប់គ្រងសារធាតុគ្រោះថ្នាក់និងសំណល់គ្រោះថ្នាក់

បុគ្គលឬម្ចាស់ទីតាំងផលិត ធ្វើអាជីវកម្ម ឬសេវាកម្មដែលផលិតឬប្រើប្រាស់សារធាតុគ្រោះថ្នាក់ ឬពាក់ព័ន្ធការបង្កើតសំណល់គ្រោះថ្នាក់ត្រូវអនុវត្តវិធានការស្ថិយរាយការណ៍អំពីការគ្រប់គ្រងសារធាតុគ្រោះថ្នាក់ និងសំណល់គ្រោះថ្នាក់នៅក្នុងទីតាំងរបស់ខ្លួន ដោយត្រូវអនុលោមតាមការតម្រូវរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

មាត្រា១៨០ .- ការរាយការណ៍អំពីការសាយភាយនិងសារធាតុបំពុលចូលទៅក្នុងបរិស្ថាន

១- បុគ្គលឬម្ចាស់ទីតាំងផលិត ឬធ្វើអាជីវកម្ម ដែលនៅក្នុងសកម្មភាពផលិតកម្ម ឬអាជីវកម្មរបស់ខ្លួនបង្កឱ្យមានការសាយភាយ និងការបន្លាស់ទីសារធាតុបំពុលចូលទៅក្នុងបរិស្ថាន ត្រូវផ្តល់របាយការណ៍ទិន្នន័យភ្លាមៗអំពីការសាយភាយ និងការបន្លាស់ទីសារធាតុបំពុលមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

២- ប្រភេទទីតាំងផលិតកម្ម ឬអាជីវកម្ម ដែលជាប់កាតព្វកិច្ចផ្តល់របាយការណ៍ទិន្នន័យភ្លាមៗអំពីការសាយភាយ និងការបន្លាស់ទីសារធាតុបំពុលចូលក្នុងបរិស្ថាន ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា១៨១ .- សិទ្ធិទទួលបានព័ត៌មានពីប្រព័ន្ធទិន្នន័យការសាយភាយនិងការបន្លាស់ទីសារធាតុបំពុល

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវដាក់ឱ្យសាធារណជនអាចចូលមើលឬទាញយកព័ត៌មានពីប្រព័ន្ធទិន្នន័យពាក់ព័ន្ធការត្រួតពិនិត្យការបំពុលបរិស្ថាន និងការសាយភាយនិងការបន្លាស់ទីសារធាតុបំពុលស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

ផ្នែកទី៥
ការឆ្លើយតបបន្ទាន់ករណីគ្រោះឧបទ្ទវហេតុបង្កការបំពុលបរិស្ថាន

មាត្រា១៨២ .- យន្តការជាតិគ្រប់គ្រងការឆ្លើយតបបន្ទាន់ករណីគ្រោះឧបទ្ទវហេតុបង្កការបំពុលបរិស្ថាន

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ចនិងយន្តការពាក់ព័ន្ធ ត្រូវរៀបចំបង្កើតយន្តការជាតិការគ្រប់គ្រងការឆ្លើយតបបន្ទាន់ករណីគ្រោះឧបទ្ទវហេតុបង្កការបំពុលបរិស្ថាន ដែលមានការកិច្ចដូចខាងក្រោម៖

ក- ធ្វើការកំណត់ហានិភ័យការបំពុលបរិស្ថាន ឬការប៉ះពាល់សុខភាពសាធារណៈនៅតំបន់ដែលងាយទទួលរងការបំពុលពីសកម្មភាពអភិវឌ្ឍ ឬពីធម្មជាតិ។

ខ- លើកស្នើវិធានការទប់ស្កាត់ហានិភ័យការបំពុលបរិស្ថាន ឬការប៉ះពាល់សុខភាពសាធារណៈ។

គ- ធ្វើការវាយតម្លៃផលប៉ះពាល់ដល់សុខភាពសាធារណៈ និងការខូចខាតបរិស្ថានពីគ្រោះឧបទ្ទវហេតុដែលបង្កឱ្យមានការសាយភាយសារធាតុពុល ឬសារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថាន។

ឃ- កំណត់និងសម្របសម្រួលការអនុវត្តវិធានការឆ្លើយតបនិងការសង្គ្រោះបន្ទាន់ នៅពេលកើតមានគ្រោះឧបទ្ទវហេតុបង្កការបំពុលបរិស្ថាន។

២- ការបង្កើតយន្តការជាតិគ្រប់គ្រងការឆ្លើយតបបន្ទាន់ករណីគ្រោះឧបទ្ទវហេតុបង្កការបំពុលបរិស្ថាន ដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៣២៧

មាត្រា១៨៣ .- ផែនការឆ្លើយតបបន្ទាន់ករណីគ្រោះឧបទ្វវហេតុបង្កការបំពុលបរិស្ថាន

បុគ្គលឬម្ចាស់ទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ដែលត្រូវបានកំណត់ថាអាចបង្កហានិភ័យបំពុលបរិស្ថានក្នុងកម្រិតខ្លាំង ត្រូវរៀបចំផែនការឆ្លើយតបបន្ទាន់ សម្រាប់ករណីកើតមានគ្រោះឧបទ្វវហេតុបង្កការបំពុលបរិស្ថានពីសកម្មភាពផលិតកម្ម អាជីវកម្មឬសេវាកម្មរបស់ខ្លួនតាមការតម្រូវរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាតិកាទី២
ការត្រួតពិនិត្យការសាយភាយសារធាតុគ្រោះថ្នាក់
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១៨៤ .- គោលបំណង

មាតិកានេះ មានគោលបំណងត្រួតពិនិត្យការសាយភាយសារធាតុគ្រោះថ្នាក់តាមរយៈការដាក់ចេញនូវវិធានការនានាដើម្បីពង្រឹងការគ្រប់គ្រងសារធាតុគ្រោះថ្នាក់តាមវិធានសុវត្ថិភាពបរិស្ថាន សំដៅធានាបានកិច្ចគាំពារបរិស្ថានការអភិរក្សជីវៈចម្រុះ និងកិច្ចគាំពារសុខភាពសាធារណៈ។

មាត្រា១៨៥ .- វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តលើសកម្មភាពនៃការផលិត ការនាំចូល ការចែកចាយ ឬការប្រើប្រាស់សារធាតុគ្រោះថ្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី២
ស្ថាប័នទទួលខុសត្រូវ

មាត្រា១៨៦ .- ក្រសួងស្ថាប័នទទួលខុសត្រូវ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវក្នុងការដឹកនាំត្រួតពិនិត្យលើការគ្រប់គ្រងនិងការសាយភាយសារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថាន។

មាត្រា១៨៧ .- តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាព សម្រាប់គ្រប់គ្រងការសាយភាយសារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថាន និងសម្រាប់ការឆ្លើយតបបន្ទាន់ចំពោះករណីគ្រោះឧបទ្វវហេតុនៃការឆេះ ការផ្ទុះ ការកំពប់ ការលេចធ្លាយសារធាតុគ្រោះថ្នាក់។

ខ- រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសារធាតុគ្រោះថ្នាក់ក្នុងផលិតផល សម្រាប់ជំរុញការត្រួតពិនិត្យការសាយភាយនិងបញ្ហាបំពុលបរិស្ថានពាក់ព័ន្ធនឹងសារធាតុគ្រោះថ្នាក់។

គ- រៀបចំបញ្ជីប្រភេទសារធាតុគ្រោះថ្នាក់ដែលត្រូវហាមឃាត់ និងបញ្ជីប្រភេទសារធាតុគ្រោះថ្នាក់ដែលអនុញ្ញាតឱ្យមានការផលិត ការនាំចូល ការចែកចាយ ឬការប្រើប្រាស់ដោយមានលក្ខខណ្ឌ។

ឃ- រៀបចំនិងគ្រប់គ្រងទិន្នន័យសារធាតុគ្រោះថ្នាក់ដែលផលិត នាំចូល ចែកចាយ និងប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ង- រៀបចំគោលការណ៍ណែនាំបច្ចេកទេសគ្រប់គ្រងការសោយកាយសារធាតុគ្រោះថ្នាក់ និងឆ្លើយតបបន្ទាន់ សម្រាប់ទប់ស្កាត់និងកាត់បន្ថយការសោយកាយសារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថាន ដែលត្រូវអនុវត្តចំពោះទីតាំង ឬសកម្មភាពដែលពាក់ព័ន្ធការផលិត ការនាំចូល ការដឹកជញ្ជូន ការស្តុកទុក ការចែកចាយ ការប្រើប្រាស់ និងការបោះបង់ចោលសារធាតុគ្រោះថ្នាក់។

ច- ចុះត្រួតពិនិត្យទីតាំង ឬសកម្មភាពពាក់ព័ន្ធការផលិត ការនាំចូល ការដឹកជញ្ជូន ការស្តុកទុក ការចែកចាយ ការប្រើប្រាស់ និងការបោះបង់ចោលសារធាតុគ្រោះថ្នាក់។

ឆ- សិក្សាស្រាវជ្រាវពីកម្រិតសោយកាយសារធាតុគ្រោះថ្នាក់នៅក្នុងបរិស្ថាន ក្នុងសំណាកជីវសាស្ត្រ និងក្នុងផលិតផលអាហារ សម្ភារៈប្រើប្រាស់ ឬសម្ភារៈក្មេងលេង។

ជ- បំពេញភារកិច្ចជាស្ថាប័នបង្គោលជាតិនៃលិខិតបកណ៍អន្តរជាតិពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគ្រោះថ្នាក់ដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

មាត្រា១៨៨ .- ការសិក្សាស្រាវជ្រាវ តាមដាន និងត្រួតពិនិត្យការសោយកាយសារធាតុគ្រោះថ្នាក់

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវសិក្សាស្រាវជ្រាវនិងត្រួតពិនិត្យទីតាំងផលិត ស្តុក និងប្រើប្រាស់សារធាតុគ្រោះថ្នាក់ និងផលិតផលដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដើម្បីជំរុញការអនុវត្តវិធានការទប់ស្កាត់ការសោយកាយឬកាត់បន្ថយហានិភ័យដល់សុខភាពសាធារណៈនិងបរិស្ថាន។

២- លទ្ធផលនៃការសិក្សាស្រាវជ្រាវនិងត្រួតពិនិត្យការសោយកាយសារធាតុគ្រោះថ្នាក់ត្រូវផ្សព្វផ្សាយ និងផ្តល់ព័ត៌មានដល់សាធារណជន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

ជំពូកទី៣
ការចុះបញ្ជីកាសារធាតុគ្រោះថ្នាក់និងផលិតផលសារធាតុគីមី ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់

មាត្រា១៨៩ .- ការចុះបញ្ជីកាសារធាតុគ្រោះថ្នាក់

១- បុគ្គលអ្នកផលិត អ្នកនាំចូល ឬអ្នកចែកចាយសារធាតុគ្រោះថ្នាក់ឬផលិតផលសារធាតុគីមី ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ត្រូវធ្វើការចុះបញ្ជីកានៅក្រសួងស្ថាប័នទទួលបន្ទុកតាមវិស័យ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

២- ប្រភេទសារធាតុគ្រោះថ្នាក់ ឬផលិតផលសារធាតុគីមីមានផ្ទុកសារធាតុគ្រោះថ្នាក់ដែលត្រូវធ្វើការចុះបញ្ជីកាពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា១៩០ .- ការផ្តល់ព័ត៌មានការចុះបញ្ជីកាសារធាតុគ្រោះថ្នាក់

បុគ្គលអ្នកផលិត អ្នកនាំចូល ឬអ្នកចែកចាយសារធាតុគ្រោះថ្នាក់ឬផលិតផលសារធាតុគីមីដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដែលបានធ្វើការចុះបញ្ជីកាដូចមានចែងក្នុងមាត្រា១៨៩(ការចុះបញ្ជីកាសារធាតុគ្រោះថ្នាក់) នៃក្រមនេះ ត្រូវផ្តល់ច្បាប់ចម្លងនៃការចុះបញ្ជីកាមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ សម្រាប់គោលបំណងនៃការរៀបចំទិន្នន័យសារធាតុគ្រោះថ្នាក់ ការអង្កេតតាមដាន ការវាយតម្លៃពីហានិភ័យ និងការចាត់វិធានការបង្ការ ឬឆ្លើយតបនឹងហានិភ័យបង្កដោយសារធាតុគ្រោះថ្នាក់ និងការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងសារធាតុគ្រោះថ្នាក់ជូនសាធារណជន។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៣២៩

មាត្រា១៩១ .ـ ការចុះបញ្ជីការផលិតផលឬសម្ភារៈប្រើប្រាស់និងសម្ភារៈក្មេងលេងដែលមានផ្ទុកសារធាតុគ្រោះថ្នាក់

១- បុគ្គលអ្នកផលិត អ្នកនាំចូល ឬអ្នកចែកចាយផលិតផល ឬសម្ភារៈប្រើប្រាស់ និងសម្ភារៈក្មេងលេងដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដែលមានចែងក្នុងបទប្បញ្ញត្តិនៃក្រមនេះ ត្រូវធ្វើការចុះបញ្ជីការនៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

២- នីតិវិធីនៃការចុះបញ្ជីការផលិតផល សម្ភារៈប្រើប្រាស់ និងសម្ភារៈក្មេងលេង ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា១៩២ .ـ ការបដិសេធការស្នើសុំចុះបញ្ជីការ

ក្រសួងស្ថាប័នទទួលបន្ទុកតាមវិស័យ និងក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវធ្វើការបដិសេធការស្នើសុំចុះបញ្ជីការសារធាតុគ្រោះថ្នាក់ និងផលិតផល សម្ភារៈប្រើប្រាស់ ឬសម្ភារៈក្មេងលេង ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដែលមានចែងក្នុងមាត្រា១៨៩(ការចុះបញ្ជីការសារធាតុគ្រោះថ្នាក់) និងមាត្រា១៩១(ការចុះបញ្ជីការផលិតផលឬសម្ភារៈប្រើប្រាស់ និងសម្ភារៈក្មេងលេងដែលមានផ្ទុកសារធាតុគ្រោះថ្នាក់) នៃក្រមនេះ ប្រសិនបើ៖

ក- សារធាតុគ្រោះថ្នាក់ និងផលិតផល សម្ភារៈប្រើប្រាស់ ឬសម្ភារៈក្មេងលេង ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដែលស្នើសុំចុះបញ្ជីការនោះ ស្ថិតក្នុងបញ្ជីហាមឃាត់នៅក្រោមបទប្បញ្ញត្តិនៃក្រមនេះ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន សម្រាប់ការផលិត ការនាំចូល ការចែកចាយ ឬការប្រើប្រាស់។

ខ- សារធាតុគ្រោះថ្នាក់ និងផលិតផល សម្ភារៈប្រើប្រាស់ ឬសម្ភារៈក្មេងលេង ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដែលស្នើសុំចុះបញ្ជីការនោះ ស្ថិតក្នុងការហាមឃាត់ការផលិត ឬប្រើប្រាស់ អនុលោមតាមលិខិតបទដ្ឋានអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

គ- សារធាតុគ្រោះថ្នាក់ និងផលិតផល សម្ភារៈប្រើប្រាស់ ឬសម្ភារៈក្មេងលេងដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដែលស្នើសុំចុះបញ្ជីការនោះ ត្រូវបានរកឃើញថាអាចនឹងបង្កឱ្យមានហានិភ័យខ្ពស់ដល់សុខភាពសាធារណៈ និងបរិស្ថាន។

ឃ- ឯកសារបញ្ជាក់ពីវត្តមានលក្ខណៈ ឬកម្រិតផ្ទុកនៃសារធាតុគ្រោះថ្នាក់មានលក្ខណៈមិនគ្រប់គ្រាន់។

មាត្រា១៩៣ .ـ ការដកហូតវិញ្ញាបនបត្រចុះបញ្ជីការ

ក្រសួងស្ថាប័នទទួលបន្ទុកតាមវិស័យនិងក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវដកហូតវិញ្ញាបនបត្រចុះបញ្ជីការសារធាតុគ្រោះថ្នាក់ និងផលិតផល សម្ភារៈប្រើប្រាស់ ឬសម្ភារៈក្មេងលេងដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ប្រសិនបើ៖

ក- មានការរកឃើញថាការប្រើប្រាស់ឬការសេយកាយសារធាតុគ្រោះថ្នាក់នោះ បានបង្កឱ្យមានហានិភ័យធ្ងន់ធ្ងរដល់សុខភាពសាធារណៈនិងបរិស្ថាន។

ខ- មានការហាមឃាត់ទាំងស្រុងដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ឬលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

ជំពូកទី៤
ការដាក់ស្លាកសញ្ញាគ្រោះថ្នាក់ សារព្រមានគ្រោះថ្នាក់ ស្លាកសញ្ញាគីមីនិងឯកសារព័ត៌មានពីសុវត្ថិភាពនៃសារធាតុគ្រោះថ្នាក់

មាត្រា១៩៤ .ـ ការដាក់ស្លាកសញ្ញាគ្រោះថ្នាក់លើសម្ភារៈវេចខ្ចប់និងមធ្យោបាយដឹកជញ្ជូនសារធាតុគ្រោះថ្នាក់

រាល់សម្ភារៈវេចខ្ចប់និងមធ្យោបាយដឹកជញ្ជូនសារធាតុគ្រោះថ្នាក់ ដែលមានចែងស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ត្រូវមានដាក់ស្លាកសញ្ញាគ្រោះថ្នាក់និងសារព្រមានគ្រោះថ្នាក់ និងត្រូវភ្ជាប់ឯកសារព័ត៌មានពីសុវត្ថិភាពនៃសារធាតុគ្រោះថ្នាក់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ទំព័រ៣៣០អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

មាត្រា១៩៥ .ـ ការដាក់សារព្រមានគ្រោះថ្នាក់លើផលិតផលឬសម្ភារៈប្រើប្រាស់និងសម្ភារៈក្មេងលេងដែលមានផ្ទុកសារធាតុគ្រោះថ្នាក់

ផលិតផលឬសម្ភារៈប្រើប្រាស់ និងសម្ភារៈក្មេងលេងដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ត្រូវដាក់សារព្រមានគ្រោះថ្នាក់ មុននឹងចែកចាយឬលក់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា១៩៦ .ـ ការដាក់ស្លាកសញ្ញាលើផលិតផលគីមីនិងផលិតផលគីមីប្រើប្រាស់

១- រាល់ផលិតផលគីមីនិងផលិតផលគីមីប្រើប្រាស់ ត្រូវដាក់ស្លាកសញ្ញាគីមីគ្រោះថ្នាក់ និងសារព្រមានគ្រោះថ្នាក់ផ្សេងៗ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

២- ស្លាកសញ្ញាគីមីគ្រោះថ្នាក់និងសារព្រមានគ្រោះថ្នាក់ដែលបិទលើផលិតផលគីមី ត្រូវមានព័ត៌មានដូចខាងក្រោម៖

ក- ព័ត៌មានអំពីផលិតផលនិងប្រភពនៃផលិតផល។

ខ- រូបសញ្ញាអំពីការបង្កគ្រោះថ្នាក់។

គ- ពាក្យព្រមាន។

ឃ- ព័ត៌មានអំពីភាពងាយរងគ្រោះ ត្រូវរៀបចំតាមលំដាប់លេខរៀង ប្រភេទ និងកម្រិតនៃការបង្កគ្រោះថ្នាក់របស់ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់។

ង- ព័ត៌មានអំពីវិធានការបង្ការឬវិធីប្រើប្រាស់។

ច- ព័ត៌មានអំពីផលិតករឬអ្នកផ្គត់ផ្គង់។

ឆ- ស្លាកសញ្ញាមានភាពច្បាស់លាស់ ងាយស្រួលអាន មិនងាយរហែក មិនងាយរបក ឬរលុបសញ្ញា។

ជ- រាល់ព័ត៌មានទាំងអស់ខាងលើត្រូវសរសេរជាភាសាខ្មែរ។

ជំពូកទី៥
ភាគច្បាប់បុគ្គលពាក់ព័ន្ធនឹងសារធាតុគ្រោះថ្នាក់

មាត្រា១៩៧ .ـ ការផ្តល់របាយការណ៍ប្រចាំឆ្នាំអំពីសារធាតុគ្រោះថ្នាក់

នីតិបុគ្គលដែលផលិត នាំចូល ចែកចាយ ឬប្រើប្រាស់សារធាតុគ្រោះថ្នាក់នៅក្នុងសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ត្រូវផ្តល់របាយការណ៍ប្រចាំឆ្នាំមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិអំពី៖

ក- ប្រភេទនិងបរិមាណសារធាតុគ្រោះថ្នាក់ដែលបានផលិត នាំចូល ចែកចាយ ប្រើប្រាស់ ឬត្រូវបោះបង់ចោល។

ខ- វិធានការនិងមធ្យោបាយសម្រាប់គ្រប់គ្រងនិងទប់ស្កាត់ការសាយភាយសារធាតុគ្រោះថ្នាក់ ឬការបង្ហានិក័យដល់សុខភាពសាធារណៈនិងបរិស្ថាន។

គ- វិធានការនិងមធ្យោបាយសម្រាប់គ្រប់គ្រងសំណល់សារធាតុគ្រោះថ្នាក់និងសំណល់ ដែលមានផ្ទុកឬប្រឡាក់សារធាតុគ្រោះថ្នាក់។

មាត្រា១៩៨ .ـ ការផ្តល់របាយការណ៍ប្រចាំឆ្នាំអំពីផលិតផលឬសម្ភារៈប្រើប្រាស់និងសម្ភារៈក្មេងលេងដែលមានផ្ទុកសារធាតុគ្រោះថ្នាក់

នីតិបុគ្គលដែលផលិត នាំចូល ចែកចាយផលិតផល ឬសម្ភារៈប្រើប្រាស់ និងសម្ភារៈក្មេងលេង ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ត្រូវផ្តល់របាយការណ៍ប្រចាំឆ្នាំមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិអំពី៖

ក- ប្រភេទ បរិមាណផលិតផល ឬសម្ភារៈប្រើប្រាស់ និងសម្ភារៈក្មេងលេង ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ដែលបានផលិត នាំចូល ចែកចាយ ឬត្រូវបោះបង់ចោល។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៣៣១

ខ- ការអនុវត្តដាក់សញ្ញាព្រមានគ្រោះថ្នាក់នៅលើផលិតផល ឬសម្ភារៈប្រើប្រាស់ និងសម្ភារៈក្មេងលេង ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់។

មាត្រា១៩៩ .- ការរៀបចំផែនការឆ្លើយតបបន្ទាន់

ម្ចាស់ឬអ្នកគ្រប់គ្រងទីតាំងផលិតកម្ម ស្តុក ចែកចាយ ឬប្រើប្រាស់សារធាតុគ្រោះថ្នាក់ ឬផលិតផល ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ត្រូវរៀបចំផែនការឆ្លើយតបសម្រាប់ការសង្គ្រោះបន្ទាន់ករណីគ្រោះឧបទ្ទវហេតុកំពប់ ឬលេចធ្លាយសារធាតុគ្រោះថ្នាក់ ឬផលិតផលដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ និងត្រូវដាក់ជូនទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា២០០ .- កាតព្វកិច្ចរបស់បុគ្គលអ្នកផលិត នាំចូល ស្តុកទុក ដឹកជញ្ជូន ចែកចាយ ឬប្រើប្រាស់សារធាតុគ្រោះថ្នាក់នៅក្នុងសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្ម

នៅក្នុងសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ប្រសិនបើកើតមានគ្រោះថ្នាក់ ឬគ្រោះឧបទ្ទវហេតុកំពប់ លេចធ្លាយ ផ្ទុះ ឆេះ ឬសាយភាយសារធាតុគ្រោះថ្នាក់ ឬផលិតផលដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ បុគ្គលអ្នកផលិត នាំចូល ស្តុកទុក ដឹកជញ្ជូន ចែកចាយ ឬប្រើប្រាស់សារធាតុគ្រោះថ្នាក់ ត្រូវមានកាតព្វកិច្ចដូចខាងក្រោម៖

ក- ជូនដំណឹងជាបន្ទាន់មកក្រសួងស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ច ឬភ្នាក់ងារសេវាសង្គ្រោះអំពីហេតុការណ៍ ឬគ្រោះឧបទ្ទវហេតុ។

ខ- ចាត់វិធានការជាបន្ទាន់ ដើម្បីកាត់បន្ថយ ទប់ស្កាត់ ឬបញ្ឈប់ការកំពប់ ឬការលេចធ្លាយ និងធ្វើការប្រមូល វេចខ្ចប់ និងសម្អាតសារធាតុគ្រោះថ្នាក់ដែលបានកំពប់ ឬលេចធ្លាយ។

គ- ចូលរួមសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់ព័ត៌មានលម្អិតទាក់ទងនឹងសារធាតុគ្រោះថ្នាក់ដែលបានកំពប់ ឬលេចធ្លាយ សិក្សានិងវាយតម្លៃអំពីផលប៉ះពាល់ដល់សុខភាពសាធារណៈ ទ្រព្យសម្បត្តិ និងបរិស្ថាន។

មាត្រា២០១ .- ការទទួលខុសត្រូវលើសារធាតុគ្រោះថ្នាក់ខូចគុណភាពឬផុតកំណត់កាលបរិច្ឆេទប្រើប្រាស់

១- បុគ្គលអ្នកផលិត នាំចូល ចែកចាយ ឬប្រើប្រាស់សារធាតុគ្រោះថ្នាក់នៅក្នុងសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ត្រូវទទួលខុសត្រូវក្នុងការទុកដាក់ ការធ្វើប្រព្រឹត្តិកម្ម ឬការបោះបង់ចោលសារធាតុគ្រោះថ្នាក់ដែលខូចគុណភាពឬផុតកំណត់កាលបរិច្ឆេទប្រើប្រាស់ អនុលោមតាមបញ្ញត្តិស្តីពីការគ្រប់គ្រងសំណល់គ្រោះថ្នាក់នៃក្រមនេះ។

២- សារធាតុគ្រោះថ្នាក់ដែលខូចគុណភាពឬផុតកំណត់កាលបរិច្ឆេទប្រើប្រាស់ ត្រូវចាត់ទុកជាសំណល់គ្រោះថ្នាក់។

មាត្រា២០២ .- ការទទួលខុសត្រូវលើការខូចខាត

បុគ្គលដែលបង្កឱ្យមានការកំពប់ឬការលេចធ្លាយសារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថាន ត្រូវទទួលខុសត្រូវលើសំណងការខូចខាតទ្រព្យសម្បត្តិ ផលប៉ះពាល់ដល់សុខភាពសាធារណៈ បរិស្ថាន និងការស្តារ ការបំពុលបរិស្ថានឡើងវិញ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

មាត្រា២០៣ .- ការបង់ថ្លៃបំពុលបរិស្ថាន



១- បុគ្គលដែលនៅក្នុងផលិតកម្ម អាជីវកម្ម ឬសេវាកម្មរបស់ខ្លួនមានការផលិតឬប្រើប្រាស់សារធាតុគ្រោះថ្នាក់ ត្រូវបង់ថ្លៃបំពុលបរិស្ថាន។

ទំព័រ៣៣២អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

២- ប្រភេទទីតាំងដែលតម្រូវឱ្យបង់ថ្លៃការបំពុលបរិស្ថាននិងអត្រាបង់ថ្លៃការបំពុលបរិស្ថាន ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្តាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី៦
ការហាមឃាត់

មាត្រា២០៤ .- ការហាមឃាត់សារធាតុគ្រោះថ្នាក់

បុគ្គលមិនត្រូវផលិត នាំចូល ចែកចាយ ឬប្រើប្រាស់សារធាតុគ្រោះថ្នាក់ ដែល៖

ក- ស្ថិតក្នុងបញ្ជីប្រភេទសារធាតុគ្រោះថ្នាក់ដែលត្រូវហាមឃាត់ ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ខ- ពុំមានចុះបញ្ជីការនៅក្រសួងស្តាប័នទទួលបន្ទុកតាមវិស័យ។

គ- ពុំមានដាក់ស្លាកសញ្ញា ឬសារព្រមានគ្រោះថ្នាក់នៅលើសម្ភារៈវេចខ្ចប់ ឬដាក់ស្លាកសញ្ញាគ្រោះថ្នាក់ក្លែងក្លាយ។

ឃ- មានការរកឃើញពីភាពគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ ឬបរិស្ថាន។

មាត្រា២០៥ .- ការហាមឃាត់ផលិតផលមានផ្ទុកសារធាតុគ្រោះថ្នាក់

បុគ្គលមិនត្រូវផលិត នាំចូល ឬចែកចាយផលិតផល សម្ភារៈប្រើប្រាស់ និងសម្ភារៈក្មេងលេង ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ដែល៖

ក- សារធាតុគ្រោះថ្នាក់នោះ ស្ថិតក្នុងបញ្ជីហាមឃាត់នៃលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ខ- ការផលិតឬការនាំចូលពុំមានចុះបញ្ជីការនៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

គ- សារធាតុគ្រោះថ្នាក់ក្នុងផលិតផលមានកម្រិតលើសស្តង់ដារបរិមាណសារធាតុគ្រោះថ្នាក់ ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ឃ- ពុំមានដាក់ស្លាកសញ្ញាព្រមានគ្រោះថ្នាក់នៅលើផលិតផល។

ង- មានការរកឃើញពីភាពគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ ឬបរិស្ថាន។

មាត្រា២០៦ .- ការហាមឃាត់ការបង្កឱ្យមានការសោយភាយសារធាតុគ្រោះថ្នាក់

ហាមឃាត់ដាច់ខាតសកម្មភាព ដែលបង្កឱ្យមានការសោយភាយសារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថានមានដូចជាអាទិ៍៖

ក- ការបញ្ចេញឬបោះបង់ចោលសារធាតុគ្រោះថ្នាក់នៅតាមទីសាធារណៈឬចូលទៅក្នុងប្រភពទឹកសាធារណៈ។

ខ- ការកម្ទេចចោល ឬការដុតសារធាតុគ្រោះថ្នាក់នៅក្នុងដីកម្មសិទ្ធិ នៅតាមទីវាលឬទីសាធារណៈ។

គ- ការបង្កឱ្យមានការកំពប់ឬលេចធ្លាយសារធាតុគ្រោះថ្នាក់។

មាត្រា២០៧ .- ការចាប់យកសារធាតុគ្រោះថ្នាក់ ឬផលិតផលដែលមានផ្ទុកសារធាតុគ្រោះថ្នាក់

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិអំណាចចាប់យកនូវសារធាតុគ្រោះថ្នាក់ ឬផលិតផលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដែលត្រូវបានហាមឃាត់ដោយអនុលោមតាមបទប្បញ្ញត្តិនៃគន្លឹទី៩នៃក្រមនេះ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៣៣៣

មាតិកាទី៣
ការគ្រប់គ្រងសំណល់រឹង
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា២០៨ .- គោលបំណង

មាតិកានេះ មានគោលបំណងគ្រប់គ្រងសំណល់រឹង តាមរយៈការដាក់ចេញនូវវិធានការនានា ដើម្បីលុបបំបាត់ការចោលសំណល់រឹងចាប់ពីទីតាំងបង្កើតរហូតដល់ទីលានទុកដាក់ចុងក្រោយ សំដៅធានាបានកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងកិច្ចគាំពារសុខភាពសាធារណៈ។

មាត្រា២០៩ .- វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តលើសកម្មភាពនាំចូល នាំចេញ ញែក វេចខ្ចប់ ប្រមូល ដឹកជញ្ជូន កែច្នៃ ទាញយកធនធាន ធ្វើប្រព្រឹត្តិកម្ម និងទុកដាក់សំរាម សំណល់រឹងទីប្រជុំជន សំណល់ប្លាស្ទិក និងសំណល់រឹងឧស្សាហកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី២
ស្ថាប័នទទួលខុសត្រូវ

មាត្រា២១០ .- ក្រសួងស្ថាប័នទទួលខុសត្រូវ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវដឹកនាំនិងពង្រឹងប្រសិទ្ធភាពការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន សំណល់ប្លាស្ទិក និងសំណល់រឹងឧស្សាហកម្ម។

មាត្រា២១១ .- តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត ផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធការគ្រប់គ្រងសំណល់រឹង និងដឹកនាំសម្របសម្រួលការអនុវត្តរវាងក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ខ- សិក្សាស្រាវជ្រាវបច្ចេកវិទ្យាពាក់ព័ន្ធនឹងការកែច្នៃ ការទាញយកធនធាន ការធ្វើប្រព្រឹត្តិកម្ម និងការទុកដាក់ចុងក្រោយនៃសំណល់រឹងប្រកបដោយសុវត្ថិភាពបរិស្ថាន។

គ- ផ្តល់ការគាំទ្រនិងជំរុញសកម្មភាពកែច្នៃនិងទាញយកធនធានពីសំណល់រឹង។

ឃ- ផ្តល់ការណែនាំបច្ចេកទេសនិងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាប្រសិទ្ធភាពអនុវត្តមុខងារគ្រប់គ្រងសំណល់រឹង។

ង- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍនានា ក្នុងការកៀរគរធនធានហិរញ្ញវត្ថុ បច្ចេកទេស មធ្យោបាយ និងសម្ភារៈសម្រាប់គាំទ្រនិងធ្វើឱ្យប្រសើរឡើងការគ្រប់គ្រងសំណល់រឹងពីដើមខ្សែដល់ចុងខ្សែ។

ច- ដឹកនាំ សម្របសម្រួល និងជំរុញការលើកកម្ពស់ការអប់រំក្នុងប្រព័ន្ធ និងការអប់រំផ្សព្វផ្សាយជាសាធារណៈពីការគ្រប់គ្រងសំណល់រឹង សំដៅជំរុញឱ្យមានការផ្លាស់ប្តូរឥរិយាបថលើការគ្រប់គ្រងសំណល់រឹង និងការចូលរួមប្រើប្រាស់និងបង់ថ្លៃសេវាសំណល់រឹង។

ទំព័រ៣៣៤អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

ឆ- ពិនិត្យនិងផ្តល់យោបល់បច្ចេកទេសលើការជ្រើសរើសទីតាំងដើម្បីបង្កើតទីលាន ការរៀបចំទីលាន និងវិធានការគាំពារបរិស្ថានក្នុងពេលប្រតិបត្តិការ និងការបិទបញ្ចប់ទីលានទុកដាក់សំណល់រឹង។

ជ- សហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តមុខងារគ្រប់គ្រងសំណល់រឹង។

ជំពូកទី៣
ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

មាត្រា២១២ .- ការបង្កើតគណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

១- ត្រូវបានបង្កើតគណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ជាយន្តការថ្នាក់ជាតិដើម្បីដឹកនាំនយោបាយនិងយុទ្ធសាស្ត្រ និងផ្តល់ការគាំទ្រធនធានថវិកា និងបច្ចេកទេសសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

២- តួនាទីនិងការកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា២១៣ .- ការគ្រប់គ្រងទិន្នន័យសំរាម សំណល់រឹងទីប្រជុំជន

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យសំរាម សំណល់រឹងទីប្រជុំជន និងត្រូវកំណត់នូវវិធានការ តម្រូវការធនធានឬមធ្យោបាយចាំបាច់សម្រាប់ជំរុញការបង្កើនសមត្ថភាពនិងប្រសិទ្ធភាពសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនឱ្យបានគ្របដណ្តប់នៅទូទាំងប្រទេស និងធានាបាននិរន្តរភាពសុវត្ថិភាពបរិស្ថាន។

មាត្រា២១៤ .- ផែនការសកម្មភាពសម្រាប់ការកាត់បន្ថយការបង្កើតសំរាម សំណល់រឹងទីប្រជុំជន

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងគ្រប់ភាគីពាក់ព័ន្ធ ត្រូវកំណត់យុទ្ធសាស្ត្រនិងផែនការសកម្មភាពសម្រាប់អនុវត្តកម្មវិធីកាត់បន្ថយការបង្កើតសំរាមតាមរយៈការញែកសំណល់នៅនឹងប្រភព ការដឹកជញ្ជូនទៅតាមប្រភេទ និងលើកកម្ពស់សកម្មភាពការកែច្នៃ ការទាញយកធនធាន និងការធ្វើប្រព្រឹត្តិកម្មសំណល់។

មាត្រា២១៥ .- រដ្ឋបាលថ្នាក់ក្រោមជាតិ

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវអនុវត្តគោលនយោបាយ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

ក- រៀបចំលិខិតបទដ្ឋានចាំបាច់នានា សម្រាប់ជំរុញការអនុវត្តវិធានការគោលនយោបាយ ច្បាប់ ផែនការយុទ្ធសាស្ត្រជាតិ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

ខ- រៀបចំផែនការសកម្មភាពនិងផែនការថវិកាសម្រាប់ការគ្រប់គ្រង ការសម្អាត ការប្រមូល ការដឹកជញ្ជូន និងការលុបបំបាត់ការចាលរាយប៉ាយនូវសំរាម សំណល់រឹងទីប្រជុំជន។

គ- ជំរុញការអនុវត្តការញែកសំណល់និងកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃសំរាម ការទាញយកធនធានពីសំរាម សំណល់រឹងទីប្រជុំជន។

ឃ- បង្កើត គ្រប់គ្រង និងចាត់ចែងសេវាសម្អាត ប្រមូល ដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន និងសេវាទីលានទុកដាក់។

ង- អប់រំនិងផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋក្នុងការធ្វើអនាម័យ ការទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ការចូលរួមប្រើប្រាស់និងការបង់សេវាប្រមូលដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៣៣៥

ច- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃប្រសិទ្ធភាពនៃការផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។
ឆ- អនុវត្តវិធានការអប់រំ និងវិធានការច្បាប់លើបទល្មើសការចោលសំរាមមាយប៉ាយ ការគេចវេះការប្រើប្រាស់ និងការមិនបង់សេវាសំរាម សំណល់រឹងទីប្រជុំជន។
ជ- រៀបចំរបាយការណ៍ប្រចាំឆ្នាំអំពីទិន្នន័យ ស្ថានភាពនិងដំណើរការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដើម្បីដាក់ជូនក្រសួងស្ថាប័នមានសមត្ថកិច្ច។

ផ្នែកទី១
ការទទួលខុសត្រូវរបស់អ្នកបង្កើតសំរាម សំណល់រឹងទីប្រជុំជន

មាត្រា២១៦ .- កាតព្វកិច្ចម្ចាស់សំរាម សំណល់រឹងទីប្រជុំជន

បុគ្គលដែលបង្កើតសំរាម សំណល់រឹងទីប្រជុំជនត្រូវមានកាតព្វកិច្ចអនុវត្តតាមគោលការណ៍កំណត់របស់រដ្ឋបាលថ្នាក់ក្រោមជាតិលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន មានជាអាទិ៍ ការញែក ការវេចខ្ចប់ ការទុកដាក់ ការបញ្ជូញ ការសម្អាត ការប្រើប្រាស់សេវា និងការបង់ថ្លៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

មាត្រា២១៧ .- វិធានការលើអ្នកប្រើប្រាស់ផលិតផលឬសម្ភារៈ

១- ការប្រើប្រាស់ផលិតផលឬសម្ភារៈដែលអាចបង្កឱ្យមានហានិភ័យដល់បរិស្ថាន សុខភាពសាធារណៈ និងពិបាកមិនអាចកែច្នៃបានក្រោយពេលក្លាយជាសំណល់ តម្រូវឱ្យមានការដាក់តម្លៃលើអ្នកប្រើប្រាស់ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

២- ប្រភេទផលិតផលឬសម្ភារៈដែលតម្រូវឱ្យមានការដាក់តម្លៃលើអ្នកប្រើប្រាស់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

មាត្រា២១៨ .- ការហាមឃាត់ការបោះចោលនិងការដុតសំរាម សំណល់រឹងទីប្រជុំជន

១- ហាមឃាត់ដាច់ខាតការបោះចោលសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាលប្រព័ន្ធទឹកលូ ប្រឡាយទឹក ប្រភពទឹកសាធារណៈឬក្នុងដីកម្មសិទ្ធិ ដែលមិនត្រូវបានអនុញ្ញាតជាកន្លែងស្តុកទុកសំរាមជាបណ្តោះអាសន្ន ឬជាកន្លែងទុកដាក់ចុងក្រោយ។

២- ហាមឃាត់ដាច់ខាតការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ក្នុងដីកម្មសិទ្ធិ ទីវាលឬការដុតក្នុងឡដុតសំណល់ ដែលមិនមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា២១៩ .- ការទទួលខុសត្រូវចំពោះការខូចខាត

បុគ្គលដែលបង្កើតសំរាម សំណល់រឹងទីប្រជុំជន ដែលបង្កឱ្យមានការបំពុលបរិស្ថាន ការប៉ះពាល់ដល់សុខភាពសាធារណៈ ឬការខូចខាតទ្រព្យសម្បត្តិបណ្តាលពីសកម្មភាពគ្រប់គ្រងរបស់ខ្លួនត្រូវទទួលខុសត្រូវលើការខូចខាតនិងការស្តារការបំពុលបរិស្ថាន អនុលោមតាមបទប្បញ្ញត្តិនៃក្រមនេះ។

ផ្នែកទី២
សេវាប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន

មាត្រា២២០ .- ការរៀបចំសេវាប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន

១- រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលខុសត្រូវក្នុងការរៀបចំឱ្យមាននិងដំណើរការសេវាប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនប្រកបដោយគុណភាព ប្រសិទ្ធភាព និងសុវត្ថិភាពបរិស្ថានក្នុងដែនដីរដ្ឋបាលរបស់ខ្លួន។

ទំព័រ៣៣៦អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

២- នីតិវិធីនិងលក្ខខណ្ឌតម្រូវសម្រាប់ការរៀបចំនិងការគ្រប់គ្រងសេវាប្រមូល ដឹកជញ្ជូន និងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា២២១ .- កាតព្វកិច្ចអ្នកផ្តល់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានសំរាម សំណល់រឹងទីប្រជុំជន

បុគ្គលដែលទទួលសិទ្ធិផ្តល់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានសំរាម សំណល់រឹងត្រូវធានា៖

ក- អនុវត្តលក្ខខណ្ឌតម្រូវដែលបានកំណត់ក្នុងកិច្ចសន្យាផ្តល់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានសំរាម សំណល់រឹងទីប្រជុំជន។

ខ- ផ្តល់សេវាដែលមិនបង្កផលប៉ះពាល់ដល់បរិស្ថាន សុខភាព ឬផលប្រយោជន៍សាធារណៈ។

គ- សហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការដោះស្រាយបញ្ហាកកស្ទះសំរាម។

ឃ- ដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនទៅទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ដែលបានកំណត់។

ង- ទទួលខុសត្រូវលើការខូចខាតទ្រព្យសម្បត្តិ ការប៉ះពាល់ដល់សុខភាពសាធារណៈ និងការស្តារការបំពុលបរិស្ថាន ដែលបង្កពីសកម្មភាពផ្តល់សេវារបស់ខ្លួន។

ច- ផ្តល់របាយការណ៍ទៀងទាត់អំពីប្រតិបត្តិការសេវាកម្មរបស់ខ្លួនជូនអាជ្ញាធរមានសមត្ថកិច្ច។

មាត្រា២២២ .- ការអនុញ្ញាតបង្កើតសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន

ការវិនិយោគបង្កើតសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ត្រូវមានការអនុញ្ញាតពីរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានការឯកភាពជាមុនពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិលើបច្ចេកទេស និងវិធានការគាំពារសុវត្ថិភាពបរិស្ថាននៃសេវាទីលាន។

ជំពូកទី៤
ការគ្រប់គ្រងសំណល់ប្លាស្ទិក

មាត្រា២២៣ .- ក្រសួងស្ថាប័នទទួលខុសត្រូវគ្រប់គ្រងសំណល់ប្លាស្ទិក

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ចត្រូវទទួលខុសត្រូវ៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត ផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់ការគ្រប់គ្រងសំណល់ប្លាស្ទិក ក្នុងគោលដៅកាត់បន្ថយការប្រើប្រាស់ផលិតផលប្លាស្ទិក ការបង្កើតសំណល់ប្លាស្ទិក និងបង្កើនសកម្មភាពកែច្នៃ និងទាញយកធនធានពីសំណល់ប្លាស្ទិក។

ខ- ធ្វើការកំណត់អំពីប្រភេទ ស្តង់ដារ និងលក្ខខណ្ឌចាំបាច់នានានៃផលិតផល ឬសម្ភារៈប្លាស្ទិកដែលអាចអនុញ្ញាតឱ្យនាំចូល ឬធ្វើការផលិតនៅក្នុងស្រុក។

គ- ធ្វើការកំណត់ប្រភេទផលិតផល ឬសម្ភារៈប្លាស្ទិកដែលត្រូវហាមឃាត់ការប្រើប្រាស់ ឬអនុញ្ញាតឱ្យប្រើប្រាស់ដោយមានលក្ខខណ្ឌ។

ឃ- ធ្វើការកំណត់ទីតាំង ឬបង្កើតតំបន់ដែលគ្មានចង់ប្លាស្ទិក ឬគោលដៅ ដែលតម្រូវឱ្យអនុវត្តវិធានការហាមឃាត់ការប្រើប្រាស់ ឬអនុញ្ញាតឱ្យប្រើប្រាស់ផលិតផល ឬសម្ភារៈប្លាស្ទិកដោយមានលក្ខខណ្ឌ។

ង- ជំរុញនិងផ្តល់ការគាំទ្រការផលិតនិងការប្រើប្រាស់ផលិតផល ឬសម្ភារៈ ដែលអាចប្រើប្រាស់ជំនួសផលិតផល ឬសម្ភារៈប្លាស្ទិក។

ច- លើកទឹកចិត្ត និងផ្តល់ការគាំទ្រលើការកែច្នៃ និងការទាញយកធនធានពីសំណល់ប្លាស្ទិក។

ឆ- អប់រំនិងលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអនុវត្តគោលនយោបាយ កម្មវិធីកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិកនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមរយៈ ការជៀសវាងប្រើថង់ប្លាស្ទិករលើសភាពចាំបាច់ ការប្រើថង់ក្រណាត់ជំនួស ឬថង់ដែលប្រើបានច្រើនដង ការបញ្ចូលទំនិញក្នុងថង់តែមួយ និងការប្រើប្រាស់សម្ភារៈងាយពុកផុយ។

មាត្រា២២៤ .- កាតព្វកិច្ចចូលរួមចំណែកកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក

ប្រជាពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចចូលរួមចំណែកក្នុងការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក តាមរយៈ ការប្រើប្រាស់ឡើងវិញនូវថង់ប្លាស្ទិកដែលបានប្រើប្រាស់រួចឬប្រើវត្ថុផ្សេងជំនួសថង់ប្លាស្ទិក។

មាត្រា២២៥ .- ការលើកទឹកចិត្តលើការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក

ម្ចាស់ទីតាំងអាជីវកម្ម ឬម្ចាស់សេវាកម្មនានា ម្ចាស់ផ្សារទំនើប ឬមជ្ឈមណ្ឌលពាណិជ្ជកម្ម ត្រូវបានលើកទឹកចិត្តឱ្យចូលរួមចំណែកដោយស្ម័គ្រចិត្តក្នុងការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក។

មាត្រា២២៦ .- ការនាំចូលនិងការផលិតថង់ឬសម្ភារៈវេចខ្ចប់ពីវត្ថុធាតុងាយពុកផុយឬជីវប្លាស្ទិក

ការនាំចូលនិងការផលិតថង់ឬសម្ភារៈវេចខ្ចប់ ដែលផលិតពីវត្ថុធាតុងាយពុកផុយឬជីវប្លាស្ទិក ត្រូវបានដាក់អាករពិសេសជាបន្ទុករបស់ផ្ទៃ។ ធុរជនពាក់ព័ន្ធត្រូវស្នើសុំដាក់អាករពិសេសជាបន្ទុករបស់ផ្ទៃទៅក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា២២៧ .- វិធានការលើការនាំចូលនិងការផលិតផលិតផលឬសម្ភារៈប្លាស្ទិក

ការនាំចូលនិងការផលិតផលិតផលឬសម្ភារៈប្លាស្ទិក ត្រូវមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ លើប្រភេទនិងលក្ខខណ្ឌតម្រូវនានា ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

មាត្រា២២៨ .- វិធានការដាក់តម្លៃលើអ្នកប្រើប្រាស់ផលិតផលឬសម្ភារៈប្លាស្ទិក

១- ការប្រើប្រាស់ផលិតផលឬសម្ភារៈប្លាស្ទិកដែលអាចបង្កឱ្យមានហានិភ័យដល់បរិស្ថាន សុខភាពសាធារណៈ និងពិបាកនិងមិនអាចកែច្នៃបានក្រោយពេលក្លាយជាសំណល់ តម្រូវឱ្យមានការដាក់តម្លៃលើអ្នកប្រើប្រាស់ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

២- ប្រភេទផលិតផលឬសម្ភារៈប្លាស្ទិកដែលតម្រូវឱ្យមានការដាក់តម្លៃលើអ្នកប្រើប្រាស់ និងទីតាំងគោលដៅត្រូវអនុវត្ត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា២២៩ .- វិធានការលើការគ្រប់គ្រងសំណល់ប្លាស្ទិកនៅតាមទីតាំងបង្កើត

បុគ្គលឬម្ចាស់ទីតាំងដែលមានការប្រើប្រាស់ផលិតផល ឬសម្ភារៈប្លាស្ទិក រួមទាំងម្ចាស់លំនៅឋាន ត្រូវទទួលខុសត្រូវក្នុងការរៀបក ទុកដាក់ និងបញ្ជូនសំណល់ប្លាស្ទិកដែលបានបង្កើតតាមការតម្រូវដោយក្រសួងស្ថាប័នមានសមត្ថកិច្ច ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា២៣០ .- ការហាមឃាត់ការចោលនិងការរុះរុតសំណល់ប្លាស្ទិក

១- ហាមឃាត់ជាដាច់ខាតការចោលសំណល់ប្លាស្ទិកនៅតាមដងផ្លូវ ទីសាធារណៈ ទីវាល ប្រព័ន្ធទឹកលូ ប្រឡាយទឹក និងចូលប្រភពទឹកសាធារណៈ។

ទំព័រ៣៣៨អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

២- ហាមឃាត់ជាដាច់ខាតការជ្រុតសំណល់ប្លាស្ទិកនៅតាមទីសាធារណៈ តាមទីវាល តាមទីលានសំរាម ឬការជ្រុតក្នុងឡជ្រុតសំណល់ ដែលមិនមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ជំពូកទី៥
ការគ្រប់គ្រងសំណល់រឹងឧស្សាហកម្ម

មាត្រា២៣១ .- ក្រសួងស្ថាប័នទទួលខុសត្រូវត្រួតពិនិត្យសំណល់រឹងឧស្សាហកម្ម

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ជាស្ថាប័នទទួលខុសត្រូវដឹកនាំត្រួតពិនិត្យលើការគ្រប់គ្រងសំណល់រឹងឧស្សាហកម្ម មានជាអាទិ៍ ការញែក ការស្តុកបណ្តោះអាសន្ន ការដឹកជញ្ជូន ការកែច្នៃ ការទាញយកធនធាន ការធ្វើប្រព្រឹត្តិកម្ម និងការទុកដាក់ចុងក្រោយ។

មាត្រា២៣២ .- កាតព្វកិច្ចម្ចាស់ទីតាំងបង្កើតសំណល់រឹងឧស្សាហកម្ម

បុគ្គលម្ចាស់ទីតាំងដែលបង្កើតសំណល់រឹងឧស្សាហកម្ម ត្រូវទទួលខុសត្រូវលើការគ្រប់គ្រងសំណល់របស់ខ្លួន មានជាអាទិ៍ ការញែក ការទុកដាក់ ការដឹកជញ្ជូន ការធ្វើប្រព្រឹត្តិកម្ម និងការទុកដាក់ចុងក្រោយនៅទីលានដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

មាត្រា២៣៣ .- លិខិតអនុញ្ញាតបញ្ចេញសំណល់រឹងឧស្សាហកម្ម

ម្ចាស់សំណល់រឹងឧស្សាហកម្មដែលមានបំណងធ្វើការបញ្ចេញសំណល់រឹងឧស្សាហកម្មពីទីតាំងរបស់ខ្លួន ត្រូវមានលិខិតអនុញ្ញាតបញ្ចេញសំណល់រឹងឧស្សាហកម្មជាមុន ពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា២៣៤ .- លិខិតអនុញ្ញាតអាជីវកម្មសំណល់រឹងឧស្សាហកម្ម

ប្រតិបត្តិករដែលធ្វើអាជីវកម្មសេវាប្រមូល ដឹកជញ្ជូន សេវាប្រព្រឹត្តិកម្ម និងទីលានទុកដាក់ចុងក្រោយសំណល់រឹងឧស្សាហកម្ម ត្រូវមានលិខិតអនុញ្ញាតអាជីវកម្មសំណល់រឹងឧស្សាហកម្មជាមុនពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ជំពូកទី៦
ការកែច្នៃ ការទាញយកធនធាន ការធ្វើប្រព្រឹត្តិកម្ម
ការនាំចេញ និងការនាំចូលសំណល់រឹង

មាត្រា២៣៥ .- លិខិតអនុញ្ញាតសេវាកម្មឬអាជីវកម្មកែច្នៃនិងទាញយកធនធានសំណល់រឹង

ការធ្វើសេវាកម្មឬអាជីវកម្មកែច្នៃ ទាញយកធនធាន ឬធ្វើប្រព្រឹត្តិកម្មសំណល់រឹងត្រូវមានលិខិតអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា២៣៦ .- ការនាំចេញសំណល់រឹងឬវត្តុធាតុដើមពីការកែច្នៃសំណល់រឹង

ការនាំចេញសំណល់រឹងឬវត្តុធាតុដើមពីការកែច្នៃសំណល់រឹង ត្រូវមានលិខិតអនុញ្ញាតជាមុនពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា២៣៧ .- ការនាំចូលសំណល់រឹង

ការនាំចូលសំណល់រឹងពីក្រៅប្រទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានហាមឃាត់ លើកលែងតែសំណល់រឹង ដែលជាកម្មវត្តុនាំចូលសម្រាប់បំពេញបន្ថែមដល់គម្រោងវិនិយោគកែច្នៃសំណល់ក្នុងស្រុក។ ក្នុងករណីនាំចូលសំណល់រឹង ត្រូវមានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល ដោយអនុវត្តតាមនីតិវិធីជាធរមាន។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៣៣៩

មាតិកាទី៤
ការគ្រប់គ្រងសំណល់គ្រោះថ្នាក់
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា២៣៨ .– គោលបំណង

មាតិកានេះ មានគោលបំណងគ្រប់គ្រងសំណល់គ្រោះថ្នាក់ តាមរយៈការដាក់ចេញនូវវិធានការនានាដើម្បីលុបបំបាត់ការចោលសំណល់គ្រោះថ្នាក់ចាប់ពីការបង្កើតរហូតដល់ការទុកដាក់ចុងក្រោយ សំដៅធានាបានកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងកិច្ចគាំពារសុខភាពសាធារណៈ។

មាត្រា២៣៩ .– វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តលើសកម្មភាពនាំចូល នាំចេញ ដឹកជញ្ជូន ប្រមូល ស្តុកទុក កែច្នៃ ទាញយកធនធាន ធ្វើប្រព្រឹត្តិកម្ម និងការទុកដាក់ចុងក្រោយនៃសំណល់គ្រោះថ្នាក់ប្រកបដោយសុវត្ថិភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី២
ស្ថាប័នទទួលខុសត្រូវ

មាត្រា២៤០ .– ក្រសួងស្ថាប័នទទួលខុសត្រូវ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវដឹកនាំការគ្រប់គ្រង និងការត្រួតពិនិត្យសំណល់គ្រោះថ្នាក់។

មាត្រា២៤១ .– តួនាទីនិងការកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត ផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេស សម្រាប់ការគ្រប់គ្រងសំណល់គ្រោះថ្នាក់។

ខ- រៀបចំបញ្ជីប្រភេទសំណល់គ្រោះថ្នាក់ ដោយអនុលោមតាមលិខិតបទដ្ឋានអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

គ- គ្រប់គ្រងទិន្នន័យនិងព័ត៌មានប្រកពបង្កើតសំណល់គ្រោះថ្នាក់ និងទីតាំងសេវាកម្មប្រមូល ដឹកជញ្ជូន កែច្នៃ ធ្វើប្រព្រឹត្តិកម្ម និងទីលានទុកដាក់ចុងក្រោយសំណល់គ្រោះថ្នាក់។

ឃ- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការគ្រប់គ្រងសំណល់គ្រោះថ្នាក់នៅទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម រួមទាំងសកម្មភាពនាំចូល នាំចេញ និងដឹកឆ្លងកាត់នៃសំណល់គ្រោះថ្នាក់។

ង- ពិនិត្យនិងផ្តល់ការអនុញ្ញាតលើសំណើគម្រោងសេវាប្រមូល ដឹកជញ្ជូន កែច្នៃ ធ្វើប្រព្រឹត្តិកម្ម កម្ទេចចោល និងទីលានទុកដាក់ចុងក្រោយសំណល់គ្រោះថ្នាក់ និងការស្នើសុំការអនុញ្ញាតបញ្ចេញ នាំចេញ និងដឹកឆ្លងកាត់នៃសំណល់គ្រោះថ្នាក់។

ច- សិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយអំពីប្រភេទ កម្រិតគ្រោះថ្នាក់ ឬផលប៉ះពាល់នៃសំណល់គ្រោះថ្នាក់ដែលសាយភាយចូលទៅក្នុងបរិស្ថាន។

ឆ- សម្របសម្រួលជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច ក្នុងការជំរុញការរៀបចំផែនការសកម្មភាព ការត្រៀមសម្ភារៈ មធ្យោបាយ និងធនធានសម្រាប់ការឆ្លើយតបបន្ទាន់ចំពោះករណីគ្រោះឧបទ្ទវហេតុនៃការឆេះ ការផ្ទុះ ការកំពប់ ការលេចធ្លាយសំណល់គ្រោះថ្នាក់។

ជ- បំពេញការកិច្ចជាស្ថាប័នបង្គោលជាតិនៃលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់គ្រោះថ្នាក់ដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

ជំពូកទី៣
និយាមការគ្រប់គ្រងសំណល់អាគុយនិងសំណល់ថ្មពិល

មាត្រា២៤២ .- កាតព្វកិច្ចរៀបចំទុកដាក់សំណល់អាគុយនិងសំណល់ថ្មពិល

លំនៅឋាន ទីផ្សារ ផ្សារទំនើប ទីកន្លែងកម្សាន្ត អគារសាធារណៈ គ្រឹះស្ថានសិក្សា សកម្មភាពអាជីវកម្ម សេវាកម្ម និងសិប្បកម្ម ត្រូវមានកាតព្វកិច្ចទុកដាក់និងរៀបចំបែងចែកសំណល់អាគុយ និងសំណល់ថ្មពិលដាច់ដោយឡែកពីសំណល់ផ្សេងទៀត ទៅតាមគោលការណ៍ណែនាំរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា២៤៣ .- ការប្រមូល ការរក្សាទុក ការដឹកជញ្ជូន ការដោះបំបែក និងការធ្វើប្រព្រឹត្តិកម្មសំណល់អាគុយនិងសំណល់ថ្មពិល

ការប្រមូល ការរក្សាទុក ការដឹកជញ្ជូន ការដោះបំបែក និងការធ្វើប្រព្រឹត្តិកម្មសំណល់អាគុយ និងសំណល់ថ្មពិលគ្រប់ប្រភេទ និងការបោះបង់ចោល ត្រូវមានលិខិតអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងត្រូវអនុវត្តតាមវិធានសុវត្ថិភាពបរិស្ថាន។

មាត្រា២៤៤ .- ការស្នើសុំលិខិតអនុញ្ញាត

១- រាល់អាជីវកម្មលើសំណល់អាគុយដែលមានលក្ខណៈជាអាជីវកម្មគ្រួសារ ត្រូវសុំលិខិតអនុញ្ញាតពីស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិរាជធានី ខេត្ត។

២- រាល់អាជីវកម្មសំណល់អាគុយដែលមានលក្ខណៈជាអាជីវកម្មខ្នាតតូចនិងមធ្យម ឬអាជីវកម្មខ្នាតធំ ត្រូវសុំលិខិតអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា២៤៥ .- ការនាំចេញសំណល់អាគុយនិងសំណល់ថ្មពិល

រាល់ការនាំចេញសំណល់អាគុយនិងសំណល់ថ្មពិលពីព្រះរាជាណាចក្រកម្ពុជាទៅក្រៅប្រទេស អាចធ្វើបានលុះត្រាតែមានការឯកភាពពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងលិខិតអនុញ្ញាតឱ្យនាំចូលរបស់សាមីប្រទេសជាមុនសិន។

មាត្រា២៤៦ .- ហាមឃាត់ការដុតឬការវាយបំបែកសំណល់អាគុយនិងសំណល់ថ្មពិល

ហាមឃាត់ជាចំខាតរាល់ការដុត ឬការវាយបំបែកសំណល់អាគុយ និងសំណល់ថ្មពិល ដែលបង្កឱ្យប៉ះពាល់ឬគ្រោះថ្នាក់ដល់សុខភាពសាធារណៈនិងបរិស្ថាន។

មាត្រា២៤៧ .- កម្រៃសេវានៃការស្នើសុំលិខិតអនុញ្ញាត

កម្រៃសេវានៃការស្នើសុំលិខិតអនុញ្ញាតសម្រាប់ការប្រមូល ការស្តុក ការដឹកជញ្ជូន ការបំបែកសំណល់អាគុយនិងសំណល់ថ្មពិលក្នុងបំណងយកសំណ ឬសារធាតុផ្សេងៗ ការធ្វើប្រព្រឹត្តិកម្ម ការបោះបង់ចោល និងការបង្កើតទីលានសុវត្ថិភាព ត្រូវអនុលោមតាមប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា២៤៨ .- កាតព្វកិច្ចរាយការណ៍

ម្ចាស់អាជីវកម្ម ត្រូវមានកាតព្វកិច្ចរាយការណ៍ជូនស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិរាជធានី ខេត្ត ឬក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ រៀងរាល់៦(ប្រាំមួយ)ខែម្តង ពីការវិវត្តនូវរាល់ការប្រមូល ការស្តុក ការទុកដាក់ ការដឹកជញ្ជូន ការដោះបំបែក ការធ្វើប្រព្រឹត្តិកម្ម និងការបោះបង់ចោលសំណល់អាគុយ និងសំណល់ថ្មពិលនៅក្នុងទីតាំងអាជីវកម្មរបស់ខ្លួន ដើម្បីធានានូវសុវត្ថិភាពបរិស្ថាននិងសុខភាពសាធារណៈ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៣៤១

មាត្រា២៤៩ .- កាតព្វកិច្ចតាមដាននិងរាយការណ៍

ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិរាជធានី ខេត្ត ត្រូវមានកាតព្វកិច្ចតាមដាននិងរាយការណ៍ជូនក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ រៀងរាល់៦(ប្រាំមួយ)ខែម្តង ពីការវិវត្តនូវរាល់ការប្រមូល ការស្តុក ការទុកដាក់ ការដឹកជញ្ជូន ការដោះបំបែក ការធ្វើប្រព្រឹត្តិកម្ម និងការបោះបង់ចោលសំណល់អគុយនិងសំណល់ថ្មពិលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ដើម្បីធានានូវសុវត្ថិភាពបរិស្ថាននិងសុខភាពសាធារណៈ។

មាត្រា២៥០ .- ការត្រួតពិនិត្យតាមដាននិងការណែនាំ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានការកិច្ចត្រួតពិនិត្យតាមដានការបំពុលដោយអាជីវកម្ម សំណល់អគុយ និងសំណល់ថ្មពិល និងធ្វើការណែនាំទៅដល់ម្ចាស់អាជីវកម្ម លើវិធានការគ្រប់គ្រងឱ្យបានត្រឹមត្រូវ។

ជំពូកទី៤
វិធានការគ្រប់គ្រងសំណល់គ្រោះថ្នាក់
ផ្នែកទី១
ការបង្កើតសំណល់គ្រោះថ្នាក់

មាត្រា២៥១ .- ការជូនដំណឹងពីការបង្កើតសំណល់គ្រោះថ្នាក់

បុគ្គលដែលបង្កើតសំណល់គ្រោះថ្នាក់នៅក្នុងផលិតកម្ម អាជីវកម្ម ឬសេវាកម្មរបស់ខ្លួនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិអំពីប្រភេទ ប្រភព និងបរិមាណសំណល់គ្រោះថ្នាក់ដែលបានបង្កើត និងវិធានការគ្រប់គ្រងដែលបានអនុវត្ត។

មាត្រា២៥២ .- កាតព្វកិច្ចរបស់ម្ចាស់សំណល់គ្រោះថ្នាក់

១- បុគ្គលដែលបង្កើតសំណល់គ្រោះថ្នាក់ត្រូវទទួលខុសត្រូវក្នុងការវេចខ្ចប់ ដាក់សញ្ញាព្រមាន ទុកដាក់ស្តុកទុក ធ្វើប្រព្រឹត្តិកម្ម និងបញ្ចេញសំណល់គ្រោះថ្នាក់ឱ្យស្របតាមវិធានសុវត្ថិភាពបរិស្ថាន។

២- វិធានសុវត្ថិភាពបរិស្ថានត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា២៥៣ .- លិខិតអនុញ្ញាតបញ្ចេញសំណល់គ្រោះថ្នាក់

១- បុគ្គលដែលបង្កើតសំណល់គ្រោះថ្នាក់នៅក្នុងផលិតកម្ម អាជីវកម្ម ឬសេវាកម្មរបស់ខ្លួន ដែលមានបំណងធ្វើការបញ្ចេញសំណល់គ្រោះថ្នាក់ចេញពីទីតាំងរបស់ខ្លួន ត្រូវមានលិខិតអនុញ្ញាតជាមុនពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

២- បុគ្គលដែលបង្កើតសំណល់គ្រោះថ្នាក់នៅក្នុងផលិតកម្ម អាជីវកម្ម ឬសេវាកម្មរបស់ខ្លួន ដែលមានបំណងធ្វើប្រព្រឹត្តិកម្ម កម្ទេចចោល ឬទុកដាក់ចុងក្រោយសំណល់គ្រោះថ្នាក់នៅលើទីតាំងរបស់ខ្លួន ត្រូវមានលិខិតអនុញ្ញាតជាមុនពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ផ្នែកទី២
ការទទួលខុសត្រូវអ្នកផលិត នាំចូល ឬអ្នកផ្គត់ផ្គង់ផ្ការចំមុខលើគ្រឿងបរិក្ខារ និងសម្ភារៈដែលបង្កើតជាសំណល់គ្រោះថ្នាក់

មាត្រា២៥៤ .- ការទទួលខុសត្រូវប្រមូលយកសំណល់គ្រោះថ្នាក់

១- នីតិបុគ្គលដែលផ្គត់ផ្គង់ផ្ការចំមុខលើឧបករណ៍ ឬគ្រឿងបរិក្ខារអគ្គិសនី និងអេឡិចត្រូនិក ត្រូវទទួលខុសត្រូវរៀបចំនិងអនុវត្តប្រព័ន្ធប្រមូលយកសំណល់នៃឧបករណ៍ឬគ្រឿងបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកត្រឡប់ទៅប្រទេសដើមវិញឬធ្វើការកម្ទេចចោលនៅក្នុងស្រុកដោយមិនបង្កគ្រោះថ្នាក់បរិស្ថានឬសុខភាពសាធារណៈ។

២- ប្រភេទគ្រឿងបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកដែលតម្រូវឱ្យមានការប្រមូលយកត្រឡប់ទៅប្រទេសដើមវិញ ឬធ្វើការកម្ទេចចោលនៅក្នុងស្រុក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា២៥៥ .- ការអនុវត្តប្រាក់កក់សំណល់គ្រោះថ្នាក់

១- នីតិបុគ្គលដែលផលិតឬនាំចូលឧបករណ៍ គ្រឿងបរិក្ខារ ឬសម្ភារៈប្រើប្រាស់ដែលក្រោយពេលប្រើប្រាស់រួចឬលែងប្រើបានក្លាយជាសំណល់គ្រោះថ្នាក់ ត្រូវអនុវត្តការដាក់បញ្ចូលតម្លៃប្រាក់កក់សំណល់បន្ថែមលើតម្លៃគ្រឿងបរិក្ខារឬសម្ភារៈប្រើប្រាស់ និងដែលត្រូវសងត្រឡប់នៅពេលយកសំណល់មកប្តូរសម្រាប់ការប្រមូលយកសំណល់ពីអតិថិជនឬអ្នកប្រើប្រាស់។

២- ប្រភេទឧបករណ៍ គ្រឿងបរិក្ខារ ឬសម្ភារៈប្រើប្រាស់ ដែលតម្រូវឱ្យមានការដាក់បញ្ចូលតម្លៃប្រាក់កក់សំណល់បន្ថែមលើតម្លៃឧបករណ៍ គ្រឿងបរិក្ខារ ឬសម្ភារៈប្រើប្រាស់ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា២៥៦ .- ការស្នើសុំការអនុញ្ញាតប្រកបអាជីវកម្ម

បុគ្គលដែលមានបំណងប្រកបអាជីវកម្មប្រមូលទិញ ស្តុកទុក ដោះបំបែក ការធ្វើប្រព្រឹត្តិកម្ម ឬឡដុតសំណល់ និងការបង្កើតទីលានចោះចោលសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតនិងបំពេញទម្រង់បែបបទនៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា២៥៧ .- កាតព្វកិច្ចចំពោះសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក

បុគ្គលដែលមានសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ត្រូវបំពេញកាតព្វកិច្ចទាំងអស់ដូចខាងក្រោម៖

ក- រក្សាទុកសំណល់នៅទីសុវត្ថិភាពនិងដាក់ដោយឡែកពីសំណល់លំនៅឋាន។

ខ- បញ្ជូនសំណល់ទៅទីតាំងកែច្នៃឬកន្លែងប្រមូលផ្តុំសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកតាមការកំណត់របស់ក្រសួងស្ថាប័នមានសមត្ថកិច្ច។

មាត្រា២៥៨ .- កាតព្វកិច្ចរបស់ម្ចាស់អាជីវកម្ម

ម្ចាស់ទីតាំងអាជីវកម្មប្រមូលទិញ ស្តុកទុក ដោះបំបែក ជំរឿង ឬកែច្នៃសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ត្រូវបំពេញកាតព្វកិច្ចទាំងអស់ដូចខាងក្រោម៖

ក- អនុវត្តតាមគោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកប្រកបដោយសុវត្ថិភាពបរិស្ថាននៅក្នុងដំណើរការអាជីវកម្មរបស់ខ្លួន។

ខ- រៀបចំទិន្នន័យសំណល់ដែលត្រូវបានបង្កើតពីអាជីវកម្មរបស់ខ្លួន។

គ- ប្រើប្រាស់សេវាប្រមូលសំណល់ដែលត្រូវបានបង្កើតពីការជួសជុល អនុលោមតាមការកំណត់របស់ស្ថាប័នមានសមត្ថកិច្ច។

មាត្រា២៥៩ .- កាតព្វកិច្ចបុគ្គលដែលផលិតបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក

បុគ្គលដែលផលិតបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោម៖

ក- ប្រមូលនិងទុកដាក់សំណល់ចេញពីដំណើរការផលិតបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកដោយអនុវត្តតាមគោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកប្រកបដោយសុវត្ថិភាពបរិស្ថាន។

ខ- បំពាក់ឧបករណ៍ត្រួតពិនិត្យការបំពុលបរិស្ថាន។

គ- រៀបចំទិន្នន័យសំណល់ដែលត្រូវបានបង្កើតពីផលិតកម្មរបស់ខ្លួន។

ឃ- ប្រើប្រាស់សេវាប្រមូលសំណល់ដែលត្រូវបានបង្កើតពីការជួសជុល អនុលោមតាមការកំណត់របស់ក្រសួងស្ថាប័នមានសមត្ថកិច្ច។

មាត្រា២៦០ .- ការហាមឃាត់ការបោះចោលសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក

ហាមឃាត់ចំពោះការបោះបង់ចោលសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកទៅក្នុងប្រភពទឹក ឬទីលានចាក់សំរាម ឬនៅទីសាធារណៈនានា និងការដុត ឬការវាយបំបែកសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិកដែលបង្កឱ្យមានគ្រោះថ្នាក់ដល់បរិស្ថាន ឬសុខភាពសាធារណៈ។

ផ្នែកទី៣
ការទទួលខុសត្រូវរបស់ប្រតិបត្តិការសំណល់គ្រោះថ្នាក់

មាត្រា២៦១ .- លិខិតអនុញ្ញាតសេវាកម្ម អាជីវកម្មសំណល់គ្រោះថ្នាក់

ប្រតិបត្តិការសំណល់គ្រោះថ្នាក់ដែលផ្តល់សេវាកម្មប្រមូល ដឹកជញ្ជូន ប្រព្រឹត្តិកម្ម កម្ទេចចោល ឬទុកដាក់សំណល់គ្រោះថ្នាក់ចុងក្រោយ ឬធ្វើអាជីវកម្មទិញ លក់ កែច្នៃ ឬទាញយកធនធានពីសំណល់គ្រោះថ្នាក់ត្រូវមានលិខិតអនុញ្ញាតសេវាកម្ម អាជីវកម្មសំណល់គ្រោះថ្នាក់ជាមុនពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា២៦២ .- កាតព្វកិច្ចរបស់ប្រតិបត្តិការសំណល់គ្រោះថ្នាក់

ប្រតិបត្តិការសំណល់គ្រោះថ្នាក់ដែលផ្តល់សេវាកម្មឬធ្វើអាជីវកម្មសំណល់គ្រោះថ្នាក់ត្រូវទទួលខុសត្រូវ៖

ក- គ្រប់គ្រងសំណល់គ្រោះថ្នាក់នៅលើទីតាំងផ្តល់សេវារបស់ខ្លួនស្របតាមវិធានសុវត្ថិភាពបរិស្ថាន និងតាមលក្ខខណ្ឌនៃលិខិតអនុញ្ញាតសេវាកម្ម អាជីវកម្មសំណល់គ្រោះថ្នាក់។

ខ- ដាក់សញ្ញាព្រមានគ្រោះថ្នាក់នៅតាមមធ្យោបាយដឹកជញ្ជូននិងទីតាំងផ្តល់សេវាកម្ម ឬធ្វើអាជីវកម្ម។

គ- ផ្តល់របាយការណ៍អំពីប្រភេទនិងបរិមាណសំណល់គ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងការផ្តល់សេវាកម្ម ឬអាជីវកម្ម និងវិធានការគ្រប់គ្រងសំណល់គ្រោះថ្នាក់មកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ រៀងរាល់១(មួយ)ឆ្នាំម្តង ឬតាមតម្រូវការចាំបាច់។

មាត្រា២៦៣ .- ការបង់ថ្លៃបំពុលបរិស្ថាន

១- ប្រតិបត្តិការសំណល់គ្រោះថ្នាក់ដែលធ្វើអាជីវកម្មទាញយកធនធានឡើងវិញ ធ្វើប្រព្រឹត្តិកម្ម កម្ទេចចោលឬទុកដាក់ចុងក្រោយសំណល់គ្រោះថ្នាក់ត្រូវបង់ថ្លៃការបំពុលបរិស្ថាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

២- ប្រភេទទីតាំងដែលតម្រូវឱ្យបង់ថ្លៃការបំពុលបរិស្ថាន និងអត្រាបង់ថ្លៃការបំពុលបរិស្ថាន ដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ផ្នែកទី៤
ការនាំចូល ការនាំចេញ និងការដឹកជញ្ជូនឆ្លងកាត់សំណល់គ្រោះថ្នាក់

មាត្រា២៦៤ .- ការហាមឃាត់ការនាំចូលសំណល់គ្រោះថ្នាក់

ការនាំចូលសំណល់គ្រោះថ្នាក់ពីក្រៅប្រទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបានហាមឃាត់ លើកលែងតែសំណល់គ្រោះថ្នាក់ដែលជាកម្មវត្ថុនាំចូលសម្រាប់បំពេញបន្ថែម ដល់គម្រោងវិនិយោគកែច្នៃសំណល់គ្រោះថ្នាក់ប៉ុណ្ណោះ។ ក្នុងករណីនេះ បែបបទនិងនីតិវិធីនៃការនាំចូលសំណល់គ្រោះថ្នាក់ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា២៦៥ .- ការអនុញ្ញាតនាំចេញសំណល់គ្រោះថ្នាក់

ការនាំចេញសំណល់គ្រោះថ្នាក់ពីព្រះរាជាណាចក្រកម្ពុជាត្រូវបានអនុញ្ញាត លុះត្រាតែបានបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

ក- មានលិខិតអនុញ្ញាតឱ្យធ្វើការនាំចូលរបស់ប្រទេសសាមី។

ខ- មានលិខិតអនុញ្ញាតឱ្យនាំចេញរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

គ- មានលិខិតធានារបស់អ្នកនាំចេញដែលបញ្ជាក់ថា សំណល់គ្រោះថ្នាក់ដែលបាននាំចេញនិងមិនធ្វើការនាំត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ។

ឃ- បានបំពេញតាមនីតិវិធីនាំចេញសំណល់គ្រោះថ្នាក់ អនុលោមតាមលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធនឹងសំណល់គ្រោះថ្នាក់ដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី និងលក្ខខណ្ឌចាំបាច់ដទៃទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល។

មាត្រា២៦៦ .- ការអនុញ្ញាតឱ្យដឹកជញ្ជូនសំណល់គ្រោះថ្នាក់ឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា

ការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ពីប្រទេសមួយទៅប្រទេសមួយទៀត ដោយឆ្លងកាត់តាមព្រះរាជាណាចក្រកម្ពុជាត្រូវបានអនុញ្ញាត លុះត្រាតែបានបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម៖

ក- មានលិខិតអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នមានសមត្ថកិច្ច រយៈពេលយ៉ាងតិច ៣០(សាមសិប)ថ្ងៃ មុនការដឹកជញ្ជូនឆ្លងកាត់។

ខ- បានបង់ថ្លៃសេវាដឹកជញ្ជូនឆ្លងកាត់តាមការកំណត់របស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គ- មានកិច្ចសន្យាទទួលសងការខូចខាតនិងការសម្អាតបរិស្ថាន ក្នុងករណីមានឧបទ្ទវហេតុលេចធ្លាយសំណល់គ្រោះថ្នាក់ដោយចៃដន្យក្នុងពេលដឹកជញ្ជូនឆ្លងកាត់។

ឃ- អាចធ្វើការសុំចតបណ្តោះអាសន្នពេលដឹកជញ្ជូនឆ្លងកាត់រយៈពេលយ៉ាងយូរត្រឹម១៥(ដប់ប្រាំ)ថ្ងៃគិតចាប់ពីថ្ងៃចូលដល់ព្រះរាជាណាចក្រកម្ពុជា។

ង- បានបំពេញតាមនីតិវិធីនាំចេញសំណល់គ្រោះថ្នាក់ ដោយអនុលោមតាមលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធនឹងសំណល់គ្រោះថ្នាក់ដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី និងលក្ខខណ្ឌចាំបាច់ដទៃទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល។

ផ្នែកទី៥
ទិដ្ឋានការលើករណីអំពាវនាវឬលេចធ្លាយសំណល់គ្រោះថ្នាក់

មាត្រា២៦៧ .- ការរៀបចំផែនការឆ្លើយតបបន្ទាន់

ម្ចាស់ទីតាំងផលិតកម្ម អាជីវកម្ម ដែលបង្កើតសំណល់គ្រោះថ្នាក់និងប្រតិបត្តិករសំណល់គ្រោះថ្នាក់ ត្រូវរៀបចំផែនការឆ្លើយតបនិងសង្គ្រោះបន្ទាន់សម្រាប់ករណីគ្រោះឧបទ្ទវហេតុកំពប់ លេចធ្លាយ ផ្ទុះ ឆេះ ឬសាយភាយសំណល់គ្រោះថ្នាក់ និងត្រូវដាក់ជូនក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដើម្បីពិនិត្យនិងផ្តល់យោបល់សម្រេច។

មាត្រា២៦៨ .- កាតព្វកិច្ចរបស់ម្ចាស់ទីតាំងផលិតកម្ម អាជីវកម្ម និងសេវាកម្មដែលបង្កើតសំណល់គ្រោះថ្នាក់និងប្រតិបត្តិករសំណល់គ្រោះថ្នាក់នៅក្នុងសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្ម

នៅក្នុងសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ប្រសិនបើកើតមានគ្រោះថ្នាក់ ឬគ្រោះឧបទ្ទវហេតុកំពប់ លេចធ្លាយ ផ្ទុះ ឆេះ ឬសាយភាយសំណល់គ្រោះថ្នាក់ ម្ចាស់ទីតាំងផលិតកម្ម អាជីវកម្ម និងសេវាកម្ម ដែលបង្កើតសំណល់គ្រោះថ្នាក់ និងប្រតិបត្តិករសំណល់គ្រោះថ្នាក់ត្រូវមានកាតព្វកិច្ចដូចខាងក្រោម៖

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៣៤៥

ក- ជូនដំណឹងជាបន្ទាន់និងស្នើសុំកិច្ចអន្តរាគមន៍ពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នមានសមត្ថកិច្ច រដ្ឋបាលថ្នាក់ក្រោមជាតិ និងភ្នាក់ងារសេវាសង្គ្រោះអំពីហេតុការណ៍ ឬគ្រោះឧបទ្ទវហេតុ។

ខ- ចាត់វិធានការជាបន្ទាន់ដើម្បីរារាំង ឬបញ្ឈប់ការកំពប់ ឬការលេចធ្លាយ និងធ្វើការប្រមូល វេចខ្ចប់ និងសម្អាតសំណល់គ្រោះថ្នាក់ដែលបានកំពប់ឬលេចធ្លាយ។

គ- ចូលរួមសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នមានសមត្ថកិច្ច ក្នុងការផ្តល់ព័ត៌មានលម្អិតទាក់ទងនឹងសំណល់គ្រោះថ្នាក់ដែលបានកំពប់ លេចធ្លាយ ផ្ទុះ ឬឆេះ និងការវាយតម្លៃផលប៉ះពាល់ ឬគ្រោះថ្នាក់ទៅលើមនុស្ស សត្វ ឬបរិស្ថានពីករណីកំពប់ ឬលេចធ្លាយសំណល់គ្រោះថ្នាក់។

មាត្រា២៦៩ .- ការទទួលខុសត្រូវលើការខូចខាតពីការកំពប់ ការលេចធ្លាយសំណល់គ្រោះថ្នាក់

ម្ចាស់សំណល់គ្រោះថ្នាក់ និងប្រតិបត្តិករសំណល់គ្រោះថ្នាក់ ត្រូវទទួលខុសត្រូវលើសំណងការខូចខាតដល់ផលប៉ះពាល់ដល់សុខភាពសាធារណៈ ទ្រព្យសម្បត្តិ ឬបរិស្ថាន និងការស្តារការបំពុលបរិស្ថានឡើងវិញ ដែលបណ្តាលមកពីការកំពប់ ការលេចធ្លាយសំណល់គ្រោះថ្នាក់ចូលទៅក្នុងបរិស្ថានស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

ផ្នែកទី៦
ការហាមឃាត់

មាត្រា២៧០ .- ការប្រើប្រាស់សេវាសំណល់គ្រោះថ្នាក់មិនមានការអនុញ្ញាត

ហាមឃាត់ដាច់ខាតការប្រគល់ឱ្យ លក់ដូរ ឬផ្តល់ជាអំណោយឱ្យទៅបុគ្គល ដែលមិនមានច្បាប់អនុញ្ញាតផ្តល់សេវាសំណល់គ្រោះថ្នាក់ពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា២៧១ .- សកម្មភាពដោះបំបែកមិនមានការអនុញ្ញាត

ហាមឃាត់ដាច់ខាតសកម្មភាពដោះបំបែកគ្រឿងបរិក្ខារឬសម្ភារៈប្រើប្រាស់ ដែលចាត់ទុកជាសំណល់គ្រោះថ្នាក់ដោយមិនមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា២៧២ .- សកម្មភាពបង្កផលប៉ះពាល់

ហាមឃាត់ដាច់ខាតសកម្មភាពស្តុកទុក បញ្ចេញ ដុត កប់ បោះចោលសំណល់គ្រោះថ្នាក់ ដែលបង្កឱ្យមានផលប៉ះពាល់ដល់សុខភាពសាធារណៈ បរិស្ថាន ឬបង្កការខូចខាតទ្រព្យសម្បត្តិ។

ជំពូកទី៥
ការត្រួតពិនិត្យការគ្រប់គ្រងសំណល់គ្រោះថ្នាក់

មាត្រា២៧៣ .- សមត្ថកិច្ចត្រួតពិនិត្យ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានការកិច្ចត្រួតពិនិត្យរាល់មធ្យោបាយគ្រប់គ្រងសំណល់គ្រោះថ្នាក់នៅទីតាំងបង្កើតសំណល់គ្រោះថ្នាក់និងទីតាំងសេវាកម្ម អាជីវកម្មសំណល់គ្រោះថ្នាក់ ដែលបានតម្រូវឱ្យធ្វើការបំពាក់ស្របតាមវិធានសុវត្ថិភាពបរិស្ថាននិងលក្ខខណ្ឌតម្រូវនៃលិខិតអនុញ្ញាតបញ្ចេញសំណល់គ្រោះថ្នាក់ ឬលិខិតអនុញ្ញាតសេវាកម្ម អាជីវកម្មសំណល់គ្រោះថ្នាក់។

មាត្រា២៧៤ .– អធិការកិច្ចសំណល់គ្រោះថ្នាក់

១- ក្នុងករណីមានសេចក្តីរាយការណ៍ ឬបណ្តឹងពីការលួចបញ្ចេញចោលសំណល់គ្រោះថ្នាក់ ឬដំណើរការសេវាសំណល់គ្រោះថ្នាក់ដែលបង្កឱ្យមានផលប៉ះពាល់ដល់សុខភាពសាធារណៈ ជីវៈចម្រុះ និងបរិស្ថាន ឬបង្កឱ្យខូចខាតទ្រព្យសម្បត្តិសាធារណៈ ឬឯកជន ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិដោយមានការសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់អនុលោមតាមនីតិវិធីអធិការកិច្ចការបំពុលបរិស្ថានដូចមានចែងក្នុងក្រមនេះ។

២- ក្នុងករណីរកឃើញថា ភាពបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ បរិស្ថាន ឬទ្រព្យសម្បត្តិបណ្តាលពីការលួចបញ្ចេញចោលសំណល់គ្រោះថ្នាក់ និងការទុកដាក់ ឬក្នុងដំណើរការសេវាសំណល់គ្រោះថ្នាក់ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានសិទ្ធិចេញលិខិតជាលាយលក្ខណ៍អក្សរដើម្បីផ្អាកសកម្មភាពលួចបញ្ចេញ ឬសកម្មភាពផលិតកម្ម សេវាកម្ម ដែលមានការពាក់ព័ន្ធនឹងការបង្កឱ្យមានគ្រោះថ្នាក់ជាបន្ទាន់ និងត្រូវចាត់ការតាមនីតិវិធីច្បាប់ជាបន្ត។

មាតិកាទី៥
ការត្រួតពិនិត្យការបំពុលទឹក
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា២៧៥ .– គោលបំណង

មាតិកានេះ មានគោលបំណងទប់ស្កាត់និងកាត់បន្ថយការបំពុលទឹក តាមរយៈការដាក់ចេញនូវវិធានការត្រួតពិនិត្យសកម្មភាពពាក់ព័ន្ធដែលបង្កឱ្យមានការបំពុលទឹកសំដៅធានាបានកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងកិច្ចគាំពារសុខភាពសាធារណៈ។

មាត្រា២៧៦ .– វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តលើសកម្មភាពបញ្ចេញសំណល់ការឬសារធាតុបំពុលពីប្រភពជាក់លាក់ និងប្រភពមិនជាក់លាក់ចូលក្នុងប្រភពទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី២
ស្ថាប័នទទួលខុសត្រូវ

មាត្រា២៧៧ .– ក្រសួងស្ថាប័នទទួលខុសត្រូវ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលខុសត្រូវដឹកនាំការគ្រប់គ្រង និងការត្រួតពិនិត្យការបំពុលទឹកដែលបង្កពីប្រភពជាក់លាក់និងប្រភពមិនជាក់លាក់។

មាត្រា២៧៨ .– តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំ និងសៀវភៅណែនាំបច្ចេកទេសពាក់ព័ន្ធការគ្រប់គ្រងការបំពុលទឹក និងការគ្រប់គ្រងការបញ្ចេញសំណល់ការ និងទឹកកខ្វក់ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៣៤៧

ខ- រៀបចំវិធានសុវត្ថិភាពបរិស្ថានសម្រាប់ការគ្រប់គ្រងសំណល់រាវ ទឹកកខ្វក់ និងសារធាតុបំពុល។

គ- អង្កេត តាមដាន និងវាយតម្លៃស្ថានភាពនៃការបំពុលទឹកសាធារណៈ និងតំបន់ងាយទទួលរងការបំពុលទឹក និងផ្សព្វផ្សាយជូនជាសាធារណៈ។

ឃ- គ្រប់គ្រងទិន្នន័យប្រភពបង្កការបំពុលទឹក ទិន្នន័យគុណភាពទឹកសាធារណៈ និងសារធាតុបំពុលដែលសាយភាយចូលក្នុងតំបន់ទឹកសាធារណៈ។

ង- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃបច្ចេកវិទ្យាប្រព្រឹត្តិកម្ម និងមធ្យោបាយគ្រប់គ្រងសំណល់រាវ ទឹកកខ្វក់ និងប្រព័ន្ធប្រព្រឹត្តិកម្មនៅតាមទីតាំងសកម្មភាពផលិតកម្ម អាជីវកម្ម និងសេវាកម្ម។

ច- ពិនិត្យនិងផ្តល់យោបល់បច្ចេកទេសបរិស្ថាន និងការទទួលស្គាល់វិស្វកម្មបរិស្ថានលើប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ និងទឹកកខ្វក់។

ឆ- សិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេស បច្ចេកវិទ្យាទប់ស្កាត់ការបំពុលតំបន់ទឹកសាធារណៈ និងភាពគ្រោះថ្នាក់នៃសារធាតុបំពុលទៅលើសុខភាពសាធារណៈ ជីវៈចម្រុះ និងបរិស្ថាន។

ជ- រៀបចំផែនការសកម្មភាព សម្រាប់ការឆ្លើយតបបន្ទាន់ករណីគ្រោះឧបទ្ទវហេតុនៃការកំពប់ ការលេចធ្លាយសារធាតុបំពុលបរិស្ថាន ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច។

ឈ- ផ្តល់ការគាំទ្រ ការណែនាំបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ញ- បំពេញការកិច្ចជាស្ថាប័នបង្គោលជាតិ នៃកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងការគ្រប់គ្រងការបំពុលទឹកដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

មាត្រា២៧៩ .- តួនាទីនិងភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

រដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទីនិងភារកិច្ចគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនអនុលោមតាមក្រមនេះនិងលិខិតបទដ្ឋានជាធរមាន។

ជំពូកទី៣
ការត្រួតពិនិត្យការបំពុលទឹកសាធារណៈ

មាត្រា២៨០ .- ផែនការសកម្មភាពគ្រប់គ្រងការបំពុលទឹកសាធារណៈ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវរៀបចំផែនការសកម្មភាពបង្ការ ទប់ស្កាត់ កាត់បន្ថយការបំពុលទឹកសាធារណៈនិងធ្វើឱ្យប្រសើរឡើងគុណភាពទឹកនៃប្រភពទឹកសាធារណៈ ដែលទទួលរងការបំពុល។

មាត្រា២៨១ .- ការរៀបចំស្តង់ដារនិងធ្វើចំណាត់ថ្នាក់គុណភាពទឹកសាធារណៈ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំស្តង់ដារគុណភាពទឹកសាធារណៈនិងធ្វើចំណាត់ថ្នាក់និងសន្ទស្សន៍គុណភាពទឹកសម្រាប់កិច្ចគាំពារសុខភាពសាធារណៈ ជីវៈចម្រុះ និងការវាយតម្លៃស្ថានភាពគុណភាពទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា២៨២ .- ការត្រួតពិនិត្យតាមដានការបំពុលទឹកសាធារណៈ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវធ្វើការត្រួតពិនិត្យតាមដានគុណភាពទឹកសាធារណៈនិងគុណភាពទឹកនៅតំបន់ងាយទទួលរងការបំពុល សម្រាប់ការវាយតម្លៃអំពីស្ថានភាពគុណភាពទឹកសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា២៨៣ .- ការផ្តល់ព័ត៌មានអំពីការបំពុលទឹកសាធារណៈ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវរៀបចំដាក់ឱ្យសាធារណជនអាចស្វែងរកព័ត៌មាន និងរបាយការណ៍អំពីលទ្ធផលត្រួតពិនិត្យ តាមដាន និងវាយតម្លៃការបំពុលទឹកសាធារណៈ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

មាត្រា២៨៤ .- ការចាត់វិធានការក្នុងករណីការបំពុលទឹកសាធារណៈ

ក្នុងករណីស្ថានភាពគុណភាពទឹក ឬសមត្ថភាពស្វ័យសម្អាតនៃតំបន់ទឹកសាធារណៈណាមួយមានការថយចុះដែលអាចបង្កឱ្យមានបញ្ហាការបំពុលទឹក ឬការប៉ះពាល់ដល់សុខភាពសាធារណៈធ្ងន់ធ្ងរ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវ៖

ក- ចាត់វិធានការទប់ស្កាត់និងកាត់បន្ថយការបំពុលទឹកសាធារណៈនិងធ្វើឱ្យប្រសើរឡើងគុណភាពទឹកនៃតំបន់ទឹកសាធារណៈ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធ។

ខ- ពិនិត្យការបង្កើតស្តង់ដារបញ្ចេញសំណល់រាវ ឬទឹកកខ្វក់ដោយឡែក សម្រាប់អនុវត្តចំពោះតំបន់ទឹកសាធារណៈដែលងាយទទួលរងការបំពុល ឬតំបន់ទឹកដែលត្រូវធ្វើការអភិរក្ស។

មាត្រា២៨៥ .- ការបំពុលទឹកឆ្លងដែន

ករណីកើតមានការបំពុលទឹកឆ្លងដែន ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នពាក់ព័ន្ធត្រូវចាត់វិធានការអន្តរាគមន៍ជាបន្ទាន់ អនុលោមតាមផែនការឆ្លើយតបបន្ទាន់និងលិខិតបទដ្ឋានអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី និងត្រូវកំណត់ពីវិសាលភាពនៃការខូចខាតបង្កពីការបំពុលទឹកឆ្លងដែន។

ជំពូកទី៤
ការត្រួតពិនិត្យការបំពុលទឹកពីប្រភពជាក់លាក់

មាត្រា២៨៦ .- លិខិតអនុញ្ញាតបញ្ចេញសំណល់រាវ

ការបញ្ចេញសំណល់រាវពីប្រភពជាក់លាក់ចូលទៅក្នុងតំបន់ទឹកសាធារណៈលើដីឬក្រោមដី និងចូលក្នុងប្រព័ន្ធលូសាធារណៈ ត្រូវមានលិខិតអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា២៨៧ .- ការទទួលខុសត្រូវរបស់ម្ចាស់ប្រភពជាក់លាក់

ម្ចាស់ឬប្រតិបត្តិកនៃប្រភពជាក់លាក់ត្រូវទទួលខុសត្រូវអនុវត្តការគ្រប់គ្រង និងការធ្វើប្រព្រឹត្តិកម្មសំណល់រាវនិងទឹកកខ្វក់របស់ខ្លួនមុនពេលបញ្ចេញចូលទៅក្នុងតំបន់ទឹកសាធារណៈ និងត្រូវទទួលខុសត្រូវលើសកម្មភាពដូចខាងក្រោម៖

ក- បំពាក់និងដំណើរការបរិក្ខារប្រព្រឹត្តិកម្មសំណល់រាវតាមលក្ខណៈបច្ចេកទេស ដើម្បីឱ្យការបញ្ចេញសំណល់រាវឆ្លើយតបនឹងស្តង់ដារបញ្ចេញ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ខ- អនុវត្តវិធានការស្វ័យតាមដានត្រួតពិនិត្យនិងស្វ័យរាយការណ៍លើការគ្រប់គ្រង និងការបញ្ចេញសំណល់រាវ។

គ- រៀបចំឱ្យមានអ្នកទទួលខុសត្រូវអនុវត្តការគ្រប់គ្រងការបំពុលបរិស្ថាន សម្រាប់ប្រតិបត្តិការបរិក្ខារប្រព្រឹត្តិកម្មសំណល់រាវរបស់ខ្លួន។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៣៨៩

មាត្រា២៨៨ .- ការតម្រូវឱ្យជូនដំណឹង

ម្ចាស់ឬប្រតិបត្តិករនៃប្រភពជាក់លាក់ ដែលបានទទួលលិខិតអនុញ្ញាតបញ្ចេញសំណល់ការ ត្រូវជូនដំណឹងជាបន្ទាន់ទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្នុងករណី៖

ក- ដំណើរការប្រព័ន្ធបរិក្ខារប្រព្រឹត្តិកម្មសំណល់ការមានភាពមិនប្រក្រតីឬមានឧបទ្ទវហេតុកើតឡើងជាយថាហេតុ។

ខ- ដំណើរការបរិក្ខារត្រួតពិនិត្យស្វ័យប្រវត្តិតាមដានគុណភាពសំណល់ការ ដែលបញ្ចេញមានភាពមិនប្រក្រតី។

គ- ខកខានមិនបានអនុវត្តលក្ខខណ្ឌតម្រូវដែលមានកំណត់ក្នុងលិខិតអនុញ្ញាតបញ្ចេញសំណល់ការ។

មាត្រា២៨៩ .- ការវិភាគសំណាកសំណល់ការ

១- សំណាកសំណល់ការដែលប្រមូលយកក្នុងពេលត្រួតពិនិត្យរបស់មន្ត្រីអធិការកិច្ច និងក្នុងការអនុវត្តតាមដានត្រួតពិនិត្យដោយម្ចាស់សំណល់ការ ត្រូវវិភាគដោយមន្ទីរពិសោធន៍របស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬមន្ទីរពិសោធន៍ផ្សេងទៀតដែលទទួលបានវិញ្ញាបនបត្រវិជ្ជាជីវៈវិភាគពីស្ថាប័នជាតិឬអន្តរជាតិ។

២- ម្ចាស់សំណល់ការត្រូវទទួលខុសត្រូវបង់ថ្លៃសេវាវិភាគសំណាកសំណល់ការរបស់ខ្លួន។

មាត្រា២៩០ .- វិធានការឆ្លើយតបករណីមានការបំពុល

១- ក្នុងករណីដែលការបញ្ចេញសំណល់ការ ឬមានឧបទ្ទវហេតុការលេចធ្លាយសំណល់ការពីប្រភពជាក់លាក់បង្កឱ្យមានផលប៉ះពាល់ដល់សុខភាពសាធារណៈ និងបរិស្ថាន ផលិតកម្ម កសិកម្ម ឧស្សាហកម្ម វារីវប្បកម្ម ឬសុវត្ថិភាពទឹកស្អាតសាធារណៈ ម្ចាស់ឬប្រតិបត្តិករប្រភពជាក់លាក់ត្រូវចាត់វិធានការឆ្លើយតបជាបន្ទាន់ ដើម្បីទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់ ឬផលប៉ះពាល់ និងត្រូវជូនដំណឹងដល់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិជាបន្ទាន់។

២- ក្នុងករណីមានការបំពុលធ្ងន់ធ្ងរ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវបញ្ជាឱ្យផ្អាកផ្នែកខ្លះ ឬផ្អាកទាំងស្រុងនៃដំណើរការរបស់ប្រភពជាក់លាក់ដែលទាក់ទងនឹងការបង្កឱ្យមានការបំពុលបរិស្ថាន។

មាត្រា២៩១ .- ការគ្រប់គ្រងសំណល់កកំពីអាងប្រព្រឹត្តិកម្ម

ម្ចាស់ឬប្រតិបត្តិករនៃប្រភពជាក់លាក់ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់កក់ ដែលកើតចេញពីដំណើរការប្រព្រឹត្តិកម្មសំណល់ការ ស្របតាមគោលការណ៍ណែនាំបច្ចេកទេសរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា២៩២ .- ការតម្រូវបង់ថ្លៃបំពុលបរិស្ថាន

១- បុគ្គលដែលបញ្ចេញសំណល់ការពីប្រភពជាក់លាក់ ហើយបង្កឱ្យមានកំណើនបន្ទុកសារធាតុបំពុលនៅក្នុងបរិស្ថានត្រូវបង់ថ្លៃបំពុលបរិស្ថាន។

២- ប្រភេទប្រភពជាក់លាក់ដែលតម្រូវឱ្យបង់ថ្លៃបំពុលបរិស្ថាននិងអត្រាបង់ថ្លៃការបំពុលបរិស្ថានដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី៥
ការត្រួតពិនិត្យការបំពុលទឹកពីប្រភពមិនជាក់លាក់

មាត្រា២៩៣ .- ផែនការសកម្មភាពសម្រាប់ទប់ស្កាត់ការបំពុលទឹកពីប្រភពមិនជាក់លាក់

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវ៖

ក- រៀបចំផែនការសកម្មភាពបង្ការនិងទប់ស្កាត់ការបំពុលទឹកពីប្រភពមិនជាក់លាក់។

ខ- ចាត់វិធានការឆ្លើយតបជាក់ស្តែងជាបន្ទាន់ សម្រាប់ការកាត់បន្ថយឬការស្តារការបំពុលទឹកពីប្រភពមិនជាក់លាក់។

គ- រៀបចំគោលការណ៍ណែនាំបច្ចេកទេសស្តីពីកិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរលើការគ្រប់គ្រងការបំពុលទឹកពីប្រភពមិនជាក់លាក់។

មាត្រា២៩៤ .- លក្ខខណ្ឌតម្រូវនៃលិខិតអនុញ្ញាតចំពោះគម្រោងឬសកម្មភាព

ក្រសួងស្ថាប័នពាក់ព័ន្ធ ដែលមានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតដល់គម្រោង ឬសកម្មភាពដែលអាចបង្កឱ្យមានការបំពុលទឹកត្រូវពិនិត្យដាក់បញ្ចូលលក្ខខណ្ឌតម្រូវនៃលិខិតអនុញ្ញាតគម្រោង ឬសកម្មភាពនោះឱ្យមានការអនុវត្តកិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរលើការគ្រប់គ្រងការបំពុលទឹកពីប្រភពមិនជាក់លាក់។

មាត្រា២៩៥ .- កាតព្វកិច្ចអនុវត្តកិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរ

បុគ្គលដែលមានសកម្មភាពពាក់ព័ន្ធនឹងការប្រើប្រាស់ដី ឬការបង្កឱ្យមានការសោយកាយសារធាតុបំពុលចូលទៅក្នុងតំបន់ទឹកសាធារណៈ ត្រូវមានកាតព្វកិច្ចអនុវត្តកិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរក្នុងការទប់ស្កាត់ការបំពុលទឹកពីសកម្មភាពគម្រោង ឬអាជីវកម្មរបស់ខ្លួន។

ជំពូកទី៦
ការត្រួតពិនិត្យការបំពុលសមុទ្រ

មាត្រា២៩៦ .- ក្រសួងស្ថាប័នទទួលខុសត្រូវ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលខុសត្រូវដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការត្រួតពិនិត្យការបំពុលសមុទ្រ និងមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបង្ការ ការទប់ស្កាត់ និងការកាត់បន្ថយការបំពុលសមុទ្រ។

ខ- រៀបចំនិងគ្រប់គ្រងទិន្នន័យពាក់ព័ន្ធការបំពុលសមុទ្រ។

គ- ត្រួតពិនិត្យសកម្មភាពប្រភពបំពុលពីដីគោក ផែនកោះ ទីតាំងបូមប្រេង និងដលយាន។

ឃ- សម្របសម្រួលការរៀបចំនិងការអនុវត្តផែនការឆ្លើយតបបន្ទាន់ ក្នុងករណីកើតមានឧបទ្ទវហេតុបំពុលសមុទ្រ។

ង- អនុវត្តការអប់រំផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹងដល់សាធារណជនពីផែនការ និងវិធានការឆ្លើយតបទប់ស្កាត់និងកាត់បន្ថយការបំពុលសមុទ្រ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៣៥១

មាត្រា២៩៧ .- ការសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តផែនការឆ្លើយតបបន្ទាន់ទាក់ទងនឹងការបំពុលសមុទ្រពីដីគោក ការដឹកជញ្ជូនតាមជលយាន ការធ្វើអាជីវកម្មប្រេង ឬរ៉ែបាតសមុទ្រ និងការដោះស្រាយបញ្ហាបំពុលបរិស្ថានសមុទ្រឆ្លងដែន។

មាត្រា២៩៨ .- ការហាមឃាត់ការបញ្ចេញសំណល់

ហាមឃាត់ដាច់ខាតចំពោះការបញ្ចេញសំណល់រឹង ភាវទីកកខ្វក់ សំណល់ប្រេង សំណល់គីមីពីដីគោកដែនគោះទីតាំងបូមប្រេង ឧបករណ៍នេសាទ ចូលទៅក្នុងសមុទ្រ ដោយមិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តិកម្មជាមុនឬមិនមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា២៩៩ .- ការទទួលខុសត្រូវរបស់ម្ចាស់ជលយាន

១- ម្ចាស់ជលយានត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់និងត្រូវនាំយកសំណល់ទាំងនោះមកទុកដាក់នៅដីគោកដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន និងលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

២- ជលយានដូចបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ មានដូចជា អាទិ៍ ជលយានដឹកទំនិញ ដឹកប្រេងឥន្ធនៈ ដឹកអ្នកដំណើរ ទេសចរណ៍ នេសាទ ដឹកម្លូង នាវាបូមជីនិងក្រួសខ្សាច់។

៣- ម្ចាស់ជលយានអន្តរជាតិត្រូវទទួលខុសត្រូវក្នុងការលេចធ្លាយសារធាតុគីមី ប្រេងឥន្ធនៈ និងសំណល់គ្រប់ប្រភេទដែលបង្កការបំពុលបរិស្ថានសមុទ្រ។

មាត្រា៣០០ .- ការទទួលខុសត្រូវរបស់ម្ចាស់គម្រោងអាជីវកម្មប្រេងឬរ៉ែបាតសមុទ្រ

ម្ចាស់គម្រោងអាជីវកម្មប្រេងឬរ៉ែបាតសមុទ្រ ត្រូវទទួលខុសត្រូវ៖

ក- រៀបចំផែនការឆ្លើយតបបន្ទាន់សម្រាប់ករណីគ្រោះឧបទ្ទវហេតុកំពប់ លេចធ្លាយ ឬឆេះប្រេង និងសារធាតុគីមី។

ខ- សហការនិងផ្តល់ព័ត៌មានបន្ទាន់មកក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងករណីកើតមានឧបទ្ទវហេតុគ្រោះថ្នាក់។

គ- បំពាក់មធ្យោបាយសម្រាប់ទុកដាក់សំណល់និងមធ្យោបាយឆ្លើយតបឧបទ្ទវហេតុ ដោយអនុលោមតាមបទប្បញ្ញត្តិនៃក្រមនេះ និងលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

មាត្រា៣០១ .- ការទទួលខុសត្រូវរបស់ម្ចាស់កំពង់ផែសាធារណៈនិងឯកជន

ម្ចាស់កំពង់ផែសាធារណៈនិងឯកជន ដោយសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំមធ្យោបាយសម្រាប់ទទួលនិងទុកដាក់សំណល់ពីជលយាន ដោយអនុលោមតាមបទប្បញ្ញត្តិនៃក្រមនេះ និងលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

មាត្រា៣០២ .- ការទទួលខុសត្រូវរបស់ម្ចាស់ទីតាំងសាងសង់ឬជួសជុលជលយាន

ម្ចាស់ទីតាំងសាងសង់ឬជួសជុលជលយាន ត្រូវទទួលខុសត្រូវគ្រប់គ្រងសំណល់ដែលបានបង្កើតពីសកម្មភាពសាងសង់ ជួសជុល រុះរើ ឬលាងសម្អាតជលយានតាមវិធានសុវត្ថិភាពបរិស្ថានសម្រាប់ការគ្រប់គ្រងសំណល់និងសារធាតុបំពុលដូចបានកំណត់នៅក្នុងចំណុច ខ នៃមាត្រា២៧៨(តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ)នៃក្រមនេះ។

មាត្រា៣០៣ .- ការបំពុលសមុទ្រឆ្លងដែន

ក្នុងករណីកើតមានការបំពុលសមុទ្រឆ្លងដែន ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នមានសមត្ថកិច្ច ត្រូវចាត់វិធានការឆ្លើយតបបន្ទាន់ដោយសហការជាមួយយន្តការពាក់ព័ន្ធថ្នាក់តំបន់ និងអន្តរជាតិ អនុលោមតាមផែនការឆ្លើយតបបន្ទាន់ លិខិតបទដ្ឋានគតិយុត្តជាធរមាន និងលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

មាត្រា៣០៤ .- ការទទួលខុសត្រូវចំពោះសំណងខូចខាតពីការបំពុលសមុទ្រ

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នមានសមត្ថកិច្ច និងយន្តការពាក់ព័ន្ធថ្នាក់ជាតិ ត្រូវសហការជាមួយយន្តការថ្នាក់តំបន់និងអន្តរជាតិកំណត់ពីវិសាលភាពនៃការខូចខាតដែលបណ្តាលមកពីការបំពុលសមុទ្រ។

២- បែបបទនិងនីតិវិធីនៃការទាមទារនិងការទូទាត់សំណងខូចខាតពីការបំពុលសមុទ្រ និងការស្តារការខូចខាតបរិស្ថានឡើងវិញត្រូវអនុលោមតាមបទប្បញ្ញត្តិនៃក្រមនេះ និងលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

មាតិកាទី៦
ការត្រួតពិនិត្យការបំពុលខ្យល់ សំឡេង និងរំញ័រ
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា៣០៥ .- គោលបំណង

មាតិកានេះ មានគោលបំណងទប់ស្កាត់និងកាត់បន្ថយការបំពុលខ្យល់ សំឡេង និងរំញ័រតាមរយៈការដាក់ចេញនូវវិធានការត្រួតពិនិត្យសកម្មភាពដែលបង្កឱ្យមានការបំពុលខ្យល់ សំឡេង និងរំញ័រ សំដៅធានាបានកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងកិច្ចគាំពារសុខភាពសាធារណៈ។

មាត្រា៣០៦ .- វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តលើសកម្មភាពបញ្ចេញសារធាតុបំពុលខ្យល់ សំឡេង និងរំញ័រពីប្រភពចល័តនិងអចល័តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី២
ស្ថាប័នទទួលខុសត្រូវ

មាត្រា៣០៧ .- ក្រសួងស្ថាប័នទទួលខុសត្រូវ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលខុសត្រូវដឹកនាំការគ្រប់គ្រង និងសម្របសម្រួលការត្រួតពិនិត្យការបំពុលខ្យល់ សំឡេង និងរំញ័រ។

មាត្រា៣០៨ .- តួនាទីនិងការកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិមានតួនាទីនិងការកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត ផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេសពាក់ព័ន្ធការគ្រប់គ្រងការបំពុលខ្យល់ សំឡេង និងរំញ័រ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៣៥៣

ខ- រៀបចំស្តង់ដារគុណភាពខ្យល់បរិយាកាស ស្តង់ដារគុណភាពខ្យល់ក្នុងអគារ ស្តង់ដារបញ្ចេញសារធាតុបំពុលខ្យល់ និងស្តង់ដារសំឡេង និងរំញ័រ និងសន្ទស្សន៍គុណភាពខ្យល់បរិយាកាស។

គ- តាមដានត្រួតពិនិត្យនិងវាយតម្លៃគុណភាពខ្យល់បរិយាកាស និងផ្សព្វផ្សាយស្ថានភាពគុណភាពខ្យល់បរិយាកាស។

ឃ- គ្រប់គ្រងទិន្នន័យគុណភាពខ្យល់បរិយាកាស ប្រភពបំពុលខ្យល់ និងសារធាតុបំពុលដែលសាយភាយចូលទៅក្នុងខ្យល់។

ង- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃបរិក្ខារប្រព្រឹត្តិកម្មសារធាតុបំពុលខ្យល់ និងបរិក្ខារតាមដានត្រួតពិនិត្យការបញ្ចេញសារធាតុបំពុលខ្យល់នៅតាមទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម។

ច- ដឹកនាំ សម្របសម្រួល និងសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការត្រួតពិនិត្យការបញ្ចេញសំឡេង និងរំញ័រនៅតាមប្រភពចល័តនិងអចល័ត។

ឆ- សិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយបច្ចេកទេស បច្ចេកវិទ្យាគ្រប់គ្រងការបំពុលខ្យល់ពីប្រភពចល័តនិងអចល័ត និងភាពគ្រោះថ្នាក់នៃសារធាតុបំពុលខ្យល់ក្នុងខ្យល់បរិយាកាសនិងខ្យល់ក្នុងអគារ។

ជ- បំពេញភារកិច្ចជាអង្គភាពបង្គោលជាតិនៃលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធនឹងកិច្ចគាំពារ និងការត្រួតពិនិត្យការបំពុលខ្យល់ដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

ជំពូកទី៣
ការត្រួតពិនិត្យការបំពុលខ្យល់ពីប្រភពចល័ត

មាត្រា៣០៩ .- ការហាមឃាត់ការបញ្ចេញសារធាតុបំពុលខ្យល់លើសស្តង់ដារពីប្រភពចល័ត

ហាមឃាត់ដាច់ខាត ការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពចល័ត ដែលមិនឆ្លើយតបនឹងស្តង់ដារបញ្ចេញសារធាតុបំពុលខ្យល់ ដូចបានបញ្ញត្តនៅក្នុងមាត្រា១៦៨(ស្តង់ដារបញ្ចេញសំណល់)នៃក្រមនេះ។

មាត្រា៣១០ .- ការរៀបចំលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងការបំពាក់ឧបករណ៍កាត់បន្ថយការបញ្ចេញសារធាតុបំពុលខ្យល់

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់អំពីប្រភេទយានយន្តដែលតម្រូវឱ្យបំពាក់ឧបករណ៍កាត់បន្ថយការបញ្ចេញសារធាតុបំពុលខ្យល់។

មាត្រា៣១១ .- ញ្ញាបនបត្របញ្ជាក់ការបញ្ចេញសារធាតុបំពុលខ្យល់

យានយន្តដែលធ្វើចរាចរនៅព្រះរាជាណាចក្រកម្ពុជា ត្រូវមានញ្ញាបនបត្របញ្ជាក់ការបញ្ចេញសារធាតុបំពុលខ្យល់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច។

ជំពូកទី៤
ការត្រួតពិនិត្យការបំពុលខ្យល់ពីប្រភពអចល័ត

មាត្រា៣១២ .- ការហាមឃាត់ការបញ្ចេញសារធាតុបំពុលខ្យល់លើសស្តង់ដារ

ហាមឃាត់ដាច់ខាតការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពអចល័តទៅក្នុងខ្យល់បរិយាកាស ដែលមិនឆ្លើយតបទៅនឹងស្តង់ដារបញ្ចេញសារធាតុបំពុលខ្យល់ ដូចបានបញ្ញត្តនៅក្នុងមាត្រា១៦៨(ស្តង់ដារបញ្ចេញសំណល់)នៃក្រមនេះ។

ទំព័រ៣៥៤អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

មាត្រា៣១៣ .ـ ការហាមឃាត់ការបញ្ចេញក្លិនអាក្រក់ប៉ះពាល់ការរស់នៅនិងសុខភាពសាធារណៈ

ហាមឃាត់ដាច់ខាតចំពោះការបង្កើត ឬការបំភាយក្លិនអាក្រក់ដែលរំខានដល់ការរស់នៅ ឬធ្វើឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ។

មាត្រា៣១៤ .ـ លិខិតអនុញ្ញាតបញ្ចេញសារធាតុបំពុលខ្យល់

ការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពអចល័តត្រូវមានលិខិតអនុញ្ញាតបញ្ចេញសារធាតុបំពុលខ្យល់ពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា៣១៥ .ـ ការត្រួតពិនិត្យការបំពុលខ្យល់នៅតាមប្រភពអចល័ត

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវទទួលខុសត្រូវត្រួតពិនិត្យការបញ្ចេញសារធាតុបំពុលខ្យល់នៅតាមប្រភពអចល័ត។

មាត្រា៣១៦ .ـ ការទទួលខុសត្រូវរបស់ម្ចាស់និងប្រតិបត្តិករចំពោះការបញ្ចេញសារធាតុបំពុលខ្យល់

ម្ចាស់ ឬប្រតិបត្តិករប្រភពអចល័តត្រូវធ្វើការបំពាក់និងដំណើរការបរិក្ខារប្រព្រឹត្តិកម្ម និងបរិក្ខារតាមដានត្រួតពិនិត្យការបញ្ចេញសារធាតុបំពុលខ្យល់ចូលទៅក្នុងខ្យល់បរិយាកាស នៅគ្រប់ចំណុចបញ្ចេញ។

មាត្រា៣១៧ .ـ ការចាត់វិធានការនិងជូនដំណឹងពីករណីបង្កបញ្ហាបំពុលខ្យល់

ក្នុងករណីគ្រឿងបរិក្ខារប្រព្រឹត្តិកម្មនិងបរិក្ខារតាមដានត្រួតពិនិត្យការបញ្ចេញសារធាតុបំពុលខ្យល់មិនដំណើរការ ឬបង្កឱ្យមានការបំពុលខ្យល់ ម្ចាស់ឬប្រតិបត្តិករប្រភពអចល័ត ត្រូវចាត់វិធានការទប់ស្កាត់ការបំពុលខ្យល់ជាបន្ទាន់ និងត្រូវជូនដំណឹងជាបន្ទាន់មកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា៣១៨ .ـ ការរក្សាទុកនិងការផ្តល់ទិន្នន័យតាមដានការបញ្ចេញសារធាតុបំពុលខ្យល់

ម្ចាស់ឬប្រតិបត្តិករប្រភពអចល័តត្រូវរក្សាទុកទិន្នន័យតាមដានការបញ្ចេញសារធាតុបំពុលខ្យល់ និងត្រូវផ្តល់ទិន្នន័យមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា៣១៩ .ـ ការតម្រូវបង់ថ្លៃបំពុលបរិស្ថាន

១- បុគ្គលដែលបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពអចល័ត ហើយបង្កឱ្យមានកំណើនបន្ទុកសារធាតុបំពុលនៅក្នុងខ្យល់បរិយាកាស ត្រូវតែម្រូវឱ្យបង់ថ្លៃបំពុលបរិស្ថាន។

២- ប្រភេទប្រភពអចល័តដែលតម្រូវឱ្យបង់ថ្លៃបំពុលបរិស្ថាន និងអត្រាបង់ថ្លៃការបំពុលបរិស្ថានដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី៥
ការត្រួតពិនិត្យគុណភាពខ្យល់ក្នុងអគារ

មាត្រា៣២០ .ـ ក្រសួងស្ថាប័នទទួលខុសត្រូវក្នុងការត្រួតពិនិត្យគុណភាពខ្យល់ក្នុងអគារ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវទទួលខុសត្រូវ៖

ក- កំណត់លក្ខខណ្ឌតម្រូវសម្រាប់ការគ្រប់គ្រងគុណភាពខ្យល់ក្នុងអគារនិងកំណត់ស្តង់ដារគុណភាពខ្យល់ក្នុងអគារ។

ខ- ធ្វើការត្រួតពិនិត្យគុណភាពខ្យល់ក្នុងអគារ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៣៥៥

មាត្រា៣២១ .ـ លក្ខខណ្ឌតម្រូវនៃការអនុម័តគម្រោងសាងសង់

រាល់ការអនុម័តគម្រោងស្នើសុំសាងសង់អគារគ្រប់ប្រភេទ ក្រសួងស្ថាប័នមានសមត្ថកិច្ចត្រូវ៖

ក- ដាក់បញ្ចូលលក្ខខណ្ឌតម្រូវពាក់ព័ន្ធគុណភាពខ្យល់ក្នុងអគារ សម្រាប់ជានាសុវត្ថិភាពសុខភាពនៃការស្នាក់នៅ ឬបម្រើការងារយៈពេលយូរក្នុងអគារ។

ខ- តម្រូវឱ្យម្ចាស់ ឬប្រតិបត្តិករអគារបំពាក់បរិក្ខារដើម្បីជានាឱ្យគុណភាពខ្យល់ក្នុងអគារមានភាពល្អប្រសើរឆ្លើយតបនឹងកម្រិតស្តង់ដារ។

មាត្រា៣២២ .ـ លិខិតបញ្ជាក់គុណភាពខ្យល់ក្នុងអគារ

១- ម្ចាស់ ឬប្រតិបត្តិករអគារត្រូវមានលិខិតបញ្ជាក់គុណភាពខ្យល់ក្នុងអគារពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

២- ការកំណត់ប្រភេទទីតាំងអគារនិងនីតិវិធីនៃការស្នើសុំលិខិតបញ្ជាក់គុណភាពខ្យល់ក្នុងអគារត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

ជំពូកទី៦
ការត្រួតពិនិត្យគុណភាពខ្យល់បរិយាកាស

មាត្រា៣២៣ .ـ ការអង្កេតតាមដានគុណភាពខ្យល់បរិយាកាស

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវធ្វើការតាមដានគុណភាពខ្យល់បរិយាកាសនិងគុណភាពខ្យល់បរិយាកាសនៅតំបន់ងាយទទួលរងការបំពុលខ្យល់ និងជុំវិញប្រភព ឬទីតាំងដែលមានសក្តានុពលបំពុលខ្យល់ ដើម្បីវាយតម្លៃអំពីស្ថានភាពគុណភាពខ្យល់បរិយាកាស។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាននូវព័ត៌មានទាក់ទងនឹងស្ថានភាពគុណភាពខ្យល់បរិយាកាសស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

មាត្រា៣២៤ .ـ ការជូនដំណឹងអំពីហានិភ័យនៃការបំពុលខ្យល់

ក្នុងករណីមានការរកឃើញហានិភ័យនៃការបំពុលខ្យល់ ដែលអាចបង្កផលប៉ះពាល់ដល់សុខភាពសាធារណៈឬបរិស្ថាន ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវធ្វើការជូនដំណឹងដល់សាធារណជនអំពីស្ថានភាពនៃការបំពុលខ្យល់ ភាពអាចបង្កឱ្យមានគ្រោះថ្នាក់ និងពីវិធានការគាំពារសុខភាព។

មាត្រា៣២៥ .ـ ការត្រួតពិនិត្យគុណភាពខ្យល់បរិយាកាសជុំវិញទីតាំងប្រភពអចល័ត

បុគ្គល ម្ចាស់អាជីវកម្ម ឬប្រតិបត្តិករប្រភពអចល័ត ដែលទទួលបានលិខិតអនុញ្ញាតបញ្ចេញសារធាតុបំពុលខ្យល់ ត្រូវទទួលខុសត្រូវក្នុងការតាមដាន និងត្រួតពិនិត្យការបំពុលខ្យល់បរិយាកាសជុំវិញទីតាំងរបស់ខ្លួន និងផ្តល់របាយការណ៍តាមដានត្រួតពិនិត្យមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា៣២៦ .ـ ការហាមឃាត់សកម្មភាពបង្កឱ្យមានការបំពុលខ្យល់

ហាមឃាត់ដាច់ខាតសកម្មភាពបង្កឱ្យមានការបំពុលខ្យល់ដូចខាងក្រោម៖

ក- ការដុតព្រៃឈើ វាលស្មៅ គល់ជញ្ជាំង និងសំណល់កសិកម្ម និងការដុតសំរាម សំណល់រឹងនៅតាមទីវាល ឬទីលានចាក់សំណល់។

ខ- ការដុតសំណល់ ឬភ្លុះឆេះគ្រប់ប្រភេទនៅតាមទីសាធារណៈ ដងផ្លូវ ទីតាំងអគារសាធារណៈឬឯកជន ឬក្នុងទីតាំងជីកម្មសិទ្ធិ ដែលបង្កឱ្យមានការប៉ះពាល់សុខភាពសាធារណៈ និងការប៉ះពាល់ដល់សន្តិសុខនិងសណ្តាប់ធ្នាប់សង្គម។

គ- ការដឹកជញ្ជូនដី ខ្សាច់ ថ្ម ឬសម្ភារៈសំណង់ដែលបង្កឱ្យមានការហុយធូលីប៉ះពាល់ដល់គុណភាពខ្យល់ សុខភាពសាធារណៈ ការធ្វើចរាចរណ៍និងសណ្តាប់ធ្នាប់សាធារណៈ។

ជំពូកទី៧
ការត្រួតពិនិត្យសារធាតុបំពុលខ្យល់ក្នុងឥន្ធនៈផូស៊ីល

មាត្រា៣២៧ .- ស្ថាប័នត្រួតពិនិត្យសមាសធាតុបង្កើតសារធាតុបំពុលខ្យល់នៅក្នុងឥន្ធនៈផូស៊ីល

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច ត្រូវទទួលខុសត្រូវក្នុងការ៖

ក- រៀបចំស្តង់ដារកម្រិតសមាសធាតុគីមីក្នុងឥន្ធនៈផូស៊ីល ដែលបង្កើតឱ្យមានបញ្ហាបំពុលខ្យល់ធ្ងន់ធ្ងរ។

ខ- រៀបចំនីតិវិធីអនុវត្តការត្រួតពិនិត្យសមាសធាតុគីមី ក្នុងឥន្ធនៈផូស៊ីលបង្កើតឱ្យមានសារធាតុបំពុលខ្យល់។

មាត្រា៣២៨ .- ការអនុញ្ញាតនាំចូលឥន្ធនៈផូស៊ីល

១- ការនាំចូល ការផលិត ការចែកចាយ និងការប្រើប្រាស់ឥន្ធនៈផូស៊ីលត្រូវមានការអនុញ្ញាតពីក្រសួងស្ថាប័នទទួលបន្ទុកវិស័យប្រេងកាត។

២- នីតិវិធីក្នុងការពិនិត្យនិងការផ្តល់លិខិតអនុញ្ញាតនាំចូលត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តស្របតាមបញ្ញត្តិនៃក្រសួងស្ថាប័នទទួលបន្ទុកវិស័យប្រេងកាត។

ជំពូកទី៨
ការបំពុលខ្យល់ឆ្លងដែន

មាត្រា៣២៩ .- ការបំពុលខ្យល់ឆ្លងដែន

ក្នុងករណីទទួលបានការជូនដំណឹង ការផ្តល់បាយការណ៍ ឬលទ្ធផលសិក្សាពីការបំពុលខ្យល់ឆ្លងដែនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ដល់បរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច ដើម្បីស្វែងរកមធ្យោបាយក្នុងការកាត់បន្ថយផលប៉ះពាល់ពីការបំពុលខ្យល់ឆ្លងដែនតាមរយៈយន្តការទូទាត់ពហុភាគី ពហុតំបន់។

មាត្រា៣៣០ .- ការបំពុលខ្យល់ឆ្លងដែនពីប្រភពក្នុងស្រុក

ក្នុងករណីកើតមានការបំពុលខ្យល់ពីប្រភពក្នុងស្រុក ដែលស្ថានភាពនៃការបំពុលអាចបង្កឱ្យមានការឆ្លងដែនអាចប៉ះពាល់ដល់ប្រទេសជិតខាង និងតំបន់ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច ត្រូវចាត់វិធានការកាត់បន្ថយឱ្យអស់លទ្ធភាព និងត្រូវជូនដំណឹងទៅប្រទេសនិងតំបន់ដែលទទួលរងផលប៉ះពាល់។

ជំពូកទី៩
ការត្រួតពិនិត្យសំឡេងនិងរំញ័រ

មាត្រា៣៣១ .- ការហាមឃាត់ការបង្កសំឡេងឬរំញ័រលើសស្តង់ដារ

ហាមឃាត់ដាច់ខាតចំពោះសកម្មភាពដែលបង្កើតសំឡេង ឬរំញ័រលើសស្តង់ដារសំឡេង និងរំញ័រដូចបានបញ្ញត្តនៅក្នុងមាត្រា១៦៩(ស្តង់ដារសំឡេងនិងរំញ័រ)នៃក្រមនេះ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៣៥៧

មាត្រា៣៣២ .- កាតព្វកិច្ចបំពាក់បរិក្ខារកាត់បន្ថយការបញ្ចេញសំឡេងឬរំញ័រ

ម្ចាស់ឬប្រតិបត្តិករទីតាំងត្រូវទទួលខុសត្រូវក្នុងការបំពាក់គ្រឿងបរិក្ខារសម្រាប់កាត់បន្ថយការបញ្ចេញសំឡេងឬរំញ័រ អនុលោមតាមបទប្បញ្ញត្តិនៃក្រមនេះ ឬលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា៣៣៣ .- លក្ខខណ្ឌតម្រូវក្នុងការអង្កេតតាមដាន

ក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវដាក់បញ្ចូលនូវលក្ខខណ្ឌតម្រូវនានាទៅក្នុងលិខិតអនុញ្ញាតនៃគម្រោងស្នើសុំសាងសង់ ឬគម្រោងដែលអាចបង្កឱ្យមានផលប៉ះពាល់ដោយការបញ្ចេញសំឡេង ឬរំញ័រ ដើម្បីធានាបានការគោរពតាមស្តង់ដារបញ្ចេញសំឡេងនិងរំញ័រ។

មាត្រា៣៣៤ .- ការទទួលខុសត្រូវចំពោះការខូចខាត

បុគ្គលដែលបង្កឱ្យមានការបញ្ចេញសំឡេងឬរំញ័រលើសកម្រិតស្តង់ដារត្រូវទទួលខុសត្រូវចំពោះការខូចខាតទ្រព្យសម្បត្តិ ឬប៉ះពាល់ដល់សុខភាពសាធារណៈនិងបរិស្ថាន។

មាតិកាទី៧
ការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់អូហ្សូន សារធាតុធ្វើឱ្យត្រជាក់ និងផលិតផលដែលមានផ្ទុកឬធ្វើឡើងសម្រាប់ប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា៣៣៥ .- គោលបំណង

មាតិកានេះ មានគោលបំណងកាត់បន្ថយនិងលុបបំបាត់ការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុធ្វើឱ្យត្រជាក់ តាមរយៈការដាក់ចេញនូវវិធានការត្រួតពិនិត្យសារធាតុបំផ្លាញស្រទាប់អូហ្សូន សារធាតុធ្វើឱ្យត្រជាក់ និងផលិតផលពាក់ព័ន្ធការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន សំដៅធានាបានកិច្ចគាំពារបរិស្ថានការអភិរក្សជីវៈចម្រុះនិងកិច្ចគាំពារសុខភាពសាធារណៈ។

មាត្រា៣៣៦ .- វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តលើសកម្មភាពផលិត នាំចូល នាំចេញ ដឹកជញ្ជូនឆ្លងកាត់ ស្តុកទុក លក់ប្រើប្រាស់ ផ្ទេរ ប្រព្រឹត្តិកម្ម និងបំផ្លាញចោលសារធាតុបំផ្លាញស្រទាប់អូហ្សូន សារធាតុធ្វើឱ្យត្រជាក់ និងផលិតផលពាក់ព័ន្ធការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី២
ស្ថាប័នទទួលខុសត្រូវ

៣- រូបវន្តបុគ្គលដែលទទួលបានការអនុញ្ញាតឱ្យបរបាញ់មានសិទ្ធិយកសំណាកសត្វព្រៃដែលបានមកពីការបរបាញ់នោះ។ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវពិនិត្យចំនួនសត្វព្រៃដែលបានបរបាញ់ជាក់ស្តែង ដើម្បីកំណត់តម្លៃបង់ចូលថវិកាជាតិ។

៤- កម្រៃសេវានៃការផ្តល់លិខិតអនុញ្ញាតឱ្យបរបាញ់និងតម្លៃប្រភេទសត្វត្រូវបរបាញ់កំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៥៦៦ .- ការបរបាញ់សត្វព្រៃ

១- អ្នកបរបាញ់ត្រូវយកលិខិតអនុញ្ញាតបរបាញ់តាមខ្លួនជានិច្ច។

២- អ្នកបរបាញ់ត្រូវបង្ហាញលិខិតអនុញ្ញាតបរបាញ់ដល់អង្គភាពមានសមត្ថកិច្ចមុនចូលក្នុងតំបន់អនុញ្ញាតឱ្យបរបាញ់។

៣- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិអាចតម្រូវឱ្យអ្នកកាន់កាប់លិខិតអនុញ្ញាតបរបាញ់ក្នុងគោលបំណងសិក្សាស្រាវជ្រាវ ឬអង្កេតតាមដានសុខភាពសត្វព្រៃត្រូវផ្តល់គំរូសំណាកឬផ្នែកណាមួយនៃសត្វព្រៃដែលបាញ់បាន។

មាត្រា៥៦៧ .- ការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត

១- បុគ្គលដែលមានបំណងស្នើសុំលិខិតអនុញ្ញាតបរបាញ់ត្រូវដាក់ពាក្យស្នើសុំទៅកាន់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

២- ពាក្យស្នើសុំលិខិតអនុញ្ញាតបរបាញ់ត្រូវបានត្រួតពិនិត្យស្របតាមការណែនាំ មុនផ្តល់ការឯកភាពពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា៥៦៨ .- លក្ខខណ្ឌចេញឬការមិនចេញលិខិតអនុញ្ញាត

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំបង្កើតទម្រង់បែបបទនៃការស្នើសុំលិខិតអនុញ្ញាតបរបាញ់សត្វព្រៃនិងផ្តល់លិខិតអនុញ្ញាតបរបាញ់សត្វព្រៃ។

២- ការចេញឬការមិនចេញលិខិតអនុញ្ញាតបរបាញ់សត្វព្រៃត្រូវធ្វើឡើង ដូចខាងក្រោម៖

ក- ការចេញលិខិតអនុញ្ញាតត្រូវតែម្ចាស់ភាព។

ខ- ការចេញលិខិតអនុញ្ញាតបានតែមួយចំពោះមួយគ្រួសារ ឬមួយក្រុម។

គ- ការមិនចេញលិខិតអនុញ្ញាតដល់បុគ្គលដែលមានប្រវត្តិពាក់ព័ន្ធនឹងការបរបាញ់សត្វព្រៃខុសច្បាប់។

ឃ- ការមិនអនុញ្ញាតដល់បុគ្គលក្នុងការផ្ទេរលិខិតអនុញ្ញាត ឬលក់សិទ្ធិបរបាញ់សត្វព្រៃទៅបុគ្គលម្នាក់ផ្សេងទៀត។

៣- លិខិតអនុញ្ញាតបរបាញ់មានសុពលភាពមិនលើសពី៦(ប្រាំមួយ)ខែ។ អ្នកបរបាញ់អាចស្នើសុំបន្តលិខិតអនុញ្ញាតបរបាញ់សត្វព្រៃ ដោយភ្ជាប់ជាមួយលិខិតអនុញ្ញាតដែលហួសសុពលភាព។

៤- ក្នុងករណីបាត់លិខិតអនុញ្ញាត អ្នកកាន់កាប់លិខិតអនុញ្ញាតត្រូវជូនដំណឹងជាបន្ទាន់ដល់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៤០៣

មាត្រា៥៦០ .- ការតាមដានសុខភាពសត្វព្រៃ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ អាចតម្រូវឱ្យអ្នកកាន់កាប់លិខិតអនុញ្ញាតបរបាញ់ ប្រមូល ទិញសត្វព្រៃ ប្រគល់នូវសំណាកសត្វព្រៃដែលបរបាញ់ ឬប្រមូលបានដើម្បីធ្វើការតាមដានពីសុខភាពសត្វព្រៃ។

អនុផ្នែកទី២
គ្រឹះស្ថានឧទ្យានសត្វព្រៃ

មាត្រា៥៦១ .- លក្ខខណ្ឌតម្រូវ

១- គ្រឹះស្ថានឧទ្យានសត្វព្រៃត្រូវស្នើសុំការអនុញ្ញាតបង្កើតគ្រឹះស្ថានឧទ្យានសត្វព្រៃ និងការនាំចូល ការនាំចេញសត្វព្រៃរបស់គ្រឹះស្ថានឧទ្យានសត្វព្រៃពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

២- ប្រាក់ចំណូលដែលប្រមូលបានពីការចេញអាជ្ញាបណ្ណឬលិខិតអនុញ្ញាតត្រូវប្រើប្រាស់គាំទ្រដល់ការអភិរក្សសត្វព្រៃ និងជីវៈចម្រុះរួមទាំងការអនុវត្តផែនការស្តារនិងគ្រប់គ្រងសត្វព្រៃឬការប្រើប្រាស់ដទៃទៀតសម្រាប់គោលដៅអភិរក្ស។

មាត្រា៥៦២ .- ការហាមឃាត់

ហាមឃាត់ចំពោះការបរបាញ់ ការទាក់ ការចាប់ ឬការប្រមូលសត្វព្រៃ និងសកម្មភាពផ្សេងទៀតពីព្រៃធម្មជាតិនូវប្រភេទសត្វព្រៃ ដូចបានកំណត់ក្នុងចំណាត់ថ្នាក់ទី២ដល់ទី៦ នៃបញ្ជីចំណាត់ថ្នាក់សត្វព្រៃសម្រាប់បម្រើឱ្យគ្រឹះស្ថានឧទ្យានសត្វព្រៃ លើកលែងមានការអនុញ្ញាតពិសេសពីរាជរដ្ឋាភិបាល។

មាត្រា៥៦៣ .- ការស្នើសុំ

ការស្នើសុំការប្រមូល ការទាក់ ការចាប់សត្វព្រៃ តាមប្រភេទដូចបានកំណត់ក្នុងបញ្ជីចំណាត់ថ្នាក់ទី៧និងទី៨ សម្រាប់គោលដៅរបស់គ្រឹះស្ថានឧទ្យានសត្វព្រៃ ត្រូវមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា៥៦៤ .- ការផ្តល់និងការផ្អាកបណ្តោះអាសន្ននៃលិខិតអនុញ្ញាត

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិអាចចេញលិខិតអនុញ្ញាតឱ្យគ្រឹះស្ថានឧទ្យានសត្វព្រៃធ្វើអាជីវកម្មសត្វព្រៃស្របតាមនីតិវិធីច្បាប់ជាធរមាននិងបទប្បញ្ញត្តិនៃក្រមនេះ។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិអាចចេញលិខិតផ្អាកជាបណ្តោះអាសន្ន លិខិតបិទទីតាំង ឬលិខិតប្រមូលដកហូតសត្វព្រៃក្នុងបរិវេណនិងក្នុងគ្រឹះស្ថានឧទ្យានសត្វព្រៃក្នុងករណីប្រតិបត្តិកឬម្ចាស់គ្រឹះស្ថានឧទ្យានសត្វព្រៃមិនអនុវត្តតាមលិខិតអនុញ្ញាតនិងលិខិតបទដ្ឋានគតិយុត្តដែលចេញដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិបានចេញឱ្យ។

ផ្នែកទី៥
លិខិតអនុញ្ញាតបរបាញ់សត្វព្រៃ

មាត្រា៥៦៥ .- លិខិតអនុញ្ញាតបរបាញ់សត្វព្រៃ

១- ការបរបាញ់សត្វព្រៃដូចបានកំណត់នៅក្នុងបញ្ជីចំណាត់ថ្នាក់ទី៧និងទី៨ ត្រូវមានលិខិតអនុញ្ញាតចេញដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា៥៥៦ .– ការគ្រប់គ្រងលើការអភិរក្ស

ការគ្រប់គ្រងលើការអភិរក្សមាន៖

ក- ការប្តូរទីកន្លែងសម្រាប់សត្វព្រៃប្រភេទណាមួយទៅកេទីដម្រកសមស្រប ក្នុងគោលបំណងស្តារប្រភេទសត្វព្រៃ ការដាក់ចិញ្ចឹមសត្វព្រៃឡើងវិញ ឬការបំពេញបន្ថែមនូវក្រុមសត្វព្រៃ ឬដើម្បីទប់ស្កាត់ការវិនាសផុតពូជក្រុមសត្វព្រៃដែលមិនអាចជៀសវាងបាន។

ខ- ការស្រាវជ្រាវឬការគ្រប់គ្រងក្រុមការ:រស់ ដោយពុំចាំបាច់សម្លាប់ឬបំផ្លាញសត្វព្រៃ។

គ- ការចាប់សត្វព្រៃសម្រាប់គោលដៅធ្វើឱ្យមានលំនឹងនៃប្រភេទក្រុមសត្វព្រៃនិងបង្កាត់ពូជដើម្បីអភិរក្សប្រភេទសត្វដែលទទួលរងការគំរាមកំហែងនៅក្នុងកន្លែងបង្កាត់ពូជដែលបានចុះបញ្ជី។

មាត្រា៥៥៧ .– ការបន្លាស់ទីកន្លែង

ការបន្លាស់ទីកន្លែងនិងការចាប់សត្វព្រៃសម្រាប់ការបង្កាត់ពូជដើម្បីអភិរក្ស ឬគ្រប់គ្រងលើការងារអភិរក្សប្រភេទសត្វព្រៃក្នុងចំណាត់ថ្នាក់ទី២ដល់ទី៦ អាចអនុញ្ញាតដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា៥៥៨ .– ការធ្វើចត្តាឡីស័កនិងការអង្កេតតាមដានពីសុខភាពសត្វព្រៃ

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិតម្រូវឱ្យធ្វើចត្តាឡីស័កសត្វព្រៃដើម្បីអង្កេតតាមដានពីសុខភាពក្នុងកសិដ្ឋានចិញ្ចឹមសត្វព្រៃ នៅមុនពេលដែលសត្វព្រៃទាំងនោះត្រូវបានប្តូរទីតាំង នាំមកបញ្ចូល ឬផ្ទេរវាងកន្លែងចត្តាឡីស័ក និងជម្រកធម្មជាតិ ឬកសិដ្ឋានចិញ្ចឹមសត្វព្រៃ ឬកន្លែងបង្កាត់ពូជអភិរក្ស ឬមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ឬគ្រឹះស្ថានឧទ្យានសត្វព្រៃ។ ក្រោយពីការធ្វើចត្តាឡីស័ក និងការអង្កេតតាមដានពីសុខភាពរបស់សត្វព្រៃ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវចេញលិខិតបញ្ជាក់ដូចខាងក្រោម៖

ក- សត្វព្រៃត្រូវបានធ្វើចត្តាឡីស័កនិងអង្កេតតាមដានពីសុខភាពមិនឱ្យលើសពី១៤(ដប់បួន)ថ្ងៃ និងត្រូវពិនិត្យនៅមុនពេលប្តូរទីតាំងនាំចូលទៅជម្រកធម្មជាតិវិញឬផ្ទេរទៅកន្លែងផ្សេង។

ខ- សត្វព្រៃនោះមិនបង្ហាញពីរោគសញ្ញាជំងឺឬមានរបួស។

គ- សត្វព្រៃដែលមានសុខភាពល្អនិងសត្វដែលមានជំងឺដោយមានស្លាកសម្គាល់។

២- ក្នុងករណីដែលសត្វព្រៃនោះមានជំងឺឬស្លាប់នៅក្នុងកំលុងពេលធ្វើចត្តាឡីស័ក ម្ចាស់ទីតាំងឬអ្នកគ្រប់គ្រងទីតាំងត្រូវជូនដំណឹងជាបន្ទាន់ទៅកាន់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា៥៥៩ .– វិធីសាស្ត្រអង្កេតតាមដានសុខភាពសត្វព្រៃ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវ៖

ក- កំណត់អត្តសញ្ញាណជំងឺសត្វព្រៃនិងត្រូវផ្សព្វផ្សាយជាសាធារណៈអំពីជំងឺដែលបានរកឃើញ។

ខ- រៀបចំវិធីសាស្ត្រអង្កេតតាមដានសុខភាពនិងជំងឺសត្វព្រៃ។

គ- ស៊ើបអង្កេត ចងក្រងឯកសារ និងឆ្លើយតបចំពោះការរាតត្បាតនៃជំងឺសត្វព្រៃ។

ឃ- រាយការណ៍អំពីលទ្ធផលនៃការសិក្សា ការអង្កេតតាមដានសុខភាពសត្វព្រៃ និងការស៊ើបអង្កេតជំងឺសត្វព្រៃ។

មូលដ្ឋានជាលក្ខណៈគ្រួសារនិងប្រពៃណី។ ប្រភេទសត្វព្រៃដែលប្រើប្រាស់ដោយសហគមន៍មូលដ្ឋានជាលក្ខណៈគ្រួសារ និងប្រពៃណីត្រូវកំណត់ដោយប្រកាសអន្តរក្រសួង។

ផ្នែកទី៤
ករណីលើកលែងសម្រាប់ការបរបាញ់សត្វព្រៃ
អនុផ្នែកទី១
ការគ្រប់គ្រងលើការបង្កគ្រោះថ្នាក់ដល់ជីវិតមនុស្ស

មាត្រា៥៥០ .- ការកំណត់ការគ្រប់គ្រងលើការបង្កគ្រោះថ្នាក់ដល់ជីវិតមនុស្ស

១- ក្នុងករណីសត្វព្រៃបង្កគ្រោះថ្នាក់ដល់ជីវិតមនុស្ស ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិអាចចាត់វិធានការសមស្របក្នុងការសម្លាប់សត្វព្រៃដែលបង្កហេតុនោះក្នុងករណីចាំបាច់។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំប្រកាសស្តីពីការត្រួតពិនិត្យសត្វព្រៃដែលបង្កគ្រោះថ្នាក់ដល់ជីវិតមនុស្ស។

មាត្រា៥៥១ .- វិធីសាស្ត្រគ្រប់គ្រងប្រភេទសត្វព្រៃបង្កគ្រោះថ្នាក់

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំវិធីសាស្ត្រក្នុងការគ្រប់គ្រងប្រភេទសត្វព្រៃបង្កគ្រោះថ្នាក់ស្របតាមលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានាដល់សុខុមាលភាពរបស់សត្វព្រៃ និងការកាត់បន្ថយហានិភ័យទៅលើសត្វព្រៃដទៃទៀតឬជីវិតមនុស្ស។

មាត្រា៥៥២ .- សត្វព្រៃដែលត្រូវបានអនុញ្ញាតឱ្យសម្លាប់ឬបំផ្លាញចោល

សត្វព្រៃដែលបានបង្កឱ្យមានគ្រោះថ្នាក់ដល់ជីវិតមនុស្សត្រូវបានអនុញ្ញាតឱ្យសម្លាប់ឬធ្វើឱ្យរបួស។ ក្នុងករណីសត្វព្រៃរងរបួសមិនអាចជាសះស្បើយវិញបានត្រូវបំផ្លាញ ឬសម្លាប់ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា៥៥៣ .- សិទ្ធិក្នុងការគ្រប់គ្រងប្រភេទសត្វក្នុងចំណាត់ថ្នាក់ទី២ដល់ទី៨

បុគ្គលអាចគ្រប់គ្រងប្រភេទសត្វព្រៃស្ថិតនៅក្នុងចំណាត់ថ្នាក់ទី២ដល់ទី៨ ដែលអាចបង្កគ្រោះថ្នាក់ដល់ជីវិតមនុស្សដោយមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬក្រសួងស្ថាប័នមានសមត្ថកិច្ច។

មាត្រា៥៥៤ .- ប្រភេទសត្វព្រៃដែលមិនមានដើមកំណើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ប្រភេទសត្វព្រៃស្ថិតនៅក្នុងចំណាត់ថ្នាក់ទី២ដល់ទី៦ និង/ឬមិនមានដើមកំណើតនៅក្នុងតំបន់ការពារធម្មជាតិដែលអាចបង្កគ្រោះថ្នាក់ឬគាបសង្កត់ដល់ជីវៈចម្រុះត្រូវធ្វើការគ្រប់គ្រងទាំងនៅក្នុងឬក្រៅតំបន់ការពារធម្មជាតិ។ ក្នុងករណីសត្វព្រៃដែលបានបង្កឱ្យមានគ្រោះថ្នាក់ដល់ជីវិតមនុស្សឬគាបសង្កត់ដល់ជីវៈចម្រុះ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិអាចអនុញ្ញាតឱ្យសម្លាប់ឬធ្វើឱ្យរបួស។

មាត្រា៥៥៥ .- ការចាប់សត្វព្រៃរស់សម្រាប់គោលដៅអភិរក្ស

ការចាប់សត្វព្រៃរស់តាមប្រភេទដូចបានកំណត់ក្នុងចំណាត់ថ្នាក់ណាមួយ សម្រាប់គោលដៅបង្កាត់ពូជអភិរក្ស ឬការគ្រប់គ្រងលើការដោះអភិរក្សត្រូវមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

ផ្នែកទី៣
ការហាមឃាត់ចំពោះការបរបាញ់សត្វព្រៃ

មាត្រា៥៤៨ .- ការហាមឃាត់ការបរបាញ់សត្វព្រៃ

១- ហាមឃាត់រាល់ការបរបាញ់ ការទាក់ ការចាប់ ការបំពុល ការសម្លាប់សត្វព្រៃ ឬការយោយីបំផ្លិចបំផ្លាញ តាមមធ្យោបាយនានា និងប្រភេទសត្វព្រៃ ដូចខាងក្រោម៖

ក- ប្រភេទសត្វព្រៃចំណាត់ថ្នាក់ទី២ដល់ទី៦ ដូចមានចែងក្នុងមាត្រា៥៤៦(ចំណាត់ថ្នាក់ប្រភេទសត្វព្រៃ) នៃក្រមនេះ។

ខ- ប្រភេទសត្វព្រៃដូចមានចែងក្នុងចំណាត់ថ្នាក់ទី៧ ដោយប្រើមធ្យោបាយដែលច្បាប់ហាមឃាត់។

គ- ការបរបាញ់ដោយសហគមន៍មូលដ្ឋាន ដោយពុំមានលិខិតអនុញ្ញាតកំណាត់កូតា ដែលចេញដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ឃ- ការកាន់កាប់ ការផលិត ការរក្សាទុក ការដឹកជញ្ជូន ឬការនាំយកឧបករណ៍ដែលអាចប្រើប្រាស់សម្រាប់បរបាញ់សត្វព្រៃ តាមមធ្យោបាយគ្រប់រូបភាព មានជាអាទិ៍ អន្ទាក់ អង្គប់ កាំភ្លើង ឬអាវុធកែច្នៃខ្សែលួស ខ្សែប្រ៊ាំងកង់ ឬខ្សែប្រ៊ាំងម៉ូតូ ឧបករណ៍ឆក់ សំណាញ់ ឬឧបករណ៍ផ្សេងៗទៀត។

ង- ការដឹកជញ្ជូនឬយកធ្វើជាកម្មសិទ្ធិ ចំពោះសត្វព្រៃក្នុងចំណាត់ថ្នាក់ទី៨ ដូចមានចែងក្នុងមាត្រា៥៤៦ (ចំណាត់ថ្នាក់ប្រភេទសត្វព្រៃ)នៃក្រមនេះ ដោយគ្មានលិខិតអនុញ្ញាតបរបាញ់និងគ្មានលិខិតអនុញ្ញាតដឹកជញ្ជូន។

ច- ទាក់ចាប់ ប្រមូល ទិញសត្វព្រៃដោយខុសច្បាប់ពីក្នុងតំបន់ការពារធម្មជាតិ សម្រាប់គោលដៅបង្កើតឬក្សាទុកក្នុងកសិដ្ឋានចិញ្ចឹមសត្វព្រៃ គ្រឹះស្ថានឧទ្យានសត្វព្រៃ ការចាប់ប្រមូលមករក្សាទុកជាឯកជន។

ឆ- ការនាំសត្វចិញ្ចឹមចូលទៅក្នុងតំបន់ស្នូលនិងតំបន់អភិរក្ស។

២- រាល់សកម្មភាពដូចមានចែងខាងលើនេះ ត្រូវបានលើកលែង ចំពោះសកម្មភាពអនុវត្តក្នុងគោលដៅគ្រប់គ្រង និងអភិរក្សសត្វព្រៃ ឬបង្កើតទីតាំងបង្កាត់ពូជអភិរក្ស និងអភិរក្សធនធានពន្ធុ មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និងគ្រឹះស្ថានឧទ្យានសត្វព្រៃក្នុងគោលបំណងរក្សាទុកសត្វព្រៃគ្រប់ប្រភេទ ដែលត្រូវបានអនុញ្ញាតដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

មាត្រា៥៤៩ .- ការហាមឃាត់ខ្ទៅ

១- ហាមឃាត់ការបរបាញ់ ការទាក់ ការដាក់អន្ទាក់ ការចាប់ ការបំពុល ការសម្លាប់សត្វព្រៃ ឬការយោយីបំផ្លិចបំផ្លាញទៅលើប្រភេទសត្វព្រៃ និងតាមមធ្យោបាយនានា ដូចខាងក្រោម៖

ក- ប្រភេទសត្វព្រៃស្ថិតក្នុងចំណាត់ថ្នាក់ទី២ដល់ទី៦ ដូចមានចែងក្នុងមាត្រា៥៤៦(ចំណាត់ថ្នាក់ប្រភេទសត្វព្រៃ)នៃក្រមនេះ លើកលែងតែករណីដូចបានកំណត់ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

ខ- ប្រភេទសត្វព្រៃស្ថិតក្នុងចំណាត់ថ្នាក់ទី៧ ដូចមានចែងក្នុងមាត្រា៥៤៦(ចំណាត់ថ្នាក់ប្រភេទសត្វព្រៃ) នៃក្រមនេះ ដោយប្រើមធ្យោបាយដែលច្បាប់ហាមឃាត់។

គ- ការផលិត ការកែច្នៃ ទិញ ជួញដូរ ដឹកជញ្ជូន ដាក់អន្ទាក់ អង្គប់ សំណាញ់នៅជាប់នឹងដី ឬលើអាកាស ប្រើអាវុធកែច្នៃ អាវុធជាតិផ្ទុះ ថ្នាំពុល និងមធ្យោបាយផ្សេងទៀត។

ឃ- ការបរបាញ់ ការចាប់ ឬំខានសត្វព្រៃដោយប្រើយានយន្តគ្រប់ប្រភេទមិនថាលើទឹក លើដី ឬលើអាកាស។

២- ការហាមឃាត់ដូចមានចែងខាងលើនេះ ត្រូវបានលើកលែង ចំពោះប្រភេទសត្វព្រៃស្ថិតក្នុងចំណាត់ថ្នាក់ដែលមានចែងក្នុងមាត្រា៥៤៦(ចំណាត់ថ្នាក់ប្រភេទសត្វព្រៃ)នៃក្រមនេះ ដែលប្រើប្រាស់ដោយសហគមន៍

ROYAUME DU CAMBODGE
MINISTERE DU PALAIS ROYAL

ផ្នែកទី២
ការធ្វើចំណាត់ថ្នាក់ប្រភេទសត្វព្រៃ

មាត្រា៥៤៤ .– សត្វព្រៃ

សត្វព្រៃគ្រប់ប្រភេទដែលជាសមាសភាគនៃធនធានធម្មជាតិ ត្រូវចាត់ទុកជាសម្បត្តិដ៏លើកលែងតែមានបញ្ញត្តិពិសេសក្នុងក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

មាត្រា៥៤៥ .– បញ្ជីចំណាត់ថ្នាក់ប្រភេទសត្វព្រៃ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសម្របសម្រួល និងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំកត់ត្រានិងគ្រប់គ្រងបញ្ជីចំណាត់ថ្នាក់ប្រភេទសត្វព្រៃរួមទាំងប្រភេទសត្វ ដែលកំពុងរងការគំរាមកំហែង សម្រាប់គ្រប់គ្រងនិងការពារក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ បញ្ជីចំណាត់ថ្នាក់ប្រភេទសត្វព្រៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា៥៤៦ .– ចំណាត់ថ្នាក់ប្រភេទសត្វព្រៃ

១- សត្វព្រៃដែលមានក្នុងបញ្ជីចំណាត់ថ្នាក់សម្រាប់ប្រភេទនីមួយៗ ដែលកំពុងរងគ្រោះថ្នាក់ត្រូវបានបែងចែកជា៨(ប្រាំបី)ចំណាត់ថ្នាក់ដូចខាងក្រោម៖

ក- ចំណាត់ថ្នាក់ទី១៖ ប្រភេទផុតពូជទាំងស្រុង។

ខ- ចំណាត់ថ្នាក់ទី២៖ ប្រភេទផុតពូជពីក្នុងព្រៃ។

គ- ចំណាត់ថ្នាក់ទី៣៖ ប្រភេទជិតផុតពូជបំផុត។

ឃ- ចំណាត់ថ្នាក់ទី៤៖ ប្រភេទជិតផុតពូជ។

ង- ចំណាត់ថ្នាក់ទី៥៖ ប្រភេទងាយទទួលរងគ្រោះ។

ច- ចំណាត់ថ្នាក់ទី៦៖ ប្រភេទជិតទទួលរងគ្រោះ។

ឆ- ចំណាត់ថ្នាក់ទី៧៖ ប្រភេទមិនទាន់រងការគំរាមកំហែង។

ជ- ចំណាត់ថ្នាក់ទី៨៖ ប្រភេទមិនមានទិន្នន័យគ្រប់គ្រាន់។

២- ការចាត់ថ្នាក់ខាងលើ ត្រូវធ្វើឡើងស្របទៅតាមស្ថានភាពជាក់ស្តែងដោយមានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនិងអ្នកជំនាញការបច្ចេកទេស។

៣- ការកំណត់និយមន័យនិងលក្ខណៈវិនិច្ឆ័យរបស់ចំណាត់ថ្នាក់ប្រភេទសត្វព្រៃនីមួយៗខាងលើត្រូវផ្អែកតាមស្ថានភាពជាក់ស្តែងនិងស្របតាមលក្ខណៈវិទ្យាសាស្ត្រ។

៤- បញ្ជីចំណាត់ថ្នាក់ប្រភេទសត្វព្រៃត្រូវធ្វើបច្ចុប្បន្នកម្មផ្អែកលើស្ថានភាពជាក់ស្តែងនិងលក្ខណៈវិនិច្ឆ័យស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

មាត្រា៥៤៧ .– ការដំឡើងចំណាត់ថ្នាក់នៃប្រភេទសត្វព្រៃ

គ្រប់ប្រភេទសត្វព្រៃអាចត្រូវដំឡើងចំណាត់ថ្នាក់ដោយផ្អែកលើមូលដ្ឋាននៃកម្រិតហានិភ័យ ការគំរាមកំហែងស្ថានភាពប្រភេទសត្វព្រៃ និងតម្លៃបេតិកភណ្ឌវប្បធម៌ឬសារៈសំខាន់ផ្នែកសេដ្ឋកិច្ច ស្របតាមចំណាត់ថ្នាក់ដូចមានចែងក្នុងមាត្រា៥៤៦នៃក្រមនេះ។

ទំព័រ៤០៨ អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

ក- រៀបចំលិខិតបទដ្ឋានគតិយុត្តនិងនីតិវិធីគ្រប់គ្រង កិច្ចគាំពារ និងការអភិរក្សសត្វព្រៃ។

ខ- បង្កើតនិងអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ផែនការគ្រប់គ្រង និងផែនការសកម្មភាពអភិរក្សប្រភេទសត្វព្រៃដែលទទួលរងការគំរាមកំហែង ស្របតាមលិខិតបទដ្ឋានគតិយុត្តឬលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

គ- តាមដាន ស្រាវជ្រាវ ទប់ស្កាត់បទល្មើសសត្វព្រៃគ្រប់ប្រភេទនៅក្នុងតំបន់ការពារធម្មជាតិរួមទាំងការនាំចេញ ការនាំចូល ការធ្វើសន្និធិ ការចរាចរ ការធ្វើអាជីវកម្ម ការប្រើប្រាស់សត្វព្រៃ និងការបរិភោគសាច់សត្វព្រៃ ដែលត្រូវបានប្រមូលផលដោយគ្មានលិខិតអនុញ្ញាត។

ឃ- ពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានពាក់ព័ន្ធនានា ស៊ើបអង្កេតតាមដាន ត្រួតពិនិត្យ កសាងសំណុំរឿងបទល្មើសសត្វព្រៃនិងធ្វើជាអង្គភាពដើមបណ្តឹងរដ្ឋប្បវេណីតាមនីតិវិធីច្បាប់។

ង- បង្កើត គ្រប់គ្រង និងរក្សាប្រព័ន្ធទិន្នន័យពាក់ព័ន្ធនឹងបទល្មើសសត្វព្រៃ។

ច- ពង្រឹងយន្តការមានស្រាប់ដើម្បីទប់ស្កាត់ការជួញដូរសត្វព្រៃ និងបង្កើតវិធីសាស្ត្រថ្មីបន្ថែមទៀតសម្រាប់ប្រយុទ្ធប្រឆាំងនឹងបទល្មើសសត្វព្រៃឆ្លងដែន ឬប្រើប្រាស់ព្រះរាជាណាចក្រកម្ពុជាជាគោលដៅឆ្លងកាត់ទៅកាន់ប្រទេសដទៃទៀត។

ឆ- ធ្វើបច្ចុប្បន្នកម្មចំណាត់ថ្នាក់ប្រភេទសត្វព្រៃ។

ជ- បង្កើតនិងអនុវត្តកម្មវិធីការពារ អភិរក្ស ពិនិត្យតាមដាន និងស្រាវជ្រាវសត្វព្រៃដែលជាប្រភេទទទួលរងគ្រោះថ្នាក់ ដូចមានចែងក្នុងមាត្រា៥៤៦(ចំណាត់ថ្នាក់ប្រភេទសត្វព្រៃ)នៃក្រមនេះ។

ឈ- រៀបចំលិខិតបទដ្ឋានគតិយុត្ត ការងារគ្រប់គ្រង និងការចេញលិខិតអនុញ្ញាតបរបាញ់សត្វព្រៃសម្រាប់សហគមន៍មូលដ្ឋានដែលនៅក្នុងឬក្រៅតំបន់ការពារធម្មជាតិ។

ញ- ពិនិត្យឡើងវិញ បដិសេធ ឬអនុញ្ញាតការប្រមាញ់សត្វព្រៃតាមលក្ខខណ្ឌនានាស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

ដ- ត្រួតពិនិត្យ តាមដាន និង/ឬចេញបទបញ្ជាប្រតិបត្តិការនៅឧទ្យានសត្វព្រៃ មជ្ឈមណ្ឌលបង្កាត់ពូជអភិរក្ស មជ្ឈមណ្ឌលសង្គ្រោះ និងស្ថានសម្បទាដល់សត្វព្រៃ និងកន្លែងប្រមូលផលសត្វព្រៃដើម្បីធ្វើអាជីវកម្ម។

ឋ- ពិនិត្យឡើងវិញ បដិសេធ ឬអនុញ្ញាតសំណើចាប់សត្វព្រៃរស់សម្រាប់គោលបំណងបង្កាត់ពូជដើម្បីអភិរក្ស។

ឌ- ជានាថាលិខិតអនុញ្ញាតនិងដំណើរការផ្តល់លិខិតអនុញ្ញាតត្រូវមានតម្លាភាពនិងត្រូវបានផ្សព្វផ្សាយជាសាធារណៈ។

ឍ- រៀបចំយុទ្ធសាស្ត្រស្តីពីការតាមដាននិងថែទាំសុខភាពសត្វព្រៃ ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងសម្របសម្រួលឱ្យមានការឆ្លើយតប ចំពោះករណីជំងឺរាតត្បាត ជំងឺឆ្លង និងសុខភាពសត្វព្រៃ។

ណ- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ភាគីពាក់ព័ន្ធ និងចូលរួមនៅក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ។

ត- លើកកម្ពស់ការអប់រំជាសាធារណៈនិងផ្សព្វផ្សាយកម្មវិធីដែលបង្ហាញពីសារៈសំខាន់នៃការគ្រប់គ្រងកិច្ចគាំពារ និងការអភិរក្សសត្វព្រៃដោយនិរន្តរភាព។

ថ- ហាមឃាត់ចំពោះការបំផ្លាញឬការកែប្រែទីជម្រកធម្មជាតិរបស់ប្រភេទសត្វព្រៃ ដោយគ្មានការអនុញ្ញាត។

២- ការបែងចែកមុខងារ តួនាទី និងការកិច្ចជាក់លាក់ទៅឱ្យថ្នាក់ដឹកនាំនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៥៣៨ .- ផែនការគ្រប់គ្រងប្រភេទរាតត្បាត

ផែនការគ្រប់គ្រងប្រភេទរាតត្បាតត្រូវកំណត់ខ្លឹមសារជាក់លាក់ ដូចខាងក្រោម៖

ក- គោលបំណង លក្ខណៈវិនិច្ឆ័យ វិធានការ សូចនាករតាមដាន និងលទ្ធផលរំពឹងទុក។

ខ- សកម្មភាពគ្រប់គ្រង វិធានការ វិធីសាស្ត្រកំចាត់ ទប់ស្កាត់ និងរារាំងប្រភេទរាតត្បាត។

គ- ទំហំ ទីតាំង កូមិសាស្ត្រ ប្រភព និងប្រភេទរាតត្បាត។

ឃ- ធនធានជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងទីជម្រកសំខាន់ៗនៅទីតាំងត្រូវគ្រប់គ្រងប្រភេទរាតត្បាត។

ង- ផ្លូវចម្លងដោយផ្ទាល់និងប្រយោល វិធានការឆ្លើយតបនិងចាំបាច់ក្នុងការទប់ស្កាត់ និងរារាំងប្រភេទរាតត្បាត។

ច- ការបញ្ជាបផែនការយុទ្ធសាស្ត្រជាតិ ផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះ និងផែនការអភិរក្ស។

ឆ- ពេលវេលានិងធនធានហិរញ្ញវត្ថុសម្រាប់អនុវត្ត។

មាត្រា៥៣៩ .- បញ្ជីសម្រាប់ប្រភេទវត្ថុជាតិព្រៃរាតត្បាត

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំបញ្ជីថ្នាក់ជាតិសម្រាប់ប្រភេទវត្ថុជាតិព្រៃរាតត្បាតដែលបង្កគ្រោះថ្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬការនាំចូលប្រភេទវត្ថុជាតិព្រៃទាំងនោះមកក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា៥៤០ .- ផែនការលុបបំបាត់ប្រភេទវត្ថុជាតិព្រៃរាតត្បាត

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបផែនការលុបបំបាត់ប្រភេទវត្ថុជាតិព្រៃរាតត្បាត ដើម្បីកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់ពីប្រភេទវត្ថុជាតិព្រៃរាតត្បាតដែលប៉ះពាល់បរិស្ថាន សេដ្ឋកិច្ច និងសង្គម។

មាត្រា៥៤១ .- លក្ខខណ្ឌតម្រូវនៃការអនុញ្ញាត

ការនាំចូលប្រភេទវត្ថុជាតិព្រៃរាតត្បាតណាមួយ ចូលទៅក្នុងតំបន់ការពារធម្មជាតិត្រូវមានការឯកភាពជាមុនពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ជំពូកទី៨
ការគ្រប់គ្រង អភិរក្សការពារ និងការអភិរក្សសត្វព្រៃ
ផ្នែកទី១
ស្ថាប័នទទួលខុសត្រូវ

មាត្រា៥៤២ .- ស្ថាប័នទទួលខុសត្រូវ

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលខុសត្រូវលើកិច្ចគាំពារ ការអភិរក្ស និងការគ្រប់គ្រងសត្វព្រៃគ្រប់ប្រភេទស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ។

២- ការគ្រប់គ្រងសត្វព្រៃដែលស្ថិតក្រៅតំបន់ការពារធម្មជាតិ ជាសមត្ថកិច្ចរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យព្រៃឈើ។

មាត្រា៥៤៣ .- តួនាទីនិងការកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទីនិងការកិច្ចដូចខាងក្រោម៖

ទំព័រ៤១០ អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

ក- គោលបំណង លក្ខណៈនៃច្បាប់ វិធានការ និងលទ្ធផលរំពឹងទុក។
ខ- សកម្មភាពគ្រប់គ្រងនិងអភិរក្សដើម្បីធានានូវមុខងារ និងតួនាទីក្នុងប្រព័ន្ធអេកូឡូស៊ី។
គ- ការគំរាមកំហែងដោយផ្ទាល់និងប្រយោល ដោយមានវិធានការឆ្លើយតបចាំបាច់ក្នុងការកាត់បន្ថយការគំរាមកំហែង និងធានាសុវត្ថិភាពប្រភេទវុក្ខជាតិព្រៃទាំងនោះ។
ឃ- ទីជម្រកសំខាន់ៗឬពិសេសសម្រាប់ការអភិរក្សវុក្ខជាតិព្រៃ។
ង- ការបញ្ជាបទៅក្នុងផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ។
ច- ការបញ្ជាបផែនការយុទ្ធសាស្ត្រជាតិនិងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះនិងផែនការអភិរក្សនានា។
ឆ- ពេលវេលានិងធនធានហិរញ្ញវត្ថុសម្រាប់អនុវត្ត។

មាត្រា៥៣៤ .- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើការស្តារវុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង

គម្រោងផែនការឬសកម្មភាពស្តារវុក្ខជាតិព្រៃត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដូចមានចែងក្នុងមាតិកាទី២(ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន)នៃគន្លឹទី៥នៃក្រមនេះ ក្នុងករណីដែលមានផលប៉ះពាល់ខ្លាំងដល់ទីជម្រក មុខងារនិងតួនាទីប្រព័ន្ធអេកូឡូស៊ី។

មាត្រា៥៣៥ .- ការរៀបចំរបាយការណ៍និងការអង្កេតតាមដាន

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសហការជាមួយភាគីពាក់ព័ន្ធត្រូវរៀបចំប្រព័ន្ធអង្កេតតាមដាននិងការរៀបចំរបាយការណ៍អំពីការអនុវត្តផែនការគ្រប់គ្រងនិងស្តារប្រភេទវុក្ខជាតិព្រៃនិងសារព័ន្ធវុក្ខជាតិព្រៃ។

ផ្នែកទី៦
ការគ្រប់គ្រងប្រភេទឧភតភ្ជាត

មាត្រា៥៣៦ .- បញ្ជីប្រភេទរាតត្បាត

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសម្របសម្រួលនិងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំកត់ត្រា និងគ្រប់គ្រងបញ្ជីប្រភេទរាតត្បាតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រោយទទួលបញ្ជីពីរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវពិនិត្យផ្ទៀងផ្ទាត់បញ្ជីប្រភេទរាតត្បាតមុនដាក់ជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។

២- ហាមឃាត់ការនាំចូលប្រភេទរាតត្បាតទាំងឡាយណាដែលមិនមានការឯកភាពពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា៥៣៧ .- ការគ្រប់គ្រងប្រភេទរាតត្បាត

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំសកម្មភាពគ្រប់គ្រងប្រភេទរាតត្បាត ដោយពិចារណាទៅលើផលប៉ះពាល់អវិជ្ជមាននិងហានិភ័យចំពោះសត្វ វុក្ខជាតិព្រៃ ប្រព័ន្ធអេកូឡូស៊ី បរិស្ថាន សេដ្ឋកិច្ច និងសង្គម។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអ្នកជំនាញបច្ចេកទេសត្រូវរៀបចំសកម្មភាពគ្រប់គ្រងប្រភេទរាតត្បាត ដើម្បីកំណត់៖

ក- ផ្លូវដែលប្រភេទវុក្ខជាតិព្រៃរាតត្បាតនោះចូលមកកាន់ដែនសមត្ថកិច្ចរបស់ខ្លួន។
ខ- វិធីសាស្ត្រនៃការគ្រប់គ្រងប្រភេទវុក្ខជាតិព្រៃដែលរាតត្បាតដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
គ- វិធីសាស្ត្រលុបបំបាត់ប្រភេទវុក្ខជាតិព្រៃដែលរាតត្បាត និងបង្កមហន្តរាយ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៤១១

មាត្រា៥២៩ .- ព័ត៌មានវិទ្យាសាស្ត្រមិនគ្រប់គ្រាន់

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិអាចបដិសេធក្នុងការផ្តល់លិខិតអនុញ្ញាតពិសេស ដូចមានចែងក្នុងមាត្រា៥២៨(ការផ្តល់លិខិតអនុញ្ញាតសម្រាប់គោលបំណងផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រ)នៃក្រមនេះ ក្នុងករណីមិនមានព័ត៌មានវិទ្យាសាស្ត្រគ្រប់គ្រាន់ ដើម្បីធ្វើការកំណត់អំពីផលប៉ះពាល់លើប្រភេទវត្ថុជាតិព្រៃដែលទទួលរងការគំរាមកំហែង។

២- ក្នុងករណីលិខិតអនុញ្ញាតត្រូវបានផ្តល់សម្រាប់គោលបំណងវិទ្យាសាស្ត្រ មិនមានព័ត៌មានវិទ្យាសាស្ត្រគ្រប់គ្រាន់ដើម្បីធ្វើការកំណត់ច្បាស់លាស់ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិអាចធ្វើការវិនិច្ឆ័យ ដើម្បីដាក់កំហិតទៅលើកម្រិតដែលកាត់បន្ថយលទ្ធភាព និងសកម្មភាពនៃការប្រមូលទាំងនេះ ដែលនឹងបង្ក ឱ្យមានការផុតពូជនៃប្រភេទវត្ថុជាតិព្រៃដែលកំពុងរងការគំរាមកំហែងឬបង្កការខូចខាតដែលមិនអាចជំនួសបាន។

មាត្រា៥៣០ .- លិខិតអនុញ្ញាតប្រមូលប្រភេទវត្ថុជាតិព្រៃ

ការស្នើសុំលិខិតអនុញ្ញាតប្រមូលយកប្រភេទវត្ថុជាតិព្រៃ ត្រូវដាក់សំណើសុំមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា៥៣១ .- ការព្យួរឬការលុបលិខិតអនុញ្ញាត

ក្នុងករណីចាំបាច់ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិព្យួរដោយបណ្តោះអាសន្នដោយមិនមានកាលកំណត់ ឬលុបលិខិតអនុញ្ញាតដោយផ្អែកលើទិន្នន័យថ្មីៗ ព័ត៌មានវិទ្យាសាស្ត្រឬការគំរាមកំហែងដែលបានរកឃើញថ្មីៗទៅលើប្រភេទវត្ថុជាតិព្រៃដែលកំពុងរងការគំរាមកំហែង និងទីជម្រក។

ផ្នែកទី៥
ផែនការគ្រប់គ្រងនិងស្តារវត្ថុជាតិព្រៃ

មាត្រា៥៣២ .- ផែនការគ្រប់គ្រងវត្ថុជាតិព្រៃ

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំផែនការគ្រប់គ្រងនិងស្តារវត្ថុជាតិព្រៃ សារព័ន្ធវត្ថុជាតិព្រៃដែលកំពុងរងការគំរាមកំហែងរយៈពេលខ្លី មធ្យម និងវែង នូវប្រភេទដែលកំពុងរងការគំរាមកំហែងមានដើមកំណើតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលបានកំណត់ក្នុងចំណាត់ថ្នាក់ប្រភេទវត្ថុជាតិព្រៃ ដូចមានចែងក្នុងមាត្រា៥២០(ចំណាត់ថ្នាក់ប្រភេទវត្ថុជាតិព្រៃ)នៃក្រមនេះ។

២- ផែនការគ្រប់គ្រងនិងស្តារវត្ថុជាតិព្រៃត្រូវរៀបចំឡើងក្នុងរយៈពេលខ្លី មធ្យម និងវែង ហើយអាចគ្របដណ្តប់ទៅលើប្រភេទវត្ថុជាតិព្រៃច្រើនប្រភេទ និងរួមបញ្ចូលទាំងប្រភេទសត្វព្រៃផងដែរ។

៣- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអ្នកជំនាញបច្ចេកទេស ដើម្បីរៀបចំផែនការគ្រប់គ្រងនិងស្តារវត្ថុជាតិព្រៃ សារព័ន្ធវត្ថុជាតិព្រៃដែលកំពុងរងការគំរាមកំហែង។

៤- ផែនការគ្រប់គ្រងនិងស្តារប្រភេទវត្ថុជាតិព្រៃ សារព័ន្ធវត្ថុជាតិព្រៃអាចត្រូវបញ្ចូលទៅក្នុងផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ។

មាត្រា៥៣៣ .- ផែនការគ្រប់គ្រងនិងស្តារវត្ថុជាតិព្រៃ

ផែនការគ្រប់គ្រងនិងស្តារវត្ថុជាតិព្រៃដែលកំពុងរងការគំរាមកំហែងត្រូវកំណត់នូវខ្លឹមសារជាក់លាក់ដូច

ផ្នែកទី៤
ការផ្តល់លិខិតអនុញ្ញាត ការប្រមូលយក និងការធ្វើពាណិជ្ជកម្ម

មាត្រា៥២៤ .- លិខិតអនុញ្ញាតសម្រាប់ធ្វើសកម្មភាពជាលក្ខណៈអន្តរជាតិ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវផ្តល់លិខិតអនុញ្ញាតពាក់ព័ន្ធទៅនឹងសកម្មភាពជាលក្ខណៈអន្តរជាតិទៅលើប្រភេទវត្ថុជាតិព្រៃ ដែលមានក្នុងបញ្ជីចំណាត់ថ្នាក់ប្រភេទទី៣ដល់ទី៨ នៃមាត្រា៥២០ (ចំណាត់ថ្នាក់ប្រភេទវត្ថុជាតិព្រៃ)នៃក្រមនេះ និងសំណាករុក្ខជាតិព្រៃទាំងនោះ ដូចខាងក្រោម៖

ក- ការថែរក្សា។

ខ- ការដើរជញ្ជូន។

គ- ការតាំងពិព័រណ៍។

ឃ- ការធ្វើសន្និធិ។

ង- ការផ្តល់ជាអំណោយថ្នាក់ដដែ។

ច- ការចូលរួមសកម្មភាពអន្តរជាតិដែលធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា៥២៥ .- ការតម្រូវឱ្យមានលិខិតអនុញ្ញាត

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិអាចផ្តល់លិខិតអនុញ្ញាតការជួញដូរ ឬការដើរជញ្ជូនវត្ថុជាតិព្រៃ ដែលស្ថិតក្នុងចំណាត់ថ្នាក់ប្រភេទទី៦និងទី៧នៃមាត្រា៥២០ (ចំណាត់ថ្នាក់ប្រភេទវត្ថុជាតិព្រៃ)នៃក្រមនេះ សម្រាប់ការប្រើប្រាស់ជាលក្ខណៈគ្រួសារនិងជាឱសថ។

២- ការផ្តល់លិខិតអនុញ្ញាតណាមួយត្រូវដាក់កម្រិតសមស្រប និងតាមពេលវេលានៃសកម្មភាពនោះ ដោយមិនត្រូវធ្វើឱ្យប៉ះពាល់ដល់ធម្មជាតិឬការស្តារឡើងវិញ។

មាត្រា៥២៦ .- ការលើកលែងលិខិតអនុញ្ញាត

សកម្មភាពខាងក្រោមនេះមិនតម្រូវឱ្យមានលិខិតអនុញ្ញាត៖

ក- ការប្រមូល ការដើរជញ្ជូន និងការប្រើប្រាស់ប្រភេទវត្ថុជាតិព្រៃក្នុងចំណាត់ថ្នាក់ប្រភេទទី៧ សម្រាប់ការប្រើប្រាស់ជាលក្ខណៈគ្រួសារនិងជាលក្ខណៈប្រពៃណី។

ខ- ការប្រមូលផល អនុផលព្រៃឈើពីចម្ការដាំដុះលើដីឯកជន។

មាត្រា៥២៧ .- លក្ខខណ្ឌមិនចេញលិខិតអនុញ្ញាត

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិមិនត្រូវចេញលិខិតអនុញ្ញាតក្នុងករណីដែលមិនមានព័ត៌មានបញ្ជាក់គ្រប់គ្រាន់ពីផ្នែកវិទ្យាសាស្ត្រ។

មាត្រា៥២៨ .- ការផ្តល់លិខិតអនុញ្ញាតសម្រាប់គោលបំណងផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រ

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិអាចផ្តល់ការអនុញ្ញាតពិសេសនៅក្នុងការប្រមូលប្រភេទវត្ថុជាតិព្រៃ ដែលមានក្នុងបញ្ជីចំណាត់ថ្នាក់ប្រភេទទី៣ដល់ទី៨នៃមាត្រា៥២០ (ចំណាត់ថ្នាក់ប្រភេទវត្ថុជាតិព្រៃ)នៃក្រមនេះ ពីកន្លែងណាមួយសម្រាប់គោលបំណងស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ ក្នុងករណីការប្រមូលនោះ មិនបង្កផលប៉ះពាល់ដល់ការអភិរក្សសារព័ន្ធវត្ថុជាតិព្រៃនៅក្នុងនិងក្រៅព្រះរាជាណាចក្រកម្ពុជា។

២- ការផ្តល់លិខិតអនុញ្ញាតនេះអាចផ្តល់ឱ្យតាមការស្នើសុំពីស្ថាប័នសិក្សា ស្ថាប័នស្រាវជ្រាវ អង្គការអភិរក្ស អាជ្ញាសន្និធិវត្ថុជាតិព្រៃសួតសម្រាប់ការសិក្សាស្រាវជ្រាវ ឬសួនភូតគាមសាស្ត្រ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៤១៣

គ- ចំណាត់ថ្នាក់ទី៣ ៖ ប្រភេទជិតផុតពូជបំផុត។

ឃ- ចំណាត់ថ្នាក់ទី៤ ៖ ប្រភេទជិតផុតពូជ។

ង- ចំណាត់ថ្នាក់ទី៥ ៖ ប្រភេទងាយទទួលរងគ្រោះ។

ច- ចំណាត់ថ្នាក់ទី៦ ៖ ប្រភេទជិតទទួលរងគ្រោះ។

ឆ- ចំណាត់ថ្នាក់ទី៧ ៖ ប្រភេទមិនទាន់រងការគំរាមកំហែង។

ជ- ចំណាត់ថ្នាក់ទី៨ ៖ ប្រភេទមិនមានទិន្នន័យគ្រប់គ្រាន់។

២- ការចាត់ថ្នាក់ខាងលើត្រូវធ្វើឡើងស្របទៅតាមស្ថានភាពជាក់ស្តែង ដោយមានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនិងអ្នកជំនាញការបច្ចេកទេស។

៣- ការកំណត់និយមន័យ និងលក្ខណៈនិច្ច័យរបស់ចំណាត់ថ្នាក់ប្រភេទវុក្ខជាតិព្រៃនីមួយៗខាងលើត្រូវផ្អែកតាមស្ថានភាពជាក់ស្តែងនិងស្របតាមលក្ខណៈវិទ្យាសាស្ត្រ។

៤- បញ្ជីចំណាត់ថ្នាក់ប្រភេទវុក្ខជាតិព្រៃ ត្រូវធ្វើបច្ចុប្បន្នកម្មផ្អែកលើស្ថានភាពជាក់ស្តែងនិងលក្ខណៈវិនិច្ច័យស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

មាត្រា៥២១ .- ការដំឡើងចំណាត់ថ្នាក់នៃប្រភេទវុក្ខជាតិព្រៃ

គ្រប់ប្រភេទវុក្ខជាតិព្រៃអាចត្រូវដំឡើងចំណាត់ថ្នាក់ដោយផ្អែកលើមូលដ្ឋាននៃកម្រិតហានិភ័យ ការគំរាមកំហែងស្ថានភាពប្រភេទវុក្ខជាតិព្រៃ និងតម្លៃបេតិកភណ្ឌវប្បធម៌ឬសារៈសំខាន់ផ្នែកសេដ្ឋកិច្ច ស្របតាមចំណាត់ថ្នាក់ដូចមានចែងក្នុងមាត្រា៥២០នៃក្រមនេះ។

ផ្នែកទី៣
សកម្មភាពហាមឃាត់ប៉ះពាល់ទីជម្រកប្រភេទវុក្ខជាតិព្រៃ

មាត្រា៥២២ .- សកម្មភាពហាមឃាត់ដែលប៉ះពាល់ដល់ទីជម្រកប្រភេទវុក្ខជាតិព្រៃ

ហាមឃាត់ចំពោះសកម្មភាពបំផ្លិចបំផ្លាញឬធ្វើឱ្យប្រែប្រួលទីជម្រកធម្មជាតិរបស់ប្រភេទវុក្ខជាតិព្រៃ ដែលកំពុងរងការគំរាមកំហែងដោយផ្ទាល់ឬប្រយោល លើកលែងតែទទួលបានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមបញ្ញត្តិដូចមានចែងនៅក្នុងជំពូកទី៧(កិច្ចគាំពារវុក្ខជាតិព្រៃ) មាតិកាទី២(ការគ្រប់គ្រងធនធានធម្មជាតិ សម្បត្តិវប្បធម៌និងទេសចរណ៍ធម្មជាតិក្នុងតំបន់ការពារធម្មជាតិ) នៃគន្លឹទី៤នៃក្រមនេះ។

មាត្រា៥២៣ .- សកម្មភាពហាមឃាត់ចំពោះប្រភេទវុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង

ហាមឃាត់ចំពោះសកម្មភាពប្រមូល ធ្វើសន្និធិ បំផ្លិចបំផ្លាញ ប្រើប្រាស់ លក់ ធ្វើពាណិជ្ជកម្ម ឬដឹកជញ្ជូនវុក្ខជាតិព្រៃ ឬបំណែករុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង ដូចមានចែងក្នុងបញ្ជីប្រភេទវុក្ខជាតិព្រៃថ្នាក់ជាតិលើកលែងតែទទួលបានការអនុញ្ញាតដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមបញ្ញត្តិនៃជំពូកទី៧(កិច្ចគាំពារវុក្ខជាតិព្រៃ) នៃមាតិកាទី២(ការគ្រប់គ្រងធនធានធម្មជាតិ សម្បត្តិវប្បធម៌ និងទេសចរណ៍ធម្មជាតិក្នុងតំបន់ការពារធម្មជាតិ) នៃគន្លឹទី៤នៃក្រមនេះ។

ទំព័រ៤១៤ អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

ឃ- រៀបចំបញ្ជីចាត់ថ្នាក់ គ្រប់គ្រង និងការពារវត្ថុជាតិព្រៃ ជាពិសេសប្រភេទកំពុងរងការគំរាមកំហែង។

ង- រៀបចំចុះបញ្ជីថ្នាក់ជាតិសម្រាប់ប្រភេទវត្ថុជាតិព្រៃដែលកំពុងរងការគំរាមកំហែង និងត្រូវបានចុះក្នុងឧបសម្ព័ន្ធនៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងវត្ថុជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់។

ច- ចាត់វិធានការនិងយន្តការសម្រាប់ការអភិរក្ស ការគ្រប់គ្រង និងការប្រើប្រាស់វត្ថុជាតិព្រៃ ការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីប្រកបដោយនិរន្តភាព។

ឆ- ស្តារឡើងវិញនូវវត្ថុជាតិព្រៃនិងប្រព័ន្ធអេកូឡូស៊ីដែលកំពុងរងការគំរាមកំហែងអាចឈានទៅផុតពូជ។

ជ- ចងក្រង គ្រប់គ្រង និងផ្សព្វផ្សាយប្រព័ន្ធទិន្នន័យវត្ថុជាតិព្រៃនិងព័ត៌មានប្រព័ន្ធអេកូឡូស៊ី។

២- ការបែងចែកមុខងារ តួនាទី និងភារកិច្ចជាក់លាក់ទៅឱ្យថ្នាក់ដឹកនាំរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៥១៧ .- កិច្ចសហការរបស់ក្រសួងស្ថាប័នមានសមត្ថកិច្ច

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការចែករំលែកព័ត៌មាន និងទិន្នន័យអំពីបទល្មើសវត្ថុជាតិព្រៃ និងប្រព័ន្ធអេកូឡូស៊ីដែលកំពុងរងការគំរាមកំហែង ដូចខាងក្រោម៖

ក- លទ្ធផលនៃការស៊ើបអង្កេតថ្នាក់ជាតិ និងថ្នាក់អន្តរជាតិស្តីពីការជួញដូរ និងដឹកជញ្ជូនវត្ថុជាតិព្រៃ និងប្រភេទឈើខុសច្បាប់។

ខ- របាយការណ៍នៃការរឹបអូសវត្ថុជាតិព្រៃ ដែលកំពុងរងការគំរាមកំហែងដូចមានចែងនៅក្នុងក្រមនេះ និងប្រភេទឈើខុសច្បាប់ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិពាក់ព័ន្ធ។

គ- ឯកសារបណ្តឹងផ្លូវច្បាប់ពាក់ព័ន្ធនឹងវត្ថុជាតិព្រៃ និងប្រព័ន្ធអេកូឡូស៊ីដែលកំពុងរងការគំរាមកំហែង។

ផ្នែកទី២
ការធ្វើចំណាត់ថ្នាក់ប្រភេទវត្ថុជាតិព្រៃ

មាត្រា៥១៨ .- វត្ថុជាតិព្រៃ

វត្ថុជាតិព្រៃគ្រប់ប្រភេទដែលជាសមាសភាគនៃធនធានធម្មជាតិត្រូវចាត់ទុកជាសម្បត្តិរដ្ឋ លើកលែងតែមានបញ្ញត្តិពិសេសក្នុងក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

មាត្រា៥១៩ .- បញ្ជីចំណាត់ថ្នាក់ប្រភេទវត្ថុជាតិព្រៃ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសម្របសម្រួល និងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំកត់ត្រានិងគ្រប់គ្រងបញ្ជីចំណាត់ថ្នាក់ប្រភេទវត្ថុជាតិព្រៃរួមទាំងប្រភេទ ដែលកំពុងរងការគំរាមកំហែងសម្រាប់គ្រប់គ្រងនិងការពារ។ បញ្ជីចំណាត់ថ្នាក់ប្រភេទវត្ថុជាតិព្រៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា៥២០ .- ចំណាត់ថ្នាក់ប្រភេទវត្ថុជាតិព្រៃ

១- វត្ថុជាតិព្រៃដែលមានក្នុងបញ្ជីចំណាត់ថ្នាក់សម្រាប់ប្រភេទនីមួយៗ ដែលកំពុងរងគ្រោះថ្នាក់ត្រូវបានបែងចែកជា ៨ ចំណាត់ថ្នាក់ដូចខាងក្រោម៖

ក- ចំណាត់ថ្នាក់ទី១ ៖ ប្រភេទផុតពូជទាំងស្រុង។

ខ- ចំណាត់ថ្នាក់ទី២ ៖ ប្រភេទផុតពូជពីក្នុងព្រៃ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៤១៥

មាត្រា៥១២ .- ការទប់ស្កាត់និងការត្រួតពិនិត្យភ្លើងឆេះព្រៃ

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវទប់ស្កាត់និងត្រួតពិនិត្យភ្លើងឆេះព្រៃ ដោយរៀបចំបង្កើតគណៈកម្មាធិការប្រយុទ្ធប្រឆាំងនឹងភ្លើងឆេះព្រៃសម្រាប់ការអនុវត្តក្នុងតំបន់ព្រៃឈើ។

២- ប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានភាតព្វកិច្ចគាំពារ ថែរក្សាព្រៃឈើ និងទប់ស្កាត់ភ្លើងឆេះព្រៃ។

មាត្រា៥១៣ .- ការផ្តល់វិញ្ញាបនបត្រព្រៃឈើតាមស្តង់ដារអន្តរជាតិនិងការគ្រប់គ្រង

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ អាចរៀបចំប្រកាសដែលពាក់ព័ន្ធទៅនឹងការផ្តល់វិញ្ញាបនបត្រព្រៃឈើតាមស្តង់ដារអន្តរជាតិដែលក្នុងនោះមានជាអាទិ៍៖

ក- ការអនុវត្តនីតិវិធីតាមដាននិងវាយត្រាលើឈើហ៊ុប។

ខ- ជាផលិតផលឈើនិងសាច់ឈើ អនុផលព្រៃឈើដែលបានមកពីការរើបអូស ឬឃាត់ទុកផលដែលមិនអាចប្រើប្រាស់ក្នុងស្រុក។

មាត្រា៥១៤ .- ប្រព័ន្ធផ្តល់លិខិតអនុញ្ញាតនិងការអង្កេតតាមដានទូទាំងប្រទេស

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ អាចរៀបចំប្រព័ន្ធផ្តល់លិខិតអនុញ្ញាត និងការតាមដានលើសកម្មភាពផលិត និងការប្រើប្រាស់នូវរាល់ផលិតផលព្រៃឈើដែលចេញពីតំបន់ព្រៃឈើគ្រប់គ្រងប្រកបដោយនិរន្តរភាព។

២- ការរៀបចំប្រព័ន្ធផ្តល់លិខិតអនុញ្ញាត និងការតាមដានជាលក្ខខណ្ឌតម្រូវសម្រាប់បុគ្គលដែលធ្វើប្រតិបត្តិការត្រូវស្របតាមលិខិតអនុញ្ញាត ដូចមានចែងក្នុងក្រមនេះ។

ជំពូកទី៧
កិច្চការពារវុក្ខជាតិព្រៃ
ផ្នែកទី១
ស្ថាប័នទទួលខុសត្រូវ

មាត្រា៥១៥ .- ក្រសួងស្ថាប័នទទួលខុសត្រូវ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលខុសត្រូវលើកិច្চគាំពារ ការអភិរក្ស និងការគ្រប់គ្រងរុក្ខជាតិព្រៃក្នុងតំបន់ការពារធម្មជាតិ។ ការគ្រប់គ្រងរុក្ខជាតិព្រៃក្រៅតំបន់ការពារធម្មជាតិជាសមត្ថកិច្চរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យព្រៃឈើ។

មាត្រា៥១៦ .- តួនាទីនិងភារកិច្চ

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទីនិងភារកិច្চដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព លិខិតបទដ្ឋានគតិយុត្តនិងពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងរុក្ខជាតិព្រៃ។

ខ- សិក្សា តាមដាន និងវាយតម្លៃផ្នែកសេដ្ឋកិច្চ សង្គម វប្បធម៌ និងបរិស្ថាន របស់រុក្ខជាតិព្រៃ ។

គ- សិក្សាវាយតម្លៃ និងគ្រប់គ្រងប្រភេទរាតត្បាតមិនមានដើមកំណើតក្នុងស្រុក ឬដែលមិនមានក្នុងធម្មជាតិក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា៥០៥ ._ ការបែងចែកថ្លៃសួយសារនិងបុព្វលាភព្រៃឈើ

ការបែងចែកថ្លៃសួយសារនិងបុព្វលាភព្រៃឈើដែលប្រមូលបាន ត្រូវអនុវត្តស្របតាមប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៥០៦ ._ លក្ខខណ្ឌលើកលែងការបង់ថ្លៃសួយសារនិងបុព្វលាភព្រៃឈើ

ការបង់ថ្លៃសួយសារនិងបុព្វលាភព្រៃឈើ ត្រូវបានលើកលែងក្នុងករណីដូចខាងក្រោម៖

ក- ការប្រមូលផល អនុផលព្រៃឈើពីព្រៃឯកជន។

ខ- ការប្រើប្រាស់ជាលក្ខណៈប្រពៃណីរបស់សហគមន៍មូលដ្ឋាន។

គ- គោលដៅវិទ្យាសាស្ត្រ។

មាត្រា៥០៧ ._ ការពន្យារពេលបង់ថ្លៃសួយសារនិងបុព្វលាភព្រៃឈើ

១- ក្នុងករណីអ្នកកាន់លិខិតអនុញ្ញាតមិនបង់ថ្លៃសួយសារនិងបុព្វលាភព្រៃឈើទៅតាមកាលបរិច្ឆេទកំណត់តាមកិច្ចព្រមព្រៀងជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ផលអនុផលព្រៃឈើទាំងនោះត្រូវយាត់ទុក។

២- ការពន្យារពេលបង់ថ្លៃសួយសារនិងបុព្វលាភព្រៃឈើត្រូវស្របតាមលក្ខណវិនិច្ឆ័យដូចមានចែងក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា៥០៨ ._ នីតិវិធីនៃការបង់ថ្លៃសួយសារនិងបុព្វលាភព្រៃឈើ

នីតិវិធីនៃការបង់ថ្លៃសួយសារនិងបុព្វលាភព្រៃឈើត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ផ្នែកទី៨

យន្តការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព

មាត្រា៥០៩ ._ យន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់និងរេចរឹលព្រៃឈើ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តយន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ និងរេចរឹលព្រៃឈើ (រេដបូក) ដើម្បីលើកកម្ពស់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព បង្កើនសន្ទិធិកាបូនព្រៃឈើ និងលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន។

មាត្រា៥១០ ._ ការដាំស្តារព្រៃឈើឡើងវិញ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវជំរុញ និងលើកកម្ពស់ការដាំស្តារព្រៃឈើឡើងវិញក្នុងតំបន់ដីព្រៃរេចរឹល ដើម្បីធ្វើឱ្យប្រសើរឡើងនូវតម្លៃប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះក្នុងតំបន់ព្រៃឈើដែលគ្រប់គ្រងប្រកបដោយនិរន្តរភាព។

មាត្រា៥១១ ._ ការដាំដុះដើមឈើ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំគោលការណ៍ណែនាំបច្ចេកទេស ដើម្បីកំណត់វិធាននានា ស្តីពីការដាំដុះដើមឈើក្នុងគោលបំណងលើកទឹកចិត្តដល់បុគ្គលក្នុងការដាំ និងរក្សាការដាំដុះដើមឈើសម្រាប់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងសមស្របទៅនឹងគោលដៅបរិស្ថាន សេដ្ឋកិច្ច និងសង្គម។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ផ្នែកទី៦

ផែនការនិងរបាយការណ៍គ្រប់គ្រងពាណិជ្ជកម្មព្រៃឈើប្រកបដោយនិរន្តរភាព

មាត្រា៥០១ .- វិសាលភាពនៃផែនការគ្រប់គ្រងពាណិជ្ជកម្មព្រៃឈើ

ផែនការគ្រប់គ្រងពាណិជ្ជកម្មព្រៃឈើ ដែលបង្កើតឡើងសម្រាប់រាល់សកម្មភាពពាណិជ្ជកម្មព្រៃឈើដែលគ្រប់គ្រងប្រកបដោយនិរន្តរភាពត្រូវសមមាត្រទៅនឹងទំហំ ដង់ស៊ីតេ និងហានិភ័យសកម្មភាពពាណិជ្ជកម្មទាំងនោះ។ ផែនការគ្រប់គ្រងពាណិជ្ជកម្មព្រៃឈើត្រូវអនុវត្តនិងធ្វើបច្ចុប្បន្នកម្មជារៀងទាត់ ដោយផ្អែកលើព័ត៌មានអង្កេតត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ដើម្បីលើកកម្ពស់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។

មាត្រា៥០២ .- ខ្លឹមសារនៃផែនការគ្រប់គ្រងពាណិជ្ជកម្មព្រៃឈើ

ផែនការគ្រប់គ្រងពាណិជ្ជកម្មព្រៃឈើប្រកបដោយនិរន្តរភាពត្រូវ៖

ក- កំណត់និយមន័យពាណិជ្ជកម្មព្រៃឈើនៃតំបន់ជាក់លាក់ ដោយអនុលោមតាមសកម្មភាពពាណិជ្ជកម្មដែលមានជាអាទិ៍ ការពិពណ៌នា និងទីតាំងនៃសកម្មភាពជាក់លាក់ដែលគ្រោងទុក។

ខ- កំណត់នូវគោលដៅ គោលបំណង និងលទ្ធផលនៃសកម្មភាពពាណិជ្ជកម្មទាក់ទងនឹងធនធានដែលត្រូវបានប្រើប្រាស់ និងលក្ខណៈនិច្ច័យ សង្គម និងចំណូល។

គ- កំណត់តួនាទីនិងការទទួលខុសត្រូវសម្រាប់ភាគីពាក់ព័ន្ធ។

ឃ- កំណត់កូតាសម្រាប់ការប្រមូលផល អនុផលព្រៃឈើ។

ង- កំណត់កាលបរិច្ឆេទនិងពេលវេលាសម្រាប់ការអនុវត្ត។

ច- កំណត់ផែនការថវិកា។

ឆ- កំណត់ការអនុវត្តការគ្រប់គ្រងឱ្យបានត្រឹមត្រូវ ដោយផ្អែកលើលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ជ- កំណត់ផែនការនៃការអនុវត្តរក្សាវប្បកម្ម។

ឈ- កំណត់នីតិវិធីសម្រាប់វិញ្ញាបនបត្រផលិតផលព្រៃឈើ ប្រសិនបើអាចអនុវត្តបាន។

ញ- កំណត់ការកែច្នៃនិងការដឹកជញ្ជូនផលិតផលព្រៃឈើ។

ដ- កំណត់វិធីសាស្ត្រ ការពិនិត្យតាមដាន និងវាយតម្លៃ និងការរៀបចំរបាយការណ៍។

មាត្រា៥០៣ .- របាយការណ៍គ្រប់គ្រងពាណិជ្ជកម្មព្រៃឈើ

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំរបាយការណ៍គ្រប់គ្រងពាណិជ្ជកម្មព្រៃឈើប្រចាំឆ្នាំដោយមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ។

២- ផែនការនិងរបាយការណ៍គ្រប់គ្រងពាណិជ្ជកម្មព្រៃឈើត្រូវដាក់ផ្សព្វផ្សាយជាសាធារណៈស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

ផ្នែកទី៧

ថ្លៃសួយសារនិងបុព្វលាភព្រៃឈើ

មាត្រា៥០៤ .- ការបង់ថ្លៃសួយសារនិងបុព្វលាភព្រៃឈើ

១- បុគ្គលដែលប្រមូលផល អនុផលព្រៃឈើ ក្នុងគោលបំណងពាណិជ្ជកម្មក្នុងតំបន់ព្រៃឈើដែលគ្រប់គ្រងប្រកបដោយនិរន្តរភាពត្រូវបង់ថ្លៃសួយសារ និងបុព្វលាភព្រៃឈើទៅកាន់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

២- វិធានសម្រាប់ការវាយតម្លៃគុណភាពនិងបរិមាណត្រូវធ្វើការវាយតម្លៃមុននឹងធ្វើការដឹកជញ្ជូន។

ច- ការប្រើប្រាស់ព្រៃឈើដើម្បីស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រឬបច្ចេកទេស។
ឆ- ការបង្កើតទីតាំងរោងសន្និធិដើម្បីលក់និងចែកចាយផល អនុផលព្រៃឈើ។
ជ- ការបង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ។
ឈ- ការបង្កើតឡដុតផ្សេងៗដែលប្រើប្រាស់វត្ថុធាតុដើមជាផល អនុផលព្រៃឈើ។
ញ- ផលិតធ្យូងនិងឈើអុស។
ដ- ការធ្វើសកម្មភាពផ្នែកពាណិជ្ជកម្មផ្សេងៗ ត្រូវស្របតាមបញ្ញត្តិនៃក្រមនេះ។
ឋ- សកម្មភាពពាណិជ្ជកម្មទាំងឡាយដែលមានទីតាំងស្ថិតនៅក្នុងព្រៃផ្តល់ផលដោយនិរន្តរភាពត្រូវមានលិខិតអនុញ្ញាតជាមុន។

មាត្រា៤៩៨ ._ ការពិនិត្យលើពាក្យសុំលិខិតអនុញ្ញាត

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវពិនិត្យពាក្យសុំលិខិតអនុញ្ញាតដោយគោរពលក្ខខណ្ឌដូចខាងក្រោម៖

ក- មានសង្គតិភាពជាមួយគោលបំណងអភិរក្សទេសភាពនៅជុំវិញ។
ខ- មានការគាំទ្រនិងជួយបង្កើនជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋានក្នុងតំបន់។
គ- មានការចូលរួមចំណែកក្នុងកិច្ចគាំពារតម្លៃជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ី។
ឃ- មានសង្គតិភាពជាមួយផែនការប្រើប្រាស់ដីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងផែនការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។
ង- អនុវត្តតាមគោលការណ៍ណែនាំនៅក្នុងដំណាក់កាលរៀបចំគម្រោង ប្រតិបត្តិការគម្រោង និងបិទគម្រោងរបស់ក្រសួងស្ថាប័នមានសមត្ថកិច្ច។
ច- បំពេញលក្ខខណ្ឌផ្សេងៗទៀតតាមស្ថានភាពជាក់ស្តែង។

ផ្នែកទី៥
សិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណី

មាត្រា៤៩៩ ._ កាតព្វកិច្ចធានារបស់រដ្ឋ

រដ្ឋត្រូវទទួលស្គាល់និងធានានូវសិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណី ទំនៀមទម្លាប់ ជំនឿ សាសនា និងការរស់នៅរបស់សហគមន៍មូលដ្ឋានដែលនៅក្នុង ឬក្បែរតំបន់ព្រៃឈើដែលគ្រប់គ្រងប្រកបដោយនិរន្តរភាពស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

មាត្រា៥០០ ._ សិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណី

១- សិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណីរបស់សហគមន៍មូលដ្ឋានសម្រាប់ផល អនុផលព្រៃឈើមិនតម្រូវឱ្យមានលិខិតអនុញ្ញាតនោះទេ។

២- សិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណី មានជាអាទិ៍៖

ក- ការរើសប្រមូលឈើងាប់ ការបេះផ្លែឈើព្រៃ ការប្រមូលទឹកឃ្មុំ ការចោះយកជ័រទឹក និងការប្រមូលអនុផលព្រៃឈើដទៃៗទៀត។
ខ- ការកាត់ស្មៅនិងការព្រៃលែងសត្វពាហនៈឱ្យស៊ីចំណី។
គ- ការប្រើប្រាស់ផល អនុផលព្រៃឈើឱ្យស្របតាមការប្រើប្រាស់ជាលក្ខណៈគ្រួសារនិងប្រពៃណី។
ឃ- សិទ្ធិដោះដូរឬលក់អនុផលព្រៃឈើជាលក្ខណៈប្រពៃណីក្នុងសហគមន៍មូលដ្ឋាន មិនតម្រូវឱ្យមានលិខិតអនុញ្ញាតនោះទេ។ បុគ្គលដែលមានបំណងធ្វើពាណិជ្ជកម្មអនុផលព្រៃឈើជាមួយសហគមន៍មូលដ្ឋានត្រូវមានលិខិតអនុញ្ញាតដូចមានចែងក្នុងមាត្រា៤៩៧(សកម្មភាពពាក់ព័ន្ធ)នៃក្រមនេះ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៤១៩

ផ្នែកទី៩
ផែនការស្តារនិងគ្រប់គ្រងសត្វព្រៃ

មាត្រា៥៨០ .- ផែនការស្តារនិងគ្រប់គ្រងប្រភេទសត្វព្រៃ

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃគ្រប់ចំណាត់ថ្នាក់ ជាពិសេសប្រភេទក្នុងចំណាត់ថ្នាក់ទី២ដល់ទី៦ ដែលមានដើមកំណើតនៅក្នុងតំបន់ការពារធម្មជាតិ។ ផែនការនេះត្រូវមានរយៈពេល១០(ដប់)ឆ្នាំយ៉ាងតិច។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំផែនការស្តារនិងគ្រប់គ្រងប្រភេទសត្វព្រៃ បន្ទាប់ពីធ្វើការពិគ្រោះយោបល់ជាសាធារណៈ។

មាត្រា៥៨១ .- លក្ខខណ្ឌនៃផែនការស្តារនិងគ្រប់គ្រងប្រភេទសត្វព្រៃ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់លក្ខខណ្ឌៈ

ក- សកម្មភាពការពារនិងអភិរក្សនៅក្នុងផែនការស្តារនិងគ្រប់គ្រងប្រភេទសត្វព្រៃ។

ខ- ទីជម្រកសំខាន់ៗសម្រាប់ការអភិរក្សប្រភេទសត្វព្រៃមានវិធានការគ្រប់គ្រងទៅតាមប្រភេទទីជម្រក និងតំបន់ក្នុងគោលដៅការពារនិងអភិរក្ស។

គ- សកម្មភាពគ្រប់គ្រងទីជម្រកនិងតំបន់ទេសភាពនៅក្នុងផែនការស្តារ និងគ្រប់គ្រងតំបន់ការពារធម្មជាតិ។

ឃ- សូចនាករដែលអាចវាស់វែងបានដែលអាចធ្វើឱ្យប្រភេទគោលដៅមានភាពប្រសើរឡើង។ ផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃត្រូវកំណត់ពេលវេលានិងធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តសកម្មភាព និងវិធានការនានា។

ង- ការបន្លាស់ទីកន្លែង វិធានការអភិរក្សក្រៅដែនជម្រកធម្មជាតិ ការបង្កាត់ពូជដើម្បីអភិរក្ស និងការស្តារសម្រាប់ការអភិរក្ស។

មាត្រា៥៨២ .- លិខិតអនុញ្ញាត

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិអាចចេញលិខិតអនុញ្ញាតសម្រាប់គម្រោងស្តារសត្វព្រៃ ឬសកម្មភាពសិក្សាស្រាវជ្រាវ ប្រមូលទិន្នន័យ ថតរូបភាព ថតយកសំឡេងសត្វព្រៃ ប្រើម៉ាស៊ីនថតរូបភាពស្វ័យប្រវត្តិ ឬផ្សាយផ្ទាល់ ផលិតខ្សែភាពយន្ត ឬវីដេអូពាក់ព័ន្ធនឹងការកំណត់ប្រភេទសត្វព្រៃក្នុងចំណាត់ថ្នាក់ទី២ដល់ទី៦។

២- មុនចេញលិខិតអនុញ្ញាតក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវពិនិត្យទៅលើផែនការស្តារ ការគ្រប់គ្រងប្រភេទសត្វព្រៃ។

មាត្រា៥៨៣ .- ការអង្កេតតាមដានស្ថានភាពនៃប្រភេទសត្វព្រៃ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសហការជាមួយភាគីពាក់ព័ន្ធ ដើម្បីអង្កេតតាមដានស្ថានភាពនៃប្រភេទសត្វព្រៃក្នុងចំណាត់ថ្នាក់ទី២ដល់ទី៦ ក្នុងរយៈពេល១០(ដប់)ឆ្នាំ បន្ទាប់ពីស្ថានភាពចំណាត់ថ្នាក់នៃប្រភេទសត្វព្រៃមានការប្រែប្រួល ស្របតាមលិខិតបទដ្ឋានគតិយុត្ត ឬបទប្បញ្ញត្តិនៃក្រមនេះ។

ផ្នែកទី១០
ការគ្រប់គ្រងទីតាំងបង្កាត់ពូជអភិរក្ស ធនធានពន្ធុ មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និងគ្រឹះស្ថានឧទ្យានសត្វព្រៃ

មាត្រា៥៨៤ .- ការចុះបញ្ជី

ការបង្កើតទីតាំងបង្កាត់ពូជអភិរក្សនិងអភិរក្សធនធានពន្ធុ មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និងគ្រឹះស្ថានឧទ្យានសត្វព្រៃក្នុងគោលបំណងរក្សាទុកសត្វព្រៃគ្រប់ប្រភេទត្រូវមានលិខិតអនុញ្ញាត និងចុះបញ្ជីនៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា៥៨៥ .- ការធ្វើអធិការកិច្ច

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើអធិការកិច្ចទីតាំងបង្កាត់ពូជអភិរក្សនិងអភិរក្សធនធានពន្ធុ មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និងគ្រឹះស្ថានឧទ្យានសត្វព្រៃ។

មាត្រា៥៨៦ .- ការដកហូតលិខិតអនុញ្ញាតឬការបញ្ឈប់ប្រតិបត្តិការបណ្តោះអាសន្ន

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិដកហូតលិខិតអនុញ្ញាត ឬបញ្ឈប់ប្រតិបត្តិការទីតាំងបង្កាត់ពូជអភិរក្សនិងអភិរក្សធនធានពន្ធុ មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និងគ្រឹះស្ថានឧទ្យានសត្វព្រៃជាបណ្តោះអាសន្ន ព្រមទាំងរឹបអូសរាល់សត្វព្រៃ ក្នុងករណីអនុវត្តផ្ទុយខ្លឹមសារលិខិតអនុញ្ញាតស្តីពីការរក្សាឬប្រមូលទុកសត្វព្រៃ។

មាត្រា៥៨៧ .- ការអង្កេតតាមដាននិងធ្វើកំណត់ត្រា

ប្រតិបត្តិករឬម្ចាស់ទីតាំងបង្កាត់ពូជអភិរក្សនិងអភិរក្សធនធានពន្ធុ មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ឬគ្រឹះស្ថានឧទ្យានសត្វព្រៃ មានការកិច្ចធ្វើរបាយការណ៍អំពីការកើត ការស្លាប់ និងការផ្ទេរសត្វព្រៃជូនក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា៥៨៨ .- ការផ្ទេរឬការប្តូរទីតាំងសត្វព្រៃ

១- រាល់ការផ្ទេរឬការប្តូរទីតាំងសត្វព្រៃត្រូវមានលិខិតអនុញ្ញាតដឹកជញ្ជូន និង/ឬត្រូវជូនដំណឹងជាមុនទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

២- ការផ្ទេរឬការប្តូរទីតាំងសត្វព្រៃពីកន្លែងមួយទៅកន្លែងមួយទៀត ត្រូវកត់ត្រាឱ្យបានច្បាស់លាស់ ហើយត្រូវជូនដំណឹងនិងផ្តល់ឯកសារដល់មន្ត្រីអនុវត្តច្បាប់នៃក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា៥៨៩ .- ការបោះបង់ចោលបំណែកសាច់ សំណាក ឬវត្តុតាំងលម្អសត្វព្រៃ

១- ការបោះបង់ចោលបំណែកសរីរាង្គ សាច់ សំណាក ឬវត្តុតាំងលម្អសត្វព្រៃដែលក្បោទុកឬចិញ្ចឹមត្រូវធ្វើឡើងស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

២- ហាមឃាត់ចំពោះការរក្សាទុកសរីរាង្គទាំងមូលឬជាផ្នែកនៃសត្វព្រៃ ក្នុងទីតាំងបង្កាត់ពូជអភិរក្សនិងអភិរក្សធនធានពន្ធុ មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ឬគ្រឹះស្ថានឧទ្យានសត្វព្រៃ លើកលែងតែមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៤២១

មាត្រា៥៩០ .- លក្ខខណ្ឌនៃការព្យាបាលសត្វព្រៃនិងទីកន្លែង

សត្វព្រៃដែលបានរក្សាទុកនៅតាមទីតាំងបង្កាត់ពូជអភិរក្សនិងអភិរក្សធនធានពន្ធុ មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ គ្រឹះស្ថានឧទ្យានសត្វព្រៃ ឬកន្លែងសន្និធិសត្វព្រៃ ត្រូវទទួលការថែទាំប្រកបដោយមនុស្សធម៌និងត្រូវអនុលោមតាមពិធីសារនៃសុខុមាលភាពសត្វឬលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា៥៩១ .- លក្ខណៈធម្មជាតិរបស់សត្វព្រៃ

១- រាល់ទីកន្លែងដែលអនុវត្តការបង្កាត់ពូជអភិរក្សនិងអភិរក្សធនធានពន្ធុ មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ គ្រឹះស្ថានឧទ្យានសត្វព្រៃ ឬកន្លែងសន្និធិសត្វព្រៃ ចំពោះប្រភេទសត្វព្រៃត្រូវធានាឱ្យបាននូវលក្ខណៈធម្មជាតិរបស់សត្វព្រៃ ហើយទ្រុងត្រូវមានលក្ខណៈសមស្របតាមស្តង់ដារដែលអាចទទួលយកបានសម្រាប់ សុខុមាលភាពរបស់សត្វ។

២- ទីកន្លែងដែលអនុវត្តការបង្កាត់ពូជអភិរក្សនិងអភិរក្សធនធានពន្ធុ ត្រូវរៀបចំសៀវភៅកំណត់ត្រាសម្រាប់ប្រភេទសត្វព្រៃ ដោយបញ្ចាក់ពីកម្មវិធីបង្កាត់ពូជឬការចិញ្ចឹម ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៣- ប្រភេទនៃការបន្តពូជ ព្រឹត្តិការណ៍បង្កាត់ពូជ និងពពួកពូជតែមួយ ត្រូវធ្វើការកត់ត្រាឱ្យបានត្រឹមត្រូវអំពីចំនួនសត្វព្រៃមេបាដើមនិងកូនដែលកើតពីមេបាដើម។ កូនដែលកើតពីមេបាដើមត្រូវដាក់សញ្ញាសម្គាល់ជាអចិន្ត្រៃយ៍ដែលអាចសម្គាល់បានអំពីចំនួនភាគយេនិងដើមកំណើតកូន។

មាត្រា៥៩២ .- ប្រព័ន្ធគ្រប់គ្រងទិន្នន័យ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់ការអង្កេត តាមដាន ត្រួតពិនិត្យ និងការគ្រប់គ្រងសត្វព្រៃដែលត្រូវរក្សាទុក និងទីតាំងរក្សាទុកសត្វព្រៃ។

មាត្រា៥៩៣ .- ការដោះលែងសត្វព្រៃ

១- ទីកន្លែងដែលមានសត្វព្រៃរស់នៅដោយការរក្សាទុកឬបានកើតក្នុងទីកន្លែងរក្សាទុកដែលតម្រូវឱ្យមានការដោះលែង ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

២- នៅមុនការដោះលែង ត្រូវធ្វើការពិនិត្យសុខភាពសត្វព្រៃ កំណត់អត្តសញ្ញាណ និងរៀបចំកន្លែងដោះលែងឱ្យសមស្របតាមលក្ខណៈធម្មជាតិ និងអង្កេតតាមដាន ត្រួតពិនិត្យ ក្រោយការដោះលែងក្នុងករណីចាំបាច់។

ផ្នែកទី១១
ការគ្រប់គ្រងសត្វព្រៃនិងបំណែកសរីរាង្គសត្វព្រៃដែលរឹបអូសបាន

មាត្រា៥៩៤ .- នីតិវិធីគ្រប់គ្រង

ការគ្រប់គ្រងសត្វព្រៃឬបំណែកសរីរាង្គសត្វព្រៃដែលរឹបអូសបាន ត្រូវអនុវត្តដូចខាងក្រោម៖

ក- សត្វព្រៃរស់ ហើយមានដើមកំណើតក្នុងស្រុក ត្រូវវាយតម្លៃសុខភាពនិងភាពសមស្របនានាមុនដោះលែងចូលទៅក្នុងព្រៃធម្មជាតិ។ ក្នុងករណីមិនសមស្របត្រូវបញ្ជូនទៅមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ដែលទទួលបានការអនុញ្ញាតដើម្បីព្យាបាលនិងថែទាំ។

ខ- សត្វព្រៃស្លាប់ បំណែកសរីរាង្គ ឬសំណាកសត្វព្រៃ អាចបំផ្លាញចោលឬក្សាទុកស្របតាមលិខិតបទដ្ឋានគតិយុត្ត ដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

គ- សត្វព្រៃរស់មិនមានដើមកំណើតក្នុងតំបន់ការពារធម្មជាតិ អាចបញ្ជូនទៅមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃដែលទទួលបានការអនុញ្ញាត ប៉ុន្តែក្នុងករណីចាំបាច់អាចផ្តល់ទៅកន្លែងដើមវិញ ឬអាចចាត់វិធានការតាមស្ថានភាពជាក់ស្តែង។

មាត្រា៥៩៥ .- ការរៀបចំរបាយការណ៍តាមអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វនិងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានធ្វើការចាប់យកប្រភេទសត្វព្រៃជិតផុតពូជ ជាសត្វព្រៃទាំងមូល ឬជាបំណែកសរីរាង្គសត្វព្រៃដូចបានកំណត់ក្នុងអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វនិងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ត្រូវរាយការណ៍ជូនដល់អាជ្ញាធរទទួលបន្ទុកគ្រប់គ្រងប្រចាំប្រទេសសាមី។

២- អាជ្ញាធរគ្រប់គ្រងដែលទទួលបន្ទុកលើអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វនិងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ប្រចាំប្រទេសសាមីត្រូវរាយការណ៍ជូនដល់លេខាធិការដ្ឋានសម្រាប់អនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះ ស្របតាមកាតព្វកិច្ចស្តីពីការរាយការណ៍ដូចបានកំណត់នៅក្នុងអនុសញ្ញានេះ។

៣- ក្នុងករណីមានប្រភេទសត្វព្រៃដែលបានកំណត់ក្នុងអនុសញ្ញានេះត្រូវបានចាប់យកក្នុងពេលកំពុងឆ្លងកាត់ឬកំពុងចែកចាយក្នុងព្រះរាជាណាចក្រកម្ពុជា នោះក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នមានសមត្ថកិច្ច ឬរដ្ឋបាលថ្នាក់ក្រោមជាតិអាចរក្សាទុកឬចាត់វិធានការបំផ្លាញវត្ថុចាប់យកស្របតាមគន្លឹះទី៩ នៃក្រមនេះ។

មាត្រា៥៩៦ .- កិច្ចសហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់អន្តរជាតិ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬក្រសួងស្ថាប័នមានសមត្ថកិច្ចអាចស្នើសុំទៅរាជរដ្ឋាភិបាលធ្វើការចរចានិងកំណត់អំពីកិច្ចព្រមព្រៀងនានាជាមួយអាជ្ញាធរពង្រឹងការអនុវត្តច្បាប់អន្តរជាតិ ឬអង្គការអន្តរជាតិ ឬអង្គការថ្នាក់តំបន់ក្នុងគោលបំណងលើកកម្ពស់កិច្ចសហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់អន្តរជាតិ។

ជំពូកទី៩
ការគ្រប់គ្រងជលផល
ផ្នែកទី១
ស្ថាប័នទទួលខុសត្រូវ

មាត្រា៥៩៧ .- ស្ថាប័នទទួលខុសត្រូវ

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលខុសត្រូវលើការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានជលផលស្ថិតក្នុងតំបន់ការពារធម្មជាតិ។

២- ការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានជលផលក្រៅតំបន់ការពារធម្មជាតិជាសមត្ថកិច្ចរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យជលផល។

មាត្រា៥៩៨ .- តួនាទីនិងភារកិច្ច

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទីនិងភារកិច្ចគ្រប់គ្រងការអភិរក្ស និងការអភិវឌ្ឍធនធានជលផលក្នុងតំបន់ការពារធម្មជាតិដូចខាងក្រោម៖

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៤២៣

ក- រៀបចំសេចក្តីព្រាងគោលនយោបាយគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានជលផល ផែនការគ្រប់គ្រង ផែនការរមេ និងផែនទីទិន្នន័យសម្រាប់គ្រប់គ្រងជលផល។

ខ- កំណត់ផែននេសាទដើម្បីអនុញ្ញាតឱ្យមានសកម្មភាពនេសាទ និងតំបន់ដែលត្រូវធ្វើការអភិរក្សធនធានជលផល។

គ- គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានជលផល ដើម្បីលើកកម្ពស់សន្តិសុខស្បៀង និងថែរក្សាមច្ឆជាតិសម្រាប់ឧត្តមប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជា។

ឃ- គ្រប់គ្រងនិងកំណត់ឱ្យមានសកម្មភាពធ្វើវារីវប្បកម្ម។

ង- សិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកទេសជលផល សេដ្ឋកិច្ច សង្គម និងបរិស្ថាន។

ច- សហការនិងចែករំលែកទិន្នន័យស្តីពីការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានជលផលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។

ឆ- អប់រំផ្សព្វផ្សាយដើម្បីលើកកម្ពស់ការយល់ដឹងរបស់សាធារណជនក្នុងការចូលរួមថែរក្សាការពារជលផល។

ជ- ធ្វើអធិការកិច្ច តាមដាន និងវាយតម្លៃលើការគ្រប់គ្រងជលផល។

ឈ- ធ្វើការស្រាវជ្រាវ ស៊ើបអង្កេត និងចាត់វិធានការផ្លូវច្បាប់លើបទល្មើសជលផល កសាងសំណុំរឿង និងតាំងខ្លួនជាអង្គភាពដើមបណ្តឹងទៅតុលាការមានសមត្ថកិច្ច។

២- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យជលផលមានសិទ្ធិអំណាចអនុវត្តតួនាទីនិងការកិច្ចរបស់ខ្លួនស្របតាមក្រមនេះ ឬច្បាប់តាមវិស័យរបស់ខ្លួន។

៣- ការបែងចែកមុខងារ តួនាទី និងការកិច្ចជាក់លាក់ទៅឱ្យថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ដោយអនុក្រឹត្យ។

ផ្នែកទី២
និរន្តរភាពនៃការគ្រប់គ្រងជលផល

មាត្រា៥៩៩ .- គោលការណ៍គ្រប់គ្រងជលផល

ការគ្រប់គ្រងជលផលត្រូវគោរពគោលការណ៍ដូចខាងក្រោម៖

ក- គ្រប់គ្រង អភិរក្ស អភិវឌ្ឍ និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាពដោយផ្អែកលើព័ត៌មាននិងទិន្នន័យវិទ្យាសាស្ត្រ។

ខ- ប្រើប្រាស់និងបែងចែកធនធានជលផលប្រកបដោយសមធម៌។

គ- លើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការគ្រប់គ្រងធនធានជលផលប្រកបដោយតម្លាភាពនិងបរិយាបន្ន។

ឃ- លើកកម្ពស់ការអភិវឌ្ឍវារីវប្បកម្មនៅតំបន់ដែលមានសក្តានុពល។

ង- គោរពកិច្ចព្រមព្រៀងអន្តរជាតិ និងលិខិតបទដ្ឋានអន្តរជាតិនិងថ្នាក់តំបន់ពាក់ព័ន្ធផ្សេងទៀតដែលព្រះរាជាណាចក្រកម្ពុជាជាផ្នែកភាគីឱ្យមានប្រសិទ្ធភាព។

ច- ធានាបាននូវលក្ខខណ្ឌការងារសមស្របក្នុងការងារដែលផលនៅលើនាវានេសាទឬនាវាពាក់ព័ន្ធការនេសាទដើម្បីការពារពលករប្រឆាំងនឹងការជួញដូរមនុស្សឬប្រើពលករដោយបង្ខំ។

ឆ- ធានាសុវត្ថិភាពចំណីអាហារ។

ជ- លើកកម្ពស់ជីវភាពអ្នកនេសាទឱ្យបានល្អប្រសើរ។

ផ្នែកទី៣
កិច្ចគាំពារនិងការអភិរក្សជលផល

មាត្រា៦០០ .- ចំណាត់ថ្នាក់តំបន់គ្រប់គ្រងជលផល

១- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញត្រូវដាក់បញ្ចូលនូវការវាយតម្លៃហេតុប៉ះពាល់នៃគម្រោងស្នើសុំដែលបង្កឱ្យមានការប្រែប្រួលអាកាសធាតុ មានជាអាទិ៍ ការគណនាបរិមាណនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់គម្រោងអភិវឌ្ឍ រួមបញ្ចូលការវិភាគលើការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

២- ម្ចាស់គម្រោងត្រូវសិក្សាអំពីជម្រើសថាមពលនានាដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទាប និងសិក្សាអំពីតម្រូវការក្នុងការកាត់បន្ថយការប្រែប្រួលចំពោះការផ្គត់ផ្គង់ទឹកដែលបណ្តាលមកពីកត្តាអាកាសធាតុ។

មាត្រា៦៨២ .- ការវិភាគនិងការវាយតម្លៃពីសក្តានុពលហេតុប៉ះពាល់ចំពោះការប្រែប្រួលអាកាសធាតុ

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញត្រូវវិភាគ និងវាយតម្លៃពីភាពងាយរងគ្រោះនៃគម្រោង ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងសកម្មភាពរបស់គម្រោងទៅលើបរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌ ដើម្បីសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ច ដោយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិច។

មាត្រា៦៨៣ .- ការវាយតម្លៃហេតុប៉ះពាល់សុខភាព

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវរាប់បញ្ចូលនូវការវាយតម្លៃហេតុប៉ះពាល់សុខភាពដែលមានជាអាទិ៍៖

ក- ទិន្នន័យមូលដ្ឋានស្តីពីសុខភាពនៅក្នុងតំបន់គម្រោងនិងរបស់ប្រជាជនដែលរងហេតុប៉ះពាល់។

ខ- ការពណ៌នាអំពីហេតុប៉ះពាល់នៃគម្រោងដែលអាចមាន ដោយសារការសាងសង់ លំហូរប្រជាជន និងការផ្លាស់ប្តូរចំពោះបរិស្ថាន។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៤៤៧

គ- វិធានការកាត់បន្ថយហេតុប៉ះពាល់ ដើម្បីកាត់បន្ថយឬលុបបំបាត់ហេតុប៉ះពាល់អវិជ្ជមាននៃគម្រោង និងវិធានការដែលត្រូវដាក់ឱ្យអនុវត្តដោយម្ចាស់គម្រោង ដើម្បីកែលម្អសុខភាពរបស់សហគមន៍មូលដ្ឋាន។

ឃ- បញ្ហានានាទាក់ទងនឹងការអង្កេតតាមដានសុខភាព និងការគ្រប់គ្រងហេតុប៉ះពាល់ដែលនៅសល់ក្នុងរយៈពេលខ្លីនិងវែងសម្រាប់គម្រោង។

មាត្រា៦៨៤ .- ការវិភាគពីហានិភ័យនៃការវាយតម្លៃហេតុប៉ះពាល់សុខភាព

ក្នុងការវាយតម្លៃហេតុប៉ះពាល់សុខភាព ម្ចាស់គម្រោងត្រូវ៖

ក- លើកផែនការគ្រប់គ្រងសុវត្ថិភាព និងសុខភាពជាផ្នែកមួយនៃការវាយតម្លៃហេតុប៉ះពាល់សុខភាពសម្រាប់បរិស្ថានការងារ ដោយវិភាគពីហានិភ័យដែលពាក់ព័ន្ធ និងប្រភេទនៃកត្តាគ្រោះថ្នាក់ក្នុងទីតាំងគម្រោង ជាអាទិ៍ កត្តាគ្រោះថ្នាក់ផ្នែករូបសាស្ត្រ គីមីសាស្ត្រ ជីវសាស្ត្រ និងវិទ្យុសកម្ម។

ខ- កំណត់និងវាយតម្លៃហានិភ័យនិងសក្តានុពលនៃហេតុប៉ះពាល់ទៅលើសុវត្ថិភាព និងសុខភាពរបស់សហគមន៍មូលដ្ឋានក្នុងដំណាក់កាលចនាគម្រោង សាងសង់គម្រោង អនុវត្តគម្រោង និងបញ្ចប់គម្រោង ព្រមទាំងលើកវិធានការគាំពារនិងផែនការគ្រប់គ្រងហេតុប៉ះពាល់នៅក្នុងដំណាក់កាលទាំងនេះ។

មាត្រា៦៨៥ .- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាបណ្តុំ

១- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញត្រូវពិភាគ និងវាយតម្លៃពីបណ្តុំនៃហេតុប៉ះពាល់ដែលបង្កឡើងដោយគម្រោងដែលមានស្រាប់ និងគម្រោងក្នុងពេលអនាគត នៅជុំវិញទីតាំងគម្រោងទាំងនោះ ដែលអាចបង្កើតឱ្យមានហេតុប៉ះពាល់គួរឱ្យកត់សម្គាល់ដល់បរិស្ថាន សេដ្ឋកិច្ចសង្គម និងវប្បធម៌។

២- នៅក្នុងរបាយការណ៍វាយតម្លៃបណ្តុំនៃហេតុប៉ះពាល់ ម្ចាស់គម្រោងត្រូវវាយតម្លៃសមត្ថភាពនៃធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម ដើម្បីគិតគូរអំពីហេតុប៉ះពាល់បន្ថែម ដោយផ្អែកលើកត្តាពេលវេលា ស្ថានភាពភូមិសាស្ត្រ និងសកម្មភាពរបស់គម្រោងនានាដែលនៅជុំវិញទីតាំងគម្រោង។

៣- ម្ចាស់គម្រោងត្រូវពិចារណាអំពីជម្រើសនៃវិធានការកាត់បន្ថយបណ្តុំនៃហេតុប៉ះពាល់ផ្សេងៗ ដើម្បីកាត់បន្ថយ ឬបញ្ចៀសបណ្តុំនៃហេតុប៉ះពាល់ដែលគួរឱ្យកត់សម្គាល់ទាំងនោះ។

មាត្រា៦៨៦ .- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន

១- គម្រោងអភិវឌ្ឍដែលអាចមានហេតុប៉ះពាល់បរិស្ថានឆ្លងដែន ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនដោយអនុលោមតាមច្បាប់ និងលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។ ក្នុងករណីនេះ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនត្រូវបញ្ចូលក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីលក្ខណៈវិនិច្ឆ័យកំណត់ពីសញ្ញាណនៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន និងឈានទៅដល់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន។

៣- បែបបទនិងនីតិវិធីនៃការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ជំពូកទី៦

ការចូលរួមជាសាធារណៈក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

មាត្រា៦៨៧ .- គោលបំណងនៃការចូលរួមជាសាធារណៈ

១- គោលបំណងចម្បងនៃការចូលរួមជាសាធារណៈ ត្រូវធានាថាគ្រប់ភាគីពាក់ព័ន្ធត្រូវបានចូលរួមនៅក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ការរស់នៅប្រកបដោយចីរភាព និងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

២- នីតិវិធីនៃការចូលរួមជាសាធារណៈ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា៦៨៨ .- សិទ្ធិរបស់អ្នកចូលរួមជាសាធារណៈក្នុងការធ្វើសកម្មភាព

ភាគីពាក់ព័ន្ធដែលមានសិទ្ធិក្នុងការចូលរួមជាសាធារណៈអាចធ្វើសកម្មភាព ដូចខាងក្រោម៖

ក- រាយការណ៍ទៅអាជ្ញាធរពាក់ព័ន្ធនិងផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាព ឬការធ្វើសេចក្តីសម្រេចណាមួយដែលអាចនឹងមានផលប៉ះពាល់ទៅលើបរិស្ថាននិងធនធានធម្មជាតិ។

ខ- លើកសំណួរស្នើឱ្យមានការស្រាយបំភ្លឺ ធ្វើការតវ៉ា និងចូលរួមពិភាក្សាអំពីសកម្មភាព ឬសេចក្តីសម្រេចណាមួយដែលអាចបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថាននិងធនធានធម្មជាតិ។

គ- ដាក់ពាក្យប្តឹងឬបណ្តឹងប្រឆាំងនឹងសេចក្តីសម្រេចស្របតាមយន្តការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ ដូចមានចែងក្នុងមាតិកាទី១(នីតិវិធីនៃការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ)នៃគន្លឹទី៩នៃក្រមនេះ។

មាត្រា៦៨៩ .- កាតព្វកិច្ចរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងម្ចាស់គម្រោង

ក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងម្ចាស់គម្រោងទាំងអស់ មុននឹងធ្វើសេចក្តីសម្រេចឬការឯកភាពលើករណីណាមួយដែលពាក់ព័ន្ធនឹងក្រមនេះត្រូវ៖

ក- ជូនដំណឹងនិងផ្តល់ព័ត៌មានចាំបាច់នានា ព្រមទាំងផ្តល់ពេលវេលាសមស្របដល់ភាគីពាក់ព័ន្ធសម្រាប់ការចូលរួមជាសាធារណៈ។

ខ- ផ្តល់ព័ត៌មានចាំបាច់នានាដល់ភាគីពាក់ព័ន្ធដោយក្នុងការផ្តល់ព័ត៌មានទាំងនោះ ត្រូវយកចិត្តទុកដាក់អំពីភាសាដែលអាចយល់បាននិងវប្បធម៌របស់ភាគីពាក់ព័ន្ធទាំងនោះ។

គ- ពិចារណាលើចំណេះដឹងខាងផ្នែកបច្ចេកទេសនិង/ឬវិទ្យាសាស្ត្រ ធ្វើជាមូលដ្ឋានក្នុងការបង្កើតគម្រោងផែនការសេកម្មភាពនិងការធ្វើសេចក្តីសម្រេច។

ឃ- យកចិត្តទុកដាក់លើតម្រូវការនិងតម្លៃរបស់ភាគីពាក់ព័ន្ធ ក្នុងដំណើរការនៃការចូលរួមជាសាធារណៈ។

ង- ផ្តល់ពេលវេលាសមស្រប ដើម្បីធ្វើការវាយតម្លៃនិងឆ្លើយតបចំពោះព័ត៌មានទាក់ទងនឹងគម្រោងស្នើសុំសកម្មភាព ផែនការ ឬសេចក្តីសម្រេចណាមួយ។

ច- ពិចារណាអំពីទំហំនៃការចូលរួមជាសាធារណៈឱ្យមានភាពសមស្របជាមួយផលប្រយោជន៍ និងការខូចខាតរបស់ភាគីពាក់ព័ន្ធ។

ឆ- ធានាថាកិច្ចដំណើរការនៃការចូលរួមជាសាធារណៈមានលក្ខណៈបត់បែន និងអាចកែសម្រួលបានតាមការព្រួយបារម្ភរបស់ភាគីពាក់ព័ន្ធ។

ជ- ធ្វើការពិចារណាគ្រប់មតិយោបល់របស់សាធារណជននៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេច។ ការទទួលយកឬបដិសេធចំពោះមតិយោបល់ខាងលើនេះត្រូវបញ្ជាក់ពីហេតុផលសមរម្យ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៤៤៩

មាត្រា៦៩០ .__ មតិយោបល់របស់សាធារណជនក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ការចូលរួមជាសាធារណៈនៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវ៖

ក- កត់ត្រាទុកនូវយោបល់របស់សាធារណជនដែលបានចូលរួម នៅក្នុងដំណាក់កាលរៀបចំផែនការនិង ក្នុងដំណាក់កាលអនុវត្តលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ខ- ផ្តោតលើបញ្ហានានា ដែលលើកឡើងដោយភាគីដែលទទួលរងហេតុប៉ះពាល់ ដែលអាចកើតមានពីគម្រោងដែលបានស្នើឡើង។

គ- ដាក់បញ្ចូលនូវសេចក្តីលម្អិតអំពីហេតុប៉ះពាល់របស់គម្រោងដល់សាធារណជន និងការទទួលយក ឬបដិសេធសំណើរបស់សាធារណជន។

ឃ- ផ្តល់ហេតុផលនៃការបដិសេធឱ្យបានច្បាស់លាស់ នៅក្នុងករណីដែលម្ចាស់គម្រោងបដិសេធសំណើរបស់សាធារណជន។

មាត្រា៦៩១ .__ ការពិគ្រោះយោបល់ជាមុន

១- កិច្ចដំណើរការចូលរួមជាសាធារណៈត្រូវធានាថាមានការពិគ្រោះយោបល់ជាមុនពីអ្នកទទួលរងផលប៉ះពាល់ដោយសារគម្រោង ចំពោះវិធានការកាត់បន្ថយហេតុប៉ះពាល់ដែលបានស្នើឡើងដោយផ្អែកលើការពិគ្រោះយោបល់និងបន្ទាប់ពីទទួលបានព័ត៌មានជាមុន។

២- ក្នុងវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាននេះ ម្ចាស់គម្រោងត្រូវ៖

ក- កំណត់វិធានការនានា ក្នុងការលើកកម្ពស់ជីវភាពនិងជួយដល់អ្នកដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង។

ខ- ធានាថាអ្នកដែលទទួលរងផលប៉ះពាល់បានចូលរួមក្នុងការរៀបចំការផ្លាស់ទីលំនៅថ្មី ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការផ្លាស់ទីលំនៅថ្មីឱ្យនៅត្រឹមកម្រិតអប្បបរមា និងធានាថាសំណងលើការបាត់បង់ទ្រព្យសម្បត្តិត្រូវបានដោះស្រាយដោយសមរម្យ ត្រឹមត្រូវ និងយុត្តិធម៌ជាមុនសិន ហើយវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានមានលក្ខណៈត្រឹមត្រូវ។

៣- ក្នុងករណីដែលសហគមន៍មូលដ្ឋានដែលរងផលប៉ះពាល់មិនយល់ស្រប ចំពោះវិធានការកាត់បន្ថយនានាដែលម្ចាស់គម្រោងបានស្នើខាងលើ គម្រោងអភិវឌ្ឍនៅតែបន្តដដែល តែម្ចាស់គម្រោងត្រូវកំណត់កេរិវិធានការកាត់បន្ថយហេតុប៉ះពាល់ផ្សេងទៀត ឬដោះស្រាយរាល់ហេតុប៉ះពាល់នោះដល់សហគមន៍មូលដ្ឋាន។

៤- នីតិវិធីនៃការដោះស្រាយសំណងដល់សហគមន៍មូលដ្ឋានដែលទទួលរងផលប៉ះពាល់ និងនីតិវិធីនៃការផ្លាស់ប្តូរលំនៅថ្មី ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

៥- បែបបទនិងនីតិវិធីនៃការទូទាត់សំណងការខូចខាតដល់សហគមន៍មូលដ្ឋាន ដែលទទួលរងផលប៉ះពាល់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៦៩២ .__ ការចូលរួមជាសាធារណៈលើវិធានការកាត់បន្ថយ

១- កិច្ចដំណើរការនៃការចូលរួមជាសាធារណៈត្រូវស្វែងរកនូវការយល់ព្រម ពីអ្នកទទួលរងផលប៉ះពាល់ពីគម្រោង ចំពោះវិធានការកាត់បន្ថយហេតុប៉ះពាល់ដែលបានស្នើឡើង។ ម្ចាស់គម្រោងត្រូវផ្តល់ផែនការគ្រប់គ្រងបរិស្ថានដែលត្រូវអនុញ្ញាតឱ្យមានការចូលរួមជាសាធារណៈ នៅក្នុងដំណើរការអង្កេតតាមដាន និងការគោរពតាមលក្ខខណ្ឌដែលមានចែងនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន។

២- របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថានត្រូវពិចារណាអំពីមតិយោបល់នានារបស់អ្នកទទួលរងផលប៉ះពាល់ ចំពោះវិធានការកាត់បន្ថយហេតុប៉ះពាល់ដែលបានស្នើឡើង។

មាត្រា៦៩៣ ._ ការផ្សព្វផ្សាយជាសាធារណៈ

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវធានាថាព័ត៌មានពាក់ព័ន្ធនឹងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងនិងឯកសារពាក់ព័ន្ធត្រូវបានផ្សព្វផ្សាយជាសាធារណៈ ហើយភាគីពាក់ព័ន្ធនិងសហគមន៍មូលដ្ឋានដែលទទួលរងផលប៉ះពាល់ដោយសារគម្រោងអាចទទួលបានព័ត៌មានគ្រប់គ្រាន់និងច្បាស់លាស់ ។

២- ម្ចាស់គម្រោងត្រូវធ្វើការផ្សព្វផ្សាយជាសារធារណៈ តាមរយៈគេហទំព័ររបស់ខ្លួនយ៉ាងហោចណាស់នូវឯកសារ ឬព័ត៌មានថតចម្លងនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងផែនការនៃគម្រោង ព្រមទាំងបណ្តាវិធានការកាត់បន្ថយហេតុប៉ះពាល់នៃគម្រោងដែលត្រូវបានស្នើឡើង។

៣- នីតិវិធីសម្រាប់ការចូលរួមជាសាធារណៈនិងសិទ្ធិទទួលបានព័ត៌មាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ជំពូកទី៧

ផែនការគ្រប់គ្រងបរិស្ថាននិងការអង្កេតតាមជានគម្រោង

មាត្រា៦៩៤ ._ ការត្រួតពិនិត្យនិងអង្កេតតាមជានការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ជាអាជ្ញាធរត្រួតពិនិត្យ និងអង្កេតតាមជានការអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់ម្ចាស់គម្រោង ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធ។

២- ម្ចាស់គម្រោងត្រូវអនុវត្តតាមរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬកិច្ចសន្យាការពារបរិស្ថាន និង/ឬផែនការគ្រប់គ្រងបរិស្ថានក្នុងរយៈពេល ៦(ប្រាំមួយ)ខែ ចាប់ពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិបានឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬកិច្ចសន្យាការពារបរិស្ថាន និង/ឬផែនការគ្រប់គ្រងបរិស្ថាន។

មាត្រា៦៩៥ ._ ការរៀបចំផែនការគ្រប់គ្រងបរិស្ថាន

១- ផែនការគ្រប់គ្រងបរិស្ថានត្រូវរៀបចំដោយម្ចាស់គម្រោង។

២- ផែនការគ្រប់គ្រងបរិស្ថាន ត្រូវដាក់បញ្ចូលលក្ខខណ្ឌតម្រូវនៃវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាននិងសង្គម ដែលបានកំណត់នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងឬកិច្ចសន្យាការពារបរិស្ថាន។

៣- ផែនការគ្រប់គ្រងបរិស្ថានត្រូវធ្វើបច្ចុប្បន្នកម្មជាប្រចាំដោយអនុលោមតាមការវិវត្តជាក់ស្តែងនៃស្តង់ដារបរិស្ថាន ការអនុវត្តជាក់ស្តែងដែលទទួលស្គាល់ជាទូទៅក្នុងវិស័យនីមួយៗ ឬការប្រែប្រួលស្ថានភាពផ្សេងៗនៃគម្រោង។

មាត្រា៦៩៦ ._ ប្រព័ន្ធគ្រប់គ្រងបរិស្ថានផ្ទៃក្នុង

១- រាល់គម្រោងអភិវឌ្ឍ និងអ្នកប្រតិបត្តិការគម្រោងត្រូវបង្កើតក្រុមការងារទទួលបន្ទុកវិស័យត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន និងរក្សាប្រព័ន្ធគ្រប់គ្រងបរិស្ថានផ្ទៃក្នុងដែលត្រូវធានាឱ្យមាននូវនីតិវិធី និងវិធីសាស្ត្រអង្កេតតាមជានដោយខ្លួនឯង ដូចមានចែងក្នុងផែនការគ្រប់គ្រងបរិស្ថាន។

២- ក្នុងករណីហេតុប៉ះពាល់បរិស្ថាន មានទំហំធំជាងហេតុប៉ះពាល់ដែលត្រូវបានប៉ាន់ប្រមាណនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬផែនការគ្រប់គ្រងបរិស្ថាន ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវចាត់វិធានការកែតម្រូវហេតុប៉ះពាល់ភ្លាមៗឬកែតម្រូវផែនការគ្រប់គ្រងបរិស្ថាន។

៣- ផែនការគ្រប់គ្រងបរិស្ថាននិងកម្មវិធីអង្កេតតាមដានដែលបានកែតម្រូវរួច ត្រូវទទួលបានការឯកភាពពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។ លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការកែតម្រូវ ឬកែលម្អជាថ្មីឡើងវិញ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

៤- ម្ចាស់គម្រោងត្រូវរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថានរៀងរាល់ត្រីមាស ឬឆមាស ហើយបញ្ជូនមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដើម្បីពិនិត្យនិងវាយតម្លៃ។ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិមានសិទ្ធិចុះត្រួតពិនិត្យដល់កន្លែង និងផ្ទៀងផ្ទាត់លទ្ធផលនៃការអង្កេតតាមដានរបស់ម្ចាស់គម្រោង។

មាត្រា៦៩៧ .- សិទ្ធិរាយការណ៍ពីបញ្ហាបរិស្ថាន

១- អ្នកដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង និងភាគីពាក់ព័ន្ធមានសិទ្ធិរាយការណ៍ពីបញ្ហា និងក្តីកង្វល់ បរិស្ថាន និងសង្គម ជូនដល់ម្ចាស់គម្រោង និងដាក់ពាក្យបណ្តឹងទៅក្រសួងស្ថាប័នមានសមត្ថកិច្ច។

២- ក្រសួងស្ថាប័នមានសមត្ថកិច្ចត្រូវឆ្លើយតបចំពោះបណ្តឹងឬញត្តិ ហើយដោះស្រាយបញ្ហាបរិស្ថាននិងសង្គមដែលពាក់ព័ន្ធ តាមពេលវេលាសមស្រប និងផ្តល់ព័ត៌មានដល់ភាគីពាក់ព័ន្ធតាមស្ថានភាពជាក់ស្តែង។

៣- បែបបទនិងនីតិវិធីនៃការដោះស្រាយបណ្តឹងឬញត្តិ ត្រូវកំណត់យោងតាមនីតិវិធីនៃការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិដែលមានចែងក្នុងក្រមនេះ។

មាត្រា៦៩៨ .- ការរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាន

១- ម្ចាស់គម្រោងនីមួយៗត្រូវរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាននៃគម្រោង ទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ។

២- លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថានត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា៦៩៩ .- ការរៀបចំបញ្ជូនរបាយការណ៍ប្រចាំត្រីមាសឬឆមាស

១- ម្ចាស់គម្រោងដែលមានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬកិច្ចសន្យាការពារបរិស្ថានត្រូវបញ្ជូនរបាយការណ៍ប្រចាំត្រីមាសឬឆមាស ទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិទាក់ទងនឹងការអង្កេតតាមដាននិងការគ្រប់គ្រងបរិស្ថានរបស់ខ្លួន។

២- ម្ចាស់គម្រោងត្រូវសិក្សាឡើងវិញនូវគោលចំណុចខ្វះខាតក្នុងរបាយការណ៍ប្រចាំត្រីមាស ឬឆមាសដែលក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិបានពិនិត្យនិងផ្តល់យោបល់ ហើយត្រូវបញ្ចូលចំណុចខ្វះខាតនេះក្នុងរបាយការណ៍ប្រចាំត្រីមាសឬឆមាសបន្ទាប់ រួចបញ្ជូនមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិដើម្បីពិនិត្យនិងវាយតម្លៃឡើងវិញ។ ម្ចាស់គម្រោងត្រូវរាយការណ៍ភ្លាមៗអំពីផលប៉ះពាល់បរិស្ថានអវិជ្ជមានដល់ក្រសួងស្ថាប័នពាក់ព័ន្ធ និងដល់សាធារណជន ដើម្បីចៀសវាងផលប៉ះពាល់អវិជ្ជមានមកលើបរិស្ថាននិងសង្គម។

៣- ម្ចាស់គម្រោងត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាននៃគម្រោង ដល់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ តាមការណែនាំរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ជំពូកទី៨
សវនកម្មបរិស្ថាន

មាត្រា៧០០ .- សវនកម្មបរិស្ថាន

១- ការអនុវត្តគម្រោង ឬសកម្មភាពណាមួយដែលទទួលបានការឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង កិច្ចសន្យាការពារបរិស្ថាន ឬលិខិតអនុញ្ញាតត្រូវធ្វើសវនកម្មបរិស្ថានដែលមានលក្ខណៈឯករាជ្យនិងត្រូវបានចងក្រងទុកជាឯកសារ។

២- ការធ្វើសវនកម្មបរិស្ថានមានដូចខាងក្រោម៖

ក- ពិនិត្យ និងបញ្ជាក់ពីគម្រោង ឬសកម្មភាពណាមួយដែលអនុលោមតាមលក្ខខណ្ឌតម្រូវរបស់ក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ខ- កំណត់និងបង្ហាញពីហេតុប៉ះពាល់បរិស្ថានរបស់គម្រោងឬសកម្មភាពណាមួយ។

គ- កំណត់និងបង្ហាញពីវិធានការណាមួយដែលអាចអនុវត្តបាន ដើម្បីធ្វើការកែតម្រូវឱ្យស្របតាមលក្ខខណ្ឌតម្រូវ។

ឃ- កាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានដល់បរិស្ថានឱ្យនៅត្រឹមកម្រិតអប្បបរមា។

មាត្រា៧០១ .- វិសាលភាពនៃគម្រោងឬសកម្មភាពដែលត្រូវធ្វើសវនកម្មបរិស្ថាន

ប្រភេទគម្រោងឬសកម្មភាពដែលជាកម្មវត្ថុនៃការធ្វើសវនកម្មបរិស្ថាន នីតិវិធីនិងរយៈពេលជាក់លាក់នៃការធ្វើសវនកម្មបរិស្ថាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា៧០២ .- គម្រោងតម្រូវធ្វើសវនកម្មបរិស្ថានខាងក្រៅ

គម្រោងនានាដែលត្រូវបានកំណត់ នៅក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែករបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ស្តីពីបញ្ជីនៃគម្រោងដែលតម្រូវឱ្យមានការធ្វើសវនកម្មបរិស្ថានខាងក្រៅត្រូវធ្វើសវនកម្មដោយសវនករបរិស្ថានឯករាជ្យដែលមានលក្ខណសម្បត្តិ ដូចមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិស្តីពីការធ្វើសវនកម្មបរិស្ថានខាងក្រៅ។

មាត្រា៧០៣ .- ការតែងតាំងនិងលក្ខណសម្បត្តិរបស់សវនករបរិស្ថាន

១- បុគ្គលដែលទទួលបាននីតិសម្បទាជាសវនករបរិស្ថាន អាចអនុវត្តសវនកម្មបរិស្ថានបានដោយមានការអនុញ្ញាតពីក្រសួងស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

២- នីតិវិធីនិងគោលការណ៍ណែនាំក្នុងការទទួលស្គាល់សវនកម្មបរិស្ថានត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា៧០៤ .- តួនាទីនិងភារកិច្ចរបស់សវនករបរិស្ថានឯករាជ្យ

សវនករបរិស្ថានឯករាជ្យមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- ជួយជ្រោមជ្រែងក្នុងការធ្វើកំណត់ត្រាបរិស្ថានឱ្យបានត្រឹមត្រូវនិងពេញលេញ។

ខ- ផ្តល់មតិយោបល់សវនកម្មផ្ទៃជីវៈជាអាទិ៍ របាយការណ៍បរិស្ថានដែលបង្ហាញនូវទិដ្ឋភាពពេញលេញនិងសមស្របអំពីការគ្រប់គ្រងបរិស្ថាននៃគម្រោងឬប្រតិបត្តិការរបស់គម្រោង។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៤៥៣

គ- ពិនិត្យភាពគ្រប់គ្រាន់នៃការអនុវត្តនីតិវិធីនៃការគ្រប់គ្រង និងការអង្កេតតាមដានបរិស្ថានផ្ទៃក្នុងព្រមទាំងការផ្តល់អនុសាសន៍ដើម្បីកែលម្អ។

ឃ- ផ្តល់ព័ត៌មានអំពីភាពមិនប្រក្រតីនិងការខ្វះចន្លោះក្នុងការគ្រប់គ្រងបរិស្ថានផ្ទៃក្នុងរបស់ខ្លួន។

ង- ត្រូវផ្តល់សំណៅច្បាប់ដើមមួយច្បាប់នៃរបាយការណ៍សវនកម្ម ជូនក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា៧០៥ .- ការចំណាយចំពោះការធ្វើសវនកម្មបរិស្ថាន

រាល់ការចំណាយដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មបរិស្ថាន ត្រូវស្ថិតក្រោមការទទួលខុសត្រូវរបស់ប្រតិបត្តិការឬម្ចាស់គម្រោង។

មាត្រា៧០៦ .- ការខកខានមិនបានធ្វើតាមបទបញ្ជាឬលក្ខខណ្ឌតម្រូវ

១- ក្នុងករណីដែលម្ចាស់គម្រោង ខកខានមិនបានធ្វើតាមបទបញ្ជាឬលក្ខខណ្ឌតម្រូវក្នុងការធ្វើសវនកម្មបរិស្ថាន ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវណែនាំឱ្យម្ចាស់គម្រោងជ្រើសរើសសវនករបរិស្ថានដែលទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដើម្បីរៀបចំរបាយការណ៍សវនកម្មបរិស្ថានលើគម្រោង ឬសកម្មភាពណាមួយនោះ។

២- រាល់ការចំណាយដែលទាក់ទងទៅនឹងសវនកម្មបរិស្ថាន ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ជាបន្ទុករបស់ម្ចាស់គម្រោង។

មាត្រា៧០៧ .- ការអង្កេតតាមដាននិងការរៀបចំរបាយការណ៍

ម្ចាស់គម្រោងដែលទទួលបានការឯកភាពលើ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង កិច្ចសន្យាការពារបរិស្ថាន ឬលិខិតអនុញ្ញាត ត្រូវអនុវត្តការអង្កេតតាមដាន និងរៀបចំរបាយការណ៍សវនកម្មបរិស្ថាន ស្របតាមលក្ខខណ្ឌតម្រូវដូចមានចែងនៅក្នុងក្រមនេះនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត។

មាត្រា៧០៨ .- ដំណោះស្រាយផលប៉ះពាល់

ក្នុងករណីដែលសវនកម្មបរិស្ថានបង្ហាញឱ្យឃើញថាផលប៉ះពាល់របស់គម្រោង និង/ឬសកម្មភាពនោះធំជាងអ្វីដែលបានប៉ាន់ប្រមាណនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬកិច្ចសន្យាការពារបរិស្ថាន ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវចាត់វិធានការភ្លាមៗដើម្បីដោះស្រាយផលប៉ះពាល់ទាំងនោះ និងបញ្ជាឱ្យធ្វើការកែតម្រូវលើផែនការគ្រប់គ្រងបរិស្ថានឱ្យបានសមស្រប ដើម្បីបញ្ចៀសផលប៉ះពាល់នៅពេលអនាគត។

មាត្រា៧០៩ .- ការស្វែងរកបាននូវព័ត៌មានពាក់ព័ន្ធនឹងរបាយការណ៍សវនកម្ម

ព័ត៌មានពាក់ព័ន្ធនឹងរបាយការណ៍សវនកម្មបរិស្ថានត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ក្រោយពេលដែលរបាយការណ៍នោះត្រូវបានដាក់បញ្ជូនទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ជំពូកទី៩
សិទ្ធិទទួលព័ត៌មានទិដ្ឋភាពបរិស្ថានជាតិ
ផ្នែកទី១
សិទ្ធិទទួលបានព័ត៌មានបរិស្ថានទិដ្ឋភាពធម្មជាតិ

មាត្រា៧១០ .- ការដាក់បង្ហាញព័ត៌មានឱ្យសាធារណជនអាចស្វែងរកបាន



១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវដាក់ព័ត៌មានពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងធនធានធម្មជាតិ អាចដាក់បង្ហាញឱ្យសាធារណជនស្វែងរកបាន។

២- ទម្រង់បែបបទនិងនីតិវិធីនៃការដាក់បង្ហាញព័ត៌មាន ដូចបានបញ្ញត្តនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា៧១១ .- សិទ្ធិទទួលព័ត៌មានពីក្រសួងស្ថាប័នសាធារណៈ

១- បុគ្គលមានសិទ្ធិស្នើសុំព័ត៌មានពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងធនធានធម្មជាតិពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ លើកលែងតែព័ត៌មានសម្ងាត់។

២- សិទ្ធិទទួលព័ត៌មានដូចបានបញ្ញត្តក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវអនុវត្តស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា៧១២ .- សិទ្ធិទទួលព័ត៌មានពីគម្រោងឯកជន

បុគ្គលមានសិទ្ធិស្នើសុំព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តគម្រោងឯកជន ពីម្ចាស់គម្រោងលើកលែងតែព័ត៌មានសម្ងាត់។

មាត្រា៧១៣ .- ការស្នើសុំដាក់ជាព័ត៌មានសម្ងាត់របស់គម្រោងវិនិយោគឯកជន

១- ម្ចាស់គម្រោងវិនិយោគឯកជន មានសិទ្ធិស្នើសុំទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ ឬរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការកំណត់ព័ត៌មានពាក់ព័ន្ធនឹងប្រតិបត្តិការគម្រោងណាមួយជាព័ត៌មានសម្ងាត់។

២- បែបបទនិងនីតិវិធីក្នុងការកំណត់ព័ត៌មានសម្ងាត់របស់គម្រោងវិនិយោគឯកជន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នមានសមត្ថកិច្ច ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

ផ្នែកទី២
បញ្ជីព័ត៌មានបរិស្ថានជាតិ

មាត្រា៧១៤ .- ការរៀបចំបញ្ជីព័ត៌មានបរិស្ថានជាតិ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំបញ្ជីព័ត៌មានបរិស្ថានជាតិដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា៧១៥ .- ការទទួលបានព័ត៌មានជាសាធារណៈពីបញ្ជីព័ត៌មានបរិស្ថានជាតិ

បញ្ជីព័ត៌មានបរិស្ថានជាតិជាព័ត៌មានដែលសាធារណជនអាចស្វែងរកបាន លើកលែងតែព័ត៌មានទាំងឡាយណាដែលជាព័ត៌មានសម្ងាត់សម្រាប់កិច្ចគាំពារដល់ប្រភេទសត្វ រុក្ខជាតិព្រៃ ឬសម្បត្តិវប្បធម៌ដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ផ្នែកទី៣
មជ្ឈមណ្ឌលទិន្នន័យបរិស្ថានជាតិ

មាត្រា៧១៦ .- មជ្ឈមណ្ឌលទិន្នន័យបរិស្ថានជាតិ

១- ត្រូវបង្កើតមជ្ឈមណ្ឌលទិន្នន័យបរិស្ថានជាតិ ដើម្បីចងក្រងរក្សាទុកនូវព័ត៌មានពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងធនធានធម្មជាតិ។

២- ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលទិន្នន័យបរិស្ថានជាតិត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា៧១៧ .- ការទទួលបានព័ត៌មានពីមជ្ឈមណ្ឌលទិន្នន័យបរិស្ថានជាតិ

ទិន្នន័យទាំងអស់ដែលរៀបចំដោយមជ្ឈមណ្ឌលទិន្នន័យបរិស្ថានជាតិ ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន លើកលែងតែទិន្នន័យដែលចាត់ទុកជាព័ត៌មានសម្ងាត់ សម្រាប់ការពារប្រភេទសត្វ និងរុក្ខជាតិព្រៃ ឬសម្បត្តិវប្បធម៌ និងបេតិកភណ្ឌធម្មជាតិ។

គន្លឹះទី៦
ការទទួលខុសត្រូវលើការខូចខាតបរិស្ថាននិងធនធានធម្មជាតិ
មាតិកាទោល
ការស្តារឡើងវិញ និងសំណងលើការខូចខាតបរិស្ថាននិងធនធានធម្មជាតិ
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា៧១៨ .- គោលបំណង

មាតិកានេះ មានគោលបំណងកំណត់អំពីកាតព្វកិច្ចរបស់ម្ចាស់គម្រោង និងប្រតិបត្តិករក្នុងការជួសជុល ការស្តារ និងការសងសំណងលើការបង្កផលប៉ះពាល់អវិជ្ជមាន ឬការខូចខាតបរិស្ថានឬធនធានធម្មជាតិ។

មាត្រា៧១៩ .- វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តលើរាល់សកម្មភាពរបស់ម្ចាស់គម្រោង និងប្រតិបត្តិករ ដែលបង្កផលប៉ះពាល់អវិជ្ជមាន ឬខូចខាតបរិស្ថានឬធនធានធម្មជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី២
ស្ថាប័នទទួលខុសត្រូវ

មាត្រា៧២០ .- ក្រសួងស្ថាប័នទទួលខុសត្រូវ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវលើការគ្រប់គ្រង និងចាត់វិធានការលើរាល់សកម្មភាពរបស់ម្ចាស់គម្រោងឬប្រតិបត្តិករ ដែលបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថានឬធនធានធម្មជាតិ។

មាត្រា៧២១ .- តួនាទីនិងការកិច្ច

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិមានតួនាទី និងការកិច្ចដូចខាងក្រោម៖

ក- រៀបចំលិខិតបទដ្ឋានគតិយុត្តនិងគោលការណ៍ណែនាំបច្ចេកទេស ដើម្បីគ្រប់គ្រង កំណត់អំពីទំហំ និងប្រភេទនៃការខូចខាតដល់បរិស្ថានឬធនធានធម្មជាតិ។

ខ- ចាត់វិធានការ បញ្ឈៀស បង្ការ និងទប់ស្កាត់ ការខូចខាតបរិស្ថានឬធនធានធម្មជាតិ។

គ- រៀបចំផែនការ និងនីតិវិធីបែបបទនៃការស្តារការខូចខាតបរិស្ថានឬធនធានធម្មជាតិ។

ឃ- ចាត់វិធានការផ្លូវច្បាប់ ឬកសាងសំណុំរឿងទៅតុលាការដោយតាំងខ្លួនជាអង្គភាពដើមបណ្តឹងក្នុងការទាមទារសំណងការខូចខាតបរិស្ថានឬធនធានធម្មជាតិ។

ង- ប្រមូល និងចងក្រងទិន្នន័យពាក់ព័ន្ធនឹងផលប៉ះពាល់បរិស្ថានឬធនធានធម្មជាតិ។

ច- ធ្វើអធិការកិច្ច តាមដាន និងពិនិត្យវាយតម្លៃលើការខូចខាតបរិស្ថានឬធនធានធម្មជាតិ។

ឆ- ធ្វើការផ្សព្វផ្សាយជាសាធារណៈ ក្នុងករណីដែលការបំពុលបរិស្ថានឬធនធានធម្មជាតិ អាចបង្កឱ្យមានផលប៉ះពាល់ដល់សុខុមាលភាពសាធារណៈ។

ជ- រៀបចំចងក្រងរបាយការណ៍ពាក់ព័ន្ធនឹងការខូចខាតបរិស្ថានឬធនធានធម្មជាតិ។

ជំពូកទី៣
ការទទួលខុសត្រូវរបស់ម្ចាស់គម្រោងឬប្រតិបត្តិការនៅមុនពេលមានការខូចខាតបរិស្ថានដ៏ធ្ងន់ធ្ងរធម្មជាតិ

មាត្រា៧២២ .– កាតព្វកិច្ចរបស់ម្ចាស់គម្រោងឬប្រតិបត្តិការក្នុងការអនុវត្តវិធានការទប់ស្កាត់ការខូចខាតបរិស្ថានឬធនធានធម្មជាតិភ្លាមៗ

១- ក្នុងករណីមានហានិភ័យកើតឡើងបន្ទាន់ ដែលអាចបង្កផលប៉ះពាល់អវិជ្ជមាន ឬការខូចខាតដល់បរិស្ថានឬធនធានធម្មជាតិ ដោយសារការអនុវត្តសកម្មភាពគម្រោងរបស់ខ្លួន ម្ចាស់គម្រោងឬប្រតិបត្តិការ ត្រូវតែចាត់វិធានការទប់ស្កាត់ការខូចខាតបរិស្ថានឬធនធានធម្មជាតិនោះភ្លាមៗ។ ក្នុងករណីដែលម្ចាស់គម្រោង ឬប្រតិបត្តិការមិនបានចាត់វិធានការ ឬចាត់វិធានការមិនបានគ្រប់គ្រាន់ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិអាចតម្រូវឱ្យម្ចាស់គម្រោង ឬប្រតិបត្តិការ ចាត់វិធានការទប់ស្កាត់ការខូចខាតបរិស្ថានឬធនធានធម្មជាតិនោះបាន។

២- វិធានការទប់ស្កាត់ការខូចខាតបរិស្ថានឬធនធានធម្មជាតិភ្លាមៗ ដូចបានបញ្ញត្តនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវធ្វើឡើងឱ្យបានសមស្របទៅតាមទំហំ និងប្រភេទនៃការខូចខាតបរិស្ថានឬធនធានធម្មជាតិ។ រាល់ការចំណាយទាក់ទងនឹងការចាត់វិធានការទប់ស្កាត់ការខូចខាតបរិស្ថានឬធនធានធម្មជាតិ ជាបន្ទុករបស់ម្ចាស់គម្រោង ឬប្រតិបត្តិការ។

៣- ក្រោយពីបានអនុវត្តនូវវិធានការទប់ស្កាត់ការខូចខាតបរិស្ថានឬធនធានធម្មជាតិ ហើយម្ចាស់គម្រោងឬប្រតិបត្តិការត្រូវជូនដំណឹងអំពីការអនុវត្តវិធានការនោះទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិជាបន្ទាន់។

ជំពូកទី៤
ការទទួលខុសត្រូវរបស់ម្ចាស់គម្រោងឬប្រតិបត្តិការនៅពេលមានការខូចខាតបរិស្ថានដ៏ធ្ងន់ធ្ងរធម្មជាតិ

មាត្រា៧២៣ .– កាតព្វកិច្ចរបស់ម្ចាស់គម្រោងឬប្រតិបត្តិការដែលធ្វើឱ្យខូចខាតបរិស្ថានឬធនធានធម្មជាតិ

១- ក្នុងករណីមានការខូចខាតបរិស្ថានឬធនធានធម្មជាតិកើតឡើង ម្ចាស់គម្រោងឬប្រតិបត្តិការដែលធ្វើឱ្យខូចខាតបរិស្ថានឬធនធានធម្មជាតិមានកាតព្វកិច្ចត្រូវទទួលខុសត្រូវចំពោះការខូចខាតនោះ។

២- ទោះបីមានបញ្ញត្តនៅក្នុងកថាខណ្ឌទី១ខាងលើនេះក៏ដោយ ម្ចាស់គម្រោងឬប្រតិបត្តិការអាចរួចផុតពីកាតព្វកិច្ចទទួលខុសត្រូវ ក្នុងករណីណាមួយដូចខាងក្រោម៖

ក- ការខូចខាតបណ្តាលមកពីសង្គ្រាមឬក្នុងករណីប្រធានសក្តិ។

ខ- ការខូចខាតត្រូវបានបង្កឡើងទាំងស្រុងដោយសារទង្វើ ឬការខកខានរបស់តតិយជនក្រៅពីបុគ្គលិកនិយោជិត ឬភ្នាក់ងាររបស់ម្ចាស់គម្រោងឬប្រតិបត្តិការ។

គ- ការខូចខាតដែលបានបង្កឡើងដោយសារតែសកម្មភាពដែលបានអនុញ្ញាតដោយច្បាប់។

ឃ- ការខូចខាតដែលបានបង្កឡើងដោយសកម្មភាពដែលបានអនុញ្ញាតជាពិសេស និងដែលបានពណ៌នាពីភាពជាក់លាក់ទាក់ទងនឹងប្រភេទ និងទំហំនៃការខូចខាតនៅក្នុងផែនការគ្រប់គ្រងបរិស្ថាននិងធនធាន

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៤៥៧

ធម្មជាតិ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង/ឬវិញ្ញាបនបត្រ និងលិខិតសម្រេចលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរួចហើយ។

៣- ការលើកលែងនូវការទទួលខុសត្រូវដូចបានបញ្ញត្តនៅក្នុងកថាខណ្ឌទី២ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើម្ចាស់គម្រោងឬប្រតិបត្តិករបានបំពានធ្ងន់ធ្ងរនៅក្នុងការអនុវត្តនីតិវិធីស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាត ឬបានបំពានធ្ងន់ធ្ងរទៅលើលក្ខខណ្ឌដែលបានកំណត់នៅក្នុងអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាត។

មាត្រា៧២៤ .- កាតព្វកិច្ចស្តារឡើងវិញនូវការខូចខាតបរិស្ថានឬធនធានធម្មជាតិ

ក្នុងករណីការខូចខាតបរិស្ថានឬធនធានធម្មជាតិបង្កឡើងដោយការអនុវត្តគម្រោង ដែលអាចស្តារឡើងវិញឱ្យមានលក្ខណៈល្អប្រសើរ ម្ចាស់គម្រោងឬប្រតិបត្តិករត្រូវធ្វើការស្តារឡើងវិញនូវការខូចខាតបរិស្ថានឬធនធានធម្មជាតិ។

មាត្រា៧២៥ .- កាតព្វកិច្ចទទួលខុសត្រូវសងសំណងការខូចខាតបរិស្ថានឬធនធានធម្មជាតិ

១- ម្ចាស់គម្រោងឬប្រតិបត្តិករត្រូវសងសំណងនៃការខូចខាតបរិស្ថានឬធនធានធម្មជាតិ ដែលបង្កឡើងដោយការអនុវត្តគម្រោងរបស់ខ្លួន ក្នុងករណីណាមួយដូចខាងក្រោម៖

ក- មិនអាចធ្វើការស្តារឡើងវិញឱ្យមានលក្ខណៈល្អប្រសើរ។

ខ- ម្ចាស់គម្រោងឬប្រតិបត្តិករ ខកខានមិនបានអនុវត្តការស្តារការខូចខាតបរិស្ថានឬធនធានធម្មជាតិឡើងវិញ ដូចបានបញ្ញត្តនៅក្នុងមាត្រា៧២៤(កាតព្វកិច្ចស្តារឡើងវិញនូវការខូចខាតបរិស្ថានឬធនធានធម្មជាតិ)នៃក្រមនេះ។

២- សំណងនៃការខូចខាតបរិស្ថានឬធនធានធម្មជាតិ ដូចបានបញ្ញត្តនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកម្រិតត្រឹមទំហំនៃការខូចខាតបរិស្ថានឬធនធានធម្មជាតិ។

មាត្រា៧២៦ .- កាតព្វកិច្ចជូនដំណឹងអំពីការខូចខាតបរិស្ថានឬធនធានធម្មជាតិ

ក្នុងករណីដែលមានការខូចខាតបរិស្ថានឬធនធានធម្មជាតិ ម្ចាស់គម្រោងឬប្រតិបត្តិករត្រូវជូនដំណឹងទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិជាបន្ទាន់ អំពីព័ត៌មាននៃការខូចខាតបរិស្ថានឬធនធានធម្មជាតិនោះ។

មាត្រា៧២៧ .- នីតិវិធីនៃការស្តារឡើងវិញនិងការសងសំណងការខូចខាតបរិស្ថានឬធនធានធម្មជាតិ

បែបបទ នីតិវិធីនៃការស្តារឡើងវិញ និងការសងសំណងការខូចខាតបរិស្ថានឬធនធានធម្មជាតិ ដូចបានបញ្ញត្តនៅក្នុងមាត្រា៧២៤(កាតព្វកិច្ចស្តារឡើងវិញនូវការខូចខាតបរិស្ថានឬធនធានធម្មជាតិ) និងមាត្រា៧២៥(កាតព្វកិច្ចទទួលខុសត្រូវសងសំណងការខូចខាតបរិស្ថានឬធនធានធម្មជាតិ)នៃក្រមនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៧២៨ .- សិទ្ធិទាមទារថ្លៃចំណាយនៃការអនុវត្តផែនការស្តារការខូចខាតបរិស្ថានឬធនធានធម្មជាតិឡើងវិញ

បុគ្គលដែលមិនបានបង្កឱ្យមានការខូចខាតបរិស្ថានឬធនធានធម្មជាតិ តែបានចំណាយលើការអនុវត្តផែនការស្តារការខូចខាតបរិស្ថានឬធនធានធម្មជាតិឡើងវិញ អាចទាមទារថ្លៃចំណាយនោះពីម្ចាស់គម្រោង ឬប្រតិបត្តិករដែលបានបង្កឱ្យមានការខូចខាតបរិស្ថានឬធនធានធម្មជាតិ ដោយអនុលោមតាមក្រមរដ្ឋប្បវេណី និងច្បាប់ផ្សេងទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលកំពុងនៅជាធរមាន។

ជំពូកទី៥

វិធានការទប់ស្កាត់និងស្តារការខូចខាតបរិស្ថាននិងធនធានធម្មជាតិឡើងវិញ

មាត្រា៧២៩ .– ការអនុវត្តវិធានការទប់ស្កាត់និងស្តារការខូចខាតបរិស្ថានឬធនធានធម្មជាតិឡើងវិញ

១- ទោះបីជាមានបញ្ញត្តិនៃមាត្រា៧២២(កាតព្វកិច្ចរបស់ម្ចាស់គម្រោងឬប្រតិបត្តិករក្នុងការអនុវត្តវិធានការទប់ស្កាត់ការខូចខាតបរិស្ថានឬធនធានធម្មជាតិភ្លាមៗ)នៃក្រមនេះក៏ដោយ ក្នុងករណីមានហានិភ័យបន្ទាន់កើតឡើងដែលបង្កឱ្យមានការខូចខាតបរិស្ថានឬធនធានធម្មជាតិ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិអាចចាត់វិធានការចាំបាច់ ដើម្បីទប់ស្កាត់ការខូចខាតបរិស្ថានឬធនធានធម្មជាតិដោយខ្លួនឯង។

២- ទោះបីជាមានបញ្ញត្តិនៃមាត្រា៧២៨(កាតព្វកិច្ចស្តារឡើងវិញនូវការខូចខាតបរិស្ថានឬធនធានធម្មជាតិ)នៃក្រមនេះក៏ដោយ ក្នុងករណីមានការខូចខាតបរិស្ថានឬធនធានធម្មជាតិ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិអាចចាត់វិធានចាំបាច់ ដើម្បីស្តារការខូចខាតបរិស្ថានឬធនធានធម្មជាតិនោះដោយខ្លួនឯង។

មាត្រា៧៣០ .– ការទាមទារថ្លៃចំណាយនៃការអនុវត្តវិធានការទប់ស្កាត់និងស្តារឡើងវិញ

ក្នុងករណីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ បានអនុវត្តវិធានការទប់ស្កាត់ដូចបានបញ្ញត្តនៅក្នុងកថាខណ្ឌទី១នៃមាត្រា៧២៩(ការអនុវត្តវិធានការទប់ស្កាត់និងស្តារការខូចខាតបរិស្ថានឬធនធានធម្មជាតិឡើងវិញ) ឬវិធានការស្តារឡើងវិញដូចបានបញ្ញត្តនៅក្នុងកថាខណ្ឌទី២នៃមាត្រា៧២៩(ការអនុវត្តវិធានការទប់ស្កាត់និងស្តារការខូចខាតបរិស្ថានឬធនធានធម្មជាតិឡើងវិញ)នៃក្រមនេះ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ អាចទាមទារថ្លៃចំណាយទៅលើការអនុវត្តវិធានការនោះ ពីម្ចាស់គម្រោងឬប្រតិបត្តិករ។

ភាគទី៧

ការអប់រំ ការស្រាវជ្រាវ វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ និងការយល់ដឹងអំពីបរិស្ថាន

មាតិកាទោល

គោលនយោបាយនិងយុទ្ធសាស្ត្រអប់រំ ស្រាវជ្រាវ វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍និងយល់ដឹងអំពីបរិស្ថាន

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា៧៣១ .– គោលបំណង

មាតិកានេះ មានគោលបំណងលើកកម្ពស់ការអប់រំ ការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា សមត្ថភាពនវានុវត្តន៍ និងការយល់ដឹងពាក់ព័ន្ធវិស័យបរិស្ថាន ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព សុខដុមរមនាក្នុងបរិស្ថានល្អ ស្អាត សុវត្ថិភាពនៃប្រព័ន្ធអេកូឡូស៊ី និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របតាមរយៈការពង្រឹង និងពង្រីកសមត្ថភាពស្រាវជ្រាវ អប់រំ កិច្ចសហប្រតិបត្តិការ និងការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធ។

មាត្រា៧៣២ .– វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តចំពោះក្រសួងស្ថាប័ន វិស័យឯកជន គ្រឹះស្ថានសិក្សា សមាគម និងអង្គការមិនមែនរដ្ឋាភិបាល សហជីព និងអង្គភាពនានា ដែលបំពេញកិច្ចការពាក់ព័ន្ធនឹងការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា សមត្ថភាពនវានុវត្តន៍ ការងារអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ និងផ្តល់ការយល់ដឹងជាសាធារណៈ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៤៥៩

ជំពូកទី២
ស្ថាប័នទទួលខុសត្រូវ

មាត្រា៧៣៣ .- ក្រសួងស្ថាប័នទទួលខុសត្រូវ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ទទួលខុសត្រូវលើការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា សមត្ថភាពនានុវត្តន៍ ការគ្រប់គ្រងទិន្នន័យបរិស្ថាន និងដឹកនាំសម្របសម្រួលការងារអប់រំ និងការផ្សព្វផ្សាយព័ត៌មានបរិស្ថាន ព្រមទាំងចាត់ចែងរៀបចំព្រឹត្តិការណ៍បរិស្ថានសំខាន់ៗ។

មាត្រា៧៣៤ .- តួនាទីនិងការកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងការកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ផែនការថវិកា គោលការណ៍ណែនាំ និងកម្មវិធីនានាពាក់ព័ន្ធនឹងសកម្មភាពស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា សមត្ថភាពនានុវត្តន៍ពាក់ព័ន្ធវិស័យបរិស្ថាន ការគ្រប់គ្រងទិន្នន័យ ការអប់រំ និងការផ្សព្វផ្សាយ ព័ត៌មានបរិស្ថាន ព្រមទាំងការវាយតម្លៃការប្រតិបត្តិមេត្រីបរិស្ថាន។

ខ- ប្រមូល វិភាគ ចងក្រង និងគ្រប់គ្រងព័ត៌មាននិងទិន្នន័យបរិស្ថាន រួមទាំងកសាងនិងគ្រប់គ្រងប្រព័ន្ធប្រមូលផ្តុំទិន្នន័យបរិស្ថាន។

គ- រៀបចំ និងគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបរិស្ថាន។

ឃ- រៀបចំរបាយការណ៍ស្តីពីស្ថានភាពបរិស្ថានជាតិ ដោយសហការនិងសម្របសម្រួលជាក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ង- លើកកម្ពស់ការយល់ដឹងអំពីបរិស្ថានដល់សាធារណជន តាមរយៈការបញ្ជ្រាបការអប់រំបរិស្ថានក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ ការផ្សព្វផ្សាយចំណេះដឹងអំពីបរិស្ថាន និងការលើកទឹកចិត្តការប្រតិបត្តិមេត្រីបរិស្ថាន។

ច- ផលិតនិងផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានស្តីពីសកម្មភាព ស្ថានភាព និងសមិទ្ធផលទាក់ទងនឹងកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ និងការរស់នៅប្រកបដោយចីរភាព។

ឆ- រៀបចំ និងចាត់ចែងព្រឹត្តិការណ៍ជាសាធារណៈពាក់ព័ន្ធនឹងសកម្មភាពផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានស្តីពីបរិស្ថាន។

ជ- សម្របសម្រួលនិងសហការជាមួយអង្គភាពនានាក្រោមឱវាទក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍនិងវិស័យឯកជនដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងបង្កើនប្រសិទ្ធភាពការងារគ្រប់គ្រងទិន្នន័យបរិស្ថាន និងការងារអប់រំផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានស្តីពីបរិស្ថាន។

ជំពូកទី៣
គោលនយោបាយ យុទ្ធសាស្ត្រនិងយន្តការសម្របសម្រួល

មាត្រា៧៣៥ .- គោលនយោបាយជាតិអប់រំបរិស្ថាន

ក្រសួងទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិ ត្រូវសហការរៀបចំសេចក្តីព្រាងគោលនយោបាយជាតិអប់រំបរិស្ថាន ដែលជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពអប់រំក្នុងប្រព័ន្ធគ្រប់កម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈ សិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា សមត្ថភាពនានុវត្តន៍ និងការផ្សព្វផ្សាយចំណេះដឹងបរិស្ថានតាមគ្រប់មធ្យោបាយ និងគ្រប់រូបភាព។ គោលនយោបាយជាតិអប់រំស្រោវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនានុវត្តន៍បរិស្ថានអាចត្រូវបានពិនិត្យនិងកែសម្រួលឡើងវិញ តាមការចាំបាច់ និងភាពជាក់ស្តែងនៃដំណើរវិវឌ្ឍន៍របស់សេដ្ឋកិច្ច សង្គម និងបរិស្ថាន។

មាត្រា៧៣៦ .– យន្តការសម្របសម្រួលការអនុវត្តគោលនយោបាយជាតិអប់រំបរិស្ថាន

ការអនុវត្តគោលនយោបាយជាតិអប់រំបរិស្ថាន ត្រូវសម្របសម្រួលដោយយន្តការអន្តរក្រសួងទទួលបន្ទុកការងារគោលនយោបាយជាតិអប់រំស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍បរិស្ថាន ដែលត្រូវបង្កើតឡើងដោយរាជរដ្ឋាភិបាលដើម្បីជំរុញការបញ្ជ្រាបផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអប់រំ ស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍បរិស្ថានទៅក្នុងផែនការអភិវឌ្ឍថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

មាត្រា៧៣៧ .– ផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពអប់រំបរិស្ថាន

ក្រសួងស្ថាប័ន និងអង្គភាពពាក់ព័ន្ធនឹងការងារអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ការសិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយជាសាធារណៈអំពីបរិស្ថាន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអប់រំ ស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍ បរិស្ថានក្នុងបរិបទនៃដែនសមត្ថកិច្ចរបស់ខ្លួនដោយអនុលោមតាមគោលនយោបាយជាតិអប់រំស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍បរិស្ថាន។ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអប់រំស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍បរិស្ថានត្រូវធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់ និងតម្រូវការជាក់ស្តែង។

មាត្រា៧៣៨ .– ការអនុវត្តផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពអប់រំបរិស្ថាន

រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ អង្គភាព ឬគ្រឹះស្ថានក្រោមឱវាទក្រសួងស្ថាប័នសាមី និងភាគីពាក់ព័ន្ធត្រូវអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអប់រំស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍បរិស្ថាននេះ ឱ្យបានសមស្របទៅតាមស្ថានភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន សំដៅធានាឱ្យបាននូវគុណភាពបរិស្ថាន តុល្យភាពនៃប្រព័ន្ធអេកូឡូស៊ី និងការរស់នៅប្រកបដោយចីរភាព។

ជំពូកទី៤
ការអប់រំនិងការស្រាវជ្រាវបរិស្ថាន
ផ្នែកទី១
ការអប់រំនិងបណ្តុះបណ្តាលបរិស្ថានក្នុងប្រព័ន្ធអប់រំ

មាត្រា៧៣៩ .– កម្មវិធីអប់រំនិងបណ្តុះបណ្តាលបរិស្ថាន

គ្រប់គ្រឹះស្ថានសិក្សាស្រាវជ្រាវក្រោមឱវាទក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវមានកម្មវិធីសិក្សាគោលអំពីបរិស្ថាន និងសម្ភារៈសម្រាប់ការអប់រំ ស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមអង្គភាពរៀងៗខ្លួន។ ការរៀបចំកម្មវិធីសិក្សាគោលអំពីបរិស្ថាន និងសម្ភារៈឧបទេសត្រូវឱ្យស្របតាមគោលនយោបាយជាតិអប់រំស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍បរិស្ថាន និងដំណើរវិវឌ្ឍន៍របស់សេដ្ឋកិច្ច សង្គម វប្បធម៌ និងបច្ចេកវិទ្យានិងវិទ្យាសាស្ត្រ។

មាត្រា៧៤០ .– ធនធានគ្រូឧទ្ទេសនិងសាស្ត្រាចារ្យ

គ្រប់គ្រឹះស្ថានសិក្សាស្រាវជ្រាវក្រោមឱវាទក្រសួងស្ថាប័នពាក់ព័ន្ធនឹងការងារអប់រំបរិស្ថានទាំងអស់ ត្រូវកសាងនិងអភិវឌ្ឍធនធានគ្រូឧទ្ទេស និងសាស្ត្រាចារ្យប្រកបដោយគុណវុឌ្ឍិ ដើម្បីធានាបាននូវប្រសិទ្ធភាព និងប្រសិទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃក្រសួងស្ថាប័នសាមី។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៤៦១

មាត្រា៧៤១ .– តម្លៃការអប់រំនិងបណ្តុះបណ្តាល

គ្រប់គ្រឹះស្ថានសិក្សាស្រាវជ្រាវក្រោមឱវាទក្រសួងស្តាប័នពាក់ព័ន្ធនឹងការងារអប់រំបរិស្ថានទាំងអស់ ត្រូវកំណត់កម្មវិធីអប់រំបណ្តុះបណ្តាលអប្បបមោ ស្របតាមគោលដៅ និងតម្លៃការនៃការអប់រំបណ្តុះបណ្តាលរបស់អង្គភាពសាមី។

ផ្នែកទី២
ការស្រាវជ្រាវ វិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍

មាត្រា៧៤២ .– មជ្ឈមណ្ឌលទិន្នន័យបរិស្ថានជាតិ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវបង្កើតមជ្ឈមណ្ឌលធនធានបរិស្ថានដែលជាមជ្ឈមណ្ឌលប្រមូលផ្តុំទិន្នន័យ ព័ត៌មាន វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍បរិស្ថាន ដើម្បីជាប្រយោជន៍ដល់អ្នកសិក្សា អ្នកស្រាវជ្រាវ អ្នករៀបចំគោលនយោបាយ និងសាធារណជន។

មាត្រា៧៤៣ .– ការស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

ក្រសួងស្តាប័ន គ្រឹះស្ថានសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងប្រតិបត្តិករពាក់ព័ន្ធនឹងវិស័យបរិស្ថានត្រូវសហការរៀបចំវេទិកាវិទ្យាសាស្ត្រ កម្មវិធីឬសកម្មភាពសិក្សាស្រាវជ្រាវរួមគ្នាក្នុងលក្ខណៈជាការសំយោគគំនិតរវាងអ្នកធ្វើគោលនយោបាយ អ្នកវិទ្យាសាស្ត្រ និងអ្នកប្រតិបត្តិ ដើម្បីមានមូលដ្ឋានពុទ្ធិវិទ្យាសាស្ត្រសម្រាប់ការរៀបចំយុទ្ធសាស្ត្រ និងការធ្វើសេចក្តីសម្រេចក្នុងការដោះស្រាយបញ្ហាប្រឈមដែលកើតមានក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយចីរភាព។

ជំពូកទី៥
ការយល់ដឹងអំពីបរិស្ថាននិងមេត្រីបរិស្ថាន
ផ្នែកទី១
ការផ្សព្វផ្សាយជាសាធារណៈអំពីបរិស្ថាន

មាត្រា៧៤៤ .– កម្មវិធីផ្សព្វផ្សាយចំណេះដឹងបរិស្ថាន

ក្រសួងស្តាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ និងអ្នកពាក់ព័ន្ធត្រូវមានផែនការសកម្មភាពនិងកម្មវិធីផ្សព្វផ្សាយចំណេះដឹងអំពីកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការរស់នៅប្រកបដោយចីរភាព។

មាត្រា៧៤៥ .– សកម្មភាពផ្សព្វផ្សាយចំណេះដឹងបរិស្ថាន

រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ អង្គភាពជំនាញមានសមត្ថកិច្ច គ្រឹះស្ថានសាធារណៈ វិស័យឯកជន និងអ្នកពាក់ព័ន្ធ មានភាតព្វកិច្ចនិងការកិច្ចផ្សព្វផ្សាយគោលនយោបាល យុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងចំណេះដឹងពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិ ឱ្យបានទូលំទូលាយតាមគ្រប់មធ្យោបាយ និងគ្រប់រូបភាព។

មាត្រា៧៤៦ .– ការចូលរួមលើកកម្ពស់ការយល់ដឹងបរិស្ថាន

ពលរដ្ឋគ្រប់រូបត្រូវមានករណីយកិច្ចចូលរួមលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីភាពចាំបាច់ និងសារប្រយោជន៍នៃកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការរស់នៅប្រកបដោយចីរភាព។

ផ្នែកទី២
មេត្រីបរិស្ថាន

មាត្រា៧៤៧ .- ការទទួលស្គាល់និងលើកទឹកចិត្តប្រតិបត្តិមេត្រីបរិស្ថាន

បុគ្គលដែលបានចូលរួមប្រតិបត្តិសកម្មភាពមេត្រីបរិស្ថាន និងប្រើប្រាស់បច្ចេកវិទ្យាទ្រទ្រង់បរិស្ថានត្រូវទទួលស្គាល់ និងលើកទឹកចិត្ត។

មាត្រា៧៤៨ .- សមត្ថកិច្ចផ្តល់ការទទួលស្គាល់និងលើកទឹកចិត្ត

ការទទួលស្គាល់និងការលើកទឹកចិត្តដល់បុគ្គលដែលបានចូលរួមប្រតិបត្តិសកម្មភាពមេត្រីបរិស្ថាន និងប្រើប្រាស់បច្ចេកវិទ្យាទ្រទ្រង់បរិស្ថានត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ដែលរៀបចំដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា៧៤៩ .- ការប្រឡងប្រណាំងមេត្រីបរិស្ថាន

ក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជនត្រូវធានានិរន្តរភាពនៃការរៀបចំឱ្យមានកម្មវិធីប្រឡងប្រណាំង និងលើកទឹកចិត្តដល់បុគ្គល ដែលបានប្រតិបត្តិសកម្មភាពមេត្រីបរិស្ថាននិងប្រើប្រាស់បច្ចេកវិទ្យាទ្រទ្រង់បរិស្ថាន។

ផ្នែកទី៣
សាលាមេត្រីបរិស្ថាន

មាត្រា៧៥០ .- សាលាមេត្រីបរិស្ថាន

១- កម្មវិធីពានរង្វាន់សាលាមេត្រីបរិស្ថាន ត្រូវបានដាក់ឱ្យអនុវត្ត និងប្រឡងប្រជែងគ្នារៀងរាល់២(ពីរ)ឆ្នាំម្តង ដើម្បីលើកទឹកចិត្តដល់គ្រឹះស្ថានសិក្សាចំណេះទូទៅ មានជាអាទិ៍ បឋមសិក្សា និងមធ្យមសិក្សាឱ្យ៖

ក- បង្កើតគោលការណ៍ និងរដ្ឋបាលរបស់សាលាលើការងារបរិស្ថាន។

ខ- បង្កើតការបង្រៀនមេរៀនបរិស្ថាន និងសកម្មភាពអប់រំបរិស្ថានក្នុងសាលា និងតំបន់ដែលនៅជុំវិញជាកម្មវិធីសិក្សាបន្ថែម ឬបញ្ជ្រាប។

គ- ដាក់ឱ្យមាននូវសម្ភារៈបរិក្ខារអប់រំបរិស្ថាន ហេដ្ឋារចនាសម្ព័ន្ធនានា និងការប្រតិបត្តិបរិស្ថានក្នុងគ្រឹះស្ថានសិក្សាចំណេះទូទៅ។

ឃ- សហការជាមួយភាគីពាក់ព័ន្ធ និងផ្សព្វផ្សាយពីការអប់រំបរិស្ថាន និងការប្រតិបត្តិបរិស្ថាននៅតាមតំបន់ដែលនៅជុំវិញគ្រឹះស្ថានសិក្សាចំណេះទូទៅ។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យអប់រំ យុវជន និងកីឡាមានភារកិច្ច ដឹកនាំ គ្រប់គ្រង វាយតម្លៃ និងសម្រេចលើរាល់កិច្ចការដែលពាក់ព័ន្ធនឹងកម្មវិធីពានរង្វាន់សាលាមេត្រីបរិស្ថាននេះ។

មាត្រា៧៥១ .- សូចនាករនៃបេក្ខភាពប្រឡងប្រជែងពានរង្វាន់សាលាមេត្រីបរិស្ថាន

គ្រឹះស្ថានសិក្សានីមួយៗ ដែលជាបេក្ខភាពប្រឡងប្រជែងពានរង្វាន់សាលាមេត្រីបរិស្ថាននឹងត្រូវបានវាយតម្លៃលើសូចនាករចំនួន១៨(ដប់ប្រាំបី)មានជាអាទិ៍៖

ក- ទស្សនវិស័យនិងបេសកកម្មដែលឆ្លុះបញ្ចាំងអំពីការលើកស្ទួយបរិស្ថាន។

ខ- គោលការណ៍ប្រតិបត្តិបរិស្ថាន។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៤៦៣

គ- រចនាសម្ព័ន្ធដឹកនាំ ការអនុវត្តកម្មវិធី សាលាមេត្រីបរិស្ថាន។
ឃ- ផែនការថវិកាសម្រាប់អនុវត្តសកម្មភាពបរិស្ថាន។
ង- ប្រព័ន្ធរាយការណ៍ សកម្មភាពបរិស្ថាន និងហិរញ្ញវត្ថុ។
ច- កម្មវិធីសិក្សាគោលនិងបន្ថែមឬបញ្ចូល ដែលបានដាក់បញ្ចូលមេរៀនស្តីពីការអប់រំបរិស្ថាន។
ឆ- ការកសាងសមត្ថភាពគ្រូបង្រៀនពីបរិស្ថាននិងធនធានធម្មជាតិ។
ជ- មេរៀននិងសកម្មភាពរៀនដែលសមស្របទៅនឹងបរិបទក្នុងស្រុកនិង/ឬតំបន់។
ឈ- សម្ភារៈឧបទេសបង្រៀនទាក់ទងនឹងបរិស្ថាន។
ញ- ក្រុមការងារ សកម្មភាព ដែលផ្សព្វផ្សាយអប់រំពីបរិស្ថាន។
ដ- បរិក្ខារប្រើប្រាស់ដែលធ្វើឱ្យមានមេត្រីភាពបរិស្ថាន។
ឋ- ការច្នៃប្រឌិតនិងការបង្កើតគំនិតសកម្មភាពថ្មីដែលមានមេត្រីភាពបរិស្ថាន។
ឌ- ទីធ្លាបៃតង ផ្ទៃបៃតង។
ឍ- សម្ភារៈឧបទេស សម្រាប់ការអនុវត្តផ្ទាល់នៅក្រៅថ្នាក់។
ណ- ការប្រតិបត្តិសកម្មភាពមេត្រីភាពបរិស្ថាន ឥរិយាបថរបស់សិស្សក្នុងការចូលរួមអនុវត្តមេត្រីភាពបរិស្ថាន។
ត- ដៃគូសហការនិងភាគីពាក់ព័ន្ធ។
ថ- កម្រិតនៃភាពជាដៃគូនិងការគាំទ្រ។
ទ- សកម្មភាពផ្សព្វផ្សាយតាមតំបន់។

មាត្រា៧៥២ .- សកម្មភាពសាលាមេត្រីបរិស្ថាន

បន្ថែមពីលើសូចនាករ ដូចមានចែងក្នុងមាត្រា៧៥១(សូចនាករនៃបេក្ខភាពប្រឡងប្រជែងពានង្វាន់សាលាមេត្រីបរិស្ថាន)នៃក្រមនេះ ការវាយតម្លៃលើបេក្ខភាពជ័យលាភីនៃពានង្វាន់សាលាមេត្រីបរិស្ថាន នឹងត្រូវគិតផងដែរទៅលើសកម្មភាពផ្សេងទៀត មានដូចជាអាទិ៍៖

ក- ការដាំស្មៅ ដាំដើមឈើ និងបន្លែ។
ខ- ការកាត់បន្ថយ ការបញ្ឈប់ការប្រើប្រាស់ថាមពលឥន្ធនៈ ហ្វូស៊ីលមកប្រើប្រាស់ថាមពលស្អាតដោយការប្រើប្រាស់ថាមពលកកើតឡើងវិញ។
គ- ការសន្សំសំចៃទឹក។
ឃ- ការគ្រប់គ្រងសំណល់ដោយត្រូវបែងចែកតាមប្រភេទសំណល់ និងត្រូវកាត់បន្ថយសំណល់ប្រើសំណល់ឡើងវិញ និងកែច្នៃសំណល់ឡើងវិញ។
ង- ហាមការលក់ចំណីអាហារ ដែលមានសេដាតិ ពណ៌ ក្លិនសិប្បនិម្មិត ក្នុងបរិវេណសាលា។
ច- ហាមការប្រើប្រាស់ថង់ប្លាស្ទិច ក្នុងការវេចខ្ចប់ចំណីអាហារ និងកេសដ្ឋៈនៅតាមតូបលក់ចំណីអាហារក្នុងបរិវេណសាលា។
ឆ- សម្អាតបន្ទប់រៀននិងបង្គន់ជាប្រចាំ ធានានូវអនាម័យល្អនិងសុខភាព។
ជ- ផ្សព្វផ្សាយទិវាកពផែនដី ទិវាគ្មានថង់ប្លាស្ទិច ទិវាក្រុងទិវា ជាអាទិ៍។
ឈ- ផ្តល់រង្វាន់ដល់សិស្ស ដែលមានស្នាដៃនិងប្រតិបត្តិការងារអប់រំបរិស្ថានបានល្អ ។
ញ- ការប្រកួតសិល្បៈបរិស្ថាន ដូចជាការបង្ហាញម៉ូតដែលប្រើសម្ភារៈ កែច្នៃឡើងវិញ ការប្រកួតរូបថត និងការប្រកួតគំនូរ ជាដើម។

មាត្រា៧៥៣ .– ពានរង្វាន់សាលាមេត្រីបរិស្ថាន

១- ពានរង្វាន់ត្រូវបានចែកជាបីផ្នែក មានដូចអាទិ៍៖

ក- ពានរង្វាន់មាសមានសុពលភាព៤(បួន)ឆ្នាំ។

ខ- ពានរង្វាន់ប្រាក់មានសុពលភាព២(ពីរ)ឆ្នាំ។

គ- ពានរង្វាន់សំរិទ្ធិមានសុពលភាព២(ពីរ)ឆ្នាំ។

២- ម្ចាស់ជ័យលាភីពានរង្វាន់មិនត្រូវបានអនុញ្ញាតឱ្យចូលរួមប្រកួតប្រជែង ពានរង្វាន់សាលាមេត្រីទៀតទេ ដរាបណាពានរង្វាន់របស់ខ្លួននៅមានសុពលភាព។

គន្លឹះទី៨
វិធានសេដ្ឋកិច្ច ហិរញ្ញវត្ថុ ប្រាក់កម្រៃនិងមូលនិធិផ្នែកបរិស្ថាន
អាតិការទី១
វិធានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា៧៥៤ .– គោលបំណង

មាតិកានេះ មានគោលបំណងកំណត់អំពីវិធាន នីតិវិធី នៃការគ្រប់គ្រងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ប្រាក់កម្រៃ មូលនិធិ និងការគ្រប់គ្រងមូលនិធិបរិស្ថាននិងសង្គម ដែលគាំទ្រដល់វិស័យបរិស្ថាន ធនធានធម្មជាតិ សង្គម និងវប្បធម៌។

មាត្រា៧៥៥ .– វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តចំពោះវិធានសេដ្ឋកិច្ច ហិរញ្ញវត្ថុ ប្រាក់កម្រៃ និងមូលនិធិផ្នែកបរិស្ថាន និងសង្គម ដែលត្រូវបានបង្កើតឡើងក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមគោលនយោបាយ ច្បាប់ និងបទដ្ឋានគតិយុត្ត របស់រាជរដ្ឋាភិបាល រួមបញ្ចូលទាំងលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

ជំពូកទី២
ស្ថាប័នទទួលខុសត្រូវ

មាត្រា៧៥៦ .– ក្រសួងស្ថាប័នទទួលខុសត្រូវ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិដោយសហការជាមួយក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវទទួលខុសត្រូវក្នុងការរៀបចំ កំណត់វិធានការសេដ្ឋកិច្ច មូលនិធិហិរញ្ញវត្ថុ កម្រៃ ពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងធនធានធម្មជាតិ ។

មាត្រា៧៥៧ .– តួនាទីនិងការកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងការកិច្ច ដូចខាងក្រោម៖

ក- ធ្វើការសម្របសម្រួលការងារហិរញ្ញវត្ថុ មូលនិធិ ពាក់ព័ន្ធវិស័យបរិស្ថាននិងធនធានធម្មជាតិជាមួយស្ថាប័នពាក់ព័ន្ធ។

ខ- រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងគោលការណ៍ហិរញ្ញវត្ថុ មូលនិធិ ពាក់ព័ន្ធនឹងបរិស្ថាននិងធនធានធម្មជាតិ ដើម្បីស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៤៦៥

គ- ទទួលខុសត្រូវ និងសម្របសម្រួលក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ ស្របតាមគោលនយោបាយ និងផែនការរបស់រាជរដ្ឋាភិបាល។

ឃ- តាមដាន និងវាយតម្លៃការអនុវត្តគម្រោងផែនការថវិកា។

ង- រៀបចំរបាយការណ៍ថវិកា និងវិធានសេដ្ឋកិច្ចក្នុងការគាំទ្រដល់បរិស្ថាន ធនធានធម្មជាតិ សង្គម និងវប្បធម៌។

ច- តាមដាន ត្រួតពិនិត្យ និងជំរុញការអនុវត្តប្រមូល និងការប្រើប្រាស់មូលនិធិបរិស្ថាន និងសង្គម។

ឆ- គ្រប់គ្រង និងប្រើប្រាស់មូលនិធិតំបន់ការពារ និងមូលនិធិទាយជ្ជទានបរិស្ថាន។

ជំពូកទី៣
វិធានសេដ្ឋកិច្ច

មាត្រា៧៥៨ .- ការវាយតម្លៃលើឱកាសនិងយន្តការលើកទឹកចិត្តឱ្យមានការវិនិយោគផ្នែកបរិស្ថាននិងធនធានធម្មជាតិ

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវដឹកនាំក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការវាយតម្លៃជាប្រចាំទៅលើឱកាស និងយន្តការលើកទឹកចិត្តឱ្យមានការវិនិយោគទៅលើផ្នែកកិច្ចគាំពារបរិស្ថាន ការអភិរក្ស ការគ្រប់គ្រង និងការស្តារឡើងវិញនូវធនធានធម្មជាតិ។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬក្រសួងស្ថាប័នពាក់ព័ន្ធត្រូវរៀបចំផែនការបាយការណ៍ និងលើកសំណើចំពោះវិធានសេដ្ឋកិច្ចស្របតាមគោលនយោបាយអាទិភាពរបស់ក្រសួងស្ថាប័នសាមី និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុន ដើម្បីពិនិត្យ សហការ និងឯកភាពឬក្នុងករណីចាំបាច់ត្រូវដាក់ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីពិនិត្យសម្រេចចំពោះការលើកទឹកចិត្ត និងវិធានទាំងនេះ។

មាត្រា៧៥៩ .- វិធានសេដ្ឋកិច្ចដើម្បីគាំទ្រគោលនយោបាយបរិស្ថាននិងធនធានធម្មជាតិ

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវរៀបចំសេចក្តីព្រាងគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តស្តីពីវិធានសេដ្ឋកិច្ចក្នុងការគាំទ្រដល់បរិស្ថាន ធនធានធម្មជាតិ សង្គម និងវប្បធម៌ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពិសេសដោយឡែកពាក់ព័ន្ធនឹងសារពើពន្ធនិងកិច្ចលទ្ធកម្ម។

២- ការរៀបចំសេចក្តីព្រាងគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្ត ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះត្រូវស្របតាមលិខិតបទដ្ឋានគតិយុត្តអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី និងត្រូវរៀបចំឱ្យមានវិធានសេដ្ឋកិច្ចពាក់ព័ន្ធនឹង៖

ក- ការដាក់បញ្ចូលស្តង់ដារពាក់ព័ន្ធការអនុវត្តការងារបរិស្ថាន និងសង្គម និងការគ្រប់គ្រងហានិភ័យទៅក្នុងការធ្វើសេចក្តីសម្រេចរបស់នីតិបុគ្គលពីវិស័យធុរកិច្ច និងហិរញ្ញវត្ថុ។

ខ- ការវិនិយោគលើវិស័យឯកជនពាក់ព័ន្ធនឹងបរិស្ថាននិងធនធានធម្មជាតិ។

គ- ការកាត់បន្ថយការធ្វើអាជីវកម្មលើព្រៃឈើ ធនធានធម្មជាតិ និងការលើកកម្ពស់ការអភិរក្សជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី។

ឃ- ការផលិតផ្សាំងនិងអុសដោយនិរន្តរភាព។

ង- ក្រួប្រមាញ់និងជលផលដោយនិរន្តរភាព។

ច- ការអភិរក្សទឹកសាប មានជាអាទិ៍ ការលើកកម្ពស់ការប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធផល និងការស្រោវជ្រាវដើម្បីការពារនិងគ្រប់គ្រងគុណភាពទឹក និងកាត់បន្ថយការបញ្ចេញសំណល់ទឹកកខ្វក់ និងសំណល់ពស។

ឆ- ការគ្រប់គ្រងធនធានធម្មជាតិនៅតាមសហគមន៍មានជាអាទិ៍ ការលើកលែងអាករលើតម្លៃបន្ថែម និងពន្ធដទៃទៀតលើប្រាក់ចំណូល ប្រាក់កម្រៃ មូលនិធិ ឬប្រាក់រួមវិភាគទានផ្សេងៗ ដែលទទួលបានពីការអនុវត្តការគ្រប់គ្រងរួមគ្នា។

ជ- ការអភិវឌ្ឍ និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធថាមពលប្រកបដោយការទទួលខុសត្រូវមានជាអាទិ៍ អគ្គិសនីខ្នាតតូច។

ឈ-ការលើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធថាមពលពីប្រភពកកើតឡើងវិញ មានជាអាទិ៍ ព្រះអាទិត្យ ខ្យល់ ទឹក និងរលកសមុទ្រ និងគ្រឿងដំឡើងដទៃទៀត។

ញ- ការប្រើប្រាស់ថាមពលស្អាត ប្រភេទនៃផលិតកម្មដែលមានប្រសិទ្ធផលធនធាន និងមានការបញ្ចេញកាបូនតិច និងការកាត់បន្ថយការបំពុលបរិស្ថាន និងសុខភាពសាធារណៈ។

ដ- ការប្រើប្រាស់បច្ចេកវិទ្យាបរិស្ថានប្រសើរបំផុត ដែលបានពិសោធនិងផ្ទៀងផ្ទាត់រួច។

ឋ- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានាក្នុងគោលបំណងការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ។

ឌ- ការបែងចែកដោយសមធម៌នូវប្រាក់ចំណូលបានមកពីយន្តការទូទាត់ការបញ្ចេញកាបូនដែលកំណត់ដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។

ឍ- ការបង់ថ្លៃលើការផលិត ឬការចែទាំសេវាកម្មធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ីទៅកាន់រូបវន្តបុគ្គលនិងសហគមន៍ដោយសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ណ- ការលើកកម្ពស់ការនាំចូល ការទិញយានយន្តមេត្រីបរិស្ថាន និងទប់ស្កាត់ការនាំចូលយានយន្ត ដែលមានផលប៉ះពាល់ខ្ពស់ដល់បរិស្ថាន និងសុខភាពសាធារណៈ។

ត- ការលើកកម្ពស់ការប្រើប្រាស់ថាមពលប្រកបដោយការទទួលខុសត្រូវមានជាអាទិ៍ ការគាំទ្រដល់ការប្រើប្រាស់ក្នុងធុរកិច្ចនូវប្រភពថាមពលប្រកបដោយការទទួលខុសត្រូវ ធុរកិច្ចដែលធ្វើពាណិជ្ជកម្មដំឡើង ឬផ្គត់ផ្គង់ផ្នែកបច្ចេកទេស ឬថែទាំឧបករណ៍ថាមពលប្រកបដោយការទទួលខុសត្រូវ ធុរកិច្ចដែលនាំចូល ផលិត ចែកចាយ ឬលក់ឧបករណ៍ដែលផលិតថាមពលប្រកបដោយការទទួលខុសត្រូវ ឬបង្កើនប្រសិទ្ធផលថាមពល ដែលមានលក្ខណសម្បត្តិត្រឹមត្រូវស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធសុខភាព សុវត្ថិភាព និងបរិស្ថាន និងការនាំចូលឧបករណ៍សម្រាប់ផលិតថាមពលប្រកបដោយការទទួលខុសត្រូវ ឬបង្កើនប្រសិទ្ធផលថាមពល។

ថ- ការអភិរក្ស និងកិច្ចគាំពារបេតិកភណ្ឌវប្បធម៌។

ទ- ការអភិរក្សថាមពល តាមរយៈការបង្កើនចំហៈ និងប្រសិទ្ធផលនៃការប្រើប្រាស់អគ្គិសនី ការទប់ស្កាត់ចំពោះការបាត់បង់ថាមពល ការកែច្នៃសំណល់ថាមពល ការជំនួសមកវិញនូវថាមពលកកើតឡើងវិញ និងមធ្យោបាយនានានៃការអភិរក្សថាមពល ដែលបានកំណត់ដោយក្រសួងស្ថាប័នមានសមត្ថកិច្ច។

ធ- រាជានការសេដ្ឋកិច្ចពាក់ព័ន្ធដទៃទៀត ដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា៧៦០ .- សំណើសម្រាប់ក្រុមហ៊ុនឯកជនឬសាធារណៈ

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច អាចចេញលិខិតអនុញ្ញាតចំពោះសំណើរបស់ក្រុមហ៊ុនឯកជន ឬសាធារណៈដើម្បីរៀបចំហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្នែកបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ អាចតម្រូវឱ្យក្រុមហ៊ុនជាក់សំណើសុំដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ជាក់បញ្ចូលកស្តុតាងនិងឯកសារគាំទ្រដែលបញ្ជាក់ពីធនធាន និងស្ថានភាពហិរញ្ញវត្ថុ ការសិក្សាទីផ្សារ ការប្រើប្រាស់ផែនការកំណត់ប្រភពដោយនិរន្តរភាព ការបង្ហាញពីការចូលរួមគាគទានរបស់គម្រោងចំពោះការអភិវឌ្ឍប្រកបដោយចីរភាពដែលធន់នឹងការប្រែប្រួលអាកាសធាតុ និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់និងសមត្ថភាពក្នុងការផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ដែលកំពុងតែជំណើរការ។

៣- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវអនុវត្តតាមដំណើរការនៃកិច្ចលទ្ធកម្មដូចបានកំណត់នៅក្នុងគោលការណ៍ណែនាំនៃគោលនយោបាយពាក់ព័ន្ធនានាស្តីពីក្រុមហ៊ុនឯកជន ឬសាធារណៈ។

ជំពូកទី៤
ទិដ្ឋានហិរញ្ញវត្ថុ

មាត្រា៧៦១ .- ការបង់ថ្លៃរាល់ប្រភេទចំណូល

ការបង់ថ្លៃរាល់ប្រភេទចំណូលទាំងអស់ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះត្រូវបង់ចូលគណនីទោលតេនាគារ ឬធនាគារដៃគូតាមការអនុញ្ញាតពីក្រសួងស្តាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែមានការព្រមព្រៀងដោយឡែករវាងក្រសួងស្តាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្តាប័នមានសមត្ថកិច្ច។

មាត្រា៧៦២ .- ការបង់ថ្លៃលើសេវាកម្មប្រព័ន្ធអេកូឡូស៊ី

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំយន្តការកំណត់ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីទៅឱ្យបុគ្គល ដែលបានចូលរួមចំណែកក្នុងការត្រួតពិនិត្យ ការពារ ឬគ្រប់គ្រងសេវាកម្មប្រព័ន្ធអេកូឡូស៊ីដោយផ្អែកលើទិន្នន័យ និងស្ថិតិប្រសើរបំផុត ដែលស្វែងកេបានពាក់ព័ន្ធនឹងស្ថានភាព និងតម្លៃនៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីដែលបានវាយតម្លៃរួចរាល់។

មាត្រា៧៦៣ .- កិច្ចសហប្រតិបត្តិការរបស់ក្រសួងស្តាប័នមានសមត្ថកិច្ច

ក្រសួងស្តាប័នមានសមត្ថកិច្ចត្រូវគាំទ្រនិងសហការ ជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិដើម្បីរៀបចំអនុវត្តនិងគ្រប់គ្រងយន្តការ ដូចមានចែងក្នុងមាត្រា៧៦២(ការបង់ថ្លៃលើសេវាកម្មប្រព័ន្ធអេកូឡូស៊ី)នៃក្រមនេះ។

ភាគីភាគទី២
ប្រាក់កម្រៃ មូលនិធិ និងការគ្រប់គ្រងមូលនិធិបរិស្ថាននិងសង្គម
ជំពូកទី១
ប្រាក់កម្រៃ សួយសារ ឬបុព្វលាភបរិស្ថាន

មាត្រា៧៦៤ .- ការទទួលខុសត្រូវក្នុងការបង់ប្រាក់កម្រៃ សួយសារ ឬបុព្វលាភបរិស្ថាន

បុគ្គលត្រូវទទួលបន្ទុកក្នុងការបង់ប្រាក់កម្រៃ សួយសារ បុព្វលាភបរិស្ថាន ឬថ្លៃផ្សេងទៀតស្របតាមប្រកាសអន្តរក្រសួងរបស់ក្រសួងស្តាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា៧៦៥ .- ការរៀបចំប្រាក់កម្រៃ សួយសារ ឬបុព្វលាភបរិស្ថាន

ក្រសួងស្តាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬក្រសួងស្តាប័នមានសមត្ថកិច្ចត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់ពីចំនួន

បុគ្គលដែលមិនអនុវត្តតាមកថាខណ្ឌទី១នៃមាត្រា២៥២(កាតព្វកិច្ចរបស់ម្ចាស់សំណល់គ្រោះថ្នាក់)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី១០០ ០០០ ០០០ (មួយរយលាន)រៀល ទៅ៣០០ ០០០ ០០០(បីរយលាន)រៀល។

មាត្រា៨៤១ .- ការបញ្ចេញសំណល់គ្រោះថ្នាក់ដោយគ្មានលិខិតអនុញ្ញាត

បុគ្គលដែលមិនអនុវត្តតាមមាត្រា២៥៣(លិខិតអនុញ្ញាតបញ្ចេញសំណល់គ្រោះថ្នាក់)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី២០០ ០០០ ០០០(ពីរយលាន) រៀល ទៅ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៤៨៩

មាត្រា៨៤២ .- ការនាំចូលសំណល់គ្រោះថ្នាក់

បុគ្គលដែលនាំចូលសំណល់គ្រោះថ្នាក់ពីក្រៅប្រទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ដោយបំពានទៅនឹងបញ្ញត្តិនៃមាត្រា២៦៨(ការហាមឃាត់ការនាំចូលសំណល់គ្រោះថ្នាក់)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី១០០ ០០០ ០០០(មួយរយលាន)រៀល ដល់៥០០ ០០០ ០០០ (ប្រាំរយលាន)រៀល។

មាត្រា៨៤៣ .- ការមិនបំពេញកាតព្វកិច្ចរបស់ម្ចាស់ទីតាំងផលិតកម្ម អាជីវកម្ម និងសេវាកម្មដែលបង្កើតសំណល់គ្រោះថ្នាក់និងប្រតិបត្តិករសំណល់គ្រោះថ្នាក់

បុគ្គលដែលមិនបានបំពេញកាតព្វកិច្ច ដូចមានចែងក្នុងមាត្រា២៦៨(កាតព្វកិច្ចរបស់ម្ចាស់ទីតាំងផលិតកម្ម អាជីវកម្ម និងសេវាកម្មដែលបង្កើតសំណល់គ្រោះថ្នាក់និងប្រតិបត្តិករសំណល់គ្រោះថ្នាក់នៅក្នុងសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្ម)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០ ០០០ ០០០(ដប់លាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល។

មាត្រា៨៤៤ .- សកម្មភាពបង្កផលប៉ះពាល់ដល់បរិស្ថាន

បុគ្គលដែលធ្វើសកម្មភាពស្តុកទុក បញ្ចេញ ជុត កប់ បោះចោលសំណល់គ្រោះថ្នាក់ ហើយបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថាន សុខភាពសាធារណៈ ឬបង្កការខូចខាតទ្រព្យសម្បត្តិ ដូចមានចែងក្នុងមាត្រា២៧២(សកម្មភាពបង្កផលប៉ះពាល់)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល។

មាត្រា៨៤៥ .- ការមិនអនុវត្តកាតព្វកិច្ចក្នុងការគ្រប់គ្រងសំណល់រាវ និងទឹកកខ្វក់

បុគ្គលដែលមិនអនុវត្តការគ្រប់គ្រងសំណល់រាវ និងទឹកកខ្វក់របស់ខ្លួនមុនពេលបញ្ចេញចូលទៅក្នុងតំបន់ទឹកសាធារណៈតាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា២៨៧(ការទទួលខុសត្រូវរបស់ម្ចាស់ប្រភពជាក់លាក់)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០ (ដប់លាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ចំនួន២(ពីរ)ដង ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងអំឡុងពេល១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

មាត្រា៨៤៦ .- ការបញ្ចេញសំណល់ដោយមិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តិកម្មជាមុនឬមិនមានការអនុញ្ញាត

១-បុគ្គលដែលបញ្ចេញសំណល់រឹង រាវ ទឹកកខ្វក់ សំណល់ប្រេង សំណល់គីមីពីដីគោក ដែនកោះ ទីតាំងបូមប្រេង ឧបករណ៍នេសាទ ចូលទៅក្នុងសមុទ្រ ដោយមិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តិកម្មជាមុន ឬគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា២៩៨(ការហាមឃាត់ការបញ្ចេញសំណល់)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ១០០ ០០០ ០០០ (មួយរយលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ចំនួន២(ពីរ)ដង ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងអំឡុងពេល១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

២- បុគ្គលដែលបញ្ចេញសំណល់រឹង រាវ ទឹកកខ្វក់ សំណល់ប្រេង សំណល់គីមីពីដីគោក ដែនកោះ ទីតាំងបូមប្រេង ឧបករណ៍នេសាទ ចូលទៅក្នុងសមុទ្រ ដោយមិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តិកម្មជាមុន ឬគ្មានការអនុញ្ញាត ហើយបានបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថាន ជីវៈចម្រុះ ឬសុខភាពសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ

ពី១(មួយ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ៥០០ ០០០ ០០០ (ប្រាំរយលាន)រៀល ។

មាត្រា៨៤៧ ._ ការមិនទទួលខុសត្រូវរបស់ម្ចាស់ជលយាន

បុគ្គលដែលមិនអនុវត្តតាមកថាខណ្ឌទី៣នៃមាត្រា២៩៩(ការទទួលខុសត្រូវរបស់ម្ចាស់ជលយាន)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ចំនួន ២(ពីរ)ដង ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងអំឡុងពេល១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

មាត្រា៨៤៨ ._ ការមិនចាត់វិធានការនិងជូនដំណឹងពីករណីបង្កបញ្ហាបំពុលខ្យល់

បុគ្គលដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា៣១៧(ការចាត់វិធានការនិងជូនដំណឹងពីករណីបង្កបញ្ហាបំពុលខ្យល់)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០ ០០០ ០០០(ដប់លាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ចំនួន២(ពីរ)ដង ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងអំឡុងពេល១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

ជំពូកទី៣
បទល្មើសពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ

មាត្រា៨៤៩ ._ បទល្មើសធនធានធម្មជាតិថ្នាក់ទី១ក្នុងតំបន់ការពារធម្មជាតិ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០ (ដប់លាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល ចំពោះបុគ្គលដែលបានប្រព្រឹត្តអំពើណាមួយនៅក្នុងតំបន់ការពារធម្មជាតិ ដូចខាងក្រោម៖

ក- ការនាំចេញ ការនាំចូលគ្រាប់ពូជរុក្ខជាតិ ការបង្កាត់ពូជប្រភេទសត្ធ ប្រភេទរុក្ខជាតិរាតត្បាត ឬប្រភេទរុក្ខជាតិចំណូលថ្មីរាតត្បាត និងពូជមច្ចជាតិគ្រប់ប្រភេទ ដោយគ្មានការអនុញ្ញាត។

ខ- ធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចបង្ក ឱ្យមានភ្លើងឆេះព្រៃ ឬភ្លើងឆេះដីមមោក។

គ- ប្រើប្រាស់ឧបករណ៍នានា ដែលបង្ការរំខានដោយសំឡេង រំញ័រ រលក និងផ្សែងដែលអាចបង្ការខូចខាតដល់ធនធានធម្មជាតិ និងកិច្ចគាំពារបរិស្ថានក្នុងតំបន់ស្នូល និងតំបន់អកិរក្ស។

ឃ- ការរុករករ៉ែដោយគ្មានលិខិតអនុញ្ញាត។

មាត្រា៨៥០ ._ បទល្មើសធនធានធម្មជាតិថ្នាក់ទី២ក្នុងតំបន់ការពារធម្មជាតិ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី១០០ ០០០ ០០០ (មួយរយលាន)រៀល ទៅ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល ចំពោះបុគ្គលដែលប្រព្រឹត្តអំពើណាមួយនៅក្នុងតំបន់ការពារធម្មជាតិ ដូចខាងក្រោម៖

ក- បង្កើតឡគ្រប់ប្រភេទឬបង្កើតមូលដ្ឋានកែច្នៃផលនិងអនុផលព្រៃឈើ រុក្ខជាតិព្រៃ និងធនធានធម្មជាតិគ្រប់ប្រភេទក្នុងតំបន់ស្នូល និងតំបន់អកិរក្ស។

ខ- បង្កើតមូលដ្ឋានសម្រាប់កែច្នៃខ្លឹមចន្ទន៍ក្រស្នា ម្រះព្រៅភ្នំ ឬវល្លិរមៀត ឬសម្រាប់ចម្រាញ់រុក្ខជាតិ ហាមឃាត់ផ្សេងទៀតក្នុងតំបន់ស្នូល និងតំបន់អភិរក្ស។

គ- កាប់ ផ្តួល រំលំ គ្រៀវ ចងរឹត បំពុល ធ្វើឱ្យរបួស ធ្វើឱ្យខូចខាត គាស់រម្លើង រុករាន ឬបំផ្លាញព្រៃឈើ និងរុក្ខជាតិព្រៃ ដែលស្ថិតក្នុងចំណាត់ថ្នាក់ទី៥ និងទី៦ នៃចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃ ដោយគ្មានការអនុញ្ញាត។

ឃ- ចាប់ដោយដាក់អន្ទាក់ ខ្នារ អង្គប់ បន្តឹង លប់ បង្កៀ ឬដោយប្រមាញ់ដែលធ្វើឱ្យរបួស បំពុល សម្លាប់ ឬប្រមូលពង និងកូនសត្វព្រៃគ្រប់ប្រភេទ ដែលស្ថិតក្នុងចំណាត់ថ្នាក់ទី៥ និងទី៦ នៃចំណាត់ថ្នាក់ប្រភេទសត្វព្រៃ ដោយគ្មានការអនុញ្ញាត។

ង- ដឹកជញ្ជូន ប្រមូល ធ្វើសន្និធិ ឬប្រមូលសន្និធិផល និងអនុផលធនធានធម្មជាតិដោយគ្មានការអនុញ្ញាត។

ច- ប្រើប្រាស់អាវុធជាតិផ្ទុះ សារធាតុគីមី ថ្នាំពុល ឬឧបករណ៍ឆក់ ដែលធ្វើឱ្យខូចខាតឬបំពុលដល់ធនធានធម្មជាតិ។

ឆ- ជួញដូរសត្វព្រៃ ឬសំណាកសត្វព្រៃគ្រប់ប្រភេទ ឬចិញ្ចឹមសត្វព្រៃសម្រាប់ការធ្វើពាណិជ្ជកម្មដោយគ្មានការអនុញ្ញាត។

ជ- យាយី ឬបំផ្លាញជម្រកពង កូន កន្លែងបន្តពូជសត្វព្រៃ និងមច្ឆជាតិ។

ឈ- រែកិល ដកចេញ ឬបំផ្លាញគោលសីមា ឬសញ្ញាសម្គាល់ព្រំប្រទល់តំបន់ការពារធម្មជាតិ។

ញ- បំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។

ដ- ចាក់លុប ឬចាក់បំពេញដី ដែនទឹក ផ្ទៃរងទឹកភ្លៀង ផ្លូវទឹក បឹងធម្មជាតិ ដីសើម តំបន់ទំនាប ទឹកផុសក្រោមដី ឬអាងទឹក ដោយគ្មានការអនុញ្ញាត។

ឋ- ធ្វើឱ្យរាំងស្ទះដល់លំហូរបរិស្ថាននៃបឹងបួ ទន្លេ ស្ទឹង អូរ ឬព្រែក ដោយគ្មានការអនុញ្ញាត។

ឌ- បោះបង្គោលហ៊ុមព័ទ្ធ ឬដាក់សញ្ញាសម្គាល់លើដីដែលជាទ្រព្យសម្បត្តិរដ្ឋក្នុងតំបន់ការពារធម្មជាតិក្នុងគោលបំណងកាន់កាប់ដើម្បីយកដីធ្វើជាកម្មសិទ្ធិ។

ឍ- នេសាទដែលផ្ទុយនឹងបទប្បញ្ញត្តិនៃក្រមនេះ ដែលធ្វើឱ្យខូចខាតដល់ធនធានធម្មជាតិទាំងក្នុងដែនសមុទ្រ និងដែនទឹកសាប ព្រៃលិចទឹក ព្រៃកោងកាង ផ្កាថ្ម និងស្មៅសមុទ្រ ក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍មូលដ្ឋាន។

ណ- យកថ្ម ក្រួស ខ្សាច់ ឬរ៉ែ ឬការគាស់ ឈូសឆាយ ឬកកាយយកដី ដោយគ្មានការអនុញ្ញាត។

មាត្រា៨៥១ .- បទល្មើសធនធានធម្មជាតិថ្នាក់ទី៣ក្នុងតំបន់ការពារធម្មជាតិ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំ ទៅ១០(ដប់)ឆ្នាំ ចំពោះបុគ្គលដែលប្រព្រឹត្តអំពើណាមួយនៅក្នុងតំបន់ការពារធម្មជាតិ ដូចខាងក្រោម៖

ក- នាំចូល ឬនាំចេញនូវប្រភេទសត្វ ឬគ្រាប់រុក្ខជាតិគ្រប់ប្រភេទ ដែលជាសត្វ ឬរុក្ខជាតិដែលស្ថិតក្នុងចំណាត់ថ្នាក់ទី២ ដល់ទី៤ នៃចំណាត់ថ្នាក់ប្រភេទសត្វព្រៃ និងរុក្ខជាតិព្រៃ ដោយគ្មានការអនុញ្ញាត។

ខ- កាប់ ផ្តួល រំលំ គ្រៀវ ចងរឹត បំពុល ធ្វើឱ្យរបួស ធ្វើឱ្យខូចខាត គាស់រម្លើង រុករាន ឬបំផ្លាញព្រៃឈើ និងរុក្ខជាតិព្រៃ ដែលស្ថិតក្នុងចំណាត់ថ្នាក់ទី២ ដល់ទី៤ នៃចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃ។

គ- បង្កឱ្យមានភ្លើងឆេះព្រៃ ឬភ្លើងឆេះដីមមោកដោយចេតនា។

ឃ- នេសាទដែលផ្ទុយនឹងបទប្បញ្ញត្តិនៃក្រមនេះ ដែលធ្វើឱ្យខូចខាតដល់ធនធានធម្មជាតិ ទាំងក្នុងដែនសមុទ្រ និងដែនទឹកសាប ព្រៃលិចទឹក ព្រៃកោងកាង ផ្កាថ្ម និងស្មៅសមុទ្រ ក្នុងតំបន់ស្នូល និងតំបន់អភិរក្ស ។

ង- ចាប់ដោយដាក់អន្ទាក់ ខ្នារ អង្គប់ បន្ដឹង លប់ បង្កៃ ឬដោយប្រមាញ់ដែលធ្វើឱ្យរបួស បំពុល សម្លាប់ ឬប្រមូលពង និងកូនសត្វព្រៃគ្រប់ប្រភេទ តាមគ្រប់រូបភាព ដែលស្ថិតក្នុងចំណាត់ថ្នាក់ទី២ ដល់ទី៤ នៃចំណាត់ថ្នាក់ប្រភេទសត្វព្រៃ ដោយគ្មានការអនុញ្ញាត។

ច- កាប់គាស់ ឬកកាន់ដីព្រៃ ឬឆ្ការ ដុត ឬឈូសឆាយដីព្រៃ ដើម្បីយកដីធ្វើជាកម្មសិទ្ធិ។

មាត្រា៨៥២ .- ការធ្វើឱ្យខូចខាត បំផ្លិចបំផ្លាញ ឬស្រង់យកសម្បត្តិវប្បធម៌ក្រោមទឹកដោយចេតនា

បុគ្គលដែលបង្កការខូចខាត ការបំផ្លិចបំផ្លាញ ឬការស្រង់យកសម្បត្តិវប្បធម៌ក្រោមទឹកដោយចេតនា ដូចមានចែងនៅក្នុងមាត្រា៤២៧(ការហាមឃាត់ចំពោះការធ្វើឱ្យខូចខាត ការស្រង់យក ឬបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ក្រោមទឹក)នៃក្រមនេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល។

ជំពូកទី៤
បទល្មើសពាក់ព័ន្ធនឹងការខាយកម្លៃបរិស្ថាន

មាត្រា៨៥៣ .- ការប្រកបវិជ្ជាជីវៈរបស់ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលមិនបានចុះបញ្ជី

បុគ្គលដែលមិនអនុវត្តតាមកថាខណ្ឌទី១នៃមាត្រា៦៥៩(ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានជានីតិបុគ្គល ឬរូបវន្តបុគ្គល)នៃក្រមនេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០ ០០០ ០០០(ដប់លាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ចំនួន២(ពីរ)ដង ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងអំឡុងពេល ១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

មាត្រា៨៥៤ .- ការបំពានលក្ខខណ្ឌការងារដោយក្លែងបន្លំឬលួចចម្លងទិន្នន័យ

បុគ្គលដែលប្រគល់ឬផ្ដល់របាយការណ៍ ទិន្នន័យ ឬព័ត៌មានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬការវាយតម្លៃហានិភ័យក្នុងគោលបំណងបំភ័ន្ត ឬធ្វើឱ្យមានការយល់ខុសដល់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ៣០០ ០០០ ០០០(បីរយលាន)រៀល។

មាត្រា៨៥៥ .- ការធ្វើសកម្មភាពសាងសង់ឬប្រតិបត្តិការគម្រោងបំពានការហាមឃាត់

បុគ្គលដែលបានធ្វើសកម្មភាពសាងសង់ ឬប្រតិបត្តិការគម្រោងមុនពេលទទួលបានលិខិត ឬវិញ្ញាបនបត្រ ឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬកិច្ចសន្យាការពារបរិស្ថាន ដូចមានចែងក្នុងមាត្រា៦៦៨(ការហាមឃាត់ចំពោះសកម្មភាពសាងសង់ ឬប្រតិបត្តិការគម្រោង)នៃក្រមនេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០ ០០០ ០០០(ដប់លាន)រៀល ដល់១០០ ០០០ ០០០(មួយរយលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ចំនួន២(ពីរ)ដង ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងអំឡុងពេល១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្ដីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៤៩៣

ជំពូកទី៥

ស្ថានទម្ងន់ទោស ទោសបន្ថែមចំពោះរូបវន្តបុគ្គល ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល និងការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត

មាត្រា៨៥៦ .– ស្ថានទម្ងន់ទោស

អំពើដូចមានចែងក្នុងមាត្រា៨២៧(ការធ្វើសកម្មភាពឬប្រតិបត្តិការពាក់ព័ន្ធនឹងសព៌ាង្គកាយកែច្នៃរស់) កថាខណ្ឌទី២នៃមាត្រា៨៣៣(ការផលិត នាំចូល ឬចែកចាយសារធាតុគ្រោះថ្នាក់ឬផលិតផលសារធាតុគីមី) កថាខណ្ឌទី២នៃមាត្រា៨៣៥(ការបង្កឱ្យមានការសាយភាយសារធាតុគ្រោះថ្នាក់) មាត្រា៨៣៩(ការនាំចូលសំណល់រឹង) មាត្រា៨៤១(ការបញ្ចេញសំណល់គ្រោះថ្នាក់ដោយគ្មានលិខិតអនុញ្ញាត) មាត្រា៨៤២(ការនាំចូលសំណល់គ្រោះថ្នាក់) មាត្រា៨៤៤(សកម្មភាពបង្កផលប៉ះពាល់ដល់បរិស្ថាន) កថាខណ្ឌទី២នៃមាត្រា៨៤៦(ការបញ្ចេញសំណល់ដោយមិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តិកម្មជាមុនឬមិនមានការអនុញ្ញាត)នៃក្រមនេះ ត្រូវផ្តន្ទាទោសដោយមានស្ថានទម្ងន់ទោសក្នុងករណីដូចខាងក្រោម៖

ក- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំ ទៅ១០(ដប់)ឆ្នាំ ក្នុងករណីដែលអំពើណាមួយដូចមានចែងខាងលើ បណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់បរិស្ថាន ជីវៈចម្រុះ សុខភាពមនុស្ស ឬធ្វើឱ្យមានពិការភាពអចិន្ត្រៃយ៍ដល់បុគ្គលដទៃ។

ខ- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ)ឆ្នាំ ទៅ១៥(ដប់ប្រាំ)ឆ្នាំ ក្នុងករណីដែលអំពើណាមួយដូចមានចែងខាងលើ បណ្តាលឱ្យបុគ្គលដទៃស្លាប់ដោយគ្មានចេតនាសម្លាប់។

គ- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥(ដប់ប្រាំ)ឆ្នាំ ទៅ៣០(សាមសិប)ឆ្នាំ ក្នុងករណីដែលអំពើណាមួយដូចមានចែងខាងលើ បណ្តាលឱ្យស្លាប់មនុស្សច្រើននាក់ ឬក្នុងករណីដែលអំពើខាងលើត្រូវបានប្រព្រឹត្តក្នុងគោលបំណងបង្កឱ្យមានការខូចខាតធ្ងន់ធ្ងរដល់បរិស្ថាន ជីវៈចម្រុះ សុខភាព ឬអាយុជីវិតអ្នកដទៃ ឬត្រូវបានធ្វើឡើងដោយក្រុមឧក្រិដ្ឋជនមានការចាត់តាំង។

មាត្រា៨៥៧ .– ការប្រកាសទោសបន្ថែមចំពោះរូបវន្តបុគ្គល

១- ចំពោះរូបវន្តបុគ្គលដែលប្រព្រឹត្តបទល្មើសដែលមានចែងចាប់ពីមាត្រា៨២៧(ការធ្វើសកម្មភាពឬប្រតិបត្តិការពាក់ព័ន្ធនឹងសព៌ាង្គកាយកែច្នៃរស់) ដល់មាត្រា៨៥៥(ការធ្វើសកម្មភាពសាងសង់ឬប្រតិបត្តិការគម្រោងបំពានការហាមឃាត់)នៃក្រមនេះ តុលាការអាចប្រកាសទោសបន្ថែមមួយឬច្រើន ដូចមានចែងក្នុងមាត្រា៥៣(ប្រភេទទោសបន្ថែម)នៃក្រមព្រហ្មទណ្ឌ។

២- ខ្លឹមសារ បែបបទ និងនីតិវិធីសម្រាប់ការអនុវត្តទោសបន្ថែមទាំងនេះត្រូវអនុលោមតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។

មាត្រា៨៥៨ .– ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៨២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងចាប់ពីមាត្រា៨២៧(ការធ្វើសកម្មភាពឬប្រតិបត្តិការពាក់ព័ន្ធនឹងសព៌ាង្គកាយកែច្នៃរស់) ដល់មាត្រា៨៥៥(ការធ្វើសកម្មភាពសាងសង់ឬប្រតិបត្តិការគម្រោងបំពានការហាមឃាត់)នៃក្រមនេះ។ នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១ ០០០ ០០០ ០០០(មួយពាន់លាន)រៀល ទៅ២ ០០០ ០០០ ០០០(ពីរពាន់លាន)រៀល និងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។

ទំព័រ៤៩៤ អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

មាត្រា៨៥៩ .- ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត

ការអនុវត្តបញ្ញត្តិនៃគន្លឹទី១០នៃក្រមនេះ មិនរារាំងដល់ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត ក្នុងករណីដែលអំពើដែលកំណត់ថាជាបទល្មើសដែលមានចែងក្នុងក្រមនេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត និងដោយពុំទាន់គិតដល់សំណងនៃការខូចខាតដទៃទៀត។

គន្លឹទី១១
អន្តរប្បញ្ញត្តិ

មាត្រា៨៦០ .- វិធានការអន្តរកាលចំពោះគម្រោងដែលបានដាក់ពាក្យសុំនៅមុនកាលបរិច្ឆេទនៃការអនុវត្តក្រមនេះ

ចំពោះគម្រោងដែលបានដាក់ពាក្យសុំនៅមុនកាលបរិច្ឆេទនៃការអនុវត្តក្រមនេះ ត្រូវចាត់ទុកថាបានដាក់ពាក្យសុំនិងត្រូវបន្តនីតិវិធីដែលនៅសេសសល់ទៅតាមបទប្បញ្ញត្តិនៃក្រមនេះ។

មាត្រា៨៦១ .- វិធានការអន្តរកាលចំពោះគម្រោងដែលបានអនុវត្តមុនកាលបរិច្ឆេទនៃការអនុវត្តក្រមនេះ

ចំពោះគម្រោងដែលបានអនុវត្តនៅមុនកាលបរិច្ឆេទនៃការអនុវត្តក្រមនេះ ត្រូវបន្តមានសុពលភាពបន្ទាប់ពីកាលបរិច្ឆេទនៃការអនុវត្តក្រមនេះ។

មាត្រា៨៦២ .- វិធានការអន្តរកាលចំពោះបទប្បញ្ញត្តិដែលទាក់ទងនឹងស្តង់ដារបរិស្ថាន

បទប្បញ្ញត្តិដែលទាក់ទងនឹងស្តង់ដារបរិស្ថាន ដែលមានជាធរមានកន្លងមកនៅតែបន្តមានអានុភាពអនុវត្តរហូតដល់មានបទប្បញ្ញត្តិដែលទាក់ទងនឹងស្តង់ដារបរិស្ថានថ្មី លើកលែងតែមានបញ្ញត្តិផ្សេងនៅក្នុងក្រមនេះ។

គន្លឹទី១២
អវសានប្បញ្ញត្តិ

មាត្រា៨៦៣ .- អានុភាពនៃបទប្បញ្ញត្តិច្បាប់

លិខិតបទដ្ឋានគតិយុត្តទាំងឡាយក្រោមច្បាប់ក្នុងវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវមានអានុភាពអនុវត្តរហូតមានបទដ្ឋានថ្មីមកជំនួស លើកលែងតែបទប្បញ្ញត្តិណាដែលផ្ទុយនឹងក្រមនេះ។

មាត្រា៨៦៤ .- និរាករណ៍

១- ត្រូវចាត់បង់អានុភាពចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត ចំពោះច្បាប់និងបទប្បញ្ញត្តិពីមុនពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិ ដែលបានកំណត់ដូចខាងក្រោម៖

ក- ច្បាប់ស្តីពីកិច្ចគាំពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស.រកម.១២៩៦.៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦។

ខ- ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨។

គ- ច្បាប់ស្តីពីជីវសុវត្ថិភាព ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០៨/០០៦ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨។

២- បទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀតដែលមានអានុភាពនៅពេលក្រមនេះ ត្រូវបានអនុវត្តហើយផ្ទុយនឹងអនុប្បញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកថាគ្មានអានុភាពត្រឹមទំហំដែលផ្ទុយនឹងក្រមនេះ ចាប់ពីថ្ងៃដែលក្រមនេះត្រូវបាន

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៤៩៥

៣- ប៉ុន្តែ បទប្បញ្ញត្តិដែលកំណត់អំពីបទល្មើសបរិស្ថាននិងធនធានធម្មជាតិក្នុងកថាខណ្ឌទី១និងទី២ ខាងលើនេះ ត្រូវបន្តមានអានុភាពអនុវត្តក្រោយការអនុវត្តនៃក្រមនេះ ចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តមុនពេលក្រមនេះត្រូវបានអនុវត្ត។

៤- រាល់បទប្បញ្ញត្តិនៃក្រមនេះត្រូវយកមកអនុវត្ត កាលណាពុំមានវិធានដោយឡែកចែងដោយច្បាប់ពិសេស។

មាត្រា៨៦៥ .- ការអនុវត្តក្រម

ក្រមនេះត្រូវយកទៅអនុវត្តក្នុងរយៈពេល១(មួយ)ឆ្នាំ ក្រោយការចូលជាធរមាននៃក្រមនេះ។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០២៣

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមទ្រង់ព្រះមេត្តាប្រោសព្រះរាជទានព្រះបរមរាជានុញ្ញាតប្រកាសឱ្យប្រើ
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សាយ សំអាល់

បានឯកភាពត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

ឧបសម្ព័ន្ធនៃក្រមបរិស្ថាននិងធនធានធម្មជាតិ
សទ្ទានុក្រម

ក

ការកសាងសមត្ថភាព (Capacity Building)

សំដៅដល់ការអនុវត្តក្នុងការពង្រឹងភាពខ្លាំង លក្ខណៈសម្បត្តិ និងធនធានដែលមានចំពោះបុគ្គលម្នាក់ៗ សហគមន៍ ស្ថាប័ន ឬសង្គមដើម្បីឆ្លើយតបទៅនឹងការប្រែប្រួល។

ការការពារសុវត្ថិភាពនុយក្លេអែរ (Nuclear Safeguard)

សំដៅដល់ប្រព័ន្ធនៃការធ្វើអធិការកិច្ច ដើម្បីផ្ទៀងផ្ទាត់ថាសារធាតុនុយក្លេអែររួមទាំងបច្ចេកវិទ្យា សកម្មភាព ឧបករណ៍ សម្ភារៈ និងបរិក្ខារពាក់ព័ន្ធត្រូវបានប្រើប្រាស់ក្នុងគោលបំណងសន្តិភាពតែប៉ុណ្ណោះ។

ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (Greenhouse Gas Mitigation)

សំដៅដល់អន្តរាគមន៍របស់មនុស្ស ដើម្បីឱ្យប្រភពបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថយចុះ ឬដើម្បីបង្កើនអាងស្រូបឧស្ម័នផ្ទះកញ្ចក់។

ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (Disaster Risk Reduction)

សំដៅដល់ការចង្អុលបង្ហាញនូវគោលដៅនិងគោលបំណងផ្នែកគោលនយោបាយ វិធានការជាយុទ្ធសាស្ត្រ និងឧបករណ៍នានា ដែលបានប្រើប្រាស់ដើម្បីប៉ាន់ប្រមាណហានិភ័យគ្រោះមហន្តរាយនាពេលអនាគតដោយការកាត់បន្ថយការប្រឈមមុខសញ្ញាគ្រោះថ្នាក់ ឬភាពងាយរងគ្រោះ ដែលកំពុងកើតមាននិងដោយការបង្កើនភាពធន់ទៅនឹងហានិភ័យទាំងនោះ។

ការកៀរគរធនធាន (Resources Mobilization)

សំដៅដល់ការប្រមូលធនធានហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុ ដើម្បីសម្រេចគោលដៅនិងគោលបំណងរបស់ស្ថាប័ន/អង្គភាព។ ធនធានហិរញ្ញវត្ថុរួមមានប្រាក់ ចំណែកធនធានមិនមែនហិរញ្ញវត្ថុរួមមាន សម្ភារៈរូបវន្ត ធនធានមនុស្ស និងពេលវេលាដែលផ្តល់ជូន។

ការកែច្នៃសព៌ាង្គកាយរស់/ការកែច្នៃហ្សែន(Genetic Modification)

សំដៅដល់បច្ចេកទេសក្នុងការផ្លាស់ប្តូរលក្ខណៈធម្មជាតិរបស់សត្ច រុក្ខជាតិ ឬមីក្រូសព៌ាង្គកាយដោយបញ្ចូលចំណែកណាមួយនៃសម្ភារពន្ធុ (ឌី អឹន អេ) ពីសព៌ាង្គកាយមួយទៅសព៌ាង្គកាយមួយទៀត។

ការកែច្នៃឡើងវិញ/សាវដ្តកម្ម (Recycling)

សំដៅដល់សកម្មភាព ដំណើរការបំបែក ឬការបំប្លែងសំរាម សំណល់រឹងទៅជាវត្ថុធាតុដើមសម្រាប់បម្រើការផលិតឡើងវិញ។

ការខូចខាតបរិស្ថាន (Environmental Degradation)

សំដៅដល់ផលប៉ះពាល់អវិជ្ជមានលើបរិស្ថានរួមមាន ការធ្វើឱ្យអន់ថយ ការបំផ្លិចបំផ្លាញ ការបាត់បង់ ឬការបាត់បង់នៃការប្រើប្រាស់សមាសភាគរបស់បរិស្ថានដូចជាធនធានធម្មជាតិ បេតិកភណ្ឌវប្បធម៌ជាដើម និងផលប៉ះពាល់អវិជ្ជមានលើសុខភាព និងសុខុមាលភាពរបស់មនុស្ស ដូចជាការបាត់បង់ប្រាក់ឈ្នូល ប្រាក់ចំណូល ប្រាក់ចំណេញពន្ធ ប្រាក់កម្រៃ ចំណូលសួយសារនានារបស់ជាតិជាដើម។

ការខូចខាតបរិស្ថានធ្ងន់ធ្ងរ (Severe Environmental Degradation)

សំដៅដល់វិសាលភាពនៃការធ្វើឱ្យអន់ថយ ការបំផ្លិចបំផ្លាញ ការបាត់បង់ ឬ ការថយចុះនូវគុណភាព ឬមុខងារ បរិស្ថាន ដូចជា ទឹក ដី ខ្យល់ ធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី និងបេតិកភណ្ឌវប្បធម៌ ក៏ដូចជា ផលប៉ះពាល់

អវិជ្ជមានលើសុខភាពមនុស្ស សេដ្ឋកិច្ចនិងសង្គម ដូចជាការបាត់បង់ប្រាក់ឈ្នួល ប្រាក់ចំណូល ប្រាក់ចំណេញពន្ធ ប្រាក់កម្រៃ ចំណូលសួយសារនានារបស់ជាតិជាដើម។

ការគ្រប់គ្រងហិរញ្ញវត្ថុ (Financial Management)

សំដៅដល់ការរៀបចំផែនការថវិកា ការត្រួតពិនិត្យនិងតម្រង់ទិសសកម្មភាពហិរញ្ញវត្ថុ ដូចជាការត្រួតពិនិត្យប្រព័ន្ធគណនេយ្យ លទ្ធកម្ម ប្រាក់កម្ចី ជាដើម និងការចាត់ចែងនិងសម្រេចលើការប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់ស្ថាប័ន/អង្គភាព។

ការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព (Sustainably Forest Resources Management/Sustainable Forest Management)

សំដៅដល់ការគ្រប់គ្រងធនធានព្រៃឈើស្របតាមគោលបំណង គោលការណ៍ណែនាំ និងបទដ្ឋានបច្ចេកទេស ដើម្បីផលប្រយោជន៍សេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន រួមទាំងការអភិរក្សជីវៈចម្រុះ។

ការគ្រប់គ្រងព្រៃឈើ (Forest Management)

សំដៅដល់ប្រព័ន្ធមួយនៃការប្រតិបត្តិសម្រាប់ការកាន់កាប់ និងប្រើប្រាស់ដីព្រៃឈើក្នុងបំណងបំពេញមុខងារអេកូឡូស៊ី (រួមទាំងនានាកាពដីវាលស្រែ) សេដ្ឋកិច្ច និងសង្គមរបស់ព្រៃឈើប្រកបដោយចីរភាព។

ការគ្រប់គ្រងធនធានជីវៈចម្រុះ (Biodiversity Resources Management)

សំដៅដល់សកម្មភាពថែរក្សា និងការពារនានាកាពនៃសព៌ាង្គកាយរស់នៅលើដី ក្នុងទឹក និងក្នុងប្រព័ន្ធអេកូឡូស៊ីផ្សេងៗទៀត ដែលមាននានាកាពសេនេទិក នានាកាពប្រភេទ និងនានាកាពប្រព័ន្ធអេកូឡូស៊ី។

ការគណនាបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់/កូតានៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (Emission quota)

សំដៅដល់បរិមាណឬចំណែកនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបដែលកំណត់ឱ្យប្រទេស ឬបណ្តាក្រុមប្រទេសអាចបញ្ចេញឧស្ម័ននៅក្រោមក្របខ័ណ្ឌនៃការបញ្ចេញឧស្ម័នសរុបជាអតិបរមា និងទៅតាមការកំណត់ធនធានកាតព្វកិច្ច។

ការអប់រំបរិស្ថាន (Environmental Education)

សំដៅដល់ការអនុវត្តវិធីសាស្ត្រ ដើម្បីអប់រំប្រជាជនឱ្យយល់ដឹងពីទំនាក់ទំនងផ្នែកសីលធម៌របស់ពួកគេជាមួយនឹងបរិស្ថាន លើកកម្ពស់នូវចំណេះដឹង ជំនាញ អាកប្បកិរិយា និងតម្លៃរបស់ប្រជាជនក្នុងកិច្ចគាំពារបរិស្ថាន ព្រមទាំងដើម្បីលើកទឹកចិត្តពួកគេឱ្យចូលរួមក្នុងវិស័យនេះ។

ការអប់រំបរិស្ថានក្នុងប្រព័ន្ធ (Formal Environmental Education)

សំដៅដល់ការអប់រំបរិស្ថាន ដែលមានរចនាសម្ព័ន្ធតាមឋានានុក្រមនៃប្រព័ន្ធអប់រំ ចាប់ពីបឋមសិក្សារហូតដល់ឧត្តមសិក្សា ដោយរួមទាំងការសិក្សាជំនាញឯកទេសទូទៅ កម្មវិធីជំនាញវិជ្ជាជីវៈ និងវិទ្យាស្ថានឯកទេសផ្សេងៗដែលមានការបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងជំនាញវិជ្ជាជីវៈពេញម៉ោង។

ការអប់រំបរិស្ថានក្រៅប្រព័ន្ធ (Informal Environmental Education)

សំដៅដល់សកម្មភាពអប់រំបរិស្ថានទាំងឡាយ ដែលរៀបចំឡើងផ្សេងពីការអប់រំក្នុងប្រព័ន្ធ ទាំងមាននិងគ្មានកម្រិតក្នុងលក្ខណៈធំទូលាយបែបណាក៏ដោយ ដើម្បីជូនក្រុមគោលដៅនានាដែលមកសិក្សាក្នុងកម្មវិធីអប់រំបរិស្ថាន។

ការរយៈបរិច្ឆេទជលសាស្ត្រ (Hydrological Period)

សំដៅដល់ការកំណត់រយៈពេលនៃប្រតិបត្តិការខាងហិរញ្ញវត្ថុ ដែលមានក្នុងផែនការស្តីពីធនធានទឹកអាងទន្លេ ឬផែនការស្តីពីសិទ្ធិប្រើប្រាស់ទឹក និងលិខិតបទដ្ឋានគតិយុត្ត។

ការចិញ្ចឹមសត្វព្រៃ (Wildlife Farm/ Wildlife Raising/ Wildlife Breeding)

សំដៅដល់ការការពារទុកសត្វព្រៃក្នុងទីបង្ខាំង ដោយការថែទាំ និងផ្តល់ចំណី ក្នុងគោលបំណងផ្សេងៗ ដូចជាសម្រាប់ផ្គាត់ពូជ ការលក់ដូរ ជាដើម។

ការប្រើប្រាស់ជាលក្ខណៈប្រពៃណី (Customary Uses)

សំដៅដល់ការអនុវត្ត ឬរបៀបអនុវត្តលើការប្រើប្រាស់ធនធានធម្មជាតិសម្រាប់ចិញ្ចឹមគ្រួសារ ឬផលប្រយោជន៍សហគមន៍តាមទំនៀមទម្លាប់ ឬប្រពៃណី។

ការប្រើប្រាស់ប្រកបដោយនិរន្តរភាព (Sustainable Consumption/ Sustainable Uses)

សំដៅដល់ការប្រើប្រាស់ធនធានធម្មជាតិ ដោយការថែរក្សាបាននូវបរិមាណ ប្រភេទ និង/ឬពូជនៃធនធានធម្មជាតិឬធនធានជីវៈចម្រុះ ដើម្បីបម្រើប្រយោជន៍ដល់អ្នកជំនាន់ក្រោយ។

ការប្រើប្រាស់ក្នុងព្រំដែនកំណត់(សកាំង្គកាយកែច្នៃរស់) (Contained Uses)

សំដៅដល់ប្រតិបត្តិការ ឬសកម្មភាពណាមួយដែលទាក់ទងនឹងសកាំង្គកាយកែច្នៃរស់ដែលធ្វើឡើងនៅក្នុងទីកន្លែង ឬមធ្យោបាយ ឬឧបករណ៍ណាមួយ ហើយស្ថិតនៅក្រោមវិធានការជាក់លាក់ដែលទប់ស្កាត់មិនឱ្យសកាំង្គកាយកែច្នៃរស់ទាំងនោះប៉ះពាល់ដល់បរិស្ថានខាងក្រៅ។

ការដាំព្រៃឈើ (Afforestation)

សំដៅដល់ការដាំដើមឈើដើម្បីបង្កើតព្រៃឈើនៅលើផ្ទៃដី ដែលមានប្រវត្តិគ្មានដើមឈើពីមុន(រយៈពេលយ៉ាងហោចណាស់៥០ឆ្នាំ)។

ការបរបាញ់សត្វព្រៃ (Wildlife Hunting/Wildlife Poaching)

សំដៅដល់សកម្មភាពទាំងឡាយណាដែលតាមកេ តាមចាប់ យាយី បំផ្លិចបំផ្លាញឬសម្លាប់សត្វព្រៃ ដោយការប្រើប្រាស់មធ្យោបាយគ្រប់ប្រភេទ។

ការអភិរក្សសត្វព្រៃ (Wildlife Conservation)

សំដៅដល់ការរៀបចំផែនការ ចាត់ចែង តម្រង់ទិស ត្រួតពិនិត្យ តាមដាន និងស្រាវជ្រាវសត្វព្រៃ ក្នុងតំបន់និងក្រៅតំបន់ក្នុងគោលបំណងទប់ស្កាត់ការផុតពូជ ដោយស្តារចំនួនសត្វ ប្រភេទសត្វ និងការបង្កាត់ពូជសត្វព្រៃ។

ការប្រើប្រាស់ជាលក្ខណៈគ្រួសារ (Family Uses)

សំដៅដល់ការបរបាញ់ ការនេសាទ ការប្រមូលរុក្ខជាតិព្រៃ និងអនុផលព្រៃឈើផ្សេងទៀត និងការដោះដូរទំនិញជាលក្ខណៈប្រពៃណី សម្រាប់គោលបំណងផ្តល់ស្បៀងអាហារដល់បុគ្គលម្នាក់ ឬគ្រួសាររបស់គេ នៅក្នុងកម្រិតអប្បបរមាដែលចាំបាច់សម្រាប់តែការរស់រានមានជីវិត និងមិនរាប់បញ្ចូលការលក់ ឬការធ្វើពាណិជ្ជកម្មនៃសំណាកប្រភេទសត្វឬរុក្ខជាតិនានា ដែលបរបាញ់ នេសាទ ឬប្រមូលបានឡើយ។

ការស្តារប្រព័ន្ធអេកូឡូស៊ី (Ecosystem Restoration)

សំដៅដល់ការធ្វើឱ្យប្រសើរឡើងវិញនូវបណ្តុំមុខងារនៃប្រព័ន្ធមួយដែលរួមផ្សំឡើងដោយភាវៈមានជីវិត និងបរិស្ថានគ្មានជីវិតដែលនៅជុំវិញភាវៈមានជីវិតទាំងនោះ ព្រមទាំងអន្តរកម្មទៅវិញទៅមក(អន្តរកម្មរវាងភាវៈមានជីវិត និងបរិស្ថានគ្មានជីវិត និងអន្តរកម្មរវាងភាវៈមានជីវិតទាំងនោះ)។

ការខូចខាតប្រព័ន្ធអេកូឡូស៊ី (Ecosystem Degradation)

សំដៅដល់ផលប៉ះពាល់អវិជ្ជមានទៅលើបណ្តុំមុខងារនៃប្រព័ន្ធមួយដែលរួមផ្សំឡើងដោយភាវៈមានជីវិត និងបរិស្ថានគ្មានជីវិតដែលនៅជុំវិញភាវៈមានជីវិតទាំងនោះ ព្រមទាំងអន្តរកម្មទៅវិញទៅមក(អន្តរកម្មរវាងភាវៈមានជីវិត និងបរិស្ថានគ្មានជីវិត និងអន្តរកម្មរវាងភាវៈមានជីវិតទាំងនោះ)។

ការប្រើប្រាស់និងផលិតកម្មប្រកបដោយនិរន្តភាព (Sustainable Production and Consumption)

សំដៅដល់ការប្រើប្រាស់សេវានិងផលិតផលពាក់ព័ន្ធនានា ដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការដោមូលដ្ឋាន និងនាំមកនូវគុណភាពជីវិតដ៏ប្រសើរ ដោយធ្វើការកាត់បន្ថយនូវការប្រើប្រាស់ធនធានធម្មជាតិនិងសារធាតុពុល ព្រមទាំងការបញ្ចេញសំណល់ និងសារធាតុបំពុលនានាឱ្យនៅកម្រិតអប្បបរមា នៅក្នុងវដ្តជីវិតនៃសេវាឬផលិតផល ដើម្បីកុំឱ្យបង្កហានិភ័យដល់តម្រូវការរបស់មនុស្សជំនាន់ក្រោយ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៤៩៩

ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ (Strategic Environmental Assessment)

សំដៅដល់អភិក្រមដែលមានការវិភាគនិងការចូលរួម ក្នុងគោលបំណងរួមបញ្ចូលការពិនិត្យពិចារណ្យផ្នែកសេដ្ឋកិច្ច សង្គម បរិស្ថាន និងវប្បធម៌ទៅក្នុងគោលនយោបាយ ផែនការ និងកម្មវិធីផ្សេងៗ។

ការគ្រប់គ្រងសំណល់គ្រោះថ្នាក់ (Hazardous Waste Management)

សំដៅដល់សកម្មភាពទាំងឡាយណាដែលធ្វើដើម្បីការពារ កាត់បន្ថយ ញែក ប្រមូល ដឹកជញ្ជូន ស្តុកទុក ធ្វើប្រព្រឹត្តិកម្ម កែច្នៃ ទាញយកមកប្រើឡើងវិញ និងបោះចោលសំណល់គ្រោះថ្នាក់។

ការចូលរួមជាសាធារណៈ (Public Participation)

សំដៅដល់ការផ្សព្វផ្សាយ ការពិគ្រោះយោបល់ កិច្ចសហការ ការចូលរួម និងការសម្រេចចិត្តនៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីធ្វើការផ្លាស់ប្តូរគំនិត មតិយោបល់ ការទទួលយកព័ត៌មានពីគ្រប់ភាគីដែលនឹងទទួលរងហេតុប៉ះពាល់ដោយផ្ទាល់និងដោយប្រយោល និងរកវិធានការកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានពីគម្រោងអភិវឌ្ឍនៅក្នុងដំណាក់កាលមុនប្រតិបត្តិគម្រោង(ការរចនាគម្រោងនិងការសាងសង់) ដំណាក់កាលប្រតិបត្តិគម្រោង និងដំណាក់កាលបញ្ចប់គម្រោង។

ការញែកសំណល់ (Waste Sorting)

សំដៅដល់សកម្មភាពបែងចែកសំណល់ទៅតាមប្រភេទនៅនឹងប្រភពបង្កើតសំណល់ ទីកន្លែងចោលសំណល់ឬនៅតាមទីតាំងកែច្នៃ ឬទាញយកធនធានពីសំណល់។

ការប្រើប្រាស់មានលក្ខណៈវិស្វកម្មពាណិជ្ជកម្ម (Commercial Uses)

សំដៅដល់ការប្រើប្រាស់ធនធានដីរៈចម្រុះ ឬធនធានធម្មជាតិក្នុងគោលបំណងទទួលបានប្រាក់ចំណេញផលប្រយោជន៍សេដ្ឋកិច្ច ឬការជួញដូរបែបពាណិជ្ជកម្ម។

ការដុតសំណល់នៅតាមទីវាល (Open burning)

សំដៅដល់ការដុតសំណល់ កម្ទេចកម្ទី ឬវត្ថុផ្សេងៗ នៅតាមទីវាល ទីសាធារណៈ ឬក្នុងបរិវេណដីកម្មសិទ្ធិរួមទាំងការដុតនៅក្នុងឡដែលមិនមានបំពាក់ឧបករណ៍បញ្ចេញផ្សែងឬកាត់បន្ថយសារធាតុបំពុលខ្យល់។

ការទាញយកធនធានពីសំណល់ (Extracting Fesources from Waste)

សំដៅដល់សកម្មភាពជ្រើសរើសឬប្រើប្រាស់សំណល់ឱ្យក្លាយទៅជារបស់ វត្ថុធាតុ ឬផលិតផលដែលមានតម្លៃសម្រាប់ការប្រើប្រាស់ឡើងវិញឬការផលិតជាថ្មី ក្នុងគោលបំណងកាត់បន្ថយបរិមាណសំណល់ដែលបង្កើតឡើងឬដែលត្រូវបោះចោល ឬបញ្ចេញចោលទៅក្នុងបរិស្ថាន។

ការបញ្ចេញសំណល់ (Waste Disposal /Waste Discharge)

សំដៅដល់សកម្មភាពឬដំណើរការបង្ហូរចេញ បំភាយចេញ ឬដឹកចេញនូវសំណល់ពីប្រភព ឬទីតាំងបង្កើតសំណល់ចូលទៅក្នុងបរិស្ថាន ឬទៅកាន់ទីតាំងដទៃក្នុងគោលបំណងណាមួយ។

ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (Green House Gas Emission)

សំដៅដល់ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និង/ឬបុរេការ និងអេរ៉ូសូលទៅក្នុងបរិយាកាសនៅក្នុងតំបន់ណាមួយនិងក្នុងកំលុងពេលកំណត់មួយ។

ការប្រែប្រួលអាកាសធាតុ (Climate Change)

សំដៅដល់ការប្រែប្រួលស្ថានភាពអាកាសធាតុ ដែលអាចកំណត់អត្តសញ្ញាណបាន(តាមរយៈការវិភាគស្ថិតិ) តាមរយៈការប្រែប្រួលតួលេខមធ្យមនិងតួលេខថេរនៃអាកាសធាតុ ហើយការប្រែប្រួលនោះបន្តកើតឡើងក្នុងរយៈពេលវែងជាច្រើនទស្សវត្សរ៍ឬយូរជាងនេះ។

ការផ្ទេរបច្ចេកវិទ្យា (Technology Transfer)

សំដៅដល់ការផ្លាស់ប្តូរចំណេះដឹងផ្នែកវឹង និងទន់ រូបិយវត្ថុ និងទំនិញក្នុងចំណោមភាគីពាក់ព័ន្ធ ដែលនាំឱ្យមានការកែសាយបច្ចេកវិទ្យាសម្រាប់បន្សាំឬការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និង/ឬការផ្សព្វផ្សាយបច្ចេកវិទ្យា និងកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកវិទ្យាទាំងក្នុងនិងក្រៅប្រទេស។

ការផ្ទៀងផ្ទាត់ (Verification)

សំដៅដល់ការវាយតម្លៃជាទៀងទាត់ដោយស្ថាប័នឯករាជ្យនៅមុន និងបន្ទាប់ពីការកំណត់របស់អង្គភាពទទួលបន្ទុកប្រតិបត្តិលើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីសកម្មភាពមនុស្ស ដែលបានតាមដានសម្រាប់ប្រភពឧស្ម័នផ្ទះកញ្ចក់ដែលកើតឡើងជាលទ្ធផលនៃសកម្មភាព គម្រោងយន្តការអភិវឌ្ឍស្អាត ដែលបានចុះបញ្ជីឬសកម្មភាពតាមកម្មវិធី(ក្រៅពីគម្រោងព្រៃឈើ)។

ការស្តារព្រៃឡើងវិញ (Reforestation)

សំដៅដល់ការដាំដើមឈើនៅលើដីដែលពីមុនធ្លាប់មានព្រៃ ប៉ុន្តែត្រូវបានប្រែក្លាយសម្រាប់គោលបំណងផ្សេងទៀត។

ការវាស់វែង ការរាយការណ៍ និងការផ្ទៀងផ្ទាត់ (Measurement, Reporting and Verification)

សំដៅដល់វិធានបច្ចេកទេសមួយដើម្បីបញ្ជាក់ពីការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ជាសត្យានុម័ត ហើយអាចប្រើប្រាស់ដើម្បីកំណត់ហិរញ្ញវត្ថុអាកាសធាតុ។

ការបង់ថ្លៃបំពុលបរិស្ថាន (Payment for Environmental Pollution)

សំដៅដល់វិធានការហិរញ្ញវត្ថុសម្រាប់ជួយកាត់បន្ថយការបំពុលបរិស្ថាន តាមរយៈការតម្រូវឱ្យបង់ថ្លៃចូលថវិការដ្ឋទៅលើការបញ្ចេញបន្ទុកសារធាតុបំពុលពីទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ចូលទៅក្នុងបរិស្ថាន។

ការបំពុលបរិស្ថាន (Environmental Pollution)

សំដៅដល់ការធ្លាក់ចូលនូវសារធាតុបំពុលពីសកម្មភាពរបស់មនុស្សឬធម្មជាតិ ដែលអាចបង្កឱ្យមានផលប៉ះពាល់ដល់ជីវៈចម្រុះ សុខភាពមនុស្ស សត្វ ឬប៉ះពាល់ដល់ដំណើរការផលិតកម្ម អាជីវកម្ម សេវាកម្ម និងការប្រើប្រាស់ដែលប្រែប្រួលនូវលក្ខណៈរូប គីមី ឬជីវសាស្ត្ររបស់បរិស្ថានខុសពីលក្ខណៈដើមនៃធម្មជាតិ។

ការបំពុលបរិស្ថានធ្ងន់ធ្ងរ (Severity of Environmental Pollution)

សំដៅដល់ការបំពុលបរិស្ថានដែលបង្កឱ្យមានហានិភ័យកម្រិតខ្លាំងទៅដល់សុខភាពឬអាយុជីវិតមនុស្ស សត្វ ឋានប្រព័ន្ធ(ឬប្រព័ន្ធអេកូឡូស៊ី) ជីវៈចម្រុះ ឬផលប្រយោជន៍សាធារណៈ មានដូចជា៖ ការបង្កឱ្យមានជំងឺធ្ងន់ធ្ងរ ជំងឺពុំរីរ៉ៃ ឬរហូតដល់បង្កឲ្យស្លាប់ ការបង្កឱ្យខូចខាតធនធានបរិស្ថាន ដោយធ្វើឱ្យទឹក ដី ខ្យល់ មានផ្ទុកជាតិពុលកម្រិតខ្ពស់ ដែលធ្វើឲ្យបាត់បង់ដីវៈចម្រុះ បាត់បង់ការប្រើប្រាស់ធនធានទឹក ដី ឬផលដំណាំនានាជាដើម។

ការបំពុលសមុទ្រ (Marine Pollution)

សំដៅដល់ការធ្លាក់ចូល ឬការបង្ហូរចូលទៅក្នុងសមុទ្រនូវសំណល់ សារធាតុបំពុល ផលិតផលប្រេង សារធាតុគីមី។ល។ ដែលអាចបង្កឱ្យប៉ះពាល់ដល់គុណភាពទឹកសមុទ្រ ឬគ្រោះថ្នាក់ដល់បរិស្ថាន ជីវៈចម្រុះ និងសត្វ។

ការអភិវឌ្ឍប្រកបដោយចីរភាព (Sustainable Development)

សំដៅដល់ការអភិវឌ្ឍដែលបំពេញសេចក្តីត្រូវការបច្ចុប្បន្ន ដោយមិនប៉ះពាល់ដល់លទ្ធភាពរបស់មនុស្សជំនាន់ក្រោយក្នុងការបំពេញសេចក្តីត្រូវការរបស់ពួកគេផ្ទាល់។

ការអភិវឌ្ឍបៃតង (Green Growth)

សំដៅដល់ការអភិវឌ្ឍដែលប្រើប្រាស់ធនធានប្រកបដោយចីរភាព រួមមាន ការថែរក្សាបរិស្ថានបៃតងនិងធនធានធម្មជាតិ ទឹកនិងអនាម័យ សេដ្ឋកិច្ចនិងវិនិយោគ ទូរគមនាគមន៍និងដឹកជញ្ជូន ឧស្សាហកម្មនិងថាមពល ទេសចរណ៍ បរិស្ថាន សន្តិសុខស្បៀងនិងសុវត្ថិភាពចំណីអាហារ និងការប្រើប្រាស់ដីធ្លី។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៥០១

ការអភិរក្សក្រៅដែនជម្រកធម្មជាតិ (Ex-situ Conservation)

សំដៅដល់ការថែរក្សាការពារជីវៈចម្រុះដែលស្ថិតនៅក្រៅជម្រកធម្មជាតិ ដូចជា ការបង្កើតជាសួនសត្វ ថ្នាល បណ្តុះកូនឈើជាដើម។

ការអភិរក្សជីវៈចម្រុះ (Biodiversity Conservation)

សំដៅដល់ការថែរក្សាការពារបាននូវនានាភាពនៃសព៌ាង្គកាយរស់នៅលើដី ក្នុងទឹក និងក្នុងប្រព័ន្ធអេកូឡូស៊ី ផ្សេងៗទៀត ដែលរួមមាន នានាភាពសេនេទិច នានាភាពប្រភេទ និងនានាភាពប្រព័ន្ធអេកូឡូស៊ី។

ការអភិរក្សធនធានពន្ធុ (Genetic Resources Conservation)

សំដៅដល់ការថែរក្សាការពារពិពិធភាពពន្ធុដែលអាចបន្តពូជនៃប្រភេទរុក្ខជាតិ សត្វ មីក្រុប... រួមនឹងគុណតម្លៃ របស់វាដែលយើងបានដឹងឬមានសក្តានុពល ដើម្បីជានាឱ្យមានភាពសម្បូរបែបនៅពេលបច្ចុប្បន្ននិងអនាគត។

ការធ្វើចំណាត់ថ្នាក់គម្រោង (Project Screening)

សំដៅដល់ការកំណត់សញ្ញាណនៃហេតុប៉ះពាល់ ឬទំហំនៃគម្រោងស្នើសុំ ដែលតម្រូវឱ្យមានការវាយតម្លៃ ហេតុប៉ះពាល់បរិស្ថាននិងសង្គមពេញលេញ ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង ឬត្រូវធ្វើកិច្ចសន្យា ការពារបរិស្ថាន។

ការនេសាទ (Fishing)

សំដៅដល់ការប៉ុនប៉ង ការស្រាវជ្រាវ ការធ្វើសកម្មភាព ដោយប្រើមធ្យោយបាយនានា ដើម្បីទាក់ទាញ ចាប់ដាក់អន្ទាក់ ធ្វើឱ្យរបួស ធ្វើឱ្យងើង សម្លាប់ និងប្រមូលយកវារីសត្វពីក្នុងដែននេសាទ។

ការវាយតម្លៃហានិភ័យ (Risk Assessment)

សំដៅដល់ការសិក្សានិងការវិភាគគម្រោងអភិវឌ្ឍន៍ ឬគម្រោងវិនិយោគ ដើម្បីកំណត់អត្តសញ្ញាណគ្រោះថ្នាក់ និងកត្តាហានិភ័យពីសកម្មភាពគម្រោងទៅលើបរិស្ថាន សុវត្ថិភាពសាធារណៈ និងសុខភាពមនុស្ស រួមទាំងគ្រោះធម្មជាតិ ឬប្រធានសក្តិទៅលើគម្រោងអភិវឌ្ឍ ឬគម្រោងវិនិយោគ មុននឹងឈានដល់ការកំណត់មធ្យោបាយសមស្របក្នុង ការគ្រប់គ្រង ការកាត់បន្ថយ ការការពារ និងការលុបបំបាត់គ្រោះថ្នាក់ ឬហានិភ័យដែលអាចកើតឡើងដាយថាហេតុ។

ការសាយភាយសារធាតុបំពុល (Pollutant Release)

សំដៅដល់ការបញ្ចេញ ការបន្សាយ ឬការឆ្លាក់ចូលសារធាតុបំពុលទៅក្នុងទឹក ដី ខ្យល់ តាមរយៈសកម្មភាព ដោយផ្ទាល់ឬប្រយោលរបស់មនុស្ស ចេតនាឬអចេតនា ជាប្រចាំឬម្តងម្កាល។

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង (Initial Environmental Impact Assessment)

សំដៅដល់ការសិក្សាដំបូងលើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ ធនធានសេដ្ឋកិច្ចសង្គម និងសម្បត្តិ វប្បធម៌ ហើយភាគច្រើនពឹងផ្អែកលើទិន្នន័យមានស្រាប់ដែលនៅក្នុង និងជុំវិញតំបន់គម្រោង ដើម្បីជាមូលដ្ឋានក្នុង ការកំណត់ ព្យាករណ៍ និងការវិភាគនូវសក្តានុពលហេតុប៉ះពាល់បរិស្ថាន និងសង្គមដែលអាចកើតមានឡើងដោយសារ សកម្មភាពគម្រោង ដើម្បីរកវិធានការកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានឱ្យដល់កម្រិតអប្បបរមា និងបង្កើនហេតុប៉ះពាល់ វិជ្ជមានឱ្យដល់កម្រិតអតិបរមា។

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ (Full Environmental Impact Assessement)

សំដៅដល់ការសិក្សាលម្អិតលើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ ធនធាន សេដ្ឋកិច្ចសង្គម និងសម្បត្តិ វប្បធម៌ ហើយភាគច្រើនពឹងផ្អែកលើទិន្នន័យចម្បងដែលនៅក្នុងនិងជុំវិញតំបន់គម្រោង ដើម្បីជាមូលដ្ឋានក្នុងការកំណត់ ព្យាករណ៍ និងការវិភាគនូវសក្តានុពលហេតុប៉ះពាល់បរិស្ថាននិងសង្គមធ្ងន់ធ្ងរ ដែលអាចកើតមានឡើងដោយសារ សកម្មភាពគម្រោង ដើម្បីរកវិធានការកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានឱ្យដល់កម្រិតអប្បបរមា និងបង្កើនហេតុប៉ះពាល់ វិជ្ជមានឱ្យដល់កម្រិតអតិបរមា។

កិច្ចគាំពារបរិស្ថាន (Environmental Protection)

សំដៅដល់បច្ចេកទេសនិងវិធានការនានា ដើម្បីថែរក្សាបរិស្ថានធម្មជាតិនិងកាត់បន្ថយឥទ្ធិពលអវិជ្ជមានដែលបណ្តាលមកពីសកម្មភាពរបស់មនុស្ស។

កីឡាប្រមាញ់ (Game Hunting)

សំដៅលើការបរបាញ់សត្វព្រៃសម្រាប់ការកំសាន្ត នៅក្នុងតំបន់ការពារធម្មជាតិដែលមានគោលការណ៍កំណត់និងការអនុញ្ញាតពីក្រសួងស្ថាប័នទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិ។

ក្រសួងស្ថាប័នមានសមត្ថកិច្ច (Competent Institution or Ministry)

សំដៅដល់ក្រសួង ស្ថាប័នដែលទទួលបន្ទុកលើការគ្រប់គ្រង ដឹកនាំ ចាត់ចែងលើវិស័យណាមួយស្របច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

ក្រសួងស្ថាប័នទទួលបន្ទុកគ្រប់គ្រងលើការផលិត ការបញ្ជូន ការចែកចាយអគ្គិសនី និងគ្រប់គ្រងលើការប្រើប្រាស់ថាមពលអគ្គិសនី (Ministries and Intitution responsible for electricity production, distribution, and management of use of electricity services)

សំដៅដល់ស្ថាប័នដែលទទួលខុសត្រូវក្នុងការធានាការផ្តល់សេវាអគ្គិសនីមានដូចជា អាជ្ញាធរអគ្គិសនីកម្ពុជាជាអាទិ៍។

កម្រៃសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ (Payment for waste water treatment service)

សំដៅដល់ថ្លៃសេវាដែលត្រូវបង់សម្រាប់សម្អាតទឹកកខ្វក់។

កម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ (Payment for waste water discharge service)

សំដៅដល់ថ្លៃសេវាដែលត្រូវបង់សម្រាប់ថែទាំ ជួសជុល ស្តារ និងពង្រីកអណ្តូងលូ បណ្តាញលូ ប្រឡាយចំហ អាងស្តុក និងដំណើរការស្ថានីយបូមទឹកកខ្វក់។

កម្មវិធីផ្តល់វិញ្ញាបនបត្រគ្រប់គ្រងនិងផលិតផលព្រៃឈើអន្តរជាតិ (Program for International Management and Forest Product Certification)

សំដៅដល់បែបបទនៃការផ្តល់វិញ្ញាបនបត្រដែលធានាដល់អ្នកទិញថា ផលិតផលព្រៃឈើត្រូវបានវាយតម្លៃនិងការចេញវិញ្ញាបនបត្របញ្ជាក់ថា ផលិតផលព្រៃឈើនោះមានប្រភពពីព្រៃឈើដែលមានការគ្រប់គ្រងតាមស្តង់ដារសង្គម សេដ្ឋកិច្ច និងបរិស្ថាន។

កសិកម្មពនេចរ (Shifting Cultivation/ Traditional Practice Shifting Cultivation)

សំដៅដល់ការធ្វើកសិកម្មតាមបែបប្រពៃណីរបស់ជនជាតិដើមភាគតិចដោយកាប់ និងដុតព្រៃដើម្បីដាំដុះហើយបន្ទាប់មកត្រូវបោះបង់មួយរយៈពេល ដើម្បីរក្សាគុណភាពដីតាមរយៈការទុកឱ្យដុះល្បាស់រុក្ខជាតិឡើងវិញ។ ការដាំដុះដំណាំត្រូវបានអនុវត្តតាមខួបវិលជុំនៅលើដីនោះ។

ឥ ៦ ៧ ៨

គណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គម (Environmental and Social Fund Committee)

សំដៅដល់គណៈកម្មាធិការដែលបង្កើតឡើងដោយរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងគោលបំណងគ្រប់គ្រងមូលនិធិរយៈពេលវែង។

គម្របព្រៃឈើ (Forest Cover)

សំដៅដល់មជ្ឈដ្ឋានធម្មជាតិឬសិប្បនិមិត្ត ជាទម្រង់ដីសើម ដីលិចទឹក ឬដីស្ងួត ដែលគ្របដណ្តប់ដោយរុក្ខជាតិដែនាម ធម្មជាតិ ឬដាំ មានកម្ពស់ចាប់ពី៥ម៉ែត្រឡើងទៅលើផ្ទៃដីលើសពី០,៥ហិកតា និងមានកម្រិត

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៥០៣

គ្របដណ្តប់របស់កន្សោមស្លឹកលើសពី១០% ចម្ការឈើដាំដូចជា កៅស៊ូ ដូងប្រេង អាកាស្យា ម៉ៃសាក់ ប្រេងខ្យល់ និងប្រភេទរុក្ខជាតិផ្តល់ឈើជាទៃទៀតដែលមានលក្ខណៈដូចរៀបរាប់ ខាងលើក៏ត្រូវបានចាត់ចូលជាគម្របព្រៃដែរ។

ជីវៈចម្រុះ (Biodiversity or Biological Resources)

សំដៅដល់បណ្តាសព៌ាង្គកាយខុសគ្នានៅក្នុងប្រភេទតែមួយ ឬប្រភេទផ្សេងគ្នា និងបណ្តាសព៌ាង្គកាយរស់នៃគ្រប់លំដាប់ថ្នាក់និងប្រភពទាំងអស់រួមទាំងប្រព័ន្ធអេកូឡូស៊ីដែនដីគោក ដែនសមុទ្រ ដែនទឹកសាប និងបណ្តាទំនាក់ទំនងអេកូឡូស៊ី ដែលនៅក្នុងនោះមានប្រព័ន្ធអេកូឡូស៊ីទាំងនេះ។

ជីវបច្ចេកវិទ្យាទំនើប (Modern Biotechnology)

សំដៅដល់ការអនុវត្តន៍ទូរៈ

ក. បច្ចេកទេសអាស៊ីតនុយក្លេអ៊ិកអាំងវីត្រូ រួមមានការប្រមូលផ្តុំអាស៊ីតឌីអុកស៊ីរីបូនុយក្លេអ៊ិក និងការចាក់អាស៊ីតនុយក្លេអ៊ិកដោយផ្ទាល់ទៅក្នុងកោសិកាឬសរីរាង្គ។

ខ. ការរលាយចូលគ្នានៃកោសិកាដែលមិនមែនគ្រួសារតែមួយ ដែលមានលទ្ធភាពយកឈ្នះនៅការផលិតឡើងវិញតាមលក្ខណៈរូបសាស្ត្រធម្មជាតិ ឬជាឧបសគ្គដល់ការផ្តុំបញ្ចូលគ្នាឡើងវិញ ហើយក៏មិនមែនជាបច្ចេកទេសប្រើប្រាស់នៅក្នុងការបង្កាត់ពូជ ឬការជ្រើសរើសតាមរបៀបបុរាណ។

ដែនជម្រកសត្វព្រៃ (Wildlife Sanctuary)

សំដៅដល់តំបន់ក្នុងដែនដីគោក ឬដែនទឹក ដែលតម្រូវឱ្យមានការធ្វើអន្តរាគមន៍យ៉ាងសកម្មសម្រាប់បំពេញគោលបំណងគ្រប់គ្រង ដើម្បីធានាឱ្យមានការថែទាំទីជម្រក និង/ឬដើម្បីបំពេញលក្ខខណ្ឌចាំបាច់សម្រាប់ប្រភេទណាមួយនៃសត្វឬរុក្ខជាតិ។

ឋបនីយជីវមណ្ឌល (Biosphere Reserve)

សំដៅដល់តំបន់តំណាងឱ្យប្រព័ន្ធអេកូឡូស៊ីមានសារៈសំខាន់ និងពុំរងនូវការខូចខាតខ្លាំង ហើយព័ទ្ធជុំវិញទៅដោយតំបន់ប្រើប្រាស់ដោយនិរន្តរភាព ដែលអនុញ្ញាតក្បែរមានសកម្មភាពមនុស្សក្នុងកម្រិតមួយជាកំណត់។

ត ថ ទ

តំបន់ជម្រាលនៃអាងទន្លេ (Basin Catchment)

សំដៅដល់តំបន់ភូមិសាស្ត្រនៃអាងទន្លេដែលប្រព័ន្ធលំហូរទឹកហូរចូលទៅក្នុងអាងទន្លេដោយរាប់បញ្ចូលទាំងទឹកលើដី និងទឹកក្រោមដី។

តំបន់សហគមន៍មូលដ្ឋាន (Local Community Area)

សំដៅដល់តំបន់បម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច សង្គមរបស់សហគមន៍មូលដ្ឋាន ដែលមានសកម្មភាពស្រាប់ រួមមានលំនៅដ្ឋាន ស្រែ និងចំការ ។ ការចេញលិខិតប្បវ័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លីនៅក្នុងតំបន់នេះ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិ។

តំបន់ការពារទេសភាព (Protected Landscape Area)

សំដៅដល់តំបន់នៃដែនដីគោក និង/ឬដែនទឹក ដែនតំបន់នោះទទួលរងអន្តរអំពើរបស់មនុស្ស ទៅលើធម្មជាតិដោយបង្កើតបានជាតំបន់ ដែលមានលក្ខណៈប្លែកខាងផ្នែកសោភណភាពធម្មជាតិ ឬកែច្នៃអេកូឡូស៊ី ឬប្បពន្ធ៍ និងជាទូទៅសម្បូរដោយជីវៈចម្រុះ។ ការថែរក្សាអន្តរអំពើជាប្រពៃណីរបៀបនេះ មានសារៈសំខាន់ជាអាយុជីវិតចំពោះកិច្ចការពារ ថែរក្សា និងការវិឌ្ឍតំបន់បែបនេះ។

តំបន់ការពារធម្មជាតិ (Protected Area)

សំដៅដល់តំបន់នៃដែនដីសម្បត្តិសាធារណៈរបស់រដ្ឋ រួមមាន ដែនដីគោក ឬដែនទឹក រួមទាំងឆ្នេរសមុទ្រ និងសមុទ្រស្ថិតនៅក្នុងតំបន់ដែលទទួលស្គាល់ដោយបទប្បញ្ញត្តិនៃច្បាប់ ឬតំបន់ដែលបង្កើតថ្មី ក្នុងដែនសមត្ថកិច្ចរបស់ក្រសួងស្ថាប័នទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិ។ តំបន់ទាំងនោះមានសារៈសំខាន់ទាំងផ្នែករូបសាស្ត្រ និងផ្នែកជីវសាស្ត្រ ដែលតម្រូវឱ្យមានការគ្រប់គ្រងតាមច្បាប់ក្នុងបំណងការពារ និងថែទាំ ជីវៈចម្រុះ ធនធានធម្មជាតិ និងធនធានវប្បធម៌ហើយត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាពគ្រប់ជំនាន់ ដើម្បីផលប្រយោជន៍បរិស្ថាន សង្គម និងសេដ្ឋកិច្ច។

តំបន់បេតិកភណ្ឌធម្មជាតិ (Natural Heritage Site)

សំដៅដល់តំបន់ក្នុងដែនដីគោក និង/ឬដែនទឹកដែលតំបន់នោះមានលក្ខណៈពិសេសពីធម្មជាតិ ឬពាក់កណ្តាលកែច្នៃធម្មជាតិ និងមានតម្លៃលេចធ្លោឬប្លែកពីគេ ដោយសារតំបន់នោះមានដោយកម្រមានគុណភាពជាតំណាងឱ្យប្រព័ន្ធធម្មជាតិនានា ឬមានគុណភាពខាងផ្នែកសោភណភាព ឬសារៈសំខាន់ខាងផ្នែកវប្បធម៌។

តំបន់ជីវសើម (Wetland)

សំដៅដល់តំបន់មានលក្ខណៈជាវាលភក់ វាលល្បាប់ តំបន់មានរុក្ខជាតិពុករលួយ ទីដែលមានទឹកក្នុងលក្ខណៈធម្មជាតិ ឬសិប្បនិម្មិត តំបន់មានទឹកលិចជាអចិន្ត្រៃយ៍ឬតាមរដូវ ទឹកនឹង ទឹកហូរ ឬទឹកភ្លាវ រួមទាំងតំបន់សមុទ្រដែលមានជម្រៅលើសពី៦ (ប្រាំមួយ) ម៉ែត្រ ក្នុងពេលទឹកនាចទាបបំផុត។

តំបន់ប្រើប្រាស់ច្រើនយ៉ាង (Multiple-Use Area)

សំដៅដល់តំបន់ក្នុងដែនដីគោក និង/ឬដែនទឹក ដែលក្នុងនោះមានសម្បូរដោយប្រព័ន្ធធម្មជាតិ ដែលពុំទាន់រងការបំផ្លិចបំផ្លាញ និងដែលតម្រូវឱ្យមានសកម្មភាពគ្រប់គ្រង ដើម្បីធានាការការពារ និងការថែទាំធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីសម្រាប់ពេលយូរអង្វែង។ ទន្ទឹមនឹងនោះដែរអោចផ្តល់ផលិតផល និងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់តាមតម្រូវការរបស់សហគមន៍។

តំបន់ដីមមោក (Humus Soil Area)

សំដៅដល់តំបន់ដីសើម ដែលមានស្រទាប់ដីមមោកមានកម្រាស់ច្រើនជាង៤០សង់ទីម៉ែត្រដោយកើតចេញពីការពុកផុយនៃបំណែករុក្ខជាតិក្នុងស្ថានភាពជាំទឹក និងកង្វះអុកស៊ីសែន ហើយសម្បូរដោយសារធាតុសរីរាង្គកាបូន (ច្រើនជាង១៨ភាគរយនៃម៉ាស់ស្ងួត)។

តំបន់ស្នូល (Core Zone)

សំដៅដល់តំបន់ដែលមានតម្លៃខ្ពស់សម្រាប់ការអភិរក្សប្រភេទសត្វ និងរុក្ខជាតិដែលកម្រ ជិតផុតពូជ ទទួលរងគ្រោះថ្នាក់ គម្រោមកំហែង ហើយនិងប្រព័ន្ធអេកូឡូស៊ីផុយស្រួយ។

ការចេញចូលតំបន់នេះត្រូវហាមឃាត់ លើកលែងតែមន្ត្រីរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ ដែលមានការកិច្ច។

អ្នកសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រធម្មជាតិ ក្នុងគោលបំណងការពារ និងអភិរក្សធនធនធម្មជាតិ ជីវៈចម្រុះ និងបរិស្ថានត្រូវមានការអនុញ្ញាតជាមុនពីក្រសួងទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិ។

តំបន់អភិរក្ស (Conservation Zone)

សំដៅដល់តំបន់ស្ថិតនៅជាប់នឹងតំបន់ស្នូល ដែលមានតម្លៃខាងការអភិរក្សធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី តំបន់ទីជម្រាល និងតំបន់ដែលមានលក្ខណៈទេសភាពធម្មជាតិ។

ការចេញ ចូលតំបន់នេះ ត្រូវមានការអនុញ្ញាតជាមុនពីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៅនឹងកន្លែង។

ការប្រើប្រាស់អនុផលធនធានធម្មជាតិសម្រាប់ជីវភាពរបស់សហគមន៍មូលដ្ឋាន និងមិនធ្វើឱ្យប៉ះពាល់ខ្លាំងដល់ជីវៈចម្រុះ ត្រូវស្ថិតក្រោមការត្រួតពិនិត្យហ្មត់ចត់បំផុត។

តំបន់ប្រើប្រាស់ដោយចីរភាព (Sustainable Use Zone)

១- សំដៅដល់តំបន់ដែលមានតម្លៃផ្នែកសេដ្ឋកិច្ចជាតិខ្ពស់ បម្រើដល់ការគ្រប់គ្រង និងអភិរក្សតំបន់ការពារធម្មជាតិផ្ទាល់ និងចូលរួមលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាន។

២- តំបន់ប្រើប្រាស់ដោយចីរភាពរួមមាន៖

ក- តំបន់អភិរក្សវប្បធម៌ធម្មជាតិនិងបេតិកភណ្ឌ។

ខ- តំបន់ទេសចរណ៍ធម្មជាតិ។

គ- តំបន់អភិរក្សសត្វព្រៃ និងសេវាកំសាន្ត។

ឃ- តំបន់ស្តារធនធានជីវៈចម្រុះ។

ង- សហគមន៍តំបន់ការពារធម្មជាតិ។

ច- តំបន់ក្តុរឧទ្យាន។

ឆ- តំបន់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ រួមមាន ប្រព័ន្ធធារាសាស្ត្រ អាងស្តុកទឹក។

ជ- វារីអគ្គិសនី បង្គោលចរន្តអគ្គីសនី។

ឈ- តំបន់កូគព្ភសាស្ត្រ។

ញ- តំបន់អាជីវកម្មជីវរុក្ខជាតិ អនុគ្រោះដល់បរិស្ថានធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិនិងតំបន់ជុំវិញ។

តំបន់ឆ្នេរ (Coastal Zone)

សំដៅដល់តំបន់ដីគោកដែលស្ថិតនៅជាប់សមុទ្រ និងទទួលឥទ្ធិពលនៃសមុទ្រ មាននៅខេត្តកំពត ខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តកែប ដោយរួមបញ្ចូលបរិណាភាពដែនសមុទ្រ ដែលលាតសន្ធឹងដល់ព្រំប្រទល់តំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ព្រះរាជាណាចក្រកម្ពុជា។

តំបន់រ៉ាមសារ (Ramsar Site)

សំដៅដល់តំបន់ដីសើម ដែលគេចាត់ទុកថា ជាតំបន់មានសារៈសំខាន់ផ្នែកអេកូឡូស៊ី ឬជីវៈចម្រុះជាលក្ខណៈអន្តរជាតិ។

តំបន់ទឹកជ្រាល (Watershed Area)

ជាតំបន់ភ្នំឬខ្ពង់រាបឬតំបន់មានរយៈកំពស់ខ្ពស់ ជាផ្ទៃរងទឹកភ្លៀងដែលមានលក្ខណៈកូមិសាស្ត្រស្ថិតនៅជុំវិញ ឬជាផ្លូវទឹកតភ្ជាប់ហូរចាក់ទៅទន្លេ អាងទន្លេ ឬសមុទ្រ។ ទឹកជ្រាលគឺជាតំបន់មួយនៅលើដី ដែលទឹកទាំងអស់មកពីទឹកភ្លៀងនិងព្រិល ហូរចុះក្រោមទៅកន្លែងទឹកតែមួយ ដូចជាអូរ ទន្លេ បឹង ឬដីល្បាយខ្សាច់។ ទឹកជ្រាលក៏ត្រូវបានហៅថាកន្លែងប្រមូលទឹកភ្លៀងផងដែរ ព្រោះដីដែលស្ថិតនៅលើខ្សែទឹក ប្រមូលទឹកទាំងអស់ បន្ទាប់មកវាក៏ហូរចុះទៅក្រោម។

ថាមពលនុយក្លេអ៊ែរ (Nuclear Energy)

សំដៅដល់ថាមពលដែលបញ្ចេញពីណ្យូនៃអាតូមតាមរយៈប្រតិកម្មបំបែក(Fission) ឬប្រតិកម្មរំលាយ (Fusion)។

ប្រតិកម្មបំបែក គឺជាប្រភេទប្រតិកម្មដែលកើតឡើងនៅក្នុងណ្យូនៃអាតូម ដែលក្នុងនោះណ្យូនៃអាតូមធ្ងន់ (ដូចជាអ៊ុយរ៉ាញ៉ូមជាដើម) ត្រូវបានបំបែកជាណ្យូស្រាលជាង ចំនួនពីរ ឬច្រើនជាងនេះ ដែលត្រូវបានហៅថាផលិតផលបំបែក (Fission Products) និងមានបញ្ចេញនូវថាមពលដែលមានទម្រង់ជារលកអេឡិចត្រូម៉ាញ៉េទិច (កាំរស្មីហ្គាម៉ាឬកាំរស្មីអ៊ិច)ឬភាគល្អិត (អាល់ហ្វា បេតា ឬណឺត្រុង) ដែលមានកម្លាំងគ្រប់គ្រាន់អាចធ្វើអ៊ីយ៉ូងកម្មនៅពេលដែលឆ្លងកាត់មជ្ឈដ្ឋានណាមួយ។

ប្រតិកម្មរំលាយ គឺជាប្រភេទប្រតិកម្មដែលកើតឡើងនៅក្នុងណ្យូនៃអាតូម ដែលក្នុងនោះណ្យូនៃអាតូមស្រាលចំនួនពីរ (ដូចជាអ៊ីដ្រូសែនជាដើម) ត្រូវបានបញ្ចូលគ្នាបង្កើតបានជាណ្យូនៃអាតូមធ្ងន់ជាងចំនួនមួយ ដោយបានបញ្ចេញនូវបរិមាណថាមពលជាច្រើនសន្ធឹកសន្ធាប់។

ថាមពលប្រកបដោយការទទួលខុសត្រូវ (Responsible Energy)

សំដៅដល់គោលការណ៍ផលិតនិងការផ្គត់ផ្គង់ថាមពល ដែលមានលក្ខណៈ៦(ប្រាំមួយ)យ៉ាងជាមួយគ្នាគឺ មានគ្រប់គ្រាន់ មាននិរន្តរភាព មានស្ថិរភាព មានគុណភាព មានតម្លៃសមរម្យ និងមាននៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា។

ថ្លៃសួយសារ (Royalty)

សំដៅដល់បរិមាណទឹកប្រាក់ដែលត្រូវបង់ជូនរដ្ឋដោយបុគ្គលគ្រប់រូប ចំពោះដល អនុផលព្រៃឈើ រុក្ខជាតិព្រៃ និងសំណាកវុក្ខជាតិព្រៃ និងសត្វព្រៃនិងសំណាកសត្វព្រៃ ដែលបានប្រមូល ឬធ្វើអាជីវកម្ម។

ទិន្នន័យ (Database)

សំដៅដល់ព័ត៌មានទាំងអស់ដែលបានប្រមូល ចងក្រង និងវិភាគសម្រាប់ការប្រើប្រាស់តាមតម្រូវការ។

ទីជម្រក (Habitat)

សំដៅដល់ទីកន្លែងឬទីតាំងដែលមានពពួកតាមប្រភេទតែមួយទៅតាមធម្មជាតិជាជម្រក ជាកន្លែងរកចំណី និងជាកន្លែងបង្កាត់ពូជរបស់ពពួកសត្វនិងរុក្ខជាតិទាំងនោះ។

ទីតាំងការពារនិងអភិរក្សប្រភពដើមធនធានពន្ធុ (Genetic Resources Protection and Conservation Area)

សំដៅទីតាំងដែលមានសមាសភាគរុក្ខជាតិ សត្វ មីក្រុប ឬសមាសភាគប្រភពដើមផ្សេងៗដែលមានផ្ទុកមុខងារ នៃឯកតាតំណពូជ ដែលមានគុណតម្លៃ សម្រាប់ការសិក្សាស្រាវជ្រាវ ការការពារ និងការអភិរក្ស។

ទេសចរណ៍ធម្មជាតិ (Eco-Tourism)

សំដៅដល់សេវាកម្មទេសចរណ៍នានា ដែលមិនធ្វើឱ្យប៉ះពាល់ដល់បរិស្ថានធម្មជាតិជុំវិញតំបន់ទេសចរណ៍ និងមានរូបភាពនិន្នាការបម្រើឱ្យសកម្មភាពអភិរក្ស។

ច ន ប

ធុរកិច្ចនូវប្រភពថាមពលប្រកបដោយការទទួលខុសត្រូវ (Responsible Energy Business)

សំដៅដល់ធុរកិច្ច ដែលបង្កើតប្រព័ន្ធថាមពលប្រកបដោយការទទួលខុសត្រូវ សម្រាប់ការផ្គត់ផ្គង់អគ្គិសនីផ្ទាល់ខ្លួនដោយត្រូវទទួលខុសត្រូវលើគោលការណ៍ផ្សេងទៀតក្រៅពី "ទទួលខុសត្រូវ" ដោយខ្លួនឯង បន្ទាប់មកប្រសិនបើចង់តភ្ជាប់ជាមួយបណ្តាញផ្គត់ផ្គង់រួមត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសសេដ្ឋកិច្ចនិងសុវត្ថិភាព ដែលកំណត់ដោយក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពល។

ធនធានធម្មជាតិ (Natural Resources)

សំដៅដល់ចំណែកមួយនៃបរិស្ថានធម្មជាតិ មានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ កូតគាម ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆជាតិ ធនធានដលផល។

ធនធានពន្ធុ (Genetic Resources)

សំដៅដល់ពិពិធភាពពន្ធុនៃហ្សែនរបស់ប្រភេទវុក្ខជាតិ សត្វ មីក្រុប ជាអាទិ៍។

និរន្តរភាព (Sustainability)

សំដៅដល់ការមិនបង្កឱ្យមានភាពរេចរឹលជាអចិន្ត្រៃយ៍ឬជាបន្តបន្ទាប់ ឬការថយចុះនូវគុណភាពនៃប្រភេទសព៌ាង្គកាយរស់ ឬគុណភាពនៃធនធានដទៃទៀតដែលស្ថិតនៅក្រោមរូបភាពនៃការប្រើប្រាស់ជាទ្រង់ទ្រាយតូចក្តី ធំក្តី។

និទស្សន៍វត្ថុនៃធនធានពន្ធុ (Genetic Resource Proof)

សំដៅដល់វត្ថុនានាដែលជាតឹកតាងឬកសុតាងនៃធនធានពន្ធុ។

ប្រភេទកម្រ (Rare Species)

សំដៅដល់ប្រភេទទាំងឡាយណាដែលមានចំនួនតិចតួច ប៉ុន្តែវាពុំស្ថិតនៅក្នុងភាពគ្រោះថ្នាក់ផុតពូជភ្លាមៗទេ។ ជាទូទៅប្រភេទទាំងនោះ គេតែងជួបប្រទះក្នុងបណ្តាភាវៈប្រចាំទីក្នុងជម្រកពិសេសណាមួយ ឬស្ថិតនៅរាយប៉ាយយ៉ាងរង្វើលនៅលើតំបន់ដ៏ធំល្វីងល្វើយ។

ប្រភេទជិតផុតពូជ (Endangered Species)

សំដៅដល់ពពួកសត្ច ឬរុក្ខជាតិ ដែលអាចវិនាសសាបសូន្យបណ្តាលមកពីការប្រែប្រួលបរិស្ថានដោយធម្មជាតិ ឬការធ្វើអាជីវកម្មផ្ទាល់របស់មនុស្ស ការខូចខាតហិនហោចជម្រក ការគំរាមកំហែងពីប្រភេទជទៃទៀត ការប្រែប្រួលបណ្តាញអាហារ ការបំពុល ឬបណ្តាលមកពីបន្សាំនៃកត្តាទាំងនេះ។

បច្ចេកវិទ្យាមេត្រីបរិស្ថាន (Environment Friendly Technology)

សំដៅដល់បច្ចេកទេសវិទ្យាថ្មីដែលមានបំណងការពារ តាមដានត្រួតពិនិត្យ ឬកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាន លើបច្ចេកវិទ្យាបរិស្ថាននិងការប្រើប្រាស់ធនធាននានា។

បណ្តុំនៃហេតុប៉ះពាល់ (Cumulative Impact)

សំដៅដល់ហេតុប៉ះពាល់ទាំងឡាយណា ដែលកើតមានឡើងពីសកម្មភាពរួមគ្នារវាងគម្រោងដែលមានស្រាប់និងគម្រោងក្នុងពេលអនាគតដែលស្ថិតនៅជុំវិញតំបន់គម្រោងទាំងនោះ ដោយផ្តោតទៅលើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម។

បន្លាស់ទីសារធាតុបំពុល (Pollutant Substance(s) Movement)

សំដៅដល់ការបញ្ជូនចេញនូវសំណល់ សារធាតុគីមីពុល ឬសារធាតុគ្រោះថ្នាក់ ទៅក្រៅបរិវេណប្រភពឬទីតាំងបង្កើត ក្នុងគោលបំណងប្រើប្រាស់ កែច្នៃ ទាញយកធនធាន ធ្វើប្រព្រឹត្តិកម្ម ឬបោះចោល រួមបញ្ចូលការបញ្ចេញទឹកកខ្វក់ ឬសំណល់រាវ ចូលទៅក្នុងប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់សាធារណៈ។

បមាណីយ/ស្តង់ដារមេត្រីបរិស្ថាន (Environmentally Friendly Standard)

សំដៅដល់បទដ្ឋានបច្ចេកទេសសម្រាប់កំណត់លក្ខណវិនិច្ឆ័យ និងសូចនាការដែលត្រូវយកមកវាយតម្លៃសកម្មភាពប្រតិបត្តិមេត្រីបរិស្ថាន។

បរធនបាលកិច្ចបរិស្ថាន (Environmental Trust)

សំដៅដល់កិច្ចការគ្រប់គ្រងនិងចាត់ចែងបរធនដែលផ្តល់ដោយបរធនបាលទាយក សម្រាប់ជាប្រយោជន៍ផ្នែកបរិស្ថានដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធានបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

បរិក្ខារតាមដានត្រួតពិនិត្យ (Monitoring Equipment)

សំដៅដល់ឧបករណ៍ឬគ្រឿងម៉ាស៊ីន ដែលបំពាក់សម្រាប់វាស់ស្ទង់និងកត់ត្រាទិន្នន័យកំហាប់សារធាតុបំពុល ឬបរិមាណសំណល់បញ្ចេញទៅក្នុងបរិស្ថាន។

បរិស្ថានឆ្លងដែន (Transboundary Environment)

សំដៅដល់ការគ្រប់គ្រងបរិស្ថាន ដែលជាកិច្ចសហប្រតិបត្តិការអន្តរជាតិរវាងប្រទេសនិងប្រទេសដែលមានផលប៉ះពាល់នៃការបំពុលបរិស្ថានជះឥទ្ធិពលលើការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដូចជា ការបំពុលខ្យល់ ផ្សែងអ័ព្ទ ការបំពុលទឹកជាដើម។

បុគ្គល (Person)

សំដៅដល់រូបបុគ្គលឬនីតិបុគ្គល។

បុព្វលាភ (Premiums)

សំដៅដល់បរិមាណទឹកប្រាក់ដែលអ្នកកាន់អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតត្រូវបង់បន្ថែមលើថ្លៃសួយសារ (បុព្វលាភប្រៃឈើ)។

ប្រព័ន្ធអេកូឡូស៊ី (Eco-system)

សំដៅដល់សំណុំអន្តរអំពើចម្រុះនៅលើផ្ទៃដីមួយជាក់លាក់រវាងបណ្តាភាវៈមានជីវិត(សារពាង្គកាយធម្មជាតិ សត្វមីក្រូ សរីរាង្គ) ជាមួយនឹងមជ្ឈដ្ឋានគ្មានជីវិត(អាកាសធាតុ មីក្រូអាកាសធាតុ ដី ទឹក) ដែលបង្កនូវស្ថាបនកម្មរបស់បរិស្ថាន និងជាឯកតាបំពេញមុខងារមួយនៅលើសំបកផែនដី។ មនុស្សរួមជាមួយសំបកផែនដី មនុស្សរួមជាមួយតម្រូវការផ្នែកសេដ្ឋកិច្ច ប្រពៃណី វប្បធម៌ និងបរិស្ថាន ក៏ជាផ្នែកចម្រុះរួមមួយនៃបណ្តាប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើដែរ។

ប្រព្រឹត្តិកម្មសំណល់ (Waste Treatment)

សំដៅដល់សកម្មភាព ឬល័នាំសម្អាត ដកយកចេញ ឬកម្ទេចចោលនូវសារធាតុគីមីពុល សារធាតុគ្រោះថ្នាក់ ឬភ្នាក់ងារចម្លងជំងឺ ដែលមាននៅក្នុងសំណល់តាមរយៈវិធីរូប គីមី ឬជីវសាស្ត្រ។

ប្រតិបត្តិករសំណល់ (Waste Operator)

សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែល៖

- ផ្តល់សេវាប្រមូល ដឹកជញ្ជូន ប្រព្រឹត្តិកម្ម កម្ទេចចោល ឬទុកដាក់សំណល់ចុងក្រោយ
- ធ្វើអាជីវកម្មទិញ លក់ កែច្នៃ ឬទាញយកធនធានពីសំណល់។

ប្រភពជាក់លាក់ (Point Source(s))

សំដៅដល់ទីតាំងជាក់លាក់ មានជាអាទិ៍ រោងចក្រ សហគ្រាស ទីតាំងផលិតកម្ម ទីតាំងអាជីវកម្ម ឬទីតាំងសេវាកម្ម ដែលបង្កើតនិងបញ្ចេញសំណល់ភាវ សារធាតុបំពុល ឬទឹកកខ្វក់ចូលទៅក្នុងបណ្តាញលូសាធារណៈ ឬតំបន់ទឹកសាធារណៈ។

ប្រភពបំពុលខ្យល់ (Air Pollution Sources)

សំដៅដល់ទីតាំង ទីកន្លែង និងមធ្យោបាយដឹកជញ្ជូន ដែលបង្កើតឬបញ្ចេញសំណល់ សារធាតុបំពុល ក្លិន ផ្សែង កម្តៅ ការរំខានដោយសំឡេងនិង រ៉ាំរ៉ៃ ជាអាទិ៍ ទៅក្នុងបរិយាកាស។

ប្រភពបំពុលខ្យល់ចល័ត (Mobile Air Pollution Sources)

សំដៅដល់ប្រភពបំពុលជាប្រភេទយានយន្ត ដែលបញ្ចេញផ្សែង ឧស្ម័ន សារធាតុបំពុលខ្យល់ ក្លិន កម្តៅ ការរំខានដោយសំឡេង និងរ៉ាំរ៉ៃ ជាដើម ចូលទៅក្នុងខ្យល់បរិយាកាស។

ប្រភពបំពុលខ្យល់អចល័ត (Constant Air Pollution Sources)

សំដៅដល់ប្រភពបំពុលមានទីតាំងជាក់លាក់ មានជាអាទិ៍ រោងចក្រ សហគ្រាស សិប្បកម្ម កសិដ្ឋាន ឃ្លាំងស្តុកសម្ភារៈ ការដ្ឋានសំណង់ ឡដុតសំរាម ដែលបញ្ចេញផ្សែង ឧស្ម័ន សារធាតុបំពុលខ្យល់ ក្លិន កម្តៅ ការរំខានដោយសំឡេងនិងរ៉ាំរ៉ៃចូលទៅក្នុងបរិយាកាស។

ប្រភពមិនជាក់លាក់ (Non-Point Source(s))

សំដៅដល់ប្រភពបំពុលមានវិសាលភាពធំទូលាយ មានជាអាទិ៍ ទីក្រុង វាលស្រែចម្ការ ដែលសំណល់ភាវ សារធាតុបំពុល ឬទឹកកខ្វក់បានហូរចេញនៅពេលមានជំនន់ទឹកភ្លៀង។

ប្រភេទកំពុងរងការគំរាមកំហែង (Threatened Species)

សំដៅដល់ប្រភេទសត្វ និងរុក្ខជាតិដែលបានចុះបញ្ជីជាប្រភេទកំពុងរងគ្រោះថ្នាក់ឈានទៅរកការវិនាសផុតពូជបំផុតកំពុងរងគ្រោះថ្នាក់ជិតផុតពូជ ឬងាយរងគ្រោះថ្នាក់ ដូចមានចុះនៅក្នុងបញ្ជីក្រហមនៃប្រភេទកំពុងទទួលរងការគំរាមកំហែង។

ប្រភេទកំពុងរងគ្រោះថ្នាក់ (Endangered Species)

សំដៅដល់ប្រភេទសត្វ និង/ឬរុក្ខជាតិទាំងឡាយ ដែលចាត់ទុកថាប្រឈមនឹងហានិភ័យខ្ពស់បំផុតនៃការផុតពូជនៅក្នុងព្រៃ រហូងទៅតាមកស្តុតាងស្វែងរកប្រសើរបំផុត។

ប្រភេទជិតផុតពូជ/ប្រភេទកំពុងរងគ្រោះថ្នាក់ខ្លាំង (Critically Endangered Species)

សំដៅដល់ប្រភេទសត្ត និងរុក្ខជាតិទាំងឡាយនៅក្នុងធម្មជាតិ ដែលដង់ស៊ីតេ និងភូមិសាស្ត្រនៃទីជម្រករបស់វាត្រូវបានថយចុះ យ៉ាងធាប់រហ័សក្នុងរយៈពេល១០(ដប់)ឆ្នាំចុងក្រោយ ឬក្នុងរយៈពេល៣(បី)ជំនាន់តំណពូជនៅក្នុងធម្មជាតិ និងប្រភេទដែលមានសារៈសំខាន់ខាងផ្នែកវិទ្យាសាស្ត្រ ព្រមទាំងមានតម្លៃសេដ្ឋកិច្ចខ្ពស់។ ឈ្មោះប្រភេទសត្វព្រៃនិងរុក្ខជាតិក្នុងក្រុមប្រភេទជិតផុតពូជ ត្រូវបានកំណត់ក្នុងបញ្ជីក្រហមនៃប្រភេទកំពុងទទួលរងការគំរាមកំហែង។

ប្រភេទមានដើមកំណើតក្នុងស្រុក (Native Species)

សំដៅដល់ប្រភេទសត្ត ឬរុក្ខជាតិទាំងឡាយណា ដែលមានដើមកំណើត ធ្លាប់បានរស់នៅឬបន្តរស់នៅ ឬមានផ្នែកណាមួយនៃរបាយរបស់វា ឬការផ្លាស់ទីជាប្រចាំ នៅក្នុងតំបន់ភូមិសាស្ត្រនៃប្រទេសកម្ពុជា មិនមែនជាលទ្ធផលនៃការនាំចូលមកថ្មី ទោះមានចេតនា ឬមិនមានចេតនាក៏ដោយ។

ប្រភេទមានដើមកំណើតក្រៅស្រុក (Alien Species)

សំដៅដល់ប្រភេទសត្ត និង/ឬរុក្ខជាតិណាមួយដែលមិនមានដើមកំណើតដំបូងនៅប្រទេសកម្ពុជា ជាអាទ៍ សត្វព្រៃរស់និងងាប់ ព្រមទាំងផ្នែកផ្សេងៗរបស់សត្វព្រៃ រុក្ខជាតិទាំងឡាយដែលត្រូវបានប្រមែប្រមូលមក។

ប្រភេទមិនទាន់រងការគំរាមកំហែង (Least Concerned Species)

សំដៅដល់ប្រភេទសត្ត និងរុក្ខជាតិដែលត្រូវបានចាត់ដោយសហភាពអន្តរជាតិសម្រាប់ការអភិរក្សធម្មជាតិ ដែលត្រូវបានវាយតម្លៃថាជាប្រភេទមិនត្រូវបានជាកម្មវត្ថុនៃការអភិរក្សទេ។

ប្រភេទរាតត្បាតមានដើមកំណើតក្រៅស្រុក (Alien Invasive Species)

សំដៅដល់រុក្ខជាតិ សត្ត ភ្នាក់ងារបង្កជំងឺ និងមីក្រូសព៉ាង្គកាយដទៃទៀតដែលពុំមានដើមកំណើតក្នុងព្រះរាជាណាចក្រកម្ពុជា ហើយអាចបង្កការខូចខាតដល់សេដ្ឋកិច្ចឬបរិស្ថាន ឬអាចមានផលប៉ះពាល់អវិជ្ជមានដល់សុខភាពមនុស្ស។ ជាងនេះ ប្រភេទរាតត្បាតមិនមានដើមកំណើតក្នុងស្រុកមានឥទ្ធិពលអវិជ្ជមានលើជីវៈចម្រុះក្នុងនោះ រួមទាំងការធ្លាក់ចុះ ឬការលុបបំបាត់ទាំងស្រុងនូវប្រភេទក្នុងស្រុក ឬការចម្លងភ្នាក់ងារបង្កជំងឺ និងការរំខានប្រព័ន្ធអេកូឡូស៊ី និងមុខងារប្រព័ន្ធអេកូឡូស៊ីក្នុងស្រុក។

ប្រសិទ្ធផលធនធាន (Resource Efficiency)

សំដៅដល់ការប្រើប្រាស់ធនធានដូចជា ថវិកា សម្ភារៈ ធនធានបរិស្ថាន ធនធានមនុស្ស ឬធនធានផ្សេងទៀតដើម្បីបំពេញមុខងារប្រកបដោយប្រសិទ្ធភាពតាមរយៈការប្រើប្រាស់ធនធានតិចជាងមុន កាត់បន្ថយសំណល់ និងសន្សំសំចៃផ្នែកសេដ្ឋកិច្ច សំដៅរក្សាបានចីរភាពបរិស្ថាន។

ឆ ម រ

ផលិតផលព្រៃឈើ (Forest Products)

សំដៅដល់វត្ថុធាតុណាមួយដែលបានមកពីព្រៃឈើសម្រាប់ការប្រើប្រាស់ដោយផ្ទាល់ ឬការប្រើប្រាស់ជាលក្ខណៈពាណិជ្ជកម្ម រួមមាន ផលព្រៃឈើ អនុផលព្រៃឈើ ចំណីសត្ត ជាអាទ៍។

ផែនការគ្រប់គ្រងបរិស្ថាន (Environmental Management Plan)

សំដៅដល់ផែនការដែលមានចែងនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដែលបានកំណត់ពីវិធានការការពារ និងកាត់បន្ថយហេតុប៉ះពាល់ ការទទួលខុសត្រូវ និងកាលវិកាគសម្រាប់អនុវត្ត តាមដាន និងវាយតម្លៃហេតុប៉ះពាល់បរិស្ថានពីគម្រោង ដោយរួមបញ្ចូលទាំងផែនការហិរញ្ញវត្ថុសម្រាប់សកម្មភាពបរិស្ថានក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិ និងបញ្ចប់គម្រោង។

មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ (Wildlife Rescue Center)

សំដៅដល់ទីតាំងមួយដែលមានគោលបំណង៖

- ស្តារ(ព្យាបាល) សត្វព្រៃដែលរងរបួស និងលែងសត្វព្រៃនោះទៅក្នុងព្រៃវិញ
- ទទួលសត្វព្រៃដែលរឹបអូសបាន និងថែទាំពួកវារហូតដល់ពេល ដែលគេអាចនាំពួកវាទៅកាន់កន្លែងដើមវិញ ឬអាចលែងបាន
- ផ្តល់ការថែទាំរយៈពេលវែងសម្រាប់សត្វព្រៃ ដែលមិនអាចបញ្ជូនត្រឡប់ទៅក្នុងព្រៃវិញ និង
- អនុវត្តការបង្កាត់ពូជសត្វបង្ខាំងទុកសម្រាប់គោលបំណងអភិរក្ស។

មុខងារកម្មប្រព័ន្ធអេកូឡូស៊ី (Ecosystem functioning)

សំដៅដល់ការបង្កើតឡើងនូវដំណើរការនានា ដែលកំណត់ដោយអន្តរកម្មផ្សេងៗក្នុងចំណោមសហគមន៍ជីវសាស្ត្រ ទាំងប្រភេទក្នុងស្រុក ទាំងប្រភេទក្រៅស្រុក ទាំងដំណើរការជីវូបសាស្ត្រ ដូចជា និយ័តកម្មទឹកនិងការបង្កើតឡើងវិញនូវដីសារធាតុចិញ្ចឹម។

មូលនិធិបរិស្ថាននិងសង្គម (Environmental and Social Fund)

សំដៅដល់មូលនិធិដែលទទួលបានពីកិច្ចគាំពារបរិស្ថាន ដៃគូអភិវឌ្ឍ អំណោយសប្បុរសជន ម្ចាស់គម្រោងនិយោគ ដែលបានដាក់ពាក្យស្នើសុំមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិដើម្បីសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងដែលបានស្នើសុំ និងពីកម្រៃផ្សេងៗទៀត។

មេត្រីបរិស្ថាន (Environmentally Friendly)

សំដៅដល់ការអនុវត្តច្បាប់ ផលិតកម្ម សេវាកម្ម និងបច្ចេកវិទ្យាដែលទ្រទ្រង់ដល់កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការគ្រប់គ្រងធនធានធម្មជាតិ និងការរស់នៅប្រកបដោយចីរភាព។

ម្ចាស់សំណល់ (Waste Owner)

សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបង្កើតសំណល់ពីសកម្មភាពផលិតកម្ម អាជីវកម្ម សេវាកម្ម រួមទាំងសកម្មភាពរស់នៅប្រចាំថ្ងៃ។

រដ្ឋបាលថ្នាក់ក្រោមជាតិ (Sub-national Administration)

សំដៅដល់រដ្ឋបាលនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ដែលទទួលបន្ទុកគ្រប់គ្រងកិច្ចការណាមួយដែលស្របច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

រុក្ខជាតិព្រៃ (Wild flora)

សំដៅដល់ប្រភេទរុក្ខជាតិដែលមិនត្រូវបានគេដាំរួមទាំងរូបធាតុលូតលាស់របស់វា កកើតឡើងនៅក្នុងប្រព័ន្ធអេកូឡូស៊ី និងជម្រកធម្មជាតិ ដោយពុំមានឬមានក្នុងកម្រិតកំណត់នូវឥទ្ធិពលរបស់មនុស្សក្នុងការកកើតមាននិងការបន្តពូជរបស់វា។

ល ទ ស

លិខិតបទដ្ឋានអន្តរជាតិ (Internation Instrument)

សំដៅដល់សន្ធិសញ្ញា អនុសញ្ញា ពិធីសារ កិច្ចព្រមព្រៀងថ្នាក់តំបន់ ឬអន្តរជាតិ ឬ ច្បាប់អន្តរជាតិផ្សេងទៀត។

លិខិតអនុញ្ញាតបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (Emission Permit)

សំដៅដល់ការកំណត់កម្រិតនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់(មិនអាចផ្ទេរ តែអាចធ្វើពាណិជ្ជកម្មបាន)ដោយអាជ្ញាធរមានសមត្ថកិច្ចដូចជា ស្ថាប័នអន្តរជាតិ ស្ថាប័នថ្នាក់កណ្តាលឬមូលដ្ឋាន ទៅកាន់អង្គភាពថ្នាក់តំបន់(ឬប្រទេស ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ) ឬអង្គភាពតាមវិស័យ(ក្រុមហ៊ុន) ក្នុងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងបរិមាណជាក់លាក់មួយ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៥១១

លំហូរបរិស្ថាន (Environmental flow)

សំដៅដល់បរិមាណ ពេលវេលា និងគុណភាពនៃលំហូរទឹកចាំបាច់សម្រាប់ទ្រទ្រង់ប្រព័ន្ធអេកូឡូស៊ី ជីវភាពរស់នៅ និងសុខុមាលភាពរបស់ភាវៈរស់ ដែលពឹងផ្អែកលើប្រព័ន្ធអេកូឡូស៊ីទាំងនោះ។

លទ្ធកម្ម (Procurement)

សំដៅដល់ដំណើរការនៃការដេញថ្លៃរហូតដល់ពេលទទួលបានទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សា។

វិញ្ញាបនបត្រឯកភាពលើកិច្ចសន្យាការពារបរិស្ថាននិងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម

(Certificate on Environmental Protection Contract and Social Impact Assessment Report)

សំដៅដល់វិញ្ញាបនបត្រដែលចេញដោយក្រសួងស្ថាប័នទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិ ដោយផ្អែកទៅលើការវាយតម្លៃបរិស្ថានរបស់គម្រោង ដែលមានចែងនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ។

វិទ្យុសកម្ម (Radioactive)

សំដៅដល់ធាតុដែលបញ្ចេញថាមពលខ្ពស់ ក្នុងទម្រង់ជារលកអេឡិចត្រូម៉ាញេទិក(កាំរស្មីហ្គាម៉ាឬកាំរស្មីអ៊ិច) ឬភាគល្អិត(អាល់ហ្ហា បេតា ឬណឺត្រុង) ដែលមានថាមពលគ្រប់គ្រាន់អាចធ្វើអ៊ីយ៉ុងកម្មនៅពេលដែលឆ្លងកាត់មជ្ឈដ្ឋានណាមួយ។

សហគមន៍មូលដ្ឋាន (Local Community)

សំដៅដល់សហគមន៍ដែលជាជនជាតិដើមភាគតិច ឬមិនមែនជាជនជាតិដើមភាគតិចដែលរស់នៅទីតាំងណាមួយជាក់លាក់ ហើយបានបង្កើត ឬចងក្រង ឬមិនបានចងក្រងជាសហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ ឬសហគមន៍ផ្សេងទៀតដែលកំណត់ដោយច្បាប់។

សហគមន៍តំបន់ការពារធម្មជាតិ (Community Protected Area)

សំដៅដល់សហគមន៍មូលដ្ឋានដែលមានរចនាសម្ព័ន្ធជ្រើសតាំងរដ្ឋបាលមួយ ដែលមានការទទួលស្គាល់ពីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ក្នុងគោលបំណងចូលរួមរៀបចំ គ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ជាក់លាក់ណាមួយនៃតំបន់ការពារធម្មជាតិប្រកបដោយនិរន្តរភាព សំដៅចូលរួមលើកកម្ពស់ជីវភាពរបស់ប្រជាសហគមន៍មូលដ្ឋាន។

សហគមន៍ទេសចរណ៍ធម្មជាតិ (Ecotourism Community)

សំដៅដល់សហគមន៍មូលដ្ឋានមួយ ដែលជាម្ចាស់និងជាអ្នកគ្រប់គ្រងដ៏សំខាន់លើហេដ្ឋារចនាសម្ព័ន្ធនិងសកម្មភាពទេសចរណ៍ធម្មជាតិ ហើយសកម្មភាពទេសចរណ៍ទាំងនោះត្រូវធ្វើប្រតិបត្តិការដោយផ្អែកលើមូលដ្ឋាននៃការបែងចែកផលប្រយោជន៍ដោយផ្ទាល់ជាមួយនឹងសហគមន៍។

សារធាតុគីមីពុល (Toxic Chemical(s))

សំដៅដល់សារធាតុគីមី ឬក្រុមសារធាតុគីមី ដែលអាចបង្កការពុលដល់មនុស្ស សត្ច ឬបង្កគ្រោះថ្នាក់ដល់បរិស្ថាន ជីវៈចម្រុះ នៅពេលមានវត្តមាននៅក្នុងបរិស្ថាន។

សារធាតុគ្រោះថ្នាក់ (Hazardous Substance(s))

សំដៅដល់សារធាតុគីមី ឬក្រុមសារធាតុគីមី ដែលបង្កការពុលភ្លាមៗឬរ៉ាំរ៉ៃ បង្កគ្រោះថ្នាក់ បង្កការប៉ះពាល់ដល់កំណើតថ្មី ហើយដែលមានលក្ខណៈធន់នឹងការបំបែកធាតុក្នុងបរិស្ថាន ភាពអាចចម្លងចូលទៅក្នុងវដ្តអាហារ និងភាពអាចកកផ្ទុំនៅក្នុងសព៌ាង្គកាយមនុស្ស សត្ច និងជីវៈចម្រុះ។

សារធាតុបំពុល (Pollutant(s) / Pollutant Substance(s))

សំដៅដល់សារធាតុគីមី ក្រុមសារធាតុគីមី សំណល់ ផ្សែង ឧស្ម័ន ក្លិន ធូលី ឬកម្តៅ ដែលធ្លាក់ចូលទៅក្នុងបរិស្ថានដោយសកម្មភាពរបស់មនុស្សតាមរយៈការបញ្ចេញចោល ការលេចធ្លាយ ឬដោយសកម្មភាពធម្មជាតិ ធ្វើឱ្យកាណភាពបរិស្ថានថយចុះ ឬអាចបង្កគ្រោះថ្នាក់ដល់បរិស្ថាន ជីវៈចម្រុះ មនុស្ស និងសត្ច។

សុពលភាព/សុពលកម្ម (Validation)

សំដៅដល់ដំណើរការនៃការវាយតម្លៃឯកភាពជ្រួមួយទៅលើសកម្មភាពគម្រោងយន្តការអភិវឌ្ឍស្អាត ឬសកម្មភាពតាមកម្មវិធីដោយអង្គភាពទទួលបន្ទុកប្រតិបត្តិដោយធ្វើការផ្ទៀងផ្ទាត់វិធាន និងលក្ខខណ្ឌតម្រូវរបស់យន្តការអភិវឌ្ឍស្អាតទៅនឹងលក្ខខណ្ឌតម្រូវនៃការរៀបចំឯកសារគម្រោង ឬឯកសារសកម្មភាពលម្អិតរបស់កម្មវិធី និងឯកសារសកម្មភាពលម្អិតនៃគម្រោងតាមផ្នែក។

សួនរុក្ខជាតិតាមសាស្ត្រ (Botanic Garden)

សំដៅដល់សួនរុក្ខជាតិដែលត្រូវបានដាំក្នុងគោលបំណងសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងដាក់តាំងបង្ហាញសម្រាប់សាធារណជនទស្សនា ឬជាសួនដែលធ្វើការប្រមូល ការដាំដុះ ការអភិរក្ស និងការតាំងបង្ហាញបណ្តាប្រភេទរុក្ខជាតិដែលមានពាសពេញសកលលោក ដោយមានដាក់ស្លាកឈ្មោះ និងប្រភពរបស់វា។

សេវាអគ្គិសនី (Electricity Services)

សំដៅដល់ការផលិត ការបញ្ជូន និងការចែកចាយអគ្គិសនី ព្រមទាំងសេវាបន្ថែមឬបន្ទាប់បន្សំភ្ជាប់ជាមួយសកម្មភាពទាំងនេះ។

សំណល់គ្រោះថ្នាក់ (Hazardous Waste)

សំដៅដល់សំណល់ ដែលមានភាពគ្រោះថ្នាក់ធ្ងន់ធ្ងរភ្លាមៗ ឬរ៉ាំរ៉ៃដល់សុខភាពមនុស្ស សត្វ បរិស្ថាន ឬបង្កការខូចខាតទ្រព្យសម្បត្តិ មានជាអាទិ៍ ភាពងាយឆាបឆេះ ភាពងាយបង្កប្រតិកម្ម ភាពងាយបង្កច្រេះកាត់ ងាយបង្កជំងឺឆ្លង ដែលតម្រូវឱ្យធ្វើការគ្រប់គ្រងដាច់ដោយឡែកពីសំណល់ធម្មតា។

ស្លាកមេត្រីបរិស្ថាន (Environmentally Friendly Label(s))

សំដៅដល់រូបសញ្ញា ដែលមានលក្ខណៈជាកំណត់តូចៗបញ្ជាក់ពីការចូលរួមប្រតិបត្តិបមាណីយមេត្រីបរិស្ថានដែលចេញដោយក្រសួងស្ថាប័នទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិសម្រាប់បិទភ្ជាប់លើផលិតផលនានា។

ស្វ័យតាមដានត្រួតពិនិត្យ(សំណល់) (Self-Monitoring)

សំដៅដល់សកម្មភាពត្រួតពិនិត្យការបំពុលបរិស្ថាន ដែលអនុវត្តដោយម្ចាស់ ឬអ្នកទទួលខុសត្រូវប្រកពបំពុលតាមរយៈការបំពាក់ឧបករណ៍តាមដានស្វ័យប្រវត្តិ ប្រព័ន្ធគ្រប់គ្រងទិន្នន័យ ជាអាទិ៍។

ហ អ ឧ

ហិរញ្ញវត្ថុបៃតង (Green Finance)

សំដៅដល់ការវិនិយោគហិរញ្ញវត្ថុ ចូលទៅក្នុងគម្រោងអភិវឌ្ឍនិង/ឬគំនិតផ្តួចផ្តើមប្រកបដោយចីរភាព សម្រាប់ផលិតផលបរិស្ថាន និងគោលនយោបាយដែលមានការលើកទឹកចិត្តដល់ការអភិវឌ្ឍប្រកបដោយចីរភាព។

ហេតុប៉ះពាល់បរិស្ថាន (Environmental Impact)

សំដៅដល់ហេតុប៉ះពាល់អវិជ្ជមាននិងវិជ្ជមានសំខាន់ៗទៅលើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម ដែលបង្កឡើងពីសកម្មភាពគម្រោងដោយផ្ទាល់ក្តីឬដោយប្រយោលក្តី។

អគារបៃតង (Green Building)

សំដៅដល់សំណង់ឬអគារដែលមាននិរន្តរភាព ទាំងរចនាសម្ព័ន្ធ ទាំងការអនុវត្តដំណើរការដែលមានការទទួលខុសត្រូវដល់បរិស្ថាននិងធនធាន ដែលមានប្រសិទ្ធភាពនៅក្នុងវដ្តជីវិតរបស់អគារពីការប្រើប្រាស់ទឹកនិងអគ្គិសនីដោយសន្សំសំចៃ ការរៀបចំផែនការរចនាអគារ ការសាងសង់ ការថែទាំ ការជួសជុល និងការបំផ្លាញ។

អនុផលធនធានធម្មជាតិ (Natural Resource By-products)

សំដៅដល់ផលឬផលិតផលដែលបានពីតំបន់ការពារធម្មជាតិ ដែលរាប់បញ្ចូលអនុផលព្រៃឈើ ជាអាទិ៍ វល្លិ ស្មៅ ឫស្សី ផ្កា ឬផ្លែរុក្ខជាតិ រុក្ខជាតិឱសថ ស្មៅ ត្រពាំង សម្រាប់បម្រើឱ្យជីវភាពរបស់ប្រជាជន។

អាជ្ញាធរមានសមត្ថកិច្ច (Competent Authority)

សំដៅដល់អាជ្ញាធរនៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងដែនដី ឬដឹកនាំ គ្រប់គ្រង និងចាត់ចែងកិច្ចការអ្វីមួយតាមវិស័យជាក់លាក់ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ឧទ្យានជាតិ (National Park)

សំដៅដល់តំបន់ធម្មជាតិក្នុងដែនដីគោកនិង/ឬដែនទឹក ដែលត្រូវបានកំណត់ដើម្បី៖

ក- ការពារតួនាទីខាងផ្នែកប្រព័ន្ធអេកូឡូស៊ីមួយឬច្រើនរបស់តំបន់ដែលបានកំណត់ សម្រាប់ជាប្រយោជន៍ដល់មនុស្សគ្រប់ជំនាន់។

ខ- កម្រិតដល់ការប្រើប្រាស់ដែលអាចធ្វើឱ្យខូចខាតឬបំផ្លិចបំផ្លាញដល់ធនធានដីវៈចម្រុះ ធនធានធម្មជាតិ ធនធានវប្បធម៌ និងមុខងារតួនាទីរបស់តំបន់នោះជាមួយនឹងគោលបំណងនៃការកំណត់តំបន់។

គ- ផ្តល់ជាមូលដ្ឋានសម្រាប់ការកម្សាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងជំនឿដែលគ្រប់សកម្មភាពទាំងនេះ ពុំបង្កការគម្រាមកំហែងដល់បរិស្ថានធម្មជាតិនិងវប្បធម៌នៅក្នុងមូលដ្ឋាន។

ឧទ្យានជាតិសមុទ្រ (National Marine Park)

សំដៅដល់តំបន់ឆ្នេរសមុទ្រទទួលឥទ្ធិពលជំនោរសមុទ្រលាយឡំជាមួយនឹងទឹកពីព្រៃភ្នំ រួមទាំងកោះគ្របដណ្តប់ដោយព្រៃឈើ រុក្ខជាតិ សត្វព្រៃ និងមច្ឆជាតិគ្រប់ប្រភេទមានលក្ខណៈប្រវត្តិសាស្ត្រ និងតម្លៃវប្បធម៌ ហើយតំបន់នេះត្រូវបានទទួលស្គាល់ដោយច្បាប់ និងគ្រប់គ្រងឱ្យមានប្រសិទ្ធភាព។

ឧស្ម័នផ្ទះកញ្ចក់ (Greenhouse Gas)

១- សំដៅដល់ឧស្ម័នដែលមាននៅក្នុងបរិយាកាស ដែលកើតឡើងដោយធម្មជាតិឬដោយសកម្មភាពមនុស្ស ហើយស្រូបយកនិងបញ្ចេញរស្មីតាមជំហានរលកជាក់លាក់ ក្នុងជំហានរលកនៃវិកាយរស្មីកម្តៅក្រហមអាំងហ្វ្រារ៉ែដែលកាយចេញពីផ្ទៃផែនដី បរិយាកាស និងពពក។ បាតុភូតទាំងនេះបង្កឱ្យមានផលផ្ទះកញ្ចក់។

២- ចំហាយទឹក ឧស្ម័នកាបូនិក ឌីអាសូតម៉ូណូអុកស៊ីត មេតាន និងអូហ្សូន ជាឧស្ម័នផ្ទះកញ្ចក់ចម្បងៗនៅក្នុងបរិយាកាសរបស់ផែនដី។ ក្រៅពីនេះ មានឧស្ម័នផ្ទះកញ្ចក់មួយចំនួនក្នុងបរិយាកាស ដែលបង្កើតឡើងដោយមនុស្សទាំងស្រុងដូចជា ហាឡូកាបូ និងសារធាតុដទៃទៀតដែលផ្ទុកក្លរនិងប្រូម គឺស្ថិតក្រោមការគ្រប់គ្រងនៃពិធីសារម៉ុងរ៉េអាល់។ ក្រៅពីឧស្ម័នកាបូនិក ឌីអាសូតម៉ូណូអុកស៊ីត និងមេតាន ពិធីសារក្យូតូ គ្រប់គ្រងឧស្ម័នផ្ទះកញ្ចក់ដទៃទៀតដូចជា ស៊ុលហ្វ អ៊ិចសាហ្វ្លុយអរីត និងពែរហ្វ្លុយអ៊ូកាបូ។

ឧស្សាហកម្មនិស្សារណកម្ម (Extractive Industry)

សំដៅដល់ឧស្សាហកម្មប្រេង ឧស្ម័ន រ៉ែ និងលោហៈនានា។



បញ្ចប់

ព្រះរាជក្រម

នស/រកម/០៦២៣/០០៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្ងានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ងហោតាស កម្ពុជឯករាជរដ្ឋបូរណាសន្តិ សុតមន្តណា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្មអាស៊ាន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុង

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៥១៥

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើ
កិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មអាស៊ាន

មាត្រា១ ..

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មអាស៊ាន ដែលបានចុះហត្ថលេខានៅរដ្ឋធានីម៉ានីលនៃសាធារណរដ្ឋហ្វីលីពីន នាថ្ងៃទី៧ ខែតុលា ឆ្នាំ២០២០ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

មាត្រា២ ..

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។

ថ្ងៃ ព្រហស្បតិ៍ ១២កើត ខែ បឋមាសាឍ ឆ្នាំជោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០២៣

ឧត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមទ្បាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

អភិឆ្ពិនីតិកោសលបណ្ឌិត ប៊ិន ឈិន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប៉ាន សូរស័ក្តិ

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មអាស៊ាន

រដ្ឋាភិបាលនៃព្រុយណេ ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ ម៉ាឡេស៊ី សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋ សិង្ហបុរី ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម រដ្ឋសមាជិកនៃសមាគម ប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ដែលតទៅនេះហៅកាត់ជារួមថា "បណ្តារដ្ឋសមាជិក" ឬហៅកាត់ រដ្ឋនីមួយៗថា "រដ្ឋសមាជិក"

ដោយកត់សម្គាល់ កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម ដែលបានចុះហត្ថលេខាដោយ រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន (AEM) នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៥ នៅទីក្រុងបាងកក ប្រទេសថៃ (ដែលតទៅនេះហៅកាត់ថា "AFAS") និងពិធីសារអនុវត្តន៍ជាបន្តបន្ទាប់របស់កិច្ចព្រមព្រៀងនេះ ដែល មានគោលបំណង ពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យសេវាកម្មក្នុងចំណោមបណ្តារដ្ឋសមាជិក លុបបំបាត់ឱ្យបានច្រើនបំផុតលើការរឹតត្បិតទាំងឡាយ ចំពោះពាណិជ្ជកម្មសេវាកម្មក្នុងចំណោម បណ្តារដ្ឋសមាជិក និងធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្ម តាមរយៈការពង្រីកភាពស៊ីជម្រៅ និងវិសាលភាពនៃការធ្វើសេរីភាវូបនីយកម្មឱ្យលើសពីអ្វី ដែលបានធ្វើឡើងដោយបណ្តារដ្ឋសមាជិក នៅក្រោមកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម (GATS)

ដោយពិចារណា លើអាណត្តិរបស់ក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ានលើកទី៧ ដែលបាន ប្រព្រឹត្តទៅនៅថ្ងៃទី២ ខែមេសា ឆ្នាំ២០១២ នៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យ ឡើងវិញ និងលើកកម្ពស់កិច្ចព្រមព្រៀងAFAS ដែលមានជាធរមាន ក្នុងការលើកកម្ពស់សមាហរណកម្ម សេដ្ឋកិច្ចនិងវិស័យសេដ្ឋកិច្ចអាស៊ាន ក្នុងន័យដូចគ្នាដែលអាស៊ានបានផ្លាស់ប្តូរកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីតំបន់វិនិយោគអាស៊ាន ព្រមទាំងកិច្ចព្រមព្រៀងអាស៊ានសម្រាប់ការជំរុញនិងការការពារវិនិយោគ ទៅជាកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន (ACIA) និងកិច្ចព្រមព្រៀងស្តីពីគម្រោងអនុគ្រោះ ពន្ធគយប្រកបដោយប្រសិទ្ធភាពជារួមសម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន ទៅជាកិច្ចព្រមព្រៀង ស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន

ដោយពិចារណាផងដែរ ទៅលើគោលការណ៍ណែនាំ និងគោលបំណង ក្នុងការលើកកម្ពស់ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មអាស៊ាន (ATISA) ដែលបានអនុម័តនៅកិច្ចប្រជុំAEM លើកទី៤៤ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ នៅទីក្រុងសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា

ដោយកត់សម្គាល់ លើសេចក្តីសម្រេចរបស់កិច្ចប្រជុំAEM លើកទី៤៨ ដែលបានប្រព្រឹត្តទៅនៅ ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៦ នៅទីក្រុងវៀងចន្ទន៍ ប្រទេសឡាវ ដែលបានណែនាំឱ្យមន្ត្រីពាក់ព័ន្ធ ពិនិត្យលទ្ធភាពក្នុងការប្រើប្រាស់វិធីសាស្ត្របែបបញ្ជីអវិជ្ជមាន ដែលអាចអនុវត្តបានក្រោមកិច្ចព្រមព្រៀង TISA ដោយពិចារណាលើអាណត្តិរបស់ផែនការលម្អិតសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥ និង ដំណើរការចរចាដែលកំពុងបន្តធ្វើនៅក្រោមក្របខ័ណ្ឌផ្សេងៗទៀត

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ដោយទទួលស្គាល់ថា កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងតំបន់អាស៊ាននឹងជានាទូវក្របខ័ណ្ឌពាណិជ្ជកម្មសេរីមួយសម្រាប់ពាណិជ្ជកម្មសេវាកម្ម ដែលនឹងពង្រឹងនិងលើកកម្ពស់ដល់ពាណិជ្ជកម្មសេវាកម្មក្នុងចំណោមបណ្តារដ្ឋសមាជិក

ដោយអះអាងជាថ្មី អំពីការសន្យារបស់យើងចំពោះវិធាននិងគោលការណ៍នានាក្រោមកិច្ចព្រមព្រៀង GATS ព្រមទាំងកត់សម្គាល់លើមាត្រាV នៃកិច្ចព្រមព្រៀងGATS ដែលអនុញ្ញាតដល់ការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្មរវាងឬក្នុងចំណោមបណ្តាភាគី ក្រោមកិច្ចព្រមព្រៀងសមាហរណកម្មសេដ្ឋកិច្ច

បានព្រមព្រៀងគ្នាដូចខាងក្រោម៖

ផ្នែកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១
គោលបំណង

គោលបំណងនៃកិច្ចព្រមព្រៀងនេះគឺដើម្បី៖

(ក) ពង្រឹងការតភ្ជាប់សេដ្ឋកិច្ចនិងផ្តល់កាលានុវត្តភាពកាន់តែច្រើន សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច

(ខ) បង្កើនពាណិជ្ជកម្មនិងការវិនិយោគលើវិស័យសេវាកម្ម ព្រមទាំងបង្កើតទីផ្សារឱ្យកាន់តែទូលំទូលាយ និងសេដ្ឋកិច្ចមាត្រដ្ឋានកាន់តែធំ

(គ) កាត់បន្ថយរបាំងពាណិជ្ជកម្មនិងការវិនិយោគក្នុងវិស័យសេវាកម្ម និងបង្កើតបរិយាកាសធុរកិច្ចដែលអាចព្យាករបាន

(ឃ) ពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចរវាងបណ្តារដ្ឋសមាជិកតាមរយៈ៖ ការជំរុញនិងការសម្រួលដល់ការប្រើប្រាស់នូវកាលានុវត្តភាពដ៏ទូលំទូលាយ ដែលផ្តល់ដោយកិច្ចព្រមព្រៀងនេះ ការជំរុញកិច្ចសហប្រតិបត្តិការផ្នែកនិយ័តកម្ម ការបង្កើតកិច្ចសហប្រតិបត្តិការក្នុងវិស័យអភិវឌ្ឍន៍ធនធានមនុស្ស និងការបង្កើនការចូលរួមរបស់សហគ្រាសធុនតូចនិងមធ្យមនៅក្នុងសកម្មភាពពាណិជ្ជកម្មនិងការវិនិយោគ *ជាដើម* និង

(ង) កាត់បន្ថយគម្លាតអភិវឌ្ឍន៍រវាងបណ្តារដ្ឋសមាជិក ដើម្បីអាចសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ប្រកបដោយសមធម៌ គុណ្យភាព និងចីរភាព។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា២
វិសាលភាព

១. កិច្ចព្រមព្រៀងនេះអនុវត្តចំពោះវិធានការនានាចាត់ឡើងដោយបណ្តារដ្ឋសមាជិក ដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម។

២. កិច្ចព្រមព្រៀងនេះមិនត្រូវអនុវត្តចំពោះ៖

(ក) សេវាកម្មដែលត្រូវបានផ្តត់ផ្តង់ដោយប្រើប្រាស់សិទ្ធិអំណាចដែលផ្តល់ដោយរដ្ឋាភិបាលនៅក្នុងដែនដីនៃរដ្ឋសមាជិកនីមួយៗ

(ខ) ច្បាប់ បទប្បញ្ញត្តិ ឬលក្ខខណ្ឌតម្រូវនានា ដែលគ្របដណ្តប់លើលទ្ធកម្មដោយភ្នាក់ងាររដ្ឋាភិបាលចំពោះសេវាកម្មទាំងឡាយ ដែលត្រូវបានទិញសម្រាប់គោលបំណងរដ្ឋាភិបាលហើយមិនស្ថិតក្នុងរូបភាពនៃការលក់បន្តបែបពាណិជ្ជកម្ម ឬក៏មិនស្ថិតក្នុងរូបភាពនៃការប្រើប្រាស់ដើម្បីផ្តត់ផ្តង់សេវាកម្មដល់ការលក់បែបពាណិជ្ជកម្ម

(គ) តឹរនាវាចរណ៍

(ឃ) ឧបត្ថម្ភធននិងជំនួយ និង

(ង) សិទ្ធិចរាចរណ៍ផ្លូវអាកាស បើទោះបីជាត្រូវបានអនុញ្ញាតក៏ដោយ ឬសេវាកម្មដែលពាក់ព័ន្ធដោយផ្ទាល់នឹងការអនុវត្តសិទ្ធិចរាចរណ៍ និង(ច) សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស លើកលែងតែសេវាកម្មដែលគាំទ្រដល់ការដឹកជញ្ជូនតាមផ្លូវអាកាស ដូចមានចែងនៅក្នុងឧបសម្ព័ន្ធស្តីពីសេវាកម្មដែលគាំទ្រដល់ការដឹកជញ្ជូនតាមផ្លូវអាកាស។

មាត្រា៣
ទំនាក់ទំនងនឹងកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន

១. កិច្ចព្រមព្រៀងACIA ដែលបានចុះហត្ថលេខានៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ នៅទីក្រុងឆាអាម ព្រះរាជាណាចក្រថៃ ព្រមទាំងការធ្វើវិសោធនកម្មជាបន្តបន្ទាប់របស់កិច្ចព្រមព្រៀងនេះ មិនអនុវត្តចំពោះវិធានការទាំងឡាយណា ដែលអនុម័តដោយឬរក្សាទុកដោយរដ្ឋសមាជិកណាមួយដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀងនេះឡើយ។

២. ថ្វីបើមានចែងនៅក្នុងកថាខណ្ឌ១ ក្នុងគោលបំណងនៃការការពារវិនិយោគពាក់ព័ន្ធនឹងការផ្តត់ផ្តង់សេវាកម្មតាមវត្តមានពាណិជ្ជកម្ម នោះមាត្រា១១ (ប្រព្រឹត្តិកម្មនៃការវិនិយោគ) មាត្រា១២ (សំណងក្នុងករណីមានការលយុគ) មាត្រា១៣ (ការផ្ទេរ) មាត្រា១៤ (ការជៀសហូត និងសំណង) មាត្រា១៥ (ឧបាទេសកម្ម) និងផ្នែក"ខ" (វិវាទវិនិយោគរវាងវិនិយោគិននិងរដ្ឋសមាជិកមួយ) នៃកិច្ចព្រមព្រៀងACIA ត្រូវបានអនុវត្ត *ហើយត្រូវយកមកអនុវត្តដូចគ្នា* ចំពោះវិធានការនានាដែលជះឥទ្ធិពលដល់ការផ្តត់ផ្តង់សេវាកម្ម ដោយអ្នកផ្តត់ផ្តង់សេវាកម្មណាមួយរបស់រដ្ឋសមាជិកផ្សេងទៀត ប៉ុន្តែនៅត្រឹមវិសាលភាពវិធានការទាំងនោះជាប់ពាក់ព័ន្ធនឹងការវិនិយោគ និងកាតព្វកិច្ចដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងACIA ប៉ុណ្ណោះ ។

ទំព័រទី៣

៣. ដើម្បីជៀសវាងការសង្ស័យ មាត្រា១១ (ប្រព្រឹត្តិកម្មនៃការវិនិយោគ) មាត្រា១២ (សំណងក្នុងករណីមានកលយុគ) មាត្រា១៣ (ការផ្ទេរ) មាត្រា១៤ (ការដកហូត និងសំណង) មាត្រា១៥ (ឧបាទេសកម្ម) និងផ្នែក"ខ" (វិវាទវិនិយោគរវាងវិនិយោគិននិងរដ្ឋសមាជិកមួយ) នៃកិច្ចព្រមព្រៀងACIA មិនត្រូវបានបញ្ចូលទៅក្នុងកិច្ចព្រមព្រៀងនេះឡើយ។

៤. ដើម្បីឱ្យកាន់តែច្បាស់ រាល់ការលើសនឹងប្រការណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ មិនត្រូវផ្អែកលើយន្តការដោះស្រាយវិវាទណាមួយក្រោមកិច្ចព្រមព្រៀងACIA ឡើយ រួមបញ្ចូលទាំងយន្តការដោះស្រាយវិវាទរវាងវិនិយោគិននិងរដ្ឋ ប៉ុន្តែមិនកំណត់ឡើយ។

មាត្រា៤
ទំនាក់ទំនងនឹងកិច្ចព្រមព្រៀងអាស៊ានស្តីពីបន្លាស់ទីរូបវន្តបុគ្គល

១. កិច្ចព្រមព្រៀងអាស៊ានស្តីពីបន្លាស់ទីរូបវន្តបុគ្គល ដែលបានចុះហត្ថលេខា នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១២ នៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា (ដោយហៅកាត់ថា "កិច្ចព្រមព្រៀងអាស៊ានស្តីពីMNP") ត្រូវអនុវត្តចំពោះវិធានការនានាចាត់ឡើងដោយរដ្ឋសមាជិក ដែលជះឥទ្ធិពលដល់ការផ្តត់ផ្តង់សេវាកម្ម តាមរយៈវត្តមានរូបវន្តបុគ្គលនៃរដ្ឋសមាជិកមួយ នៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត ហើយត្រូវមានអធិកភាពចំពោះករណីអសង្គតិភាពណាមួយទៅនឹងកិច្ចព្រមព្រៀងនេះ។

២. ដោយយោងទៅតាមប្រការទាំងឡាយនៅក្រោមផ្នែកទី២ និងទី៣ នៃកិច្ចព្រមព្រៀងនេះ កិច្ចព្រមព្រៀងអាស៊ានស្តីពីMNP ត្រូវមានអធិកភាព និងត្រូវអនុវត្តទាំងស្រុងលើវិធានការដែលជះឥទ្ធិពលដល់ការផ្តត់ផ្តង់សេវាកម្ម តាមរយៈវត្តមានរូបវន្តបុគ្គលនៃរដ្ឋសមាជិកមួយនៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត។

មាត្រា៥
និយមន័យ

សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ វាក្យសព្ទ៖

(ក) "**សេវាកម្មដែលត្រូវបានផ្តត់ផ្តង់ដោយប្រើប្រាស់សិទ្ធិអំណាចដែលផ្តល់ដោយរដ្ឋាភិបាល**" សំដៅដល់ រាល់សេវាកម្មទាំងឡាយ ដែលត្រូវបានផ្តត់ផ្តង់ក្នុងរូបភាពដែលមិនមែនជាការធ្វើពាណិជ្ជកម្ម ឬការប្រកួតប្រជែងជាមួយអ្នកផ្តត់ផ្តង់សេវាមួយឬច្រើនផ្សេងទៀត។

(ខ) "**វត្តមានពាណិជ្ជកម្ម**" សំដៅដល់ បែបផែនទាំងឡាយនៃការបង្កើតស្ថាប័នធុរកិច្ច ឬស្ថាប័នវិជ្ជាជីវៈ រួមទាំងតាមរយៈ៖

(i) ការបង្កើត ការទិញយក ឬការរក្សាទុកនូវនីតិបុគ្គលណាមួយ ឬ

(ii) ការបង្កើតឬការរក្សាទុកនូវសាខាឬការិយាល័យតំណាងណាមួយ

ទៅក្នុងដែនដីនៃរដ្ឋសមាជិកមួយ ក្នុងគោលបំណងផ្តត់ផ្តង់សេវាកម្ម។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

(គ) "**គ្រឿងបរិក្ខារកុំព្យូទ័រ**" សំដៅដល់ បណ្តុំសីវើកុំព្យូទ័រនិងឧបករណ៍ផ្ទុកឯកសារ សម្រាប់ការដំណើរការឬការផ្ទុកព័ត៌មានសម្រាប់ការប្រើប្រាស់បែបពាណិជ្ជកម្ម។

(ឃ) "**ពន្ធផ្តាល់**" រួមបញ្ចូលនូវបណ្តាពន្ធលើចំណូលសរុប លើមូលធនសរុប ឬលើសមាសធាតុនៃចំណូលឬនៃមូលធន រួមទាំងបណ្តាពន្ធលើអត្ថប្រយោជន៍ពីការផ្ទេរកម្មសិទ្ធិទ្រព្យសម្បត្តិ ពន្ធលើអចលនទ្រព្យ តេអមរតក និងអំណោយ និងពន្ធលើប្រាក់ឈ្នួលឬប្រាក់បៀវត្សន៍សរុប ដែលចំណាយដោយសហគ្រាស ក៏ដូចជាបណ្តាពន្ធលើការរួមសមូលធន។

(ង) "**កញ្ចប់ចុងក្រោយនៃកិច្ចព្រមព្រៀង AFAS**" សំដៅដល់ កញ្ចប់សន្យាទី១០ ដែលត្រូវបានធ្វើឡើងដោយបណ្តារដ្ឋសមាជិក ក្រោមកិច្ចព្រមព្រៀងAFAS ដែលបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីAEM និងកញ្ចប់សន្យាចុងក្រោយដែលចុះហត្ថលេខាដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន (AFM) និងរដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន (ATM) នៅមុនការចូលជាធរមាននៃតារាងវិធានការបដិលោម ស្របតាមមាត្រា១១ (វិធានការបដិលោម)។

(ច) "**GATS**" សំដៅដល់ កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម។

(ឆ) "**ការវិនិយោគ**" សំដៅដល់ ការវិនិយោគដែលត្រូវបានផ្តល់និយមន័យក្រោមកថាខណ្ឌ(គ) នៃមាត្រា៨ (និយមន័យ) នៃកិច្ចព្រមព្រៀងACIA ដូចដែលអាចនឹងត្រូវបានធ្វើវិសោធនកម្ម

(ជ) "**វិនិយោគិន**" សំដៅដល់ រូបវន្តបុគ្គលនៃរដ្ឋសមាជិកមួយ ឬនីតិបុគ្គលនៃរដ្ឋសមាជិកមួយដែលកំពុងធ្វើឬបានធ្វើការវិនិយោគនៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត។

(ឈ) "**នីតិបុគ្គល**" សំដៅដល់ នីតិបុគ្គលទាំងឡាយ ដែលត្រូវបានបង្កើតឬរៀបចំឡើងនៅក្រោមច្បាប់ជាធរមាននៃរដ្ឋសមាជិកមួយ ទោះជាក្នុងគោលបំណងដើម្បីប្រាក់ចំណេញឬក្នុងគោលបំណងដទៃទៀត ទោះជាកម្មសិទ្ធិឯកជនឬកម្មសិទ្ធិរបស់រដ្ឋាភិបាល រួមមានសាជីវកម្ម ក្រុមហ៊ុនបរធនបាលកិច្ច ក្រុមហ៊ុនសហកម្មសិទ្ធិ ក្រុមហ៊ុនចម្រុះទុន សហគ្រាសឯកកម្មសិទ្ធិ ឬសមាគម។

(ញ) "**នីតិបុគ្គលនៃរដ្ឋសមាជិកផ្សេងទៀត**" សំដៅដល់ នីតិបុគ្គលដែល៖

(i) ត្រូវបានបង្កើតឬរៀបចំឡើងនៅក្រោមច្បាប់របស់រដ្ឋសមាជិកផ្សេងទៀតនោះ ព្រមទាំងចូលរួមក្នុងប្រតិបត្តិការធុរកិច្ចជាជុំកំកួន នៅក្នុងដែនដីនៃរដ្ឋសមាជិកនោះ ឬរដ្ឋសមាជិកផ្សេងទៀត ឬ

(ii) ក្នុងករណីនៃការផ្តត់ផ្តង់សេវាកម្មតាមរយៈវត្តមានពាណិជ្ជកម្ម ដែលត្រូវបានកាន់កាប់ឬគ្រប់គ្រងដោយ៖

(១) រូបវន្តបុគ្គលនៃរដ្ឋសមាជិកនោះ ឬ

(២) នីតិបុគ្គលនៃរដ្ឋសមាជិកផ្សេងទៀតនោះ ដូចមានចែងក្នុងវាក្យខណ្ឌ(i)

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

(ជ) នីតិបុគ្គល៖

(i) "ត្រូវបានកាន់កាប់" ដោយបុគ្គលនៃរដ្ឋសមាជិកមួយ ប្រសិនបើកម្មសិទ្ធិលើសពី ៥០ភាគរយនៃភាគទុនរបស់នីតិបុគ្គលនោះ ត្រូវបានកាន់កាប់ដោយបុគ្គលនៃរដ្ឋសមាជិកនោះ

(ii) "ត្រូវបានគ្រប់គ្រង" ដោយបុគ្គលនៃរដ្ឋសមាជិកមួយ ប្រសិនបើបុគ្គលនោះមានអំណាចតែងតាំងសមាសភាពភាគច្រើននៃនាយករបស់ខ្លួន ឬមានសិទ្ធិដឹកនាំតាមផ្លូវច្បាប់នូវសកម្មភាពនានានៃនីតិបុគ្គលនោះ និង

(iii) "ត្រូវបានចងសម្ព័ន្ធ" ជាមួយបុគ្គលផ្សេងទៀត នៅពេលដែលនីតិបុគ្គលនោះ គ្រប់គ្រងឬត្រូវបានគ្រប់គ្រងដោយបុគ្គលផ្សេងទៀតនោះ ឬនៅពេលដែលទាំងនីតិបុគ្គលនិងបុគ្គលផ្សេងទៀតនោះ ត្រូវបានគ្រប់គ្រងដោយបុគ្គលដូចគ្នា។

(ឯ) "វិធានការ" សំដៅដល់ វិធានការទាំងឡាយចាត់ឡើងដោយរដ្ឋសមាជិកមួយ ទោះជាក្នុងទម្រង់ច្បាប់ បទប្បញ្ញត្តិ វិធាន នីតិវិធី សេចក្តីសម្រេច វិធានការរដ្ឋបាល ឬក្នុងទម្រង់ផ្សេងទៀត[1]

(ឌ) "វិធានការនានាចាត់ឡើងដោយរដ្ឋសមាជិក" សំដៅដល់ វិធានការទាំងឡាយណា ដែលធ្វើឡើងដោយ៖

(i) រដ្ឋាភិបាលនិងអាជ្ញាធរថ្នាក់មជ្ឈិម ថ្នាក់តំបន់ ឬថ្នាក់មូលដ្ឋានរបស់រដ្ឋសមាជិកមួយ និង

(ii) អង្គភាពក្រៅរដ្ឋាភិបាលនានា ដែលប្រើប្រាស់នូវអំណាចប្រតិភូកម្មដោយរដ្ឋាភិបាល ឬអាជ្ញាធរថ្នាក់មជ្ឈិម ថ្នាក់តំបន់ ឬថ្នាក់មូលដ្ឋានរបស់រដ្ឋសមាជិកមួយ

(ឍ) "វិធានការនានាចាត់ឡើងដោយរដ្ឋសមាជិក ដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម" រួមបញ្ចូលទាំងវិធានការនានា ដែលពាក់ព័ន្ធនឹង៖

(i) ការទិញ ការទូទាត់ ឬការប្រើប្រាស់សេវាកម្ម

(ii) ឱកាសទទួលបាននិងការប្រើប្រាស់នូវសេវាកម្មទាំងឡាយ ដែលត្រូវបានតម្រូវដោយរដ្ឋសមាជិកឱ្យផ្តល់នូវសេវាកម្មនោះដល់សាធារណជនទូទៅ ដោយវិធានការបែបនេះពាក់ព័ន្ធនឹងការផ្តត់ផ្តង់សេវាកម្ម និង

(iii) វត្តមាននៃបុគ្គល រួមទាំងវត្តមានពាណិជ្ជកម្មរបស់រដ្ឋសមាជិកមួយ ដើម្បីធ្វើការផ្តត់ផ្តង់សេវាកម្មនៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត

[1] វិធានការ។ ត្រូវរួមបញ្ចូលទាំងបណ្តាវិធានការពន្ធទៅតាមវិសាលភាពដូចមានគ្របដណ្តប់ដោយកិច្ចព្រមព្រៀង GATS។

ទំព័រទី៦

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

(ណ) "**អ្នកផ្តត់ផ្គង់សេវាផ្តាច់មុខ**" សំដៅដល់ បុគ្គល ស្ថាប័នសាធារណៈ ឬស្ថាប័នឯកជន ដែលនៅក្នុងទីផ្សារពាក់ព័ន្ធក្នុងដែនដីនៃរដ្ឋសមាជិកមួយ ត្រូវបានអនុញ្ញាតឬត្រូវបានបង្កើតឡើងជាផ្លូវការឬជាជរមានដោយរដ្ឋសមាជិកនោះ ឱ្យធ្វើជាអ្នកផ្តត់ផ្គង់តែមួយគត់នូវសេវាកម្មនោះ

(ត) "**រូបវន្តបុគ្គលនៃរដ្ឋសមាជិកផ្សេងទៀត**" សំដៅដល់ រូបវន្តបុគ្គលដែលស្ថិតក្រោមច្បាប់នៃរដ្ឋសមាជិកនោះ៖

(i) គឺជាជនជាតិឬពលរដ្ឋនៃរដ្ឋសមាជិកនោះ ឬ

(ii) មានសិទ្ធិស្នាក់នៅអចិន្ត្រៃយ៍នៅក្នុងដែនដីនៃរដ្ឋសមាជិកនោះ ករណីដែលទាំងរដ្ឋសមាជិកនោះនិងរដ្ឋសមាជិកដែលបុគ្គលនោះផ្តត់ផ្គង់សេវាកម្ម ទទួលស្គាល់និវេសនជនអចិន្ត្រៃយ៍ ហើយផ្តល់នូវប្រព្រឹត្តិកម្មចំពោះនិវេសនជនអចិន្ត្រៃយ៍របស់ខ្លួន ដូចគ្នាស្មើទាំងស្រុងទៅនឹងការផ្តល់នូវប្រព្រឹត្តិកម្មចំពោះជនជាតិខ្លួនពាក់ព័ន្ធនឹងវិធានការនានាដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម

(ថ) "**បុគ្គល**" សំដៅដល់ រូបវន្តបុគ្គល ឬនីតិបុគ្គល

(ទ) "**វិស័យ**" នៃសេវាកម្មមួយ សំដៅដល់៖

(i) ដោយយោងទៅនឹងការសន្យាតាមវិស័យ គឺជាអនុវិស័យមួយ ឬច្រើន ឬទាំងអស់នៃសេវាកម្មនោះ ដូចបានបញ្ជាក់នៅក្នុងតារាងសន្យាតាមវិស័យរបស់រដ្ឋសមាជិកមួយ

(ii) ម្យ៉ាងទៀត ជាវិស័យសេវាកម្មនោះទាំងមូល ដែលរួមបញ្ចូលនូវអនុវិស័យសេវាកម្មទាំងអស់របស់វា

(ធ) "**សេវាកម្ម**" រួមបញ្ចូលនូវសេវាកម្មទាំងឡាយនៅក្នុងវិស័យទាំងឡាយ លើកលែងតែសេវាកម្មដែលត្រូវបានផ្តត់ផ្គង់ដោយប្រើប្រាស់សិទ្ធិអំណាចដែលផ្តល់ដោយរដ្ឋាភិបាល

(ន) "**អ្នកប្រើប្រាស់សេវាកម្ម**" សំដៅដល់ បុគ្គលទាំងឡាយណាដែលទទួលយកឬប្រើប្រាស់សេវាកម្ម

(ប) "**សេវាកម្មរបស់រដ្ឋសមាជិកផ្សេងទៀត**" សំដៅដល់ សេវាកម្មណាមួយដែលត្រូវបានផ្តត់ផ្គង់៖

(i) ចេញពីឬនៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀតនោះ ឬក្នុងករណីដឹកជញ្ជូនផ្លូវសមុទ្រ ត្រូវបានផ្តត់ផ្គង់ដោយនាវាដែលបានចុះបញ្ជីក្រោមច្បាប់នៃរដ្ឋសមាជិកផ្សេងទៀតនោះ ឬដោយបុគ្គលណាមួយនៃរដ្ឋសមាជិកផ្សេងទៀតនោះ ដែលផ្តត់ផ្គង់សេវាកម្មតាមរយៈប្រតិបត្តិការរបស់នាវាណាមួយ និង/ឬការប្រើប្រាស់នាវានោះទាំងស្រុងឬដោយផ្នែក ឬ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

(ii) ដោយអ្នកផ្តត់ផ្តង់សេវាកម្មរបស់រដ្ឋសមាជិកផ្សេងទៀតនោះ ក្នុងករណីការផ្តត់ផ្តង់សេវាកម្មតាមរយៈវត្តមានពាណិជ្ជកម្ម ឬតាមរយៈវត្តមានរូបវន្តបុគ្គល

(ផ) "**អ្នកផ្តត់ផ្តង់សេវាកម្ម**" សំដៅដល់ បុគ្គលទាំងឡាយដែលធ្វើការផ្តត់ផ្តង់សេវាកម្ម[2]

(ព) "**ការផ្តត់ផ្តង់សេវាកម្ម**" រួមបញ្ចូលនូវផលិតកម្ម ការចែកចាយ ការធ្វើទីផ្សារ ការលក់ និងការផ្តល់សេវាកម្ម

(ភ) "**ពាណិជ្ជកម្មសេវាកម្ម**" សំដៅដល់ ការផ្តត់ផ្តង់សេវាកម្ម៖

(i) ចេញពីដែនដីនៃរដ្ឋសមាជិកមួយ ចូលទៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត ("ការផ្តត់ផ្តង់សេវាកម្មឆ្លងកាត់ព្រំដែន")

(ii) នៅក្នុងដែនដីនៃរដ្ឋសមាជិកមួយ ទៅដល់អ្នកប្រើប្រាស់សេវាកម្មនៃរដ្ឋសមាជិកផ្សេងទៀត ("ការប្រើប្រាស់សេវាកម្មនៅបរទេស");

(iii) ដោយអ្នកផ្តត់ផ្តង់សេវាកម្មនៃរដ្ឋសមាជិកមួយ តាមរយៈវត្តមានពាណិជ្ជកម្មនៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត ("វត្តមានពាណិជ្ជកម្ម");

(iv) ដោយអ្នកផ្តត់ផ្តង់សេវាកម្មនៃរដ្ឋសមាជិកមួយ តាមរយៈវត្តមានរូបវន្តបុគ្គលនៃរដ្ឋសមាជិកនៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត ("វត្តមានរូបវន្តបុគ្គល") និង

(ម) "**សិទ្ធធ្វើចរាចរ**" សំដៅដល់ សិទ្ធិទាំងឡាយសម្រាប់សេវាកម្មដែលមានក្នុងតារាងសន្យា ឬគ្មានក្នុងតារាងសន្យា ដើម្បីធ្វើប្រតិបត្តិការ និង/ឬ ដឹកអ្នកដំណើរ ទំនិញ និងបញ្ញើ ដើម្បីទទួលបានជាលាភការ ឬជាការជួលចេញពី ទៅកាន់ នៅក្នុង ឬពីលើដែនដីនៃរដ្ឋសមាជិកមួយ រួមបញ្ចូលទាំងគោលដៅបម្រើសេវាកម្ម ផ្លូវធ្វើប្រតិបត្តិការ ប្រភេទនៃចរាចរ សមត្ថភាពដែលត្រូវផ្តល់ ពន្ធគយដែលត្រូវយកព្រមជាមួយលក្ខខណ្ឌនានា និងលក្ខណៈវិនិច្ឆ័យនានាសម្រាប់ការកំណត់ក្រុមហ៊ុនអាកាសចរណ៍ រួមបញ្ចូលទាំងលក្ខណៈវិនិច្ឆ័យ ដូចជាតួលេខ ភាពជាម្ចាស់កម្មសិទ្ធិ និងការគ្រប់គ្រង។

ផ្នែកទី២
ភាពព្វកិច្ចស្នូល និងវិន័យ

មាត្រា៦
ប្រព្រឹត្តិកម្មជាតិ

១. រដ្ឋសមាជិកនីមួយៗ ត្រូវផ្តល់ដល់សេវាកម្មនិងអ្នកផ្តត់ផ្តង់សេវាកម្មរបស់រដ្ឋសមាជិកផ្សេងទៀត ពាក់ព័ន្ធនឹងរាល់វិធានការដែលជះឥទ្ធិពលដល់ការផ្តត់ផ្តង់សេវាកម្ម នូវប្រព្រឹត្តិកម្មដែលមាន

[2] ការណីដែលសេវាកម្មពុំត្រូវបានផ្តត់ផ្តង់ផ្ទាល់ដោយនីតិបុគ្គលណាមួយ ប៉ុន្តែត្រូវបានផ្តត់ផ្តង់តាមរយៈទម្រង់ផ្សេងៗនៃវត្តមានពាណិជ្ជកម្ម [illegible]ណាមួយ ឬការិយាល័យតំណាងណាមួយ នោះអ្នកផ្តត់ផ្តង់សេវាកម្ម (ឧទាហរណ៍ នីតិបុគ្គល) តាមរយៈវត្តមានបែបនេះ [illegible]ប្រព្រឹត្តិកម្មដែលផ្តល់ចំពោះអ្នកផ្តត់ផ្តង់សេវាកម្មទាំងឡាយនៅក្រោមកិច្ចព្រមព្រៀងនេះដែរ។ ប្រព្រឹត្តិកម្មបែបនេះ [illegible]ចំពោះវត្តមានពាណិជ្ជកម្មដែលសេវាកម្មត្រូវបានផ្តត់ផ្តង់ ហើយមិនចាំបាច់ផ្តល់ដល់ផ្នែកផ្សេងៗទៀតរបស់អ្នកផ្តត់ផ្តង់នោះ [illegible]ទីតាំងនៅក្រៅដែនដីដែលសេវាកម្មនោះត្រូវបានផ្តត់ផ្តង់ឡើយ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ភាពអនុគ្រោះមិនឱ្យតិចជាងប្រព្រឹត្តិកម្មដែលខ្លួនផ្តល់ ដោយស្ថិតក្នុងលក្ខខណ្ឌដូចគ្នា[3] ដល់សេវាកម្មនិងអ្នកផ្តត់ផ្តង់សេវាកម្មរបស់ខ្លួន។[4]

២. រដ្ឋសមាជិកមួយអាចបំពេញបានតាមលក្ខខណ្ឌតម្រូវនៃកថាខណ្ឌ១ តាមរយៈការផ្តល់ដល់សេវាកម្មនិងអ្នកផ្តត់ផ្តង់សេវាកម្មនៃរដ្ឋសមាជិកផ្សេងទៀត នូវប្រព្រឹត្តិកម្មជាផ្លូវការដូចគ្នាឬប្រព្រឹត្តិកម្មជាផ្លូវការខុសគ្នា ពីប្រព្រឹត្តិកម្មដែលខ្លួនផ្តល់ដល់សេវាកម្មនិងអ្នកផ្តត់ផ្តង់សេវាកម្មដូចគ្នារបស់ខ្លួន។

៣. ប្រព្រឹត្តិកម្មជាផ្លូវការដូចគ្នាឬជាផ្លូវការខុសគ្នា ត្រូវចាត់ទុកថាមានភាពអនុគ្រោះតិចជាង ប្រសិនបើវាបានកែប្រែលក្ខខណ្ឌប្រកួតប្រជែង ដោយផ្តល់ភាពអនុគ្រោះដល់សេវាកម្មឬអ្នកផ្តត់ផ្តង់សេវាកម្មរបស់រដ្ឋសមាជិកនោះ ធៀបនឹងសេវាកម្មឬអ្នកផ្តត់ផ្តង់សេវាកម្មដូចគ្នានៃរដ្ឋសមាជិកផ្សេងទៀត។

មាត្រា៧
ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត

១. រដ្ឋសមាជិកនីមួយៗ ត្រូវផ្តល់ដល់អ្នកផ្តត់ផ្តង់សេវាកម្មនៃរដ្ឋសមាជិកផ្សេងទៀត នូវប្រព្រឹត្តិកម្មដែលមានភាពអនុគ្រោះមិនឱ្យតិចជាងភាពអនុគ្រោះដែលខ្លួនផ្តល់ ដោយស្ថិតក្នុងលក្ខខណ្ឌដូចគ្នា ដល់អ្នកផ្តត់ផ្តង់សេវាកម្មនៃរដ្ឋសមាជិកណាមួយផ្សេងទៀត ឬរដ្ឋមិនមែនសមាជិក។

២. រដ្ឋសមាជិកនីមួយៗ ត្រូវផ្តល់ដល់សេវាកម្មដែលផ្តត់ផ្តង់ដោយរដ្ឋសមាជិកផ្សេងទៀត នូវប្រព្រឹត្តិកម្មដែលមានភាពអនុគ្រោះមិនឱ្យតិចជាងភាពអនុគ្រោះដែលខ្លួនផ្តល់ ដោយស្ថិតក្នុងលក្ខខណ្ឌដូចគ្នា ដល់សេវាកម្មដែលផ្តត់ផ្តង់នៅក្នុងដែនដីរបស់ខ្លួនដោយអ្នកផ្តត់ផ្តង់សេវាកម្មនៃរដ្ឋសមាជិកណាមួយផ្សេងទៀត ឬរដ្ឋមិនមែនសមាជិក។

៣. ដើម្បីឱ្យកាន់តែច្បាស់ ពាក់ព័ន្ធនឹងសេវាកម្មដែលស្ថិតក្នុងវិសាលភាពនៃកិច្ចព្រមព្រៀងនេះ ប្រព្រឹត្តិកម្មអនុគ្រោះទាំងឡាយណា ដែលផ្តល់ដោយរដ្ឋសមាជិកមួយដល់អ្នកផ្តត់ផ្តង់សេវាកម្មនៃរដ្ឋសមាជិកផ្សេងទៀតឬរដ្ឋមិនមែនសមាជិក ព្រមទាំងដល់សេវាកម្មរបស់រដ្ឋទាំងនោះ ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងឬកិច្ចរៀបចំនាពេលអនាគត ដែលរដ្ឋសមាជិកមួយគឺជាភាគីត្រូវធ្វើការផ្តល់បន្តដល់បណ្តារដ្ឋសមាជិកទាំងអស់ផងដែរ ដោយផ្អែកលើមូលដ្ឋានប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត។ កិច្ចព្រមព្រៀងនិងកិច្ចរៀបចំទាំងឡាយ ដែលបានបញ្ចប់ឬបានចុះហត្ថលេខា នាមុនការចុះហត្ថលេខានៃកិច្ចព្រមព្រៀងATISA និងវិសោធនកម្មទាំងឡាយក្នុងពេលអនាគតរបស់កិច្ចព្រមព្រៀងឬកិច្ចរៀបចំទាំងនោះ មិនត្រូវក្លាយជាកម្មវត្ថុចំពោះមាត្រានេះឡើយ។

---

[3] ដើម្បីឱ្យកាន់តែច្បាស់ ថាតើប្រព្រឹត្តិកម្មត្រូវបានផ្តល់ឱ្យក្នុង "លក្ខខណ្ឌដូចគ្នា" ឬយ៉ាងណា ក្រោមមាត្រា៦ (ប្រព្រឹត្តិកម្មជាតិ) ឬមាត្រា៧ (ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត) គឺវាអាស្រ័យទៅនឹងស្ថានភាពទាំងមូលនៃលក្ខខណ្ឌនានា រួមបញ្ចូលដ្ឋាន៉ាតីប្រព្រឹត្តិកម្មពាក់ព័ន្ធមានការវៃកញ្ចែកខុសគ្នារវាងសេវាកម្មឬអ្នកផ្តត់ផ្តង់សេវាកម្មដែរឬយ៉ាងណា ដោយផ្អែកលើមូលដ្ឋានវាលបញ្ចាំងសុខមាលភាពសាធារណៈស្របច្បាប់។

[4] ប្រការអ្វីនៅក្នុងមាត្រានេះ ត្រូវបានបកស្រាយដើម្បីតម្រូវឱ្យរដ្ឋសមាជិកណាមួយផ្តល់នូវសំណងទូទាត់ចំពោះគុណវិបត្តិប្រកួតប្រជែងណាមួយ ដែលជាលទ្ធផលចេញពីចរិតលក្ខណៈបរទេសនៃសេវាកម្មឬអ្នកផ្តត់ផ្តង់សេវាកម្មពាក់ព័ន្ធឡើយ។

ទំព័រទី៩

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៤. ប្រព្រឹត្តិកម្មដូចមានចែងក្នុងកថាខណ្ឌ១ដល់៣ ពុំត្រូវអនុវត្តចំពោះសេវាកម្មហិរញ្ញវត្ថុឡើយ ហើយមាត្រា១១ (ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត) នៃឧបសម្ព័ន្ធស្តីពីសេវាកម្មហិរញ្ញវត្ថុ ត្រូវអនុវត្តចំពោះសេវាកម្មហិរញ្ញវត្ថុ។

៥. ប្រការទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ពុំត្រូវបកស្រាយដើម្បីរាំងរដ្ឋសមាជិកណាមួយពីការប្រគល់ឬការផ្តល់នូវអត្ថប្រយោជន៍នានាដល់ប្រទេសជិតខាង ក្នុងគោលបំណងសម្រួលដល់ការដោះដូរនានា ដោយកំណត់ចំពោះតំបន់ដែលមានព្រំដែនជាប់គ្នា នូវសេវាកម្មដែលត្រូវបានផលិតនិងប្រើប្រាស់ក្នុងស្រុកឡើយ។

៦. ប្រសិនបើមានចែងក្នុងកថាខណ្ឌ១ដល់៥ ខាងលើ រដ្ឋសមាជិកពីរឬច្រើនអាចធ្វើការចរចានិងព្រមព្រៀងគ្នា ដើម្បីធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្មចំពោះវិស័យឬអនុវិស័យជាក់លាក់នានា ("រដ្ឋសមាជិកដែលចូលរួម")។ ការផ្តល់បន្តទាំងឡាយនូវប្រព្រឹត្តិកម្មអនុគ្រោះបែបនេះដល់រដ្ឋសមាជិកដែលនៅសេសសល់ ដោយផ្អែកលើមូលដ្ឋានប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត ត្រូវធ្វើឡើងតាមការស្ម័គ្រចិត្តត្រង់ផ្នែកណាដែលជារបស់រដ្ឋសមាជិកដែលចូលរួម។

៧. រដ្ឋសមាជិកដែលចូលរួមត្រូវផ្តល់ព័ត៌មានដល់រដ្ឋសមាជិកដែលនៅសេសសល់ តាមរយៈលេខាធិការដ្ឋានអាស៊ាន អំពីវឌ្ឍនភាពឬក៏លទ្ធផលនៃការចរចា។ រដ្ឋសមាជិកដែលមានបំណងចូលរួមក្នុងការចរចាដែលកំពុងបន្តក្នុងចំណោមរដ្ឋសមាជិកដែលចូលរួម អាចធ្វើបែបនេះបានដោយការពិគ្រោះយោបល់ជាមួយនឹងរដ្ឋសមាជិកដែលចូលរួម។

៨. រដ្ឋសមាជិកណាមួយ ដែលមិនមែនជាភាគីទៅនឹងកិច្ចព្រមព្រៀងណាមួយដែលសម្រេចបានអនុលោមតាមកថាខណ្ឌ៦ នាពេលសមស្របណាមួយ អាចក្លាយជាភាគីមួយនៃកិច្ចព្រមព្រៀងនោះ ដោយផ្តល់នូវការសន្យានៅត្រឹមកម្រិតប្រហាក់ប្រហែលគ្នាឬកម្រិតដែលអាចទទួលយកបានដល់រដ្ឋសមាជិកដែលចូលរួម។

មាត្រា៨
ច្រកចូលទីផ្សារ

បើទោះជាផ្អែកលើមូលដ្ឋាននៃផ្នែកណាមួយរបស់តំបន់ ឬផ្អែកលើមូលដ្ឋាននៃដែនដីទាំងមូលរបស់ខ្លួនក្តី រដ្ឋសមាជិកមួយមិនត្រូវរក្សាទុកឬអនុម័តនូវវិធានការទាំងឡាយណាដែលត្រូវបានចាត់ទុកថាជា៖

(ក) ការដាក់កំណត់ទៅលើចំនួនអ្នកផ្តត់ផ្តង់សេវាកម្ម ទោះជាក្នុងទម្រង់កូតាចំនួន ភាពផ្តាច់មុខ អ្នកផ្តត់ផ្តង់សេវាកម្មផ្តាច់មុខ ឬលក្ខខណ្ឌតម្រូវសម្រាប់ការពិចារណាលើតម្រូវការសេដ្ឋកិច្ច

(ខ) ការដាក់កំណត់ទៅលើតម្លៃសរុបនៃប្រតិបត្តិការសេវាកម្ម ឬទ្រព្យសកម្ម ក្នុងទម្រង់ជាកូតាចំនួន ឬលក្ខខណ្ឌតម្រូវសម្រាប់ការពិចារណាលើតម្រូវការសេដ្ឋកិច្ច

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

(គ) ការដាក់កំណត់ទៅលើចំនួនសរុបនៃការប្រតិបត្តិសេវាកម្ម ឬលើបរិមាណសរុបនៃទិន្នផលសេវាកម្ម គិតជាឯកតាលេខដែលបានរៀបចំឡើងក្នុងទម្រង់ជាកូតា ឬលក្ខខណ្ឌតម្រូវសម្រាប់ការពិចារណាលើតម្រូវការសេដ្ឋកិច្ច[5]

(ឃ) ការដាក់កំណត់ទៅលើចំនួនសរុបនៃរូបវន្តបុគ្គល ដែលអាចនឹងត្រូវបានជួលមកធ្វើការនៅក្នុងវិស័យសេវាកម្មជាក់លាក់ណាមួយ ឬដែលអ្នកផ្តត់ផ្តង់សេវាកម្មអាចនឹងជួលមកធ្វើការ ហើយជាបុគ្គលដែលចាំបាច់សម្រាប់និងដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការផ្តត់ផ្តង់សេវាកម្មជាក់លាក់ណាមួយ ក្នុងទម្រង់ជាកូតាចំនួន ឬលក្ខខណ្ឌតម្រូវ សម្រាប់ការពិចារណាលើតម្រូវការសេដ្ឋកិច្ច

(ង) វិធានការទាំងឡាយណាដែលរឹតត្បិត ឬតម្រូវចំពោះប្រភេទជាក់លាក់នៃនីតិបុគ្គល ឬក្រុមហ៊ុនចម្រុះទុន ដែលតាមរយៈវិធានការទាំងនោះ ទើបអ្នកផ្តត់ផ្តង់សេវាកម្មអាចផ្តល់សេវាកម្មណាមួយបាន និង

(ច) ការដាក់កំណត់ទៅលើការរួមចំណែកនៃមូលធនបរទេស ក្នុងទម្រង់ជាអត្រាភាគរយអតិបរមាដែលអនុញ្ញាតចំពោះភាគទុនបរទេស ឬលើតម្លៃសរុបនៃការវិនិយោគបរទេសជាលក្ខណៈបុគ្គលឬជាលក្ខណៈរួម។

មាត្រា៩
វត្តមានក្នុងស្រុក

រដ្ឋសមាជិកមួយមិនត្រូវដាក់លក្ខខណ្ឌតម្រូវ ដើម្បីឱ្យអ្នកផ្តត់ផ្តង់សេវាកម្មណាមួយរបស់រដ្ឋសមាជិកផ្សេងទៀត ធ្វើការបង្កើតឬរក្សាទុកនូវការិយាល័យតំណាងឬទម្រង់ទាំងឡាយនៃនីតិបុគ្គល ឬក្លាយជានិវេសនជន នៅក្នុងដែនដីរបស់ខ្លួន ដែលចាត់ទុកជាលក្ខខណ្ឌមួយសម្រាប់ការផ្តត់ផ្តង់សេវាកម្មឆ្លងកាត់ព្រំដែនឡើយ។[6]

មាត្រា១០
គណៈគ្រប់គ្រងជាន់ខ្ពស់និងក្រុមប្រឹក្សាភិបាល

១. រដ្ឋសមាជិកមួយមិនត្រូវដាក់លក្ខខណ្ឌតម្រូវ ដើម្បីឱ្យនីតិបុគ្គលណាមួយរបស់រដ្ឋសមាជិកនោះផ្តល់ការតែងតាំងនៅក្នុងតួនាទីថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ដល់រូបវន្តបុគ្គលនៃជនជាតិជាក់លាក់ណាមួយឡើយ។

---

[5] ការកត្រាខណ្ឌ(គ) មិនគ្របដណ្តប់លើវិធានការនានាចាត់ឡើងដោយរដ្ឋសមាជិក ដែលដាក់កម្រិតចំពោះធាតុចូលសម្រាប់ការផ្តត់ផ្តង់សេវាកម្មឡើយ។

[6] ឃ្មានអ្នកនៅក្នុងមាត្រានេះ ដែលត្រូវរាវាំងរដ្ឋសមាជិកមួយពីការអនុម័តនិងរក្សាទុកនូវវិធានការនិយតកម្មនានារបស់ខ្លួន ពាក់ព័ន្ធនឹងការដ្ឋប៉ីប្រាលនិងទីតាំងនៃគ្រឿងបរិក្ខារកុំព្យូទ័រឡើយ។

ទំព័រទី១១

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

២. រដ្ឋសមាជិកមួយអាចដាក់លក្ខខណ្ឌតម្រូវថា សមាសភាពភាគច្រើននៃក្រុមប្រឹក្សាភិបាលរបស់នីតិបុគ្គលណាមួយរបស់រដ្ឋសមាជិកនោះ គឺជាជនជាតិជាក់លាក់ណាមួយ ឬក៏ជានិវេសន៍ជន នៅក្នុងដែនដីរបស់រដ្ឋសមាជិកនោះ ប្រសិនបើលក្ខខណ្ឌតម្រូវបែបនេះមិនបន្ថយនូវលទ្ធភាពរបស់វិនិយោគិនក្នុងការអនុវត្តការគ្រប់គ្រងទៅលើការវិនិយោគរបស់ខ្លួន។

ផ្នែកទី៣
ការរក្សាសិទ្ធិ

មាត្រា១១
វិធានការបដិលោម

១. មាត្រា៦ (ប្រព្រឹត្តិកម្មជាតិ) មាត្រា៧ (ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត) មាត្រា៨ (ច្រកចូលទីផ្សារ) មាត្រា៩ (វត្តមានក្នុងស្រុក) និងមាត្រា១០ (គណៈគ្រប់គ្រងជាន់ខ្ពស់និងក្រុមប្រឹក្សាភិបាល) ពុំអនុវត្តចំពោះ៖

(ក) វិធានការបដិលោមដែលមានស្រាប់ទាំងឡាយ ដែលត្រូវបានរក្សាទុកដោយរដ្ឋសមាជិកមួយនៅ៖

(i) ថ្នាក់មជ្ឈិមរបស់រដ្ឋាភិបាល ដូចមានចែងក្នុងតារាងវិធានការបដិលោមរបស់ខ្លួនក្នុងឧបសម្ព័ន្ធI

(ii) ថ្នាក់តំបន់របស់រដ្ឋាភិបាល ដូចមានចែងក្នុងតារាងវិធានការបដិលោមរបស់ខ្លួនក្នុងឧបសម្ព័ន្ធI ឬ

(iii) រដ្ឋាភិបាលថ្នាក់មូលដ្ឋាន

(ខ) ការបន្តឬការកែប្រែថ្មីភ្លាមៗនៃវិធានការបដិលោមទាំងឡាយ ដូចមានចែងក្នុងវាក្យខណ្ឌ(ក) ឬ

(គ) ការធ្វើវិសោធនកម្មលើវិធានការបដិលោមណាមួយ ដូចមានចែងក្នុងវាក្យខណ្ឌ(ក) ដោយស្ថិតក្នុងវិសាលភាពដែលការធ្វើវិសោធនកម្មមិនបន្ថយនូវអនុលោមភាពនៃវិធានការនោះទៅនឹងមាត្រា៦ (ប្រព្រឹត្តិកម្មជាតិ) មាត្រា៧ (ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត) មាត្រា៨ (ច្រកចូលទីផ្សារ) មាត្រា៩ (វត្តមានក្នុងស្រុក) និងមាត្រា១០ (គណៈគ្រប់គ្រងជាន់ខ្ពស់និងក្រុមប្រឹក្សាភិបាល) ដូចដែលធ្លាប់មានស្រាប់ភ្លាមៗនៅមុនកាលបរិច្ឆេទនៃការចូលជាធរមាននៃតារាងវិធានការបដិលោមរបស់រដ្ឋសមាជិកនីមួយៗ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២. មាត្រា៦ (ប្រព្រឹត្តិកម្មជាតិ) មាត្រា៧ (ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត) មាត្រា៨ (ច្រកចូលទីផ្សារ) មាត្រា៩ (វត្តិមានក្នុងស្រុក) និងមាត្រា១០ (គណៈគ្រប់គ្រងជាន់ខ្ពស់និងក្រុមប្រឹក្សាកិបាល) មិនអនុវត្តចំពោះវិធានការទាំងឡាយណា ដែលរដ្ឋសមាជិកមួយអនុម័តឬក្សាទុកពាក់ព័ន្ធនឹងវិស័យ អនុវិស័យ ឬសកម្មភាព ដូចមានចែងក្នុងតារាងវិធានការបដិលោមរបស់ខ្លួនក្នុងឧបសម្ព័ន្ធII។

៣. តារាងវិធានការបដិលោមដូចមានចែងក្នុងឧបសម្ព័ន្ធIនិងII ដែលភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកិច្ចព្រមព្រៀងនេះត្រូវបង្កើតជាផ្នែកសំខ្លួនៃកិច្ចព្រមព្រៀង។

៤. បណ្តារដ្ឋសមាជិកត្រូវចាប់ផ្តើមការពិភាក្សានានា នៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមានដើម្បីអនុវត្តគោលការណ៍ ដែលពាក់ព័ន្ធនឹងការធ្វើវិសោធនកម្មចំពោះវិធានការបដិលោមណាមួយ ដូចមានចែងក្នុងវាក្យខណ្ឌ១(ក) ដោយស្ថិតក្នុងវិសាលភាពដែលការធ្វើវិសោធនកម្មមិនបន្ថយនូវអនុលោមភាពនៃវិធានការនោះទៅនឹងមាត្រា៦ (ប្រព្រឹត្តិកម្មជាតិ) មាត្រា៧ (ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត) មាត្រា៨ (ច្រកចូលទីផ្សារ) មាត្រា៩ (វត្តិមានក្នុងស្រុក) និងមាត្រា១០ (គណៈគ្រប់គ្រងជាន់ខ្ពស់និងក្រុមប្រឹក្សាកិបាល) ដូចដែលធ្លាប់មានស្រាប់ភ្លាមៗនៅមុនការធ្វើវិសោធនកម្ម។ លទ្ធផលនៃការពិភាក្សាត្រូវយកមកអនុវត្ត នៅពេលតារាងវិធានការបដិលោមរបស់រដ្ឋសមាជិកនីមួយៗចូលជាធរមាន។

មាត្រា១២
ការផ្លាស់ប្តូរទៅជាតារាងវិធានការបដិលោម

១. បណ្តារដ្ឋសមាជិកត្រូវដាក់ជូនលេខាធិការដ្ឋានអាស៊ាន នូវតារាងវិធានការបដិលោមរបស់ខ្លួនក្នុងឧបសម្ព័ន្ធI និងឧបសម្ព័ន្ធII ដោយយោងតាមមាត្រា១១ (វិធានការបដិលោម) ក្នុងរយៈពេល ៥ឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។ វៀតណាមត្រូវទទួលបានពេលវេលាបន្ថែមរហូតដល់៧ឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។ កម្ពុជា ឡាវ និងមីយ៉ាន់ម៉ាត្រូវទទួលបានពេលវេលាបន្ថែមរហូតដល់១៣ឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។ វិធានការបដិលោមដូចដែលមាននៅក្នុងតារាងរបស់រដ្ឋសមាជិកនីមួយៗ ត្រូវឆ្លុះបញ្ចាំងនូវកម្រិតនៃការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម ដែលមានសមភាពឬល្អប្រសើរជាង កម្រិតនៃការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មដែលបានផ្តល់រួចក្រោមកញ្ចប់ចុងក្រោយនៃកិច្ចព្រមព្រៀង AFAS របស់ខ្លួន។

២. ក្នុងរយៈពេល២ឆ្នាំ បន្ទាប់ពីបណ្តារដ្ឋសមាជិករៀបចំរួចនូវតារាងវិធានការបដិលោមរបស់ខ្លួនក្នុងឧបសម្ព័ន្ធIនិងII ស្របតាមកថាខណ្ឌ១ នៃមាត្រានេះ បណ្តារដ្ឋសមាជិក រក្សាសិទ្ធិដើម្បីធ្វើវិសោធនកម្មលើតារាងវិធានការបដិលោមរបស់ខ្លួនក្នុងឧបសម្ព័ន្ធIនិងII ដោយស្ថិតនៅក្នុងវិសាលភាពដែលការធ្វើវិសោធនកម្មនោះ មិនបង្កឱ្យមានភាពថយចុះនូវកម្រិតនៃការសន្យាដែលបានផ្តល់រួចក្រោមតារាងសន្យារបស់ខ្លួន ក្នុងកញ្ចប់ចុងក្រោយនៃកិច្ចព្រមព្រៀងAFAS។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៣. តារាងវិធានការបដិរោមក្នុងឧបសម្ព័ន្ធនិងII ដែលបានរៀបចំរួចដោយបណ្តារដ្ឋសមាជិក ត្រូវមានជាធរមានជាមួយគ្នានឹងតារាងសន្យារបស់បណ្តារដ្ឋសមាជិក ក្រោមកិច្ចព្រមព្រៀង AFAS សម្រាប់រយៈពេល៧ឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ រយៈពេល៩ឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះសម្រាប់វៀតណាម ឬរយៈពេល១៥ឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះសម្រាប់កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។ ហួតដល់ពេលនោះ ករណីកើតមាននូវភាពខុសគ្នាក្នុងការបកស្រាយលើការសន្យារបស់រដ្ឋសមាជិកមួយ នោះតារាងសន្យារបស់ខ្លួនក្រោមកិច្ចព្រមព្រៀងAFAS ត្រូវមានអធិកភាព។

មាត្រា១៣
វិធានការការពារសុវត្ថិភាព

១. បណ្តារដ្ឋសមាជិកកត់សម្គាល់អំពីកិច្ចចរចាពហុភាគី អនុលោមតាមមាត្រាX នៃកិច្ចព្រមព្រៀង GATS អំពីចម្ងល់ពីវិធានការការពារក្នុងសភាពអាសន្នផ្អែកលើគោលការណ៍មិនរើសអើង។ នៅពេលបញ្ចប់កិច្ចចរចាពហុភាគីទាំងនោះ បណ្តារដ្ឋសមាជិកត្រូវធ្វើការពិនិត្យឡើងវិញក្នុងគោលបំណងពិភាក្សាអំពីការធ្វើវិសោធនកម្មឱ្យបានសមស្របទៅលើកិច្ចព្រមព្រៀងនេះ ដើម្បីដាក់បញ្ចូលនូវលទ្ធផលទាំងឡាយនៃកិច្ចចរចាពហុភាគីទាំងនោះ។

២. ក្នុងករណីដែលការអនុវត្តការសន្យាដែលធ្វើឡើងនៅក្នុងកិច្ចព្រមព្រៀងនេះ បណ្តាលឱ្យប៉ះពាល់ជាដុំកំភួនទៅលើវិស័យសេវាកម្មរបស់រដ្ឋសមាជិក នៅមុនការបញ្ចប់កិច្ចចរចាពហុភាគីដូចមានចែងក្នុងកថាខណ្ឌ១ រដ្ឋសមាជិកដែលរងការប៉ះពាល់អាចស្នើសុំឱ្យមានការពិគ្រោះយោបល់ជាមួយរដ្ឋសមាជិកនោះឬបណ្តារដ្ឋសមាជិកពាក់ព័ន្ធ។ រដ្ឋសមាជិកឬបណ្តារដ្ឋសមាជិកដែលត្រូវបានស្នើសុំត្រូវចូលរួមក្នុងការពិគ្រោះយោបល់ជាមួយនឹងរដ្ឋសមាជិកស្នើសុំ អំពីការសន្យាដែលរដ្ឋសមាជិកឬបណ្តារដ្ឋសមាជិកដែលត្រូវបានស្នើសុំគិតថា អាចបណ្តាលឱ្យប៉ះពាល់ជាដុំកំភួន និងអំពីលទ្ធភាពរបស់រដ្ឋសមាជិកស្នើសុំក្នុងការអនុម័តនូវវិធានការណាមួយ ដើម្បីកាត់បន្ថយផលប៉ះពាល់នោះ។ រដ្ឋសមាជិកស្នើសុំត្រូវជូនដំណឹងដល់បណ្តារដ្ឋសមាជិកទាំងអស់ផ្សេងទៀត អំពីការស្នើសុំរបស់ខ្លួនសម្រាប់ការពិគ្រោះយោបល់ដូចមានចែងក្នុងកថាខណ្ឌនេះ។

៣. វិធានការទាំងឡាយណាដែលចាត់ឡើងដោយអនុលោមនឹងកថាខណ្ឌ២ ត្រូវមានការឯកភាពគ្នាជារួមដោយបណ្តារដ្ឋសមាជិកពិគ្រោះយោបល់។

៤. បណ្តារដ្ឋសមាជិកពិគ្រោះយោបល់ត្រូវជូនដំណឹងអំពីលទ្ធផលនៃការពិគ្រោះយោបល់ ដល់បណ្តារដ្ឋសមាជិកទាំងអស់ផ្សេងទៀតឱ្យបានឆាប់តាមដែលអាចអនុវត្តបាន និងមិនត្រូវយឺតជាងកិច្ចប្រជុំបន្ទាប់របស់រដ្ឋមន្ត្រីAEM បន្ទាប់ពីការបញ្ចប់នៃការពិគ្រោះយោបល់នោះឡើយ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ផ្នែកទី៤
ភាគព្វកិច្ច និងវិន័យរបស់បទប្បញ្ញត្តិ

មាត្រា១៤
តម្លាភាព

១. បណ្តារដ្ឋសមាជិកទទួលស្គាល់ថា វិធានការគ្រប់គ្រងពាណិជ្ជកម្មប្រកបដោយតម្លាភាពមានសារៈសំខាន់ក្នុងការសម្របសម្រួលដល់លទ្ធភាពរបស់អ្នកផ្គត់ផ្គង់សេវាកម្ម ដើម្បីទទួលបាននូវមធ្យោបាយចូលទៅកាន់និងធ្វើប្រតិបត្តិការនៅក្នុងទីផ្សាររវាងគ្នានិងគ្នា។ រដ្ឋសមាជិកនីមួយៗត្រូវជំរុញតម្លាភាពបទប្បញ្ញត្តិនៅក្នុងពាណិជ្ជកម្មសេវាកម្ម។

ការរបាះពុម្ពផ្សាយ

២. លើកលែងតែស្ថិតក្នុងស្ថានភាពអាសន្ន និងយ៉ាងយូរបំផុតត្រឹមពេលនៃការចូលជាធរមានរបស់ខ្លួន រដ្ឋសមាជិកនីមួយៗត្រូវរបាះពុម្ពផ្សាយនូវ៖

(ក) រាល់វិធានការពាក់ព័ន្ធនៃការអនុវត្តទូទៅ ដែលជាប់ពាក់ព័ន្ធឬជះឥទ្ធិពលដល់ការប្រតិបត្តិរបស់កិច្ចព្រមព្រៀងនេះ និង

(ខ) រាល់កិច្ចព្រមព្រៀងអន្តរជាតិ ដែលជាប់ពាក់ព័ន្ធឬជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម ដែលរដ្ឋសមាជិកគឺជាភាគី។

៣. តាមលទ្ធភាពដែលអាចធ្វើទៅបាន រដ្ឋសមាជិកនីមួយៗត្រូវធ្វើយ៉ាងណាឱ្យវិធានការ និងកិច្ចព្រមព្រៀងអន្តរជាតិនានាដូចមានចែងក្នុងកថាខណ្ឌ២ អាចរកបានតាមអ៊ីនធឺណែត ហើយតាមលទ្ធភាពដែលអនុញ្ញាតក្រោមក្របខ័ណ្ឌច្បាប់ក្នុងស្រុករបស់ខ្លួន ផ្សាយជាភាសាអង់គ្លេស។

៤. ករណីដែលការបោះពុម្ពផ្សាយដូចមានចែងក្នុងកថាខណ្ឌ២និង៣ ពុំអាចអនុវត្តបាន ដូច្នេះព័ត៌មានបែបនោះ[7] ត្រូវធ្វើយ៉ាងណាឱ្យអាចរកបានជាសាធារណៈ។

៥. តាមលទ្ធភាពដែលអាចធ្វើទៅបាននិងតម្រូវតាមក្របខ័ណ្ឌច្បាប់ក្នុងស្រុករបស់ខ្លួន រដ្ឋសមាជិកនីមួយៗត្រូវផ្តល់នូវឱកាសសមស្រប សម្រាប់ការបញ្ចេញមតិយោបល់ដោយបុគ្គលពាក់ព័ន្ធនឹងផលប្រយោជន៍របស់បណ្តារដ្ឋសមាជិក លើបទប្បញ្ញត្តិនៃការអនុវត្តទូទៅទាំងឡាយណា ដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម ដែលខ្លួនស្នើសុំដើម្បីអនុម័ត ធ្វើវិសោធនកម្ម ឬធ្វើនិវាករណ៍នៅមុនពេលនៃការអនុម័តនិងការបោះពុម្ពផ្សាយរបស់ខ្លួន។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

[7] ដើម្បីភាពច្បាស់លាស់ បណ្តារដ្ឋសមាជិកឯកភាពថា ព័ត៌មានបែបនោះអាចបោះពុម្ពផ្សាយជាភាសាតាមជម្រើសរបស់រដ្ឋសមាជិកនីមួយៗ។

៦. តាមលទ្ធភាពដែលអាចធ្វើទៅបាន រដ្ឋសមាជិកនីមួយៗត្រូវអនុញ្ញាតឱ្យមានពេលវេលាសមស្រប អាងការបោះពុម្ពផ្សាយនូវបទប្បញ្ញត្តិចុងក្រោយនានា ដែលពាក់ព័ន្ធនឹងកម្មវត្ថុនៃកិច្ចព្រមព្រៀងនេះ និងកាលបរិច្ឆេទដែលបទប្បញ្ញត្តិទាំងនោះចាប់ផ្តើមមានប្រសិទ្ធភាព។

ការិយាល័យទំនាក់ទំនង

៧. រដ្ឋសមាជិកនីមួយៗ ត្រូវចាត់តាំងការិយាល័យទំនាក់ទំនងមួយ ដើម្បីសម្របសម្រួលដល់ការប្រាស្រ័យទាក់ទងរវាងបណ្តារដ្ឋសមាជិក អំពីបញ្ហាទាំងឡាយណាដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀងនេះ។ តាមការស្នើសុំពីរដ្ឋសមាជិកផ្សេងទៀត ការិយាល័យទំនាក់ទំនងត្រូវ៖

(ក) កំណត់នូវការិយាល័យ ឬមន្ត្រីដែលទទួលខុសត្រូវចំពោះបញ្ហាពាក់ព័ន្ធ និង

(ខ) ជួយទៅតាមការចាំបាច់ ក្នុងការសម្របសម្រួលដល់ការប្រាស្រ័យទាក់ទងជាមួយនឹងរដ្ឋសមាជិកស្នើសុំ ពាក់ព័ន្ធនឹងបញ្ហានោះ។

៨. រដ្ឋសមាជិកនីមួយៗ ត្រូវឆ្លើយតបភ្លាមៗចំពោះសំណើទាំងឡាយរបស់រដ្ឋសមាជិកផ្សេងទៀត សម្រាប់ព័ត៌មានជាក់លាក់ស្តីពី៖

(ក) វិធានការណាមួយដូចមានចែងក្នុងវាក្យខណ្ឌ២(ក) ឬកិច្ចព្រមព្រៀងអន្តរជាតិនានាដូចមានចែងក្នុងវាក្យខណ្ឌទី២(ខ) និង

(ខ) ការបង្កើតថ្មីឬការផ្លាស់ប្តូរណាមួយចំពោះច្បាប់ បទប្បញ្ញត្តិ ឬគោលការណ៍ណែនាំរដ្ឋបាលដែលមានស្រាប់ ដែលជៈឥទ្ធិពលគួរឱ្យកត់សម្គាល់ដល់ពាណិជ្ជកម្មសេវាកម្ម ដែលគ្របដណ្តប់ដោយការសន្យារបស់រដ្ឋសមាជិក ក្រោមកិច្ចព្រមព្រៀងនេះ។

៩. តាមលទ្ធភាពដែលអាចធ្វើបាន និងតម្រូវតាមច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួន រដ្ឋសមាជិកនីមួយៗត្រូវឆ្លើយតបនឹងសំណួរទាំងឡាយរបស់បុគ្គលពាក់ព័ន្ធនឹងផលប្រយោជន៍នៃបណ្តារដ្ឋសមាជិកអំពីវិធានការពាក់ព័ន្ធរបស់រដ្ឋសមាជិកនោះ ដែលទាក់ទងនឹងកម្មវត្ថុនៃកិច្ចព្រមព្រៀងនេះ។

មាត្រា១៥
ការលាតត្រដាងព័ត៌មានសម្ងាត់

១. ពុំមានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយដើម្បីតម្រូវឱ្យរដ្ឋសមាជិកមួយផ្តល់ដល់រដ្ឋសមាជិកផ្សេងទៀតនូវព័ត៌មានសម្ងាត់ ដែលការលាតត្រដាងនូវព័ត៌មានបែបនោះ អាចនឹងរារាំងដល់ការអនុវត្តច្បាប់ ឬមួយវិញ្ញទៀតមានលក្ខណៈផ្ទុយនឹងផលប្រយោជន៍សាធារណៈ ឬអាចបុរេនិច្ឆ័យចំពោះផលប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់របស់នីតិបុគ្គលជាក់លាក់សាធារណៈ ឬឯកជន។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២. ករណីដែលរដ្ឋសមាជិកមួយផ្តល់នូវព័ត៌មានដល់រដ្ឋសមាជិកផ្សេងទៀត ដោយអនុលោមតាមកិច្ចព្រមព្រៀងនេះ ហើយចាត់ទុកព័ត៌មាននោះថាជាការសម្ងាត់ ដូច្នេះរដ្ឋសមាជិកផ្សេងទៀតនោះត្រូវរក្សានូវភាពសម្ងាត់នៃព័ត៌មានទាំងនោះ។ ព័ត៌មានបែបនោះ ត្រូវយកទៅប្រើប្រាស់សម្រាប់តែគោលបំណងដូចដែលបានបញ្ជាក់ប៉ុណ្ណោះ ហើយពុំត្រូវយកទៅលាតត្រដាងដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរដាក់លាក់ ពីរដ្ឋសមាជិកដែលផ្តល់ព័ត៌មាននោះឡើយ។

មាត្រា១៦
បទប្បញ្ញត្តិក្នុងស្រុក

១. រដ្ឋសមាជិកនីមួយៗត្រូវធានាថា រាល់វិធានការនៃការអនុវត្តទូទៅដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម ត្រូវបានគ្រប់គ្រងក្នុងលក្ខណៈសមស្រប សត្យានុម័ត និងមិនលម្អៀង។

២. (ក) រដ្ឋសមាជិកនីមួយៗត្រូវរក្សាឬបង្កើតឱ្យបានឆាប់តាមដែលអាចធ្វើទៅបាននូវ អង្គជំនុំជម្រះឬនីតិវិធីបែបតុលាការ មជ្ឈត្តកម្ម ឬរដ្ឋបាល តបតាមសំណើរបស់អ្នកផ្តត់ផ្គង់សេវាកម្មរងការប៉ះពាល់ ដើម្បីអនុញ្ញាតឱ្យមានការពនិត្យឡើងវិញភ្លាមៗ និងករណីសមហេតុផលមានដំណោះស្រាយសមរម្យ ចំពោះសេចក្តីសម្រេចរដ្ឋបាលនានាដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម។ ករណីដែលនីតិវិធីទាំងនោះពុំមានឯករាជ្យភាពពីភ្នាក់ងារដែលទទួលបន្ទុកពិនិត្យលើសេចក្តីសម្រេចរដ្ឋបាលពាក់ព័ន្ធទាំងនោះ រដ្ឋសមាជិកនោះត្រូវធានាថា នីតិវិធីទាំងនោះធ្វើឡើងសម្រាប់ការពិនិត្យឡើងវិញប្រកបដោយសត្យានុម័ត និងមិនលម្អៀងយ៉ាងពិតប្រាកដ។

(ខ) ប្រការទាំងឡាយនៃវាក្យខណ្ឌ(ក) ពុំត្រូវបានបកស្រាយដើម្បីតម្រូវឱ្យរដ្ឋសមាជិកមួយបង្កើតនូវអង្គជំនុំជម្រះឬនីតិវិធីទាំងឡាយណា ដែលផ្ទុយទៅនឹងរចនាសម្ព័ន្ធរដ្ឋធម្មនុញ្ញឬចរិតលក្ខណៈនៃប្រព័ន្ធច្បាប់របស់ខ្លួនឡើយ។

៣. ករណីដែលច្បាប់ឬបទប្បញ្ញត្តិក្នុងស្រុកតម្រូវឱ្យមាននូវ សេចក្តីអនុញ្ញាតសម្រាប់ការផ្តត់ផ្គង់សេវាកម្ម នោះអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋសមាជិកត្រូវ៖

(ក) ក្នុងករណីពាក្យស្នើសុំពុំមានភាពពេញលេញ តបតាមសំណើរបស់អ្នកដាក់ពាក្យស្នើសុំបង្ហាញនូវគ្រប់ព័ត៌មានបន្ថែមទាំងឡាយដែលតម្រូវឱ្យមានដើម្បីបំពេញពាក្យស្នើសុំឱ្យបានពេញលេញ និងផ្តល់នូវឱកាសដើម្បីដោះស្រាយភាពខ្វះចន្លោះទាំងនោះ ក្នុងអំឡុងពេលសមស្របមួយ

(ខ) តបតាមសំណើរបស់អ្នកដាក់ពាក្យស្នើសុំ ដោយពុំមានការពន្យារពេលមិនសមហេតុផល ផ្តល់នូវព័ត៌មានពាក់ព័ន្ធនឹងស្ថានភាពនៃពាក្យស្នើសុំ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

(គ) ស្ថិតក្នុងរយៈពេលសមស្របបន្ទាប់ពីការដាក់ពាក្យស្នើសុំ ដែលចាត់ទុកថាមានភាពពេញលេញក្រោមច្បាប់និងមទប្បញ្ញត្តិក្នុងស្រុក ជូនដំណឹងដល់អ្នកដាក់ពាក្យស្នើសុំអំពីការសម្រេចពាក់ព័ន្ធនឹងពាក្យស្នើសុំនោះ និង

(ឃ) ប្រសិនបើពាក្យស្នើសុំត្រូវបានបញ្ឈប់ឬបដិសេធ តាមលទ្ធភាពអតិបរិមាដែលអាចធ្វើទៅបាន ជូនដំណឹងដល់អ្នកដាក់ពាក្យស្នើសុំអំពីមូលហេតុនៃការសម្រេចបែបនោះជាលាយលក្ខណ៍អក្សរនិងគ្មានការពន្យារពេល។ អ្នកដាក់ពាក្យស្នើសុំនឹងមានលទ្ធភាពក្នុងការដាក់ឡើងវិញនូវពាក្យស្នើសុំថ្មី តាមឆន្ទានុសិទ្ធិរបស់ខ្លួន។

៤. ករណីដែលរដ្ឋសមាជិកមួយអនុម័តឬរក្សាទុកនូវវិធានការទាំងឡាយណាពាក់ព័ន្ធនឹង តម្រូវការនិងនីតិវិធីក្នុងការផ្តល់អាជ្ញាប័ណ្ណ តម្រូវការនិងនីតិវិធីចំពោះគុណវុឌ្ឍិ ឬករណីដែលរដ្ឋសមាជិកមួយអនុម័តឬរក្សាទុកនូវវិធានការទាំងឡាយណាពាក់ព័ន្ធនឹង ស្តង់ដាបច្ចេកទេស ក្នុងន័យជាលក្ខខណ្ឌសម្រាប់ការផ្គត់ផ្គង់សេវាកម្ម នោះរដ្ឋសមាជិកត្រូវធានាថា៖

(ក) វិធានការបែបនោះ ផ្អែកលើលក្ខណៈវិនិច្ឆ័យប្រកបដោយសត្យានុម័តនិងតម្លាភាព

(ខ) នីតិវិធីទាំងនោះមិនលម្អៀង ហើយនីតិវិធីទាំងនោះមានលក្ខណៈគ្រប់គ្រាន់ សម្រាប់ឱ្យអ្នកដាក់ពាក្យស្នើសុំអាចបំភ្លឺបាន ថាតើពួកគេបានបំពេញតាមតម្រូវការដែរឬយ៉ាងណាករណីដែលមានតម្រូវការដូចខាងលើនេះ

(គ) នីតិវិធីទាំងនោះមានភាពសមស្រប ហើយនីតិវិធីទាំងនោះផ្ទាល់ពុំបង្កជាឧបសគ្គដល់ការបំពេញតាមតម្រូវការនានាដោយមិនសមហេតុផលឡើយ

៥. (ក) រដ្ឋសមាជិកមិនត្រូវអនុវត្តនូវតម្រូវការសម្រាប់ការផ្តល់អាជ្ញាប័ណ្ណ និងតម្រូវការគុណវុឌ្ឍិព្រមទាំងស្តង់ដាបច្ចេកទេសណាមួយ ដែលបណ្តាលឱ្យមោយៈឬបន្ថយនូវកាតព្វកិច្ចរបស់ខ្លួននៅក្រោមកិច្ចព្រមព្រៀងនេះ ក្នុងលក្ខណៈមួយដែល៖

(i) មិនអនុលោមតាមលក្ខណៈវិនិច្ឆ័យ ដូចមានចែងក្នុងវាក្យខណ្ឌ ៤(ក) (ខ) ឬ (គ) និង

(ii) ពុំអាចធ្វើការរំពឹងទុកអំពីរដ្ឋសមាជិកនោះបានដោយសមហេតុផល នៅក្នុងពេលដែលការសន្យាចំពោះវិស័យទាំងនោះត្រូវបានធ្វើឡើង។

(ខ) ក្នុងការកំណត់ថា តើរដ្ឋសមាជិកមួយមានអនុលោមភាពទៅនឹងកាតព្វកិច្ចនៅក្រោមវាក្យខណ្ឌ៥(ក) នោះការពិចារណាត្រូវពិនិត្យលើស្តង់ដាអន្តរជាតិរបស់អង្គការអន្តរជាតិពាក់ព័ន្ធនានា ដែលអនុវត្តដោយរដ្ឋសមាជិកនោះ។

៦. ពាក់ព័ន្ធនឹងសេវាកម្មវិជ្ជាជីវៈ[8] រដ្ឋសមាជិកនីមួយៗត្រូវផ្តល់នូវនីតិវិធីគ្រប់គ្រាន់ ដើម្បីផ្ទៀងផ្ទាត់សមត្ថភាពអ្នកជំនាញវិជ្ជាជីវៈរបស់រដ្ឋសមាជិកផ្សេងទៀត។

---

[8] ដូចដែលបានធ្វើចំណាត់ថ្នាក់នៅក្រោមវិស័យសេវាកម្មធុរកិច្ច យោងតាមឯកសារ MTN.GNS/W/120 របស់អង្គការពាណិជ្ជកម្ម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៧. ទៅតាមលទ្ធភាពដែលអនុញ្ញាតដោយច្បាប់និងបទប្បញ្ញត្តិក្នុងស្រុក រដ្ឋសមាជិកនីមួយៗត្រូវធានាថា អាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនទទួលយកនូវឯកសារថតចម្លងដែលបានធ្វើនីត្យានុកូលកម្ម ស្របតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន ជំនួសឱ្យឯកសារច្បាប់ដើម។

៨. ប្រសិនបើតម្រូវការសម្រាប់ការផ្តល់អាជ្ញាប័ណ្ណឬតម្រូវការគុណវុឌ្ឍិ រួមបញ្ចូលទាំងការបញ្ចប់ពេញលេញនៃការពិនិត្យពិចារណា នោះរដ្ឋសមាជិកនីមួយៗត្រូវ តាមលទ្ធភាពដែលអាចធ្វើទៅបានធានាថា៖

(ក) ការពិនិត្យពិចារណាត្រូវបានរៀបចំកាលវិភាគនៅចន្លោះពេលញឹកញាប់ដែលសមស្រប

(ខ) រយៈពេលសមស្របមួយគឺត្រូវបានផ្តល់ជូន ដើម្បីអនុញ្ញាតឱ្យបុគ្គលពាក់ព័ន្ធនឹងផលប្រយោជន៍ដាក់ពាក្យស្នើសុំ។

៩. ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន បណ្តារដ្ឋសមាជិកត្រូវខិតខំទទួលយកពាក្យស្នើសុំក្នុងទម្រង់អេឡិចត្រូនិក ដែលស្ថិតក្រោមលក្ខខណ្ឌសមមូលនៃនីត្យានុកូលភាពដូចទៅនឹងការដាក់ស្នើជាក្រដាសស្មាមដែរ។

១០. រដ្ឋសមាជិកនីមួយៗត្រូវធានាថា កម្រៃសេវាសម្រាប់ការផ្តល់ការអនុញ្ញាត[9] ដែលយកដោយអាជ្ញាធរមានសមត្ថកិច្ចគឺសមស្របនិងមានតម្លាភាព ហើយការយកកម្រៃបែបនោះផ្ទាល់ពុំបង្កជាការរឹតត្បិតដល់ការផ្តត់ផ្តង់សេវាកម្មពាក់ព័ន្ធឡើយ។

១១. ប្រសិនបើលទ្ធផលនៃការចចារពាក់ព័ន្ធកថាខណ្ឌ៤ នៃមាត្រាVI នៃកិច្ចព្រមព្រៀងGATS ចូលជាធរមាន មាត្រានេះត្រូវធ្វើវិសោធនកម្មតាមការសមស្រប បន្ទាប់ពីមានការពិគ្រោះយោបល់រវាងបណ្តារដ្ឋសមាជិក ដើម្បីធ្វើឱ្យលទ្ធផលទាំងនោះអាចអនុវត្តជាធរមាននៅក្រោមកិច្ចព្រមព្រៀងនេះ។

មាត្រា១៧
ការទទួលស្គាល់

១. សម្រាប់គោលបំណងនៃការផ្តល់អាជ្ញាប័ណ្ណ ឬការផ្តល់វិញ្ញាបនបត្រ ដល់អ្នកផ្តត់ផ្តង់សេវាកម្ម រដ្ឋសមាជិកមួយអាចទទួលស្គាល់នូវ ការអប់រំឬបទពិសោធន៍ដែលទទួលបាន លក្ខខណ្ឌតម្រូវដែលបំពេញតាម ឬអាជ្ញាប័ណ្ណឬវិញ្ញាបនបត្រដែលត្រូវបានផ្តល់ជូនក្នុងរដ្ឋសមាជិកផ្សេងទៀត។ ការទទួលស្គាល់បែបនេះ ដែលអាចសម្រេចបានតាមរយៈការធ្វើសុខដុមនីយកម្មឬក្រៅពីនេះ អាចនឹងអាស្រ័យទៅលើកិច្ចព្រមព្រៀង ឬកិច្ចរៀបចំណាមួយជាមួយនឹងរដ្ឋសមាជិកពាក់ព័ន្ធ ឬក៏អាចនឹងត្រូវបានផ្តល់ជូនដោយស្វ័យភាព។

---

[9] ឧទាហរណ៍សម្រាប់ការផ្តល់ការអនុញ្ញាតរួមមាន កម្រៃសេវានៃការផ្តល់អាជ្ញាប័ណ្ណ និងកម្រៃសេវាពាក់ព័ន្ធនានាទៅនឹងនីតិវិធីគុណវុឌ្ឍិ ប៉ុន្តែមិនរួមបញ្ចូលកម្រៃដែលតំណាងឱ្យការពិចារណាមិនមែនលើការប្រើប្រាស់ធនធានធម្មជាតិ ការទូទាត់លើការដេញថ្លៃជាសាធារណៈ ការដាក់សំណើរបស់ពាណិជ្ជករដែលមិនរើសអើងនានាចំពោះការផ្តល់សម្បទាន ឬវិភាគទានភាគច្រើននានាចំពោះការផ្តល់សេវាកម្មជាសកលឡើយ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

๒. ពុំមានអ្វីនៅក្នុងមាត្រានេះត្រូវបានបកស្រាយ ដើម្បីរារាំងរដ្ឋសមាជិកមួយពីការផ្តល់នូវការទទួលស្គាល់ដោយស្វ័យភាពឡើយ។ ករណីដែលរដ្ឋសមាជិកមួយយល់ព្រមផ្តល់នូវការទទួលស្គាល់ដោយស្វ័យភាពដល់រដ្ឋសមាជិកផ្សេងទៀត រដ្ឋសមាជិកនោះត្រូវផ្តល់ឱកាសគ្រប់គ្រាន់ដល់រដ្ឋសមាជិកផ្សេងៗទៀត ដើម្បីបំភ្លឺថា ការអប់រំ បទពិសោធន៍ អាជ្ញាប័ណ្ណ ឬវិញ្ញាបនបត្រដែលទទួលបាន ឬលក្ខខណ្ឌតម្រូវដែលបំពេញតាម នៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងៗទៀតនោះ គប្បីត្រូវបានទទួលស្គាល់ផងដែរ។

៣. ក្នុងគោលបំណងជួយសម្រួលបន្ថែមទៀតដល់បន្លាស់ទីនៃអ្នកជំនាញវិជ្ជាជីវៈនិងពលកម្មជំនាញ បណ្តារដ្ឋសមាជិកត្រូវលើកទឹកចិត្តឱ្យអាជ្ញាធរមានសមត្ថកិច្ច ធ្វើការចរចាកិច្ចព្រមព្រៀង ឬកិច្ចរៀបចំទទួលស្គាល់គ្នាទៅវិញទៅមកនានា នៅក្នុងវិស័យដែលពួកគេចាត់ទុកថាសមស្រប។

៤. រដ្ឋសមាជិកមួយមិនត្រូវយល់ព្រមផ្តល់នូវការទទួលស្គាល់ ក្នុងលក្ខណៈមួយដែលអាចបង្កឱ្យមានការរើសអើងរវាងបណ្តារដ្ឋសមាជិក ពាក់ព័ន្ធនឹងការអនុវត្តស្តង់ដា ឬលក្ខណៈវិនិច្ឆ័យរបស់ខ្លួន ក្នុងការផ្តល់ការអនុញ្ញាត ការផ្តល់អាជ្ញាប័ណ្ណ ឬការចេញវិញ្ញាបនបត្រដល់អ្នកផ្គត់ផ្គង់សេវាកម្ម ឬការរឹតត្បិតបែបក្លែងបន្លំចំពោះពាណិជ្ជកម្មសេវាកម្មឡើយ។

មាត្រា១៨
ការទូទាត់ និងការផ្ទេរ

១. លើកលែងតែស្ថិតក្រោមកាលៈទេសៈដូចដែលបានប្រមើលទុកមុនក្នុងមាត្រា១៩ (ការរឹតត្បិតដើម្បីការពារតុល្យភាពជញ្ជីងទូទាត់) រដ្ឋសមាជិកមួយមិនត្រូវដាក់ការរឹតត្បិតចំពោះការផ្ទេរនិងការទូទាត់ជាអន្តរជាតិ សម្រាប់ប្រតិបត្តិការចរន្តទាំងឡាយ ដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់សេវាកម្ម ដែលខ្លួនបានសន្យាក្រោមកិច្ចព្រមព្រៀងនេះឡើយ។

២. ពុំមានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះត្រូវជះឥទ្ធិពលដល់សិទ្ធិនិងកាតព្វកិច្ចរបស់បណ្តារដ្ឋសមាជិក ក្នុងនាមជាសមាជិកនៃអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដែលនៅក្រោមមាត្រានានានៃកិច្ចព្រមព្រៀងរបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិឡើយ រួមទាំងការប្រើប្រាស់សកម្មភាពដោះដូរទាំងឡាយ ដែលអនុលោមទៅនឹងមាត្រានានានៃកិច្ចព្រមព្រៀងរបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ ក្នុងន័យនេះ រដ្ឋសមាជិកមួយមិនត្រូវដាក់ការរឹតត្បិតលើប្រតិបត្តិការមូលធននានាឡើយ លើកលែងតែមានចែងក្នុងមាត្រា១៩ (ការរឹតត្បិតដើម្បីការពារតុល្យភាពជញ្ជីងទូទាត់) ឬផ្អែកតាមសំណើរបស់ IMF។

មាត្រា១៩
ការរឹត្បិតដើម្បីការពារតុល្យភាពជញ្ជីងទូទាត់



១. ស្ថិតក្នុងស្ថានការណ៍ដែលជួបនឹងការលំបាកធ្ងន់ធ្ងរលើតុល្យភាពជញ្ជីងទូទាត់ និងជួបការលំបាកដែកហិរញ្ញវត្ថុពីខាងក្រៅ ឬការគំរាមកំហែងផ្សេងៗពីស្ថានការណ៍បែបនោះ ឬប្រសិនបើមានកាលៈទេសៈពិសេសដោយឡែក មូលហេតុបន្លាស់ទីនៃមូលធន ឬការគំរាមកំហែងបង្កឱ្យ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មានផលវិនាសដល់សេដ្ឋកិច្ចឬហិរញ្ញវត្ថុធ្ងន់ធ្ងរនៅក្នុងរដ្ឋសមាជិកមួយ រដ្ឋសមាជិកនោះអាចអនុម័តឬរក្សាទុកនូវការរឹតត្បិតលើពាណិជ្ជកម្មសេវាកម្ម រួមទាំងលើការទូទាត់និងការផ្ទេរ។ វាត្រូវបានទទួលស្គាល់ថា សម្ពាធដាក់លាក់ចំពោះតុល្យភាពដញ្ជីងទូទាត់របស់រដ្ឋសមាជិកមួយនៅក្នុងដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ច ឬការផ្លាស់ប្តូរសេដ្ឋកិច្ចអាចបណ្តាលឱ្យមានភាពចាំបាច់ក្នុងការប្រើប្រាស់ការរឹតត្បិតនានា ដើម្បីធានាដល់ការថែរក្សាបាននូវកម្រិតនៃការបម្រុងហិរញ្ញវត្ថុគ្រប់គ្រាប់ សម្រាប់ការអនុវត្តកម្មវិធីរបស់ខ្លួនក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ឬការផ្លាស់ប្តូរសេដ្ឋកិច្ច។

២. ការរឹតត្បិតដូចមានចែងក្នុងកថាខណ្ឌ១៖

(ក) មិនត្រូវរើសអើងក្នុងចំណោមបណ្តារដ្ឋសមាជិកឡើយ

(ខ) ត្រូវមានសង្គតិភាពទៅនឹងមាត្រានានានៃកិច្ចព្រមព្រៀងរបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ

(គ) ត្រូវចៀសវាងនូវការខូចខាតមិនចាំបាច់ដល់ផលប្រយោជន៍ពាណិជ្ជកម្ម សេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់រដ្ឋសមាជិកផ្សេងទៀត

(ឃ) មិនត្រូវលើសពីអ្វីដែលជាភាពចាំបាច់ សម្រាប់ការដោះស្រាយចំពោះកាលៈទេសៈដូចដែលបានពណ៌នាក្នុងកថាខណ្ឌ១ និង

(ង) ត្រូវធ្វើឡើងជាបណ្តោះអាសន្ន និងត្រូវលុបចោលជាបន្តបន្ទាប់ នៅពេលដែលស្ថានភាពដូចមានបញ្ជាក់ក្នុងកថាខណ្ឌ១ មានភាពប្រសើរឡើងវិញ។

៣. ក្នុងការកំណត់នូវស្ថានភាពដែលបណ្តាលឱ្យកើតមាននូវការរឹតត្បិតបែបនេះ បណ្តារដ្ឋសមាជិកត្រូវផ្តល់អទិភាពដល់ការផ្តត់ផ្គង់សេវាកម្មទាំងឡាយណា ដែលមានសារៈសំខាន់ជាងគេចំពោះកម្មវិធីសេដ្ឋកិច្ចឬការអភិវឌ្ឍរបស់ខ្លួន។ ទោះជាយ៉ាងណាក្តី ការរឹតត្បិតបែបនេះពុំត្រូវអនុម័តឬរក្សាទុកក្នុងគោលបំណងការពារវិស័យសេវាកម្មដាក់លាក់ណាមួយឡើយ។

មាត្រា២០
ភាពផ្តាច់មុខនិងអ្នកផ្តត់ផ្គង់សេវាកម្មផ្តាច់មុខ

១. រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្តត់ផ្គង់សេវាកម្មផ្តាច់មុខនៅក្នុងដែនដីរបស់ខ្លួន សម្រាប់ការផ្តត់ផ្គង់សេវាកម្មផ្តាច់មុខនោះនៅក្នុងទីផ្សារពាក់ព័ន្ធ ពុំប្រព្រឹត្តនូវសកម្មភាពក្នុងលក្ខណៈមួយដែលអសង្គតិភាពទៅនឹងកាតព្វកិច្ចរបស់រដ្ឋសមាជិកនោះនៅក្រោម មាត្រា៧ (ប្រព្រឹត្តិកម្មពាណិជ្ជកម្មជាតិដែលទទួលបានភាពអនុគ្រោះបំផុត) និងមាត្រា១១ (វិធានការបដិសេម)។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២. ករណីដែលអ្នកផ្តត់ផ្គង់ផ្តាច់មុខរបស់រដ្ឋសមាជិកមួយ ប្រកួតប្រជែងដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្នុងការផ្តត់ផ្គង់សេវាកម្មដែលស្ថិតនៅក្រៅវិសាលភាពនៃសិទ្ធិផ្តាច់មុខរបស់ខ្លួន ហើយដែលសេវាកម្មនោះជាកម្មវត្ថុទៅនឹងការសន្យារបស់រដ្ឋសមាជិកនោះក្រោមកិច្ចព្រមព្រៀងនេះ រដ្ឋសមាជិកនោះត្រូវធានាថា អ្នកផ្តត់ផ្គង់បែបនេះមិនបំពានទីផ្តាច់មុខរបស់ខ្លួន ដោយប្រព្រឹត្តនូវសកម្មភាពក្នុងលក្ខណៈមួយដែលអសង្គតិភាពទៅនឹងការសន្យាទាំងនោះ ក្នុងដែនដីរបស់ខ្លួនឡើយ។

៣. តបតាមសំណើរបស់រដ្ឋសមាជិកមួយដែលមានមូលហេតុក្នុងការជឿជាក់ថា អ្នកផ្តត់ផ្គង់សេវាកម្មផ្តាច់មុខនៃរដ្ឋសមាជិកផ្សេងទៀត កំពុងប្រព្រឹត្តសកម្មភាពក្នុងលក្ខណៈមួយដែលអសង្គតិភាពទៅនឹងកថាខណ្ឌ១ឬ២ នោះរដ្ឋមន្ត្រីAEM អាចស្នើរដ្ឋសមាជិកដែលបង្កើត រក្សាទុក ឬផ្តល់ការអនុញ្ញាតដល់អ្នកផ្តត់ផ្គង់បែបនោះ ផ្តល់នូវព័ត៌មានជាក់លាក់អំពីប្រតិបត្តិការពាក់ព័ន្ធនានា។

៤. ប្រសិនបើ បន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ រដ្ឋសមាជិកមួយផ្តល់សិទ្ធិផ្តាច់មុខពាក់ព័ន្ធនឹងការផ្តត់ផ្គង់សេវាកម្មណាមួយ ដែលគ្របដណ្តប់ដោយការសន្យារបស់ខ្លួនក្រោមកិច្ចព្រមព្រៀងនេះ រដ្ឋសមាជិកនោះត្រូវជូនដំណឹងដល់រដ្ឋមន្ត្រី AEM មិនឱ្យតិចជាងបីខែ មុនពេលវេលាដែលប៉ុនប៉ងចាប់ផ្តើមអនុវត្តការផ្តល់សិទ្ធិផ្តាច់មុខនោះ ហើយមាត្រា៣៣ (វិសោធនកម្ម) ត្រូវអនុវត្ត។

៥. ប្រការទាំងឡាយនៃមាត្រានេះត្រូវអនុវត្តផងដែរ ចំពោះករណីដែលអ្នកផ្តត់ផ្គង់សេវាកម្មផ្តាច់មុខទាំងឡាយ ដែលរដ្ឋសមាជិកមួយជាផ្លូវការឬជាធរមាន (ក) អនុញ្ញាតឬបង្កើតឱ្យមានអ្នកផ្តត់ផ្គង់សេវាកម្មមួយក្រុមតូច និង (ខ) រារាំងគួរឱ្យកត់សម្គាល់ចំពោះការប្រកួតប្រជែង ក្នុងចំណោមអ្នកផ្តត់ផ្គង់សេវាកម្មទាំងនោះ ក្នុងដែនដីរបស់ខ្លួន។

មាត្រា២១
ការអនុវត្តធុរកិច្ច

១. បណ្តារដ្ឋសមាជិកទទួលស្គាល់ថា ការអនុវត្តធុរកិច្ចដាក់លាក់មួយចំនួនរបស់អ្នកផ្តត់ផ្គង់សេវាកម្មក្រៅពីការអនុវត្តទាំងឡាយដូចមានចែងក្នុងមាត្រា២០ (ភាពផ្តាច់មុខនិងអ្នកផ្តត់ផ្គង់សេវាកម្មផ្តាច់មុខ) អាចបន្ទុចបង្អាក់ដល់ការប្រកួតប្រជែង និងដោយហេតុនេះ បង្កជាការរឹតត្បិតដល់ពាណិជ្ជកម្មសេវាកម្ម។

២. តបតាមសំណើរបស់រដ្ឋសមាជិកផ្សេងទៀត រដ្ឋសមាជិកនីមួយៗត្រូវចូលរួមក្នុងការពិគ្រោះយោបល់ក្នុងគោលបំណងដើម្បីលុបបំបាត់ការអនុវត្តនានា ដូចមានចែងក្នុងកថាខណ្ឌ១។ រដ្ឋសមាជិកដែលត្រូវបានស្នើសុំនោះត្រូវពិចារណាឱ្យបានពេញលេញនិងប្រកបដោយសមានចិត្តចំពោះសំណើនោះ និងត្រូវសហការតាមរយៈការផ្តល់ព័ត៌មានមិនសម្ងាត់ដែលអាចរកបានជា

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

សាធារណៈដែលទាក់ទងនឹងបញ្ហាចោទសួរនោះ។ រដ្ឋសមាជិកដែលត្រូវបានស្នើសុំក៏ត្រូវផ្តល់ផងដែរនូវពត៌មានដែលអាចរកបានដទៃទៀតដល់រដ្ឋសមាជិកស្នើសុំ ដោយអនុលោមតាមច្បាប់ក្នុងស្រុករបស់ខ្លួន និងតាមសេចក្តីសម្រេចនៃការព្រមព្រៀងគ្នាប្រកបដោយភាពពេញចិត្តពាក់ព័ន្ធនឹងការការពារចំពោះកិច្ចការសម្ងាត់របស់ខ្លួនដោយរដ្ឋសមាជិកស្នើសុំ។

មាត្រា២២
ការលើកលែងទូទៅ

ដោយអាស្រ័យតាមលក្ខខណ្ឌតម្រូវថា វិធានការទាំងនោះពុំត្រូវបានអនុវត្តក្នុងលក្ខណៈមួយដែលបង្កឱ្យមានការរើសអើងតាមអំពើចិត្ត ឬពុំសមហេតុផលរវាងប្រទេសទាំងឡាយ ករណីដែលស្ថិតក្នុងលក្ខខណ្ឌដូចគ្នា ឬបង្កឱ្យមានការរឹតត្បិតបែបក្លែងបន្លំចំពោះពាណិជ្ជកម្មសេវាកម្ម នោះពុំមានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយដើម្បីរារាំងដល់ការអនុម័តឬការអនុវត្តដោយរដ្ឋសមាជិកណាមួយនូវវិធានការទាំងឡាយណាដែល៖

(ក) ចាំបាច់ដើម្បីការពារក្រមសីលធម៌សាធារណៈ ឬ ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ;[10]

(ខ) ចាំបាច់ដើម្បីការពារអាយុជីវិតឬសុខភាពរបស់មនុស្ស សត្វ ឬ រុក្ខជាតិ

(គ) ចាំបាច់ដើម្បីធានានូវការអនុវត្តតាមច្បាប់ឬបទប្បញ្ញត្តិនានា ដែលមិនផ្ទុយទៅនឹងប្រការទាំងឡាយនៃកិច្ចព្រមព្រៀងនេះ រួមបញ្ចូលទាំងវិធានការពាក់ព័ន្ធនឹង៖

(i) ការទប់ស្កាត់ចំពោះការអនុវត្តបែបឆបោកនិងក្លែងបន្លំ ឬដើម្បីទប់ទល់ចំពោះលទ្ធផលនៃការខកខានក្នុងការបំពេញតាមកិច្ចសន្យាសេវាកម្មនានា

(ii) ការការពារឯកជនភាពរបស់បុគ្គលពាក់ព័ន្ធនឹងការដំណើរការ និងការចែកចាយទិន្នន័យផ្ទាល់ខ្លួន និងការការពារការសម្ងាត់នៃកំណត់ត្រានិងគណនីបុគ្គល ឬ

(iii) សុវត្ថិភាព

(ឃ) មិនអនុលោមទៅនឹងមាត្រា៦ (ប្រព្រឹត្តិកម្មជាតិ) ក្នុងករណីភាពខុសគ្នានៃប្រព្រឹត្តិកម្មនោះត្រូវបានធ្វើឡើងក្នុងគោលបំណងធានាឱ្យបាននូវការដាក់បន្ទុកឬការប្រមូលពន្ធផ្ទាល់ប្រកបដោយសមធម៌ឬប្រសិទ្ធភាព[11] ពាក់ព័ន្ធនឹងសេវាកម្មឬអ្នកផ្តត់ផ្តង់សេវាកម្មរបស់បណ្តារដ្ឋសមាជិកផ្សេងទៀត ឬ

---

[10] ការលើកលែងដើម្បីសណ្តាប់ធ្នាប់សាធារណៈ អាចត្រូវបានយកមកប្រើចំពោះវិតករណីដែលការគំរាមកំហែងពិតប្រាកដឬធ្ងន់ធ្ងរគ្រប់គ្រាន់ពាក់ព័ន្ធដល់ផលប្រយោជន៍ណាមួយនៅក្នុងចំណោមផលប្រយោជន៍ជាមូលដ្ឋាននានារបស់សង្គម។

[11] ការលើកលែងណាមួយណាដែលមានគោលដៅធានានូវការដាក់បន្ទុកឬការប្រមូលពន្ធផ្ទាល់ប្រកបដោយសមធម៌ឬប្រសិទ្ធភាព រួមបញ្ចូលវិធានការលើកលែងណាមួយណា ដែលចាត់ឡើងដោយរដ្ឋសមាជិកមួយក្រោមប្រព័ន្ធពន្ធរបស់ខ្លួន ដែល៖

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

(ង) មិនអនុលោមនឹងមាត្រា៧ (ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត) ក្នុងករណីដែលភាពខុសគ្នានៃប្រព្រឹត្តិកម្ម គឺជាលទ្ធផលនៃកិច្ចព្រមព្រៀងណាមួយស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា ឬប្រការនានាស្តីពីការចៀសវាងការយកពន្ធត្រួតគ្នានៅក្នុងកិច្ចព្រមព្រៀងឬកិច្ចរៀបចំអន្តរជាតិផ្សេងៗទៀត ដែលរដ្ឋសមាជិកនោះជាប់កាតព្វកិច្ច។

មាត្រា ២៣
ការលើកលែងផ្នែកសន្តិសុខ

១. ពុំមានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះដែលនឹងត្រូវបកស្រាយ៖

(ក) ដើម្បីតម្រូវឱ្យរដ្ឋសមាជិកមួយផ្តល់ព័ត៌មានណាមួយ ដែលការលាតត្រដាងព័ត៌មាននេះត្រូវបានចាត់ទុកថា ផ្ទុយនឹងផលប្រយោជន៍ចម្បងផ្នែកសន្តិសុខរបស់ខ្លួន ឬ

(ខ) ដើម្បីរារាំងរដ្ឋសមាជិកមួយពីការចាត់វិធានការណាមួយ ដែលខ្លួនគិតថាចាំបាច់សម្រាប់ការពារផលប្រយោជន៍ចម្បងផ្នែកសន្តិសុខរបស់ខ្លួន៖

(i) ទាក់ទងនឹងការផ្គត់ផ្គង់សេវាកម្ម ដែលប្រព្រឹត្តទៅដោយផ្ទាល់ឬដោយប្រយោលក្នុងគោលបំណងផ្តល់ការផ្គត់ផ្គង់សម្រាប់ការបង្កើតកម្លាំងយោធា

(ii) ទាក់ទងនឹងវត្ថុធាតុដែលអាចបំបែកបាននិងរំលាយបញ្ចូលគ្នាបាន ឬវត្ថុធាតុនានាដែលកើតចេញពីសារធាតុទាំងនេះ

(i) អនុវត្តចំពោះអ្នកផ្គត់ផ្គង់សេវាកម្មដែលជាអនិវេសនជន ដោយទទួលស្គាល់នូវភាពពិតជាក់ស្តែងថា កាតព្វកិច្ចពន្ធរបស់អនិវេសនជន គឺត្រូវបានកំណត់ស្របទៅតាមវត្ថុទាំងឡាយដែលអាចជាប់ពន្ធ ដែលមានប្រភពឬស្ថិតនៅក្នុងដែនដីរបស់រដ្ឋសមាជិកនោះ ឬ

(ii) អនុវត្តចំពោះអនិវេសនជន ដើម្បីធានានូវការដាក់បន្ទុកឬការប្រមូលពន្ធនៅក្នុងដែនដីរបស់រដ្ឋសមាជិកនោះ ឬ

(iii) អនុវត្តចំពោះអនិវេសនជនឬនិវេសនជនទាំងឡាយ ដើម្បីរារាំងចំពោះការចៀសវាងឬការគេចវេសពីការបង់ពន្ធ រួមទាំងវិធានការប្រតិបត្តិតាម ឬ

(iv) អនុវត្តចំពោះអ្នកប្រើប្រាស់សេវាកម្មទាំងឡាយ ដែលសេវាកម្មនោះត្រូវបានផ្គត់ផ្គង់នៅក្នុងឬមកពីដែនដីរបស់រដ្ឋសមាជិកផ្សេងទៀត ដើម្បីធានានូវការដាក់បន្ទុកឬការប្រមូលពន្ធ ដែលបានមកពីប្រភពនានានៅក្នុងដែនដីរបស់រដ្ឋសមាជិកនោះ ពីអ្នកប្រើប្រាស់សេវាកម្មបែបនោះ ឬ

(v) កំណត់អំពីភាពខុសគ្នារវាង អ្នកផ្គត់ផ្គង់សេវាកម្មទាំងឡាយដែលរងការជាប់ពន្ធចំពោះកម្មវត្ថុនានាដែលអាចជាប់ពន្ធទូទាំងពិភពលោក ចេញពីអ្នកផ្គត់ផ្គង់សេវាកម្មផ្សេងទៀត ដោយទទួលស្គាល់នូវភាពខុសគ្នារបស់ចរិតលក្ខណៈនៃមូលដ្ឋានពន្ធរវាងពួកគេ ឬ

(vi) កំណត់អំពី ចំណូលដែលត្រូវបម្រុងទុកឬត្រូវបែងចែក ផលចំណេញ កំណើន ការខាតបង់ ការថយចុះ ឬឥណទាន របស់បុគ្គលឬសាខាដែលតាំងនៅជាអចិន្ត្រៃយ៍ ឬរវាងបុគ្គលឬសាខាពាក់ព័ន្ធនឹងបុគ្គលដដែលនេះ ដើម្បីការពារនូវមូលដ្ឋានពន្ធរបស់រដ្ឋសមាជិកនោះ។

លក្ខខណ្ឌកំណត់ឬទស្សនាទានពន្ធនានា ដូចមានចែងនៅក្នុងកថាខណ្ឌ(យ) នៃមាត្រា២២ (ការលើកលែងទូទៅ) និងនៅក្នុងកំណត់ឯកសាលាចុងទាំងនេះ ត្រូវបានកំណត់ដោយអាស្រ័យទៅតាមនិយមន័យនិងទស្សនាទានពន្ធ ឬនិយមន័យនិងទស្សនាទានដែលមានសម្រាស់ឬប្រហាក់ប្រហែល ដោយស្ថិតក្រោមច្បាប់ក្នុងស្រុករបស់រដ្ឋសមាជិកដែលអនុវត្តវិធានការនេះ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ទំព័រទី២៤

(iii) ទាក់ទងនឹងវិធានការនានាចាត់ឡើង ដើម្បីការពារហេដ្ឋារចនាសម្ព័ន្ធសាធារណៈសំខាន់ៗ រួមមាន ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ថាមពល និងធារាសាស្ត្រ ពីការប៉ុនប៉ងដោយចេតនាដើម្បីបង្អាក់ដំណើរការ ឬធ្វើឱ្យខូចខាតហេដ្ឋារចនាសម្ព័ន្ធទាំងនោះ

(iv) ដែលត្រូវបានធ្វើឡើងក្នុងពេលសង្គ្រាម ឬនៅក្នុងភាពអាសន្នផ្សេងទៀតនៅក្នុងទំនាក់ទំនងអន្តរជាតិ

(គ) ដើម្បីរក៉ាំងរដ្ឋសមាជិកណាមួយពីការចាត់វិធានការទាំងឡាយណា ដែលស្របតាមកាតព្វកិច្ចរបស់ខ្លួនក្រោមធម្មនុញ្ញអង្គការសហប្រជាជាតិ សម្រាប់ការរក្សាសន្តិភាពនិងសន្តិសុខអន្តរជាតិ។

២. ព័ត៌មានយ៉ាងពេញលេញជាទីបំផុតតាមដែលអាចធ្វើបាន អំពីវិធានការទាំងឡាយណាដែលត្រូវបានអនុវត្តក្រោមកថាខណ្ឌ១(ខ)និង(គ) និងអំពីការបញ្ចប់នៃវិធានការទាំងនោះ ត្រូវផ្តល់ជាព័ត៌មានជូនដល់រដ្ឋមន្ត្រីAEM ។

មាត្រា ២៤
ឧបត្ថម្ភធន

១. ថ្វីបើមានចែងក្នុងមាត្រា២ (វិសាលភាព) បណ្តារដ្ឋសមាជិកត្រូវពិនិត្យឡើងវិញលើបញ្ហានិន័យនានាស្តីពីឧបត្ថម្ភធនពាក់ព័ន្ធនឹងពាណិជ្ជកម្មសេវាកម្ម ដោយពិចារណាលើនិន័យទាំងឡាយដែលបានព្រមព្រៀងនៅក្រោមមាត្រាXV នៃកិច្ចព្រមព្រៀងGATS ក្នុងគោលបំណងរួមបញ្ចូលនិន័យទាំងនោះទៅក្នុងកិច្ចព្រមព្រៀងនេះ។

២. រដ្ឋសមាជិកមួយដែលយល់ថាខ្លួនរងនូវឥទ្ធិពលអវិជ្ជមាន ដោយសារឧបត្ថមធនពាក់ព័ន្ធនឹងពាណិជ្ជកម្មសេវាកម្មរបស់រដ្ឋសមាជិកផ្សេងទៀត អាចស្នើសុំការពិគ្រោះយោបល់ជាមួយនឹងរដ្ឋសមាជិកនោះអំពីបញ្ហាទាំងនោះ។ រដ្ឋសមាជិកដែលត្រូវបានស្នើសុំ ត្រូវផ្តល់នូវការពិចារណាប្រកបដោយសមានចិត្តចំពោះសំណើ។

៣. ប្រការទាំងឡាយនៃមាត្រា៣៤ (ការដោះស្រាយវិវាទ) មិនត្រូវអនុវត្តចំពោះសំណើណាមួយដែលបានលើកឡើង ឬការពិគ្រោះយោបល់នានាដែលបានប្រព្រឹត្តទៅក្រោមប្រការទាំងឡាយនៃមាត្រានេះឡើយ ឬមិនត្រូវអនុវត្តចំពោះវិវាទទាំងឡាយដែលកើតឡើងរវាងបណ្តារដ្ឋសមាជិកដែលបណ្តាលមកពីឬនៅក្រោមប្រការទាំងឡាយនៃមាត្រានេះ។



អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៥៤១

ផ្នែកទី ៥
កិច្ចសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ

មាត្រា ២៥
ការបង្កើននូវការចូលរួមរបស់សមាគ្រាសធុនមីក្រូ តូច និងមធ្យម នៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន

១. បណ្តារដ្ឋសមាជិកត្រូវលើកកម្ពស់សមត្ថភាពសហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) ដើម្បីចូលរួមនិងទទួលបានអត្ថប្រយោជន៍ពីកាលានុវត្តភាពនានា ដែលបានផ្តល់ជូនដោយកិច្ចព្រមព្រៀងនេះ។

២. បណ្តារដ្ឋសមាជិកត្រូវខិតខំព្យាយាមធ្វើសហប្រតិបត្តិការនៅក្នុងវិស័យដូចខាងក្រោម៖

(ក) ការអភិវឌ្ឍនិងការជំរុញការកសាងសមត្ថភាព ដែលរួមបញ្ចូល តែមិនកំណត់ចំពោះ ការហ្វឹកហ្វឺន ការផ្តល់មគ្គទេសក៍ ការបណ្តុះបណ្តាល និងសិក្ខាសាលា ដើម្បីផ្តល់ព័ត៌មានដល់ MSMEs អំពីអត្ថប្រយោជន៍នានាដែលអាចទទួលបានដោយ MSMEs ក្រោមកិច្ចព្រមព្រៀងនេះ

(ខ) ការសម្របសម្រួលនូវការអភិវឌ្ឍកម្មវិធីនានា ដើម្បីជួយដល់ MSMEs ក្នុងការចូលរួមនិងការធ្វើសមាហរណកម្មប្រកបដោយប្រសិទ្ធភាពទៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ និងខ្សែច្រវាក់តម្លៃសកល

(គ) ការកំណត់និងការលើកឡើងអំពីរបាំងនានា ដែលអាចជាឧបសគ្គដល់ MSMEs ក្នុងការចូលទៅកាន់ទីផ្សាររបស់រដ្ឋសមាជិកផ្សេងទៀត

(ឃ) ការកំណត់និងការឈានឆ្ពោះទៅរកដំណោះស្រាយសមស្រប ដែលអាចទទួលយកបានទៅវិញទៅមក ដើម្បីពង្រឹងសមត្ថភាព MSMEs ក្នុងការចូលរួមសកម្មភាពពាណិជ្ជកម្ម និងវិនិយោគ

(ង) ការដោះដូរព័ត៌មានទៅវិញទៅមក ដើម្បីជួយដល់រដ្ឋសមាជិកក្នុងការគ្រប់គ្រងនិងការអនុវត្តកិច្ចព្រមព្រៀង ដែលពាក់ព័ន្ធជាមួយនឹង MSMEs និង

(ច) សកម្មភាពផ្សេងទៀតដែលនឹងត្រូវព្រមព្រៀងគ្នាទៅវិញទៅមក។

ពុំមានរដ្ឋសមាជិកណាមួយ ត្រូវធ្វើឧបាស្រ័យទៅនឹងការដោះស្រាយវិវាទក្រោមមាត្រា ៣៤ (ការដោះស្រាយវិវាទ) ចំពោះបញ្ហាទាំងឡាយណាដែលកើតឡើងក្រោមមាត្រានេះឡើយ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ២៦
ជំនួយបច្ចេកទេស

បណ្តារដ្ឋសមាជិកបញ្ជាក់អំពីសារៈសំខាន់នៃជំនួយបច្ចេកទេស និងការចែករំលែកចំណេះដឹងនិងបទពិសោធន៍ក្នុងចំណោមបណ្តារដ្ឋសមាជិក ដើម្បីសម្រួលដល់ការរៀបចំតារាងវិធានការបដិណោម ដែលស្របតាមមាត្រា១១ (វិធានការបដិណោម) ដោយអាស្រ័យទៅតាមលទ្ធភាពនៃធនធាន។

មាត្រា ២៧[12]
ការបង្កើននូវការចូលរួមរបស់កម្ពុជា* ឡាវ* មីយ៉ាន់ម៉ា* និងវៀតណាម

១. ដោយបានពិចារណាលើកម្រិតខុសគ្នានៃការអភិវឌ្ឍរបស់បណ្តារដ្ឋសមាជិក កិច្ចព្រមព្រៀងនេះនឹងរួមបញ្ចូលនូវទម្រង់នៃភាពទន់ភ្លន់ដែលសមស្រប រួមទាំងបទប្បញ្ញត្តិនានាសម្រាប់ប្រព្រឹត្តិកម្ម ពិសេសនិងដោយឡែកជូនដល់កម្ពុជា* ឡាវ* មីយ៉ាន់ម៉ា* និងវៀតណាម។

២. ក្នុងន័យនេះ ការបង្កើនការចូលរួមរបស់កម្ពុជា* ឡាវ* មីយ៉ាន់ម៉ា* និងវៀតណាម នៅក្នុងកិច្ចព្រមព្រៀងនេះត្រូវសម្រួលតាមរយៈ៖

(ក) ការពង្រឹងសមត្ថភាពសេវាកម្មក្នុងស្រុក ព្រមទាំងប្រសិទ្ធផលនិងភាពប្រកួតប្រជែងរបស់ខ្លួន *ជាដើម* តាមរយៈការប្រើប្រាស់មធ្យោបាយបច្ចេកវិទ្យាពាក់ព័ន្ធនឹងមូលដ្ឋានពាណិជ្ជកម្ម

(ខ) ការធ្វើឱ្យកាន់តែប្រសើរឡើងនូវការចូលទៅកាន់បណ្តាញចែកចាយ និងបណ្តាញព័ត៌មាន

(គ) ការទទួលស្គាល់ថា ការសន្យារបស់កម្ពុជា* ឡាវ* មីយ៉ាន់ម៉ា* និងវៀតណាម ត្រូវបានធ្វើឡើងស្របតាមដំណាក់កាលនៃការអភិវឌ្ឍរៀងខ្លួនៗ និង

(ឃ) ការផ្តល់ភាពទន់ភ្លន់ដ៏សមស្របសម្រាប់កម្ពុជា* ឡាវ* មីយ៉ាន់ម៉ា* និងវៀតណាម ក្នុងដំណើរការនៃការរៀបចំតារាង និងការធ្វើវិសោធនកម្ម ចំពោះឧបសម្ព័ន្ធរបស់ពួកគេ ដែលយោងតាមមាត្រា១២។

មាត្រា ២៨
ការចូលរួមពីវិស័យឯកជន

១. បណ្តារដ្ឋសមាជិកត្រូវលើកទឹកចិត្តដល់កិច្ចសន្ទនា អន្តរកម្ម និងការកសាងបណ្តាញរវាងអ្នកផ្តត់ផ្តង់សេវាកម្មរបស់ខ្លួន។

២. បណ្តារដ្ឋសមាជិកអាចអញ្ជើញតំណាងនៃអ្នកផ្តត់ផ្តង់សេវាកម្ម ឬសមាគម ដើម្បីផ្តល់ជាធាតុចូល និង/ឬ ទស្សនៈនានា អំពីបញ្ហាទាំងឡាយពាក់ព័ន្ធនឹងពាណិជ្ជកម្មសេវាកម្ម។

---

[12] សម្រាប់ឆ្នាំ២០២៤ ៖) បង្ហាញអំពីប្រទេសអភិវឌ្ឍន៍តិចតួច ដូចបានកំណត់ដោយលក្ខណៈនៃច្បាប់ដែលចេញដោយគណៈកម្មាធិការរបស់ UNOSOC សម្រាប់គោលនយោបាយអភិវឌ្ឍន៍។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ផ្នែកទី ៦

អនុសាសនាឃ្លាន្តិ

មាត្រា ២៩

ទំនាក់ទំនងទៅនឹងកិច្ចព្រមព្រៀងផ្សេងទៀត

ពុំមានអ្វីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវដកហូតនូវសិទ្ធិនិងកាតព្វកិច្ចដែលមានស្រាប់របស់រដ្ឋសមាជិកមួយ ក្រោមកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត[13] ដែលរដ្ឋសមាជិកនោះគឺជាភាគីឡើយ។

មាត្រា ៣០

ឧបសម្ព័ន្ធនិងលិខិតបកររណ៍គតិយុត្តនាពេលអនាគត

១. កិច្ចព្រមព្រៀងនេះត្រូវរួមបញ្ចូលនូវឧបសម្ព័ន្ធនិងមាតិកានានាដូចខាងក្រោម ដែលខ្លឹមសារនៅក្នុងនោះត្រូវបង្កើតជាផ្នែកស្នូលនៃកិច្ចព្រមព្រៀងនេះ៖

(ក) ឧបសម្ព័ន្ធស្តីពីសេវាកម្មហិរញ្ញវត្ថុ

(ខ) ឧបសម្ព័ន្ធស្តីពីសេវាកម្មទូរគមនាគមន៍

(គ) ឧបសម្ព័ន្ធស្តីពីសេវាកម្មគាំទ្រដល់ការដឹកជញ្ជូនផ្លូវអាកាស

(ឃ) ឧបសម្ព័ន្ធ១ ស្តីពីវិធានការបដិលោម និង

(ង) ឧបសម្ព័ន្ធ២ ស្តីពីវិធានការបដិលោម

២. រាល់លិខិតបកររណ៍គតិយុត្តនាពេលអនាគតនានាដែលបានឯកភាពគ្នា ស្របតាមកិច្ចព្រមព្រៀងនេះត្រូវបង្កើតជាផ្នែកស្នូលនៃកិច្ចព្រមព្រៀងនេះផងដែរ។

មាត្រា៣១

យន្តការស្ថាប័ន

១. រដ្ឋមន្ត្រីAEM ត្រូវមានការកិច្ចទទួលខុសត្រូវ ចំពោះការអនុវត្តកិច្ចព្រមព្រៀងនេះ។

២. រដ្ឋមន្ត្រីAEM ត្រូវសម្របសម្រួលនិងត្រួតពិនិត្យលើ ការអនុវត្តកិច្ចព្រមព្រៀងនេះដោយគ្រប់បណ្តារដ្ឋសមាជិក និងគ្រប់គណៈអាស៊ាននានាដែលពាក់ព័ន្ធ។

៣. សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ គណៈកម្មាធិការសម្របសម្រួលអាស៊ានស្តីពីសេវាកម្ម (CCS) និងមន្ត្រីរដ្ឋាភិបាលពាក់ព័ន្ធ ត្រូវជួយដល់រដ្ឋមន្ត្រីAEM ក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ។

[13] ឧទាហរណ៍ កិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត- រួមបញ្ចូលទាំង កិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងពន្ធ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៤. នៅក្នុងការបំពេញមុខងាររបស់ខ្លួន រដ្ឋមន្ត្រីAEM អាចនឹងបង្កើតគណៈបុត្រសម្ព័ន្ធ និងចាត់តាំងពួកគេឱ្យ ប្រតិបត្តិ/អនុវត្ត/បំពេញ កិច្ចការដាក់លាក់នានា រឺធ្វើប្រតិភូកម្មការទទួលខុសត្រូវរបស់ខ្លួនឱ្យទៅគណៈបុត្រសម្ព័ន្ធណាមួយ។

មាត្រា៣២
ការពិនិត្យឡើងវិញ

ដោយមានទស្សនៈក្នុងការអនុវត្តនូវគោលបំណងនៃកិច្ចព្រមព្រៀងនេះបន្ថែមទៀត បណ្តារដ្ឋសមាជិកត្រូវអនុវត្តនូវការពិនិត្យឡើងវិញទូទៅលើប្រការនានារបស់កិច្ចព្រមព្រៀងនេះ ក្នុងអំឡុងពេល៥ឆ្នាំបន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀង។ ជារៀងរាល់៥ឆ្នាំបន្ទាប់ពីនោះ បណ្តារដ្ឋសមាជិកត្រូវអនុវត្តនូវការពិនិត្យឡើងវិញជាបន្តបន្ទាប់លើប្រការនានានៃកិច្ចព្រមព្រៀង រួមជាមួយគ្នានឹងតារាងវិធានការបដិលោម វៀរលែងតែមានការឯកភាពផ្ទុយពីនេះដោយបណ្តារដ្ឋសមាជិក។

មាត្រា៣៣
វិសោធនកម្ម

១. ប្រការទាំងឡាយនៃកិច្ចព្រមព្រៀងនេះ អាចនឹងត្រូវបានកែប្រែតាមរយៈការធ្វើវិសោធនកម្មដែលមានការឯកភាពទៅវិញទៅមកជាលាយលក្ខណ៍អក្សរដោយបណ្តារដ្ឋសមាជិក។

២. ថ្វីបើមានចែងនៅក្នុងកថាខណ្ឌ១ ឧបសម្ព័ន្ធនានាដូចមានចែងក្នុងកថាខណ្ឌ១ នៃមាត្រា៣០ (ឧបសម្ព័ន្ធនិងលិខិតបកអណ៍គតិយុត្តនាពេលអនាគត) អាចនឹងត្រូវបានកែប្រែតាមរយៈការធ្វើវិសោធនកម្មដែលអនុម័តដោយ កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន កិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលធនាគារកណ្តាលអាស៊ាន ឬកិច្ចប្រជុំរដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ានតាមការសមគួរ។ ការធ្វើវិសោធនកម្មបែបនេះ ត្រូវដាក់ជាឧបសម្ព័ន្ធតាមបែបបទរដ្ឋបាលទៅនឹងកិច្ចព្រមព្រៀងនេះ និងប្រើប្រាស់ជាផ្នែកសួលនៃកិច្ចព្រមព្រៀងនេះ។

មាត្រា៣៤
ការដោះស្រាយវិវាទ

វៀរលែងតែត្រូវបានបញ្ជាក់ផ្សេងទៀតនៅក្នុងកិច្ចព្រមព្រៀងនេះ ពិធីសារអាស៊ានស្តីពីការលើកកម្ពស់យន្តការដោះស្រាយវិវាទ ដែលបានចុះហត្ថលេខានៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤ នៅទីក្រុងវៀងចន្ទន៍ ប្រទេសឡាវ ឬពិធីសារក្រោយៗទៀតរបស់ពិធីសារនេះត្រូវអនុវត្តចំពោះការដោះស្រាយវិវាទពាក់ព័ន្ធនឹងការបកស្រាយឬការអនុវត្តកិច្ចព្រមព្រៀងនេះ។

មាត្រា៣៥
ការបដិសេធផលប្រយោជន៍

រដ្ឋសមាជិកម្នាក់អាចបដិសេធចំពោះការផ្តល់ផលប្រយោជន៍ពីកិច្ចព្រមព្រៀងនេះ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

(ក) ចំពោះការផ្តត់ផ្តង់សេវាកម្មណាមួយ ប្រសិនបើរកឃើញថា សេវាកម្មនោះត្រូវបានផ្តត់ផ្តង់មកពីឬនៅក្នុងដែនដីនៃរដ្ឋមិនមែនសមាជិក

(ខ) ក្នុងករណីការផ្តត់ផ្តង់សេវាកម្មដឹកជញ្ជូនតាមដែនសមុទ្រ ប្រសិនបើរកឃើញថា សេវាកម្មនោះត្រូវបានផ្តត់ផ្តង់៖

(i) ដោយនាវាដែលបានចុះបញ្ជីក្រោមច្បាប់របស់រដ្ឋមិនមែនសមាជិក និង

(ii) ដោយបុគ្គលនៃរដ្ឋមិនមែនសមាជិក ដែលធ្វើប្រតិបត្តិការ និង/ឬ ប្រើប្រាស់នាវានោះទាំងមូលឬដោយផ្នែក

(គ) ចំពោះអ្នកផ្តត់ផ្តង់សេវាកម្មដែលជានីតិបុគ្គល ប្រសិនបើរកឃើញថា នីតិបុគ្គលនោះមិនមែនជាអ្នកផ្តត់ផ្តង់សេវាកម្មនៃរដ្ឋសមាជិកផ្សេងទៀត។

មាត្រា៣៦
ការរៀបចំអន្តរកាលពាក់ព័ន្ធនឹងកិច្ចព្រមព្រៀង AFAS

១. ដោយយោងតាមមាត្រា១២ (ការផ្លាស់ប្តូរទៅជាតារាងវិធានការបដិលោម) កិច្ចព្រមព្រៀងAFAS និងតារាងនៃការសន្យារបស់កិច្ចព្រមព្រៀងAFAS ដែលធ្វើឡើងដោយបណ្តារដ្ឋសមាជិកក្រោមកិច្ចព្រមព្រៀងAFAS ដែលបានចុះហត្ថលេខាដោយ រដ្ឋមន្ត្រីAEM រដ្ឋមន្ត្រីAFM និងរដ្ឋមន្ត្រីATM នឹងនៅតែមានសុពលភាព *ហើយត្រូវយកមកអនុវត្តដូចគ្នា* ហូតដល់រយៈពេល៧ឆ្នាំបន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ រហូតដល់រយៈពេល៩ឆ្នាំបន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងចំពោះវៀតណាម ឬរហូតដល់រយៈពេល១៥ឆ្នាំបន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះចំពោះកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។

២. កិច្ចព្រមព្រៀងAFAS ព្រមទាំងពិធីសារទាំងឡាយរបស់កិច្ចព្រមព្រៀងAFAS ត្រូវជំនួសដោយកិច្ចព្រមព្រៀងនេះនិងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ បន្ទាប់ពីការបញ្ចប់ពេញលេញនៃរយៈពេលរៀងៗខ្លួនដូចមានចែងក្នុងកថាខណ្ឌ១។

មាត្រា៣៧
ការចូលជាធរមាន

១. កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមានក្នុងរយៈពេលមួយរយប៉ែតសិប(១៨០)ថ្ងៃ បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

២. បណ្តារដ្ឋសមាជិកត្រូវបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួន សម្រាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។ បន្ទាប់ពីការបញ្ចប់នៃនីតិវិធីផ្ទៃក្នុងរបស់ខ្លួនសម្រាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ រដ្ឋសមាជិកនីមួយៗត្រូវជូនដំណឹងដល់អគ្គលេខាធិការអាស៊ានជាលាយលក្ខណ៍អក្សរ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៣. ករណីដែលរដ្ឋសមាជិកមួយមិនអាចធ្វើការជូនដំណឹងអំពីការបញ្ចប់នៃនីតិវិធីផ្ទៃក្នុងរបស់ខ្លួនក្នុងរយៈពេលមួយរយប៉ែតសិប(១៨០)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចុះហត្ថលេខា នោះសិទ្ធិនិងកាតព្វកិច្ចរបស់រដ្ឋសមាជិកនោះក្រោមកិច្ចព្រមព្រៀងនេះ ត្រូវចាប់ផ្តើមក្នុងកាលបរិច្ឆេទដែលរដ្ឋសមាជិកនោះជូនដំណឹងអំពីការបញ្ចប់នៃនីតិវិធីផ្ទៃក្នុងរបស់ខ្លួន។

៤. អគ្គលេខាធិការអាស៊ានត្រូវជូនដំណឹងភ្លាមៗដល់បណ្តារដ្ឋសមាជិកទាំងអស់ អំពីការជូនដំណឹងឬការដាក់តម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ននីមួយៗ ដូចមានចែងក្នុងកថាខណ្ឌ២ នៃមាត្រានេះ។

មាត្រាទី ៣៨
ការតម្កល់ទុក

កិច្ចព្រមព្រៀងនេះត្រូវតែម្កល់ទុកជាមួយនឹងអគ្គលេខាធិការអាស៊ាន ដែលជាអ្នកត្រូវផ្តល់ជូនភ្លាមៗនូវច្បាប់ចម្លងដែលមានការបញ្ជាក់ ទៅកាន់រដ្ឋសមាជិកនីមួយៗ។

ជាសក្ខីភាព ហត្ថលេខីខាងក្រោម ដោយទទួលបានសិទ្ធិប្រទានពេញលេញដែលផ្តល់ដោយរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មអាស៊ាន។

បានធ្វើ នៅរដ្ឋធានីម៉ានីល សាធារណរដ្ឋហ្វីលីពីន នាថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០ ក្នុងឯកសារច្បាប់ដើមតែមួយគត់ជាភាសាអង់គ្លេស។

តំណាងរដ្ឋាភិបាលព្រុយណេ

តំណាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

តំណាងរដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌូណេស៊ី

តំណាងរដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

តំណាងរដ្ឋាភិបាលម៉ាឡេស៊ី

តំណាងរដ្ឋាភិបាលសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា

តំណាងរដ្ឋាភិបាលសាធារណរដ្ឋហ្វីលីពីន

តំណាងរដ្ឋាភិបាលសាធារណរដ្ឋសិង្ហបុរី

តំណាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ

តំណាងរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ឧបសម្ព័ន្ធស្តីពីសេវាកម្មហិរញ្ញវត្ថុ

មាត្រា១
វិសាលភាព

១. ឧបសម្ព័ន្ធនេះអនុវត្តចំពោះវិធានការនានាដែលជះឥទ្ធិពលដល់ការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ។ ការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុនៅក្នុងឧបសម្ព័ន្ធនេះ ត្រូវសំដៅដល់ការផ្គត់ផ្គង់សេវាកម្ម៖

(ក) ចេញពីដែនដីនៃរដ្ឋសមាជិកមួយ ចូលទៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត (ម៉ូដទី១៖ ការផ្គត់ផ្គង់សេវាកម្មឆ្លងកាត់ព្រំដែន)

(ខ) នៅក្នុងដែនដីនៃរដ្ឋសមាជិកមួយ ទៅដល់អ្នកប្រើប្រាស់សេវាកម្មនៃរដ្ឋសមាជិកផ្សេងទៀត (ម៉ូដទី២៖ ការប្រើប្រាស់សេវាកម្មនៅបរទេស)

(គ) ដោយអ្នកផ្គត់ផ្គង់សេវាកម្មនៃរដ្ឋសមាជិកមួយ តាមរយៈវត្តមានពាណិជ្ជកម្មនៅក្នុងដែនដីនៃរដ្ឋសមាជិកដទៃទៀត (ម៉ូដទី៣៖ វត្តមានពាណិជ្ជកម្ម)

(ឃ) ដោយអ្នកផ្គត់ផ្គង់សេវាកម្មនៃរដ្ឋសមាជិកមួយ តាមរយៈវត្តមានរូបវន្តបុគ្គលនៃរដ្ឋសមាជិកនៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត (ម៉ូដទី៤៖ វត្តមានរូបវន្តបុគ្គល)។

២. ឧបសម្ព័ន្ធនេះមិនអនុវត្តចំពោះ សេវាកម្មដែលត្រូវបានផ្គត់ផ្គង់ដោយប្រើប្រាស់សិទ្ធិអំណាចដែលផ្តល់ដោយរដ្ឋាភិបាល ដូចខាងក្រោម៖

(ក) រាល់សកម្មភាពដែលអនុវត្តដោយធនាគារកណ្តាលឬអាជ្ញាធរប្រឹយវត្ត ឬដោយអង្គភាពសាធារណៈផ្សេងទៀត ក្នុងការតាមដានគោលនយោបាយរូបិយវត្ថុឬអត្រាប្តូរប្រាក់

(ខ) រាល់សកម្មភាពដែលជាផ្នែកនៃប្រព័ន្ធកំណត់ដោយច្បាប់ ពាក់ព័ន្ធនឹងសន្តិសុខសង្គម ឬផែនការចូលនិវត្តន៍សាធារណៈ ឬ

(គ) សកម្មភាពផ្សេងទៀតដែលធ្វើឡើងដោយអង្គភាពសាធារណៈសម្រាប់គណនី ឬការធានា ឬការប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់រដ្ឋាភិបាល។

៣. សម្រាប់គោលបំណងនៃឧបសម្ព័ន្ធនេះ ប្រសិនបើរដ្ឋសមាជិកអនុញ្ញាតឱ្យមានសកម្មភាពណាមួយ ដូចមានចែងក្នុងវាក្យខណ្ឌ២(ខ) ឬ ២(គ) ដែលអនុវត្តដោយអ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុរបស់ខ្លួន ក្នុងការប្រកួតប្រជែងជាមួយអង្គភាពសាធារណៈ ឬអ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុណាមួយ "សេវាកម្ម" ត្រូវរួមបញ្ចូលនូវសកម្មភាពបែបនោះ។

ដើម្បីឱ្យកាន់តែច្បាស់ ឧបសម្ព័ន្ធនេះត្រូវមានអធិកភាពបើទោះជាមានអសង្គតិភាពណាមួយទៅនឹងបទប្បការផ្សេងទៀតនៅក្នុងកិច្ចព្រមព្រៀងនេះ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា២
និយមន័យ

សម្រាប់គោលបំណងនៃឧបសម្ព័ន្ធនេះ៖

(ក) **ការផ្តត់ផ្គង់សេវាកម្មហិរញ្ញវត្ថុឆ្លងកាត់ព្រំដែន** សំដៅដល់ ការផ្តត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ នៅក្នុងវាក្យខណ្ឌ១(ក) និង (ខ) នៃមាត្រា១ (វិសាលភាព) នៃឧបសម្ព័ន្ធនេះ

(ខ) **គ្រឹះស្ថានហិរញ្ញវត្ថុ** សំដៅដល់ អន្តរការីហិរញ្ញវត្ថុ ឬសមាគ្រាសផ្សេងទៀត ដែលត្រូវបានអនុញ្ញាតឱ្យធ្វើអាជីវកម្ម នឹងត្រូវបានគ្រប់គ្រងឬត្រួតពិនិត្យដោយធនាគារកណ្តាល អាជ្ញាធរប៉ិយវត្ថុ ឬអាជ្ញាធរសេវាកម្មហិរញ្ញវត្ថុ ដោយស្ថិតក្រោមច្បាប់នៃរដ្ឋសមាជិក ដែលជាម្ចាស់ដែនដីដែលខ្លួនដាក់ទីតាំង។

(គ) "**សេវាកម្មហិរញ្ញវត្ថុ**" សំដៅដល់ សេវាកម្មទាំងឡាយណាដែលមានចរិតលក្ខណៈហិរញ្ញវត្ថុ ផ្តល់ដោយអ្នកផ្តត់ផ្គង់សេវាកម្មហិរញ្ញវត្ថុនៃរដ្ឋសមាជិកមួយ។ សេវាកម្មហិរញ្ញវត្ថុ រួមមាន សេវាកម្មធានារ៉ាប់រងនិងសេវាកម្មពាក់ព័ន្ធនឹងការធានារ៉ាប់រង ព្រមទាំងសេវាកម្មធនាគារ និងសេវាកម្មហិរញ្ញវត្ថុផ្សេងទៀត (ក្រៅពីការធានារ៉ាប់រង)។ សេវាកម្មហិរញ្ញវត្ថុ រួមបញ្ចូលនូវសកម្មភាពដូចខាងក្រោម៖

សេវាកម្មធានារ៉ាប់រងនិងសេវាកម្មពាក់ព័ន្ធនឹងការធានារ៉ាប់រង

(i) សេវាកម្មធានារ៉ាប់រងផ្ទាល់(រួមទាំងសហធានារ៉ាប់រង)៖
   ក. អាយុជីវិត
   ខ. មិនមែនអាយុជីវិត

(ii) ការធានារ៉ាប់រងបន្តនិងការផ្ទេរហានិភ័យសេវាកម្មធានារ៉ាប់រងបន្ត

(iii) អន្តរការីធានារ៉ាប់រង ដូចជា ឈ្មួញកណ្តាលនិងភ្នាក់ងារធានារ៉ាប់រង

(iv) សេវាកម្មទ្រទ្រង់ដល់ការធានារ៉ាប់រង មានដូចជា ការប្រឹក្សាយោបល់ ការគណនានិងការវិភាគផ្សេងៗ ការវាយតម្លៃលើហានិភ័យ និងសេវាកម្មទូទាត់ចំពោះការទាមទារផលប្រយោជន៍។

សេវាកម្មធនាគារនិងសេវាកម្មហិរញ្ញវត្ថុផ្សេងទៀត (ក្រៅពីការធានារ៉ាប់រង)

(v) ការទទួលប្រាក់បញ្ញើនិងការទទួលមូលនិធិសំណងផ្សេងទៀតពីសាធារណជន

(vi) ការផ្តល់ឥណទានគ្រប់ប្រភេទ រួមមាន ឥណទានអតិថិជន ឥណទានអ៊ីប៉ូតែក ការទិញបំណុលនិងការផ្តល់ហិរញ្ញប្បទានចំពោះប្រតិបត្តិការពាណិជ្ជកម្ម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

(vii) កតិសន្យាហិរញ្ញវត្ថុ

(viii) ការសៅកម្មទូទាត់និងផ្ទេរប្រាក់ រួមបញ្ចូល ឥណទាន កម្រៃផ្សេងៗ ប័ណ្ណឥណពន្ធ មូលប្បទានបត្រសម្រាប់អ្នកធ្វើដំណើរ និងមូលប្បទានបត្រធនាគារ

(ix) ការធានានិងការសន្យា

(x) ការធ្វើពាណិជ្ជកម្មសម្រាប់គណនីផ្ទាល់ខ្លួន ឬគណនីរបស់អតិថិជន មិនថាជាការដោះដូរឬយ៉ាងណា នៅក្នុងទីផ្សារជួញដូរកាគហ៊ុនបន្ទាប់បន្សំ ឬក្រៅពីនេះ មានដូចតទៅ៖

ក. ឧបករណ៍ទីផ្សាររូបិយវត្ថុ (រួមមានមូលប្បទានបត្រ រូបិយណត្តិ វិញ្ញាបនបត្រប្រាក់បញ្ញើ)

ខ. ទីផ្សារប្តូរប្រាក់

គ. ឧបករណ៍និស្សន្ទ រួមមានប៉ុន្តែមិនកម្រិតចំពោះ កិច្ចសន្យាអនាគត និងអុបសិន

ឃ. ឧបករណ៍អត្រាប្តូរប្រាក់និងអត្រាការប្រាក់ រួមបញ្ចូលទាំងផលិតផលដូចជាប្រតិបត្តិការស្វប់ កិច្ចព្រមព្រៀងអត្រាការប្រាក់ក្នុងពេលអនាគត

ង. មូលបត្រដែលអាចផ្ទេរបាន និង

ច. ឧបករណ៍អាចជួញដូរបានផ្សេងទៀត និងទ្រព្យសកម្មហិរញ្ញវត្ថុ រួមទាំងមាសដុំ

(xi) ការចូលរួមក្នុងការបោះផ្សាយមូលបត្រគ្រប់ប្រភេទ រួមមាន ការធានាទិញនិងការជាក់លក់មូលបត្រចង្អៀតក្នុងនាមជាភ្នាក់ងារ (មិនថាជាលក្ខណៈសាធារណៈឬឯកជន) និងការផ្តល់នូវសៅកម្មដែលពាក់ព័ន្ធនឹងការបោះផ្សាយទាំងនោះ

(xii) អាជីវកម្មឈ្មួញកណ្តាលជួញដូររូបិយវត្ថុ

(xiii) ការគ្រប់គ្រងទ្រព្យសកម្ម ដូចជា ការគ្រប់គ្រងសាច់ប្រាក់ ឬផលបត្រ គ្រប់ទម្រង់នៃការគ្រប់គ្រងការវិនិយោគរួម ការគ្រប់គ្រងមូលនិធិសោធន សៅកម្មមូលបត្រ សៅកម្មរក្សាទុក និងបរិធានបាលកិច្ច

(xiv) សៅកម្មដាត់ទាត់និងទូទាត់សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ រួមមានមូលបត្រ ឧបករណ៍និស្សន្ទ និងឧបករណ៍អាចជួញដូរបានផ្សេងទៀត

(xv) ការផ្តល់និងការផ្ទេរព័ត៌មានហិរញ្ញវត្ថុ និងដំណើរការទិន្នន័យហិរញ្ញវត្ថុ និងកម្មវិធីកុំព្យូទ័រពាក់ព័ន្ធ ដោយអ្នកផ្តត់ផ្គង់សៅកម្មហិរញ្ញវត្ថុផ្សេងទៀត និង



(xvi) ការផ្តល់ការប្រឹក្សាយោបល់ អន្តរការិយកម្ម និងសេវាកម្មទ្រទ្រង់ដល់សេវាកម្មហិរញ្ញវត្ថុផ្សេងទៀត សម្រាប់គ្រប់សកម្មភាពដូចមានចែងនៅក្នុងវាក្យខណ្ឌ (v) ដល់ (xv) ដែលរួមបញ្ចូលទាំងរបាយការណ៍និងការវិភាគឥណទាន ការវិនិយោគនិងការស្រាវជ្រាវលើផលបត្រ និងអនុសាសន៍ ដំបូន្មានអំពីការទិញយកនិងការរៀបចំរចនាសម្ព័ន្ធសាជីវកម្មនិងយុទ្ធសាស្ត្រ

(ឃ) "**អ្នកផ្តត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ**" សំដៅដល់ រូបវន្តបុគ្គលឬនីតិបុគ្គលនៃរដ្ឋសមាជិកមួយដែលមានបំណងផ្តត់ផ្គង់ឬកំពុងផ្តត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ ប៉ុន្តែវាក្យសព្ទ "អ្នកផ្តត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ" នេះ មិនរាប់បញ្ចូលអង្គភាពសាធារណៈឡើយ

(ង) "**សេវាកម្មហិរញ្ញវត្ថុថ្មី**" សំដៅដល់ សេវាកម្មហិរញ្ញវត្ថុដែលមិនមានផ្តត់ផ្គង់ដោយអ្នកផ្តត់ផ្គង់សេវាកម្មហិរញ្ញវត្ថុណាមួយនៅក្នុងដែនដីនៃរដ្ឋសមាជិកមួយ ប៉ុន្តែត្រូវបានផ្តត់ផ្គង់ និងត្រូវបានគ្រប់គ្រងនៅក្នុងដែនដីនៃរដ្ឋសមាជិកផ្សេងទៀត។ សេវាកម្មទាំងនោះអាចរួមបញ្ចូលនូវសេវាកម្មពាក់ព័ន្ធនឹងផលិតផលដែលមានស្រាប់និងថ្មី ឬក្នុងលក្ខណៈមួយដែលផលិតផលនោះត្រូវបានចែកចាយ។

(ច) "**អង្គភាពសាធារណៈ**" សំដៅដល់៖

(i) រដ្ឋាភិបាល ធនាគារកណ្តាល ឬអាជ្ញាធររូបិយវត្ថុនៃរដ្ឋសមាជិកមួយ ឬអង្គភាពមួយដែលត្រូវបានកាន់កាប់ឬគ្រប់គ្រងដោយរដ្ឋសមាជិកមួយ ដែលជាទូទៅចូលរួមអនុវត្តមុខងាររបស់រដ្ឋាភិបាល ឬសកម្មភាពនានាសម្រាប់បំពេញគោលបំណងរបស់រដ្ឋាភិបាល មិនរួមបញ្ចូលអង្គភាពដែលជាទូទៅផ្តត់ផ្គង់សេវាកម្មហិរញ្ញវត្ថុតាមបែបលក្ខណៈពាណិជ្ជកម្មឡើយ ឬ

(ii) អង្គភាពឯកជនដែលបំពេញនូវមុខងារនានា ដែលជាធម្មតាមុខងារទាំងនោះច្រើនតែបំពេញដោយធនាគារកណ្តាលឬអាជ្ញាធររូបិយវត្ថុ នៅពេលដែលអង្គភាពឯកជននោះអនុវត្តនូវមុខងារទាំងនោះ និង

(ឆ) "**អង្គភាពស្វ័យនិយតករ**" សំដៅដល់ ស្ថាប័នមិនមែនរដ្ឋាភិបាលទាំងឡាយណា រួមមានក្រុមហ៊ុនផ្សារមូលបត្រឬក្រុមហ៊ុនផ្សារអនាគត ភ្នាក់ងារទូទាត់ឬផាត់ទាត់ អង្គភាពឬសមាគមផ្សេងទៀត ដែល៖

(i) ត្រូវបានទទួលស្គាល់ថាជាអង្គភាពស្វ័យនិយតករ និង/ឬ

(ii) អនុវត្តអំណាចរៀបចំបទប្បញ្ញត្តិនិងត្រួតពិនិត្យ ទៅលើអ្នកផ្តត់ផ្គង់សេវាកម្មហិរញ្ញវត្ថុឬគ្រឹះស្ថានហិរញ្ញវត្ថុ នៅក្នុងដែនដីរបស់ខ្លួន

ដោយអនុលោមតាមក្របខ័ណ្ឌគតិយុត្តិ ឬតាមប្រតិកូកម្មអំណាចពីរដ្ឋាភិបាលឬអាជ្ញាធរថ្នាក់កណ្តាល ថ្នាក់តំបន់ ឬថ្នាក់មូលដ្ឋាន។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា៣
សេវាកម្មហិរញ្ញវត្ថុថ្មី

រដ្ឋសមាជិកនីមួយៗ ("រដ្ឋសមាជិកជាម្ចាស់ផ្ទះ") ត្រូវផ្តល់ការផ្តល់ការពិចារណាប្រកបដោយហេតុផល ចំពោះការដាក់ពាក្យស្នើសុំដោយគ្រឹះស្ថានហិរញ្ញវត្ថុរបស់រដ្ឋសមាជិកផ្សេងទៀត ដែលត្រូវបានបង្កើតនៅក្នុងដែនដីនៃរដ្ឋសមាជិកជាម្ចាស់ផ្ទះ ដើម្បីធ្វើការផ្តល់សេវាកម្មហិរញ្ញវត្ថុថ្មីណាមួយនៅក្នុងដែនដីនៃរដ្ឋសមាជិកជាម្ចាស់ផ្ទះ ដែលរដ្ឋសមាជិកជាម្ចាស់ផ្ទះនោះក៏បានផ្តល់ការអនុញ្ញាតដល់គ្រឹះស្ថានហិរញ្ញវត្ថុរបស់ខ្លួន ស្ថិតក្នុងលក្ខខណ្ឌដូចគ្នា ដើម្បីធ្វើការផ្តត់ផ្តង់ដោយពុំចាំបាច់អនុម័តច្បាប់ឬកែប្រែច្បាប់ដែលមានស្រាប់[1]។

ករណីដែលពាក្យស្នើសុំទទួលបានការឯកភាព ការផ្តល់សេវាកម្មហិរញ្ញវត្ថុថ្មីគឺត្រូវអាស្រ័យទៅនឹងការផ្តល់អាជ្ញាប័ណ្ណ ទម្រង់ស្ថាប័នឬគតិយុត្ត ឬការតម្រូវផ្សេងទៀតរបស់រដ្ឋសមាជិកជាម្ចាស់ផ្ទះ។

មាត្រា៤
វិធានការការពារសុវត្ថិភាព

១. ថ្វីបើមានចែងក្នុងប្រការផ្សេងទៀតទាំងឡាយនៃកិច្ចព្រមព្រៀងនេះ រដ្ឋសមាជិកមួយមិនត្រូវបានរារាំងពីការដាក់ចេញនូវវិធានការនានាក្នុងមូលហេតុនៃការប្រុងប្រយ័ត្នឡើយ រួមមាន សម្រាប់ការការពារវិនិយោគិន អ្នកតម្កល់ប្រាក់ ម្ចាស់ប័ណ្ណធានារ៉ាប់រង ឬអ្នកទទួលបានតួនាទីក្សាទុកចិត្តដែលជំពាក់ដោយអ្នកផ្តត់ផ្តង់សេវាកម្មហិរញ្ញវត្ថុមួយ ឬដើម្បីធានានូវបូរណភាពនិងស្ថិរភាពនៃប្រព័ន្ធហិរញ្ញវត្ថុ ឬដើម្បីធានានូវស្ថិរភាពនៃអត្រាប្តូរប្រាក់ ដែលមានលក្ខខណ្ឌដូចខាងក្រោម៖

(ក) ករណីដែលវិធានការទាំងនោះ មិនស្របទៅនឹងប្រការនានានៃកិច្ចព្រមព្រៀងនេះ វិធានការទាំងនោះមិនត្រូវប្រើប្រាស់ជាមធ្យោបាយ ក្នុងការចៀសវាងការសន្យាឬកាតព្វកិច្ចរបស់រដ្ឋសមាជិកនោះនៅក្រោមកិច្ចព្រមព្រៀងនេះឡើយ និង

(ខ) ចំពោះវិធានការដើម្បីធានានូវស្ថិរភាពនៃអត្រាប្តូរប្រាក់ វិធានការទាំងនោះត្រូវធ្វើឡើងមិនឱ្យលើសពីភាពចាំបាច់ និងត្រូវបានលុបចោល នៅពេលដែលលក្ខខណ្ឌនានាលែងឆ្លុះបញ្ចាំងពីភាពសមហេតុផលនៃការប្រព្រឹត្តទៅឬការរក្សាទុក ហើយវិធានការទាំងនោះត្រូវអនុវត្តដោយផ្អែកលើមូលដ្ឋានប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត។

២. ពុំមានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយដើម្បីតម្រូវឱ្យរដ្ឋសមាជិកមួយលាតត្រដាងនូវព័ត៌មានពាក់ព័ន្ធនឹងកិច្ចការនិងគណនីបុគ្គលរបស់អតិថិជន ឬព័ត៌មានដែលជាការសម្ងាត់ឬព័ត៌មានពាក់ព័ន្ធនឹងផលប្រយោជន៍ ដែលជាកម្មសិទ្ធិរបស់អង្គភាពសាធារណៈឡើយ។

---

[1] ដើម្បីឱ្យកាន់តែច្បាស់ រដ្ឋសមាជិកមួយអាចដាក់ចេញនូវបទប្បញ្ញត្តិថ្មី ឬវិធានការពាក់ព័ន្ធបន្ថែមផ្សេងទៀត ក្នុងការអនុញ្ញាតចំពោះការផ្តត់ផ្តង់នៃសេវាកម្មហិរញ្ញវត្ថុថ្មី។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា៥
ការទទួលស្គាល់

១. រដ្ឋសមាជិកមួយអាចទទួលស្គាល់វិធានការប្រុងប្រយ័ត្នរបស់រដ្ឋផ្សេងៗទៀត ឬស្ថាប័នដែលរៀបចំស្តង់ដាអន្តរជាតិនានា ក្នុងការកំណត់ពីរបៀបដែលវិធានការរបស់រដ្ឋសមាជិកពាក់ព័ន្ធនឹងសេវាកម្មហិរញ្ញវត្ថុត្រូវបានអនុវត្ត[2]។ ការទទួលស្គាល់បែបនេះ ដែលអាចនឹងសម្រេចទៅបានតាមរយៈការធ្វើសុខដុមនីយកម្មឬតាមមធ្យោបាយផ្សេងទៀត អាចផ្អែកលើកិច្ចព្រមព្រៀងឬកិច្ចសម្របសម្រួលណាមួយជាមួយនឹងរដ្ឋពាក់ព័ន្ធ ឬស្ថាប័នដែលរៀបចំស្តង់ដាអន្តរជាតិនានា ឬក៏អាចផ្តល់ជូនរដោយស្វយ័ត។

២. រដ្ឋសមាជិកមួយដែលជាភាគីនៃកិច្ចព្រមព្រៀងឬកិច្ចសម្របសម្រួលបែបនោះ ដូចមានចែងក្នុងកថាខណ្ឌ១ មិនថានៅពេលអនាគតឬមានស្រាប់ ត្រូវផ្តល់នូវកាលានុវត្តភាពគ្រប់គ្រាន់សម្រាប់រដ្ឋសមាជិកផ្សេងទៀតដែលមានចំណាប់អារម្មណ៍ ដើម្បីចរចាលើការចូលរួមរបស់ពួកគេនៅក្នុងកិច្ចព្រមព្រៀងឬកិច្ចសម្របសម្រួលនោះ ឬដើម្បីចរចាលើកិច្ចព្រមព្រៀងឬកិច្ចសម្របសម្រួលដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ដោយស្ថិតក្រោមកាលៈទេសៈដែលមាននូវបទប្បញ្ញត្តិការគ្រប់គ្រង ការអនុវត្តបទប្បញ្ញត្តិនោះ ដែលមានលក្ខណៈសមមូល ហើយប្រសិនបើសមគួរនីតិវិធីនានាពាក់ព័ន្ធនឹងការចែករំលែកព័ត៌មានរវាងភាគីនៃកិច្ចព្រមព្រៀងឬកិច្ចសម្របសម្រួលនោះ។ ករណីដែលរដ្ឋសមាជិកមួយផ្តល់នូវការទទួលស្គាល់ដោយស្វយ័ត រដ្ឋសមាជិកនោះត្រូវផ្តល់នូវកាលានុវត្តភាពគ្រប់គ្រាន់សម្រាប់រដ្ឋសមាជិកផ្សេងទៀត ដើម្បីបំភ្លឺថា កាលៈទេសៈបែបនោះពិតជាមានមែន។

មាត្រា៦
តម្លាភាព

១. បណ្តារដ្ឋសមាជិកទទួលស្គាល់ថា បទប្បញ្ញត្តិនិងគោលនយោបាយគ្រប់គ្រងលើសកម្មភាពនានានៃសេវាកម្មហិរញ្ញវត្ថុដែលប្រកបដោយតម្លាភាព មានសារៈសំខាន់ក្នុងការសម្របសម្រួលដល់អ្នកផ្តត់ផ្តង់សេវាកម្មហិរញ្ញវត្ថុបរទេស ឱ្យមានលទ្ធភាពឈានចូលទៅកាន់និងធ្វើប្រតិបត្តិការនៅក្នុងទីផ្សាររវាងគ្នានិងគ្នា។ រដ្ឋសមាជិកនីមួយៗប្តេជ្ញាចិត្តក្នុងការជំរុញតម្លាភាពបទប្បញ្ញត្តិនៅក្នុងសេវាកម្មហិរញ្ញវត្ថុ។

២. រដ្ឋសមាជិកនីមួយៗត្រូវជានាថា វិធានការនៃការអនុវត្តទូទៅដែលត្រូវបានអនុម័តឬក្សាទុកដោយរដ្ឋសមាជិកនោះ ត្រូវបានផ្សព្វផ្សាយទាន់ពេលវេលា ឬម៉្យាងទៀតធ្វើយ៉ាងណាឱ្យអាចរកបានជាសាធារណៈ។ ព័ត៌មានទាំងនោះអាចត្រូវបានផ្សព្វផ្សាយជាភាសាតាមជម្រើសរបស់

---

[2] ដើម្បីឱ្យកាន់តែច្បាស់ ពុំមានអ្វីនៅក្នុងមាត្រា១១ (ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត) នៃឧបសម្ព័ន្ធនេះត្រូវបានបំភ្លេចចោលដើម្បីតម្រូវឱ្យរដ្ឋសមាជិកផ្តល់នូវការទទួលស្គាល់វិធានការប្រុងប្រយ័ត្នរបស់រដ្ឋសមាជិកផ្សេងទៀតឡើយ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ដ្ឋសមាជិក។ ដ្ឋសមាជិកនីមួយៗ ត្រូវខិតខំព្យាយាមក្នុងការផ្សព្វផ្សាយជាភាសាអង់គ្លេសនូវការបកប្រែទាំងស្រុង ឬខ្លឹមសារសង្ខេប ឬសេចក្តីពន្យល់នៃវិធានការនៃការអនុវត្តទូទៅទាំងនោះ។ ការផ្សព្វផ្សាយបែបនោះមិនត្រូវចាត់ទុកថា ជាការបកប្រែផ្លូវការឡើយ លើកលែងតែមានការបញ្ជាក់ផ្ទុយពីនេះ។

៣. តាមលទ្ធភាពដែលអាចធ្វើទៅបាន ដ្ឋសមាជិកនីមួយៗត្រូវ៖

(ក) ធ្វើការផ្សព្វផ្សាយ ឬធ្វើយ៉ាងណាឱ្យបុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍អាចទទួលបានជាមុននូវច្បាប់និងបទប្បញ្ញត្តិនៃការអនុវត្តទូទៅពាក់ព័ន្ធនឹងការផ្តត់ផ្តង់សេវាកម្មហិរញ្ញវត្ថុដែលរដ្ឋសមាជិកនោះបានស្នើឡើងដើម្បីអនុម័ត ព្រមទាំងគោលបំណងនៃច្បាប់និងបទប្បញ្ញត្តិទាំងនោះ និង

(ខ) ផ្តល់ឱ្យបុគ្គលពាក់ព័ន្ធនឹងផលប្រយោជន៍[3] និងរដ្ឋសមាជិកផ្សេងទៀតនូវកាលានុវត្តភាពសមស្រប ដើម្បីផ្តល់យោបល់ចំពោះច្បាប់និងបទប្បញ្ញត្តិដែលបានស្នើឡើងទាំងនោះ។

៤. អាជ្ញាធរផ្នែកនិយតកម្មនៃរដ្ឋសមាជិកនីមួយៗ ត្រូវធ្វើយ៉ាងណាឱ្យបុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍អាចដឹងអំពីលក្ខខណ្ឌតម្រូវនានា រាប់បញ្ចូលទាំងឯកសារនានាដែលតម្រូវឱ្យមាន សម្រាប់ការបំពេញពាក្យស្នើសុំពាក់ព័ន្ធនឹងការផ្តត់ផ្តង់សេវាកម្មហិរញ្ញវត្ថុ។

៥. ករណីមានការស្នើជាលាយលក្ខណ៍អក្សរពីអ្នកដាក់ពាក្យស្នើសុំ អាជ្ញាធរផ្នែកនិយតកម្មត្រូវផ្តល់ព័ត៌មានដល់អ្នកដាក់ពាក្យស្នើសុំនោះអំពីស្ថានភាពនៃការស្នើសុំ។ ប្រសិនបើអាជ្ញាធរនោះតម្រូវឱ្យផ្តល់នូវព័ត៌មានបន្ថែមពីអ្នកដាក់ពាក្យស្នើសុំ អាជ្ញាធរនោះត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យស្នើសុំក្នុងរយៈពេលមួយសមស្រប។

៦. អាជ្ញាធរផ្នែកនិយតកម្មត្រូវធ្វើសេចក្តីសម្រេចចិត្តផ្នែករដ្ឋបាល ចំពោះពាក្យស្នើសុំដែលពេញលេញរបស់អ្នកដាក់ពាក្យស្នើសុំពាក់ព័ន្ធនឹងការផ្តត់ផ្តង់សេវាកម្មហិរញ្ញវត្ថុ នៅក្នុងអំឡុងពេល ១៨០ថ្ងៃ ហើយត្រូវជូនដំណឹងឱ្យបានទាន់ពេលវេលាដល់អ្នកដាក់ពាក្យស្នើសុំអំពីសេចក្តីសម្រេចចិត្តនោះ។ ពាក្យស្នើសុំមួយមិនត្រូវចាត់ទុកថាពេញលេញឡើយ រហូតដល់រាល់ការបកស្រាយបំភ្លឺនានាត្រូវបានប្រព្រឹត្តទៅ ហើយអាជ្ញាធរផ្នែកនិយតកម្មចាត់ទុកថារាល់ព័ត៌មានចំបាច់ត្រូវបានទទួល។ ករណីដែលការអនុវត្តជាក់ស្តែងមិនអាចប្រព្រឹត្តទៅបានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តក្នុងអំឡុងពេល ១៨០ថ្ងៃ អាជ្ញាធរផ្នែកនិយតកម្មត្រូវជូនដំណឹងដល់អ្នកដាក់ពាក្យស្នើសុំក្នុងរយៈពេលមួយសមស្រប ហើយត្រូវខិតខំព្យាយាមធ្វើសេចក្តីសម្រេចចិត្តឱ្យបានក្នុងរយៈពេលមួយសមស្របបន្ទាប់ពីនោះ។

---

[3] អាជ្ញាធរដ្ឋសមាជិក បានបញ្ជាក់អំពីការយល់ជាមួយដូចគ្នាថា បុគ្គលពាក់ព័ន្ធនឹងផលប្រយោជន៍នៅក្នុងមាត្រានេះ គឺជាបុគ្គលទាំងឡាយដែលមានផលប្រយោជន៍ផ្ទាល់ផ្នែកហិរញ្ញវត្ថុរបស់ពួកគេ អាចនឹងរងគ្រោះថ្នាក់ពីការអនុម័តនូវច្បាប់និងបទប្បញ្ញត្តិនៃការអនុវត្តទូទៅនោះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

៧. ករណីមានការស្នើដាលាយលក្ខណ៍អក្សរពីអ្នកដាក់ពាក្យស្នើសុំដែលមិនទទួលបានជោគជ័យ អាជ្ញាធរផ្នែកនិយតកម្មដែលបានបដិសេធចំពោះពាក្យស្នើសុំ ត្រូវតែខិតខំព្យាយាមផ្តល់ព័ត៌មានដល់អ្នកដាក់ពាក្យស្នើសុំ អំពីហេតុផលនានាសម្រាប់ការបដិសេធចំពោះពាក្យស្នើសុំនោះ។

៨. រដ្ឋសមាជិកនីមួយៗត្រូវរក្សាទុកឬបង្កើតនូវយន្តការសមស្រប ដែលឆ្លើយតបចំពោះការសាកសួរព័ត៌មាននានាពីសំណាក់បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ទាក់ទងទៅនឹងវិធានការនៃការអនុវត្តទូទៅដែលគ្របដណ្តប់ដោយឧបសម្ព័ន្ធនេះ។

៩. រដ្ឋសមាជិកនីមួយៗត្រូវចាត់វិធានការសមស្របដែលអាចនឹងធ្វើទៅបាន ដើម្បីធានាថា វិធាននៃការអនុវត្តទូទៅដែលបានអនុម័តឬរក្សាទុកដោយអង្គភាពស្វ័យនិយតករ[4] របស់រដ្ឋសមាជិកនោះ ត្រូវបានផ្សព្វផ្សាយទាន់ពេលវេលា ឬម៉្យាងទៀតធ្វើយ៉ាងណាឱ្យអាចរកបានជាសាធារណៈ[5]។

១០. តាមលទ្ធភាពដែលអាចអនុវត្តទៅបាន រដ្ឋសមាជិកនីមួយៗគប្បីអនុញ្ញាតឱ្យមានរយៈពេលសមស្របមួយ រវាងការផ្សព្វផ្សាយអំពីបទប្បញ្ញត្តិចុងក្រោយ និងកាលបរិច្ឆេទនៃការចូលជាធរមានរបស់បទប្បញ្ញត្តិនោះ។

មាត្រា៧
ប្រព័ន្ធទូទាត់និងផាត់ទាត់

ស្ថិតក្រោមខចែងនិងលក្ខខណ្ឌនានា ដែលផ្តល់នូវប្រព្រឹត្តិកម្មជាតិ ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុក នោះរដ្ឋសមាជិកនីមួយៗត្រូវអនុញ្ញាតឱ្យគ្រឹះស្ថានហិរញ្ញវត្ថុរបស់រដ្ឋសមាជិកផ្សេងទៀតដែលបានបង្កើតឡើងនៅក្នុងដែនដីនៃរដ្ឋសមាជិកជាម្ចាស់ផ្ទះ ទទួលបាននូវលទ្ធភាពចូលទៅកាន់ប្រព័ន្ធទូទាត់និងផាត់ទាត់ ដែលត្រូវបានប្រតិបត្តិការដោយអង្គភាពសាធារណៈ និងលទ្ធភាពចូលទៅកាន់ឧបករណ៍សម្រួលដល់ការផ្តល់មូលនិធិនិងហិរញ្ញប្បទានផ្លូវការនានា ដែលមានក្នុងប្រតិបត្តិការធុរកិច្ចទូទៅ។ កថាខណ្ឌនេះមិនមានបំណងដើម្បីផ្តល់នូវលទ្ធភាពចូលទៅកាន់ឧបករណ៍ឥណទានធនាគារកណ្តាលរបស់រដ្ឋសមាជិកនោះឡើយ។

មាត្រា៨
អង្គភាពស្វ័យនិយតករ

ប្រសិនបើរដ្ឋសមាជិកមួយ តម្រូវឱ្យគ្រឹះស្ថានហិរញ្ញវត្ថុណាមួយនៃរដ្ឋសមាជិកផ្សេងទៀតក្លាយទៅជាសមាជិកនៃ ឬចូលរួមក្នុង ឬមានលទ្ធភាពចូលទៅកាន់អង្គភាពស្វ័យនិយតកដើម្បីផ្តល់នូវសេវាកម្មហិរញ្ញវត្ថុនៅក្នុងដែនដីរបស់ខ្លួន រដ្ឋសមាជិកនោះនឹងខិតខំព្យាយាមដើម្បីធានាថា អង្គភាពស្វ័យនិយតកនោះប្រតិបត្តិតាមកាតព្វកិច្ចនានានៅក្នុងមាត្រា៦ (ប្រព្រឹត្តិកម្មជាតិ) នៃកិច្ចព្រមព្រៀងនេះ និងមាត្រា១១ (ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត) នៃឧបសម្ព័ន្ធនេះ។

---

[4] កថាខណ្ឌនេះ អនុវត្តចំពោះតែរដ្ឋសមាជិកណាមួយ ករណីដែលរដ្ឋសមាជិកនោះបានបង្កើតនូវអង្គភាពស្វ័យនិយតកប៉ុណ្ណោះ។ ដើម្បីឱ្យកាន់តែច្បាស់ បណ្តារដ្ឋសមាជិកបានឯកភាពថា ព័ត៌មានបែបនោះអាចនឹងត្រូវបានផ្សព្វផ្សាយជាភាសាតាមដម្រើសរបស់រដ្ឋសមាជិកនីមួយៗ។

មាត្រា៩
ការផ្ទេរព័ត៌មាននិងដំណើរការព័ត៌មាន

១. រដ្ឋសមាជិកមួយមិនត្រូវចាត់វិធានការនានាដែលៈ

(ក) រារាំងដល់ការផ្ទេរព័ត៌មាន រួមមាន ការផ្ទេរទិន្នន័យតាមរយៈប្រព័ន្ធអេឡិចត្រូនិក ដែលចាំបាច់សម្រាប់ការធ្វើប្រតិបត្តិការធុរកិច្ចទូទៅរបស់អ្នកផ្តត់ផ្តង់សេវាកម្មហិរញ្ញវត្ថុ

(ខ) រារាំងដល់ដំណើរការព័ត៌មាន ដែលចាំបាច់សម្រាប់ការធ្វើប្រតិបត្តិការធុរកិច្ចទូទៅរបស់អ្នកផ្តត់ផ្តង់សេវាកម្មហិរញ្ញវត្ថុ ឬ

(គ) រារាំងដល់ការផ្ទេរឧបករណ៍ ដែលចាំបាច់សម្រាប់ការធ្វើប្រតិបត្តិការធុរកិច្ចទូទៅរបស់អ្នកផ្តត់ផ្តង់សេវាកម្មហិរញ្ញវត្ថុ ដោយអាស្រ័យទៅនឹងវិធាននៃការនាំចូលទាំងឡាយ ដែលមានសង្គតិភាពទៅនឹងកិច្ចព្រមព្រៀងអន្តរជាតិនានា។

២. ពុំមានអ្វីនៅក្នុងកថាខណ្ឌ១ ដែលៈ

(ក) រឹតត្បិតដល់សិទ្ធិរបស់រដ្ឋសមាជិកមួយដើម្បីការពារទិន្នន័យផ្ទាល់ខ្លួន ឯកជនភាពផ្ទាល់ខ្លួន និងការសម្ងាត់នៃកំណត់ត្រានិងគណនីបុគ្គល រួមបញ្ចូលទាំងភាពអនុលោមទៅតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុក ដរាបណាសិទ្ធិបែបនោះមិនត្រូវបានប្រើប្រាស់ជាមធ្យោបាយក្នុងការគេចវេះពីការសន្យាឬកាតព្វកិច្ចនានារបស់រដ្ឋសមាជិកនោះ ក្រោមកិច្ចព្រមព្រៀងនេះ

(ខ) រារាំងដល់និយតករណាមួយនៃរដ្ឋសមាជិក ក្រោមមូលហេតុផ្នែកច្បាប់និងការប្រុងប្រយ័ត្នពីការតម្រូវឱ្យអ្នកផ្តត់ផ្តង់សេវាកម្មហិរញ្ញវត្ថុនៅក្នុងដែនដីរបស់ខ្លួន ប្រតិបត្តិតាមបទប្បញ្ញត្តិក្នុងស្រុក ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងទិន្នន័យ[6] និងការផ្ទុកទិន្នន័យ និងការថែទាំប្រព័ន្ធទិន្នន័យ ក៏ដូចជាការរក្សាទុកនូវច្បាប់ចម្លងនៃកំណត់ត្រានានានៅក្នុងដែនដីរបស់ខ្លួន ឬ

(គ) ត្រូវបានបកស្រាយ ដើម្បីតម្រូវឱ្យរដ្ឋសមាជិកមួយធ្វើការអនុញ្ញាតឱ្យមានការផ្តត់ផ្តង់សេវាកម្មឆ្លងកាត់ព្រំដែន ឬការប្រើប្រាស់សេវាកម្មនៅបរទេសចំពោះសេវាកម្មនានាពាក់ព័ន្ធនឹងអ្វីដែលខ្លួនពុំបានធ្វើការសន្យា រួមទាំង ធ្វើការអនុញ្ញាតឱ្យអ្នកផ្តត់ផ្តង់សេវាកម្មហិរញ្ញវត្ថុដែលជាអនិវេសនជន ធ្វើការផ្តត់ផ្តង់នូវ ទោះជាក្នុងនាមជាអ្នកផ្តត់ផ្តង់បង្គោលតាមរយៈអន្តរការីឬក្នុងនាមជាអន្តរការី ការផ្តល់និងការផ្ទេរព័ត៌មានហិរញ្ញវត្ថុ និងដំណើរការទិន្នន័យហិរញ្ញវត្ថុ ដូចមានចែងក្នុងកថាខណ្ឌ(គ)(xv) នៃមាត្រា២ (និយមន័យ) នៃឧបសម្ព័ន្ធនេះ។[7]

---

[6] ដើម្បីឱ្យកាន់តែច្បាស់ ការគ្រប់គ្រងទិន្នន័យ រួមមាន កាតព្វកិច្ចដំណើរការក្នុងមូលដ្ឋាននៃប្រតិបត្តិការទូទាត់ក្នុងស្រុក។

[7] ដើម្បីឱ្យកាន់តែច្បាស់ ករណីដែលរដ្ឋសមាជិកមួយមិនបានធ្វើការសន្យាវិស័យសេវាកម្ម ដែលពាក់ព័ន្ធនឹងការផ្តត់ផ្តង់សេវាកម្មឆ្លងកាត់ [illegible]ឬការប្រើប្រាស់សេវាកម្មនៅបរទេសចំពោះសេវាកម្មណាមួយ រដ្ឋសមាជិកនោះត្រូវមានសិទ្ធិក្នុងការចាត់វិធានការនានាដែលរារាំង [illegible]ការផ្ទេរព័ត៌មាន ដំណើរការព័ត៌មាន ឬការផ្ទេរឧបករណ៍ ដូចមានចែងក្នុងកថាខណ្ឌ១ ពាក់ព័ន្ធនឹងការផ្តត់ផ្តង់សេវាកម្មឆ្លងកាត់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា១០
ការដោះស្រាយវិវាទ

សមាជិកនៃក្រុមការងារដែលត្រូវបានបង្កើតស្របតាមមាត្រា៣៤ (ការដោះស្រាយវិវាទ) នៃកិច្ចព្រមព្រៀងនេះ សម្រាប់ការដោះស្រាយវិវាទលើបញ្ហាពាក់ព័ន្ធនឹងការប្រុងប្រយ័ត្ន និងបញ្ហាពាក់ព័ន្ធនឹងហិរញ្ញវត្ថុផ្សេងទៀត ត្រូវមានជំនាញចាំបាច់ពាក់ព័ន្ធទៅនឹងសេវាកម្មហិរញ្ញវត្ថុជាក់លាក់ដែលស្ថិតក្នុងវិវាទ។

មាត្រា១១
ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត

១. រដ្ឋសមាជិកនីមួយ។ ត្រូវផ្តល់ដល់សេវាកម្មនិងអ្នកផ្តត់ផ្តង់សេវាកម្មនៃរដ្ឋសមាជិកផ្សេងទៀត នូវប្រព្រឹត្តិកម្មដែលមានភាពអនុគ្រោះមិនឲ្យតិចជាងភាពអនុគ្រោះដែលខ្លួនផ្តល់ ដោយស្ថិតក្នុងលក្ខខណ្ឌដូចគ្នា ដល់សេវាកម្មនិងអ្នកផ្តត់ផ្តង់សេវាកម្មនៃរដ្ឋសមាជិកណាមួយផ្សេងទៀត។[8]

២. ច្វីបើមានចែងក្នុងកថាខណ្ឌ១ បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ប្រសិនបើរដ្ឋសមាជិកមួយបញ្ចប់ឬធ្វើវិសោធនកម្មកិច្ចព្រមព្រៀងទាំងឡាយណា ជាមួយនឹងរដ្ឋសមាជិកណាមួយផ្សេងទៀត ឬរដ្ឋមិនមែនសមាជិក នោះរដ្ឋសមាជិកផ្សេងទៀតអាចស្នើសុំធ្វើការចរចាក្នុងគោលបំណងដាក់បញ្ចូលក្រោមកិច្ចព្រមព្រៀងនេះ នូវប្រព្រឹត្តិកម្មដែលមានភាពអនុគ្រោះមិនឱ្យតិចជាងភាពអនុគ្រោះដែលផ្តល់ដោយកិច្ចព្រមព្រៀងនោះឡើយ។ រដ្ឋសមាជិកដែលត្រូវបានស្នើសុំ ត្រូវចូលរួមក្នុងការចរចាជាមួយនឹងរដ្ឋសមាជិកស្នើសុំ។ រាល់ការផ្តល់នូវប្រព្រឹត្តិកម្មអនុគ្រោះបែបនោះដល់រដ្ឋសមាជិកដែលនៅសេសសល់ ដោយផ្អែកលើមូលដ្ឋានប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត ត្រូវធ្វើឡើងតាមការស្ម័គ្រចិត្តចំពោះផ្នែកទាំងឡាយណាដែលជារបស់រដ្ឋសមាជិកដែលត្រូវបានស្នើសុំ។

៣. រដ្ឋសមាជិកអាចរក្សាទុកនូវវិធានការដែលអសង្គតិភាពទៅនឹងកថាខណ្ឌ១ ប្រសិនបើវិធានការបែបនោះត្រូវបានដាក់បញ្ចូលនៅក្នុង និងបំពេញតាមលក្ខខណ្ឌនៃ បញ្ជីលើកលែងប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុតរបស់ខ្លួន។

៤. ប្រការទាំងឡាយនៃកិច្ចព្រមព្រៀងនេះ មិនត្រូវបានបកស្រាយដើម្បីរារាំងរដ្ឋសមាជិកណាមួយពីការអនុញ្ញាតឬការផ្តល់អត្ថប្រយោជន៍នានាដល់ប្រទេសជាប់ព្រំដែន ក្នុងគោលបំណងសម្រួលដល់ការដោះដូរនានាដែលកំណត់ចំពោះតំបន់មានព្រំដែនជាប់គ្នានូវសេវាកម្មដែលត្រូវបានផលិត និងប្រើប្រាស់ក្នុងតំបន់មូលដ្ឋាន។

ព្រំដែនឬការប្រើប្រាស់សេវាកម្មនៅបរទេសចំពោះសេវាកម្មនោះ ដោយអ្នកផ្តត់ផ្តង់សេវាកម្មហិរញ្ញវត្ថុដូចមានចែងក្រោមកថាខណ្ឌ១។ យ៉ាងណាមិញ រដ្ឋសមាជិកមួយមិនត្រូវគេចវេះពីកាតព្វកិច្ចរបស់ខ្លួន ដើម្បីអនុញ្ញាតចំពោះការផ្ទេរនិងដំណើរការទាំងឡាយណាដែលមានពាក់ព័ន្ធនឹងការផ្តត់ផ្តង់សេវាកម្មឆ្លងកាត់ព្រំដែនឬការប្រើប្រាស់សេវាកម្មនៅបរទេសចំពោះសេវាកម្មមួយ ដែលប្រព្រឹត្តទៅសម្រាប់គោលបំណងនៃការគ្រប់គ្រងត្រួតពិនិត្យជាក្រុម និងការប្រតិបត្តិតាមលក្ខខណ្ឌតម្រូវនៃរបាយការណ៍របស់រដ្ឋសមាជិកផ្សេងទៀតឡើយ។ ឧទ្យានឿម្បីឱ្យកាន់តែច្បាស់ កាតព្វកិច្ចនានានៅក្នុងកថាខណ្ឌ១និង៣ អនុវត្តចំពោះតែការសន្យាវិស័យសេវាកម្មហិរញ្ញវត្ថុ ក្រោមកញ្ចប់សន្យាទាងស្រោយរបស់កិច្ចព្រមព្រៀងAFAS លើកលែងតែការសន្យាក្រោមកិច្ចព្រមព្រៀងក្របខណ្ឌសមាហរណកម្មធនាគារអាស៊ាន (ABIF)។

ទំព័រទី៤២

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា១២
ការរៀបចំដើម្បីពន្លឿនសមាហរណកម្មហិរញ្ញវត្ថុ

១. រដ្ឋសមាជិកពីរឬច្រើនអាចរៀបចំការចរចានិងឯកភាពគ្នា ដើម្បីធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម សេវាកម្មចំពោះវិស័យឬអនុវិស័យជាក់លាក់ ("បណ្តារដ្ឋសមាជិកចូលរួម")។ ការផ្តល់នូវប្រព្រឹត្តិកម្មអនុគ្រោះចំពោះបណ្តារដ្ឋសមាជិកដែលនៅសេសសល់ ដោយផ្អែកលើមូលដ្ឋានប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត ត្រូវធ្វើឡើងតាមការស្ម័គ្រចិត្តចំពោះផ្នែកទាំងឡាយណាដែលជារបស់រដ្ឋសមាជិកចូលរួម។

២. បណ្តារដ្ឋសមាជិកចូលរួម ត្រូវរក្សានូវការផ្តល់ព័ត៌មានដល់រដ្ឋសមាជិកដែលនៅសេសសល់តាមរយៈលេខាធិការដ្ឋានអាស៊ានអំពីវឌ្ឍនភាពឬលទ្ធផលនៃការចរចា រួមទាំងការរៀបចំតារាងសន្យាសម្រាប់វិស័យឬអនុវិស័យជាក់លាក់ដែលពាក់ព័ន្ធ។ រដ្ឋសមាជិកទាំងឡាយណាដែលមានបំណងចូលរួមការចរចាដែលកំពុងបន្តនានា ក្នុងចំណោមបណ្តារដ្ឋសមាជិកចូលរួម អាចធ្វើទៅបានដោយការពិគ្រោះយោបល់ជាមួយនឹងបណ្តារដ្ឋសមាជិកចូលរួម។

៣. រដ្ឋសមាជិកណាមួយដែលមិនមែនជាភាគីនៃកិច្ចព្រមព្រៀងណាមួយ ដែលធ្វើឡើងស្របតាមកថាខណ្ឌ១ អាចចូលរួមក្នុងកិច្ចព្រមព្រៀងនោះបាន ដោយអាស្រ័យទៅនឹងការឯកភាពគ្នាជាឯកច្ឆន្ទពីបណ្តារដ្ឋសមាជិកចូលរួម។

៤. បណ្តារដ្ឋសមាជិកចូលរួម អាចកែលម្អបន្ថែមលើប៉ារ៉ាម៉ែត្រសម្រាប់វិស័យឬអនុវិស័យជាក់លាក់ដែលនឹងធ្វើការសន្យា ដូចដែលអាចនឹងផ្អែកតាមការឯកភាពគ្នាជារួម ដោយបណ្តារដ្ឋសមាជិកចូលរួមទាំងអស់ ក្នុងគោលបំណងនៃការធ្វើសេរីភាវូបនីយកម្មបន្ថែមលើពាណិជ្ជកម្មសេវាកម្ម។

៥. រាល់កិច្ចព្រមព្រៀងដែលធ្វើឡើងស្របតាមកថាខណ្ឌ១ ត្រូវដាក់តម្កល់ជាមួយនឹងអគ្គលេខាធិការអាស៊ាន ដែលជាអ្នកត្រូវផ្តល់ជូនភ្លាមៗនូវច្បាប់ចម្លងដែលមានការបញ្ជាក់ទៅកាន់រដ្ឋសមាជិកចូលរួមនីមួយៗ និងជូនដំណឹងដូចគ្នាដល់បណ្តារដ្ឋសមាជិកផ្សេងទៀត។

មាត្រា១៣
ច្រកចូលទីផ្សារសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ[9]

ពាក់ព័ន្ធនឹងច្រកចូលទីផ្សារសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុណាមួយរបស់រដ្ឋសមាជិកផ្សេងទៀត តាមរយៈម៉ូដទី៣ៈ វត្តមានពាណិជ្ជកម្ម ដូចបានកំណត់ក្នុងមាត្រា១ (វិសាលភាព) នៃឧបសម្ព័ន្ធនេះ វៀរលែងតែមានចែងផ្ទុយពីនេះនៅក្នុងតារាងវិធានការបដិលោម បើទោះជាផ្អែកលើមូលដ្ឋាននៃផ្នែកណាមួយរបស់តំបន់ឬផ្អែកលើមូលដ្ឋាននៃដែនដីទាំងមូលរបស់ខ្លួនក្តី រដ្ឋសមាជិកមួយមិនត្រូវរក្សាទុកឬអនុម័តនូវវិធានការនានាដែលជាៈ

---

[9] រដ្ឋសមាជិកអាចសម្រេចចិត្តដើម្បីអនុញ្ញាតចំពោៈការផ្ទេរមូលធនទៅក្នុងដែនដីរបស់ខ្លួន ប្រសិនបើការផ្ទេរមូលធននោៈពាក់ព័ន្ធនឹងការសន្យារបស់ច្រកចូលទីផ្សាររបស់ខ្លួន ពាក់ព័ន្ធនឹងគ្រឹៈស្ថានហិរញ្ញវត្ថុក្រោមជំពូកនេៈ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៥៥៩

១. ការដាក់កំណត់ទៅលើ៖

(ក) ចំនួនគ្រឹះស្ថានហិរញ្ញវត្ថុ ទោះជាក្នុងទម្រង់កូតាចំនួន ភាពផ្តាច់មុខ អ្នកផ្តត់ផ្តង់សេវាកម្ម ផ្តាច់មុខ ឬលក្ខខណ្ឌតម្រូវសម្រាប់ការពិចារណាលើតម្រូវការសេដ្ឋកិច្ច

(ខ) តម្លៃសរុបនៃប្រតិបត្តិការសេវាកម្មហិរញ្ញវត្ថុ ឬទ្រព្យសកម្ម ក្នុងទម្រង់ជាកូតាចំនួន ឬ លក្ខខណ្ឌតម្រូវសម្រាប់ការពិចារណាលើតម្រូវការសេដ្ឋកិច្ច

(គ) ចំនួនសរុបនៃការប្រតិបត្តិសេវាកម្មហិរញ្ញវត្ថុ ឬបរិមាណសរុបនៃទិន្នផលសេវាកម្មហិរញ្ញវត្ថុ គិតជាឯកតាលេខដែលបានរៀបចំឡើងក្នុងទម្រង់ជាកូតា ឬលក្ខខណ្ឌតម្រូវសម្រាប់ ការពិចារណាលើតម្រូវការសេដ្ឋកិច្ច[10]

(ឃ) ចំនួនសរុបនៃរូបវន្តបុគ្គល ដែលអាចនឹងត្រូវបានជួលមកធ្វើការនៅក្នុងវិស័យសេវាកម្ម ហិរញ្ញវត្ថុជាក់លាក់ណាមួយ ឬដែលគ្រឹះស្ថានហិរញ្ញវត្ថុអាចនឹងជួលមកធ្វើការ ហើយជា បុគ្គលដែលចាំបាច់សម្រាប់ និងដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹង ការផ្តត់ផ្តង់សេវាកម្ម ហិរញ្ញវត្ថុជាក់លាក់មួយ ក្នុងទម្រង់ជាកូតាចំនួន ឬលក្ខខណ្ឌតម្រូវសម្រាប់ការពិចារណា លើតម្រូវការសេដ្ឋកិច្ច

(ង) ការរួមចំណែកនៃមូលធនបរទេស ក្នុងទម្រង់ជាអត្រាភាគរយអតិបរមាដែលអនុញ្ញាត ចំពោះភាគទុនបរទេស ឬតម្លៃសរុបនៃការវិនិយោគបរទេសជាលក្ខណៈបុគ្គល ឬជា លក្ខណៈរួម។

២. រឹតត្បិតឬតម្រូវចំពោះប្រភេទជាក់លាក់នៃនីតិបុគ្គល ឬក្រុមហ៊ុនចម្រុះទុន ដែលតាមរយៈវិធានការ ទាំងនោះ ទើបគ្រឹះស្ថានហិរញ្ញវត្ថុអាចផ្តត់ផ្តង់សេវាកម្មណាមួយបាន។

មាត្រា១៤
ការផ្តត់ផ្តង់សេវាកម្មហិរញ្ញវត្ថុឆ្លងកាត់ព្រំដែន[11]

១. រដ្ឋសមាជិកនីមួយៗត្រូវអនុញ្ញាត ដោយស្ថិតក្រោមខចែងនិងលក្ខខណ្ឌនានាដែលផ្តល់នូវ ប្រព្រឹត្តិកម្មជាតិ ឱ្យអ្នកផ្តត់ផ្តង់សេវាកម្មហិរញ្ញវត្ថុឆ្លងកាត់ព្រំដែននៃរដ្ឋសមាជិកផ្សេងទៀតដើម្បី

---

[10] កថាខណ្ឌ១(គ) មិនគ្របដណ្តប់លើវិធានការនានារបស់រដ្ឋសមាជិក ដែលដាក់កំណត់លើធាតុចូលសម្រាប់ការផ្តត់ផ្តង់សេវាកម្ម ហិរញ្ញវត្ថុឡើយ។

[11] ដើម្បីឱ្យកាន់តែច្បាស់ មាត្រានេះនឹងអនុវត្តនៅពេលដែលធ្វើការផ្ទេរទៅជាវិធីសាស្ត្របញ្ជីអវិជ្ជមាន។ តារាងវិធានការបដិលោម សម្រាប់ឧស្សាកម្មហិរញ្ញវត្ថុ យោងតែទៅលើមាត្រា៦ (ប្រព្រឹត្តិកម្មជាតិ) និងមាត្រា១០ (គណៈគ្រប់គ្រងជាន់ខ្ពស់និងក្រុមប្រឹក្សាកិបាល) ឯកត្ថចព្រមទាំងនេះ និងមាត្រា១៣ (ច្រកចូលទីផ្សារសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ) និងមាត្រា១៤ (ការផ្តត់ផ្តង់សេវាកម្មហិរញ្ញវត្ថុឆ្លងកាត់ព្រំដែន) នៃរាបសម្ព័ន្ធនេះប៉ុណ្ណោះ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ផ្តត់ផ្តង់សេវាកម្មហិរញ្ញវត្ថុ ដូចមានបញ្ជាក់ក្នុងឧបសម្ព័ន្ធស្តីពី (ការផ្តត់ផ្តង់សេវាកម្មហិរញ្ញវត្ថុឆ្លងកាត់ព្រំដែន)។[12]

២. រដ្ឋសមាជិកនីមួយៗត្រូវអនុញ្ញាតឱ្យបុគ្គលដែលមានទីតាំងក្នុងដែនដីរបស់ខ្លួន និងជនជាតិរបស់ខ្លួនដែលមានទីតាំងនៅទីណាក៏ដោយ ដើម្បីទិញសេវាកម្មហិរញ្ញវត្ថុពីអ្នកផ្តត់ផ្តង់សេវាកម្មហិរញ្ញវត្ថុឆ្លងកាត់ព្រំដែននៃរដ្ឋសមាជិកផ្សេងទៀត ដែលមានទីតាំងនៅក្នុងដែនដីនៃរដ្ឋសមាជិកមួយក្រៅពីរដ្ឋសមាជិកដែលធ្វើការអនុញ្ញាត។ កាតព្វកិច្ចនេះមិនតម្រូវអោយរដ្ឋសមាជិកមួយអនុញ្ញាតឱ្យអ្នកផ្តត់ផ្តង់ទាំងនោះ ដើម្បីធ្វើអាជីវកម្មឬជំរុញលើកទឹកចិត្តឱ្យធ្វើអាជីវកម្មនៅក្នុងដែនដីរបស់ខ្លួនឡើយ។ រដ្ឋសមាជិកអាចកំណត់និយមន័យ "ការធ្វើអាជីវកម្ម" និង "ការជំរុញលើកទឹកចិត្តឱ្យធ្វើអាជីវកម្ម" សម្រាប់គោលបំណងនៃកាតព្វកិច្ចនេះ ប្រសិនបើនិយមន័យទាំងនោះមិនអសង្គតិភាពទៅនឹងកថាខណ្ឌ១។

៣. ដោយពុំបុរេវិនិច្ឆ័យចំពោះមធ្យោបាយនានានៃបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រុងប្រយ័ត្ន ចំពោះការផ្តត់ផ្តង់សេវាកម្មហិរញ្ញវត្ថុឆ្លងកាត់ព្រំដែន រដ្ឋសមាជិកមួយអាចតម្រូវឱ្យមានការចុះបញ្ជី ឬការផ្តល់អាជ្ញាប័ណ្ណ ចំពោះអ្នកផ្តត់ផ្តង់សេវាកម្មហិរញ្ញវត្ថុឆ្លងកាត់ព្រំដែននៃរដ្ឋសមាជិកផ្សេងទៀត និងចំពោះឧបករណ៍ហិរញ្ញវត្ថុ។

មាត្រា១៥
វត្តមានក្នុងស្រុក

មាត្រា៩ (វត្តមានក្នុងស្រុក) នៅក្នុងកិច្ចព្រមព្រៀងនេះ មិនត្រូវអនុវត្តចំពោះការផ្តត់ផ្តង់សេវាកម្មហិរញ្ញវត្ថុឡើយ។



[12] ការផ្តត់ផ្តង់សេវាកម្មហិរញ្ញវត្ថុឆ្លងកាត់ព្រំដែន ដែលផ្តត់ផ្តង់សេវាកម្មហិរញ្ញវត្ថុណាមួយដូចមានបញ្ជាក់ក្នុងឧបសម្ព័ន្ធ (ការផ្តត់ផ្តង់សេវាកម្មហិរញ្ញវត្ថុឆ្លងកាត់ព្រំដែន) របស់រដ្ឋសមាជិកមួយ ហើយប្រសិនបើបន្លាស់ទីមូលធនឆ្លងកាត់ព្រំដែនគឺជាផ្នែកមួយនៃសេវាកម្មជាន់មួយនៃសេវាកម្មនោះ:ផ្ទាល់ រដ្ឋសមាជិកនោះ:សន្យាអនុញ្ញាតចំពោះបន្លាស់ទីមូលធនបែបនោះ។

ឧបសម្ព័ន្ធស្តីពីសេវាកម្មទូរគមនាគមន៍

មាត្រា១
វិសាលភាព

១. ឧបសម្ព័ន្ធនេះ ត្រូវអនុវត្តចំពោះវិធានការនានាចាត់ឡើងដោយរដ្ឋសមាជិក ដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មលើបណ្តាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍សាធារណៈ។

២. ឧបសម្ព័ន្ធនេះមិនត្រូវអនុវត្តចំពោះវិធានការនានាដែលពាក់ព័ន្ធនឹងសេវាសោតទស្សន៍ ដូចមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់រដ្ឋសមាជិកនីមួយៗឡើយ។

៣. ពុំមានអ្វីនៅក្នុងឧបសម្ព័ន្ធនេះត្រូវបានបកស្រាយ ដើម្បីៈ

(ក) តម្រូវឱ្យរដ្ឋសមាជិកមួយអនុញ្ញាតឱ្យអ្នកផ្តត់ផ្គង់សេវាកម្មនៃរដ្ឋសមាជិកមួយផ្សេងទៀត បង្កើត កសាង ជាវ ជួល ប្រតិបត្តិការ ឬផ្តត់ផ្គង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍ឡើយ វៀរលែងតែមានចែងផ្ទុយពីនេះដោយអាស្រ័យទៅនឹងតារាងវិធានការបដិលោមរបស់ខ្លួន ក្រោមកិច្ចព្រមព្រៀងនេះ ឬ

(ខ) តម្រូវឱ្យរដ្ឋសមាជិកមួយ (ឬតម្រូវឱ្យរដ្ឋសមាជិកដាក់កាតព្វកិច្ចលើអ្នកផ្តត់ផ្គង់សេវាកម្មក្រោមយុត្តាធិការរបស់ខ្លួន) បង្កើត កសាង ជាវ ជួល ប្រតិបត្តិការ ឬផ្តត់ផ្គង់នូវបណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍ដែលមិនត្រូវបានផ្តល់ជូនជាសាធារណៈ។

មាត្រា២
និយមន័យ

សម្រាប់គោលបំណងនៃឧបសម្ព័ន្ធនេះ វាក្យសព្ទៈ

(ក) "និន្នាការថ្លៃដើម" សំដៅដល់ ការយកថ្លៃដើមធ្វើជាគោល និងអាចរួមបញ្ចូលនូវផែលចំណេញសមស្របមួយ ហើយអាចពាក់ព័ន្ធទៅនឹងវិធីសាស្ត្រនៃការគណនាថ្លៃដើមផ្សេងៗគ្នាចំពោះបរិក្ខារឬសេវាកម្មផ្សេងគ្នា។

(ខ) "អ្នកប្រើប្រាស់ចុងក្រោយ" សំដៅដល់ អ្នកជាវ ឬអ្នកប្រើប្រាស់ចុងក្រោយនូវបណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ រួមទាំងអ្នកផ្តត់ផ្គង់សេវាកម្មណាមួយក្រៅពីអ្នកផ្តត់ផ្គង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ។

(គ) "បរិក្ខារសោវន្ត" សំដៅដល់ គ្រឿងបរិក្ខារទាំងឡាយនៃបណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ ដែលៈ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

(i) ត្រូវបានផ្តល់ផ្តាច់មុខឬយ៉ាងច្រើនលើសលប់ ដោយអ្នកផ្តត់ផ្តង់តែមួយ ឬដោយអ្នកផ្តត់ផ្តង់ក្នុងចំនួនមានកម្រិត និង

(ii) មិនអាចជំនួសបានតាមលក្ខណៈសេដ្ឋកិច្ចឬបច្ចេកទេស ដើម្បីផ្តល់សេវាកម្ម។

(ឃ) "**សេវាទូរស័ព្ទរ៉ូមីងអន្តរជាតិ**" សំដៅដល់ សេវាទូរស័ព្ទចល័តបែបពាណិជ្ជកម្ម ដែលត្រូវបានផ្តល់ស្របតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងអ្នកផ្តត់ផ្តង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ចុងក្រោយប្រើប្រាស់នូវទូរស័ព្ទចល័តឬឧបករណ៍ផ្សេងទៀតនៃប្រទេសដើម សម្រាប់សេវាជាសម្លេង ទិន្នន័យ ឬការផ្ញើសារខណៈដែលស្ថិតនៅក្រៅដែនដី ដែលបណ្តាញទូរគមនាគមន៍សាធារណៈនៃប្រទេសដើមរបស់អ្នកប្រើប្រាស់ចុងក្រោយនោះតាំងនៅ។

(ង) "**ស្ថានីយ៍ប្រព័ន្ធខ្សែកាបក្រោមបាតសមុទ្រអន្តរជាតិ**" សំដៅដល់ បរិវេណ[1] ដែលការតភ្ជាប់ប្រព្រឹត្តទៅជាមួយនឹងប្រព័ន្ធខ្សែកាបក្រោមបាតសមុទ្រអន្តរជាតិណាមួយ ដូចដែលត្រូវបានកំណត់ដោយអង្គភាពនិយ័តកម្មទូរគមនាគមន៍ ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ឬដោយអ្នកផ្តត់ផ្តង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈដែលកាន់កាប់ឬគ្រប់គ្រងលើបរិវេណនោះ បើចាំបាច់។

(ច) "**បណ្តាញជួលជាវ**" សំដៅដល់ បរិក្ខារទូរគមនាគមន៍រាងទីតាំងពីរឬច្រើន ដែលត្រូវបានរៀបចំជាលក្ខណៈដោយឡែកសម្រាប់ការប្រើប្រាស់ជាលក្ខណៈផ្តាច់មុខ ឬរៀបចំឱ្យមានភាពទំនេរអោចប្រើប្រាស់បាន សម្រាប់អ្នកប្រើប្រាស់ជាក់លាក់។

(ឆ) "**អ្នកផ្តត់ផ្តង់រមេ**" សំដៅដល់ អ្នកផ្តត់ផ្តង់ដែលមានសមត្ថភាពធ្វើឱ្យជះឥទ្ធិពលខ្លាំងដល់លក្ខខណ្ឌនៃការចូលរួម ដោយពាក់ព័ន្ធទៅនឹងថ្លៃនិងការផ្តត់ផ្តង់នៅក្នុងទីផ្សារពាក់ព័ន្ធចំពោះបណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ ដែលបណ្តាលមកពីៈ

(i) ការគ្រប់គ្រងលើបរិក្ខារសោរវន្ត ឬ

(ii) ការប្រើប្រាស់តួនាទីរបស់ខ្លួនក្នុងទីផ្សារ

(ជ) "**ភាពមិនរើសអើង**" សំដៅដល់ ប្រព្រឹត្តិកម្មដែលមានភាពអនុគ្រោះមិនតិចជាងប្រព្រឹត្តិកម្មដែលត្រូវបានផ្តល់ជូនអ្នកប្រើប្រាស់ផ្សេងទៀតណាមួយ នៃបណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈដូចគ្នា ដោយស្ថិតក្នុងលក្ខខណ្ឌដូចគ្នា។



[1] ប្រទេសស្ថានីយ៍អាចរួមបញ្ចូលទាំងចំណុចចូលដំណើរការដែលបានកំណត់ផ្សេងទៀត។

(ឈ) "**ទិន្នន័យឯកជន**" សំដៅដល់ រាល់ព័ត៌មានទាំងឡាយណា អំពីរូបវន្តបុគ្គលដែលមានអត្តសញ្ញាណឬដែលអាចកំណត់អត្តសញ្ញាណបាន។

(ញ) "**បណ្តាញទូរគមនាគមន៍សាធារណៈ**" សំដៅដល់ ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍សាធារណៈ ដែលអនុញ្ញាតចំពោះទូរគមនាគមន៍រវាងនិងក្នុងចំណោមទីតាំងបញ្ចប់នៃបណ្តាញដែលបានកំណត់។

(ដ) "**សេវាទូរគមនាគមន៍សាធារណៈ**" សំដៅដល់ សេវាទូរគមនាគមន៍ទាំងឡាយណា ដែលត្រូវបានតម្រូវយ៉ាងច្បាស់លាស់ឬមានជាធរមាន ដោយរដ្ឋសមាជិកមួយដើម្បីឱ្យផ្តល់ជូនជាទូទៅដល់សាធារណៈ។ សេវាទាំងនោះអាចរួមមញ្ជូលនូវ ការបញ្ជូនទូរលេខ ទូរស័ព្ទតេឡិច និងការបញ្ជូនទិន្នន័យ *ជាដើម* ដែលជាទូទៅពាក់ព័ន្ធនឹងការបញ្ជូនព័ត៌មានដែលផ្តល់ដោយអតិថិជន រវាងទីតាំងកំណត់ពីរឬច្រើន ដោយពុំមានការផ្លាស់ប្តូរទម្រង់ឬមាតិកានៃព័ត៌មានរបស់អតិថិជនពីចុងម្ខាងទៅចុងម្ខាងឡើយ។

(ឋ) "**ទូរគមនាគមន៍**" សំដៅដល់ ការបញ្ជូននិងការទទួលរលកសញ្ញាក្នុងទម្រង់អេឡិកត្រូម៉ាញ៉េទិក។

(ឌ) "**អង្គភាពនិយ័តកម្មទូរគមនាគមន៍**" សំដៅដល់ អង្គភាពឬបណ្តាអង្គភាពនៅក្នុងដែនដីនៃរដ្ឋសមាជិកមួយ ដែលទទួលខុសត្រូវនៅក្រោមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់រដ្ឋសមាជិកនោះ សម្រាប់ការធ្វើនិយ័តកម្មទូរគមនាគមន៍ និង

(ឍ) "**អ្នកប្រើប្រាស់**" សំដៅដល់ អ្នកប្រើប្រាស់ចុងក្រោយ ឬអ្នកផ្តត់ផ្គង់បណ្តាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍សាធារណៈ។

មាត្រា៣
សិទ្ធិចូលប្រើប្រាស់និងការប្រើប្រាស់

១. រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្តត់ផ្គង់សេវាកម្មណាមួយនៃរដ្ឋសមាជិកផ្សេងទៀតទទួលបានសិទ្ធិចូលប្រើប្រាស់ និងការប្រើប្រាស់បណ្តាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍សាធារណៈក្នុងខចែងនិងលក្ខខណ្ឌទាន់ពេលវេលា តម្លាភាព សមហេតុផល និងមិនរើសអើង វៀរលែងតែមានភាពផ្ទុយពីនេះដោយអាស្រ័យទៅនឹងតារាងវិធានការបដិរោមរបស់ខ្លួន ក្រោមកិច្ចព្រមព្រៀងនេះ។ កាតព្វកិច្ចនេះត្រូវអនុវត្តតាមរយៈកថាខណ្ឌ២ ដល់ ៦ *ជាដើម*។



២. រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្តត់ផ្គង់សេវាកម្មរបស់រដ្ឋសមាជិកផ្សេងទៀតមានសិទ្ធិចូលប្រើប្រាស់ និងការប្រើប្រាស់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈដែលផ្តល់

នៅក្នុងដែនដីឬឆ្លងកាត់ព្រំដែននៃរដ្ឋសមាជិកនោះ រួមបញ្ចូលទាំង បណ្តាញដួលជាវដោយឯកជន ហើយក្នុងន័យនេះ ដោយអាស្រ័យទៅនឹងប្រការនានានៃកថាខណ្ឌ ៥ និង ៦ ត្រូវធានាថា អ្នកផ្តត់ផ្គង់បែបនេះត្រូវបានអនុញ្ញាតឱ្យ៖

(ក) ទិញ ឬដួល និងបំពាក់បរិក្ខារចុងបណ្តាញឬបរិក្ខារដទៃទៀត ដែលភ្ជាប់ទៅវិញទៅមក ជាមួយនឹងបណ្តាញ និងដែលចាំបាច់ដើម្បីផ្តត់ផ្គង់សេវាកម្មរបស់ខ្លួន

(ខ) តភ្ជាប់ទៅវិញទៅមកនូវបណ្តាញដួលជាវដោយឯកជនឬបណ្តាញកម្មសិទ្ធិផ្ទាល់ខ្លួន ជាមួយនឹងបណ្តាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍សាធារណៈ ឬភ្ជាប់ជាមួយនឹងបណ្តាញដួលជាវឬបណ្តាញកម្មសិទ្ធិផ្ទាល់ខ្លួនរបស់អ្នកផ្តត់ផ្គង់សេវាកម្មផ្សេងទៀត និង

(គ) ប្រើប្រាស់ប្រតូកូលនៃប្រព័ន្ធដំណើរការតាមដម្រើសផ្ទាល់ខ្លួន ក្នុងការផ្តត់ផ្គង់សេវាកម្ម ណាមួយ ដែលជាដម្រើសផ្សេងៗទៅតាមការចាំបាច់ ដើម្បីធានាពីភាពមានរួចរាល់នូវ បណ្តាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍ ដើម្បីផ្តល់ជាទូទៅដល់សាធារណៈ។

៣. រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្តត់ផ្គង់សេវាកម្មរបស់រដ្ឋសមាជិកផ្សេងទៀតអាចប្រើប្រាស់ បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ សម្រាប់ការបន្លាស់ទីព័ត៌មាននៅក្នុង ប្រទេសឬឆ្លងកាត់ព្រំដែន រាប់បញ្ចូលទាំងការប្រាស្រ័យទាក់ទងផ្ទៃក្នុងក្រុមហ៊ុននៃអ្នកផ្តត់ផ្គង់ សេវាកម្មនោះ និងសម្រាប់សិទ្ធិចូលប្រើប្រាស់ព័ត៌មានរក្សាទុកក្នុងមូលដ្ឋានទិន្នន័យ ឬដែល ក្រៅពីនេះ រក្សាទុកនៅក្នុងទម្រង់ដែលអាចអានបានដោយម៉ាស៊ីនកុំព្យូទ័រ នៅក្នុងដែនដីនៃ រដ្ឋសមាជិកណាមួយ។

៤. ថ្វីបើមានចែងនៅក្នុងកថាខណ្ឌ ៣ រដ្ឋសមាជិកមួយអាចអនុវត្តនូវវិធានការនានា តាមការចាំបាច់ ដើម្បី៖

(ក) ធានាឱ្យបាននូវសន្តិសុខនិងការសម្ងាត់របស់សារ ឬ

(ខ) ការពារនូវទិន្នន័យឯកជនរបស់អ្នកប្រើប្រាស់ចុងក្រោយ នៃបណ្តាញទូរគមនាគមន៍ឬសេវា ទូរគមនាគមន៍សាធារណៈ

ប្រសិនបើ វិធានការទាំងនោះពុំត្រូវបានអនុវត្តក្នុងលក្ខណៈមួយដែលបង្កឱ្យមាននូវការរើសអើង តាមអំពើចិត្តឬមិនសមហេតុផល ឬការរឹតត្បិតបែបក្លែងបន្លំចំពោះពាណិជ្ជកម្មសេវាកម្ម។



៥. រដ្ឋសមាជិកនីមួយៗត្រូវធានាថា ពុំមានលក្ខខណ្ឌណាមួយត្រូវបានដាក់បន្ទុកទៅលើសិទ្ធិចូល ប្រើប្រាស់និងការប្រើប្រាស់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ ក្រៅពី ការចាំបាច់ដើម្បី៖

(ក) ការពារភាពទទួលខុសត្រូវផ្នែកសេវាសាធារណៈរបស់អ្នកផ្តត់ផ្តង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ ជាពិសេសលើលទ្ធភាពរបស់ពួកគេក្នុងការបង្កើតនូវបណ្តាញឬសេវារបស់ខ្លួន ដែលមានរួចរាល់សម្រាប់ផ្តល់ជាទូទៅដល់សាធារណៈ ឬ

(ខ) ការពារភាពពេញលេញឥតចន្លោះផ្នែកបច្ចេកទេស នៃបណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ។

៦. ប្រសិនបើពួកគេបំពេញតាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងកថាខណ្ឌ៥ លក្ខខណ្ឌនានាសម្រាប់សិទ្ធិចូលប្រើប្រាស់និងការប្រើប្រាស់បណ្តាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍សាធារណៈ រួមមានៈ

(ក) តម្រូវការក្នុងការប្រើប្រាស់ដែនតភ្ជាប់បច្ចេកទេសដែលជាក់លាក់ រួមទាំងប្រូតូកូលនៃដែនតភ្ជាប់ សម្រាប់ការតភ្ជាប់បណ្តាញជាមួយបណ្តាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍សាធារណៈ

(ខ) តម្រូវការនានាតាមការចាំបាច់ សម្រាប់ការបំពេញប្រតិបត្តិការរវាងគ្នាទៅវិញទៅមកនៃសេវាទូរគមនាគមន៍សាធារណៈ និងដើម្បីលើកទឹកចិត្តចំពោះសមិទ្ធផលនៃគោលដៅដូចមានចែងក្នុងមាត្រា១៧ (ទំនាក់ទំនងជាមួយអង្គការអន្តរជាតិ)

(គ) លិខិតអនុញ្ញាតចំពោះប្រភេទនៃបរិធានទូរគមនាគមន៍ឬឧបករណ៍ផ្សេងទៀត ដែលអាចតភ្ជាប់ជាមួយនឹងបណ្តាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍សាធារណៈ ព្រមទាំងតម្រូវការបច្ចេកទេសពាក់ព័ន្ធនឹងការភ្ជាប់នៃគ្រឿងបរិក្ខារទាំងនោះទៅនឹងបណ្តាញ

(ឃ) ការរឹតត្បិតលើការតភ្ជាប់បណ្តាញទៅវិញទៅមកនៃបណ្តាញជួលជាវឯកជនឬបណ្តាញកម្មសិទ្ធិផ្ទាល់ខ្លួន ជាមួយនឹងបណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ ឬក៏ជាមួយនឹងបណ្តាញជួលជាវឯកជនឬបណ្តាញកម្មសិទ្ធិផ្ទាល់ខ្លួនរបស់អ្នកផ្តត់ផ្តង់សេវាកម្មផ្សេងទៀត ឬ

(ង) ការជូនដំណឹង ការអនុញ្ញាត ការចុះបញ្ជី និងការផ្តល់អាជ្ញាប័ណ្ណ។

មាត្រា៤
លេខទូរគមនាគមន៍ដែលអាចកាន់កាប់បានដោយអ្នកប្រើប្រាស់

រដ្ឋសមាជិកនីមួយៗត្រូវខិតខំធានាថា អ្នកផ្តត់ផ្តង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈនៅក្នុងដែនដីរបស់ខ្លួន ផ្តល់លេខទូរគមនាគមន៍ដែលអាចកាន់កាប់បានដោយអ្នកប្រើប្រាស់សម្រាប់សេវាទូរស័ព្ទចល័ត ស្របតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន ឱ្យបានតាមលទ្ធភាពដែលអាចធ្វើទៅបានទាំងផ្នែកបច្ចេកទេសនិងផ្នែកសេដ្ឋកិច្ច ដោយផ្អែកលើមូលដ្ឋានទាន់ពេលវេលានៃក្នុងលក្ខខណ្ឌសមហេតុផល។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា៥
ការការពារភាពប្រកួតប្រជែង[2]

១. រដ្ឋសមាជិកនីមួយៗត្រូវអនុម័តឬរក្សានូវវិធានការសមស្របនានា សម្រាប់គោលបំណងក្នុងការទប់ស្កាត់អ្នកផ្គត់ផ្គង់ដែលមានតែមួយឬអ្នកផ្គត់ផ្គង់ច្រើនរួមគ្នា ដែលចាត់ទុកជាអ្នកផ្គត់ផ្គង់មេពីការចូលរួមនៅក្នុងឬកំពុងបន្តការអនុវត្តដែលមានលក្ខណៈប្រឆាំងនឹងការប្រកួតប្រជែង។

២. ការអនុវត្តដែលមានលក្ខណៈប្រឆាំងនឹងការប្រកួតប្រជែង ដូចមានចែងនៅក្នុងកថាខណ្ឌ១ ជាពិសេស រួមមាន៖

(ក) ការចូលរួមនៅក្នុងការឧបត្ថម្ភធនដែលមានលក្ខណៈប្រឆាំងនឹងការប្រកួតប្រជែង

(ខ) ការប្រើប្រាស់ព័ត៌មានដែលទទួលបានពីគូប្រកួតប្រជែង បង្កជាលទ្ធផលដែលមានលក្ខណៈប្រឆាំងនឹងការប្រកួតប្រជែង និង

(គ) ពុំផ្តល់លទ្ធភាពដល់អ្នកផ្គត់ផ្គង់ផ្សេងទៀតនៃបណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ ក្នុងការទទួលបានព័ត៌មានបច្ចេកទេសពាក់ព័ន្ធនឹងបរិក្ខារសារវន្តនិងព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មឱ្យបានទាន់ពេលវេលា ដែលព័ត៌មានទាំងនោះចាំបាច់សម្រាប់ពួកគេក្នុងការផ្គត់ផ្គង់សេវាកម្ម។

មាត្រា៦
ប្រព្រឹត្តិកម្មដោយអ្នកផ្គត់ផ្គង់មេ

រដ្ឋសមាជិកនីមួយៗត្រូវធានាថា ដោយស្ថិតក្នុងស្ថានភាពដូចគ្នា អ្នកផ្គត់ផ្គង់មេក្នុងដែនដីរបស់ខ្លួនផ្តល់ដល់អ្នកផ្គត់ផ្គង់បណ្តាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍សាធារណៈនៃរដ្ឋសមាជិកផ្សេងទៀតនូវប្រព្រឹត្តិកម្មដែលមានភាពអនុគ្រោះមិនឱ្យតិចជាងប្រព្រឹត្តិកម្ម ដែលអ្នកផ្គត់ផ្គង់មេនោះផ្តល់ដល់ក្រុមហ៊ុនបុត្រសម្ព័ន្ធនិងក្រុមហ៊ុនសាខារបស់ខ្លួន ឬអ្នកផ្គត់ផ្គង់សេវាកម្មដែលមិនមែនជាក្រុមហ៊ុនសាខារបស់ខ្លួនផ្សេងទៀត ពាក់ព័ន្ធនឹង៖

(ក) ភាពអាចរកបាន ការផ្តល់ជូន អត្រាតម្លៃ ឬគុណភាព នៃសេវាទូរគមនាគមន៍ដូចគ្នា[3] និង

(ខ) ភាពអាចរកបាននៃដែនតភ្ជាប់បច្ចេកទេសដែលចាំបាច់សម្រាប់ការតភ្ជាប់បណ្តាញ។

---

[2] ឃ្លា និងចុងន្យាក្នុងការអនុវត្តមាត្រានេះនៅចុងឆ្នាំ២០១៩ ។

[3] ត្រឹលនស៊ុតាន្យាក្នុងការអនុវត្តអនុកថាខណ្ឌនេះនៅចុងឆ្នាំ២០២០។

ទំព័រទី៥១

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា៧
ការលក់បន្ត[4]

រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្គត់ផ្គង់មេទាំងឡាយនៅក្នុងដែនដីរបស់ខ្លួនមិនដាក់លក្ខខណ្ឌ ឬការរឹតត្បិតនានាដែលមិនសមហេតុផល ឬរើសអើង ចំពោះការលក់បន្តនៃសេវាទូរគមនាគមន៍សាធារណៈ ដោយអ្នកផ្គត់ផ្គង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈនៃរដ្ឋសមាជិកផ្សេងទៀត។

មាត្រា៨
ការតភ្ជាប់បណ្តាញ[5]

១. រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្គត់ផ្គង់បណ្តាញទូរគមនាគមន៍សាធារណៈនៅក្នុងដែនដីរបស់ខ្លួន ផ្តល់ការតភ្ជាប់បណ្តាញដល់អ្នកផ្គត់ផ្គង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈនៃរដ្ឋសមាជិកផ្សេងទៀត ទៅតាមវិសាលភាពដូចមានកំណត់ក្នុងច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន។

២. រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្គត់ផ្គង់មេដែលកាន់កាប់លើបរិក្ខារសារវន្តនៅក្នុងដែនដីរបស់ខ្លួន ផ្តល់នូវការតភ្ជាប់បណ្តាញ សម្រាប់បរិធាននិងឧបករណ៍របស់អ្នកផ្គត់ផ្គង់បណ្តាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍សាធារណៈនៃរដ្ឋសមាជិកផ្សេងទៀត នៅទីតាំងណាមួយដែលអាចប្រព្រឹត្តទៅបានតាមលក្ខណៈបច្ចេកទេសនៅក្នុងបណ្តាញនោះ។ ការតភ្ជាប់បណ្តាញបែបនេះត្រូវបានផ្តល់ដោយ៖

(ក) ស្ថិតក្រោម ខចែង លក្ខខណ្ឌនានា (រួមទាំងស្តង់ដានិងភាពលម្អិតផ្នែកបច្ចេកទេស) និងអត្រាតម្លៃនិងគុណភាព ដែលមិនរើសអើង ហើយដែលមានភាពអនុគ្រោះមិនឱ្យតិចជាងភាពអនុគ្រោះដែលត្រូវបានផ្តល់ចំពោះសេវាកម្មដូចគ្នារបស់ខ្លួន ឬចំពោះសេវាកម្មដូចគ្នារបស់អ្នកផ្គត់ផ្គង់សេវាកម្មដែលមិនមែនជាក្រុមហ៊ុនសាខារបស់ខ្លួន ឬចំពោះក្រុមហ៊ុនបុត្រសម្ព័ន្ធឬក្រុមហ៊ុនសាខារបស់ខ្លួន

(ខ) ស្ថិតក្នុងភាពទាន់ពេលវេលា និងអាស្រ័យលើ ខចែង លក្ខខណ្ឌនានា (រួមទាំងស្តង់ដានិងភាពលម្អិតផ្នែកបច្ចេកទេស) និងអត្រាតម្លៃដែលផ្អែកលើនិន្នាការថ្លៃដើម ដែលមាន

---

[4] ព្រុយណេ អាចទាមទារឱ្យអ្នកមានអាជ្ញាបណ្ណ ដែលទិញសេវាទូរគមនាគមន៍សាធារណៈផ្អែកលើមូលដ្ឋានលក់ដុំ លក់បន្តនូវសេវាកម្មរបស់ខ្លួនចំពោះតែអ្នកប្រើប្រាស់ចុងក្រោយប៉ុណ្ណោះ។

[5] ឥម្ពាណ សន្សាក្នុងការអនុវត្តមាត្រានេះនៅចុងឆ្នាំ២០១៩ ។

[6] ឥណ្ឌូនេស៊ សន្សាក្នុងការអនុវត្តមាត្រានេះ ខណៈណាមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន។

[7] ឡាវ្ធាណាមាសន្សាក្នុងការអនុវត្តមាត្រានេះនៅចុងឆ្នាំ២០២០។

[8] ឥម្ពាណ សន្សាក្នុងការអនុវត្តមាត្រានេះនៅចុងឆ្នាំ២០១៩ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

តម្លាភាព សមហេតុផល អាស្រ័យលើលទ្ធភាពសេដ្ឋកិច្ច និងលាតត្រដាងគ្រប់គ្រាន់ ហើយដែលអាស្រ័យហេតុនេះ អ្នកផ្គត់ផ្គង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈនៃរដ្ឋសមាជិកផ្សេងទៀត ពុំចាំបាច់ទូទាត់ចំណាយចំពោះគ្រឿងបង្គុំឬបរិក្ខារដែលខ្លួនមិនត្រូវការជាចាំបាច់សម្រាប់ការផ្តល់សេវាកម្មឡើយ និង

(គ) ផ្អែកតាមការអស្នើសុំ ចំពោះបណ្តាទីតាំងបន្ថែមទៅលើទីតាំងចុងបណ្តាញ ដែលត្រូវបានផ្តល់ដល់អ្នកផ្គត់ផ្គង់បណ្តាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍សាធារណៈភាគច្រើនគឺជាកម្មវត្ថុនៃការគិតថ្លៃដែលឆ្លុះបញ្ចាំងថ្លៃដើមនៃការបំពាក់បរិក្ខារចាំបាច់បន្ថែម។

៣. រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្គត់ផ្គង់បណ្តាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍សាធារណៈនៃរដ្ឋសមាជិកផ្សេងទៀត អាចធ្វើការតភ្ជាប់បណ្តាញបរិក្ខារនិងឧបករណ៍របស់ពួកគេជាមួយអ្នកផ្គត់ផ្គង់មេដែលកាន់កាប់លើបរិក្ខារសោវន្តនៅក្នុងដែនដីរបស់ខ្លួន ដោយអនុលោមតាមជម្រើសយ៉ាងតិចមួយក្នុងចំណោមជម្រើសខាងក្រោម៖

(ក) សេចក្តីយោងស្តីពីការតភ្ជាប់បណ្តាញដែលអនុម័តដោយអង្គភាពនិយតកម្មទូរគមនាគមន៍របស់រដ្ឋសមាជិកនោះ ដោយក្នុងនោះមានអត្រាតម្លៃ ខចែង និងលក្ខខណ្ឌនានា ដែលអ្នកផ្គត់ផ្គង់មេដែលកាន់កាប់លើបរិក្ខារសោវន្ត ផ្តល់ជូនដាទូទៅដល់អ្នកផ្គត់ផ្គង់សេវាទូរគមនាគមន៍សាធារណៈ

(ខ) ខចែងនិងលក្ខខណ្ឌនានានៃកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់បណ្តាញដែលមានស្រាប់ ឬ

(គ) កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់បណ្តាញថ្មីតាមរយៈការចរចាពាណិជ្ជកម្ម។

៤. រដ្ឋសមាជិកនីមួយៗត្រូវធានាថា នីតិវិធីអនុវត្តសម្រាប់ការតភ្ជាប់បណ្តាញទៅនឹងអ្នកផ្គត់ផ្គង់មេត្រូវបានផ្សព្វផ្សាយជាសាធារណៈ។

៥. រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្គត់ផ្គង់មេនៅក្នុងដែនដីរបស់ខ្លួន ត្រូវធ្វើយ៉ាងណាឱ្យកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់បណ្តាញ ឬសំណើកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ដែលត្រូវផ្តល់អាចស្វែងរកបានជាសាធារណៈ។

៦. រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្គត់ផ្គង់មេដែលកាន់កាប់លើបរិក្ខារសោវន្តមិនប្រើប្រាស់ឬផ្តល់នូវព័ត៌មានរសើបឬព័ត៌មានសម្ងាត់ផ្នែកពាណិជ្ជកម្ម អំពីអ្នកផ្គត់ផ្គង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ ឬអំពីអ្នកប្រើប្រាស់ចុងក្រោយ ដែលទទួលបានតាមរយៈការធ្វើពុរកិច្ចលើការតភ្ជាប់បណ្តាញរបស់ខ្លួន ជាមួយនឹងបរិក្ខារទូរគមនាគមន៍របស់អ្នកផ្គត់ផ្គង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ ក្នុងគោលដៅផ្សេងក្រៅពីការធ្វើពុរកិច្ចលើការតភ្ជាប់បណ្តាញឡើយ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា៩
ការផ្តល់និងការកំណត់ថ្លៃសេវាកម្មបណ្តាញដួលជាវ[6]

រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្តត់ផ្គង់មេដែលកាន់កាប់លើបរិក្ខារសោវន្តនៅក្នុងដែនដីរបស់ខ្លួន ផ្តល់ដល់អ្នកផ្តត់ផ្គង់បណ្តាញទូរគមនាគមន៍និងសេវាទូរគមនាគមន៍សាធារណៈរបស់រដ្ឋសមាជិកផ្សេងទៀត នូវសេវាកម្មបណ្តាញដួលជាវដែលជាបណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ ក្នុងលក្ខខណ្ឌនិងអត្រាតម្លៃដែលសមហេតុផល មិនរើសអើង និងតម្លាភាព។

មាត្រា១០
សហទីតាំង[7]

ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្តត់ផ្គង់មេដែលកាន់កាប់លើបរិក្ខារសោវន្តក្នុងដែនដីរបស់ខ្លួន អនុញ្ញាតឱ្យអ្នកផ្តត់ផ្គង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈនៃរដ្ឋសមាជិកផ្សេងទៀត អាចដំឡើងបរិក្ខាររបស់ពួកគេនៅក្នុងអគាររបស់អ្នកផ្តត់ផ្គង់មេ ស្របតាមខចែងនិងលក្ខខណ្ឌនានា រួមមាន លទ្ធភាពផ្នែកបច្ចេកទេសនិងភាពទំនេរនៃទីតាំងក្នុងករណីដែលអាចអនុវត្តទៅបាន និងស្ថិតក្នុងអត្រាតម្លៃដែលសមហេតុផល មិនរើសអើង(រួមបញ្ចូលទាំងពេលវេលាសមស្រប) និងតម្លាភាព។

មាត្រា១១
អង្គភាពនិយ័តកម្មទូរគមនាគមន៍ឯករាជ្យ

១. រដ្ឋសមាជិកនីមួយៗត្រូវធានាថា អង្គភាពនិយ័តកម្មទូរគមនាគមន៍របស់ខ្លួន គឺស្ថិតនៅដាច់ដោយឡែកពី និងពុំជាប់ពាក់ព័ន្ធនឹងការទទួលខុសត្រូវចំពោះមុខអ្នកផ្តត់ផ្គង់សេវាទូរគមនាគមន៍សាធារណៈណាមួយឡើយ។

២. រដ្ឋសមាជិកនីមួយៗត្រូវធានាថា សេចក្តីសម្រេចចិត្តនិងនីតិវិធីដែលប្រើប្រាស់ដោយអង្គភាពនិយ័តកម្មទូរគមនាគមន៍របស់ខ្លួន គឺមិនលម្អៀងចំពោះរាល់អ្នកចូលរួមក្នុងទីផ្សារ។

---

[6] កម្ពុជា សន្យាក្នុងការអនុវត្តមាត្រានេះនៅចុងឆ្នាំ២០១៩ ។
ឥណ្ឌូនេស៊ី សន្យាក្នុងការអនុវត្តមាត្រានេះ ខណៈណាមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន។
វៀតណាម សន្យាក្នុងការអនុវត្តមាត្រានេះនៅចុងឆ្នាំ២០២០ ។
កម្ពុជា សន្យាក្នុងការអនុវត្តមាត្រានេះនៅចុងឆ្នាំ២០១៩ ។
ឥណ្ឌូនេស៊ី សន្យាក្នុងការអនុវត្តមាត្រានេះ ខណៈណាមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន។
ម៉ាឡេស៊ី សន្យាក្នុងការអនុវត្តមាត្រានេះនៅចុងឆ្នាំ២០១៩ ។
វៀតណាម សន្យាក្នុងការអនុវត្តមាត្រានេះនៅចុងឆ្នាំ២០២០ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា១២
សេវាសកល

រដ្ឋសមាជិកនីមួយៗមានសិទ្ធិដើម្បីកំណត់នូវប្រភេទនៃកាតព្វកិច្ចសេវាសកល ដែលខ្លួនមានបំណងរក្សាទុក។ កាតព្វកិច្ចបែបនេះមិនត្រូវបានចាត់ទុកជាការប្រឆាំងនឹងការប្រកួតប្រជែងឡើយ ប្រសិនបើកាតព្វកិច្ចទាំងនោះត្រូវបានគ្រប់គ្រងប្រកបដោយតម្លាភាព មិនរើសអើង និងមានលក្ខណៈប្រកួតប្រជែងដោយអព្យាក្រឹត្យ ហើយមិនបានដាក់បន្ទុកលើសពីភាពចាំបាច់ចំពោះប្រភេទនៃសេវាសកលដែលកំណត់ដោយរដ្ឋសមាជិកនោះ។

មាត្រា១៣
ការផ្តល់អាជ្ញាប័ណ្ណ[8]

១. ករណីដែលអាជ្ញាប័ណ្ណ សម្បទាន ការអនុញ្ញាត ការចុះបញ្ជី ឬប្រភេទនៃការអនុញ្ញាតផ្សេងទៀត ត្រូវបានតម្រូវឱ្យមានសម្រាប់ការផ្តត់ផ្តង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈ នោះរដ្ឋសមាជិកនីមួយៗត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនូវ៖

(ក) លក្ខណៈវិនិច្ឆ័យនិងនីតិវិធីនៃការផ្តល់អាជ្ញាប័ណ្ណ ឬការអនុញ្ញាតផ្សេងទៀត និងរយៈពេលដែលត្រូវការជាធម្មតាដើម្បីផ្តល់សេចក្តីសម្រេចចិត្តលើពាក្យស្នើសុំអាជ្ញាប័ណ្ណ សម្បទាន ការអនុញ្ញាត ការចុះបញ្ជី ឬប្រភេទនៃការអនុញ្ញាតផ្សេងទៀត និង

(ខ) ខចែង និងលក្ខខណ្ឌនានានៃអាជ្ញាប័ណ្ណ សម្បទាន ការអនុញ្ញាត ការចុះបញ្ជី ឬប្រភេទនៃការអនុញ្ញាតផ្សេងទៀត បែបឯកត្តជន ដែលខ្លួនបានដាក់ចេញរួច។[9]

២. អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋសមាជិកមួយ ត្រូវជូនដំណឹងដល់អ្នកដាក់ពាក្យស្នើសុំអំពីលទ្ធផលនៃពាក្យស្នើសុំរបស់ខ្លួនដោយពុំមានការពន្យារពេលបន្ទាប់ពីមានសេចក្តីសម្រេចចិត្ត។ ករណីសេចក្តីសម្រេចចិត្តបដិសេធចំពោះពាក្យស្នើសុំអាជ្ញាប័ណ្ណ សម្បទាន ការអនុញ្ញាត ការចុះបញ្ជី ឬប្រភេទនៃការអនុញ្ញាតផ្សេងទៀត អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋសមាជិកនោះត្រូវជូនដំណឹងដល់អ្នកដាក់ពាក្យស្នើសុំអំពីមូលហេតុនៃការបដិសេធ ស្របតាមការស្នើសុំ។

មាត្រា១៤
ការបែងចែកនិងការប្រើប្រាស់ធនធានកម្រ[10]

១. រដ្ឋសមាជិកនីមួយៗត្រូវអនុវត្តនីតិវិធីរបស់ខ្លួនក្នុងការបែងចែកនិងការប្រើប្រាស់ធនធានកម្រដែលពាក់ព័ន្ធនឹងទូរគមនាគមន៍ រួមបញ្ចូលទាំង ហ្វ្រេកង់ស៍ និងក្បាលលេខទូរគមនាគមន៍ ក្នុងលក្ខណៈមួយដែលមានសត្យានុម័ត ទាន់ពេលវេលា តម្លាភាព និងមិនរើសអើង។

---

[8] កម្មវិ សន្យាក្នុងការអនុវត្តមាត្រានេះនៅចុងឆ្នាំ២០១៩ ។

[9] ដើម្បីឱ្យកាន់តែច្បាស់ ខចែងនិងលក្ខខណ្ឌនានាអាចនឹងមិនរាប់បញ្ចូលនូវខចែងនិងលក្ខខណ្ឌជាក់លាក់នៃអ្នកមានអាជ្ញាបណ្ណ ដែលឯ[illegible]ឆ្នាំពីតម្រូវឱ្យមាត់។

[10] កម្មវិ សន្យាក្នុងការអនុវត្តមាត្រានេះនៅចុងឆ្នាំ២០១៩ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២. រដ្ឋសមាជិកនីមួយៗត្រូវផ្សព្វផ្សាយជាសាធារណៈ អំពីស្ថានភាពបច្ចុប្បន្ននៃការបែងចែកបន្ទាប់ហ្វ្រេកង់ស៍ ប៉ុន្តែមិនត្រូវបានទាមទារឱ្យផ្តល់ព័ត៌មានអំពីអត្តសញ្ញាណលម្អិតនៃហ្វ្រេកង់ស៍ដែលត្រូវបានបែងចែកសម្រាប់ការប្រើប្រាស់ជាក់លាក់ក្នុងគោលដៅរបស់រដ្ឋាភិបាលឡើយ។

៣. វិធានការរបស់រដ្ឋសមាជិកមួយ ក្នុងការបែងចែកនិងផ្តល់ការប្រើប្រាស់វិសាលគមន៍ហ្វ្រេកង់ស៍និងការគ្រប់គ្រងហ្វ្រេកង់ស៍ មិនមែនជាវិធានការដែលអសង្គតិភាពនឹងមាត្រា៨ (ច្រកចូលទីផ្សារ) នៃកិច្ចព្រមព្រៀងនេះឡើយ។ ក្នុងន័យនេះ រដ្ឋសមាជិកនីមួយៗរក្សានូវសិទ្ធិក្នុងការបង្កើតនិងអនុវត្តគោលនយោបាយគ្រប់គ្រងវិសាលគមន៍និងហ្វ្រេកង់ស៍ ដែលអាចជះឥទ្ធិពលចំពោះការកម្រិតចំនួននៃអ្នកផ្តត់ផ្តង់បណ្តាញទូគមនាគមន៍ឬសេវាទូគមនាគមន៍សាធារណៈ ប្រសិនបើការកម្រិតនោះមានសង្គតិភាពទៅនឹងប្រការនានានៃកិច្ចព្រមព្រៀងនេះ។ សិទ្ធិបែបនោះ រួមមានលទ្ធភាពក្នុងការបែងចែងបន្ទាប់ហ្វ្រេកង់ស៍ ដោយពិចារណាលើតម្រូវការបច្ចុប្បន្ននិងអនាគតនិងភាពទំនេរនៃវិសាលគមន៍។

មាត្រា១៥
តម្លាភាព

រដ្ឋសមាជិកនីមួយៗត្រូវធានាថា រាល់ព័ត៌មានពាក់ព័ន្ធនឹងលក្ខខណ្ឌនានាដែលជះឥទ្ធិពលដល់សិទ្ធិចូលប្រើប្រាស់និងការប្រើប្រាស់បណ្តាញទូគមនាគមន៍និងសេវាទូគមនាគមន៍សាធារណៈ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដោយរួមមាន តារាងតម្លៃ និងខចែងនិងលក្ខខណ្ឌនានានៃសេវាកម្មភាពលម្អិតផ្នែកបច្ចេកទេសនៃដែនតភ្ជាប់ជាមួយបណ្តាញនិងសេវាបែបនោះ ព័ត៌មានអំពីអង្គភាពនានាដែលទទួលខុសត្រូវចំពោះការរៀបចំនិងការអនុម័តស្តង់ដា ដែលជះឥទ្ធិពលលើសិទ្ធិចូលប្រើប្រាស់និងការប្រើប្រាស់ លក្ខខណ្ឌនានាដែលអនុវត្តចំពោះការបំពាក់បរិធានឬបរិក្ខារផ្សេងទៀត និងសេចក្តីជូនដំណឹង ការអនុញ្ញាត ការចុះបញ្ជី ឬការផ្តល់អាជ្ញាប័ណ្ណ ប្រសិនបើមាន។

មាត្រា១៦
ការដោះស្រាយវិវាទទូគមនាគមន៍

១. រដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្តត់ផ្តង់បណ្តាញទូគមនាគមន៍ឬសេវាទូគមនាគមន៍សាធារណៈនៃរដ្ឋសមាជិកផ្សេងទៀត អាចមានពេលវេលាសមស្របដើម្បីធ្វើឧបាស្រ័យទៅកាន់អង្គភាពនិយ័តកម្មទូគមនាគមន៍របស់ខ្លួនឬអង្គភាពដោះស្រាយវិវាទ ដើម្បីដោះស្រាយវិវាទនានាដែលកើតឡើងក្រោមឧបសម្ព័ន្ធនេះ ស្របតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន។



២. ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន រដ្ឋសមាជិកនីមួយៗត្រូវធានាថាអ្នកផ្តត់ផ្តង់បណ្តាញទូគមនាគមន៍ឬសេវាទូគមនាគមន៍សាធារណៈណាមួយ ដែលរងនូវផលប៉ះពាល់ពីការកំណត់ឬសេចក្តីសម្រេចចិត្តរបស់អង្គភាពនិយ័តកម្មទូគមនាគមន៍ពាក់ព័ន្ធ

របស់ខ្លួន អាចប្តឹងទាមទារឱ្យអង្គភាពនោះធ្វើការពិចារណាឡើងវិញអំពីការកំណត់ឬសេចក្តីសម្រេចចិត្តបែបនោះ។ ពុំមានរដ្ឋសមាជិកណាមួយត្រូវអនុញ្ញាតឱ្យមានបណ្តឹងទាមទារបែបនោះ ដើម្បីបង្កើតជាមូលដ្ឋានសម្រាប់ការមិនប្រតិបត្តិទៅតាមការកំណត់ឬសេចក្តីសម្រេចចិត្តរបស់អង្គភាពនិយ័តកម្មនោះឡើយ វៀរលែងតែអាជ្ញាធរមានសមត្ថកិច្ចព្យួរឬដកចេញនូវការកំណត់ឬសេចក្តីសម្រេចចិត្តនោះ។

៣. រដ្ឋសមាជិកនីមួយៗត្រូវជានាថា អ្នកផ្តត់ផ្តង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈណាមួយ ដែលរងការប៉ះពាល់ដោយការកំណត់ឬការសម្រេចចុងក្រោយរបស់អង្គភាពនិយ័តកម្មទូរគមនាគមន៍ពាក់ព័ន្ធរបស់ខ្លួន អាចស្នើសុំពិនិត្យឡើងវិញនូវការកំណត់ឬសេចក្តីសម្រេចនេះ ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួន។

មាត្រា១៧
ទំនាក់ទំនងនឹងអង្គការអន្តរជាតិ

បណ្តារដ្ឋសមាជិកទទួលស្គាល់នូវសារៈសំខាន់នៃស្តង់ដាអន្តរជាតិសម្រាប់ភាពចុះសម្រុងគ្នាទូទាំងពិភពលោកនិងអន្តរប្រតិបត្តិការនៃបណ្តាញនិងសេវាទូរគមនាគមន៍ និងការទទួលយ៉ាប់រងដើម្បីជំរុញស្តង់ដានេះ តាមរយៈការងាររបស់ស្ថាប័នអន្តរជាតិពាក់ព័ន្ធ រួមមាន សហភាពទូរគមនាគមន៍អន្តរជាតិ និងអង្គការអន្តរជាតិសម្រាប់ស្តង់ដាជាដើម។

មាត្រា១៨
ទូរស័ព្ទរ៉ូមីងអន្តរជាតិ

១. បណ្តារដ្ឋជាសមាជិកត្រូវខិតខំព្យាយាមដើម្បីធ្វើកិច្ចសហប្រតិបត្តិការ ស្តីពីការជំរុញអត្រាតម្លៃប្រកបដោយតម្លាភាពនិងសមហេតុផលសម្រាប់សេវាទូរស័ព្ទរ៉ូមីងអន្តរជាតិ ដែលអាចនឹងជួយដល់ការជំរុញកំណើនពាណិជ្ជកម្មក្នុងចំណោមបណ្តារដ្ឋសមាជិក និងលើកកម្ពស់សុខុមាលភាពអតិថិជន។

២. រដ្ឋសមាជិកអាចជ្រើសរើសនូវដំហាននានា ដើម្បីលើកកម្ពស់តម្លាភាពនិងភាពប្រកួតប្រជែងពាក់ព័ន្ធនឹងអត្រាតម្លៃសេវាទូរស័ព្ទរ៉ូមីងអន្តរជាតិ និងជម្រើសនៃបច្ចេកទេសផ្សេងពីសេវារ៉ូមីង ដូចជា៖

(ក) ការជានាព័ត៌មានពាក់ព័ន្ធនឹងអត្រាតម្លៃលក់រាយ គឺអាចស្វែងរកបានដោយងាយចំពោះអតិថិជន និង

(ខ) ការធ្វើអប្បបរមាកម្មលើឧបសគ្គចំពោះការប្រើប្រាស់ជម្រើសនៃបច្ចេកទេសផ្សេងពីសេវារ៉ូមីង ដែលករណីនេះ នៅពេលដែលអតិថិជនធ្វើដំណើរទៅក្នុងដែនដីនៃរដ្ឋសមាជិកមួយដោយចេញពីដែនដីនៃរដ្ឋសមាជិកផ្សេងទៀត អាចចូលប្រើប្រាស់បាននូវសេវាទូរគមនាគមន៍ដោយប្រើប្រាស់នូវឧបករណ៍តាមជម្រើសរបស់ខ្លួន។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៣. បណ្តារដ្ឋសមាជិកទទួលស្គាល់ថា រដ្ឋសមាជិកមួយអាចជ្រើសរើសដើម្បីដំរុញភាពប្រកួតប្រជែងពាក់ព័ន្ធនឹងអត្រាតម្លៃសេវាទូរស័ព្ទរ៉ូមីងអន្តរជាតិ រួមទាំង តាមរយៈកិច្ចរៀបចំពាណិជ្ជកម្មនានា ឬដើម្បីអនុម័តឬរក្សាទុកនូវវិធានការនានា ដែលដៈឥទ្ធិពលដល់អត្រាតម្លៃសម្រាប់សេវារ៉ូមីងអន្តរជាតិដែលលក់ដុំនិង/ឬលក់រាយ ក្នុងគោលបំណងជានានូវអត្រាតម្លៃដែលសមស្រប។ ប្រសិនបើរដ្ឋសមាជិកមួយយល់ថាសមហេតុផល រដ្ឋសមាជិកនោះអាចធ្វើកិច្ចសហប្រតិបត្តិការ និងអនុវត្តយន្តការនានាជាមួយនឹងបណ្តារដ្ឋសមាជិកផ្សេងទៀត ដើម្បីសម្រួលដល់ការអនុវត្តវិធានការទាំងនោះ រួមបញ្ចូលទាំង តែមិនកំណត់ តាមរយៈការឈានចូលទៅក្នុងកិច្ចរៀបចំណាមួយជាមួយនឹងបណ្តារដ្ឋសមាជិកទាំងនោះ។

៤. ប្រសិនបើរដ្ឋសមាជិកមួយ ("រដ្ឋសមាជិកទីមួយ") ជ្រើសរើសគ្រប់គ្រងអត្រាតម្លៃឬលក្ខខណ្ឌនានាសម្រាប់សេវាទូរស័ព្ទរ៉ូមីងអន្តរជាតិដែលលក់ដុំនិង/ឬលក់រាយ រដ្ឋសមាជិកនោះត្រូវជានាថាអ្នកផ្តត់ផ្តង់សេវាទូរគមនាគមន៍សាធារណៈនៃរដ្ឋសមាជិកផ្សេងទៀត ("រដ្ឋសមាជិកទីពីរ") មានលទ្ធភាពទទួលបាននូវអត្រាតម្លៃឬលក្ខខណ្ឌនានាដែលបានរៀបចំនោះ ចំពោះសេវាទូរស័ព្ទរ៉ូមីងអន្តរជាតិដែលលក់ដុំនិង/ឬលក់រាយ សម្រាប់អតិថិជនរបស់ខ្លួនដែលធ្វើដំណើរនៅក្នុងដែនដីនៃរដ្ឋសមាជិកទីមួយ ប្រសិនបើរដ្ឋសមាជិកទីពីរបានឈានចូលទៅក្នុងកិច្ចរៀបចំណាមួយជាមួយនឹងរដ្ឋសមាជិកទីមួយ ដើម្បីគ្រប់គ្រងអត្រាតម្លៃឬលក្ខខណ្ឌនានាតាមបែបបដិការ ចំពោះសេវាទូរស័ព្ទរ៉ូមីងអន្តរជាតិដែលលក់ដុំនិង/ឬលក់រាយ សម្រាប់អ្នកផ្តត់ផ្តង់របស់រដ្ឋសមាជិកទាំងពីរនោះ។[11] ថ្វីបើយ៉ាងនេះក៏ដោយ រដ្ឋសមាជិកទីមួយអាចនឹងតម្រូវឱ្យអ្នកផ្តត់ផ្តង់នៃរដ្ឋសមាជិកទីពីរ ប្រើប្រាស់ពេញលេញនូវវិធីសាស្ត្រនៃការចរចាផ្នែកពាណិជ្ជកម្មដើម្បីឈានដល់ការព្រមព្រៀងគ្នាលើខចែងនានាសម្រាប់ការទទួលបានអត្រាតម្លៃឬលក្ខខណ្ឌទាំងនោះ។

៥. រដ្ឋសមាជិកមួយដែលជានានូវលទ្ធភាពទទួលបានអត្រាតម្លៃឬលក្ខខណ្ឌនានាដែលបានរៀបចំសម្រាប់សេវាទូរស័ព្ទរ៉ូមីងអន្តរជាតិដែលលក់ដុំនិង/ឬលក់រាយ ដូចមានចែងក្នុងកថាខណ្ឌ៤ ត្រូវបានចាត់ទុកថាប្រតិបត្តិស្របទៅតាមមាត្រា៧ (ប្រព្រឹត្តកម្មប្រជាជាតិដែលទទួលបាន

---

[11] ដើម្បីឱ្យកាន់តែច្បាស់៖

(ក) ពុំមានរដ្ឋសមាជិកណាមួយ ដោយពឹងផ្អែកតែម្យ៉ាងលើមូលដ្ឋាននៃកាតព្វកិច្ចនានាដែលជំពាក់ដោយរដ្ឋសមាជិកទីមួយក្រោមប្រការពាក់ព័ន្ធនឹងប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត ឬក្រោមប្រការពាក់ព័ន្ធនឹងការមិនរើសអើងដាក់លាក់ផ្នែកទូរគមនាគមន៍ ដែលនៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិណាមួយ ត្រូវធ្វើការស្នើសុំឬទទួលបានសម្រាប់អ្នកផ្តត់ផ្តង់របស់ខ្លួន នូវលទ្ធភាពក្នុងការទទួលបានអត្រាតម្លៃឬលក្ខខណ្ឌនានាដែលបានរៀបចំ ចំពោះសេវាទូរស័ព្ទរ៉ូមីងអន្តរជាតិដែលលក់ដុំនិង/ឬលក់រាយ ដែលមានចែងនៅក្រោមមាត្រានេះឡើយ។

(ខ) លទ្ធភាពទទួលបានអត្រាតម្លៃឬលក្ខខណ្ឌនានាដែលបានរៀបចំដោយរដ្ឋសមាជិកទីមួយ ត្រូវប្រព្រឹត្តទៅបានសម្រាប់អ្នកផ្តត់ផ្តង់របស់រដ្ឋសមាជិកទីពីរ លុះត្រាតែអត្រាតម្លៃឬលក្ខខណ្ឌនានាដែលបានរៀបចំនោះគឺអាចប្រៀបធៀបគ្នាបានយ៉ាងសមស្របទៅនឹងអត្រាតម្លៃឬលក្ខខណ្ឌនានាដែលបានរៀបចំតាមបែបបដិការក្រោមកិច្ចរៀបចំនោះ។ ក្នុងករណីគ្មានការឯកភាពគ្នា អង្គភាពនិយ័តកម្មទូរគមនាគមន៍នៃរដ្ឋសមាជិកទីមួយត្រូវកំណត់ថាតើ អត្រាតម្លៃឬលក្ខខណ្ឌនានាបែបនោះគឺអាចប្រៀបធៀបគ្នាបានយ៉ាងសមស្របដែរឬយ៉ាងណា។ សម្រាប់គោលបំណងនៃកំណត់សម្គាល់ជើងទំព័រនេះ អត្រាតម្លៃឬលក្ខខណ្ឌនានាដែលអាចប្រៀបធៀបគ្នាបានយ៉ាងសមស្រប សំដៅដល់ អត្រាតម្លៃឬលក្ខខណ្ឌនានាដែលត្រូវបានឯកភាពថាអាចប្រៀបធៀបគ្នាបានដោយអ្នកផ្តត់ផ្តង់ពាក់ព័ន្ធ ឬ ក្នុងករណីគ្មានការឯកភាពគ្នា ដែលត្រូវបានកំណត់ថាអាចប្រៀបធៀបគ្នាបានដោយអង្គភាពនិយ័តកម្មទូរគមនាគមន៍នៃរដ្ឋសមាជិកទីមួយ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ភាពអនុគ្រោះបំផុត) នៃកិច្ចព្រមព្រៀងនេះ និងមាត្រា៣ (សិទ្ធិចូលប្រើប្រាស់និងការប្រើប្រាស់) និងមាត្រា៦ (ប្រព្រឹត្តិកម្មដោយអ្នកផ្តត់ផ្តង់មេ) នៃឧបសម្ព័ន្ធនេះ។

៦. ពុំមានអ្វីនៅក្នុងមាត្រានេះត្រូវតែម្រូវឱ្យរដ្ឋសមាជិកមួយ ធ្វើការគ្រប់គ្រងអត្រាតម្លៃនិងលក្ខខណ្ឌ នានា សម្រាប់សេវាទូរស័ព្ទរ៉ូមីងអន្តរជាតិឡើយ។

មាត្រា១៩
ស្ថានីយ៍ប្រព័ន្ធខ្សែកាបក្រោមបាតសមុទ្រអន្តរជាតិ[12] [13]

១. ករណីស្ថិតក្រោមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន រដ្ឋសមាជិកមួយអនុញ្ញាតឱ្យអ្នកផ្តត់ផ្តង់បណ្តាញទូរគមនាគមន៍សាធារណៈណាមួយនៅក្នុងដែនដីរបស់ខ្លួន ធ្វើប្រតិបត្តិការស្ថានីយ៍ប្រព័ន្ធខ្សែកាបក្រោមបាតសមុទ្រអន្តរជាតិ ក្នុងនាមជាបណ្តាញទូរគមនាគមន៍សាធារណៈ រដ្ឋសមាជិកនោះត្រូវធានាថា អ្នកផ្តត់ផ្តង់បែបនោះផ្តល់ដល់អ្នកផ្តត់ផ្តង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈនៃរដ្ឋសមាជិកផ្សេងទៀត នូវប្រព្រឹត្តិកម្មដែលសមហេតុផល និងមិនរើសអើង ស្ថិតក្នុងកាលៈទេសៈដូចគ្នា។

២. ករណីដែលបរិក្ខារនិងសេវាកម្មនៃប្រព័ន្ធខ្សែកាបក្រោមបាតសមុទ្រ មិនអាចជំនួសបានតាមលក្ខណៈសេដ្ឋកិច្ចនិងបច្ចេកទេស នោះរដ្ឋសមាជិកនីមួយៗត្រូវធានាថា អ្នកផ្តត់ផ្តង់មេណាមួយដែលកាន់កាប់ឬគ្រប់គ្រងស្ថានីយ៍ប្រព័ន្ធខ្សែកាបអ្រក្រោមបាតសមុទ្រអន្តរជាតិ ក្នុងដែនដីរបស់ខ្លួន អនុញ្ញាតឱ្យអ្នកផ្តត់ផ្តង់បណ្តាញទូរគមនាគមន៍ឬសេវាទូរគមនាគមន៍សាធារណៈនៃរដ្ឋសមាជិកផ្សេងទៀត៖

(i) អាចចូលប្រើប្រាស់ស្ថានីយ៍ប្រព័ន្ធខ្សែកាបក្រោមបាតសមុទ្រអន្តរជាតិ និង

(ii) ធ្វើសហទីតាំងសម្រាប់ឧបករណ៍បញ្ជូននិងពង្រាយការតភ្ជាប់ នៅឯស្ថានីយ៍ប្រព័ន្ធខ្សែកាបក្រោមបាតសមុទ្រអន្តរជាតិ

ដោយផ្អែកលើខចែងនិងលក្ខខណ្ឌនានា និងនៅក្នុងអត្រាតម្លៃដែលសមហេតុផល មិនរើសអើង និងតម្លាភាព។

---

[12] ឥណ្ឌូនេស៊ី សន្យាក្នុងការអនុវត្តមាត្រានេះ ខណៈណាមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន។

[13] សម្រាប់វៀតណាម៖

(i) មាត្រានេះត្រូវអនុវត្តចំពោះតែអ្នកផ្តត់ផ្តង់មេ ដែលកាន់កាប់ឬគ្រប់គ្រងស្ថានីយ៍ប្រព័ន្ធខ្សែកាបក្រោមបាតសមុទ្រអន្តរជាតិរបស់វៀតណាម

(ii) ទោះជាមានចែងក្រោមថាខណ្ឌ២(i) លទ្ធភាពចូលប្រើប្រាស់ស្ថានីយ៍ប្រព័ន្ធខ្សែកាបក្រោមបាតសមុទ្រអន្តរជាតិ ត្រូវស្របទៅនឹងច្បាប់និងបទប្បញ្ញត្តិក្នុងស្រុកពាក់ព័ន្ធរបស់វៀតណាម និង

(iii) ទោះជាមានចែងក្រោមថាខណ្ឌ២(ii) ការធ្វើសហទីតាំងសម្រាប់ស្ថានីយ៍ប្រព័ន្ធខ្សែកាបក្រោមបាតសមុទ្រអន្តរជាតិ ដែលកាន់កាប់ឬគ្រប់គ្រងដោយអ្នកផ្តត់ផ្តង់មេនៅក្នុងដែនដីរបស់វៀតណាម ត្រូវលើកលែងការធ្វើសហទីតាំងបែបរបវន្ត។ ប្រការនេះអាចរួមបញ្ចូលការធ្វើសហទីតាំងបែបនិម្មិត។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ឧបសម្ព័ន្ធស្តីពីសេវាកម្មគាំទ្រដល់ការដឹកជញ្ជូនផ្លូវអាកាស

១. "**សេវាកម្មជួសជុលនិងថែទាំអាកាសយាន**" សំដៅដល់ សកម្មភាពពាក់ព័ន្ធនឹងការជួសជុលនិងការថែទាំ ដែលត្រូវបានប្រព្រឹត្តទៅចំពោះអាកាសយានមួយ ឬមួយផ្នែកនៃអាកាសយាន នៅខណៈពេលដែលអាកាសយាននោះត្រូវបានដាក់ពីប្រតិបត្តិការសេវាកម្ម ហើយមិនរាប់បញ្ចូលការថែទាំក្នុងខ្សែច្រវាក់ប្រតិបត្តិការសេវាកម្មឡើយ។

២. "**ការលក់ឬការធ្វើទីផ្សារចំពោះសេវាកម្មដឹកជញ្ជូនផ្លូវអាកាស**" សំដៅដល់ កាលានុវត្តភាពទាំងឡាយសម្រាប់ក្រុមហ៊ុនដឹកជញ្ជូនផ្លូវអាកាសពាក់ព័ន្ធ ដើម្បីលក់ឬធ្វើទីផ្សារដោយសេរីលើសេវាកម្មដឹកជញ្ជូនផ្លូវអាកាសរបស់ខ្លួន ដោយរួមបញ្ចូលគ្រប់ទិដ្ឋភាពនៃការធ្វើទីផ្សារ មានដូចជាការស្រាវជ្រាវទីផ្សារ ការផ្សព្វផ្សាយ និងការចែកចាយ។ សកម្មភាពទាំងនេះមិនរួមបញ្ចូលនូវការកំណត់ថ្លៃនៃសេវាកម្មដឹកជញ្ជូនផ្លូវអាកាស ឬលក្ខខណ្ឌអនុវត្តឡើយ។

៣. "**សេវាកម្មបម្រុងទុកមុនតាមប្រព័ន្ធកុំព្យូទ័រ**" សំដៅដល់ សេវាកម្មទាំងឡាយដែលត្រូវបានផ្តល់ដោយប្រព័ន្ធកុំព្យូទ័រ ដែលមានផ្ទុកព័ត៌មានអំពីកាលវិភាគហោះហើររបស់ក្រុមហ៊ុនដឹកជញ្ជូនផ្លូវអាកាស ភាពទំនេររបស់យន្តហោះ ថ្លៃសំបុត្រយន្តហោះ និងលក្ខខណ្ឌនៃថ្លៃ ដែលតាមរយៈប្រព័ន្ធបែបនេះ ការបម្រុងទុកមុនឬការចេញសំបុត្រយន្តហោះអាចប្រព្រឹត្តទៅបាន។

៤. "**ការជួលអាកាសយានដោយគ្មានក្រុមអាកាសយានិក**" សំដៅដល់ ការជួលអាកាសយានមួយដោយគ្មានក្រុមអាកាសយានិក ដែលជាធម្មតាហៅកាត់ថា "ការជួលស្ងួត"។ ស្ថិតនៅក្រោមកិច្ចព្រមព្រៀងជួលភាគច្រើន អ្នកសុំជួលដែលជាអ្នកផ្តល់នូវក្រុមអាកាសយានិក គឺជាភាគីមានតួនាទីទទួលខុសត្រូវ ហើយក៏ជាអ្នកដែលត្រូវតែអនុវត្តតួនាទីគ្រប់គ្រងប្រតិបត្តិការរបស់អាកាសយាន រួមជាមួយនឹងការទទួលខុសត្រូវនានាចំពោះអ្នកបម្រើការ។

៥. "**ការជួលអាកាសយានដោយមានក្រុមអាកាសយានិក**" សំដៅដល់ ការជួលអាកាសយានមួយដោយមានក្រុមអាកាសយានិក ដែលជាធម្មតាហៅកាត់ថា "ការជួលសើម"។ នៅក្នុងការជួលសើម អ្នកជួលឱ្យជាធម្មតាអនុវត្តតួនាទីគ្រប់គ្រងប្រតិបត្តិការរបស់អាកាសយាន។ ជាទូទៅ ស្ថានភាពនៃការជួលសើម មានន័យថា អាកាសយាននោះគប្បីត្រូវបានប្រតិបត្តិការក្រោមវិញ្ញាបនបត្រប្រតិបត្តិការផ្លូវអាកាស (AOC) ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋដែលចុះបញ្ជីអាកាសយាននោះ។

៦. "**សេវាកម្មបញ្ជូនទំនិញផ្លូវអាកាស**" សំដៅដល់ សកម្មភាពនិងការរៀបចំសេវាកម្មដឹកជញ្ជូនផ្លូវអាកាសនិងសេវាកម្មពាក់ព័ន្ធ ដែលត្រូវបានផ្តល់ជូនឬអនុវត្តក្នុងនាមតំណាងឱ្យអ្នកបញ្ជូនទំនិញ/អ្នកទទួលទំនិញ សម្រាប់ការដឹកជញ្ជូនទំនិញតាមផ្លូវអាកាសដែលចេញពីអាកាសយានដ្ឋានដើមទៅគោលដៅចុងក្រោយ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

សៀលភាពនៃសេវាកម្ម រួមមានសេវាកម្មដូចខាងក្រោម៖

(i) ការធានាកន្លែងទំនេរសម្រាប់ផ្ទុកទំនិញជាមួយក្រុមហ៊ុនអាកាសចរណ៍

(ii) ការរៀបចំឯកសារចាំបាច់សម្រាប់ការនាំចេញ/នាំចូល

(iii) ការរៀបចំដំណើរការបែបបទគយ

(iv) ការទទួលនិងការប្រគល់ទំនិញ

(v) ការវេចខ្ចប់/ការរៀបចំបញ្ចូលឃ្លាំង

(vi) ការប្រមូលទំនិញជាក់រួមគ្នា និងការដឹកជញ្ជូនទំនិញជាលក្ខណៈដាច់ដោយឡែក

(vii) សេវាកម្មបញ្ជូនទំនិញពីផ្ទះមួយទៅផ្ទះមួយ និងសេវាកម្មកស្តុការកម្ម និង

(viii) សេវាកម្មដឹកជញ្ជូនទំនិញក្នុងស្រុក។

៧. "**ការបម្រើសេវាកម្មគ្រប់គ្រងរៀបចំទំនិញ**" សំដៅដល់ សេវាកម្មដែលត្រូវបានផ្តល់ឬរៀបចំសម្រាប់ឃ្លាំងទំនិញ ដំណើរការសម្របសម្រួលនានា និងសេវាកម្មទាំងឡាយសម្រាប់ការផ្ទុកនិងការបម្រើសេវាកម្មគ្រប់គ្រងរៀបចំចំពោះគ្រប់ប្រភេទនៃការដឹកជញ្ជូន ដែលត្រូវបានដឹកជញ្ជូនតាមផ្លូវអាកាស។ ការបម្រើសេវាកម្មគ្រប់គ្រងរៀបចំទំនិញ គ្របដណ្តប់លើការបម្រើសេវាកម្មគ្រប់គ្រងរៀបចំបែបរូបវន្តនៃទំនិញចេញ/ចូល ការដឹកជញ្ជូនឆ្លងកាត់ ការបម្រើសេវាកម្មគ្រប់គ្រងរៀបចំចំពោះការដឹកជញ្ជូនមិនប្រក្រតី ការត្រួតពិនិត្យឯកត្តាផ្ទុក (ULD) និងសេវាកម្មពាក់ព័ន្ធនឹងការត្រួតពិនិត្យដោយគយ។

៨. "**សេវាកម្មបម្រើម្ហូបអាហារលើអាកាសយាន**" សំដៅដល់ ការរៀបចំ/ការផលិតម្ហូបអាហារនិងកេសជ្ជៈនានាសម្រាប់ក្រុមហ៊ុនអាកាសចរណ៍ រួមមាន ការលើកដាក់ឡើង/ចុះនៃឧបករណ៍និងសម្ភារៈផ្តត់ផ្តង់ក្នុងការបម្រើម្ហូបអាហារ ការរៀបចំរទេះរុញ ទស្សនាវដ្តី ផ្កា វត្ថុអនុស្សាវរីយ៍ និងសម្ភារៈបន្ទាប់បន្សំផ្សេងៗចូលក្នុង/ចេញពីអាកាសយាន ការដុះលាង ការសម្អាត ការទុកដាក់ឧបករណ៍បម្រើម្ហូបអាហារ និងការបោកសម្អាតកម្រាលប្រើប្រាស់ក្នុងបន្ទប់អាកាសយាន។

៩. "**សេវាកម្មចាក់ប្រេងឥន្ធនៈ**" សំដៅដល់ ការគ្រប់គ្រងនិងការធ្វើប្រតិបត្តិការយានយន្តដឹកជញ្ជូនប្រេងឥន្ធនៈសម្រាប់អាកាសយាន និងយានយន្តបម្រើការនៅអាកាសយានដ្ឋាន និងការចែកចាយផលិតផលប្រេងឥន្ធនៈ។ (អង្គការសហប្រជាជាតិ CPC 74220, 74610, 61300, 62113, 622271)

១០. "**ការថែទាំអាកាសយានក្នុងខ្សែច្រវាក់ប្រតិបត្តិការសេវាកម្ម**" សំដៅដល់ ការថែទាំត្រួតពិនិត្យទៀងទាត់និងមិនទៀងទាត់ និងការផ្តល់ការបញ្ជាក់អំពីដំណើរការខុសប្រក្រតី ដែលសកម្មភាពនេះប្រព្រឹត្តទៅ*នៅតាមផ្លូវ* និងនៅស្ថានីយ៍មូលដ្ឋាន រួមជាមួយនឹងការប្រើប្រាស់រយៈពេលយ៉ាងហ្មត់ចត់ត្រឹម២៤ម៉ោង។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

១១. "**ការបម្រើសេវាកម្មនៅលើផ្ទៃដី**" សំដៅដល់ សេវាកម្មទាំងឡាយ ដែលត្រូវបានផ្តល់ដោយឧបករណ៍គាំទ្រនៅលើផ្ទៃដី សម្រាប់បម្រើសេវាកម្មដល់អាកាសយានមួយនៅពេលមកដល់ក្នុងអំឡុងពេលកំពុងសំចតរហូតដល់ពេលនៃការចេញដំណើរ។

សេវាកម្មទាំងនោះ រួមមានការសម្របសម្រួលដូចខាងក្រោម៖

(i) ឧបករណ៍គាំទ្រនៅលើផ្ទៃដី (GSE) ឧទាហរណ៍ ត្រាក់ទ័រអូសឬសណ្តោងអាកាសយាន ឧបករណ៍ផ្តល់ខ្យល់ម៉ាស៊ីនត្រជាក់ ឧបករណ៍បញ្ជោះម៉ាស៊ីនអាកាសយាន ឧបករណ៍ផ្តល់ថាមពលអគ្គីសនី ឧបករណ៍លើកដាក់ឥវ៉ាន់ ឧបករណ៍ ULDs

(ii) សេវាកម្មរថយន្តដឹកជញ្ជូនអ្នកដំណើរ និងក្រុមអាកាសយានិកទៅកាន់និងចេញមកពីអាកាសយាន ឆ្ពោះទៅស្ថានីយ៍អ្នកដំណើរ

(iii) សេវាកម្មសន្តិសុខចំពោះអាកាសយាន ក៏ដូចជាអ្នកដំណើរនៅតំបន់បម្រើសេវាកម្មនៅលើផ្ទៃដី

(iii) សេវាកម្មសម្អាតផ្នែកខាងក្នុងអាកាសយាននិងបង្គន់អនាម័យ

(iv) សេវាកម្មផ្គត់ផ្គង់ទឹកចល័ត

(v) សេវាកម្មកញ្ចប់បុស្តិ៍ប្រៃសណីយ៍ និង

(vi) ការថែទាំឧបករណ៍ GSE និង ULDs ។

១២. "**ការបម្រើសេវាកម្មឥវ៉ាន់របស់អ្នកដំណើរ**" សំដៅដល់ ដំណើរការចំពោះប្រព័ន្ធនៃការចេញដំណើរនិងការមកដល់នៅឯស្ថានីយ៍។ ចំពោះការចេញដំណើរ ការបម្រើសេវាកម្មឥវ៉ាន់របស់អ្នកដំណើររួមមានសកម្មភាពចំនួនបី ដូចជា៖ (១) អ្នកដំណើរដែលបានចុះឈ្មោះចូលបញ្ជីពីក្នុងក្រុង ធ្វើការចុះឈ្មោះនៅក្រៅបរិវេណអាកាសយានដ្ឋាន (២) ការចុះឈ្មោះចូលបញ្ជីនៅឯស្ថានីយ៍នៃអាកាសយានដ្ឋាន និង (៣) អ្នកដំណើរដែលបានចុះឈ្មោះចូលបញ្ជីរួច មានឥវ៉ាន់តាមខ្លួននៅឯច្រកអាកាសយាន ហើយធ្វើការចុះចូលបញ្ជីនៅហ្នឹងកន្លែង។ ចំពោះការមកដល់ការបម្រើសេវាកម្មឥវ៉ាន់របស់អ្នកដំណើររួមមានសកម្មភាពចំនួនបី ដូចជា៖ (១) ការដោក់ចុះឥវ៉ាន់របស់អ្នកដំណើរពីអាកាសយាន (២) ការដឹកជញ្ជូនឥវ៉ាន់របស់អ្នកដំណើររវាងអាកាសយាននិងកន្លែងយកឥវ៉ាន់ និង (៣) ការលើកដាក់ឥវ៉ាន់របស់អ្នកដំណើរទៅលើកន្លែងយកឥវ៉ាន់។

១៣. "**ការបម្រើសេវាកម្មអ្នកដំណើរ**" សំដៅដល់ ការទទួលខុសត្រូវក្នុងការផ្តល់សេវាកម្មដល់អ្នកដំណើរចាប់តាំងពីកន្លែងនៃការចុះឈ្មោះចូលបញ្ជីទៅដល់អាកាសយាន ស្របទៅតាមនីតិវិធី និងសេចក្តីណែនាំរបស់ក្រុមហ៊ុនដឹកជញ្ជូន។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ព្រះរាជក្រម

នស/រកម/០៧២៣/ ០០៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សហនគូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ច្បាប់
ស្តីពី
អត្រានុកូលដ្ឋាន
ស្ថិតិអត្រានុកូលដ្ឋាន
និងអត្តសញ្ញាណកម្ម

ទំព័រ៥៨០ អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១.- គោលបំណង

ច្បាប់នេះកំណត់អំពីវិធាននិងនីតិវិធីដែលទាក់ទងនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន ការចុះបញ្ជីស្នាក់នៅ ការរៀបចំស្ថិតិអត្រានុកូលដ្ឋាន ការចុះបញ្ជីអត្តសញ្ញាណបុគ្គលនិងការរៀបចំនិងការគ្រប់គ្រងបញ្ជីប្រជាជន ក្នុងគោលបំណងដើម្បី៖

ក- ធានាឱ្យមានការចុះបញ្ជីអត្រានុកូលដ្ឋាន ជាកាតព្វកិច្ច ជាសកល ដោយជាប់លាប់និងជាអចិន្ត្រៃយ៍។

ខ- ធានាឱ្យមានការចុះបញ្ជីអត្តសញ្ញាណបុគ្គលជាសកល ដោយជាប់លាប់និងជាអចិន្ត្រៃយ៍។

គ- ធានាថាការចុះបញ្ជីស្នាក់នៅ ជាកាតព្វកិច្ច ជាសកល ដោយជាប់លាប់និងជាអចិន្ត្រៃយ៍។

ឃ- ធានាឱ្យមនុស្សគ្រប់រូបមានអត្តសញ្ញាណខាងផ្លូវច្បាប់តាមរយៈការចុះបញ្ជីអត្រានុកូលដ្ឋាននិងការចុះបញ្ជីអត្តសញ្ញាណ ដោយផ្តល់ចំពោះបុគ្គលម្នាក់ៗនូវលេខសម្គាល់អត្តសញ្ញាណបុគ្គល។

ង- ធានានូវការគោរពសិទ្ធិមនុស្ស ការទទួលបានសេវាគ្រប់ប្រភេទ ហើយជាមូលដ្ឋានសម្រាប់រៀបចំផែនការអភិវឌ្ឍន៍និងការតាមដានភាពរីកចម្រើននៃសង្គម។

មាត្រា២.- វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះជនគ្រប់រូបដែលរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជានិងប្រជាពលរដ្ឋខ្មែរដែលរស់នៅបរទេស។

មាត្រា៣.- និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យដូចមានក្នុងសទ្ធានុក្រមជាឧបសម្ព័ន្ធនៃច្បាប់នេះ។

ជំពូកទី២
ការចុះបញ្ជីអត្រានុកូលដ្ឋាន

ផ្នែកទី១
វិធានទូទៅ

មាត្រា៤.- ព្រឹត្តិការណ៍ជីវិតដែលត្រូវចុះបញ្ជី

ព្រឹត្តិការណ៍ជីវិតដែលតម្រូវឱ្យចុះបញ្ជី រួមមានកំណើតរស់ មរណភាព និងអាពាហ៍ពិពាហ៍។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៥៨១

២- ក្រៅពីព្រឹត្តិការណ៍ជីវិតដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ព្រឹត្តិការណ៍ជីវិតផ្សេងទៀតក៏ត្រូវចុះបញ្ជីផងដែរ រួមមានការទទួលស្គាល់កូន ការបញ្ជាក់អំពីនត្តិភាពនៃបុត្តភាព ការបញ្ជាក់អំពីអត្តិភាពនៃមាតុភាព សុំកូន ការកាត់កាល់កូនសុំ ការលែងលះ មោឃភាពអាពាហ៍ពិពាហ៍ ការលុបចោលអាពាហ៍ពិពាហ៍ និងព្រឹត្តិការណ៍ជីវិតផ្សេងទៀតដែលច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតតម្រូវឱ្យចុះបញ្ជីស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ផ្នែកទី២
បញ្ជីអត្រានុកូលដ្ឋាន

មាត្រា៥ .- ប្រភេទបញ្ជីអត្រានុកូលដ្ឋាន

បញ្ជីអត្រានុកូលដ្ឋាន រួមមានបញ្ជីកំណើតរស់ បញ្ជីមរណភាព និងបញ្ជីអាពាហ៍ពិពាហ៍។

មាត្រា៦ .- ទម្រង់បញ្ជីអត្រានុកូលដ្ឋាន

១- បញ្ជីអត្រានុកូលដ្ឋានអាចរក្សាទុកក្នុងទម្រង់ជាក្រដាសនិង/ឬទម្រង់អេឡិចត្រូនិក។

២- ទម្រង់និងព័ត៌មានដែលមាននៅក្នុងបញ្ជីអត្រានុកូលដ្ឋាននិងទម្រង់ប្រើប្រាស់ដើម្បីដូនដំណឹង រាយការណ៍និងចុះបញ្ជីព្រឹត្តិការណ៍ជីវិត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លើកលែងតែមានបទប្បញ្ញត្តិដោយឡែកចែងនៅក្នុងច្បាប់នេះ។

ផ្នែកទី៣
មន្ត្រីអត្រានុកូលដ្ឋាន

មាត្រា៧ .- មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ

១- អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ គឺជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

២- ក្នុងករណីដែលអគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃអវត្តមាន អគ្គនាយករងម្នាក់ដែលទទួលសិទ្ធិជាអគ្គនាយកស្តីទីមានសិទ្ធិអំណាចទទួលខុសត្រូវជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

មាត្រា៨ .- មន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត

១- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត ក្នុងដែនសមត្ថកិច្ចដែលខ្លួនគ្រប់គ្រង។

២- ក្នុងករណីដែលអភិបាលនៃគណៈអភិបាលរាជធានី ខេត្តអវត្តមាន អភិបាលរងរាជធានី ខេត្ត ដែលទទួលសិទ្ធិជាអភិបាលស្តីទីនៃគណៈអភិបាលរាជធានី ខេត្ត មានសិទ្ធិអំណាចទទួលខុសត្រូវជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត និងត្រូវរាយការណ៍ជាផ្លូវការជូនមន្ត្រីអត្រានុកូលដ្ឋាន

មាត្រា៩ .- មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ

១- អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ ក្នុងដែនសមត្ថកិច្ចដែលខ្លួនគ្រប់គ្រង។

២- ក្នុងករណីដែលអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌអវត្តមាន អភិបាលរងក្រុង ស្រុក ខណ្ឌ ដែលទទួលសិទ្ធិជាអភិបាលស្តីទីនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ មានសិទ្ធិអំណាចទទួលខុសត្រូវជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ និងត្រូវរាយការណ៍ជាផ្លូវការជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត។

មាត្រា១០ .- មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់

១- មេឃុំ ចៅសង្កាត់ ជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ក្នុងដែនសមត្ថកិច្ចដែលខ្លួនគ្រប់គ្រង។

២- ក្នុងករណីដែលមេឃុំ ចៅសង្កាត់អវត្តមាន មេឃុំ ចៅសង្កាត់ ត្រូវប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរជូនអ្នកជំនួយការមេឃុំ ចៅសង្កាត់តាមឋានានុក្រម និងត្រូវរាយការណ៍ជាផ្លូវការជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ។

៣- ក្នុងករណីដែលមេឃុំ ចៅសង្កាត់អវត្តមានដោយសារមរណភាពឬការបញ្ឈប់មុខតំណែងក្នុងរយៈពេលអន្តរកាលដែលមិនទាន់មានការតែងតាំងមេឃុំ ចៅសង្កាត់ថ្មី មេឃុំ ចៅសង្កាត់ស្តីទី គឺជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់។

មាត្រា១១ .- មន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវចាត់តាំងមន្ត្រី១(មួយ)រូបជាមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស និងត្រូវជូនដំណឹងទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃអំពីការចាត់តាំងនេះ។

ផ្នែកទី៤
សមត្ថកិច្ចនៃមន្ត្រីអត្រានុកូលដ្ឋាន

មាត្រា១២ .- សមត្ថកិច្ចនៃមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ មានសមត្ថកិច្ចដូចខាងក្រោម៖

ក- គ្រប់គ្រងនិងរក្សាទុកបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទដែលបានអនុវត្តរួច។

ខ- ជានាការអនុវត្តបទប្បញ្ញត្តិនិងលិខិតបទដ្ឋាននានាស្តីពីអត្រានុកូលដ្ឋានដែលស្ថិតនៅក្រោមច្បាប់នេះ។

គ- ដាក់ចេញគោលការណ៍ សេចក្តីណែនាំនិងបែបបទនិងនីតិវិធីស្របតាមការកំណត់ក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ។

ឃ- ត្រួតពិនិត្យនិងណែនាំដល់មន្ត្រីអត្រានុកូលដ្ឋានគ្រប់ថ្នាក់ រួមទាំងមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេសលើការអនុវត្តការងារអត្រានុកូលដ្ឋាន។

ROYAUME DU CAMBODGE
MINISTERE DU PALAIS ROYAL

ង- អភិវឌ្ឍផែនការនិងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីអត្រានុកូលដ្ឋាន។

ច- ជំរុញឱ្យមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត និងមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេសផ្តល់របាយការណ៍អត្រានុកូលដ្ឋានឱ្យបានទៀងទាត់និងត្រឹមត្រូវតាមការកំណត់។

ឆ- រាយការណ៍រាល់ករណីរំលោភបទប្បញ្ញត្តិច្បាប់ដែលប្រព្រឹត្តដោយមន្ត្រីអត្រានុកូលដ្ឋាន ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីចាត់វិធានការតាមច្បាប់។

ជ- ពិនិត្យសម្រេចនិងអនុញ្ញាតឱ្យកែតម្រូវទិន្នន័យអត្រានុកូលដ្ឋានឬអនុញ្ញាតឱ្យចុះបញ្ជីអត្រានុកូលដ្ឋានឡើងវិញ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ឈ- ពិនិត្យនិងសម្រេចលើការចុះបញ្ជីអត្រានុកូលដ្ឋាន ក្នុងករណីដែលមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ផ្សេងទៀតមិនអាចសម្រេចបាន។

ញ- ពិនិត្យនិងសម្រេចលើបណ្តឹងមិនសុខចិត្តនឹងការចាត់ចែង រួមទាំងសេចក្តីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋានគ្រប់លំដាប់ថ្នាក់និងមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា អំពីការចុះបញ្ជីអត្រានុកូលដ្ឋាន។

ដ- ចេញសេចក្តីចម្លងសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍ ក្នុងករណីដែលមានការស្នើសុំ។

ឋ- ក្នុងករណីដែលចាំបាច់ ស្នើសុំគោលការណ៍ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងការបង្កើតការិយាល័យចុះបញ្ជីអត្រានុកូលដ្ឋាននៅមូលដ្ឋានសុខាភិបាលឬកន្លែងផ្សេងទៀតដែលព្រឹត្តិការណ៍ជីវិតអាចកើតឡើង ដោយរៀបចំឱ្យមានបុគ្គលិកអត្រានុកូលដ្ឋានឬធ្វើប្រតិកូកម្មភារកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានទៅឱ្យមន្ត្រីសុខាភិបាល។

ឌ- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតដែលកំណត់ដោយអនុក្រឹត្យ។

មាត្រា១៣.- សមត្ថកិច្ចនៃមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត មានសមត្ថកិច្ចដូចខាងក្រោម៖

ក- ចេញសេចក្តីចម្លងសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍តាមការស្នើសុំ។

ខ- កែតម្រូវកំហុសនៅក្នុងបញ្ជីអត្រានុកូលដ្ឋានដែលជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋាន ឬយោងតាមបទប្បញ្ញត្តិនៃច្បាប់នេះឬច្បាប់ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

គ- តាមដាន ត្រួតពិនិត្យ និងគាំទ្រការអនុវត្តការងាររបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីធានាការអនុវត្តបទប្បញ្ញត្តិនិងលិខិតបទដ្ឋាននានាស្តីពីអត្រានុកូលដ្ឋាន ដែលស្ថិតនៅក្រោមច្បាប់នេះ។

ឃ- អភិវឌ្ឍផែនការនិងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីអត្រានុកូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ង- ជំរុញឱ្យមន្ត្រីអត្រានុកូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួនផ្តល់របាយការណ៍អត្រានុកូលដ្ឋានឱ្យបានទៀងទាត់និងត្រឹមត្រូវតាមការកំណត់។

ច- ពិនិត្យនិងសម្រេចលើការចុះបញ្ជីអត្រានុកូលដ្ឋាន ក្នុងករណីដែលមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ មិនអាចសម្រេចបាន។

ឆ- ពិនិត្យនិងសម្រេចលើបណ្តឹងមិនសុខចិត្តនឹងការចាត់ចែង រួមទាំងសេចក្តីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ អំពីការចុះបញ្ជីអត្រានុកូលដ្ឋាន។

ជ- បំពេញភារកិច្ចចាំបាច់ផ្សេងទៀត ដែលកំណត់ដោយអនុក្រឹត្យ។

មាត្រា១៤.- សមត្ថកិច្ចនៃមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ មានសមត្ថកិច្ចដូចខាងក្រោម៖

ក- ចេញសេចក្តីចម្លងសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍ តាមការស្នើសុំ។

ខ- កែតម្រូវកំហុសនៅក្នុងបញ្ជីអត្រានុកូលដ្ឋាន ដែលជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋាន យោងតាមបទប្បញ្ញត្តិនៃច្បាប់នេះឬច្បាប់ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

គ- តាមដាន ត្រួតពិនិត្យ និងគាំទ្រការអនុវត្តការងាររបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ដើម្បីធានាការអនុវត្តបទប្បញ្ញត្តិនិងលិខិតបទដ្ឋាននានាស្តីពីអត្រានុកូលដ្ឋាន ដែលស្ថិតនៅក្រោមច្បាប់នេះ។

ឃ- គាំទ្រនិងពង្រឹងសមត្ថភាពដល់មន្ត្រីអត្រានុកូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ង- ជំរុញឱ្យមន្ត្រីអត្រានុកូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួនផ្តល់របាយការណ៍អត្រានុកូលដ្ឋានឱ្យបានទៀងទាត់និងត្រឹមត្រូវតាមការកំណត់។

ច- ពិនិត្យនិងសម្រេចលើការចុះបញ្ជីអត្រានុកូលដ្ឋានក្នុងករណីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ មិនអាចសម្រេចបាន។

ឆ- ពិនិត្យនិងសម្រេចលើបណ្តឹងមិនសុខចិត្តនឹងការចាត់ចែង រួមទាំងសេចក្តីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ អំពីការចុះបញ្ជីអត្រានុកូលដ្ឋាន។

ជ- បំពេញភារកិច្ចចាំបាច់ផ្សេងទៀត ដែលកំណត់ដោយអនុក្រឹត្យ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៥៨៥

មាត្រា១៥.- សមត្ថកិច្ចនៃមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ មានសមត្ថកិច្ចដូចខាងក្រោម៖

ក- ពិនិត្យនិងកត់ត្រាព័ត៌មានចាំបាច់នានាទាក់ទងនឹងកំណើតរស់ មរណភាព និងអាពាហ៍ពិពាហ៍។

ខ- ចេញសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍ច្បាប់ដើមនិងសេចក្តីចម្លង។

គ- កែតម្រូវកំហុសនៅក្នុងបញ្ជីអត្រានុកូលដ្ឋាន ដែលជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានយោងតាមបទប្បញ្ញត្តិនៃច្បាប់នេះឬច្បាប់ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

ឃ- ផ្តល់ការអនុញ្ញាតសម្រាប់ការបូជាសពឬការបញ្ចុះសព។

ង- កត់ត្រា កែតម្រូវ ឬធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋាន តាមសេចក្តីសម្រេចជាស្ថាពររបស់តុលាការនិង/ឬទៅតាមការសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់លើដែលមានអានុភាពអនុវត្ត។

ច- ផ្តល់របាយការណ៍អត្រានុកូលដ្ឋានឱ្យបានទៀងទាត់និងត្រឹមត្រូវទៅតាមការកំណត់។

ឆ- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនចំពោះការចុះបញ្ជីអត្រានុកូលដ្ឋាននិងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការចុះបញ្ជីអត្រានុកូលដ្ឋាន។

ជ- សហការជាមួយសមត្ថកិច្ចនៅមូលដ្ឋាន មន្ត្រីសុខាភិបាល មន្ត្រីអប់រំ មន្ត្រីសង្គមកិច្ច និងមន្ត្រីនៃក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត អំពីការងារអត្រានុកូលដ្ឋាន ក្នុងករណីដែលចាំបាច់។

ឈ- ចុះបញ្ជីអត្រានុកូលដ្ឋានចល័តនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីសម្រេចឱ្យបាននូវការចុះបញ្ជីអត្រានុកូលដ្ឋានពេញលេញ។

ញ- បំពេញការកិច្ចចាំបាច់ផ្សេងទៀត ដែលកំណត់ដោយអនុក្រឹត្យ។

មាត្រា១៦.- សមត្ថកិច្ចនៃមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា

មន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា មានសមត្ថកិច្ចដូចខាងក្រោម៖

ក- ពិនិត្យនិងកត់ត្រាព័ត៌មានចាំបាច់នានាទាក់ទងនឹងកំណើតរស់ មរណភាព និងអាពាហ៍ពិពាហ៍។

ខ- ចេញសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍ច្បាប់ដើមនិងសេចក្តីចម្លង។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

គ- កែតម្រូវកំហុសនៅក្នុងបញ្ជីអត្រានុកូលដ្ឋាន ដែលជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋាន យោងតាមបទប្បញ្ញត្តិនៃច្បាប់នេះឬច្បាប់ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

ឃ- ផ្តល់របាយការណ៍អត្រានុកូលដ្ឋានឱ្យបានទៀងទាត់និងត្រឹមត្រូវទៅតាមការកំណត់។

ង- បំពេញការកិច្ចចាំបាច់ផ្សេងទៀត ដែលកំណត់ដោយអនុក្រឹត្យ។

ផ្នែកទី៥
ការចុះបញ្ជីកំណើតរស់

មាត្រា១៧.- ការចុះបញ្ជីកំណើតរស់

រាល់កំណើតរស់ដែលកើតឡើងក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវរាយការណ៍និងចុះបញ្ជីដោយរយោងតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

មាត្រា១៨.- ទីកន្លែងចុះបញ្ជីកំណើតរស់

អ្នករាយការណ៍ ត្រូវដាក់ពាក្យដើម្បីចុះបញ្ជីកំណើតរស់ នៅការិយាល័យអត្រានុកូលដ្ឋានណាមួយនៃ៖

ក- ឃុំ សង្កាត់ ដែលកំណើតរស់បានកើតឡើង។

ខ- ឃុំ សង្កាត់ ដែលអ្នករាយការណ៍ស្នាក់នៅ។

គ- កន្លែងផ្សេងទៀត តាមការកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងមហាផ្ទៃ។

មាត្រា១៩.- រយៈពេលសម្រាប់ចុះបញ្ជីកំណើតរស់

១- អ្នករាយការណ៍ត្រូវដាក់ពាក្យដើម្បីចុះបញ្ជីកំណើតរស់ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃគិតចាប់ពីកាលបរិច្ឆេទដែលទារកកើត។

២- ក្រសួងមហាផ្ទៃអាចពន្យាររយៈពេលកំណត់នៃការដាក់ពាក្យសុំចុះបញ្ជីកំណើតរស់សម្រាប់ភូមិសាស្ត្រជាក់លាក់ ឬក្រុមជនជាតិដើមភាគតិច ឬដោយសារមូលហេតុផ្សេងទៀត ក្នុងករណីដែលចាំបាច់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

មាត្រា២០.- អ្នករាយការណ៍អំពីកំណើតរស់

១- បុគ្គលទទួលខុសត្រូវជាអ្នករាយការណ៍អំពីកំណើតរស់ ត្រូវបានកំណត់តាមអាទិភាពដូចខាងក្រោម៖

ក- ម្តាយរបស់ទារក។

ខ- ឪពុករបស់ទារក។

គ- អ្នកអាណាព្យាបាលទូទៅរបស់ឪពុកម្តាយទារក។

ឃ- ញាតិជានីតិជនដែលមើលថែទារក។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ង- រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ឬអ្នកតំណាងឬបុគ្គលផ្សេងទៀត ដែលកំណត់ដោយច្បាប់នេះឬច្បាប់ផ្សេងទៀត។

២- ក្នុងករណីដែលមានការចាំបាច់ អ្នករាយការណ៍ក្រៅពីបុគ្គលដែលបានកំណត់ខាងលើត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា២១.- ការជូនដំណឹងអំពីកំណើតរស់ដែលកើតនៅក្នុងមូលដ្ឋានសុខាភិបាល

១- ប្រធានឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាលដែលកំណើតរស់បានកើតឡើង ត្រូវផ្តល់ឯកសារបញ្ជាក់អំពីកំណើតរស់ទៅឱ្យអ្នករាយការណ៍ទៅតាមអាទិភាពដែលបានកំណត់នៅក្នុងមាត្រា២០(អ្នករាយការណ៍អំពីកំណើតរស់) នៃច្បាប់នេះ។

២- ប្រសិនបើទារកកើតនៅក្រៅមូលដ្ឋានសុខាភិបាល ហើយម្តាយនិងទារកធ្វើដំណើរទៅមូលដ្ឋានសុខាភិបាលក្នុងរយៈពេល៤៨(សែសិបប្រាំបី)ម៉ោង ប្រធានឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាល ត្រូវផ្តល់ឯកសារបញ្ជាក់អំពីកំណើតរស់ឱ្យទៅអ្នករាយការណ៍ទៅតាមអាទិភាពដែលបានកំណត់នៅក្នុងមាត្រា២០(អ្នករាយការណ៍អំពីកំណើតរស់) នៃច្បាប់នេះ។

៣- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២ខាងលើនេះ ប្រធានឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាល ត្រូវធ្វើច្បាប់ចម្លងនៃឯកសារបញ្ជាក់អំពីកំណើតរស់នោះមួយច្បាប់ទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច។

៤- ទម្រង់ បែបបទ និងនីតិវិធីសម្រាប់ការផ្តល់ឯកសារបញ្ជាក់អំពីកំណើតរស់ដល់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

មាត្រា២២.- ការជូនដំណឹងអំពីកំណើតរស់ដែលកើតនៅក្រៅមូលដ្ឋានសុខាភិបាល

ប្រសិនបើកំណើតរស់កើតនៅក្រៅមូលដ្ឋានសុខាភិបាល ហើយម្តាយនិងទារកមិនបានធ្វើដំណើរទៅកាន់មូលដ្ឋានសុខាភិបាលក្នុងរយៈពេល៤៨(សែសិបប្រាំបី)ម៉ោង បុគ្គលឬស្ថាប័នដែលបានដឹងពីព្រឹត្តិការណ៍កំណើតរស់នេះ អាចត្រូវឱ្យផ្តល់ព័ត៌មានឬឯកសារដូចមានកំណត់នៅក្នុងប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

មាត្រា២៣.- ពាក្យសុំចុះបញ្ជីកំណើតរស់

១- អ្នករាយការណ៍ អាចដាក់ពាក្យសុំចុះបញ្ជីកំណើតរស់ជាលាយលក្ខណ៍អក្សរ ដោយផ្ទាល់មាត់ឬតាមទម្រង់អេឡិចត្រូនិក។

២- ក្នុងពាក្យសុំចុះបញ្ជីកំណើតរស់ អ្នករាយការណ៍ត្រូវបំពេញពាក្យសុំនូវចំណុចខាងក្រោម:

ក- ឈ្មោះរបស់ទារក។

ខ- ភេទរបស់ទារក។

គ- ថ្ងៃ ខែ ឆ្នាំកំណើត ម៉ោងនិងទីកន្លែងទារកកើតរស់។

ឃ- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល សញ្ជាតិ និងលំនៅឋានរបស់ឪពុកម្តាយរបស់ទារក។

ង- ឈ្មោះថ្ងៃ ខែ ឆ្នាំកំណើតលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល និងអាសយដ្ឋានបច្ចុប្បន្នរបស់អ្នករាយការណ៍ ក្នុងករណីដែលអ្នករាយការណ៍មិនមែនជាម្តាយឬឪពុក។

ច- ថ្ងៃ ខែ ឆ្នាំ ដែលពាក្យសុំត្រូវបានធ្វើឡើង។

ឆ- ចំណុចផ្សេងទៀត ដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

៣- ទម្រង់និងបែបបទនៃពាក្យសុំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

មាត្រា២៤.- ឯកសារភ្ជាប់ជាមួយនឹងពាក្យសុំចុះបញ្ជីកំណើតរស់

១- អ្នករាយការណ៍ ត្រូវភ្ជាប់ឯកសារបញ្ជាក់អំពីកំណើតរស់ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ឬកថាខណ្ឌទី២នៃមាត្រា២១(ការជូនដំណឹងអំពីកំណើតរស់ដែលកើតនៅក្នុងមូលដ្ឋានសុខាភិបាល) នៃច្បាប់នេះ ជាមួយនឹងពាក្យសុំចុះបញ្ជីកំណើតរស់។ ប្រសិនបើអ្នករាយការណ៍មិនមានឯកសារបញ្ជាក់អំពីកំណើតរស់នោះទេ អ្នករាយការណ៍ត្រូវភ្ជាប់ឯកសារផ្សេងទៀតដែលអាចបញ្ជាក់អំពីកំណើតរស់របស់ទារក។

២- អ្នករាយការណ៍ក៏ត្រូវភ្ជាប់ផងដែរនូវឯកសារដែលអាចបញ្ជាក់អត្តសញ្ញាណរបស់ឪពុកម្តាយរបស់ទារកជាមួយនឹងពាក្យសុំចុះបញ្ជីកំណើតរស់។

៣- ឯកសារផ្សេងទៀតដែលអាចបញ្ជាក់អំពីកំណើតរស់របស់ទារកដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី២នៃកថាខណ្ឌទី១និងឯកសារដែលអាចបញ្ជាក់អត្តសញ្ញាណរបស់ឪពុកម្តាយរបស់ទារកដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

មាត្រា២៥.- នីតិវិធីចុះបញ្ជីកំណើតរស់

១- នៅពេលទទួលបានពាក្យសុំចុះបញ្ជីកំណើតរស់និងឯកសារភ្ជាប់ដែលបានកំណត់នៅក្នុងមាត្រា២៣(ពាក្យសុំចុះបញ្ជីកំណើតរស់) និងមាត្រា២៤(ឯកសារភ្ជាប់ជាមួយនឹងពាក្យសុំចុះបញ្ជីកំណើតរស់) នៃច្បាប់នេះ មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើការពិនិត្យ ផ្ទៀងផ្ទាត់ និងកត់ត្រាព័ត៌មាននោះទៅក្នុងបញ្ជីកំណើតរស់។

២- ព័ត៌មានអប្បបរមាសម្រាប់ការចុះបញ្ជីកំណើតរស់ រួមមានឈ្មោះ ភេទ ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើតរបស់អ្នកកើត។

៣- ប្រសិនបើមន្ត្រីអត្រានុកូលដ្ឋានពិនិត្យឃើញថាពាក្យសុំចុះបញ្ជីកំណើតរស់ខ្វះនូវព័ត៌មានណាមួយក្នុងចំណោមព័ត៌មានអប្បបរមាដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ខាងលើនេះ មន្ត្រី

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៥៨៩

ក- បណ្តឹងមិនសុខចិត្តទាក់ទងនឹងការសម្រេចឬការបដិសេធដោយអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវប្តឹងទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃដែលបានទទួលសេចក្តីសម្រេចឬការបដិសេធនោះ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវធ្វើការសម្រេចលើបណ្តឹងមិនសុខចិត្តនេះ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃដែលបានទទួលបណ្តឹងមិនសុខចិត្តនោះ។ នីតិវិធីនៃការប្តឹងមិនសុខចិត្តទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ខ- ក្នុងករណីបុគ្គលណាម្នាក់មិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បុគ្គលនោះអាចដាក់ពាក្យបណ្តឹងទៅតុលាការដែលមានសមត្ថកិច្ចក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច ឬការបដិសេធនោះ។

៣- បណ្តឹងចំពោះសេចក្តីសម្រេចឬការបដិសេធដោយមជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន ដូចបានបញ្ញត្តនៅក្នុងចំណុច ង នៃកថាខណ្ឌទី២ នៃមាត្រា១៥៤(ការកែតម្រូវសម្រង់ព័ត៌មាន) នៃច្បាប់នេះ ត្រូវដាក់ទៅតុលាការដែលមានសមត្ថកិច្ចដោយផ្ទាល់ នៅក្នុងរយៈពេល៣០(សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីទទួលបានសេចក្តីសម្រេចឬការបដិសេធនោះ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៦៣៩

ផ្នែកទី២
ការការពារឯកជនភាពបុគ្គល

មាត្រា១៥៩ .- ការរក្សាការសម្ងាត់និទ្ទេសអត្តសញ្ញាណបុគ្គល

១- ព័ត៌មានដែលមាននៅក្នុងបញ្ជីត្រូវបានការពារ។ ការរក្សាការសម្ងាត់នៃព័ត៌មានឯកជន នៃបុគ្គលដែលបានកត់ត្រានិងរក្សាទុកនៅក្នុងបញ្ជីប្រជាជន បញ្ជីអត្រានុកូលដ្ឋាន បញ្ជីស្នាក់នៅ បញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងបញ្ជីអត្តសញ្ញាណបុគ្គលផ្សេងទៀត ដែលស្ថិតនៅក្រោមច្បាប់នេះ ត្រូវបានការពារ។

២- បញ្ជីឈ្មោះបុគ្គលដែលមាននៅក្នុងបញ្ជីប្រជាជន បញ្ជីអត្រានុកូលដ្ឋាន បញ្ជីស្នាក់នៅ បញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងបញ្ជីអត្តសញ្ញាណបុគ្គលផ្សេងទៀតដែលស្ថិតនៅក្រោមច្បាប់នេះ មិនត្រូវផ្សព្វផ្សាយឬបង្ហាញដោយបុគ្គលឬគ្រឹះស្ថានឬអង្គភាពណាមួយដែលមិនទទួលបានការអនុញ្ញាតពីច្បាប់ ឬពីលិខិតបទដ្ឋានគតិយុត្ត ឬសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ផ្នែកទី៣
សន្តិសុខទិន្នន័យ

មាត្រា១៦០ .- សុវត្ថិភាពទិន្នន័យក្នុងពេលប្រមូល បញ្ជូន ប្រើប្រាស់និងផ្ទុកទិន្នន័យ

១- ការប្រមូល ការបញ្ជូន ការប្រើប្រាស់និងការផ្ទុកទិន្នន័យអត្តសញ្ញាណបុគ្គល ត្រូវធ្វើឡើងក្នុងលក្ខណៈមួយដែលធានាបាននូវសន្តិសុខ សុក្រឹតភាព សុចរិតភាពទិន្នន័យ ការពារទិន្នន័យមិនឱ្យមានការប្រើប្រាស់ដោយគ្មានការអនុញ្ញាតនិងធានាមិនឱ្យមានការបាត់បង់។

២- នីតិវិធីនៃការប្រមូល ការបញ្ជូន ការប្រើប្រាស់និងការផ្ទុកទិន្នន័យ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃឬក្រសួងឬស្ថាប័នពាក់ព័ន្ធផ្សេងទៀត។

មាត្រា១៦១ .- សិទ្ធិរបស់មន្ត្រីសាធារណៈក្នុងការប្រើប្រាស់ទិន្នន័យអត្តសញ្ញាណបុគ្គល

១- សិទ្ធិរបស់មន្ត្រីសាធារណៈក្នុងការប្រើប្រាស់ទិន្នន័យអត្តសញ្ញាណបុគ្គលត្រូវបានកម្រិតឱ្យប្រើប្រាស់បានតែចំពោះទិន្នន័យអត្តសញ្ញាណបុគ្គល ដែលចាំបាច់សម្រាប់បំពេញមុខងារសាធារណៈរបស់មន្ត្រីសាធារណៈនោះប៉ុណ្ណោះ។

២- បែបបទ នីតិវិធី និងលក្ខខណ្ឌនៃការប្រើប្រាស់ទិន្នន័យអត្តសញ្ញាណបុគ្គលដោយមន្ត្រីសាធារណៈ ដូចបានបញ្ញត្តនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា១៦២ .- ការរក្សាទុកជាឯកសារបណ្ណសារអចិន្ត្រៃយ៍

១- ទោះបីជាមានបញ្ញត្តនៅក្នុងច្បាប់ស្តីពីបណ្ណសារក៏ដោយ ចំពោះ៖

ក- បញ្ជីអត្រានុកូលដ្ឋាននិងបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវរក្សាទុកជាអចិន្ត្រៃយ៍នៅក្រសួងមហាផ្ទៃ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ខ- បញ្ជីប្រជាជនត្រូវរក្សាទុកជាអចិន្ត្រៃយ៍នៅមជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន។

គ- បញ្ជីស្នាក់នៅ បញ្ជីសញ្ជាតិ បញ្ជីលិខិតឆ្លងដែន និងបញ្ជីអន្តោប្រវេសន៍ ត្រូវរក្សាទុកនៅក្រសួងមហាផ្ទៃ។

២- រយៈពេលនៃការរក្សាទុកបញ្ជីដូចបានបញ្ញត្តនៅក្នុងចំណុច គ នៃកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ជំពូកទី៨
កម្រៃសេវា

មាត្រា១៦៣.- ទិសាលភាពនៃសេវា

សេវានៃជំពូកនេះ សំដៅដល់សេវាដែលបានកំណត់នៅក្នុងជំពូកទី២(ការចុះបញ្ជីអត្រានុកូលដ្ឋាន) ជំពូកទី៣(ស្ថិតិអត្រានុកូលដ្ឋាន) ជំពូកទី៤(ការចុះបញ្ជីស្នាក់នៅ) ជំពូកទី៥(ការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ) និងជំពូកទី៧(ការប្រើប្រាស់ទិន្នន័យ ការការពារឯកជនភាពបុគ្គលនិងសន្តិសុខទិន្នន័យ) នៃច្បាប់នេះ។

មាត្រា១៦៤.- សេវាដែលមិនតម្រូវឱ្យបង់កម្រៃ

សេវាដែលមិនតម្រូវឱ្យបង់កម្រៃ រួមមាន៖

ក- សេវាចុះបញ្ជីកំណើតរស់ មរណភាព អាពាហ៍ពិពាហ៍ និងការកែតម្រូវកំហុសបច្ចេកទេសដោយមន្ត្រីអត្រានុកូលដ្ឋាន។

ខ- សេវាចុះបញ្ជីតាមសេចក្តីសម្រេចរបស់តុលាការ។

គ- សេវាចុះបញ្ជីស្នាក់នៅ។

ឃ- សេវាផ្សេងទៀតដែលមិនតម្រូវឱ្យបង់កម្រៃសេវា ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា១៦៥.- ការកំណត់កម្រៃសេវាដែលត្រូវបង់

១- ក្រៅពីសេវាដែលមិនតម្រូវឱ្យបង់កម្រៃ ដូចបានបញ្ញត្តនៅក្នុងមាត្រា១៦៤(សេវាដែលមិនតម្រូវឱ្យបង់កម្រៃ) នៃច្បាប់នេះ ស្ថាប័នដែលមានសមត្ថកិច្ចអាចយកកម្រៃសេវាបាន។

២- កម្រៃសេវាដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ។

ជំពូកទី៩
ការត្រួតពិនិត្យនិងអធិការកិច្ច

មាត្រា១៦៦.- ការត្រួតពិនិត្យនិងអធិការកិច្ច

១- ការងារអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន ការចុះបញ្ជីស្នាក់នៅ អត្តសញ្ញាណកម្ម ការងារផ្សេងទៀតដែលបានកំណត់នៅក្នុងច្បាប់នេះ ត្រូវទទួលការត្រួតពិនិត្យនិងការធ្វើសវនកម្ម ឬអធិការកិច្ច ដោយមានលក្ខណៈជាប្រព័ន្ធ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៦៤១

២- បែបបទ លក្ខខណ្ឌ និងនីតិវិធីនៃការត្រួតពិនិត្យនិងការធ្វើសវនកម្មផ្ទៃក្នុងឬអធិការកិច្ច ត្រូវកំណត់ដោយក្រសួង ស្ថាប័ន ដែលមានសមត្ថកិច្ចពាក់ព័ន្ធ។

ជំពូកទី១០
ទោសប្បញ្ញត្តិ

មាត្រា១៦៧.- អំពើមិនចុះបញ្ជីអត្រានុកូលដ្ឋានឬចុះបញ្ជីផ្សេងៗ

អំពើរបស់មន្ត្រីចុះបញ្ជីដែលបដិសេធដោយចេតនាដោយគ្មានមូលហេតុចំពោះការចុះបញ្ជីអត្រានុកូលដ្ឋាន ឬការចុះបញ្ជីស្នាក់នៅ ឬការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលច្បាប់នេះតម្រូវឱ្យចុះបញ្ជីឬបដិសេធកត់ត្រាព័ត៌មានទាក់ទងនឹងអត្រានុកូលដ្ឋាន ឬការស្នាក់នៅ ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលច្បាប់នេះតម្រូវឱ្យកត់ត្រា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី១០០ ០០០(មួយសែន)រៀល ទៅ២ ០០០ ០០០(ពីរលាន)រៀល។

មាត្រា១៦៨.- អំពើធ្វើឱ្យខូចខាតឬបំផ្លាញឬធ្វើឱ្យបាត់បង់បញ្ជីដោយចេតនា

មន្ត្រីដែលមានសមត្ថកិច្ចរក្សាទុកបញ្ជីអត្រានុកូលដ្ឋាន ឬបញ្ជីស្នាក់នៅ ឬបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬបញ្ជីប្រជាជន ដែលច្បាប់នេះតម្រូវឱ្យរក្សាទុក ហើយបានធ្វើឱ្យខូចខាត ឬបំផ្លាញ ឬធ្វើឱ្យបាត់បង់បញ្ជីនោះដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំទៅ១០(ដប់)ឆ្នាំ។

មាត្រា១៦៩.- អំពើលុបឬកែប្រែព័ត៌មាននៅក្នុងបញ្ជីឬបញ្ចូលទិន្នន័យមិនពិតនៅក្នុងបញ្ជី

មន្ត្រីដែលមានសមត្ថកិច្ចគ្រប់គ្រងបញ្ជីអត្រានុកូលដ្ឋាន ឬបញ្ជីស្នាក់នៅ ឬបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរឬបញ្ជីប្រជាជនដែលបានលុប ឬកែប្រែព័ត៌មាននៅក្នុងបញ្ជី ឬបញ្ចូលទិន្នន័យមិនពិតទៅក្នុងបញ្ជីនោះដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំទៅ ១០(ដប់)ឆ្នាំ។

មាត្រា១៧០.- អំពើចូលដល់បញ្ជីដោយចេតនា

១- មន្ត្រីដែលគ្មានសមត្ថកិច្ចចូលដល់បញ្ជីអត្រានុកូលដ្ឋាន ឬបញ្ជីស្នាក់នៅ ឬបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬបញ្ជីប្រជាជន ហើយបានចូលដល់បញ្ជីនោះដោយចេតនា ឬមន្ត្រីដែលមានសមត្ថកិច្ចចូលដល់បញ្ជីអត្រានុកូលដ្ឋាន ឬបញ្ជីស្នាក់នៅ ឬបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬបញ្ជីប្រជាជន ហើយបានចូលដល់បញ្ជីនោះដោយចេតនាហួសពីសមត្ថកិច្ចរបស់ខ្លួន ឬមន្ត្រីដែលមានសមត្ថកិច្ចហើយបានអនុញ្ញាតឱ្យអ្នកផ្សេងទៀតចូលដល់ឬចែករំលែកព័ត៌មានពីបញ្ជីអត្រានុកូលដ្ឋាន ឬបញ្ជីស្នាក់នៅ ឬបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬបញ្ជីប្រជាជន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ២(ពីរ)ឆ្នាំនិងពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀល ទៅ៤ ០០០ ០០០(បួនលាន)រៀល។

២- ក្នុងករណីដែលអំពើដែលបានប្រព្រឹត្តដូចបញ្ញត្តនៅក្នុងកថាខណ្ឌទី១ខាងលើនេះ បណ្តាលឱ្យមានការខូចខាតដល់បញ្ជីឬប្រព័ន្ធប្រព្រឹត្តកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំទៅ ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀល ទៅ១០ ០០០ ០០០(ដប់លាន)រៀល។

ទំព័រ៦៤២អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

មាត្រា១៧១ .- អំពើផ្តល់ព័ត៌មានឬឯកសារក្លែងក្លាយដោយចេតនា សម្រាប់ការចុះបញ្ជី ការកត់ត្រា ឬការផ្ទេរដំណឹង

បុគ្គលដែលផ្តល់ព័ត៌មានឬឯកសារក្លែងក្លាយដោយចេតនាសម្រាប់ការចុះបញ្ជីអត្រានុកូលដ្ឋាន ឬការចុះបញ្ជីស្នាក់នៅ ឬការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬសម្រាប់កត់ត្រា ឬជូនដំណឹងទាក់ទងនឹងអត្រានុកូលដ្ឋាន ឬការស្នាក់នៅ ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ៦(ប្រាំមួយ)ខែ និងពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀលទៅ ៣ ០០០ ០០០(បីលាន)រៀល។

មាត្រា១៧២ .- អំពើក្លែងបន្លំ ឬកែប្រែសំបុត្រអត្រានុកូលដ្ឋាន សៀវភៅស្នាក់នៅ ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬសេចក្តីចម្លង ឬសម្រង់នៃបញ្ជីអត្រានុកូលដ្ឋាន បញ្ជីស្នាក់នៅ ឬបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬបញ្ជីប្រជាជន ដោយចេតនា

បុគ្គលដែលក្លែងបន្លំឬកែប្រែដោយចេតនានូវសំបុត្រអត្រានុកូលដ្ឋាន សៀវភៅស្នាក់នៅ ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬសេចក្តីចម្លង ឬសម្រង់នៃបញ្ជីអត្រានុកូលដ្ឋាន បញ្ជីស្នាក់នៅ ឬបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬបញ្ជីប្រជាជន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំទៅ ១០(ដប់)ឆ្នាំ។

ជំពូកទី១១
អន្តរប្បញ្ញត្តិ
ផ្នែកទី១
លិខិតបទដ្ឋានគតិយុត្តនិងនីតិវិធី
ដែលមានមុនកាលបរិច្ឆេទអនុវត្តជាធ្លាប់

មាត្រា១៧៣ .- អន្តរកាលនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តដែលមានកន្លងមក

នៅពេលដែលច្បាប់នេះមានអានុភាពអនុវត្ត លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន ការចុះបញ្ជីស្នាក់នៅ ការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងស្តីតិអត្រានុកូលដ្ឋានដែលកំពុងអនុវត្តនៅតែមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានបទប្បញ្ញត្តិថ្មីមកជំនួសលើកលែងតែបទប្បញ្ញត្តិណាដែលផ្ទុយនឹងច្បាប់នេះ។

មាត្រា១៧៤ .- នីតិវិធីដែលបានចាប់ផ្តើមមុនពេលច្បាប់នេះត្រូវបានអនុវត្ត

ក្រោយពេលច្បាប់នេះត្រូវបានអនុវត្ត នីតិវិធីណាដែលបានចាប់ផ្តើមហើយដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តចាស់តែមិនទាន់ចប់ ត្រូវបន្តនីតិវិធីដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្ត

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៦៤៣

ផ្នែកទី២
ព្រឹត្តិការណ៍ជីវិតនិងសេចក្តីសម្រេចរបស់តុលាការ
ដែលកើតមុនកាលបរិច្ឆេទអនុវត្តជាទូទៅ

មាត្រា១៧៥ .. ព្រឹត្តិការណ៍កំណើតរស់ឬមរណភាពដែលកើតឡើងមុនកាលបរិច្ឆេទអនុវត្តជាទូទៅ

១- ព្រឹត្តិការណ៍កំណើតរស់ឬមរណភាព ដែលបានកើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តច្បាប់នេះ តែមិនទាន់បានដាក់ពាក្យសុំចុះបញ្ជីត្រឹមកាលបរិច្ឆេទនៃការអនុវត្ត ត្រូវធ្វើការចុះបញ្ជីតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

២- បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ មិនត្រូវយកមកអនុវត្តចំពោះការចុះបញ្ជីមរណភាពរបស់បុគ្គលដែលមិនស្គាល់អត្តសញ្ញាណ ដូចបានបញ្ញត្តនៅក្នុងមាត្រា៦០(ការចុះបញ្ជីមរណភាពរបស់បុគ្គលដែលមិនស្គាល់អត្តសញ្ញាណ) នៃច្បាប់នេះ។

មាត្រា១៧៦ .. សេចក្តីសម្រេចរបស់តុលាការដែលទាក់ទងនឹងការចុះបញ្ជីអត្រានុកូលដ្ឋានមុនកាលបរិច្ឆេទអនុវត្តជាទូទៅ

១- សេចក្តីសម្រេចរបស់តុលាការទាំងឡាយណាដែលទាក់ទងនឹងការចុះបញ្ជីអត្រានុកូលដ្ឋានដូចជាការលែងលះ បិតុភាព មាតុភាព សុំកូន ការផ្តាច់មត៌កនិងការកែតម្រូវកំហុសនានាដែលបានចូលជាស្តាពរមុនកាលបរិច្ឆេទអនុវត្តជាទូទៅ ប៉ុន្តែមិនទាន់បានរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច អ្នកដាក់ពាក្យសុំទៅតុលាការឬបុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចរបស់តុលាការ អាចរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចបាន។

២- សេចក្តីសម្រេចរបស់តុលាការដែលទាក់ទងនឹងការប្តូរឈ្មោះដែលបានចូលជាស្តាពរមុនកាលបរិច្ឆេទអនុវត្តជាទូទៅ ប៉ុន្តែមិនទាន់បានរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច អ្នកដាក់ពាក្យសុំទៅតុលាការ ត្រូវរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ស្របតាមបញ្ញត្តិនៃកថាខណ្ឌទី៣នៃមាត្រា៨៩(ការប្តូរឈ្មោះដោយតុលាការ) នៃច្បាប់នេះ។

ជំពូកទី១២
អវសានប្បញ្ញត្តិ

ផ្នែកទី១
សុពលភាពនៃកំណត់ត្រាដែលមានកន្លងមក នីតិវិធីកន្លងមក
និងបទប្បញ្ញត្តិច្បាប់ផ្សេងទៀត

មាត្រា១៧៧ .. សុពលភាពនៃកំណត់ត្រាដែលមានមុនកាលបរិច្ឆេទនៃការអនុវត្តជាទូទៅនៃច្បាប់នេះ

១- រាល់កំណត់ត្រានៅក្នុងបញ្ជីអត្រានុកូលដ្ឋាន បញ្ជីស្នាក់នៅ និងបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលត្រូវបានធ្វើឡើងមុនកាលបរិច្ឆេទអនុវត្តជាទូទៅ ត្រូវបន្តមានសុពលភាពដូចគ្នាទៅនឹងកំណត់ត្រាអត្រានុកូលដ្ឋាន កំណត់ត្រាបញ្ជីស្នាក់នៅឬកំណត់ត្រាបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលធ្វើឡើងក្រោមច្បាប់នេះ។

ទំព័រ៦៤៤ អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

២- រាល់សំបុត្រអត្រានុកូលដ្ឋាន សៀវភៅស្នាក់នៅនិងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលនៅមានសុពលភាព ដែលបានចេញមុនកាលបរិច្ឆេទអនុវត្តជាទូទៅនិងរាល់សេចក្តីចម្លងឬសម្រង់ដែលមានការបញ្ជាក់ដែលចេញពីកំណត់ត្រាអត្រានុកូលដ្ឋាននិងកំណត់ត្រាស្នាក់នៅដែលធ្វើឡើងមុនកាលបរិច្ឆេទអនុវត្តជាទូទៅ ត្រូវបន្តមានសុពលភាពដូចនឹងសំបុត្រអត្រានុកូលដ្ឋាន សៀវភៅស្នាក់នៅ អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនិងសេចក្តីចម្លងឬសម្រង់ដែលចេញក្រោមច្បាប់នេះ។

ផ្នែកទី២
កាលបរិច្ឆេទនៃការអនុវត្តច្បាប់

មាត្រា១៧៨ .- កាលបរិច្ឆេទនៃការអនុវត្តច្បាប់នេះ

១- កាលបរិច្ឆេទនៃការអនុវត្តច្បាប់នេះ រួមមានកាលបរិច្ឆេទនៃការអនុវត្តជាទូទៅនិងកាលបរិច្ឆេទនៃការអនុវត្តដូចមានបញ្ញត្តិនៅក្នុងមាត្រា១៧៩(កាលបរិច្ឆេទអនុវត្តសម្រាប់បញ្ញត្តិទាក់ទងនឹងអាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន មជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជននិងប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន) មាត្រា១៨០(កាលបរិច្ឆេទអនុវត្តសម្រាប់បញ្ញត្តិពាក់ព័ន្ធនឹងការជូនដំណឹងដោយវិស័យសុខាភិបាលនិងការបញ្ជាក់អំពីមូលហេតុនៃមរណភាព) និងមាត្រា១៨១(កាលបរិច្ឆេទអនុវត្តសម្រាប់បញ្ញត្តិពាក់ព័ន្ធនឹងការជូនដំណឹងដោយតុលាការ) នៃច្បាប់នេះ។

២- បទប្បញ្ញត្តិនៃច្បាប់នេះលើកលែងតែបញ្ញត្តិដែលបានកំណត់នៅក្នុងមាត្រា១៧៩(កាលបរិច្ឆេទអនុវត្តសម្រាប់បញ្ញត្តិទាក់ទងនឹងអាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន មជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជននិងប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន) មាត្រា១៨០(កាលបរិច្ឆេទអនុវត្តសម្រាប់បញ្ញត្តិពាក់ព័ន្ធនឹងការជូនដំណឹងដោយវិស័យសុខាភិបាលនិងការបញ្ជាក់អំពីមូលហេតុនៃមរណភាព) និងមាត្រា១៨១(កាលបរិច្ឆេទអនុវត្តសម្រាប់បញ្ញត្តិពាក់ព័ន្ធនឹងការជូនដំណឹងដោយតុលាការ) នៃច្បាប់នេះ ត្រូវអនុវត្តភ្លាមនៅកាលបរិច្ឆេទដែលរយៈពេល១២(ដប់ពីរ)ខែ បានកន្លងផុតក្រោយពេលច្បាប់នេះចូលជាធរមាន។ កាលបរិច្ឆេទនេះហៅថា កាលបរិច្ឆេទអនុវត្តជាទូទៅ។

មាត្រា១៧៩ .- កាលបរិច្ឆេទអនុវត្តសម្រាប់បញ្ញត្តិទាក់ទងនឹងអាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន មជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជននិងប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន

ក្រោយកាលបរិច្ឆេទអនុវត្តជាទូទៅ បញ្ញត្តិខាងក្រោមត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទដែលកំណត់ដោយអនុក្រឹត្យ ក្រោយពីបានបង្កើតនិងដាក់ឱ្យដំណើរការអាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន មជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជននិងប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន៖

ក- មាត្រា២៦(ការផ្តល់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល)។

ខ- មាត្រា៥៨(ការបិទអត្តសញ្ញាណខាងផ្លូវច្បាប់របស់មរណជន)។

គ- មាត្រា៩៦(ការបញ្ជូនទិន្នន័យ)។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៦៤៥

ឃ- កថាខណ្ឌទី២ នៃមាត្រា១២១(ការរក្សាទុក ការថែទាំបញ្ជីស្នាក់នៅ និងការបញ្ជូនព័ត៌មានបញ្ជីស្នាក់នៅ)។

ង- កថាខណ្ឌទី១ នៃមាត្រា១៣៥(ការបញ្ជូនទិន្នន័យនិងការថែរក្សាទិន្នន័យអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ)។

ច- រាល់មាត្រានៃជំពូកទី៦(ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន) គិតចាប់ពីមាត្រា១៣៨ រហូតដល់មាត្រា១៥១។

ឆ- ចំណុច ង នៃកថាខណ្ឌទី២ មាត្រា១៥៤(ការកែតម្រូវសម្រង់ព័ត៌មាន)។

ជ- មាត្រា១៥៥(ទិន្នន័យនៃបញ្ជីប្រជាជន)។

ឈ- មាត្រា១៥៦(ការប្រើប្រាស់ទិន្នន័យក្នុងបញ្ជីប្រជាជន)។

ញ- មាត្រា១៥៧(ការផលិតទិន្នន័យស្ថិតិចេញពីបញ្ជីប្រជាជន)។

ដ- កថាខណ្ឌទី៣ នៃមាត្រា១៥៨(បណ្តឹងមិនសុខចិត្តចំពោះសេចក្តីសម្រេចឬការបដិសេធទាក់ទងនឹងសិទ្ធិទទួលបានព័ត៌មានអត្តសញ្ញាណបុគ្គល)។

មាត្រា១៨០ .- កាលបរិច្ឆេទអនុវត្តសម្រាប់បញ្ញត្តិពាក់ព័ន្ធនឹងការជូនដំណឹងដោយវិស័យសុខាភិបាលនិងការបញ្ជាក់អំពីមូលហេតុនៃមរណភាព

១- ក្រោយកាលបរិច្ឆេទអនុវត្តជាទូទៅ បញ្ញត្តិពាក់ព័ន្ធនឹងការជូនដំណឹងដោយវិស័យសុខាភិបាលខាងក្រោម ត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទដែលកំណត់ដោយអនុក្រឹត្យ៖

ក- កថាខណ្ឌទី៣ នៃមាត្រា២១(ការជូនដំណឹងអំពីកំណើតរស់ដែលកើតនៅក្នុងមូលដ្ឋានសុខាភិបាល)។

ខ- កថាខណ្ឌទី១ នៃមាត្រា២២(ការជូនដំណឹងអំពីកំណើតរស់ដែលកើតនៅក្រៅមូលដ្ឋានសុខាភិបាល)។

គ- កថាខណ្ឌទី៣ នៃមាត្រា៤៥(ការជូនដំណឹងអំពីមរណភាពដែលកើតឡើងនៅក្នុងមូលដ្ឋានសុខាភិបាល)។

ឃ- កថាខណ្ឌទី២ នៃមាត្រា៤៦(ការជូនដំណឹងអំពីមរណភាពដែលកើតឡើងនៅក្រៅមូលដ្ឋានសុខាភិបាល)។

ង- មាត្រា៤៧(ការជូនដំណឹងអំពីមរណភាពបណ្តាលមកពីគ្រោះមហន្តរាយធម្មជាតិឬគ្រោះអាសន្នទ្រង់ទ្រាយធំ)។

២- ក្រោយកាលបរិច្ឆេទអនុវត្តជាទូទៅ បញ្ញត្តិខាងក្រោមពាក់ព័ន្ធនឹងការបញ្ជាក់អំពីមូលហេតុនៃមរណភាព ត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទដែលកំណត់ដោយអនុក្រឹត្យ៖

ក- មាត្រា៤៨(លិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព ក្នុងករណីមរណភាពប្រក្រតី)

ខ- កថាខណ្ឌទី២និងកថាខណ្ឌទី៣ នៃមាត្រា៤៩(លិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព ក្នុងករណីមរណភាពខុសប្រក្រតីឬគួរឱ្យសង្ស័យ)

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

គ- មាត្រា៥០(លិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព ក្នុងករណីគ្រោះមហន្តរាយធម្មជាតិឬគ្រោះអាសន្នទ្រង់ទ្រាយធំ)។

មាត្រា១៨១ .. កាលបរិច្ឆេទអនុវត្តសម្រាប់បញ្ញត្តិពាក់ព័ន្ធនឹងការជូនដំណឹងដោយតុលាការ

ក្រោយកាលបរិច្ឆេទអនុវត្តជាទូទៅ បញ្ញត្តិពាក់ព័ន្ធនឹងការជូនដំណឹងដោយតុលាការខាងក្រោម ត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទដែលកំណត់ដោយអនុក្រឹត្យ៖

ក- កថាខណ្ឌទី២និងកថាខណ្ឌទី៣ នៃមាត្រា៧៨(ការចុះបញ្ជីអំពីការលែងលះ មោយភាព និងការលុបចោលអាពាហ៍ពិពាហ៍)។

ខ- មាត្រា៧៩(នីតិវិធីចុះបញ្ជីអំពីការលែងលះ មោយភាព និងការលុបចោលអាពាហ៍ពិពាហ៍)។

គ- កថាខណ្ឌទី២ នៃមាត្រា៨១(ការចុះបញ្ជីតាមសេចក្តីសម្រេចរបស់តុលាការ)។

ឃ- កថាខណ្ឌទី២ នៃមាត្រា៨៤(ការចុះបញ្ជីផ្តាច់មត៌ក)។

ង- កថាខណ្ឌទី៤ និងកថាខណ្ឌទី៥ នៃមាត្រា៨៧(ការកែតម្រូវបញ្ជីអត្រានុកូលដ្ឋានតាមសេចក្តីសម្រេចរបស់តុលាការ)។

ច- កថាខណ្ឌទី៤ នៃមាត្រា៨៩(ការប្តូរឈ្មោះដោយតុលាការ)។

មាត្រា១៨២ .. ការធ្វើឱ្យនិរាករណ៍បទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀត

បទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀតដែលមានអានុភាពនៅពេលច្បាប់នេះត្រូវបានអនុវត្ត ហើយផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវចាត់ទុកថាគ្មានអានុភាពត្រឹមទំហំដែលផ្ទុយនឹងច្បាប់នេះ ចាប់ពីកាលបរិច្ឆេទដែលច្បាប់នេះត្រូវបានអនុវត្ត។

ថ្ងៃ ពុធ ១៤ ភៃ ខែ ឧសភា ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០២៣

ពរលៃ.២ពាន.៧.ពាឯកី

ឧសីហមុនី

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមទ្បាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម	បានយកសេចក្តីគោរពជម្រាបជូន
ឧបនាយករដ្ឋមន្ត្រីប្រចាំការ	សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី	**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន	**សម្តេចក្រឡាហោម ស ខេង**

ឧបសម្ព័ន្ធនៃច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម សង្ខានុក្រម

១- ការចងក្រងស្ថិតិអត្រានុកូលដ្ឋាន សំដៅដល់ដំណើរការនៃការបង្រួមនិងការសង្ខេបព័ត៌មានអំពីព្រឹត្តិការណ៍ជីវិតតាមរយៈការចាត់ថ្នាក់និងរៀបឡើងជាតារាងទិន្នន័យទៅតាមប្រភេទឬក្រុម ដើម្បីផលិតនូវស្ថិតិអត្រានុកូលដ្ឋានផ្អែកទៅតាមតារាងដែលត្រូវបានកំណត់ទុកជាមុន(Predetermined Tabulation)។

២- កំណើតរស់ សំដៅដល់ការធាក់ចេញឬការទាញចេញពេញលេញនូវផលិតផលគភ៌ពីម្តាយដោយមិនគិតរយៈពេលនៃការមានគភ៌ ហើយបន្ទាប់ពីការបំបែកចេញពីម្តាយនោះ ទារកដកដង្ហើមឬបង្ហាញភស្តុតាងផ្សេងទៀតនៃជីវិត ដូចជាបេះដូងលោត មានជីពចរទងសុកឬសាច់ដុំមានចលនាជាក់លាក់ មិនថាទងសុកត្រូវបានកាត់ផ្តាច់ឬមានជាប់សុកមកជាមួយក្តី។

៣- ទារកស្លាប់កើត សំដៅដល់ការស្លាប់ទារកមុនពេលធ្លាក់ចេញឬទាញយកចេញទាំងអស់នូវទារក និងសាខាទារក(ដូចជា សុក ទងសុក ទឹកភ្លោះ និងថង់ទឹកភ្លោះជាអាទិ៍) ពីផ្ទៃរបស់ម្តាយ ដោយមិនគិតរយៈពេលនៃការមានគភ៌។ ការស្លាប់នេះត្រូវបានស្តែងចេញឱ្យឃើញថាក្រោយការចាកចេញពីផ្ទៃម្តាយ ទារកនោះពុំមានដកដង្ហើមនិងពុំបង្ហាញឱ្យឃើញថាមានសញ្ញាជីវិតផ្សេងទៀត ដូចជាចង្វាក់បេះដូង ជីពចរទងសុក និងចលនាសាច់ដុំ។

៤- ទិន្នន័យអត្តសញ្ញាណបុគ្គល សំដៅដល់ព័ត៌មាននានាដែលអាចកំណត់បានអត្តសញ្ញាណបុគ្គលណាម្នាក់។

៥- បណ្តឹងមិនសុខចិត្ត សំដៅដល់បណ្តឹងឧបាស្រ័យតាមផ្លូវរដ្ឋបាលរបស់បុគ្គលណាមួយដែលប្តឹងចំពោះការចាត់ចែង រួមទាំងសេចក្តីសម្រេចឬការយឺតយ៉ាវឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់អាជ្ញាធរមានសមត្ថកិច្ច។

៦- ព័ត៌មានជីវមាត្រ សំដៅដល់ការវាស់ស្ទង់លក្ខណៈជីវសាស្ត្រនិងលក្ខណៈផ្សេងទៀត មានដូចជាស្នាមខ្ទៀដៃ ប្រស្រីភ្នែក មុខ ហត្ថលេខាឬសំឡេងជាអាទិ៍ ដែលអាចប្រមូលបានដោយឌីជីថលនិងត្រូវបានប្រើប្រាស់សម្រាប់កំណត់អត្តសញ្ញាណរបស់បុគ្គលម្នាក់ៗ។

៧- មរណភាព សំដៅដល់ការបាត់បង់ជាអចិន្ត្រៃយ៍នូវរាល់ភស្តុតាងនៃជីវិតនៅក្នុងពេលណាមួយក្រោយកំណើតរស់។

៨- មូលដ្ឋានសុខាភិបាល សំដៅដល់មូលដ្ឋានសុខាភិបាលសាធារណៈនិងមូលដ្ឋានសុខាភិបាលឯកជន។

៩- មូលដ្ឋានសុខាភិបាលសាធារណៈ សំដៅដល់មន្ទីរពេទ្យជាតិ រួមទាំងមន្ទីរពេទ្យយោធា មន្ទីរពេទ្យនគរបាលនិងមន្ទីរពេទ្យបង្អែករាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មណ្ឌលសុខភាពនិងប៉ុស្តិ៍សុខភាព។

១០- មូលដ្ឋានសុខាភិបាលឯកជន សំដៅដល់មន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល មន្ទីរសម្ភព-រោគស្ត្រី និងគ្លីនិកឯកជន។

១១- លិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព សំដៅដល់ទម្រង់ដែលត្រូវបានបំពេញដោយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រដែលច្បាប់បានកំណត់ ដើម្បីធ្វើការកត់ត្រានិងបញ្ជាក់អំពីមូលហេតុនិងប្រភេទនៃមរណភាព យោងតាមការចាត់ថ្នាក់ជំងឺជាលក្ខណៈអន្តរជាតិ (International Classification of Diseases (ICD))។

១២- លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល សំដៅដល់លេខកូដសម្រាប់សម្គាល់របស់បុគ្គលម្នាក់ៗ។

១៣- ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា សំដៅដល់ស្ថានឯកអគ្គរាជទូត ស្ថានអគ្គកុងស៊ុល និងស្ថានកុងស៊ុល។

១៤- ស្ថិតិអត្រានុកូលដ្ឋាន សំដៅដល់ស្ថិតិអំពីព្រឹត្តិការណ៍ជីវិតរបស់ពលរដ្ឋ។

១៥- សំបុត្រអត្រានុកូលដ្ឋាន សំដៅដល់ឯកសារក្នុងទម្រង់ជាក្រដាសឬអេឡិចត្រូនិក ដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានដែលមានព័ត៌មានដូចគ្នាទាំងស្រុងឬមួយផ្នែកនៃព័ត៌មាននៅក្នុងកំណត់ត្រានៃបញ្ជីអត្រានុកូលដ្ឋាន ហើយក្រោយពេលបានចេញដោយមន្ត្រីអត្រានុកូលដ្ឋានរួចហើយ នឹងត្រូវមានអានុភាពនិងសុពលភាពពេញលេញដូចកំណត់ត្រានៃបញ្ជីអត្រានុកូលដ្ឋាន។

១៦- អត្តសញ្ញាណ សំដៅដល់លក្ខណៈជាមូលដ្ឋាននៃអត្តសញ្ញាណបុគ្គល រួមមានឈ្មោះ ភេទ ទីកន្លែងកំណើត និងថ្ងៃ ខែ ឆ្នាំកំណើត។

១៧- អត្តសញ្ញាណខាងផ្លូវច្បាប់ សំដៅដល់លក្ខណៈជាមូលដ្ឋាននៃអត្តសញ្ញាណបុគ្គល រួមមានឈ្មោះ ភេទ ទីកន្លែងកំណើត និងថ្ងៃ ខែ ឆ្នាំកំណើត ដែលបានផ្តល់និងចេញដោយមន្ត្រីអត្រានុកូលដ្ឋានតាមរយៈការចុះបញ្ជីកំណើតរស់។ ក្នុងករណីដែលគ្មានការចុះបញ្ជីកំណើតរស់ អត្តសញ្ញាណស្របច្បាប់អាចត្រូវបានផ្តល់ដោយអាជ្ញាធរអត្តសញ្ញាណកម្មដែលទទួលស្គាល់ដោយច្បាប់។

១៨- អាសយដ្ឋានបច្ចុប្បន្ន សំដៅដល់ទីតាំងលំនៅឋានដែលបុគ្គលកំពុងរស់នៅក្នុងភូមិសាស្ត្ររដ្ឋបាលជាក់លាក់ដូចមានលេខផ្ទះ ឈ្មោះផ្លូវ ក្រុម ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

១៩- អាពាហ៍ពិពាហ៍ សំដៅដល់កិច្ចសន្យាពិសេសដែលកើតចេញពីឆន្ទៈព្រមព្រៀងរវាងបុរសម្នាក់និងនារីម្នាក់ដែលមានបំណងរួមរស់ជាមួយគ្នានិងសង្គ្រោះគ្នាទៅវិញទៅមក ហើយបុរសនិងនារីនោះ ត្រូវតែមានលក្ខខណ្ឌដូចបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី។

២០- អ្នកតំណាងនៃលំនៅឋាន សំដៅដល់បុគ្គលណាម្នាក់ដែលធ្វើជាអ្នកតំណាងនៃលំនៅឋាននោះក្នុងគោលបំណងនៃការចុះបញ្ជីស្នាក់នៅ។

២១- អ្នករាយការណ៍ សំដៅដល់បុគ្គលឬស្ថាប័នដែលច្បាប់បានកំណត់ឱ្យរាយការណ៍ជូនមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចអំពីព្រឹត្តិការណ៍ជីវិតដែលបានកើតឡើង និងផ្តល់នូវរាល់ព័ត៌មាននិងចរិតលក្ខណៈទាំងអស់នៃព្រឹត្តិការណ៍នោះ សម្រាប់ជាមូលដ្ឋានដល់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចអាចធ្វើការចុះបញ្ជីព្រឹត្តិការណ៍នោះតាមផ្លូវច្បាប់។

២២- ឯកជនភាព សំដៅដល់ផ្នែកឯកជននៃជីវិតដែលបុគ្គលគ្រប់រូបមានសិទ្ធិទទួលបានការការពារដោយច្បាប់។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៦៤៩

២៣- ឯកសារសម្គាល់ការស្នាក់នៅ សំដៅដល់ឯកសាររដ្ឋបាលដែលប្រើប្រាស់ក្នុងគោលបំណងចុះបញ្ជីស្នាក់នៅនិងគ្រប់គ្រងមនុស្សគ្រប់រូបដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ឯកសារសម្គាល់ការស្នាក់នៅ អាចមានទម្រង់ជាសៀវភៅឬបណ្ណឬលិខិតបញ្ជាក់និងឯកសាររដ្ឋបាលផ្សេងទៀតដែលបញ្ជាក់ពីអាសយដ្ឋានបច្ចុប្បន្នរបស់បុគ្គលម្នាក់ឬច្រើននាក់។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ព្រះរាជក្រម
យើង

ន.ស/រកម/០៧២៣/ ០១០

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្ងានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ងហោតាស កម្ពុជឯករាជរដ្ឋបូរណាសន្តិ សុតមន្តណា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៨ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០១៧/០១០ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៦ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
  បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០១៧/០១១ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០១៧/០១៣ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១១៩/០០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី៤ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ២២២/០០៤/២០២៣ កបធ.ច ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖



ច្បាប់
ស្តីពី
វិសោធនកម្មច្បាប់ចោះឆ្លាត



អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៦៥៣

មាត្រាមួយ .. គោលបំណង

ច្បាប់នេះចែងអំពីការធ្វើវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្នុងគោលបំណងលើកស្ទួយគុណតម្លៃនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សដែលបានចារឹកនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជាច្បាប់កំពូលរបស់ជាតិ និងលើកកម្ពស់ការទទួលខុសត្រូវរបស់អ្នកដឹកនាំនយោបាយដែលត្រូវជ្រើសរើសតាមរយៈការបោះឆ្នោតតាមបែបប្រជាធិបតេយ្យសេរីពហុបក្សទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ។

មាត្រាពីរ .. វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

មាត្រា២៣ មាត្រា១៤២ និងមាត្រា១៤៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅ៖

មាត្រា២៣ .. ថ្មី

ប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិ និងមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១-មានសញ្ជាតិខ្មែរពីកំណើត

២-មានអាយុ ២៥ (ម្ភៃប្រាំ) ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត

៣-មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត

៤-បានអនុវត្តសិទ្ធិបោះឆ្នោតដោយបានបោះឆ្នោតសម្រាប់ការបោះឆ្នោតជាសកលចំនួនពីរលើកចុងក្រោយជាប់គ្នា ដែលរៀបចំឡើងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លើកលែងតែករណីដែលការមិនអាចអនុវត្តសិទ្ធិបោះឆ្នោតនេះមានមូលហេតុសមស្រប

៥-មានលំនៅឋាន ឬទីសំណាក់ក្នុងព្រះរាជាណាចក្រកម្ពុជា

៦-មានការតែងតាំងពីគណបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត។

បែបបទ លក្ខខណ្ឌ និងនីតិវិធី ព្រមទាំងមូលហេតុសមស្របនៃការមិនអាចអនុវត្តសិទ្ធិបោះឆ្នោតនេះបាន សម្រាប់ការអនុវត្តចំណុចទី៤ នៃមាត្រានេះ ត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

មាត្រា១៤២ .. ថ្មី

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតប្រសិនបើមាន ដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

- ឃាត ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។

-បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។

-ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោត ប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។

-រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។

-ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។

-រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោត តាមការកំណត់។

-ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។

-ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។

-បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។

-បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។

-ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។

-ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

មាត្រា១៤៣ .- ថ្មី

ត្រូវលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ឬ/និងត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌដទៃទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តអំពើល្មើសដូចបានចែងក្នុងមាត្រា១៤២ថ្មី ខាងលើនេះ។

បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ គណបក្សនយោបាយដែលបានប្រព្រឹត្តអំពើល្មើសដូចបានចែងក្នុងមាត្រា១៤២ថ្មី ខាងលើ អាចត្រូវបានដកសិទ្ធិមិនឱ្យចូលរួមការបោះឆ្នោតសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

មាត្រាបី .- វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

មាត្រា៣៥ មាត្រា១៧១ និងមាត្រា១៧២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅ៖

មាត្រា៣៥ .- ថ្មី

ប្រជាពលរដ្ឋទាំងពីរភេទ ដែលមានបំណងឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរពីកំណើត

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៦៥៥

-ចេះអាន និងសរសេរអក្សរខ្មែរ

-បានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោត

-មានអាយុយ៉ាងតិច ២៥ (ម្ភៃប្រាំ) ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

-បានអនុវត្តសិទ្ធិបោះឆ្នោតដោយបានបោះឆ្នោតសម្រាប់ការបោះឆ្នោតជាសកលលើកចុងក្រោយ ដែលរៀបចំឡើងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លើកលែងតែករណីដែលការមិនអាចអនុវត្តសិទ្ធិបោះឆ្នោតនេះមានមូលហេតុសមស្រប។ បែបបទ លក្ខខណ្ឌ និងនីតិវិធី ព្រមទាំងមូលហេតុសមស្របនៃការមិនអាចអនុវត្តសិទ្ធិបោះឆ្នោតនេះបាន ត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

មាត្រា ១៧១ .- ថ្មី

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិតៈ

-ការាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬការាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។

-បង្កការអុកឡុក ឬការាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។

-ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោត ប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។

-ការាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។

-ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។

-ការាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោត តាមការកំណត់។

-ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។

-ធ្វើឱ្យមានការគាបសង្កត់ឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។

-បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។

-បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។

-ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។

-ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្ម ដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

មាត្រា១៧២ .- ថ្មី

ត្រូវលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ឬ/និងត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌដទៃទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តអំពើល្មើសដូចបានចែងក្នុងមាត្រា១៧១ថ្មី ខាងលើនេះ។

បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ គណបក្សនយោបាយដែលបានប្រព្រឹត្តអំពើល្មើសដូចបានចែងក្នុងមាត្រា១៧១ថ្មី ខាងលើ អាចត្រូវបានដកសិទ្ធិមិនឱ្យចូលរួមការបោះឆ្នោតសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

មាត្រាបួន .- វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

មាត្រា១៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅៈ

មាត្រា១៣ .- ថ្មី

មាត្រា២៣ថ្មី ២៤ ២៥ ២៦ថ្មី ២៧ ២៨ ២៩ ៣០ ៣១ថ្មី ៣២ថ្មី ៣៣ ៣៤ ៣៥ ៣៦ និងមាត្រា៣៧ នៃច្បាប់ស្តីពីបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តចំពោះការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ប៉ុន្តែ បេក្ខជននេះត្រូវមានអាយុយ៉ាងតិច ៤០ (សែសិប) ឆ្នាំ។

មាត្រាប្រាំ .- វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

មាត្រា១៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅៈ

មាត្រា១៥ .- ថ្មី

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានបំណាងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវបំពេញលក្ខខណ្ឌដូចមានចែងក្នុងមាត្រា២១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងបានអនុវត្តសិទ្ធិបោះឆ្នោតដោយបានបោះឆ្នោតសម្រាប់ការបោះឆ្នោតជាសកលលើកចុងក្រោយ ដែលរៀបចំឡើងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លើកលែងតែករណីដែលការមិនអាចអនុវត្តសិទ្ធិបោះឆ្នោតនេះមានមូលហេតុសមស្រប។

បែបបទ លក្ខខណ្ឌ និងនីតិវិធី ព្រមទាំងមូលហេតុសមស្របនៃការមិនអាចអនុវត្តសិទ្ធិបោះឆ្នោតនេះបាន ត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៦៥៧

មាត្រាប្រាំមួយ .- វិសោធនកម្មដោយការកែប្រែមាត្រាពាក់ព័ន្ធមួយចំនួននៅក្នុងច្បាប់បោះឆ្នោត

"មាត្រា២៣" នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលមានចែងក្នុងមាត្រា២៦ មាត្រា៣១ មាត្រា៣២ មាត្រា១៣៥ និងមាត្រា១៣៨ស្ងួន នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបានកែប្រែទៅជា "មាត្រា២៣ថ្មី" ដែលមានខ្លឹមសារដូចមានចែងក្នុងមាត្រាពីរនៃច្បាប់នេះ។ "មាត្រា២៦" "មាត្រា៣១" "មាត្រា៣២" "មាត្រា១៣៥" "មាត្រា១៣៨" និង "មាត្រា១៣៨ស្ងួន" ដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបានកែប្រែតាមលំដាប់លំដោយទៅជា "មាត្រា២៦ថ្មី" "មាត្រា៣១ថ្មី" "មាត្រា៣២ថ្មី" "មាត្រា១៣៥ថ្មី" "មាត្រា១៣៨ថ្មី" និង "មាត្រា១៣៨ស្ងួនថ្មី"។

"មាត្រា៣៥" នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានចែងក្នុងមាត្រា៤៥ មាត្រា៤៦ និងមាត្រា៥៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានកែប្រែទៅជា "មាត្រា៣៥ថ្មី" ដែលមានខ្លឹមសារដូចមានចែងក្នុងមាត្រាបីនៃច្បាប់នេះ។ "មាត្រា៤៥" "មាត្រា៤៦" "មាត្រា៤៨" និង "មាត្រា៥៩" ដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានកែប្រែតាមលំដាប់លំដោយទៅជា "មាត្រា៤៥ថ្មី" "មាត្រា៤៦ថ្មី" "មាត្រា៤៨ថ្មី" និង "មាត្រា៥៩ថ្មី"។

"មាត្រា១៣៥" និង "មាត្រា១៣៨" នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលមានចែងក្នុងមាត្រា៨ និងមាត្រា២៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវបានកែប្រែតាមលំដាប់លំដោយទៅជា "មាត្រា១៣៥ថ្មី" និង "មាត្រា១៣៨ថ្មី"។ "មាត្រា៨" និង "មាត្រា២៨" ដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវបានកែប្រែតាមលំដាប់លំដោយទៅជា "មាត្រា៨ថ្មី" និង "មាត្រា២៨ថ្មី"។

"មាត្រា១៥" នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលមានចែងក្នុងមាត្រា១២ថ្មី មាត្រា១៣ថ្មី និងមាត្រា២៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានកែប្រែទៅជា "មាត្រា១៥ថ្មី" ដែលមានខ្លឹមសារដូចមានចែងក្នុងមាត្រាប្រាំនៃច្បាប់នេះ។ "មាត្រា១២ថ្មី" "មាត្រា១៣ថ្មី" "មាត្រា២៤" និង "មាត្រា២៥" ដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានកែប្រែតាមលំដាប់លំដោយទៅជា "មាត្រា១២ថ្មី(មួយ)" "មាត្រា១៣ថ្មី(មួយ)" "មាត្រា២៤ថ្មី" និង "មាត្រា២៥ថ្មី"។

មាត្រាប្រាំពីរ .- អន្តរប្បញ្ញត្តិ

សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ លក្ខខណ្ឌទាក់ទងនឹងការអនុវត្តសិទ្ធិបោះឆ្នោតសម្រាប់ការឈរឈ្មោះឱ្យគេបោះឆ្នោតដូចមានចែងក្នុងចំណុចទី៤ នៃមាត្រា២៣ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងមាត្រា១៣ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវបានកំណត់យកត្រឹមការបោះឆ្នោតជាសកលមួយលើកចុងក្រោយ ដែលរៀបចំឡើងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប៉ុណ្ណោះ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រាប្រាំបី .. អវសានប្បញ្ញត្តិ

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ អង្គារ ៤ រោជ ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០២៣

ឧ សីហមុនី

ពរលា.៤ពាឧ.១ពាឥ៥

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

ព្រះរាជក្រម

នស/រកម/០៧២៣/ ០៦៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាដ្ឋរាស្ត្រ ពុទ្ធិន្ត្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស អម្ពុជឯករាជរដ្ឋបូរណសន្តិ សុតមន្តណ សីរីវិបុណ
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិធានដើមកំណើតទំនិញ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ច្បាប់
ស្តីពី
វិធានដើមកំណើតទំនិញ



ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១ .. គោលបំណង

ច្បាប់នេះកំណត់អំពីគោលការណ៍និងវិធានដើមកំណើតនៃទំនិញនាំចេញនិងទំនិញនាំចូល ក្នុងគោលបំណងជំរុញនិងសម្រួលពាណិជ្ជកម្មដែលទទួលបានប្រយោជន៍ពីការអនុគ្រោះពាណិជ្ជកម្ម និងការអនុវត្តក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ព្រមទាំងចូលរួមទប់ស្កាត់ការក្លែងបន្លំដើមកំណើតទំនិញ។

មាត្រា២ .. វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តលើវិធានដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងវិធានដើមកំណើតទំនិញក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងត្រូវអនុវត្តចំពោះ៖

១- ផលិតករនិងអ្នកនាំចេញនាំចូល ដែលមានតម្រូវការសំអាងដើមកំណើតទំនិញនិងស្លាកសញ្ញាសម្គាល់ដើមកំណើតផលិតផល។

២- អាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញនៃទំនិញនាំចេញ។

៣- អាជ្ញាធរទទួលសំអាងដើមកំណើតទំនិញនៃទំនិញនាំចូល។

៤- នីតិបុគ្គលឬស្ថាប័នដែលចូលរួមក្នុងសកម្មភាពពាណិជ្ជកម្ម ដែលធ្វើប្រតិវេទន៍ដើមកំណើតទំនិញ។

មាត្រា៣ .. និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- **វិធានដើមកំណើតទំនិញ** សំដៅដល់វិធានដើមកំណើតទំនិញឬវិធានប្រភពដើមទំនិញ ដែលមានវិធានដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មនិងវិធានដើមកំណើតទំនិញក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម។

២- **វិធានដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម** សំដៅដល់វិធានកំណត់ដើមកំណើតទំនិញ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងប្រទេសពីរឬច្រើន អនុលោមតាមកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្មឆ្នាំ១៩៩៤ របស់អង្គការពាណិជ្ជកម្មពិភពលោក ឬកិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្មនានា។

៣- **វិធានដើមកំណើតទំនិញក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម** សំដៅដល់វិធានកំណត់ដើមកំណើតនៃទំនិញនាំចេញនិងទំនិញនាំចូល សម្រាប់អនុវត្តគោលការណ៍ប្រព្រឹត្តកម្មប្រជាជាតិដែលទទួលបានការអនុគ្រោះបំផុត ពន្ធប្រឆាំងការលក់បង្ខូចថ្លៃ ពន្ធប៉ះប៉ូវ និងវិធានការការពារ លក្ខខណ្ឌតម្រូវក្នុងការកំណត់ដើមកំណើតទំនិញ ការរឹតត្បិតបរិមាណ លទ្ធកម្មរដ្ឋាភិបាល និងការប្រមូលស្ថិតិពាណិជ្ជកម្ម។

៤- **អាជ្ញាធរទទួលសំអាងដើមកំណើតទំនិញ** សំដៅដល់រដ្ឋបាលគយដែលទទួលបានសិទ្ធិឱ្យទទួលសំអាងដើមកំណើតនៃទំនិញនាំចូល។

៥- **អាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ** សំដៅដល់ក្រសួងពាណិជ្ជកម្មដែលមានអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មឬអង្គភាពផ្សេងទៀត ដែលទទួលបានសិទ្ធិពីក្រសួងពាណិជ្ជកម្ម ក្នុងការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញចំពោះទំនិញនាំចេញ និងគ្រប់គ្រងអ្នកនាំចេញដែលមានការ

៦- **វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ** សំដៅដល់ទម្រង់ជាក់លាក់មួយដែលចេញដោយអាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ និងបញ្ជាក់ថាទំនិញដែលមានក្នុងវិញ្ញាបនបត្រនោះមានដើមកំណើតនៅក្នុងប្រទេសជាក់លាក់ណាមួយ។

៧- **ប្រតិវេទន៍ដើមកំណើតទំនិញ** សំដៅដល់សេចក្តីប្រកាស ដែលធ្វើឡើងដោយអ្នកនាំចេញ ឬដោយអ្នកនាំចូល ដែលបញ្ជាក់ពីដើមកំណើតរបស់ទំនិញ ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាតិ ឬក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ឬកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ឬក្រោមប្រព័ន្ធអនុគ្រោះជាឯកតោភាគី។

៨-**វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម** សំដៅដល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ដែលត្រូវបានប្រើសម្រាប់ការអនុវត្តក្នុងគោលបំណងទទួលបានការអនុគ្រោះពន្ធក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីឬកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ឬក្រោមប្រព័ន្ធអនុគ្រោះជាឯកតោភាគី។

៩- **វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម** សំដៅដល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ដែលត្រូវបានប្រើសម្រាប់ការអនុវត្តក្នុងគោលបំណងមិនមែនប្រព្រឹត្តកម្មអនុគ្រោះពន្ធ។

១០- **ប្រព្រឹត្តកម្មប្រជាជាតិដែលទទួលបានការអនុគ្រោះបំផុត** សំដៅដល់គោលការណ៍មិនរើសអើងរវាងដៃគូពាណិជ្ជកម្មរបស់ប្រទេសមួយ។

១១- **សំអាងដើមកំណើតទំនិញ** សំដៅដល់ឯកសារឬការប្រកាសក្នុងទម្រង់ជាក្រដាសឬអេឡិចត្រូនិក ដែលជាកស្តុតាងបញ្ជាក់ថា ទំនិញដែលពាក់ព័ន្ធបំពេញបាននូវលក្ខណៈវិនិច្ឆ័យដើមកំណើតទំនិញ ក្រោមវិធានដើមកំណើតទំនិញដែលបានកំណត់។ សំអាងដើមកំណើតទំនិញ រួមមានវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញនិងប្រតិវេទន៍ដើមកំណើតទំនិញ។

១២- **ប្រទេសអន្តរការី** សំដៅដល់ប្រទេសមួយឬច្រើន ដែលទំនិញត្រូវបានដឹកជញ្ជូនឆ្លងកាត់ ក្រៅពីប្រទេសដើមកំណើតនិងប្រទេសនាំចូលចុងក្រោយ។

ជំពូកទី២

វិធានដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម

មាត្រា៤ ... វិធានដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីឬកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា

ការកំណត់ដើមកំណើតទំនិញដើម្បីទទួលបានប្រព្រឹត្តកម្មអនុគ្រោះពន្ធ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីឬកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា ត្រូវអនុវត្តដោយអនុលោមតាមវិធានដើមកំណើតទំនិញក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីឬកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី។

មាត្រា៥ ... វិធានដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មជាឯកតោភាគី

ការកំណត់ដើមកំណើតទំនិញដើម្បីទទួលបានប្រព្រឹត្តកម្មអនុគ្រោះពន្ធ ក្នុងក្របខ័ណ្ឌនៃការផ្តល់ភាពអនុគ្រោះជាឯកតោភាគី ត្រូវអនុវត្តដោយអនុលោមតាមវិធានដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មរបស់ប្រទេសនាំចូល។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៦៦៣

ជំពូកទី៣
វិធានដើមកំណើតទំនិញក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម

មាត្រា៦ .- ការកំណត់ដើមកំណើតទំនិញ

ការកំណត់ដើមកំណើតទំនិញ ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- ទំនិញដែលទទួលបានទាំងស្រុងឬផលិតទាំងស្រុងនៅប្រទេសមួយ ឬ
- ការកែច្នៃជាសារវន្ត។

ទំនិញដែលទទួលបានឬផលិតទាំងស្រុងនៅក្នុងប្រទេសមួយ ត្រូវចាត់ទុកថាមានដើមកំណើតនៅប្រទេសនោះ។ ទំនិញដែលត្រូវបានចាត់ទុកថាជាទំនិញដែលទទួលបានទាំងស្រុងឬផលិតទាំងស្រុងនៅក្នុងប្រទេសមួយ មានដូចខាងក្រោម៖

ក- ផលិតផលរ៉ែ រួមទាំងប្រេងកាតដែលទាញយកចេញពីក្នុងដី ដែនទឹក ឬពីក្រោមបាតសមុទ្រនៃប្រទេសនោះ។

ខ- រុក្ខជាតិនិងផលិតផលរុក្ខជាតិដែលបានប្រមូលផលនិងប្រមូលទុកនៅប្រទេសនោះ។

គ- សត្វរស់ដែលបានកើតនិងបានចិញ្ចឹមនៅប្រទេសនោះ។

ឃ- ទំនិញបានមកពីសត្វរស់ដែលបានចិញ្ចឹមនៅក្នុងប្រទេសនោះ។

ង- ទំនិញបានមកពីការប្រមាញ់ឬការនេសាទនៅក្នុងប្រទេសនោះ។

ច- ទំនិញបានមកពីការនេសាទសមុទ្រនិងបណ្តាទំនិញក្នុងសមុទ្រដទៃទៀតដែលត្រូវបានយកពីសមុទ្រ ដោយនាវាដាក់ទង់ជាតិនៃប្រទេសនោះ។

ឆ- ទំនិញបានមកទាំងស្រុងពីនាវារោងចក្រនៃប្រទេសនោះ ចេញពីទំនិញដែលមានចែងក្នុងចំណុច ច ខាងលើ។

ជ- ទំនិញដែលទាញយកចេញពីដីសមុទ្រឬបាតសមុទ្រនៅក្រៅដែនទឹករបស់ប្រទេសនោះ ក្នុងលក្ខខណ្ឌដែលប្រទេសនោះមានសិទ្ធិផ្តាច់មុខក្នុងការទាញយកពីក្នុងដីសមុទ្រឬបាតសមុទ្រនោះ។

ឈ- កម្ទេចកម្ទីឬកាកសំណល់បានមកពីផលិតកម្មនិងដំណើរការផលិត និងបំណែកភាគប្រើប្រាស់រួចដែលបានប្រមូលនៅក្នុងប្រទេសនោះ និងសមស្របសម្រាប់តែគោលបំណងក្នុងការទាញយកមកប្រើប្រាស់ឡើងវិញជាវត្ថុធាតុដើម។

ញ- ទំនិញត្រូវបានផលិតទាំងស្រុងនៅក្នុងប្រទេសនោះចេញពីទំនិញដែលមានចែងក្នុងចំណុច ក ដល់ចំណុច ឈ ខាងលើ។

ក្នុងករណីប្រទេសច្រើនពាក់ព័ន្ធក្នុងដំណើរការផលិតទំនិញ ការកំណត់ដើមកំណើតទំនិញ ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យនៃការកែច្នៃជាសារវន្ត។ ការកំណត់ដើមកំណើតទំនិញដោយលក្ខណៈវិនិច្ឆ័យនៃការកែច្នៃជាសារវន្ត ត្រូវធ្វើឡើងតាមការផ្លាស់ប្តូរចំណាត់ថ្នាក់ទំនិញតាមតារាងពន្ធគយ ឬវិធានភាគរយតម្លៃបន្ថែម។

លក្ខណៈបច្ចេកទេសលម្អិតនៃការកែច្នៃជាសារវន្ត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

មាត្រា៧ .. ប្រតិបត្តិការនិងការកែច្នៃអប្បបរមា

ប្រតិបត្តិការដូចខាងក្រោមដែលប្រព្រឹត្តចំពោះវត្ថុជាតុមិនមានដើមកំណើត ដើម្បីផលិតទំនិញមួយ ត្រូវចាត់ទុកថាជាប្រតិបត្តិការឬការកែច្នៃមិនមានភាពគ្រប់គ្រាន់ក្នុងការផ្តល់ដើមកំណើតទំនិញដល់ទំនិញនោះឡើយ៖

១- ប្រតិបត្តិការចាំបាច់សម្រាប់ការថែរក្សាទុកទំនិញ អំឡុងពេលដឹកជញ្ជូនឬរក្សាទុក។

២- ប្រតិបត្តិការដើម្បីធ្វើឱ្យប្រសើរឡើងនូវការវេចខ្ចប់ ឬគុណភាពទំនិញឆ្លើយតបនឹងទីផ្សារ ឬដើម្បីរៀបចំសម្រាប់ការដឹកជញ្ជូនទំនិញ ដូចជាការបំបែកជាដុំៗ ការដាក់តម្រៀបជាក្រុមនិងការចាត់ថ្នាក់នៃកញ្ចប់ និងការវេចខ្ចប់ឡើងវិញជាដើម។

៣- ការធ្វើដំឡើងសាមញ្ញ។

៤- ការលាយទំនិញដែលមានដើមកំណើតទំនិញខុសៗគ្នា ក្នុងលក្ខខណ្ឌដែលលក្ខណៈនៃទំនិញទទួលបាន មិនមានភាពខុសប្លែកខ្លាំងពីលក្ខណៈនៃទំនិញដែលបានលាយបញ្ចូលគ្នា។

៥- ប្រតិបត្តិការឬដំណើរការផ្សេងទៀតត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដោយអនុលោមតាមបច្ចុប្បន្នភាពចុងក្រោយនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនិងកិច្ចព្រមព្រៀងពាណិជ្ជកម្មផ្សេងទៀត ឬស្ថាប័នអន្តរជាតិនានា។

មាត្រា៨ .. ការដឹកជញ្ជូនត្រង់

ទំនិញអាចរក្សាស្ថានភាពដើមកំណើត ដូចមានចែងក្នុងមាត្រា៦នៃច្បាប់នេះ ប្រសិនបើបំពេញបានតាមលក្ខខណ្ឌដូចខាងក្រោម៖

១- ទំនិញនោះត្រូវបានដឹកជញ្ជូនត្រង់ពីប្រទេសដើមកំណើតទៅប្រទេសនាំចូល។

២- ទំនិញត្រូវបានដឹកជញ្ជូនឆ្លងកាត់ប្រទេសអន្តរការី ប្រសិនបើទំនិញនោះមិនបានឆ្លងកាត់ការកែប្រែឬកែច្នៃណាមួយបន្ថែមក្នុងប្រទេសអន្តរការីនោះ ក្រៅពីសកម្មភាពកស្តុភារកម្ម មានដូចជាការលើកដាក់ ការស្តុកទុក ឬប្រតិបត្តិការចាំបាច់ផ្សេងៗ ក្នុងការថែរក្សាឬដឹកជញ្ជូនទំនិញនោះទៅកាន់ប្រទេសនាំចូល។

ជំពូកទី៤
សំអាងដើមកំណើតទំនិញឆ្លងស្លាកសញ្ញាសម្គាល់ដើមកំណើតផលិតផល

មាត្រា៩ .. សំអាងដើមកំណើតទំនិញ

វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ជាក្រដាសឬទម្រង់អេឡិចត្រូនិក និងប្រតិវេទន៍ដើមកំណើតទំនិញ ត្រូវបានចាត់ទុកជាសំអាងដើមកំណើតទំនិញ។ សំអាងដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ត្រូវអនុវត្តដោយអនុលោមតាមលក្ខខណ្ឌតម្រូវវិធានដើមកំណើតទំនិញក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីឬកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី។ សំអាងដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ក្នុងក្របខ័ណ្ឌនៃការផ្តល់ភាពអនុគ្រោះជាឯកតោភាគី ត្រូវអនុវត្តអនុលោមតាមបទប្បញ្ញត្តិស្តីពីវិធានដើមកំណើតទំនិញរបស់ប្រទេសនាំចូល។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៦៦៥

វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ត្រូវមានភ្ជាប់ជាមួយព័ត៌មានអប្បបរមានិងតាមទម្រង់របស់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មនៃទំនិញនាំចេញ ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

មាត្រា១០ ៖ លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ព័ត៌មានសម្គាល់ដើមកំណើតផលិតផលក្រោមវិធានដើមកំណើតទំនិញ

លក្ខខណ្ឌនិងនីតិវិធីក្នុងការផ្តល់ព័ត៌មានសម្គាល់ដើមកំណើតផលិតផល ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដោយអនុលោមតាមវិធានដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មរបស់ប្រទេសនាំចូល ឬក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលព្រះរាជាណាចក្រកម្ពុជាជាភាគី និងលក្ខណៈវិនិច្ឆ័យដើមកំណើតទំនិញ ដូចមានចែងក្នុងមាត្រា៦នៃច្បាប់នេះ។

មាត្រា១១ ៖ យថាភូតភាពនៃវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ

វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មនិងវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ក្នុងទម្រង់ជាក្រដាសដែលមានយថាភូតភាព ត្រូវមានហត្ថលេខាទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ចនិងត្រាផ្លូវការរបស់អាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ឬការសម្គាល់យថាភូតភាពតាមមធ្យោបាយផ្សេងទៀតតាមការកំណត់របស់អាជ្ញាធរឬស្ថាប័នមានសមត្ថកិច្ចចេញវិញ្ញាបនបត្រនៃប្រទេសនាំចេញ។

ក្នុងករណីវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទាំងនោះ ត្រូវបានចេញជាទម្រង់អេឡិចត្រូនិកដោយអាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញឬស្ថាប័នមានសមត្ថកិច្ចចេញវិញ្ញាបនបត្រនៃប្រទេសនាំចេញ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនិងកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា ដែលព្រះរាជាណាចក្រកម្ពុជានិងប្រទេសនាំចូលជាភាគី ឬនៃប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មជាឯកតោភាគី ឬនៃច្បាប់និងបទប្បញ្ញត្តិជាធរមាន។

នីតិវិធីក្នុងការកំណត់យថាភូតភាពនៃវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់អេឡិចត្រូនិកដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

មាត្រា១២ ៖ តម្រូវការរក្សាទុកឯកសារ

បុគ្គលដែលជាផលិតករ អ្នកនាំចេញត្រូវរក្សាទុកសំណុំឯកសារសំអាងដើមកំណើតទំនិញនៅទីកន្លែងធុរកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា រយៈពេល៣(បី)ឆ្នាំ សម្រាប់ធ្វើអធិការកិច្ចនិងការត្រួតពិនិត្យរបស់មន្ត្រីមានសមត្ថកិច្ចក្រសួងពាណិជ្ជកម្ម។

បុគ្គលដែលជាផលិតករ អ្នកនាំចេញ ឬអ្នកនាំចូល ត្រូវរក្សាទុកសំណុំឯកសារសំអាងដើមកំណើតទំនិញនៅទីកន្លែងធុរកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់ស្តីពីគយ សម្រាប់ធ្វើអធិការកិច្ចនិងការត្រួតពិនិត្យរបស់រដ្ឋបាលគយ។

ទំព័រ៦៦៦ អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

ឯកសារពាក់ព័ន្ធដូចមានចែងក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២នៃមាត្រានេះ អាចរក្សាទុកក្នុងឧបករណ៍ផ្ទុកណាមួយ ដែលអាចទាញទិន្នន័យវិញបានភ្លាមៗ រួមមានទម្រង់អេឡិចត្រូនិកឬតាមទម្រង់ជាក្រដាស ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

មាត្រា១៣ .. ការក្លែងបន្លំដើមកំណើតទំនិញ

បុគ្គលមិនត្រូវប្រព្រឹត្តឬប៉ុនប៉ងប្រព្រឹត្តដោយចេតនានូវអំពើក្លែងបន្លំដើមកំណើតទំនិញ ដើម្បីទទួលបានប្រព្រឹត្តកម្មអនុគ្រោះពន្ធ ឬដើម្បីគេចវេះពន្ធប្រឆាំងការលក់បង្ខូចថ្លៃ ឬពន្ធប៉ះប៉ូវអនុវត្តនៅប្រទេសនាំចូល។

ត្រូវបានហាមឃាត់អំពើក្លែងបន្លំដើមកំណើតទំនិញដូចខាងក្រោម៖

១- ការក្លែងសំអាងដើមកំណើតទំនិញ ឬ

២- ការក្លែងព័ត៌មានលើសំអាងដើមកំណើតទំនិញ។

មាត្រា១៤ .. ការមិនអនុលោមក្នុងការស្នើសុំបញ្ជាក់ដើមកំណើតទំនិញ

បុគ្គលមិនត្រូវប្រព្រឹត្តដោយចេតនានូវអំពើមិនអនុលោមក្នុងការស្នើសុំបញ្ជាក់ដើមកំណើតទំនិញឡើយ។

ត្រូវបានហាមឃាត់អំពើមិនអនុលោមក្នុងការស្នើសុំបញ្ជាក់ដើមកំណើតទំនិញដូចខាងក្រោម៖

១- ការប្រកាសប្រភពទំនិញមិនត្រឹមត្រូវ។

២- ការប្រកាសវត្ថុធាតុដើមសម្រាប់ផលិតទំនិញមិនត្រឹមត្រូវ។

៣- ការផ្តល់ព័ត៌មានអំពីតម្លៃលើវិក្កយបត្រនាំចូលវត្ថុធាតុដើមមិនត្រឹមត្រូវ។

៤- ការផ្តល់ព័ត៌មានអំពីតម្លៃលើវិក្កយបត្រនាំចេញទំនិញមិនត្រឹមត្រូវ។

៥- ការចាត់ថ្នាក់ទំនិញមិនត្រឹមត្រូវ។

៦- ការផ្តល់ព័ត៌មានអំពីលក្ខណៈនិថ្លៃយដើមកំណើតទំនិញមិនត្រឹមត្រូវ។

៧- ការផ្តល់របាយការណ៍ផលិតភាពមិនត្រឹមត្រូវ។

៨- ការផ្តល់ព័ត៌មានអំពីមធ្យោបាយផលិតកម្មមិនត្រឹមត្រូវ។

៩- ការផ្តល់ព័ត៌មានអំពីតម្លៃចំណាយមិនត្រឹមត្រូវ។

មាត្រា១៥ .. ការលើកលែងសំអាងដើមកំណើតទំនិញ

ការលើកលែងសំអាងដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ត្រូវអនុវត្តតាមបញ្ញត្តិក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីឬកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ឬតាមបញ្ញត្តិក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មជាឯកតោភាគី។

សំអាងដើមកំណើតទំនិញក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ត្រូវបានលើកលែងចំពោះ៖

១- ទំនិញនាំចេញ លើកលែងតែមានការតម្រូវពីប្រទេសនាំចូល ឬតាមការស្នើសុំរបស់អ្នកនាំចេញ។

២- ទំនិញនាំចូល លើកលែងតែមានការចាំបាច់ក្នុងការប្រើប្រាស់សម្រាប់ការអនុវត្តវិធានការពាណិជ្ជកម្ម ឬវិធានការសម្រាប់គោលបំណងការពារសុខុមាលភាពនិងសុវត្ថិភាពសាធារណៈដោយព្រះរាជាណាចក្រកម្ពុជា។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៦៦៧

ជំពូកទី៥
អាជ្ញាធរមានសមត្ថកិច្ច
ផ្នែកទី១
អាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ

មាត្រា១៦ .- អាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ

ក្រសួងពាណិជ្ជកម្ម ដែលមានអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មឬអង្គភាពផ្សេងទៀត ដែលទទួលបានសិទ្ធិពីក្រសួងពាណិជ្ជកម្ម ជាអាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ទាំងទម្រង់ជាក្រដាស និងទម្រង់អេឡិចត្រូនិក។ ក្រសួងពាណិជ្ជកម្ម ជាស្ថាប័នគ្រប់គ្រងនិងផ្តល់នីតិសម្បទាដល់អ្នកនាំចេញដែលមានការទទួលស្គាល់ ក្នុងការបញ្ជាក់ដើមកំណើតទំនិញដោយខ្លួនឯង។

នីតិវិធីក្នុងការស្នើសុំនិងផ្តល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

មាត្រា១៧ .- ការរក្សាទុកឯកសារដោយអាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ

អាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ត្រូវរក្សាទុកឯកសារ កំណត់ត្រា និងព័ត៌មានពាក់ព័ន្ធនឹងវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទទួលបានដើមកំណើត ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ឯកសារពាក់ព័ន្ធដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ អាចរក្សាទុកក្នុងឧបករណ៍ផ្ទុកឬមធ្យោបាយណាមួយដែលអាចទាញទិន្នន័យវិញបានភ្លាមៗ រួមមានទម្រង់អេឡិចត្រូនិកឬទម្រង់ជាក្រដាសដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

មាត្រា១៨ .- ការផ្ទៀងផ្ទាត់

ក្រសួងពាណិជ្ជកម្មមានសមត្ថកិច្ចក្នុងការពិនិត្យផ្ទៀងផ្ទាត់ជាលក្ខណៈប្រតិសកម្មលើវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ឬប្រតិវេទន៍ដើមកំណើតទំនិញ ចំពោះទំនិញនាំចេញពីកម្ពុជា តាមការចាំបាច់ឬតាមសំណើរបស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចូល ដែលមានការសង្ស័យចំពោះយថាភូតភាពនៃឯកសារឬសុក្រឹតភាពនៃព័ត៌មានទាក់ទងនឹងដើមកំណើតទំនិញដែលមានការសង្ស័យ ឬផ្នែកណាមួយនៃព័ត៌មានឬឯកសារនៃទំនិញនាំចេញនោះ។

តាមសំណើរបស់ក្រសួងពាណិជ្ជកម្ម អ្នកនាំចេញត្រូវផ្តល់ព័ត៌មានឬឯកសារពាក់ព័ន្ធនឹងដើមកំណើតទំនិញមកក្រសួងពាណិជ្ជកម្ម ដើម្បីធ្វើការពិនិត្យផ្ទៀងផ្ទាត់ជាលក្ខណៈប្រតិសកម្មតាមការកំណត់។

ផ្នែកទី២
អាជ្ញាធរទទួលសំអាងដើមកំណើតទំនិញ

មាត្រា១៩ .- អាជ្ញាធរទទួលសំអាងដើមកំណើតទំនិញ

រដ្ឋបាលគយជាអាជ្ញាធរទទួលសំអាងដើមកំណើតទំនិញទាំងក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ផ្តល់ដោយអ្នកនាំចូល ផលិតករ ឬតំណាង ដែលទទួលបានសិទ្ធិ។ នីតិវិធីក្នុងការទទួលសំអាងដើមកំណើតទំនិញសម្រាប់ទំនិញនាំចូល ត្រូវអនុលោមតាមច្បាប់ស្តីពីគយនិងបទប្បញ្ញត្តិជាធរមាន។

ទំព័រ៦៦៨ អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

មាត្រា២០ .. ការផ្ទៀងផ្ទាត់

រដ្ឋបាលគយមានសមត្ថកិច្ចក្នុងការពិនិត្យផ្ទៀងផ្ទាត់ជាលក្ខណៈប្រតិសកម្មនូវសំអាងដើមកំណើតទំនិញ ដែលបានបង្ហាញនៅពេលនាំចូល ចំពោះយថាភូតភាពនៃឯកសារឬសុក្រឹតភាពនៃព័ត៌មានទាក់ទងនឹងដើមកំណើតទំនិញ។ រដ្ឋបាលគយមានសិទ្ធិតម្រូវឱ្យអ្នកនាំចូល ផ្តល់ព័ត៌មានឬឯកសារពាក់ព័ន្ធនឹងដើមកំណើតទំនិញ ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

រដ្ឋបាលគយអាចស្នើសុំកិច្ចសហការពីអាជ្ញាធរឬស្ថាប័នចេញសំអាងដើមកំណើតទំនិញនៃប្រទេសដើមកំណើតឬប្រទេសនាំចេញ ដើម្បីធ្វើការផ្ទៀងផ្ទាត់ជាលក្ខណៈប្រតិសកម្ម។

ជំពូកទី៦
មន្ត្រីមានសមត្ថកិច្ចនិងនីតិវិធីនៃការស៊ើបអង្កេត

មាត្រា២១ .. ការស៊ើបអង្កេតដើមកំណើតទំនិញសម្រាប់ទំនិញនាំចេញ

ក្រសួងពាណិជ្ជកម្មមានសមត្ថកិច្ចធ្វើការស៊ើបអង្កេតលើដើមកំណើតទំនិញនាំចេញ។

ការស៊ើបអង្កេតដើមកំណើតទំនិញនាំចេញ ត្រូវធ្វើឡើងតែក្នុងករណីជាប់ពាក់ព័ន្ធការក្លែងបន្លំដើមកំណើតទំនិញ ដើម្បីទទួលបានអត្រាពន្ធអនុគ្រោះនៅប្រទេសនាំចូល ឬផលប្រយោជន៍នានា ឬដើម្បីគេចវេះពីវិធានការប្រឆាំងការលក់បង្ហូចថ្លៃ វិធានការប៉ះប៉ូវ និងវិធានការការពារ។

ការស៊ើបអង្កេតលើដើមកំណើតទំនិញនាំចេញ ត្រូវធ្វើឡើងតាមរយៈការចុះពិនិត្យទីតាំងខ្សែច្រវាក់ផលិតកម្ម ឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងព័ត៌មានផ្សេងទៀត ដែលទាក់ទងនឹងដើមកំណើតទំនិញ។ នីតិវិធីនៃការស៊ើបអង្កេតដើមកំណើតទំនិញនាំចេញ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

មាត្រា២២ .. មន្ត្រីស៊ើបអង្កេតដើមកំណើតទំនិញសម្រាប់ទំនិញនាំចេញ

មន្ត្រីស៊ើបអង្កេតត្រូវជ្រើសរើសចេញពីអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម តាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដើម្បីពិនិត្យបទល្មើសនៅក្នុងច្បាប់នេះ។

មាត្រា២៣ .. នីតិវិធីនៃការផ្តល់នីតិសម្បទា

មន្ត្រីស៊ើបអង្កេតទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ឱ្យពិនិត្យបទល្មើសដែលមានចែងក្នុងច្បាប់នេះស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ចំពោះមន្ត្រីស៊ើបអង្កេតដើមកំណើតទំនិញនាំចេញ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

មាត្រា២៤ .. សិទ្ធិរបស់មន្ត្រីស៊ើបអង្កេត

មន្ត្រីស៊ើបអង្កេតដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌មានសិទ្ធិពិនិត្យ ស្រាវជ្រាវស៊ើបអង្កេត កោះហៅនិងស្តាប់ចម្លើយ ឆែកឆេរ ចាប់យកវត្ថុតាង និងប្រមូលទិន្នន័យ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសក្រោមច្បាប់នេះដោយអនុវត្តតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៦៦៩

មន្ត្រីស៊ើបអង្កេតមានសិទ្ធិស្នើសុំជំនួយពីអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងៗទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដែលមានចែងក្នុងច្បាប់នេះ។

មាត្រា២៥ .. ការស្តាប់ចម្លើយសាក្សី

មន្ត្រីស៊ើបអង្កេតអាចស្តាប់ចម្លើយសាក្សីណាមួយបាន ប្រសិនបើមន្ត្រីស៊ើបអង្កេតនោះយល់ឃើញថាសក្ខីកម្មរបស់សាក្សីអាចមានប្រយោជន៍ដល់ការស៊ើបអង្កេត ដោយអនុវត្តតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ក្នុងករណីសាក្សីណាមួយបដិសេធមិនចូលខ្លួនដោយគ្មានមូលហេតុ ធ្វើឱ្យប៉ះពាល់ដល់ដំណើរការស៊ើបអង្កេត ស្វែងរកបទល្មើស មន្ត្រីស៊ើបអង្កេតអាចស្នើសុំទៅព្រះរាជអាជ្ញាមានសមត្ថកិច្ចបញ្ជាឱ្យសាក្សីរូបនោះចូលខ្លួនផ្តល់ចម្លើយចំពោះមុខមន្ត្រីស៊ើបអង្កេត។

មាត្រា២៦ .. ការស៊ើបអង្កេតដើមកំណើតទំនិញសម្រាប់ទំនិញនាំចូល

ការស៊ើបអង្កេតដើមកំណើតទំនិញនាំចូលចំពោះករណីពាក់ព័ន្ធនឹងការក្លែងបន្លំដើមកំណើតទំនិញ ដើម្បីទទួលបានប្រព្រឹត្តកម្មពន្ធអនុគ្រោះ ឬផលប្រយោជន៍នានា ឬដើម្បីគេចវេះពីវិធានការប្រឆាំងការលក់បង្ខូចថ្លៃ វិធានការប៉ះប៉ូវ និងវិធានការការពារ ជាសមត្ថកិច្ចរបស់មន្ត្រីគយដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ដោយអនុវត្តស្របតាមច្បាប់នេះ ច្បាប់ស្តីពីគយនិងបទប្បញ្ញត្តិជាធរមាន។

មាត្រា២៧ .. ការស៊ើបអង្កេតរួមលើដើមកំណើតទំនិញ

ក្នុងករណីចាំបាច់ ក្រសួងពាណិជ្ជកម្មឬរដ្ឋបាលគយអាចស្នើសុំកិច្ចសហការពីស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការស៊ើបអង្កេតរួម។

ជំពូកទី៧
ទោសប្បញ្ញត្តិ

មាត្រា២៨ .. ទណ្ឌកម្ម

ទណ្ឌកម្មនៅក្នុងច្បាប់នេះ រួមមានទណ្ឌកម្មរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌ៖

ទណ្ឌកម្មរដ្ឋបាល រួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការផ្អាកជាបណ្តោះអាសន្នឬការបញ្ឈប់សកម្មភាពប្រតិបត្តិការអាជីវកម្ម
- ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ។

ការព្រមានជាលាយលក្ខណ៍អក្សរ ការផ្អាកជាបណ្តោះអាសន្ន ឬការបញ្ឈប់សកម្មភាពប្រតិបត្តិការអាជីវកម្ម ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ ជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម។

អំពើល្មើសដែលត្រូវទទួលរងទណ្ឌកម្មរដ្ឋបាលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

បុគ្គលដែលមិនសុខចិត្តចំពោះការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលអាចដាក់ពាក្យប្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានការសម្រេចពីការដាក់ទណ្ឌកម្មនោះ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មត្រូវធ្វើសេចក្តីសម្រេចចំពោះបណ្តឹងតវ៉ាក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានពាក្យបណ្តឹងតវ៉ា។

ក្នុងករណីដែលបុគ្គលនោះនៅតែមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បុគ្គលនោះអាចដាក់ពាក្យប្តឹងទៅតុលាការ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើបណ្តឹងតវ៉ានោះ។

ប្រភេទទណ្ឌកម្មរដ្ឋបាល សមត្ថកិច្ច និងនីតិវិធីនៃការប្តឹងតវ៉ាចំពោះការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលពាក់ព័ន្ធនឹងដើមកំណើតទំនិញនាំចូល ត្រូវអនុវត្តស្របតាមច្បាប់ស្តីពីគយនិងបទប្បញ្ញត្តិជាធរមាន។

ទណ្ឌកម្មព្រហ្មទណ្ឌ រួមមាន៖

- ការពិន័យអន្តរការណ៍
- ការពិន័យជាប្រាក់
- ទោសដាក់ពន្ធនាគារ។

អំពើល្មើសផ្សេងទៀតដែលត្រូវពិន័យអន្តរការណ៍ស្របតាមច្បាប់នេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

ការសម្រេចដាក់ពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់មន្ត្រីស៊ើបអង្កេតនិង/ឬមន្ត្រីគយ ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌។

ការបង់ប្រាក់ពិន័យអន្តរការណ៍ នាំឱ្យរំលត់បណ្តឹងអាជ្ញា។

ការបង់ប្រាក់ពិន័យអន្តរការណ៍ មិននាំឱ្យរួចផុតពីកាតព្វកិច្ចអនុវត្តវិធានការរដ្ឋបាលនិងទណ្ឌកម្មរដ្ឋបាលផ្សេងទៀតដែលបានដាក់ចេញស្របតាមច្បាប់នេះឡើយ។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីស៊ើបអង្កេតនិង/ឬមន្ត្រីគយដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការមានសមត្ថកិច្ច។

បែបបទនិងនីតិវិធីនៃការពិន័យអន្តរការណ៍សម្រាប់អំពើល្មើសពាក់ព័ន្ធនឹងដើមកំណើតទំនិញនាំចេញ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ចំពោះបែបបទនិងនីតិវិធីនៃការពិន័យអន្តរការណ៍សម្រាប់អំពើល្មើសពាក់ព័ន្ធនឹងដើមកំណើតទំនិញនាំចូលត្រូវអនុវត្តស្របតាមច្បាប់ស្តីពីគយនិងបទប្បញ្ញត្តិជាធរមាន។

ការបង់ប្រាក់ពិន័យអន្តរការណ៍ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យអន្តរការណ៍ និងការចាត់ចែងប្រាក់ចំណូលដែលបានពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសពាក់ព័ន្ធនឹងដើមកំណើតទំនិញនាំចេញដូចមានចែងស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា២៩ .. ការមិនរក្សាទុកឯកសារ

បុគ្គលទាំងឡាយមិនបានរក្សាទុកសំណុំឯកសារសំអាងដើមកំណើតទំនិញដូចមានកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា១២ នៃច្បាប់នេះ ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ។ ក្នុងករណីមិនអនុវត្តតាមការព្រមានជាលាយលក្ខណ៍អក្សរ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៦៧១

មាត្រា៣០ .. ការប្រព្រឹត្តអំពើមិនអនុលោមក្នុងការស្នើសុំបញ្ជាក់ដើមកំណើតទំនិញ

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើមិនអនុលោមក្នុងការស្នើសុំបញ្ជាក់ដើមកំណើតទំនិញ ដូចមានចែងក្នុងមាត្រា១៤ នៃច្បាប់នេះ។

ក្នុងករណីទទួលការព្រមានជាលាយលក្ខណ៍អក្សរដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះម្តងរួចហើយ ហើយបុគ្គលនេះនៅតែបន្តប្រព្រឹត្តអំពើមិនអនុលោមក្នុងការស្នើសុំបញ្ជាក់ដើមកំណើតទំនិញទៀត ត្រូវផ្អាកជាបណ្តោះអាសន្ននូវសកម្មភាពប្រតិបត្តិការអាជីវកម្ម។

ក្នុងករណីដែលសកម្មភាពប្រតិបត្តិការអាជីវកម្មត្រូវបានផ្អាកជាបណ្តោះអាសន្ន ដូចមានចែងក្នុងកថាខណ្ឌទី២ខាងលើនេះរួចហើយ ហើយបុគ្គលនេះនៅតែបន្តប្រព្រឹត្តអំពើមិនអនុលោមក្នុងការស្នើសុំបញ្ជាក់ដើមកំណើតទំនិញទៀត ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល។

ប្រាក់ពិន័យអន្តរការណ៍ត្រូវកើនឡើងទ្វេដង ក្នុងករណីបុគ្គលដែលទទួលការពិន័យអន្តរការណ៍ម្តងរួចហើយនៅតែបន្តប្រព្រឹត្តអំពើមិនអនុលោមក្នុងការស្នើសុំបញ្ជាក់ដើមកំណើតទំនិញទៀត។

បុគ្គលដែលទទួលការពិន័យអន្តរការណ៍ទ្វេដង ដូចមានចែងក្នុងកថាខណ្ឌទី៤ នៃមាត្រានេះរួចហើយ ហើយនៅតែបន្តប្រព្រឹត្តអំពើមិនអនុលោមក្នុងការស្នើសុំបញ្ជាក់ដើមកំណើតទំនិញទៀតត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀលទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល។

មាត្រា៣១ .. ការប្រព្រឹត្តអំពើក្លែងបន្លំដើមកំណើតទំនិញ

បុគ្គលទាំងឡាយដែលប្រព្រឹត្តអំពើផ្ទុយនឹងមាត្រា១៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល។

មាត្រា៣២ .. ការទទួលខុសត្រូវរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៣០ និងមាត្រា៣១នៃច្បាប់នេះ។

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា៣០និងមាត្រា៣១ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។

មាត្រា៣៣ .. ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត

ក្នុងការអនុវត្តបទប្បញ្ញត្តិនៃជំពូកទី៧ នៃច្បាប់នេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀតក្នុងករណីដែលអំពើដែលកំណត់ថាជាបទល្មើសដែលមានចែងក្នុងច្បាប់នេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

ជំពូកទី៨
អន្តរប្បញ្ញត្តិ

មាត្រា៣៤ .- ការបន្តសុពលភាពវិញ្ញាបនបត្រ

វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញដែលបានចេញមុនច្បាប់នេះចូលជាធរមាន ត្រូវបន្តមានសុពលភាពដដែល។

ជំពូកទី៩
អវសានប្បញ្ញត្តិ

មាត្រា៣៥ .- ការទុកជានិរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

ថ្ងៃ ៧ ដ ៣ អៀ ខែ បដមាមាសាស័ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០២៣

ភារ.លេ.ម្ភ៣០៧-៧៤០០

ន ស៊ីហមុនី

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមទ្បាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

អ៊ិត្ថិនីតិកោសលបណ្ឌិត ប៊ិន ឈិន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប៉ាន សូរស័ក្តិ

ព្រះរាជក្រម

ន.ស/រកម/០៧២៣/ ០១៤ យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្ងានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ
ខេមរាជនា សម្ងហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុតមន្តណា សិរីវិបុណា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ សម្រាប់គម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងឫស្សីជ្រុំកណ្តាល អានុភាព ៧០ មេហ្គាវ៉ាត់ ផ្គួបជាមួយគម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងវាលថ្មកំបុត អានុភាព ១០០ មេហ្គាវ៉ាត់ ខេត្តកោះកុង ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ សម្រាប់គម្រោងអភិវឌ្ឍវារីអគ្គិសនី ស្ទឹងឫស្សីជ្រុំកណ្តាល អានុភាព ៧០ មេហ្គាវ៉ាត់ ផ្ទូបជាមួយគម្រោងអភិវឌ្ឍវារីអគ្គិសនី ស្ទឹងវាលថ្មកំបុត អានុភាព ១០០ មេហ្គាវ៉ាត់ ខេត្តកោះកុង

មាត្រា១ .-

អនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចំពោះក្រសួងរ៉ែនិងថាមពល និងអគ្គិសនីកម្ពុជា ឱ្យក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងអនុវត្តគម្រោងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ និងកិច្ចព្រមព្រៀងទិញថាមពល អគ្គិសនី រវាងអគ្គិសនីកម្ពុជានិងក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣ ។ ការធានានេះមានអត្ថបទទាំងស្រុងដែលបានចុះហត្ថលេខាកាលពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃរាជរដ្ឋាភិបាលកម្ពុជា ភ្ជាប់មកជាមួយនេះ ។

មាត្រា២ .-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តលិខិតធានាទូទាត់នេះ ។

មាត្រា៣ .-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ថ្ងៃ សៅរ៍ ៦ រោច ខែ បាមិមាសាស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០ ៨ ខែ កក្កដា ឆ្នាំ២០២៣

ពរលា.២៣០៧.១៤៣០

ន សីហមុនី

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ៉ត្ថ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..៥០៧.....សហវ.....

ថ្ងៃសុក្រ ១៣កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី ៥ ខែមិថុនា ឆ្នាំ២០២៣

លិខិតឆានរបស់រាជរដ្ឋាភិបាលលើការទូទាត់

ជូន ÷ **ក្រុមហ៊ុន ខ្សែ អេឡិកទ្រីខល ជៅថ័រ**
ជូនចំពោះ ÷ **អ្នកឧកញ៉ា កុក អាន**
ប្រធានក្រុមប្រឹក្សាភិបាល
អាសយដ្ឋាន ÷ លេខ ២០, ផ្លូវលេខ ២១៧, សង្កាត់វាលវង់,
ខណ្ឌ៧មករា, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ÷ (៨៥៥) ៩៣ ២២៧ ៥៥៥

យោង ÷

(ក) សិទ្ធិប្រទានលេខ ២៦ សប្រទ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

(ខ) កិច្ចព្រមព្រៀងអនុវត្តគម្រោង (IA) ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣ ដែលបានចុះហត្ថលេខា រវាង រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយ **រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល (ក.រ.ថ)** និង **ក្រុមហ៊ុន ខ្សែ អេឡិកទ្រីខល ជៅថ័រ (ក្រុមហ៊ុន)**។

(គ) **អគ្គិសនីកម្ពុជា** ជាសហគ្រាសរដ្ឋ ទទួលខុសត្រូវមានកំណត់ បានបង្កើតឡើងដោយ ព្រះរាជក្រឹត្យលេខ ជស/រកត/ ០៣៩៦/១០ ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៦ មានការិយាល័យធំរបស់ខ្លួន តាំងនៅផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា រាប់បញ្ចូលទាំងអ្នកបន្តវេន និង អ្នកដែលបានអនុញ្ញាតឱ្យទទួលសិទ្ធិ (**អ.ក**) ដែលបានចុះកិច្ចព្រមព្រៀងទិញថាមពលអគ្គិសនី (PPA) ជាមួយក្រុមហ៊ុន ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

(ឃ) រាជរដ្ឋាភិបាលកម្ពុជា យល់ព្រមផ្តល់÷ (១)-ការធានាលើការទូទាត់ថ្លៃទិញថាមពលអគ្គិសនី ក្នុងករណីដែល អ.ក មិនធ្វើការទូទាត់ និង (២)-ការធានាលើការទូទាត់បញ្ចប់កិច្ចព្រមព្រៀង ស្របតាម PPA និង/ឬ IA ក្នុងករណីដែលក្រុមហ៊ុនមិនអាចអនុវត្តគម្រោងបាន ដែលបណ្តាលមកពីព្រឹត្តិការណ៍ប្រធានស័ក្តិផ្នែកនយោបាយ។

(ង) តាមការតម្រូវក្នុងប្រការ ៥.៣ នៃកិច្ចព្រមព្រៀងអនុវត្តគម្រោង (IA) **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ស.ហ.ឥ)** ជំនួសមុខឱ្យរាជរដ្ឋាភិបាលកម្ពុជា (**រាជរដ្ឋាភិបាល ឬ អ្នកធានា**) បានយល់ព្រមផ្តល់លិខិតធានានេះ ដែលជាកាតព្វកិច្ចទូទាត់របស់ អ.ក/ក.រ.ថ ស្របតាម PPA និង IA។

ដូច្នេះ យើងខ្ញុំសូមធានា ថា÷

១. អ្នកធានា សូមធានា និងសន្យា ដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធ ទូទាត់ឱ្យក្រុមហ៊ុននូវចំនួនទឹកប្រាក់ណាមួយ និងទាំងអស់ ដែលត្រូវបង់ និងជំពាក់ដោយ ក.រ.ថ ឬ អ.ក ឱ្យក្រុមហ៊ុនស្របតាម IA ឬ PPA ដែល ក.រ.ថ ឬ អ.ក ខកខានក្នុងការទូទាត់ អនុលោមតាមអាណត្តិ នៃ IA ឬ PPA។

២. លិខិតធានានេះ ត្រូវជាការធានាថាបន្តរហូត និងឱ្យបានសមស្រប និងត្រូវទូទាត់តុល្យការទឹកប្រាក់ដែលត្រូវបង់ឱ្យក្រុមហ៊ុន គ្រប់ពេលដោយ ក.រ.ថ ឬ អ.ក ស្របតាម IA និង/ឬ PPA ទោះជាមានលិខិតជូនដំណឹងណាមួយ ស្តីពីការបញ្ចប់កិច្ចព្រមព្រៀង ការរំលាយ ឬអសមត្ថភាព ឬការផ្លាស់ប្តូរណាមួយក្នុងព្រះរាជក្រឹត្យពាក់ព័ន្ធនឹង ក.រ.ថ ឬ អ.ក ឬក្នុងនាម ឬរបៀប ឬការទូទាត់គណនីណាមួយ ឬបញ្ហាផ្សេងទៀតក៏ដោយ។

៣. មុនពេលឈានដល់ការអនុវត្តលិខិតធានានេះ និងធ្វើសំណើសុំការទូទាត់ពីអ្នកធានា ក្រុមហ៊ុនត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរ ស្នើសុំការទូទាត់ពី ក.រ.ថ និង/ឬ អ.ក។

ក្រោយរយៈពេលហុកសិប (៦០) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃវិក្កយបត្រ ដូចមានចែងក្នុងប្រការ ៨.៧.១ នៃ PPA ឬសំណើសុំទូទាត់ណាមួយពីក្រុមហ៊ុន ទៅ អ.ក ឬ ក.រ.ថ ត្រូវបានទទួលដោយ អ.ក ឬ ក.រ.ថ ក្រុមហ៊ុនអាចជូនដំណឹងទៅអ្នកធានា ជាលាយលក្ខណ៍អក្សរថា ការទូទាត់ដោយ ក.រ.ថ និង/ឬ អ.ក បានហួសកាលកំណត់ និងលើកសំណើសុំការទូទាត់ពីអ្នកធានា ស្របតាមលិខិតធានានេះ ហើយអ្នកធានា ត្រូវធ្វើការទូទាត់ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃទទួលបានសំណើ។ ការយឺតយ៉ាវក្នុងការទូទាត់របស់អ្នកធានា ក្រោមលិខិតធានានេះ ត្រូវគិតការប្រាក់តាមអត្រាការប្រាក់ប្រចាំឆ្នាំ LIBOR បូក ៣% (បីភាគរយ)។ ហើយពុំមានសំណើណាមួយ ដែលធ្វើឡើងដោយក្រុមហ៊ុន ស្របតាមលិខិត

ធានានេះ ដែលប៉ះពាល់ ឬជំទាស់សិទ្ធិរបស់ក្រុមហ៊ុន ក្នុងការធ្វើសំណើបន្ថែម ឬសំណើផ្សេងទៀត ចំពោះវិក្កយបត្រដែលមិនទាន់ទូទាត់ផ្សេងទៀត។

ទឹកប្រាក់ទាំងអស់ ដែលអ្នកធានាត្រូវទូទាត់តាមលិខិតធានានេះ ត្រូវបង់ទាំងអស់ចូលក្នុងគណនីធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលក្រុមហ៊ុនបានកំណត់ ជាដុល្លារអាមេរិកឱ្យក្រុមហ៊ុន។

៤. រាល់សំណើសុំទូទាត់ ដែលបានធ្វើឡើងតាមលិខិតធានានេះ ត្រូវធ្វើឡើងតាមរយៈអ្នករត់សំបុត្រ ឬ ដោយផ្ទាល់ ដោយមន្ត្រីទទួលបានការអនុញ្ញាតស្របច្បាប់របស់ក្រុមហ៊ុន នៅការិយាល័យរបស់អ្នកធានា និងត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ ដែលមានចុះហត្ថលេខាដោយមន្ត្រីដែលបានទទួលការអនុញ្ញាតស្របច្បាប់របស់ក្រុមហ៊ុន ដោយគ្មានកាតព្វកិច្ចណាផ្សេងទៀត ដោយបញ្ជាក់ថា÷

"យើងខ្ញុំ សូមបញ្ជាក់ថា÷

(១). ក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ៉រ (ក្រុមហ៊ុន) បានធ្វើសំណើសុំទូទាត់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អ្នកធានា) នូវចំនួនទឹកប្រាក់ ..... {បញ្ចូលទឹកប្រាក់} ដុល្លារអាមេរិក ស្របតាមចំណុចទី១ នៃលិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់ ចុះថ្ងៃទី.... ខែ..... ឆ្នាំ..... រវាងអ្នកធានា និងក្រុមហ៊ុន។

(២). ចំនួនទឹកប្រាក់ខាងលើ គឺដល់ពេលត្រូវទូទាត់ដោយ អ.ក ឬ ក.រ.ថ ស្របតាម PPA/IA រវាងក្រុមហ៊ុន និង អ.ក/ក.រ.ថ និងពុំមានផ្នែកណាមួយនៃចំនួនទឹកប្រាក់ដែលបានបញ្ជាក់ខាងលើ ជាកម្មវត្ថុនៃវិវាទ រវាងអ.ក/ក.រ.ថ និងក្រុមហ៊ុនឡើយ។

(៣). សំណើសុំទូទាត់ពី ក.រ.ថ/អ.ក ជាលាយលក្ខណ៍អក្សរ បានធ្វើរួចហើយ។

(៤). ចំនួនទឹកប្រាក់នេះ នៅពុំទាន់បានទូទាត់ដោយ ក.រ.ថ/អ.ក រហូតដល់ថ្ងៃនេះ។"

៥. អ្នកធានា សូមបញ្ជាក់ និងអះអាង នៅថ្ងៃនេះថា÷

- អ្នកធានា មានសិទ្ធិពេញសមត្ថភាព និងការអនុញ្ញាតស្របច្បាប់ ក្នុងការទទួលកាតព្វកិច្ច ការចុះហត្ថលេខា និងការប្រគល់ ព្រមទាំងប្រតិបត្តិ និងអង្កេតតាមអាណត្តិ និងបញ្ញត្តិនានា នៃលិខិតធានានេះ។
- លិខិតធានានេះ ជាកាតព្វកិច្ចស្របច្បាប់ មានសុពលភាព និងប្រសិទ្ធភាព និងជាឯកសារចំណងផ្លូវច្បាប់ អនុលោមតាមអាណត្តិរបស់លិខិតធានានេះ។
- រាល់សកម្មភាពចាំបាច់ត្រូវបានអនុវត្ត និងរាល់ការយល់ព្រម ដែលតម្រូវឱ្យមាន ត្រូវបានទទួលរួចហើយ ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់សិទ្ធិក្នុងការចុះហត្ថលេខា ការប្រគល់ និងការប្រតិបត្តិលិខិតធានានេះ។

- កាតព្វកិច្ច និងកិច្ចព្រមព្រៀងនានារបស់អ្នកធានា ក្នុងលិខិតធានានេះ ជាកាតព្វកិច្ចដោយគ្មានលក្ខខណ្ឌរបស់អ្នកធានា ដែលក្នុងការអនុវត្តកាតព្វកិច្ចទាំងនេះ ជំនឿទុកចិត្ត និងកិត្តិយសរបស់អ្នកធានាត្រូវបានប្រកាន់ខ្ជាប់។
- អ្នកធានា បានយល់ព្រមដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធថា ការចុះហត្ថលេខាការប្រគល់ និងការអនុវត្តដោយអ្នកធានា តាមលិខិតធានានេះ គឺជាសកម្មភាពពាណិជ្ជកម្ម មិនមែនជាសកម្មភាពសាធារណៈ ឬជាសកម្មភាពរដ្ឋាភិបាលទេ ហើយលិខិតធានានេះ ជាកាតព្វកិច្ចដោយផ្ទាល់ ដោយគ្មានលក្ខខណ្ឌ និងដោយមិនអាចបដិសេធបានឡើយ។
- ប្រសិនបើមានបណ្តឹងណាមួយចំពោះអ្នកធានា ឬចំពោះទ្រព្យសម្បត្តិរបស់អ្នកធានា ក្នុងយុត្តាធិការណាមួយ ដែលទាក់ទងនឹងលិខិតធានានេះ ពុំមានអភ័យឯកសិទ្ធិណាមួយពីបណ្តឹងនោះ ត្រូវបានទាមទារដោយ ឬតាងនាមរបស់ខ្លួន ឬទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់ខ្លួន ដែលមានបច្ចុប្បន្ន ឬអាចទទួលបាននាពេលអនាគត។

៦. លិខិតធានានេះ ត្រូវមានសុពលភាព និងប្រសិទ្ធភាព ចាប់ពីកាលបរិច្ឆេទចាប់ផ្តើមការសាងសង់ (Construction Commencement Date) រហូតដល់បញ្ចប់អាណត្តិ នៃIA ឬPPA និងត្រូវបន្តពេលយូរតទៅទៀតតាមចំនួនទឹកប្រាក់ជំពាក់ណាមួយ ដែល ក.រ.ថ ឬ អ.ក នៅជំពាក់ក្រុមហ៊ុន ទាក់ទងនឹងអាណត្តិនោះ ឬនៅពុំទាន់ទូទាត់។

៧. មិនយកការខកខាន ឬការយឺតយ៉ាវណាមួយដោយក្រុមហ៊ុន ក្នុងការអនុវត្តសិទ្ធិ ឬការដោះស្រាយណាមួយក្រោមលិខិតធានានេះ ជាការបដិសេធសិទ្ធិ ឬការដោះស្រាយឡើយ។ គ្មានការអនុវត្តសិទ្ធិ ឬការដោះស្រាយតែមួយ ឬតែមួយផ្នែក ច្រានចោលការអនុវត្តបន្ថែមនូវសិទ្ធិ ឬការដោះស្រាយណាមួយផ្សេងទៀតឡើយ។ ការបដិសេធរបស់ក្រុមហ៊ុន មានប្រសិទ្ធភាពលុះត្រាតែការបដិសេធនោះ ធ្វើឡើងជាលាយលក្ខណ៍អក្សរ។ សិទ្ធិ និងការដោះស្រាយនានា ដែលបានផ្តល់ឱ្យក្រុមហ៊ុន ដោយលិខិតធានានេះ គឺជាការផ្តល់បន្ថែម និងមិនលើកលែងសិទ្ធិ និងការដោះស្រាយណាមួយ ដែលបានផ្តល់ដោយច្បាប់ឡើយ។

៨. រាល់លិខិតជូនដំណឹង ឬលិខិតឆ្លើយឆ្លងផ្សេងៗទៀត (ដែលត្រូវហៅកាត់រួមគ្នាថា "លិខិតជូនដំណឹង") ដែលត្រូវផ្តល់ ឬធ្វើឡើង ស្របតាមលិខិតធានានេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវបញ្ជូនទៅបុគ្គល និងអាសយដ្ឋាន ដូចមានបញ្ជាក់ខាងក្រោម ដោយត្រូវប្រគល់ផ្ទាល់ដៃ ឬតាមប្រៃសណីយ៍។ រាល់លិខិតជូនដំណឹង ត្រូវបានចាត់ទុកថាបានប្រគល់÷

(ក). ពេលបានប្រគល់ផ្ទាល់ដៃ, ឬ

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៦៧៩

(ខ). នៅពេលប្រគល់ដោយមានការកត់ត្រាត្រឹមត្រូវ និងមានការបានទទួលដោយអ្នកផ្ញើឯកសារអន្តរជាតិដែលមានការទទួលស្គាល់ បញ្ជូនទៅភាគីទទួល ទៅកាន់អាសយដ្ឋានដូចខាងក្រោម (ឬក៏អាសយដ្ឋានផ្សេងទៀត ដែលភាគីទទួលនោះ អាចបញ្ជាក់តាមរយៈលិខិតជូនដំណឹងឱ្យទៅភាគីប្រគល់លិខិត តាមអាសយដ្ឋាន ឬលេខទូរសារចែងខាងក្រោម)÷

សម្រាប់ អ្នកធានា÷

ជូនចំពោះ ÷ ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អាសយដ្ឋាន ÷ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ទូរស័ព្ទលេខ ÷ (៨៥៥) ២៣ ៨៩០ ៦៦៦

សម្រាប់ ក្រុមហ៊ុន÷

អាសយដ្ឋាន ÷ ផ្ទះលេខ ២០, ផ្លូវលេខ ២១៧, សង្កាត់វាលវង់,
ខណ្ឌ៧មករា, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខ ÷ (៨៥៥) ៩៣ ២២៧ ៥៥

ជូនចំពោះ ÷ លោកប្រធានក្រុមប្រឹក្សាភិបាល
ក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ

ឬក៏អាសយដ្ឋានផ្សេងទៀត ដែលភាគីណាមួយ អាចជូនដំណឹងឱ្យភាគីមួយទៀត។

៩. អ្នកធានាមិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមលិខិតធានានេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីក្រុមហ៊ុនឡើយ ហើយក្រុមហ៊ុនមិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមលិខិតធានានេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីអ្នកធានាឡើយ។ ថ្វីបើមានបញ្ញត្តិក្នុងវាក្យខណ្ឌមុននេះក្តី សម្រាប់គោលបំណងអភិវឌ្ឍន៍ ឬការផ្តល់ហិរញ្ញប្បទានជាអចិន្ត្រៃយ៍ដល់គម្រោង ក្រុមហ៊ុនអាចប្រគល់សិទ្ធិ ឬបង្កើតការធានាផលប្រយោជន៍ ចំពោះសិទ្ធិ និងផលប្រយោជន៍ ក្នុង និងចំពោះលិខិតធានានេះ សម្រាប់ជាប្រយោជន៍ដល់អ្នកឱ្យខ្ចីប្រាក់។ លិខិតធានានេះ ត្រូវជាចំណងផ្លូវច្បាប់ និងមានប្រសិទ្ធភាពជាប្រយោជន៍ដល់អ្នកធានា និងក្រុមហ៊ុន ព្រមទាំងអ្នកបន្តវេន និងអ្នកទទួលសិទ្ធិស្របច្បាប់របស់ភាគីនីមួយៗ។

១០. សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកធានា និងក្រុមហ៊ុន ក្រោម ឬអនុលោមតាមលិខិតធានានេះ និងអាណត្តិនៃលិខិតធានានេះ ត្រូវបានគ្រប់គ្រងដោយ និងបកស្រាយតាមច្បាប់កម្ពុជា។ ប្រសិនបើ ពុំមានចែងក្នុងច្បាប់កម្ពុជា ច្បាប់នៃប្រទេសអង់គ្លេស នឹងត្រូវជាច្បាប់គ្រប់គ្រងមជ្ឈត្តវិនិច្ឆ័យ។

១១. ប្រសិនបើមានវិវាទ ឬការខ្វែងគំនិតណាមួយកើតឡើង តាមរូបភាពណាក៏ដោយ ឬពាក់ព័ន្ធនឹងលិខិតធានានេះ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីភាគីមួយបានទទួលសេចក្តីជូនដំណឹងពីភាគីមួយទៀត ស្តីពីការកើតឡើងនៃវិវាទ អ្នកធានា និងក្រុមហ៊ុន ត្រូវដោះស្រាយវិវាទនោះ តាមរយៈការពិភាក្សាជាមិត្តភាព។ ប្រសិនបើមិនអាចដោះស្រាយបាន តាមរយៈការពិភាក្សាជាមិត្តភាពទេ ត្រូវដាក់វិវាទនោះទៅមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរ ដើម្បីដោះស្រាយស្របទៅតាមវិធាន នៃមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរនោះ។ ប្រសិនបើមានភាពមិនស្របគ្នាដោយអន្លើ រវាងបញ្ញត្តិនេះ និងវិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរនោះ បញ្ញត្តិនេះត្រូវមានប្រសិទ្ធភាព។ សេចក្តីសម្រេច ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយគឺជាសេចក្តីសម្រេចស្ថាពរ និងមានប្រសិទ្ធភាពទៅលើអ្នកធានា និងក្រុមហ៊ុន និងអាចយកមកអនុវត្តនៅក្នុងតុលាការកម្ពុជាណាមួយ ដែលមានយុត្តាធិការធ្វើឱ្យសេចក្តីសម្រេចនេះអនុវត្តបាន។ ភាគីទាំងពីរ ត្រូវទទួលយក និងអនុវត្តសេចក្តីសម្រេចនោះ ហើយភាគីនីមួយៗ ត្រូវទម្លាក់ចោលដោយឥតលក្ខខណ្ឌ នូវសិទ្ធិណាមួយដែលគេអាចមាន ដើម្បីតវ៉ាអំពីសុពលភាពនៃសេចក្តីសម្រេចនេះ ឬយុត្តាធិការនៃតុលាការមជ្ឈត្តវិនិច្ឆ័យនោះ ដើម្បីធ្វើសច្ចការឯកសារយោងណាមួយទៅមជ្ឈត្តវិនិច្ឆ័យ ដែលលិខិតធានានេះមានប្រសិទ្ធភាពអនុវត្ត។ ការទូទាត់តាមសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យ ត្រូវធ្វើជាប្រាក់ដុល្លារអាមេរិក។ ចំណាយលើមជ្ឈត្តវិនិច្ឆ័យ ត្រូវទូទាត់ដោយភាគីដែលចាញ់ក្តី លើកលែងតែមានការកំណត់ផ្សេងពីនេះ ដោយតុលាការមជ្ឈត្តវិនិច្ឆ័យនោះ។ ភាគីដែលទទួលខុសត្រូវទូទាត់តាមសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យ ត្រូវបង់ការប្រាក់តាមអត្រា LIBOR បូក ៣% (បីភាគរយ) ទៅឱ្យភាគីម្ខាងទៀត នៅពេលទទួលសេចក្តីសម្រេចពីមជ្ឈត្តវិនិច្ឆ័យនោះ ដោយគិតចាប់ពីកាលបរិច្ឆេទត្រូវទូទាត់ រហូតដល់ថ្ងៃទូទាត់រួច។

១២. ពាក្យសរសេរជាអក្សរធំដែលបានប្រើ ប៉ុន្តែពុំមានកំណត់ន័យក្នុងលិខិតធានានេះ ត្រូវមានន័យដូចបានកំណត់ក្នុង PPA ឬ IA តាមដែលអាចអនុវត្តបាន។

១៣. ប្រសិនបើបញ្ញត្តិណាមួយ ឬច្រើន ដែលមានក្នុងលិខិតធានានេះ ត្រូវបានរកឃើញថាគ្មានសុពលភាព ខុសច្បាប់ ឬគ្មានតម្លៃតាមផ្លូវច្បាប់ បញ្ញត្តិទាំងនោះ ត្រូវរក្សាតម្លៃដែលអនុញ្ញាតដោយច្បាប់ ហើយភាពគ្មានសុពលភាព ភាពខុសច្បាប់ ឬភាពគ្មានតម្លៃតាមផ្លូវច្បាប់នោះ ពុំមានឥទ្ធិពលដល់សុពលភាពនៃបញ្ញត្តិផ្សេងទៀតនៃលិខិតធានានេះឡើយ។ តាមការឯកភាពគ្នាទៅវិញទៅមក គ្មានការទូទាត់កាត់កងការប្តឹងទាមទារទៅវិញទៅមក ការបន្ទរបន្ទប់ ឬការបន្ទប់កាតព្វកិច្ចណាមួយ ដែលអ្នកធានាមាន ឬអាចមានចំពោះក្រុមហ៊ុន ត្រូវតែមានសម្រាប់អ្នកធានាចំពោះក្រុមហ៊ុន ទាក់ទងនឹងកាតព្វកិច្ចណាមួយរបស់អ្នកធានា ចំពោះក្រុមហ៊ុន ក្រោមលិខិតធានានេះឡើយ។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៦៨១

១៤. លិខិតធានានេះ ត្រូវផុតកំណត់នៅពេលបញ្ចប់ IA និង PPA ប្រសិនបើគ្មានការតវ៉ា ហើយនៅរក្សាការធានានេះដដែល ហេតុដូចនេះការស្នើសុំជាលាយលក្ខណ៍អក្សរណាមួយពីក្រុមហ៊ុន ជូនមកអ្នកធានា ត្រូវតែទទួលបានដោយអ្នកធានា មុនពេលបញ្ចប់នោះ។

១៥. ក្រុមហ៊ុនអាចប្រគល់សិទ្ធិ ឬផ្តល់ការធានាលើសិទ្ធិក្រោមលិខិតធានានេះ ឱ្យដល់អ្នកឱ្យខ្ចីប្រាក់។ តាមសំណើជាលាយលក្ខណ៍អក្សររបស់ក្រុមហ៊ុន យើងខ្ញុំនឹងចុះហត្ថលេខាកិច្ចព្រមព្រៀងផ្ទាល់ (Direct Agreement) ដូចមានទម្រង់កំណត់ក្នុង IA (ដោយជំនួស "ក.រ.ថ" ដោយ "ស.ហ.វ") (ឬការទទួលស្គាល់ផ្សេងទៀតលើផលប្រយោជន៍នៃអ្នកឱ្យខ្ចីប្រាក់ តាមសំណើសមហេតុសមផល និងមានប្រសិទ្ធភាពដូចគ្នា) ជាកម្មវត្ថុនៃការទទួលដោយអ្នកធានានូវឯកសារដែលរៀបចំត្រឹមត្រូវ និងចុះហត្ថលេខាដោយក្រុមហ៊ុន និងអ្នកឱ្យខ្ចីប្រាក់ ឬភ្នាក់ងាររបស់ពួកគេ។

១៦. លិខិតធានានេះ នឹងចូលជាធរមាន និងមានប្រសិទ្ធភាពអនុវត្ត បន្ទាប់ពីទទួលបានការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា។

សូមអ្នកឧកញ៉ា ទទួលនូវការរាប់អាន ពីខ្ញុំ



អគ្គបណ្ឌិតសភាចារ្យ សុខ ទូន្លមុនីរ័ត្ន

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងរ៉ែ និងថាមពល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- អាជ្ញាធរអគ្គិសនីកម្ពុជា
- អគ្គិសនីកម្ពុជា
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
N°.002.....MEF/.....

Phnom Penh, 6 June ,2023

GOVERNMENT GUARANTEE OF PAYMENT

To : **KHMER ELECTRICAL POWER CO., LTD.**
Address : No. 20, Rue 217, Sangkat Viel Vong,
Khan 7 Makara, Phnom Penh, Cambodia.
Tel No. : 855 93 227 555
Attention : Chairman of Board of Directors, Khmer Electrical Power Co., Ltd.
Attention : Mr. KOK AN, Chairman of The Board of Directors

Dear Sir,

We refer to:

(A) Delegation of Full Power No. 26 DFP date 25 April 2023 by Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of the Kingdom of Cambodia. (Attachment 1)

(B) The Implementation Agreement **("IA")** dated 26 May 2023, entered into between the Royal Government of Cambodia **("RGC")** represented by **Minister** of MINISTRY OF MINES AND ENERGY **("MME")** and KHMER ELECTRICAL POWER CO., LTD. **(the "Company").**

(C) ELECTRICITÉ DU CAMBODGE, a wholly state-owned limited liability enterprise incorporated by Royal Decree No. CHS/RD/0396/10 of the RGC dated 9 March 1996, with its principal office located at Street 19, Wat Phnom, Daun Penh, Phnom Penh, in the Kingdom of Cambodia, including its successors and permitted assignees **("EDC")** has entered into a Power Purchase Agreement **("PPA")** with the Company dated 26 May 2023.

(D) The RGC agrees to provide: (i) guarantee on power purchase in the event of non-payment by EDC; and (ii) guarantee on the payment on the termination in accordance

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៦៨៣

with the PPA and/or the IA in the event that the Company is unable to operate the Project arising from the Political Force Majeure Events.

(E) It is a requirement of the Implementation Agreement in accordance with its Section 5.3, the Minister of Economy and Finance (**"MEF"**) on behalf of Royal Government of Cambodia (the **"Guarantor"**) has agreed to issue this Guarantee of the Payment obligations of EDC/MME under the PPA and the IA.

We hereby guarantee that:

1. The Guarantor hereby irrevocably and unconditionally guarantees and promises to pay the Company any and every sum of money which is due and owed by MME or EDC to the Company under the IA or PPA that MME or EDC has failed to pay in accordance with the terms of the IA or PPA.

2. This Guarantee shall be a continuing security and accordingly, shall extend to cover the balance due to the Company at any time from MME or EDC under the IA or PPA, notwithstanding any notice of termination or the liquidation or other incapacity or any change in Royal Decree concerning MME or EDC or in the name or style thereof or any settlement of account or other matter whatsoever.

3. Before taking steps to enforce this Guarantee and demand payment from the Guarantor, the Company shall be obliged only to make demand in writing for payment from MME or EDC. Any time after sixty (60) days from the date of the invoice(s) as specified in Section 8.7.1 of the PPA or any payment demand from the Company to EDC or MME being received by EDC or MME, the Company may notify the Guarantor in writing that payment from MME or EDC is overdue and make a demand for payment from the Guarantor under this Guarantee, and the Guarantor shall make payment within thirty (30) days of such notice. The Guarantor's late payment hereunder shall bear interest at an annual rate of LIBOR plus 3% (three percent). No demand made by the Company hereunder shall prejudice or restrict the right of the Company to make further or other demands against any other unpaid invoice(s).

   All sums payable by the Guarantor under this Guarantee shall be fully paid to the bank account designated by the Company in the Kingdom of Cambodia in US Dollars to the Company.

4. Any demand for payment made pursuant to this Guarantee shall be made by courier or in person by a duly authorized officer of the Company at the Guarantor's offices and shall be accompanied by a certificate signed by a duly authorized officer of the Company stating, without the obligation to substantiate, that:

ទំព័រ៦៨៤ អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

"We hereby certify that:

(1) Khmer Electrical Power Co., Ltd. (the "Company") is making this demand on the Ministry of Economy and Finance (the "Guarantor") in the amount of U.S. Dollars [•] [insert amount] in accordance with Section 1 of the Guarantee dated [•], between the Guarantor and the Company;

(2) The amount specified above is due and payable by EDC/MME under the PPA/IA between the Company and EDC/MME and no part of the amount specified above is the subject of a dispute between the EDC/MME and the Company;

(3) Demand in writing for payment from EDC/MME has been made;

(4) Such amount, on the date hereof, remains unpaid by EDC/MME."

5. The Guarantor represents and warrants that, as of the date hereof:

- The Guarantor has full power, authority, and legal right to incur the obligation, to execute and deliver, and to perform and observe the terms and provisions of this Guarantee.
- This Guarantee constitutes legal, valid, binding, and enforceable obligations of the Guarantor in accordance with its terms.
- All necessary action has been taken, and all approvals required have obtained, under the Laws of the Kingdom of Cambodia to authorize the execution, delivery, and performance of this Guarantee.
- The obligations and covenants of the Guarantor in this Guarantee constitute unconditional obligations of the Guarantor, for the performance of which the full faith and credit of the Guarantor is pledged.
- The Guarantor unconditionally and irrevocably agrees that the execution, delivery, and performance by it of this Guarantee constitute commercial acts rather than public or governmental acts and such Guarantee constitutes its unconditional and irrevocable direct obligation.
- Should any proceedings be brought against the Guarantor or its assets in any jurisdiction in relation to this Guarantee, no immunity from such proceedings shall be claimed by or on its behalf or with respect to its assets which it now has or may acquire in the future.

6. This Guarantee shall remain in full force and effect from the Construction Commencement Date until the termination of the Term of the IA or PPA and for so long thereafter as any amount owed to the Company by MME or EDC in connection with such term is or may be outstanding.

7. No failure or delay by the Company to exercise any right or remedy under this Guarantee shall constitute a waiver of that right or remedy. No single or partial exercise of any right or remedy shall preclude any other or further exercise thereof or the exercise of any other right

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៦៨៥

or remedy. No waiver by the Company shall be effective unless it is in writing. The rights and remedies of the Company provided by this Guarantee are cumulative and not exclusive of any rights or remedies provided by law.

8. All notices or other communications (together "Notices") to be given or made hereunder shall be in writing, shall be addressed for the attention of the person indicated below and shall be delivered personally or by courier. All Notices shall be deemed delivered:
   (a) when presented personally, or
   (b) upon the day of duly recorded and receipted delivery by a recognized international document courier, addressed to the receiving Party, at the address indicated below (or such other address as such party may have specified by notice delivered to the delivering Party at its address or facsimile number specified below).

   The address for service of Notice shall be:

   For the Guarantor :
   Address : Ministry of Economy and Finance
   Tel : (855) 23 890 666
   Attention : Minister, Ministry of Economy and Finance
   For the Company :
   Address : No. 20, Rue 217, Sangkat Viel Vong, Khan 7 Makara, Phnom Penh, Cambodia.
   Tel No. : 855 93 227 555
   Attention : Chairman of Board of Directors, Khmer Electrical Power Co., Ltd.

   or such other addresses as either Party may have notified to the other Party.

9. The Guarantor shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Company, and the Company shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Guarantor. Notwithstanding the provision of the immediately preceding sentence, for the purpose of development or permanent financing of the Project, the Company may assign or create a security interest over its rights and interests in and to this Guarantee in favor of the Lenders. This Guarantee shall be binding upon and inure to the benefit of the Guarantor and the Company and the respective successors and permitted assignees of each Party.

10. The rights and obligations of the Guarantor and the Company under or pursuant to this Guarantee and the terms of this Guarantee shall be governed by and construed according to the Laws of Cambodia. If there is no applicable written law in Cambodia, the English law shall also be the law governing any arbitration.

ទំព័រ៦៨៦ អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

11. If there is any dispute or difference of any kind whatsoever arising out of or in connection with this Guarantee, the Guarantor and the Company shall attempt for a period of thirty (30) days after the receipt by one Party of a notice from the other Party of the existence of the dispute to settle such dispute through mutual amicable discussions. Should such dispute can't be resolved through mutual amicable discussions, then it shall be submitted to the Singapore International Arbitration Center for arbitration in accordance with the arbitration rules of the Singapore International Arbitration Center. And if there are discrepancies between this clause and the rules of the Singapore International Arbitration Center, this clause shall govern. The award rendered shall be in writing and shall be final, conclusive and binding upon the Guarantor and the Company and award thereon may be entered in any Cambodian court having jurisdiction for its enforcement. Such Parties shall execute and perform the award and each Party hereby irrevocably waives any right it may have to contest the validity of such award or the jurisdiction of the arbitration tribunal to hear any reference to arbitration to which this Guarantee applies. Any payment under arbitration award shall be payable in U.S. Dollars. The costs of arbitration shall be borne by the losing Party, unless otherwise determined by the arbitration tribunal. The Party that is responsible to pay an arbitration award shall pay interest at a rate of LIBOR plus 3% (three percent) to the other Party in receipt of such arbitration award from the due date for the payment of such award until the date of payment of such award.

12. The capitalized terms used but not defined in this Guarantee shall have the meanings given to them in the Power Purchase Agreement or IA as applicable.

13. If one or more provisions contained in this Guarantee is held or found to be invalid, illegal, or unenforceable in any respect, the provision(s) shall be given effect to the extent permitted by law and the invalidity, illegality, or unenforceability of any provision shall not affect the validity of the remaining provisions of this Guarantee. Subject to mutual agreement, no set-off, counterclaim, reduction, or diminution of any obligation that the Guarantor has or may have against the Company shall be available to the Guarantor against the Company in connection with any obligation of the Guarantor to the Company under this Guarantee.

14. This Guarantee shall expire upon the termination of the IA and PPA if no claim has been made and remains outstanding hereunder and any written demand made to the Guarantor by the Company hereunder must therefore be received by the Guarantor before that time.

15. The Company is entitled to assign or grant security over its rights under this Guarantee to Lenders. We shall, at the written request of the Company, execute a Direct Agreement in substantially the form set out in the IA (substituting "MEF" for "MME") (or such other acknowledgement of the interests of the Lenders as they may reasonably request and is substantially to the same effect), SUBJECT ONLY to receipt by it of an engrossment of

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៦៨៧

such document duly executed by the Company and the Lenders or their agent.

16. This Guarantee shall become in full force and effective on its ratification by legislatures of the Kingdom of Cambodia.

Yours sincerely,

Dr. AUN PORNMONIROTH
DEPUTY PRIME MINISTER, MINISTER,
MINISTRY OF ECONOMY AND FINANCE

CC:
- Ministry of Royal Palace
- Secretariat of Senate
- Secretariate of National Assembly
- Office of Council of Ministers
- Council for the Development of Cambodia (CDC)
- Ministry of Foreign Affairs and International Cooperation
- Ministry of Mines and Energy
- Cabinet of Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of the Kingdom of Cambodia
- Electricity Authority of Cambodia (EAC)
- Electricite du Cambodge (EDC)
- File

ទំព័រ៦៨៨ អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៦ សប្រទ

ថ្ងៃអង្គារ ៦ កើត ខែ ពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០២៣

សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/១២២២/០១២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣
- យោងតាមការសម្រេចរបស់គណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៣

រាជរដ្ឋាភិបាល

ប្រគល់សិទ្ធិពេញសមត្ថភាព ជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងអនុវត្តគម្រោង កិច្ចព្រមព្រៀងជួលទីតាំង ជាមួយក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ៉ែរ និងលើលិខិតធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដោយអគ្គិសនីកម្ពុជា និង/ឬ ក្រសួងរ៉ែនិងថាមពល ទៅឱ្យក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ៉ែរ សម្រាប់គម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងបូស្សីជ្រុំកណ្ដាល អានុភាព ៧០ មេហ្គាវ៉ាត់ និងគម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងវាលថ្មកំបុត អានុភាព ១០០ មេហ្គាវ៉ាត់ ផ្ទួបគ្នា នៅខេត្តកោះកុង។

ក្នុងករណីដែលឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ៉ា** មានឧុរៈជាយថាហេតុ ឯកឧត្តមអាចផ្ទេរសិទ្ធិនេះបាន។

ដើម្បីជាសក្ខីភាព នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិ ព្រះរាជាណាចក្រ ✓ លេចតាមអំណាចច្បាប់ បានចុះហត្ថលេខាខាងក្រោមលើសិទ្ធិប្រទាននេះ។

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia

រាជរដ្ឋាភិបាល
Royal Government
№ 26 DFP

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

Phnom Penh, 25 April , 2023

DELEGATION OF FULL POWERS

- Seen the Constitution of the Kingdom of Cambodia
- Seen the Royal Decree NS/RKT/0918/925 dated 06 of September 2018 on the nomination of the Royal Government of the Kingdom of Cambodia
- Seen the Royal Kram NS/RKM/0618/012 dated 28 of June 2018 promulgating the Law on the Organization and Functioning of the Council of Ministers
- Seen the Royal Kram NS/RKM/0196/18 dated 24 of January 1996 promulgating the Law on the Establishment of the Ministry of Economy and Finance
- Seen the Royal Kram NS/RKM/1021/014 dated 15 of October 2021 promulgating the Law on Investment of Kingdom of Cambodia
- Seen the Royal Kram NS/RKM/1222/012 dated 10 of December 2022 promulgating the Law on Finance for Management of the Year 2023
- Referring to the decision of Council of Ministers in its plenary session on 7 of April 2023

THE ROYAL GOVERNMENT

Delegates herewith to **H.E. Dr. AUN PORNMONIROTH,** Deputy Prime Minister, Minister of Economy and Finance, full powers to sign the Implementation Agreement, Lease Agreement, and the Governmental Guarantee of Payments by the EDC/MME to Khmer Electrical Power Co., Ltd. for the Development of 70 MW Middle Stung Russei Chrum Hydroelectric Project, together with the 100 MW Stung Veal Thmar Kambot Hydroelectric Project in Koh Kong Province.

These powers include the powers of delegation.

In witness whereof the undersigned, the Prime Minister of the Kingdom of Cambodia with full powers duly entrusted to him, has signed this delegation of full powers.

Prime Minister

Samdech Akka Moha Sena Padei Techo HUN SEN

ព្រះរាជក្រម

នស/រកម/០៧២៣/ ០១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សម្ងានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សម្ងហោតាស អម្ពុជឯករាជរដ្ឋបូរណាសន្តិ សុតមន្តលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ឡាក់ឃី សូឡា ផៅវ៉ែរ ឯ.ក សម្រាប់គម្រោងអភិវឌ្ឍស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព ៨០ មេហ្គាវ៉ាត់ ខេត្តព្រៃវែង ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យ ច្បាស់លាស់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ នាសម័យប្រជុំ វិសាមញ្ញលើកទី១០ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ឡាក់ឃី សូឡា ផៅវ័រ ឯ.ក សម្រាប់គម្រោងអភិវឌ្ឍស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព ៨០ មេហ្គាវ៉ាត់ ខេត្តព្រៃវែង

មាត្រា១ .-

អនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចំពោះក្រសួងរ៉ែនិងថាមពល និងអគ្គិសនីកម្ពុជា ឱ្យក្រុមហ៊ុន ឡាក់ឃី សូឡា ផៅវ័រ ឯ.ក ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងអនុវត្តគម្រោងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងក្រុមហ៊ុន ឡាក់ឃី សូឡា ផៅវ័រ ឯ.ក និងកិច្ចព្រមព្រៀងទិញថាមពលអគ្គិសនី រវាងអគ្គិសនីកម្ពុជានិងក្រុមហ៊ុន ឡាក់ឃី សូឡា ផៅវ័រ ឯ.ក ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញកាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣។ ការធានានេះមានអត្ថបទទាំងស្រុងដែលបានចុះហត្ថលេខាកាលពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃរាជរដ្ឋាភិបាលកម្ពុជា ភ្ជាប់មកជាមួយនេះ។

មាត្រា២ .-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តលិខិតធានាទូទាត់នេះ។

មាត្រា៣ .-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ ពេរ៉ៃ ៦ ពាត ខែ បាបិមាតាស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០ ៨ ខែ កក្កដា ឆ្នាំ២០២៣

ពាសា.២៣០៧.១៨៣១

ន លីហមុនី

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០០៤.....សហវ.....

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី ៦ ខែ [illegible] ឆ្នាំ២០២៣

លិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់

ជូន ÷ **ក្រុមហ៊ុន ឡាក់ឃី សូឡា ផៅវ៉រ ឯ.ក**
ជូនចំពោះ ÷ **លោកនាយកក្រុមហ៊ុន**
អាសយដ្ឋាន ÷ លេខ ៤, ផ្លូវលំ, សង្កាត់អូរអំបិល, ក្រុងសិរីសោភ័ណ,
ខេត្តបន្ទាយមានជ័យ, ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ÷ (៨៥៥) ៩៣ ៥០០ ០៨៧

យោង ÷

(ក) សិទ្ធិប្រទានលេខ ២៧ សប្រទ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

(ខ) កិច្ចព្រមព្រៀងអនុវត្តគម្រោង (IA) ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣ ដែលបានចុះហត្ថលេខា រវាងរាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយ **រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល (ក.រ.ថ)** និង **ក្រុមហ៊ុន ឡាក់ឃី សូឡា ផៅវ៉រ ឯ.ក (ក្រុមហ៊ុន)**។

(គ) **អគ្គិសនីកម្ពុជា** ជាសហគ្រាសរដ្ឋ ទទួលខុសត្រូវមានកំណត់ បានបង្កើតឡើងដោយ ព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៦/១០ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៩៦ មានការិយាល័យធំរបស់ខ្លួន តាំងនៅផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា រាប់បញ្ចូលទាំងអ្នកបន្តវេន និងអ្នកដែលបានអនុញ្ញាតឱ្យទទួលសិទ្ធិ (អ.ក) ដែលបានចុះកិច្ចព្រមព្រៀងទិញថាមពលអគ្គិសនី (PPA) ជាមួយក្រុមហ៊ុន ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៦៩៣

(ឃ) រាជរដ្ឋាភិបាលកម្ពុជា យល់ព្រមផ្តល់÷ (១)-ការធានាលើការទូទាត់ថ្លៃទិញថាមពលអគ្គិសនី ក្នុងករណីដែល អ.ក មិនធ្វើការទូទាត់ និង (២)-ការធានាលើការទូទាត់បញ្ចប់កិច្ចព្រមព្រៀង ស្របតាមប្រការ ១៥.៥ នៃ PPA និង/ឬ IA។

(ង) តាមការតម្រូវក្នុងប្រការ ៤.៨ នៃកិច្ចព្រមព្រៀងអនុវត្តគម្រោង (IA) **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ស.ហ.វ)** ជំនួសមុខឱ្យរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា **(រាជរដ្ឋាភិបាល ឬ អ្នកធានា)** បានយល់ព្រមចុះហត្ថលេខាលើលិខិតធានាលើការទូទាត់ ដែលជាកាតព្វកិច្ចទូទាត់របស់ អ.ក/ក.រ.ថ ស្របតាម PPA។ ក្នុងលិខិតធានានេះ រាជរដ្ឋាភិបាល និងក្រុមហ៊ុន ត្រូវបានហៅកាត់ដោយឡែក ថា "ភាគី" និងហៅកាត់រួមគ្នាថា "ភាគីទាំងពីរ"។

ដូច្នេះ យើងខ្ញុំសូមធានា ថា÷

១. អ្នកធានា ដោយមានជំនឿចិត្ត និងដោយកិត្តិយស នៃរាជរដ្ឋាភិបាលកម្ពុជា សូមធានា និងសន្យាដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធ ទូទាត់ឱ្យក្រុមហ៊ុន នូវចំនួនទឹកប្រាក់ណាមួយ និងទាំងអស់ ដែលត្រូវបង់ និងជំពាក់ដោយ ក.រ.ថ ឬ អ.ក ឱ្យក្រុមហ៊ុន ស្របតាម IA ឬ PPA ដែល ក.រ.ថ ឬ អ.ក ខកខានក្នុងការទូទាត់ អនុលោមតាមអាណត្តិ នៃ IA ឬ PPA។

២. លិខិតធានានេះ ត្រូវជាការធានាថាបន្តរហូត និងឱ្យបានសមស្រប និងត្រូវទូទាត់តុល្យការទឹកប្រាក់ដែលត្រូវបង់ឱ្យក្រុមហ៊ុន គ្រប់ពេលដោយ ក.រ.ថ និង/ឬ អ.ក ស្របតាម IA និង/ឬ PPA ទោះជាមានលិខិតជូនដំណឹងណាមួយ ស្តីពីការបញ្ចប់កិច្ចព្រមព្រៀង ការរំលាយ ឬអសមត្ថភាព ឬការផ្លាស់ប្តូរណាមួយ ក្នុងព្រះរាជក្រឹត្យពាក់ព័ន្ធនឹង ក.រ.ថ និង/ឬ អ.ក ឬក្នុងនាម ឬរបៀប ឬការទូទាត់គណនីណាមួយ ឬបញ្ហាផ្សេងទៀតក៏ដោយ។

៣. មុនពេលឈានដល់ការអនុវត្តលិខិតធានានេះ និងធ្វើសំណើសុំការទូទាត់ពីអ្នកធានា ក្រុមហ៊ុនត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរ ស្នើសុំការទូទាត់ពី ក.រ.ថ និង/ឬ អ.ក តាមជាក់ស្តែង។

ក្រោយរយៈពេលហុកសិប (៦០) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃវិក្កយបត្រ ដូចមានចែងក្នុងប្រការ ៨.៥ នៃ PPA ឬសំណើសុំទូទាត់ណាមួយពីក្រុមហ៊ុន ទៅ អ.ក ឬ ក.រ.ថ ត្រូវបានទទួលដោយ អ.ក ឬ ក.រ.ថ ក្រុមហ៊ុនអាចជូនដំណឹងទៅអ្នកធានា ជាលាយលក្ខណ៍អក្សរថា ការទូទាត់ដោយ ក.រ.ថ និង/ឬ អ.ក បានហួសកាលកំណត់ និងលើកសំណើសុំការទូទាត់ពីអ្នកធានា ស្របតាមលិខិតធានានេះ ហើយអ្នកធានា ត្រូវធ្វើការទូទាត់ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃទទួលបានសំណើ។ ការយឺតយ៉ាវក្នុងការទូទាត់របស់អ្នកធានា ក្រោមលិខិតធានានេះ ត្រូវគិតការប្រាក់តាមអត្រាការប្រាក់ប្រចាំឆ្នាំ LIBOR បូក ៣% (បីភាគរយ)។ ហើយពុំមានសំណើណាមួយ ដែលធ្វើឡើងដោយក្រុមហ៊ុន ស្របតាមលិខិត

ធានានេះ ដែលប៉ះពាល់ ឬជំទាស់សិទ្ធិរបស់ក្រុមហ៊ុន ក្នុងការធ្វើសំណើបន្ថែម ឬសំណើផ្សេងទៀត ចំពោះវិក្កយបត្រដែលមិនទាន់ទូទាត់ផ្សេងទៀត។

ទឹកប្រាក់ទាំងអស់ ដែលអ្នកធានាត្រូវទូទាត់តាមលិខិតធានានេះ ត្រូវបង់ទាំងអស់ចូលក្នុងគណនីធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលក្រុមហ៊ុនបានកំណត់ ជាដុល្លារអាមេរិកឱ្យក្រុមហ៊ុន។

៤. រាល់សំណើសុំទូទាត់ ដែលបានធ្វើឡើងតាមលិខិតធានានេះ ត្រូវធ្វើឡើងតាមរយៈអ្នករត់សំបុត្រ ឬ ដោយផ្ទាល់ ដោយមន្ត្រីទទួលបានការអនុញ្ញាតស្របច្បាប់របស់ក្រុមហ៊ុន នៅការិយាល័យរបស់ អ្នកធានា និងត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ ដែលមានចុះហត្ថលេខាដោយមន្ត្រីដែលបានទទួលការអនុញ្ញាតស្របច្បាប់របស់ក្រុមហ៊ុន ដោយគ្មានកាតព្វកិច្ចណាផ្សេងទៀត ដោយបញ្ជាក់ថា÷

"យើងខ្ញុំ សូមបញ្ជាក់ថា÷

(១). ក្រុមហ៊ុន ឡាក់យី សូឡា ផៅវ៉រ ឯ.ក ឬអ្នកបន្តវេន ឬអ្នកដែលបានអនុញ្ញាតឱ្យទទួលសិទ្ធិ (ក្រុមហ៊ុន) បានធ្វើសំណើសុំទូទាត់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អ្នកធានា) នូវចំនួនទឹកប្រាក់ ..... {បញ្ចូលទឹកប្រាក់} ដុល្លារអាមេរិក ស្របតាមចំណុចទី១ នៃលិខិតធានារបស់ រាជរដ្ឋាភិបាលលើការទូទាត់ ចុះថ្ងៃទី.... ខែ..... ឆ្នាំ..... រវាងអ្នកធានា និងក្រុមហ៊ុន។

(២). ចំនួនទឹកប្រាក់ខាងលើ គឺដល់ពេលត្រូវទូទាត់ដោយ អ.ក ឬ ក.រ.ថ ស្របតាម PPA/IA រវាងក្រុមហ៊ុន និង អ.ក/ក.រ.ថ និងពុំមានផ្នែកណាមួយ នៃចំនួនទឹកប្រាក់ដែលបានបញ្ជាក់ខាងលើ ជាកម្មវត្ថុនៃវិវាទ រវាង អ.ក/ក.រ.ថ និងក្រុមហ៊ុន។

(៣). សំណើសុំទូទាត់ពី ក.រ.ថ/អ.ក ជាលាយលក្ខណ៍អក្សរ បានធ្វើរួចហើយ។

(៤). ចំនួនទឹកប្រាក់នេះ នៅពុំទាន់បានទូទាត់ដោយ ក.រ.ថ/អ.ក រហូតដល់ថ្ងៃនេះ។"

៥. អ្នកធានា សូមអះអាង នៅថ្ងៃនេះថា÷

- អ្នកធានា មានសិទ្ធិពេញសមត្ថភាព និងការអនុញ្ញាតស្របច្បាប់ ក្នុងការទទួលកាតព្វកិច្ច ការចុះហត្ថលេខា និងការប្រគល់ ព្រមទាំងប្រតិបត្តិ និងអង្កេតតាមអាណត្តិ និងបញ្ញត្តិនានា នៃលិខិតធានានេះ។
- លិខិតធានានេះ ជាកាតព្វកិច្ចស្របច្បាប់ មានសុពលភាព និងប្រសិទ្ធភាព និងជាឯកសារចំណងផ្លូវច្បាប់ អនុលោមតាមអាណត្តិរបស់លិខិតធានានេះ។
- រាល់សកម្មភាពចាំបាច់ត្រូវបានអនុវត្ត និងរាល់ការយល់ព្រម ដែលតម្រូវឱ្យមាន ត្រូវបានទទួលរួចហើយ ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់សិទ្ធិក្នុងការចុះហត្ថលេខា ការប្រគល់ និងការប្រតិបត្តិលិខិតធានានេះ។

- កាតព្វកិច្ច និងកិច្ចព្រមព្រៀងនានារបស់អ្នកធានា ក្នុងលិខិតធានានេះ ជាកាតព្វកិច្ចដោយគ្មានលក្ខខណ្ឌរបស់អ្នកធានា ដែលក្នុងការអនុវត្តកាតព្វកិច្ចទាំងនេះ ជំនឿទុកចិត្ត និងកិត្តិយសរបស់អ្នកធានាត្រូវបានប្រកាន់ខ្ជាប់។
- អ្នកធានា បានយល់ព្រមដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធថា ការចុះហត្ថលេខាការប្រគល់ និងការអនុវត្តដោយអ្នកធានា តាមលិខិតធានានេះ គឺជាសកម្មភាពពាណិជ្ជកម្ម មិនមែនជាសកម្មភាពសាធារណៈ ឬជាសកម្មភាពរដ្ឋាភិបាលទេ ហើយលិខិតធានានេះ ជាកាតព្វកិច្ចដោយផ្ទាល់ ដោយគ្មានលក្ខខណ្ឌ និងដោយមិនអាចបដិសេធបានឡើយ។
- ប្រសិនបើមានបណ្តឹងណាមួយចំពោះអ្នកធានា ឬចំពោះទ្រព្យសម្បត្តិរបស់អ្នកធានា ក្នុងយុត្តាធិការណាមួយ ដែលទាក់ទងនឹងលិខិតធានានេះ ពុំមានអភ័យឯកសិទ្ធិណាមួយពីបណ្តឹងនោះ ត្រូវបានទាមទារដោយ ឬតាងនាមរបស់ខ្លួន ឬទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់ខ្លួន ដែលមានបច្ចុប្បន្ន ឬអាចទទួលបាននាពេលអនាគត។

៦. លិខិតធានានេះ ត្រូវមានសុពលភាព និងប្រសិទ្ធភាព ចាប់ពីកាលបរិច្ឆេទចូលជាធរមាន (Effective Date) នៃPPA រហូតដល់បញ្ចប់អាណត្តិ នៃIA ឬPPA និងត្រូវបន្តពេលយូរតទៅទៀតតាមចំនួនទឹកប្រាក់ជំពាក់ណាមួយ ដែល ក.រ.ថ ឬ អ.ក នៅជំពាក់ក្រុមហ៊ុន ទាក់ទងនឹងអាណត្តិនោះ ឬនៅពុំទាន់ទូទាត់។ ប៉ុន្តែ ចំពោះការធានាលើថ្លៃទិញថាមពលអគ្គិសនី ក្នុងករណីដែល អ.ក ពុំបានទូទាត់ លិខិតធានានេះ ត្រូវមានប្រសិទ្ធភាពចាប់ពីថ្ងៃដំណើរការអាជីវកម្មនៃគម្រោង (Commercial Operation Date) ឬចាប់ពីកាលបរិច្ឆេទដាក់ឱ្យដំណើរការសាកល្បង ដូចមាននិយមន័យ កំណត់នៅក្នុង PPA នៃគម្រោង។

៧. មិនយកការខកខាន ឬការយឺតយ៉ាវណាមួយដោយក្រុមហ៊ុន ក្នុងការអនុវត្តសិទ្ធិ ឬការដោះស្រាយណាមួយក្រោមលិខិតធានានេះ ជាការបដិសេធសិទ្ធិ ឬការដោះស្រាយឡើយ។ គ្មានការអនុវត្តសិទ្ធិ ឬការដោះស្រាយតែមួយ ឬតែមួយផ្នែក ច្រានចោលការអនុវត្តបន្ថែមនូវសិទ្ធិ ឬការដោះស្រាយណាមួយផ្សេងទៀតឡើយ។ ការបដិសេធរបស់ក្រុមហ៊ុន មានប្រសិទ្ធភាពលុះត្រាតែការបដិសេធនោះ ធ្វើឡើងជាលាយលក្ខណ៍អក្សរ។ សិទ្ធិ និងការដោះស្រាយនានា ដែលបានផ្តល់ឱ្យក្រុមហ៊ុន ដោយលិខិតធានានេះ គឺជាការផ្តល់បន្ថែម និងមិនលើកលែងសិទ្ធិ និងការដោះស្រាយណាមួយ ដែលបានផ្តល់ដោយច្បាប់ឡើយ។

៨. រាល់លិខិតជូនដំណឹង ឬលិខិតឆ្លើយឆ្លងផ្សេងៗទៀត (ដែលត្រូវហៅកាត់រួមគ្នាថា "លិខិតជូនដំណឹង") ដែលត្រូវផ្តល់ ឬធ្វើឡើង ស្របតាមលិខិតធានានេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវបញ្ជូនទៅបុគ្គល និងអាសយដ្ឋាន ដូចមានបញ្ជាក់ខាងក្រោម ដោយត្រូវប្រគល់ផ្ទាល់ដៃ ឬតាមប្រៃសណីយ៍។ រាល់លិខិតជូនដំណឹង ត្រូវបានចាត់ទុកថាបានប្រគល់÷

(ក). ពេលបានប្រគល់ផ្ទាល់ដៃ, ឬ

(ខ). នៅពេលប្រគល់ដោយមានការកត់ត្រាត្រឹមត្រូវ និងមានការបានទទួលដោយអ្នកផ្ញើឯកសារអន្តរជាតិដែលមានការទទួលស្គាល់ បញ្ជូនទៅភាគីទទួល ទៅកាន់អាសយដ្ឋានដូចខាងក្រោម (ឬក៏អាសយដ្ឋានដទៃទៀត ដែលភាគីទទួលនោះ អាចបញ្ជាក់តាមរយៈលិខិតជូនដំណឹងឱ្យទៅភាគីប្រគល់លិខិត តាមអាសយដ្ឋាន ឬលេខទូរសារចែងខាងក្រោម)÷

សម្រាប់ អ្នកធានា÷

ជូនចំពោះ ÷ ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អាសយដ្ឋាន ÷ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ទូរស័ព្ទលេខ ÷ (៨៥៥) ២៣ ៨៩០ ៦៦៦

សម្រាប់ ក្រុមហ៊ុន÷

ជូនចំពោះ ÷ លោកនាយកក្រុមហ៊ុន

អាសយដ្ឋាន ÷ ផ្ទះលេខ ៤, ផ្លូវលំ, សង្កាត់អូរអំបិល, ក្រុងសិរីសោភ័ណ, ខេត្តបន្ទាយមានជ័យ, ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខ ÷ (៨៥៥) ៩៣ ៥០០ ០៨៧

ឬក៏អាសយដ្ឋានផ្សេងទៀត ដែលភាគីណាមួយ អាចជូនដំណឹងឱ្យភាគីមួយទៀត។

៩. អ្នកធានាមិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមលិខិតធានានេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីក្រុមហ៊ុនឡើយ ហើយក្រុមហ៊ុនមិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមលិខិតធានានេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីអ្នកធានាឡើយ លើកលែងការផ្ទេរសិទ្ធិជូនអ្នកឱ្យខ្ចីប្រាក់ ដូចមានចែងក្នុងចំណុចទី១៥ខាងក្រោម។ ថ្វីបើមានបញ្ញត្តិក្នុងវាក្យខណ្ឌមុននេះក្តី សម្រាប់គោលបំណងអភិវឌ្ឍន៍ ឬការផ្តល់ហិរញ្ញប្បទានជាអចិន្ត្រៃយ៍ដល់គម្រោង ក្រុមហ៊ុនអាចប្រគល់សិទ្ធិ ឬបង្កើតការធានាផលប្រយោជន៍ចំពោះសិទ្ធិ និងផលប្រយោជន៍ ក្នុង និងចំពោះលិខិតធានានេះ សម្រាប់ជាប្រយោជន៍ដល់អ្នកឱ្យខ្ចីប្រាក់។ លិខិតធានានេះ ត្រូវជាចំណងផ្លូវច្បាប់ និងមានប្រសិទ្ធភាព ជាប្រយោជន៍ដល់អ្នកធានា និងក្រុមហ៊ុន ព្រមទាំងអ្នកបន្តវេន និងអ្នកទទួលសិទ្ធិស្របច្បាប់របស់ភាគីនីមួយៗ។

១០. សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកធានា និងក្រុមហ៊ុន ក្រោម ឬអនុលោមតាមលិខិតធានានេះ និងអាណត្តិនៃលិខិតធានានេះ ត្រូវបានគ្រប់គ្រងដោយ និងបកស្រាយតាមច្បាប់កម្ពុជា។ ប្រសិនបើ ពុំមានចែងក្នុងច្បាប់កម្ពុជា ច្បាប់នៃប្រទេសអង់គ្លេស នឹងត្រូវជាច្បាប់គ្រប់គ្រងមជ្ឈត្តវិនិច្ឆ័យ។

១១. ប្រសិនបើមានវិវាទ ឬការខ្វែងគំនិតណាមួយកើតឡើង តាមរូបភាពណាក៏ដោយ ឬពាក់ព័ន្ធនឹងលិខិតធានានេះ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីភាគីមួយបានទទួលសេចក្តីជូនដំណឹងពីភាគីមួយ

ទៀត ស្តីពីការកើតឡើងនៃវិវាទ អ្នកធានា និងក្រុមហ៊ុន ត្រូវដោះស្រាយវិវាទនោះ តាមរយៈការពិភាក្សាជាមិត្តភាព។ ប្រសិនបើមិនអាចដោះស្រាយបាន តាមរយៈការពិភាក្សាជាមិត្តភាពទេ ត្រូវដាក់វិវាទនោះ ទៅមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរ ដើម្បីដោះស្រាយស្របទៅតាមវិធាន នៃមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរនោះ។ ប្រសិនបើមានភាពមិនស្របគ្នាដោយអន្លើ រវាងបញ្ញត្តិនេះ និងវិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរនោះ បញ្ញត្តិនេះត្រូវមានប្រសិទ្ធភាព។ សេចក្តីសម្រេច ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយគឺជាសេចក្តីសម្រេចស្ថាពរ និងមានប្រសិទ្ធភាពទៅលើអ្នកធានា និងក្រុមហ៊ុន និងអាចយកមកអនុវត្តនៅក្នុងតុលាការកម្ពុជាណាមួយ ដែលមានយុត្តាធិការធ្វើឱ្យសេចក្តីសម្រេចនេះអនុវត្តបាន។ ភាគីទាំងពីរ ត្រូវទទួលយក និងអនុវត្តសេចក្តីសម្រេចនោះ ហើយភាគីនីមួយៗ ត្រូវទម្លាក់ចោលដោយឥតលក្ខខណ្ឌ នូវសិទ្ធិណាមួយដែលគេអាចមាន ដើម្បីតវ៉ាអំពីសុពលភាពនៃសេចក្តីសម្រេចនេះ ឬយុត្តាធិការនៃតុលាការមជ្ឈត្តវិនិច្ឆ័យនោះ ដើម្បីធ្វើសច្ចការឯកសារយោងណាមួយទៅមជ្ឈត្តវិនិច្ឆ័យ ដែលលិខិតធានានេះ មានប្រសិទ្ធភាពអនុវត្ត។ ការទូទាត់តាមសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យ ត្រូវធ្វើជាប្រាក់ដុល្លារអាមេរិក។ ចំណាយលើមជ្ឈត្តវិនិច្ឆ័យ ត្រូវទូទាត់ដោយភាគីដែលចាញ់ក្តី លើកលែងតែមានការកំណត់ផ្សេងពីនេះ ដោយតុលាការមជ្ឈត្តវិនិច្ឆ័យនោះ។ ភាគីដែលទទួលខុសត្រូវទូទាត់តាមសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យ ត្រូវបង់ការប្រាក់តាមអត្រា LIBOR បូក ៣% (បីភាគរយ) ទៅឱ្យភាគីម្ខាងទៀត នៅពេលទទួលសេចក្តីសម្រេចពីមជ្ឈត្តវិនិច្ឆ័យនោះ ដោយគិតចាប់ពីកាលបរិច្ឆេទត្រូវទូទាត់ រហូតដល់ថ្ងៃទូទាត់រួច។

១២. ពាក្យសរសេរជាអក្សរធំដែលបានប្រើ ប៉ុន្តែពុំមានកំណត់ន័យក្នុងលិខិតធានានេះ ត្រូវមានន័យដូចបានកំណត់ក្នុង PPA ឬ IA តាមដែលអាចអនុវត្តបាន។

១៣. ប្រសិនបើបញ្ញត្តិណាមួយ ឬច្រើន ដែលមានក្នុងលិខិតធានានេះ ត្រូវបានរកឃើញថាគ្មានសុពលភាពខុសច្បាប់ ឬគ្មានតម្លៃតាមផ្លូវច្បាប់ បញ្ញត្តិទាំងនោះ ត្រូវរក្សាតម្លៃដែលអនុញ្ញាតដោយច្បាប់ ហើយភាពគ្មានសុពលភាព ភាពខុសច្បាប់ ឬភាពគ្មានតម្លៃតាមផ្លូវច្បាប់នោះ ពុំមានឥទ្ធិពលដល់សុពលភាពនៃបញ្ញត្តិផ្សេងទៀត នៃលិខិតធានានេះឡើយ។ តាមការឯកភាពគ្នាទៅវិញទៅមក គ្មានការទូទាត់កាត់កង ការប្តឹងទាមទារទៅវិញទៅមក ការបន្ទូរបន្ថយ ឬការបន្ថយកាតព្វកិច្ចណាមួយ ដែលអ្នកធានាមាន ឬអាចមានចំពោះក្រុមហ៊ុន ត្រូវតែមានសម្រាប់អ្នកធានាចំពោះក្រុមហ៊ុន ទាក់ទងនឹងកាតព្វកិច្ចណាមួយរបស់អ្នកធានា ចំពោះក្រុមហ៊ុន ក្រោមលិខិតធានានេះឡើយ។

១៤. យោងតាមចំណុចទី៦ខាងលើ លិខិតធានានេះ ត្រូវផុតកំណត់នៅពេលបញ្ចប់ IA និង PPA និងការបំពេញចប់សព្វគ្រប់នូវបទប្បញ្ញត្តិនានា តាមអាណត្តិរបស់លិខិតធានានេះ ប្រសិនបើគ្មានការតវ៉ា ហើយនៅរក្សាការធានានេះដដែល ហេតុដូចនេះ ការស្នើសុំជាលាយលក្ខណ៍អក្សរណាមួយពីក្រុមហ៊ុន ជូនមក

អ្នកធានា ត្រូវតែទទួលបានក្នុងរយៈពេលមួយរយប៉ែតសិប (១៨០) ថ្ងៃ ក្រោយពីបានបញ្ចប់ចុងក្រោយ នៃ IA និង PPA និងការបញ្ចប់នៃមជ្ឈត្តវិនិច្ឆ័យដែលពាក់ព័ន្ធ។

១៥. ក្រុមហ៊ុនអាចប្រគល់សិទ្ធិ ឬផ្តល់ការធានាលើសិទ្ធិ ក្រោមលិខិតធានានេះ ឱ្យដល់អ្នកឱ្យខ្ចីប្រាក់។ តាមសំណើជាលាយលក្ខណ៍អក្សររបស់ក្រុមហ៊ុន យើងខ្ញុំនឹងចុះហត្ថលេខាកិច្ចព្រមព្រៀងផ្ទាល់ (Direct Agreement) ដូចមានទម្រង់កំណត់នៅក្នុង IA (ដោយជំនួស "ក.រ.ថ" ដោយ "ស.ហ.វ") (ឬការទទួលស្គាល់ផ្សេងទៀត លើផលប្រយោជន៍នៃអ្នកឱ្យខ្ចីប្រាក់ តាមសំណើសមហេតុសមផល និងមានប្រសិទ្ធភាពដូចគ្នា) ជាកម្មវត្ថុនៃការទទួលដោយអ្នកធានា នូវឯកសារដែលរៀបចំត្រឹមត្រូវ និងចុះហត្ថលេខាដោយក្រុមហ៊ុន និងអ្នកឱ្យខ្ចីប្រាក់ ឬភ្នាក់ងាររបស់ពួកគេ។

១៦. លិខិតធានានេះ នឹងចូលជាធរមាន និងមានប្រសិទ្ធភាពអនុវត្ត បន្ទាប់ពីទទួលបានការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា។

សូមលោក ទទួលនូវការរាប់អាន ពីខ្ញុំ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ចម្លងជូន:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួងរ៉ែ និងថាមពល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
-អាជ្ញាធរអគ្គិសនីកម្ពុជា
-អគ្គិសនីកម្ពុជា
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
N°.004.....MEF/.....

Phnom Penh, 6 June , 2023

GOVERNMENTAL GUARANTEE OF PAYMENT

To	:	**LUCKY SOLAR POWER CO., LTD.**
Attention	:	The Director of the Company
Address	:	#4, St. Lom, Sangkat Ou Ambel, Serei Saophoan, Banteay Meanchey, Cambodia.
Fax/Tel No.	:	(855) 93 500 087

Dear Sir,

We refer to:

(A) Delegation of Full Power No. 27 DFP dated 25 April 2023 by Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of the Kingdom of Cambodia.

(B) The Implementation Agreement (**"IA"**) dated 26 May 2023, entered between the Royal Government of Cambodia (**"RGC"**) represented by the **Minister** of MINISTRY OF MINES AND ENERGY (**"MME"**) and LUCKY SOLAR POWER CO., LTD. and any of its permitted successors in title and assigns (the **"Company"**).

(C) ELECTRICITE DU CAMBODGE, a wholly state-owned limited enterprise incorporated by Royal Decree No. CHS/RD/0396/10 of the RGC dated 9 March 1996, with its principal office located at Street 19, Wat Phnom, Daun Penh District, Phnom Penh, the Kingdom of Cambodia, including its successors and permitted assignees (**"EDC"**) has entered into a Power Purchase Agreement (**"PPA"**) with the Company dated 26 May 2023.

(D) The Royal Government of Cambodia agrees to provide: (i) guarantee on power purchase in the event of non-payment by EDC; and (ii) guarantee on the payment on the termination in accordance with Section 15.5 of the PPA and/or the IA.

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

ទំព័រ៧០០អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

(E) It is a requirement of the Implementation Agreement in accordance with its Section 4.8 that the **Minister** of Economy and Finance (**"MEF"**) on behalf of the Royal Government of Cambodia (the "**RGC**" or "**Guarantor**") has agreed to enter into this Guarantee of the payment obligations of EDC/MME under the PPA. In this Guarantee, the RGC and the Company are referred to individually as a **"Party"** and collectively as the **"Parties"**.

We hereby guarantee that:

1. The Guarantor with the full faith and credit of the Royal Government of Cambodia hereby irrevocably and unconditionally guarantees and promises to pay the Company any and every sum of money which is due and owed by MME or EDC to the Company under the IA or PPA that MME or EDC has failed to pay in accordance with the terms of the IA or PPA.

2. This Guarantee shall be a continuing security and accordingly, shall extend to cover the balance due to the Company at any time from MME and/or EDC under the IA and/or PPA, notwithstanding any notice of termination or the liquidation or other incapacity or any change in Royal Decree concerning MME and/or EDC or in the name or style thereof or any settlement of account or other matter whatsoever.

3. Before taking steps to enforce this Guarantee and demand payment from the Guarantor, the Company shall be obliged only to make demand in writing for payment from MME and/or EDC, as applicable.

   At any time after sixty (60) Days from the date of the invoice(s) as specified in Section 8.5 of the PPA or any payment demand from the Company to EDC or MME being received by EDC or MME, the Company may notify the Guarantor in writing that payment from MME and/or EDC is overdue and make a demand for payment from the Guarantor under this Guarantee, and the Guarantor shall make payment within 30 (thirty) Days of such notice. The Guarantor's late payment hereunder shall bear interest at an annual rate of LIBOR plus 3% (three percent). No demand made by the Company hereunder shall prejudice or restrict the right of the Company to make further or other demands against any other unpaid invoice(s).

   All sums payable by the Guarantor under this Guarantee shall be fully paid to the bank account designated by the Company in the Kingdom of Cambodia in US Dollars to the Company.

4. Any demand for payment made pursuant to this Guarantee shall be made by courier or in person by a duly authorized officer of the Company at the Guarantor's offices and shall be accompanied by a certificate signed by a duly authorized officer of the Company stating, without the obligation to substantiate, that

   "We hereby certify that:

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៧០១

(1) Lucky Solar Power Co., Ltd. or a permitted successor or assign (the "Company") is making this demand on the Ministry of Economy and Finance (the "Guarantor") in the amount of US Dollars — [insert amount] in accordance with Section 1 of the Guarantee dated ——, between the Guarantor and the Company;

(2) The amount specified above is due and payable by EDC or MME under the PPA/IA between the Company and EDC/MME and no part of the amount specified above is the subject of a dispute between the EDC/MME and the Company that has not been adjudicated;

(3) Demand in writing for payment from MME/EDC has been made;

(4) Such amount, on the date hereof remains unpaid by MME/EDC."

5. The Guarantor warrants that, as of the date hereof:

- The Guarantor has full power, authority, and legal right to incur the obligation, to execute and deliver, and to perform and observe the terms and provisions of this Guarantee.
- This Guarantee constitutes legal, valid, binding, and enforceable obligations of the Guarantor in accordance with its terms,
- All necessary action has been taken, and all approvals required have obtained, under the Laws of Kingdom of Cambodia to authorize the execution, delivery, and performance of this Guarantee.
- The obligations and covenants of the Guarantor in this Guarantee constitute unconditional obligations of the Guarantor, for the performance of which the full faith and credit of the Guarantor is pledged.
- The Guarantor unconditionally and irrevocably agrees that the execution, delivery, and performance by it of this Guarantee constitute commercial acts rather than public or governmental acts and such Guarantee constitutes our unconditional and irrevocable direct obligation.
- Should any proceedings be brought against it or its assets in any jurisdiction in relation to this Guarantee, no immunity from such proceedings shall be claimed by or on its behalf or with respect to its assets which it now has or may acquire in the future.

6. This Guarantee shall remain in full force and effect from the Effective Date of the PPA until the termination of the term of the IA or PPA and for so long thereafter as any amount owed to the Company by MME or EDC in connection with such term is or may be outstanding. However, such Guarantee on power purchase in the event of non-payment by EDC shall be applicable from the Commercial Operation Date (COD) or commencement of Provisional Operation, as definition stipulated in the PPA of the Project.

7. No failure or delay by the Company to exercise any right or remedy under this Guarantee shall constitute a waiver of that right or remedy. No single or partial exercise of any right or remedy shall preclude any other or further exercise thereof or the exercise of any other right or remedy. No waiver by the Company shall be effective unless it is in writing. The rights and remedies of

ទំព័រ៧០២អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

the Company provided by this Guarantee are cumulative and not exclusive of any rights or remedies provided by law.

8. All notices or other communications (together "Notices") to be given or made hereunder shall be in writing, shall be addressed for the attention of the person indicated below and shall be delivered personally or by courier. All Notices shall be deemed delivered:

   (a) when presented personally, or

   (b) upon the delivery of duly recorded and receipted delivery by a recognized international document courier, addressed to the receiving Party; at the address indicated below (or such other address as such party may have specified by notice delivered to the delivering Party at its address or facsimile number specified below).

   The address for service of Notices shall be:

   For the Guarantor:

Attention	:	Minister, Ministry of Economy and Finance
Address	:	Ministry of Economy and Finance
Tel	:	(855) 23 890 666

   For the Company:

Attention	:	The Director of the Company
Address	:	#4, Street Lom, Sangkat Ou Ambel, Serei Saophoan, Banteay Meanchey, Kingdom of Cambodia
Fax/Tel No.	:	(855) 93 500 087

   or such other addresses as either Party may have notified to the other Party.

9. The Guarantor shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Company and the Company shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Guarantor, except for transfers to Lenders as provided in paragraph 15 below. Notwithstanding the provision of the immediately preceding sentence, for the purpose of development or permanent financing of the Project, the Company may assign or create a security interest over its rights and interests in and to this Guarantee in favor of the Lenders. This Guarantee shall be binding upon and inure to the benefit of the Guarantor and the Company and the respective successors and permitted assignees of each Party.

10. The rights and obligations of the Guarantor and the Company under or pursuant to this Guarantee and the terms of this Guarantee shall be governed by and construed according to the Laws of Cambodia. If there is no applicable written law in Cambodia, the English law shall also be the law governing any arbitration.

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៧០៣

11. If there is any dispute or difference of any kind whatsoever arising out of or in connection with this Guarantee the Guarantor and the Company shall attempt for a period of thirty (30) days after the receipt by one Party of a notice from the other Party of the existence of the dispute to settle such dispute through mutual amicable discussions. If such dispute cannot be resolved through mutual amicable discussions, then it shall be submitted to the Singapore International Arbitration Center for arbitration in accordance with the arbitration rules of the Singapore International Arbitration Center. And if there are discrepancies between this clause and the rules of the Singapore International Arbitration Center, this clause shall govern. The award rendered shall be in writing and shall be final, conclusive and binding upon the Guarantor and the Company and award thereon may be entered in any Cambodian court having jurisdiction for its enforcement. Such Parties shall execute and perform the award and each Party hereby irrevocably waives any right it may have to contest the validity of such award or the jurisdiction of the arbitration tribunal to hear any reference to arbitration to which this Guarantee applies. Any payment under arbitration award shall be payable in U.S. Dollars. The costs of arbitration shall be borne by the losing Party, unless otherwise determined by the arbitration tribunal. The Party that is responsible to pay an arbitration award shall pay interest at a rate of LIBOR plus 3% (three percent) to the other Party in receipt of such arbitration award from the due date for the payment of such award until the date of payment of such award.

12. The capitalized terms used but not defined in this Guarantee shall have the meanings given to them in the Power Purchase Agreement or IA, as applicable.

13. If one or more provisions contained in this Guarantee is held or found to be invalid, illegal, or unenforceable in any respect, the provision(s) shall be given effect to the extent permitted by law and the invalidity, illegality, or unenforceability of any provision shall not affect the validity of the remaining provisions of this Guarantee. Subject to mutual agreement to the contrary, no set-off counterclaim, reduction, or diminution of any obligation that the Guarantor has or may have against the Company shall be available to the Guarantor against the Company in connection with any obligation of the Guarantor to the Company under this Guarantee.

14. Subject to Clause 6 hereof, this Guarantee shall expire upon the complete termination of the IA and PPA, and fulfillment of any operative surviving provisions per the terms thereof, and provided that, no claim has been made and remains outstanding hereunder and provided further that any written demand made to us by you hereunder must be received by us within one hundred eighty (180) days after the final termination of the IA and the PPA and completion of any related arbitration.

15. The Company is entitled to assign or grant security over its rights under this Guarantee to Lenders. We shall, at the written request of the Company, execute a Direct Agreement in substantially the

ទំព័រ៧០៤អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

form set out in the IA (substituting "MEF" for "MME") (or such other acknowledgement of the interests of the Lenders as they may reasonably request and is substantially to the same effect), SUBJECT ONLY to receipt by it of an engrossment of such document duly executed by the Company and the Lenders or their agent.

16. This Guarantee shall become in full and effective on its ratification by legislatures of the Kingdom of Cambodia.

Yours sincerely,

Dr. AUN PORNMONIROTH
DEPUTY PRIME MINISTER, MINISTER,
MINISTRY OF ECONOMY AND FINANCE

CC:
- Ministry of Royal Palace
- Secretariat of Senate
- Secretariate of National Assembly
- Office of Council of Ministers
- Council for the Development of Cambodia (CDC)
- Ministry of Foreign Affairs and International Cooperation
- Ministry of Mines and Energy
- Cabinet of Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of the Kingdom of Cambodia
- Electricity Authority of Cambodia (EAC)
- Electricite du Cambodge (EDC)
- File

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៧០៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ..២៧.សប្រទ..

ថ្ងៃអង្គារ ៦កើត ខែ ពិសាខ ឆ្នាំថោះ បញ្ឆស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០២៣

សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/១២២២/០១២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣
- យោងតាមការសម្រេចរបស់គណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៣

រាជរដ្ឋាភិបាល

ប្រគល់សិទ្ធិពេញសមត្ថភាព ជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ៉ត្ថ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងអនុវត្តគម្រោង ជាមួយក្រុមហ៊ុន ឡាក់ឃី សូឡា ផៅវ៉រ ឯ.ក និងលើលិខិតធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដោយអគ្គិសនីកម្ពុជា និង/ឬ ក្រសួងរ៉ែនិងថាមពល ទៅឱ្យក្រុមហ៊ុន ឡាក់ឃី សូឡា ផៅវ៉រ ឯ.ក សម្រាប់គម្រោងអភិវឌ្ឍស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលពន្លឺព្រះអាទិត្យអានុភាព ៨០ មេហ្គាវ៉ាត់ នៅខេត្តព្រៃវែង។

ក្នុងករណីដែលឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ៉ត្ថ** មានធុរៈជាយថាហេតុ ឯកឧត្តមអាចផ្ទេរសិទ្ធិនេះបាន។

ដើម្បីជាសក្ខីភាព នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិពេញលេញតាមអំណាចច្បាប់ បានចុះហត្ថលេខាខាងក្រោមលើសិទ្ធិប្រទាននេះ។

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

រាជរដ្ឋាភិបាល
Royal Government
Nº 27 DFP

Phnom Penh, 25 April , 2023

DELEGATION OF FULL POWERS

- Seen the Constitution of the Kingdom of Cambodia
- Seen the Royal Decree NS/RKT/0918/925 dated 06 of September 2018 on the nomination of the Royal Government of the Kingdom of Cambodia
- Seen the Royal Kram NS/RKM/0618/012 dated 28 of June 2018 promulgating the Law on the Organization and Functioning of the Council of Ministers
- Seen the Royal Kram NS/RKM/0196/18 dated 24 of January 1996 promulgating the Law on the Establishment of the Ministry of Economy and Finance
- Seen the Royal Kram NS/RKM/1021/014 dated 15 of October 2021 promulgating the Law on Investment of Kingdom of Cambodia
- Seen the Royal Kram NS/RKM/1222/012 dated 10 of December 2022 promulgating the Law on Finance for Management of the Year 2023
- Referring to the decision of Council of Ministers in its plenary session on 7 of April 2023

THE ROYAL GOVERNMENT

Delegates herewith to **H.E. Dr. AUN PORNMONIROTH,** Deputy Prime Minister, Minister of Economy and Finance, full powers to sign the Implementation Agreement, and the Governmental Guarantee of Payments by the EDC/MME to Lucky Solar Power Co., Ltd. for the Development of 80 MW Solar Photovoltaic Power Plant Project in Prey Veng Province.

These powers include the powers of delegation.

In witness whereof the undersigned, the Prime Minister of the Kingdom of Cambodia with full powers duly entrusted to him, has signed this delegation of full powers.

Prime Minister

Samdech Akka Moha Sena Padei Techo HUN SEN

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៧០៧

ព្រះរាជក្រម

នស/រកម/០៧២៣/ ០១៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាវជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជ៦ករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ស្នេថេក ខូ អិលធីឌី សម្រាប់គម្រោងអភិវឌ្ឍស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព ១៥០ មេហ្គាវ៉ាត់ ខេត្តពោធ៍សាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យ ចុះសេចក្តីប្រឹទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ នាសម័យប្រជុំ ពេញអង្គលើកទី១០ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ស្នេថេក ខូ អិលធីឌី សម្រាប់គម្រោងអភិវឌ្ឍស្ថានីយផលិតអគ្គិសនី ជើរជោយថាមពលពន្លឺព្រះអាទិត្យ អានុភាព ១៥០ មេហ្ហាវ៉ាត់ ខេត្តពោធ៍សាត់

មាត្រា១ .-

អនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចំពោះក្រសួងរ៉ែនិងថាមពល និងអគ្គិសនីកម្ពុជា ឱ្យក្រុមហ៊ុន ស្នេថេក ខូ អិលធីឌី ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងអនុវត្តគម្រោងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងក្រុមហ៊ុន ស្នេថេក ខូ អិលធីឌី និងកិច្ចព្រមព្រៀងទិញថាមពលអគ្គិសនី រវាងអគ្គិសនីកម្ពុជានិងក្រុមហ៊ុន ស្នេថេក ខូ អិលធីឌី ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣។ ការធានានេះមានអត្ថបទទាំងស្រុងដែលបានចុះហត្ថលេខាកាលពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃរាជរដ្ឋាភិបាលកម្ពុជា ភ្ជាប់មកជាមួយនេះ។

មាត្រា២ .-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តលិខិតធានាទូទាត់នេះ។

មាត្រា៣ .-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៨ ខែ [illegible] ឆ្នាំ២០២៣

[illegible]

[illegible]

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមទ្បាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០០៥.....សហវ.....

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំថោះ បញ្ញស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី ៦ ខែ [illegible] ឆ្នាំ២០២៣

លិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់

ជូន ÷ **ក្រុមហ៊ុន ស្លេថេក ខូ អិលធីឌី**
ជូនចំពោះ ÷ **លោកនាយកក្រុមហ៊ុន**
អាសយដ្ឋាន ÷ លេខ ៣៦, ផ្លូវលេខ ៣៥២, សង្កាត់បឹងកេងកង១,
ខណ្ឌបឹងកេងកង, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ÷ (៨៥៥) ២៣ ២១៥ ៤៧១

យោង ÷

(ក) សិទ្ធិប្រទានលេខ ២៨ សប្រទ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

(ខ) កិច្ចព្រមព្រៀងអនុវត្តគម្រោង (IA) ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣ ដែលបានចុះហត្ថលេខា រវាងរាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយ **រដ្ឋមន្ត្រីក្រសួងរៃ និងថាមពល (ក.រ.ថ)** និង **ក្រុមហ៊ុន ស្លេថេក ខូ អិលធីឌី (ក្រុមហ៊ុន)**។

(គ) **អគ្គិសនីកម្ពុជា** ជាសហគ្រាសរដ្ឋ ទទួលខុសត្រូវមានកំណត់ បានបង្កើតឡើងដោយ ព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៦/១០ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៩៦ មានការិយាល័យធំរបស់ខ្លួន តាំងនៅផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា រាប់បញ្ចូលទាំងអ្នកបន្តវេន និងអ្នកដែលបានអនុញ្ញាតឱ្យទទួលសិទ្ធិ (**អ.ក**) ដែលបានចុះកិច្ចព្រមព្រៀងទិញថាមពលអគ្គិសនី (PPA) ជាមួយក្រុមហ៊ុន ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

(ឃ) រាជរដ្ឋាភិបាលកម្ពុជា យល់ព្រមផ្តល់÷ (១)-ការធានាលើការទូទាត់ថ្លៃទិញថាមពលអគ្គិសនី ក្នុងករណីដែល អ.ក មិនធ្វើការទូទាត់ និង (២)-ការធានាលើការទូទាត់បញ្ចប់កិច្ចព្រមព្រៀង ស្របតាមប្រការ ១៥.៥ នៃ PPA និង/ឬ IA។

(ង) តាមការតម្រូវក្នុងប្រការ ៤.៨ នៃកិច្ចព្រមព្រៀងអនុវត្តគម្រោង (IA) **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ស.ហ.ទ)** ជំនួសមុខឱ្យរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា (**រាជរដ្ឋាភិបាល ឬ អ្នកធានា**) បានយល់ព្រមចុះហត្ថលេខាលើលិខិតធានាលើការទូទាត់ ដែលជាកាតព្វកិច្ចទូទាត់របស់ អ.ក/ក.រ.ថ ស្របតាម PPA។ ក្នុងលិខិតធានានេះ រាជរដ្ឋាភិបាល និងក្រុមហ៊ុន ត្រូវបានហៅកាត់ដោយឡែក ថា "ភាគី" និងហៅកាត់រួមគ្នាថា "ភាគីទាំងពីរ"។

ដូច្នេះ យើងខ្ញុំសូមធានា ថា÷

១. អ្នកធានា ដោយមានជំនឿចិត្ត និងដោយកិត្តិយស នៃរាជរដ្ឋាភិបាលកម្ពុជា សូមធានា និងសន្យាដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធ ទូទាត់ឱ្យក្រុមហ៊ុន នូវចំនួនទឹកប្រាក់ណាមួយ និងទាំងអស់ ដែលត្រូវបង់ និងជំពាក់ដោយ ក.រ.ថ ឬ អ.ក ឱ្យក្រុមហ៊ុន ស្របតាម IA ឬ PPA ដែល ក.រ.ថ ឬ អ.ក ខកខានក្នុងការទូទាត់ អនុលោមតាមអាណត្តិ នៃ IA ឬ PPA។

២. លិខិតធានានេះ ត្រូវជាការធានាថាបន្តរហូត និងឱ្យបានសមស្រប និងត្រូវទូទាត់តុល្យការទឹកប្រាក់ដែលត្រូវបង់ឱ្យក្រុមហ៊ុន គ្រប់ពេលដោយ ក.រ.ថ និង/ឬ អ.ក ស្របតាម IA និង/ឬ PPA ទោះជាមានលិខិតជូនដំណឹងណាមួយ ស្តីពីការបញ្ចប់កិច្ចព្រមព្រៀង ការរំលាយ ឬអសមត្ថភាព ឬការផ្លាស់ប្តូរណាមួយ ក្នុងព្រះរាជក្រឹត្យពាក់ព័ន្ធនឹង ក.រ.ថ និង/ឬ អ.ក ឬក្នុងនាម ឬរបៀប ឬការទូទាត់គណនីណាមួយ ឬបញ្ហាផ្សេងទៀតក៏ដោយ។

៣. មុនពេលឈានដល់ការអនុវត្តលិខិតធានានេះ និងធ្វើសំណើសុំការទូទាត់ពីអ្នកធានា ក្រុមហ៊ុនត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរ ស្នើសុំការទូទាត់ពី ក.រ.ថ និង/ឬ អ.ក តាមជាក់ស្តែង។

ក្រោយរយៈពេលហុកសិប (៦០) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃវិក្កយបត្រ ដូចមានចែងក្នុងប្រការ ៨.៥ នៃ PPA ឬសំណើសុំទូទាត់ណាមួយពីក្រុមហ៊ុន ទៅ អ.ក ឬ ក.រ.ថ ត្រូវបានទទួលដោយ អ.ក ឬ ក.រ.ថ ក្រុមហ៊ុនអាចជូនដំណឹងទៅអ្នកធានា ជាលាយលក្ខណ៍អក្សរថា ការទូទាត់ដោយ ក.រ.ថ និង/ឬ អ.ក បានហួសកាលកំណត់ និងលើកសំណើសុំការទូទាត់ពីអ្នកធានា ស្របតាមលិខិតធានានេះ ហើយអ្នកធានា ត្រូវធ្វើការទូទាត់ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃទទួលបានសំណើ។ ការយឺតយ៉ាវក្នុងការទូទាត់របស់អ្នកធានា ក្រោមលិខិតធានានេះ ត្រូវគិតការប្រាក់តាមអត្រាការប្រាក់ប្រចាំឆ្នាំ LIBOR បូក ៣% (បីភាគរយ)។ ហើយពុំមានសំណើណាមួយ ដែលធ្វើឡើងដោយក្រុមហ៊ុន ស្របតាមលិខិត

ធានានេះ ដែលប៉ះពាល់ ឬជំទាស់សិទ្ធិរបស់ក្រុមហ៊ុន ក្នុងការធ្វើសំណើបន្ថែម ឬសំណើផ្សេងទៀត ចំពោះវិក្កយបត្រដែលមិនទាន់ទូទាត់ផ្សេងទៀត។

ទឹកប្រាក់ទាំងអស់ ដែលអ្នកធានាត្រូវទូទាត់តាមលិខិតធានានេះ ត្រូវបង់ទាំងអស់ចូលក្នុងគណនីធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលក្រុមហ៊ុនបានកំណត់ ជាដុល្លារអាមេរិកឱ្យក្រុមហ៊ុន។

៤. រាល់សំណើសុំទូទាត់ ដែលបានធ្វើឡើងតាមលិខិតធានានេះ ត្រូវធ្វើឡើងតាមរយៈអ្នករត់សំបុត្រ ឬ ដោយផ្ទាល់ ដោយមន្ត្រីទទួលបានការអនុញ្ញាតស្របច្បាប់របស់ក្រុមហ៊ុន នៅការិយាល័យរបស់ អ្នកធានា និងត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ ដែលមានចុះហត្ថលេខាដោយមន្ត្រីដែលបានទទួលការអនុញ្ញាតស្របច្បាប់របស់ក្រុមហ៊ុន ដោយគ្មានកាតព្វកិច្ចណាផ្សេងទៀត ដោយបញ្ជាក់ថា÷

"យើងខ្ញុំ សូមបញ្ជាក់ថា÷

(១). ក្រុមហ៊ុន ស្នេថេក ខូ អិលធីឌី ឬអ្នកបន្តវេន ឬអ្នកដែលបានអនុញ្ញាតឱ្យទទួលសិទ្ធិ (ក្រុមហ៊ុន) បានធ្វើសំណើសុំទូទាត់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អ្នកធានា) នូវចំនួនទឹកប្រាក់ ..... {បញ្ចូលទឹកប្រាក់} ដុល្លារអាមេរិក ស្របតាមចំណុចទី១ នៃលិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់ ចុះថ្ងៃទី.... ខែ..... ឆ្នាំ..... រវាងអ្នកធានា និងក្រុមហ៊ុន។

(២). ចំនួនទឹកប្រាក់ខាងលើ គឺដល់ពេលត្រូវទូទាត់ដោយ អ.ក ឬ ក.រ.ថ ស្របតាម PPA/IA រវាងក្រុមហ៊ុន និង អ.ក/ក.រ.ថ និងពុំមានផ្នែកណាមួយ នៃចំនួនទឹកប្រាក់ដែលបានបញ្ជាក់ខាងលើ ជាកម្មវត្ថុនៃវិវាទ រវាង អ.ក/ក.រ.ថ និងក្រុមហ៊ុន។

(៣). សំណើសុំទូទាត់ពី ក.រ.ថ/អ.ក ជាលាយលក្ខណ៍អក្សរ បានធ្វើរួចហើយ។

(៤). ចំនួនទឹកប្រាក់នេះ នៅពុំទាន់បានទូទាត់ដោយ ក.រ.ថ/អ.ក រហូតដល់ថ្ងៃនេះ។"

៥. អ្នកធានា សូមអះអាង នៅថ្ងៃនេះថា÷

- អ្នកធានា មានសិទ្ធិពេញសមត្ថភាព និងការអនុញ្ញាតស្របច្បាប់ ក្នុងការទទួលកាតព្វកិច្ច ការចុះហត្ថលេខា និងការប្រគល់ ព្រមទាំងប្រតិបត្តិ និងអង្កេតតាមអាណត្តិ និងបញ្ញត្តិនានា នៃលិខិតធានានេះ។
- លិខិតធានានេះ ជាកាតព្វកិច្ចស្របច្បាប់ មានសុពលភាព និងប្រសិទ្ធភាព និងជាឯកសារចំណងផ្ទូវច្បាប់ អនុលោមតាមអាណត្តិរបស់លិខិតធានានេះ។
- រាល់សកម្មភាពចាំបាច់ត្រូវបានអនុវត្ត និងរាល់ការយល់ព្រម ដែលតម្រូវឱ្យមាន ត្រូវបានទទួលរួចហើយ ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់សិទ្ធិក្នុងការចុះហត្ថលេខា ការប្រគល់ និងការប្រតិបត្តិលិខិតធានានេះ។
- កាតព្វកិច្ច និងកិច្ចព្រមព្រៀងនានារបស់អ្នកធានា ក្នុងលិខិតធានានេះ ជាកាតព្វកិច្ចដោយគ្មានលក្ខខណ្ឌរបស់អ្នកធានា ដែលក្នុងការអនុវត្តកាតព្វកិច្ចទាំងនេះ ជំនឿទុកចិត្ត និងកិត្តិយសរបស់អ្នកធានាត្រូវបានប្រកាន់ខ្ជាប់។

- អ្នកធានា បានយល់ព្រមដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធថា ការចុះហត្ថលេខា ការប្រគល់ និងការអនុវត្តដោយអ្នកធានា តាមលិខិតធានានេះ គឺជាសកម្មភាពពាណិជ្ជកម្ម មិនមែនជាសកម្មភាពសាធារណៈ ឬជាសកម្មភាពរដ្ឋាភិបាលទេ ហើយលិខិតធានានេះ ជាកាតព្វកិច្ចដោយផ្ទាល់ ដោយគ្មានលក្ខខណ្ឌ និងដោយមិនអាចបដិសេធបានឡើយ។
- ប្រសិនបើមានបណ្តឹងណាមួយចំពោះអ្នកធានា ឬចំពោះទ្រព្យសម្បត្តិរបស់អ្នកធានា ក្នុងយុត្តាធិការណាមួយ ដែលទាក់ទងនឹងលិខិតធានានេះ ពុំមានអភ័យឯកសិទ្ធិណាមួយពីបណ្តឹងនោះ ត្រូវបានទាមទារដោយ ឬតាងនាមរបស់ខ្លួន ឬទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់ខ្លួន ដែលមានបច្ចុប្បន្ន ឬអាចទទួលបាននាពេលអនាគត។

៦. លិខិតធានានេះ ត្រូវមានសុពលភាព និងប្រសិទ្ធភាព ចាប់ពីកាលបរិច្ឆេទចូលជាធរមាន (Effective Date) នៃPPA រហូតដល់បញ្ចប់អាណត្តិនៃIA ឬPPA និងត្រូវបន្តពេលយូរតទៅទៀតតាមចំនួនទឹកប្រាក់ជំពាក់ណាមួយ ដែល ក.រ.ថ ឬ អ.ក នៅជំពាក់ក្រុមហ៊ុន ទាក់ទងនឹងអាណត្តិនោះ ឬនៅពុំទាន់ទូទាត់។ ប៉ុន្តែ ចំពោះការធានាលើថ្លៃទិញថាមពលអគ្គិសនី ក្នុងករណីដែល អ.ក ពុំបានទូទាត់ លិខិតធានានេះ ត្រូវមានប្រសិទ្ធភាពចាប់ពីថ្ងៃដំណើរការអាជីវកម្មនៃគម្រោង (Commercial Operation Date) ឬចាប់ពីកាលបរិច្ឆេទដាក់ឱ្យដំណើរការសាកល្បង ដូចមាននិយមន័យ កំណត់នៅក្នុង PPA នៃគម្រោង។

៧. មិនយកការខកខាន ឬការយឺតយ៉ាវណាមួយដោយក្រុមហ៊ុន ក្នុងការអនុវត្តសិទ្ធិ ឬការដោះស្រាយណាមួយក្រោមលិខិតធានានេះ ជាការបដិសេធសិទ្ធិ ឬការដោះស្រាយឡើយ។ គ្មានការអនុវត្តសិទ្ធិ ឬការដោះស្រាយតែមួយ ឬតែមួយផ្នែក ច្រានចោលការអនុវត្តបន្ថែមនូវសិទ្ធិ ឬការដោះស្រាយណាមួយផ្សេងទៀតឡើយ។ ការបដិសេធរបស់ក្រុមហ៊ុន មានប្រសិទ្ធភាពលុះត្រាតែការបដិសេធនោះ ធ្វើឡើងជាលាយលក្ខណ៍អក្សរ។ សិទ្ធិ និងការដោះស្រាយនានា ដែលបានផ្តល់ឱ្យក្រុមហ៊ុន ដោយលិខិតធានានេះ គឺជាការផ្តល់បន្ថែម និងមិនលើកលែងសិទ្ធិ និងការដោះស្រាយណាមួយ ដែលបានផ្តល់ដោយច្បាប់ឡើយ។

៨. រាល់លិខិតជូនដំណឹង ឬលិខិតឆ្លើយឆ្លងផ្សេងៗទៀត (ដែលត្រូវហៅកាត់រួមគ្នាថា "លិខិតជូនដំណឹង") ដែលត្រូវផ្តល់ ឬធ្វើឡើង ស្របតាមលិខិតធានានេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវបញ្ជូនទៅបុគ្គល និងអាសយដ្ឋាន ដូចមានបញ្ជាក់ខាងក្រោម ដោយត្រូវប្រគល់ផ្ទាល់ដៃ ឬតាមប្រៃសណីយ៍។ រាល់លិខិតជូនដំណឹង ត្រូវបានចាត់ទុកថាបានប្រគល់÷

(ក). ពេលបានប្រគល់ផ្ទាល់ដៃ, ឬ

(ខ). នៅពេលប្រគល់ដោយមានការកត់ត្រាត្រឹមត្រូវ និងមានការបានទទួលដោយអ្នកផ្ញើឯកសារអន្តរជាតិដែលមានការទទួលស្គាល់ បញ្ជូនទៅភាគីទទួល ទៅកាន់អាសយដ្ឋានដូចខាង

ក្រោម (ឬក៏អាសយដ្ឋានដទៃទៀត ដែលភាគីទទួលនោះ អាចបញ្ជាក់តាមរយៈលិខិតជូនដំណឹងឱ្យទៅភាគីប្រគល់លិខិត តាមអាសយដ្ឋាន ឬលេខទូរសារចែងខាងក្រោម)÷

សម្រាប់ អ្នកធានា÷

ជូនចំពោះ ÷ ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អាសយដ្ឋាន ÷ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ទូរស័ព្ទលេខ ÷ (៨៥៥) ២៣ ៨៩០ ៦៦៦

សម្រាប់ ក្រុមហ៊ុន÷

ជូនចំពោះ ÷ លោកនាយកក្រុមហ៊ុន

អាសយដ្ឋាន ÷ ផ្ទះលេខ ៣៦, ផ្លូវលេខ ៣៥២, សង្កាត់បឹងកេងកង១, ខណ្ឌបឹងកេងកង, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខ ÷ (៨៥៥) ២៣ ២១៥ ៤៧១

ឬក៏អាសយដ្ឋានផ្សេងទៀត ដែលភាគីណាមួយ អាចជូនដំណឹងឱ្យភាគីមួយទៀត។

៩. អ្នកធានាមិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬភាពកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមលិខិតធានានេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីក្រុមហ៊ុនឡើយ ហើយក្រុមហ៊ុនមិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬភាពកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមលិខិតធានានេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីអ្នកធានាឡើយ លើកលែងការផ្ទេរសិទ្ធិជូនអ្នកឱ្យខ្ចីប្រាក់ ដូចមានចែងក្នុងចំណុចទី១៥ខាងក្រោម។ ថ្វីបើមានបញ្ញត្តិក្នុងវាក្យខណ្ឌមុននេះក្តី សម្រាប់គោលបំណងអភិវឌ្ឍន៍ ឬការផ្តល់ហិរញ្ញប្បទានជាអចិន្ត្រៃយ៍ដល់គម្រោង ក្រុមហ៊ុនអាចប្រគល់សិទ្ធិ ឬបង្កើតការធានាផលប្រយោជន៍ចំពោះសិទ្ធិ និងផលប្រយោជន៍ ក្នុង និងចំពោះលិខិតធានានេះ សម្រាប់ជាប្រយោជន៍ដល់អ្នកឱ្យខ្ចីប្រាក់។ លិខិតធានានេះ ត្រូវជាចំណងផ្លូវច្បាប់ និងមានប្រសិទ្ធភាព ជាប្រយោជន៍ដល់អ្នកធានា និងក្រុមហ៊ុន ព្រមទាំងអ្នកបន្តវេន និងអ្នកទទួលសិទ្ធិស្របច្បាប់របស់ភាគីនីមួយៗ។

១០. សិទ្ធិ និងភាពកិច្ចរបស់អ្នកធានា និងក្រុមហ៊ុន ក្រោម ឬអនុលោមតាមលិខិតធានានេះ និងអាណត្តិនៃលិខិតធានានេះ ត្រូវបានគ្រប់គ្រងដោយ និងបកស្រាយតាមច្បាប់កម្ពុជា។ ប្រសិនបើ ពុំមានចែងក្នុងច្បាប់កម្ពុជា ច្បាប់នៃប្រទេសអង់គ្លេស នឹងត្រូវជាច្បាប់គ្រប់គ្រងមជ្ឈត្តវិនិច្ឆ័យ។

១១. ប្រសិនបើមានវិវាទ ឬការខ្វែងគំនិតណាមួយកើតឡើង តាមរូបភាពណាក៏ដោយ ឬពាក់ព័ន្ធនឹងលិខិតធានានេះ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីភាគីមួយបានទទួលសេចក្តីជូនដំណឹងពីភាគីមួយទៀត ស្តីពីការកើតឡើងនៃវិវាទ អ្នកធានា និងក្រុមហ៊ុន ត្រូវដោះស្រាយវិវាទនោះ តាមរយៈការពិភាក្សាជាមិត្តភាព។ ប្រសិនបើមិនអាចដោះស្រាយបាន តាមរយៈការពិភាក្សាជាមិត្តភាពទេ ត្រូវដាក់វិវាទនោះទៅមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរ ដើម្បីដោះស្រាយស្របទៅតាមវិធាន នៃមជ្ឈមណ្ឌល

ឯកឧត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមទ្រង់ព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..៣៧៥.....សហវ.....

ថ្ងៃសុក្រ ១៣ កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០២៣

លិខិតធានារបស់រាជរដ្ឋាភិបាលលើការធ្វើដាក់

ជូន ÷ **ក្រុមហ៊ុន ស្ទឹង មេឌីក ហាយឌ្រូអ៊ៅថ័រ**

ជូនចំពោះ ÷ **លោកឧកញ៉ា លី យ៉ុងដាត់**
ប្រធានក្រុមប្រឹក្សាភិបាល

អាសយដ្ឋាន ÷ លេខ ៣៤៤, មហាវិថីម៉ៅសេទុង, សង្កាត់ទួលស្វាយព្រៃទី១,
ខណ្ឌចំការមន, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

ទូរសារ/ទូរស័ព្ទ ÷ (៨៥៥) ២៣ ២១៣ ៣១៤

យោង ÷

(ក) សិទ្ធិប្រទានលេខ ៤២ សប្រទ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** (ឧបសម្ព័ន្ធ១)។

(ខ) កិច្ចព្រមព្រៀងអនុវត្តគម្រោង (IA) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ ដែលបានចុះហត្ថលេខា រវាង រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយ **រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល (ក.រ.ថ)** និង **ក្រុមហ៊ុន ស្ទឹង មេឌីក ហាយឌ្រូអ៊ៅថ័រ (ក្រុមហ៊ុន)**។

(គ) **អគ្គិសនីកម្ពុជា** ជាសហគ្រាសរដ្ឋ ទទួលខុសត្រូវមានកំណាត់ បានបង្កើតឡើងដោយ ព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៦/១០ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៩៦ មានការិយាល័យធំរបស់ខ្លួន តាំងនៅផ្លូវ ព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា រាប់បញ្ចូលទាំង អ្នកបន្តវេន និងអ្នកដែលបានអនុញ្ញាតឱ្យទទួលសិទ្ធិ (**អ.ភ**) ដែលបានចុះកិច្ចព្រមព្រៀងទិញថាមពល អគ្គិសនី (PPA) ជាមួយក្រុមហ៊ុន ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៧៦១

(ឃ) រាជរដ្ឋាភិបាលកម្ពុជា យល់ព្រមផ្តល់÷ (១)-ការធានាលើការទូទាត់ថ្លៃទិញថាមពលអគ្គិសនី ក្នុងករណីដែល អ.ក មិនធ្វើការទូទាត់ និង (២)-ការធានាលើការទូទាត់បញ្ចប់កិច្ចព្រមព្រៀង ស្របតាម PPA និង/ឬ IA ក្នុងករណីដែលក្រុមហ៊ុនមិនអាចអនុវត្តគម្រោងបាន ដែលបណ្តាលមកពីព្រឹត្តិការណ៍ប្រធានស័ក្តិផ្នែកនយោបាយ។

(ង) តាមការតម្រូវក្នុងប្រការ ៥.៣ នៃកិច្ចព្រមព្រៀងអនុវត្តគម្រោង (IA) **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ស.ហ.ឥ)** ជំនួសមុខឱ្យរាជរដ្ឋាភិបាលកម្ពុជា (**អ្នកធានា**) បានយល់ព្រមផ្តល់លិខិតធានានេះដែលជាកាតព្វកិច្ចទូទាត់របស់ អ.ក ឬ ក.រ.ថ ស្របតាម PPA និង IA។

ដូច្នេះ យើងខ្ញុំសូមធានាថា÷

១. អ្នកធានា សូមធានា និងសន្យា ដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធ ទូទាត់ឱ្យក្រុមហ៊ុនន្លូវចំនួនទឹកប្រាក់ណាមួយ និងទាំងអស់ ដែលត្រូវបង់និងជំពាក់ដោយ ក.រ.ថ ឬ អ.ក ឱ្យក្រុមហ៊ុនស្របតាម IA ឬ PPA ដែល ក.រ.ថ ឬ អ.ក ខកខានក្នុងការទូទាត់អនុលោមតាមអាណត្តិ នៃ IA ឬ PPA (**លិខិតធានា**)។

២. លិខិតធានានេះ ត្រូវជាការធានាថាបន្តរហូត និងឱ្យបានសមស្រប និងត្រូវទូទាត់តុល្យការទឹកប្រាក់ដែលត្រូវបង់ឱ្យក្រុមហ៊ុន គ្រប់ពេលដោយ ក.រ.ថ ឬ អ.ក ស្របតាម IA និង/ឬ PPA ទោះជាមានលិខិតជូនដំណឹងណាមួយស្តីពីការបញ្ចប់កិច្ចព្រមព្រៀង ការរំលាយ ឬអសមត្ថភាព ឬការផ្លាស់ប្តូរណាមួយ ក្នុងព្រះរាជក្រឹត្យពាក់ព័ន្ធនឹង ក.រ.ថ ឬ អ.ក ឬក្នុងនាម ឬរបៀប ឬការទូទាត់គណនីណាមួយ ឬបញ្ហាផ្សេងទៀតក៏ដោយ។

៣. មុនពេលឈានដល់ការអនុវត្តលិខិតធានានេះ និងធ្វើសំណើសុំការទូទាត់ពីអ្នកធានា ក្រុមហ៊ុនត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរ ស្នើសុំការទូទាត់ពី ក.រ.ថ និង/ឬ អ.ក។

ក្រោយរយៈពេលហុកសិប (៦០) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃវិក្កយបត្រ ដូចមានចែងក្នុងប្រការ ៨.៧.១ នៃ PPA ឬសំណើសុំទូទាត់ណាមួយពីក្រុមហ៊ុន ទៅ អ.ក ឬ ក.រ.ថ ត្រូវបានទទួលដោយ អ.ក ឬ ក.រ.ថ ក្រុមហ៊ុនអាចជូនដំណឹងទៅអ្នកធានាជាលាយលក្ខណ៍អក្សរថា ការទូទាត់ដោយ ក.រ.ថ និង/ឬ អ.ក បានហួសកាលកំណត់ និងលើកសំណើសុំការទូទាត់ពីអ្នកធានា ស្របតាមលិខិតធានានេះ ហើយអ្នកធានា ត្រូវធ្វើការទូទាត់ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ។ ការយឺតយ៉ាវក្នុងការទូទាត់របស់អ្នកធានាក្រោមលិខិតធានានេះ ត្រូវគិតការប្រាក់តាមអត្រាការប្រាក់ប្រចាំឆ្នាំ LIBOR បូក ៣% (បីភាគរយ)។

ពុំមានសំណើណាមួយ ដែលធ្វើឡើងដោយក្រុមហ៊ុនស្របតាមលិខិតធានានេះ ដែលប៉ះពាល់ ឬជិទាស់សិទ្ធិរបស់ក្រុមហ៊ុន ក្នុងការធ្វើសំណើបន្ថែម ឬសំណើផ្សេងទៀត ចំពោះវិក្កយបត្រដែលមិនទាន់ទូទាត់ផ្សេងទៀត។

ទឹកប្រាក់ទាំងអស់ ដែលអ្នកធានាត្រូវទូទាត់តាមលិខិតធានានេះ ត្រូវបង់ទាំងអស់ចូលក្នុងគណនីធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលក្រុមហ៊ុនបានកំណត់ ជាផ្លូវការអាមេរិកឱ្យក្រុមហ៊ុន។

៤. រាល់សំណើសុំទូទាត់ ដែលបានធ្វើឡើងតាមលិខិតធានានេះ ត្រូវធ្វើឡើងតាមរយៈអ្នករត់សំបុត្រ ឬ ដោយផ្ទាល់ ដោយមន្ត្រីទទួលបានការអនុញ្ញាតស្របច្បាប់របស់ក្រុមហ៊ុន នៅការិយាល័យរបស់អ្នកធានា និងត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ ដែលមានចុះហត្ថលេខាដោយមន្ត្រីដែលបានទទួលការអនុញ្ញាតស្របច្បាប់របស់ក្រុមហ៊ុន ដែលមិនមែនជាកាតព្វកិច្ច ដោយបញ្ជាក់ថា÷

"យើងខ្ញុំ សូមបញ្ជាក់ថា÷

(១). ក្រុមហ៊ុន ស្ទឹង មេទឹក ហាយដ្រូផៅវ័រ (ក្រុមហ៊ុន) ធ្វើសំណើសុំការទូទាត់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អ្នកធានា) នូវចំនួនទឹកប្រាក់ ..... {បញ្ចូលទឹកប្រាក់} ដុល្លារអាមេរិក ស្របតាមចំណុចទី១ នៃលិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់ ចុះថ្ងៃទី.... ខែ..... ឆ្នាំ..... រវាងអ្នកធានា និងក្រុមហ៊ុន។

(២). ចំនួនទឹកប្រាក់ខាងលើ គឺដល់ពេលត្រូវទូទាត់ដោយ អ.ក ឬ ក.រ.ថ ស្របតាម PPA ឬ IA រវាងក្រុមហ៊ុន និង អ.ក ឬ ក.រ.ថ និងពុំមានផ្នែកណាមួយនៃចំនួនទឹកប្រាក់ដែលបានបញ្ជាក់ខាងលើ ជាកម្មវត្ថុនៃវិវាទរវាងអ.ក ឬ ក.រ.ថ និងក្រុមហ៊ុនឡើយ។

(៣). សំណើសុំទូទាត់ពី ក.រ.ថ ឬ អ.ក ជាលាយលក្ខណ៍អក្សរ បានផ្ញើរួចហើយ។

(៤). ចំនួនទឹកប្រាក់នេះ នៅពុំទាន់បានទូទាត់ដោយ ក.រ.ថ ឬ អ.ក រហូតដល់ថ្ងៃនេះ។"

៥. អ្នកធានាសូមបញ្ជាក់ និងអះអាងនៅថ្ងៃនេះថា÷

- អ្នកធានា មានសិទ្ធិពេញសមត្ថភាព និងការអនុញ្ញាតស្របច្បាប់ ក្នុងការទទួលកាតព្វកិច្ច ការចុះហត្ថលេខា និងការប្រគល់ ព្រមទាំងប្រតិបត្តិ និងអង្កេតតាមអាណត្តិ និងបញ្ញត្តិនានា នៃលិខិតធានានេះ។
- លិខិតធានានេះ ជាកាតព្វកិច្ចស្របច្បាប់ មានសុពលភាព និងប្រសិទ្ធភាព និងជាឯកសារចំណងផ្លូវច្បាប់ អនុលោមតាមអាណត្តិរបស់លិខិតធានានេះ។
- រាល់សកម្មភាពចាំបាច់ត្រូវបានអនុវត្ត និងរាល់ការយល់ព្រមដែលតម្រូវឱ្យមាន ត្រូវបានទទួលរួចហើយ ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់សិទ្ធិក្នុងការចុះហត្ថលេខា ការប្រគល់ និងការប្រតិបត្តិលិខិតធានានេះ។

- កាតព្វកិច្ច និងកិច្ចព្រមព្រៀងនានារបស់អ្នកធានា ក្នុងលិខិតធានានេះ ជាកាតព្វកិច្ចដោយគ្មានលក្ខខណ្ឌរបស់អ្នកធានា ដែលក្នុងការអនុវត្តកាតព្វកិច្ចទាំងនេះ ជំនឿទុកចិត្ត និងកិត្តិយសរបស់អ្នកធានាត្រូវបានប្រកាន់ខ្ជាប់។
- អ្នកធានា បានយល់ព្រមដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធថា ការចុះហត្ថលេខាការប្រគល់ និងការអនុវត្តដោយអ្នកធានា តាមលិខិតធានានេះ គឺជាសកម្មភាពពាណិជ្ជកម្ម មិនមែនជាសកម្មភាពសាធារណៈ ឬជាសកម្មភាពរដ្ឋាភិបាលទេ ហើយលិខិតធានានេះ ជាកាតព្វកិច្ចដោយផ្ទាល់ ដោយគ្មានលក្ខខណ្ឌ និងដោយមិនអាចបដិសេធបានឡើយ។
- ប្រសិនបើមានបណ្តឹងណាមួយចំពោះអ្នកធានា ឬចំពោះទ្រព្យសម្បត្តិរបស់អ្នកធានា ក្នុងយុត្តាធិការណាមួយ ដែលទាក់ទងនឹងលិខិតធានានេះ ពុំមានអភ័យឯកសិទ្ធិណាមួយពីបណ្តឹងនោះ ត្រូវបានទាមទារដោយ ឬតាងនាមរបស់ខ្លួន ឬទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់ខ្លួន ដែលមានបច្ចុប្បន្ន ឬអាចទទួលបាននាពេលអនាគត។

៦. លិខិតធានានេះ ត្រូវមានសុពលភាព និងប្រសិទ្ធភាព ចាប់ពីកាលបរិច្ឆេទចាប់ផ្តើមការសាងសង់ (Construction Commencement Date) រហូតដល់បញ្ចប់អាណត្តិ នៃ IA ឬPPA និងត្រូវបន្តពេលយូរតទៅទៀតតាមចំនួនទឹកប្រាក់ជំពាក់ណាមួយ ដែល ក.រ.ថ ឬ អ.ក នៅជំពាក់ក្រុមហ៊ុន ទាក់ទងនឹងអាណត្តិនោះ ឬនៅពុំទាន់ទូទាត់។

៧. មិនយកការខកខាន ឬការយឺតយ៉ាវណាមួយដោយក្រុមហ៊ុន ក្នុងការអនុវត្តសិទ្ធិ ឬការដោះស្រាយណាមួយក្រោមលិខិតធានានេះ ជាការបដិសេធសិទ្ធិ ឬការដោះស្រាយឡើយ។ គ្មានការអនុវត្តសិទ្ធិ ឬការដោះស្រាយតែមួយ ឬតែមួយផ្នែក ត្រានចោលការអនុវត្តបន្ថែមនូវសិទ្ធិ ឬការដោះស្រាយណាមួយផ្សេងទៀតឡើយ។ ការបដិសេធរបស់ក្រុមហ៊ុន មានប្រសិទ្ធភាពលុះត្រាតែការបដិសេធនោះ ធ្វើឡើងជាលាយលក្ខណ៍អក្សរ។ សិទ្ធិ និងការដោះស្រាយនានា ដែលបានផ្តល់ឱ្យក្រុមហ៊ុន ដោយលិខិតធានានេះ គឺជាការផ្តល់បន្ថែម និងមិនលើកលែងសិទ្ធិ និងការដោះស្រាយណាមួយ ដែលផ្តល់ដោយច្បាប់ឡើយ។

៨. រាល់លិខិតជូនដំណឹង ឬលិខិតឆ្លើយឆ្លងផ្សេងៗទៀត (ដែលត្រូវហៅកាត់រួមគ្នាថា "លិខិតជូនដំណឹង") ដែលត្រូវផ្តល់ ឬធ្វើឡើងស្របតាមលិខិតធានានេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវបញ្ជូនទៅបុគ្គល និងអាសយដ្ឋានដូចមានបញ្ជាក់ខាងក្រោម ដោយត្រូវប្រគល់ផ្ទាល់ដៃ ឬតាមប្រៃសណីយ៍។ រាល់លិខិតជូនដំណឹង ត្រូវបានចាត់ទុកថាបានប្រគល់÷

(ក). ពេលបានប្រគល់ផ្ទាល់ដៃ, ឬ

(ខ). នៅពេលប្រគល់ដោយមានការកត់ត្រាត្រឹមត្រូវ និងមានការបានទទួលដោយអ្នកធ្វើឯកសារអន្តរជាតិដែលមានការទទួលស្គាល់ បញ្ជូនទៅភាគីទទួល ទៅកាន់អាសយដ្ឋានដូចខាង

ក្រោម (ឬក៏អាសយដ្ឋានដទៃទៀត ដែលភាគីទទួលនោះ អាចបញ្ជាក់តាមរយៈលិខិតជូនដំណឹងឱ្យទៅភាគីប្រគល់លិខិត តាមអាសយដ្ឋាន ឬលេខទូរសារចែងខាងក្រោម)÷

សម្រាប់ អ្នកធានា÷

ជូនចំពោះ	÷	ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អាសយដ្ឋាន	÷	ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ទូរស័ព្ទលេខ	÷	(៨៥៥) ២៣ ៨៩០ ៦៦៦

សម្រាប់ ក្រុមហ៊ុន÷

អាសយដ្ឋាន	÷	ផ្ទះលេខ ៣៤៤, មហាវិថីម៉ៅសេទុង, សង្កាត់ទួលស្វាយព្រៃទី១, ខណ្ឌចំការមន, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ទូរសារ/ទូរស័ព្ទ	÷	(៨៥៥) ២៣ ២១៣ ៣១៤
ជូនចំពោះ	÷	ប្រធានក្រុមប្រឹក្សាភិបាល ក្រុមហ៊ុន ស្ទឹង មេទឹក ហាយដ្រូផោវ៉រ

ឬក៏អាសយដ្ឋានផ្សេងទៀត ដែលភាគីណាមួយ អាចជូនដំណឹងឱ្យភាគីមួយទៀត។

៩. អ្នកធានាមិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមលិខិតធានានេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីក្រុមហ៊ុនឡើយ ហើយក្រុមហ៊ុនមិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមលិខិតធានានេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីអ្នកធានាឡើយ។ ថ្វីបើមានបញ្ញត្តិក្នុងវាក្យខណ្ឌមុននេះក្តី សម្រាប់គោលបំណងអភិវឌ្ឍន៍ ឬការផ្តល់ហិរញ្ញប្បទានជាអចិន្ត្រៃយ៍ដល់គម្រោង ក្រុមហ៊ុនអាចប្រគល់សិទ្ធិ ឬបង្កើតការធានាផលប្រយោជន៍ ចំពោះសិទ្ធិ និងផលប្រយោជន៍ ក្នុង និងចំពោះលិខិតធានានេះ សម្រាប់ជាប្រយោជន៍ដល់អ្នកឱ្យខ្ចីប្រាក់។ លិខិតធានានេះ ត្រូវជាចំណងផ្លូវច្បាប់ និងមានប្រសិទ្ធភាពជាប្រយោជន៍ដល់អ្នកធានា និងក្រុមហ៊ុន ព្រមទាំងអ្នកបន្តវេន និងអ្នកទទួលសិទ្ធិស្របច្បាប់របស់ភាគីនីមួយៗ។

១០. សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកធានា និងក្រុមហ៊ុន ក្រោម ឬអនុលោមតាមលិខិតធានានេះ និងអាណត្តិនៃលិខិតធានានេះ ត្រូវបានគ្រប់គ្រងដោយ និងបកស្រាយតាមច្បាប់កម្ពុជា ដែលនឹងជាច្បាប់គ្រប់គ្រងមជ្ឈត្តវិនិច្ឆ័យផងដែរ។

១១. ប្រសិនបើមានវិវាទ ឬការខ្វែងគំនិតណាមួយកើតឡើង តាមរូបភាពណាក៏ដោយ ឬពាក់ព័ន្ធនឹងលិខិតធានានេះ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីភាគីមួយបានទទួលសេចក្តីជូនដំណឹងពីភាគីមួយទៀត ស្តីពីការកើតឡើងនៃវិវាទ អ្នកធានា និងក្រុមហ៊ុន ត្រូវដោះស្រាយវិវាទនោះ តាមរយៈការពិភាក្សា

ជាមិត្តភាព។ ប្រសិនបើមិនអាចដោះស្រាយបាន តាមរយៈការពិភាក្សាជាមិត្តភាពទេ ត្រូវដាក់វិវាទនោះ ទៅមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរ ដើម្បីដោះស្រាយស្របទៅតាមវិធាន នៃមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរនោះ។ ប្រសិនបើមានភាពមិនស្របគ្នាដោយអន្លើ រវាងបញ្ញត្តិនេះ និងវិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរនោះ បញ្ញត្តិនេះត្រូវមានប្រសិទ្ធភាព។ សេចក្តីសម្រេច ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយគឺជាសេចក្តីសម្រេចស្ថាពរ និងមានប្រសិទ្ធភាពទៅលើអ្នកធានា និងក្រុមហ៊ុន និងអាចយកមកអនុវត្តនៅក្នុងតុលាការកម្ពុជាណាមួយ ដែលមានយុត្តាធិការធ្វើឱ្យសេចក្តីសម្រេចនេះអនុវត្តបាន។ ភាគីទាំងពីរ ត្រូវទទួលយក និងអនុវត្តសេចក្តីសម្រេចនោះ ហើយភាគីនីមួយៗ ត្រូវទម្លាក់ចោលដោយឥតលក្ខខណ្ឌ នូវសិទ្ធិណាមួយដែលគេអាចមាន ដើម្បីតវ៉ាអំពីសុពលភាព នៃសេចក្តីសម្រេចនេះ ឬយុត្តាធិការនៃតុលាការមជ្ឈត្តវិនិច្ឆ័យនោះ ដើម្បីធ្វើសច្ចការឯកសារយោងណាមួយទៅមជ្ឈត្តវិនិច្ឆ័យ ដែលលិខិតធានានេះមានប្រសិទ្ធភាពអនុវត្ត។ ការទូទាត់តាមសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យ ត្រូវធ្វើជាប្រាក់ដុល្លារអាមេរិក។ ចំណាយលើមជ្ឈត្តវិនិច្ឆ័យ ត្រូវទូទាត់ដោយភាគីដែលចាញ់ក្តី លើកលែងតែមានការកំណត់ផ្សេងពីនេះ ដោយតុលាការមជ្ឈត្តវិនិច្ឆ័យនោះ។ ភាគីដែលទទួលខុសត្រូវទូទាត់តាមសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យ ត្រូវបង់ការប្រាក់តាមអត្រា LIBOR បូក ៣% (បីភាគរយ) ទៅឱ្យភាគីម្ខាងទៀត នៅពេលទទួលសេចក្តីសម្រេចពីមជ្ឈត្តវិនិច្ឆ័យនោះ ដោយគិតចាប់ពីកាលបរិច្ឆេទត្រូវទូទាត់ រហូតដល់ថ្ងៃទូទាត់រួច។

១២. ពាក្យសរសេរជាអក្សរធំដែលបានប្រើ ប៉ុន្តែពុំមានកំណត់ន័យក្នុងលិខិតធានានេះ ត្រូវមានន័យដូចបានកំណត់ក្នុង PPA ឬ IA តាមដែលអាចអនុវត្តបាន។

១៣. ប្រសិនបើបញ្ញត្តិណាមួយ ឬច្រើន ដែលមានក្នុងលិខិតធានានេះ ត្រូវបានរកឃើញថាគ្មានសុពលភាព ខុសច្បាប់ ឬគ្មានតម្លៃតាមផ្លូវច្បាប់ បញ្ញត្តិទាំងនោះត្រូវរក្សាតម្លៃដែលអនុញ្ញាតដោយច្បាប់ ហើយភាពគ្មានសុពលភាព ភាពខុសច្បាប់ ឬភាពគ្មានតម្លៃតាមផ្លូវច្បាប់នោះ ពុំមានឥទ្ធិពលដល់សុពលភាព នៃបញ្ញត្តិផ្សេងទៀតនៃលិខិតធានានេះឡើយ។ តាមការឯកភាពគ្នាទៅវិញទៅមក គ្មានការទូទាត់កាត់កងការប្តឹងទាមទារទៅវិញទៅមក ការបន្ធូរបន្ថយ ឬការបន្ថយកាតព្វកិច្ចណាមួយ ដែលអ្នកធានាមាន ឬអាចមានចំពោះក្រុមហ៊ុន ត្រូវតែមានសម្រាប់អ្នកធានាចំពោះក្រុមហ៊ុន ទាក់ទងនឹងកាតព្វកិច្ចណាមួយរបស់អ្នកធានា ចំពោះក្រុមហ៊ុនក្រោមលិខិតធានានេះឡើយ។

១៤. លិខិតធានានេះ ត្រូវផុតកំណត់នៅពេលបញ្ចប់ IA និង PPA ប្រសិនបើគ្មានការតវ៉ា ហើយនៅរក្សាការធានានេះដដែល ហេតុដូចនេះការស្នើសុំជាលាយលក្ខណ៍អក្សរណាមួយពីក្រុមហ៊ុន ជូនមកអ្នកធានា ត្រូវតែទទួលបានដោយអ្នកធានា មុនពេលបញ្ចប់នោះ។

១៥. ក្រុមហ៊ុនអាចប្រគល់សិទ្ធិ ឬផ្តល់ការធានាលើសិទ្ធិក្រោមលិខិតធានានេះ ឱ្យអ្នកឱ្យខ្ចីប្រាក់។ តាមសំណើជាលាយលក្ខណ៍អក្សររបស់ក្រុមហ៊ុន យើងខ្ញុំនឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្ទាល់ (Direct Agreement) ដូចមានទម្រង់កំណត់ក្នុង IA (ជំនួស "ក.រ.ថ" ដោយ "ស.ហ.រ") (ឬការទទួលស្គាល់ផ្សេងទៀតលើផលប្រយោជន៍នៃអ្នកឱ្យខ្ចីប្រាក់ តាមសំណើសមហេតុសមផល និងមានប្រសិទ្ធភាពដូចគ្នា)។

១៦. លិខិតធានានេះ នឹងចូលជាធរមាន និងមានប្រសិទ្ធភាពអនុវត្ត បន្ទាប់ពីទទួលបានការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា។

សូមអ្នកឧកញ៉ា ទទួលនូវការរាប់អាន ពីខ្ញុំ



អគ្គបណ្ឌិតសភាចារ្យ ង៉ូន ជ័ន្ធមុនីរ័ត្ន

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងរ៉ែ និងថាមពល
- ឧទ្ទិសលើយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- អាជ្ញាធរអគ្គិសនីកម្ពុជា
- អគ្គិសនីកម្ពុជា
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
N°...006.....MEF/.....

Phnom Penh, 16 June , 2023

GOVERNMENT GUARANTEE OF PAYMENT

To : STEUNG METEUK HYDROPOWER CO., LTD.
Address : #344, Mao Tse Tung Blvd, Sangkat Toul Svay Prey 1,
Khan Chamkar Morn, Phnom Penh, Cambodia.
Fax/Tel : +855 23 213 314
Attention : Mr. LY YONGPHAT, Chairman of The Board of Directors

Dear Sir,

We refer to:

(A) Delegation of Full Power No. 42 DFP dated 12 June 2023 by Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of the Kingdom of Cambodia. (Attachment 1)

(B) The Implementation Agreement **("IA")** dated 12 June 2023, entered into between the Government of the Kingdom of Cambodia **("GKC")** represented by **Minister** of MINISTRY OF MINES AND ENERGY **("MME")** and STEUNG METEUK HYDROPOWER CO., LTD. **(the "Company")**.

(C) ELECTRICITÉ DU CAMBODGE, a wholly state-owned limited liability enterprise incorporated by Royal Decree No. CHS/RD/0396/10 of the GKC dated 9 March 1996, with its principal office located at Yukunthor Street, Daun Penh, Phnom Penh, in the Kingdom of Cambodia, including its successors and permitted assignees **("EDC")** has entered into a Power Purchase Agreement **("PPA")** with the Company dated 13 June 2023.

(D) The GKC agrees to provide: (i) guarantee on power purchase in the event of non-payment by EDC; and (ii) guarantee on the payment on the termination in accordance with the PPA and/or the IA in the event that the Company is unable to operate the Project arising from the Political Force Majeure Events.

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

ទំព័រ៧៦៨អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

(E) It is a requirement of the Implementation Agreement in accordance with its Section 5.3, the Minister of Economy and Finance **("MEF")** on behalf of Royal Government of Cambodia **(the "Guarantor")** has agreed to issue this Guarantee of the payment obligations of EDC/MME under the PPA and the IA.

We hereby guarantee that:

1. The Guarantor hereby irrevocably and unconditionally guarantees and promises to pay the Company any and every sum of money which is due and owed by MME or EDC to the Company under the IA or PPA that MME or EDC has failed to pay in accordance with the terms of the IA or PPA **(the "Guarantee").**

2. This Guarantee shall be a continuing security and accordingly, shall extend to cover the balance due to the Company at any time from MME or EDC under the IA or PPA, notwithstanding any notice of termination or the liquidation or other incapacity or any change in Royal Decree concerning MME or EDC or in the name or style thereof or any settlement of account or other matter whatsoever.

3. Before taking steps to enforce this Guarantee and demand payment from the Guarantor, the Company shall be obliged only to make demand in writing for payment from MME or EDC. Any time after sixty (60) days from the date of the invoice(s) as specified in Section 8.7.1 of the PPA or any payment demand from the Company to EDC/MME being received by EDC or MME, the Company may notify the Guarantor in writing that payment from MME or EDC is overdue and make a demand for payment from the Guarantor under this Guarantee, and the Guarantor shall make payment within thirty (30) days. The Guarantor's late payment hereunder shall bear interest at an annual rate of LIBOR plus 3% (three percent). No demand made by the Company hereunder shall prejudice or restrict the right of the Company to make further or other demands against any other unpaid invoice(s).

   All sums payable by the Guarantor under this Guarantee shall be fully paid to the bank account designated by the Company in the Kingdom of Cambodia in US Dollars to the Company.

4. Any demand for payment made pursuant to this Guarantee shall be made by courier or in person by a duly authorized officer of the Company at the Guarantor's offices and shall be accompanied by a certificate signed by a duly authorized officer of the Company stating, without the obligation to substantiate, that:

   "We hereby certify that:

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៧៦៩

(1) STEUNG METEUK HYDROPOWER CO., LTD (the Company) is making this demand on the Ministry of Economy and Finance (the "Guarantor") in the amount of U. S. Dollars [•] [insert amount] in accordance with Section 1 of the Guarantee dated [•], between the Guarantor and the Company;

(2) The amount specified above is due and payable by [EDC/MME] under the PPA/IA between the Company and EDC/MME and no part of the amount specified above is the subject of a dispute between the EDC/MME and the Company;

(3) Demand in writing for payment from EDC/MME has been made;

(4) Such amount, on the date hereof, remains unpaid by EDC/MME."

5. The Guarantor represents and warrants that, as of the date hereof:

- The Guarantor has full power, authority, and legal right to incur the obligation, to execute and deliver, and to perform and observe the terms and provisions of this Guarantee.
- This Guarantee constitutes legal, valid, binding, and enforceable obligations of the Guarantor in accordance with its terms.
- All necessary action has been taken, and all approvals required have been obtained, under the Laws of the Kingdom of Cambodia to authorize the execution, delivery, and performance of this Guarantee.
- The obligations and covenants of the Guarantor in this Guarantee constitute unconditional obligations of the Guarantor, for the performance of which the full faith and credit of the Guarantor is pledged.
- The Guarantor unconditionally and irrevocably agrees that the execution, delivery, and performance by it of this Guarantee constitute commercial acts rather than public or governmental acts and such Guarantee constitutes its unconditional and irrevocable direct obligation.
- Should any proceedings be brought against the Guarantor or its assets in any jurisdiction in relation to this Guarantee, no immunity from such proceedings shall be claimed by or on its behalf or with respect to its assets which it now has or may acquire in the future.

6. This Guarantee shall remain in full force and effect from the Construction Commencement Date until the termination of the Term of the IA or PPA and for so long thereafter as any amount owed to the Company by EDC/MME in connection with such term is or may be outstanding.

7. No failure or delay by the Company to exercise any right or remedy under this Guarantee

ទំព័រ៧៧០អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

shall constitute a waiver of that right or remedy. No single or partial exercise of any right or remedy shall preclude any other or further exercise thereof or the exercise of any other right or remedy. No waiver by the Company shall be effective unless it is in writing. The rights and remedies of the Company provided by this Guarantee are cumulative and not exclusive of any rights or remedies provided by law.

8. All notices or other communications (together **"Notices"**) to be given or made hereunder shall be in writing, shall be addressed for the attention of the person indicated below and shall be delivered personally or by courier. All Notices shall be deemed delivered:
   (a) when presented personally, or
   (b) upon the day of duly recorded and receipted delivery by a recognized international document courier, addressed to the receiving Party, at the address indicated below (or such other address as such party may have specified by notice delivered to the delivering Party at its address or facsimile number specified below).

   The address for service of Notice shall be:

   For the Guarantor :
   - Address : Ministry of Economy and Finance
   - Tel : (855) 23 890 666
   - Attention : Minister, Ministry of Economy and Finance

   For the Company :
   - Address : #344, Mao Tse Tung Blvd., Sangkat Toul Svay Prey 1, Khan Chamkar Morn, Phnom Penh, Cambodia.
   - Fax/Tel No. : +855 23 213 314
   - Attention : Chairman of The Board of Directors, STEUNG METEUK HYDROPOWER CO., LTD.

   or such other addresses as either Party may have notified to the other Party.

9. The Guarantor shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Company, and the Company shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Guarantor. Notwithstanding the provision of the immediately preceding sentence, for the purpose of development or permanent financing of the Project, the Company may assign or create a security interest over its rights and interests in and to this Guarantee in favor of the Lenders. This Guarantee shall be binding upon and inure to the benefit of the Guarantor and the Company and the respective successors and permitted assignees of each Party.

10. The rights and obligations of the Guarantor and the Company under or pursuant to this

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៧៧១

Guarantee shall be governed by and construed according to the Laws of Cambodia, which shall also be the procedural law governing any arbitration.

11. If there is any dispute or difference of any kind whatsoever arising out of or in connection with this Guarantee, the Guarantor and the Company shall attempt for a period of thirty (30) days after the receipt by one Party of a notice from the other Party of the existence of the dispute to settle such dispute through mutual amicable discussions. Should such dispute can't be resolved through mutual amicable discussions, then it shall be submitted to the Singapore International Arbitration Center for arbitration in accordance with the arbitration rules of the Singapore International Arbitration Center. And if there are discrepancies between this clause and the rules of the Singapore International Arbitration Center, this clause shall govern. The award rendered shall be in writing and shall be final, conclusive and binding upon the Guarantor and the Company and award thereon may be entered in any Cambodian court having jurisdiction for its enforcement. Such Parties shall execute and perform the award and each Party hereby irrevocably waives any right it may have to contest the validity of such award or the jurisdiction of the arbitration tribunal to hear any reference to arbitration to which this Guarantee applies. Any payment under arbitration award shall be payable in U.S. Dollars. The costs of arbitration shall be borne by the losing Party, unless otherwise determined by the arbitration tribunal. The Party that is responsible to pay an arbitration award shall pay interest at a rate of LIBOR plus 3% (three percent) to the other Party in receipt of such arbitration award from the due date for the payment of such award until the date of payment of such award.

12. The capitalized terms used but not defined in this Guarantee shall have the meanings given to them in the Power Purchase Agreement or IA as applicable.

13. If one or more provisions contained in this Guarantee is held or found to be invalid, illegal, or unenforceable in any respect, the provision(s) shall be given effect to the extent permitted by law and the invalidity, illegality, or unenforceability of any provision shall not affect the validity of the remaining provisions of this Guarantee. Subject to mutual agreement, no set-off, counterclaim, reduction, or diminution of any obligation that the Guarantor has or may have against the Company shall be available to the Guarantor against the Company in connection with any obligation of the Guarantor to the Company under this Guarantee.

14 This Guarantee shall expire upon the termination of the IA and PPA if no claim has been made and remains outstanding hereunder and any written demand made to the Guarantor by the Company hereunder must therefore be received by the Guarantor before that time.

ទំព័រ៧៧២អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣

15 The Company is entitled to assign or grant security over its rights under this Guarantee to Lenders. We shall, at the written request of the Company, execute a Direct Agreement in substantially the form set out in the IA (substituting "MEF" for "MME") (or such other acknowledgement of the interests of the Lenders as they may reasonably request and is substantially to the same effect).

16 This Guarantee shall become in full force and effective on its ratification by legislatures of the Kingdom of Cambodia.

Yours sincerely,

Dr. AUN PORNMONIROTH
Deputy Prime Minister, Minister,
Ministry of Economy and Finance.

CC:
- Ministry of Royal Palace
- Secretariat of Senate
- Secretariate of National Assembly
- Office of Council of Ministers
- Council for the Development of Cambodia (CDC)
- Ministry of Foreign Affairs and International Cooperation
- Ministry of Mines and Energy
- Cabinet of Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of the Kingdom of Cambodia
- Electricity Authority of Cambodia (EAC)
- Electricite du Cambodge (EDC)
- File

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៧៧៣



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៤ សហវ

ថ្ងៃចន្ទ ទី២៨ ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣

សិទ្ធិប្រធាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/១២២២/០១២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣

រាជរដ្ឋាភិបាល

ប្រគល់សិទ្ធិពេញសមត្ថភាព ជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងអនុវត្តគម្រោង កិច្ចព្រមព្រៀងជួលទីតាំង ជាមួយក្រុមហ៊ុន ស្ទឹង មេទឹក ហាយដ្រូផៅវ៉ែរ និងលើលិខិតផ្ទេរទឹកនានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដោយអគ្គិសនីកម្ពុជា និង/ឬ ក្រសួងរ៉ែនិងថាមពល ទៅឱ្យក្រុមហ៊ុន ស្ទឹង មេទឹក ហាយដ្រូផៅវ៉ែរ សម្រាប់គម្រោងអភិវឌ្ឍភាវីអគ្គិសនីស្ទឹងមេទឹក អានុភាព ១៥០ មេហ្គាវ៉ាត់ នៅខេត្តកោះកុង។

ក្នុងករណីដែលឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** មានធុរៈជាយថាហេតុ ឯកឧត្តមអាចផ្ទេរសិទ្ធិនេះបាន។

ដើម្បីជាសក្ខីភាព នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមច្បាប់ និងតាមអំណាចច្បាប់ បានចុះហត្ថលេខាខាងក្រោមលើសិទ្ធិប្រធាននេះ។

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia

រាជរដ្ឋាភិបាល
Royal Government

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

Phnom Penh, June 12, 2023

DELEGATION OF FULL POWERS

- Seen the Constitution of the Kingdom of Cambodia
- Seen the Royal Decree NS/RKT/0918/925 dated 06 of September 2018 on the nomination of the Royal Government of the Kingdom of Cambodia
- Seen the Royal Kram NS/RKM/0618/012 dated 28 of June 2018 promulgating the Law on the Organization and Functioning of the Council of Ministers
- Seen the Royal Kram NS/RKM/0196/18 dated 24 of January 1996 promulgating the Law on the Establishment of the Ministry of Economy and Finance
- Seen the Royal Kram NS/RKM/1021/014 dated 15 of October 2021 promulgating the Law on Investment of Kingdom of Cambodia
- Seen the Royal Kram NS/RKM/1222/012 dated 10 of December 2022 promulgating the Law on Finance for Management of the Year 2023

THE ROYAL GOVERNMENT

Delegates herewith to **H.E. Dr. AUN PORNMONIROTH,** Deputy Prime Minister, Minister of Economy and Finance, full powers to sign the Implementation Agreement, Lease Agreement, and the Governmental Guarantee of Payments by the EDC/MME to Steung Meteuk Hydropower Co., Ltd. for the Development of 150 MW Stung Meteuk Hydroelectric Project in Koh Kong Province.

These powers include the powers of delegation.

In witness whereof the undersigned, the Prime Minister of the Kingdom of Cambodia with full powers duly entrusted to him, has signed this delegation of full powers.

Prime Minister

Samdech Akka Moha Sena Padei Techo HUN SEN

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៧៧៥

ព្រះរាជក្រម

ន.ស/រកម/១០២៣/ ០១៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សហានភូមិន្ទាធិសាសនា រក្ខតខត្តិយា ខេមរារដ្ឋារាស្ត្រ ពុទ្ធិន្ទ្រោធរោមហាក្សត្រ
ខេមរាជនា សម្ងហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេច លេខ ២២៦/០០៨/២០២៣ កបធ.ច ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ ហើយដែលមានអត្ថន័យទាំងស្រុងដូចតទៅ៖

ច្បាប់
ស្តីពី
ការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

មាត្រា១ .-

ត្រូវបានបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ចំណុះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា២ .-

រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែនមានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រងកិច្ចការព្រំដែននៃព្រះរាជាណាចក្រកម្ពុជា ទាំងព្រំដែនគោកនិងព្រំដែនសមុទ្រ។

មាត្រា៣ .-

រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែនត្រូវដឹកនាំនិងគ្រប់គ្រងដោយរដ្ឋមន្ត្រីមួយរូប អមដោយរដ្ឋលេខាធិការនិងអនុរដ្ឋលេខាធិការមួយចំនួន តាមការចាំបាច់។

រដ្ឋលេខាធិការនិងអនុរដ្ឋលេខាធិការបំពេញភារកិច្ចតាមការប្រគល់ពីរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។

មាត្រា៤ .-

ក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួន រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែនទទួលខុសត្រូវចំពោះនាយករដ្ឋមន្ត្រីនិងចំពោះរដ្ឋសភា។

មាត្រា៥ .-

រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែនមានសិទ្ធិចេញប្រកាស សេចក្តីសម្រេច សារាចរ និងសេចក្តីណែនាំនានា ស្របតាមច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែនមានកញ្ចប់ថវិការបស់ខ្លួនដែលផ្គត់ផ្គង់ដោយថវិកាជាតិ និងមានមន្ត្រីរាជការក្របខ័ណ្ឌនិងមន្ត្រីជាប់កិច្ចសន្យា ដើម្បីដំណើរការការងាររបស់ខ្លួន ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៣៧៧

មាត្រា៦ .-

ការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែនត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៧ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

មាត្រា៨ .-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃព្រហស្សតី ៦កាន៩ខែ ភ្រមបទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៤ ខែ ក្កុលា ឆ្នាំ២០២៣

ពរលរ.៤កា១០.៤៤៤៦

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយកដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយកដ្ឋមន្ត្រីប្រចាំការ
ដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈដ្ឋមន្ត្រី

ម៉ឡ៊ វិសុត

ព្រះរាជក្រម

នស/រកម/១០២៣/ ០១៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សហនភូមិជាតិសាសនា អគ្គមហាឧត្តមាធិបតីយ៉ា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សម្ភូហោតាស អគ្គមហាឧកញ៉ាជ័យរាជ្ជបូរណាសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការបង្កើតក្រសួងអធិការកិច្ច ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ២២៥/០០៧/២០២៣ កបធ.ច ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ ហើយដែលមានសេចក្តីទាំងស្រុង

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ច្បាប់
ស្តីពី
ការបង្កើតក្រសួងអធិការកិច្ច

មាត្រា១ .-

ត្រូវបានបង្កើតក្រសួងអធិការកិច្ច ចំណុះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា២ .-

ក្រសួងអធិការកិច្ចមានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រងវិស័យអធិការកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា៣ .-

ក្រសួងអធិការកិច្ចត្រូវដឹកនាំនិងគ្រប់គ្រងដោយរដ្ឋមន្ត្រីមួយរូប អមដោយរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការមួយចំនួនតាមការចាំបាច់។

រដ្ឋលេខាធិការនិងអនុរដ្ឋលេខាធិការបំពេញការកិច្ចតាមការប្រគល់ពីរដ្ឋមន្ត្រី។

មាត្រា៤ .-

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអធិការកិច្ចត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៥ .-

ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យអធិការកិច្ចដែលនៅជាធរមាន ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានការកំណត់ជាថ្មី ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

មាត្រា៦ .-

លិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងការអនុវត្តច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

មាត្រា៧ .-

ការងារ និងចេនាសម្ព័ន្ធទាំងឡាយ ដោយរួមទាំងមន្ត្រីរាជការ បុគ្គលិក ចលនទ្រព្យ និងអចលនទ្រព្យ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ត្រូវធ្វើសមាហរណកម្មឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអធិការកិច្ច។

មាត្រា៨ .-

មន្ត្រីរាជការនិងបុគ្គលិក ដែលកំពុងបម្រើការងារនៅក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ត្រូវបន្តអនុវត្តតួនាទីនិងការកិច្ចរបស់ខ្លួន ស្របតាមលិខិតបទដ្ឋានគតិយុត្តដែលមានមុនពេលច្បាប់នេះចូលជាធរមាន រហូតដល់មានការរៀបចំចាត់ចែងនិងតែងតាំងជាថ្មី ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា៩ .-

ច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

មាត្រា១០ .-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៧ ខែ ភ្នំ ឆ្នាំ២០២៣

ន ស៊ីហមុនី

នរោត្តម សីហមុនី

ក.ស.ព.ជ.ប.ប.២៤៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកនិស្សារគណៈរដ្ឋមន្ត្រី

ង៉ែត ទិស្សុត

ព្រះរាជក្រម

នស/រកម/១១២៣/ ០៤០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សហនភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ

ខេមរាជនា សម្ងហោតាស អគ្គមជ្ឈឯករាជរដ្ឋបូរណាសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៤ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញតាមសេចក្តីសម្រេចលេខ២២៧/០០៩/២០២៣ កបធ.ច ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ ហើយដែលបានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ច្បាប់

ស្តីពី

ការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល

មាត្រា១ .–

ត្រូវបានបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ចំណុះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា២ .–

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល មានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រងវិស័យអាកាសចរណ៍ស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា៣ .–

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលត្រូវដឹកនាំនិងគ្រប់គ្រងដោយរដ្ឋមន្ត្រីមួយរូប អមដោយរដ្ឋលេខាធិការនិងអនុរដ្ឋលេខាធិការមួយចំនួន តាមការចាំបាច់។

រដ្ឋលេខាធិការនិងអនុរដ្ឋលេខាធិការបំពេញការកិច្ចតាមការប្រគល់ពីរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

មាត្រា៤ .–

ក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួន រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ទទួលខុសត្រូវចំពោះនាយករដ្ឋមន្ត្រីនិងចំពោះរដ្ឋសភា។

មាត្រា៥ .–

រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលមានសិទ្ធិចេញប្រកាស សេចក្តីសម្រេច សារាចរ និងសេចក្តីណែនាំនានា ស្របតាមច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រះរាជក្រម ឆ្នាំ២០២៣ ទំព័រ ៧៨៣

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលមានកញ្ចប់ថវិការបស់ខ្លួនដែលផ្គត់ផ្គង់ដោយថវិកាជាតិ និងមានមន្ត្រីរាជការក្របខ័ណ្ឌនិងមន្ត្រីជាប់កិច្ចសន្យា ដើម្បីដំណើរការការងាររបស់ខ្លួន ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា៦ .–

ការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៧ .–

ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យអាកាសចរណ៍ស៊ីវិលដែលនៅជាធរមាន ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានការកំណត់ជាថ្មី ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

មាត្រា៨ .–

លិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងការអនុវត្តច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលដែលមានមុនពេលច្បាប់នេះចូលជាធរមាន ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

មាត្រា៩ .–

មន្ត្រីរាជការនិងបុគ្គលិកដែលកំពុងបម្រើការងារនៅរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវបន្តអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួនស្របតាមលិខិតបទដ្ឋានគតិយុត្តដែលមានមុនពេលច្បាប់នេះចូលជាធរមានរហូតដល់មានការរៀបចំចាត់ចែងនិងតែងតាំងជាថ្មី ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា១០ .–

ច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

មាត្រា១១ .–

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃព្រហស្បតិ៍ ៤រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០២៣

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមទ្រង់ព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ង៉ែត ទីសុត

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី